អៀង មូលី

ជីវិតលើផ្លូវបត់បែនទៅរកសន្តិភាព

រូបភាពនៅក្របខាងក្រៅ៖

ផ្នែកខាងលើ រូបថតអ្នកនិពន្ធ ថតនៅប្រទេសបារាំង ក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ ។
ផ្នែកខាងក្រោម រូបថតនៃអង្គប្រជុំមួយរបស់ក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជា ឬ អេស អិន ស៊ី (SNC) នៅក្នុងព្រះរាជដំណាក់ច័ន្ទ នាព្រះបរមរាជវាំង ក្រោមព្រះរាជាធិបតីភាពនៃសម្តេចព្រះ នរោត្តម សីហនុ ប្រធាន អេស អិន ស៊ី នៅឆ្នាំ ១៩៩២ (រូបនៅជួរមុខរាប់ពីឆ្វេងទៅស្តាំ ឯកឧត្តម ខៀវ សំផន, ឯកឧត្តម អ៊ឹម ឈុនលឹម, អ្នកនិពន្ធ (អៀង មូលី), សម្តេចតេជោ ហ៊ុន សែន, ឯកឧត្តម ឱិត មន្នី និង សម្តេចព្រះ នរោត្តម សីហនុ) ។

ជីវិតលើផ្លូវបត់បែនទៅរកសន្តិភាព

អៀង មូលី

ជីវិតលើផ្លូវបត់បែនទៅរកសន្តិភាព

ការផ្សាយរបស់អ្នកនិពន្ធ

ភ្នំពេញ

២០១៣

រក្សាសិទ្ធិគ្រប់យ៉ាង© មីនា ២០១៣ ដោយ អៀង មូលី

បោះពុម្ពនៅក្នុងព្រះរាជាណាចក្រកម្ពុជា

ឯកសារបន្ថែមអាចមើលបាននៅលើគេហ៍ទំព័រ

www.iengmouly.net

សូមឧទ្ទិសសៀវភៅនេះជូន
លោកឪពុក និង អ្នកម្តាយរបស់ខ្ញុំ
ដែលបានលាចាកលោកយើងនេះទៅហើយ
ដើម្បីទុកជាការរំលឹកដល់គុណរបស់
លោកទាំងពីរ ។

មាតិកា

	ទំព័រ
សេចក្តីថ្លែងអំណរគុណ	xvii
បុព្វកថា ដោយលោកបណ្ឌិតសភាចារ្យ ស៊ិន សំណាង	xviii
អារម្ភកថា	xxi
ពាក្យសរសេរកាត់	xxix
វគ្គ១ ភូមិកំណើតខ្ញុំ (ទសវត្សរ៍ឆ្នាំ ១៩៥០-១៩៦០)	០១
ការធ្វើដំណើរពីភូមិខ្ញុំទៅកាន់ទីក្រុង	០២
ជីវភាពប្រចាំថ្ងៃរបស់ប្រជាជន	០៥
អ្នកស្រែខ្មែរ និង ពាណិជ្ជករចិន	០៨
ភាពសុខដុមរមនាខាងជាតិសាសន៍ និង សាសនា	១១
ភាពស៊ីវិល័យនៃអ្នកភូមិស្នាយពលក្រោម	១២
វង្សត្រកូលខ្ញុំ	១៦
ការឆ្លងទន្លេនៅភូមិស្នាយពល	២៣
កុមារភាព បងប្អូន និង កិច្ចការរបស់ឪពុកខ្ញុំ	២៥
ថ្ងៃចូលរៀនលើកដំបូង និង តម្លៃគ្រូ	២៩
សកម្មភាពក្រៅថ្នាក់រៀន	៣២
ការគិតគូរអំពីបញ្ហាស្រុកទេស	៣៦
ខ្ញុំចូលចិត្តកសាងកុសល	៣៩
ខ្ញុំចូលចិត្តអានសៀវភៅ	៤០
ចង់ស្គាល់ភ្នំពេញខានបានលេខ១	៤២
លាភូមិស្នាយពល	៤៤

វគ្គទី២ ការសិក្សា និងជីវភាពនៅទីក្រុង (ទសវត្សរ៍ឆ្នាំ ១៩៦០-៧០) ៤៦
ផ្ទះឈើប្រក់សង្កសីនៅផ្សារដើមគ ៤៦
ជីវភាពប្រចាំថ្ងៃ ៤៨
បានចូលរៀនវិទ្យាល័យ ៥០
វិធីពង្រីកចំណេះខាងភាសាបារាំង ៥៣
បានចូលសិក្សានៅមហាវិទ្យាល័យពាណិជ្ជសាស្ត្រ ៥៤
គន់មើលសិស្សនារីវិទ្យាល័យដេកាត ៥៩
អាហារូបករណ៍ពីរាជរដ្ឋាភិបាល ៦០
ប្រឡងចេញយកសញ្ញាប័ត្រជាប់លេខ១ ៦២
ជីវិតក្នុងពិភពកម្មករ ៦៤
បានការធ្វើនៅក្នុងក្រុមហ៊ុនសុរាគារខ្មែរ ៦៧
ខ្ញុំចេះតែចង់រៀនបន្ត ៦៨
ខ្ញុំចេះតែចង់រៀនបន្តនៅប្រទេសបារាំង ៦៩
ខ្ញុំចង់ធ្វើជាគណនេយ្យករឯករាជ្យ ៧០
ស្ថានការណ៍ប្រែប្រួល ៧៤
រៀបការបងប្រុសទី១ ៧៩
ចូលធ្វើការក្នុងក្រុមហ៊ុនឯកជន ៨០
និយាយគ្នាតាមវចនានុក្រម ៨៤
មន្ត្រីពន្ធដារសួថា «រៀបចំរួចស្រេចហើយឬនៅ?» ៨៥
មានគណនីនៅក្រេឌីលីយ៉ោណេ ៨៧
ក្រុមហ៊ុនកូមិនខ្មែរជាក្រុមហ៊ុនចុងក្រោយ ៨៨
កូដកម្មដោយឥតប្រាប់មុន ៩១
ទីបំផុតខ្ញុំសម្រេចចេញទៅស្រុកបារាំង ៩៣
រៀបការបងប្រុសទី២ ៩៥
ថ្ងៃចុងក្រោយនៅកម្ពុជា ៩៧

វគ្គទី៣ ប្រទេសកម្ពុជាក្នុងភ្លើងសង្គ្រាម (ទសវត្សរ៍ឆ្នាំ ១៩៧០) ៩៩
ព្រឹត្តិការណ៍ ១៨ មីនា ១៩៧០ ១០១
គេថា ធ្វើតាមរដ្ឋធម្មនុញ្ញ ១០៧
រដ្ឋាភិបាល លន់ នល់ កំចាត់វៀតណាមកុម្មុយនីស្ត ១០៩
សម្តេច សីហនុ មានប្រតិកម្មតបវិញ ១១២
លន់ នល់ ជានរណា? ១១៤
សិរិមត: និង ជម្លោះក្នុងរាជវង្ស? ១១៧
សម្តេច សីហនុ លែងទុកចិត្តអាមេរិក ១២៤
ខ្មែរក្រហម និង ពួកបញ្ញវន្ត ១២៨
ខ្ញុំធ្វើកុម្ម៉ង់ដូ ១៣២
អ្នកណាក៏អាចទិញសក្តិពាក់បានដែរ សម័យ លន់ នល់ ១៣៤
សម្ព័ន្ធភាព លន់ នល់ បែកគ្នាជាបក្សផ្សេងៗ ១៣៥
រដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ និង គណបក្សប្រជាធិបតេយ្យ ១៣៧
បោះឆ្នោតក្នុងរបបសាធារណរដ្ឋ ១៤៤
សម្ព័ន្ធភាព លន់ នល់ សាកល្បងរួបរួមគ្នាវិញ ១៤៥
ក្រុមប្រជាធិបតេយ្យចង់ធ្វើជាស្ពានឈានទៅបញ្ចប់សង្គ្រាម ១៤៦
ការចុះទន់ខ្សោយនៃរបប លន់ នល់ ១៤៩
ខ្មែរក្រហមប្រើល្បិចដើម្បីឈ្នះសង្គ្រាម ១៥១
មហានិនាសកម្មត្រូវចងចាំជាមេរៀនប្រវត្តិសាស្ត្រ ១៥៣

វគ្គទី៤ ជីវិតនៅទីក្រុងប៉ារីស (ទសវត្សរ៍ឆ្នាំ ១៩៨០) ១៥៧
ដំណើរគ្រាដំបូងតាមយន្តហោះ ១៥៧
ជីវិតផ្សងព្រេងនៅទីក្រុងប៉ារីស ១៦១
ជាដំបូងខ្ញុំខំរកការធ្វើ ១៧១
អ្នកប្រុសតូច ១៧៦

បារាំងថាខ្ញុំធ្វើការខុសច្បាប់ ១៧៩
សុំសិទ្ធិជ្រកកោននយោបាយ ១៨២
ជីវិតថ្មីជាអ្នកទីក្រុងប៉ារីស ១៨៥
សប្បាយលាយទឹកភ្នែកនៅថ្ងៃ ១៧ មេសា ១៩៧៥ ១៩០
មិនចូលបដិវត្តន៍ព្រោះជាប់កំអែលមូលធននិយម ១៩៤
ស្ថានភាពជនភៀសខ្លួនខ្មែរនៅទីក្រុងប៉ារីស ១៩៥
ឡើងហាន:ដោយមិនដឹងខ្លួន ១៩៨
ចែកឲ្យដាច់មនោសញ្ចេតនា និង ការងារ ២១០
វិលមកជួបសហគមន៍ខ្មែរវិញ ២១៥

វគ្គទី៥ សម្រែកស្រែករកសេរីភាព (ទសវត្សរ៍ឆ្នាំ ១៩៨០) ២១៨
ជាតិជាជនភៀសខ្លួន គ្មានអ្នកតូច គ្មានអ្នកធំ ២១៩
សឺន សាន ជានរណា? ២២១
សមាគមទូទៅខ្មែរនៅបរទេស ២២៤
ខ្មែរក្រហមប្រមូលយកជ័យជំនះ ១៧ មេសា តែម្នាក់ឯង ២២៥
សម្តេច សីហនុ យាងទៅទីក្រុងញូយ៉ក ២២៦
ព្រះអង្គសុំលាលែងពីតំណែងប្រមុខរដ្ឋនៃរបបខ្មែរក្រហម ២២៧
សកម្មភាពរបស់សមាគម អា ហ្សេ កា អឺ ២២៨
ជំនួបជាមួយលោកតា សឺន សាន ២៣០
ខំធ្វើការដើម្បីសហគមន៍ខ្មែរ ២៣៣
ចលនាតស៊ូខ្មែរសេរីកា ២៣៥
ឃ្លាតកាយ ណាយចិត្ត ២៣៩
ខ្មែរក្រហមមានជម្លោះជាមួយប្រទេសជិតខាង ២៤០
យុទ្ធសាស្ត្រចិន នាំឲ្យថៃ និង ខ្មែរក្រហមផ្តាកជម្លោះ ២៤៣
នរណាជាដៃទី៣? ២៤៧

ទាហានថៃជួយយុទ្ធជនសេរីកា ២៥២
ជម្លោះរវាងខ្មែរក្រហម និង វៀតណាម ២៥៨
ចលនាតស៊ូផ្ទៃក្នុងប្រឆាំង ប៉ុល ពត ២៦៥
ហ៊ុន សែន ចេញប្រឆាំង ប៉ុល ពត ២៦៦
ខ្មែរក្រហមផ្តាច់ទំនាក់ទំនងការទូត ២៧៣
រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ២៧៥
ប៉ុល ពត ស្នើសុំឲ្យសម្តេច សីហនុ ជួយ ២៧៧
ភាពគឃ្លើនរបស់ខ្មែរក្រហមចំពោះព្រះអង្គ ២៨២
បានពួក អេហ្វ ប៊ី អាយ ជួយរំដោះព្រះអង្គ ២៨៤
ទីបំផុតព្រះអង្គព្រមយាងត្រឡប់ទៅស្រុកចិនវិញ ២៨៥
អរផង ក័យផង ចំពោះជ័យជំនះ ៧ មករា ២៨៦
អបអរសាទរព្រះអង្គ ដែលនៅគង់ព្រះជន្មនៅឡើយ ២៨៨
នយោបាយជាន់ខ្ពស់របស់លោកតា សឺន សាន ២៨៩
លោកតា សឺន សាន និង សម្តេច សីហនុ តាមមាគ៌ាទីទៃៗ ២៩៣
លោកតាប្រកាសបង្កើតរណសិរ្ស ៣០១
ខ្ញុំជាសកម្មជន រ.ជ.រ.ប.ខ. ៣០៧
ព្រះអង្គទាមទារចរចាផ្ទាល់ជាមួយវៀតណាម ៣១០
សម្តេច សីហនុ យាងមកដល់ទីក្រុងប៉ារីស ៣១២
បានទទួលដំណឹងពីម្តាយខ្ញុំ ៣១៣
ជាតុពិត នៃជ័យជំនះ ៧ មករា ៣១៥

វគ្គទី៦ ចេញទៅធ្វើសង្គ្រាម (ទសវត្សរ៍ឆ្នាំ ១៩៨០) ៣១៨
ចិន និង អាស៊ាន ត្រៀមកម្លាំងវាយបក ៣១៨
មេដឹកនាំអ្នកជាតិនិយមប៉ះទង្គិចពាក្យសំដីគ្នា ៣២១
ខ្មែរក្រហមខំកែមុខមាត់ថ្មី ៣២៣

រត់ការឲ្យបងថ្លៃស្រីបានចេញពីដំរុំ	៣២៤
បាតុកម្មប្រឆាំង ៧ មករា នៅទីក្រុងប៉ារីស	៣២៨
ពួកយើងនៅទីក្រុងប៉ារីស	៣៣១
លោកតាថ្លែងថា សត្រូវនៃសត្រូវ គឺជាមិត្ត	៣៣៤
ស្ថាប័ន និង សមាជ នៃ រ.ជ.រ.ប.ខ.	៣៣៦
សម្តេច សីហនុ លាឈប់ពីតំណែងប្រធានសហព័ន្ធខ្មែរ	៣៤៤
ពេលនោះ លោកតាដើរតួឯក	៣៤៧
ជំរុំ រ.ជ.រ.ប.ខ. រងការវាយប្រហារ	៣៥០
ពួកបរទេសថា លោកតាក្បាលរឹង	៣៥២
ក្រុមកូមុិច ជ្រើសរើសសមាជិកថ្មី	៣៥៤
ការិយាល័យផ្សាយព័ត៌មាន រ.ជ.រ.ប.ខ. នៅក្រៅប្រទេស	៣៥៥
សម្តេច សីហនុ ត្រៀមចូលរួមជាថ្មីជាមួយខ្មែរក្រហម	៣៥៧
មូលហេតុមិនចូលគ្នានៃក្រុម សឺន សាន និង សីហនុ	៣៥៩
លោកតាមិនអាចបង្រួបបង្រួមអ្នកជាតិនិយម	៣៦៥
លោកតាថ្លែងថា ដើម្បីបត់ស្តាំ ត្រូវសៀរឆ្វេងបន្តិច	៣៦៧
ចូលទ្រុងខ្លា លោកតាសុំដំបងមួយ	៣៦៩
លោកតាប្រកាសថា ខ្ញុំស្មគ្រចិត្តចេញទៅតស៊ូ	៣៧០
ក្រុមកូមុិច បង្កើតបញ្ជាចំរុងចំរាស់ថ្មី	៣៧២
សន្និសីទអន្តរជាតិមួយស្តីពីកម្ពុជា	៣៧៦
ជំនួប សឺន សាន - សីហនុ	៣៧៨
ជំនួប សឺន សាន - សីហនុ - ខៀវ សំផន នៅ សឺង្ហបុរី	៣៨០
តស៊ូមតិគ្នាក្នុងគណៈកម្មការចំពោះកិច្ច	៣៨២
បើលោកតាមិនធ្វើ ព្រះអង្គក៏មិនធ្វើ	៣៨៨
ខ្មែរក្រហមទទួលការគាំទ្រពីសម្តេច សីហនុ	៣៩០
ខ្ញុំជូនលោកតាទៅជួបទូតអាមេរិកជាលើកដំបូង	៣៩១

ខ្ញុំ និង បង ប៉ែន ថាល់ ចេញទៅសមរភូមិ ៣៩៣
បង ប៉ែន ថាល់ ថា៖ កុំឲ្យបាត់បង់សេចក្តីថ្លៃថ្នូរ ៣៩៧
ខកចិត្ត ពេលជាន់ទឹកដីថៃ ថ្ងៃដំបូង ៣៩៨

វគ្គទី៧ លោកអគ្គលេខា (ទសវត្សរ៍ឆ្នាំ ១៩៨០-១៩៩០) ៤០៩
ពួកជក់ខ្សៀ និង មនុស្សជាភ្នែក ជាត្រចៀករបស់លោកតា ៤១០
អ្វីដែលហៅថា «ទៅគោរពទង់ជាតិ» ៤១២
ចលនាតស៊ូខ្មែរ ក្រោមការគ្រប់គ្រងរបស់យោធាថៃ ៤១៤
រដ្ឋាភិបាលចម្រុះត្រីភាគីកើតក្រោមគំនាបយោធាថៃ ៤១៦
លោកតាឲ្យខ្ញុំរៀបចំប្រព័ន្ធគណនេយ្យ ៤២៤
ខ្ញុំថា៖ ការចូលរួមក្នុងត្រីភាគី មិនមែនជាជោគជ័យទេ ៤២៧
សមាសភាពរដ្ឋាភិបាលត្រីភាគី ដែលថៃទទួលស្គាល់មុនគេ ៤២៨
ខ្ញុំ និង បង ប៉ែន ថាល់ ទៅបំពេញបេសកកម្មនៅអាហ្វ្រិក ៤៣០
ផ្លាស់ហាន:ពីជនភៀសខ្លួន ទៅជាអ្នកការទូត ៤៣៥
បង ប៉ែន ថាល់ ដួលសន្លប់ តែគាត់ថា អត់ឈឺអ្វីទេ? ៤៣៧
យុវជនជាតិតូហ្គោ ៤៣៩
តាលួត ត្រូវគេលួចបាញ់សម្លាប់នៅជំរុំអំពិល ៤៤២
បង្កើតគណកម្មាធិការជំនួសលោក ជៀន ដែល ៤៤៤
ការបែកបាក់គ្នាលើកទីមួយ ក្នុងជួរ រ.ជ.រ.ប.ខ. ៤៤៦
នគរបាលថៃ លបចុះមកឆែកឆេរទីស្នាក់ការរបស់យើង ៤៤៩
យើងរើមកនៅម៉ាយ៉ោឡាប់ ៤៥០
ខ្ញុំចូលធ្វើការក្នុងកងទ័ព ៤៥១
ក្រុមមេទ័ពថ្មី ខំបញ្ចេញថ្វីដៃ ៤៥៤
ទ័ពយើងខ្លាំង ឬ ខ្សោយ អាស្រ័យលើលោក ឆាវលិត ៤៥៨
លោក សក់ ស៊ុតសាខន និង ក្រុមលោក ជៀន ដែល ៤៦០

វៀតណាមវាយបកវិញ	៤៦១
អនុប្រធានថ្មី រ.ជ.រ.ប.ខ.	៤៦៦
អ្នកស្រី សួន កាសេត បានត្រូវអញ្ជើញឲ្យចេញពីទឹកដីថៃ	៤៦៧
លោក ថាច់ រ៉េង រត់តាម អ្នកស្រី សួន កាសេត	៤៦៨
មហាសន្និបាត រ.ជ.រ.ប.ខ.	៤៧០
ខ្ញុំត្រឡប់មកបាងកកវិញ ដើម្បីធ្វើកាកបាតក្រហម	៤៧២
សម្តេច ប៉ែន នុត ប្រដៅឲ្យពួកយើងរួបរួមគ្នា	៤៧២
យន្តការរួម រ.ជ.រ.ប.ខ. និង ហ៊ុនស៊ិនប៊ិច	៤៧៥
ពែកមីកូ និង ម៉ាយ៉ាឡាប់	៤៧៦
ទស្សនកិច្ចនៅកូរ៉េខាងត្បូង	៤៧៨
លោក ជៀន ដែល បញ្ជាឲ្យបោះបង់ជំរុំអំពិល	៤៨០
ការងារដ៏សំខាន់នៅកាកបាតក្រហម	៤៨១
ពួកទាហានទាមទារឯករាជ្យពីលោកតា សឺន សាន	៤៨៣
ក្រុម សឺន សាន និង សក់ ស៊ុតសាខន តម្លើងសំឡេងជាក់គ្នា	៤៨៥
ពួកតាៗនៅប៉ារីស គាំទ្រលោក សក់ ស៊ុតសាខន	៤៨៦
ស្ងាត់ៗលោក ថាច់ រ៉េង ត្រឡប់មកបាងកកវិញ	៤៨៨
ការបែកបាក់លើកទី២ ក្នុងជួរ រ.ជ.រ.ប.ខ.	៤៩០
បង ប៉ែន ថាល់ ទទួលមរណភាពនៅប៉េកាំង	៤៩២
បក្សប្រហារ ដែលយើងនឹកមិនដល់	៤៩៤
ក្រុមលោក សក់ ស៊ុតសាខន ឈប់ទទួលស្គាល់លោកតាជាប្រធាន	៤៩៩
ខ្ញុំលួចចេញទៅអារញ្ញទាំងកណ្តាលអង្រាត្រ	៥០០
ទាហានថៃតាមរកខ្ញុំ	៥០២
នាយទាហានថៃកាន់កាប់ទ័ពយើងដោយផ្ទាល់	៥០៣
គេប្រើល្បិចកុំឲ្យខ្ញុំជួបលោក សូឡា	៥០៥
លោកតា សឺន សាន អាចទៅធ្វើទស្សនកិច្ចនៅសាយធូ	៥០៧

ក្រុម សក់ ស៊ុតសាខន ចង់ឲ្យលោកតាធ្វើប្រធានកិត្តិយស ៥០៩
លោក សក់ ស៊ុត សាខន សុំរៀបចំកូម៉ិចជាថ្មី ៥១២
រ.ជ.រ.ប.ខ. ធ្លាក់កាន់តែជ្រៅទៅក្នុងជ្រោះនៃវិបត្តិផ្ទៃក្នុង ៥១៤
លោកតាទៅតវ៉ាឯប៉េកាំង តែចិនឲ្យសម្រុះសម្រួល ៥១៦
មានគេសរសេរខុសពីរឿងវិបត្តិផ្ទៃក្នុង រ.ជ.រ.ប.ខ. ៥២១
លោកតា សឺន សាន ចង់ដកលោក នាង ជិន ហាន ៥២៣
មេទ័ពថៃបញ្ជាឲ្យលោក ថាច់ រ៉ង ចេញពីទឹកដីថៃ ៥២៥
វិបត្តិផ្ទៃក្នុងបានត្រូវបញ្ចប់ ៥២៦
យើងមានអ្នកគាំទ្រ និង អ្នករត់ចោលជួរ ៥២៩
ទីបំផុតគេហៅខ្ញុំថា៖ លោកអគ្គលេខា ៥៣១

វគ្គទី៨ ជំរុំជាយដែន (ទសវត្សរ៍ឆ្នាំ ១៩៨០-១៩៩០) ៥៣៧
ជំរុំនៅលើទឹកដីខ្មែរ ៥៣៨
ខ្ញុំរៀនវិជ្ជាត្រៃវេទ ៥៤២
ខ្ញុំចង់សាកល្បងវិជ្ជាត្រៃវេទ ៥៤៧
អាងវិជ្ជាត្រៃវេទ នាំគ្នាទៅគាស់កំណប់ ៥៤៨
នៅជំរុំសាយធូ ៥៥១
ការងារផ្នែកសិទ្ធិមនុស្ស ៥៥៤
គណៈកម្មការយុត្តិធម៌ ៥៥៧
មានបញ្ញវន្តចូលមកជួយ ៥៥៨
ពួកយើងរកវិធីពង្រីកការអប់រំនៅក្នុងជំរុំ ៥៥៩
សកម្មជនប្រមូលកម្លាំងជាតិ ៥៦៤
លិខិតប្រចាំសប្តាហ៍របស់អគ្គលេខាធិការ ៥៦៥
ប្រធានជំរុំ និង មេទ័ព ៥៦៧
យកបាយកញ្ចប់ទៅចែកខ្មែរគ្នាឯង ត្រូវយូអិនស្តីបន្ទោស ៥៦៨

ដំណើរទៅតំបន់រំដោះ ៥៧០
ប្រាសាទបន្ទាយឆ្មារ អាចរងគ្រោះដោយជនទុច្ចរិត ៥៧៣
នៅតំបន់រំដោះ ខ្ញុំប្រាប់អ្នកស្រុកឲ្យចាំមើលទង់ជាតិយើង ៥៧៦

វគ្គទី៩ ដំណើរតាមផ្លូវបត់បែនទៅរកសន្តិភាព (ទសវត្សរ៍ឆ្នាំ ១៩៨០-១៩៩០) ៥៨០
ទិដ្ឋភាពពីរនៃបញ្ហាកម្ពុជាពិតជាត្រឹមត្រូវ ៥៨១
រ.ជ.រ.ប.ខ. ប្រកាន់គោលជំហរដូចខ្មែរក្រហម ៥៨៤
ក្រុមលោកតា សឺន សាន រិះគន់សម្តេច សីហនុ ៥៨៦
សហគមន៍អន្តរជាតិទទួលយកសីលធម៌សកលថ្មី ៥៨៨
ភាគនីមួយៗ និង គោលជំហរក្នុងការធ្វើសង្គ្រាម ៥៩០
សេអូសេស្កូ ណែនាំឲ្យ ខៀវ សំផន ជានាជាមួយ ហេង សំរិន ៥៩១
ហ៊ុន សែន ថា៖ «វាយផង ចរចាផង» ៥៩២
វៀតណាមមិនយកយូអិន តែសុខចិត្តចរចាជាមួយអាស៊ាន ៥៩៣
អាស៊ានឲ្យត្រីភាគីពង្រឹងឯកភាព និង សាមគ្គីភាព ៥៩៨
ផែនការសន្តិភាព ៨ ចំណុចរបស់ត្រីភាគី ៦០៦
រំលឹកឡើងវិញបន្តិចអំពី ចិន និង វិបត្តិផ្ទៃក្នុង រ.ជ.រ.ប.ខ. ៦០៧
ជំនួយជាចំហររបស់អាមេរិកលើកដំបូង ៦១២
ខ្ញុំប្រាប់មន្ត្រីអាមេរិកថា៖ «បើមិនជួយ ក៏យើងនៅតែតស៊ូ» ៦១៤
លោកតាបានស៊ីញ៉ៀលើក្រដាស តែលុយបានទៅអ្នកផ្សេង ៦១៥
អាមេរិកចង់ឲ្យមានទំនាក់ទំនងជាមួយវៀតណាម ៦១៨
នៅឡាហាវ៉ាន ហ៊ុន សែន - គាត ឈន់ លបទាក់ទងគ្នា ៦២១
វៀតណាមស្នើសម្តេចរៀបចំឲ្យមានការចរចាជាពីរដំណាក់កាល ៦២៤
សេអូសេស្កូ ទូលសម្តេចឲ្យខំរកដំណោះស្រាយនយោបាយ ៦២៧
លោកតាចង់សុំឲ្យតំបន់អង្គរអព្យាក្រឹត ៦២៩
ខ្ញុំទៅឃោសនាជាថ្មីនៅអឺរ៉ុប ៦៣៣

ពួកយើងមិនដឹងថា សម្តេចយាងទៅព្យុងយ៉ាង ដើម្បីធ្វើអ្វីទេ? ៦៣៤
ព្រះអង្គផ្តាកធ្វើប្រធានត្រីភាគី ព្រោះខ្មែរក្រហមរំលោភ ៦៣៦
ខ្មែរក្រហមភ័យខ្លាចបាត់អាសនៈ ៦៣៨
លោកតា សឺន សាន ទៅស្នាបស្នង់នៅរូម៉ានី ៦៤០
គំរោងជួបចរចាគ្នាតាមរូបភាពទីទៃៗ ៦៤២
មិត្តភាពរវាងលោក យ៉ាស្សែរ អារ៉ាហ្វាត់ និង សម្តេច សីហនុ ៦៤៤
ខ្មែរក្រហមរិះគន់សម្តេចថា ធ្លាក់ក្នុងអន្ទាក់របស់វៀតណាម ៦៤៥
ចិនថា មិនទាន់ដល់ពេលចរចាទេ ៦៤៧
បង្ហាញរូបភាពថា សាមគ្គី នៅពេលដែលបែកបាក់ ៦៥០
ទីបំផុតសម្តេចឪសុំឲ្យតាៗជួយឲ្យមានការជួបគ្នា ៦៥១
ជំនួប សីហនុ - ហ៊ុន សែន នៅ ហ្សឺរ អង់តាកជីន័រ ៦៥៤
សម្តេចសុំឲ្យប្តូរឈ្មោះ ភ្លេងជាតិ និង ទង់ជាតិនៃប្រទេសខ្មែរ ៦៥៨
លោកតាមិនចូលរួមប្រជុំ តែលបសុំជួប ហ៊ុន សែន ស្ងាត់ៗ ៦៦០
ជំនួបលើកទី២ នៅ សាំង ហ្សែកម៉ាំង អង់ ឡេយ ៦៦៧
សេចក្តីសន្និដ្ឋាន ៦៧២
ឯកសារគន្ថនិទ្ទេស ៦៧៩
ឯកសារឧបសម្ព័ន្ធ ៦៩៥

សេចក្តីថ្លែងអំណរគុណ

ដើម្បីឲ្យសៀវភៅនេះប្រសូត្រលេចចេញជារូបរាងឡើង ខ្ញុំបានពឹងពាក់សហការី មិត្តភក្តិ និង ញាតិមិត្រមួយចំនួនដូចខាងក្រោមនេះ៖

១) លោកបណ្ឌិតសភាចារ្យ ស៊ន សំណាង ដែលបានចំណាយពេលច្រើនជួយផ្ទៀងផ្ទាត់អក្ខរាវិរុទ្ធ ពាក្យពេចន៍ និង ផ្តល់មតិដ៏មានតម្លៃ អំពីរបៀបសរសេរ និង ការស្រាវជ្រាវឯកសារ ដើម្បីញុំាងឲ្យសៀវភៅនេះមានលក្ខណៈកាន់តែសុក្រឹតឡើង ។

២) លោក ស៊ន ពិសិដ្ឋ បេក្ខជនបណ្ឌិតប្រវត្តិសាស្ត្រនៃរាជបណ្ឌិតសភាកម្ពុជា ដែលបានជួយកែសម្រួលឲ្យការវាយអក្សរក្នុងកុំព្យូទ័រ អាចសមស្របតាមរបៀបយូនីកូដ និង ជួយត្រួតពិនិត្យការបោះពុម្ពផ្សាយ ។

៣) លោក ស៊ន ច័ន្ទវីរៈ ដែលបានជួយរចនារូបក្របសៀវភៅ និង ជួយដោះស្រាយរាល់បញ្ហាបច្ចេកទេសកុំព្យូទ័រ ។

៤) កញ្ញា អ៊ុក នីឡា ដែលបានជួយវាយអត្ថបទមួយភាគធំនៃសៀវភៅនេះ ។

សូមអស់លោក និង នាងកញ្ញាទទួលនូវអំណរគុណដ៏ស្មោះអំពីអ្នកនិពន្ធ ។

នៅទីបញ្ចប់ ខ្ញុំក៏សូមអរគុណ ភរិយា និង កូនរបស់ខ្ញុំទាំងពីរជាទីស្រឡាញ់ សេដ្ឋា, ធម្មៈ (Thomas), និង អែម៉ា (Emma), ដែលបានយោគយល់ដល់ខ្ញុំទុកពេលវេលាគ្រប់គ្រាន់ឲ្យខ្ញុំមានលទ្ធភាព ដើម្បីសរសេរ និង ធ្វើការស្រាវជ្រាវឯកសារចាំបាច់នានា រហូតបានសម្រេចចប់សព្វគ្រប់ជាស្តាពរ ។

បុព្វកថា

សៀវភៅដែលមានចំណងជើងថា «ជីវិតលើផ្លូវបត់បែនទៅរកសន្តិភាព» ជាស្នាដៃនិពន្ធរបស់វរជនខ្មែរមួយរូប ដែលបានខិតខំរៀបចំចងក្រងនូវកម្រងអនុស្សាវរីយ៍ តាំងពីកុមារភាព រហូតដល់ទសវត្សរ៍ឆ្នាំ ១៩៨០ ។ យុវជនជំនាន់ក្រោយ និង អ្នកដែលមិនបានចូលប្រឡូកដោយផ្ទាល់ នៅក្នុងឆាកនយោបាយជាតិ ក្នុងក្របខ័ណ្ឌនៃរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ (រ.ជ.រ.ប.ខ) គប្បីស្វែងយល់អំពីតម្លៃនៃស្នាដៃដ៏សំខាន់នេះ ។

ខ្លឹមសារនៃស្នាដៃនេះ ជាបឋម ផ្តោតលើជីវិតពិតរបស់អ្នកនិពន្ធផ្សារភ្ជាប់នឹងជីវភាពរស់នៅរបស់ក្រុមគ្រួសារ ដែលមានវាសនាបត់បែនទៅតាមវាសនានៃកម្ពុជា នាសម័យកោះសន្តិភាព (១៩៥៥-១៩៧០) និង សម័យព្យុះសង្ឃរានៃសង្គ្រាម និង បដិវត្តន៍បង្ហូរឈាម (១៩៧០-១៩៧៨) ដូចក្រុមគ្រួសារខ្មែរដទៃទៀតដែរ ។

បន្ថែមលើប្រវត្តិនៃក្រុមគ្រួសារលោកតាអៀង អ្នកនិពន្ធរួមចំណែកយ៉ាងសំខាន់ក្នុងការចែករំលែកនូវចំណេះដឹងជាក់ស្តែងអំពីសង្គមកម្ពុជា ដល់ជនានុជនជំនាន់ក្រោយ ដោយលោកជាសាក្សីម្នាក់នៃព្រឹត្តិការណ៍ជាតិ តាំងពីទសវត្សរ៍ឆ្នាំ ១៩៥០ នោះមក ។

ក្នុងខ្លឹមសារទី២នេះ លោកបានរំលឹកអំពីជីវភាពប្រចាំថ្ងៃរបស់អ្នកស្រែចម្ការដោយឆ្លុះបញ្ចាំងនូវមនោសញ្ចេតនាស្នេហាទឹកដី ភូមិកំណើត ដែលនៅសម័យនោះប្រជាពលរដ្ឋខ្មែរខំថែរក្សាប្រពៃណីជាតិ និង រស់នៅជាមួយគ្នាដោយសុខដុមរមនាក្នុងឯករាជ្យ និង សន្តិភាពក្រោយសង្គ្រាមឥណ្ឌូចិនលើកទី១ (១៩៤៦-១៩៥៤)។

អ្នកនិពន្ធបង្ហាញនូវការសោកស្តាយ ចំពោះការបាត់បង់ទៅនូវសន្តិភាព ក្រោយព្រឹត្តិការណ៍ ១៨ មីនា ១៩៧០ នៅក្រោមឥទ្ធិពលនៃសង្គ្រាមត្រជាក់ ដែលបង្កឡើងដោយសារមហិច្ឆិតានៃមហាអំណាចលោកសេរី និង កុម្មុយនីស្ត នៅដំណាក់កាលចុងក្រោយនៃសង្គ្រាមឥណ្ឌូចិនលើកទី២ (១៩៥៥-១៩៧៥) ។

ទន្ទឹមនឹងនេះ លោកក៏បានរំលឹកអំពីជីវិតសិក្សា ពីកម្រិតបឋមដល់កម្រិតឧត្តម ដោយបានបោះជំហានឈានឡើង ដោយជោគជ័យជាលំដាប់ ពីសាលារៀននៅស្រុកស្រែចម្ការ រហូតដល់គ្រឹះស្ថានមធ្យម និង ឧត្តមសិក្សា នៅរាជធានីភ្នំពេញ ។ ការសិក្សាផង និង ការចូលប្រឡូកក្នុងការងារដំណាលគ្នាផងនោះ នាំឲ្យលោកមានបទពិសោធន៍ក្នុងទំនាក់ទំនងសង្គម តាំងពីយុវវ័យ ទាំងនៅក្នុង ទាំងនៅក្រៅប្រទេស ។

ទេពកោសល្យនេះ ជួយជំរុញឲ្យលោកបានចេញទៅសិក្សានៅប្រទេសបារាំង នៅឆ្នាំ ១៩៧៣ ហើយជីវិតផ្សងព្រេង នៅលើទឹកដីថ្មី ក៏បានចាប់ផ្តើមឡើង ។ លោកបានរួចផុតពីភ្នក់ភ្លើងសង្គ្រាមក្នុងប្រទេសមែន ប៉ុន្តែជីវិតតែលតោលជាជនភៀសខ្លួន តម្រូវឲ្យមានការតស៊ូប្តូរផ្តាច់ រហូតដល់បានសម្រេចនូវជោគជ័យគួរជាទីពេញចិត្ត គឺមានការងារ និង ជីវភាពធូរធារ ។ «អ្នកប្រុសតូច» ជានាមថ្មីដែលសហការីផ្តល់ជូនលោកនោះ មានន័យគ្រប់គ្រាន់ សម្រាប់អះអាងអំពីជោគជ័យនៃការតស៊ូនៅឯប្រទេសបារាំង ។

ជោគជ័យតែម្នាក់ឯងបែបនោះ មិនអាចធ្វើឲ្យលោកស្ងប់ចិត្តបានឡើយ ។ ក្រោយពេលដួលរលំនៃរបបសាធារណរដ្ឋខ្មែរ នៅថ្ងៃ ១៧ មេសា ១៩៧៥ ដំណឹងអំពីអំពើឃោរឃៅនៃរបបប៉ុលពត បានធ្វើឲ្យលោកងាកមករកស្វែងយល់អំពីសភាពការណ៍ស្រុកទេសរបស់ខ្លួនឡើងវិញ ។ បន្ទាប់មកទៀត ដោយការដួលរលំនៃរបបប៉ុលពត នៅថ្ងៃទី ៧ មករា ១៩៧៩ មិនទាន់នាំមកនូវសន្តិភាព

ទាំងស្រុងដល់ប្រទេសកម្ពុជានៅឡើយនោះ លោកបានកំណត់នូវផ្លូវដែលត្រូវដើរ នៅក្នុងដំណាក់កាលថ្មី ។

លោកបានលះបង់សេចក្តីសុខផ្ទាល់ខ្លួន ដើម្បីចូលប្រឡូកក្នុងជួរឧត្តមសិរ្យ ជាតិរំដោះប្រជាពលរដ្ឋខ្មែរ (រ.ជ.រ.ប.ខ) នៅដើមទសវត្សរ៍ឆ្នាំ ១៩៨០ ។ គឺចាប់ពីពេលនោះហើយ ដែលជីវិតរបស់លោកស្ថិតនៅលើផ្លូវបត់បែនមករកសន្តិភាព ។ នេះជាខ្លឹមសារទី៣នៃស្នាដៃ ដែលលាតត្រដាងតាមរយៈសកម្មភាពរបស់លោកនៅក្នុង រ.ជ.រ.ប.ខ ។

នៅឆ្នាំ ១៩៧៩ សង្គ្រាមឥណ្ឌូចិនលើកទី៣បានផ្ទុះឡើង ហើយទឹកដីកម្ពុជាបានក្លាយជាសមរភូមិក្តៅ ។ បណ្តាមហាអំណាចលោកសេរី និង កុម្មុយនីស្តនៅប្រឈមមុខគ្នាយ៉ាងខ្លាំងក្លានៅឡើយ នៅដំណាក់កាលចុងក្រោយនៃសង្គ្រាមត្រជាក់ ។ ក្រៅពីពួកប៉ុលពតដែលមានបាតដៃជាប់ដិតជាមដោយស្នាមលោហិតនោះ កូនខ្មែរជាច្រើននៅក្នុងចលនាតស៊ូនានាពីគ្រប់ទិសទី បានរួមចំណែកក្នុងការស្ថាបនាសន្តិភាព សម្រាប់ជាតិមាតុភូមិរបស់ខ្លួនឡើងវិញ ។

លោក អៀង មូលី ដែលជាអ្នកនិពន្ធស្នាដៃនេះ ក៏បានលះបង់យុវវ័យដ៏ផូរផង់របស់លោកដោយអង់អាច និង ប្រកបដោយមនសិការជាតិ ដើម្បីរួមចំណែកក្នុងការស្ថាបនាសន្តិភាពឡើងវិញផងដែរ ។ សៀវភៅដែលមានចំណងជើងថា «ជីវិតលើផ្លូវបត់បែនទៅរកសន្តិភាព» ឆ្លុះបញ្ចាំងពិតប្រាកដនូវការតស៊ូប្រកបដោយការប្តេជ្ញាចិត្តកម្រិតខ្ពស់របស់អ្នកនិពន្ធ ដែលបានស្គាល់គ្រប់រសជាតិនៃជីវិត គឺការលំបាក ការងាយស្រួល បរាជ័យ និង ជោគជ័យ ដែលមានអត្ថន័យដ៏ជ្រាលជ្រៅសម្រាប់ជីវិតផ្ទាល់ខ្លួនផង និង សម្រាប់វាសនានៃជាតិមាតុភូមិផង ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ មីនា ២០១៣

បណ្ឌិតសភាចារ្យ ស៊ន សំណាង

អារម្ភកថា

ជាយូរមកហើយ ខ្ញុំតែងតែមានគំនិតចង់ឃើញខ្មែរយើងសរសេរអំពីរឿងរ៉ាវ
របស់ខ្មែរដោយជនជាតិខ្មែរខ្លួនឯង ព្រោះថាសៀវភៅអំពីខ្មែរភាគច្រើនៗតែត្រូវបាន
សរសេរដោយអ្នកនិពន្ធជនជាតិបរទេស ជាពិសេស អ្នកនិពន្ធនៃប្រទេសលោកខាង
លិច ។ ខ្ញុំនឹកដល់អ្នកចេះដឹង អ្នកមានបទពិសោធន៍ក្នុងឆាកជីវិតខាងផ្នែកវិជ្ជាជីវៈ
ខាងផ្នែកសិល្បៈ ឬ ខាងផ្នែកនយោបាយដែលប្រាកដជាមានប្រធានបទយ៉ាងច្រើន
ទាក់ទងនិងជីវិតរបស់គេម្នាក់ៗ ។ ប្រសិនបើគេសរសេរ បោះពុម្ព និង ផ្សព្វផ្សាយ
នូវបទពិសោធន៍ ឬ រឿងរ៉ាវទាំងឡាយដែលអ្នកទាំងនោះបានជួបប្រទះ នោះអនុ
ជនជំនាន់ក្រោយអាចយកទៅពិចារណា ឬ រៀនសូត្រទុកជាមេរៀនបាន ។

ចំពោះរូបខ្ញុំដំបូងឡើង ខ្ញុំសរសេរសៀវភៅនេះ ជារបៀបជីវប្រវត្តិសម្រាប់
ទុកឲ្យកូនចៅខ្ញុំយល់ដឹងពីទឹកដី ភូមិកំណើត និង ខ្សែស្រឡាយនៃត្រកូល អៀង
តែប៉ុណ្ណោះ ។ ក៏ប៉ុន្តែ ដោយសារខ្ញុំបានឆ្លងកាត់ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រជាងប្រាំ
មួយទសវត្សរ៍មកនោះ ជួនកាលក្នុងហាន:ជាពលរដ្ឋសាមញ្ញធម្មតា ដែលទទួលរង
នូវផលប៉ះពាល់ ជួនកាលជាអ្នកសង្កេតការណ៍ និង ជួនកាលមួយផ្នែកតូចក្នុងហាន:
ជាតួអង្គមួយ ឬ ជាសាក្សីរស់ម្នាក់ ខ្ញុំក៏មានគំនិតបើកទូលាយឲ្យសាធារណជន
យល់ដឹងផងនូវហេតុការណ៍ទាំងនោះ ។ សៀវភៅនេះ ក៏ក្លាយទៅជាសំណេរអំពី
បញ្ហាសង្គម សេដ្ឋកិច្ច និង នយោបាយនៃប្រទេសកម្ពុជាយើង តាមការចងចាំ ឬ
តាមការយល់ដឹងផ្ទាល់ និង តាមឯកសារស្រាវជ្រាវបន្ថែម ។ ទាំងនេះក៏ដោយសារ
ខ្ញុំយល់ថាសៀវភៅអំពីខ្មែរ សរសេរដោយខ្មែរនៅមិនទាន់សម្បូណ៌បែបនៅឡើយ ។

បូកផ្សំជាមួយរឿងរ៉ាវផ្ទាល់របស់ខ្ញុំ សៀវភៅនេះមួយផ្នែកជារឿងដំណាល

អំពីប្រវត្តិសាស្ត្រ ឬ អំពីព្រឹត្តិការណ៍សង្គមជាតិពីជំនាន់មួយ ទៅជំនាន់មួយ ជាពិសេសព្រឹត្តិការណ៍ ដែលកើតមាននៅទសវត្សរ៍ចុងក្រោយៗនេះ ។ កុមារភាពរបស់ខ្ញុំចាប់ផ្តើមនៅក្នុងសង្គមខ្មែរមួយ ដែលកាន់ព្រះពុទ្ធសាសនា ប្រកាន់ទំនៀមទម្លាប់ គោរពរាជានិយម និង នៅក្នុងបរិបទនយោបាយមួយដែលកំពុងឈានចេញពីសម័យអសន្តិសុខឆ្ពោះទៅរកសម័យឯករាជ្យជាតិ ។ ក្នុងមួយរយៈ នៅសម័យប្រទេសជាតិស្ថិតនៅក្នុងសន្តិភាព រូបខ្ញុំក៏ដូចជាក្មេងៗខ្មែរឯទៀត បានចំរើនដឹងក្តីឡើងដោយមិនដែលនឹកថា ថ្ងៃណាមួយខាងមុខប្រជាជាតិនឹងជួបនូវក្តីមហន្តរាយសោះឡើយ ។ នៅសម័យសន្តិភាពនោះ ប្រជារាស្ត្រខ្មែរភាគច្រើន មានជំនឿជឿជាក់លើការដឹកនាំរបស់សម្តេចព្រះ នរោត្តម សីហនុ ដែលអ្នកស្រុកជាទូទៅហៅព្រះអង្គថាសម្តេចឪ និង ដែលគេនាំគ្នាគោរពទុកជាទីសក្ការៈខ្ពស់ស្មើរស្មើអង្គព្រះពុទ្ធ និង ព្រះអាទិទេពជាម្ចាស់ ។ ម្នាក់ៗជឿថារបបគ្រប់គ្រងរដ្ឋរបស់ព្រះអង្គនឹងនៅស្ថិតស្ថេរគង់វង្សជាអមតៈ គ្មានអ្វីអាចធ្វើឲ្យរង្គោះរង្គើ ឬ ដួលរលំបានឡើយ ។ ក៏ប៉ុន្តែ ព្រេងវាសនាប្រទេសជាតិមិនត្រូវបានចារដូចពួកយើងនឹកស្រមៃនោះទេ ។

ចាប់ពីខែ មីនា ១៩៧០ ភ្លើងសង្គ្រាមបានឆេះសន្ធោសន្ធៅនៅកម្ពុជារហូតនាំមកនូវរបបប្រល័យពូជសាសន៍ឯងមួយ(An Auto-Genocidal Regime) ដែលកម្រឃើញមាននៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិយើងនេះ ។ ប្រជាជាតិ និង ប្រជារាស្ត្រខ្មែរទាំងមូលទទួលរងនូវមហាវិនាសកម្ម ដែលពិបាករកពាក្យមកចែងឲ្យសម ឬ ឲ្យចំបានឡើយ ។ អ្នកនៅក្នុងប្រទេសទទួលរងនូវការកាប់សម្លាប់ ការបង្អត់អាហារ ការបង្ខំឲ្យធ្វើការជាទម្ងន់ ព្រមទាំងការនិរាសព្រាត់ប្រាសប្រពន្ធ ប្តី កូនចៅ បងប្អូន ញាតិមិត្រជាទីស្រឡាញ់ជាដើម ធ្វើឲ្យបាត់បង់អស់នូវសិទ្ធិ និង សេរីភាព ដែលជាសេចក្តីថ្លៃថ្នូររបស់មនុស្ស ។ អ្នកទ្រាំមិនបាន ក៏លបលួចរត់ចេញទៅក្រៅប្រទេស ។ អ្នកខ្លះក៏រើបំរះ ក្រោកឡើង បង្កើតជាចលនាតស៊ូប្រដាប់អាវុធប្រឆាំង

របប ប៉ុល ពត ។

ខ្សែជីវិតក្នុងយុវវ័យរបស់ខ្ញុំ ក៏អណ្តែតត្រសែតទៅតាមកម្លាំងបោកបក់នៃព្យុះភ្លើងសង្គ្រាម ។ នៅប្រទេសបារាំង បែកពីឪពុកម្តាយ និង ដោយឯកោម្នាក់ឯង ជីវិតជាជនភៀសខ្លួនរបស់ខ្ញុំ ដែលបានឆ្លងកាត់ឧបសគ្គមួយចំនួនរួចហើយនោះ មិនបានកាត់ផ្តាច់ឬសគល់ឈាមជ័រដាខ្មែររបស់ខ្ញុំបានឡើយ ។ ព្រឹត្តិការណ៍ទាំងឡាយនាទសវត្សរ៍ឆ្នាំ ១៩៧០ បាននាំឲ្យខ្ញុំចូលប្រឡូកក្នុងឆាកនយោបាយដែលចាប់ផ្តើមឡើងនៅក្រៅប្រទេស ។ ក្នុងការចូលរួមក្នុងជួរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ (រ.ជ.រ.ប.ខ) នៅដើមទសវត្សរ៍ឆ្នាំ ១៩៨០ គំនឹតចម្បងដំបូងនៃការតស៊ូរបស់ខ្ញុំនោះគឺធ្វើការប្រឆាំងរបប ប៉ុល ពត ដើម្បីរំដោះប្រជាពលរដ្ឋខ្មែរពីទាសភាព ។ ក៏ប៉ុន្តែដោយឈរជើងលើភូមិសាស្ត្រនយោបាយមួយដែលអនុគ្រោះដល់ខ្មែរក្រហម ប៉ុល ពត នោះ រណសិរ្សនេះមិនត្រឹមតែផ្តោកការតស៊ូប្រឆាំង ប៉ុល ពត ប៉ុណ្ណោះទេ ផ្ទុយទៅវិញ ថែមទាំងបានសហការជាមួយពួកប្រល័យពូជសាសន៍នេះនៅក្នុងរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យហៅថារដ្ឋាភិបាលត្រីភាគីទៀតផង ។ នោះគឺជាសម្ព័ន្ធភាពមួយ ដែលមានខ្មែរក្រហមជាកម្លាំងស្នូល ។ នេះជាសំណើចចំអកនៃព្រហ្មលិខិត។

នៅក្នុងបរិបទនៃភូមិសាស្ត្រនយោបាយនាសម័យនោះ មនុស្សភាគច្រើននៃសម្ព័ន្ធភាពត្រីភាគី សម្លឹងឃើញវត្តមានកងទ័ពវៀតណាមនៅកម្ពុជាថាជាការកាន់កាប់ទឹកដីខ្មែរដោយកងទ័ពនេះ ។ ដូច្នេះ វត្តមាននៃកងទ័ពវៀតណាមនៅកម្ពុជាក៏ក្លាយជាប្រធានបទនៃការឃោសនារបស់ពួកខ្មែរក្រហម ក្នុងការស្វែងរកការគាំទ្រពីក្នុង និង ពីក្រៅប្រទេស ។ តាមពិត ចាប់តាំងពីមានការបោះឆ្នោតសកលនៅឆ្នាំ ១៩៩៣ រហូតមក ពាក្យឃោសនាអំពីវៀតណាមត្រួតត្រាកម្ពុជា លែងមានន័យអ្វី

ទាំងអស់រួចទៅហើយ ។ ក៏ប៉ុន្តែ ប្រធានបទបែបនេះក៏នៅត្រូវបានអ្នកលេងល្បែង នយោបាយយកមកប្រើតទៅទៀតរហូតទល់សព្វថ្ងៃ ដើម្បីដណ្តើមប្រៀបខាងផ្នែក នយោយបាយ ។

សៀវភៅនេះ រៀបរាប់អំពីប្រវត្តិនៃចលនាតស៊ូប្រឆាំងវៀតណាម ជាពិសេស អំពីរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ (រ.ជ.រ.ប.ខ) ដែលខ្ញុំធ្លាប់កាន់តំណែងជា អគ្គលេខាធិការ និង អំពីការកកើតនៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ព្រម ទាំងតួនាទីរបស់អ្នកដឹកនាំនៃរដ្ឋាភិបាលនេះ រួមទាំងតួនាទីដ៏សំខាន់របស់សម្តេច ព្រះ នរោត្តម សីហនុ ផង ។ តាមពិត សម្ព័ន្ធភាពត្រីភាគីជួយបន្តជីវិតនយោបាយ របស់ខ្មែរក្រហម ប៉ុល ពត បានមួយរយៈពេលទៀត ។ ជម្លោះផ្ទៃក្នុងនៅក្នុងជួរ.ជ. រ.ប.ខ.ដែលធ្វើឲ្យរណសិរ្ស សឺន សាននិយម ចុះអន់ថយ និង ទន់ខ្សោយជាលំដាប់ នោះត្រូវបានលើកមករៀបរាប់ ។ ជាមួយនោះ ក៏មានលើកឡើងអំពីការប្រណាំង ប្រជែងគ្នារវាងចលនាតស៊ូមិនមែនកុម្មុយនីស្ត និង អំពីឧត្តមភាពយោធាផ្តាច់មុខ របស់ខ្មែរក្រហមទៅលើដៃគូទាំងពីរក្នុងរដ្ឋាភិបាលចម្រុះត្រីភាគី ។ ការលើកឡើង ទាំងនោះបង្ហាញអំពីចំណុច ដែលនាំឲ្យសម្ព័ន្ធភាពត្រីភាគីមិនអាចទទួលជោគជ័យ និង ជាហេតុផលមួយជំរុញសម្តេចព្រះ នរោត្តម សីហនុ ឲ្យស្វែងរកវិធីជួបចរចា ផ្ទាល់ជាមួយមេដឹកនាំក្រុងភ្នំពេញ ។ គោលជំហរនេះផ្ទុយស្រឡះពីគោលជំហរ របស់ខ្មែរក្រហម និង ក្រុម សឺន សាននិយម ។

ដោយរបប ប៉ុល ពត ជាសត្រូវរួមរបស់ខ្មែរ ចលនាប្រឆាំង ប៉ុល ពត នៅ ក្នុងប្រទេសក៏បានផ្ទុះឡើងតាំងពីឆ្នាំ ១៩៧៧ ។ នៅក្នុងចលនាតស៊ូនោះ ប្រធាន កងវរសេនាធំមួយរូប ដែលកំពុងស្ថិតក្នុងយុវវ័យនៅឡើយនាសម័យនោះ បាន បង្ហាញនូវការប្តេជ្ញាចិត្តដ៏មោះមុត និង សេចក្តីក្លាហានដ៏រឹងមាំអស្ចារ្យក្រមាននៅ

ក្នុងប្រវត្តិសាស្ត្រកម្ពុជា រហូតដល់សម្រេចជោគជ័យផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត បានទាំងស្រុង ។ ដូច្នេះហើយបានជាសៀវភៅនេះ ក៏បានលើកយកមកអធិប្បាយនូវប្រវត្តិវីរភាពនោះ ដែលជាប្រវត្តិតស៊ូរបស់សម្តេចតេជោ ហ៊ុន សែន បច្ចុប្បន្ននាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។ សម្តេចតេជោជាមេដឹកនាំខ្មែរមួយ រូបដែលកើតចេញពីត្រកូលកសិករខ្មែរសុទ្ធសាធ ។ លោកត្រូវបានគូបដិបក្ខវាយតម្លៃខុសលើសមត្ថភាពកាងារដឹកនាំ ។ ទីបំផុត អង្គការចាត់តាំងរបស់ខ្មែរក្រហម ប៉ុល ពត ទាំងនយោបាយ ទាំងយោធា បានត្រូវរំលាយចោលជាស្ថាពរ ដោយសារនយោបាយឈ្នះ/ឈ្នះរបស់សម្តេចតេជោនៅចុងទសវត្សរ៍ឆ្នាំ ១៩៩០ ។ នយោបាយឈ្នះ/ឈ្នះនេះ ជាប្រធានបទនៃការស្រាវជ្រាវដោយឡែក នៅក្នុងសៀវភៅមួយទៀត ។

តាមធម្មតា យុវជនច្រើនប្រកាន់យកឧត្តមគតិស្រឡាញ់អំពើស្អាតស្អំ យុត្តិធម៌សង្គម និង មានស្មារតីស្នេហាជាតិខ្ពស់ ។ នៅពេលស្រុកកើតសង្គ្រាមជាមួយបរទេសឈ្លានពាន ពួកគេច្រើនស្ម័គ្រចិត្តធ្វើជាទាហានការពារទឹកដី ។ បើមានបដិវត្តន៍ យុវជនភាគច្រើនស្ម័គ្រចិត្តធ្វើជាកម្លាំងឈានមុខ ឬ កម្លាំងស្រួចនៃបដិវត្តន៍នោះ ។ សម្តេចតេជោ ហ៊ុន សែន ដែលជាយុវជនម្នាក់នាទសវត្សរ៍ឆ្នាំ ១៩៧០ ស្ថិតនៅក្នុងចំណោមយុវជនខាងលើ ។ ចំណែកឯរូបខ្ញុំៗចូលរួមធ្វើសកម្មភាពដំបូងប្រឆាំង ប៉ុល ពត ដែរ ក៏ប៉ុន្តែភូមិសាស្ត្រនយោបាយសម័យនោះ តម្រូវឲ្យចូលរួមក្នុងសម្ព័ន្ធភាពត្រីភាគីទៅវិញ ។ នៅក្នុងសៀវភៅរបស់លោកក្រោមចំណង ជើងថា «១០ ឆ្នាំនៃដំណើរកម្ពុជា» សម្តេចតេជោ បានចាត់ទុកការចូលរួមណាមួយក្នុងរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យនោះថាគឺជាការឡើងជិះនាវារបស់ខ្មែរក្រហម ។ ការចាត់ទុកនេះពិតជាត្រឹមត្រូវ ។

ការលើកឡើងអំពីសកម្មភាពចលនាតស៊ូប្រឆាំងកងទ័ពវៀតណាម នៅទសវត្សរ៍ឆ្នាំ ១៩៨០ អាចពិពណ៌នាបានថាជាការបង្ហាញអំពីទស្សនិយភាពលេចចេញពីការធ្វើដំណើរតាមកប៉ាល់របស់ខ្មែរក្រហមនោះឯង ។ ការស្រុះស្រួលគ្នាបង្កើតក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជាហៅកាត់ថា អេស អិន ស៊ី (SNC: Supreme National Council) បានផ្តល់លទ្ធភាពឲ្យខ្ញុំអាចលោតចេញពីនាវា «កម្ពុជាប្រជាធិបតេយ្យ» មកជិះនាវាជាតិដ៏ធំវិញម្តង ។ ចាប់តាំងពីបានមកដល់ភ្នំពេញ នៅចុងឆ្នាំ ១៩៩១ ខ្ញុំបានប្តេជ្ញាថាមិនវិលត្រឡប់ទៅធ្វើការតស៊ូនៅតាមទល់ដែនខ្មែរ-ថៃទៀតទេ ។ ខ្ញុំនៅចាំបានថានៅខែ កក្កដា ១៩៩២ តាមរថយន្តជិះជាមួយគ្នាពីឧដុង្គមកភ្នំពេញ បន្ទាប់ពីបានចូលរួមក្នុងពិធីរុក្ខទិវា លោកឯកអគ្គរដ្ឋទូតអាមេរិក ឆាលត្វាយនីង (Charles Twining) សួរខ្ញុំថាប្រសិនបើមានហេតុការណ៍អាក្រក់អ្វីកើតឡើង តើអ្នកត្រឡប់ទៅធ្វើការតស៊ូតាមជាយដែនឬទេ? ខ្ញុំឆ្លើយថាទេ! ខ្ញុំមិនត្រឡប់ទៅទល់ដែនវិញជាដាច់ខាត ព្រោះខ្ញុំមានបទពិសោធន៍ឆ្អែតឆ្អន់អស់ហើយ ។ ខ្ញុំសង្កត់ធ្ងន់ថា ខ្ញុំនឹងប្រឹងប្រែងឲ្យអស់សមត្ថភាព ដើម្បីចូលរួមធ្វើឲ្យមានការបោះឆ្នោត ។ បញ្ហាការចូលរួមបោះឆ្នោត ឬ មិនចូលរួមបោះឆ្នោតនៅឆ្នាំ ១៩៩៣ នោះ ជាចំណុចផ្លូវបំបែក ដែលត្រូវដើរផ្សេងគ្នារវាងខ្ញុំនិង សម្តេច សឺន សាន ។ ខ្ញុំប្រកាន់ជំហរឥតប្រែប្រួលថាត្រូវតែចូលរួមបោះឆ្នោត រីឯក្រុម សឺន សាន និយមនៅទីទើរ ម្តងថាមិនចូលរួម ម្តងថាសុំពន្យារពេលបោះឆ្នោត ។ ជាសំណាងល្អ និង ទោះបីមានឧបសគ្គច្រើនយ៉ាងណាក៏ដោយ ខ្មែរយើងទាំងអស់ស្ទើរតែទូទាំងប្រទេស លើកលែងតែអ្នកនៅក្នុងតំបន់ខ្មែរក្រហមកាន់កាប់ប៉ុណ្ណោះ បាននាំគ្នាទៅបោះឆ្នោតយ៉ាងគគ្រឹកគគ្រេងនៅឆ្នាំ ១៩៩៣ ។ រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ជាច្បាប់កំពូល សម្រាប់ធ្វើជាដំបូលតែមួយ ឲ្យគ្រួសារខ្មែរគ្រប់និន្នាការនយោបាយអាចជ្រកកោន និង រួមរស់ជាមួយគ្នាដោយសុខដុមរមនា ។

នៅទីបំផុត ខ្ញុំក៏បានចូលរួមក្នុងគណបក្សប្រជាជនកម្ពុជា ក្រោមការដឹកនាំរបស់សម្តេចទាំងបី ដើម្បីបំរើប្រជាជន និង ប្រជាជាតិតទៅទៀត ។ គណបក្សខ្មែរដ៏ធំនេះ មានប្រពៃណីផ្សារភ្ជាប់ជោគវាសនារបស់ខ្លួនទៅជាមួយជោគវាសនារបស់ប្រជាជនទាំងមូល ។ នេះជាជីវិតនយោបាយរបស់ខ្ញុំ ដែលជាជីវិតលើផ្លូវបត់បែនមួយ ។ នេះជាផ្លូវបត់បែនឆ្ពោះទៅរកសន្តិភាព។ នៅភាគទីមួយ សៀវភៅនេះនិយាយត្រឹមដំនួប សីហនុ - ហ៊ុន សែន នាចុងឆ្នាំ ១៩៨៧ ព្រោះនោះជាចំណុចគន្លឹះ ដើម្បីទំលុះភាពទាល់ច្រក បើកផ្លូវឲ្យមានការចរចាជាបន្តបន្ទាប់ឈានទៅរកដំណោះស្រាយទិដ្ឋភាពផ្ទៃក្នុងនៃបញ្ហាកម្ពុជា ។

ដោយបានសិក្សាលើឯកសារជាង ២០០០ ច្បាប់ អត្ថបទកាសែត សៀវភៅអំពីកម្ពុជា និង កំណត់ចំណាំមួយចំនួន ខ្ញុំសង្ឃឹមថាសៀវភៅនេះអាចផ្តល់សារប្រយោជន៍ខ្លះៗដល់អ្នកអាន ឲ្យអាចយល់ដឹងអំពីបញ្ហាស្រុកទេសនាទសវត្សរ៍កន្លងមក ។ សៀវភៅនេះ មានចំណុចលម្អិតជាច្រើន ដែលអស់លោកអ្នកអានអាចសំគាល់ថាឥតប្រយោជន៍ ។ ក៏ប៉ុន្តែដោយមួយផ្នែកពាក់ព័ន្ធជាមួយជីវប្រវត្តិឯកជនចំណុចលម្អិតនោះ ត្រូវរក្សាទុក ។ ខ្ញុំជឿថា សៀវភៅនេះក៏ប្រាកដជាទទួលរងនូវការរិះគន់ ឬ វាយតម្លៃទាប ខ្ពស់ តាមមនោសញ្ចេតនា ឬ និន្នាការនយោបាយរបស់អ្នកអាន ។ ខ្ញុំសរសេរសៀវភៅនេះ ទៅតាមដំណើរជីវិតជាក់ស្តែង និង ព្រឹត្តិការណ៍ ដែលខ្ញុំយល់ដឹង ដោយព្យាយាមប្រើបញ្ញា មិនប្រើបេះដូង ព្រោះថាបើសរសេរទៅតាមមនោសញ្ចេតនា សំណេរនេះអាចទោទន់ ទៅតាមការស្អប់ការស្រឡាញ់ ការភ័យខ្លាច ដែលនឹងឃ្លាតចេញឆ្ងាយពីការពិត ។

ដូចខ្ញុំបានលើកពីខាងដើម ខ្ញុំចង់ឃើញខ្មែរសរសេរអំពីរឿងរ៉ាវខ្មែរឲ្យបានច្រើន ដើម្បីចូលរួមកសាងធនធានបញ្ញាញាណរបស់ជាតិយើងឲ្យធំទូលំទូលាយ ។

ខ្ញុំធ្លាប់បានស្តាប់ពាក្យនិទានរបស់ពលរដ្ឋខ្មែរជាច្រើន ជាពិសេស ពីជន រួមឈាមដែលឆ្លងកាត់របប ប៉ុល ពត ។ អ្នកទាំងនោះមានរឿងរ៉ាវនិយាយមិនចេះ ចប់ ។ ក៏ប៉ុន្តែ ខ្ញុំក៏យល់ដែរថា អ្នកសរសេររឿងរ៉ាវទាំងអស់នោះ នឹងមានទឹកចិត្ត សរសេរ តែក្នុងករណីមានអ្នកអាន ។ បើគ្មានអ្នកអាន គេមិនដឹងសរសេរដើម្បីអ្វី ។ យើងគួរនាំគ្នាអានសៀវភៅឲ្យបានច្រើន រហូតបង្កើតឲ្យបានទៅជាទម្លាប់នៃការ អានសៀវភៅ សមដូចពាក្យស្លោកថា អានច្រើន បង្កើនបញ្ញា ។ នៅក្នុងប្រទេស អភិវឌ្ឍជាច្រើន គេផ្តល់អាទិភាពនៃការវិនិយោគទៅលើការកសាង និង ការពង្រឹង ធនធានបញ្ញាញាណ ។ សៀវភៅនេះនៅក្រោមចំណងជើងថា៖ «ជីវិតលើផ្លូវបត់ បែនទៅរកសន្តិភាព» ជាការរួមចំណែកដ៏តូចស្តួចស្តើងមួយរបស់ខ្ញុំក្នុងការកសាង ធនធានបញ្ញាញាណរបស់ខ្មែរ ដែលយើងម្នាក់ៗត្រូវចូលរួមក្នុងពេលនេះ និង ពេល អនាគតខាងមុខកុំបីអាក់ខានឡើយ ។

កម្រងពាក្យសរសេរកាត់ជាភាសាខ្មែរ

ក.ជ.រ.ប.ខ	កងទ័ពជាតិរំដោះប្រជាពលរដ្ឋខ្មែរ (KPNAF)
កូមុិច	គណៈកម្មាធិការប្រតិបត្តិ (COMEX)
រ.ជ.រ.ប.ខ	រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ (KPNLF)
អ.ស.ប	អង្គការសហប្រជាជាតិ (UN)
អាស៊ាន	សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN)
អេស សេ អេហ្វ	សង្គមវិជ្ជាជីវៈគណនេយ្យនៃប្រទេសបារាំង (SCF)
អេស អិន ស៊ី	ក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជា (SNC)
អា ហ្សេ កា អឺ	សមាគមទូទៅខ្មែរនៅបរទេស (AGKE)
ពែកមីកូ	គណៈកម្មាធិការសហការយោធា (PERMICO)
ហ៊្វុនស៊ិនប៉ិច	រណសិរ្សរួបរួមជាតិ ដើម្បី កម្ពុជា ឯករាជ្យ អព្យាក្រឹត្យ សន្តិ និង សហប្រតិបត្តិការ (FUNCINPEC)

កម្រងពាក្យសរសេរកាត់ជាភាសាបរទេស

AGKE	Association des Khmers à l'Etranger
ASEAN	Association of Southeast Asian Nations
CGDK	Coalition Government of Democratic Kampuchea
COMEX	Comité Exécutif
FUNCINPEC	Front Uni National pour un Cambodge Indépendant Neutre Et Coopératif
KPNAF	Khmer People's National Liberation Armed Forces
KPNLF	Khmer People's National Liberation Front
PERMICO	Permanent Military Committee for Coordination
PCCS	Provisional Central Committee for the Salvation of KPNLF
SNC	Supreme National Council
SCF	Société de Comptabilité de France

នៅលើផែនទីខេត្តព្រៃវែង សព្វថ្ងៃផ្លូវជាតិលេខ ៨ ភ្ជាប់ពីស្ពានព្រែកតាមាក់ ទៅអន្លង់ជ្រៃ និង ពញាក្រែក នៃខេត្តកំពង់ចាម ។ ក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ ខ្ញុំធ្លាប់ជិះកង់ តាមកំណាត់ផ្លូវនេះ ដើម្បីធ្វើដំណើរទៅភ្នំពេញ

ប្រភពផែនទី ៖ប៉ែបសាយក្រសួងសាធារណការ

វគ្គទី ១
ភូមិកំណើតខ្ញុំ
(ទសវត្សរ៍ឆ្នាំ ១៩៥០-១៩៦០)

ខ្ញុំកើតនៅភូមិស្នាយពល ក្នុងឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង នៅឆ្នាំ ១៩៥០ គឺជាងហុកសិបឆ្នាំមកហើយ ។ ភូមិស្នាយពល ជាទីរួមស្រុកនៃស្រុកពារាំង ដែលស្ថិតនៅ ផ្នែកបូព៌ានៃប្រទេសកម្ពុជា ។ នៅពេលនោះ ភូមិនេះមានប្រជាពលរដ្ឋតែ ៥០០ ឬ ៦០០ នាក់ប៉ុណ្ណោះ ។ ភូមិស្នាយពលមានចំងាយប្រហែល ៧០ គីឡូម៉ែត្រពីទីក្រុងភ្នំពេញ ក៏ប៉ុន្តែដោយសារហេដ្ឋារចនាសម្ព័ន្ធខាងផ្នែកគមនាគមន៍មិនល្អ ការធ្វើដំណើរពីរាជធានីភ្នំពេញមានការលំបាកជាខ្លាំង ។

ដើម្បីបានជាប្រយោជន៍ដល់អ្នកសិក្សាជំនាន់ក្រោយ ខ្ញុំសូមបង្ហាញអំពីព្រឹត្តិការណ៍ជាតិ និង អន្តរជាតិខ្លះៗ ក្នុងបរិបទប្រវត្តិសាស្ត្រនៅសម័យនោះ ដែលមានការពាក់ព័ន្ធនឹងចំណុចនានាជាបន្តបន្ទាប់ ។

ប្រទេសកម្ពុជាជាប្រទេសមួយនៅក្នុងឧបទ្វីបឥណ្ឌូចិន ។ ឥណ្ឌូចិនជាតំបន់មួយនៅចន្លោះឥណ្ឌា និង ចិន ដែលមានប្រទេសកូមា ថៃ ឡាវ វៀតណាម និង កម្ពុជា ។ ប៉ុន្តែចាប់ពីសម័យអាណានិគមកម្មបារាំង (Colonisation française/ French colonization) នៅពាក់កណ្តាលសតវត្សទី១៩ គេសម្គាល់ឥណ្ឌូចិនចំពោះតែបីប្រទេសគឺ កម្ពុជា វៀតណាម និង ឡាវ ដែលនៅសម័យនោះគេនិយមហៅថា ឥណ្ឌូចិនបារាំង (Indochine française)[1] ។

[1] French Indochina was part of the French colonial empire in Southeast Asia. ឥណ្ឌូចិនបារាំង ជាផ្នែកមួយនៃចក្រភពអាណានិគមបារាំងនៅតំបន់អាស៊ីអាគ្នេយ៍ ។

សង្គ្រាមឥណ្ឌូចិនលើកទី១ (Première Guerre d'Indochine)[2] ដែលជាសង្គ្រាមរវាងប្រទេសទាំងបីខាងលើដើម្បីទាមទារឯករាជ្យពីប្រទេសបារាំង បានចាប់ផ្តើមនៅឆ្នាំ ១៩៤៦ និង បញ្ចប់នៅឆ្នាំ ១៩៥៤ ។ សន្និសីទក្រុងហ្សឺណែវ (Conférence de Genève) ពីថ្ងៃទី ៨ ឧសភា ដល់ថ្ងៃទី ២១ កក្កដា ១៩៥៤ គឺជាសន្និសីទ ដែលប្រទេសជាច្រើនបានចូលរួម ដើម្បីបញ្ចប់សង្គ្រាមនៅឥណ្ឌូចិន ។ ប្រទេសទាំងបីនៅឥណ្ឌូចិនមានវាសនាខុសៗពីគ្នា៖ ប្រទេសវៀតណាមត្រូវបែងចែកជាពីរ ប្រទេសឡាវក៏មានរបបគ្រប់គ្រងពីរ ចំណែកប្រទេសកម្ពុជាមានឯកភាពទឹកដីទាំងស្រុងនៅឆ្នាំ ១៩៥៤ ។ លើសពីនេះទៀត យើងមានឯកភាពខាងនយោបាយចាប់ពីឆ្នាំ ១៩៥៥ នៅពេលដែលមានការបង្កើតចលនាសង្គមរាស្ត្រនិយម ។ យើងរស់នៅក្នុងសុខសន្តិភាព ចាប់ពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៥០ ក៏ប៉ុន្តែផ្លូវគមនាគមន៍នៅសម័យនោះ នៅមិនទាន់ល្អនៅឡើយទេ ។

ការធ្វើដំណើរពីភូមិខ្ញុំទៅកាន់ទីក្រុង

គេច្រើនធ្វើដំណើរពីភ្នំពេញ ទៅភូមិស្នាយពល តាមទោចក្រយាន ឬ ទោចក្រយានយន្តដែលត្រូវចំណាយពេលអស់ជាងកន្លះថ្ងៃ ។ ប៉ុន្តែទោះជាមានការលំបាកយ៉ាងណាក្តី អ្នកស្រុកភូមិខ្ញុំនិយមធ្វើដំណើរមកកាន់ទីក្រុងភ្នំពេញជាងធ្វើដំណើរទៅកាន់ទីរួមខេត្តព្រៃវែង ដែលមានចំងាយប្រហែលតែ ៣០ គីឡូម៉ែត្រប៉ុណ្ណោះ ។ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៦០-៧០ ផ្លូវពីស្នាយពល ទៅទីរួមខេត្ត

[2] The First Indochina War (December 1946- July 1954) was fought between French forces vs. Viet Minh, Pathet Lao and Khmer Issarak. សង្គ្រាមឥណ្ឌូចិនលើកទី១ ពីខែ ធ្នូ ១៩៤៦ ដល់ កក្កដា ១៩៥៤ ជាសង្គ្រាមរវាងកងកម្លាំងបារាំងប្រឆាំង ពួកវៀតមិញ ប៉ាថេតឡាវ និង ខ្មែរឥស្សរៈ ។

ព្រៃវែងនៅតែមានការលំបាកនៅឡើយ ហើយទទួលរងនូវការខូចខាតជាញឹកញាប់ ដោយសារទឹកជំនន់ ។ អ្នកភូមិយើងតែងធ្វើដំណើរតាមផ្លូវថ្នល់ នៅរដូវប្រាំងដែល ចាប់ផ្តើមពីខែ វិច្ឆិកា ទៅខែ ឧសភា ។

ក្នុងសម័យនោះ មានរថយន្តឈ្នួលដឹកអ្នកដំណើរពីស្នាយពល ទៅទីរួម ខេត្តព្រៃវែងចំនួនពីរគ្រឿង ។ រថយន្តមួយពណ៌ក្រហម អ្នកស្រុកច្រើនហៅថា ឡានក្រហម ឬ អាក្រហម ។ រថយន្តមួយទៀតពណ៌ខៀវ គេហៅថាឡានខៀវ ឬ អាខៀវ ។ ថៅកែឡានឈ្នួលនេះជាជនជាតិវៀតណាមកាត់ចិន ។ អ្នកស្រុក ហៅ ថាថៅកែថាក់ ឬ ចិកថាក់ចំពោះឡានខៀវ និង ថៅកែស៊ុង ឬ ចិកស៊ុង ចំពោះឡានក្រហម ។ ការធ្វើដំណើរចម្ងាយសាមសិបគីឡូម៉ែត្រពីស្នាយពល ទៅទីរួមខេត្តព្រៃវែង ត្រូវប្រើពេល ៣ ទៅ ៤ ម៉ោង ។ តាមផ្លូវ រថយន្តឈ្នួលត្រូវ ឈប់ជាញឹកញាប់ ដើម្បីដាក់អ្នកដំណើរ ឬ ដាក់ទំនិញផ្សេងៗរួមទាំងបន្លែ ផ្លែឈើ ឬ សត្វជ្រូក មាន់ ទា ទៀតផង ។

នៅតាមផ្លូវ គេឃើញវាលស្រែវែងឆ្ងាយ ដែលមានដើមត្នោតរាប់ពាន់ដើម ដុះច្រូងច្រាងតាមភ្លឺរាប់គីឡូម៉ែត្រ ។ ជារឿយៗនៅពេលធ្វើដំណើរ ជួនកាលគេត្រូវ ចុះដើរទាំងអស់គ្នា ដើម្បីជួយសម្រាលទម្ងន់រថយន្ត នៅពេលណាដែលត្រូវឆ្លងអូរ ឬ ប្រឡាយទឹកម្តងៗ បើពុំនោះទេរថយន្តអាចត្រូវជាប់គាំង ។ អ្នកដំណើរទាំងនោះ ត្រូវជួយរុញរថយន្តផងក៏មាន ។ នៅពេលឆ្លងកាត់ភូមិនីមួយៗ ជាពិសេសត្រង់ម្តុំ ភូមិព្រៃញៅ ពួកក្មេងតូចៗទាំងខ្លួនទទេរត់ប្រជេញគ្នា តាមពីក្រោយរថយន្ត ស្រែក ហ៊ោរកញ្ជ្រៀវយ៉ាងសប្បាយ ក្នុងធូលីដីដែលហុយសំពោង ។ ក្មេងៗខ្លះរត់លោត តោងឈរនៅខាងក្រោយរថយន្ត អស់មួយស្របក់យ៉ាងរីករាយ ។ ខ្លួនប្រាណ ក្បាល មុខ មាត់របស់ពួកគេប្រឡាក់ប្រឡូសដោយធូលីសសំព្រុស នាំឲ្យមើលមិន ស្គាល់ ។ ផ្លូវថ្នល់ទៅកាន់ទីរួមខេត្តនោះត្រូវបាន គេបរទេះគោ ឬ ក្របីពីលើទៀត

ផង ។

ផ្លូវពីស្នាយពល ទៅភ្នំពេញ ក៏មិនខុសគ្នាប៉ុន្មានដែរ ។ ក៏ប៉ុន្តែនៅសម័យនោះ ពុំមានរថយន្តចេញចូល ឬ ប្រើប្រាស់នៅឡើយទេ ។ ផ្លូវនោះជាផ្លូវតូចតាចដែលអ្នកជិះទោចក្រយានអាចធ្វើដំណើរបានដោយស្រួលផង អាចឈប់សំរាកស្រស់ស្រូបចំណីអាហារ ឬ ភេសជ្ជៈផង ដែលគេជាក់លក់តាមផ្លូវ ហូរហែជាប់រហូត មិនដូចផ្លូវពីស្នាយពល ទៅព្រៃវែងទេ ។ ផ្លូវពីស្នាយពល ទៅភ្នំពេញ[3]ត្រូវឆ្លងកាត់ទន្លេ និង ព្រៃកជាច្រើន ជាពិសេស ឆ្លងកាត់ទន្លេតូចតាមស្ពានឫស្សីមួយ ។ ស្ពាននេះរលាស់ចុះឡើង នៅពេលគេដើរឆ្លងកាត់ម្តងៗ ។ ផ្លូវនេះនាំរហូតដល់ទន្លេធំ ឬ ទន្លេមេគង្គ នៅក្នុងខេត្តកណ្តាល ។ ម្យ៉ាងទៀត គេត្រូវឆ្លងកាត់ព្រៃស្តុបយ៉ាងវែង ចាប់ពីភូមិកំពង់ចម្លង ភូមិព្រៃបាំង រហូតដល់ភូមិព្រះវិហារសួគ៌ ។ នៅពេលគេមកដល់ព្រៃកតាមាក់ អ្នកដំណើរត្រូវឡើងកប៉ាល់បន្តដំណើរឆ្ពោះទៅភ្នំពេញ ។

នៅរដូវវស្សា ទាំងផ្លូវពីស្នាយពល ទៅទីរួមខេត្តព្រៃវែង ទាំងផ្លូវទៅភ្នំពេញ មិនអាចធ្វើចរាចរណ៍បានឡើយ ដោយហេតុមានទឹកជំនន់ឡើងលិច ក្នុងរយៈពេលពីបីទៅបួនខែគឺ ពីខែ សីហា ទៅខែ វិច្ឆិកា ។ នៅពេលនោះ អ្នកស្រុកភូមិខ្ញុំធ្វើដំណើរតាមផ្លូវទឹក ។ ក្នុងសម័យនោះ មានតែពាណិជ្ជករពីរ ឬ បីនាក់ទេ ដែលប្រកបអាជីវកម្មដឹកជញ្ជូនតាមផ្លូវទឹកនេះ ។

កាណូតដឹកអ្នកដំណើរ និង ទំនិញត្រូវចំណាយពេលកន្លះថ្ងៃ ឬ ពេញមួយថ្ងៃ មុននឹងទៅដល់ទីក្រុងភ្នំពេញ អាស្រ័យដោយស្ថានភាពទឹកជំនន់គឺ ទឹកឡើង ឬ ទឹកស្រក ។ ការធ្វើដំណើរតាមកាណូតអាចធ្វើឲ្យកើតក្តីមនោរម្យក្នុងអារម្មណ៍ខ្លាំងណាស់ដោយសារទេសភាពធម្មជាតិគួរជាទីគាប់ភ្នែកដែលយើងឆ្លងកាត់ ។ ជាពិសេស នៅពេលដែលយើងទទួលទានអាហារម្តងៗ ម្ហូបដ៏ឆ្ងាញ់ពិសារបស់យើង

[3] ផ្លូវនេះសព្វថ្ងៃ បានក្លាយជាកំណាត់មួយនៃផ្លូវជាតិលេខ៨ ដែលត្រូវបានពង្រីក និង ក្រាលកៅស៊ូយ៉ាងល្អស្អាត ។

ជាម្ហូបដ៏សាមញ្ញៗដូចជា៖ បាយខ្ទប់ស្លឹកឈូកជាមួយមុាំល្ហុង ឬ ជាមួយត្រីងៀតដុតជាដើម ។ តាមកាណូត យើងអាចមើលឃើញទំហំទឹកល្ហល្ហេវវែងឆ្ងាយ ធំទូលាយដែលគួរឲ្យស្រមៃថា យើងកំពុងធ្វើដំណើរនៅក្នុងមហាសមុទ្រ ។ ពីខែ កញ្ញា ទៅខែតុលា កំពស់ទឹកឡើងខ្ពស់ កន្លែងខ្លះខ្ពស់ស្ទើរផុតចុងត្នោត ធ្វើឲ្យយើងមើលឃើញផ្ទៃទឹកនៅជាប់នឹងជើងមេយ ។ នៅកន្លែងខ្លះ ទឹកឡើង លិចដល់ដំបូលផ្ទះ ។ នៅពេលធ្វើដំណើរ គេអាចប្រទះឃើញពពួកសត្វស្លាបចំរុះពណ៌ ហើររំលងយើងទាំងហ្វូងៗ ឬ ហែលលេងនៅក្បែរៗយើង ជាពិសេស ពួកសត្វទុងធំៗ ។ ត្រីក៏សម្បូណ៌ណាស់ដែរ ។ នៅរដូវទឹកស្រក តាមព្រែកនានា ពេលណាកាណូតយើងឆ្លងកាត់ ត្រីខ្លះលោតចេញពីទឹកផ្លោតចុះផ្លោតឡើង គួរឲ្យចង់ចុះទៅចាប់ ។ កាលសម័យនោះ យើងមិនទាន់ស្គាល់និយមន័យនៃពាក្យអេកូឡូស៊ី (Ecology) នៅឡើយទេ ។ នៅពេលទឹកស្រកខ្លាំង កាណូតបើកយឺតៗព្រោះត្រូវគេចជៀសមែកឈើតូចធំ នៅតាមមាត់ទឹកកុំឲ្យវាត់មកត្រូវអ្នកដំណើរ ។

ជីវភាពប្រចាំថ្ងៃរបស់ប្រជាជន

នៅក្នុងភូមិខ្ញុំ អ្នកស្រុកមួយចំនួនតែងមានទោចក្រយាន (កង់) និង ភាគច្រើនមានទូកតូចៗ ឬ ទូកសំប៉ាននៅប្រចាំគ្រួសារផង ។ អ្នកដែលមានម៉ូតូថែមទាំងមានទូក គេរាប់ថាជាអ្នកធូរធារ ឬ អ្នកមាន ។ ឧពុកម្តាយខ្ញុំមានទូក និង មានម៉ូតូក៏ប៉ុន្តែទូកយើងគ្មានម៉ាស៊ីនទេ[4] ។ ក្រោយមកក្នុងចុងទសវត្សរ៍ឆ្នាំ ១៩៦០ គ្រួសារណាដែលមានចាប់ពីផ្ទះឈើប្រក់ក្បឿងឡើងទៅ ហើយមានទូរទស្សន៍ មានម៉ូតូ និង ទូកម៉ាស៊ីន គ្រួសារនោះ អ្នកស្រុកឲ្យឈ្មោះថាគ្រួសារអ្នកមាន ។

[4] Cf. Roland Thomas, L'évolution économique du Cambodge (1900-1940), Thèse de Doctorat, Université de Paris 7, 1978, p. 142-144 (L'établissement des moyens de communications).

ភូមិស្នាយពលចែកជាពីរគឺ៖ ភូមិស្នាយពលលើនៅខាងកើត និង ភូមិស្នាយពលក្រោមនៅខាងលិច ។ អ្នកភូមិស្នាយពលលើច្រើនប្រកបរបរធ្វើស្រែ ។ ពួកគាត់ចេញទៅធ្វើការតាំងពីព្រឹកព្រលឹមមុនថ្ងៃរះ ។ អ្នកស្រែច្រើនហៅរកគ្នាឲ្យជួយគ្នាទៅវិញទៅមក ។ គេប្រមូលគ្នាទាំងភូមិទៅជួយភ្ជួររាស់ដកស្មូង ឬ ច្រូតកាត់ ។ គេជួយគ្នាម្តងម្នាក់ ដៃលពួកអ្នកស្រុកហៅថាវេរប្រាស់ដៃគ្នា ។ ជាទូទៅ គេបង្កើតបរិយាកាសសប្បាយរីករាយក្នុងការងារ ដោយមានបុរស និង ស្ត្រី ជាពិសេសកម្លោះក្រមុំ ធ្វើការផងច្រៀងតាមរបៀបចម្រៀងប្របកែផ្តោះផ្តងឆ្លើយឆ្លងគ្នាផង ដើម្បីបំបាត់ការនឿយហត់ ។ ក្រៅពីធ្វើស្រែ ប្រុសៗឡើងត្នោតយកទឹកត្នោតមកធ្វើស្ករ ឬ ធ្វើទឹកត្នោតជូរ ដៃលជាភេសជ្ជៈពេញនិយមនាសម័យនោះ ។ នៅពេលទំនេរបួចដៃពីស្រែចំការ ក្នុងចំណោមអ្នកស្រុកភូមិស្នាយពលលើ ពួកប្រុសៗច្រើនទៅធ្វើការជាជាងឈើ ឬ កម្មករសំណង់ នៅភូមិស្នាយពលក្រោម ព្រោះសេដ្ឋកិច្ចនៅទីនោះមានការលូតលាស់ចំរើនជឿនលឿនជាង ។ ចំណែកឯពួកស្រីៗជួយធ្វើការប្រុសៗ ដូចជាកូរស្ករ ឬ ត្បាញស្លឹកត្នោតធ្វើកន្ទេល ឬ ចាក់ស្មុកជាដើម ។

ផ្ទះសម្បែងនៅភូមិស្នាយពលលើភាគច្រើនៗធ្វើពីឈើ ឬ ឫស្សីប្រក់ស្លឹកតែគេក៏ឃើញមានផ្ទះឈើប្រក់ក្បឿងមួយៗដែរ ។ ក្នុងសម័យនោះ ពីភូមិស្នាយពលលើ ទៅភូមិស្នាយពលក្រោម មានចំងាយប្រមាណតែមួយគីឡូម៉ែត្រប៉ុណ្ណោះក៏ប៉ុន្តែ ចំពោះខ្ញុំដៃលនៅតូច ចំងាយមួយគីឡូម៉ែត្រហាក់ដូចជាឆ្ងាយសម្បើមណាស់ ។

រវាងភូមិស្នាយពលលើ និង ភូមិស្នាយពលក្រោម ជីវភាពរស់នៅរបស់អ្នកស្រុក មានសភាពខុសគ្នាយ៉ាងដាច់ស្រឡះ ។ នៅភូមិស្នាយពលក្រោម គេឃើញមានផ្ទះឈើប្រក់ក្បឿង និង ផ្ទះឋ្មមួយៗផង ។ ពាណិជ្ជករដៃលមានសញ្ជាតិដើមជាជនជាតិចិន និង មន្ត្រីរាជការភាគច្រើនជាគ្រូបង្រៀនច្រើនរស់នៅភូមិស្នាយពល

ក្រោម ។ នៅក្នុងភូមិនេះ មានផ្សារមួយជាទីដែលអ្នកស្រុកមកពីភូមិជិតខាងនាំយកបន្លែ ត្រី សាច់ មកលក់ ។ ជារៀងរាល់ថ្ងៃ នៅម៉ោងប្រមាណ ៤ ឬ ៥ ទៀបភ្លឺ គេតែងឮសម្លេងជ្រូកស្រែករោទ៍យ៉ាងទ្រហឹង កន្ទ្រាក់ស្មារតីអ្នកផងឲ្យភ្ញាក់ពីដំណេក ព្រោះចិនកាប់ជ្រូក ចាប់ផ្តើមចាក់កជ្រូក ដើម្បីយកសាច់មកលក់នៅទីផ្សារ ។ ចិនកាប់ជ្រូកធ្វើបែបនេះ ដើម្បីបង្កកឈាមស្រស់ និង ស្ងោរចំអិនទុកលក់ ។ ចិនកាប់ជ្រូកមិនមែនលក់តែសាច់ជ្រូកប៉ុណ្ណោះទេ តែគេក៏មានលក់គ្រឿងក្នុងផងដែរ ។ ចាប់ពីម៉ោង ៥ ឡើងទៅ មនុស្សចាប់ផ្តើមធ្វើដំណើរតាមផ្លូវធំទៅផ្សារស្នាយពលយ៉ាងគគ្រឹកគគ្រេង ។ ជាបន្តបន្ទាប់ អ្នកធ្វើដំណើរថ្មើរជើង ឬ ជិះកង់ ឬ ម៉ូតូ ដោយមានទូល ឬ ដឹកបន្លែបង្គា ត្រីសាច់ ឬ ទំនិញផ្សេងៗមកលក់មានចំនួនកាន់តែច្រើនឡើងៗ ។ អ្នកលក់រៀបចំទំនិញ បន្លែបង្គា ត្រី សាច់ សាច់ជ្រូក សាច់គោនៅលើគ្រែឫស្សី ។ ភាគច្រើន នៅផ្សារគេលក់ដូរតែម្តូបម្ហាសំរាប់ទទួលទានតែប៉ុណ្ណោះ។ របស់របរឯទៀតដូចជាៈ ខោអាវ មុង ភួយ ប្រដាប់ប្រដាប្រើប្រាស់ ឬ ឧបករណ៍ធ្វើស្រែចំការ ត្រូវបានដាក់លក់តាមផ្ទះចិនជាហូរហែនៅតាមផ្លូវធំ ។ ផ្ទះលក់ដូររបស់របរទាំងនោះ ជារបស់ពាណិជ្ជករចិន ដែលចូលមករស់នៅក្នុងភូមិជាច្រើនជំនាន់មកហើយ ។ ចាប់ពីម៉ោង ៦ ទៅ ៧ ព្រឹកឡើងទៅ ទីផ្សារមានសភាពកុះករ និងកាន់តែកុះកររឡើង ដោយសារតែពួកស្ត្រីមេផ្ទះនាំគ្នាមករកទិញបន្លែត្រីសាច់ ដើម្បីធ្វើម្ហូបប្រចាំគ្រួសារ ។ ជាធម្មតាស្ត្រីខ្មែរ ច្រើនចំណាយពេលមួយព្រឹក ឬ មួយល្ងាចដើម្បីធ្វើម្ហូប ។ ចាប់ពីម៉ោង ៩ ព្រឹកទៅទីផ្សារត្រូវរំសាយ ហើយក្លាយទៅជាទីស្ងប់ស្ងាត់ មិនអ៊ូអរគគ្រឹកគគ្រេងដូចពេលមុនឡើយ[5] ។

[5] Cf. Roland Thomas, L'évolution économique du Cambodge (1900-1940), op.cit, p. 156-164 (L'organisation commerciale: le Chinois).

អ្នកស្រែខ្មែរ និង ពាណិជ្ជករចិន

ដោយសារបានកំរៃពីការលក់ដូរផលិតផលនៅទីផ្សារ អ្នកស្រែចាយលុយទិញទំនិញ និង របស់របរសំខាន់ៗតាមផ្ទះចិន មុននឹងត្រឡប់ទៅភូមិរៀងៗខ្លួនវិញ ។ ភូមិស្នាយពលមានភូមិតូចៗជាច្រើន នៅជុំវិញ ។ ភូមិនេះជាមជ្ឈមណ្ឌលពាណិជ្ជកម្មប្រចាំស្រុក ។ អ្នកស្រែមកពីភូមិទាំងនោះរៀងរាល់ថ្ងៃ ទាំងព្រឹក ទាំងល្ងាច ដើម្បីទិញអីវ៉ាន់យកទៅទុកប្រើប្រាស់ ។ អ្នកស្រែ និង ពាណិជ្ជករចិនទាំងនោះមានទំនាក់ទំនងគ្នាល្អណាស់ ។ គេអាចមកទិញអីវ៉ាន់ពេលណាក៏បាន យប់ក៏បាន ថ្ងៃក៏បាន ។ សំខាន់បំផុត បើមិនទាន់មានលុយ អ្នកស្រែក៏អាចទិញទំនិញ ឬ អីវ៉ែអីវ៉ាន់ពីពាណិជ្ជករចិនបានដែរ ដោយសារគេអាចជឿបណ្តាក់គ្នាបាន ។ ពេលយប់ គេអាចមកគោះទ្វារផ្ទះចិន ដើម្បីទិញរបស់របរ ដែលគេត្រូវការជាបន្ទាន់ដូចជា៖ ថ្នាំសង្កូវ ប្រេងកាត ឬ សំលៀកបំពាក់ ឬ កេសជ្ជៈចាំបាច់ជាដើម ។ ពាណិជ្ជករចិនមិនប្រញាប់ប្រញាល់ទារប្រាក់ជំពាក់ភ្លាមទេ គេគ្រាន់តែកត់ត្រាទុករួច គេរង់ចាំរដូវច្រូតកាត់ រដូវប្រមូលផលក្នុងខែចុងឆ្នាំ ទើបគេទូទាត់គ្នាម្តង ។ ក៏ប៉ុន្តែ អ្នកស្រែត្រូវបង់ការប្រាក់ខ្ពស់ ដែលជួនកាលការប្រាក់នោះ កាន់តែកើនច្រើនឡើងៗបន្ថែមលើប្រាក់កម្ចីដើម ។ អ្នកស្រែច្រើនធ្វើការទូទាត់ប្រាក់ជំពាក់ទាំងដើមទាំងការនោះដែលគេគិតជារង្វាល់ស្រូវតាមចំនួនតៅ ឬ ហាំង[6] ។ ក្រោយដែលទូទាត់បំណុលរួចហើយ អ្នកស្រែច្រើនទុកផលស្រូវសេសសល់នៅក្នុងជង្រុក សំរាប់ទទួលទាន ឬ ទុកលក់បណ្តើរៗក្នុងរដូវខាងមុខ ។ ដូច្នេះ ប្រសិនបើផលស្រូវបានច្រើន អ្នកស្រែអាចនៅសល់ស្រូវច្រើនដែលគេអាចដូរយកខោអាវសំលៀកបំពាក់ ឬ របស់របរប្រើប្រាស់បានច្រើន ។ អ្នកស្រែសម័យនោះភាគច្រើន រកបានគ្រាន់តែសម្រាប់

[6] តៅ និង ហាំងជារង្វាស់រង្វាល់ខ្មែរពីបូរាណ ។ ជាធម្មតា ក្នុងមួយហាំង មានពីរតៅ ។

សងបំណុលចិនប៉ុណ្ណោះ ។

អ្នកស្រែមួយចំនួនមានដីធ្វើស្រែផង និង មានដីសំរាប់សង់ផ្ទះផង ។ ក៏ប៉ុន្តែអ្នកស្រែខ្លះ មិនបានទទួលផលគ្រប់គ្រាន់ ពុំអាចឲ្យមានលទ្ធភាពសងបំណុលចាស់បាន ។ ដូច្នេះ ពីមួយឆ្នាំទៅមួយឆ្នាំ អ្នកស្រែនោះជំពាក់បំណុលចិនកាន់តែច្រើនដែលនៅទីបញ្ចប់ត្រូវថៅកែចិនរឹបអូសយកដីធ្លីអស់ផង ។ ក្នុងករណីនេះ ពួកគាត់ត្រូវធ្វើស្រែប្រវាស់គ្នាជាមួយចិន ។ ពួកចិនជាអ្នកកំណត់តម្លៃទំនិញនៅទីផ្សារ ។ តម្លៃទីផ្សារឡើងចុះស្រេចទៅលើសហគមន៍ចិន ដែលមានខ្សែរយៈតាមបណ្តាញរបស់គេនៅទូទាំងប្រទេស ។ ថៅកែចិនជាអ្នកផ្តល់ទំនិញទៅដល់អ្នកភូមិ ទៅតាមប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ។ តាមការជាក់ស្តែង អ្នកស្រែជាអ្នកទិញ ជាអ្នកត្រូវការជានិច្ច រីឯថៅកែចិនជាអ្នកផ្តល់ ជាអ្នកផ្តត់ផ្គង់ ។ សេចក្តីត្រូវការរបស់អ្នកស្រែខ្មែរចេះតែកើនឡើងឥតឈប់ឈរ ដែលជាលេសឲ្យថៅកែចិន តម្លើងថ្លៃទំនិញជាប់ជាប្រចាំ ។

អ្វីដែលគួរកត់សំគាល់នៅក្នុងភូមិតូចដូចជាភូមិស្នាយពលនោះគឺ ភាពងាយស្រួលរបស់ជនជាតិចិន ក្នុងការបត់បែនសម្របសម្រួលធ្វើសមាហរណកម្មខ្លួនចូលមកក្នុងសង្គមខ្មែរ ។ ប្រសិនបើបុរសជនជាតិចិនខ្លះមិនទាន់អាចនិយាយភាសាខ្មែរបានច្បាស់ក៏ដោយ ក៏ប្រពន្ធ ឬ កូនចិនអាចនិយាយភាសាខ្មែរបានល្អឥតខ្ចោះដូចកូនចៅខ្មែរយើងដែរ ។ គ្រួសារជនជាតិចិននៅក្នុងភូមិ ច្រើនជាអ្នកកាន់ព្រះពុទ្ធសាសនា ។ យាយចាស់ៗច្រើនទៅវត្ត និង ជួយផ្គត់ផ្គង់ធ្វើបុណ្យទានតាមប្រពៃណីខ្មែរ ថែមពីលើប្រពៃណីចិនរបស់ពួកគេផ្ទាល់ទៀតផង ។

ពួកចិនបានរៀបការកូនស្រីរបស់គេជាមួយកូនកម្លោះខ្មែរ ដែលភាគច្រើនធ្វើជាមន្ត្រីរាជការ ។ គួររំលឹកថា អាពាហ៍ពិពាហ៍ខ្មែរ-ចិននេះបាននាំឲ្យមានកូនកាត់ជាច្រើន ដែលបានទាមទារសញ្ជាតិកម្ពុជា តាំងពីទសវត្សរ៍ឆ្នាំ ១៩២០ (ដើម្បីបង់

ពន្ធតិច)[7]។ នៅសម័យនោះ អ្នកស្រែមិនសូវចូលចិត្តបញ្ជូនកូនទៅរៀននៅសាលាទេ ព្រោះចង់ទុកកូនឲ្យជួយធ្វើស្រែ ឬ ឃ្វាលគោក្របី ។ ក៏ប៉ុន្តែ ចំពោះអ្នកស្រែខ្លះដែលមានលទ្ធភាពបញ្ជូនកូនទៅសាលា ពួកគាត់បានទទួលរង្វាន់មកវិញ ដោយកូនដែលបានបញ្ចប់ការសិក្សា បានទទួលការងារធ្វើក្នុងរាជការ ហើយកូននោះក៏ជួយទំនុកបំរុងតបស្នងសងគុណឪពុកម្តាយវិញដែរ ។

នៅទសវត្សរ៍ឆ្នាំ ១៩៥០ អ្នកដែលរៀនចប់សាលាបឋមសិក្សា[8] អាចចូលធ្វើគ្រូបង្រៀនបាន ។ នៅទសវត្សរ៍ឆ្នាំ ១៩៦០ អ្នកដែលរៀន និង ប្រឡងជាប់សញ្ញាប័ត្រឌីប្លូម[9] ទើបអាចប្រឡងធ្វើជាគ្រូបង្រៀន ។ ក៏ប៉ុន្តែអ្នកដែលមានសញ្ញាប័ត្រកាន់តែខ្ពស់ ក៏អាចចូលបំរើរាជការក្នុងមុខតំណែងកាន់តែធំ ។ ប្រាក់ខែរបស់គ្រូបង្រៀនមានប្រហែល ១០០ ដុល្លារ ក្នុងមួយខែ ដែលជាប្រាក់ខែខ្ពស់បង្គួរសំរាប់ប្រជាពលរដ្ឋខ្មែរក្នុងសម័យនោះ បើប្រៀបធៀបទៅនឹងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋធម្មតា ។ មុខរបរគ្រូបង្រៀនមានប្រជាប្រិយភាពខ្លាំងណាស់ដែលធ្វើឲ្យពួកចិននៅក្នុងភូមិ ចង់លើកកូនក្រមុំឲ្យ ។ លោកគ្រូកម្លោះៗដែលចេញមកធ្វើការដំបូងពួកចិន ចង់លើកកូនឲ្យដោយសន្យាទិញម៉ូតូថ្មីជាចំណងដៃថែមទៀតផង ។ តាមធម្មតា ការងារនៅក្នុងរាជការត្រូវបានគេគោរពរាប់អានណាស់ ។ គ្រូបង្រៀនត្រូវបានពង្រាយទៅតាមភូមិនានាជាច្រើនទូទាំងប្រទេស ដូចនេះទើបពួកលោកគ្រូ ។ ទទួលនូវការពេញនិយមជាទូទៅ ។

---

[7] Sorn Samnang, L'évolution de la société cambodgienne entre les deux guerres mondiales (1919-1939), Thèse d'Histoire, Université Paris 7, Octobre 1995, p. 174.

[8] អ្នកមាន វិញ្ញាបនបត្របញ្ចប់បឋមសិក្សា ដែលខ្មែរយើងសម័យនោះហៅថាជាប់ សេកទីហ្វីកា Certificat ។

[9] ពាក្យឌីប្លូមនេះប្រែពីភាសាបារាំង Diplôme d'Etudes Secondaires du Premier Cycle (D.E.S.P.C) ដែលខ្មែរយើងហៅថា សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ឬ សញ្ញាបត្របញ្ចប់ការសិក្សាថ្នាក់ទី៩ (Grade 9) ។

ភាពសុខដុមរមនាខាងជាតិសាសន៍ និង សាសនា

ការរស់នៅជាសហគមន៍ទាំងចិន ទាំងវៀតណាម ចាម និង ខ្មែរបានប្រព្រឹត្តទៅដោយសុខដុមរមនារវាងគ្នា និង គ្នាល្អណាស់ ។ ចិនៗ ទោះបីនៅជាអាណិជកជនបរទេសក៏ដោយ ក៏ត្រូវបានអ្នកស្រុកអ្នកភូមិ រាប់អានស្មើភាពគ្នាដោយគ្មានប្រកាន់ជាតិសាសន៍អ្វីឡើយ ។

ក្រៅពីជនជាតិវៀតណាមកាត់ចិនពីរគ្រួសារ ដែលប្រកបរបរជើរឡានឈ្នួលមាន គ្រួសារពីរទៀតដែលរស់នៅក្នុងភូមិស្នាយពល ។ គ្រួសារមួយជាជាងកាត់ដេរខោអាវ និង មួយទៀតរកស៊ីចិញ្ចឹមជ្រូក ដាំបន្លែ និង លក់ម្ហូបអាហារវៀតណាម ជាពិសេស លក់បាញ់ហយ ។ អ្នកស្រុកភូមិយើងចាត់ទុកជនជាតិវៀតណាមជាអាណិកជនបរទេសខ្លាំងជាងពួកចិន ព្រោះពួកនេះមិនកាន់ព្រះពុទ្ធសាសនា និង មិនដែលទៅវត្តជាមួយពួកខ្មែរយើងម្តងណាឡើយ ។ ក្រៅពី ចិន និង វៀតណាម នៅមានជនជាតិចាមមួយគ្រួសារទៀតដែរ តែប្រហែលជាដោយសារពុំមានវិហារចាមបានជាគេមិនសូវឃើញពួកនេះនៅក្នុងភូមិ ។ យូរៗទៅគេក៏មិនឃើញមានជនជាតិចាមរស់នៅតទៅទៀតឡើយ ។ ដូច្នេះនៅទីបំផុត មុខរបរកាប់គោលក់សាច់ ក៏ត្រូវបានធ្លាក់មកជនជាតិខ្មែរវិញ ។ តាមធម្មតា ពួកចាមនាំគ្នាប្រកបរបរនេសាទត្រី ឬ កាប់គោយកសាច់លក់ ។ នៅភូមិស្នាយពល គេហាក់ដូចជាធ្វើការបែងចែកការកិច្ចគ្នារវាងជនជាតិ ចិន ចាម និង វៀតណាម ក្នុងការប្រកបរបរចិញ្ចឹមជីវិត ។ ចិនៗលក់សាច់ជ្រូក ពួកចាមលក់សាច់គោ ។ សាសនារបស់ពួកចាមមិនអនុញ្ញាតឲ្យទទួលទានសាច់ជ្រូកទេ ។ ពួកចាមកាន់សាសនាឥស្លាម បានត្រូវចាត់ទុកជាជនជាតិខ្មែរពេញសិទ្ធិ ដែលគេហៅថា "ខ្មែរឥស្លាម" ។ តាមសៀវភៅប្រវត្តិសាស្ត្រដែលខ្ញុំបានអាន ជនជាតិចាមមានកំណើត នៅក្នុងប្រទេសមួយឈ្មោះ "ចម្ប៉ា" ដែល

បានត្រូវវៀតណាម វាយយកទឹកដី បំបាត់ចេញពីផែនទីពិភពលោកច្រើនរយឆ្នាំមកហើយ ។ ទីតាំងប្រទេសចម្ប៉ា ស្ថិតនៅចំតំបន់អណ្តាមកណ្តាលនៃប្រទេសវៀតណាមបច្ចុប្បន្ន ។ ព្រះចៅនៃប្រទេសចម្ប៉ាចុងក្រោយបង្អស់ និង សេនារេហ៍ពលរបស់ព្រះអង្គត្រូវបានកៀសខ្លួនមករស់នៅក្នុងប្រទេសកម្ពុជានៅឆ្នាំ ១៧២០[10] ។ នៅក្នុងភូមិស្នាយពលកាលសម័យមុនសង្គ្រាម ជនជាតិខ្មែរ ចិន វៀតណាម និង ចាម ឬ ខ្មែរឥស្លាម បានរស់នៅជាមួយគ្នាដោយសុខសាន្តពុំមានទំនាស់រវាងគ្នា និង គ្នាទេ ។

ភាពស៊ីវិល័យនៃអ្នកភូមិស្នាយពលក្រោម

ភូមិស្នាយពលក្រោម ជាទីទំនាបនៅប៉ែកខាងលិច ស្ថិតនៅជាប់នឹងស្ទឹងមួយឈ្មោះថា៖ "ស្ទឹងស្នាយពល" ។ អ្នកភូមិខ្លះនៅតាមដងស្ទឹងប្រកបរបរនេសាទត្រី ។ អ្នកខ្លះទៀតប្រកបរបរលក់នំបញ្ចុក ។ ភូមិស្នាយពលមានឈ្មោះល្បីថាមាននំបញ្ចុកឆ្ងាញ់ ។ ដោយសារតែមានឈ្មោះល្បី "នំបញ្ចុកឆ្ងាញ់" យ៉ាងនេះ ទើបអ្នកទីក្រុងមួយចំនួនតែងនិយមធ្វើដំណើរ មកទិញយកទៅទទួលទានជាញឹកញាប់ ។ អ្នកស្រុកបី ឬ បួនគ្រួសាររកស៊ីលក់នំបញ្ចុក រហូតមានជីវភាពសមរម្យអាចបញ្ជូនកូនឲ្យទៅរៀននៅទីក្រុងភ្នំពេញបាន ។

អ្នកស្រុកខ្លះទៀត ប្រកបរបរដឹកអង្ករតាមទោចក្រយានទៅលក់ តាមភូមិនានា នៅជំនាមាត់ទន្លេធំ ។ អ្នករកស៊ីទាំងនោះគេទិញអង្ករ តាមរោងម៉ាស៊ីនកិនស្រូវ យកមកច្រកបាវក្រចៅ ១០០ គីឡូក្រាម រួចដឹកតាមកង់យកទៅលក់

[10] D G E Hall, A History of South-East Asia, Third Edition, London, 1968, p. 194.

តាមតំបន់មាត់ទន្លេ ចម្ងាយប្រមាណ ៤០ ឬ ៥០ គីឡូម៉ែត្រពីភូមិរបស់ខ្លួន ។ ពេលត្រឡប់មកផ្ទះវិញ អ្នកខ្លះទិញថ្នាំជក់យកមកប្តឹងលក់រាយ តាមបណ្តាភូមិនានានៅស្រុកស្រែ ។ អ្នករកស៊ីដឹកអង្ករលក់នោះ គេតែងនិយមហៅថាអ្នកឌុបអង្ករ ។ ពួកគាត់ចេញពីផ្ទះទៅរកស៊ីតាំងពីព្រឹកនៅម៉ោង ៤ ឬ ៥ ជិតភ្លឺ ដោយដឹកអង្ករយកទៅលក់ហូរហែចាប់ពីភូមិព្រៃកតាមាក់ ក្នុងស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល រហូតតាមដងទន្លេធំ ។ ពួកស្ត្រីជាប្រពន្ធត្រៀមសារ៉ុង និង សាប៊ូទុកឲ្យប្តីងូតទឹកសម្អាតខ្លួន និង សម្រាកនៅពេលត្រឡប់មកវិញ នៅប្រមាណម៉ោង ៣ ឬ ៤ រសៀល ។

អ្នកភូមិស្នាយពលក្រោម រស់នៅរបៀបស៊ីវិល័យ មិនខុសពីអ្នកទីក្រុងឡើយ ។ អ្នកស្រុកទាំងនោះចូលចិត្តលេងភ្លេង ច្រៀងរាំ និង លេងកីឡាប្រជាប្រិយដូចជា កីឡាបាល់ទាត់ ឬ កីឡាបាល់ទះជាដើម ។ នៅពេលបុណ្យចូលឆ្នាំខ្មែរនាពាក់កណ្តាលខែ មេសា រៀងរាល់ឆ្នាំ អ្នកស្រុកនាំគ្នាច្រៀងរាំតាមផ្លូវបីយប់បីថ្ងៃយ៉ាងសប្បាយអឺងកង ។ ពួកគេច្រើននាំគ្នារាំវង់ ខ្លះហៅថារាំឡាំធនដោយមានឧបករណ៍ភ្លេងដៃលគេមានរៀងៗខ្លួន ដូចជាស្គរ(ស្គរដី) ម៉ង់ដូលីន អាកកដេអុង និង ហ្គីតាជាដើម ។

មន្ត្រីរាជការសាលាស្រុកភាគច្រើន មានទីលំនៅៗភូមិស្នាយពលក្រោម ។ ដូច្នេះអ្នកភូមិនេះ សម្បូណ៌ដោយអ្នកធូរធារ ដែលតែងនិយមមកទទួលទានអាហារពេលព្រឹកនៅហាងគុយទាវតែមួយគត់ នៅជិតមាត់ស្ទឹងស្នាយពល ។ មន្ត្រីម្នាក់ដែលទទួលខុសត្រូវផ្នែកគណនេយ្យប្រចាំស្រុក បានត្រូវអ្នកស្រុកឲ្យឈ្មោះថា៖ "ចីដោយ" ។ ចីដោយមានបើកអោងល្ខោនបាសាក់ ដែលសម្តែងរៀងរាល់ល្ងាចនៅគ្រប់រដូវ ។

ក្រុមល្ខោនបាសាក់នេះមានសិល្បករ សិល្បការិនីពី ១០ ទៅ ២០ នាក់ បើគិតរួមទាំងអ្នកភ្លេងផង ។ ជារៀងរាល់ថ្ងៃ រវាងម៉ោង ៣ ឬ ៤ ល្ងាច តួសម្តែង ៣ ឬ ៤ នាក់ ក្នុងសម្លៀកបំពាក់ជាតួអង្គដែលត្រូវសំដែងក្នុងសាច់រឿង ជិះរទេះគោក្រោយមក ជិះរ៉ឺម៉កម៉ូតូ មកបាចសំបុត្រឃោសនាតាមផ្លូវធំ ដោយវាយស្គរប្រកូកប្រកាស ឲ្យអ្នកស្រុកទៅមើលល្ខោន ដែលពួកគេនឹងសម្តែងនៅពេលយប់ ។ ចាប់ពីម៉ោង ៦ ល្ងាចទៅ ស្គរធំរោទ៍យ៉ាងខ្លាំងញាប់តន្ទើនជាប់រហូតគ្មានដាច់ ដែលគេអាចស្តាប់ឮតាំងពីចម្ងាយ ។ ស្នូរស្គរល្ខោនរោទ៍យ៉ាងរញ្ជួយដីនោះ ទាញកន្ត្រាក់អារម្មណ៍អ្នកស្រុក ឲ្យម្នីម្នានាំគ្នាទៅមើលល្ខោន ។ សំបុត្រចូលមើលល្ខោនសម័យនោះតម្លៃខ្ពស់ជាងគេគឺ ១០ រៀល ស្មើនឹង ៣ កាក់ដុល្លារសហរដ្ឋអាមេរិក ។ ឯតម្លៃទាបបង្អស់គឺ ១ រៀល សម្រាប់អង្គុយលើក្តារបន្ទះនៅខាងក្រោយ ដែលគេរៀបជាថ្នាក់ៗពីខ្ពស់ទៅទាប មួយកាំទាបបន្តិចមួយកាំទាបបន្តិច ឆ្ពោះទៅរកឆាកនៅខាងមុខ ។ កន្លែងខ្ពស់ជាងគេនៅខាងក្រោយបង្អស់មានកំពស់ជិត ៣ ម៉ែត្រ ដែលគេនិយមហៅថាថ្នាក់ "ឡូស" ។

រាល់ល្ងាចនៅពេលឮសូរស្គររោទ៍កាលណា ពួកយើងក្មេងៗទធាក់ជើង ចង់ទៅមើលល្ខោនស្ទើរទ្រាំពុំបាន តែងតែទាញដៃទាញជើងឪពុកម្តាយឲ្យនាំទៅមើលការសម្តែងសិល្បៈដ៏ប្រជាប្រិយនេះ ។ បើឪពុកម្តាយមិននាំទៅទេ ក្មេងៗខ្លះលួចទៅមើលដោយខ្លួនឯង ។ បើគ្មានលុយទេ គេលបហែកជញ្ជាំងស្លឹករួចលូនឡើងទៅអង្គុយលើថ្នាក់ "ឡូស" ក្រោយបង្អស់ ។ នៅពេលត្រូវសម្តែងរឿងថ្មីអ្នកដឹកនាំរឿង តែងប្រមូលសិល្បករមកប្រជុំដែលគេហៅថា៖ "សមរឿង" ។ អ្នកដឹកនាំរឿងចែកតួអង្គឲ្យសិល្បករម្នាក់ៗសម្តែងតាមសាច់រឿង ដោយគាត់គ្រាន់តែនិទានត្រួសៗឲ្យសិល្បករទាំងអស់ស្តាប់ ។ សិល្បករម្នាក់ៗ បញ្ចេញនូវទេពកោសល្យរបស់ខ្លួនដោយមិនចាំបាច់អានអត្ថបទណាមួយឡើយ ។ ពេលគេត្រូវនិយាយ ឬ

ច្រៀង គេនិយាយ ឬ ច្រៀងតាមការបិនប្រសប់របស់គេម្នាក់ៗ ។ ខ្ញុំក៏ដូចជាកុមារឯទៀតមួយចំនួនដែរ តែងតែមកមើលគេសមរឿងមិនដែលខាន ព្រោះនៅពេលនោះ យើងអាចមើលឃើញ តួឯកប្រុសស្រី តួយក្ស ឬ តួកំប្លែងដោយផ្ទាល់ក្នុងភាពធម្មតា មិនតែងតួដូចយើងឃើញនៅពេលសម្តែងលើឆាកនោះទេ ។

សិល្បករនាសម័យនោះ មានជីវភាពមិនសូវធូរធារប៉ុន្មានឡើយ ។ តួយក្សដែលមានឈ្មោះល្បីដូចជាតួយក្សឈ្មោះ យក្សខេងជាដើម តែងតែដើរបបក់កង្កែបនៅពេលថ្ងៃ ដើម្បីយកមកធ្វើជាម្ហូបបន្ថែម ក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់គាត់ ។ ជាទូទៅ សិល្បៈល្ខោនបាសាក់ មានប្រជាប្រិយភាពណាស់ ក៏ប៉ុន្តែសិល្បករខ្មែរមិនត្រូវទទួលបាននូវការគោរពរាប់អាន ដូចសិល្បករនៅលោកខាងលិចឡើយ ។ រហូតពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៦០ រោងល្ខោនជាមជ្ឈមណ្ឌលកែកំសាន្តតែមួយគត់នៅក្នុងស្រុកពារាំងរបស់យើង ។ ក៏ប៉ុន្តែ បន្តិចម្តងៗដោយសារឥទ្ធិពលនៃទូរទស្សន៍ ដែលបានជ្រៀតចូលតាមលំនៅដ្ឋានរបស់ប្រជាពលរដ្ឋដាលំដាប់នោះ ល្ខោនបាសាក់របស់យើង ក៏កាន់តែបាត់បង់នូវប្រជាប្រិយភាពបន្តិចម្តងៗ រហូតដល់ត្រូវបិទរោងឈប់សម្តែងរៀងរហូត ចាប់ពីចុងទសវត្សរ៍ឆ្នាំ ១៩៦០ មក ។

នៅភូមិស្នាយពលក៏ដូចជានៅភូមិនានា ក្នុងប្រទេសកម្ពុជាយើងដែរព្រះពុទ្ធសាសនាមានការរីកសុះសាយល្អណាស់[11] ។ វត្តអារាមជាមជ្ឈមណ្ឌល ឬ ទីប្រជុំនៃសកម្មភាពសង្គមកិច្ចទាំងឡាយ ។ គេនិយមទៅធ្វើបុណ្យទាន ឬ ពិធីធំៗនៅក្នុងវត្ត ។ អ្នកភូមិយើងតែងនិយមទៅធ្វើបុណ្យនៅវត្តស្នាយពល ឬ វត្តរកាដែលស្ថិតនៅក្នុងភូមិមួយក្បែរភូមិស្នាយពល ។ ជីដូនជីតា និង ឪពុកម្តាយខ្ញុំ តែងតែទៅធ្វើបុណ្យនៅវត្តរកាជាប់ជានិច្ច ដោយសារព្រះគ្រូចៅអធិការជាគ្រូផង និង ជាមិត្តជិតស្និទ្ធ

[11] Cf. Sorn Samnang, L'évolution de la société cambodgienne entre les deux guerres mondiales (1919-1939), op.cit, p. 301-319.

ប្រចាំគ្រួសារយើងផង ។ យើងប្រគេនព្រះនាមព្រះចៅអធិការថា៖ "លោកតាវត្ត រកា" ។ យាយៗ តាៗ ដែលគោរពប្រតិបត្តព្រះពុទ្ធសាសនាយ៉ាងខ្ជាប់ខ្ជួនតែងទៅ វត្តរៀងរាល់ថ្ងៃសីល ដើម្បីទៅសុំសីល ឬ ស្តាប់ព្រះសង្ឃសំដែងធម្មទេសនា ។ ចំពោះពួកយើងក្មេងៗ យើងបានទទួលការអប់រំឲ្យយល់ថា ព្រះពុទ្ធសាសនាមាន លក្ខណៈសាមញ្ញជាទីបំផុតគឺ នៅលើមេឃមានទេវតាចាំកត់ត្រាទុកនូវទង្វើរបស់ យើងម្នាក់ៗ ។ បើយើងធ្វើល្អ យើងនឹងបានឡើងឋានសួគ៌ តែបើយើងធ្វើអាក្រក់ យើងនឹងចុះនរកតាមបញ្ជីកត់ត្រារបស់ទេវតានោះ ។

វង្សត្រកូលខ្ញុំ

ភូមិដែលខ្ញុំចាប់កំណើតស្ថិតនៅចន្លោះភូមិស្នាយពលលើ និង ភូមិស្នាយពល ក្រោមដែលនាសម័យនោះមានផ្ទះតែ ៤ ឬ ១០ ខ្នងប៉ុណ្ណោះ ។ ជីតាខ្ញុំខាងម្តាយ សង់ផ្ទះនេះ តាំងពីទសវត្សរ៍ដំបូងនៃសតវត្សទី ២០ មកម្ល៉េះ ។ ផ្ទះនោះជាផ្ទះឈើ ប្រក់ក្បឿង ប្រកបដោយសសរមូលធំៗខ្មៅរលោង ។ ជញ្ជាំងឈើត្រូវបានធ្វើពីក្តារ ប្រណិតបិទផ្ចិតភ្ជាប់តគ្នា តាមបច្ចេកទេសមួយ ដែលគេមិនអាចមើលឃើញដៃក គោលមួយគ្រាប់ណាឡើយ ។ នៅខាងមុខ មានយ៉ដែលមានបង្គាន់ដៃឈើព័ទ្ធជុំ វិញ ។ នៅផ្នែកខាងក្រោយ មានផ្ទះបាយដាច់ដោយឡែកពីផ្ទះធំ ។ ពេលឡើង ជណ្តើរទៅខាងលើ និង ឆ្លងកាត់យ៉ានោះចូលទៅខាងក្នុង គេឃើញទូរឈើធំពីរសង់ ជាជញ្ជាំងបាំងចែកបន្ទប់ធំៗជាស្រេច ម្ខាងឆ្វេងម្ខាងស្តាំ ដោយមានឆ្លាក់ក្បាច់រចនា លំអផង ។ ផ្ទះនេះជាកម្មសិទ្ធិរបស់ជីតាខ្ញុំខាងម្តាយ ឈ្មោះលោកតា យិន អ៊ុច ។

លោកតា យិន អ៊ុច ជាមន្ត្រីមានមុខមានមាត់ប្រចាំភូមិស្រុក ដោយសារតែ

បានបម្រើរាជការក្នុងមុខតំណែងផ្សេងៗអស់ជាយូរឆ្នាំមកហើយ ។ ដំបូងគាត់ធ្វើជាមេឃុំ បន្ទាប់មក ជាសមាជិកក្រុមប្រឹក្សាពិគ្រោះយោបល់នៃព្រះរាជាណាចក្រកម្ពុជា ជាចៅនិគម និង នៅចុងក្រោយជាអាជ្ញាសាលា ។ ខ្ញុំមិនបានស្គាល់ជីតារបស់ខ្ញុំនេះទេ ព្រោះគាត់ធ្វើមរណៈកាលទៅហើយ កាលខ្ញុំកំពុងនៅជាទារកនៅឡើយ ។ ជីតាខ្ញុំរស់នៅជាបែបអភិជន ។ គាត់ធ្វើដំណើរតាមរទេះសំឡី ដែលមានអ្នកបររទេះជូនគាត់ និង មានខ្ញុំបំរើនៅចាំបម្រើគាត់ជាប្រចាំ ។ លោកតា យិន អ៊ុច រៀបអាពាហ៍ពិពាហ៍ជាមួយជីដូនខ្ញុំឈ្មោះលោកយាយ អ៊ុង គូ ។ លោកយាយលោកតាមានកូនទាំងអស់ ៧ នាក់គឺស្រី ៥ នាក់ និង ប្រុស ២ នាក់ ។ ម្តាយរបស់ខ្ញុំឈ្មោះ សុខា ជាកូនទី ៣ ។

កូនស្រីទាំង ៥ នាក់របស់លោកយាយលោកតា សុទ្ធតែបានទៅរៀននៅសាលាបឋមសិក្សាទាំងអស់ ។ ក៏ប៉ុន្តែ មានតែម្តាយមីងខ្ញុំឈ្មោះ សាម៉ឺឌី ទេ ដែលបានធ្វើជាគ្រូបង្រៀន ចំណែកឪពុកមាខ្ញុំពីរនាក់នោះ សុទ្ធតែបានរៀនខ្ពស់តទៅទៀតហើយ បានទទួលមុខតំណែងដ៏សមគួរក្នុងមុខងារសាធារណៈ ។ ក្នុងសម័យមុនខ្ញុំកើតនោះ ជាទូទៅឪពុកម្តាយមិនចង់បញ្ជូនកូនស្រីឲ្យទៅរៀននៅសាលាទេ ។ ឪពុកម្តាយខ្លះ ទុកកូនស្រីនៅផ្ទះដើម្បីឲ្យរៀនធ្វើស្ត្រីមេផ្ទះ សម្រាប់អនាគតរបស់នាង ។ ឪពុកម្តាយខ្លះអាចបារម្ភថាមិនអាចឃុំគ្រងកូនស្រីបាន ប្រសិនបើបណ្តោយឲ្យទៅរៀននៅសាលា ក្រៅពីក្រសែភ្នែករបស់ពួកគាត់ ។ ម្តាយខ្ញុំមិនបានរៀនចប់បឋមសិក្សាទេ តែគាត់អាចអាន និង សរសេរបាន ។

ឪពុកម្តាយជំនាន់បូរាណចិញ្ចឹមបីបាច់ថែរក្សា និង អប់រំកូនស្រីឲ្យដើរតាមគន្លងប្រពៃណីយ៉ាងហ្មត់ចត់ត្រឹមត្រូវជាទីបំផុត ។ កូនស្រីៗ ពេលពេញក្រមុំត្រូវស្ថិតនៅក្នុងម្លប់ មិនឲ្យត្រូវកំដៅថ្ងៃដែលនាំឲ្យខូចសម្រស់ ។ ប្រសិនបើដើរទៅណាមកណាត្រូវមានចាស់ទុំទៅជាមួយ ។ នារីក្រមុំមិនត្រូវនិយាយជាមួយប្រុសៗ

ឡើយ ។ បើត្រូវរៀបអាពាហ៍ពិពាហ៍ ឪពុកម្តាយជាអ្នករើសគូស្រករឲ្យ និង សម្រេចថាត្រូវរៀបការ ឬ មិនត្រូវរៀបការ ។ កូនកម្លោះ និង កូនក្រមុំ មិនចាំបាច់ស្គាល់គ្នាពីមុនមកទេ ស្រេចលើឪពុកម្តាយជាអ្នកទុកដាក់ទាំងស្រុងតែម្តង ។ តាមធម្មតា គ្រួសារខាងកូនប្រុសជាអ្នកចូលទៅស្តីដណ្តឹង ។ ប្រសិនបើយល់ព្រម គ្រួសារកូនស្រីនឹងបង្គាប់ឲ្យខាងកូនប្រុសនាំមកនូវមាសប្រាក់ ស្រូវអង្ករទុកជាជំនូនជូនដល់ខាងកូនស្រី ។ បន្ថែមពីលើជំនូននោះ កូនប្រុសត្រូវមកនៅបម្រើខាងកូនស្រីមួយរយៈពេល អ្នកខ្លះមួយឆ្នាំ អ្នកខ្លះពីរឆ្នាំ ឬ លើសពីនេះ អាស្រ័យលើលក្ខខណ្ឌដែលគ្រួសារខាងស្រីកំណត់ ។ ក្នុងពេលដែលកូនប្រុសមកបម្រើខាងស្រីនេះ បើអនាគតឪពុកក្មេក ឬ ម្តាយក្មេកមិនពេញចិត្តនឹងការងារ ឬ កិរិយាមារយាទរបស់កូនប្រុសនោះទេ គ្រួសារខាងស្រីអាចផ្តាច់ឈប់ឲ្យរៀបការ ដោយមិនចាំបាច់សងជំនូនទៅខាងប្រុសវិញក៏បាន ។ ឪពុកនិងម្តាយខ្ញុំ បានគ្នាជាគូស្រករក្នុងបរិបទនៃប្រពៃណីខ្មែរពីបរមបូរាណយ៉ាងនេះ ។ កាលនោះ ខ្មែរយើងនៅកាន់ប្រពៃណីតឹងតែងណាស់ មិនដូចទសវត្សរ៍ឆ្នាំ ១៩៦០ ដែលពួកចិនៗលើកកូនក្រមុំឲ្យលោកគ្រូៗ ខ្មែរដោយស្រួលៗនោះទេ។

ឪពុកខ្ញុំឈ្មោះ អៀង មុត ។ គាត់កើតនៅភូមិមេសប្រចាន់ ដែលជាប់នឹងទន្លេតូច ។ គ្រួសារឪពុកខ្ញុំជាគ្រួសារកសិករ ហើយសុទ្ធតែបានបួសរៀនតាមផ្លូវព្រះពុទ្ធសាសនា ។ ជីតាខ្ញុំឈ្មោះលោកតា គង់ អៀង ឯជីដូនខ្ញុំឈ្មោះ លោកយាយ ហ៊ូ ឱ ។ លោកយាយលោកតាមានកូន ៦ នាក់ ប្រុស ៤ នាក់ ស្រី ២ នាក់ ។ ឪពុកខ្ញុំជាកូនទី ៤ ។ ក្រៅពីកូនស្រីទាំងពីរនាក់ចេញ កូនប្រុសទាំងបួនរបស់លោកយាយលោកតាសុទ្ធតែបានបួសជាភិក្ខុសាមណេរទាំងអស់ ។ តាមធម្មតា ក្មេងៗច្រើនទៅនៅវត្ត រហូតអាយុបាន ១៣ ទៅ ១៥ ឆ្នាំ គេនាំគ្នាបួសជាសាមណេរ ។ នៅវត្ត ពួកសាមណេរ ឬ ពួកលោកនេន រៀនធម៌អាថ៌ព្រះពុទ្ធសាសនាផង រៀន

អក្សរសាស្ត្រ លេខនព្វន្ត រៀនក្បាច់គិតលេខ[12]ដូចចិនផង ឬ រៀនធ្វើជាង ជាងឈើ ជាងកំបោរ[13]ជាដើម ។ល។ រហូតដល់ព្រះជន្ម (អាយុ) ១៨ ព្រះវស្សា (ឆ្នាំ) ។ ក្នុងចន្លោះអាយុ ១៨ និង ២១ ឆ្នាំ គេអាចលាចាកសិក្ខាបទ ឬ សឹក (តាមពាក្យសាមញ្ញ) មកជាគ្រហស្ថរស់នៅជួយធ្វើការឪពុកម្តាយ ដូចយុវជនឯទៀតបាន ។ តែសាមណេរខ្លះ ក៏នៅបន្តកេទជាសង្ឃតទៅទៀត ដោយគ្រាន់តែបំពេញបន្ថែមឲ្យទៅជាភិក្ខុពេញលក្ខណៈ ។ ភិក្ខុអាចស្ថិតនៅជាសង្ឃរហូតមួយជីវិត ឬ អាចលាចាកសិក្ខាបទមកជាពលរដ្ឋធម្មតានៅពេលណាមួយក៏បាន ។ លោកនេនដែលលាចាកសិក្ខាបទ គេច្រើនហៅ "ជី" រីឯភិក្ខុដែលលាចាកសិក្ខាបទហៅថា "អន្ឋិត" តាមពាក្យសាមញ្ញធម្មតារបស់អ្នកស្រុក ឬ ហៅថាបណ្ឌិត តាមពាក្យវប្បធម៌ ។

ឪពុកខ្ញុំ និង ឪពុកធំខ្ញុំទាំងអស់សុទ្ធតែបានបួសជាភិក្ខុ ។ បងបង្អស់របស់ឪពុកខ្ញុំឈ្មោះ អៀង ប៊ុន ស្ថិតនៅជាសង្ឃ គង់នៅវត្តសារវន្តតេជោក្រុងភ្នំពេញ រហូតដល់ឆ្នាំ ១៩៧៤ ទើបលោកសុគត ។ អាយុ ២៨ ឆ្នាំ ឪពុកខ្ញុំលាចាកសិក្ខាបទពីភិក្ខុមកនៅជួយធ្វើការម្តាយដែលនៅមេម៉ាយ ក្រោយពីជីតាខ្ញុំបានចូលមរណកាលទៅ ។ ដល់គាត់មានអាយុ ៣០ ឆ្នាំ ឪពុកខ្ញុំជាកម្លោះចាស់ នៅពេលដែលម្តាយខ្ញុំទើបមានអាយុតែ ១៨ ឆ្នាំប៉ុណ្ណោះ ។ គ្រួសារខាងឪពុក និង ម្តាយខ្ញុំបានត្រូវរ៉ូវគ្នា ដើម្បីរៀបចំឲ្យអ្នកទាំងពីរបានគ្នាជាប្តីប្រពន្ធតទៅ ។ ដោយសារគ្រួសារខាងឪពុកខ្ញុំមានសភាពអន់ខ្សោយជាង គាត់ត្រូវទទួលបង្គាប់យ៉ាងធ្ងន់ និង ត្រូវមកធ្វើការបម្រើគ្រួសារខាងម្តាយខ្ញុំ ក្នុងរយៈពេលមួយឆ្នាំ មុននឹងរៀបការ ។ ក្នុងរយៈ

[12] ក្បាច់ជាឧបករណ៍គិតលេខរបស់ពាណិជ្ជករចិន ដែលគេអាចប្រើធ្វើលេខ បូក ដក គុណ ចែក ក្នុងសម័យដែលមិនទាន់មានម៉ាស៊ីនគិតលេខទំនើប ។

[13] កាលជំនាន់ដើម គេហៅជាងកំបោរ ឥឡូវគេហៅ ជាងស៊ីម៉ង់ ។

ពេលមួយឆ្នាំនេះ ឪពុកខ្ញុំត្រូវធ្វើការទាំងយប់ទាំងថ្ងៃ ដោយអត់ខ្លាចនឿយហត់ឡើយ ។ ក្នុងរយៈពេលនេះ គាត់មិនអាចនិយាយលេង ឬ ទៅណាមកណាជាមួយគួដណ្តឹងគាត់ឡើយ ។ នៅទីបញ្ចប់ ឪពុក និង ម្តាយខ្ញុំបានរៀបអាពាហ៍ពិពាហ៍នៅឆ្នាំ ១៩៤៥ ។ ការមកធ្វើការបម្រើអនាគតឪពុកក្មេកម្តាយក្មេក ជាបទពិសោធន៍ដ៏ល្អសំរាប់ឪពុកខ្ញុំ ព្រោះដីតាខ្ញុំគឺ លោកតា យិន អ៊ុច មានការពេញចិត្តចំពោះការងារ របស់អនាគតកូនប្រសារគាត់ជាទីបំផុត ។

ក្រោយពីរៀបការហើយ ឪពុកខ្ញុំបានទទួលការបំពាក់បំប៉នវិជ្ជាផ្នែកច្បាប់ជាពិសេសច្បាប់រដ្ឋប្បវេណី ច្បាប់ព្រហ្មទណ្ឌ និង នីតិក្រមនានាពីដីតាខ្ញុំ ។ ក្រោយពីបានទទួលការបំពាក់បំប៉នផ្នែកច្បាប់រួចមក ឪពុកខ្ញុំបានទទួលមរតកពីដីតាខ្ញុំ ដោយត្រូវបានទទួលការតែងតាំងជាអាជ្ញាសាលា ។ កាលសម័យមុនសង្គ្រាមនោះ មុខងារអាជ្ញាសាលាជាមុខងារក្នុងវិជ្ជាជីវៈសេរី ដែលមានមុខនាទីសម្រេចអនុវត្តសាលក្រមរបស់តុលាការ ជាពិសេសផ្នែករដ្ឋប្បវេណី និង ធ្វើការប្រគល់ដីការកោះដល់គូក្តីឲ្យចូលរួមសវនាការរបស់តុលាការ ។ នៅសម័យនោះ មុខតំណែងអាជ្ញាសាលាខុសពីមុខតំណែងព្រះរាជអាជ្ញា ព្រោះតំណែងអាជ្ញាសាលាអាចផ្ទេរពីឪពុកទៅកូនបាន ។ ប៉ុន្តែក្រោយមក មុខតំណែងនេះត្រូវឆ្លងកាត់ការប្រឡងវិជ្ជាជីវៈទូទាំងប្រទេសដោយមានគណៈមេប្រយោគ ដែលក្នុងនោះមានចៅក្រមជាន់ខ្ពស់ជាសមាជិក និង មានរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាប្រធាន ។ ឪពុកខ្ញុំបានទទួលកាន់តំណែងជាអាជ្ញាសាលា នៅឆ្នាំ ១៩៤៩ ។ មួយឆ្នាំកន្លងមក លោកតា យិន អ៊ុច ក៏ទទួលមរណភាពលាចាកយើងទៅ ។

នៅប្រទេសខ្មែរយើងៗដាក់ឈ្មោះត្រកូលមុនឈ្មោះយើងផ្ទាល់ មិនដូចនៅប្រទេសលោកខាងលិចឡើយ ។ ឪពុកខ្ញុំដាក់ឈ្មោះដីតាខ្ញុំនៅខាងមុខ ដូច្នេះឈ្មោះគាត់គឺ អៀង មុត ។ តាមការនិយាយរ៉ាយរ៉ាប់របស់ឪពុកខ្ញុំ លោកតា អៀង

មានបទពិសោធន៍យ៉ាងច្រើនក្នុងជីវិតរបស់គាត់ ។ កាលគាត់នៅក្មេង គាត់រៀនក្បាច់គុន ហើយមានការប៉ិនប្រសប់ក្នុងការប្រើដំបង ។ កាលចុងសតវត្សទី ១៩ ឪពុកមាម្នាក់របស់កម្លោះ អៀង ធ្វើជាមេឃុំ ។ លោកមេឃុំមានកម្រិតវិជ្ជាគុនដំបងយ៉ាងជំនាញដែលគេទទួលស្គាល់ថាគាត់ជាគ្រូគុននិយម ។ ប្រហែលជាដោយយល់ឃើញថា អ្នកចេះវិជ្ជាគុននិយមអាចទទួលគ្រោះថ្នាក់ដោយសារវិជ្ជានេះ ទើបលោកមេឃុំហាមប្រាមកូនក្មួយទាំងអស់ មិនឲ្យទៅហាត់រៀនវិជ្ជានេះឡើយ ។ តែប្រសិនបើលោកមេឃុំដឹងថា មានកូនក្មួយណាមួយហ៊ានចចេសលួចទៅរៀន គាត់នឹងដេញចេញ មិនឲ្យរស់នៅក្នុងភូមិជាមួយគាត់ឡើយ ។ បើចង់មករស់នៅក្នុងភូមិវិញ ទាល់តែកូនក្មួយនោះប្រយុទ្ធឈ្នះគាត់ទើបបាន ។ បើមិនឈ្នះត្រូវតែនិរទេសខ្លួនចេញ ។

ជាច្រើនលើក យុវជន អៀង តែងលួចទៅរៀនវិជ្ជាគុន ហើយជាច្រើនលើកលោកឪពុកមាជាមេឃុំតែងហៅយុវជន អៀង ឲ្យមកល្បងថ្វីដៃជាមួយគាត់ ។ ម្តងៗយុវជន អៀង តែងតែប្រកួតចាញ់លោកមាមេឃុំ ហើយតែងត្រូវនិរទេសទៅនៅស្រុកផ្សេង ។ ប៉ុន្តែនៅលើកចុងក្រោយ គាត់បានដើរស្វែងរករៀនវិជ្ជាគុនពីស្ត្រីគ្រូគុនម្នាក់អាយុប្រមាណ ៣០ ឆ្នាំ នៅស្រុកលើ (ពួកអ្នកស្រុកយើង តែងនិយមហៅអ្នកស្រុកនៅចាប់ពី ៣មដាំង ទៅមេមត់ ក្នុងខេត្តកំពង់ចាមថាអ្នកស្រុកលើ) ។ យុវជន អៀង បានហាត់រៀនឈានដល់កម្រិតគុននិយមខ្ពស់ និង ល្មមគ្រប់គ្រាន់អាចប្រកួតជាមួយលោកមេឃុំជាឪពុកមាបាន ។ នៅលើកនេះ កម្លោះ អៀង ឈ្នះ ហើយត្រូវបានអនុញ្ញាតឲ្យរស់នៅក្នុងស្រុកជាធម្មតាវិញ ។ ដោយសារវិជ្ជាគុននិយមរបស់គាត់ លោកតា អៀង បានប្រយុទ្ធជាមួយខ្លាមួយក្បាល និង បានសម្លាប់សត្វខ្លាព្រមទាំងទុកស្បែកខ្លានោះ ឲ្យកូនចៅមើលតៗនៅជំនាន់ក្រោយផង ។ ខ្ញុំធ្លាប់បានឃើញស្បែកខ្លាធំមួយផ្ទាំងដោយផ្ទាល់ភ្នែក ដែលព្រះគ្រូ អៀង ប៊ុន ជាឪពុកធំ

ខ្ញុំ លោកថែរក្សានៅក្នុងកុដិរបស់លោក នៅក្នុងវត្តសាវន្តតេជោក្រុងភ្នំពេញនាឆ្នាំ ១៩៦០ ។ សូមបញ្ជាក់ថាជីតាខ្ញុំក៏បានហាមប្រាម កូនចៅក្រោយៗមកមិនឲ្យហាត់រៀនវិជ្ជាគុននិយមទៀតឡើយ ដោយប្រហែលជាគាត់យល់ឃើញដូចលោកឪពុកមាមេឃុំរបស់គាត់ដែរ ។

ដោយសារវិជ្ជាគុននិយមនេះ ទើបជីតារបស់ខ្ញុំបានចូលបម្រើព្រះមហាក្សត្រក្នុងព្រះបរមរាជវាំងជាមហាតលិកមួយរយៈ ក្នុងរជ្ជកាលព្រះបាទ នរោត្តម[14] ។ ក្រោយមកជីតាខ្ញុំបានមករស់នៅក្នុងភូមិមេសប្រចាន់ ។ គាត់ជាមេក្រុមទូកងដែលអង្គុយក្បាលទូក លើកច្រវាគ្រវីគ្រវាត់ ដើម្បីអ្នកអុំៗទូកស្មើចង្វាក់គ្នាឲ្យទូកមានល្បឿនលឿន ឬ យឺត ។ ក្រោយមកលោកតា អៀង បានក្លាយជាអាចារ្យប្រចាំវត្តមេសប្រចាន់ រហូតដល់ពេលលោកតាលាចាកលោកទៅក្នុងជន្មាយុប្រហែល ៧០ ឆ្នាំក្នុងឆ្នាំ ១៩៣៩ ។

ឪពុកម្តាយខ្ញុំមានកូន ១១ នាក់គឺ ប្រុស ៩ នាក់ និងស្រី ២ នាក់ ។ ខ្ញុំជាកូនទី ៣ ។ យើងទាំងអស់គ្នាសុទ្ធតែបានត្រូវបីបាច់ថែរក្សាតាមបែបប្រពៃណីរបស់អ្នកស្រុកដែលគេគោរពតៗគ្នារៀងមក ។ ខ្ញុំជាកូនដែលកើត ក្រោយពីចាប់កំណើតក្នុងផ្ទៃម្តាយអស់រយៈពេលតែ ៧ ខែទេ ។ គេអាចហៅថាកូនមិនគ្រប់ខែក៏បាន ។ នៅស្រុកយើង កូនកើត ៧ ខែគេថាមិនគ្រប់ទឹកអាចមានបញ្ហាមិនដូចពួកកូនកើតគ្រប់ខែទេ ។ រាល់ៗដងនៅពេលកើតកូន ម្តាយខ្ញុំតែងហៅរកយាយម៉ប ឬ ឆ្មបប្រចាំភូមិឈ្មោះ យាយកា ។

[14] នេះជាការដំណាលប្រាប់គ្នាតៗមក ដោយពួកយើងពុំមានឯកសារច្បាស់លាស់ឡើយ ។

ការឆ្លងទន្លេនៅភូមិស្នាយពល

ការកើតកូន ខ្មែរយើងតែងហៅថាឆ្លងទន្លេ ព្រោះគេប្រដូចឧបសគ្គនៃការកើតកូន ទៅនឹងឧបសគ្គដែលអាចកើតឡើងក្នុងការហែលទឹក ឬ ជិះទូកឆ្លងទន្លេដែរគឺ បើឆ្លងមិនរួច ឬ មិនដល់ច្រាំងអាចត្រូវលង់ទឹកស្លាប់ ។ ការឆ្លងទន្លេក៏ដូច្នោះដែរ ទាំងកូនទាំងម្តាយ អាចទទួលគ្រោះថ្នាក់ដល់ជីវិត ។ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៥០ នៅក្នុងភូមិស្នាយពល មានមន្ត្រីសុខាភិបាលតែម្នាក់គត់មានឋានៈត្រឹមគិលានុប្បដ្ឋាកគ្មានធ្មបនៅប្រចាំទេ[15] ។ អ្នកស្រុកភាគច្រើននៅពេលមាន ជម្ងឺតែងទៅរកគ្រូបូរាណប្រើថ្នាំខ្មែរជាជាងទៅរកគ្រូពេទ្យ ។ នៅពេលស្ត្រីកំពុងឆ្លងទន្លេគឺទារកកំពុងចេញពីផ្ទៃម្តាយ មនុស្សប្រុសៗ គេមិនអនុញ្ញាតឲ្យនៅក្នុងបន្ទប់ជាមួយឡើយ ។ បុរសដែលក្លាយជាឪពុកត្រូវរៀបចំគ្រែ ចង្រ្កាន និង ធ្យូងនៅទីដាច់ដោយឡែក ព្រោះនៅពេលដែលទារកចេញមកហើយ ស្ត្រីជាម្តាយត្រូវមកសម្រាកអាំងភ្លើងយកកម្តៅ អស់រយៈពេលបីថ្ងៃទើបឈប់ ។ នៅពេលប្រពន្ធសម្រាកនៅលើគ្រែបុរសជាប្តី ត្រូវថែទាំមើលភ្លើងធ្យូង ភ្លើងក្នុងចង្រ្កានកុំឲ្យរលត់ ។ ការនេះ ជាការទទួលខុសត្រូវរបស់បុរសជាស្វាមីដែលមិនត្រូវខ្វះបានឡើយ ព្រោះនៅពេលភរិយាឆ្លងទន្លេនេះហើយ ដែលប្តីត្រូវបញ្ជាក់ពីសេចក្តីស្រឡាញ់ចំពោះប្រពន្ធ ឪពុកចំពោះកូន ដែលទើបនឹងកើត និង ចំពោះគ្រួសារទាំងមូលផង ។

នៅពេលឆ្លងទន្លេនេះ យាយម៉បនឹងបំពេញការកិច្ចរបស់គាត់ដូចជា៖ ផ្សំថ្នាំលាយម្សៅ ឬ លាយរមៀតជាដើម ។ ម្តាយខ្ញុំ គាត់តែងពិសាស្រាវ៉ូម (Rhum) ជំនួសស្រាថ្នាំនៅពេលឆ្លងទន្លេម្តងៗ ។ បីថ្ងៃក្រោយមក គេអាចរើចង្រ្កានពីក្រោម

[15] Cf. Sorn Samnang, L'évolution de la société cambodgienne entre les deux guerres mondiales (1919-1939), op.cit, p. 396-399.

គ្រែចេញ ដែលខ្មែរយើងហៅថាទម្លាក់ចង្រ្កាន ។ ម្តាយត្រូវនៅបន្តសម្រាកលើគ្រែនេះតទៅទៀត មិនមានកំណត់ពេលឡើយ រហូតទាល់តែមានកម្លាំងពលំគ្រប់គ្រាន់ ។ ក្នុងរយៈពេលនេះ គេត្រូវប្រយ័ត្នប្រយែងយ៉ាងខ្លាំង ព្រោះសសៃនៅខ្ចីអាចឲ្យទាស់ នាំមកនូវជម្ងឺផ្សេងៗ ។

តាមទម្លាប់ខ្មែរយើង កូនកើតមកភ្លាម គេមិនទាន់ប្រញាប់ប្រញាល់ដាក់ឈ្មោះឲ្យកូននោះដូចនៅលោកខាងលិចនោះទេ ។ ប្រហែលជាដូនតាយើងយល់ឃើញថាត្រូវរង់ចាំមើលបន្តិចសិន ព្រោះអត្រាទារកស្លាប់ភ្លាមៗ ឬ ក្នុងអាយុពីមួយអាទិត្យទៅមួយខែ មានកម្រិតខ្ពស់ពេក ទើបគេមិនប្រញាប់រកឈ្មោះដាក់ឲ្យកូននៅពេលភ្លាមៗនោះ ។ ឪពុកខ្លះរង់ចាំពិភាក្សាជាមួយព្រះសង្ឃ លោកតាអាចារ្យ ឬ មេស្រុក មេភូមិ ដើម្បីរកឈ្មោះដាក់ឲ្យកូនឲ្យបានសមរម្យ ។ ការចុះសំបុត្រកំណើតរបស់ទារក ក៏មានលក្ខណៈដូចគ្នានេះដែរគឺ មិនប្រញាប់ប្រញាល់ប៉ុន្មានឡើយ ។ យូរៗទៅ ការចុះសំបុត្រកំណើត ក៏ស្រេចតែលើមន្ត្រីអត្រានុកូលដ្ឋានជាអ្នកសម្រេចថ្ងៃណា ខែណា ដែលសមស្រប ។ ក៏ប៉ុន្តែ ឪពុកម្តាយភាគច្រើន តែងចាំថ្ងៃខែកំណើតរបស់កូន ទៅតាមប្រតិទិនច័ន្ទគតិគឺ គេរាប់ឆ្នាំតាមឈ្មោះសត្វទាំង១២ និង តាមខែដែលយើងហៅថាខែខ្មែរ ដោយមានខ្នើត និង រនោចផង ។ ព្រោះទាំងនេះមានសារសំខាន់ណាស់ សម្រាប់ធ្វើការទស្សន៍ទាយតាមក្បួនហោរាសាស្ត្រអំពីជោគវាសនាអនាគតរបស់កូនម្នាក់ៗ ។

ចំពោះរូបខ្ញុំអ្វីៗដែលមានចុះក្នុងបញ្ជីជាតិរបស់ខ្ញុំ ក៏ខុសស្រឡះពីអ្វីៗដែលឪពុកម្តាយខ្ញុំបាននិយាយប្រាប់ផ្ទាល់មាត់តៗមក ។ ជាធម្មតាឪពុកម្តាយខ្ញុំ តាំងពីពួកយើងជាកូននៅតូចៗ តែងតែបង្រៀនឲ្យយើងស្គាល់ថ្ងៃខែ ឆ្នាំកំណើតមិនឲ្យភ្លេចឡើយ ។ ជារឿយៗ គាត់តែងសួរកូនឈ្មោះអ្វី? កើតឆ្នាំអ្វី? ខែអ្វី? ថ្ងៃអ្វី? ខ្ញុំកើតថ្ងៃអង្គារ ខែអស្សុជ ឆ្នាំខាល បើគិតឲ្យត្រូវពិតប្រាកដគឺ ថ្ងៃអង្គារទី ២៤ ខែ

តុលា ឆ្នាំ ១៩៥០ ។ ចំណែកនៅក្នុងបញ្ជីជាតិរបស់ខ្ញុំ ថ្ងៃខែកំណើតគឺ ថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ១៩៥០ ឯនោះទេ ។

តាមទម្លាប់ ពួកយើងមិនដែលប្រារព្ធពិធីបុណ្យខួបកំណើតទេ ក៏ប៉ុន្តែ ឪពុកម្តាយខ្ញុំច្រើនរៀបចំពិធីសូត្រមន្តជាច្រើនដងក្នុងមួយឆ្នាំៗ ។ ឪពុកខ្ញុំឧស្សាហ៍ អញ្ជើញហោរាឲ្យមកទស្សន៍ទាយ មើលជោគជតារាសីជាញឹកញាប់ ។ ហោរារបស់ ឪពុកខ្ញុំឈ្មោះ តាយី នៅភូមិព្រៃញៅ ។ តាយី តែងតែគន់គូរវាយលេខអត្ថៈ តើរាសី របស់គ្រួសាររយើងឡើង ឬ ចុះ តើពេលណាដែលយើងត្រូវនិមន្តព្រះសង្ឃមកសូត្រ មន្តស្រោចទឹក លើករាសី ឬ រំដោះគ្រោះ ។ តាយី បានក្លាយទៅជាមនុស្សទុកចិត្ត របស់គ្រួសាររយើង ហើយឪពុកម្តាយខ្ញុំក៏មានជំនឿលើគាត់យ៉ាងមុតមាំ ។ តាមការ ណែនាំរបស់គាត់ ឪពុកខ្ញុំតែងនិមន្តលោកតាវត្តរកាមកសូត្រមន្ត និង ស្រោចទឹក រាល់ៗដង ជាទម្លាប់រៀងៗមក ។

កុមារភាព បងប្អូន និង កិច្ចការរបស់ឪពុកខ្ញុំ

ខ្ញុំដឹងក្តីឡើងក្រោមការចិញ្ចឹមបីបាច់ថែរក្សារបស់ឪពុកម្តាយខ្ញុំ ។ ខ្ញុំមានបង ២ នាក់ទៀត បងបង្អស់ឈ្មោះ ឈឿន ហៅក្រៅថាបង "នាង" និង បងបន្ទាប់ឈ្មោះ ស៊ីនឿន ហៅបង "ផាត" ។ នៅក្នុងផ្ទះរបស់យើងៗនៅជាមួយជីដូនខ្ញុំគឺ លោក យាយ អ៊ុង គូ និង ម្តាយមីងខ្ញុំគឺ អ្នកមីងសាម៉ឺឌី ។ ខ្ញុំមិនបានស្គាល់លោកយាយ ហ៊ូ ឌិ ខាងឪពុកខ្ញុំទេ ដោយហេតុថាលោកយាយបានស្លាប់ជាយូរឆ្នាំទៅហើយ ។ ឪពុកម្តាយខ្ញុំមិនមានអ្នកបរទេះ ឬ អ្នកបម្រើឆ្វេងស្តាំដូចជីតាខ្ញុំទេ ។ ម្តាយខ្ញុំជាប់រវល់ការងារមេផ្ទះ ធ្វើម្ហូបអាហារ និង ថែទាំកូនចៅ ដោយមានជំនួយការពីបងជីដូន មួយខ្ញុំខ្លះ ដែលត្រូវជាក្មួយរបស់ឪពុកខ្ញុំ ។ កាលខ្ញុំនៅតូចៗនៅឡើយ បងស្រីដែល

នៅជួយមើលថែទាំខ្ញុំឈ្មោះ បងជ្រូក ។ បងជ្រូក មកស្នាក់នៅជាមួយពួកយើង ដើម្បីរៀនបញ្ចប់ថ្នាក់បឋមសិក្សា យកសញ្ញាប័ត្រទៅប្រឡងចូលធ្វើមន្ត្រីរាជការ ។ នៅពេលចេញពីសាលា បងជ្រូកតែងជួយធ្វើការម្តាយខ្ញុំ មើលថែទាំខ្ញុំ នាំខ្ញុំដើរលេងផង និង ច្រៀងបំពេរលួងកុំឲ្យខ្ញុំយំផង ។ ដោយសារខ្ញុំនៅតូចពេក កាលពេលនោះ ខ្ញុំពុំមានចាំទុកនូវអនុស្សាវរីយ៍ណាមួយជាមួយបងជ្រូកទេ ។ ក្រោយមកបងជ្រូក បានប្រឡងជាប់ជាឆ្មបរដ្ឋ ។ ខ្ញុំឮថានៅសម័យសង្គមបងជ្រូក បានប្តីជាសហគ្រិន ហើយមានជីវភាពធូរធារ រហូតមានផ្ទះថ្មមួយល្វែងធំ ស្ថិតនៅតាមមហាវិថីម៉ៅសេទុងត្រង់ម្តុំក្បែរផ្សារដើមគបច្ចុប្បន្ន ។ បងជ្រូក ប្រហែលត្រូវបាត់បង់ជីវិតក្នុងសម័យប៉ុល ពត ព្រោះរហូតដល់សព្វថ្ងៃនេះ ខ្ញុំមិនដែលបានទទួលដំណឹងអ្វីពីគាត់សោះឡើយ ។

ឪពុកខ្ញុំជាប់រវល់បំពេញការងារប្រចាំការិយាល័យរបស់គាត់នៅឯផ្ទះផងនិងនៅទីរួមខេត្តព្រៃវែង ដើម្បីចូលរួមកាត់ក្តីនៅសាលាដំបូងផង ។ ដូច្នេះ ក្នុងមួយខែៗ ឪពុកខ្ញុំមិនសូវនៅផ្ទះទេ ។ កាលសម័យនោះ ខេត្តព្រៃវែងចែកជា ១០ ស្រុក ក្នុង ១០ ស្រុកនោះ មានអាជ្ញាសាលាតែ ៣ នាក់ប៉ុណ្ណោះ ។ ឪពុកខ្ញុំត្រូវទទួលចាត់ការ ៣ ស្រុកគឺ៖ ស្រុកពារាំង ស្រុកស៊ីធរកណ្តាល និង ស្រុកកញ្ជ្រៀច ។ មុខងារអាជ្ញាសាលា មិនមានបៀវត្សប្រចាំខែទេ តែទទួលកម្រៃក្នុងការសម្រេចសាលក្រម ឬ ប្រគល់ដីការកោះ ។ ក្នុងសម័យនោះ អ្នកស្រុកផ្តើមធ្វើដំណើរតាមទោចក្រយានយន្តជាបណ្តើរៗហើយ ។ ឪពុកខ្ញុំពុំមានលទ្ធភាពទិញម៉ូតូថ្មីមកប្រើទេ ។ គាត់អាចទិញត្រឹមតែម៉ូតូចាស់មធ្យម ឬ ជំនំៗ ។ ដោយទំហំទឹកដីទាំង ៣ ស្រុកធំទូលាយ ការធ្វើដំណើរតាមម៉ូតូរបស់ឪពុកខ្ញុំ ក៏មានការលំបាក ព្រោះម៉ូតូចាស់នោះខូចញឹកញាប់ពេក ។ ពេលខ្លះឪពុកខ្ញុំត្រូវបណ្តើរម៉ូតូរាប់គីឡូម៉ែត្រ ទម្រាំរកជាងជួសជុលមុននឹងអាចបន្តដំណើរទៅមុខទៀតបាន ។ ខ្ញុំអាណិតឪពុកខ្ញុំណាស់ ព្រោះ

គាត់មិនដែលបានប្រើម៉ូតូថ្មីសោះ ក្នុងមួយជីវិតរបស់គាត់ ។ ម៉ូតូដែលគាត់ពេញចិត្តជាងគេគឺ ម៉ូតូបារាំងម៉ាក "ម៉ូប៊ីឡែត" (Mobilette) ។ ចាប់ពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៦០ មក ម៉ូតូជប៉ុនម៉ាកហុងដា ស៊ុយហ្សុយគី ចាប់ផ្តើមលុកចូលមកដល់ភូមិយើងជាបន្តបន្ទាប់ តែឪពុកខ្ញុំនៅតែប្រើម៉ូតូម៉ូប៊ីឡែតដដែល ។

ដើម្បីជួយធ្វើការរបស់គាត់ ឪពុកខ្ញុំជួលជំនួយការម្នាក់ ដោយឲ្យប្រាក់ប្រចាំថ្ងៃ ។ ជំនួយការនោះ ចេះត្រឹមតែសរសេរ ឬ អានអក្សរខ្មែរតែប៉ុណ្ណោះ និង គ្មានមុខការអ្វីទៀតក្រៅពីប្រគល់ដីកាកោះ ឬ សេចក្តីជូនដំណឹងដល់កូនក្តី ទាំងដើមចោទទាំងចុងចម្លើយ ។ នៅពេលចេញទៅសម្រេចសាលក្រមរបស់តុលាការ ឪពុកខ្ញុំតែងសុំអន្តរាគមន៍ជានិច្ចពីអាជ្ញាធរមូលដ្ឋាន ជាពិសេស ពីសមត្ថកិច្ចតម្រួត ព្រោះការងារសម្រេចសាលក្រមនោះគឺ ត្រូវរឹបអូសទ្រព្យសម្បត្តិ ផ្ទះសម្បែង ឬ គោក្របីរបស់អ្នកចាញ់ យកទៅឲ្យអ្នកឈ្នះ ឬ យកទៅលក់ឡាយឡុងយកប្រាក់ទៅឲ្យអ្នកឈ្នះតាមសេចក្តីសំរេចរបស់តុលាការ ។ ការងារបែបនេះអាចមានគ្រោះថ្នាក់ណាស់ ព្រោះអ្នកចាញ់អាចមិនព្រមឲ្យរឹបអូស ហើយក៏អាចតវ៉ៃតាមអំពើហឹង្សាក៏មាន ។ ដោយសារទំនាក់ទំនងជាប់ជានិច្ចជាមួយអាជ្ញាធរមូលដ្ឋាន ជាពិសេស ជាមួយចៅហ្វាយស្រុក ឪពុកខ្ញុំក៏ក្លាយជាមន្ត្រីមានមុខមានមាត់ប្រចាំស្រុកផងដែរ ។

នៅឯផ្ទះ ក្នុងការិយាល័យរបស់គាត់ ឪពុកខ្ញុំធ្វើការផ្តល់យោបល់ខាងផ្លូវច្បាប់ដូចមេធាវីដែរ ។ ជួនកាលគាត់ជួយធ្វើពាក្យបណ្តឹងដល់គូក្តីដែលមានជម្លោះត្រូវឡើងតុលាការ ។ពាក្យមួយច្បាប់តម្លៃ ១០០ រៀល ឬ ប្រហែល ៣ ដុល្លារសហរដ្ឋអាមេរិក ។ ឪពុកខ្ញុំតែងទទួលភ្ញៀវនៅក្នុងបន្ទប់ធំក្នុងផ្ទះ ។ នៅខាងក្រោយតុធំដែលយើងនាំគ្នាហៅថាសាឡុង មានកញ្ចក់ឆ្លុះមុខយ៉ាងធំ ដែលមានក្របធ្វើពីឈើឆ្លាក់ក្បាច់យ៉ាងល្អប្រណិត អមដោយរូបក្បាលទន្សោងពីរដែលមានស្នែងវែង ព្យួរជាប់ខាងលើខ្ពស់ផុតក្បាលមនុស្សចាស់ ។ ខេត្តព្រៃវែងសម័យនោះ ជាខេត្តដែលល្បីថា

មានក្តីក្តាំច្រើន ។ អតិថិជនរបស់ឪពុកខ្ញុំ ភាគច្រើនជាអ្នកស្រែចម្ការ ។ ពួកគាត់ជិះកង់កាត់ពីតំបន់នានានៃស្រុកទាំង ៣ មករកឪពុកខ្ញុំ ដើម្បីឲ្យជួយសម្រេចសាលក្រមតុលាការដែលសម្រេចឲ្យឈ្នះ ឬ មកពិភាក្សាច្បាប់ដើម្បីធ្វើពាក្យប្តឹង ឬ រកវិធីការពារខ្លួន ចំពោះពាក្យបណ្តឹងរបស់អ្នកដទៃជាដើម ។

ភាគច្រើន នៅពេលធ្វើដំណើរតាមរទេះកង់ អ្នកស្រុកទាំងនោះ ស្លៀកតែក្រមាប៉ុណ្ណោះទេ ឯខោដែលជាទូទៅជាខោឡាញ់ ពួកគាត់ចងនៅនឹងដៃកង់បង្ការកុំឲ្យទទឹក ឬ ប្រឡាក់ នៅពេលឆ្លងកាត់ទឹក ភក់ ដីហុយតាមផ្លូវជាដើម ។ ពេលមកដល់មុខផ្ទះខ្ញុំ ពួកគាត់ផ្អែកកង់ទល់នឹងទ្វាររបង រួចរលាស់ខោឡាញ់ ផ្លាស់ក្រមា ស្លៀកខោឡាញ់នោះ និង សម្អាតរាងកាយឲ្យបានសមរម្យមុននឹងចូលមកជួបឪពុកខ្ញុំ ។ នេះជាសុជីវធម៌ ឬ ការគោរពដែលអ្នកស្រែតូចតាចសម្តែងឡើង ចំពោះមន្ត្រីរាជការដែលពួកគាត់ចាត់ទុកជាអ្នកធំ ។ ចំពោះអ្នកធំ អ្នកស្រុកប្រើពាក្យ ព្រះតេជគុណ និង ពាក្យខ្ញុំបាទ ឬ បាទទានជាដើម ។ល។

នៅពេលទំនេរពីការងារ នៅផ្ទះ ឪពុកខ្ញុំដាំដំណាំដូចជា ដូង ស្វាយ ខ្នុរ ជាដើម ។ ពួកយើងមិនមានទឹកម៉ាស៊ីនស្អាតសម្រាប់ទទួលទាន និង ប្រើប្រាស់ស្រោចដំណាំទេ ។ យើងប្រើទឹកស្រះដែលស្ថិតប្រមាណ ៣០ ម៉ែត្រពីផ្ទះ។ ក្រៅពីស្រះ យើងប្រើពាងធំៗរក្សាទុកទឹកភ្លៀងសម្រាប់ទទួលទាន ។ នៅពេលអស់ទឹកភ្លៀង ឪពុកម្តាយខ្ញុំជួលកម្មករឲ្យរែកទឹកពីអណ្តូងផ្ទះអ្នកជិតខាងចម្ងាយប្រមាណ ១០០ ម៉ែត្រមកប្រើប្រាស់ ។ ក្រោយមកខ្ញុំដឹងថាពួកកម្មករដែលយើងហៅថាគូលីមិនចង់មកស៊ីឈ្នួលរែកទឹកឲ្យពួកយើងទេ ដោយអ្នកទាំងនោះខ្លាចគេយល់ច្រឡំថាពួកគាត់ជាអ្នកទោស ។ ព្រោះកាលសម័យជីតាខ្ញុំ គាត់ច្រើនប្រើអ្នកទោសឲ្យជំរះស្មៅ ឬ រែកទឹកដាក់ពាងជាញឹកញាប់ ។

ថ្ងៃចូលរៀនលើកដំបូង និង តម្លៃគ្រូ

កាលខ្ញុំអាយុបាន ៦ ឆ្នាំ ខ្ញុំប្រើល្បិចដើម្បីឲ្យឆាប់បានទៅរៀនមុនពេលគ្រប់អាយុ ។ ក្នុងសម័យនោះ ពុំទាន់មានថ្នាក់មត្តេយ្យនៅឡើយទេ ។ កូនក្មេងទាល់តែអាយុ ៧ ឆ្នាំ ទើបឪពុកម្តាយឲ្យទៅរៀន ។ នៅពេលចូលរៀនលើកដំបូងម្តងៗ កុមារខ្លះ ខ្លាចសាលា យំស្រែកមិនចង់ចូលរៀន ។ ឪពុកម្តាយខ្ញុំ ប្រគល់ការៈឲ្យម្តាយមីងខ្ញុំគឺ អ្នកមីងសាម៉ឺឌី ជាអ្នកសម្រេចតើពេលណាខ្ញុំអាចចូលរៀនបាន ព្រោះខ្ញុំចេះតែទារទៅសាលារៀន ។ កាលនោះ អ្នកមីងសាម៉ឺឌី ជាអ្នកគ្រូ បង្រៀនថ្នាក់ឧត្តមដ្ឋាន[16] នៅសាលាបឋមសិក្សាស្នាយពល ។ អ្នកមីងជាអ្នកគ្រូក្រមុំដែលមានរូបសម្ផស្សស្អាតជាងគេនៅក្នុងភូមិ ។ តាមពិត ឪពុកម្តាយខ្ញុំចង់ឲ្យខ្ញុំទៅរៀនដែរ តែចង់ឲ្យខ្ញុំរង់ចាំដល់អាយុគ្រប់ ៧ ឆ្នាំសិន ។

ថ្ងៃមួយ នៅពេលម្តាយមីងខ្ញុំកំពុងអង្គុយបោកខោអាវ ខ្ញុំរត់ទៅជិតគាត់ហើយស្រែថា "ហេ ហេ អ្នកមីងឥឡូវខ្ញុំលូកដៃដល់ត្រចៀកហើយ" ។ អ្នកមីងអស់សំណើច ព្រោះតាមធម្មតានៅជំនាន់នោះ ក្មេងៗអាចចាត់ទុកថាធំល្មម អាចទៅរៀនបាន នៅពេលដែលពួកគេអាចលើកដៃស្តាំដាក់ពីលើក្បាល ហើយលូកទៅដល់ត្រចៀកខាងឆ្វេងបាន ។ ក៏ប៉ុន្តែ ខ្ញុំមិនធ្វើយ៉ាងដូច្នោះទេ ខ្ញុំលូកដៃស្តាំពីក្រោយក្បាលទៅប៉ះត្រចៀកឆ្វេងតែម្តង ដោយមិនដាក់ដៃលើក្បាលដូចអ្នកឯទៀតទេ ។ ម្តាយមីងខ្ញុំ ឲ្យខ្ញុំធ្វើកាយវិការនេះម្តងទៀត ហើយនៅទីបំផុតគាត់សន្យាថា នាំខ្ញុំទៅសាលារៀននៅព្រឹកថ្ងៃស្អែក ។ ព្រឹកឡើង អ្នកមីងឲ្យខ្ញុំឡើងជិះកង់ នៅខាងក្រោយ ហើយគាត់ក៏ឌុបយកខ្ញុំទៅរៀន ។ ខ្ញុំមានក្តីរំភើបជាអនេក ដោយបានទៅរៀនផង

[16] ថ្នាក់ឧត្តមដ្ឋាន ជាថ្នាក់បញ្ចប់បឋមសិក្សា និង ត្រូវប្រឡងចូលរៀនអនុវិទ្យាល័យ ។

និង បានជិះកង់ជាមួយអ្នកគ្រូក្រមុំ ដែលជាបវរកញ្ញាមួយរូបប្រចាំភូមិរបស់យើងផង ។

ខ្ញុំមានការសប្បាយរីករាយជាខ្លាំង ក្នុងការសិក្សារបស់ខ្ញុំនៅសាលាបឋមសិក្សាស្នាយពល ។ នៅពេលយើងរៀនដល់ថ្នាក់មជ្ឈិមដ្ឋានទី១(ថ្នាក់ទី៤ថ្មី) យើងចាប់រៀនភាសាបារាំង ។ នៅពេលចូលរៀនអនុវិទ្យាល័យ មុខវិជ្ជាទាំងអស់លើកលែងតែមុខវិជ្ជាខ្មែរចេញ សុទ្ធតែជាភាសាបារាំង ។ ចេះភាសាបារាំង គេចាត់ទុកជាអ្នកចេះដឹង និង ជាបញ្ញវន្ត ។ ខ្មែរយើងមួយចំនួនច្រើននិយាយខ្មែរលាយបារាំងដើម្បីបង្ហាញថា ជាអ្នកចេះដឹង ។ គួរកត់សម្គាល់ថានៅជំនាន់នោះ ប្រពៃណីខ្មែរយើងឲ្យតម្លៃខ្លាំងណាស់ដល់លោកគ្រូអ្នកគ្រូ ។ កូនសិស្សមានការគោរពកោតខ្លាចគ្រូជាទីបំផុត ។ នៅក្នុងសង្គម គ្រូត្រូវបានចាត់ទុកជាឪពុកម្តាយទីពីរ បន្ទាប់ពីឪពុកម្តាយបង្កើត ។ តាមឋានានុក្រមនៃការគោរព គេគោរពព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ មាតា បិតា បន្ទាប់មក គេគោរពគ្រូបាធ្យាយ ។ សូម្បីតែក្នុងសិល្បៈប្រពៃណីមួយចំនួន ក៏មានការគោរពគ្រូមុននឹងសម្តែងដែរ ។ ដោយសារប្រពៃណីគោរពគ្រូយ៉ាងនេះ ធម្មតាការងាររបស់អ្នកគ្រូ លោកគ្រូ មិនមានការលំបាកឡើយ ។ កូនសិស្សខ្លាចគ្រូ គោរពគ្រូ និង ស្តាប់គ្រូខ្លាំងណាស់ ។ ក៏ប៉ុន្តែនៅមានលោកគ្រូអ្នកគ្រូខ្លះ ប្រើអំពើហឹង្សា លើសិស្សទៀតផង ។ ក្នុងថ្នាក់រៀនខ្លះ លោកគ្រូកាចត្រៀមរំពាត់ផ្តៅពីរ ឬ បីដើម ។ លោកគ្រូដែលកាចខ្លាំង ប្រើដន្ទល់បង្ហុច វាយលើសិស្សណាដែលខ្ជិលច្រអូសមិន ចេះមេរៀន ឬ មានអាកប្បកិរិយាមិនគប្បី ។ តែទោះបីជាលោកគ្រូ អ្នកគ្រូកាចសម្បើមយ៉ាងណាក៏ដោយ ក៏កូនសិស្សនៅតែដឹងគុណលោកគ្រូ អ្នកគ្រូ អស់មួយជីវិត ។

មួយឆ្នាំក្រោយមក ម្តាយមីងរបស់ខ្ញុំ ត្រូវរៀបការជាមួយមន្ត្រីគយម្នាក់ឈ្មោះ អ៊ុក ថន ដែលមានស្រុកកំណើតនៅភូមិស្នាយពលក្រោម ។ ខ្ញុំក៏មិនបាន

ដឹងថាអ្នកមីង និង លោកពូមានទំនាក់ទំនងគ្នាតាំងពីពេលណា និង យ៉ាងដូចម្តេច ទេ ព្រោះម្នាក់នៅបង្រៀនឯស្នាយពល និង ម្នាក់ទៀតកំពុងបំពេញការកិច្ចនៅឯទីក្រុងឯណោះ ។ បន្ទាប់ពីរៀបការភ្លាមមក ម្តាយមីងខ្ញុំបានរើទៅនៅជាមួយស្វាមីរបស់គាត់ឯក្រុងភ្នំពេញ ។

ចាប់ពីពេលដែលឪពុកម្តាយខ្ញុំរៀបអាពាហ៍ពិពាហ៍មក ប្រពៃណីរបស់អ្នកស្រុកយើង មានការប្រែប្រួលច្រើន ។ ឥឡូវ គេមិនចាំបាច់ឲ្យកូនកម្លោះមកនៅបំរើគ្រួសារខាងស្រីជាមុននោះទៀតទេ ។ បើត្រូវរ៉ូវគ្នា គេអាចរៀបចំពិធីអាពាហ៍ពិពាហ៍បាន ។ ក៏ប៉ុន្តែ ជាការចាំបាច់គេត្រូវរកគ្រូហោរាគន់គូរ ត្រួតពិនិត្យ ខែ ឆ្នាំ តើបើបានគ្នាជាគូស្រករអាចល្អ ឬ អាក្រក់? ពិសេសទៅទៀត គេរកលោកអាចារ្យជ្រើសរើសពេលវេលាសម្រាប់រៀបមង្គលការ ដើម្បីឲ្យគូស្វាមី មានសិរីសួស្តី និង ជោគជ័យក្នុងជីវិតទៅអនាគត ។ ទោះបីប្រពៃណីរបស់យើង មានការវិវឌ្ឍខ្លះក៏ដោយ ក៏គេនៅរៀបចំពិធីអាពាហ៍ពិពាហ៍ក្នុងរយៈពេលបីថ្ងៃ បីយប់ដូចពីមុនដែរ ។

ប៉ុន្មានថ្ងៃមុនពេលពិធីមង្គលការរបស់ម្តាយមីងខ្ញុំចាប់ផ្តើម ម្នាក់ៗវល់ញាប់ដៃ ។ ប្រុសៗនាំគ្នាសង់រោង ឯស្ត្រីៗនាំគ្នាវេចនំ មាននំអន្សម នំគម នំបត់ តាមទម្លាប់ ។ គេសង់រោងធំសម្រាប់ពិធីជប់លៀង និង រោងតូចមួយទៀតជារោងសម្រាប់ទទួលកូនកម្លោះ ដែលត្រូវស្នាក់នៅក្នុងរយៈពេលនៃពិធីទាំងមូល និងដែលជាទីកន្លែងសម្រាប់អ្នកភ្លេង និង អ្នកចំរៀង សម្តែងសិល្បៈប្រពៃណីផង ។ នៅខាងក្រោយផ្ទះ ពួកកម្មករនាំគ្នាជីករណ្តៅធ្វើចង្ក្រានខ្ទះត្នោត ទុកសម្រាប់ចំអិនម្ហូបអាហារ ដែលគេត្រូវការផ្តត់ផ្តង់ដល់ភ្ញៀវក្នុងរយៈពេលបីថ្ងៃ បីយប់នៃពិធីរួមទាំងពិធីជប់លៀងធំនៅថ្ងៃបង្ហើយផង ។ ឃើញគេធ្វើរោងបាយ និង ជីករណ្តៅយ៉ាងនេះ កាលនោះខ្ញុំមានអាយុទើបតែបាន ៧ ឆ្នាំ ខ្ញុំនឹកឆ្ងល់ក្នុងចិត្តថា ហេតុដូចម្តេចបានជាគ្មានអ្នកណាបើកហាងដែលមានបន្ទប់ធំទូលាយ មានតុកៅអីស្រេច ត្រៀមជួល

ក្នុងពេលមង្គលការ ដោយមិនចាំបាច់ធ្វើរោង ឬ ជីកដីធ្វើអ្វី?កាលនោះ ខ្ញុំអត់ដឹងថា នៅទីក្រុងភ្នំពេញ គេមានសណ្ឋាគារ ឬ ភោជនីយដ្ឋានធំៗ ដែលគេអាចជួលកន្លែងសម្រាប់រៀបចំពិធីផ្សេងៗរួចទៅហើយ ។

សកម្មភាពក្រៅថ្នាក់រៀន

ម្តាយមីងយើងបានឃ្លាតពីយើងទៅ តែផ្ទះយើងក៏ទទួលបានអ្នកចំណូលថ្មីៗទៀតដែរ ។ គ្រួសារយើង ចេះតែមានចំនួនសមាជិកកើនឡើងៗពីមួយឆ្នាំទៅមួយឆ្នាំ ។ មុនពេលខ្ញុំចេញទៅរៀននៅភ្នំពេញនៅឆ្នាំ ១៩៦៤ ខ្ញុំមានប្អូនស្រីពីរនាក់ គឺ វន្នី កើតឆ្នាំ ១៩៥២ ស៊ីថាន ឆ្នាំ ១៩៥៤ និង ប្អូនប្រុសបួននាក់គឺ៖ វណ្ណៈ កើតឆ្នាំ ១៩៥៦ ណារ៉ែន ឆ្នាំ ១៩៥៩ វុធធៀន ឆ្នាំ ១៩៦២ និង វុធធឿន ឆ្នាំ ១៩៦៤ ។ ប្អូនប្រុសពីរនាក់ទៀតគឺ វុទ្ធា កើតនៅឆ្នាំ ១៩៦៦ និង សោភា ឆ្នាំ ១៩៧០ ។

កាលរស់នៅឯភូមិស្នាយពលនោះ ពួកយើងមានចិញ្ចឹមសត្វដូចជា៖ មាន់ ទា ឆ្កែ និង ឆ្មាផង ។ នៅឆ្នាំខ្លះ ឪពុកខ្ញុំ ចិញ្ចឹមគោ ឬ សេះ ដើម្បីយកលាមកមកធ្វើជី សម្រាប់ដំណាំដាំដុះរបស់គាត់ ។ នៅខាងក្រោយផ្ទះ យើងពុំមានធ្វើរបងទេ តែមានស្នាមភ្លោះ និង ព្រៃរបោះតូចៗរួមផ្សំនឹងគុម្ពឫស្សីដុះព័ទ្ធជុំជិត ។ ជាមួយនោះ ក៏មានដើមត្នោតយ៉ាងខ្ពស់លលៃ ដុះលេចទៅលើយ៉ាងខ្ពស់ចំនួនពីរ ឬ បីដើមទៀត ។ ពួកយើងឧស្សាហ៍ទៅរើសត្នោតទុំដែលជ្រុះមកដី ដើម្បីទុកឲ្យម្តាយយើងធ្វើនំ (នំត្នោត) ឬ ធ្វើចាហួយជាដើម ។ នៅចុងត្នោតដែលខ្ពស់ជាងគេ មានសត្វក្រសារមួយគូកាច់សំបុកនៅទីនោះ ។

ព្រឹកមួយ នៅពេលខ្ញុំទៅរើសគ្នោតទុំ ខ្ញុំឃើញកូនសត្វក្រសារស្រែកខ្សាវៗ ដែលនៅពីចម្ងាយយើងពុំអាចឮសម្រែកបានឡើយ ។ ខ្ញុំចូលទៅរើសផ្លែគ្នោតទុំ និង យកកូនសត្វក្រសារមកចិញ្ចឹម ។ ពេលកូនក្រសារកាន់តែធំបន្តិចម្តងៗ គេក៏ក្លាយ ទៅជាមិត្តសំឡាញ់ជិតស្និទ្ធជាមួយសត្វឯទៀត ជាពិសេស ជាមួយសត្វឆ្កែរបស់ យើង ។ រាល់ពេលខ្ញុំត្រឡប់មកពីសាលារៀនវិញ ទាំងឆ្កែ ទាំងក្រសាររត់មកទទួល ខ្ញុំ ។ ឆ្កែលោតប្រតោងលិទ្ធដៃលិទ្ធជើង ឯក្រសារក៏ទទះស្លាប ស្រែកកកេកកកាក រត់មកជិត ហើយយកចំពុះមកប្រចិកដៃប្រចិកជើងខ្ញុំយ៉ាងសប្បាយរីករាយ ។ កូន សត្វក្រសាររស់នៅជាមួយពួកយើង រហូតដល់ពេលដែលគេអាចហើរដោយខ្លួនឯង បាន គេក៏ហើរទៅរស់នៅជាមួយហ្វូងក្រសារឯទៀតដោយសេរី និង ដោយសុខ សាន្ត ។

ក្នុងរយៈពេលនោះ យើងក៏មានចិញ្ចឹមសត្វស្វាមួយក្បាលដែរ ។ នៅរាល់ ពេលព្រឹក ជាមួយស្នូរសម្រែកសត្វជ្រូក ដែលស្រែកថ្ងូរមិនឈប់នោះ សត្វស្វាក៏ជួយ ដាស់យើងឲ្យភ្ញាក់ពីដំណេកទាំងពេលព្រឹកទៀបភ្លឺដែរ ។ យើងមិនបានចិញ្ចឹមសត្វ ស្វាទុកក្នុងទ្រុងទេគឺ យើងលែងវាឲ្យមានសេរីភាពនៅពេលថ្ងៃ ។ នៅពេលល្ងាច ទើបយើងចងវាទុក ។ មុននឹងយើងបិទទ្វារផ្ទះ និង ចូលនិទ្រានៅខាងក្នុង យើងចង ស្វាភ្ជាប់ជាមួយសសរបង្គោលអង្រឹងដែលយើងដាក់នៅយ៉ាខាងមុខ សម្រាប់មើល ទេសភាពនៅមុខផ្ទះ ។ នៅពេលជិតភ្លឺ សត្វស្វាតែងលោតពីសសរមួយ ទៅសសរ មួយ អង្រែនអង្រឹងមិនឈប់ដែលយើងពិបាកនឹងទ្រាំ ។ សត្វស្វារស់នៅជាមួយសត្វ ឯទៀតដោយសុខស្រួលដោយគ្មានបញ្ហាអ្វីឡើយ ។ ស្វានោះចូលចិត្តប្រឡែងលេង ជាមួយឆ្កែ ។

បន្ទាប់ពីពេលបាយ នៅពេលដែលចាស់ៗសម្រាន្តថ្ងៃ ស្វាសម្ងំរកចៃ ឬ ជួយសម្អាតរោមឆ្កែដែលនៅជិតខ្លួន ។ ថ្ងៃមួយ មេឆ្កែរបស់យើងកើតកូនប្រាំ ។ ស្វា

ស្រឡាញ់ចូលចិត្តកូនឆ្កែណាស់ ។ វាប្រឡែងលេងជាមួយ និង ថ្នាក់ថ្នមកូនឆ្កែជានិច្ច ។ ក្រោយមកប៉ុន្មានថ្ងៃ នៅពេលដែលខ្ញុំកំពុងសម្លឹងអានសៀវភៅ និង ទន្ទេញមេរៀន ខ្ញុំឮសំឡេងឆ្កែព្រូសឥតឈប់ដែលធ្វើឲ្យខ្ញុំបែកអារម្មណ៍ ។ សម្លឹងតាមបង្អួចខ្ញុំឃើញឆ្កែរត់ជុំវិញដើមអំពិលដែលនៅក្បែរផ្ទះ វាព្រូសផង វាប៉ុនប៉ងឡើងដើមអំពិលផង ។ នៅពេលខ្ញុំមកដល់ ឆ្កែនៅតែព្រូស វាព្រូសឡើងលើ ដោយយកជើងកន្ត្រោងឡើងតាមគល់អំពិល ។ នៅឯលើមែកអំពិល ខ្ញុំឃើញស្វាអង្គុយយ៉ាងស្រួល ដៃវាម្ខាងកាន់កូនឆ្កែ ដៃម្ខាងទៀតរកចៃឲ្យកូនឆ្កែនោះ ។ កូនឆ្កែស្រែកបន្តិចបន្តួចហាក់ដូចជាបានទទួលការថ្នាក់ថ្នមដែលវាពេញចិត្ត ។ ទោះជាខ្ញុំខំស្រែកហៅយ៉ាងណាក៏ដោយ ក៏ស្វាពុំព្រមយកកូនឆ្កែចុះមកដីវិញដែរ ។ ពេលឮខ្ញុំហៅ ស្វាធ្វើមាត់ជីបអូចៗ ញាក់មុខញាក់មាត់តែប៉ុណ្ណោះ ។ នៅទីបំផុត ខ្ញុំក៏រត់ទៅយកចេកទុំមួយផ្លែមកគ្រវីឲ្យស្វាជាសញ្ញាថាចុះមកដីវានឹងបានរង្វាន់ ។ ស្វាក៏បីកូនឆ្កែចុះមកដីវិញយ៉ាងស្រួល ។ ប៉ុន្មានខែក្រោយមកយើងក៏យកស្វាទៅប្រគេនលោក ព្រោះយើងជឿថាស្វានោះនឹងបានទទួលសេរីភាព និង អាចរស់នៅដោយសុខសាន្តនៅក្នុងព្រៃក្បែរវត្តជាពុំខាន ។

កាលនៅវ័យកុមារខ្ញុំចូលចិត្តលេងល្បែងធ្វើគ្រូ ធ្វើជាសង្ឃ ឬ ជួនកាលធ្វើស្តេចជាដើម ។ ជាពិសេស លេងល្បែងអ្វីដែលក្មេងៗឯទៀតត្រូវគោរពកោតខ្លាច ។ ជួនកាលខ្ញុំរៀនធ្វើត្រាប់តាមសម្តេចឪ (គឺព្រះករុណាសម្តេចព្រះ នរោត្តម សីហនុ កាលព្រះអង្គនៅកាន់អំណាចជាព្រះប្រមុខរដ្ឋ) ។ ខ្ញុំនៅចាំថាសម្តេចយាងមកភូមិស្នាយពលពីរដងដែរ លើកចុងក្រោយនៅឆ្នាំ ១៩៦៣ ។ ជារៀងរាល់ថ្ងៃ យើងតែងឮតាមវិទ្យុជាតិនូវព្រះសូរសៀងរបស់ព្រះអង្គដែលទ្រង់ថ្លែងជាញឹកញាប់ ។ សម័យនោះ ពួកយើងគោរពសម្តេចឪ ដូចយើងគោរពព្រះពុទ្ធអង្គយ៉ាងដូច្នោះដែរ ។

ខ្ញុំក៏ធ្លាប់លេងល្បែងដូចជាលេងបញ្ជាំងកុនជាដើម ។ ពេលនោះ យើងគ្មាន

ភ្លើងអគ្គិសនី និង គ្មានម៉ាស៊ីនបញ្ចាំងទេ ។ ខ្ញុំយកកញ្ចក់ឆ្លុះមុខមកជិតពន្លឺភ្លើងទៀន ធ្វើឲ្យកញ្ចក់ជះពន្លឺទៀនទៅទីងងឹតខាងមុខ លេចចេញជាពន្លឺការ៉ែបួនជ្រុង ឬ មូលទៅតាមរាងរបស់កញ្ចក់ ។ បើយើងកាត់ក្រដាសធ្វើជារាងសត្វអ្វីមួយ ឬ រាងមនុស្ស ដាក់លើកញ្ចក់ៗក៏បញ្ចាំងស្រមោលខ្មៅនៃរាងសត្វ ឬ រាងមនុស្សនោះនៅក្នុងពន្លឺការ៉ែ ឬ មូលទៅទីងងឹត ។ ខ្ញុំអាចយោល ឬ បង្វិលរូបក្រដាសធ្វើឲ្យមានចលនាចុះឡើងជាមួយការធ្វើអត្ថាធិប្បាយកំប្លុកកំប្លែង តាមការនឹកឃើញរបស់ខ្ញុំ ។

នៅឆ្នាំដំបូងនៃទសវត្សរ៍ឆ្នាំ ១៩៦០ ភូមិយើងចាប់ផ្តើមមានអគ្គិសនីជាបណ្តើរៗហើយ ។ ថៅកែម្នាក់បានដំឡើងម៉ាស៊ីនភ្លើងដែលមានកម្លាំងមិនលើសពីម្ភៃគីឡូវ៉ាត់ ដើម្បីឲ្យអ្នកស្រុកជាវភ្លើងប្រើ ចាប់ពីម៉ោង ៥ ទៅ ៦ ព្រឹក និង ពីម៉ោង ៦ ល្ងាចទៅម៉ោង ១០ យប់ ។ អំពូលម៉ែត្រមួយប្រវែង០,៣០ម៉ែត្រ ជាវថ្លៃ ៣០ រៀល ឬ ១ ដុល្លារស.រ.អាក្នុងមួយខែ ។ ផ្ទះយើងជាវតែអំពូលបីតឹកមួយសម្រាប់ប្រើជាប្រចាំតែប៉ុណ្ណោះ ។ យើងដាក់អំពូលឲ្យខ្ពស់ផុតពីជញ្ជាំងបាំងចែកបន្ទប់ដើម្បីឲ្យពន្លឺអាចជះចូលទៅគ្រប់បន្ទប់ ព្រោះផ្ទះយើងពុំមានពិដានទេ ។ ក៏ប៉ុន្តែ ពន្លឺពុំអាចបំភ្លឺឲ្យច្បាស់នៅគ្រប់បន្ទប់ឡើយ ។ នៅពេលយប់ បើត្រូវការធ្វើកិច្ចការដែលគ្រូដាក់ឲ្យធ្វើ ខ្ញុំត្រូវមកធ្វើកិច្ចការនោះនៅការិយាល័យរបស់ឪពុកខ្ញុំ ដូច្នេះជួនកាលខ្ញុំត្រូវលង់លក់នៅក្នុងការិយាល័យនោះក៏មាន ។

ដើម្បីចៀសវាងផលវិបាកបែបនេះ ខ្ញុំក៏លបតភ្លើងដោយខ្លួនឯង ។ កាលនោះ ខ្ញុំមិនទាន់យល់ដឹងគ្រោះថ្នាក់អគ្គិសនីឆក់យ៉ាងដូចម្តេចនៅឡើយទេ ។ ខ្ញុំទិញអំពូលមូលមួយគ្រាប់ពីផ្ទះចិននៅក្បែរផ្សារ ហើយក៏តខ្សែលួសធម្មតា ព្រោះមិនអាចរកខ្សែភ្លើងធម្មតាបាន ។ ខ្ញុំតអំពូលដាក់ប្រើនៅក្នុងបន្ទប់ខ្ញុំយ៉ាងស្រួល ដោយមិនចាំបាច់ចំណាយប្រាក់ជាវថ្លៃអគ្គិសនីដូចអ្នកឯទៀតឡើយ ។ អស់ជាច្រើនសប្តាហ៍ យើងសប្បាយនឹងប្រើភ្លើងបន្តែមដោយមិនបាច់បង់ថ្លៃ ។ ក៏ប៉ុន្តែ ថ្ងៃមួយ

ជាចៃដន្យ ខ្ញុំប្រទះឃើញខ្សែលួសត្រង់តំណតពីខ្សែភ្លើងធំ មានពណ៌ក្រហមដូចរងើកភ្លើង ។ ខ្ញុំស្ទុះទៅជិតខ្សែលួសតំណក៏ឃើញកំពុងឆេះប្រវែងប្រហែល ១០ សង្ហីម៉ែត្រ ។ ខ្ញុំភ័យខ្លាំងណាស់ ព្រោះខ្ញុំខ្លាចឆេះផ្ទះ ។ ដូច្នេះ ខ្ញុំក៏យកដំបងមកវាយផ្តាច់ខ្សែលួសឲ្យដាច់ចេញពីខ្សែភ្លើងមួយរំពេច ។ ខ្សែលួសក៏លែងឆេះ តែអំពូលមូលរបស់ខ្ញុំក៏ឈប់ភ្លឺតាំងពីថ្ងៃនោះមកដែរ ។ ខ្ញុំលាក់ការសម្ងាត់នេះមិនឲ្យនរណាដឹងឮឡើយ ។ ខ្ញុំក៏លែងហ៊ានលេងល្បែងដ៏គ្រោះថ្នាក់នេះតទៅទៀត ព្រោះអាចនាំឲ្យឆេះផ្ទះដែលជាកេរដំណែលរបស់ដូនតាខ្ញុំ ។

ការគិតគូរអំពីបញ្ហាស្រុកទេស

ជាទូទៅ នៅសម័យនោះ ភូមិយើងមិនទាន់មានចង្កៀងអគ្គិសនីបំភ្លឺជាសាធារណៈនៅឡើយទេ ។ ប៉ុន្តែ ដោយសារពន្លឺចង្កៀងអគ្គិសនីដែលដុះចេញពីផ្ទះនានានៅសង្ខាងផ្លូវធំនោះ យើងក៏អាចមើលឃើញម្តងៗនូវអ្នកដំណើរថ្មើរជើង ឬអ្នកជិះកង់ ជិះម៉ូតូដែលធ្វើដំណើរហូរហែតាមផ្លូវ ។ ដោយសារមានពន្លឺចង្កៀងភ្លឺបន្តិចបន្តួចនេះ អ្នកស្រុកក៏ចូលចិត្តដើរលេងយប់ ។ នៅពីលើយ៉ាងមុខផ្ទះជួនកាលខ្ញុំអាចឃើញភ្ញៀវចូលមកលេងដោយមិនបានត្រៀមទុក ។ ពេលណាមានគេមករក ខ្ញុំជូនដំណឹងទៅឪពុកខ្ញុំភ្លាម ។ ជាញឹកញាប់ ភ្ញៀវច្រើនមកលេងក្រោយពេលបាយល្ងាចរួច ព្រោះពួកគាត់ចង់ជជែកគ្នាពីនេះពីនោះ រហូតដល់ពេលងងុយទើបត្រឡប់ទៅផ្ទះវិញ ។ អ្នកទាំងនោះ ច្រើនវែកញែកអំពីបញ្ហានយោបាយអន្តរជាតិរាប់ទាំងសង្គ្រាមនៅកូរ៉េ ជម្លោះនៅកុងហ្គោ ជាពិសេស សង្គ្រាមនៅប្រទេសជិត

ខាងគឺ នៅប្រទេសលាវ[17] ឬ វៀតណាម និង បញ្ហាប្រណាំងប្រជែងផ្នែកបរមាណូ ។ អ្នកទាំងនោះ ក៏ធ្វើអត្ថាធិប្បាយអំពីមហាយក្សធំៗដូចជា៖ សហភាពសូវៀត ស.រ.អា បារាំង អង់គ្លេស និង ចិនជាដើម... ។ ពួកគាត់ ធ្វើអត្ថាធិប្បាយទៅលើព័ត៌មានដែលបានទទួលតាមវិទ្យុជាតិ និង ដែលមានផ្សាយមួយថ្ងៃ ៣ ដង។ ក៏ប៉ុន្តែជាទូទៅពួកគាត់ ច្រើននិយាយតាមសម្តេចឪ ដែលលោកតែងធ្វើអត្ថាធិប្បាយតាមវិទ្យុជារៀងរាល់ថ្ងៃ ។

ក្នុងសម័យនោះ សម្តេចជាព្រះប្រមុខរដ្ឋ និង ជាប្រធានចលនាសង្គមរាស្ត្រនិយម ។ សម្តេចតែងយាងទៅសួរសុខទុក្ខប្រជារាស្ត្ររបស់ព្រះអង្គ នៅទីកន្លែងជាច្រើននៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយជារៀងរាល់ដង ព្រះអង្គតែងថ្លែងព្រះសុន្ទរកថាដែលគេផ្សាយតាមវិទ្យុជាច្រើនម៉ោង ក្នុងមួយថ្ងៃៗ ។ ឪពុកខ្ញុំ និងភ្ញៀវរបស់គាត់ មិនសូវធ្វើអត្ថាធិប្បាយអំពីបញ្ហាក្នុងស្រុកទេ លើកលែងតែមានរឿងរ៉ាវណាដែលទាក់ទងដល់រដ្ឋមន្ត្រី និង មន្ត្រីធំៗដែលគាត់ស្គាល់ ។ ទាំងអស់គ្នាតែងកោតសរសើរការដឹកនាំដ៏ឈ្លាសវៃរបស់សម្តេចឪ ។ ខ្ញុំក៏បានរៀនសូត្រអំពីរឿងនយោបាយអន្តរជាតិ តាមរយៈការស្តាប់ចាស់ៗពិភាក្សាគ្នា នៅពេលចាក់តែជូនពួកគាត់ ។ ខ្ញុំក៏ដឹងនៅពេលក្រោយមកថា ឪពុកខ្ញុំក៏ធ្លាប់ឈរឈ្មោះបោះឆ្នោតតំណាងរាស្ត្រដែលរៀបចំឡើងជាលើកដំបូង ដោយសង្គមរាស្ត្រនិយមដែរ ប៉ុន្តែមិនបានជាប់ឆ្នោត ។

នៅរៀងរាល់សប្តាហ៍ លោកចៅហ្វាយស្រុកតែងកោះអញ្ជើញលោកមេឃុំគ្រប់ឃុំឲ្យមករួមប្រជុំនៅសាលាស្រុក ។ លោកមេឃុំមេសប្រចាន់ ជាបងប្អូនជីដូនមួយរបស់ឪពុកខ្ញុំ ។ រាល់ៗដង នៅពេលប្រជុំរួចគាត់តែងមកផ្ទះខ្ញុំ ដើម្បីរួមពិសា

[17] សម័យនោះ គេហៅថាប្រទេស លាវ ឥឡូវគេហៅថា ប្រទេសឡាវ ។

បាយថ្ងៃត្រង់ ឬ ក៏ចូលមកសំណេះសំណាលជាមួយឪពុកខ្ញុំ ។ ដំបូងគាត់ធ្វើដំណើរតាមទោចក្រយាន ក្រោយមកតាមទោចក្រយានយន្ត ហើយគាត់តែងដាក់កង់ ឬ ម៉ូតូរបស់គាត់នៅក្រោមផ្ទះ រួចឡើងជណ្តើរទៅឯលើ ដើម្បីជួបឪពុកខ្ញុំនៅការិយាល័យរបស់គាត់ ។ នៅពេលលោកមេឃុំជាប់រវល់ជជែក ឬ និយាយលេងជាមួយឪពុកខ្ញុំៗក៏រវល់ត្រួតពិនិត្យរបស់របររបស់គាត់ នៅឯក្រោម ដែលគាត់ចងជារមូរធំនៅលើចង្កើរកង់ ឬ ម៉ូតូរបស់គាត់ដែរ ។ រមូរដ៏ធំនោះគឺ ទស្សនាវដ្តីចំនួនដប់ ឬ ម្ភៃក្បាលដែលគាត់ត្រូវយកទៅផ្សព្វផ្សាយនៅតាមឃុំរបស់គាត់ ។ ខ្ញុំព្យាយាមទាញយកទស្សនាវដ្តីពីរ ឬ បីក្បាលនៅកណ្តាលរមូរ យកមកទុកអានខ្លួនឯង ដោយមិនឲ្យលោកមេឃុំដឹងជាមុនឡើយ ។ ឯលោកមេឃុំមិនដែលចាប់អារម្មណ៍ថាមានអ្នកលួចដកហូតទស្សនាវដ្តីរបស់គាត់ដែរទេ ព្រោះខ្ញុំចងរឹតបន្តឹងរមូរឯកសារនោះឲ្យណែនឡើងវិញ មិនអាចជ្រុះបានឡើយ ។

ទស្សនាវដ្តីសម័យនោះ ឈ្មោះអ្នកជាតិនិយម ដែលជាទស្សនាវដ្តីមានប្រជាប្រិយភាពណាស់ និង ដែលត្រូវបានបោះពុម្ពផ្សាយ ដោយចលនាសង្គមរាស្ត្រនិយម ។ ខ្ញុំចូលចិត្តអានអត្ថបទ និង មើលរូបភាព នៅក្នុងទស្សនាវដ្តីនោះណាស់ ព្រោះគេមានផ្សព្វផ្សាយអំពីសកម្មភាពការងាររបស់រាជរដ្ឋាភិបាល និង ព្រះឆាយាល័ក្ខណ៍របស់ព្រះមហាក្សត្រ ព្រះមហាក្សត្រីយានី សម្តេចព្រះឧបយុវរាជ ក្រោយមកសម្តេចព្រះប្រមុខរដ្ឋ និង មន្ត្រីធំៗ ។ ខ្ញុំចូលចិត្តអានព័ត៌មានអន្តរជាតិ ដែលអាចជួយខ្ញុំឲ្យយល់ដឹងនូវប្រធានបទដែលឪពុកខ្ញុំ និង ភ្ញៀវរបស់គាត់តែងជជែកគ្នាលេងនៅរាល់ៗយប់នោះ ។ ខ្ញុំចូលចិត្តមើលរូបគំនូរកំប្លុកកំប្លែង ដូចជារូបរបស់លោកប្រធានាធិបតី អៃសិនហាវ័រ (Eisenhower)[18] នៃសហរដ្ឋអាមេរិក លោក

[18] Dwight David Eisenhower (October 14, 1890 – March 28, 1969) was the 34th President of the United States from 1953 until 1961. លោក អៃសិនហាវ័រ ជាប្រធានាធិបតីទី ៣៤ នៃសហរដ្ឋអាមេរិក ពីឆ្នាំ១៩៥៣ ដល់ឆ្នាំ១៩៦១។

គ្រុតឆេវ (Khrushchev)[19] នៃសហភាពសូវៀត លោក ដឺហ្គោល (De Gaulle)[20] នៃប្រទេសបារាំងជាដើម ។ ក្នុងនោះក៏មានរូបកំប្លុកកំប្លែងរបស់សម្តេចឪ និង រូបរបស់មន្ត្រីធំៗឯទៀតមួយចំនួនដែរ ។ ដូច្នេះ ការអានទស្សនាវដ្តីនេះរាប់បានថា ជាការរៀនសូត្រមួយផ្នែកនយោបាយអន្តរជាតិរបស់ខ្ញុំ ។

ខ្ញុំចូលចិត្តកសាងកុសល

នៅពេលខ្ញុំចូលរៀនថ្នាក់ឧត្តមដ្ឋាន ឪពុកខ្ញុំ ម្តាយខ្ញុំ បានសង្កេតឃើញថា ខ្ញុំចូលចិត្តគូរគំនូរ និង មើលសៀវភៅ ។ ខ្ញុំចូលចិត្តគូររូបសត្វ ផ្ទះ ឡាន ដើមឈើ និង ទេសភាពដោយប្រើពណ៌ទឹក ។ ក៏ប៉ុន្តែ អ្វីដែលគួរកត់សម្គាល់នោះគឺ ខ្ញុំគូរគំនូរ ព្រះពុទ្ធ ក្នុងព្រះឥរិយាបថផ្សេងៗ និង ក្នុងសកម្មភាពសំខាន់ៗរបស់ព្រះអង្គ ។ ជីដូន និង ម្តាយខ្ញុំសប្បាយចិត្ត និង ចង់ឃើញរូបគំនូរទាំងអស់នោះណាស់ ហើយ តែងលើកទឹកចិត្តខ្ញុំឲ្យគូរឲ្យបានច្រើន ។ ពួកគាត់និយាយថា អំពើទាំងនេះជាការ កសាងកុសល ដូចសាងអំពើល្អ ឬ ធ្វើបុណ្យយ៉ាងដូច្នោះដែរ ដែលអាចនាំឲ្យយើង ឡើងឋានសួគ៌បាន ។ ម្យ៉ាងទៀត ខ្ញុំក៏ចូលចិត្តអានសៀវភៅធម៌ ដែលប្រដៃប្រដៅ យើង ឲ្យប្រព្រឹត្តទៅតាមគន្លងព្រះពុទ្ធសាសនា ឬ ឲ្យយល់ដឹងអំពីវិន័យព្រះសង្ឃ

[19] Nikita Sergeyevich Khrushchev (April 15, 1894 – September 11, 1971) led the Soviet Union during part of the Cold War. He served as First Secretary of the Communist Party of the Soviet Union from 1953 to 1964, and as Chairman of the Council of Ministers, or Premier, from 1958 to 1964. លោក គ្រុតឆេវ ជាអ្នកដឹកនាំសហភាពសូវៀត ពីឆ្នាំ ១៩៥៣ ដល់ឆ្នាំ ១៩៦៤ ក្នុងឋានៈជាលេខាទី១នៃបក្សកុម្មុយនីស្ត ពីឆ្នាំ ១៩៥៣ ដល់ ១៩៦៤ និង ជានាយករដ្ឋមន្ត្រី ពីឆ្នាំ ១៩៥៨ ដល់ ១៩៦៤ ។

[20] Charles André Joseph Marie de Gaulle (22 November 1890 – 9 November 1970) was a French general and statesman who led the Free French Forces during World War II. He later founded the French Fifth Republic in 1958 and served as its first President from 1959 to 1969. លោក ដឺហ្គោល ជាឧត្តមសេនីយ និងរដ្ឋបុរសបារាំងដែល បានដឹកនាំកងកម្លាំងបារាំងសេរីប្រឆាំងកងទ័ពអាឡឺម៉ង់នៅសង្គ្រាមលោកលើកទី២។ លោកជាស្ថាបនិកនៃសាធារណរដ្ឋ បារាំងទី៥ និង ជាប្រធានាធិបតីទី១នៃសាធារណរដ្ឋនេះ ពីឆ្នាំ ១៩៥៩ ដល់ ១៩៦៩ ។

ដែរ ។

ថ្ងៃមួយជីដូនខ្ញុំ នាំខ្ញុំទៅលេងភូមិកំពង់ទ្រា ក្នុងឃុំមេសប្រចាន់ ។ នៅក្នុងផ្ទះ ដែលយើងសម្រាក ខ្ញុំក៏រើសយកសៀវភៅធម៌ដែលមានចំណាស់មួយក្បាលមកអាន ។ នៅវគ្គដំបូង ខ្ញុំចាប់ផ្តើមអានឮៗយ៉ាងច្បាស់ៗ និង មួយៗដោយមានការប្រុងប្រយ័ត្នមិនឲ្យខុសអក្ខរាវិរុទ្ធ ឬ វគ្គឃ្លាឡើយ ។ នៅពេលខ្ញុំកំពុងអាននោះ យាយៗបួនដប់នាក់ចូលមកអង្គុយបត់ជើងជុំវិញខ្ញុំ ។ យាយម្នាក់ស្ទុះទៅដុតធូបនៅចំពោះមុខខ្ញុំ ហាក់ដូចជាយល់ថាខ្ញុំកំពុងតែសូត្រធម៌ ឬ សម្តែងធម៌ទេសនាក្នុងពិធីបុណ្យមែនទែនដូច្នោះដែរ ។ ដោយឃើញដូច្នេះ ខ្ញុំក៏មិនហ៊ានឈប់ហើយត្រូវបន្តអានរហូតដល់ចប់ ។ ជីដូនខ្ញុំក៏និយាយថា ខ្ញុំធ្វើបុណ្យបានច្រើនណាស់ ដោយសារបានអានសៀវភៅធម៌ជូនចាស់ៗស្តាប់ ។ ខ្ញុំដក់ចិត្តជាប់នឹងព្រះពុទ្ធសាសនាស្ទើរតែចង់បែកចិត្តឈប់រៀន នៅពេលអាយុ ១៣ ឆ្នាំ ដើម្បីទៅសាងផ្នួសបួសជាសាមណេរ ។ ក៏ប៉ុន្តែ នៅទីបញ្ចប់ខ្ញុំមិនបានបួសទេ ហើយបន្តរៀនរហូតមក ។ ខ្ញុំមានចិត្តចង់ធ្វើបុណ្យតាំងពីតូច ។ នៅពេលខ្ញុំជិះកង់ ឬ ម៉ូតូ ហើយជួបមនុស្សចាស់ ឬ ព្រះសង្ឃដែលកំពុងតែដើរ ឬ និមន្តក្រោមកម្តៅថ្ងៃ ខ្ញុំតែងតែហៅគាត់ ឬ និមន្តលោកឲ្យជិះកង់ជាមួយខ្ញុំ រួចខ្ញុំជូនដំណើរគាត់ ឬ ព្រះអង្គទៅដល់ទីដៅ ។

ខ្ញុំចូលចិត្តអានសៀវភៅ

នៅខាងលិចផ្ទះខ្ញុំ មានផ្ទះបងប្អូនជីទួតមួយម្នាក់ ហៅផ្ទះនឹងប៉ែន (បងថ្លៃ) ។ នឹងប៉ែនទើបនឹងសង់ផ្ទះ ហើយប្តូរយកមុខរបរថ្មី ។ កាលពីមុនគាត់លក់និង តំឡើង ឬ ជួសជុលទោចក្រយាន ។ នៅទសវត្សរ៍ឆ្នាំ ១៩៦០ គាត់មកប្រកប

របរជាអ្នកលក់សៀវភៅ ជាម្ចាស់បណ្ណាគារម្តងវិញ ។ នៅក្នុងបណ្ណាគារ គាត់លក់ប្រដាប់ប្រដាសិស្សានុសិស្ស សៀវភៅមេរៀនគ្រប់មុខ សៀវភៅប្រលោមលោក និង សៀវភៅធម៌ ។ ឃុវៗម្តង គាត់ក៏មានលក់សៀវភៅទស្សនាវដ្តីខ្លះដែរ ។ បន្តិចម្តងៗ បណ្ណាគារក៏កាន់តែមានសៀវភៅច្រើនឡើងៗ ។ ចាប់តាំងពីគាត់បើកបណ្ណាគារមក ខ្ញុំតែងមកជួយរៀបចំសៀវភៅតាមមុខសញ្ញា ដើម្បីអ្នកទិញស្រួលមើល និង ស្រួលយក ។ ខ្ញុំរៀបសៀវភៅតាមចំណងជើង តាមប្រធានបទ ឬ តាមអ្នកនិពន្ធជាដើម ។ ជាទូទៅ ខ្ញុំមកជួយគាត់នៅពេលដែលខ្ញុំទំនេរពីការសិក្សារបស់ខ្ញុំ ។ ក៏ប៉ុន្តែនៅពេល ដែលខ្ញុំមកជួយធ្វើការនោះ ខ្ញុំក៏ឆ្លៀតអានសៀវភៅទាំងនោះស្ទើរតែទាំងអស់ ទាំងសៀវភៅរៀន ទាំងសៀវភៅធម៌ ទាំងសៀវភៅប្រលោមលោក ដែលមានអ្នកនិពន្ធ ពីបុរាណ ឬ សម័យទំនើប ទាំងចាស់ទាំងក្មេង ។ ខ្ញុំអានសៀវភៅមិនរើសមុខ ទាំងសៀវភៅតុក្កតាកំប្លុកកំប្លែង សៀវភៅអប់រំសីលធម៌ សៀវភៅអប់រំផ្សេងៗទៀត រួមទាំងសៀវភៅអប់រំផ្លូវភេទ កីឡា ឬ សិល្បៈជាដើមៗល។ ដោយសារខ្ញុំមានការជក់ចិត្តជិតអារម្មណ៍ក្នុងការអានសៀវភៅនេះ ឃុវៗទៅ ខ្ញុំមិនសូវនៅផ្ទះប៉ុន្មានទេ ខ្ញុំចំណាយពេលវេលាយ៉ាងច្រើននៅក្នុងបណ្ណាគារនេះ ។ ខ្ញុំអានសៀវភៅភ្លេចបាយ ភ្លេចទឹក ដែលម្តងៗម្តាយខ្ញុំត្រូវស្រែកហៅខ្លាំងៗជាញឹកញាប់ ពីលើយ៉ាងមុខផ្ទះ ឲ្យទៅទទួលទានអាហារទាន់ពេលវេលា ។ ដូច្នេះ ខ្ញុំមិនសូវបាននៅរួមទទួលទានអាហារជាមួយឪពុកម្តាយខ្ញុំ ដូចកូនៗឯទៀតឡើយ ។ ខ្ញុំទទួលស្គាល់ថាការអានសៀវភៅច្រើននេះ ក៏ជួយសំរួលឲ្យខ្ញុំមានចំណេះដឹងទូទៅច្រើន ធ្វើឲ្យការសិក្សារីកចំរើនឆាប់រហ័ស ពោលគឺរៀនឆាប់ចេះឆាប់ដឹងតទៅមុខទៀតដែរ ។

ចង់ស្គាល់ភ្នំពេញខានបានលេខ១

កាលខ្ញុំនៅរៀននៅសាលាបឋមសិក្សាស្នាយពល ខ្ញុំតែងដើរទៅរៀន ។ ក៏ប៉ុន្តែនៅពេលដែលខ្ញុំប្រឡងជាប់ចូលរៀននៅអនុវិទ្យាល័យពារាំង ខ្ញុំមិនអាចដើរបានទៀតឡើយ ព្រោះសាលាអនុវិទ្យាល័យនៅឆ្ងាយពីផ្ទះ ។ ដូច្នេះ ឪពុកម្តាយខ្ញុំក៏ទិញកង់ឲ្យមួយ ។ ក្នុងហានៈជាសិស្សអនុវិទ្យាល័យ ការរៀនសូត្ររបស់យើងក៏ត្រូវផ្លាស់ប្តូរដែរ ។ ជាដំបូងគេលែងហៅលោកគ្រូ ថាលោកគ្រូទៀតហើយ គេហៅថាសាស្ត្រាចារ្យ ។ យើងមិនមែនមានគ្រូតែម្នាក់ដូចពីមុនទេ យើងមានគ្រូច្រើនទៅតាមមុខវិជ្ជា ។ គ្រូម្នាក់បង្រៀនមុខវិជ្ជាមួយដាច់ដោយឡែកៗពីគ្នា ។ យើងឈប់ស្លៀកខោខ្លីអាវដៃខ្លីទៀតហើយ ។ ឥឡូវយើងស្លៀកខោគគីជើងវែង និង ពាក់អាវស ។ នៅអនុវិទ្យាល័យ មុខវិជ្ជាទាំងឡាយសុទ្ធតែជាភាសាបារាំង លើកលែងតែមុខវិជ្ជាអក្សរសាស្ត្រខ្មែរចេញ ។ នៅឆ្នាំទីមួយនៅអនុវិទ្យាល័យពារាំង ខ្ញុំរៀនបានលេខល្អខាងប្រវត្តិសាស្ត្រ វិទ្យាសាស្ត្រ គណិតសាស្ត្រ តែងសេចក្តី ទាំងខ្មែរទាំងបារាំង ។

តាមធម្មតាខ្ញុំត្រូវបានលេខ ១ ក៏ប៉ុន្តែខ្ញុំត្រូវធ្លាក់មកនៅលេខ ៣ វិញ ដោយសារខ្ញុំខានមិនបានចូលរួមប្រឡងក្នុងវិជ្ជាមួយមុខ នាធមាសទីមួយ ។ កាលនោះ ទីក្រុងភ្នំពេញជាទីក្រុងដ៏ល្អប្រណិតនៅអាស៊ីភាគអាគ្នេយ៍យើងនេះ ។ ទីក្រុងភ្នំពេញមានផ្លូវចរាចរខ្វាត់ខ្វែង មានហាងលក់ទំនិញដេរដាស មានសួនច្បារល្អប្រិមប្រិយ មានអាគារតូចធំ ខ្ពស់ទាប ទាំងផ្នែកសាធារណៈ ទាំងផ្នែកឯកជន ប្រកបដោយការតុបតែងរចនាដែលគួរឲ្យទាក់ទាញអារម្មណ៍ ។ ជាច្រើនដង ខ្ញុំចេះ តែចង់មកលេងភ្នំពេញ ។ នៅពេលណាបងប្រុសខ្ញុំ ដែលបានទៅរៀននៅរាជធានី មកលេងផ្ទះម្តងៗ គាត់តែងបបួលទៅលេងភ្នំពេញ ខ្ញុំចេះតែចង់ទៅជាមួយ ។ ក៏ប៉ុន្តែ រាល់ៗដង ឪពុកម្តាយខ្ញុំមិនដែលអនុញ្ញាតឲ្យទៅលេងទេ ព្រោះខ្លាចខានរៀន ។ ចំពោះខ្ញុំ

ការទៅទស្សនាទីក្រុងភ្នំពេញ អាចចាត់ទុកជាការទទួលរង្វាន់ដ៏ធំអស្ចារ្យដែរ ។ តាមធម្មតា យើងអាចទៅលេងភ្នំពេញបាន ក្នុងឱកាសពិធីបុណ្យធំៗដូចជា បុណ្យអុំទូក បុណ្យឯករាជ្យជាតិ ជាពិសេស ក្នុងឱកាសសមាជជាតិ (កាលសម័យសង្គមរាស្ត្រនិយម រាជរដ្ឋាភិបាលរៀបចំជាសមាជជាតិមួយឆ្នាំពីរដង ដើម្បីឲ្យរាស្ត្របានសួរដេញដោលរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល ចំពោះបញ្ហាទាំងឡាយដែលគេចង់ដឹងចង់យល់)។

ថ្ងៃមួយ នៅពេលដែលបងប្រុសទី២របស់ខ្ញុំគឺ បងស៊ីនឿន មកលេងផ្ទះ គាត់បបួលខ្ញុំទៅលេងភ្នំពេញ ។ ឮថា ទៅលេងភ្នំពេញ ខ្ញុំមានអារម្មណ៍ស្រើបស្រាលចង់ទៅលេងខ្លាំងណាស់ ហើយក៏ប្រឹងរកនឹកហេតុផលដើម្បីពន្យល់ឪពុកម្តាយខ្ញុំឲ្យគាត់យល់ព្រម ។ កាលនោះ ខ្ញុំលាក់មិនឲ្យគាត់ដឹងថាខ្ញុំកំពុងប្រឡងឆមាសទេ ។ ដោយសារតែអវត្តមានក្នុងមុខវិជ្ជាមួយយ៉ាងដូចនេះ ទើបខ្ញុំត្រូវទទួលពិន្ទុសូន្យក្នុងមុខវិជ្ជានោះ ។ តាមធម្មតាសិស្សនៅអនុវិទ្យាល័យត្រូវទទួលពិន្ទុក្នុងមុខវិជ្ជាមួយពី ០ ទៅ ២០ ។

ជារៀងរាល់ឆ្នាំ ទីចាត់ការអនុវិទ្យាល័យតែងរៀបចំពិធីប្រគល់រង្វាន់ដល់ជ័យលាភីដែលបានពិន្ទុល្អប្រចាំត្រីមាស ឬ ប្រចាំឆមាស ឬ ប្រចាំឆ្នាំ ។ ក្នុងពិធីចែករង្វាន់លើកដំបូងនេះ ខ្ញុំគ្មានសង្ឃឹមថានឹងបានទទួលរង្វាន់អ្វី ដូចសិស្សឯទៀតទេ ដោយសារតែពិន្ទុសូន្យក្នុងមួយមុខវិជ្ជា ។ ដូច្នេះ ចំពោះពិធីចែករង្វាន់លើកនេះ ខ្ញុំហាក់ដូចជាមិនសូវយកចិត្តទុកដាក់ប៉ុន្មានឡើយ ។ ពេលមកដល់មាត់ទ្វារសាលា ខ្ញុំបណ្តើរកង់យ៉ាងយឺតៗ សម្លឹងទៅខាងមុខឃើញកូនសិស្សឯទៀតជួបជុំគ្នាយ៉ាងកុះករនៅមុខទីចាត់ការរបស់អនុវិទ្យាល័យ ។ លោកនាយក កំពុងប្រកាសហៅឈ្មោះសិស្សដែលត្រូវទទួលរង្វាន់ ។ រង្វាន់មានពីរផ្នែកមួយគឺ ប័ណ្ណសរសើរចំពោះសិស្សដែលបានពិន្ទុច្រើន និង មួយទៀតគឺតារាងកិត្តិយស ។ សិស្សណាដែលត្រូវ

លោកនាយកប្រកាសហៅឈ្មោះ ក៏ស្ទុះលោតដោយអំណរ ហើយដើរទៅទទួលយ៉ាងសង្ហា ។ ក្រោយពីបានទទួលរង្វាន់ហើយ អ្នកខ្លះក៏ចេញទៅកាន់ទីផ្សេង ។ នៅពេលដែលខ្ញុំដើរកាន់តែជិតទីកន្លែងចែករង្វាន់ ខ្ញុំសង្កេតឃើញ ក្រុមហ្វូងសិស្សានុសិស្សហាក់ដូចជាមានចំនួនចុះចេញបន្តិច ។ លោកនាយកបានបញ្ចប់ការចែកប័ណ្ណសរសើរ ហើយកំពុងរៀបចំប្រកាសឈ្មោះដំណាក់ដែលត្រូវទទួលតារាងកិត្តិយស ។

ខ្ញុំគ្មាននឹកសង្ឃឹមទាល់តែសោះថាអាចនឹងមានមុខទទួលរង្វាន់អ្វីមួយឡើយ ហើយកំពុងនឹករអ៊ូក្នុងចិត្តបន្ទោសខ្លួនឯងថាមិនគួរខានប្រឡង ហើយបែរជាទៅដើរលេង នៅភ្នំពេញទៅវិញយ៉ាងដូច្នេះសោះ ។ ខ្ញុំគួរតែទប់ចិត្តកុំឲ្យដឹកនាំខ្ញុំទៅដើរលេងចោលការប្រឡងយ៉ាងដូច្នេះ ។ កំពុងតែលង់ក្នុងក្តីមួហ្មងយ៉ាងនេះ ស្រាប់តែខ្ញុំឮសូរសម្លេងមួយមកដាស់អារម្មណ៍ខ្ញុំឲ្យភ្ញាក់ស្មារតីឡើង ។ ឈ្មោះខ្ញុំត្រូវលោកនាយកហៅមុនគេ ដើម្បីឲ្យទៅទទួលតារាងកិត្តិយស ។ នៅពេលភ្លាមៗនោះខ្ញុំមិនទាន់ជឿថាខ្ញុំអាចទទួលរង្វាន់នេះនៅឡើយទេ តែនៅពេលដែលឃើញអ្នកឯទៀតក្រឡេកមើលមកខ្ញុំគ្រប់គ្នា ទើបខ្ញុំប្រាកដក្នុងចិត្តថាខ្ញុំពិតជាជំយលាកីមែន ។ ខ្ញុំមានសេចក្តីរីករាយក្នុងចិត្តឥតឧបមា ចំពោះហេតុការណ៍ដែលកើតឡើងសម្រាប់ខ្ញុំដែលខ្ញុំមិនបាននឹកដល់ទាល់តែសោះ ។ នេះជាសុភមង្គលមួយដែលខ្ញុំចងចាំរហូតអស់មួយជីវិត ។

លាភូមិស្នាយពល

តាំងពីពេលដែលបងប្រុសខ្ញុំទាំងពីរនាក់ បានទៅរៀននៅទីក្រុងភ្នំពេញមក ការបញ្ជូនកូនឲ្យទៅបន្តវិជ្ជានៅរាជធានី បានក្លាយទៅជាប្រពៃណីមួយរបស់ឪពុក

ម្តាយខ្ញុំ ។ ដូច្នេះ លើកនេះជាវេនរបស់ខ្ញុំគឺ ជាពេលដែលខ្ញុំត្រូវបែកចេញពីភូមិកំណើតរបស់ខ្ញុំ ដើម្បីទៅរៀនបន្តនៅភ្នំពេញ ។ បងប្រុសធំបង្អស់របស់ខ្ញុំគឺ បងឈឿន ឬ បងនាងមានការកិច្ចស្វែងរកសាលា ។ កាលលើកមុនគាត់បានជួយឲ្យបងប្រុសបន្ទាប់គឺ បងស៊ីនឿន បានចូលរៀននៅវិទ្យាល័យព្រះយុគន្ធរ ។ ចំពោះខ្ញុំ បងនាងរកបានសាលានៅទួលគោក ដែលមានឈ្មោះថា "វិទ្យាល័យសង្គមរាស្ត្រនិយម" ។ នៅឆ្នាំ ១៩៦៤ ខ្ញុំក៏មករស់នៅទីក្រុងភ្នំពេញ ។

ខ្ញុំឃ្លាតចេញពីភូមិកំណើតរបស់ខ្ញុំ កាលខ្ញុំអាយុបាន ១៤ ឆ្នាំ ហើយខ្ញុំមិនដែលនឹកគិតថា ថ្ងៃមួយគ្រួសារខ្ញុំទាំងមូលនឹងត្រូវបង្ខំចិត្តបែកចេញពីភូមិកំណើតនេះម្តងណាឡើយ ។ ក្នុងរយៈពេលដែលខ្ញុំរស់នៅទីក្រុងភ្នំពេញ ខ្ញុំតែងតែឆ្លៀតទៅលេងភូមិកំណើតរបស់ខ្ញុំជារឿយៗ រហូតដល់ឆ្នាំ ១៩៧០ នៅពេលដែលប្រទេសកម្ពុជាយើងធ្លាក់ចូលក្នុងភ្នក់ភ្លើងសង្គ្រាម ។ តាំងពីពេលនោះមក ខ្ញុំត្រូវរង់ចាំអស់រយៈពេល ២២ ឆ្នាំ ទើបអាចវិលមកភូមិកំណើតខ្ញុំវិញ ។ ភូមិខ្ញុំ ក្នុងរយៈពេលដ៏វែងនេះ ក៏ដូចជាភូមិនានាឯទៀតនៅទូទាំងប្រទេសកម្ពុជាទាំងមូលដែរ ត្រូវទទួលរងទុក្ខដោយសារសង្គ្រាមបំផ្លិចបំផ្លាញ ដោយសារបដិវត្តន៍ប្រកបដោយអំពើសាហាវយង់ឃ្នងប្រល័យពូជសាសន៍ ដោយសារការបែកបាក់ព្រាត់ប្រាស់គ្នា ដោយសារការលុកលុយនៃកងទ័ពបរទេស និង ដោយសារអស្ថិរភាពនយោបាយ ។ អ្វីដែលកើតឡើង នៅភូមិកំណើតរបស់ខ្ញុំ ក៏អាចកើតមានឡើងនៅតាមភូមិនានាឯទៀតទូទាំងប្រទេស ដោយហេតុថាភូមិទាំងនោះមានលក្ខណៈវប្បធម៌ សង្គម និងសេដ្ឋកិច្ចប្រហាក់ប្រហែលគ្នា ។ ខ្ញុំតែងនឹកដល់ភូមិខ្ញុំជានិច្ច នៅពេលដែលខ្ញុំពិចារណាអំពីតម្លៃនៃអ្វីដែលហៅថា "សេរីភាព" "ប្រពៃណីជាតិ" "សេចក្តីថ្លៃថ្នូរបស់មនុស្ស" និង "វឌ្ឍនភាព" ។

វគ្គទី២
ការសិក្សា និង ជីវភាពនៅទីក្រុង
(ទសវត្សរ៍ឆ្នាំ ១៩៦០-៧០)

មុនពេលដែលខ្ញុំត្រូវមករស់នៅៗទីក្រុងភ្នំពេញមួយឆ្នាំ ឪពុកខ្ញុំបានទិញផ្ទះឈើតូចមួយខ្នង ដើម្បីឲ្យបងប្រុសខ្ញុំទាំងពីរនាក់ស្នាក់នៅ និង បន្តការសិក្សា ។ ភ្នំពេញនាសម័យនោះជាទីក្រុងទំនើប ដែលមានគេអួតថាជាគុជនៃអាស៊ីភាគអាគ្នេយ៍ ។ អាគារសោធារណៈទាំងឡាយត្រូវសាងសង់ឡើងយ៉ាងមានរបៀបរៀបរយ និង មានការថែទាំយ៉ាងត្រឹមត្រូវ ។ ភ្នំពេញជាទីក្រុងតូចច្រឡឹងដែលមានផ្លូវ ឬ វិថីខ្នាត់ខ្នែងប្រកបដោយចរាចរណ៍ឥតស្រាកស្រាន្ត ។ ក៏ប៉ុន្តែពួកយើងមិនបានរស់នៅក្នុងតំបន់ទាន់សម័យទាំងនោះទេ យើងរស់នៅក្នុងសង្កាត់ក្រីក្រមួយឈ្មោះថា "ផ្សារដើមគ" ។

ផ្ទះឈើប្រក់សង្កសីនៅផ្សារដើមគ

នៅក្នុងសង្កាត់នេះយើងមិនមានភ្លើងអគ្គិសនី និង ទឹកស្អាតប្រើប្រាស់ទេ ។ ពេលយប់យើងអុជចង្កៀងប្រេងកាតដើម្បីបំភ្លឺ ជាពិសេស នៅពេលយើងអាន ឬ ធ្វើលំហាត់មេរៀនរបស់យើងតែប៉ុណ្ណោះ ។ យើងប្រើចង្ក្រានធ្យូង ដើម្បីចំអិនអាហារ ឯធ្យូងនោះយើងទិញពីផ្ទះចិននៅជិតខាងមកប្រើ ។ ពួកយើងទិញទឹកដែលគេអូសលក់ ពីផ្ទះមួយទៅផ្ទះមួយ ។ ទឹកនោះ គេដាក់ក្នុងធុងស៊ីតេន ឬ

ធុងសាំង ផ្ទុកនៅលើរ៉ឺម៉កអូសដោយកម្លាំងមនុស្ស ។ នៅទីក្រុងខុសពីនៅស្រុកស្រែ អ្វីៗក៏ត្រូវ ចំណាយប្រាក់ដៃគឺ គ្មានអ្វីដែលបានមកដោយទទេនោះទេ ។ នៅរដូវ ភ្លៀង ពួកយើងសន្សំសំចៃប្រាក់ខ្លះ ដោយយើងខំត្រងទឹកភ្លៀងយកមករក្សាទុកក្នុង ពាងធំមួយ ។ មិនយូរប៉ុន្មានក្រោយមក ចរន្តអគ្គិសនីក៏បាន តភ្ជាប់តាមបណ្តាញ មកដល់ផ្សារដើមគ ។

ផ្ទះឈើរបស់យើងមានទទឹង ៤ ម៉ែត្រ និង បណ្តោយ ៦ ម៉ែត្រ លើកខ្ពស់ ផុតពីដី ដើម្បីអាចឲ្យយើងមានកន្លែងផ្ទែកខាងក្រោមធ្វើជាផ្ទះបាយផង និង មាន កន្លែងចងអង្រឹងមួយ ឬ ពីរបានផង ។ ជណ្តើរឈើឡើងទៅលើ នាំទៅរកយ៉តូច មួយទំហំ ១,៥ ម៉ែត្រ គុណ១,៥ ម៉ែត្រ ។ ផ្ទះឈើយើងនោះ មានតំបូលប្រក់សង្កសី ។ យើងគ្មានបន្ទប់ទឹកអ្វីច្បាស់លាស់ទេ ។ នៅពេលយើងជំរះកាយ យើងប្រើ ផ្តិលងូតទឹកពាង ដែលយើងដាក់នៅក្រោមដើមក្រឧប ដែលជួយបាំងកំដៅថ្ងៃ ។ យើងដាក់ពាងទឹកព័ទ្ធដោយស្លឹកត្នោតចងភ្ជាប់ជាមួយបន្ទះឫស្សី កំពស់ត្រឹមចង្កេះ ដើម្បីធ្វើជាបន្ទប់ទឹករបស់ពួកយើង ។

យើងរស់នៅក្នុងបរិវេណដីទទឹង ១២ ម៉ែត្រ និង បណ្តោយ ២៤ ម៉ែត្រ ។ យើងធ្វើបង្គន់ចាក់ទឹកនៅចុងម្ខាងដីឯក្រោយផ្ទះ ។ ចំពោះពួកយើងដែលមកពីទី ជនបទ មានបង្គន់បែបនេះ យើងគិតថាមានអនាម័យណាស់ទៅហើយ ។ អ្នក ស្រុកដែលរស់នៅក្បែរខាងយើង ភាគច្រើនជាកម្មករអោងចក្រ អ្នកជាក់ស៊ីក្លូ ឬ មន្ត្រី រាជការតូចតាច។ តាមពិតយើងរស់នៅក្នុងតំបន់ដែលគ្មានអនាម័យគ្រប់គ្រាន់ទេ ។

ទឹកសំអុយដែលនៅតាមលូ ជាមួយនឹងបង្គន់បើកចំហបានជះឥតឈប់ ឈរនូវក្លិនអាក្រក់ដែលមនុស្សធម្មតាពិបាកទ្រាំ ។ ទឹកសំអុយដែលត្រូវគាំងស្ទះ ដោយសំរាម ក៏ក្លាយទៅជាទីជម្រកនៃពពួកសត្វមូស ដែលកើតមានមីរដេរដាស ។ ដូច្នេះ នៅពេលយប់យើងត្រូវទទួលទានដំណេកនៅក្នុងមុង ការពារកុំឲ្យមូសខាំ ។

បើយើងធ្វើដំណើរចេញពីផ្លូវធំគឺ មហាវិថីម៉ៅសេទុង ដែលនៅជំនាន់នោះនៅមិនទាន់ចាក់កៅស៊ូនៅឡើយនោះ យើងត្រូវដើរតាមផ្លូវដ៏ចង្អៀតប្រវែងប្រមាណ ៣០០ ម៉ែត្រ ទើបទៅដល់ផ្ទះឈើរបស់យើង ។ នៅតាមដងផ្លូវចង្អៀតនេះមួយកំណាត់ យើងត្រូវឆ្លងកាត់ផ្សារដើមគ ដែលឈ្មួញរៀបចំលក់ដូររបស់របរចំណីចំណុក ម្ហូបអាហារគ្រប់មុខហូរហៃ នៅក្រោមលំហមេឃ ។ បន្ទាប់ពីផ្សារ យើងដើរលើស្ពានឈើឆ្លងអូរ ឬ បឹងមួយដែលពោរពេញទៅដោយគំនរសំរាម ។ ផ្លូវសម័យនោះភាគច្រើនធ្វើលើដីឥដ្ឋ ។ នៅពេលភ្លៀងម្តងៗយើងជួបនឹងភាពប៉ប៉ិចប៉ប៉ាច់ ហើយត្រូវរអិលដួលស្ទើរចាប់មិនឈ្នះ ។ តំបន់យើងនេះ ក៏សម្បូរណ៍ទៅដោយជនទុច្ចរិត ចោរឆក់ ចោរលួចណាស់ដែរ ។ កាលពុំទាន់មានភ្លើងអគ្គិសនី នៅពេលយប់ងងឹតយូរៗម្តង យើងឃើញស្ត្រីលក់បង្អែមពពាយនាយលក់នំចំណីរបស់គាត់ដោយស្រែកថា៖ "ផ្លែអាយអើយផ្លែអាយ បាយដំណើបទ្រាប សណ្តែកបាយ សង្ឃ្យ៉ាសែសយ" ។ល។ ដោយមានក្មេងកាន់ចង្កៀងបំភ្លឺផ្លូវដើរពីមុខផង ។ ពេលយប់យើងត្រូវលើទោចក្រយានរបស់យើងយកទៅដាក់លើផ្ទះ ការពារកុំឲ្យចោរលួច ។ ទ្វារ បង្អួចត្រូវបិទឲ្យជិត និង ដាក់គន្លឹះឲ្យជាប់ ទោះបីជាយើងពុំមានរបស់របរដ៏មានតម្លៃអ្វីឡើយ ។ នៅក្នុងផ្ទះគ្រឿងសង្ហារិម និង អសង្ហារិមរបស់យើងមានត្រឹមតែតុពីរ ទូឈើមួយ កៅអីបួន ឬ ប្រាំ និង គ្រែឈើមួយសម្រាប់បងទីមួយរបស់ខ្ញុំ ។ ខ្ញុំ និង បងស៊ីនឿន យើងចងមុងក្រាលកន្ទេលផ្ទាល់លើក្តារតែម្តង ។

ជីវភាពប្រចាំថ្ងៃ

ក្នុងជីវភាពប្រចាំថ្ងៃរបស់យើងៗបែងចែកការកិច្ចគ្នា ។ បងប្រុសទីមួយទទួលបន្ទុកចាត់ការទូទៅ រាប់តាំងពីការផ្គត់ផ្គង់ភ័ស្តុភារហូតដល់ការថែទាំជួសជុលផ្ទះសម្បែង ។ បងប្រុសទីពីរ ទទួលបន្ទុកខាងម្ហូបអាហារ ឯចំណែកខ្ញុំ ជាជំនួយការ

គ្រប់បែបយ៉ាងដល់បងៗទាំងពីរ ។ នៅថ្ងៃសម្រាក យើងលាងសម្អាតទោចក្រយាន និង បោកខោអាវរៀងៗខ្លួន ។ នៅពេលដែលយើងជាប់រវល់យ៉ាងមមាញឹកក្នុងការសិក្សា យើងមិនធ្វើម្ហូបខ្លួនយើងទេ យើងទិញម្ហូបឆ្អិនស្រេចដែលគេដាក់លក់នៅរានលក់ម្ហូបថោកៗសំរាប់អ្នកធាក់ស៊ីក្លូ ។ កាលណាយើងដាំបាយឆ្អិនស្រេចបាច់ហើយយើងទៅទិញម្ហូប ជាពិសេសសម្លម្ហូរឃ្មុនដែលមានតម្លៃមួយចានថ្លៃបីរៀល ។ យូរៗទៅ ដោយយើងឧស្សាហ៍ទៅទិញសម្លនៅរានដដែលៗ ខ្ញុំក៏ត្រូវបានអ្នកស្រីម្ចាស់រានរាប់អាន ។ យើងទិញតែបីរៀល គាត់ដួសសម្លឲ្យស្នើរតែពេញមួយចានយួរគ្រប់គ្រាន់ល្មមសំរាប់គ្នាទាំងបីនាក់ ។ នៅពេលដែលយើងជិតដាច់ស្បៀងម្តងៗ យើងនាំគ្នាទៅភូមិស្នាយពល ដើម្បីទៅដឹកយកមកភ្នំពេញនូវអង្ករ ត្រីងៀត ត្រីឆ្អើរ និង ប្រាក់ខ្លះ ។ ជាធម្មតា ឳពុកម្តាយខ្ញុំ ផ្តល់ប្រាក់ម្តងៗឲ្យពួកយើងប្រហែល ៥០ ឬ ៦០ រៀលតែប៉ុណ្ណោះ ។

ជួនកាល ឳពុកខ្ញុំគាត់មកលេងពួកយើងនៅភ្នំពេញ ដោយមិនបានប្រាប់មុន ។ ពេលគាត់មកលេងម្តងៗ ពួកយើងសប្បាយចិត្តណាស់ ព្រោះគាត់តែងនាំពួកយើងទៅទទួលទានអាហារ នៅហាងលក់ម្ហូបចិននៅ តាមដងមហាវិថីម៉ៅសេទុង ។ ម្តាយខ្ញុំមិនសូវមានឱកាសមកលេងទីក្រុងភ្នំពេញទេ ព្រោះជាប់រវល់មើលប្អូនៗតូចៗ ។

នៅសង្កាត់ផ្សារដើមគ ពួកយើងក៏មិនមែនរស់នៅតែឯកឯងនោះទេ ។ នៅប្រហែល ២០០ ម៉ែត្រពីផ្ទះយើង ក៏មានផ្ទះម្តាយធំខ្ញុំដែល មានកូនប្រុស ៣ នាក់រស់នៅជាមួយដែរ ។ ដូច្នេះជាញឹកញយ បងប្អូនជីដូនមួយរបស់យើងតែងមកលេងជាមួយពួកយើង ។ ជាពិសេស នៅក្រោយពេលបាយថ្ងៃត្រង់ ពួកយើងតែងចងអង្រឹង សំរាកអានមេរៀន ឬ បើពុំនោះទេ ពួកយើងនាំគ្នាលេងកីឡាពីងប៉ុង ។ នៅសម័យនោះ ពួកយើងនាំគ្នារៀនមេរៀនតាមរបៀបពីបុរាណគឺ ទន្ទេញមេរៀន

ឲ្យចាំមាត់ ។ ជិតពេលប្រឡងម្តងៗ យើងនាំគ្នាស្រែកទន្ទេញមេរៀនយ៉ាងឮៗគឺ ឮដល់ផ្ទះអ្នកជិតខាង អស់រាប់ម៉ោងក្នុងមួយថ្ងៃៗ ។ នៅសម័យនោះ ខ្ញុំហាក់ដូចជាមិនសូវខំប្រឹងរៀនសូត្រប៉ុន្មានឡើយ ។ ខ្ញុំច្រើនគេងលើអង្រឹង មើលមេរៀន ហើយក៏ច្រើនលង់លក់លើអង្រឹង ដោយសៀវភៅធ្លាក់គ្របលើមុខជាញឹកញាប់ ។ បងជីដូនមួយខ្ញុំម្នាក់ ច្រើនតែឃើញខ្ញុំស្រមុកលើអង្រឹង ហើយតែងតែចោទសួរថា "ខ្ញុំមិនយល់សោះ តើមូលី រៀនមេរៀនរបៀបយ៉ាងដូចម្តេច បើឃើញតែរៀនដេកយ៉ាងនេះ ?"

បានចូលរៀនវិទ្យាល័យ

នៅសាលារបស់ខ្ញុំគឺវិទ្យាល័យសង្គមរាស្ត្រនិយម ការសិក្សាចែកជាពីរផ្នែក៖ ផ្នែកបឋមភូមិស្ថិតនៅក្នុងវិទ្យាល័យទួលគោក ជាប់នឹងសាលាបឋមសិក្សា ពៅ អ៊ុម ឯផ្នែកមធ្យមភូមិស្ថិតនៅចំការមន ។ បងប្រុសទីមួយរបស់ខ្ញុំ គាត់តែងទៅរៀននៅចំការមន ចំណែកខ្ញុំៗទៅរៀននៅទួលគោក ។ រាល់ព្រឹកខ្ញុំចេញដំណើរពីផ្ទះទៅទិសខាងជើង ដោយធាក់កង់តាមមហាវិថីម៉ៅសេទុង ឆ្លងកាត់តាមមហាវិថីសហភាពសូវៀត បន្តតាមវិថីសម្តេច ប៉ែន នុត[21] រហូតដល់ខាងមុខមហាវិទ្យាល័យដូរតន្ត្រី[22] ។ កាលណាមកដល់អាគារមហាវិទ្យាល័យដូរតន្ត្រី ខ្ញុំតែងតែកំណត់ថាដល់ទីដៅហើយ ព្រោះអាគារវិទ្យាល័យរបស់យើងស្ថិតនៅក្បែរនោះ ។

[21] សម័យឥឡូវ វិថីនេះមានឈ្មោះថា វិថីសេនាប្រមុខ គិម អ៊ីល ស៊ុង ។

[22] ក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ មានមហាវិទ្យាល័យតូរ្យតន្ត្រីមួយនៅម្តុំសាលា ពៅ អ៊ុម គេអាចសំគាល់បានដោយសារឧបករណ៍ភ្លេង ឬ ស្នូរភ្លេង ដែលពួកនិស្សិតហាត់លេងនៅទីនោះ ។

សាលារបស់យើង សាងសង់អំពីឈើប្រក់ក្បឿងខ្លះ ប្រក់ហ្វីប្រូស៊ីម៉ង់ខ្លះ ។ នៅក្នុងថ្នាក់រៀននីមួយៗ ប្រដាប់ប្រដារប្រើប្រាស់ ឬ គ្រឿងសង្ហារិម អសង្ហារិម ក៏មិនខុសគ្នាប៉ុន្មានពីថ្នាក់រៀន នៅសាលាឯកូមិស្សាយពលឡើយ ។ ខុសគ្នាតែនៅភ្នំពេញ ក្នុងថ្នាក់រៀន មានបំភ្លឺដោយភ្លើងអគ្គិសនី ។ សិស្សានុសិស្សភាគច្រើនធ្វើដំណើរមករៀនដោយជិះទោចក្រយានដូចខ្ញុំដែរ ។ សិស្សដែលមានឪពុកម្តាយជាអ្នកធូរធារ គេជិះម៉ូតូ(ទោចក្រយានយន្ត) ឬ អ្នកខ្លះជិះរថយន្តមកជាមួយឪពុកម្តាយរបស់គេ ឬ អ្នកខ្លះទៀត មានអ្នកបើកបរជូនដំណើរមកជាមួយ ។ តាមរយៈរបៀបរបបធ្វើដំណើរមករៀន គេអាចសំគាល់បាននូវឋានៈសង្គមខុសៗគ្នារបស់សិស្សានុសិស្សទាំងនោះ ។ ក្នុងន័យនេះ ស្ថានភាពសង្គមរបស់ខ្ញុំ អាចនិយាយបានស្ថិតនៅផ្នែកអ្នកក្រីក្រដែលជាភាគច្រើនជាងគេ ។ ក៏ប៉ុន្តែ បើពិនិត្យឲ្យស៊ីជម្រៅទៅ ខ្ញុំក៏នៅគ្រាន់បើជាងសិស្សខ្លះទៀតដែលគ្មានផ្ទះសម្បែង ហើយស្នាក់នៅជ្រកកោនតាមផ្ទះបងប្អូន ឬ នៅតាមវត្តអារាម ។ នៅសម័យនោះ ខ្ញុំមិនដែលនឹកដល់ការតស៊ូរវាងវណ្ណៈ និង វណ្ណៈអ្វីណាមួយឡើយ ។ ពួកយើងដែលជាអ្នកកាន់ព្រះពុទ្ធសាសនា មានជំនឿថា អ្នកមាន អ្នកក្រ អ្នកធំ ឬ អ្នកតូចមានភាពខុសគ្នាក៏អាស្រ័យដោយផលកម្មដែលគេសាងក្នុងជាតិមុន ឬ មានសំណាងក្នុងជាតិនេះ ។ បើជាតិនេះ យើងមានភាពទន់ទាប តែបើយើងខិតខំប្រឹងប្រែង យើងក៏អាចផ្លាស់ប្តូរវាសនាយើងបាន បើមិនបានក្នុងជាតិនេះ យើងនឹងគង់បានសម្រេចនៅជាតិក្រោយ ។ ជីវិត ឬ វាសនារបស់យើងត្រូវចាក់ពុម្ពឡើង ដោយការចាប់ជាតិឡើងវិញរបស់យើងម្នាក់ៗ ។

នៅភ្នំពេញ សាស្ត្រាចារ្យជាច្រើន ច្រើនតែជាស្ត្រី ។ អ្នកគ្រូៗទាំងនោះ ច្រើនតែជាភរិយារបស់មន្ត្រីជាន់ខ្ពស់ ឬ ពាណិជ្ជករ អ្នកមានៗ ។ ស្វាមីភរិយាខ្លះប្រកបរបរជាសាស្ត្រាចារ្យទាំងប្តីទាំងប្រពន្ធ ។ អ្នកទាំងនោះ បើករថយន្ត

មកធ្វើការ រីឯអ្នកខ្លះទៀត ត្រូវបានជូនដំណើរដោយអ្នកបើកបរដែលស្លៀកពាក់ឯកសណ្ឋានផង ។ លើកលែងតែបុគ្គលិកនៅការិយាល័យខ្លះ ខ្ញុំមិនដែលឃើញសាស្ត្រាចារ្យណាមកបង្រៀនដោយជិះកង់ ឬ ជិះម៉ូតូទេ ។ ពួកគាត់សុទ្ធតែមានរថយន្តស្ទើរតែគ្រប់ៗគ្នា ។ កាលនោះ មន្ត្រីណាដែលមានប្រពន្ធជាអ្នកគ្រូ សុទ្ធតែចាត់ទុកថាជាមនុស្សគ្រាន់បើ ។ មានប្រពន្ធជាអ្នកគ្រូ គ្រាន់បើជាងអ្នកដែលមានភរិយានៅផ្ទះធម្មតា ។

អ្នកគ្រូរបស់ខ្ញុំមួយចំនួន សុទ្ធតែធ្លាប់បានទៅរស់នៅឯប្រទេសបារាំងជាមួយស្វាមី ដែលមានខ្លះជានិស្សិតសាលាជាន់ខ្ពស់ ឬ ជាមន្ត្រីដែលត្រូវបានទៅរៀនសូត្របន្ថែម ឬ ត្រូវទៅធ្វើកម្មសិក្សា ។ កាលសម័យនោះ អ្នកធ្លាប់បានទៅបរទេសជាពិសេស ទៅប្រទេសបារាំង សុទ្ធតែត្រូវបានទទួលការគោរពរាប់អានខ្ពស់ជាងអ្នកនៅក្នុងស្រុក ។ គេច្រើនហៅអ្នកទាំងនេះថា "ជើងស្រុកបារាំង" ។ បើនៅស្រុកស្រែគ្រូបង្រៀនមានប្រជាប្រិយភាព នៅទីក្រុងអ្នក "ជើងស្រុកបារាំង" ក៏ប្រជាប្រិយណាស់ដែរ ។ យុវជនដូចជារូបខ្ញុំជាដើម តែងតែស្រមៃចង់ទៅស្រុកបារាំងជានិច្ច ។ អ្នកគ្រូៗរបស់ខ្ញុំទាំងនោះ និយាយភាសាបារាំងច្រើនជាងភាសាខ្មែរ ហើយស្លៀកពាក់តាមម៉ូតទំនើបៗទៀតផង ។

នៅឆ្នាំដំបូង ការសិក្សារបស់ខ្ញុំមានការលំបាកបន្តិច ។ វិលវល់នឹងជីវិតថ្មោងថ្មីនៅទីក្រុង ខ្ញុំប្រហែលជាត្រូវការពេលវេលាខ្លះ ដើម្បីឲ្យស៊ាំនឹងជីវភាពនេះ ។ នៅទីបញ្ចប់ឆមាសទី ១ ក្នុងចំណោមសិស្ស ៤០ នាក់ ខ្ញុំត្រូវទទួលចំណាត់ថ្នាក់ទី ២៣ ។ ក៏ប៉ុន្តែនៅចុងឆ្នាំ ខ្ញុំឡើងមកទី ១៨ វិញ ។ នៅទីក្រុងភ្នំពេញ ខ្ញុំឃើញមិត្តរួមថ្នាក់របស់ខ្ញុំ គេមានចំណេះដឹងទូទៅច្រើនជាងខ្ញុំ ដោយសារគេជាអ្នកទីក្រុង ។ ក៏ប៉ុន្តែ ទោះបីជាខ្ញុំមានប្រភពមកពីស្រែដែលគេហៅថាអ្នកស្រុកស្រែក៏ដោយ ក៏ខ្ញុំរៀនឈ្នះអ្នកទីក្រុងខាងផ្នែកតែងសេចក្តីជាភាសាបារាំងដែរ ។ ខ្ញុំនឹកមិនដល់ថា

ខ្ញុំអាចឈ្នះគេខាងផ្នែកវិជ្ជានេះសោះ ព្រោះតាមធម្មតាអ្នកនៅទីក្រុងត្រូវតែមានប្រៀបជាងយើងជានិច្ច ។ ក្នុងការតែងសេចក្តីជាភាសាបារាំងនេះ បើសិស្សគ្រាន់បើគេទទួលពិន្ទុ ១១ ឬ ១២ ខ្ញុំទទួលបាន ១៣ ឬ ១៤ ។ អ្នកគ្រូខាងផ្នែកភាសាបារាំង តែងហៅខ្ញុំឲ្យឈរអានអត្ថបទរបស់ខ្ញុំ ដែលបានពិន្ទុល្អជាងគេ ឲ្យសិស្សទាំងអស់ស្តាប់ ។ ខ្ញុំ មានមោទនភាពណាស់ចំពោះលទ្ធផលដ៏ល្អនេះ ទោះបីជាកាលសម័យនោះ ខ្ញុំនៅមិនទាន់និយាយបារាំងបានល្អនៅឡើយក៏ដោយ ។

វិធីពង្រីកចំណេះខាងភាសាបារាំង

ដើម្បីហាត់និយាយបារាំងឲ្យបានស្ទាត់ល្អ ខ្ញុំតែងជិះកង់ទៅតំបន់វត្តភ្នំដែលមានជនជាតិបារាំងភាគច្រើនស្នាក់អាស្រ័យនៅ ។ តាមធម្មតាខ្ញុំតែងសង្កេតឃើញពួកបារាំងធ្វើដំណើរឡើងចុះ តាមដងផ្លូវ ឬ តាមសួនច្បារមុខវិទ្យាល័យបារាំងដេកាត (Descartes) ។ ពេលទៅដល់ទីនោះ ខ្ញុំផ្អែកទោចក្រយានរបស់ខ្ញុំទល់នឹងដើមក្ងោកដ៏ធំ រួចឈរសម្ងំចាំមើលក្រែងមានបារាំងដើរមក ។ ពេលឃើញ ខ្ញុំស្រែកសួរជាភាសាបារាំងថា៖ "លោក លោកស្រី អញ្ជើញទៅណា? ឬ ថា លោក លោកស្រីឈ្មោះអ្វី?" ជាដើម ។ ជនជាតិបារាំងទាំងនោះហាក់ដូចជាភ្ញាក់ផ្អើលយ៉ាងខ្លាំងចំពោះសំណួររបស់ខ្ញុំ ដែលមិនច្បាស់ នៅមានសំនៀងខ្មែរនៅឡើយ ។ នៅពេលខ្លះ នៅពេលបារាំងឆ្លើយមកវិញ ខ្ញុំស្តាប់មិនបាន ព្រោះបារាំងនិយាយញាប់ពេក ។ ទោះជាយ៉ាងណាក្តី ក្រោយពីបាននិយាយជាមួយបារាំងមួយម៉ាត់ ឬ ពីរម៉ាត់ ខ្ញុំក៏អស់ចិត្តដែរ ។ នៅថ្នាក់រៀនឯទៀត គេមានជនជាតិបារាំងជាគ្រូបង្រៀនភាសាបារាំង ដូច្នេះពួកសិស្សៗមិនពិបាកទៅហាត់រៀននិយាយភាសាបារាំងនៅវត្តភ្នំដូចខ្ញុំឡើយ ។

ការសិក្សានៅភ្នំពេញរបស់យើង ត្រូវបានផ្អាកជាញឹកញាប់ក្នុងមួយខែៗ ដោយសាររាជរដ្ឋាភិបាលត្រូវការនាំសិស្សានុសិស្សទៅចូលរួមក្នុងពិធីផ្សេងៗ ដូចជាធ្វើបដិសណ្ឋារកិច្ចទទួលអ្នកដឹកនាំនៃប្រទេសជាមិត្តនានា ដែលមកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជាយើង ។ នៅសម័យនោះ សង្គមរាស្ត្រនិយមក្រោមការដឹកនាំរបស់សម្តេច សីហនុ មានមិត្តភក្តិជាច្រើននៅក្នុងពិភពលោក ជាពិសេសក្នុង ចំណោមប្រទេសតតិយលោក ។ ក្នុងពិធីបដិសណ្ឋារកិច្ចនោះ ពួកយើងត្រូវស្លៀកពាក់ឯកសណ្ឋានយុវន ដែលមានឈ្មោះពិតប្រាកដថា "យុវជនរាជសង្គមនិយមខ្មែរ" ។ ឯកសណ្ឋាននោះគឺ ខោអាវកាគីដៃវែង ជើងវែង ក្រវ៉ាត់កពណ៌ខ្មៅ និងព្យួរបន្តោងមានព្រះឆាយាលក្ខណ៍សម្តេច នៅហោប៉ៅអាវខាងលើខាងមុខផង ។ ឯកសណ្ឋានទាំងនោះ យើងត្រូវចំណាយប្រាក់ខ្លួនយើងដើម្បីទិញ ឬ កាត់នៅហាងចិនដែលមានដេរដាសនៅក្នុងរាជធានី ។ ដូច្នេះ យើងស្លៀកឯកសណ្ឋានសាលានៅថ្ងៃរៀនធម្មតា ឬ ស្លៀកពាក់ឯកសណ្ឋានយុវន នៅពេលមានពិធីសំខាន់ៗ ។ បន្ថែម លើពិធីបដិសណ្ឋារកិច្ច យើងក៏ត្រូវចូលរួមជាញឹកញាប់ក្នុងបាតុកម្មផ្សេងៗ ដែលត្រូវបានរៀបចំឡើង ដើម្បីគាំទ្រសម្តេចឪព្រះប្រមុខរដ្ឋ ឬ ដើម្បីធ្វើការហត្ថកម្មជាច្រើនទៀតផង ។

បានចូលសិក្សានៅមហាវិទ្យាល័យពាណិជ្ជសាស្ត្រ

មួយឆ្នាំក្រោយមក បងប្រុសទីមួយរបស់ខ្ញុំ ក៏ឈប់រៀននៅវិទ្យាល័យសង្គមរាស្ត្រនិយម ព្រោះគាត់ប្រឡងជាប់ចូលរៀននៅវិទ្យាស្ថានគរុកោសល្យនៅកំពង់កន្ធួតក្នុងខែត្រកណ្តាល ។ គាត់ត្រូវទទួលការបំពាក់បំប៉នវិជ្ជាគរុកោសល្យក្នុងរយៈពេលពីរឆ្នាំ មុននឹងចេញទៅបង្រៀនសិស្សតាមសាលា ។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏គាត់នៅតែតាមត្រួតពិនិត្យការសិក្សារបស់ខ្ញុំដែរ ។ ថ្ងៃមួយនៅពេល

វិស្សមកាល យើងធ្វើដំណើរទៅលេងស្រុកកំណើតរបស់យើង ឯកូមិស្នាយពលទាំងអស់គ្នា ។ បងប្រុសខ្ញុំហុចស្រោមសំបុត្រដ៏ធំមួយមកឲ្យខ្ញុំ ។ ក្នុងនោះមានឯកសារមួយចំនួន ជាពិសេស ពាក្យសុំប្រឡងចូលរៀននៅមហាវិទ្យាល័យពាណិជ្ជសាស្ត្រ ដែលសម័យនោះ គេហៅទូទៅថា "សាលាពាណិជ្ជកម្ម" ។ ខ្ញុំមិនដែលដឹង មិនដែលឮឈ្មោះសាលានោះឡើយ ។ ម្យ៉ាងទៀតខ្ញុំក៏មិនយល់ថានៅពេលរៀនចប់អាចប្រកបការងារអ្វីដែរ ។ ឪពុកម្តាយខ្ញុំ ក៏ពុំមានប្រតិកម្មអ្វីចំពោះគំនិតរបស់បងប្រុសខ្ញុំនោះទេ ។ មុខវិជ្ជាពាណិជ្ជកម្មជាមុខវិជ្ជាដ៏ថ្មីសន្លាង សម្រាប់ពួកយើង ជាពិសេស ចំពោះឪពុកម្តាយខ្ញុំ ដែលតែងតែប្រាថ្នាឲ្យកូនចៅបានរៀនសូត្រ ដើម្បីបំរើការងារក្នុងរាជការ ជាជាងធ្វើការក្នុងវិស័យឯកជន ។ តាមធម្មតាអ្នកមានសញ្ញាប័ត្រខាងផ្នែកពាណិជ្ជកម្ម តែងរកការងារបានក្នុងក្រុមហ៊ុនឯកជន ច្រើនជាងក្នុងក្របខ័ណ្ឌមន្ត្រីរាជការ ។ នៅទីបំផុត ខ្ញុំក៏យល់ព្រមត្រៀមខ្លួនប្រឡងចូលរៀននៅសាលាពាណិជ្ជកម្ម ឬ មហាវិទ្យាល័យពាណិជ្ជសាស្ត្រ ។ ក្នុងការប្រឡងចូលនេះគេរើសតែសិស្សចំនួន ៤០ នាក់តែប៉ុណ្ណោះ ក្នុងចំណោមបេក្ខជន ៧០០ នាក់សំរាប់វគ្គសិក្សាកំរិតទីមួយ ។ មុខវិជ្ជាតែងសេចក្តីជាភាសាខ្មែរ ជាមុខវិជ្ជាមួយដែលអាចទទួលពិន្ទុច្រើនក្នុងការប្រឡងប្រជែង ។

ខ្ញុំមិនបានត្រៀមប្រឡងជាដុំកំភួនអ្វីទេ លើកលែងតែរំលឹកឡើងវិញនូវក្បួនរេខានព្វន្ត (Arithmétique) ខ្លះៗតែប៉ុណ្ណោះ ។ នៅក្នុងវិញ្ញាសាតែងសេចក្តីជាភាសាខ្មែរ មានប្រធានបទស្តីពីសកម្មភាពនៅក្នុងផ្ទះលក់ទំនិញមួយ ។ ដោយធ្លាប់មានទំនាក់ទំនងជាញឹកញាប់ជាមួយពួកពាណិជ្ជករចិននៅកូមិស្នាយពល ខ្ញុំរៀបរាប់បានក្បោះក្បាយល្អណាស់ អំពីជីវិតប្រចាំថ្ងៃយ៉ាងមមាញឹករបស់ចិនលក់ចាប់ហួយម្នាក់ឈ្មោះចិកសេង ។ តាមពិត ចិកសេង គ្រាន់តែជាឈ្មោះដែលខ្ញុំប្រឌិតឡើងជាតួអង្គសំខាន់នៅក្នុងការតែងសេចក្តីរបស់ខ្ញុំ សំរាប់ការប្រឡងប្រជែង

តែប៉ុណ្ណោះ ។

ខ្ញុំរៀបរាប់ថា ចិកសេង ជាមនុស្សឧស្សាហ៍ធ្វើការ ។ ជារៀងរាល់ថ្ងៃគាត់ភ្ញាក់ពីព្រលឹមប្រកបដោយទឹកមុខញញឹមជានិច្ច រង់ចាំទទួលភ្ញៀវ និង រៀបចំទុកដាក់ទំនិញរបស់គាត់ឲ្យមានរបៀបរៀបរយគួរជាទីគាប់ភ្នែក ។ នៅទីបំផុត ខ្ញុំក៏ប្រឡងជាប់ចូលរៀនមហាវិទ្យាល័យពាណិជ្ជសាស្ត្រ ហើយខ្ញុំនឹកថាប្រហែលជាខ្ញុំបានពិន្ទុល្អក្នុងការតែងសេចក្តីស្តីអំពី ចិកសេង នោះពុំខានឡើយ ។

និស្សិតទាំង ៤០ នាក់ដែលបានទទួលជោគជ័យក្នុងការប្រឡងប្រជែងនេះចេញមកពីឋានៈសង្គមផ្សេងៗគ្នាគឺ ក្នុងចំណោមអ្នកស្រែចំការ មន្ត្រីរាជការ មន្ត្រីថ្នាក់ធំ និង គហបតីអ្នកមានទ្រព្យសម្បត្តិជាដើម ។ ក្នុងនោះ ខ្ញុំចាប់ផ្តើមរាប់អានគ្នាជាមិត្តភក្តិចាប់ពីអាទិត្យទីមួយ ជាមួយយុវនិស្សិតមួយចំនួន ដែលយូរៗទៅក៏ក្លាយទៅជិតស្និទ្ធជារៀងរហូតមក ។ ទីមួយ យុវតីពីរនាក់ ម្នាក់ឈ្មោះកញ្ញា អ៊ឹង កនិដ្ឋា ជាកូនស្រីរបស់លោក អ៊ឹង អ៊ី ជាមន្ត្រីធំក្នុងព្រះបរមរាជវាំង ធ្លាប់កាន់តំណែងជារដ្ឋមន្ត្រី[23] ថ្នាក់អគ្គមហាសេនា និង អភិបាលខេត្តជាច្រើនដង ។ ម្នាក់ទៀតគឺ កញ្ញា កែវ សូដាវ៉ា ជាសាច់ញាតិរបស់មហាសេដ្ឋីក្នុងស្រុកម្នាក់ ។ អ្នកទាំងពីរធ្វើដំណើរមករៀន ដោយមានអ្នកបើកបរក្នុងឯកសណ្ឋានបរជិយន្តជូនមករាល់ថ្ងៃ ។ កញ្ញាទាំងពីរសុទ្ធតែបានរៀននៅសាលាបារាំងគឺ ម្នាក់នៅវិទ្យាល័យដេកាត (Descartes) និង ម្នាក់ទៀតនៅសាលាដូនជីកាតូលិកឯទីក្រុងកែប ។ អ្នកទាំងពីរនិយាយភាសាបារាំងយ៉ាងស្ទាត់ជំនាញ និង យ៉ាងច្បាស់លាស់ ។ ក្នុងចំណោមប្រុសៗ ខ្ញុំស្គាល់យុវជនម្នាក់ឈ្មោះ អ៊ុំ មន្តា ដែលមានឪពុកជាតម្រួតក្រុង ។

---

[23] Ministère de l `Information, Documents, Cabinets Ministériels Khmers, du 18 mars 1945 au 18 mars 1970, Phnom Penh, 1970, p. 34. (ឯ. ឧ. អ៊ឹង អ៊ី មានតួនាទីជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ ថ្នាក់អគ្គមហាសេនាដែលមានឋានៈធំជាងគេក្នុងកុងស៊ីយ៍សេនាបតី (Conseil des Ministres) គឺស្មើរដ្ឋមន្ត្រីទី១ ពីថ្ងៃទី ១៨ មីនា ដល់ ១៣ សីហា ១៩៤៥ ក្នុងគណៈរដ្ឋមន្ត្រីដឹកនាំផ្ទាល់ដោយព្រះមហាក្សត្រព្រះករុណាព្រះបាទ នរោត្តម សីហនុ)

មិត្តម្នាក់នេះជិះម៉ូតូហុងដាមករៀន ហើយតែងតែបបួលពួកយើងទៅទទួលទានគុយទាវរាល់ព្រឹកនៅភោជនីយដ្ឋានក្បែររោងអ្នកតាចិន ដែលនៅមិនឆ្ងាយពីសាលារបស់យើងនោះ ។ រាល់ៗដង នៅពេល មន្តា បបួលពួកយើងទៅញុំាគុយទាវ ពួកយើងមិនដែលប្រកែកទេ ហើយតែងនឹកក្នុងចិត្តថាមុខរបរជាតម្រួតក្រុង (នគរបាលក្រុង) របស់ឪពុកមន្តា ប្រហែលជារកប្រាក់ចំណូលបានច្រើនណាស់ ទើបកូនមានលុយកាក់ចាយវាយឥតឈប់ឈរជារៀងរាល់ថ្ងៃ ។ ក៏ប៉ុន្តែតាមពិតមិនមែនឪពុកមន្តាទេ ដែលជាអ្នកផ្តល់ប្រាក់កាសឲ្យគឺ បងស្រីរបស់មន្តាម្នាក់ដែលជាអ្នករាំរបាំព្រះរាជទ្រព្យ ដែលតែងតែផ្តល់ប្រាក់កាសដល់ មន្តា មិនដែលដាច់ ។ បងស្រីនោះជាគូកំណាន់ចិត្តរបស់មន្ត្រីធំម្នាក់ នៅក្នុងព្រះបរមរាជវាំង ដែលជាអ្នកមានសម្បត្តិស្តុកស្តម្ភ ។ មន្តា ចូលចិត្តទុកសក់វែងដូចពួកហ៊ីពី ស្លៀកខោជីន (Jean) ឬខោជើងធំមិនដែលខាន ។

ក្នុងចំណោមមិត្តភ័ក្តិទាំងអស់ ខ្ញុំនៅក្មេងជាងគេ ។ ក្រៅពីនោះយើងមានមិត្តពីរនាក់ទៀត មានអាយុចាស់ជាងគេនៅក្នុងថ្នាក់គឺ ស៊ុន សារ៉ុម និង នូ វ៉ាន់ថន ។ សារ៉ុម វ៉ាន់ថន មន្តា និង ខ្ញុំ យើងជាមិត្តជិតស្និទ្ធណាស់ ។ ឪពុកសារ៉ុមជាបសុពេទ្យ ដូចនេះ គ្រួសារសារ៉ុមពុំមានបញ្ហាហិរញ្ញវត្ថុអ្វីទេ ។ សារ៉ុមជាមនុស្សខ្ជិយ ។ ក៏ប៉ុន្តែ សម័យនោះ ពួកយើងមិនសូវចាប់អារម្មណ៍ពីលក្ខណៈផ្លូវភេទរបស់គាត់ប៉ុន្មានទេ យើងគ្រាន់តែនិយាយចំអន់លេង ពីអាកប្បកិរិយាមាយាម្ចិកម្ច៉ក់ដូចស្រីរបស់គាត់តែប៉ុណ្ណោះ ។ សារ៉ុម និង មន្តា ដើរជាមួយគ្នាជានិច្ចមិនសូវនៅបែកគ្នាឡើយ ។ វ៉ាន់ថន មានជីវភាពខ្សត់ខ្សោយដូចខ្ញុំដែរ ។ មុននឹងបានមកចូលរៀននៅមហាវិទ្យាល័យពាណិជ្ជសាស្ត្រនេះ វ៉ាន់ថន ប្រកបរបរជាអ្នកប្រដាល់ដើម្បីរកប្រាក់មកចិញ្ចឹមម្តាយចាស់ និង ប្អូនស្រីរបស់គាត់ ។ ខ្ញុំតែងដើរជាមួយវ៉ាន់ថនជានិច្ច ដោយសារផ្ទះយើងទាំងពីរនៅជិតគ្នា ។ វ៉ាន់ថន គ្មានមធ្យោបាយធ្វើ

ដំណើរ ខ្ញុំមានទោចក្រយានកញ្ចាស់មួយ ។ ដូច្នេះ យើងប្រវាស់ដៃគ្នាគឺ វ៉ាន់ថន ជាអ្នកធាក់កង់ ឯខ្ញុំចាំជិះពីក្រោយ ។ គាត់ប្រើកម្លាំង ឯខ្ញុំដាក់ទោចក្រយានរបស់ខ្ញុំឲ្យប្រើរួមគ្នា ។

មុខវិជ្ជាដែលពួកយើងរៀនមានមុខវិជ្ជាគណនេយ្យ ពាណិជ្ជកម្ម ច្បាប់រដ្ឋប្បវេណី ច្បាប់ពាណិជ្ជកម្ម (ច្បាប់ទាំងពីរនេះ យើងរៀនគោលធំៗ មិនបានស៊ីជម្រៅប៉ុន្មានទេ) វិទ្យាសាស្ត្រសេដ្ឋកិច្ច និង នព្វន្តសាស្ត្រដែលទាក់ទងនឹងសកម្មភាពពាណិជ្ជកម្មជាដើម ។ សាស្ត្រាចារ្យសុទ្ធសឹងជាមន្ត្រីជាន់ខ្ពស់ ដែលមានបទពិសោធន៍ក្នុងមុខងារសាធារណៈ ក៏ដូចជាមុខងារក្នុងវិស័យឯកជន ។ សាស្ត្រាចារ្យខ្លះធ្លាប់កាន់ ឬ កំពុងកាន់តំណែងជារដ្ឋមន្ត្រីក្នុងរាជរដ្ឋាភិបាល ។ អស់លោកទាំងនោះ មានសញ្ញាប័ត្រជាន់ខ្ពស់មកពីបរទេស ជាពិសេសមកពីប្រទេសបារាំង ។ ពួកគាត់សុទ្ធតែមានការងារធ្វើនៅច្រើនកន្លែងគឺ ធ្វើការប្រចាំក្រសួងផង បង្រៀននៅតាមមហាវិទ្យាល័យផង ។ លោកសាស្ត្រាចារ្យខ្លះបង្រៀននៅមហាវិទ្យាល័យពាណិជ្ជសាស្ត្រផង និង នៅមហាវិទ្យាល័យនិតិសាស្ត្រ និង សេដ្ឋសាស្ត្រផង ។

នៅពេលដែលខ្ញុំចូលរៀននោះលោក ខៀវ សំផន ដែលជាសាស្ត្រាចារ្យម្នាក់ទើបនឹងបាត់ខ្លួនពីរាជធានី ។ ដូច្នេះ ខ្ញុំគ្រាន់តែឮឈ្មោះគាត់តែប៉ុណ្ណោះ ។ លោក ខៀវ សំផន មានឈ្មោះល្បី ព្រោះគាត់មានឈ្មោះក្នុងចំណោមអ្នកដឹកនាំខ្មែរក្រហម ។ ខុសស្រឡះពីអស់លោកសាស្ត្រាចារ្យឯទៀត ដែលមានអ្នកបើករថយន្តជូនដំណើរមកធ្វើការរៀងរាល់ថ្ងៃ ពីមាត់មួយទៅមាត់មួយ ខ្ញុំឮថាគាត់មកបង្រៀនដោយជិះទោចក្រយានយន្តវ៉េស្ប៉ា (Vespa) កញ្ចាស់មួយ ទោះបីជាគាត់មានឋានៈខ្ពង់ខ្ពស់ក៏ដោយ រហូតដល់ពេលគាត់ទិញបានរថយន្តចំណាស់បន្តិច ម៉ាកវ៉ុលវ៉ាហ្គែន (Volkwagen) ។ ក្នុងអាយុជាងសាមសិបឆ្នាំ លោក ខៀវ សំផន នៅលីវ ។ ផ្ទុយពីលោក ខៀវ សំផន យើងមានព្រឹទ្ធបុរសរងម្នាក់ដែលនៅលីវដែរ តែចូលចិត្ត

ប្រើរថយន្តកីឡា (Sport) បើកដំបូល ។ ពួកនិស្សិតខ្សឹបៗគ្នាថាលោកព្រឹទ្ធបុរសរងរូបនេះ ដើរលេងបារនៅម្តុំផ្សារធំថ្មីទល់ៗភ្លឺមិនដែលខានឡើយ ។

ក្នុងការសិក្សាជាដំបូង ខ្ញុំជួបនឹងការលំបាកជាច្រើន ដោយសារមុខវិជ្ជាទាំងឡាយសុទ្ធតែថ្មីសន្លាង សំរាប់ខ្ញុំទាំងអស់ ។ ក៏ប៉ុន្តែ នៅទីបញ្ចប់ឆ្នាំទីមួយ ខ្ញុំក៏បានក្លាយទៅជានិស្សិតពូកែម្នាក់នៅក្នុងថ្នាក់ ។ នៅពេលនោះ ខ្ញុំនឹកប្រដូចខ្លួនខ្ញុំដូចជាវត្ថុរឹងអ្វីមួយដែលត្រូវគេបោះទៅក្នុងទឹក ។ ជាដំបូង វត្ថុនោះធ្លាក់ទៅដល់បាតខាងក្រោម តែក្រោយមកបន្តិចម្តងៗ វត្ថុនោះក៏ងើបឡើងលើរហូតដល់អណ្តែតលើផ្ទៃទឹកវិញ ។ អ្វីដែលគួរឲ្យភ្ញាក់ផ្អើលជាងគេម្តងទៀតគឺ ខ្ញុំរៀនឈ្នះមិត្តរួមថ្នាក់ទាំងអស់ ខាងផ្នែកភាសាបារាំង ទោះជាអ្នកខ្លះធ្លាប់រៀននៅវិទ្យាល័យដេកាត ឬ វិទ្យាល័យបារាំងឯទៀតក៏ដោយ ។

គន់មើលសិស្សនារីវិទ្យាល័យដេកាត

នៅសម័យនោះ ពួកយើងមានអ្នកគ្រូជនជាតិបារាំងម្នាក់ ឈ្មោះអ្នកស្រី នីកូល ប៊ែរីយេ (Nicole Berrier) ។ ពួកយើងរៀនពីគាត់នូវមុខវិជ្ជាសំខាន់ៗដូចជាក្បួនវេយ្យាករណ៍ និង ការសរសេរសំបុត្រឆ្លើយឆ្លងខាងផ្នែកពាណិជ្ជកម្មជាភាសាបារាំង ។ ចាប់តាំងពីខ្ញុំបានចូលរៀននៅមហាវិទ្យាល័យពាណិជ្ជសាស្ត្រមក ខ្ញុំមិនចាំបាច់ទៅចាំស្តាក់និយាយភាសាបារាំង ជាមួយជនជាតិបារាំង នៅឯវត្តភ្នំទៀតទេ ។ ព្រោះខ្ញុំព្យាយាមនិយាយជាមួយអ្នកគ្រូខ្ញុំផ្ទាល់តែម្តង ។ ក៏ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក៏ពួកយើងនៅតែបន្តទៅដើរលេងនៅតាមតំបន់វត្តភ្នំតទៅទៀតដែរ ។ នៅពេលសម្រាក ពួកយើងនាំគ្នាទៅមើលសិស្សនារីៗនៃវិទ្យាល័យដេកាត លេងកីឡាបាល់បោះ ឬ បាល់ទះ ក្នុងសំលៀកបំពាក់ខោខ្លីអាវខ្លីរបស់នាង ដែលបញ្ចេញសាច់ភ្លៅរាងស្រឡូកស្រឡួន ធ្វើឲ្យពួកយើងជក់អារម្មណ៍យ៉ាងខ្លាំង ។ នៅពេលនោះ ខ្ញុំ

ពុំបានដឹងថាពួកសិស្សនារីៗទាំងនោះ ពាក់ស្រោមជើងវែងជាប់សាច់ ដែលបារាំងហៅថាកុលឡង់ (Collant) នោះឡើយ ។

អាហារូបករណ៍ពីរាជរដ្ឋាភិបាល

នៅបំណាច់ឆ្នាំទីមួយ ខ្ញុំដាក់ពាក្យសុំអាហារូបករណ៍ពីរាជរដ្ឋាភិបាលដោយសារតែជីវភាពរបស់ខ្ញុំកាន់តែដុនដាបទៅ ។ ក្រោយពីឆ្នាំសិក្សាទីពីរចាប់ផ្តើមបានប៉ុន្មានសប្តាហ៍ ខ្ញុំក៏ទទួលដំណឹងល្អថាក្រសួងសិក្សាធិការបានសំរេចផ្តល់អាហារូបករណ៍ឲ្យខ្ញុំចំនួន ៦០០ រៀល[24] ក្នុងមួយត្រីមាស ។ ថ្ងៃនោះ ដោយត្រេកអរពេកខ្ញុំក៏ប្រញាប់ប្រញាល់ធ្វើដំណើរទៅភូមិស្នាយពល ដើម្បីនាំដំណឹងដ៏ល្អនេះទៅជំរាបឪពុកម្តាយខ្ញុំ ។ ម្តាយខ្ញុំមានការរីករាយជាខ្លាំង ព្រោះអាហារូបករណ៍នេះនឹងជួយសំរាលបន្ទុកដ៏ធ្ងន់ធ្ងរបស់ក្រុមគ្រួសារយើង ។

នៅថ្ងៃបើកប្រាក់លើកទីមួយមកដល់ ខ្ញុំបបួលបងប្រុសខ្ញុំទាំងពីរនាក់ ទៅជើរលេងកំសាន្តនៅទីក្រុងភ្នំពេញទាំងអស់គ្នា ។ បងឈឿន ធ្វើដំណើរពីកំពង់កន្លតមកភ្នំពេញ ដើម្បីចូលរួមជាមួយពួកយើង ។ គាត់ទើបទិញបានទោចក្រយានយន្តកញ្ចាស់មួយ ។ ដូច្នេះ ក្នុងដំណើរកំសាន្តក្នុងក្រុងភ្នំពេញ ពួកយើងជិះម៉ូតូមួយទាំងបីនាក់ ។ យើងនាំគ្នាចូលភោជនីយដ្ឋាន ស្រស់ស្រូបអាហារឆ្ងាញ់ៗ ចូលហាងលក់ខោអាវ និង ចូលទស្សនាខ្សែភាពយន្ត ។ នៅសម័យនោះ ច្បាប់ចរាចរណ៍ត្រូវបានអនុវត្តបានត្រឹមត្រូវបង្គួរដែរ ។ តាមច្បាប់ចរាចរណ៍ យើងអាចជិះទោចក្រយានយន្តបានតែពីរនាក់ប៉ុណ្ណោះគឺ អ្នកបើកបរម្នាក់ និង អ្នកជិះខាងក្រោយម្នាក់ទៀត ។ បើប្រព្រឹត្តល្មើស យើងនឹងទទួលពិន័យពីតម្រួតក្រុងយ៉ាងធ្ងន់ធ្ងរ ។ ដូច្នេះ ពួកយើង

[24] មានតម្លៃស្មើ២០ដុល្លារ ដែលអាចទិញគុយទាវបានច្រើនចាន ព្រោះគុយទាវមួយចានថ្លៃតែ ៣ ទៅ ៥ រៀលប៉ុណ្ណោះ ។

ទាំងបីនាក់ត្រូវនាំគ្នាឃ្លាំមើលជៀសវាងកុំឲ្យជួបនឹងតម្រួត ។ យើងត្រូវលបមើលពីចម្ងាយ ។ នៅទីណាដែលមានតម្រួត គ្នាយើងម្នាក់ត្រូវចុះដើរហូតដល់ផុតផ្ទាយពីក្នែកតម្រួតនោះ ទើបលោតឡើងជិះម៉ូតូវិញ ។ អាហារូបករណ៍នោះមានចំនួនតិចតួចទេ តែសម័យនោះ ចំពេលដែលយើងកំពុងខ្វះខាត អាហារូបករណ៍នេះបានធ្វើឲ្យពួកយើងសប្បាយរីករាយឥតឧបមា ។

បន្ថែមលើការសិក្សានៅមហាវិទ្យាល័យពាណិជ្ជសាស្ត្រ ខ្ញុំនៅព្យាយាមទៅរៀនភាសាចិនរាល់ល្ងាច នៅវិទ្យាល័យព្រះស៊ីសុវត្ថិ ។ នៅសម័យនោះ ស្ថានទូតចិន ស្ថានទូតរុស្សី ស្ថានទូតអាល្លឺម៉ង់ សុទ្ធតែបានរៀបចំបង្រៀនភាសារៀងៗខ្លួន នៅវិទ្យាល័យព្រះស៊ីសុវត្ថិ ដោយមិនចាំបាច់បង់ប្រាក់ឡើយ ។ ចាប់ពីម៉ោង ៨ ល្ងាចទៅ ខ្ញុំចូលទៅរៀនភាសាចិនជាមួយលោកគ្រូជនជាតិចិន ដែលត្រូវបញ្ជូនមកពីទីក្រុងប៉េកាំង ។ លោកគ្រូចិនទាំងនោះនិយាយភាសាខ្មែរបានច្បាស់ល្អណាស់ ហើយភាគច្រើនសុទ្ធតែបានរៀននៅមហាវិទ្យាល័យអក្សរសាស្ត្រនៅរាជធានីភ្នំពេញ ។ អស់រយៈពេលមួយខែ ខ្ញុំចាប់ផ្តើមចេះនិយាយខ្លះៗ និង ចេះច្រៀងចំរៀងជាភាសាចិនមួយបទ ដែលលោកគ្រូនិយាយថាជាព្រះរាជនិពន្ធរបស់សម្តេចឪ និង ដែលត្រូវគេយកទៅបកប្រែជាភាសាចិន ។ ខ្ញុំទើបរៀនភាសាចិនបានមួយខែ ក៏មានព្រឹត្តិការណ៍មួយដ៏សំខាន់បានកើតឡើងនៅប្រទេសចិនគឺ បដិវត្តន៍វប្បធម៌ដែលបានបង្ខំឲ្យលោកគ្រូចិន ត្រឡប់ទៅស្រុករបស់ពួកគាត់វិញអស់ លែងបានបង្រៀនតទៅទៀត ។ ចាប់តាំងពីពេលនោះមក ខ្ញុំក៏ពុំមានឱកាសបានទៅរៀនភាសាចិនទៀតដែរ ។

ប្រឡងចេញយកសញ្ញាប័ត្រជាប់លេខ១

ការសិក្សាកំរិតទីមួយ នៅមហាវិទ្យាល័យពាណិជ្ជសាស្ត្រត្រូវប្រើរយៈពេលពីរឆ្នាំ ។ នៅទីបញ្ចប់ និស្សិតត្រូវប្រឡងយកសញ្ញាប័ត្រមួយបញ្ជាក់ពីការសិក្សាផ្នែកពាណិជ្ជសាស្ត្រ ដែលអាចជាជំនួយក្នុងការស្វែងរកការធ្វើទៅអនាគត ។ នៅជិតថ្ងៃប្រឡងសញ្ញាប័ត្រមួយថ្ងៃ នៅពេលដែលពួកយើងកំពុងហ្វឹកហាត់ ដើម្បីត្រៀមខ្លួនចូលប្រឡងយ៉ាងសកម្មនោះ សារ៉ុម ផ្តល់យោបល់ថា ដើម្បីប្រឡងឲ្យជាប់ពួកយើងត្រូវរៀបចំធ្វើពិធីសែនអ្នកតានៅក្នុងសាលា ។ យើងមិនត្រូវធ្វើមិនដឹងមិនឮអំពីឫទ្ធីបារមីរបស់អ្នកតានោះឡើយ ។ សំណែនមានក្បាលជ្រូក និង គ្រឿងស្រវឹងសុរា ស្រាបៀរជាដើម ។

មហាវិទ្យាល័យពាណិជ្ជសាស្ត្រតាំងនៅក្បែរព្រះសក្យមុនីចេតិយ ដែលនៅពីមុខស្ថានីយរថភ្លើង ។ នៅក្នុងបរិវេណសាលាផ្នែកខាងជើង មានដើមចេកដុះច្រូងច្រាងស៊ុបទ្រុប ។ នៅកណ្តាលទីធ្លាសាលា មានដើមពោធិមួយដើមដែលមានអាយុជាងមួយរយឆ្នាំដុះយ៉ាងខ្ពស់ ហើយដែលមានរោងអ្នកតាមួយនៅខាងក្រោម ។ នៅក្នុងបរិវេណនេះ ក៏មានកម្មករសាលាមួយគ្រួសាររស់នៅជាប្រចាំដែរ ។ កាលពីពេលមុន និស្សិតជាច្រើនជំនាន់ ធ្លាប់បានមកធ្វើពិធីសែនបន់ស្រន់សុំជ័យជំនះពីអ្នកតានេះដែរ ។ ដូច្នេះពួកយើងក៏សំរេចថាមិនត្រូវបំភ្លេចប្រពៃណីនេះទេ ។

នៅយប់នោះ សារ៉ុម ជាអ្នករៀបចំគ្រឿងសំណែន ហើយនាំយកទៅក្នុងបរិវេណសាលា ។ ពិធីសែនបន់ស្រន់ចាប់ផ្តើមនៅម៉ោង ៩ យប់ ក្នុងរាត្រីដ៏ស្ងាត់ជ្រងំក្រោមពន្លឺនៃចង្កៀងអគ្គិសនីមូលតូចមួយ ។ យើងម្នាក់ៗធ្វើការបួងសួងសុំឲ្យបារមីអ្នកតាជួយឲ្យពួកយើងប្រឡងជាប់ ។ តាមធម្មតា យើងត្រូវមានអាចារ្យនាំមុខនៅក្នុងពិធីក្រៅព្រះពុទ្ធសាសនានេះ តែពេលនោះយើងពុំមានអាចារ្យទេ ។ មួយ

ស្របក់ក្រោយមក យើងក៏បែកគ្នាដោយទុកគ្រឿងសំណែនទាំងអស់នៅក្រោមដើមពោធិនៅមុខអ្នកតា ។ ពួកយើងនឹកថាគ្រឿងសំណែនដែលមានក្បាលជ្រូក និងស្រាបៀរបួនដប់ដបដែលយើងមិនទាន់គាស់បើកផងនោះ នឹងបានទៅជាអាហារដ៏ប្រណិតសំរាប់គ្រួសារកម្មករសាលា ដែលរស់នៅជាប្រចាំក្នុងបរិវេណនោះមិនខានឡើយ ។ ខ្ញុំនឹកក្នុងចិត្តថា គំនិតនាំឲ្យមានពិធីបន់ស្រន់អ្នកតានេះ ប្រហែលជាចេញពីកម្មករសាលានោះ ព្រោះជាទម្លាប់ដែលគាត់តែងនាំឲ្យធ្វើជាយូរមកហើយ ។ នៅទីបំផុត ពួកយើងក៏ប្រឡងជាប់មែន ។ តែនៅក្នុងចិត្ត ខ្ញុំនៅតែគិតថាពួកយើងប្រឡងជាប់ ដោយសារការខំប្រឹងប្រែងរបស់យើង មិនមែនដោយសារការបន់ស្រន់នោះឡើយ ។ ខ្ញុំប្រឡងបានលេខ ១ ក្នុងចំណោមនិស្សិតដែលបានប្រឡងជាប់នាសម័យប្រឡងលើកទីមួយចំនួន ១៩ នាក់ ។ មន្ត្រា ជាប់លេខ ៣ សារ៉ុម ជាប់លេខ ៥ វ៉ាន់ថន លេខ ៩ ។ មិត្តនារីទាំងពីរនាក់គឺ កន្និដ្ឋា និង សូដាវ៉ា ប្រឡងពុំបានជាប់ដូចបំណងនៅលើកនេះទេ តែបានទទួលជោគជ័យនៅលើកក្រោយគឺ នៅសម័យប្រឡងទីពីរ ដែលប្រព្រឹត្តនៅប៉ុន្មានខែក្រោយមក ។ ជាមួយនឹងជោគជ័យជាប់លេខ ១ ក្នុងការប្រឡងយកសញ្ញាប័ត្រសិក្សាពាណិជ្ជកម្មកំរិតមួយនេះ ខ្ញុំក៏ប្រឡងជាប់លេខ ១ សម្រាប់ទទួលយកវិញ្ញាបនប័ត្រសិក្សារបស់រដ្ឋផ្នែកគណនេយ្យដែរ ។

តាមធម្មតាកាលណាយើងទទួលសញ្ញាប័ត្រសិក្សាខាងពាណិជ្ជកម្ម យើងត្រូវចេញទៅរកការងារនៅក្នុងក្រុមហ៊ុនរដ្ឋ ឬ ឯកជន ព្រោះតាមផ្លូវបច្ចេកទេស ការសិក្សាកំរិតនេះ គ្រាន់តែជាការបំប៉នមុខវិជ្ជាជីវៈ ឲ្យក្លាយទៅជាបុគ្គលិកការិយាល័យ ឬ គណនេយ្យថ្នាក់ក្រោម និង ថ្នាក់កណ្តាលរបស់ក្រុមហ៊ុនតែប៉ុណ្ណោះ មិនមែនជាការសិក្សាដើម្បីឈានទៅរកសញ្ញាប័ត្រជាន់ខ្ពស់តទៅទៀតឡើយ ។ ក៏ប៉ុន្តែចំពោះខ្ញុំៗនៅមិនទាន់ចង់ចេញទៅធ្វើការអ្វីទេ ខ្ញុំចង់បន្តការសិក្សាជាន់ខ្ពស់តទៅទៀត ។ ក្នុងករណីនេះ ខ្ញុំត្រូវដាក់ពាក្យប្រឡងចូលរៀននៅកំរិតទីពីរតទៅទៀត ។

ដោយសារខ្ញុំជានិស្សិតចាស់ប្រចាំសាលា ខ្ញុំអាចជ្រើសរើសវិញ្ញាសាប្រឡងចូលបាន ដោយមិនបាច់ធ្វើតេស្តខាងនព្វន្តសាស្ត្រទេ តែត្រូវធ្វើតេស្តខាងគណនេយ្យ ។ ខ្ញុំនឹកថាខ្ញុំពូកែខាងវិជ្ជាគណនេយ្យ ដូច្នេះខ្ញុំគ្មានបារម្ភអ្វីចំពោះការធ្វើតេស្តនេះទេ ។ ក៏ប៉ុន្តែ អ្វីដែលខ្ញុំជឿថាខ្លាំង ក៏ប្រែក្លាយទៅជាខ្សោយទៅវិញ ។ ខ្ញុំធ្លាក់តេស្តខាងផ្នែកគណនេយ្យ ដែលនាំឲ្យបរាជ័យក្នុងការប្រឡងចូលរៀនបន្តនៅមហាវិទ្យាល័យពាណិជ្ជសាស្ត្រ ។ យ៉ាងនេះហើយទើបខ្ញុំត្រូវបង្ខំចិត្តស្វែងរកការងារដោយខ្លួនឯង ។ ដោយជាប់រវល់ត្រៀមប្រឡងចូលរៀនបន្តនោះ ខ្ញុំមិនបានគិតគូររកការងារធ្វើភ្លាមៗដូចមិត្តភក្តិឯទៀតទេ ។ ឥឡូវមិត្តភក្តិទាំងអស់នេះ គេសុទ្ធតែបានការងារធ្វើជាលេខាធិការ ឬ ជំនួយគណនេយ្យករនៅក្រុមហ៊ុនរដ្ឋ "សុរាគារខ្មែរ" តាមរយៈកនិដ្ឋា ដែលមានគូដណ្តឹងជាប្រធានផ្នែកហិរញ្ញវត្ថុ និង ផ្នែកគណនេយ្យរបស់ក្រុមហ៊ុនរដ្ឋនេះ ។ ខ្ញុំត្រូវស្វែងរកការងារធ្វើដោយខ្លួនឯង ។ ខ្ញុំក៏ដាក់ពាក្យសុំរកការងារធ្វើនៅក្រសួងការងារ និង សង្គមកិច្ច ។

ជីវិតក្នុងពិភពកម្មករ

ថ្ងៃមួយនៅពេលខ្ញុំទៅលេងភូមិស្នាយពល ខ្ញុំស្តាប់វិទ្យុជាតិ ។ ខ្ញុំឮគេហៅឈ្មោះខ្ញុំឲ្យទៅមើលប្រកាសស្តីពីលទ្ធផលនៃការដាក់ពាក្យរបស់ខ្ញុំ ។ នៅពេលត្រឡប់ទៅភ្នំពេញវិញ ទើបខ្ញុំដឹងថាខ្ញុំត្រូវបានទទួលឲ្យចូលធ្វើការជាជំនួយគណនេយ្យករ នៅរោងចក្ររដ្ឋធ្វើកែវនៅជើងឯក ក្បែររាជធានី ។ ក្នុងតួនាទីជាជំនួយការគណនេយ្យករនេះ ខ្ញុំនឹងត្រូវទទួលប្រាក់ប្រចាំខែចំនួនប្រហែល ៤០ ដុល្លារ.អា ។ ខ្ញុំធ្វើការនៅរោងចក្ររដ្ឋធ្វើកែវតែមួយខែតែប៉ុណ្ណោះ ចាប់ពីខែ កញ្ញា ដល់ខែ តុលា ១៩៦៨ ព្រោះប្រាក់ខែ ៤០ ដុល្លារនោះ មិនគ្រប់គ្រាន់សំរាប់ការធ្វើដំណើរ និង ម្ហូបអាហារប្រចាំថ្ងៃឡើយ ។

រោងចក្រធ្វើកែវស្ថិតប្រហែលជិត ២០ គ.ម. ពីរាជធានីភ្នំពេញ ដូច្នេះខ្ញុំមិនអាចធ្វើដំណើរតាមទោចក្រយានដូចមុនឡើយ ។ ខ្ញុំត្រូវចំណាយប្រាក់ជិះរ៉ឺម៉កម៉ូតូទៅធ្វើការរៀងរាល់ថ្ងៃ ។ ម្យ៉ាងទៀត ដោយខ្ញុំត្រូវទៅធ្វើការនៅការិយាល័យ ខ្ញុំត្រូវស្លៀកពាក់ឲ្យបានស្អាតបាត ហើយត្រូវចូលទៅទទួលទានអាហារនៅភោជនីយដ្ឋានណាដែលសមរម្យ ដើម្បីឲ្យសមជាអ្នកធ្វើការនៅក្នុងការិយាល័យផង ។

រាល់ថ្ងៃ ខ្ញុំចេញតាំងពីព្រលឹមដើម្បីទៅធ្វើការឲ្យបានមុនម៉ោង ៧ ព្រឹក រហូតដល់ម៉ោង ៦ ល្ងាចទើបត្រឡប់មកផ្ទះវិញ ។ ខ្ញុំត្រូវធ្វើការនៅក្នុងបន្ទប់របស់លោកនាយគណនេយ្យករ ដែលជាបន្ទប់មួយដាច់ដោយឡែកពីបុគ្គលិកដទៃទៀត ។ ក៏ប៉ុន្តែនៅក្នុងបន្ទប់នោះ មានការិយាល័យរបស់លោកនាយ ការិយាល័យរបស់នាយរង និង ការិយាល័យរបស់មន្ត្រីទទួលបន្ទុកគិតគូរតម្លៃនៃផលិតផលផង ។

លោកនាយគណនេយ្យករ ជាសាស្ត្រាចារ្យមួយរូប ដែលមានឈ្មោះល្បីនៅក្នុងមហាវិទ្យាល័យពាណិជ្ជសាស្ត្រ ។ គាត់រស់នៅជាអភិជន ដែលទទួលការអប់រំនៅប្រទេសបារាំង ។ គាត់មានប្រពន្ធជាជនជាតិបារាំង ។ គាត់មកធ្វើការដោយមានអ្នកបើកបរពាក់ឯកសណ្ឋាន ។ នៅបាំងខាងក្រោយនៃរថយន្តម៉ាកដេអេស (DS) របស់បារាំង គាត់ជក់ខ្សៀយ៉ាងសង្ហារ ។ តាមធម្មតា លោកនាយមកធ្វើការនៅរោងចក្រកែវមួយអាទិត្យម្តង ពីព្រោះគាត់ធ្វើការនៅច្រើនកន្លែង ទាំងក្នុងក្រុមហ៊ុនរដ្ឋ ទាំងក្នុងក្រុមហ៊ុនឯកជន ជាប្រធានផ្នែកគណនេយ្យ ជាអ្នកត្រួតបញ្ជី ឬ ជាស្នងការគណនេយ្យ ។ល។ បន្ថែមលើមុខងារជាសាស្ត្រាចារ្យនៅមហាវិទ្យាល័យពាណិជ្ជសាស្ត្រផង នៅមហាវិទ្យាល័យនិតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចផង ។

ក្នុងការងាររបស់ពួកយើង ប្រសិនបើជាការចាំបាច់ យើងត្រូវទៅរកលោកនាយនៅផ្ទះរបស់គាត់ ដែលជាភូមិគ្រឹះមួយនៅតាមវិថីសហពន្ធរុស្សី ។ ឬបើរកគាត់

មិនឃើញ យើងអាចទៅរកលោកនាយ នៅកន្លែងធ្វើការដទៃទៀតរបស់គាត់ ដូច ជានៅឯស្ថានីយរាជអយស្ទ័យយានជាដើម ។ ខ្ញុំឮគេនិយាយតៗគ្នាថាធ្វើការជា មួយលោកនាយនេះ នឹងមានអនាគតល្អ ព្រោះអាចចេះដឹងការងារច្រើន ។ ក៏ប៉ុន្តែ លោកនាយ មិនងាយឲ្យប្រាក់ខែច្រើនឡើយ ។

រោងចក្រធ្វើកែវ ក៏ដូចជារោងចក្ររដ្ឋមួយចំនួនធំទៀតដែរ សុទ្ធសឹងជា ជំនួយរបស់សាធារណរដ្ឋប្រជាមានិតចិន ជូនដល់រាជរដ្ឋាភិបាលកម្ពុជា ។ នៅពេល ខ្ញុំចូលធ្វើការនោះ គេឃើញមានទីប្រឹក្សាបច្ចេកទេសដែលជាជនជាតិចិនមួយចំនួន នៅឡើយ ។ ក្នុងរយៈពេលមួយខែនៅក្នុងរោងចក្ររដ្ឋនេះ ខ្ញុំបានស្គាល់លោកនាយ គណនេយ្យករច្បាស់ណាស់ តែខ្ញុំមិនដែលបានជួបមុខលោកប្រធានអគ្គនាយក ដែលមានឋានៈជាឧត្តមមន្ត្រីគឺ លោក ទេព ថន ម្តងណាឡើយ ។ នៅពេលខ្ញុំដាក់ ពាក្យសុំឈប់ពីការងារ លោកនាយនិយាយជាភាសាបារាំងមករកខ្ញុំថា៖ "លោក ច្បាស់ជាចង់ឈប់ពីការងារមែនឬ?" គាត់បន្ថែមថា "មែន ខ្ញុំមិនអាចឲ្យប្រាក់ខែ លើសពីនេះទេក្នុងពេលនេះ" ។ ខ្ញុំឆ្លើយថាប្រាក់ខែរបស់ខ្ញុំមានចំនួនមិនគ្រប់គ្រាន់ សំរាប់ការរស់នៅៗភ្នំពេញឡើយ ។ តាមការពិត ខ្ញុំមិនប៉ងប្រាថ្នាទារយកប្រាក់ខែ ខ្ពស់អ្វីនោះទេ តែប្រាក់ខែ ៤០ ដុល្លារ ពិតជាមិនគ្រប់គ្រាន់សំរាប់តម្លៃជីវភាពនៅ សម័យនោះសោះឡើយ ។ ដូច្នេះ នៅអាយុជិត ១៨ ឆ្នាំ ខ្ញុំក៏លាឈប់ពីការងារនៅ រោងចក្ររដ្ឋធ្វើកែវនោះទៅ ។ នៅអាយុ ១៨ ឆ្នាំនេះ ខ្ញុំនឹកថាខ្ញុំប្រហែលជានៅក្មេង មែន តែខ្ញុំជឿថាខ្ញុំបានទទួលការហ្វឹកហាត់ក្នុងការងារបានល្អហើយ ។ ការងារនៅ ក្នុងរោងចក្ររដ្ឋធ្វើកែវ ជាបទពិសោធន៍ដ៏វិសេសវិសាលមួយសំរាប់ខ្ញុំក្នុងពិភពកម្ម ករនៅរោងចក្រ ។

បានការធ្វើនៅក្នុងក្រុមហ៊ុនសុរាគារខ្មែរ

នៅទីបំផុត ខ្ញុំត្រូវពឹងពាក់ កន្និដ្ឋា ដើម្បីឲ្យជួយរកការងារធ្វើនៅក្នុងក្រុមហ៊ុនសុរាគារខ្មែរ ។ ដោយសារគុណបុណ្យរបស់កន្និដ្ឋា ខ្ញុំក៏បានទទួលការធ្វើជាលេខាធិការគណនេយ្យ នៅក្រោមអំណាចរបស់គូដណ្តឹងរបស់នាង ។ ក៏ប៉ុន្តែ ខ្ញុំត្រូវទៅធ្វើការនៅឯរោងចក្រសុរាគារខ្មែរឯគីឡូលេខ ៦ គឺ មិនធ្វើការជាមួយមិត្តភក្តិឯទៀត នៅទីស្នាក់ការកណ្តាលរបស់ក្រុមហ៊ុនឡើយ ។ ខ្ញុំត្រូវធ្វើការនៅខាងផ្នែកវាយតម្លៃនៃផលិតផលស្រាបៀរជាមួយនឹងបុគ្គលិកមួយចំនួន ដែលសុទ្ធតែជាអតីតនិស្សិតចេញពីមហាវិទ្យាល័យពាណិជ្ជសាស្ត្រ ។ ក្នុងមុខងារថ្មីនេះ ខ្ញុំត្រូវបានទទួលប្រាក់ខែលើសពីរដង បើប្រៀបធៀបនឹងប្រាក់ខែនៅរោងចក្រធ្វើកែវ ។

ព្រឹកៗ រាល់ថ្ងៃធ្វើការ ខ្ញុំជិះរថយន្តកង់បី ហៅថា ឡាំប្រឺតា (Lambretta) ពីផ្សារដើមគ ទៅឈប់នៅផ្សារថ្មី រួចទៅជិះរថយន្តកង់បីមួយទៀត ពីផ្សារថ្មីទៅគីឡូលេខ ៦ ។ សម័យនោះ យើងធ្វើការពីរពេលគឺ នៅពេលព្រឹកពីម៉ោង ៧ ដល់ម៉ោង ១២ ថ្ងៃត្រង់ និង ពីម៉ោង ២ រសៀល ដល់ម៉ោង ៥ ល្ងាច ។ តាមធម្មតា ពេលមកដល់ផ្សារធំថ្មី មុននឹងឡើងរថយន្ត បន្តដំណើរត្រឡប់មកផ្សារដើមគ ដើម្បីសម្រាកខ្ញុំតែងទិញសាច់ចំអិនស្រាប់ សាច់កាត់ជាកំណាត់ៗដុំៗ មាន គ្រឿងក្នុង បេះដូង ឬ ពោះវៀនគាន់ជាដើម ដែលចិនដាក់លើគ្រែចល័ត ដើរលក់ តាមចំណតរថកង់បី ។ ខ្ញុំពមសាច់ពីរ ឬ បីម៉ាត់នៅពេលរង់ចាំ មុននឹងឡើងជិះឡាំប្រឺតាមកទទួលទានអាហារថ្ងៃត្រង់ឯផ្ទះ ។ ក្រោយពីធ្វើការនៅគីឡូលេខ ៦ បានប៉ុន្មានខែ ខ្ញុំក៏ត្រូវផ្លាស់មកធ្វើការនៅក្នុងរាជធានីវិញ ។

ខ្ញុំចេះតែចង់រៀនបន្ត

ទោះជាខ្ញុំជាប់រវល់ក្នុងការងារក្តី ខ្ញុំក៏តែងតែចិញ្ចឹមចិត្តទុកជានិច្ចថានឹងបន្តការសិក្សាឲ្យបានខ្ពស់តទៅទៀត ។ ដូច្នេះ ខ្ញុំក៏ឆ្លៀតឱកាសទៅចុះឈ្មោះរៀននៅសាលាឯកជនឈ្មោះហៅថា "វិជ្ជាស្ថានពាណិជ្ជកម្ម" (Institut Commercial) ស្ថិតនៅក្បែរផ្សារធំថ្មី នៅជាប់ជាមួយវិទ្យាល័យឯកជនឈ្មោះ វ៉ុលទែរ (Lycée Voltaire) ។ នៅឆ្នាំ ១៩៧០ ខ្ញុំក៏ចូលប្រឡងយកសញ្ញាប័ត្រជាន់ខ្ពស់ខាងគណនេយ្យដែលរៀបចំឡើងដោយមហាវិទ្យាល័យពាណិជ្ជសាស្ត្រ ។ វិញ្ញាសាប្រឡងមានវិញ្ញាសាសរសេរ និង វិញ្ញាសាផ្ទាល់មាត់ ។ នៅពេលដែលខ្ញុំចូលទៅក្នុងបន្ទប់ ដែលត្រូវចូលម្នាក់ម្តងៗ ដើម្បីទៅធ្វើវិញ្ញាសាផ្ទាល់មាត់ ខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងព្រោះលោកមេប្រយោគដែលអង្គុយរង់ចាំសួរដេញដោលខ្ញុំនោះ គ្មាននរណាក្រៅពីលោកនាយគណនេយ្យករចាស់របស់ខ្ញុំ កាលខ្ញុំធ្វើការនៅរោងចក្ររដ្ឋធ្វើកែវនោះទេ ។ លោកមេប្រយោគនោះឈ្មោះលោក អ៊ឹង ភូរិន ។ នៅពេលដែលខ្ញុំចូលអង្គុយទល់មុខគាត់ៗញញឹមហើយសួរមកខ្ញុំថា៖ "លោកឈ្មោះ អៀង មូលលី មែនទេ?" ខ្ញុំឆ្លើយយ៉ាងរហ័សថា៖ "បាទទាន" ។ បន្ទាប់មក លោកមេប្រយោគឲ្យខ្ញុំលូកដៃទៅក្នុងប្រអប់មួយ ដើម្បីចាប់យកក្រដាស់បត់ផ្ចត់យ៉ាងត្រឹមត្រូវមួយសន្លឹកក្នុងចំណោមក្រដាស់ផ្ចត់ជាច្រើន ដែលមានសរសេរជាសំណួរ ដែលខ្ញុំត្រូវឆ្លើយដោយផ្ទាល់មាត់ ។ ខ្ញុំក៏ប្រឡងជាប់វិញ្ញាបនរដ្ឋគណនេយ្យថ្នាក់ជាន់ខ្ពស់ ដែលជាសញ្ញាប័ត្រផ្នែកគណនេយ្យថ្នាក់ខ្ពស់ជាងគេ នៅប្រទេសកម្ពុជាយើងនៅឆ្នាំ ១៩៧០ ។

ខ្ញុំចេះតែចង់រៀនបន្តនៅប្រទេសបារាំង

ដោយសារទទួលបាននូវសញ្ញាប័ត្រនេះ ខ្ញុំក៏មានចិត្តចង់បន្តទៅសិក្សានៅប្រទេសបារាំងថែមទៀត ។ ចិត្តដែលចេះតែចង់ទៅរៀននៅប្រទេសបារាំង ក៏ព្រោះតែយល់ឃើញថា ឲ្យតែមានសញ្ញាប័ត្រណាមួយមកពីប្រទេសបារាំង សញ្ញាប័ត្រនោះតែងតែមានតម្លៃជាងសញ្ញាប័ត្រក្នុងស្រុកជានិច្ច ។ ក៏ប៉ុន្តែ គំនិតនោះក៏ចាប់ផ្តើមជួបប្រទះនឹងឧបសគ្គបណ្តើរៗទៅហើយ ព្រោះនៅពេលនោះ ប្រទេសកម្ពុជាយើង ចាប់ផ្តើមធ្លាក់ចូលក្នុងភ្នក់ភ្លើងសង្គ្រាមកើតឡើងដោយព្រឹត្តិការណ៍ ១៨ មីនា ១៩៧០ ។ ខ្ញុំគ្មានសង្ឃឹមថានឹងអាចចាកចេញទៅក្រៅប្រទេសបានទេ នៅសម័យស្រុកកើតសង្គ្រាមនោះ ។ ក៏ប៉ុន្តែ ខ្ញុំក៏ខិតខំរិះរកវិធីផ្សេងដើម្បីអាចប្រឡងយកសញ្ញាប័ត្រពីប្រទេសបារាំង ។ វិធីមួយនោះគឺ ធ្វើការសិក្សាតាមលិខិតឆ្លើយឆ្លង (Distant Learning) ។ ខ្ញុំចាប់ផ្តើមសរសេរលិខិត ទៅស្ថាប័នសិក្សាជាច្រើននៅប្រទេសបារាំង ។ ចម្លើយត្រឡប់មកវិញមានដដែលៗគឺ គេឲ្យខ្ញុំសុំការទទួលស្គាល់ពីប្រទេសបារាំងជាមុនថាតើសញ្ញាប័ត្រដែលខ្ញុំមាននោះ មានតម្លៃស្មើនឹងសញ្ញាប័ត្របារាំងត្រឹមកំរិតណា? បើគេដឹងថាអាចត្រឹមកំរិតណាហើយ ទើបគេអាចឲ្យខ្ញុំចូលរៀន ឬ ត្រៀមប្រឡងពីចម្ងាយ ដើម្បីឈានទៅយកសញ្ញាប័ត្របារាំងណាមួយ ។ ខ្ញុំគិតថាការទទួលស្គាល់សញ្ញាប័ត្រ ជាការកិច្ចរបស់ក្រសួងមានសមត្ថកិច្ចបារាំង និង ខ្មែរគឺមិនមែនជាការកិច្ចរបស់ឯកជនណាមួយដែលអាចធ្វើបានឡើយ ។ ដូច្នេះ ខ្ញុំក៏ព្យាយាមធ្វើការទាក់ទងជាមួយមន្ត្រីមហាវិទ្យាល័យពាណិជ្ជសាស្ត្រ ដើម្បីស្វែងរកការទទួលស្គាល់នោះ ។ ក៏ប៉ុន្តែ នៅពេលនោះ គ្មាននរណាអាចផ្តល់ព័ត៌មានដល់ខ្ញុំបានច្បាស់លាស់ឡើយ ។ អស់រយៈពេលជាច្រើនខែ ដោយគ្មានបានផលអ្វីជាក់ស្តែងនោះ ខ្ញុំក៏ដាច់ចិត្តសរសេរលិខិតជាភាសាបារាំងមួយច្បាប់ ចុះថ្ងៃទី

២២ ខែមករា ឆ្នាំ ១៩៧១ ទៅក្រសួងសិក្សាធិការនៅទីក្រុងប៉ារីស ដោយពន្យល់ពីគោលបំណងរបស់ខ្ញុំ និង មុខវិជ្ជាទាំងឡាយដែលខ្ញុំបានរៀនចប់នៅក្នុងប្រទេសកម្ពុជា ។ ខ្ញុំមានបំណងចង់ឈោងយកមុខរបរជាអ្នកជំនាញគណនេយ្យ (Expert Comptable) បន្ទាប់ពីបានការអនុញ្ញាតឲ្យចុះឈ្មោះរៀនក្នុងគ្រឹះស្ថានសិក្សារបស់បារាំងណាមួយ ។ ខ្ញុំនឹកថា ខ្ញុំនឹងរៀនតាមលិខិតឆ្លើយឆ្លងផង ធ្វើការនៅក្នុងប្រទេសកម្ពុជាផង ។ ក៏ប៉ុន្តែ ពីមួយខែទៅមួយខែ ខ្ញុំតែងទន្ទឹងរង់ចាំចម្លើយពីប្រទេសបារាំង ដែលបាត់ឈឹងពុំឃើញឆ្លើយតបមកខ្ញុំវិញសោះ ។ សេចក្តីសង្ឃឹមរបស់ខ្ញុំក្នុងការបន្តវិជ្ជាតាមលិខិតឆ្លើយឆ្លងនោះ ក៏រលាយបាត់បន្តិចម្តងៗរហូតដល់អស់សង្ឃឹមសូន្យតែម្តង ។

ខ្ញុំចង់ធ្វើជាគណនេយ្យករឯករាជ្យ

នៅពេលជាមួយគ្នានោះ ខ្ញុំក៏មានគំនិតចង់ប្រកបរបរជាគណនេយ្យករឯករាជ្យ ដែលអាចបើកការិយាល័យបំរើសេវាគណនេយ្យដល់ក្រុមហ៊ុនពាណិជ្ជកម្ម ឬ ក្រុមហ៊ុនឧស្សាហកម្មដោយខ្លួនឯង ។ នៅសម័យនោះ ប្រទេសយើងពុំទាន់មានច្បាប់ ឬ ក្បួនខ្នាតទាក់ទងនឹងលក្ខន្តិកៈនៃគណនេយ្យករឯករាជ្យច្បាស់លាស់នៅឡើយទេ ។ តាមខ្ញុំដឹងថាក្នុងពេលកន្លងមក មានគណនេយ្យកររដែលមានបទពិសោធន៍ ជាពិសេសជនជាតិវៀតណាមមួយចំនួន បានទៅចុះឈ្មោះ ទទួលបាននូវការទទួលស្គាល់ពីតុលាការពាណិជ្ជកម្មនៅរាជធានីភ្នំពេញ ។ កាលណាមានចុះឈ្មោះក្នុងបញ្ជី ដែលទទួលស្គាល់ដោយតុលាការហើយ គណនេយ្យករនោះអាចប្រកបអាជីវកម្មជាគណនេយ្យករឯករាជ្យដោយសេរី ។ ដូច្នេះបានជានៅឆ្នាំ ១៩៧១ ខ្ញុំក៏បានធ្វើពាក្យទៅសុំចុះបញ្ជីការនៅតុលាការពាណិជ្ជកម្មក្រុងភ្នំពេញ ។ ក៏ប៉ុន្តែ កាលនោះប្រហែលជាលោកចាងហ្វាង ដែលជាចៅក្រមទទួលខុសត្រូវយល់

ថាខ្ញុំនៅក្មេងពេក ទើបគាត់ឆ្លើយប្រាប់ខ្ញុំថាគាត់មិនដែលដឹងឮពីរបៀបរបបនៃការចុះឈ្មោះគណនេយ្យករណាមួយ នៅក្រោមអំណាចសាលារបស់គាត់ឡើយ ។ ដូច្នេះ បំណងរបស់ខ្ញុំដែលចង់ប្រកបរបរជាគណនេយ្យករឯករាជ្យ ក៏រលាយបាត់ទៀតដែរ ។ តែទោះជាយ៉ាងណាក៏ដោយ ក៏ខ្ញុំនៅខំព្យាយាម ដើម្បីឈានឲ្យបានទៅដល់ទីដៅដែលខ្ញុំបានកំណត់រួចហើយនោះ ។ ខ្ញុំចាប់ផ្តើមធ្វើការស្រាវជ្រាវរាវរកសមាគមវិជ្ជាជីវៈខាងផ្នែកគណនេយ្យនៅប្រទេសបារាំង ដើម្បីសុំឲ្យគេជួយណែនាំ ។

ខ្ញុំរកឃើញអាស័យដ្ឋានពីរនៅទីក្រុងប៉ារីស ។ ខ្ញុំសរសេរសំបុត្រទៅសមាគមគណនេយ្យមួយឈ្មោះ Société de Comptabilité de France (SCF) ឬ អេស.សេ.អេហ្វ ដោយរៀបរាប់អំពីសកម្មភាពការងារបទពិសោធន៍ និង ការរៀនសូត្ររបស់ខ្ញុំហើយខ្ញុំស្នើសុំចូលជាសមាជិកក្នុងឋានៈវិជ្ជាជីវៈណាមួយនៃសមាគមនោះ ។

តាមពិត ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ខ្ញុំក៏មានការរីកចំរើនខ្លះដែរក្នុងមុខរបរវិជ្ជាជីវៈរបស់ខ្ញុំគឺ ខ្ញុំមិនមែនស្ថិតនៅជាន់ទាបទៀតឡើយ ។ រយៈពេលបីខែក្រោយដែលខ្ញុំចូលធ្វើការនៅក្រុមហ៊ុនសុវាគារខ្មែរ ក្នុងឋានៈជាជំនួយគណនេយ្យករ ខ្ញុំត្រូវបានឡើងឋានៈជាគណនេយ្យកររពេញសិទ្ធិ ។ នៅឆ្នាំ ១៩៧១ ខ្ញុំក៏ចេញពីក្រុមហ៊ុនសុវាគារខ្មែរ ទៅធ្វើការនៅក្នុងក្រុមហ៊ុនស្តង់ឌីណាវមួយ ជាទីដែលខ្ញុំបានទទួលប្រាក់ខែកើនឡើងបីដង បើប្រៀបធៀបទៅនឹងប្រាក់ខែរបស់ខ្ញុំនៅក្រុមហ៊ុនសុវាគារខ្មែរ (SKD) ។ ជាមួយគ្នានោះ តាមលិខិតចុះថ្ងៃទី ២៤ ខែសីហា ១៩៧១ សមាគមគណនេយ្យ អេស.សេ.អេហ្វ បានផ្តល់ដំណឹងដល់ខ្ញុំថាគណៈកម្មាធិការនាយករបស់សមាគម បានផ្តល់ឋានៈដល់ខ្ញុំជាសមាជិកគណនេយ្យករគុណវុឌ្ឍី (Membre Comptable Qualifié) ។ ឋានៈវិជ្ជាជីវៈនេះមានសារសំខាន់ខ្លាំងណាស់ចំពោះខ្ញុំ ក៏ប៉ុន្តែ នៅពេលភ្លាមៗនោះ ខ្ញុំហាក់ដូចជាមិនសូវយក

ចិត្តទុកដាក់ប៉ុន្មានឡើយ ។ ដោយសារហានៈវិជ្ជាជីវៈនេះ ខ្ញុំក៏កើតមានចិត្តចង់ទៅរៀននៅប្រទេសបារាំងសារជាថ្មីម្តងទៀត ។

ចំពោះលិខិតដែលខ្ញុំសរសេរ ទៅក្រសួងសិក្សាធិការរបស់ប្រទេសបារាំង ដើម្បីសុំការទទួលស្គាល់សញ្ញាប័ត្ររបស់ខ្ញុំនោះ ក្រសួងនេះ បានឆ្លើយភ្លាមៗមកខ្ញុំវិញនៅខែ កុម្ភៈ ឆ្នាំ ១៩៧១ ដែរ ។ តាមពិត ខ្ញុំត្រូវបានអនុញ្ញាតឲ្យចុះឈ្មោះរៀននៅវិជ្ជាស្ថានជាតិបច្ចេកទេសគណនេយ្យ និង សេដ្ឋកិច្ច (Institut National des Techniques Economiques et Comptables) នៅទីក្រុងប៉ារីស ។ ក៏ប៉ុន្តែ លិខិតនោះបានត្រូវផ្ញើទៅអាស័យដ្ឋានរបស់ខ្ញុំ នៅទីកន្លែងធ្វើការ ឯក្រុមហ៊ុនសុរាគារខ្មែរឯនោះ នៅពេលដែលខ្ញុំចេញទៅធ្វើការនៅកន្លែងផ្សេងទៀតទៅហើយនោះ ។ នៅពេលសំបុត្រនោះទៅដល់ក្រុមហ៊ុនសុរាគារខ្មែរ លោកនាយផ្នែកបុគ្គលិកក៏ទុកចោលនៅលើការិយាល័យរបស់គាត់យ៉ាងព្រងើយ ដោយមិនបានអើពើផ្ញើបន្តមកខ្ញុំឡើយ ។

ដោយពុំបានដឹងថា ក្រសួងសិក្សាធិការបារាំង បានផ្ញើចម្លើយមកខ្ញុំរួចហើយនៅខែ កុម្ភៈ ឆ្នាំ ១៩៧១ នោះ នៅដើមឆ្នាំ ១៩៧២ ខ្ញុំក៏សរសេរសុំទៅអាជ្ញាធរបារាំងម្តងទៀត ឲ្យទទួលស្គាល់សញ្ញាប័ត្ររបស់សាលាសារជាថ្មី ។ កាលនោះ ខ្ញុំចូលចិត្តសរសេរសំបុត្រឆ្លើយឆ្លងទៅក្រៅប្រទេសណាស់ ។ លើកនេះក្រសួងសិក្សាធិការបារាំង បានតម្រូវឲ្យខ្ញុំផ្តល់ដល់អាជ្ញាធរបារាំងនូវឯកសារផ្លូវការណាមួយដែលមានចែងលំអិតអំពីកម្មវិធីសិក្សារបស់ខ្ញុំ ។ ដូច្នេះ ខ្ញុំក៏ត្រូវធ្វើការទាក់ទងជាថ្មីជាមួយមន្ត្រីនៃមហាវិទ្យាល័យពាណិជ្ជសាស្ត្រ ដើម្បីរកឯកសារផ្លូវការស្តីពីកម្មវិធីសិក្សានោះ ។ ក៏ប៉ុន្តែ គ្មានមន្ត្រីណាម្នាក់អាចផ្តល់ឯកសារនោះដល់ខ្ញុំបានឡើយ ។

នៅទីបំផុត ខ្ញុំក៏ដោះស្រាយបញ្ហានេះ ដោយរៀបរៀងកម្មវិធីសិក្សានោះដោយខ្លួនឯង ។ ខ្ញុំចម្លងមុខវិជ្ជាលំអិតទាំងឡាយដែលខ្ញុំបានរៀន ។ ខ្ញុំវាយអង្គុលី

លេខខ្លួនឯង រួចខ្ញុំសុំឲ្យកម្មករនៅមហាវិទ្យាល័យពាណិជ្ជសាស្ត្រជួយយកទៅវាយ ត្រាផ្លូវការរបស់មហាវិទ្យាល័យដើម្បីឲ្យមានលក្ខណៈត្រឹមត្រូវ ។ ខ្ញុំផ្ញើឯកសារនោះ ទៅប្រទេសបារាំង ។ នៅចុងឆ្នាំ ១៩៧២ ខ្ញុំបានទទួលចម្លើយម្តងទៀតថា ខ្ញុំ មានសិទ្ធិត្រៀមប្រឡងយកសញ្ញាប័ត្រជាន់ខ្ពស់ខាងវិជ្ជាគណនេយ្យ នៅប្រទេស បារាំងបាន ។ លើកនេះ ចំពោះខ្ញុំ សេចក្តីសង្ឃឹមកើតមានឡើងវិញហើយ ។ ខ្ញុំក៏ចាប់ស្រមៃម្តងទៀតថា នឹងទៅទាញយកមុខរបរជាអ្នកជំនាញការខាងផ្នែក គណនេយ្យឲ្យបាន ។ មួយសប្តាហ៍បន្ទាប់ពីបានចម្លើយពីប្រទេសបារាំងមក ខ្ញុំក៏ ឆ្លៀតទៅលេងមិត្តភក្តិរបស់ខ្ញុំ នៅក្រុមហ៊ុនសុរាគារខ្មែរ ។ នៅពេលខ្ញុំទើបតែដើរ ចូលទៅក្នុងការិយាល័យរដ្ឋបាលនៃក្រុមហ៊ុន លោកនាយផ្នែកបុគ្គលិកសម្តែង អាកប្បកិរិយារាប់អានដ៏ចម្លែកមករកខ្ញុំ ដោយហៅឲ្យចូលមកអង្គុយលេងនៅក្នុង ការិយាល័យរបស់គាត់ ។ នៅពេលនោះ លោកនាយបានរើគំនរឯកសារមួយចំនួន រួចហូតយកសំបុត្រមួយច្បាប់ ដែលនៅខាងក្រោមបង្អស់មកហុចឲ្យខ្ញុំ ។ ខ្ញុំពិនិត្យ លិខិតនោះ ទើបយល់ថាជាលិខិតដែលក្រសួងសិក្សាធិការបារាំងបានផ្ញើមកខ្ញុំ តាំង ពីខែ កុម្ភៈ ឆ្នាំ ១៩៧១ មកម្ល៉េះ ។ ខ្ញុំនឹកហួសចិត្ត ដោយសារការយឺតយ៉ាវនេះ ។ ប្រសិនបើខ្ញុំដឹងថា បារាំងបានឆ្លើយមកកាលពីជាងមួយឆ្នាំមុននោះ ម្ល៉េះខ្ញុំមិនខាត ពេលវេលាវង់ចាំចម្លើយ និង មានការលំបាកក្នុងការតាក់តែងកម្មវិធីសិក្សាអ្វីឡើយ ។ លោកនាយហាក់ពុំមានយកចិត្តទុកដាក់ចំពោះក្តីមួរហ្មងរបស់ខ្ញុំទេ ។ គាត់រក្សា ឥរិយាបថយ៉ាងរំភើយ ដោយពុំបានគិតថាទង្វើរបស់គាត់ធ្វើឲ្យខ្ញុំខាតពេលវេលាដ៏ មានតំលៃយ៉ាងសន្ធឹកសន្ធាប់របស់ខ្ញុំសោះឡើយ ។

ស្ថានការណ៍ប្រែប្រួល

ចាប់តាំងពីខ្ញុំចេញធ្វើការមក មានព្រឹត្តិការណ៍សំខាន់ៗបានកើតឡើងក្នុងវង្វង់គ្រួសាររបស់យើង ។ បងប្រុសទីមួយរបស់ខ្ញុំ បានចេញទៅបង្រៀននៅកំពង់ស្រឡៅ ក្នុងខែត្រព្រះវិហារ ក្បែរទល់ដែនប្រទេសលាវ ។ យូរៗម្តង គាត់មកលេងពួកយើងនៅភ្នំពេញ ដោយយកមកជាមួយនូវផលិតផលរត់ពន្ធមួយចំនួនដូចជា ស្រា Cognac ឬ ទឹកអប់បារាំងជាដើម ។ នៅសម័យនោះ ទឹកអប់ម៉ាកសំប៉ាញ (Champagne) កំពុងពេញនិយមណាស់ដែរ ។ នៅឆ្នាំ ១៩៧០ បងប្រុសខ្ញុំត្រូវផ្លាស់មកបង្រៀននៅខែត្រកណ្តាលជិតរាជធានីភ្នំពេញវិញ ។ បងប្រុសទីពីររបស់ខ្ញុំ បានការងារធ្វើនៅធនាគារជាតិនៃកម្ពុជា នៅពេលដែលគាត់បន្តការសិក្សានៅមហាវិទ្យាល័យនិតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ។

ផ្ទះឈើដ៏តូចរបស់យើង ត្រូវបានជួសជុលកែលំអឡើង ដោយបានត្រូវលើកឡើងឲ្យខ្ពស់ថែមទៀត និង រៀបឥដ្ឋចាក់ស៊ីម៉ង់ត៍ខាងក្រោម រៀបបន្ទប់លាបពណ៌យ៉ាងស្អាតបាត រៀបចំប្រព័ន្ធអគ្គិសនី និង ប្រព័ន្ធទឹកស្អាតយ៉ាងទំនើប ។ ក៏ប៉ុន្តែ ចាប់ពីត្រីមាសទី ៣ នៃឆ្នាំ ១៩៧០ ផលវិបាកនៃសង្គ្រាមចាប់ផ្តើមគាបសង្កត់មកលើជីវភាពរបស់យើងម្នាក់ៗកាន់តែខ្លាំងឡើងៗជាលំដាប់ ។ ប្រទេសយើងត្រូវចែកជាតំបន់ពីរផ្សេងគ្នា មួយជាតំបន់ព្រៃម៉ាគី និង តំបន់មួយទៀតជាតំបន់ដែលស្ថិតនៅក្រោមការត្រួតត្រារបស់រដ្ឋាភិបាល លន់ នល់ ។

នៅភូមិស្នាយពល មន្ត្រីរាជការសំខាន់ៗ ទាំងប៉ូលីស ទាំងស៊ីវិល ភាគច្រើនបានភៀសខ្លួនចេញមករស់នៅៗទីក្រុងភ្នំពេញ ។ ម្តាយខ្ញុំ និង ប្អូនតូចៗមាន វន្នី វុធៀន វុធឿន វុទ្ធា និង សោភា បានមករស់នៅជាមួយពួកយើង ឯរាជធានីតាំងពីខែ មេសា ឆ្នាំ ១៩៧០ មកម្លេះ ។ ចំណែកឪពុកខ្ញុំ ប្អូនខ្ញុំមាន ស៊ីថាន វណ្ណៈ

និង ណារើន មិនទាន់បានមករស់នៅជាមួយយើងនៅឡើយទេ អ្នកទាំងនោះបន្ត រស់នៅក្នុងភូមិស្នាយពលអស់មួយរយៈទៀត ។ យើងបែកគ្នាជាពីរក្រុម មួយក្រុម មករស់នៅក្នុងក្រុងភ្នំពេញ មួយក្រុមទៀតរស់នៅៗក្នុងភូមិស្នាយពលជាបណ្តោះ អាសន្នសិន ។ ក៏ប៉ុន្តែ ក្រោយពីម្តាយខ្ញុំចេញពីភូមិស្នាយពលមិនយូរប៉ុន្មានមាន យុទ្ធជន ក្នុងសំលៀកបំពាក់ខ្មៅមួយក្រុម បានជិះម៉ូតូចូលមកក្នុងភូមិ ហើយរៀបចំ ជាគណៈកម្មាធិការបដិវត្តន៍ប្រជាជនគ្រប់គ្រងស្រុកពារាំងទាំងមូល ។ ខ្ញុំឮគេ និយាយថា យុទ្ធជនដែលមកមុនគេនោះគឺ ពួកកុម្មុយនីស្តសញ្ជាតិវៀតណាម ។ គណៈកម្មាធិការស្រុកនេះ ក៏រៀបចំគណៈកម្មាធិការឃុំ និង ភូមិជាបន្តបន្ទាប់នា ពេលក្រោយៗមកទៀត ។

ខ្ញុំមានឪពុកមាពីររូប ដែលជាប្អូនបង្កើតរបស់ម្តាយខ្ញុំ ។ ឪពុកមាម្នាក់ដែល ជាប្អូនពៅបានត្រូវជ្រើសរើសឲ្យកាន់តំណែងជាប្រធានគណៈកម្មាធិការស្រុក ដែល មានអំណាចស្មើនឹងអភិបាលស្រុកយ៉ាងនោះដែរ ។ កាលក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ គាត់ជាអ្នកបច្ចេកទេសម្នាក់ ធ្វើការនៅរោងចក្រវាយនភ័ណ្ឌ នៅខេត្តកំពង់ចាម ។ គាត់ត្រូវបានរបបសង្គមរាស្ត្រនិយមរបស់សម្តេច សីហនុ ចោទប្រកាន់ថាជាពួក ខ្មែរក្រហម ហើយត្រូវជាប់ឃុំឃាំងនៅពន្ធនាគារព្រៃស អស់រយៈពេលជាច្រើនឆ្នាំ ។ តាមពិតឪពុកមាខ្ញុំ មិនមែនជាជនកុម្មុយនីស្តអ្វីទេ គាត់គ្រាន់តែមានទំនាក់ទំនង ជិតស្និទ្ធជាមួយបញ្ញវន្ត ដែលមាននិន្នាការសង្គមនិយមមួយចំនួន ដូចជាលោក កោគ ធាយ ជាដើមតែប៉ុណ្ណោះ ។ ប៉ុន្មានខែមុនពេលលោក លន់ នល់ ទម្លាក់ សម្តេចពីអំណាច រដ្ឋាភិបាល លន់ នល់ បានដោះលែងអ្នកទោសនយោបាយទាំង អស់ពីពន្ធនាគារព្រៃស ដើម្បីអូសទាញឲ្យអ្នកទាំងនោះគាំទ្ររបបថ្មី ដែលនឹងកើត ឡើងក្រោយព្រឹត្តិការណ៍ ១៨ មីនា ១៩៧០ ។ ឪពុកមាខ្ញុំ ក៏ស្ថិតនៅក្នុងចំណោម អ្នកទទួលការលើកលែងទោសពីលោក លន់ នល់ ដែរ ។ ក៏ប៉ុន្តែ ហាក់ដូចជាការ

ចំអកនៃព្រហ្មលិខិត អ្នកទោសដែលត្រូវលោក លន់ នល់ ដោះលែងទាំងនោះ មិនបានគាំទ្ររបបរបស់គាត់ទាំងអស់ទេ ភាគច្រើនអ្នកទាំងនោះ បានរត់ចូលព្រៃម៉ាគី (Maquis)[25] ទៅបំរើចលនាតស៊ូ តាមការស្រែកអំពាវនាវរបស់សម្តេច សីហនុ ប្រឆាំងតទល់នឹងរបប លន់ នល់ ទៅវិញ ។ នៅពេលទទួលសេរីភាពភ្លាម ឪពុកមាខ្ញុំស្នាក់នៅក្នុងក្រុងភ្នំពេញតែរយៈពេលមួយយ៉ាងខ្លីតែប៉ុណ្ណោះ ។ គាត់ត្រឡប់មករស់នៅ ក្នុងភូមិកំណើត ឯភូមិស្នាយពល រហូតដល់ពេលដែលគាត់ត្រូវទទួលការជ្រើសតាំងជាគណៈកម្មាធិការស្រុកពារាំង ។ ភូមិស្នាយពល ក៏ក្លាយជាតំបន់ម៉ាគីមួយដ៏រឹងមាំ នៅទិសបូព៌ានៃប្រទេសកម្ពុជា សម្រាប់ពួកខ្មែរក្រហម ។

ក្រោយពីពេលដែល "រដ្ឋអំណាចបដិវត្តន៍ថ្មី" ត្រូវបានរៀបចំឡើងនៅក្នុងភូមិ យើងក៏ដាច់ការទាក់ទងគ្នាទាំងស្រុង ដោយសារពួកខ្មែរក្រហមធ្វើការហាមប្រាមមិនឲ្យអ្នកស្រុកទាក់ទងជាមួយតំបន់ខ្មាំងទៀតឡើយ ដែលក្នុងនោះមានរួមទាំងរាជធានីភ្នំពេញផង ។ ដូច្នេះ គ្រួសារខ្ញុំត្រូវកាត់ផ្តាច់ពាក់កណ្តាលឲ្យរស់នៅបែកគ្នា មួយផ្នែកនៅស្នាយពល មួយផ្នែកនៅភ្នំពេញ ។ យើងរងទុក្ខវេទនា ដោយសារការបែកខ្ញែកគ្នានេះយ៉ាងខ្លាំង ។ ឪពុកខ្ញុំ និយាយប្រាប់ខ្ញុំថាក្នុងរយៈជិតមួយឆ្នាំនៃការរស់នៅបែកគ្នានេះ គាត់ព្យាយាមលួចរត់មកភ្នំពេញជាច្រើនដងដែរ ។ នៅពេលមួយនោះ គាត់បានគេចផុតពីការត្រួតពិនិត្យរបស់ក្រុមខ្មែរក្រហម នៅស្រុកពារាំង តែគាត់ត្រូវបានក្រុមខ្មែរក្រហមនៅស្រុកជិតខាងគឺ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ចាប់បានហើយឃុំឃាំងគាត់អស់រយៈពេលមួយថ្ងៃមួយយប់ ។

[25] The Maquis were rural guerrilla bands of French Resistance fighters, called *maquisards*, during the Occupation of France in World War II. Initially, they were composed of men who had escaped into the mountains to avoid conscription into Vichy France's Service du travail obligatoire (STO) to provide forced labor for Germany. To avert capture and deportation to Germany and remain free, they became increasingly organized in active resistance groups. ម៉ាគីមកពីភាសាបារាំង និយាយអំពីក្រុមអ្នកតស៊ូបារាំងប្រឆាំងកងទ័ពអាឡឺម៉ង់ នាសម័យសង្គ្រាមលោកលើកទី២ ដែលនាំគ្នាលាក់ខ្លួនតាមព្រៃភ្នំ ដើម្បីគេចចេញពីការចាប់បង្ខំឲ្យធ្វើទាហាន ឬ ចាប់បញ្ជូនទៅជំរុំប្រមូលធ្មុំនៃកងទ័ពអាឡឺម៉ង់ ។ ការលាក់ខ្លួននោះ ហៅថាចូលព្រៃម៉ាគី ដើម្បីធ្វើការតស៊ូប្រឆាំងអំណាចណាមួយ ។

ដោយមិនទាន់អាចសំរេចបំណងក្នុងការលួចចេញពីតំបន់ខ្មែរក្រហម ដើម្បីមករស់នៅជុំគ្នានៅទីក្រុងភ្នំពេញបាននោះ និង ប្រហែលជាក្នុងបំណងឲ្យថ្នាក់ដឹកនាំខ្មែរក្រហមជឿទុកចិត្តថាគាត់មិនវែសគេចចេញ ពីតំបន់របស់ពួកគេកាន់កាប់នោះទេ ទើបឪពុកខ្ញុំសំរេចរៀបការប្អូនស្រីខ្ញុំ ស៊ីថាន ជាមួយគ្រូបង្រៀនម្នាក់ នៅពេលដែលនាងមានអាយុប្រហែល ១៦ ឆ្នាំ ។ ពិធីរៀបអាពាហ៍ពិពាហ៍ប្អូនស្រីខ្ញុំបានប្រព្រឹត្តទៅដោយពុំមានការចូលរួមពីក្រុមគ្រួសារយើង ដែលស្ថិតនៅឯក្រុងភ្នំពេញទេ ។ កាលសម័យនោះ ពួកខ្មែរក្រហមនៅត្រូវការការគាំទ្រពីប្រជាពលរដ្ឋនៅឡើយ ។ ពួកគេ នៅមិនទាន់តឹងតែងណាស់ណាទេ ក្នុងការគ្រប់គ្រងប្រជាពលរដ្ឋដែលរស់នៅក្រោមអំណាចរបស់ខ្លួន ។ ដូច្នេះហើយទើបអាពាហ៍ពិពាហ៍របស់ប្អូនស្រីខ្ញុំ អាចប្រព្រឹត្តតាមប្រពៃណីខ្មែរខ្លះៗបាន ។ ក៏ប៉ុន្តែ ពួកខ្មែរក្រហមចាប់ផ្តើមគាបសង្កត់ប្រជាពលរដ្ឋ មិនឲ្យមានសេរីភាពសំដែងមតិ សេរីភាពក្នុងការរួមប្រជុំ និង ខាងជំនឿជាបណ្តើរៗហើយ ។ ព្រះសង្ឃត្រូវរៀនសូត្រខាងនយោបាយ និង ត្រូវជួយរដ្ឋអំណាច ដើម្បីប្រមែប្រមូលប្រជាពលរដ្ឋឲ្យគាំទ្រសម្តេច សីហនុ ជាពិសេស គាំទ្ររដ្ឋអំណាចខ្មែរក្រហមប្រឆាំងនឹង "ចក្រពត្រិអាមេរិក និង បរិវារ" គឺ ពួកលន់ នល់ ។ យុវជន ឬ យុវតី ជាដំបូងត្រូវឃោសនាបញ្ចុះបញ្ចូលឲ្យចូលទៅបំរើកងទ័ព "សម្តេចឪ" តែក្រោយៗមក ត្រូវកេណ្ឌឲ្យទៅបំរើកងទ័ពខ្មែរក្រហម ។

ការឃោសនាបញ្ចុះបញ្ចូលរបស់ខ្មែរក្រហមកាលនោះ មានប្រសិទ្ធិភាពណាស់ ។ យ៉ាងនោះហើយ ទើបមានយុវជន យុវតី ស្ម័គ្រចិត្តចូលបំរើកងទ័ពយ៉ាងគគ្រឹកគគ្រេង ។ កាលសម័យនោះ នៅក្នុងតំបន់ដែលគេហៅថាតំបន់រំដោះនោះ ការកាន់កាំភ្លើង និង ស្លៀកពាក់ខោអាវខ្មៅ ហាក់ដូចជាម៉ូតទំនើបជាទីពេញនិយមរបស់កំលោះក្រមុំជាច្រើន ។ ពួកគេបាក់ចិត្តធ្វើតាមគ្នា និង បបួលគ្នាថតរូបក្នុងសំលៀកបំពាក់ខ្មៅដៃកាន់កាំភ្លើងទុកជាអនុស្សាវរីយ៍ផង ។ ប្រហែលជាដោយសារ

ការបាក់ចិត្តយ៉ាងនេះហើយ ទើបប្អូនស្រីខ្ញុំខកខានមិនបានមករួមរស់ជាមួយពួកយើងនៅឯភ្នំពេញ ហើយសុខចិត្តរៀបការ និង រស់នៅក្នុងភូមិស្នាយពលជារៀងរហូត ។

ប៉ុន្មានខែក្រោយពីពិធីរៀបអាពាហ៍ពិពាហ៍ប្អូនស្រីខ្ញុំនោះមក ឪពុកខ្ញុំ និង ប្អូនប្រុសខ្ញុំពីរនាក់ទៀតគឺ វណ្ណៈ និង ណារ៉ែន បានគេចផុតពីការត្រួតពិនិត្យរបស់ខ្មែរក្រហម ហើយបានមកជួបជុំជាមួយពួកយើងវិញនៅភ្នំពេញ ដោយសារក្លែងខ្លួនជាអ្នកនេសាទជិះទូកតូចរកត្រីតាមស្ទឹង និង ទន្លេ ។ ដំណើរគេចខ្លួនពីភូមិកំណើតរបស់ឪពុកខ្ញុំ និង ប្អូនខ្ញុំ ប្រកបដោយគ្រោះថ្នាក់ជាទីបំផុត ព្រោះកងកំលាំងរបស់លន់ នល់ ប្រើយន្តហោះវាយប្រហារ ដោយគ្រាប់មីស៊ីល ឬ ទម្លាក់គ្រាប់បែកទៅលើទីដៅណា ដែលពួកគេសង្ស័យថាជាខ្មាំងគឺ ពួកវៀតកុង ឬ ពួកខ្មែរក្រហម ។ ទូកតូចរបស់ឪពុកខ្ញុំនោះ ក៏ត្រូវរងនូវការបាញ់រះដែរ ។ ក៏ប៉ុន្តែ នៅទីបំផុត ប្រហែលជាអ្នកបើកបរយន្តហោះចម្បាំងមើលឃើញផ្ទាល់ភ្នែកថា ទូកតូចនោះជាទូកនេសាទដោយគ្មានអ្វីដែលគួរឲ្យបារម្ភទេ ទើបគេឈប់បាញ់រះ និង ទុកទូកនោះឲ្យចូលដល់តំបន់ដែលគ្រប់គ្រងដោយរដ្ឋអំណាច លន់ នល់ ។ នៅពេលមកដល់ភ្នំពេញ ប្អូនប្រុសខ្ញុំ វណ្ណៈ គ្របមុខដោយក្រមាមិនឲ្យអ្នកណាឃើញមុខគេទេ ។ នៅពេលដែលខ្ញុំបើកក្រមាមើលទៅមុខវានោះ ខ្ញុំមានសេចក្តីតក់ស្លុតយ៉ាងខ្លាំង ព្រោះរង្វង់មុខដ៏ក្មេងខ្ចីរបស់វា ត្រូវមានស្នាមឆេះរោលរាលខ្មៅពេញមុខ ។ ខ្ញុំនឹកថា ប្អូនប្រុសត្រូវរងគ្រោះ ដោយការទម្លាក់គ្រាប់បែក ឬ បាញ់រះដោយយន្តហោះ ឬ រងគ្រោះដោយសារសង្គ្រាមមិនខានឡើយ ។ យើងបានធូរចិត្តបន្តិចក្នុងមួយនាទីក្រោយមក នៅពេលដែលដឹងថាមុខវណ្ណៈ ត្រូវឆេះរោលរាលដោយសារល្បែងលេងជាមួយប្រេងសាំង មិនមែនរងគ្រោះដោយសារសង្គ្រាមនោះទេ ។ នៅពេលពួកគេមកដល់ទីក្រុងភ្នំពេញនោះ ខ្ញុំសុំច្បាប់ឈប់សម្រាកពីការងារពេញមួយថ្ងៃ ដើម្បីបានជួបជុំគ្នា ។

ជាការល្អដែរ ដែលយើងទើបនឹងពង្រីកផ្ទះយើងឲ្យធំជាងមុន ដែលអាចឲ្យយើងទទួលសមាជិកថ្មី ដែលទើបតែមកដល់នោះ ។

រៀបការបងប្រុសទី១

អស់រយៈពេលដ៏យូរមកហើយ ដែលយើងចង់ឲ្យបងប្រុសទីមួយរបស់យើងគឺបងឈឿនមានគូស្រករ ។ យើងរង់ចាំវត្តមានរបស់ឪពុកយើង ដើម្បីគិតគូរសំរេចរឿងដ៏សំខាន់នេះ ។ ឥឡូវគាត់បានមកដល់ភ្នំពេញ ដូច្នេះសម្រាប់ពួកយើងពេលវេលាបានមកដល់ហើយ ។ មុនពេលឪពុកខ្ញុំមកដល់ បងប្រុសខ្ញុំបានបង្ហាញពីការសម្រេចចិត្តរបស់គាត់រួចទៅហើយគឺ គាត់សំដៅចំលើមិត្តនារី ដែលជាគ្រូបង្រៀនហើយដែលធ្លាប់បានរៀនជាមួយគ្នានៅកំពង់កន្ធួតឈ្មោះអ្នកគ្រូ ស៊ីណាត ។ ឪពុកខ្ញុំមិនដំទាស់ចំពោះការសម្រេចចិត្តនោះទេ ។ ដូច្នេះ មួយខែក្រោយមក យើងក៏រៀបចំពិធីអាពាហ៍ពិពាហ៍របស់បងប្រុសខ្ញុំ ។ សម្រាប់ពិធីនេះ ខ្ញុំមានភារកិច្ចទទួលខុសត្រូវផ្នែកភេសជ្ជៈ ដោយសារតាមរយៈមិត្តភក្តិដែលខ្ញុំមាននៅក្នុងក្រុមហ៊ុនសុរាគារខ្មែរ ខ្ញុំអាចរកបាននូវសុរាល្អៗ ដែលមានតម្លៃសមរម្យ ។ ពួកយើងសម្រេចជ្រើសរើសយកស្រាវ៉ូម ណេហ្គ្រីតា (Negreta) លាយជាមួយសូដា និង ទឹកកក សម្រាប់ពិធីជប់លៀង នៅក្នុងភោជនីយដ្ឋានធំមួយនៅម្តុំផ្សារចាស់ ។ នៅក្នុងឱកាសនោះ បងប្រុសទីពីររបស់ខ្ញុំ បងស៊ីនឿន បានអញ្ជើញគ្រូជនជាតិបារាំងរបស់គាត់ពីរនាក់ឲ្យមកចូលរួម ។ គ្រូបារាំងម្នាក់បានប្រើប្រាស់កាមេរ៉ាថតខ្សែភាពយន្តទំហំ ១៦ មម របស់គាត់ (Camera) ដើម្បីថតពិធីជប់លៀងទាំងមូលផង ។ ខ្សែភាពយន្តនោះមានប្រជាប្រិយភាពជាខ្លាំង នៅពេលដែលពួកយើងយកមកបញ្ចាំងឲ្យបងប្អូន និង ញាតិមិត្តដែលបានចូលរួមក្នុងពិធីជប់លៀងទស្សនានៅពេលក្រោយៗមក ។

បងប្រុសទី១របស់ខ្ញុំពូកែធ្វើការទាក់ទងណាស់ ។ មួយខែក្រោយពីរៀបការមក គាត់ទទួលបាននូវការអនុញ្ញាតឲ្យភរិយាថ្មោងថ្មីរបស់គាត់ បានផ្លាស់មកបង្រៀននៅសាលាជាមួយគាត់ ក្បែររាជធានីភ្នំពេញដែរ ។ ដូច្នេះ ផ្ទះយើងក៏ទទួលបាននូវសមាជិកថ្មីទៀត ។ យើងមានគ្នាកាន់តែច្រើនឡើងៗ ព្រោះថាគ្រួសារខាងបងថ្លៃខ្ញុំ ក៏បានមករួមរស់ជាមួយពួកយើងថែមទៀត ។ ដោយសារសង្គ្រាម ជីវភាពយើងក៏កាន់តែមានការលំបាកដែរ ។ មនុស្សម្នាកាន់តែមានចំនួនច្រើនឡើង នាំឲ្យមានការលំបាកក្នុងការផ្គត់ផ្គង់ជាអនេកកប្បការ ។

ចូលធ្វើការក្នុងក្រុមហ៊ុនឯកជន

នៅខែ កុម្ភៈ ១៩៧១ ខ្ញុំឈប់ធ្វើការនៅក្នុងក្រុមហ៊ុនសុរាគារខ្មែរទៀតហើយ ដោយខ្ញុំរកការបានធ្វើនៅក្នុងក្រុមហ៊ុនសូគីឡេ (Sokilait) ។ កាលនោះ បន្ទាប់ពីបានទម្លាក់សម្តេច សីហនុ ពីអំណាច រដ្ឋាភិបាល លន់ នល់ បានចាប់ផ្តើមអនុវត្ត នយោបាយបណ្តេញជនជាតិវៀតណាមឲ្យចេញពីកម្ពុជា ។ ជនជាតិវៀតណាមដែលត្រូវចាប់ខ្លួន ត្រូវប្រមូលឲ្យនៅក្នុងជំរុំ រួចត្រៀមបញ្ជូនទៅប្រទេសវៀតណាមវិញ ។ ជនជាតិវៀតណាម ដែលគេរកឃើញរស់នៅក្រៅជំរុំជនភៀសខ្លួនអាចទទួលនូវការបង្ក្រាបពីអាជ្ញាធរ ។ ដោយសារមានការភ័យខ្លាចយ៉ាងខ្លាំង នោះទើបលោកគ្រូជនជាតិបារាំងរបស់បងខ្ញុំ ដែលមានសង្សារជាស្ត្រីជនជាតិវៀតណាមដ៏ក្មេងខ្ចីមួយនាក់ផងនោះ បានមកសុំឲ្យពួកយើងរកវិធីជួយរំដោះនាងឲ្យចេញផុតពីរាជធានីភ្នំពេញ ទៅរកទីកន្លែងដែលមានសុវត្ថិភាព ។ យើងបានសុខចិត្តជួយរំដោះសង្សាររបស់លោកគ្រូបារាំងនោះ ។ យើងឲ្យស្ត្រីវៀតណាមនោះស្លៀកសារ៉ុងបន្លំជាស្ត្រីខ្មែរ និង ហាមកុំឲ្យនិយាយស្តីអ្វីសោះ នៅពេលយើងឆ្លងកាត់ប៉ុស្តិ៍ត្រួតពិនិត្យរបស់ក្រុមតម្រួតយោធាដែលនៅជាបន្តបន្ទាប់តាមផ្លូវ ។ ពួកយើងមានភ័ព្ធ

សំណាងណាស់ ព្រោះឆ្លងកាត់តំបន់ត្រួតពិនិត្យដោយពុំមានជួបប្រទះនូវឧបសគ្គ អ្វីទាំងអស់ រហូតទៅដល់ "អ្នកលឿង" ដែលជាទីដៅនៃដំណើររបស់យើង ។ ស្ត្រីក្មេងជនជាតិវៀតណាមនោះ បានជួបនឹងគ្រួសាររបស់នាងនៅអ្នកលឿង ហើយ បានសំដែងអំណរគុណដ៏រំភើប ចំពោះពួកយើង ។ ដោយសារការបណ្តេញជន ជាតិវៀតណាមចេញពីកម្ពុជាយ៉ាងនេះហើយ ទើបជនជាតិវៀតណាម ដែលធ្វើការ ជាគណនេយ្យករនៅក្នុងក្រុមហ៊ុន សូគីឡេ (Sokilait) បានបង្ខំចិត្តលះបង់ការងារ ហើយបានទទួលទិដ្ឋាការទៅរស់នៅឯប្រទេសបារាំង ។ ដោយសារក្រុមហ៊ុនត្រូវ ការគណនេយ្យករជាចាំបាច់ខានពុំបាន ទើបគេជ្រើសរើសខ្ញុំឲ្យចូលមកជំនួសជន ជាតិវៀតណាមនោះទៅ ។

នៅក្នុងក្រុមហ៊ុនថ្មីនេះ ខ្ញុំបានរៀនសូត្ររបៀបរបបធ្វើការថ្មីៗទៀត ព្រោះ ម្តងនេះ ខ្ញុំធ្វើការក្នុងក្រុមហ៊ុនឯកជនសុទ្ធសាធតែម្តង ដែលតម្រូវឲ្យយើងមាន ប្រសិទ្ធភាពក្នុងការងារច្បាស់លាស់ពិតប្រាកដ ។ បើប្រៀបធៀបទៅនឹងក្រុមហ៊ុន សុរាគារខ្មែរ ដែលខ្ញុំបានសន្មត់ថារបៀបរបបការងារមានលក្ខណៈសកម្មជាងនៅ ក្នុងមន្ទីរ ឬ ក្រសួងនានានៃរដ្ឋាភិបាលរួចទៅហើយនោះ ខ្ញុំក៏ឃើញថាការងារនៅ សូគីឡេ មានប្រសិទ្ធិភាពខ្ពស់ ហើយបុគ្គលិកគ្រប់គ្នាសុទ្ធតែប្រញឹកក្នុងការងារគ្មាន ពេលនិយាយគ្នាលេងឥតប្រយោជន៍មួយនាទីណាឡើយ ។ សូគីឡេមានការគ្រប់ គ្រងតាមបទដ្ឋានអន្តរជាតិ ដោយសារក្រុមហ៊ុននេះមានភាគហ៊ុនអន្តរជាតិមកពី ប្រទេសដាណឺម៉ាក អូស្ត្រាលី ស៊ុយអែត និង ខ្មែរ ។ ប្រធានធំរបស់ក្រុមហ៊ុនមេ[26] ជាជនជាតិដាណឺម៉ាក ដែលកាន់តំណែងជាកុងស៊ុលតំណាងផលប្រយោជន៍ ប្រទេសដាណឺម៉ាក នៅព្រះរាជាណាចក្រកម្ពុជាផង ។ លោកកុងស៊ុល ជាប្រធាន អគ្គនាយក ចំណែកអគ្គនាយករង ជាជនជាតិស៊ុយអែត ។ ថ្នាក់ដឹកនាំដែលមាន

[26] Société mère គឺក្រុមហ៊ុនដែលបង្កើតក្រុមហ៊ុនឯទៀត ។

សញ្ជាតិជាណឺម៉ាក មានតួនាទីទទួលខុសត្រូវផ្នែកគ្រប់គ្រង ឯពួកជនជាតិអូស្ត្រាលី មានការកិច្ចខាងផលិតកម្ម ខាងថែទាំ ខាងត្រួតពិនិត្យគុណភាព និង ខាងផ្នែកស្រាវជ្រាវ ។ ខ្ញុំចូលចិត្តពួកអូស្ត្រាលីណាស់ ដោយឃើញគេប្រឡូកធ្វើការដោយផ្ទាល់ជាមួយពួកកម្មករខ្មែរ ។ ពួកគេមិនប្រកាន់ខ្លួនឡើយ ទោះបីជាពួកគេសុទ្ធសឹងជាវិស្វកមានជំនាញខ្ពស់យ៉ាងណាក៏ដោយ ។ ខ្ញុំនឹកក្នុងចិត្តថា ប្រសិនបើខ្មែរយើងវិញ បើមានឋានៈជាវិស្វកអ្នកហើយនោះ មិនងាយនឹងចូលមកប្រឡូកផ្ទាល់ក្នុងការងារជាមួយពួកកម្មករឡើយ ព្រោះតាមទម្លាប់កន្លងមក ពួកវិស្វកខ្មែរភាគច្រើនចាំតែលូកហោប៉ៅខោស្រែកបញ្ជាពីចម្ងាយតែប៉ុណ្ណោះ ។ ទាំងនេះជាការសង្កេតរបស់ខ្ញុំនាសម័យនោះ ។

ខ្ញុំបានត្រូវជ្រើសរើសឲ្យចូលធ្វើការនៅសូគីឡេ ជំនួសគណនេយ្យករវៀតណាមនោះ ដោយលោកនាយគណនេយ្យករម្នាក់ឈ្មោះ លន់ មាន ដែលធ្លាប់បានរៀនសូត្រនៅសាលាពាណិជ្ជកម្មដែរ ហើយមានបំណងចង់បានគណនេយ្យករក្មេងម្នាក់ ដែលមានបទពិសោធន៍គ្រប់គ្រាន់ និង មានចិត្តស្និតស្នាញក្នុងការងារ ។ ខ្ញុំឮគេថាលោក លន់ មាន ជាប់ជាសាច់ញាតិជាមួយលោក លន់ នល់ ផង ដូច្នេះហើយទើបគាត់មានទំនាក់ទំនងល្អជាមួយមន្ត្រីថ្នាក់ដឹកនាំធនាគាររដ្ឋ និង ក្រសួងសំខាន់ៗដូចជាក្រសួងសេដ្ឋកិច្ច និង ពាណិជ្ជកម្មជាដើម ។ លោកនាយប្រើពេលវេលារបស់គាត់ភាគច្រើនក្នុងទំនាក់ទំនងសាធារណៈ ច្រើនជាងកិច្ចការខាងគណនេយ្យ ព្រោះក្រុមហ៊ុនត្រូវការចរចាជាមួយរដ្ឋាភិបាល ឬ ធនាគារដើម្បីទទួលឲ្យបាននូវភាពអនុគ្រោះសំខាន់ៗ សំរាប់ក្រុមហ៊ុនដូចជាប្រាក់កម្ចីបន្ថែមពីធនាគារអាជ្ញាប័ណ្ណនាំចេញនាំចូល ឬ ការទូទាត់តម្លៃទំនិញ ដែលរដ្ឋាភិបាលអាចផ្តល់មកក្រុមហ៊ុន។ល។ កាលពីសម័យសង្គមរាស្ត្រនិយម វិស័យធនាគារត្រូវបានធ្វើជាតួបនីយកម្មទាំងអស់ ពុំមានធនាគារឯកជនទេ ។ នៅក្រោយពេលដែលលោក

លន់ នល់ ឡើងកាន់អំណាច ប្រទេសយើងក៏ចាប់ផ្តើមទទួលបាននូវការវិនិយោគទុនឯកជនមួយចំនួន ។ ក៏ប៉ុន្តែ ក្រុមហ៊ុនស៊ូគីឡេ នៅតែបន្តធ្វើការជាមួយធនាគារដ្ឋដ៏ធំមួយឈ្មោះ ធនាគារខ្មែរសំរាប់ពាណិជ្ជកម្ម ។ តាមរយៈទំនាក់ទំនងល្អ ក្រុមហ៊ុនក៏ទទួលបានប្រាក់កម្ចីច្រើន ឬ ក៏ត្រូវអនុញ្ញាតឲ្យពន្យារពេលសងប្រាក់ជំពាក់ជាច្រើនលើកច្រើនគ្រា ។ ក្រៅពីសេចក្តីត្រូវការខាងផ្នែកសាច់ប្រាក់ក្រុមហ៊ុនក៏នៅត្រូវការនាំចូលឲ្យបានឆាប់ៗនូវសំភារៈ ឬវត្ថុធាតុដើមជាច្រើនទៀត ។ ម្យ៉ាងទៀត បើតាមខ្ញុំចាំមានតែក្រុមហ៊ុនស៊ូគីឡេទេ ដែលមានភ័ព្វសំណាងបានទទួលប្រាក់សំណងពីក្រសួងពាណិជ្ជកម្ម នៅពេលដែលតម្លៃផលិតទឹកដោះគោឡើងខ្ពស់ពីតម្លៃដែលក្រសួងកំណត់ឲ្យលក់នៅលើទីផ្សារ ។ ក្នុងសម័យសង្គ្រាម អតិផរណាចេះតែកើនឡើងរាល់ថ្ងៃ ដូច្នេះតំលៃទំនិញនៅលើទីផ្សារ ចេះតែកើនឡើងឥតឈប់ឈរ ។ ក្រសួងពាណិជ្ជកម្មមានគោលនយោបាយកំណត់តម្លៃទំនិញចាំបាច់ទាំងឡាយមិនឲ្យឡើងហួសហេតុផលពេក ជាពិសេសតម្លៃទឹកដោះគោ ។ ក្នុងទំនាក់ទំនងនេះ លោក លន់ មាន បានទទួលការគ្រាំទ្រដ៏រឹងមាំពីថ្នាក់ដឹកនាំក្រុមហ៊ុន ។ មួយថ្ងៃៗ គាត់ត្រូវបានអនុញ្ញាតឲ្យដកសាច់ប្រាក់ជាច្រើនសន្ធឹកសន្ធាប់ដើម្បីយកទៅជប់លៀង ឬ សូកមន្ត្រីធំៗរបស់ធនាគារ ឬ របស់ក្រសួងនានាដែលក្រុមហ៊ុនត្រូវការភាពអនុគ្រោះ ។ ជាមួយគ្នានោះ ក្រុមហ៊ុនក៏បានបង្កើតផ្នែកស្វែងរកទីផ្សារ (Marketing Department) ដែលមានស្ត្រីក្មេងៗស្លៀកសំលៀកបំពាក់ឯកសណ្ឋានដ៏ស្រស់ស្អាតនៅធ្វើការងារជាប្រចាំ ។ ពួកស្ត្រីទាំងនោះ ចេះនិយាយភាសារបរទេសយ៉ាងស្ទាត់ជំនាញ ទាំងភាសាបារាំង ទាំងភាសាអង់គ្លេស ឬ ចិន ។ ពួកនាងៗទាំងនោះមួយភាគធំសុទ្ធតែចេញពីសាលាបារាំង ឬ មកពីបរទេស ។ ក្នុងចំណោមនោះ មានស្ត្រីក្មេងៗពីរនាក់ជាចិនកន្តាំង ឬ ចិនតៃវ៉ាន់ ។ ខ្ញុំឮគេនិយាយថា នាងទាំងពីរនាក់នោះ មានការកិច្ចសំខាន់គឺទាក់ទាញអារម្មណ៍ ឬ បំរើសេវាគ្រប់យ៉ាង

កំដរថ្នាក់ដឹកនាំក្រសួង មានដូចជារដ្ឋមន្ត្រីច្រើនជាងការងារស្វែងរកទីផ្សារ ។

និយាយគ្នាតាមវចនានុក្រម

បន្ទាប់ពីខ្ញុំធ្វើការបាន ៦ ខែ លោក លន់ មាន ត្រូវផ្លាស់ចេញទៅកាន់តំណែងផ្សេង ហើយគាត់ត្រូវជំនួសដោយនាយគណនេយ្យករថ្មី ដែលមានសញ្ជាតិជាណឺម៉ាក[27] ។ លោកនាយថ្មី មិនចេះនិយាយភាសាបរទេសអ្វីផ្សេង ក្រៅពីភាសាអង់គ្លេស បន្ថែមលើភាសាជាណាម៉ាក ដែលជាភាសាកំណើតរបស់គាត់ ។ នៅពេលនោះ ខ្ញុំមិនទាន់ចេះនិយាយភាសាអង់គ្លេសនៅឡើយទេ ខ្ញុំចេះតែភាសាខ្មែរ និង បារាំងប៉ុណ្ណោះ ។ ដូច្នេះ ខ្ញុំត្រូវការអ្នកបកប្រែភាសាក្នុងការងារជាមួយលោកនាយរបស់ខ្ញុំ ។ ដើម្បីសំរួលការងាររបស់យើង ក្រុមហ៊ុនបានជ្រើសរើសអ្នកបកប្រែម្នាក់ ។ អ្នកបកប្រែនោះ គ្រាន់តែចេះភាសាអង់គ្លេសតែមិនមានបទពិសោធន៍ណាសោះក្នុងកិច្ចការហិរញ្ញវត្ថុ និង គណនេយ្យ ។ ជាច្រើនលើកច្រើនសារ ខ្ញុំទទួលបាននូវការបកប្រែមិនច្បាស់លាស់ ចំពោះការណែនាំរបស់លោកនាយ ជាហេតុឲ្យពួកយើងមានការលំបាកក្នុងការងារ ។ នៅទីបំផុត លោកនាយ និង ខ្ញុំ យើងទាំងពីរនាក់ សម្រេចចិត្តមិនត្រូវការអ្នកបកប្រែភាសាទៀតទេ ។ យើងប្រើវចនានុក្រមបារាំង-អង់គ្លេសចំនួនពីរក្បាល មួយក្បាលសម្រាប់លោកនាយ មួយក្បាលទៀតសំរាប់ខ្ញុំ ។ បើខ្ញុំចង់ពន្យល់អ្វី ខ្ញុំបើកវចនានុក្រមលើពាក្យបារាំង ដែលមានបកប្រែភាសាអង់គ្លេសបង្ហាញទៅគាត់ បើលោកនាយចង់ពន្យល់អ្វីមកខ្ញុំ គាត់បើកវចនានុក្រម លើពាក្យអង់គ្លេសដែលមានបកប្រែជាបារាំងបង្ហាញមកខ្ញុំទៅវិញទៅមក ។ ក៏ប៉ុន្តែ យើងទាំងពីរនាក់ប្តេជ្ញាចិត្តរៀងៗខ្លួនថាក្នុងរយៈពេលមួយឆ្នាំ ខ្ញុំត្រូវចេះភាសា

[27] លោកប្រធានក្រុមគណនេយ្យនោះឈ្មោះ E. W. N. Eichmeyer.

អង់គ្លេស ឯលោកនាយត្រូវចេះភាសាបារាំង ។ យើងធ្វើយ៉ាងនេះ ក្នុងរយៈពេល ពេញមួយឆ្នាំ ។ ក្នុងរយៈពេលមួយឆ្នាំនេះ ខ្ញុំខិតខំរៀនភាសាអង់គ្លេសដោយខ្លួន ឯង តាយរយៈខ្សែអាត់សម្លេង និង ការអានសៀវភៅ ។ នៅពេលដែលខ្ញុំអាច និយាយភាសាអង់គ្លេសបានខ្លះៗនោះ ពួកយើងចាប់ផ្តើមជជែលគ្នានិយាយគឺ នៅ ពេល ដែលខ្ញុំនិយាយអង់គ្លេស លោកនាយនិយាយភាសាបារាំងមកវិញ ។ មិនយូរ ប៉ុន្មាន យើងក៏អាចនិយាយទាក់ទងគ្នាជាភាសាអង់គ្លេសបាន ឯលោកនាយរបស់ខ្ញុំ នៅតែបន្តនិយាយភាសាបារាំងបានយ៉ាងរដិបរដុបតទៅទៀត ។ ខ្ញុំរក្សាមិត្តភាពដ៏ ជិតស្និទ្ធ បានល្អណាស់ជាមួយនាយចៅហ្វាយរបស់ខ្ញុំ រហូតដល់ពេលដែលខ្ញុំបែក ចេញទៅរស់នៅឯប្រទេសបារាំង ។

នៅសម័យនោះ ខ្ញុំអាចនិយាយបានថា ខ្ញុំមានការចងចាំល្អ ជាពិសេស ចងចាំខាងលេខ ឬ ចំនួនដែលអាចឲ្យខ្ញុំឆ្លើយភ្លាមៗ ចំពោះសំណួរទាក់ទងទៅនឹង ចំនួនប្រាក់កាសចំណូលចំណាយ និង លេខគណនីយ ដែលគេចងក្រងជាផែនការ គណនេយ្យ (Plan Comptable) ដែលមានលេខជាច្រើនខ្ទង់ ។ ម្យ៉ាងទៀត ខ្ញុំក៏រៀន ភាសាបរទេសឆាប់ចេះណាស់ដែរ ដូចជាភាសាអ៊ីតាលី ដែលខ្ញុំអាចសរសេរសំបុត្រ ឆ្លើយឆ្លងបន្តិចបន្តួចបាន ក្រោយពីបានរៀនខ្លួនឯងតាមរយៈសៀវភៅមេរៀន ដែល មានខ្សែអាត់ថតសម្លេងក្នុងរយៈពេលដ៏ខ្លី ។ ក៏ប៉ុន្តែ ខ្ញុំមានចំណុចខ្សោយមួយដ៏ធំ គឺ ខ្ញុំមិនព្យាយាមរៀនឱ្យបានវែងឆ្ងាយ ឬ ជ្រៅជ្រះគឺ គ្រាន់តែមួយឆាវៗ រួចក៏រលត់ បាត់អស់ទៅ ។

មន្ត្រីពន្ធដារសួរថា "រៀបចំរួចស្រេចហើយឬនៅ?"

មុនពេលលោក លន់ មាន ត្រូវប្តូរមុខតំណែងចេញពីផ្នែកគណនេយ្យគាត់ បានអនុញ្ញាតឲ្យខ្ញុំទៅ ធ្វើការក្រៅម៉ោងបន្ថែមនៅក្នុងក្រុមហ៊ុនឯកជនពីរទៀតដែល

មានក្រុមហ៊ុនមេដាររបស់បារាំង ។ ក្រុមហ៊ុនមួយ មានទីតាំងនៅក្បែរសូគីឡេដែរ ។ ដូច្នេះ នៅពេលថ្ងៃត្រង់ ពេលសម្រាកការងារនៅសូគីឡេ ខ្ញុំក៏ប្រញាប់ប្រញាល់ទៅធ្វើការបន្ថែមនៅក្នុងក្រុមហ៊ុនបារាំងនោះ ។ ក្រុមហ៊ុនមួយទៀតមានទីតាំងនៅតាមមហាវិថីព្រះនរោត្តម ។ រាល់ពេលល្ងាច កាលណាខ្ញុំចេញពីសូគីឡេ ខ្ញុំត្រូវបន្តការងារនៅក្រុមហ៊ុនបារាំងមួយនោះទៀត រហូតម៉ោងប្រមាណប្រាំបួនយប់ ។ ខ្ញុំធ្វើការផ្ទាល់ជាមួយនាយកក្រុមហ៊ុនដែលជាជនជាតិបារាំង បន្ទាប់ពីគណនេយ្យការរបស់ក្រុមហ៊ុនដែលជាជនជាតិវៀតណាមរបស់ក្រុមហ៊ុននោះ បានបោះបង់ចោលការងារ ដោយត្រូវបង្ខំចិត្តត្រឡប់ទៅស្រុកគេវិញ តាមនយោបាយរបស់រដ្ឋាភិបាល លន់ នល់ បន្ទាប់ពីព្រឹត្តិការណ៍ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៧០ ។ អស់រយៈពេលមួយឆ្នាំមកហើយដែលក្រុមហ៊ុនគ្មានគណនេយ្យការធ្វើការ ហើយការងារផ្នែកគណនេយ្យនេះ ក៏ចេះតែកើនឡើងគរជាគំនរឯងរាល់ថ្ងៃ ។ ខ្ញុំមានភារកិច្ចរៀបចំបញ្ជីស្នាមរបស់ក្រុមហ៊ុនឲ្យមានសណ្តាប់ធ្នាប់ឡើងវិញ ។ ក្នុងរយៈពេលជាងមួយឆ្នាំកន្លងមកហើយនោះ ក្រុមហ៊ុនបារាំងទាំងពីរពុំដែលបានបង់ពន្ធអ្វីឡើយ ។ ដូច្នេះ ខ្ញុំត្រូវរៀបចំឯកសារគណនេយ្យឲ្យបានត្រឹមត្រូវទាន់ពេលវេលា និង ត្រូវគិតគូរបង់ពន្ធជូនរដ្ឋតាមច្បាប់ផង ។ នៅសម័យ លន់ នល់ នោះ ប្រទេសយើងជួបប្រទះនូវអំពើពុករលួយយ៉ាងធ្ងន់ធ្ងរ ។ ចំពោះខ្ញុំ ដែលមិនធ្លាប់មានទំនាក់ទំនងជាមួយផ្នែករដ្ឋការ ខ្ញុំមិនបានយល់ពីរបៀបរបបការងារដែលត្រូវធ្វើឡើងជាមួយមន្ទីរ ឬ ក្រសួងនាសម័យនោះឡើយ ។

តាមពិតនៅសម័យនោះ ការបង់ពន្ធដារ មិនមានការអ្វីពិបាកនោះទេគឺ គេគ្រាន់តែចរចាជាមួយមន្ត្រីពន្ធដារឲ្យត្រូវរ៉ូវគ្នាទៅក៏រួចគ្នាទៅហើយ ។ បើត្រូវបង់ ១០០ យើងអាចចរចាបង់តែ ៥០ ឬ ៦០ ដោយជូនជាសាគុណមួយផ្នែកដល់មន្ត្រីទទួលខុសត្រូវនោះ ។ ថ្ងៃមួយ ខ្ញុំបានណាត់ពេលសុំជួបមន្ត្រីពន្ធដារ ដើម្បីនាំយក

បញ្ជីនាំចូល និង បញ្ជីចំណូលទៅជូនគាត់ពិនិត្យក្នុងការវាយតម្លៃនាំចូលដែលក្រុមហ៊ុនបារាំងត្រូវបង់ជូនរដ្ឋ ។ នៅថ្ងៃដែលកំណត់ត្រូវជួបគ្នានោះ ខ្ញុំបានបង្ហាញបញ្ជីសៀវភៅជូនមន្ត្រីពន្ធដារពិនិត្យ ។ នៅពេលចាប់ផ្តើមមន្ត្រីនោះសួរខ្ញុំថា "អ្វីៗរៀបចំស្រេចហើយឬនៅ?" ខ្ញុំឆ្លើយថា "បាទទាន" ដោយនឹកថា ការងារដែលខ្ញុំធ្វើនោះបានរៀបចំស្រេចបាច់ហើយ ។ ក៏ប៉ុន្តែ មន្ត្រីពន្ធដារនោះ នៅតែបន្តសួរខ្ញុំដដែលថា "អ្វីៗរៀបចំស្រេចហើយឬៗនៅ?" នៅពេលដែលគាត់បើកសៀវភៅពីទំព័រមួយទៅទំព័រមួយ ។ តាមពិត ខ្ញុំមិនបានយល់អំពីភាសារបស់គាត់ដែលធ្លាប់និយាយទៅកាន់អ្នកឯទៀតដែលមានបទពិសោធន៍ច្បាស់លាស់ ។ តាមពិតអ្វីដែលមន្ត្រីនោះចង់និយាយគឺ គាត់ចង់សួរថា តើខ្ញុំបានត្រៀមស្រោមសំបុត្រទុកនៅក្នុងចន្លោះទំព័រសៀវភៅនោះហើយឬនៅ? ដូច្នេះហើយ ទើបគាត់ចេះតែសួរដដែលៗនៅពេលដែលខ្ញុំឆ្លើយថា "បាទទានៗៗ" ។ ដោយសារមិនឃើញមានស្រោមសំបុត្រនោះ យើងពុំបានសំរេចការងារអ្វីឡើយ ហើយត្រូវណាត់ពេលនៅថ្ងៃក្រោយទៀត ។ បីអាទិត្យក្រោយមក ខ្ញុំក៏ទៅជួបមន្ត្រីនោះសាជាថ្មី ជាមួយនិងស្រោមសំបុត្រប្រកបដោយប្រាក់មួយចំនួនផង ។ លើកនេះការងាររបស់យើងបានប្រព្រឹត្តទៅយ៉ាងរលូន និង ឆាប់រហ័ស ដោយគ្មានបញ្ហាអ្វីធំដុំឡើយ ។

មានគណនីនៅក្រេឌីលីយ៉ោណេ[28]

ក្នុងសម័យនោះ ខ្ញុំមានការងារជាប់រវល់យ៉ាងមមាញឹក ។ ខ្ញុំពុំសូវមានឱកាសបានជួបមុខឪពុកម្តាយ បងប្អូនដែលរស់នៅភ្នំពេញឡើយ ។ ខ្ញុំរកប្រាក់បានល្មមគ្រាន់តែចិញ្ចឹមបងប្អូនញាតិសន្តាន ដែលរស់នៅជាមួយខ្ញុំនៅទីក្រុងភ្នំពេញ

[28] Crédit Lyonais ក្រេឌីលីយ៉ោណេ ជាធនាគារដ៏ធំមួយនៅប្រទេសបារាំង ។

ដែលកាន់តែមានចំនួនច្រើនឡើងៗដោយសារនាំគ្នាគេចពីសង្គ្រាម និង គ្រាន់តែទប់ទល់ទំនិញឡើងថ្លៃជារៀងរាល់ថ្ងៃ ដែលជានិច្ចជាកាលឡើងលឿនជាងប្រាក់ចំណូលរបស់យើងទៀតផង នាសម័យនោះ ។ នៅឆ្នាំ ១៩៧១ ខ្ញុំសន្សំសំចៃប្រាក់បានត្រឹមតែទិញទោចក្រយានយន្តម៉ាកហុកដា (HONDA CP 50) មួយគ្រឿង ដែលពួកស្ត្រីភាគច្រើននិយមប្រើប្រាស់ ព្រោះមានភាពងាយស្រួលក្នុងការបើកបរ និង មានតំលៃថោកជាងគេក្នុងចំណោមទោចក្រយានយន្តម៉ាកហុងដា (HONDA) ទាំងអស់ ។ ក្រោយមក ខ្ញុំក៏មានលទ្ធភាពបើកគណនីមួយនៅប្រទេសបារាំងតាមរយៈសំបុត្រឆ្លើយឆ្លង ។ ខ្ញុំមានមោទនភាពណាស់ ដោយទទួលបាននូវមូលប្បទានប័ត្របារាំងរបស់ធនាគារក្រេឌីលីយ៉ោណេ (Crédit Lyonais) ទោះបីជាខ្ញុំមិនដែលបានទៅប្រទេសបារាំង និង មានប្រាក់បន្តិចបន្តួចក្នុងគណនីនោះយ៉ាងណាក៏ដោយ[29] ។

ក្រុមហ៊ុនកូមិនខ្មែរជាក្រុមហ៊ុនចុងក្រោយ

នៅខែ កញ្ញា ១៩៧២ ខ្ញុំត្រូវបានផ្លាស់ឲ្យទៅធ្វើការនៅក្រុមហ៊ុនមេឈ្មោះ កូមិន្ទខ្មែរ (Comin Khmer) ។ ក៏ប៉ុន្តែ ខ្ញុំត្រូវបំរើការងារនៅក្នុងផ្នែកមួយផ្សេងពីផ្នែកគណនេយ្យ ។ ផ្នែកនោះឈ្មោះថា អ៊ី ឌី ភី (E D P) “Electronic Data Processing ” ដែលជាផ្នែកថ្មីទំនើបនៅក្នុងសម័យនោះ ។ ផ្នែកនេះបិតនៅក្រោមការគ្រប់គ្រងរបស់លោក លៀស ចាន់ថុន ដែលជាបញ្ញវន្តខ្មែរមួយរូបដែលមានបរិញ្ញាប័ត្រមកពីសហរដ្ឋអាមេរិកផ្នែកពាណិជ្ជកម្ម (Bachelor Degree of Business Administration)។ លោក លៀស ចាន់ថុន មានទំនាក់ទំនងជិតស្និទ្ធជាមួយថ្នាក់

[29] តាមពិត នៅក្នុងគណនីនោះ ខ្ញុំមានប្រាក់ចំនួន ៦៧៥ ហ្រ្វង់ ឬ ជាង ២០០ ដុល្លារអាមេរិក ។

ដឹកនាំរបស់ក្រុមហ៊ុន ជាពិសេសក្រុមហ៊ុនស្កង់ឌីណាវ (Scandinave) ។ ខ្ញុំឮគេថា លោក លៀស ចាន់ថុន ជាមន្ត្រីគ្រប់គ្រងមួយរូប ដែលបានផ្តើមគំនិតរៀបចំផ្នែកថ្មីនេះ ។ ខ្ញុំត្រូវទៅធ្វើការនៅឯស្នាក់ការកូមិន្ទខ្មែរ (Comin Khmer) ដែលតាំងនៅតាមវិថីកម្ពុជាក្រោម ដែលជាវិថីមួយមានចរាចរណែនណាន់តាន់តាប់ជាប់ជានិច្ច ។ ដូច្នេះ ខ្ញុំទៅធ្វើការនៅទីកន្លែងដែលជិតជាង កាលខ្ញុំនៅឯក្រុមហ៊ុនសូគីឡេ ។

នៅពេលខ្ញុំផ្លាស់មកកូមិន្ទខ្មែរនោះ ខ្ញុំក៏ឈប់ធ្វើការក្រៅម៉ោងឲ្យក្រុមហ៊ុនបារាំងទាំងពីរនោះទៀតហើយ ដោយហេតុថាក្រុមហ៊ុនទាំងពីរនោះ ត្រូវបានបញ្ចប់សកម្មភាពរបស់គេទាំងស្រុងព្រោះតែភ្លើងសង្គ្រាមចេះតែឆេះសន្ធោសន្ធៅឡើងៗ។ មុខងារថ្មីរបស់ខ្ញុំនៅផ្នែកអ៊ី ឌី ភី (E D P) នេះ ជាមុខងារអ្នកត្រួតពិនិត្យ “E D P Controller” តែមួយគត់នៅក្នុងក្រុមហ៊ុន ។ ភារកិច្ចរបស់ខ្ញុំ មានជាអាទិដូចជាចុះលេខកូដរបស់ឯកសារទាំងអស់ត្រួតពិនិត្យមុននឹងបញ្ជូនទៅផ្នែកកុំព្យូទ័រ ។ នៅផ្នែកកុំព្យូទ័រ ប្រសិនបើមានការភ័ន្តច្រឡំ ខ្ញុំត្រូវរកការភ័ន្តច្រឡំនោះឲ្យឃើញ និងកែតម្រូវឡើងវិញ ។ ម្យ៉ាងទៀត ខ្ញុំត្រូវត្រួតពិនិត្យឯកសារកុំព្យូទ័រទាំងឡាយមុននឹងចែកចាយឲ្យប្រើប្រាស់ ។ តាមពិត ក្រុមហ៊ុនកូមិន្ទខ្មែរ ជាក្រុមហ៊ុនទំនើបមួយដែលមានឧបករណ៍អេឡិចត្រូនិកប្រើប្រាស់សំរាប់ការងាររបស់គេ ។ ក៏ប៉ុន្តែកុំព្យូទ័រសម័យនោះ ជាកុំព្យូទ័រធំៗហើយដែលគេប្រើប្រាស់តាមប្រព័ន្ធចោះកាតដែលគេហៅថាកាត ៨២ ខ្ទង់ ។ ក្រោយមក នៅពេលខ្ញុំចេញដំណើរទៅប្រទេសបារាំង ក្រុមហ៊ុនកូមិន្ទខ្មែរ ចាប់ផ្តើមប្រើប្រព័ន្ធថាស (Disk System) ។

ខ្ញុំធ្វើការក្នុងការិយាល័យជាមួយអ្នករៀបរៀងកម្មវិធី (Software Programmer) ម្នាក់ឈ្មោះ ផាន់ សូរិយាស៊ី ដែលទើបតែត្រឡប់មកពីប្រទេសបារាំង ។ សូរិយាស៊ី ជាមនុស្សស្អាតហើយចូលចិត្តស្លៀកពាក់ហ៊ីហា ។ តាមធម្មតា តុធ្វើការរបស់យើងត្រូវរៀបចំទុកដាក់ទល់មុខគ្នា ។ ក៏ប៉ុន្តែ សូរិយាស៊ី បានសុំឲ្យខ្ញុំប្តូរទី

កន្លែងដោយរៀបតុរបស់គេ ចូលជ្រៅនៅខាងក្នុងបន្ទប់ ឯតុរបស់ខ្ញុំនៅក្បែរមាត់ទ្វារ ។ ខ្ញុំក៏យល់ព្រមរៀបចំតាមសំណើនោះ។ ក៏ប៉ុន្តែ ខ្ញុំនឹកក្នុងចិត្តថាគាត់នេះអាចគិតថា "ខ្ញុំមានជម្ងឺឆ្លងណាមួយហើយ ទើបគេមិនចង់ឲ្យនៅជិត ប្រហែលគេខ្លាចឆ្លងជម្ងឺអ្វីពីខ្ញុំទេដឹង?" តាមពិតនៅជំនាន់នោះ ខ្ញុំមានរូបរាងកាយស្គមស្គាំងម្យ៉ាងដោយសារការនឿយហត់ក្នុងការងារ និង ម្យ៉ាងទៀតទំនងជា នៅពេលនោះខ្ញុំពុំបានទទួលទានអាហារឲ្យគ្រប់គ្រាន់តាមតម្រូវការកាឡូរី ។ បន្ថែមលើពីនោះខ្ញុំក៏មានសម្បុរខ្មៅដូចជនជាតិអាហ្វ្រិកដែរ ។ ក៏ប៉ុន្តែនៅទីបំផុត សូរិយោស៊ី ក៏ក្លាយទៅជាមិត្តជិតស្និទ្ធម្នាក់របស់ខ្ញុំ ។ ការិយាល័យរបស់យើងទាំងពីរនាក់ នៅចន្លោះបន្ទប់ចោះកាតដែលមាននារីក្មេងៗ ជាអ្នកចោះដោយប្រើឧបករណ៍ទំនើបៗ និង ការិយាល័យរបស់លោក លៀស ចាន់ ថុន ។ ដូច្នេះហើយជាប់ជានិច្ច យើងត្រូវរំខានដោយសារការដើរឆ្លងកាត់មិនឈប់ឈររវាងលោកនាយ និង នារីក្មេងៗទាំងនោះ ។

ប៉ុន្មានខែក្រោយមក ខ្ញុំត្រូវបានបញ្ជូនឲ្យទៅរៀនវិជ្ជាផ្នែករៀបចំកម្មវិធី(Soft ware Programmer) ដែលរៀបចំដោយក្រុមហ៊ុន អាយ ប៊ី អិម (IBM) ប្រចាំកម្ពុជា ។ ខ្ញុំប្រឡងជាប់តេស្ត ចូលរៀនពេលល្ងាចខាងផ្នែកភាសារៀបចំកម្មវិធី (Program language) ហៅថា ហ្គាប់ "Gap" សំរាប់កុំព្យូទ័រ អាយ ប៊ី អិម ៣៦០/២០ (IBM 360/20) ។ បន្ទាប់ពីបានទទួលលទ្ធផលថា ខ្ញុំបានជាប់តេស្តភ្លាម សូរិយោស៊ី បានប្រាប់ខ្ញុំថាខ្លួនគាត់ជាអ្នកផ្តល់អនុសាសន៍ឲ្យក្រុមហ៊ុន អាយ ប៊ី អិម ទទួលយកខ្ញុំឲ្យទៅរៀន ។ នៅទីបញ្ចប់នៃការរៀនសូត្រនោះ ខ្ញុំក៏អាចចេះសរសេរកម្មវិធីផ្នែកគណនេយ្យបានខ្លះៗ ។ នៅថ្ងៃទី ២៩ មិថុនា ១៩៧៣ ខ្ញុំក៏ប្រឡងជាប់វិញ្ញាបនប្រ័តដែលផ្តល់ឲ្យដោយក្រុមហ៊ុន អាយ ប៊ី អិម នៃប្រទេសកម្ពុជានោះ ។ ទោះបីជាខ្ញុំបានមកបំរើការងារថ្មីក្នុងមុខវិជ្ជាជីវៈថ្មីក៏ដោយ ក៏ខ្ញុំនៅជាប់

ជំពាក់ក្នុងការសិក្សាផ្នែកគណនេយ្យរបស់ខ្ញុំជានិច្ច ។ ខ្ញុំនៅតែព្យាយាមធ្វើការរៀនសូត្រតាមរយៈសំបុត្រឆ្លើយឆ្លងជាមួយគ្រឹះស្ថានសិក្សារបស់បារាំងតទៅទៀត ។

ដើម្បីឆ្លើយតបទៅនឹងអតិផរណា និង សេចក្តីត្រូវការនៃសាច់ប្រាក់ដែលចេះតែកើនឡើងនៅក្នុងពេលសង្គ្រាមនោះ ក្រុមហ៊ុនកូមិន្ទខ្មែរបានទទួលការអនុញ្ញាតពីរដ្ឋាភិបាល ឲ្យចេញបណ្ណខ្ចីប្រាក់ដែលផ្តល់ការប្រាក់ខ្ពស់ ។ បន្ថែមលើនេះ ក្រុមហ៊ុនក៏មានរៀបចំពិធីចាប់ឆ្នោតជូនរង្វាន់ ដល់អ្នកដែលមានបណ្ណខ្ចីប្រាក់របស់ក្រុមហ៊ុននោះ ។ កិច្ចប្រតិបត្តិការបែបនេះ មានប្រជាប្រិយខ្លាំងណាស់ និង បានទទួលជោគជ័យយ៉ាងខ្លាំងដោយសារប្រជាពលរដ្ឋ ដែលជាអ្នកមានប្រាក់កាសបបួលគ្នាមកទិញបណ្ណខ្ចីប្រាក់មិនឈប់ឈរ ។ ក្រុមហ៊ុនក៏បានប្រែក្លាយទៅជាទីផ្សារហិរញ្ញវត្ថុដែលពួកអ្នកមាន ឬ អ្នកមានល្មមៗអាចយកប្រាក់មកវិនិយោគបាន ។ យ៉ាងនេះហើយ ទើបនៅជាន់ខាងក្រោមនៃការិយាល័យរបស់យើងមានពោរពេញទៅដោយអតិថិជន ដែលយកប្រាក់មកឲ្យក្រុមហ៊ុនខ្ចី ឬ ចូលមកស្តាប់លទ្ធផលនៃការចាប់ឆ្នោតយករង្វាន់ ។ ថ្នាក់ដឹកនាំក្រុមហ៊ុន មានភាពវៃឆ្លាតក្នុងការដោះស្រាយបញ្ហាហិរញ្ញវត្ថុ ដែលគ្មាននរណាជៀសរួចនៅក្នុងសង្គ្រាម ក៏ប៉ុន្តែពួកគេត្រូវទទួលបរាជ័យក្នុងការដោះស្រាយបញ្ហាផ្នែកសង្គម ។

កូដកម្មដោយឥតប្រាប់មុន

ថ្ងៃមួយនៅពេលដែលខ្ញុំកំពុងតែវល់យ៉ាងខ្លាំងក្នុងការងារ មានសហការីម្នាក់រត់មកប្រាប់យ៉ាងត្រហេបត្រហបថាទ្វារចេញចូលទាំងអស់ និង របងរបស់ក្រុមហ៊ុន ត្រូវក្រុមពួកសហជីពពលករបញ្ឈប់ឲ្យចាក់សោរ ព្រោះពួកគេនាំគ្នាធ្វើកូដកម្ម ។ ខ្ញុំមានការងឿងឆ្ងល់យ៉ាងខ្លាំង ព្រោះខ្ញុំមិនដែលដឹង ពុំដែលឮថាមានសហជីពណាមួយនៅក្នុងក្រុមហ៊ុននោះទេ ។ ម្យ៉ាងទៀត ពួកយើងក៏ពុំដែលបានទទួលការ

ណែនាំ ឬ ការផ្តល់ដំណឹងជាមុនៗនឹងមានកូដកម្មនោះទេ ។ តាមពិត នៅពេលមុននោះ រដ្ឋាភិបាលបានអនុញ្ញាតឲ្យមានការបង្កើតសហជីពពលករ ដែលដឹកនាំដោយទីប្រឹក្សាមួយរូបរបស់លោកប្រធានាធិបតី លន់ នល់ ដែលជាបញ្ញវន្តមួយរូបមកពីសហរដ្ឋអាមេរិក ក្នុងគោលដៅនយោបាយអ្វីមួយ ។ នៅពេលនោះរបប លន់ នល់ កំពុងជួបប្រទះនូវការបែកបាក់គ្នាយ៉ាងធ្ងន់ធ្ងរ ។ សូមបញ្ជាក់ថាបន្ទាប់ពីមានការកែប្រែរបបរាជានិយម មកជារបបសាធារណរដ្ឋវិញនោះ លោក លន់ នល់ បានប្រកាសខ្លួនឯងជាប្រធានាធិបតីនៃសាធារណរដ្ឋនៅឆ្នាំ ១៩៧២ ។ បន្ទាប់មកគាត់បានរៀបចំឲ្យមានការបោះឆ្នោតជ្រើសរើសប្រធានាធិបតី ដែលគាត់បានទទួលជ័យជំនះ ។ កូដកម្មបានបញ្ឈប់ការងាររបស់យើងទាំងអស់នៅក្នុងក្រុមហ៊ុន ។ ពួកយើងជួបជុំគ្នានៅក្នុងការិយាល័យរៀងៗខ្លួន នៅគ្រាដែលថ្នាក់ដឹកនាំក្រុមហ៊ុនជាប់រវល់និយាយទូរសព្ទ័ទាក់ទងមន្ត្រីរដ្ឋាភិបាលនានា ។ លោកប្រធានបុគ្គលិករបស់ក្រុមហ៊ុនបានប្រឹងប្រែងតាមលទ្ធភាពរបស់គាត់ ដើម្បីព្យាយាមចរចារកផ្លូវដោះស្រាយជាមួយពួកសហជីព ដែលជាកូដករទាំងនោះ តែពុំបានជោគជ័យ ។ ខ្ញុំព្យាយាមទូរសព្ទ័ទៅបងប្រុសខ្ញុំគឺ បងស៊ីនឿន នៅឯធនាគារជាតិកម្ពុជា តែក៏ពុំបានទទួលជោគជ័យដែរ ។ ដូច្នេះ ពួកក្រុមគ្រួសាររបស់យើង ក៏គ្មាននរណាដឹងដែរថាចាប់តាំងពីម៉ោងបីរសៀលរហូតមក ពួកយើងត្រូវជាប់នៅក្នុងអាគាររបស់ក្រុមហ៊ុនមិនអាចចេញទៅណារួចបានឡើយ ។ ម្យ៉ាងទៀត នៅផ្ទះយើង ក៏យើងគ្មានទូរស័ព្ទប្រើដែរ ។ នៅពេលនោះ ក៏គ្មានអ្នកកាសែត ឬ អ្នកទូរទស្សន៍មកធ្វើការផ្សព្វផ្សាយភ្លាមៗនោះទេ ។ ដូច្នេះនៅពេលយប់ ទើបក្រុមគ្រួសាររបស់យើងចាប់ផ្តើមបារម្ភពីព្រឹត្តិការណ៍អ្វីមួយ ដែលជាឧបសគ្គមិនអាចឲ្យខ្ញុំត្រឡប់ទៅផ្ទះវិញបានដូចធម្មតា ។ ដោយខ្លាចខ្ញុំមានគ្រោះថ្នាក់ ដែលប៉ះពាល់ដល់សុវត្ថិភាពខ្ញុំនោះ ទើបបងប្រុសធំបង្អស់របស់ខ្ញុំគឺ បងឈឿន (ឬ បងនាង) និងប្រពន្ធរបស់គាត់នាំគ្នាជិះម៉ូតូយ៉ាង

ប្រញាប់ប្រញាល់ទាំងពីរនាក់ មករកខ្ញុំទាំងយប់នៅឯស្នាក់ការក្រុមហ៊ុន ។ នៅពេលនោះទើបពួកគាត់ដឹងថាពួកយើងត្រូវជាប់នៅក្នុងអាគារមិនអាចចេញទៅណារួច ។ ប៉ុន្តែជាសំណាងល្អ ប៉ុន្មាននាទីក្រោយមក ក្រុមសហជីពពលកររនោះ ក៏បានទទួលបញ្ជាពីថ្នាក់ដឹកនាំរបស់ពួកគេឲ្យបញ្ឈប់កូដកម្ម និង បើកទ្វាររបងអាគារក្រុមហ៊ុនឡើងវិញ ។ យើងត្រឡប់ទៅផ្ទះវិញនៅវេលាម៉ោង ១០ យប់ ហើយកូដកម្មនោះក៏ចប់សព្វគ្រប់តែត្រឹមនោះទៅ ។

ខ្ញុំពុំបានយល់អំពីហេតុផល ដែលនាំឲ្យក្រុមសហជីពពលករបញ្ឈប់កូដកម្មនោះទេ ។ ក៏ប៉ុន្តែ ព្រឹត្តិការណ៍ដ៏ចៃដន្យនេះបានធ្វើឲ្យខ្ញុំនឹកគិតរកវិធីចាកចេញពីប្រទេសកម្ពុជាជាថ្មីឡើងវិញ ។ ពួកយើងចាប់ផ្តើមជជែកគ្នាយ៉ាងហ្មត់ចត់អំពីគំរោងការរបស់ខ្ញុំ ក្នុងការចេញដំណើរទៅប្រទេសបារាំង ។ ក្រុមគ្រួសារយើងទាំងមូល បានយល់ស្របតាមបំណងរបស់ខ្ញុំ ។

ទីបំផុតខ្ញុំសម្រេចចេញទៅស្រុកបារាំង

យុវនិស្សិត និង មន្ត្រីមួយចំនួនបានទទួលអាហារូបករណ៍ ពីប្រទេសដទៃឲ្យទៅបន្តការសិក្សា ឬ ធ្វើការហ្វឹកហាត់មុខវិជ្ជាជំនាញនានានៅឯបរទេស ។ ខ្ញុំបានសំរេចចិត្តថា ខ្ញុំនឹងចេញដំណើរទៅប្រទេសបារាំងដោយខ្លួនឯង ។ ខ្ញុំបានសន្សំប្រាក់មួយចំនួនល្មមអាចទិញសំបុត្រយន្តហោះបាន ។ ដើម្បីត្រៀមការរស់នៅរបស់ខ្ញុំឯប្រទេសបារាំង ខ្ញុំបានសរសេរសំបុត្រទៅសមាគម អេស សេ អេហ្វ (S C F) ក្នុងហាន:ខ្ញុំជាសមាជិកសកម្មរបស់សមាគម ដើម្បីស្នើសមាគមឲ្យជួយរកការងារធ្វើនៅប្រទេសបារាំងនោះ ។ សមាគម អេស សេ អេហ្វ បានផ្តល់ដំបូន្មានឲ្យខ្ញុំថាខ្ញុំត្រូវទៅសុំការងារខ្លួនឯងផ្ទាល់នៅឯប្រទេសបារាំង ព្រោះថានិយោជកត្រូវការធ្វើ

សំភាសន៍ ជាមុនសិន មុននឹងរើសយើងឲ្យចូលធ្វើការ ។ គេមិនអាចធ្វើសំភាសន៍បានទេ ប្រសិនបើយើងមិននៅក្នុងប្រទេសបារាំង ។

ដើម្បីទទួលការអនុញ្ញាតឲ្យទៅសិក្សានៅប្រទេសបារាំងដោយខ្លួនឯង ខ្ញុំត្រូវទៅសុំការអនុញ្ញាតពីក្រសួងអប់រំ ដើម្បីបញ្ជាក់ថាតើក្នុងការសិក្សានៅឯបរទេសរបស់ខ្ញុំនោះមានភាពត្រឹមត្រូវដែរឬទេ? និង ថាតើខ្ញុំមានសមត្ថភាពអាចទ្រទ្រង់ចំណាយនានារបស់ខ្ញុំក្នុងការសិក្សានោះឬទេ? ដោយសារបងប្រុសខ្ញុំគឺ បង ស៊ីនឿន មានទំនាក់ទំនងល្អជាមួយក្រសួង ខ្ញុំក៏បានទទួលការអនុញ្ញាតដោយពុំមានបញ្ហាអ្វីធំដុំឡើយ ។ សូមបញ្ជាក់ថា នៅសម័យនោះ ជនជាតិខ្មែរណា ដែលមានបំណងចេញទៅក្រៅប្រទេស ត្រូវមានទិដ្ឋាការអនុញ្ញាតឲ្យចេញទៅក្រៅប្រទេស ពីក្រសួងមហាផ្ទៃជាមុនសិន ទើបស្ថានទូតនានាអាចផ្តល់ទិដ្ឋាការចូលទៅក្នុងប្រទេសរបស់គេនីមួយៗ ។

ខ្ញុំមិនទាន់មានលិខិតឆ្លងដែន និង គ្មានអត្តសញ្ញាណប័ណ្ណប្រចាំខ្លួននៅឡើយទេ ។ ដូច្នេះ ខ្ញុំត្រូវធ្វើឯកសារទាំងនេះនៅក្រសួងសន្តិសុខជាតិ ។ នៅសម័យនោះ ក្រុមប៉ូលីស និង អន្តោប្រវេសន៍ជាផ្នែកដែលមានរបៀបរបបការងារផ្នែកការិយាល័យដ៏សន្ធឹកសន្ធាប់ និង ជាផ្នែកដែលមានអំពើពុករលួយយ៉ាងធ្ងន់ធ្ងរ ។ ក៏ប៉ុន្តែដោយសារ បងស៊ីនឿន មានមិត្តភ័ក្រម្នាក់ជាអធិការប៉ូលីស ខ្ញុំក៏ពុំសូវពិបាកក្នុងការរត់ការនោះឡើយ ។ ខ្ញុំនៅចាំបានថានៅពេលទៅយកលិខិតឆ្លងដែន និងទិដ្ឋាការចេញក្រៅប្រទេសនោះ ខ្ញុំត្រូវកាន់ឯកសារទៅសុំចុះហត្ថលេខាពីមន្ត្រី ក្នុងប្រមាណម្តៃការិយាល័យ ទំរាំបានចប់សព្វគ្រប់ ។ តាមធម្មតា ពលរដ្ឋខ្មែរសាមញ្ញត្រូវចំណាយប្រាក់យ៉ាងច្រើន មុននឹងទទួលឯកសារគ្រប់គ្រាន់ក្នុងការធ្វើដំណើរចេញទៅក្រៅប្រទេស ។ ដោយសារខ្ញុំមានឯកសារគ្រប់គ្រាន់ ខ្ញុំក៏បានទទួលទិដ្ឋាការពីស្ថានទូតបារាំងសំរាប់ការធ្វើដំណើររបស់ខ្ញុំ ។

រៀបការបងប្រុសទី២

មុនពេលចេញដំណើរទៅប្រទេសបារាំងនោះ មានព្រឹត្តិការណ៍ដ៏សំខាន់មួយទៀតបានកើតឡើងនៅក្នុងគ្រួសាររបស់យើង ។ ក្រុមគ្រួសាររបស់យើងនឹងរៀបចំពិធីមង្គលការឲ្យបងប្រុសទី២របស់ខ្ញុំគឺ បងស៊ីនឿន ។ ករណីបងស៊ីនឿនមិនដូចបងទីមួយរបស់ខ្ញុំទេ ព្រោះបងស៊ីនឿន មិនបានស្គាល់អនាគតភរិយារបស់គាត់សោះឡើយ ។ កាលនោះ ម្តាយមីងរបស់ខ្ញុំគឺ អ្នកមីងសាម៉ឺឌី បានផ្តល់គំនិតក្រោយពីបានសង្កេតយ៉ាងហ្មត់ចត់លើគ្រួសារមួយដែលនៅជិតខាង ហើយដែលមានទំនាក់ទំនងល្អជាមួយគ្នា ។ គ្រួសារនោះគឺ ជាគ្រួសាររបស់ចៅហ្វាយស្រុកម្នាក់ដែលមានឋានន្តរសក្តិរហូតដល់ថ្នាក់ឧត្តមមន្ត្រី ។ លោកចៅហ្វាយស្រុកជាមនុស្សមិនសូវមាត់ក តែរាក់ទាក់ និង មានសន្តានចិត្តល្អ ។ ប្រពន្ធរបស់គាត់ជាស្ត្រីមានប្រាជ្ញាហើយមានប្រភពចេញពីត្រកូលជាន់ខ្ពស់ ដែលមានឪពុកជាវេជ្ជបណ្ឌិតដ៏ល្បីល្បាញ ។ លោកស្រីប្រពន្ធចៅហ្វាយស្រុក ជាប្អូនបង្កើតរបស់លោក ហួត សម្បត្តិ ដែលធ្លាប់កាន់តំណែងច្រើនដងជារដ្ឋមន្ត្រី នៅក្នុងសម័យសង្គមរាស្ត្រនិយម ។ នៅពេលដែលមានរដ្ឋប្រហារខែ មីនា ១៩៧០ នោះ លោក ហួត សម្បត្តិ កំពុងកាន់តំណែងជាឯកអគ្គរាជទូតព្រះរាជាណាក្រកម្ពុជា ប្រចាំនៅអង្គការសហប្រជាជាតិ ។ នៅពេល បងស៊ីនឿន រៀបការនោះ លោក ហួត សម្បត្តិ កំពុងស្ថិតនៅទីក្រុងប៉េកាំង នៃប្រទេសចិន បំរើការងារជារដ្ឋមន្ត្រី នៃរដ្ឋាភិបាលនិរទេសរបស់សម្តេចសីហនុ ។ តែទោះបីជាមានបញ្ហាផ្នែកនយោបាយយ៉ាងនេះក៏ដោយ ក៏គ្រួសារលោកចៅហ្វាយស្រុកមានទំនាក់ទំនងល្អជាមួយលោក លន់ នល់ ដែរ ។ លោកចៅហ្វាយស្រុកមានកូនក្រមុំដ៏ស្រស់ស្អាតម្នាក់ឈ្មោះ ទេពធីតា ដែលកំពុងសិក្សានៅ សាលាប៊ីទីលីសេ (Petit Lycée) ជាប់នឹងវិទ្យាល័យដេកាត ។ ម្តាយមីងខ្ញុំ និង

លោកស្រីប្រពន្ធចៅហ្វាយស្រុកយល់ស្របគ្នាថា បងស៊ីនឿន គួរតែរៀបការជាមួយនឹងទេពធីតា ។ ម្តាយមីងខ្ញុំ បាននាំពាក្យទៅជំរាបម្តាយខ្ញុំ ម្តាយខ្ញុំក៏ជំរាបទៅឪពុកខ្ញុំ ទីបំផុតទាំងអស់គ្នាព្រមព្រៀងលើការជ្រើសរើសនេះ លើកលែងតែសាមីខ្លួនទាំងពីរដែលនៅមិនទាន់ស្គាល់គ្នានៅឡើយ ។ ដូច្នេះ មុននឹងសំរេចទៅស្តីដណ្តឹងទេពធីតា បងស៊ីនឿន និង បងនាងបានសាកល្បងលបទៅលួចមើលនាង ទេពធីតាជាមុនសិន ។

បងទាំងពីរនាក់នាំគ្នាជិះរថយន្តទៅលបមើលនាង ទេពធីតា ពីក្នុងឡាននៅឯប៊ីទីលីសេ ។ បងស៊ីនឿន ទើបតែទិញរថយន្តចំណាស់មួយម៉ាកម៉ូស្គូវីត (Moscovit) ។ ចំពោះបង ស៊ីនឿន គ្រាន់តែឃើញក្លាមក៏ចាប់ចិត្តស្រឡាញ់ភ្លែត ។ បងខ្ញុំទាំងពីរលបទៅមើល ទេពធីតា អស់រយៈពេលប្រហែលមួយសប្តាហ៍ ។ នៅទីបំផុតទាំងអស់គ្នាក៏សំរេចចិត្តរៀបមង្គលការមួយខែក្រោយមក ។ ចំពោះក្រុមគ្រួសារយើង ពិធីមង្គលការនេះជាពិធីដ៏ធំដុំមួយចុងក្រោយបង្អស់ មុននឹងអ្វីៗទាំងអស់ត្រូវវិនាសបាត់បង់ដោយសារសង្គ្រាម ។

ខ្ញុំសង្កេតឃើញ នៅក្នុងពិធីជប់លៀងមានមន្ត្រីធំៗជាច្រើនបានចូលរួម ។ ពិធីជប់លៀងដ៏ធំនោះ បានរៀបចំឡើងនៅភោជនីយដ្ឋានដ៏ល្បីល្បាញមួយឈ្មោះ ព្រះច័ន្ទពេញវង់ (La Lune) ។ បងស៊ីនឿន និង គ្រួសាររបស់ភរិយាគាត់មានការរាប់អានពីមន្ត្រីជាន់ខ្ពស់ជាច្រើន ដោយហេតុថា បងប្រុសខ្ញុំបានចូលរួមយ៉ាងសកម្មក្នុងគណបក្សប្រជាធិបតេយ្យ ។ គាត់ជាសមាជិកគណៈកម្មាធិការមួយរូបនៃគណបក្សនេះ ដែលជាគណបក្សប្រឆាំងយ៉ាងចេញមុខនឹងរបប លន់ នល់ ។ បងស៊ីនឿនត្រូវរាប់បញ្ចូលជាថ្នាក់ដឹកនាំយុវវ័យនៃគណបក្សប្រជាធិបតេយ្យ ។ ប្រសិនបើគណបក្សប្រជាធិបតេយ្យសម័យនោះត្រូវឡើងកាន់អំណាច បងប្រុសខ្ញុំប្រហែលជានឹងត្រូវបានតែងតាំង ក្នុងតំណែងរដ្ឋមន្ត្រីក្រសួងណាមួយមិនខានឡើយ ។

បន្ទាប់ពីពិធីមង្គលការបានចប់សព្វគ្រប់ហើយ បងស៊ីនឿន បានរើអីវ៉ាន់ ដែលមានតែខោអាវបន្តិចបន្តួចទៅរស់នៅជាមួយ ឪពុក ម្តាយក្មេករបស់គាត់ ។

ថ្ងៃចុងក្រោយនៅកម្ពុជា

ខ្ញុំបន្តធ្វើការនៅកូមិន្នខ្មែរ រហូតដល់ថ្ងៃខ្ញុំឈប់ពីការងារមួយថ្ងៃមុនពេលខ្ញុំចេញទៅប្រទេសបារាំង ។ ម្តាយខ្ញុំបានត្រៀមសាច់គោ និង សាច់ជ្រូកងៀត ដោយបារម្ភខ្លាចខ្ញុំពុំមានអ្វីបរិភោគនៅឯប្រទេសឆ្ងាយ ។ ឪពុកខ្ញុំ ត្រួតពិនិត្យយ៉ាងល្អិតល្អន់នូវសំលៀកបំពាក់ក្នុងវ៉ាលី ហើយផ្តាំថាកុំភ្លេចយកអង្ករទៅជាមួយ ។ ថ្ងៃដែលខ្ញុំត្រូវចេញដំណើរគឺ នៅថ្ងៃទី ៥ សីហា ១៩៧៣ ។ ឪពុកខ្ញុំ ហៅខ្ញុំមកជិត ដោយមានធូបបីសរសៃកាន់នៅជាប់នឹងដៃ ។ ខ្ញុំក្រាបថ្វាយបង្គំឪពុកម្តាយខ្ញុំបីដង ដើម្បីទទួលនូវពរជ័យតាមប្រពៃណីខ្មែរ ។ បងស៊ីនឿន ជាអ្នកចាត់ចែងខាងផ្នែកសំបុត្រយន្តហោះ និង កិច្ចការផ្នែករដ្ឋបាលដូចជាទិដ្ឋាការ និង លិខិតឆ្លងដែនជាដើម ។ បងនាង បងទីមួយរបស់ខ្ញុំ ត្រៀមទឹកក្តៅស្រោចឲ្យខ្ញុំងូត ដើម្បីឲ្យបានស្រួលខ្លួន មុននឹងធ្វើដំណើរទៅឆ្ងាយ ។ ក៏ប៉ុន្តែ មុននឹងយើងចេញដំណើរចេញពីផ្ទះនោះ យើងបានទទួលដំណឹងថាជើងយន្តហោះរបស់យើងត្រូវពន្យារទៅថ្ងៃទី ៦ សីហា ១៩៧៣ វិញ ។ នៅថ្ងៃចុងក្រោយនេះ ខ្ញុំក៏ក្រាបថ្វាយបង្គំឪពុកម្តាយខ្ញុំបីដងដូចមុនទៀត និង ជំរាបលាលោកទាំងពីរទាំងក្តីអាល័យ ។ នោះជាឱកាសចុងក្រោយ ដែលខ្ញុំបានសំដែងនូវការគោរពចំពោះឪពុកដ៏ជាទីស្រឡាញ់របស់ខ្ញុំ ។ បងនាង ត្រៀមទឹកក្តៅឲ្យខ្ញុំងូតជាថ្មីម្តងទៀតនោះគឺ ជាការស្រឡាញ់ចុងក្រោយរបស់គាត់ចំពោះខ្ញុំ ។

នៅឯចំណតអាកាសយានដ្ឋានពោធិចិនតុង មានមនុស្សម្នាច្រើនណែនណាន់ មានទាំងវត្តមានអ្នកធ្វើដំណើរ និង ទាំងអ្នកជូនដំណើរផង ។ អ្នកខ្លះយំលា

ឪពុកម្តាយ ញាតិមិត្ត ឬ កូនចៅដែលបែកចេញទៅ ។ ឪពុកម្តាយខ្ញុំ បងប្អូនខ្ញុំលើក លែងតែស៊ីថានចេញ សុទ្ធតែបានមកជូនដំណើរខ្ញុំនៅព្រលានយន្តហោះពោធិចិន តុងទាំងអស់ ។

ដូច្នេះ នៅពេលដែលខ្ញុំមានអាយុ ២៣ ឆ្នាំ ខ្ញុំក៏បែកចេញពីប្រទេសកម្ពុជា ដោយមានប្រាក់កាសបន្តិចបន្តួចគឺ ប្រមាណ ៣០០ ដុល្លារ និង អង្ករ ១៥ គីឡូ ក្រាម សាច់ងៀត ព្រមទាំងសំលៀកបំពាក់ខ្លះៗតែប៉ុណ្ណោះ ។ នៅពេលដែលខ្ញុំចូល ទៅក្នុងយន្តហោះ ខ្ញុំក៏លែងឃើញមុខឪពុក បង ប្អូនខ្ញុំទាំងបួននាក់គឺ បងឈឿន បងស៊ីនឿន ប្អូនប្រុសណារ៉ែន វុធធៀន តទៅទៀតជារៀងរហូត ។ នៅពេលនោះ ខ្ញុំមិនបាននឹកថាដំណើររបស់ខ្ញុំនេះមានរយៈពេលជាងម្តែផ្នាំឯណោះ ទើបខ្ញុំអាច វិលមកមាតុប្រទេសរបស់ខ្ញុំវិញ ។ ខ្ញុំមិនដែលនឹកឃើញថា ប្រទេសកម្ពុជាក្លាយទៅ ជាទីកន្លែងនៃមហាសោកនាដកម្មដ៏ធំធេងមួយ ដែលបានបំផ្លាញជីវិតជនស្លូតត្រង់ រាប់លាននាក់យ៉ាងនេះសោះ ។ ខ្ញុំមិនដែលនឹកថាបដិវត្តន៍នៃប្រទេសកម្ពុជាបាន បំផ្លិចបំផ្លាញសង្គមជាតិយើងឲ្យរលត់រលាយយ៉ាងដូច្នេះឡើយ ។

យុវវ័យរបស់ខ្ញុំ បានស្ថិតនៅក្រោមការគាបសង្កត់នៃវាសនារបស់ប្រទេស ជាតិ ក្នុងយុគសម័យមួយ ដែលមិនអាចប្រមើលអនាគតបាន ។ ក៏ប៉ុន្តែ ឆាក ដំបូងនៃជីវិតនេះ ក៏បានឆ្លុះបង្ហាញនូវការប្តេជ្ញាចិត្តឆ្ពោះទៅមុខជានិច្ចរបស់ខ្ញុំដែរ ។ សេចក្តីស្នេហា ឬ ព្រហ្មវិហារធម៌របស់ឪពុកម្តាយខ្ញុំមកលើរូបខ្ញុំ និង ការជួយ ទំនុកបំរុងរបស់ក្រុមគ្រួសារបងប្អូនញាតិមិត្តខ្ញុំ បានក្លាយជាប្រភពថាមពលដើម្បីឲ្យ ខ្ញុំអាចពុះពារគ្រប់ឧបសគ្គ និង អាចឆ្លងកាត់នូវរាល់ការលំបាកទាំងឡាយ ។ ខ្ញុំពុំ អាចបំភ្លេចបានឡើយនូវបទពិសោធន៍ដ៏មានតម្លៃ ក្នុងវគ្គដំបូងនៃជីវិតនេះ ។

វគ្គទី ៣
ប្រទេសកម្ពុជាក្នុងភ្លើងសង្គ្រាម
(ទសវត្សរ៍ឆ្នាំ ១៩៧០)

កាលនោះនៅខែ មីនា ១៩៧០ នៅពេលដែលប្រជាជាតិខ្មែរទាំងមូលកំពុងរៀបចំជារៀងរាល់ថ្ងៃនូវពិធីគោរពព្រះវិញ្ញាណក្ខន្ធនៃសម្តេចព្រះសង្ឃរាជ ជួន ណាត ។ នៅពេលនោះហើយដែលប្រវត្តិសាស្ត្រនៃប្រជាជាតិកម្ពុជាយើងបានប្រែទំព័រថ្មីពីទំព័រសន្តិភាព និង ស្ថិរភាពធ្លាក់ទៅក្នុងទសវត្សរ៍ដ៏ខ្មៅងងឹតដែលប្រជារាស្ត្ររងទុក្ខវេទនាឥតឈប់ឈរ ដោយសារសង្គ្រាមបំផ្លិចបំផ្លាញដ៏ព្រៃផ្សៃ និង ដោយសាររបបប្រល័យពូជសាសន៍ ។ នោះគឺជាសម័យកាលដែលជាតិខ្មែរត្រូវហូរឈាម និង រងទឹកភ្នែកឥតល្ហែល្ហើយ ។ ពាក្យចាស់និយាយថា "អ្នកធំស្លាប់ផែនដីរង្គើរ" ។ ពាក្យចាស់នេះ ប្រហែលជាលេចចេញនៅជំនាន់ដើម នៅពេលព្រះមហាក្សត្រសុគតម្តងៗ តែងមានការដណ្តើមរាជ្យគ្នា ។ ពួកយើងធ្លាប់រៀនតាមសៀវភៅប្រវត្តិសាស្ត្រតាំងពីក្មេងៗមកថា ប្រទេសខ្មែរយើងពុំសូវមានការផ្ទេរអំណាច ឬ ការផ្ទេររាជសម្បត្តិ ពីព្រះមហាក្សត្រមួយអង្គទៅមួយអង្គទៀតដោយសន្តិវិធីទេគឺ ជាញឹកញាប់ការផ្លាស់ប្តូរនោះច្រើនធ្វើឡើងតាមការធ្វើចំបាំងរាំងដល់ ។ ទោះបីជាសម្តេចព្រះសង្ឃរាជ ជួន ណាត ពុំមែនជាព្រះមហាក្សត្រសោយរាជ្យក៏ដោយ ក៏ការយាងចូលទិវង្គតរបស់ព្រះអង្គ អាចរាប់ថាជាប្រផ្នូលអាក្រក់មួយរបស់ប្រជាប្រជាជាតិយើងដែរ ។

តាមពិត សម្តេចព្រះសង្ឃរាជ ជួន ណាត ជាឥស្សរជនដ៏ខ្ពង់ខ្ពស់មួយរូបដែលប្រជាជាតិខ្មែរសំដែងនូវការគោរពចំពោះព្រះអង្គ មិនមែនត្រឹមតែជាស្តេចសង្ឃ

ធម្មតានោះទេ តែព្រះអង្គគឺ ជាអ្នកប្រាជ្ញខ្មែរមួយរូប ដែលបានធ្វើពលិកម្មព្រះជន្ម ទាំងស្រុង ដើម្បីលើកតម្កើងអក្សរសាស្ត្រ និង វប្បធម៌ខ្មែរ ។ សម្តេចព្រះសង្ឃរាជ អង្គនេះ ទ្រង់បាននិពន្ធសៀវភៅវចនានុក្រមខ្មែរ និង សៀវភៅមួយចំនួនទៀត សំរាប់ការសិក្សារបស់ព្រះសង្ឃ និង ពុទ្ធបរិស័ទទាំងឡាយ ។ សម្តេច ជួន ណាត ចេះភាសាបារាំង អង់គ្លេស ថៃ ឡាវ ភូមា វៀតណាម និង ចិនខ្លះៗ ។ សម្តេច បង្រៀនភាសាបាលី និង សំស្ក្រឹត ព្រមទាំងផ្តល់បទសំភាសន៍ផ្នែកអក្សរសាស្ត្ររៀង រាល់សប្តាហ៍ តាមវិទ្យុជាតិ ។ កម្មវិធីសំភាសន៍អក្សរសាស្ត្រនេះ មានប្រជាប្រិយភាព ខ្លាំងណាស់ ហើយខ្ញុំក៏តែងតែត្រងត្រាប់ស្តាប់ពុំដែលខានឡើយ។ សម្តេចព្រះសង្ឃ រាជមានសិស្សានុសិស្សរបស់លោកជាច្រើន ដែលជាមន្ត្រីរាជការ ដែលមានអ្នកខ្លះ បានក្លាយទៅជារដ្ឋមន្ត្រី ឬ មន្ត្រីជាន់ខ្ពស់ក្នុងជួររាជរដ្ឋាភិបាលផង ។ តាមក្បួនពិធី ការនៃព្រះបរមរាជវាំង សម្តេចព្រះសង្ឃរាជមានឋានៈស្មើនឹងស្តេចផែនដីមួយអង្គ ដែរ ដែលគេត្រូវប្រើពាក្យរាជសព្ទដើម្បីថ្លែងទៅកាន់ព្រះអង្គ ។

សូមបញ្ជាក់ថា បើប្រៀបធៀបទៅភាសាបរទេស ភាសាខ្មែរយើងមានភាព សម្បូណ៌បែបសម្បើមណាស់ ព្រោះខ្មែរយើងមានពាក្យជាច្រើន ដែលមានន័យដូច គ្នា សំរាប់យកទៅប្រើឲ្យសមតាមឋានៈសង្គម ពោលគឺខ្មែរយើងមានពាក្យសំរាប់ប្រើ ជាមួយស្តេច ជាមួយមន្ត្រី ជាមួយរាស្ត្រ ជាមួយព្រះសង្ឃ ជាមួយគ្រហស្ថ ជាមួយ មនុស្សចាស់ និង ជាមួយកូនក្មេងជាដើម ។ គ្រាន់តែពាក្យស៊ី មានមិនតិចជាងដប់ ពាក្យទេ ។

សម្តេចព្រះសង្ឃរាជ ជួន ណាត បានសុគតតាំងពីខែ កញ្ញា ១៩៦៩ មក ម្ល៉េះ ដូច្នេះបើតាមពិធីការ ព្រះបរមសពរបស់ព្រះអង្គ ត្រូវតំកល់ទុកយ៉ាងហោច ណាស់ក្នុងរវាងប្រាំមួយខែ ទើបគេប្រារព្ធព្រះរាជពិធីថ្វាយព្រះភ្លើង ដែលអាច នឹងត្រូវកំណត់នៅខែ មីនា ១៩៧០ ។ ធ្វើយ៉ាងនេះ ដើម្បីទុកឱកាសឲ្យ

ប្រជានុរាស្ត្រ ពុទ្ធបរិស័ទមានឱកាសថ្វាយបង្គំព្រះបរមសព ដែលកំពុងតំកល់ទុកនៅវត្តឧណ្ណាលោម ក្រុងភ្នំពេញ ។ ក្នុងរយៈពេលនៃការតំកល់ទុកនេះរហូតដល់ថ្ងៃថ្វាយព្រះភ្លើង គេមានរៀបចំពិធី តាមប្រពៃណីព្រះពុទ្ធសាសនាជាប់រហូតទាំងថ្ងៃទាំងយប់ ។ គណៈប្រតិភូខេត្ត ក្រុង បន្តគ្នាពីទីឆ្ងាយជិត លើកគ្នាមកថ្វាយបង្គំព្រះបរមសព ។ ដើម្បីជាកិត្តិយសថ្វាយសម្តេចព្រះសង្ឃរាជ មន្ត្រី ប៉ូលីស ទាហាន និង ក្រុមយុវនៃ ក្នុងសំលៀកបំពាក់ឯកសណ្ឋាន បានត្រូវចាត់ឲ្យទៅឈរយាម ឬ ធ្វើជារបងកិត្តិយសសំរាប់ទទួលភ្ញៀវជាន់ខ្ពស់ ឬ គណៈប្រតិភូទាំងនោះ ។

ព្រឹត្តិការណ៍ ១៨ មីនា ១៩៧០

អស់រយៈពេលជាច្រើនខែមកហើយ ដែលខ្ញុំត្រូវបានចាត់តាំងឲ្យមកឈរយាមនៅមាត់ទ្វារព្រះមហាកុដិក្នុងសំលៀកបំពាក់យុវនៃ ។ ជារៀងរាល់ថ្ងៃ នៅពេលទៅដល់ ខ្ញុំតែងតែឈរឥតកំរើកនៅនឹងមួយកន្លែង ចាប់ពីម៉ោងបីល្ងាចរហូតដល់ម៉ោងប្រាំបីយប់ ។ កាលសម័យនោះ ខ្ញុំនៅធ្វើការក្នុងក្រុមហ៊ុនរដ្ឋសុរាគារខ្មែរ ។ ខ្ញុំ និង មន្ត្រីថ្នាក់ទាបមួយចំនួន ត្រូវចាត់ឲ្យឈរយាមនៅមហាកុដិនៃសម្តេចព្រះសង្ឃរាជ ។ ពេលនោះ ខ្ញុំពុំបានដឹងថា ពិធីរៀបចំថ្វាយព្រះភ្លើងនឹងត្រូវប្រព្រឹត្តទៅនៅពេលណានោះទេ ខ្ញុំគ្រាន់តែនឹកស្រមៃថា នៅពេលនោះគេនឹងមានប្រារព្ធពិធីដ៏ធំអធិកអធម ដើម្បីឲ្យសមនឹងព្រះហានៈសម្តេចព្រះសង្ឃរាជ ។ ក៏ប៉ុន្តែ នៅពេលនោះ ប្រជាជាតិយើងកំពុងតែរង់ចាំព្រះរាជដំណើរយាងត្រឡប់មកវិញនៃព្រះប្រមុខរដ្ឋ សម្តេច សីហនុ ដែលទ្រង់បានយាងទៅព្យាបាលព្រះរោគ នៅឯទីក្រុងប៉ារីស ប្រទេសបារាំងអស់រយៈពេលជាច្រើនខែមកហើយ ។ តាមពាក្យចចាមអារាមពីមាត់មួយទៅមាត់មួយថា សម្តេចនឹងទ្រង់យាងមកវិញនៅពាក់កណ្តាលខែ មីនា នេះ ។

នៅក្នុងរយៈពេលអវត្តមានសម្តេចព្រះប្រមុខរដ្ឋ ស្ថានភាពនយោបាយរបស់ប្រទេសយើង ក៏កាន់តែធ្លាក់ចុះដុនដាបទៅជាលំដាប់ ។ ជាច្រើនសប្តាហ៍ និង ជាច្រើនខែមកហើយ សារព័ត៌មានក្នុងស្រុក ដែលជាទម្លាប់សុទ្ធតែមានស្វាមីភក្តិចំពោះសម្តេចបានផ្សព្វផ្សាយព័ត៌មានដ៏អាស្រូវជាច្រើន ទាក់ទងទៅនឹងអំពើពុករលួយរបស់អ្នកនៅជិតនឹងសម្តេចព្រះប្រមុខរដ្ឋ ។ ម្យ៉ាងទៀត ក៏មានការប៉ះទង្គិចខាងផ្លូវអាវុធជាញឹកញាប់រវាងកងយោធពលខេមរភូមិន្ទ និង ពួកវៀតកុងនៅតាមទល់ដែន ។ នៅតាមតុការ្យ អ្នកស្រុកនិយាយយ៉ាងពេញមាត់ថា មានអ្នកធំៗលួចជួយពួកវៀតកុង ដោយបានផ្តល់ដល់ពួកយួនកុម្មុយនីស្តទាំងនេះ នូវស្បៀងអាហារ និង ថ្នាំសង្កូវជាដើម ។

នៅថ្ងៃទី ៨ មីនា ១៩៧០ ប្រជាពលរដ្ឋនាំគ្នាធ្វើបាតុកម្មប្រឆាំងនឹងវៀតកុងនៅក្នុងភូមិមួយឈ្មោះ ភូមិចន្ទ្រា នៅខេត្តស្វាយរៀង ។ ពួកអ្នកស្រុកទាំងនោះធ្វើបាតុកម្មទាមទារបណ្តេញពួកវៀតកុងឲ្យចេញពីដីខ្មែរ ។ នៅថ្ងៃ ១១ មីនា ១៩៧០ នៅទីក្រុងភ្នំពេញ និស្សិតក៏នាំគ្នាធ្វើបាតុកម្ម ដែលបានប្រែក្លាយទៅជាអំពើហឹង្សាប្រឆាំងនឹងស្ថានទូតវៀតណាមខាងជើង និង វៀតកុងដោយក្រុមបាតុករនាំគ្នាវាយលុកចូលទៅក្នុងអាគារ ធ្វើឲ្យស្ថានទូតទាំងពីរមានការខូចខាតយ៉ាងដំណំ ។ ចំពោះអ្នកស្រុកធម្មតា គេមិននឹកស្មានថាចាប់ផ្តើមពីបាតុកម្មបែបនេះ សភាពការណ៍ អាចនាំទៅដល់ការទំលាក់សម្តេចព្រះប្រមុខរដ្ឋជាទីគោរពរបស់ពួកគេឲ្យចេញពីអំណាចនោះឡើយ ។ នៅថ្ងៃទី ១៦ មីនា ពួកនិស្សិតបានបន្តធ្វើបាតុកម្មមួយទៀតដែលនៅពេលនោះ បុរសម្នាក់ត្រូវបានក្រុមបាតុកររាយធ្វើបាបយ៉ាងខ្លាំង ព្រោះតែគាត់ហ៊ានស្រែកជេរសម្តេចឪ ។ ក្រុមបាតុកររចោទប្រកាន់បុរសនោះថាធ្វើវិទ្ធង្សនា និង ក្បត់ប្រឆាំងនឹងព្រះរាជបល្ល័ង្ក ។ ជាទូទៅ អ្នកស្រុកយល់ថាបាតុកម្មថ្ងៃទី១៦ មីនានោះ ជាបាតុកម្មគាំទ្រសម្តេចឪ មិននឹកស្មានថាបាតុកម្មនោះ

ជាបឋមសញ្ញានៃការផ្លាស់ប្តូរអ្នកដឹកនាំនោះឡើយ ។ មានពាក្យចចាមអារាមខ្លះនិយាយថា ពួកបាតុករដែលហ៊ានធ្វើបាតុកម្មប្រឆាំងស្ថានទូតវៀតណាមទាំងពីរនោះ ប្រាកដជាបានទទួលសញ្ញាភ្លើងខៀវពីសម្តេចឪហើយ ព្រោះថានៅសម័យនោះគ្មាននរណាអាចធ្វើសកម្មភាពនយោបាយអ្វី ដោយគ្មានការយល់ព្រមពីព្រះអង្គនោះឡើយ ។ នៅពេលនោះ ខ្ញុំមិនបានចូលរួមធ្វើបាតុកម្មជាមួយពួកនិស្សិតទេ ព្រោះជាប់បំពេញការងារនៅឯក្រុមហ៊ុនសុរាគារខ្មែរ ។ នៅទីបំផុត អ្វីៗដែលយើងស្មានមិនដល់នោះ ក៏បានកើតឡើងមែន ។ នោះក៏ជាសោកដនាដកម្មដ៏ឃោរឃៅងមួយសំរាប់ប្រជាជាតិយើង ។

រសៀលថ្ងៃទី ១៨ មីនា ១៩៧០ នោះគឺ ជាពេលវេលាដ៏ខ្លោចផ្សានៅក្នុងប្រវត្តិសាស្ត្រខ្មែរ ។ នៅពេលនោះ ខ្ញុំកំពុងតែដើរតាមផ្លូវដីដ៏មានធូលីហុយទ្រលោមចេញពីផ្ទះឆ្ពោះទៅផ្សារដើមគគ្រាមកំដៅថ្ងៃដ៏ខ្លាំង និង ទៅកាន់ស្ថានីយឡាំប្រីតា ឬ រថយន្តកង់បី ដើម្បីបន្តដំណើរទៅវត្តឧណ្ណាលោមដូចធម្មតា ។ នៅពេលដើរទៅជិតស្ពានហៀបនឹងឆ្លងទៅស្ថានីយរថយន្តកង់បីនោះ ខ្ញុំឮសម្លេងបទភ្លេងដែលបន្លឺតាមវិទ្យុ នៅតាមតូបលក់ទំនិញទាំងឡាយ ដែលតាំងនៅហូរហែតាមដងផ្លូវគឺសម្លេងបទភ្លេងនគរាជ លាយឡំនឹងសម្លេងទ្រហឹងអឹងអាប់នៃរថយន្ត ឬ ទោចក្រយានយន្ត ដែលបើកគគ្រឹកគគ្រេង ដោយមានបញ្ចេញសម្លេងស៊ីផ្លេចេញពីច្រើនទិសទៀតផង ។ ក៏ប៉ុន្តែ ខ្ញុំស្តាប់ឮតែវគ្គចុងក្រោយនៃបទនគរាជ ។ ខ្ញុំខំផ្ទៀងត្រចៀកស្តាប់ ដោយនឹកថា ប្រហែលជាវិទ្យុបានផ្សាយនូវព្រះរាជសាររបស់សម្តេចព្រះមហាក្សត្រីយានី[30] ព្រោះតាមធម្មតា បន្ទាប់ពីព្រះអង្គមានព្រះសុវណ្ណយ៉ូរួចហើយ វិទ្យុជាតិតែងតែចាក់ផ្សាយនូវបទនគរាជជាកិត្តិយស ។ ក៏ប៉ុន្តែនៅលើកនេះ បន្ទាប់ពីសម្លេងបទភ្លេងនគរាជ ខ្ញុំឮតែសម្លេងភ្លេងព្យុហយាត្រា

[30] សម្តេចព្រះមហាក្សត្រីយានី ស៊ីសុវត្ថិ កុសុមៈ ជាព្រះមាតារបស់សម្តេច សីហនុ ។

(Marche militaire) នៃក្រុមយោធា ដែលមានលក្ខណៈខុសប្លែកពីធម្មតា ។ នៅក្នុងតូបលក់ទំនិញនីមួយៗ ខ្ញុំឃើញមនុស្សម្នាអង្គុយជុំៗស្តាប់វិទ្យុផ្សាយសម្លេង ។ ពួកគេហាក់ដូចកំពុងតាមដានព្រឹត្តិការណ៍ដ៏សំខាន់អ្វីមួយ ។ ខ្ញុំក៏បង្អង់ឈ្បឿនរង់ចាំស្តាប់វិទ្យុដូចគេដែរ ។ មិនយូរប៉ុន្មាន បទភ្លេងយោធាព្យុហយាត្រាក៏ត្រូវផ្អាក ហើយវិទ្យុជាតិ ក៏ចាក់ផ្សាយនូវសេចក្តីប្រកាសព័ត៌មានរបស់លោក ចេង ហេង ប្រធានរដ្ឋសភា ដែលកំពុងកាន់តំណែងជាប្រមុខរដ្ឋស្តីទីក្នុងពេលអវត្តមានសម្តេច សីហនុ ។ លោក ចេង ហេង មានប្រសាសន៍ ក្នុងសារដ៏ខ្លីរបស់គាត់មានន័យជាអាទិ៍ថា "រដ្ឋសភា និង ក្រុមប្រឹក្សាព្រះរាជាណាចក្រ ដែលបានរួមប្រជុំជាសមាជបានសំរេចដកសេចក្តីទុកចិត្តពីសម្តេច នរោត្តម សីហនុ ពីតំណែងរបស់ព្រះអង្គចាប់ពីម៉ោងដប់បីនៃថ្ងៃទី ១៨ មីនា ១៩៧០ នេះតទៅ"[31] ។ ព័ត៌មាននេះបានធ្វើឲ្យខ្ញុំកាំងស្មារតី ដូចត្រូវឆក់នឹងចរន្តអគ្គិសនី ហើយខ្ញុំក៏ប្រញាប់ប្រញាល់ត្រឡប់ទៅផ្ទះវិញ លះបង់ចោលនូវគំនិតដើម ដែលថានឹងទៅបំពេញករណីយកិច្ចយាមព្រះមហាកុដិថ្វាយសម្តេចព្រះសង្ឃរាជដូចសព្វៗដង ។

ពេលមកដល់ផ្ទះ ខ្ញុំឃើញបងប្រុសខ្ញុំទាំងពីរនាក់កំពុងអង្គុយស្តាប់វិទ្យុយ៉ាងយកចិត្តទុកដាក់ ។ អ្នកទាំងពីរក៏យល់ស្របតាមខ្ញុំគឺ មិនគួរចេញទៅក្រៅផ្ទះទេថ្ងៃនេះ ហើយយើងគួរតែត្រៀមលក្ខណៈ ចំពោះហេតុការណ៍ដ៏អាក្រក់ទាំងឡាយដែលអាចនឹងកើតមានឡើង ។ យើងបញ្ឈប់សកម្មភាពអ្វីផ្សេងៗទាំងអស់ ហើយយើងទាំងបីនាក់បន្តស្តាប់វិទ្យុតទៅទៀត ។ នៅពេលនោះខ្ញុំមានអារម្មណ៍ថា ព្រឹត្តិការណ៍នេះអាចមានការពាក់ព័ន្ធសាំញ៉ាំ នាំទៅបង្កឲ្យមានសង្គ្រាមលោកលើកទីបីផង ។

[31] Ministère de l 'Information, Documents, Cabinets Ministériels Khmers, du 18 mars 1945 au 18 mars 1970, Message à la Nation de Son Excellence Cheng Heng, Président de l'Assemblée Nationale, Exerçant les Pouvoirs de Chef de l'Etat, op. cit, p. 120.

ផ្ទុយទៅវិញ បងប្រុសទីពីររបស់ខ្ញុំប្រកាន់ឥរិយាបថដូចគ្នានឹងក្រុមនិស្សិតសាកលវិទ្យាល័យទាំងឡាយដែលមានសុទិដ្ឋិនិយម និង គាំទ្រការទំលាក់សម្តេច សីហនុ ។ ពួកនិស្សិតជំនាន់នោះមានការពេញចិត្តចំពោះការដួលរលំនៃរបបរាជានិយម ។ បងប្រុសខ្ញុំមានជំនឿថា ព្រឹត្តិការណ៍នេះ ជាព្រឹត្តិការណ៍ដ៏សំខាន់ដែលនាំមកប្រទេសកម្ពុជាយើងនូវលទ្ធិប្រជាធិបតេយ្យយ៉ាងពិតប្រាកដ ។

វិទ្យុជាតិនៅបន្តផ្សាយបទភ្លេងយោធាព្យុហយាត្រា លាយឡំនឹងសារលោកប្រមុខរដ្ឋស្តីទីព្រមជាមួយនិងសេចក្តីប្រកាសព័ត៌មានរបស់រាជរដ្ឋាភិបាល ។ រាជរដ្ឋាភិបាលចុងក្រោយសម័យនោះមានឈ្មោះថា "រដ្ឋាភិបាលស្រោចស្រង់ជាតិ" ។ កាលនោះ សម្តេច សីហនុ បានតែងតាំងរដ្ឋាភិបាលមួយក្រោមការដឹកនាំរបស់លោក លន់ នល់ ជានាយករដ្ឋមន្ត្រី នៅចុងខែ មករា ១៩៦៨ ។ ក្នុងជំនាន់សម្តេច សីហនុ កាន់អំណាចនោះ រាជរដ្ឋាភិបាលត្រូវបានផ្លាស់ប្តូរជាញឹកញាប់តាមព្រះទ័យរបស់ព្រះអង្គ ។ រាជរដ្ឋាភិបាលនីមួយៗ ជាទូទៅមានអាយុមិនលើសពីប្រាំមួយខែឡើយ ។ នៅក្នុងការផ្សាយរបស់វិទ្យុជាតិនោះ យើងឮសេចក្តីជូនដំណឹងធ្វើឡើងដោយលោកឧត្តមសេនីយ លន់ នល់ ដែលជំរាបជូនសាធារណជនអំពីការដេកហូតមុខតំណែងស្នងការកណ្តាលប៉ូលីស ប្រចាំរាជធានីភ្នំពេញ ដែលជាមនុស្សជំនិតម្នាក់របស់សម្តេច នរោត្តម សីហនុ ។ តាមការផ្សាយដំណឹងផ្សេងទៀត លោកឧត្តមសេនីយ លន់ នល់ បានចុះហត្ថលេខាលើសេចក្តីប្រកាសព័ត៌មានរបស់រដ្ឋាភិបាលស្រោចស្រង់ជាតិស្តីពីវិបត្តិនយោបាយដែលគេចោទថា បង្កើតឡើងដោយសម្តេច សីហនុ និង ស្តីពីសេចក្តីសម្រេចរបស់រដ្ឋសភា និង ក្រុមប្រឹក្សាព្រះរាជាណាចក្រក្នុងការដេកហូតតំណែងប្រមុខរដ្ឋពីសម្តេច នរោត្តម សីហនុ ដែលត្រូវជំនួសដោយលោក ចេង ហេង រហូតដល់ពេលមានការបោះឆ្នោតរើសប្រមុខរដ្ឋថ្មី

ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា[32] ។ ពួកយើងទាំងបីនាក់បន្ត ចំណាយពេលស្តាប់វិទ្យុរហូតដល់ពេលយប់ជ្រៅ ។ នៅទីបំផុត វិទ្យុជាតិក៏បានធ្វើ ការចាក់ផ្សាយនូវការពិភាក្សារបស់រដ្ឋសភា ស្តីអំពីការសំរេចចិត្តដកតំណែងប្រមុខ រដ្ឋពីសម្តេច សីហនុ ។

សមាជិកសភា និង ក្រុមប្រឹក្សាព្រះរាជាណាចក្រ បានលើកយកការអនុវត្ត រដ្ឋធម្មនុញ្ញមកជជែកដោយមិនបាននិយាយអំពីរដ្ឋប្រហារយោធាណាមួយឡើយ ។ វាគ្មិនជាច្រើនដែលគេស្គាល់ថាធ្លាប់មានកក្តីភាពចំពោះសម្តេចព្រះប្រមុខរដ្ឋ បាន ធ្វើការវាយប្រហារយ៉ាងខ្លាំងទៅលើព្រះអង្គ ។ លោក អ៊ិន តាំ ដែលជាប្រធានរដ្ឋ សភាស្តីទី បានចេញមុខប្រឆាំងនឹងសម្តេចយ៉ាងខ្លាំងក្លា ។ នៅក្នុងសម័យប្រជុំនោះ ពួកអ្នកតំណាងរាស្ត្រ និង ក្រុមសមាជិកក្រុមប្រឹក្សាព្រះរាជាណាចក្រ បានចោទ ប្រកាន់សម្តេច សីហនុ លើបទល្មើសប្រាំប្រការគឺ៖[33] អំពើក្បត់ជាតិ ការរំលោភជា ញឹកញាប់លើរដ្ឋធម្មនុញ្ញ ការលួចសម្បត្តិជាតិ អំពើពុករលួយ និង ការធ្វើឲ្យបាត់ បង់នូវសេចក្តីថ្លៃថ្នូរ និង កិត្តិយសជាតិ ។ ក្នុងហានៈជាពលរដ្ឋតូចតាច ពួកយើងពុំ បានយល់ស៊ីជម្រៅនូវអ្វីដែលហៅថានយោបាយឡើយ ។ ក៏ប៉ុន្តែ បើគ្រាន់តែស្តាប់ ការពិភាក្សាតាមផ្លូវច្បាប់អំពីវិធីជ្រើសរើស និង ការតែងតាំងប្រមុខរដ្ឋអាចធ្វើឲ្យ យើងជឿបានថានោះគឺ ជាការអនុវត្តតាមរដ្ឋធម្មនុញ្ញ មិនមែនជារដ្ឋប្រហារយោធា ណាមួយឡើយ ។

[32] Ministère de l ‘Information, Documents, Cabinets Ministériels Khmers, du 18 mars 1945 au 18 mars 1970, “Communiqué du Gouvernement de Sauvetage”, op. cit, p. 119.

[33] Ministère de l ‘Information, Documents, Cabinets Ministériels Khmers, du 18 mars 1945 au 18 mars 1970, “Motion à l’Assemblée Nationale”, op. cit, pp. 126-127.

គេថាធ្វើតាមរដ្ឋធម្មនុញ្ញ[34]

ច្បាប់រដ្ឋធម្មនុញ្ញទីមួយនៃព្រះរាជាណាចក្រកម្ពុជា បានត្រូវប្រកាសឲ្យប្រើនៅខែ ឧសភា ១៩៤៧ នៅពេលដែលសម្តេច នរោត្តម សីហនុ ទ្រង់សោយរាជ្យនៅឡើយ ។ សូមរំលឹកថា នៅឆ្នាំ ១៩៤១ អាជ្ញាធរអាណាព្យាបាលបារាំង បានជ្រើសរើសសម្តេច សីហនុ ឲ្យគ្រងរាជសម្បត្តិជំនួសព្រះអយ្យកោ (ជីតា) របស់ព្រះអង្គគឺ ព្រះករុណាព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស ក្រោយពេលទ្រង់បានសោយព្រះទីវង្គតទៅ ។ ដូច្នេះនៅក្នុងព្រះជន្មតែ ១៩ ព្រះវស្សា សម្តេច សីហនុ ឡើងគ្រងរាជសម្បត្តិជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ។ នៅឆ្នាំ ១៩៥៥ ព្រះករុណាព្រះបាទសម្តេច នរោត្តម សីហនុ បានទ្រង់ដាក់រាជ្យថ្វាយព្រះបិតារបស់ព្រះអង្គគឺព្រះករុណាព្រះបាទ សុរាម្រឹត ដើម្បីមានឱកាសចូលប្រឡូកក្នុងឆាកនយោបាយ ។ នេះជាករណីមួយដ៏ចំឡែក នៅក្នុងប្រទេសកម្ពុជាយើង ។ តាមធម្មតាគេធ្លាប់តែឃើញ ព្រះបិតា "ឪពុក" បង្វែររាជសម្បត្តិទុកឲ្យព្រះរាជបុត្រ "កូន" តែក្នុងករណីសម្តេច សីហនុ នេះគឺ ព្រះអង្គជាបុត្រផ្ទៃ រាជសម្បត្តិថ្វាយព្រះរាជបិតាព្រះអង្គទៅវិញ ។

នៅសម័យនោះ ប្រទេសកម្ពុជាប្រកាន់របបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ (Monarchie constitutionnelle) ដែលមានព្រះមហាក្សត្រជាប្រមុខរដ្ឋ ។ ចាប់ពីទ្រង់ដាក់រាជសម្បត្តិមក សម្តេច សីហនុ បានបំពេញមុខនាទីជានាយករដ្ឋមន្ត្រី ជាច្រើនលើកច្រើនសារ ។ ក៏ប៉ុន្តែ ក្នុងសម័យមុនឆ្នាំ ១៩៧០ នោះ នាយករដ្ឋមន្ត្រីអាចប្រគល់នាទីឲ្យរដ្ឋមន្ត្រីទី១ ធ្វើការជំនួសក៏បាន ។ ឧទាហរណ៍

[34] ទាំងប្រកាសព័ត៌មានរបស់រដ្ឋាភិបាលស្រោចស្រង់ជាតិ ទាំងសារជូនប្រជាជាតិរបស់លោក ចេង ហោង ប្រមុខរដ្ឋស្តីទី សុទ្ធតែបានចែងថាការដេកសម្តេច សីហនុ ពីតំណែងប្រមុខរដ្ឋ ធ្វើឡើងតាមរដ្ឋធម្មនុញ្ញទាំងអស់ ។

ដូចជានៅឆ្នាំ ១៩៦៨ ដោយសារសម្តេច សីហនុ ទ្រង់កាន់តំណែងជាប្រមុខរដ្ឋផង ជានាយករដ្ឋមន្ត្រីផង ទើបព្រះអង្គបានតែងតាំងលោក សឺន សាន ជារដ្ឋមន្ត្រីទី១ ឲ្យដឹកនាំការងាររាជរដ្ឋាភិបាលជំនួសព្រះអង្គ ។

នៅឆ្នាំ ១៩៦០ នៅពេលដែលព្រះករុណាព្រះបាទ សុរាម្រឹត បានទ្រង់ចូលទីវង្គត សម្តេច សីហនុ បានធ្វើឲ្យមានការកែប្រែរដ្ឋធម្មនុញ្ញ ដើម្បីបង្កើតឲ្យមានមុខតំណែងព្រះប្រមុខរដ្ឋមួយឡើង ។ នៅពេលនោះ ព្រះអង្គទ្រង់ទទួលយកតំណែងជាព្រះប្រមុខរដ្ឋនេះ ដោយរក្សាទុកព្រះវរមាតាជាសម្តេចព្រះមហាក្សត្រីយានី ដែលជានិមិត្តរូបនៃព្រះរាជបល្ល័ង្ក ។ តាមការកែសំរួលថ្មីនៃរដ្ឋធម្មនុញ្ញនោះ មុខតំណែងប្រមុខរដ្ឋ ត្រូវជ្រើសរើសឡើងដោយចលនាសង្គមរាស្ត្រនិយមហើយនិងទទួលបានការបោះឆ្នោតគាំទ្រដោយអង្គប្រជុំពិសេសរបស់រដ្ឋសភា និង ក្រុមប្រឹក្សាព្រះរាជាណាចក្រ ដែលហៅថាអង្គប្រជុំសមាជ ។ នៅថ្ងៃ ១៨ មីនា ១៩៧០ នេះ ក៏មានការប្រជុំជាសមាជ ដើម្បីដកហូតសេចក្តីទុកចិត្តពីសម្តេច សីហនុ ក្នុងតំណែងព្រះអង្គជាប្រមុខរដ្ឋដែរ ។ ក៏ប៉ុន្តែ នៅពេលនោះ រដ្ឋសភា និង ក្រុមប្រឹក្សាព្រះរាជាណាចក្រ ពុំបានជ្រើសរើសបេក្ខជនណាមួយឲ្យមកកាន់តំណែងប្រមុខរដ្ឋជំនួសព្រះអង្គឡើយ ។

យប់ទីមួយនៃទិវាដ៏ខ្មៅងងឹតក្នុងប្រវត្តិសាស្ត្រនេះ មានសភាពស្ងប់ស្ងៀមល្អណាស់ ក៏ប៉ុន្តែពួកយើង មិនបានទទួលទានដំណេកឲ្យបានលង់លក់ដូចធម្មតាឡើយ ។ ព្រឹកឡើងយើងនាំគ្នាទៅធ្វើការតាមទំលាប់ ។ នៅតាមផ្លូវ ខ្ញុំសង្កេតឃើញចលនាឥតឈប់ឈរនៃរថយន្តយោធា ពីផ្លូវមួយទៅផ្លូវមួយ ពីទីកន្លែងមួយ ទៅទីកន្លែងមួយ ។ យោធាដែលមានប្រដាប់ដោយអាវុធយ៉ាងសម្បើមផងនោះ បាននាំខ្លួនមន្ត្រីជាន់ខ្ពស់នៃរបបសម្តេច សីហនុ ដឹកឆ្ពោះទៅទីកន្លែងដែលយើងមិនស្គាល់ ។ ខ្ញុំឮគេនិយាយថា មន្ត្រីជាន់ខ្ពស់ទាំងនោះត្រូវបាននាំយកទៅឃុំខ្លួន ។

ខ្ញុំសង្កេតឃើញមានរទេះតង់ និង រថពាសដែកមួយចំនួននៅខាងមុខអាគារសោធារណៈ ឬ អាគាររបស់រដ្ឋាភិបាល ។ ចរាចរណ៍តាមផ្លូវហាក់ដូចជាប្រព្រឹត្តទៅដោយស្រួល និង មានរបៀបរៀបរយជាងមុន ។ ខ្ញុំសង្កេតឃើញថាក្នុងរយៈពេលមួយខែបន្ទាប់ពីព្រឹត្តិការណ៍ ១៨ មីនា នោះ ការអនុវត្តច្បាប់ និង ការគោរពច្បាប់ហាក់ដូចជាបានប្រព្រឹត្តទៅយ៉ាងត្រឹមត្រូវ និង ហ្មត់ចត់ជាទីបំផុត ។

រដ្ឋាភិបាល លន់ នល់ កំចាត់វៀតណាមកុម្មុយនីស្ត

របបថ្មីដែលទើបតែងតាំងឡើងនេះបានផ្អែកធម្មានុរូបភាព[35] (Légitimité) របស់ខ្លួន ទៅលើមនោសញ្ចេតនាស្អប់ឃួនរបស់ខ្មែរភាគច្រើននៅពេលនោះ ។ ខ្មែរយើងមួយចំនួនយល់ថាជនជាតិវៀតណាមជាសត្រូវសួពូជ ។ ប្រទេសកម្ពុជាយើងបានត្រូវបាត់បង់ទឹកដីមួយចំនួន ដោយសារជនជាតិវៀតណាមជាច្រើនសតវត្សកន្លងមកហើយ ។ ដូច្នេះគេមិនអាចឲ្យមានការបាត់បង់ទឹកដីខ្មែរតទៅទៀតបានឡើយ ។ ការកាន់កាប់ទឹកដីណាមួយរបស់ខ្មែរដោយជនជាតិវៀតណាម អាចដុតភ្លើងកំហឹងរបស់ជនជាតិខ្មែរ ដែលភាគច្រើនជាអ្នកជាតិនិយមឆ្អិនឆ្អៅ ។ នៅពេលនោះ យើងមិនបាននឹកដល់សង្គ្រាមស៊ីវិលរវាងខ្មែរ និង ខ្មែរនោះទេ ព្រោះខ្មែរណាក៏ដូចខ្មែរណា ជឿថាគេមិនអាចសំលាប់ខ្មែរគ្នាឯងបានឡើយ ។ ប្រសិនបើមានបរទេសឈ្លានពាន ប៉ុនប៉ងដណ្តើមទឹកដីខ្មែរ ខ្មែរម្នាក់ៗត្រៀមខ្លួនជាស្រេច ដើម្បីធ្វើពលីកម្ម ចំពោះជាតិមាតុប្រទេស ។ ខ្ញុំជឿថារហូតមកដល់ថ្ងៃនេះ ខ្មែរយើងភាគច្រើន នៅតែមានសេចក្តីស្នេហាជាតិបែបនេះជានិច្ច ។

រដ្ឋាភិបាល លន់ នល់ បានធ្វើការឃោសនាយ៉ាងខ្លាំងក្លា និង កាចសាហាវ

[35] អាចនិយាយពីលក្ខណៈស្របច្បាប់ ឬ ដែលមិនផ្ទុយពីច្បាប់ក៏បាន ។

ប្រឆាំងវៀតណាមកុម្មុយនីស្តគឺ ពួកវៀតកុង និង វៀតណាមខាងជើង ដោយគេប្រកាន់គោលជំហរថាការទំលាក់សម្តេច សីហនុ ចេញពីតំណែងនោះគឺ ជាកិច្ចប្រតិបត្តិការជៀសមិនរួច ដើម្បីបញ្ឈប់ការកាន់កាប់ទឹកដីខ្មែរដោយពួកវៀតណាមកុម្មុយនីស្តទាំងនោះ ។

សូមបញ្ជាក់ថានៅសម័យនោះ ពួកវៀតកុង(Viet Cong)[36] និង វៀតណាមខាងជើង បានទទួលការគាំទ្រយ៉ាងរឹងមាំពីអាណិកជនវៀតណាមនៅកម្ពុជា និងពីសម្តេច សីហនុ ។ លោក លន់ នល់ ក៏បានចាប់ផ្តើមបំផ្លាញចោលនូវរាល់បណ្តាញវៀតណាមនៅក្នុងប្រទេស ។ ដំណាក់កាលដំបូង មានការចាប់ឃាត់ជនសង្ស័យថាជាបណ្តាញវៀតណាមកុម្មុយនីស្ត ហើយបន្តបន្ទាប់មក ក៏ចាប់ផ្តើមបណ្តេញជនជាតិវៀតណាមជាទូទៅចេញពីកម្ពុជា។ ជនជាតិវៀតណាមទាំងនោះត្រូវចាត់ឲ្យទៅនៅក្នុងជំរុំបណ្តោះអាសន្ន មុននឹងត្រូវគេបញ្ជូនទៅប្រទេសគេវិញ ឬទៅប្រទេសទី៣ ។

នៅពេលនោះ មានជនជាតិវៀតណាមជាច្រើន ប្រញាប់ប្រញាល់លក់ចេញនូវទ្រព្យសម្បត្តិរបស់ខ្លួន ឬ ឧបករណ៍ប្រើប្រាស់ល្អៗទាំងឡាយ រួចស្ម័គ្រចិត្តចូលទៅរស់នៅក្នុងជំរុំតាមការកំណត់របស់រដ្ឋាភិបាល ជាជាងរង់ចាំឲ្យប៉ូលីសចូលមកចាប់ខ្លួន ។ នៅក្នុងសភាពការណ៍បែបនេះ ខ្ញុំក៏ឆ្លៀតទិញបាននូវវិទ្យុមួយគ្រឿងដែលមានតំលៃថោកសមល្មម ហើយដែលអាចឲ្យខ្ញុំចាប់បាននូវការផ្សាយព័ត៌មាន

[36] មុនឆ្នាំ ១៩៧៥ ប្រទេសវៀតណាមចែកជាពីរគឺ ប្រទេសវៀតណាមខាងជើង ដែលជាប្រទេសសង្គមនិយម និង ប្រទេសវៀតណាមខាងត្បូងដែលជាប្រទេសសេរី និង ជាសម្ព័ន្ធមិត្តរបស់ស.រ.អា ។ ប្រទេសទាំងពីរធ្វើសង្គ្រាមរវាងគ្នានិងគ្នាដោយប្រទេសវៀតណាមខាងជើង ជួយពួកវៀតកុងឲ្យផ្តួលរំលំរបបសេរី នៅវៀតណាមខាងត្បូង ។ ពួកវៀតកុងជាយុទ្ធជនបដិវត្តនៅវៀតណាមខាងត្បូង បានបង្កើតរដ្ឋាភិបាលបណ្តោះអាសន្នមួយ ដែលរាជរដ្ឋាភិបាលរបស់សម្តេច សីហនុ ទទួលស្គាល់ថាជា រដ្ឋាភិបាលស្របច្បាប់ ។ ក្រោយជ័យជំនះឆ្នាំ ១៩៧៥ ប្រទេសវៀតណាមទាំងពីរបានបញ្ចូលគ្នាជាប្រទេសតែមួយវិញឈ្មោះថា សាធារណរដ្ឋសង្គមនិយមវៀតណាមរហូតសព្វថ្ងៃ ។

អន្តរជាតិពីប្រទេសផ្សេងៗ ។ នយោបាយរបស់រដ្ឋាភិបាល លន់ នល់ ប្រឆាំងវៀតណាម បានទទួលការគាំទ្រយ៉ាងខ្លាំងពីក្រុមនិស្សិត បញ្ញវន្ត និង អ្នករស់នៅក្នុងទីក្រុង ។ យុវជនខ្មែរមួយចំនួន បានស្ម័គ្រចិត្តចូលបំរើកងទ័ព លន់ នល់ ។ យុវជនដែលមានចិត្តពោរពេញទៅដោយសេចក្តីស្នេហាជាតិនោះ ត្រូវបានគេបញ្ជូនទៅសមរភូមិមុខភ្លាមៗ ដោយពុំបានទទួលការរៀបចំ និង ហ្វឹកហាត់ឲ្យបានមាំមួនផ្នែយស្រឡះពីពួកវៀតកុង ដែលគេស្គាល់ថា ជាយុទ្ធជនមានបទពិសោធន៍យ៉ាងល្បីល្បាញក្នុងពិភពលោក ។ យុវជនទាំងនោះក៏ត្រូវពលីជីវិតភ្លាមៗ នៅទីលានប្រយុទ្ធ ។ យុវជនខ្មែររាប់ពាន់នាក់ បានត្រូវស្លាប់នៅប៉ុន្មានខែដំបូងនៃសង្គ្រាម ដែលគេនឹកថាស្លាប់ដើម្បីបុព្វហេតុជាតិ ។

ផ្នែយពី បងស៊ីនឿន ដែលសំដែងការគាំទ្រចំពោះរដ្ឋអំណាចថ្មី ខ្ញុំមានគំនិតអភិរក្សជាង ហើយសំដែងការព្រួយបារម្ភពីវាសនារបស់យើងទាំងអស់គ្នា ។ កាលណាយើងជជែកគ្នាអំពីនយោបាយ យើងតែងប៉ះទង្គិចពាក្យសំដីគ្នាជានិច្ច ព្រោះយើងតែងអាងហេតុផលផ្សេងៗពីគ្នា ។ ក៏ប៉ុន្តែជានិច្ចកាលបងទី១ ហៅ បងនាង ឬ បងឈឿន តែងគាំទ្រខ្ញុំ ដូច្នេះនៅក្នុងផ្ទះយើងៗមានគ្នាពីរនាក់ ដែលមានគំនិតដូចគ្នាប្រឆាំងនឹងម្នាក់ទៀត ដែលមានគំនិតគាំទ្ររបបថ្មី ។

ដោយសារវិទ្យុទទួលសម្លេងរបស់ខ្ញុំមានកំលាំងខ្លាំង ខ្ញុំមានការងាយស្រួលក្នុងការបើកស្តាប់ ដោយលួចលាក់នូវការផ្សាយប្រចាំថ្ងៃរបស់វិទ្យុប៉េកាំង ។ នៅពេលនោះ វិទ្យុនេះតែងធ្វើបទអត្ថាធិប្បាយនយោបាយ ដែលទទួលការពេញចិត្តពីប្រជាពលរដ្ឋមួយចំនួនធំ ដែលនៅតែមានស្នាមីភ័ក្តិ គោរព និង ស្រឡាញ់សម្តេចសីហនុ តទៅទៀតនោះ ។

សម្តេច សីហនុ មានប្រតិកម្មតបវិញ

សម្តេច នរោត្តម សីហនុ បានយាងចេញពីទីក្រុងប៉ារីសឆ្ពោះទៅទីក្រុងមូស្គូ នៅថ្ងៃទី ១៣ មីនា ១៩៧០ ។ ថ្ងៃទី ១៣ តាមធម្មតាចំពោះពួកអ្នកហែរហមព្រះអង្គខ្លះ ដែលជឿលើអបិយជំនឿនិយាយថាមិនគួរនឹងធ្វើដំណើរនៅថ្ងៃនោះឡើយ ។ សម្តេចទ្រង់ត្រូវធ្វើដំណើរទស្សនកិច្ចមួយនៅសហភាពសូវៀត ។ នៅថ្ងៃដែលពួក លន់ នល់ ទំលាក់ព្រះអង្គចេញពីតំណែងនោះ ក៏ត្រូវចំថ្ងៃដែលព្រះអង្គត្រូវយាងចេញពីក្រុងមូស្គូឆ្ពោះទៅប្រទេសចិន ។ អ្នកហែរហមព្រះអង្គមួយចំនួន បានទទួលដំណឹងតាមវិទ្យុរួចហើយ នូវដំណឹងអាក្រក់ស្តីពីការដេកហូតតំណែងនោះ ក៏ប៉ុន្តែគ្មាននរណាហ៊ានទៅទូលព្រះអង្គដោយផ្ទាល់ឡើយ ។ នៅក្នុងរថយន្ត ដែលព្រះអង្គគង់ប្រថាប់ជាមួយលោកនាយករដ្ឋមន្ត្រី កូស៊ីហ្គីន តាមក្បួនរថយន្តឆ្ពោះទៅវាលយន្តហោះ គឺលោកនាយករដ្ឋមន្ត្រីសូវៀតនេះហើយ ដែលទូលថ្វាយសម្តេចនូវដំណឹងដ៏អាក្រក់នោះ ។ នៅក្នុងសៀវភៅ ដែលមានចំណងជើងថា "សេ អ៊ី អា ប្រឆាំងប្រទេសកម្ពុជា"[37] ឆ្លើយនឹងសំណួររបស់លោកនាយករដ្ឋមន្ត្រីសូវៀត ដែលចោទសួរព្រះអង្គថា តើព្រះអង្គមានបំណងនឹងធ្វើដូចម្តេចចំពោះហេតុការណ៍នេះ? សម្តេច មានបន្ទូលថា ខ្ញុំនឹងបន្តប្រឆាំងតបតវិញ ។ ប្រតិកម្មរបស់សម្តេចមានលក្ខណៈភ្លាមៗ គឺត្រូវការប្រឆាំងទប់ទល់ និង សងសឹកពួក លន់ នល់ វិញ ។

នៅពេលដែលព្រះអង្គយាងដល់ទីក្រុងប៉េកាំង ព្រះអង្គត្រូវបានទទួលស្វាគមន៍ដោយលោកនាយករដ្ឋមន្ត្រី ជូ អេនឡាយ នៃប្រទេសចិន ដែលបានអញ្ជើញបណ្តាអង្គទូតប្រចាំប្រទេសចិនទាំងអស់ ឲ្យមកធ្វើបដិសណ្ឋារកិច្ចថ្វាយ

[37] Norodom Sihanouk, La C.I.A. Contre le Cambodge, François Maspero, Paris, 1973, p. 13-21.

ព្រះអង្គ ដើម្បីបង្ហាញថា សម្តេចទ្រង់នៅតែត្រូវបានទទួលស្គាល់ជាព្រះប្រមុខរដ្ឋ ពេញច្បាប់នៃប្រទេសកម្ពុជា ។ នៅក្នុងសៀវភៅនោះ ឆ្លើយតបនឹងសំណូររបស់ លោកនាយករដ្ឋមន្ត្រី ជូ អេនឡាយ ដែលចោទសួរដូចលោក កូស៊ីហ្គីន ដែរនោះ សម្តេចទ្រង់មានបន្ទូលថា "ខ្ញុំនឹងធ្វើការតស៊ូរហូតដល់ជីវិតចុងក្រោយ" ។ ក៏ប៉ុន្តែ លោកនាយករដ្ឋមន្ត្រី ជូ អេនឡាយ ទូលសុំឲ្យសម្តេចពិចារណាឲ្យមែនទែន ក្នុងរយៈពេលម្តែបួនម៉ោងខាងមុខ មុននឹងសំរេចជាចុងក្រោយ ។

មួយថ្ងៃបន្ទាប់មក សម្តេច សីហនុ ក៏បានជួបជាមួយលោកនាយករដ្ឋមន្ត្រី ផាំ វ៉ាន់ដុង នៃប្រទេសវៀតណាមខាងជើង ដែលបានធ្វើដំណើរពិសេសពីទីក្រុង ហាណូយមកទីក្រុងប៉េកាំង ដើម្បីពិភាក្សាអំពីបញ្ហាកម្ពុជា ។ លោក ផាំ វ៉ាន់ដុង បានទូលសួរព្រះអង្គថា តើសម្តេចចង់ឲ្យកាគីវៀតណាម ជួយព្រះអង្គយ៉ាងដូច ម្តេច?សម្តេចមានបន្ទូលឆ្លើយតបទៅវិញក្នុងន័យជាអាទិថា៖ "យើងខ្ញុំត្រូវការគ្រូ បង្វឹកយោធា ឬ យោធាចារ្យ[38] យើងខ្ញុំមិនខ្វះអ្នកស្មគ្រចិត្តកាន់អាវុធទេ ហើយ ប្រទេសចិនបានសន្យារួចជាស្រេចថា នឹងផ្តល់អាវុធយុទ្ធភណ្ឌ ។ អ្វីដែលយើងខ្វះ នោះគឺ កម្មាភិបាលដែលមានការហ្វឹកហាត់គ្រប់គ្រាន់ ។ វៀតណាមមានពួកទាំង នោះ ដ៏ខ្លាំងពូកែមួយក្នុងលោក សម្រាប់ធ្វើសង្គ្រាមប្រភេទនេះ" ។ លោក ផាំ វ៉ាន់ដុង បានឆ្លើយថា "[ទូលបង្គំ]ខ្ញុំនឹងប្រាប់លោក(ឧត្តមសេនីយ) យ៉ាប់[39] ឲ្យ បញ្ជូនកម្មាភិបាលពូកែៗចំនួន ២០០០ នាក់ មកថ្វាយព្រះអង្គ" ។ សម្តេច សីហនុ និង លោកនាយករដ្ឋមន្ត្រី ផាំ វ៉ាន់ដុង ក៏បានផ្លាស់ប្តូរមតិគ្នាតទៅទៀតយ៉ាងយូរ អំពីមធ្យោបាយល្អៗ ដើម្បីសម្របសម្រួលការតស៊ូប្រយុទ្ធរបស់ប្រជាជនឥណ្ឌូចិន

[38] គ្រូបង្វឹកផ្នែកក្បួនយោធា ។

[39] លោកឧត្តមសេនីយ រ៉ូ ង្វៀង យ៉ាប់ ជារដ្ឋមន្ត្រីក្រសួងការពារជាតិនៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម នៅសម័យនោះ ។

ទាំងបី ។

នៅថ្ងៃ ២០ និង ២១ មីនា សម្តេចបានប្តេជ្ញាថា នឹងធ្វើការតស៊ូប្រឆាំង លោក លន់ នល់ ហើយនៅថ្ងៃទី ២៣ មីនា ព្រះអង្គក៏ទ្រង់ធ្វើការអំពាវនាវដល់ ប្រជាពលរដ្ឋខ្មែរឲ្យចូលក្នុងព្រៃដែលហៅថា ព្រៃម៉ាគី ដើម្បីរួបរួមគ្នាជាមួយរាជ រដ្ឋាភិបាលរួបរួមជាតិកម្ពុជា (GRUNK: Gouvernement Royal d'Union Nationale du Kampuchéa) និង រណសិរ្សរួបរួមជាតិកម្ពុជា (FUNK: Front Uni National du Kampuchéa) ដែលនៅពេលនោះ គ្មានអ្នកណាដឹងថាជារដ្ឋាភិបាល ស្ថិតនៅក្រោមអំណាចរបស់ពួកខ្មែរក្រហមសោះឡើយ ។ សម្តេច សីហនុ ប្រកាស បង្កើតរាជរដ្ឋាភិបាលក្រៅប្រទេសនេះឡើងជាផ្លូវការនៅថ្ងៃទី ៥ ឧសភា ១៩៧០ ។

ចាប់តាំងពីព្រះអង្គបានមករស់នៅលើទឹកដីនៃប្រទេសចិនមក ទីក្រុង ប៉េកាំងបានក្លាយជាបង្អែកដ៏រឹងមាំរបស់ព្រះអង្គ ។ ចំណែកឯវិទ្យុប៉េកាំងវិញ ក៏បានក្លាយជាឧបករណ៍របស់ព្រះអង្គ ក្នុងការឃោសនាអំពាវនាវប្រកួកប្រកាសឲ្យ ប្រជាពលរដ្ឋខ្មែរ ក្រោកឡើងប្រឆាំងរបប លន់ នល់ និង ចូលរួមធ្វើបដិវត្តន៍មួយ ថ្មី ។

លន់ នល់ ជានរណា ?[40]

មុនថ្ងៃ ១៨ មីនា ១៩៧០ លោក លន់ នល់ បានត្រូវប្រជាពលរដ្ឋទូទៅ ទទួលស្គាល់ថា ជានាយទាហានមួយរូប ដែលបានទទួលសេចក្តីទុកចិត្តយ៉ាងខ្លាំង

[40] លោក លន់ នល់ បានសរសេរសៀវភៅ **ជំណើរខ្មែរថ្មី (Le néo-khmérisme)** ដើម្បីបង្ហាញអំពីគោលគំនិតនៃរបបរបស់ គាត់។

ពីសម្តេចព្រះប្រមុខរដ្ឋ ។ ពួកយើងហៅគាត់ថាលោក General "លោកឧត្តមសេនីយ" ពីព្រោះនៅសម័យនោះលោក លន់ នល់ ជានាយទាហានពាក់សញ្ញឧត្តមសេនីយ ដែលគេស្គាល់ជាងគេនៅក្នុងប្រទេស ។ យើងបានដឹងថាលោកឧត្តមសេនីយ លន់ នល់ បានចាប់ផ្តើមពាក់សញ្ញប្រាំតែម្តង មិនមែនក្នុងឋានៈជានាយទាហានធម្មតាទេ ។ ដំបូងឡើយ គាត់ធ្វើជាចៅក្រម រួចផ្ទេរក្របខណ្ឌមកជាមន្ត្រីរដ្ឋបាល ធ្វើជាបាឡាត់ស្រុក (មានឋានៈប្រហាក់ប្រហែលអភិបាលរងស្រុក) រហូតឡើងជាចៅហ្វាយខេត្ត ។

នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៥០ នៅពេលដែលព្រះករុណាព្រះបាទ នរោត្តម សីហនុ ទ្រង់បំពេញព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យពីបារាំង លោក លន់ នល់ កំពុងកាន់តំណែងជាចៅហ្វាយខេត្តបាត់ដំបង ។ ដើម្បីដឹកនាំកិច្ចប្រតិបត្តិការសឹកនៅតំបន់នោះ ព្រះមហាក្សត្របានតែងតាំងលោកចៅហ្វាយខេត្ត ក្នុងឋានៈជានាយទាហានសញ្ញ "វរសេនីយឯក" ។ ដូច្នេះ លោក លន់ នល់ ចាប់ផ្តើមធ្វើទាហានពីសញ្ញប្រាំ ឡើងរហូតដល់ថ្នាក់ឧត្តមសេនីយឯក ឬ ផ្កាយបី ។

ទោះបីជាលោកមានប្រវត្តិដើម ចេញពីក្របខណ្ឌមន្ត្រីស៊ីវិលយ៉ាងណាក៏ដោយ លោកឧត្តមសេនីយ លន់ នល់ ត្រូវបានទទួលការគោរពយ៉ាងធំធេងពីនាយទាហាន និង ពលទាហានភាគច្រើនរបស់កងទ័ពខ្មែរ ។ ដោយសារគាត់មានសម្បុរខ្មៅ កូនទាហានភាគច្រើនឲ្យឈ្មោះគាត់ថា "ប៉ាខ្មៅ" ។ លោកឧត្តមសេនីយ មានរូបរាងធំខ្ពស់ជាងជនជាតិខ្មែរយើងធម្មតា ដែលគេអាចប្រដូចរូបគាត់ទៅមនុស្សសម័យអង្គរ ។ លោក លន់ នល់ មានដើមកំណើតចេញមកពីខេត្តព្រៃវែងដូចខ្ញុំដែរ ។ ឪពុកគាត់ធ្លាប់ធ្វើជាចៅហ្វាយស្រុក ឯជីតាធ្លាប់ធ្វើជាចៅហ្វាយខេត្ត នៅខេត្តព្រៃវែងនេះតែម្តង ។ លោក លន់ នល់ ជាមនុស្សជឿលើអាគមអូមអាម ដែលតម្រូវ

ឲ្យស្វែងរកគ្រូទាយ ឲ្យគន់គូររកពេលវេលាល្អ ឬ ឲ្យព្រះសង្ឃសូត្រមន្តប្រោះព្រំមុននឹងធ្វើការអ្វីៗសំខាន់ៗ ។

អស់រយៈពេលជាច្រើនឆ្នាំមុនថ្ងៃទី ១៨ មីនា ១៩៧០ ក្រៅពីការងារយោធា លោក លន់ នល់ តែងធ្វើសកម្មភាពជាច្រើនខាងផ្នែកព្រះពុទ្ធសាសនាធ្វើការឧបត្ថម្ភព្រះសង្ឃ និង វត្តអារាមទូទាំងប្រទេសកម្ពុជា ។ ខ្ញុំមិនដឹងថាលោក លន់ នល់ មានការយល់ដឹងផ្នែកព្រះពុទ្ធសាសនា ដល់កំរិតណាទេ គ្រាន់តែនឹកថាគាត់មានជំនឿយ៉ាងមុតមាំលើអច្ឆរិយវត្ថុ អ្នកតា និង ទេវតា ឬ បារមីផ្សេងៗ ។ នៅខែ មករា ១៩៧០ លោក លន់ នល់ បានចាត់ឲ្យនាំនូវម៉ាស៊ីនភ្លើងកំលាំងច្រើនគីឡូវ៉ាត់មួយគ្រឿង ទៅប្រគេនព្រះសង្ឃនៅវត្តកំពង់ទ្រា ក្នុងស្រុកពារាំង ។

លោក លន់ នល់ មានភរិយា ដែលមានគេគោរពរាប់អានច្រើន ឈ្មោះដំទាវ ខេង ។ លោកដំទាវ ខេង បានទទួលមរណភាពនៅឆ្នាំ ១៩៦៩ ។ ក្នុងចំណោមបងប្អូនជាច្រើននាក់ លោក លន់ នល់ ក៏មានប្អូនប្រុសម្នាក់ឈ្មោះ លន់ ណុន ដែលក្រោយមកបានក្លាយជាមនុស្សដៃស្តាំ និង ជាបន្ទុកដ៏ធ្ងន់ផ្នែកនយោបាយរបស់គាត់ផង ។ ខ្ញុំឮគេនិយាយថានៅខែ មីនា ១៩៧០ នោះ លោក លន់ នល់ ហាក់ដូចជាមានការស្ទាក់ស្ទើរក្នុងការធ្វើរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ។ តាមពាក្យចចាមអារាម លោក លន់ នល់ ស្ថិតនៅក្រោមការបង្ខិតបង្ខំរបស់អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមត៖[41] ដែលនៅក្នុងពេលនោះ កាន់តំណែងជាឧបនាយករដ្ឋមន្ត្រី ហើយជាមិត្តជិតស្និទ្ធរបស់គាត់ ។ ខ្ញុំឮគេថា ដំបូងឡើងគឺ អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមត៖ទេ ដែលជាអ្នកផ្តួចផ្តើមធ្វើរដ្ឋប្រហារនោះ ។ ខ្ញុំពុំបានដឹងច្បាស់លាស់ដោយលំអិតនៃកិច្ចប្រតិបត្តិការធ្វើរដ្ឋប្រហារនោះទេ ។ ខ្ញុំក៏មិនបានដឹងថាអ្នកអង្គ

[41] អ្នកខ្លះហៅថាព្រះអង្គម្ចាស់ ក៏ប៉ុន្តែតាមការផ្ទៀងផ្ទាត់ ព្រះអង្គមានបិតាជាស្តេចឯមាតាជារាស្ត្រ ដូច្នេះអាចហៅត្រឹមអ្នកអង្គម្ចាស់ សិរិមត៖ ។

ម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ ជិតស្និទ្ធជាមួយសម្តេច សីហនុ ដល់កំរិតណា ឬ ទំនាក់ទំនងជាមួយលោក លន់ នល់ បែបណាទេនាសម័យនោះ ។ តាមសៀវភៅប្រវត្តិសាស្ត្រ ខ្ញុំគ្រាន់តែដឹងថាលោក លន់ នល់ និង អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ ជាអ្នកបង្កើតគណបក្សនយោបាយមួយក្នុងទសវត្សរ៍ឆ្នាំ ១៩៤០ ឈ្មោះគណបក្សខេមរៈបុណ្យការ ។

សិរិមតៈ និង ជម្លោះក្នុងរាជវង្ស?

អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ ជាសមាជិកមួយអង្គនៃព្រះរាជវង្សានុវង្ស ដែលធ្លាប់បានកាន់តំណែងជាច្រើនលើក ច្រើនគ្រាជារដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការក្នុងរាជរដ្ឋាភិបាលដូចជា នៅក្នុងក្រសួងការពារប្រទេស ក្រសួងអប់រំ ក្រសួងទេសចរណ៍ និង ឃោសនាការជាដើម ។ អ្នកអង្គម្ចាស់ និង សម្តេច សីហនុ ជាបងប្អូនជីទួតមួយ ព្រោះទាំងពីរព្រះអង្គសុទ្ធតែជាចៅទួតរបស់ព្រះករុណាព្រះបាទ ស៊ីសុវត្ថិ ទាំងអស់ សម្តេច សីហនុ ខាងព្រះមាតា ឯអ្នកអង្គម្ចាស់ សិរិមតៈខាងព្រះបិតា ។ នៅឆ្នាំ ១៩៥២ នៅពេលដែលព្រះករុណាព្រះបាទ នរោត្តម សីហនុ ដឹកនាំព្រះរាជបូជនីយកិច្ចដើម្បីឯករាជ្យនោះ អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ[42] កំពុងកាន់តំណែងជារដ្ឋលេខាធិការក្រសួងការពារជាតិ ។

កាលពីសម័យមុន ខ្មែរយើងភាគច្រើនក៏ធ្លាប់បានដឹងថា នៅក្នុងក្រុមរាជ

[42] Ministère de l'Information, Documents, Cabinets Ministériels Khmers, du 18 mars 1945 au 18 mars 1970, op. cit, page 34. ក្នុងគណៈរដ្ឋមន្ត្រីទី១៨ ដឹកនាំដោយព្រះករុណាព្រះបាទ នរោត្តម សីហនុ ពីថ្ងៃទី ២៤ មករា ដល់ ២៨ កក្កដា ១៩៥៣ អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ បានឡើងកាន់តំណែងជារដ្ឋមន្ត្រីក្រសួងការពារជាតិ និង ក្រសួងប្រៃសណីយ និងទូរគមនាគមន៍ តាមឯកសារដដែលទំព័រ ៣៥ ។

រង្សានុវង្សមានការខ្វែងយោបល់គ្នា ឬ មិនចុះសំរុងគ្នាក្នុងការឡើងគ្រងរាជសម្បត្តិ ។ ជាទូទៅគេដឹងថា នៅប្រទេសយើង មានខ្សែរាជវង្សពីរចេញពីព្រះបាទ អង្គឌួង ដែលអាចឡើងសោយរាជ្យបានគឺ ខ្សែព្រះបាទ នរោត្តម មួយ និង មួយទៀត ខ្សែរបស់ព្រះបាទ ស៊ីសុវត្ថិ ។ សម្តេច សីហនុ ទ្រង់ប្រសូតចេញពីខ្សែទាំងពីរគឺ ខ្សែព្រះ នរោត្តម តាមរយៈព្រះបិតា និង ខ្សែព្រះ ស៊ីសុវត្ថិ តាមរយៈព្រះមាតារបស់ព្រះអង្គ ។

ព្រះបាទ អង្គឌួង បានត្រូវទទួលស្គាល់ថា ជាអ្នកគ្រប់គ្រងដែនដីខ្មែរនៅឆ្នាំ ១៨៤៥ ។ ព្រះអង្គបានឡើងគ្រងរាជសម្បត្តិជាផ្លូវការជាព្រះមហាក្សត្រនៅឆ្នាំ ១៨៤៨ បន្ទាប់ពីពេលដែលប្រទេសសៀម និង អាណ្ណាម (ក្រោយមកហៅថា ថៃ និង វៀតណាម) បានបន្តយការប្រកួតប្រជែងគ្នា ក្នុងការដណ្តើមឥទ្ធិពលលើប្រទេសខ្មែរ ។

ព្រះបាទ អង្គឌួង[43] ជាព្រះមហាក្សត្រទី១ ដែលបានផ្តួចផ្តើមគំនិតចង់ឲ្យបារាំងមកជួយការពារខ្មែរ ចេញពីឥទ្ធិពលរបស់ប្រទេសជិតខាងទាំងពីរ ជាពិសេសពីប្រទេសសៀមនៅសម័យនោះ ។ ទំនាក់ទំនងរបស់ព្រះបាទ អង្គឌួង ដើម្បីបញ្ចប់ឥទ្ធិពលសៀមមកលើកម្ពុជា បានចាប់ផ្តើមនៅឆ្នាំ ១៨៥៣ ដោយការបញ្ជូនមន្ត្រីជាន់ខ្ពស់ខ្មែរពីររូបឈ្មោះ កុយ និង ប៉ែន (ដែលមានខ្សែលោហិតពីជនជាតិព័រទុយហ្គាល់) ទៅកាន់សិង្ហបុរីជាសម្ងាត់ ដើម្បីនាំព្រះរាជសារទៅជូនមន្ត្រីកុងស៊ុលបារាំង ដែលត្រូវបញ្ជូនបន្តទៅថ្វាយព្រះចៅអធិរាជបារាំង ណាប៉ូឡេអុងទី៣ (Napoleon III)[44] ។ បន្ទាប់មក លោក សាល ដឺ ម៉ុងទីញ៉ (Charles de Montigny) អ្នកការទូតបារាំងដែលបានមកដល់កំពង់ផែកំពត នៅថ្ងៃទី ១៨ តុលា

[43] អេង-សុត, ឯកសារមហាបុរសខ្មែរ - ផែនដីព្រះអង្គឌួង - ភ្នំពេញ ១៩៦៩ ទំព័រ១០៧០-១០៩៧ ។

[44] Khin Sok, Le Cambodge entre le Siam et le Vietnam (de 1775 à 1860), Ecole Française d'Extrême-Orient, Paris, 1991, p. 149. ក្នុងសៀវភៅនេះ មិនមាននិយាយពីងារពិតប្រាកដរបស់មន្ត្រីទាំងពីររូបនេះទេ ក៏ប៉ុន្តែជាការដាក់ស្តែង

១៨៥៦ នោះ បានតាក់តែងអត្ថបទអនុសញ្ញាពាណិជ្ជកម្ម និង សាសនា ដើម្បីស្ថាបនាទំនាក់ទំនងជាមួយកម្ពុជា ។ ប៉ុន្តែដោយមានការគាបសង្កត់ពីសៀមព្រះបាទ អង្គឌួង មិនបានយាងទៅឡាយព្រះហស្តលេខាលើអនុសញ្ញានោះឡើយ ។ នេះជាការប៉ុនប៉ងលើកដំបូងរបស់ព្រះរាជាខ្មែរ ក្នុងការបញ្ចប់ឥទ្ធិពលសៀមមកលើកម្ពុជាប៉ុន្តែមិនបានសម្រេច[45] ។ សន្ធិសញ្ញាអាណាព្យាបាលត្រូវបានចុះហត្ថលេខា នៅថ្ងៃទី ១១ សីហា ១៨៦៣ នៅព្រះរាជវាំងឧដុង្គ រវាងព្រះបាទ នរោត្តម និង លោកឧត្តមនាវី ដឺឡាក្រង់ឌីយ៉ែ (De la Grandière) ដែលជាទេសាភិបាលបារាំងនៅកូសាំងស៊ីន (Gouverneur de la Cochinchine) ។

ព្រះបាទ អង្គឌួង មានព្រះរាជបុត្រាបីព្រះអង្គ ដែលប្រសូតចេញពីព្រះមហេសីផ្សេងៗគ្នាគឺ ព្រះបាទ នរោត្តម ព្រះបាទ ស៊ីសុវត្ថិ និង ព្រះអង្គម្ចាស់ស៊ីវត្តា ។ ក៏ប៉ុន្តែ មានតែព្រះរាជវង្សរបស់ព្រះបាទ នរោត្តម និង ព្រះបាទ ស៊ីសុវត្ថិទេ ដែលអាចឡើងគ្រងរាជសម្បត្តិបាន ដោយហេតុថា ព្រះអង្គម្ចាស់ ស៊ីវត្តា ធ្លាប់បានធ្វើការបះបោរប្រឆាំងព្រះបាទ នរោត្តម ។ តាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មានតែព្រះរាជវង្សានុវង្ស ដែលចេញមកពីខ្សែព្រះរាជបុត្រច្បងទាំងពីរព្រះអង្គនៃព្រះបាទ អង្គឌួង នោះទេ ដែលអាចឡើងគ្រងរាជសម្បត្តិបាន ។ ក្រោយមករដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ក៏បានចែងដូចរដ្ឋធម្មនុញ្ញមុននេះដែរ ក្នុងការឡើងគ្រងរាជសម្បត្តិ ។

តាមប្រពន្ធ័រាជានិយមនៃប្រទេសកម្ពុជាយើង គេពុំបានកំណត់ឲ្យមានរាជឱរសស្នងរាជ្យ (Prince héritier) ដែលអាចឡើងគ្រងរាជសម្បត្តិដោយស្វ័យប្រវត្ត

មន្ត្រីជាន់ខ្ពស់ថ្នាក់នេះសុទ្ធតែមានងារ យ៉ាងហោចណាស់ក៏ថ្នាក់ស្មើឧកញ៉ាដែរ ។ នៅក្នុងឯកសារមហាបុរស គេអាចឃើញមានឧកញ៉ាពិភក្តិមន្ត្រី កុយ មួយរូបដែរ ក្នុងរដ្ឋកាលព្រះបាទ អង្គឌួង ។

[45] សិន សំណាង, អនុសញ្ញាពាណិជ្ជកម្ម និង សាសនា ថ្ងៃទី ១៨ តុលា ១៨៥៦ នៅក្នុងទស្សនាវដ្តីរាជបណ្ឌិតសភាកម្ពុជា លេខ ១ ឆ្នាំ ២០០២ ទំព័រ ៨៤-៩៣ ។

ជាព្រះមហាក្សត្រថ្មី នៅពេលដែលព្រះមហាក្សត្រគ្រងរាជ្យទ្រង់ចូលទីវង្គតនោះឡើយ ។ តាមប្រព័ន្ធបែបនេះ នៅពេលដែលព្រះមហាក្សត្រគ្រងរាជ្យសុគត ក្រុមប្រឹក្សារាជសម្បត្តិជាអ្នកជ្រើសរើសព្រះមហាក្សត្រថ្មី ក្នុងចំណោមព្រះអង្គម្ចាស់ទាំងឡាយ ដែលចេញមកពីខ្សែទាំងពីរនៃព្រះរាជវង្សានុវង្សនេះ ។ នេះជាប្រព័ន្ធរាជាធិបតេយ្យជ្រើសតាំង (Monarchie élective) ។ មានតែព្រះអង្គម្ចាស់ទេដែលមានសិទ្ធិជាបេក្ខជនក្នុងតំណែងព្រះមហាក្សត្រ ចំណែកឯព្រះអង្គម្ចាស់ក្សត្រីពុំមានសិទ្ធិឡើងគ្រងរាជសម្បត្តិឡើយ ។

គួររំលឹកថា ក្រៅពីព្រះនាង លីវ យី ឬ ព្រះនាង សោមា ដែលជាព្រះមហាក្សត្រីយានីដំបូងនៃសម័យនគរភ្នំ (សតវត្សទី១ ដល់គ.ស. ៥៥០) ក៏មានព្រះមហាក្សត្រីយានីពីរអង្គទៀតគឺព្រះនាង ជ័យទេវី នៅចុងសម័យចេនឡា (គ.ស. ៥៥០-៨០២) និង ព្រះអង្គម្ចាស់ក្សត្រីព្រះនាម អង្គមី បានឡើងសោយរាជ្យមួយរយៈដែរ នៅចុងសម័យឧដុង្គ ។ ប្រហែលដោយសារមានបទពិសោធន៍ដ៏ជូរចត់តាំងពីពេលនោះមក ទើបព្រះអង្គម្ចាស់ក្សត្រីលែងមានសិទ្ធិឡើងគ្រងរាជ្យជារៀងរហូត ។ តាមប្រព័ន្ធ ដែលគ្មានការចាត់តាំងរាជឱរសស្នងរាជ្យឲ្យឡើងគ្រងរាជ្យដោយស្វ័យប្រវត្តនេះ បានធ្វើឲ្យព្រះអង្គម្ចាស់ទាំងឡាយ អាចក្លាយជាបេក្ខជនព្រះមហាក្សត្របាន ។ ព្រះបុត្រាមួយអង្គៗអាចមានសិទ្ធិឡើងគ្រងរាជ្យ មានសិទ្ធិអំណាចប្រហាក់ប្រហែលគ្នាគឺ គ្មានអង្គណាធំជាងអង្គណាពេកទេ ។ ម្យ៉ាងទៀត ព្រះក្សត្រាទាំងនោះ ក៏តែងមានមន្ត្រីធំ មេទ័ព ឬ អ្នកមានឥទ្ធិពលជាមនុស្សជំនិតរៀងៗខ្លួន ។ មនុស្សជំនិត ទាំងនោះ ក៏តែងខឹតខំប្រណាំងប្រជែងគ្នាជំរុញបេក្ខជនដែលគេគាំទ្ររៀងៗខ្លួនឲ្យបានឡើងសោយរាជ្យ ។ ទាំងនេះក៏អាចនាំឲ្យមានជម្លោះរាជបល្ល័ង្កជាញឹកញាប់ដែរ ។ ប៉ុន្តែប្រព័ន្ធនេះ ក៏មានចំណុចវិជ្ជមានដែរ ប្រសិនបើការជ្រើសរើសនោះ ប្រព្រឹត្តទៅដោយយុត្តិធម៌ ព្រោះការជ្រើសរើសដោយការស្រុះ

ស្រួលមូលមតិគ្នា នៅក្នុងក្រុមប្រឹក្សារាជសម្បត្តិជាសមូហភាពទៅលើបេក្ខភាពដែលមានគុណសម្បត្តិខ្ពស់ជាងគេ ក៏ជាការចាប់បង្ខំឲ្យភាគីពាក់ព័ន្ធក្នុងការជ្រើសរើសនោះ ដែលភាគច្រើនសុទ្ធតែជាអ្នកមានឥទ្ធិពលនៅក្នុងព្រះរាជាណាចក្រ គ្មានលេស ឬ ហេតុផលអ្វីក្រៅពីទទួលយកសេចក្តីសម្រេចទាំងអស់គ្នាតែប៉ុណ្ណោះ ។

ដូច្នេះដោយយោងលើចំណុចវិជ្ជមាននេះ ទើបការស្នងរាជសម្បត្តិនៅប្រទេសកម្ពុជាយើង បានស្ថិតនៅក្នុងប្រព័ន្ធជ្រើសតាំង ដែលអាចហៅថាតាមបែបប្រជាធិបតេយ្យក៏បាន ។ ក៏ប៉ុន្តែជួនកាលក៏មានករណីពិសេស ដែលព្រះមហាក្សត្រគ្រងរាជ្យ នៅពេលហៀបនឹងសុគត ផ្តាំផ្ញើឲ្យព្រះរាជបុត្រអង្គណាមួយឡើងសោយរាជ្យតពីព្រះអង្គទៅ ។ ក្នុងករណីនេះ ព្រះក្សត្រាអង្គនោះនឹងអាចក្លាយជាអ្នកស្នងរាជសម្បត្តិបាន ។ ជាទម្លាប់ព្រះមហាក្សត្រគ្រងរាជ្យនោះ តែងជ្រើសរើសព្រះរាជបុត្រច្បង ក្នុងចំណោមព្រះរាជបុត្រច្រើនអង្គ ។ គួរកត់សំគាល់ថាព្រះមហាក្សត្រមួយអង្គៗតែងមានព្រះមហេសីច្រើនអង្គ ដូច្នេះទើបព្រះអង្គតែងតាំងព្រះមហេសីមួយអង្គឲ្យធ្វើធំជាងគេ លើព្រះមហេសីឯទៀត ជាព្រះរាជអគ្គមហេសី ។ ដោយសារព្រះមហាក្សត្រមានព្រះមហេសីច្រើនព្រះអង្គ ព្រះអង្គក៏មានព្រះរាជបុត្រា និងបុត្រីច្រើនអង្គដែរ ។

នៅពេលព្រះបាទ នរោត្តម សុគតនៅឆ្នាំ ១៩០៤ ការប្រជុំក្រុមប្រឹក្សារាជសម្បត្តិ ដែលនៅក្រោមអធិបតីភាពរបស់លោករេស៊ីដង់ជាន់ខ្ពស់ (Résident supérieur) បារាំង បានជ្រើសរើសសម្តេចព្រះ ស៊ីសុវត្ថិ ជាព្រះអនុជ ឬ ប្អូនឲ្យឡើងសោយរាជ្យជាបន្ត ។ ក្រោយមកទៀត មុននឹងព្រះអង្គចូលទីវង្គត ព្រះករុណាព្រះបាទ ស៊ីសុវត្ថិ បានបន្សល់ទុកនូវមតកសាសន៍ (Testament)[46] ឬ បណ្តាំ

[46] Sorn Samnang, L'évolution de la société cambodgienne entre les deux guerres mondiales (1919-1939), op.cit, pp. 93-95.

ជាលាយលក្ខណ៍អក្សរ សម្រាប់ឲ្យក្រុមប្រឹក្សារាជសម្បត្តិជ្រើសតាំងព្រះរាជបុត្រ របស់ព្រះអង្គគឺ សម្តេចព្រះ មុនីវង្ស ឲ្យគ្រងរាជ្យជាព្រះមហាក្សត្រជំនួសតទៅ ទៀត ។ នៅមុនពេលដែលព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស សុគត ទ្រង់ផ្តាំផ្ញើឲ្យរាជបុត្រ ព្រះអង្គព្រះនាមព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មុនីរ៉ែត ឡើងគ្រងរាជ្យជំនួសតទៅទៀតគឺ បំភ្លេចខ្សែព្រះ នរោត្តម ចោលទាំងស្រុងតែម្តង ។ ក៏ប៉ុន្តែ អាជ្ញាធរបារាំងប្រឆាំងនឹង ការផ្ទេររាជសម្បត្តិនេះ ។ ប្រសិនបើគ្មានការប្រឆាំង ពីអាជ្ញាធរបារាំងទេនោះ ប្រហែលជាព្រះរាជវង្សខ្សែព្រះ ស៊ីសុវត្ថិ នឹងត្រូវបន្តសោយរាជ្យតទៅទៀត ។ សម្តេច សីហនុ បានទទួលស្គាល់អំពីទំនាស់រាជវង្សនេះ ។ នៅក្នុងសៀវភៅ ដែល ព្រះអង្គទ្រង់និពន្ធក្នុងឆ្នាំ ១៩៧២ ក្រោមចំណងជើងថា "សេ អ៊ី អា ប្រឆាំង ប្រទេសកម្ពុជា" សម្តេច សីហនុ បានទំលាក់កំហុសទៅលើរដ្ឋាភិបាលអាណាព្យា បាលបារាំង ពាក់ព័ន្ធទៅនឹងការឡើងសោយរាជ្យរបស់ព្រះអង្គ ដោយលើកឡើងថា បារាំងជាអ្នកបង្កឲ្យមានការបែកបាក់ក្នុងព្រះរាជវង្ស ។ តាមពិត ពួកបារាំងយល់ថា ត្រូវបង្វែរាជបល្ល័ង្កនេះទៅខ្សែព្រះ នរោត្តម ម្តងវិញ ។ បារាំងបានជ្រើសរើសផ្លូវ កណ្តាល ដើម្បីជៀសវាងកុំឲ្យមានការធ្ងន់ស្រាលទៅខ្សែព្រះរាជវង្សណាមួយ ។ ដូច្នេះហើយបានជានៅឆ្នាំ ១៩៤១ នៅពេលដែលព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស ទ្រង់ចូលទីវង្គតនោះ បារាំងបានសម្លឹងឃើញបេក្ខភាពរបស់ព្រះអង្គម្ចាស់ សីហនុ ក្នុងការឡើងគ្រងរាជសម្បត្តិជាបន្ត ។

ព្រះអង្គម្ចាស់ សីហនុ មានព្រះជន្ម ១៩ ព្រះវស្សាតែប៉ុណ្ណោះ គ្មានបទ ពិសោធន៍ក្នុងឆាកនយោបាយនៅឡើយទេ ដែលបារាំងជឿថាពួកគេអាចមាន ឥទ្ធិពលលើព្រះអង្គ ឬ អាចញាក់ខ្សែឲ្យព្រះអង្គធ្វើតាមបំណងបាន ។ ព្រះអង្គម្ចាស់ សីហនុ មានបិតាជាខ្សែព្រះ នរោត្តម និង ព្រះមាតាជាខ្សែព្រះ ស៊ីសុវត្ថិ ។ សម្តេច សីហនុ ជាព្រះរាជបុត្ររបស់ព្រះបាទ នរោត្តម សុរាម្រឹត ដែលមានព្រះបាទ

នរោត្តម ជាព្រះឯយ្យកោ ឬ ជីតា ។ សម្តេច សីហនុ ក៏ជាព្រះរាជបុត្ររបស់សម្តេច ព្រះមហាក្សត្រីយានី ស៊ីសុវត្ថិ កុសុមៈ ដែលជាព្រះរាជបុត្រីរបស់ព្រះករុណាព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស ឬ ដែលមានព្រះបាទ ស៊ីសុវត្ថិ ជាព្រះឯយ្យកោផងដែរ ។ ការជ្រើសរើសយកព្រះអង្គម្ចាស់ នរោត្តម សីហនុ ជាព្រះមហាក្សត្រ និង ការជំរុះបេក្ខភាពរបស់ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មុនីរ៉ែត នោះបានធ្វើឲ្យព្រះរាជវង្សានុវង្សខ្សែខាងព្រះ ស៊ីសុវត្ថិ មានការមិនពេញចិត្ត ។ គួរបញ្ជាក់ថាព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មុនីរ៉ែត ជាព្រះអនុជបង្កើត ឬ ប្អូនបង្កើតរបស់ព្រះមហាក្សត្រីយានី ស៊ីសុវត្ថិ កុសុមៈ ព្រះមាតារបស់សម្តេច សីហនុ ដូច្នេះ ព្រះអង្គជាព្រះមាតុលា ឬ ឪពុកមាខាងម្តាយរបស់សម្តេច សីហនុ ។ ព្រះអងម្ចាស់ ស៊ីសុវត្ថិ មុនីរ៉ែត មានព្រះហានៈជាសម្តេចក្រុមព្រះ រហូតដល់ព្រឹត្តិការណ៍ ១៨ មីនា ១៩៧០ ។

បើតាមសម្តេច សីហនុ អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ ដែលជាខ្សែព្រះ ស៊ីសុវត្ថិ គាំទ្របេក្ខភាពព្រះ ស៊ីសុវត្ថិ មុនីរ៉ែត ក្នុងតំណែងព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ។ ដូច្នេះ ការឡើងសោយរាជ្យរបស់ព្រះករុណា នរោត្តម សីហនុ បានធ្វើឲ្យអ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ កើតក្តីទោមនស្ស ។ ព្រឹត្តិការណ៍ ១៨ មីនា ១៩៧០ អាចបកស្រាយថាជាការសងសឹកនៃខ្សែព្រះ ស៊ីសុវត្ថិ ប្រឆាំងនឹងខ្សែព្រះនរោត្តម គឺ អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ ប្រឆាំងនឹងសម្តេចព្រះ នរោត្តម សីហនុ ។

នៅក្នុងសៀវភៅដដែលនោះ សម្តេច សីហនុ ទ្រង់បានបញ្ជាក់នូវប្រតិកម្មទីមួយចំពោះរដ្ឋប្រហារ ១៨ មីនា ១៩៧០ ដូចតទៅនេះ៖ "គ្មានអ្វីធ្ងល់ចំពោះខ្ញុំទេ ដែលថាអ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ ជាអ្នកធ្វើរដ្ឋប្រហារនោះ[47] ។ អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ មានការស្អប់ខ្ពើមខ្ញុំតាំងពីតូចមកម្ល៉េះ ព្រោះគេជឿថាខ្ញុំមិនត្រូវ

[47] Norodom Sihanouk, La C.I.A. contre le Cambodge, op.cit, p. 19.

ឡើងសោយរាជ្យទេ ព្រោះរាជសម្បត្តិត្រូវធ្លាក់ទៅសម្តេច ស៊ីសុវត្ថិ មុនីរ៉ែត ដែលត្រូវជាឪពុកមារបស់គេ" ។ ជាច្រើនឆ្នាំក្រោយមកក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ នៅភាពជាជនភៀសខ្លួន ខ្ញុំបានស្គាល់គូស្វាមីភរិយាមួយគូ ដែលព្រះស្វាមីជាព្រះបុត្រានៃអ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ និង ព្រះមហេសីជាបុត្រីនៃសម្តេច នរោត្តម សីហនុ ។ ខ្ញុំនឹកក្នុងចិត្តថាខ្សែនៃព្រះរាជវង្សានុវង្សទាំងពីរ បានស្រុះស្រួលជានានឹងគ្នាវិញហើយ ។

សម្តេច សីហនុ លែងទុកចិត្តអាមេរិក

គួររំលឹកថា នៅមុនរដ្ឋប្រហារថ្ងៃ ១៨ មីនា នោះ មានក្រុមអ្នកនយោបាយមួយចំនួនដែលមិនពេញចិត្តចំពោះនយោបាយដឹកនាំរបស់សម្តេច សីហនុ ក្នុងរយៈពេលកន្លងមក ។ នៅឆ្នាំ ១៩៥៥ បន្ទាប់ពីព្រះអង្គបានបង្កើតចលនានយោបាយរបស់ព្រះអង្គដែលមានឈ្មោះថា"សង្គមរាស្ត្រនិយម" និង បន្ទាប់ពីបានជម្រុះចោលនូវគណបក្សនយោបាយមួយចំនួននោះមក តាមរយៈការបោះឆ្នោតប្រជាមតិ ឬបាតុកម្មនានានោះ សម្តេច សីហនុ បានធ្វើការដឹកនាំប្រទេសតាមរបៀបមួយបែបផ្ទាល់របស់ព្រះអង្គ ។

នៅឆ្នាំ ១៩៦៣ សម្តេចធ្វើជាតូបនីយកម្មវិស័យធនាគារ ធានារ៉ាប់រង ការនាំចេញនាំចូល និង ផ្នែកឧស្សាហកម្មមួយចំនួនទៀត ។ សម្តេចបានបង្កើតក្រុមហ៊ុនរដ្ឋជាច្រើន ក្នុងនោះមានក្រុមហ៊ុនសុរាគារខ្មែរ និង រោងចក្រធ្វើកែវ ដែលខ្ញុំបានចូលធ្វើការដំបូងនាចុងឆ្នាំ ១៩៦៨ ។ សម្តេច សីហនុ បានកាត់ទំនាក់ទំនងជាមួយសហរដ្ឋអាមេរិក ដែលធ្វើឲ្យប្រទេសយើងបាត់បង់នូវជំនួយយោធា និងសេដ្ឋកិច្ចរបស់ប្រទេសមហាអំណាចនោះ ។ សម្តេចបានរឹតចំណងមេត្រីភាពជាមួយប្រទេសកុម្មុយនីស្តដូចជា ប្រទេសចិន សហភាពសូវៀត ប្រទេសអឺរ៉ុបខាង

កើត ប្រទេសគុយបា កូរ៉េខាងជើង វៀតណាមខាងជើង និង វៀតកុង ។ ក្នុងផ្នែក លោកខាងលិច សម្តេចបានធ្វើការពង្រឹងចំណងមេត្រីភាពជាមួយបារាំង ដែលទ្រង់ យកមកជំនួសសហរដ្ឋអាមេរិក ។ ព្រះអង្គមានការគោរពយ៉ាងខ្លាំងចំពោះលោក ឧត្តមសេនីយ ដឺហ្គោល[48] ។

សម្តេច សីហនុ មានហេតុផលក្នុងការប្រឆាំងនឹងសហរដ្ឋអាមេរិក និង សម្ពន្ធមិត្តរបស់គេគឺ ប្រទេសវៀតណាមខាងត្បូង និង ប្រទេសថៃ ដែលបានគាំទ្រ ក្រុមបះបោរប្រឆាំងព្រះអង្គមួយក្រុមមានឈ្មោះថាក្រុមខ្មែរសេរី ។ ក្រុមខ្មែរសេរី ធ្វើ វិទ្ធង្សនាប្រឆាំងព្រះអង្គនៅតាមទល់ដែនខ្មែរ-ថៃ និង ខ្មែរ-វៀតណាមខាងត្បូង ។ ចលនាខ្មែរសេរីនេះ ដឹកនាំដោយលោក សឺង ង៉ុកថាញ់ ដែលត្រូវបានតែងតាំងជា នាយករដ្ឋមន្ត្រីនៅឆ្នាំ ១៩៤៥ ដោយសារកងទ័ពជប៉ុន ដែលចូលមកដណ្តើមបាន អំណាចមួយរយៈពេលយ៉ាងខ្លីពីបារាំង នៅក្នុងប្រទេសកម្ពុជា ។ បន្ទាប់មកលោក សឺង ង៉ុកថាញ់ ត្រូវបានបារាំងចាប់ដាក់គុក ។ ក្រោយមកគាត់បានភៀសខ្លួនទៅ ប្រទេសវៀតណាម ។ នៅទសវត្សរ៍ឆ្នាំ ១៩៥០ លោក សម សារី ដែលធ្លាប់ជាជំ នួយការដ៏ជិតស្និទ្ធម្នាក់របស់សម្តេច សីហនុ នៅពេលបង្កើតចលនាសង្គមរាស្ត្រ និយមនោះ ក៏បានរត់ទៅចូលរួមជាមួយនឹងលោក សឺង ង៉ុកថាញ់ ។ សូមរំលឹកថា លោក សម សារី ជាឪពុករបស់លោក សម រង្ស៊ី ដែលជាមេគណបក្សប្រឆាំងមួយ នៅក្នុងប្រទេសកម្ពុជា ។

កាលសម័យនោះ ក៏មានគំរោងការបះបោររបស់លោក ដាប ឈួន ឈ្មោះ ផ្លូវការ ឈួន ម្ទុលពេជ្រ ស្តេចត្រាញ់មួយរូប នៅខេត្តសៀមរាប ដោយមានការពាក់

[48] Charles de Gaulle (22 November 1890 – 9 November 1970) founded the French Fifth Republic in 1958 and served as its first President from 1959 to 1969. លោក ដឺហ្គោល ជាឧត្តមសេនីយ និង រដ្ឋបុរសបារាំង ដែលបានដឹកនាំ កងកម្លាំងបារាំងសេរី ប្រឆាំងកងទ័ពអាឡឺម៉ង់នៅសង្គ្រាមលោកលើកទី២ ។ លោកជាស្ថាបនិកនៃសាធារណរដ្ឋបារាំងទី៥ និង ជាប្រធានាធិបតីទី១នៃសាធារណរដ្ឋនេះ ពីឆ្នាំ ១៩៥៩ ដល់ ១៩៦៩ ។

ព័ន្ធជាមួយសហរដ្ឋអាមេរិក ប្រទេសវៀតណាមខាងត្បូង និង ប្រទេសថៃ ។ គំរោងក្បត់របស់លោក ជាប ឈួន បានត្រូវរំកិលមុខ ហើយលោក ជាប ឈួន ក៏ត្រូវបានសំលាប់ក្នុងកិច្ចប្រតិបត្តិយោធាមួយដែលដឹកនាំឡើងដោយលោក លន់ នល់ ។ នៅសម័យនោះ លោក លន់ នល់ ជាមនុស្សម្នាក់ដែលបានទទួលការទុកចិត្តយ៉ាងខ្លាំងពីសម្តេច នរោត្តម សីហនុ ។

មានគំរោងការមួយទៀតក្នុងការធ្វើឃាតសម្តេចព្រះ នរោត្តម សីហនុ និងព្រះវរបិតា ព្រមទាំងព្រះវរមាតារបស់ព្រះអង្គ ដោយក្រុមសម្ព័ន្ធមិត្តរបស់សហរដ្ឋអាមេរិក ។ គំរោងប៉ុនប៉ងធ្វើឃាតនោះ បានកើតឡើងនៅថ្ងៃទី ៣១ សីហា ១៩៥៩ ។ នៅពេលនោះ មានការនាំយកមកថ្វាយព្រះករុណាព្រះបាទ សុរាម្រឹត និង សម្តេចព្រះមហាក្សត្រយានី កុសុមៈ នូវដង្វាយដែលគេដាក់ក្នុងប្រអប់លាបម្រ័ក្សណ៍ខ្មុកពីរយ៉ាងខ្មៅរលោង ។ ព្រះអង្គម្ចាស់ វក្កគិរិវិណ្ណ ប្រធានព្រះរាជពិធីការបានបើកប្រអប់ទីមួយ រំពេចនោះប្រអប់ម្រ័ក្សណ៍ខ្មុកក៏ផ្ទុះឡើងភ្លាម ធ្វើឲ្យព្រះអង្គម្ចាស់សុគត ព្រមគ្នាជាមួយមន្ត្រីព្រះបរមរាជវាំងម្នាក់ទៀតនៅនឹងកន្លែង ។ ជាសំណាងល្អ ព្រះករុណាព្រះបាទ សុរាម្រឹត និង សម្តេចព្រះមហាក្សត្រយានី បានរួចព្រះជន្មផុតពីការប៉ុនប៉ងធ្វើគត់នេះ ដោយសារតែព្រះអង្គទាំងពីរ ទ្រង់ជាប់រវល់នៅក្នុងបន្ទប់ផ្សេងទៀតនៃព្រះរាជដំណាក់នៅក្បែរទីកើតហេតុនោះ ។ កាលនោះ ព្រះមហាក្សត្រ និងព្រះមហាក្សត្រយានីទ្រង់កំពុងប្រទានព្រះរាជសារនាការចំពោះលោក សឺន សាន អគ្គទេសាភិបាលនៃធនាគារជាតិកម្ពុជា និង ជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសដែលបានចូលមកក្រាបថ្វាយបង្គំលា មុននឹងចេញដំណើរទៅបំពេញបេសកម្មនៅក្រៅប្រទេស ។ ម្តែផ្នាំក្រោយមក លោក សឺន សាន បានក្លាយជាប្រធានចលនាតស៊ូប្រឆាំងវៀតណាម និង ជាប្រធានចលនាតស៊ូរបស់ខ្ញុំ ហើយបានរៀបរាប់ពីព្រឹត្តិការណ៍នេះប្រាប់ពួកយើង ។

ការកើតឡើងជាញឹកញាប់នូវផែនការក្បត់ ឬ ផែនការធ្វើឃាតព្រះអង្គ ដោយពួកខ្មែរសេរី ដោយមានកំស្តុតាងជាប់ពាក់ព័ន្ធជាមួយសហរដ្ឋអាមេរិក និង ប្រទេសលោកខាងលិចខ្លះ ជាហេតុផលនាំឲ្យព្រះអង្គលែងទុកចិត្តអាមេរិក ។ ចំណែកសហរដ្ឋអាមេរិក នៅសម័យនោះ ត្រូវការស្វែងរកនូវសម្ព័ន្ធភាពរឹងមាំរបស់ខ្លួននៅកម្ពុជា ដែលមាននិន្នាការស្រឡាញ់លោកសេរី ប្រឆាំងកុម្មុយនីស្ត និង ដែលសុខចិត្តជាក់ខ្លួនជារណបអាមេរិក ។ ក្រុមអ្នកនយោបាយខ្មែរដែលមាននិន្នាការទៅរកសហរដ្ឋអាមេរិកនេះ ត្រូវសម្តេច សីហនុ ឲ្យឈ្មោះថាពួកខ្មែរខៀវ ។ ពួកខ្មែរខៀវនោះ ក៏ត្រូវចោទប្រកាន់ថាជាពួកសាធារណរដ្ឋ ជាអ្នកផ្តួលរំលំរបបរាជានិយម ឬ ព្រះរាជបល្ល័ង្ក ដែលជាអំពើក្បត់ជាតិ ។ ខ្មែរខៀវណា ឬ អ្នកសាធារណរដ្ឋនិយមណា ដែលរកឃើញថាមានទំនាក់ទំនងជាមួយខ្មែរសេរីរបស់លោក សឺង ង៉ុកថាញ់ ត្រូវបានចាប់ដាក់គុក ឬ ត្រូវសម្លាប់ចោល ។

នៅសម័យនោះ សម្តេច សីហនុ បានលើកទឹកចិត្តឲ្យប្រជារាស្ត្រ ធ្វើការប្រឆាំងនឹងពួកខ្មែរសេរីយ៉ាងខ្លាំងក្លាបំផុត ។ នៅក្នុងការផ្សាយនៃវិទ្យុជាតិមានកម្មវិធីបើកឲ្យប្រជាពលរដ្ឋ មកស្រែកជេរប្រឆាំងនឹងពួកខ្មែរសេរីជារៀងរាល់ថ្ងៃ ។ ការស្រែកជេរតាមវិទ្យុជាតិនេះ ជាការប្រឆាំងតទល់នឹងការឃោសនារបស់វិទ្យុខ្មែរសេរីដែលវាយប្រហារសម្តេច សីហនុ ពីតំបន់ភ្នំដងរែក នៅតាមទល់ដែនខ្មែរ-ថៃ ។ បន្ទាប់ពីរដ្ឋប្រហារ ខែ មីនា ១៩៧០ លោក សឺង ង៉ុកថាញ់ បានត្រឡប់មកប្រទេសកម្ពុជាវិញ ហើយបានទទួលតំណែងជានាយករដ្ឋមន្ត្រីរបស់លោក លន់ នល់ នៅឆ្នាំ ១៩៧២ ។

ខ្មែរក្រហម និង ពួកបញ្ញវន្ត

ក្រៅពីពួកខ្មែរខៀវ សម្តេច សីហនុ ក៏បានលាបពណ៌ឲ្យអ្នកនយោបាយខ្មែរមួយក្រុមទៀត ដែលមានមនោគមវិជ្ជាគាំទ្រពួកកុម្មុយនីស្ត ឬ សង្គមនិយមជាពួកខ្មែរក្រហម "Khmer Rouge" ។ ក្នុងមជ្ឈដ្ឋានអន្តរជាតិ គេស្គាល់ពួកខ្មែរក្រហមនេះថាជា "Khmer Rouge" ព្រោះសម្តេចសីហនុ ធ្លាប់ប្រើឈ្មោះជាភាសាបារាំងនេះជារៀងរហូតមក ។ កាលក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ នោះ មានមនុស្សម្នាក់ដែលមានការចេះដឹងដ៏ល្អបង្គួរដែរ ហើយដែលមានស្រុកកំណើតនៅជាមួយខ្ញុំ និង មានអាយុច្រើនជាងខ្ញុំ បានសួរខ្ញុំថា អ្វីដែលហៅថាខ្មែរក្រហមនោះ ព្រោះតែគេមានមុខពណ៌ក្រហម ឬ ស្បែកពណ៌ក្រហម ឬ យ៉ាងណា? ខ្ញុំនឹកក្នុងចិត្តថា មនុស្សដែលមានការចេះដឹងប៉ុណ្ណឹងដែរ មិនគួរលើកយកសំណួរបែបនេះមកសួរខ្ញុំសោះ ព្រោះសំណួរនេះសំរាប់តែក្មេងមិនចេះដឹង ឬ អ្នកមិនចេះអក្សរទេ ។

នៅពេលដែលសម្តេច សីហនុ ខិតចូលជិតពួកប្រទេសកុម្មុយនីស្ត និង ដកព្រះអង្គឆ្ងាយចេញពីពួកលោកខាងលិច សម្តេចក៏ចាត់ឲ្យមានការចាប់ខ្មែរក្រហមដាក់គុកដែរ ។ បញ្ញវន្ត មានគ្រូបង្រៀន ឬ សាស្ត្រាចារ្យមួយចំនួនធំ បានត្រូវចាប់ខ្លួន និង ជាប់ឃុំឃាំងក្នុងពន្ធនាគារ ។ ក្នុងចំណោមនោះ ក៏មានឪពុកមាខ្ញុំម្នាក់ដែរ ដូចខ្ញុំបានរៀបរាប់នៅវគ្គមុនរួចហើយ ។ គាត់ត្រូវចាប់ខ្លួន និង ជាប់ឃុំឃាំងក្នុងពន្ធនាគារ ដោយសារតែគាត់បានទៅធ្វើការសិក្សាផ្នែកបច្ចេកទេសនៅប្រទេសចិនតែប៉ុណ្ណោះ ។ បញ្ញវន្តមួយចំនួនទៀតរត់គេចខ្លួនពីការចាប់ខ្លួន និង ចេញទៅរួមដៃគ្នាជាមួយពួកខ្មែរក្រហមនៅតាមមូលដ្ឋានសម្ងាត់របស់ពួកគេ ។ ពួកទាំងនោះ រាប់ទាំងមេខ្មែរក្រហមធំៗដូចជា ប៉ុល ពត ឬ សាឡុត ស ខៀវ សំផន សុន សេន អៀង សារី ហ៊ូ នឹម ហ៊ូ យន់ ជាដើម ។ លោក ខៀវ សំផន និង ដៃគូរបស់គាត់ពីរ

នាក់ទៀត បានបាត់ខ្លួនពីក្រុងភ្នំពេញនៅឆ្នាំ ១៩៦៧ ដែលនៅពេលនោះ មជ្ឈដ្ឋានទូទៅមានជំនឿថាអ្នកទាំងបីនាក់នោះ ត្រូវបានប៉ូលីសរបស់សម្តេច សីហនុ សម្លាប់ស្លាប់បាត់ទៅហើយ ។ បញ្ញវន្តដែលមាននិន្នាការសង្គមនិយម ដែលបានទៅសិក្សានៅប្រទេសបារាំងមួយចំនួនត្រូវបានពួកនិស្សិត ឬ សិស្សានុសិស្សមួយចំនួនធំទទួលស្គាល់ថាជាបញ្ញវន្តស្អាតស្អំ មានចិត្តស្រឡាញ់ជាតិ មានចិត្តគំនិតស្រឡាញ់បដិវត្តន៍ប្រឆាំងនឹងមនោគមវិជ្ជារបស់លោកខាងលិច ។ បញ្ញវន្តទាំងនោះ ខ្លះជាសាស្ត្រចារ្យ បានធ្វើការអប់រំណែនាំយើងក្មេងៗឲ្យស្អប់អារ្យធម៌លោកសេរី ឬ លោកខាងលិច ដែលគេចាត់ទុកជាពួកអាណានិគមនិយម និង ចក្រព័ត្រនិយមថ្មី ។ លោកគ្រូសាស្ត្រាចារ្យខ្លះអប់រំឲ្យយើងបោះបង់ចោលនូវអ្វីៗមកពីលោកខាងលិច ដូចជាប្រៀបធៀបថាបុិកគួករបស់យើង មានរសជាតិឆ្ងាញ់ជាងផ្លែប៉ោម ដែលមកពីប្រទេសលោកខាងលិចទៅទៀតគឺ ពួកគាត់ចង់អប់រំឲ្យយើងបោះបង់ ឬ កុំប្រើប្រាស់ផលិតផលប្រណិតដែលត្រូវនាំចូលពីបរទេស ។

នៅប្រទេសកម្ពុជាយើង នាសម័យនោះ ពិតពអ្នកនយោបាយមានចំនួនតិចតួចនៅឡើយ ក៏ប៉ុន្តែពួកគេបិតនៅក្នុងវណ្ណៈខ្ពស់ ដែលភាគច្រើននៅដាច់ពីប្រជាជន ។ ប្រជាពលរដ្ឋយើងដែលជាអ្នកស្រុកធម្មតា តែងតែគោរពអ្នកធំដែលគេជឿថាសុទ្ធតែបានសាងបុណ្យបារមីពីជាតិមុន ទើបបានជាមានភព្វសំណាងមកកើតជាអ្នកធំក្នុងជាតិនេះ ។ នៅសម័យនោះ គេសង្កេតឃើញបញ្ញវន្តយើងមានពីរប្រភេទគឺ បញ្ញវន្តមួយផ្នែក ដែលទទួលការសិក្សាក្នុងស្រុកខ្មែរតាមបែបព្រះពុទ្ធសាសនា និង បញ្ញវន្តមួយផ្នែកទៀត ដែលបានទទួលការសិក្សានៅបស្ចឹមប្រទេស ។

បញ្ញវន្តប្រភេទទីមួយ បិតនៅក្នុងចំណោមព្រះសង្ឃ ដែលបានសិក្សាធម៌វិន័យ ដែលគេអាចហៅថា "ធម៌ថ្មី"គឺជាអ្នករៀនសូត្រចេះចាំច្បាស់លាស់នូវព្រះត្រៃបិដក ហើយដែលអាចបកប្រែនូវធម៌របស់ព្រះសាម្មាសម្ពុទ្ធជាភាសាខ្មែរបានយ៉ាង

ច្បាស់លាស់ ។ បញ្ញវន្តទាំងនោះ មានជំនឿថាព្រះពុទ្ធ ព្រះអង្គមិនបានហាមប្រាម មិនឲ្យព្រះសង្ឃ ឬ ពុទ្ធបរិស័ទពាក់ពន្ធ័នឹងសកម្មភាពនយោបាយនោះទេ ។ ផ្ទុយទៅវិញ ពួកបញ្ញវន្តទាំងនោះជឿថា ការចូលរួមក្នុងសកម្មភាពនយោបាយជាការចូលរួមក្នុងការកសាងសន្តិភាព និង ធ្វើឲ្យប្រជាពលរដ្ឋទទួលសុភមង្គល ។ ពួកបញ្ញវន្តទាំងនោះ ធ្វើការរិះគន់ចំពោះអ្នកកាន់ធម៌ចាស់ ដែលមិនបានយល់ដឹងអំពីព្រះត្រៃបិដក ហើយដែលចេះតែសូត្រធម៌តាមៗគ្នាជាភាសាបាលី និង សំស្រ្តឹតដោយមិនយល់ដឹងពីខ្លឹមសារ ឬ ន័យពិតប្រាកដនៃពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធអង្គនោះឡើយ ។ ពួកគេចោទប្រកាន់ព្រះសង្ឃដែលចេះតែសូត្រមន្ត ប្រោះព្រំស្រោចទឹក ធ្វើយ័ន្ត និង គាថានោះថា ជាអ្នកប្រកាន់ធម៌ចាស់ ។ ក្នុងទសវត្សរ៍ឆ្នាំ ១៩៤០ គឺ ពួកព្រះសង្ឃធម៌ថ្មីនេះហើយ ដែលបាននាំគ្នាធ្វើបាតុកម្មប្រឆាំងនឹងបារាំង នៅតាមវិថីនានានៅទីក្រុងភ្នំពេញ ។ មិនត្រឹមតែប៉ុណ្ណោះទេ ព្រះសង្ឃទាំងនោះ ក៏បានធ្វើការទាមទារឲ្យមានសិទ្ធិសេរីភាពជូនប្រជាពលរដ្ឋដែរ ។ ដោយសារមានភាពផ្ទុយគ្នាពីលក្ខណៈអភិរក្សនេះហើយ ទើបបាតុកម្មទាំងប៉ុន្មានរបស់ព្រះសង្ឃទាំងនោះ ហាក់ដូចជាធ្វើឲ្យមានការប៉ះពាល់ដល់ព្រះរាជបល្ល័ង្ក ដែលជាបង្អែកមួយនៃព្រះពុទ្ធសាសនារបស់ខ្មែរ ។ បញ្ញវន្តប្រភេទនេះ មួយចំនួនធំបិតនៅជាប់ក្នុងរង្វង់អ្នកជាតិនិយមដូចជាៈ ព្រះគ្រូអាចារ្យ ហែម ចៀវ ព្រះភិក្ខុប៉ាង ខាត់ ព្រះភិក្ខុ ខៀវ ដុំ ជាដើម ឯមួយចំនួនទៀត ដើរតាមពួកកុម្មុយនីស្តដូចជាអាចារ្យ មៀន ជាដើម ។

បញ្ញវន្តប្រភេទទីពីរគឺ ជាបញ្ញវន្ត ដែលបានសិក្សានៅរាជធានីភ្នំពេញ ឬ នៅបរទេស ជាពិសេស នៅប្រទេសបារាំង ។ បញ្ញវន្ត ដែលបានរៀនសូត្រនៅបរទេសនោះ មួយចំនួនជាសមាជិកព្រះរាជវង្សានុវង្ស មួយចំនួនជាកូនចៅរបស់មន្ត្រីធំៗ និង កូនចៅគហបតី ឬ កូនអ្នកមាន ។ ចំណែកឯបញ្ញវន្តមួយចំនួនទៀត ជាបញ្ញ

វន្តចេញពីរាស្ត្រសាមញ្ញធម្មតា ។ ក្រុមដែលមានដើមកំណើតចេញពីរាស្ត្រសាមញ្ញ ធម្មតានោះ មិនមានទ្រព្យសម្បត្តិ ទៅធ្វើការសិក្សានៅបរទេសបានទេ ប្រសិនបើ គ្មានការធ្វើពលីកម្មយ៉ាងធំធេងរបស់ឪពុកម្តាយ ឬ បើគ្មានអាហារូបករណ៍ពីរាជរដ្ឋាភិបាល ឬ ពីបរទេស ។ នៅក្នុងចំណោមបញ្ញវន្តប្រភេទទីពីរនេះគឺ មានក្រុមកូនស្តេច កូនចៅអ្នកធំ និង កូនអ្នកមានម្ខាង និង ម្ខាងទៀត ក្រុមកូនអ្នកក្រ ។

បញ្ញវន្តដែលចូលមកធ្វើនយោបាយ ក៏ព្រោះតែសកម្មភាពនយោបាយនោះ អាចនាំពួកគេទៅកាន់តំណែងខ្ពស់ ឬ ក៏យ៉ាងហោចណាស់អាចនៅរក្សាហានៈសង្គម របស់ខ្លួនបាន ឬ ក៏គេធ្វើនយោបាយ ដោយសារជំនឿរបស់គេតែប៉ុណ្ណោះ ។ ពួក ក្រុមកូនអ្នកធំ និង ក្រុមកូនអ្នកមាន បិតនៅក្នុងចំណោមក្រុមអភិរក្សនិយម ផ្ទុយ ទៅវិញ ក្រុមកូនអ្នកក្រ តែងមាននិន្នាការទៅរកសង្គមនិយម ។ ទាំងនេះ ក៏ព្រោះថា អ្នកទាំងនោះ ដែលមានហានៈទន់ទាប នឹកគិតថាភាពទន់ទាបរបស់ខ្លួនក៏ដោយ សារអំពើអយុត្តិធម៌ក្នុងសង្គម ។ កូនចៅអ្នកធំ កូនចៅអ្នកមាន គេមានប្រាក់កាស ចាយវាយសម្បូណ៌សប្បាយហ៊ឺហា មានរបស់របរប្រើប្រាស់ល្អជាង មានជីវភាព ធូរធារជាង ។ល។ ដូច្នេះ ក្រុមកូនអ្នកក្រភាគច្រើន ក្រោយពីបានជ្រួតជ្រាបដោយ មនោគមវិជ្ជាសង្គមនិយមផង យល់ឃើញថាដោយសង្គមមានភាពអយុត្តិធម៌ ពួក គេត្រូវតែតាំងចិត្តប្តេជ្ញាធ្វើការតស៊ូ ដើម្បីឲ្យមានយុត្តិធម៌ក្នុងសង្គម ហើយក៏ប្រកាន់ យកមាគ៌ាម៉ាក្សនិយម ដើម្បីធ្វើការប្រយុទ្ធប្រឆាំងនឹងអយុត្តិធម៌សង្គមនោះ ។

សម្តេច សីហនុ តែងមានព្រះបន្ទូលជាញឹកញាប់ថា "ក្នុងសម័យសង្គម រាស្ត្រនិយម និស្សិតខ្មែរយើង ដែលបានទៅរៀននៅប្រទេសបារាំង នៅពេលត្រឡប់ មកប្រទេសខ្មែរវិញច្រើនតែក្លាយទៅជាជនកុម្មុយនីស្ត ។ ចំណែកឯនិស្សិត ដែល បញ្ជូនឲ្យទៅរៀននៅសហភាពសូវៀត នៅពេលត្រឡប់មកវិញ ច្រើនតែក្លាយទៅជា ជនមូលធននិយម" ។ ទាំងនេះ ក៏ជាការពិតមួយដែរ ព្រោះនៅពេលដែលនិស្សិត

មានធនធានតិចតួច ត្រូវបានបញ្ជូនឲ្យទៅរៀននៅប្រទេសបារាំង បានឃើញភាពសម្បូណ៌សប្បាយ ដែលខ្លួនមិនអាចឈោងទៅដល់ និង ម្យ៉ាងទៀត ដោយត្រូវទទួលបានការឃោសនាអប់រំមនោគមវិជ្ជាពីបញ្ញវន្តឆ្វេងនិយមរបស់បារាំងផង ក៏វាយតម្លៃស្ថានភាពនោះជាអយុត្តិធម៌ក្នុងសង្គម ។ អ្នកដឹកនាំខ្មែរក្រហមជាច្រើននាក់បិតនៅក្នុងក្រុមបញ្ញវន្តបែបនេះ ។ ផ្ទុយទៅវិញ អ្នកដែលបានទៅរៀននៅទីក្រុងម៉ូស្គូ បានឃើញដោយផ្ទាល់ភ្នែកនូវអ្វីដែលហៅថាកុម្មុយនីស្ត ។ ពួកក្រុមនោះមើលឃើញថា នៅក្នុងរបបកុម្មុយនីស្ត ពួកគេនឹងបាត់បង់អស់នូវសេរីភាព និងសិទ្ធិរបស់បុគ្គល ។ ក្នុងចំណោមបញ្ញវន្តឆ្វេងនិយមទាំងឡាយ ភាគច្រើនជាគ្រូបង្រៀន ឬ សាស្ត្រាចារ្យដែលមានឥទ្ធិពលយ៉ាងធំធេងទៅលើយុវជន ។ ពួកគេចេះធ្វើការទាក់ទាញយុវជនខ្មែរឲ្យដើរតាមគេ និង ធ្វើការលើកកំពស់មេដឹកនាំធំៗរបស់គេ ដែលភាគច្រើនត្រូវបានទទួលស្គាល់ថាជាអ្នកដឹកនាំស្អាតស្អំ និង មានការចេះដឹងខ្ពស់ ។ ពួកបញ្ញវន្តទាំងនោះ ផ្តល់ការគាំទ្រដ៏រឹងមាំ និង យ៉ាងថ្លៃថ្លាចំពោះខ្មែរក្រហមក្នុងការតស៊ូរបស់ពួកគេ ដើម្បីឡើងកាន់អំណាចនៅក្នុងប្រទេសខ្មែរ ។

ខ្ញុំធ្វើកុម្ម៉ង់ដូ

នៅក្នុងសម័យសង្គ្រាមនោះ បន្ទាប់ពីរដ្ឋប្រហារ រដ្ឋាភិបាលលោក លន់ នល់ បានចេញបញ្ជាឲ្យមន្ត្រីអ្នករដ្ឋការផ្នែកស៊ីវិលទាំងអស់ ចូលបំរើការងារក្នុងកងកុម្ម៉ង់ដូ ។ នាយទាហានជាច្រើនរូប បានត្រូវចាត់ទៅតាមក្រសួង ឬ មន្ទីរនានា ដើម្បីធ្វើការហ្វឹកហ្វឺនដល់មន្ត្រីអ្នករដ្ឋការស៊ីវិលនូវមុខវិជ្ជាបាញ់កាំភ្លើង និង ចំណេះដឹងផ្នែកប្រយុទ្ធផ្សេងៗ ។ ការកិច្ចសំខាន់ៗរបស់ក្រុមកុម្ម៉ង់ដូ មានដូចជាយាមការពារអាគារសាធារណៈទាំងថ្ងៃ ទាំងយប់ និង ជួយផ្តល់ការគាំទ្រផ្នែកភស្តុភារចំពោះកងទ័ពនៅពេលត្រូវការ ។ ក្នុងឋានៈជាបុគ្គលិករបស់ក្រុមហ៊ុនរដ្ឋ ខ្ញុំក៏ត្រូវទទួលការ

កិច្ចក្នុងកងកុម្មង់ដូដូចជាមន្ត្រីរដ្ឋការទូទៅដែរ ។ ខ្ញុំត្រូវទទួលការហ្វឹកហ្វឺនផ្នែកការពារខ្លួន វិន័យយោធា និង បច្ចេកទេសបាញ់កាំភ្លើងដែរ ។ ក៏ប៉ុន្តែ ខ្ញុំមិនបានចូលទៅហ្វឹកហ្វឺនឲ្យបានទៀងទាត់ទេ ព្រោះខ្ញុំមិនសូវចូលចិត្តហាត់រៀនមុខវិជ្ជាទាំងនោះ ។ ដូច្នេះ ថ្នាក់ដឹកនាំរបស់ក្រុមហ៊ុនបានចេញលិខិតព្រមាន ហាក់បីដូចជាស្តីបន្ទោសថា ខ្ញុំមិនមែនជាអ្នកស្រឡាញ់ជាតិយ៉ាងដូច្នោះដែរ ។

ក្នុងហានៈជាសមាជិកកងកុម្ម៉ង់ដូ ខ្ញុំមានភារកិច្ចធ្វើការយាមកាមតាមច្រកចេញចូលនៃអាគាររបស់ក្រុមហ៊ុនសុរាគារខ្មែរ អស់រយៈពេលជាច្រើនម៉ោងក្នុងមួយថ្ងៃ នៅពេលថ្ងៃ ។ នៅពេលយប់ពួកយើងត្រូវចាត់ឲ្យទៅយាមភូមិគ្រឹះរបស់លោកប្រធានអគ្គនាយក ។ នៅពេលយាមនោះ ពួកយើងកាន់កាំភ្លើងម៉ាកការ៉ប៊ីន A1 របស់បារាំង ក្រោយមកដោយសារមានជំនួយពីសហរដ្ឋអាមេរិក គេដូរកាំភ្លើងការ៉ាប៊ីន មកកាំភ្លើងM16 វិញ ។ លោកប្រធានអគ្គនាយកជាមនុស្សមានចិត្តសប្បុរស ។ រាល់យប់ គាត់តែងរៀបចំម្ហូបអាហារ និង តែទឹកកកទុកឲ្យយើងជានិច្ចមុននឹងយើងចាប់ផ្តើមធ្វើការងាររបស់យើង ។ យើងមិនដែលឃើញគាត់ផ្ទាល់ ឬ សមាជិកណាម្នាក់របស់គ្រួសារគាត់ឡើយ ។ ព្រោះពួកយើងត្រូវចាត់ឲ្យទៅឈរយាម នៅលើដំបូលភូមិគ្រឹះរបស់គាត់ ។ លោកប្រធានអគ្គនាយករបស់ខ្ញុំនោះ ជាមន្ត្រីគយ និងរដ្ឋាករ ដែលមានហានៈជាអធិការគយ ។ មុខតំណែងគយ ជាមុខតំណែងដែលអាចរកប្រាក់ចំណូលបានយ៉ាងស្រួល ធ្វើឲ្យជីវភាពរបស់ពួកគាត់មានការធូរធារយ៉ាងខ្លាំង ។ ភរិយារបស់គាត់ជាស្ត្រីម្នាក់ដែលមានឈ្មោះល្បី ធ្លាប់កាន់តំណែងជារដ្ឋលេខាធិការក្រសួងឃោសនាការពីឆ្នាំ ១៩៦៧ ដល់ ១៩៦៩ ក្នុងសម័យសង្គមរាស្ត្រនិយម ។

លោកស្រី ជិន រ៉ែន ដែលជាភរិយារបស់លោកប្រធានអគ្គនាយកនោះជាស្ត្រីដ៏កម្រដែលបានឡើងកាន់តំណែងរហូតដល់ថ្នាក់រដ្ឋមន្ត្រី ។ លោកប្រធានអគ្គនា

យក ជិន រ៉ែន ត្រូវបានចាត់ឲ្យមកកាន់តំណែង ជាប្រធានអគ្គនាយកក្រុមហ៊ុនសុរាគារខ្មែរនេះ បន្ទាប់ពីលោក ភួង ម៉ារហ្គាំង ដែលជាអ្នកជំនួយការជិតស្និទ្ធម្នាក់របស់សម្តេច សីហនុ បានត្រូវចោទប្រកាន់ថា បានលួចប្រាក់របស់ក្រុមហ៊ុន ហើយត្រូវផ្តន្ទាទោសជាប់គុកជាច្រើនឆ្នាំ ។ នៅរាល់ពេលដែលខ្ញុំឈរយោមនៅលើដំបូលផ្ទះរបស់លោកប្រធាននោះ ខ្ញុំមានអារម្មណ៍រាយមាយ ដោយចេះតែនឹកបារម្ភចំពោះអនាគតរបស់ខ្ញុំ ដែលកំពុងជួបប្រទះនូវឧបសគ្គដ៏ធំ ដោយសារតែរដ្ឋប្រហារយោធានោះ ។

ប្រជាពលរដ្ឋក្នុងទីក្រុងភ្នំពេញ ហាក់ដូចជាចេះបត់បែនតាមជីវភាពប្រចាំថ្ងៃ និង ភាពជាក់ស្តែងនៃសភាពការណ៍នយោបាយរបស់ប្រទេស ។ អ្នកនៅទីក្រុងទាំងនោះ នាំគ្នាផ្តើលស្លៀកពាក់ឯកសណ្ឋានយោធា ដែលឯកសណ្ឋានទាំងនោះបានក្លាយជាម៉ូតសំលៀកបំពាក់របស់ពួកគេ ។ សមាជិកកុម្ម៉ង់ដូធម្មតា ស្លៀកពាក់ឯកសណ្ឋានយោធា តែគ្មានពាក់សញ្ញាស័ក្តិយសអ្វីទេ ។ ក៏ប៉ុន្តែ មេកុម្ម៉ង់ដូស្លៀកពាក់ឯកសណ្ឋានយោធា ព្រមទាំងមានកាំភ្លើងខ្លី (Pistolet) នៅចង្កេះ ។ នៅសម័យនោះ នរណាដែលមានកាំភ្លើងខ្លី (Pistolet) នៅចង្កេះ បង្ហាញសញ្ញាថាអ្នកនោះជាមេ ។ ម្យ៉ាងទៀត នរណាដែលមានកាំភ្លើងខ្លីនៅនឹងចង្កេះ ក៏បញ្ចេញភាពសង្ហារផងដែរ ។

អ្នកណាក៏អាចទិញសក្តិពាក់បានដែរ សម័យ លន់ នល់

មន្ត្រីអ្នករដ្ឋការមួយចំនួនសុំផ្ទេរទៅផ្នែកយោធា ហើយក៏ក្លាយទៅជាមេទាហាន ។ ក៏ប៉ុន្តែសម័យនោះ នៅក្នុងជួរកងទ័ពលោក លន់ នល់ កើតមានអំពីពុករលួយយ៉ាងធាប់រហ័សរហូតដល់ថ្នាក់ ដែលគេអាចទិញស័ក្តិយកមកពាក់បាន ។ ដូច្នេះហើយ កងទ័ពរបស់លោក លន់ នល់ កាន់តែកើនចំនួនឡើងឥតឈប់ឈរ

រួមផ្សំដោយបុគ្គលិកស៊ីវិល ដែលផ្ទេរមកពីគ្រប់ផ្នែក ដូចជាអ្នករដ្ឋការស៊ីវិលធម្មតា គ្រូបង្រៀន បូកផ្សំជាមួយអ្នកជំនួញ ជាងឈើ ជាងដែក ចិនកាប់ជ្រូក ជាងកាត់សក់ សិល្បករ សិល្បការិនី អ្នកលេងល្ខោន អ្នកលេងកុន អ្នកចំរៀង អ្នកច្រៀងអាយ៉ៃ ។ល។ និង មនុស្សមួយចំនួនដែលយល់ថាកងទ័ពជាកន្លែងដែលគេអាចរកលុយបាន អាចធ្វើជាអ្នកមាន នៅក្នុងសម័យសង្គ្រាម ។ មិត្តរបស់ខ្ញុំម្នាក់ដែលធ្លាប់រៀននៅមហាវិទ្យាល័យឈ្មោះ មន្តា បានចូលទៅបំរើកងទ័ពមានហានៈជាអនុសេនីយទោ ចាប់ពីឆ្នាំដំបូងនៃសង្គ្រាម ។ មន្តា បានត្រូវបាត់ខ្លួនតាំងពីពេលនោះរហូតមក ។ ខ្ញុំឮគេថា មន្តា បានស្លាប់នៅពេលប្រយុទ្ធលើកទីមួយ នៅឯកំពង់សិលា មួយឆ្នាំបន្ទាប់មក ។

នៅពេលចេញពីក្រុមហ៊ុនសុរាគារខ្មែរ (S K D) ខ្ញុំសង្កេតឃើញថា បន្ទុកនៃសង្គ្រាមដែលត្រូវរែកពុនទាំងអស់គ្នានោះ មិនបានត្រូវចែករំលែកឲ្យបានដល់ពលរដ្ឋគ្រប់ៗគ្នាឡើយ ជាពិសេសពលរដ្ឋដែលរកស៊ីចិញ្ចឹមជីវិតនៅក្នុងវិស័យឯកជន ។ នៅក្នុងក្រុមហ៊ុនសូគីឡេ និង កូមិន្នខ្មែរ បុគ្គលិកទាំងអស់មិនបានត្រូវចាប់បង្ខំឲ្យទៅធ្វើការយោមកាមដូចមន្ត្រីអ្នករដ្ឋការទេ ។ ក្រុមហ៊ុនឯកជនទាំងនោះ គេជួលទាហានឲ្យមកយាមអាគារ ដើម្បីទុកឱកាសឲ្យបុគ្គលិករបស់គេ គិតគូរតែពីការខិតខំបំពេញការងាររបស់ក្រុមហ៊ុនតែប៉ុណ្ណោះ ។

សម្ព័ន្ធភាព លន់ នល់ បែកគ្នាជាបក្សផ្សេងៗ

មួយឆ្នាំបន្ទាប់ពីបានកាន់អំណាចមក របប លន់ នល់ កាន់តែបាត់បង់ទៅៗនូវការគាំទ្រពីប្រជាពលរដ្ឋ និង ទីតាំងទឹកដីរបស់ខ្លួន ធ្វើឲ្យតំបន់ដែលរបបនេះកាន់កាប់កាន់តែរួញតូចទៅៗ ។ នៅខែ មីនា ១៩៧១ រណសិរ្សរបស់សម្តេច សីហនុ ដែលឋិតនៅក្រោមអំណាចរបស់ខ្មែរក្រហម បានប្រកាសថាពួកគេបានកាន់កាប់

ទឹកដីបួនភាគប្រាំនៃប្រទេសកម្ពុជារួចទៅហើយ ។ ដម្លោះរវាងភាគីដែលធ្លាប់បានរួបរួមគ្នាធ្វើការវាយរំលំរបបសម្តេច សីហនុ នោះ ក៏កាន់តែលេចធ្លោឡើងជាសាធារណៈ ។ នៅថ្ងៃទី ៩ តុលា ១៩៧០ លោក លន់ នល់ បានប្រកាសបង្កើតសាធារណរដ្ឋខ្មែរ ។ អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ បានប្តេជ្ញាបោះបង់ចោលនូវឋានៈ និង បុព្វសិទ្ធិជាស្តេច ដើម្បីមកធ្វើជាពលរដ្ឋសាមញ្ញវិញ។ បន្ទាប់មក អ្នកអង្គម្ចាស់ សិរិមតៈ ក៏បង្កើតគណបក្សមួយឈ្មោះថា គណបក្សសាធារណរដ្ឋខ្មែរ ។ ចំណែកឯលោក អ៊ិន តាំ ដែលជាប្រធានរដ្ឋសភាស្តីទី បានធ្វើការប្រមែប្រមូលអ្នកប្រជាធិបតេយ្យទាំងឡាយ និង ធ្វើឲ្យមានដំណើរការឡើងវិញនូវគណបក្សប្រជាធិបតេយ្យ ដែលត្រូវបានបង្កើតនៅទសវត្សរ៍ឆ្នាំ ១៩៤០ ដោយអ្នកនយោបាយដ៏ល្បីៗទាំងឡាយ ដែលធ្វើឲ្យប្រសូតឡើងនូវរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៤៧ ។

លោក អ៊ិន តាំ ឡើងកាន់តំណែងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃនៅខែ ធ្នូ ១៩៦៤ បន្ទាប់ពីគាត់បង្កលក្ខណៈឲ្យចាប់ខ្លួននូវខ្មែរសេរីពីរនាក់ ដែលជាភ្នាក់ងាររបស់លោក សឺង ង៉ុកថាញ់ ។ ក្នុងចំណោមខ្មែរសេរីពីរនាក់នោះ មានម្នាក់ឈ្មោះ ព្រាប អ៊ិន ដែលត្រូវជាសាច់ញាតិរបស់គាត់ផង ។ នៅឆ្នាំ ១៩៦៤ នោះ លោក ព្រាប អ៊ិន បានត្រូវគេនាំមកបង្ហាញខ្លួននៅចំពោះអង្គសមាជពិសេសមួយ នៅក្នុងក្រុងភ្នំពេញ ហើយត្រូវបានតុលាការសឹកកាត់ទោសប្រហារជីវិត ។ លោក ព្រាប អ៊ិន បានត្រូវគេនាំយកទៅបាញ់ចោលនៅត្រពាំងក្រឡឹង ក្នុងខេត្តកំពង់ស្ពឺ ។ ការបាញ់សម្លាប់នោះ បានត្រូវថតជាឯកសារដែលក្រសួងយោសនាការសម័យនោះយកទៅបញ្ចាំងផ្សព្វផ្សាយគ្រប់ទីកន្លែង នៅក្នុងប្រទេសកម្ពុជា ។

លោក អ៊ិន តាំ មានសំដីថ្នមាត់ពូកែនិយាយតាមរបៀបព្រោកប្រាជ្ញលេបខាយរបស់គាត់ ។ រាល់ៗដង នៅពេលដែលគាត់និយាយជាសាធារណៈ គាត់តែង

តែរំលឹកអំពីសេចក្តីស្រឡាញ់របស់គាត់ចំពោះស្រុកខ្មែរ ប្រពៃណីខ្មែរ សិល្បៈខ្មែរ ជាពិសេស ភ្លេងខ្មែរ ។ រហូតដល់ថ្ងៃ គាត់ចូលរួមទម្លាក់សម្តេច សីហនុ ពីតំណែងប្រមុខរដ្ឋ លោក អ៊ិន តាំ តែងតែថ្លែងជាសាធារណៈ នូវសេចក្តីស្វាមីភក្តិរបស់គាត់ចំពោះអង្គសម្តេច ។ នៅពេលដែលគេទំលាក់សម្តេច សីហនុ ពីតំណែងនោះ លោក អ៊ិន តាំ មានមុខនាទីជាប្រធានរដ្ឋសភាស្តីទី ដោយហេតុថា លោក ចេង ហេង ដែលជាប្រធានរដ្ឋសភាពេញសិទ្ធិនោះ ត្រូវឡើងកាន់តំណែងជាប្រមុខរដ្ឋស្តីទីនៅពេលអវត្តមានរបស់សម្តេច សីហនុ ។ បន្ទាប់ពីរដ្ឋប្រហារមកលោក អ៊ិន តាំ បានក្លាយទៅជាអ្នកប្រឆាំងសម្តេច សីហនុ យ៉ាងស្លាប់រស់ និង ប្រកាសថាជាអ្នកលបលួចស្រឡាញ់ និង គាំទ្រលោក លន់ នល់ ជាយូរមកហើយ ។

ចាប់ពីពេលនោះមក គាត់បាននិយាយជាសាធារណៈថា៖ "ជាច្រើនឆ្នាំមកហើយ ខ្ញុំលួចស្រឡាញ់លោក លន់ នល់ ព្រោះលោកជាអ្នកដឹកនាំខ្មែរដ៏ពិសេសមួយរូប" ។ ប៉ុន្តែអស់រយៈពេលមួយឆ្នាំ បន្ទាប់ពីរដ្ឋប្រហារមក លោក អ៊ិន តាំ បានផ្លាស់ប្តូរចិត្តគំនិតមកធ្វើជាអ្នកប្រឆាំងរបបលោក លន់ នល់ យ៉ាងចេញមុខក្នុងឋានៈជាប្រធានគណបក្សប្រឆាំងឈ្មោះ "គណបក្សប្រជាធិបតេយ្យ" ។

រដ្ឋធម្មនុញ្ញឆ្នាំ ១៩៤៧ និង គណបក្សប្រជាធិបតេយ្យ

គណបក្សប្រជាធិបតេយ្យ បានត្រូវបង្កើតឡើងនៅឆ្នាំ ១៩៤៦ ដោយបញ្ញវន្តដ៏ឆ្នើមៗមួយចំនួន ដែលមានគំនិតចង់នាំលទ្ធិប្រជាធិបតេយ្យមកក្នុងប្រទេសកម្ពុជា និង ចង់បានឯករាជភាពពីបារាំង។ បញ្ញវន្តទាំងនោះ ដែលធ្លាប់បានទៅរៀននៅប្រទេសបារាំង មានជាអាទិ៍ ព្រះអង្គម្ចាស់ សុីសុវត្ថិ យុគ្គវង្ស លោក អៀវ កើស លោក សឹម វ៉ា លោក ឈាន វ៉ែម និង លោក ជុន អ៊ុក ។ លើកលែងតែព្រះអង្គម្ចាស់ យុគ្គវង្ស និង លោក អៀវ កើស ចេញ ខ្ញុំសុទ្ធតែបានធ្វើការផ្ទាល់ជាមួយនឹងវរជន

ទាំងអស់នោះ ។ ជាពិសេស លោក ឈាន រ៉ែម លោក ស៊ឹម វ៉ា និង លោក ជុន អ៊ុក នៅក្នុងជួរណេសិរ្សមួយ ដែលដឹកនាំដោយអ្នកនយោបាយជើងចាស់ម្នាក់ទៀតគឺ លោក សឺន សាន ។ ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ យុត្តិវង្ស ជាកូនខ្មែរដ៏កម្រមួយរូប ព្រោះព្រះអង្គបានសិក្សានៅប្រទេសបារាំង រហូតទទួលបានសញ្ញាប័ត្រថ្នាក់បណ្ឌិតផ្នែកគណិតសាស្ត្រ ។ ព្រះអង្គម្ចាស់អង្គនេះ មានការចេះដឹងជ្រៅជ្រះណាស់ ។ តាមសៀវភៅប្រវត្តិសាស្ត្រ ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ យុត្តិវង្ស ទ្រង់សុគតក្នុងព្រះជន្មយ៉ាងក្មេងគឺ ៣៤ ព្រះវស្សា ក្រោមទំងន់នៃការងារ និង ដោយសារជំងឺរបេង និង គ្រុនចាញ់នៅឆ្នាំ ១៩៤៧ ។ លោក អៀវ កើស បានត្រូវគេសំលាប់នៅខែ មករា ១៩៥០ ។ វរជនទាំងពីររូបនេះ សុទ្ធតែជាអ្នកចូលរួមបង្កើតនូវរដ្ឋធម្មនុញ្ញទីមួយនៃព្រះរាជាណាចក្រកម្ពុជាយើង ដែលបានទទួលស្គាល់សិទ្ធិសំខាន់ៗរបស់ពលរដ្ឋ និង ដែលបានសាងខឿននៃរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ។ រដ្ឋធម្មនុញ្ញទីមួយនេះ បានត្រូវអនុម័តដោយរដ្ឋសភា ដែលជ្រើសតាំងឡើងតាមរយៈការបោះឆ្នោតសកលរបស់ពលរដ្ឋភេទប្រុសទាំងអស់ ។ នៅសម័យនោះ ពលរដ្ឋខ្មែរភេទស្រី មិនទាន់មានសិទ្ធិចូលរួមក្នុងការបោះឆ្នោតនៅឡើយទេ ។ ការបោះឆ្នោតបានធ្វើឡើងនៅសម័យអាណាព្យាបាល (Protectorat) បារាំងដោយអនុវត្តតាមកិច្ចព្រមព្រៀងបណ្តោះអាសន្ន (Modus Vivendi) ដែលចុះហត្ថលេខានៅថ្ងៃ ៧ មករា ១៩៤៦ បន្ទាប់ពីបារាំងបានវិលមកត្រួតត្រាប្រទេសកម្ពុជាវិញ ក្រោយសង្គ្រាមលោកលើកទី២ ។ ក្នុងកិច្ចព្រមព្រៀងនោះ បារាំងបានទទួលស្គាល់ស្វ័យភាពនៃព្រះរាជាខ្មែរក្នុងការគ្រប់គ្រងផ្ទៃក្នុងៗប្រទេស ដែលអនុញ្ញាតឲ្យមានការបង្កើតគណបក្សនយោបាយ ឲ្យមានសេរីភាពខាងការសំដែងមតិ សេរីភាពក្នុងការចូលរួមប្រជុំ ព្រមទាំងសេរីភាពស៊ីវិលផ្សេងៗទៀត ។

ការបោះឆ្នោតលើកទី១ បានប្រព្រឹត្តទៅនៅខែ កញ្ញា ១៩៤៦ ។ គណបក្ស

ប្រជាធិបតេយ្យ ទទួលបានជោគជ័យគឺ បានទទួល ៥០ កៅអីលើកៅអីចំនួន ៦៩ ។ ដោយសារជោគជ័យនៃការបោះឆ្នោតនេះ គណបក្សប្រជាធិបតេយ្យបានបង្កើតរដ្ឋាភិបាលមួយដែលមានព្រះអង្គម្ចាស់ យុត្តិវង្ស ជានាយករដ្ឋមន្ត្រី ។ អាណត្តិរបស់រដ្ឋាភិបាលនេះ រួមមានទាំងការព្រាង និង អនុម័តឲ្យប្រើប្រាស់នូវរដ្ឋធម្មនុញ្ញថ្មី ដែលត្រូវប្រកាសឲ្យប្រើជាផ្លូវការនៅថ្ងៃទី ១៦ ឧសភា ១៩៤៧ ដោយព្រះករុណាព្រះបាទ នរោត្តម សីហនុ ។ ក៏ប៉ុន្តែ នៅក្នុងរដ្ឋធម្មនុញ្ញនោះ មានបទបញ្ញត្តិមួយចំនួន បានអនុញ្ញាតឲ្យព្រះមហាក្សត្រចូលជ្រៀតជ្រែក ក្នុងកិច្ចការរបស់រដ្ឋាភិបាល ។ រដ្ឋធម្មនុញ្ញសម័យនោះ បានចែងថាអំណាចនីតិប្រតិបត្តិ នីតិបញ្ញត្តិ និងអំណាចតុលាការទាំងឡាយ ចេញមកពីព្រះមហាក្សត្រ ជាហេតុឲ្យព្រះអង្គមានអំណាចរុះរើរដ្ឋាភិបាល និង រំលាយរដ្ឋសភាបាន ទោះបីជារដ្ឋសភានោះបានត្រូវប្រជាពលរដ្ឋបោះឆ្នោតឲ្យក៏ដោយ ។

ចាប់តាំងពីឆ្នាំ ១៩៤៦ រៀងមក គណបក្សប្រជាធិបតេយ្យបានទទួលជ័យជំនះជាប់ជានិច្ច ក៏ប៉ុន្តែនៅអាណត្តិនីមួយៗ គណបក្សនេះមិនបានកាន់អំណាចឲ្យគ្រប់អាយុកាលនៃអាណត្តិទេ ដោយសារព្រះមហាក្សត្រព្រះបាទ នរោត្តម សីហនុ ចេះតែមានហេតុផល រំលាយរដ្ឋសភារបស់គណបក្សប្រជាធិបតេយ្យនេះជានិច្ច ដើម្បីព្រះអង្គក្តាប់ស្ថានការណ៍នយោបាយ ឲ្យស្ថិតនៅក្នុងកណ្តាប់ព្រះហស្តព្រះអង្គបាន ។ ដូច្នេះគណបក្សប្រជាធិបតេយ្យក៏ចេះតែឈ្នះឆ្នោតជាដរាបរហូតដល់ថ្ងៃដែលព្រះមហាក្សត្រទ្រង់សម្រេចព្រះទ័យ ដាក់រាជសម្បត្តិថ្វាយព្រះវររាជបិតារបស់ព្រះអង្គហើយទ្រង់យាងចូលប្រឡូកក្នុងឆាកនយោបាយដោយផ្ទាល់ព្រះអង្គ ។ នៅឆ្នាំ ១៩៥៥ ព្រះអង្គបានបង្កើតចលនាសង្គមរាស្ត្រនិយម ។ ចាប់តាំងពីពេលនោះ ប្រទេសកម្ពុជាយើង បានស្ថិតនៅក្រោមរបបគ្រប់គ្រងមួយដែលមានលក្ខណៈជារបបនៃបក្សតែមួយ ដោយគណបក្សប្រជាធិបតេយ្យ ត្រូវនៅសម្ងំស្ងៀមក្នុងភាព

អសកម្មរហូតដល់ឆ្នាំ ១៩៧១ ។

បន្ថែមលើរណសិរ្សយោធា លោក លន់ នល់ បានបើករណសិរ្សប្រយុទ្ធលើវិស័យជាច្រើនទៀត ដូចជាការធ្វើឲ្យមានភាពបរិសុទ្ធនៃជាតិសាសន៍ខ្មែរដែលគេ ឲ្យឈ្មោះថា "ខ្មែរមន" ដោយមានវិធីសាស្ត្រយកព្រះពុទ្ធសាសនាទៅតទល់ប្រឆាំងលទ្ធិកុម្មុយនីស្ត និង យកគំនិតបដិវត្តន៍សម័យថ្មីគឺ បដិវត្តន៍សាធារណរដ្ឋ ប្រឆាំងរបបរាជានិយម ដោយសង្ឃឹមថាអាចនឹងរក្សាបាននូវការគាំទ្រពីប្រជាពលរដ្ឋចំពោះរបបរបស់គាត់ ។ ហេតុដូច្នេះហើយទើបគេអនុញ្ញាតឲ្យមានការបង្កើតគណបក្សនយោបាយជាច្រើន ។ ប្អូនប្រុសលោក លន់ នល់ ឈ្មោះ លន់ ណុន បានបង្កើតគណបក្សនយោបាយមួយឈ្មោះ គណបក្សសង្គមសាធារណរដ្ឋដែលប្រមូលផ្តុំអ្នកគាំទ្រលោក លន់ នល់ ទាំងអស់ និង ជាគណបក្សប្រណាំងប្រជែងជាមួយក្រុមអ្នកកាន់អំណាចមួយទៀតគឺ គណបក្សសាធារណរដ្ឋរបស់អតីតអ្នកអង្គម្ចាស់ស៊ីសុវត្ថិ សិរីមតៈ ។ ចំណែកឯគណបក្សប្រជាធិបតេយ្យ ក៏មានសកម្មភាពឡើងវិញនៅក្នុងឆាកនយោបាយថ្មីនៃប្រទេសកម្ពុជាយើងដែរ ដោយបន្តប្រកាន់យករូបសញ្ញាចាស់ ដែលមានសញ្ញាក្បាលដំរីកាន់ផ្កាឈូកបី ។ គណបក្សនេះ ទាក់ទាញបាននិស្សិត និង បញ្ញវន្ត ហើយដើតួនាទីជាគណបក្សប្រឆាំង ។ នៅក្នុងចំណោមថ្នាក់ដឹកនាំនៃគណបក្ស គេសង្កេតឃើញមានវរជនល្បីៗពីររូបគឺ លោក ចៅ សៅ និង លោក ឌុក ប៉ាស៊ី បន្ថែមលើវរជនពូកែខាងថ្វីសំជីមួយរូបទៀតគឺ លោក អ៊ិន តាំ ។

លោក ឌុក ប៉ាស៊ី មានឈ្មោះថាជាអ្នកនយោបាយស្តាំនិយម ដែលសម្តេច សីហនុ លាបពណ៌ថា"ខ្មែរខៀវ" ។ គាត់ធ្លាប់បានកាន់តំណែងជាអនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌នៅខែ តុលា ១៩៥៨ អស់រយៈពេលប្រាំមួយខែ និង ជារដ្ឋលេខាធិការក្រសួងផែនការ ក្នុងរយៈពេលប្រាំមួយខែទៀត ចាប់ពីខែ តុលា ១៩៦៦ ។

លោក ឳក រ៉ាស៊ី ក៏ជាអ្នកតំណាងរាស្ត្រអស់រយៈពេលជាច្រើនឆ្នាំទៀតផង ។ ក្រៅពីនោះ គាត់បានបង្កើតកាសែតមួយឈ្មោះថា "ភ្នំពេញប្រេស" "Phnom Penh Presse" ចេញផ្សាយនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៥០ និង ១៩៦០ ។ នៅក្នុងពេលដែលគណបក្សប្រជាធិបតេយ្យធ្វើសកម្មភាពឡើងវិញនៅឆ្នាំ ១៩៧១ នោះ លោក ឳក រ៉ាស៊ី នៅធ្វើជាសាស្ត្រចារ្យច្បាប់ បង្រៀននៅមហាវិទ្យាល័យច្បាប់ ។

លោក ចៅ សៅ ក៏ជាសាស្ត្រចារ្យបង្រៀននៅមហាវិទ្យាល័យច្បាប់ម្នាក់ទៀតដែរ ។ ក៏ប៉ុន្តែ គាត់ជាអ្នកនយោបាយប្រភេទមួយទៀត ដែលផ្ទុយពីលោក ឳក រ៉ាស៊ី ។ លោក ចៅ សៅ មាននិន្នាការទោរទន់ទៅរកសង្គមនិយម ដែលសម្តេច នរោត្តម សីហនុ បានលាបពណ៌ថាជាពួកខ្មែរ "ស៊ីជម្ពូ"[49] ។ លោក ចៅ សៅ មានការគោរពរាប់អានខ្លាំងពីមជ្ឈដ្ឋានទូទៅ ដោយសារភាពស្អាតស្អំមិនពុករលួយរបស់គាត់ ។ លោក ចៅ សៅ ធ្លាប់កាន់តំណែងជា អនុរដ្ឋលេខាធិការ រដ្ឋលេខាធិការក្រសួងហិរញ្ញវត្ថុ ក្រសួងផែនការ ចាប់ពីឆ្នាំ ១៩៦២ រហូតដល់ខែ តុលា ១៩៦៦ នៅក្នុងរដ្ឋាភិបាលមួយ ដែលមានស្តេរភាពជាងគេដែលមានព្រះអង្គម្ចាស់ នរោត្តម កន្តុល ជានាយករដ្ឋមន្ត្រី ។ លោក ចៅ សៅ ជាអ្នកនយោបាយខ្មែរមួយរូបដ៏កម្រដែលមិនប្រកាន់ខ្លួនគឺ ស្លៀកពាក់សាមញ្ញបំផុតនៅក្រៅម៉ោងធ្វើការ ។ គាត់ពាក់ស្បែកជើងផ្នាត់ បើករថយន្តធុន 2CV ទៅទទួលទានគុយទាវតាមចិញ្ចើមថ្នល់ ។ នៅពេលគេសួរគាត់ហេតុអ្វីបានធ្វើយ៉ាងនេះ គាត់និយាយថានេះជាវិធីល្អណាស់ដើម្បីឲ្យស្គាល់ជីវភាពពិតប្រាកដរបស់ប្រជាពលរដ្ឋ ។ ជាទូទៅ អ្នកស្រុកមួយចំនួនធំ តែងរិះគន់មន្ត្រីធំៗថ្នាក់រដ្ឋមន្ត្រីជាដើមថារស់នៅខ្ពស់ពេក នៅដាច់ឆ្ងាយពីប្រជាពលរដ្ឋ រហូតមិនដឹងអង្ករមួយគីឡូក្រាមថ្លៃប៉ុន្មាន ឬ គុយទាវមួយចានថ្លៃប៉ុន្មានជា

[49] ក្រៅពីពួកខ្មែរខៀវ និង ខ្មែរក្រហម សម្តេច សីហនុ បានដាក់ឈ្មោះខ្មែរមួយក្រុមទៀតដែលមាននិន្នាការទៅឆ្វេងគឺ សង្គមនិយមដែរ តែមិនទាន់ដល់ថ្នាក់ក្រហមឆ្អិនឆ្អៅដូចខ្មែរក្រហមថា ជាពួកខ្មែរស៊ីជម្ពូ ។

ដើម ។ ដូច្នេះ លោក ចៅ សៅ ចាប់ផ្តើមធ្វើខុសគេ ។ គាត់មានដើមកំណើតនៅកម្ពុជាក្រោមគឺ នៅភូមិភាគខាងត្បូងនៃប្រទេសវៀតណាមបច្ចុប្បន្ន ។ ខ្មែរយើងអាចស្គាល់បងប្អូនទាំងនោះជាខ្មែរក្រោម ដោយសារឈ្មោះ និង សំនៀងភាសានិយាយរបស់ពួកគាត់ ។ នៅកម្ពុជាក្រោម គេដាក់នាមត្រកូលទៅតាមភូមិកំណើត ទោះបីជាម្នាក់ៗចេញមកពីគ្រួសារទីទៃពីគ្នាក៏ដោយ ។ តាមរយៈឈ្មោះរបស់ពួកគាត់ យើងអាចស្គាល់គ្រួសារគាត់ផង និង ភូមិរបស់ពួកគាត់ផង ។ ឈ្មោះនាមត្រកូលដែលគេប្រើច្រើនជាងគេគឺ៖ ចៅ សឺន ឬ សឺង ទ្រឿង ថាច់ ជាញ់ និង គិម ជាដើម ។ បងប្អូនកម្ពុជាក្រោម ដែលមករស់នៅលើទឹកដីកម្ពុជាកណ្តាលយើងនេះ បង្កើតបានជាសហគមន៍ដ៏រឹងមាំមួយ ដែលចេះស្រឡាញ់គ្នា និង មានសាមគ្គីភាពរវាងគ្នា និង គ្នាយ៉ាងខ្លាំង ។ ដោយសារឆ្លាប់ទទួលរងទុក្ខវេទនា ដោយការធ្វើទុក្ខបុកម្នេញរបស់ជនជាតិវៀតណាម មកលើរូបគេ ជាពិសេស នៅវៀតណាមខាងត្បូងនេះ បងប្អូនខ្មែរកម្ពុជាក្រោម មានស្មារតីស្នេហាជាតិយ៉ាងខ្ពស់ ហើយនិយមចូលប្រឡូកក្នុងឆាកនយោបាយយ៉ាងខ្លាំងក្លាបំផុត ។

ភ្លាមៗបន្ទាប់ពីគណបក្សប្រជាធិបតេយ្យ ចាប់ផ្តើមដំណើរការឡើងវិញនោះ បងប្រុសទី២របស់ខ្ញុំគឺ បងស៊ីនឿន ក៏ស្ម័គ្រចូលជាសមាជិកគណបក្សនេះ ដូចជានិស្សិតមួយចំនួននៅមហាវិទ្យាល័យច្បាប់ដែរ ។ បន្ទាប់មក គាត់ក៏ចាប់ឡើងឋានៈក្នុងជួរគណបក្សយ៉ាងឆាប់រហ័ស ។ បងប្រុសខ្ញុំមានទំនាក់ទំនងល្អណាស់ ជាមួយថ្នាក់ដឹកនាំគណបក្ស ។ នៅទីបំផុត បងខ្ញុំក៏អន្ទងខ្ញុំឲ្យចូលជាសមាជិកគណបក្សប្រជាធិបតេយ្យជាមួយគាត់ដែរ ។ នៅសម័យនោះ ខ្ញុំពុំមានការយល់ដឹងអំពីប្រវត្តិ ឬ គោលនយោបាយរបស់គណបក្សនោះប៉ុន្មានឡើយ ។ បងខ្ញុំឲ្យខ្ញុំខំអានឯកសាររបស់បក្សជាភាសាបារាំង រៀបរៀងដោយលោក ចៅ សៅ ។ ឯកសារនោះបានធ្វើការវិភាគយ៉ាងលំអិតអំពីស្ថានភាពនយោបាយ សង្គម និង សេដ្ឋកិច្ចរបស់

ប្រទេសកម្ពុជា និង អំពីកំណើត ព្រមទាំងសមិទ្ធផលរបស់គណបក្សក្នុងទសវត្សរ៍ឆ្នាំ ១៩៤០ និង ១៩៥០ ។ ខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះការវាយតម្លៃ និង ការវិភាគផ្នែកសង្គម និង សេដ្ឋកិច្ចរបស់លោក ចៅ សៅ ព្រមទាំងគោលនយោបាយប្រឆាំងរបប លន់ នល់ ។ ម្យ៉ាងទៀត អ្វីដែលនាំឲ្យខ្ញុំច្រួលច្រាលក្នុងចិត្តចង់ចូលរួមនោះគឺ ដោយឃើញផ្ទាល់ភ្នែកនូវឥស្សរជនល្បីៗដែលពួកយើងគ្រាន់តែធ្លាប់ឮឈ្មោះតាមវិទ្យុ ឬ សារព័ត៌មាន និង មិនដែលបានចូលជិតដូចជាលោក អ៊ុន តាំ ចៅ សៅ ឌុក រ៉ាស៊ី ជាដើមផង ។ ព្រោះពេលនោះ ខ្ញុំមិនមែនគ្រាន់តែអាចចូលរួមប្រជុំនយោបាយជាមួយពួកគាត់តែប៉ុណ្ណោះទេ តែអាចនិយាយលេងជាមួយពួកគាត់ដែលអាចចាត់ទុកជាសំណាងខ្ពស់ផងក៏បាន ។ តាមធម្មតា អស់លោកអ្នកធំៗច្រើនរស់នៅជាច់ដោយឡែកពីមហាជនដែលយើងកម្រជួបផ្ទាល់បានណាស់ ។

ខ្ញុំស្ម័គ្រចិត្តជួយធ្វើការងារគណបក្សខាងផ្នែកគណនេយ្យ ដែលជាមុខងារតូចតាចមួយ និង ជាការងារក្រៅម៉ោងធ្វើការផង ។ ខ្ញុំមិនបានដឹងថាគណបក្សបានប្រាក់ចំណូលពីណាមកទេ ។ ក៏ប៉ុន្តែ ខ្ញុំគ្រាន់តែដឹងថា កាលណាគណបក្សត្រូវការប្រាក់ អ្នកដឹកនាំមួយរូបឈ្មោះលោក ច្ចាន់ គិមជាង ជាអ្នកផ្តល់ប្រាក់ឲ្យ ។ ក៏ប៉ុន្តែ ខ្ញុំមិនបានខិតខំសង្វាតធ្វើការឲ្យគណបក្សឲ្យបានជាប់លាប់ទេ ។ ខ្ញុំធ្វើឈប់ៗ ។ ក៏ប៉ុន្តែខ្ញុំតែងចូលរួមយ៉ាងទៀងទាត់នៅចុងសប្តាហ៍ ដើម្បីទៅទទួលទានអាហារពេលព្រឹកជាមួយលោក ចៅ សៅ នៅភោជនីយដ្ឋាន "ថ្មដា" ។ នៅទីនោះ លោក ចៅ សៅ មិនដែលខាតពេលវេលាទេ ។ គាត់តែងឆ្លៀតធ្វើការយោសនាឲ្យគណបក្សរបស់គាត់ជានិច្ច ជាពិសេសនៅតាមតុកាហ្វេ ។

រៀងរាល់អាទិត្យ គណបក្សតែងធ្វើការប្រជុំ ដែលខ្ញុំចូលរួមមិនសូវខានឡើយ ។ ប៉ុន្តែ ខ្ញុំមិនមែនចូលរួម ដើម្បីសំដែងមតិអ្វីទេគឺ គ្រាន់តែស្តាប់មតិ ឬ បទអត្ថាធិប្បាយនយោបាយរបស់ថ្នាក់ដឹកនាំតែប៉ុណ្ណោះ ។ ជាធម្មតាលោក អ៊ុន

តាំ តែងបើកអង្គប្រជុំ ធ្វើការរៀបរាប់ពីសភាពការណ៍នយោបាយ និង យោធា ចំណែកឯលោក ចៅ សៅ និយាយអំពីស្ថានភាពសេដ្ឋកិច្ចនៃប្រទេសខ្មែរ ព្រមទាំង ព្រឹត្តិការណ៍ពិភពលោក ។ គឺនៅក្នុងអង្គប្រជុំនោះហើយ ដែលខ្ញុំអាចសង្កេតឃើញ វត្តមានបញ្ញវន្តមួយចំនួន ដែលមកចូលរួមប្រជុំ រួចក្រោយៗមកក៏បាត់ខ្លួន និង បន្ត បន្ទាប់មកទៀត ឮថានាំគ្នាទៅចូលរួមជាមួយខ្មែរក្រហមក្នុង "ព្រៃម៉ាគី" ប្រឆាំងរបប លោក លន់ នល់ ជាបន្តបន្ទាប់ ។

បោះឆ្នោតក្នុងរបបសាធារណរដ្ឋ

នៅខែ មេសា ១៩៧២ លោក លន់ នល់ បានរៀបចំប្រជាមតិនៅក្នុងទឹកដី ដែលរដ្ឋការរបស់គាត់កាន់កាប់ ដើម្បីអនុម័តរដ្ឋធម្មនុញ្ញថ្មីនៃរបបសាធារណរដ្ឋ ។ នៅពេលនោះគឺ ជាការបោះឆ្នោតលើកទីមួយ និង លើកចុងក្រោយដែលខ្ញុំបានទៅ ចូលរួមនៅលើទឹកដីនៃប្រទេសកម្ពុជា រហូតដល់ឆ្នាំ ១៩៩៣ ទើបខ្ញុំបានបោះឆ្នោត ជាថ្មីទៀត ។ កាលនោះ ខ្ញុំមិនបានបោះឆ្នោតគាំទ្ររដ្ឋធម្មនុញ្ញសាធារណរដ្ឋនោះទេ ។ ក្រោយមកលោក លន់ នល់ ក៏ស្នើឲ្យមានការបោះឆ្នោតជ្រើសរើសប្រធានាធិបតី តែខ្ញុំមិនបានទៅបោះឆ្នោតទៀតទេ ។ គណបក្សប្រជាធិបតេយ្យ បានជ្រើស រើសលោក អ៊ិន តាំ ឲ្យឈរឈ្មោះជាបេក្ខជនប្រធានាធិបតី ។ បេក្ខជនម្នាក់ទៀតគឺ លោក កែវ អន ដែលជាព្រឹទ្ធបុរសនៃមហាវិទ្យាល័យច្បាប់ ។ គណបក្សប្រជាធិប តេយ្យ បានដឹកនាំការឃោសនាយ៉ាងគគ្រឹកគគ្រេងខ្លាំងណាស់ ។ គណបក្សនេះ មានការគាំទ្រយ៉ាងច្រើន ជាពិសេសពីយុវជន ហើយនិងមានការដឹកនាំល្អ ដែល អាចឲ្យយើងម្នាក់ៗនឹកថា លោក អ៊ិន តាំ អាចនឹងទទួលជ័យជំនះក្នុងការបោះ ឆ្នោតប្រធានាធិបតីនោះ ។ ក៏ប៉ុន្តែនៅទីបំផុត ជ័យជំនះត្រូវបានទៅលោក លន់

នល់ ទៅវិញ ទោះបីជាលទ្ធផលនៃការរាប់សន្លឹកឆ្នោតនៅរដ្ឋធានីភ្នំពេញ បានបង្ហាញឲ្យឃើញថា លោក អ៊ិន តាំ បានសន្លឹកឆ្នោតច្រើនជាងគេ ។ នៅពេលល្ងាចនោះខ្ញុំ និង បងស៊ីនឿន នាំគ្នាទៅស្តាប់សភាពការណ៍នៅឯផ្ទះលោក អ៊ិន តាំ ។ ពួកយើងត្រៀមខ្លួនដើម្បីរៀបចំពិធីអបអរសាទរចំពោះជោគជ័យ នៃការបោះឆ្នោតទៅហើយ ក៏ប៉ុន្តែនៅពេលដែលគេទទួលលទ្ធផលនៅតាមខេត្តដែលស្ថិតនៅក្រោមការត្រួតត្រារបស់ទាហានទាំងអស់នោះ លោក លន់ នល់ បានទទួលសម្លេងគាំទ្រច្រើនជាងគេ ។ សូមបញ្ជាក់ថា លោក លន់ នល់ ត្រូវបានលោក អ៊ិន តាំ និងក្រុមអ្នកតំណាងរាស្ត្ររបស់គាត់ លើកតំកើងជាសេនាប្រមុខនៅឆ្នាំ ១៩៧១ ។

សម័ន្ធភាព លន់ នល់ សាកល្បងរួបរួមគ្នាវិញ

លោក លន់ នល់ ត្រូវបានប្រកាសជាផ្លូវការក្នុងតំណែងជាប្រធានាធិបតីនៃសាធារណរដ្ឋខ្មែរនៅខែ មិថុនា ១៩៧២ ។ ក៏ប៉ុន្តែស្ថានភាពនយោបាយបានគាបសង្កត់របបសាធារណរដ្ឋកាន់តែខ្លាំងក្លាឡើងជារៀងរាល់ថ្ងៃ ។ ប្រហែលជាដោយសារមានការផ្តល់ដំបូន្មានពីសហរដ្ឋអាមេរិកផង បានជាលោកសេនាប្រមុខ លន់ នល់ ខិតខំព្យាយាមបង្រួបបង្រួមដៃគូរបស់គាត់ ដែលធ្លាប់បានរួមគ្នាទម្លាក់សម្តេចសីហនុ និង អូសទាញក្រុមប្រឆាំងឲ្យចូលមកសហការជាមួយគាត់ ។ ក្រុមលោក លន់ នល់ បានអូសទាញលោក ឌុក ប៉ាស៊ី ដោយផ្តល់មុខតំណែងជាឯកអគ្គរដ្ឋទូតប្រចាំទីក្រុងឡុងដ៍នៃប្រទេសអង់គ្លេស ។ អ្នកដឹកនាំគណបក្សធ្វើការរិះគន់ថាលោក ឌុក ប៉ាស៊ី មានទម្លាប់ធ្វើការជាមួយអ្នកកាន់អំណាច ទោះបីជាគាត់ធ្លាប់ប្រយុទ្ធប្រឆាំងនឹងអ្នកកាន់អំណាចនោះក៏ដោយ ។ ក៏ប៉ុន្តែ ចំពោះលោក ឌុក ប៉ាស៊ី គាត់សំអាងលើទ្រឹស្តីមួយ ដែលមានយុទ្ធសាស្ត្រចូលរួមក្នុងរដ្ឋអំណាច ដើម្បីទៅវាយរំលំ

ពីខាងក្នុង[50] ។ លោក អ៊ិន តាំ នៅទីបំផុត ក៏ត្រូវអូសទាញ ហើយគាត់ក៏សុខចិត្ត ទទួលតំណែងជានាយករដ្ឋមន្ត្រីរបស់លោក លន់ នល់ ។ គាត់សំរេចចូលរួមបំរើ លោក លន់ នល់ ដោយពុំបានពិគ្រោះជាមួយគណបក្សជាមុនឡើយ ដែលនៅទីបំផុតលោក អ៊ិន តាំ ត្រូវបានបណ្តេញចេញពីគណបក្ស ។ តាំងពីពេលនោះមក លោក ចៅ សៅ បានឡើងមកគ្រប់គ្រងគណបក្សយ៉ាងពេញទំហឹង ។ នៅទសវត្សរ៍ឆ្នាំ ១៩៤០ គណបក្សនេះក៏ធ្លាប់បានបណ្តេញលោក ស៊ឹម វ៉ា ដែលជាអ្នកដឹកនាំដ៏ល្បីមួយរូបឲ្យចេញពីតំណែងប្រធានគណបក្សដែរ ។

ក្រុមប្រជាធិបតេយ្យចង់ធ្វើជាស្ពានឈានទៅបញ្ចប់សង្គ្រាម

ប៉ុន្មានខែមុនខ្ញុំចេញដំណើរទៅប្រទេសបារាំង ខ្ញុំ និង បងស៊ីនឿន ព្រមទាំងមិត្តភក្តិខ្លះទៀត តែងនាំគ្នាជិះឡាន 2CW ជាមួយលោក ចៅ សៅ ធ្វើដំណើរជុំវិញក្រុងភ្នំពេញ ។ ពួកយើងតែងផ្លាស់ប្តូរគំនិតគ្នាអំពីវិធីណាខ្លះ ដែលយើងអាចប្រើក្នុងការគ្រប់គ្រងប្រទេស ប្រសិនបើគណបក្សប្រជាធិបតេយ្យ ត្រូវឡើងកាន់អំណាច ។ នៅពេលនោះ យើងលើកបញ្ហាអំពើពុករលួយដែលកំពុងស៊ីរូងសង្គមខ្មែរយ៉ាងជ្រៅ ហើយដែលកំពុងគំរាមកំហែងអនាគតរបស់យើងមកពិភាក្សាគ្នា ។ ពួកយើងនឹកឃើញថា បញ្ហានោះមិនងាយដោះស្រាយបានឡើយ ក៏ប៉ុន្តែក្នុងចំណោមយើងនោះ ក៏មានម្នាក់និយាយបែបកំប្លែងលេងថា អ្នកដែលប្រព្រឹត្តអំពើពុករលួយគួរតែត្រូវសំលាប់ចោល។ នៅក្នុងចិត្តពួកយើង គ្មាននរណានឹកដល់ការកាប់សំលាប់នរណាម្នាក់ងាយៗនោះទេ ។ ចំពោះពួកយើងៗគ្រាន់តែនិយាយលេងបែបកំប្លុក

[50] នេះដោមតិដែលមេដឹកនាំគណបក្សប្រជាធិបតេយ្យ ជាពិសេស លោក ចៅ សៅ ធ្លាប់បកស្រាយប្រាប់ពួកយើងក្មេងៗ នាសម័យនោះ ។

កំប្លែងតែប៉ុណ្ណោះ ផ្ទុយពីក្រុមខ្មែរក្រហម ដែលបានកាប់សំលាប់ប្រជាពលរដ្ឋ និង មន្ត្រីរដ្ឋការរបស់របបលោក លន់ នល់ ស្ទើរតែទាំងអស់យ៉ាងឃោរឃៅបំផុត ។

ពួកអ្នកប្រជាធិបតេយ្យក៏បានសាកល្បងធ្វើជាស្ពាន ដើម្បីឲ្យមានការចរចា គ្នារវាងសាធារណរដ្ឋខ្មែររបស់លោក លន់ នល់ ជាមួយនឹងភាគីម្ខាងទៀតគឺ រណ សិរ្សខ្មែរក្រហមដែលមានព្រះនាមសម្តេច សីហនុ ជាអ្នកដឹកនាំ ។ នៅពេលនោះ ប្រជាពលរដ្ឋខ្មែរភាគច្រើននៅភ្នំពេញ និង នៅទីដ៏ទៃទៀត ប្រហែលរួមទាំង សម្តេច សីហនុ ផង មានជំនឿថាមេខ្មែរក្រហមធំជាងគេគឺ លោក ខៀវ សំផន ។ ជាដំបូង ខ្ញុំក៏មានជំនឿបែបនេះដែរ ។ ហើយខ្ញុំក៏មានបំណងចង់ទៅចូលរួមរណសិរ្សរបស់ សម្តេច សីហនុ នៅឯទីក្រុងប៉េកាំងដែរ ។ នៅពេលដែលខ្ញុំជំរាបគាត់ពីផែនការនេះ និង គោលបំណងរបស់ខ្ញុំក្នុងការចាកចេញពីប្រទេសកម្ពុជាទៅប្រទេសបារាំងនោះ លោក ចៅ សៅ បានទូន្មានកុំឲ្យសំរេចចិត្តយ៉ាងរាក់កំភែលបែបនេះ ព្រោះគាត់ ដឹងច្បាស់ថាមិនមែនសម្តេច សីហនុ ឬ លោក ខៀវ សំផន ទេ ដែលជាអ្នកដឹកនាំ អង្គការខ្មែរក្រហមនោះ ។ ក៏ប៉ុន្តែលោក ចៅ សៅ ក៏មិនបានប្រាប់ខ្ញុំអំពីលោក សាឡុត ស ឬ ប៉ុល ពត ដែរទេ គាត់គ្រាន់តែនិយាយអំពីប្រវត្តិនៃចលនាកុម្មុយនីស្ត ឥណ្ឌូចិន ។ គាត់និយាយថា អ្នកដឹកនាំពិតប្រាកដនៃចលនាកុម្មុយនីស្តស្ថិតនៅក្នុង ភាពងងឹតជានិច្ច ។ ពួកគេមិនដែលបើកចំហរឲ្យគេស្គាល់ជាសាធារណៈនោះទេ ។ លុះត្រាដល់ពេលគេឡើងកាន់អំណាច ទើបគេបញ្ចេញមុខ ។ លោក ចៅ សៅ ក៏ បានពន្យល់អំពីប្រវត្តិសាស្ត្រផ្សេងៗ ដែលមេកុម្មុយនីស្តសម្លាប់គ្នាម្តងមួយៗ ។ លោក ចៅ សៅ បានផ្តែផ្តាំខ្ញុំកុំឲ្យធ្វើអ្វីផ្តេសផ្តាសឲ្យសោះគឺ ឲ្យខ្ញុំនៅអព្យាក្រឹត្យ ក៏ប៉ុន្តែឲ្យខ្ញុំខិតខំថែរក្សាទំនាក់ទំនងល្អជាមួយសហគមន៍ខ្មែរនៅឯបរទេសនោះ ឲ្យ បានច្រើនជាទីបំផុត ។

បងស៊ីនឿន ក៏ខិតខំខ្លាំងណាស់ដែរ ដើម្បីទំនាក់ទំនងជាមួយឪពុកមាខ្ញុំ

ដែលជាគណៈស្រុកនៃចលនាខ្មែរក្រហម នៅស្រុកពារាំង ដែលជាស្រុកកំណើតរបស់ខ្ញុំ ។ ខ្ញុំមិនបានដឹងថា បងស៊ីនឿន បានទទួលអាណត្តិពីគណបក្សឲ្យទៅធ្វើការទាក់ទងជាមួយឪពុកមាខ្ញុំនោះទេ ។ ក៏ប៉ុន្តែ ខ្ញុំហាក់ដូចជាយល់ថានោះគឺ ជានយោបាយរបស់គណបក្ស ដើម្បីបញ្ចប់សង្គ្រាមតាមរយៈការចរចាគ្នា ។ បងប្រុសខ្ញុំ ធ្វើសំបុត្រយ៉ាងខ្លីពីរដងទៅឪពុកមាខ្ញុំ តែគាត់មិនដែលបានទទួលចម្លើយម្តងណាឡើយ ។ ក៏ប៉ុន្តែ ចំពោះសំបុត្រទីបី ឪពុកមាខ្ញុំឆ្លើយយ៉ាងខ្លីតែពីរម៉ាត់ថា "កុំធ្វើអ្វី និង នៅឲ្យស្ងៀម" ។ នៅឆ្នាំ ១៩៧៧ ឪពុកមាខ្ញុំ ក៏ត្រូវខ្មែរក្រហមចាប់ខ្លួន និង យកទៅសម្លាប់ចោលដូចកម្មាភិបាលខ្មែរក្រហមមួយចំនួនធំទៀតដែរ ។

សូមរំលឹកថាលោក សឺន សាន ដែលឡើងកាន់តំណែងជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុនៅក្នុងរដ្ឋាភិបាល រៀបចំឡើងដោយគណបក្សប្រជាធិបតេយ្យ នៅឆ្នាំ ១៩៤៦ និង ដែលក្រោយមកក៏បានក្លាយជាមេដឹកនាំចលនាតស៊ូនាសម័យប្រឆាំងកងទ័ពវៀតណាមនៅទសវត្សរ៍ឆ្នាំ ១៩៨០ នោះ ក៏ធ្លាប់បានដើរតួនាទីដើម្បីជំរុញឲ្យមានការចរចាផ្សះផ្សារគ្នារវាងលោក លន់ នល់ និង សម្តេច សីហនុ ដែរ ។ ដោយធ្លាប់មានស្នាដៃល្អ និង មានស្វាមីភក្តិជាច្រើនឆ្នាំចំពោះសម្តេច សីហនុ និងដោយសារមានទំនាក់ទំនងល្អជាមួយលោក លន់ នល់ ផងនោះ លោក សឺន សាន ប្រហែលនឹកថា នឹងអាចធ្វើជាស្ពានឲ្យមានការចរចាគ្នាបាន ។ នៅពេលដំបូងនៃជម្លោះគឺ នៅពេលដែលលោក លន់ នល់ កំពុងតែមានឥទ្ធិពលខ្លាំង ហើយនៅពេលដែលសម្តេច សីហនុ កំពុងនៅអន់ខ្សោយនៅឡើយនោះ លោក លន់ នល់ ប្រកែកមិនព្រមចរចា ។ ក្រោយមកនៅពេលសភាពការណ៍រឹតតែដុនដាបទៅ លោក លន់ នល់ ចុះខ្សោយ ហើយក៏សុខចិត្តចរចា ក៏ប៉ុន្តែ សម្តេច សីហនុ នៅឯទីក្រុងប៉េកាំងប្រកែកពុំព្រមចរចាម្តងវិញ ។ ខ្មែរយើងភាគច្រើននឹកថាប្រហែលជាស្រុកយើងត្រូវទំនាយថាត្រូវតែកើតសង្គ្រាមរងទុក្ខវេទនាបែបនេះ ព្រោះថាប្រសិនបើភាគីទាំងសង

ខាងសុខចិត្តយល់ព្រមចរចារកវិធីដោះស្រាយជម្លោះតាមសន្តិវិធីវិញ ប្រហែលយើងមិនរងកម្មខ្លោចផ្សាយ៉ាងនេះទេ ។ ក៏ប៉ុន្តែ ចំពោះខ្ញុំៗយល់ឃើញថានេះជាអត្តចរិតអាក្រក់មួយរបស់ខ្មែរ ។ នៅពេលណាគេនឹកថាគេខ្លាំង គេមិនព្រមសម្រុះសម្រួលគ្នាជាមួយគូបដិបក្ខទេ ។

ការចុះទន់ខ្សោយនៃរបប លន់ នល់

ជោគជ័យរបស់ពួកខ្មែរក្រហមដែលបានផ្តួលរំលំរបប លន់ នល់ ក្នុងខែមេសា ១៩៧៥ ជាព្រឹត្តិការណ៍ដ៏ខ្លោចផ្សាមួយ បានរុញច្រានប្រជារាស្ត្រ និង ប្រជាជាតិខ្មែរឲ្យធ្លាក់ចូលក្នុងមហាសោកនាដកម្មមួយអស់រយៈពេល បីឆ្នាំ ប្រាំបីខែ ម្តៃថ្ងៃ មុននឹងត្រូវទទួលការវាយរំលំ ពីកងកម្លាំងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាដោយមានជំនួយពីកងទ័ពវៀតណាម ។ មូលហេតុដែលនាំឲ្យខ្មែរក្រហមឈ្នះសង្គ្រាមនោះមានច្រើនយ៉ាង ។ ម្យ៉ាងគឺរបប លន់ នល់ ជារបបទន់ខ្សោយដែលគ្មានលទ្ធភាពអាចរស់រានមានអាយុបានដោយខ្លួនឯង ប្រសិនបើគ្មានជំនួយពីក្រៅប្រទេស ។ ការដកខ្លួនចេញរបស់សហរដ្ឋអាមេរិកពីសង្គ្រាមនៅវៀតណាម និងនៅតំបន់នាសម័យនោះ ក៏ជាកត្តាជួយជំរុញឲ្យរបបសាធារណរដ្ឋខ្មែររបស់លោក លន់ នល់ ធាប់រលំរលាយថែមទៀតដែរ ។ ម្យ៉ាងទៀតនៅក្នុងសង្គ្រាមត្រជាក់ ពួកខ្មែរក្រហមបានទទួលការគាំទ្រសាមគ្គីសង្គមនិយមអន្តរជាតិ ដែលអាចឲ្យពួកគេមានលទ្ធភាពចាត់តាំងអង្គការ និង កាន់កាប់ប្រទេសទាំងមូលបាន ។ លើសពីនេះទៅទៀត ពួកខ្មែរក្រហមបានទទួលការគាំទ្រពីសម្តេច សីហនុ ដែលមានតំលៃថ្លៃថ្លាចំពោះបដិវត្តន៍ខ្មែរក្រហម ។ សាធារណរដ្ឋខ្មែរ បានធ្លាក់ខ្លួននៅក្នុងស្ថានភាពមួយដ៏ទន់ខ្សោយជាទីបំផុតគឺ ភាពទន់ខ្សោយខាងផ្នែកនយោបាយ និង បន្ទាប់មកទន់ខ្សោយខាងផ្នែកយោធា ។ បន្ទាប់ពីពួកគេនាំគ្នាទម្លាក់សម្តេច សីហនុ ចេញភ្លាម

គឺនៅពេលប្រទេសកំពុងធ្លាក់ចូលក្នុងភ្លើងសង្គ្រាមដ៏សន្ធោសន្ធៅនោះ ដែលទាមទារឲ្យមានការប្រមែប្រមូលផ្តុំកំលាំងជាតិទាំងមូល របបសាធារណរដ្ឋបែរជាជាប់ផុងក្នុងការបាក់បែកគ្នាជាក្រុមជាបក្សជាពួក ប្រឆាំងតែគ្នាឯងទៅវិញ ។ ការប្រកាន់បក្សពួកមិនបានជួយពង្រឹងឯកភាពជាតិឡើយ ។ នៅពេលនោះ ពួកគេត្រូវប្រឈមមុខនឹងការបែកបាក់ផ្ទៃក្នុងផង ប្រឈមមុខនឹងពួករាជានិយមផង ពួកកុម្មុយនីស្តខ្មែរក្រហមផង បូកផ្សំជាមួយនិងការបាត់បង់នូវការគាំទ្រពីប្រជាពលរដ្ឋខ្មែរភាគច្រើនផង ។ អំពើអនាធិបតេយ្យ ក៏លេចចេញឡើង ព្រមៗគ្នាជាមួយអំពីពុករលួយដែលចេះតែរីកធំធាត់ឡើង និង ស៊ីរូងសង្គមខ្មែរយ៉ាងខ្លាំង ។ នៅទីបំផុត ស្ថានភាពនោះក៏នាំទៅរកភាពរលំរលាយនៃរបបសាធារណរដ្ឋទាំងមូលតែម្តង ។

ខាងផ្នែកយោធាកងទ័ពសាធារណរដ្ឋ ត្រូវបានប្រមូលផ្តុំជាកងឯកភាពធំៗ មានទីតាំងនៅក្នុងបន្ទាយដើម្បីការពារទីក្រុងធំៗ និង រដ្ឋធានីភ្នំពេញ ។ កងឯកភាពទាំងនោះ ប្រើយុទ្ធវិធីធ្វើចលនាពេលថ្ងៃ និង សំរាកពេលយប់ ។ ឯទ័ពខ្មែរក្រហមធ្វើផ្ទុយពីនេះ ។ ពួកគេនាំគ្នាកាន់កាប់ភូមិ និង រៀបចំការប្រយុទ្ធនៅពេលយប់ ។ ពួកគេបាញ់កាំភ្លើងបំផ្លោងគ្រាប់ចូលបន្ទាយទាហាន កាត់ផ្តាច់ខ្សែផ្តល់ភ័ស្តុភារ ។ គេធ្វើការរំដោះភូមិ ដើម្បីទៅឡោមព័ទ្ធទីក្រុង នៅពេលដែលមេទ័ពសាធារណរដ្ឋមួយភាគធំ គិតតែប្រព្រឹត្តអំពើពុករលួយប្រមែប្រមូលទ្រព្យសម្បត្តិ ពុំបានចេញទៅចូលរួមក្នុងសង្គ្រាមដោយផ្ទាល់ និង ចេះតែបញ្ជាពីចម្ងាយតែប៉ុណ្ណោះ ។ ទឹកចិត្តកូនទាហានក៏ធ្លាក់ចុះ ។ ពួកកូនទាហាននោះ ក៏នាំប្រពន្ធកូនទៅរស់នៅជាមួយនៅក្នុងបន្ទាយ ឬ ក៏នៅទីលានប្រយុទ្ធខាងមុខ ។ ចំពោះពួកខ្មែរក្រហមគេគិតគូរតែរឿងពង្រឹងកំលាំង ដើម្បីវាយកំទេចរបប លន់ នល់ និង ក្តាប់អំណាចយ៉ាងណែននៅក្នុងតំបន់រំដោះតាមគ្រប់រូបភាព ។

ខ្មែរក្រហមប្រើល្បិចដើម្បីឈ្នះសង្គ្រាម

នៅក្នុងតំបន់ដែលឥទ្ធិពលពួកគេនៅមិនទាន់រឹងមាំ ពួកខ្មែរក្រហមប្រើនយោបាយលួងលោម ដោយយកព្រះនាមសម្តេច សីហនុ ទៅប្រើ ។ គេថាពួកគេជាកងទ័ពរបស់សម្តេច សីហនុ ។ គេមកបំរើប្រជាពលរដ្ឋ មកការពារប្រជាពលរដ្ឋ ។ មានពេលខ្លះពួកគេជួយធ្វើស្រែចំការអ្នកស្រុក ឬ ជួយឃ្វាលគោ ជួយបោសសំអាតផ្ទះសម្បែងរបស់អ្នកស្រុក ជួយថែរក្សាអ្នកជម្ងឺ ។ល។ មានករណីខ្លះ ប្រសិនបើកូនទាហានខ្មែរក្រហមបេះបោចផលដំណាំអ្នកស្រុកដោយមិនបានសុំជាមុន ពួកគេមិនភ្លេចចងបន្សល់ទុកនូវសំបុត្រអភ័យទោស ឬ ពាក្យពេចន៍ផ្អែមល្ហែម ឬ ជួនកាលមានទុកប្រាក់កាសឲ្យផង ។ ដោយសារតែល្បែងសង្គ្រាមចិត្តសាស្ត្រយ៉ាងនេះហើយ ទើបពួកគេឈ្នះសង្គ្រាម ។ នៅក្នុងភូមិស្រុកដែលពួកគេក្តាប់អំណាចបានណែនហើយនោះ ពួកខ្មែរក្រហមក៏ប្រើកំលាំង ឬ អំពើកាចសាហាវយង់ឃ្នងដើម្បីពង្រឹងឥទ្ធិពលរបស់គេ លាយឡំជាមួយនឹងសង្គ្រាមចិត្តសាស្ត្រ តាមវិធីធ្វើការឃោសនារបស់ពួកកុម្មុយនីស្ត ។ បន្ថែមលើនេះ ពួកគេធ្វើការឃោសនាដែលសង្កត់ធ្ងន់លើសង្គ្រាមរំដោះជាតិឲ្យរួចចេញពី "ចក្រព័ត្រអាមេរិក និង ពួកខ្ញុំកញ្ជះវ៉ា" គឺជាសង្គ្រាមរំដោះជាតិមួយ ដែលដឹកនាំដោយអគ្គមគ្គុទេសក៍ ដែលគេជឿថាស្របច្បាប់គឺ សម្តេច សីហនុ ។ តាមប្រពៃណីរាជានិយម នៅប្រទេសកម្ពុជាយើង ប្រជារាស្ត្រមួយចំនួនធំនៅតែទទួលស្គាល់ព្រះអង្គថា ជាអ្នកមានបុណ្យ ជាស្តេចលើពួកគេ ។ ឯចំណែកសម្តេច សីហនុ ព្រះអង្គឯងវិញ ក៏ទ្រង់យល់ដឹងនូវដំរៅទឹកចិត្តរបស់ប្រជារាស្ត្ររបស់ព្រះអង្គដែរ ។ ព្រះអង្គតែងមានបន្ទូលថា "កូនចៅរាស្ត្រគួចតាច" ហើយព្រះអង្គក៏ចេះទាក់ទាញការគាំទ្រពីប្រជារាស្ត្រគួចតាចនោះ តាមរយៈព្រះរាជសារដ៏ញឹកញាប់ ដែលព្រះអង្គផ្ញើពីទីក្រុងប៉េកាំងមក ។ សម្តេច សីហនុ

ក៏ទ្រង់ជ្រាបដែរថាពួកខ្មែរក្រហមគ្រាន់តែយកព្រះអង្គទៅប្រើជាឈ្នាន់ ដើម្បីឲ្យពួកគេបានឈានឡើងកាន់អំណាចតែប៉ុណ្ណោះ ។ ព្រះអង្គធ្លាប់មានព្រះរាជបន្ទូលប្រាប់អ្នកការសែតបរទេសថាពួកខ្មែរក្រហម នឹងបោះបង់ព្រះអង្គចោល ដូចគេខ្ជាក់គ្រាប់ផ្លែស៊ីរីចេញយ៉ាងដូច្នោះដែរ ។ បើយើងមើលទៅ ប្រហែលជាសម្តេចមានការគុំគួនយ៉ាងខ្លាំងចំពោះក្រុមលោក លន់ នល់ ដែលទម្លាក់ព្រះអង្គចេញពីតំណែង ឬ ទំនងជាព្រះអង្គពុំមានផ្លូវឯណាទៀត ក្រៅពីសហការជាមួយពួកខ្មែរក្រហម ដើម្បីទ្រង់ដណ្តើមយកអំណាចមកវិញឲ្យបាននោះ ទើបសម្តេចសុខចិត្តរួបរួមជាមួយពួកនេះ ។ នៅទីបំផុត ពួកខ្មែរក្រហម ក៏បោះបង់ព្រះអង្គចោលមែន ។ នៅពេលដែលពួកគេទទួលជោគជ័យផ្តួលរំលំរបប លន់ នល់ ហើយនោះ ពួកខ្មែរក្រហមពុំបានប្រញាប់យាងសម្តេចឲ្យទ្រង់ចូលនិវត្តមកមាតុភូមិវិញភ្លាមទេ ។ ពួកគេរង់ចាំ រហូតដល់ខែ កញ្ញា ១៩៧៥ ទើបយាងសម្តេចមកទីក្រុងភ្នំពេញ ក្នុងរយៈពេលដ៏ខ្លី មុននឹងបញ្ជូនព្រះអង្គឲ្យទៅថ្លែងសុន្ទរកថានៅអង្គការសហប្រជាជាតិ ក្នុងនាមពួកខ្មែរក្រហម នៅទីក្រុងញូវយ៉ក ។ សម្តេចយាងត្រឡប់មកប្រទេសកម្ពុជាវិញ នៅខែ ធ្នូ ១៩៧៥ ក្នុងឋានៈព្រះអង្គជាប្រមុខរដ្ឋ ដែលគ្មានអំណាចអ្វីទាំងអស់ ។ សម្តេចសីហនុ បានទ្រង់លាឈប់ពីតំណែងជាព្រះប្រមុខរដ្ឋខ្មែរក្រហម ឬ កម្ពុជាប្រជាធិបតេយ្យនៅថ្ងៃទី ២ មេសា ១៩៧៦ ។

ដោយសារអំពើឃោរឃៅយ៉ាងខ្លាំងក្លា ពួកខ្មែរក្រហមបានបង្កើតនូវរដ្ឋអំណាចមួយដែលបង្ហូរឈាមប្រជារាស្ត្រឯងដ៏ធំអស្ចារ្យនៅក្នុងពិភពលោក ។ អំពើប្រល័យពូជសាសន៍ ឬ បើនិយាយឲ្យចំអំពើស្វ័យប្រល័យពូជសាសន៍បានទទួលការផ្តន្ទាទោសយ៉ាងធំធេង និង ការខ្ពើមរអើមពីសំណាក់អន្តរជាតិ ។ ក្រៅពីវិធីពិសេសរបស់ពួកគេក្នុងការកាប់សម្លាប់ គេអាចសង្កេតឃើញចំណុចមួយចំនួនធំដែលឆ្លុះបញ្ចាំងនូវលក្ខណៈនៃរបបផ្តាច់ការនិយមគឺ៖ ការអប់រំឲ្យស្អប់ខ្ពើមគ្នា ការ

កំទេចចោលនូវប្រព័ន្ធក្រុមគ្រួសារ ការកំទេចចោលនូវប្រពៃណីសង្គម និង អារ្យធម៌ ទំនៀមទម្លាប់ពីបុរាណកាល ការប្រឌិតខ្មាំងសត្រូវ ការបង្កើតមនុស្សថ្មីនៅក្នុងសង្គមថ្មី អំណាចដ៏ធំធេងរបស់បក្ស និង ថ្នាក់ដឹកនាំបក្ស ។ល។ ក្នុងរយៈពេលនៃការគ្រប់គ្រងប្រទេសរបស់ពួកគេ ពួកខ្មែរក្រហមមិនត្រឹមតែកាប់សម្លាប់ផ្តាច់ជីវិតជនជាតិខ្មែររាប់លាននាក់ប៉ុណ្ណោះទេ ពួកគេក៏បានកាត់ផ្តាច់នូវទងព្រលឹងរបស់ជាតិខ្មែរដែរ ។ មានសៀវភៅ និង អត្ថបទជាច្រើនដែលបានរៀបរាប់រួចមកហើយ និងយ៉ាងលំអិតនូវវិធី ឬ យុទ្ធសាស្ត្របំផ្លិចបំផ្លាញវប្បធម៌ ប្រពៃណីជាតិ ទំនៀមទម្លាប់ជាតិ ដោយមិនទាន់និយាយអំពីការលុបបំបាត់នូវសិទ្ធិ និង សេចក្តីថ្លៃថ្នូររបស់មនុស្សផង ។ ខ្ញុំទំនងជាមនុស្សម្នាក់ ក្នុងចំណោមមនុស្សមួយចំនួនតូចដែលមានភ័ព្វសំណាង បានគេចរួចពីអំពើព្រៃផ្សៃកាប់សម្លាប់នៃពួកខ្មែរក្រហម ។ ក៏ប៉ុន្តែខ្ញុំក៏ដូចជាគ្រួសារខ្មែរស្ទើតែទាំងអស់ ដែលបានបាត់បង់មនុស្សជាទីស្រឡាញ់ ដោយសារអំពើសាហាវយង់ឃ្នងរស់ពួកព្រៃផ្សៃនេះ ។ ឪពុកខ្ញុំស្លាប់នៅក្នុងឆ្នាំ ១៩៧៥ ដោយសារការអត់ឃ្លាន ។ បងឈឿន បងស៊ីនឿន និង ប្អូនប្រុសពីរនាក់ទៀតគឺ៖ ណារ៉ែន និង វុធធៀន ត្រូវគេបញ្ជូនទៅជំរុំ "អប់រំ" នៅឆ្នាំ ១៩៧៧ ហើយក៏បាត់ដំណឹងសូន្យឈឹងរហូតមក ។

មហាវិនាសកម្មត្រូវចងចាំជាមេរៀនប្រវត្តិសាស្ត្រ

វគ្គនេះនៃប្រវត្តិសាស្ត្រទំនើបរបស់កម្ពុជា ត្រូវបានកត់សំគាល់ដោយការរងទុក្ខវេទនា ដោយសង្គ្រាមឥតឈប់ឈរ និង ដោយការបំផ្លិចបំផ្លាញដ៏មហិមា ។ ក៏ប៉ុន្តែដើម្បីខ្មែរជំនាន់ក្រោយ ខ្មែរគ្រប់រូបគប្បីដកស្រង់ យកមេរៀនពីព្រឹត្តិការណ៍ដ៏អភ័ព្វទាំងនោះ ។ មេរៀនទីមួយ ដែលខ្មែរយើងត្រូវរៀនសូត្រគឺ ត្រូវចេះសំរុះសំរួលគ្នា រស់នៅជាមួយគ្នា និង គោរពគ្នាទៅវិញទៅមក ទោះបីជាយើងប្រឆាំង ឬ

ប្រណាំងប្រជែងគ្នាយ៉ាងណាក៏ដោយ ។ កាលពីអតីតកាល អ្នកដឹកនាំខ្មែរយើងច្រើនទទួលមត៌កនូវវប្បធម៌នៃអំណាចប្រមូលផ្តុំ ឬ អំណាចផ្តាច់ការ ។ អ្នកដឹកនាំទាំងនោះ មិនបានរិះរកនូវវិធីសាស្ត្រនៃការចែករំលែក ឬ នូវតុល្យភាពនៃអំណាចនោះឡើយ ។ រាល់ៗដង នៅពេលដែលយើងមានជម្លោះផ្ទៃក្នុង យើងកម្រនឹងអាចសំរុះសំរួល ឬ ផ្សះផ្សាគ្នាណាស់ ។ អ្នកឈ្នះមិនដែលទុកឲ្យអ្នកចាញ់អាចរួមរស់នៅជាមួយបានឡើយ ឯអ្នកចាញ់ក៏គ្មានជំរើសអ្វី ក្រៅពីស្វែងរករស់ដោយខ្លួនឯងដែរ ។ ពួកគេរង់ចាំពេលវេលាមកដល់ ដើម្បីធ្វើការសងសឹកវិញ ។

បើនិយាយតាមធម៌របស់ព្រះពុទ្ធ គ្មានអ្វីដែលមានភាពអមតៈ មិនប្រែប្រួលនោះឡើយ ។ នោះរាប់ទាំងជ័យជំនះ និង បរាជ័យផង ។ ដូច្នេះរវាងខ្មែរ និង ខ្មែរ ទាំងអ្នកឈ្នះ និង អ្នកចាញ់ត្រូវតែចេះត្រៀមខ្លួនរិះរកបន្ត ដើម្បីធ្វើការផ្សះផ្សាគ្នា ។ ក្នុងកាលកន្លងមក ជាទម្លាប់ទូទៅ នៅពេលដែលខ្លួនបានសេចក្តីសុខ ឬ មានសុវត្ថិភាពហើយ អ្នកចាញ់ក៏មិនដែលទទួលស្គាល់ពីបរាជ័យរបស់ខ្លួនដែរ ហើយក៏តែងតែទៅសុំឲ្យបរទេសចូលរួមនៅក្នុងជម្លោះ ជាពិសេស អ្នកនៅជិតខាងយើងអាស្រ័យទៅតាមកាលៈទេសៈ ដើម្បីឲ្យបរទេសអ្នកជិតខាងទាំងនោះ ជួយពួកគេដែលចាញ់ទៅហើយនោះ ឲ្យត្រឡប់មកកាន់អំណាចវិញ ។ រាល់ៗដង អ្នកជិតខាងរបស់យើងទាំងនោះ ក៏មានចិត្តសប្បុរសជួយផ្តល់មធ្យោបាយឲ្យខ្មែរកាប់សម្លាប់គ្នាតទៅទៀត ។ ជួនកាល អ្នកជិតខាងទាំងនោះក៏បានទទួលផលចំណេញអំពីការអន់ថយរបស់ខ្មែរដែរ ។

មេរៀនដ៏សំខាន់មួយទៀតសំរាប់ខ្មែរគឺ ត្រូវហ៊ានទទួលខុសត្រូវចំពោះសកម្មភាព ឬ អំពើដែលខ្លួនបានធ្វើ ។ នៅក្នុងព្រឹត្តិការណ៍នៃការដួលរំលំរបស់កម្ពុជានៅក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ ឬ ការដួលរំលំរបស់របប លន់ នល់ ឬ ការឡើងកាន់អំណាចនៃរបបខ្មែរក្រហមនៅឆ្នាំ ១៩៧៥ ខ្ញុំពុំទាន់ឃើញមានថ្នាក់ដឹកនាំខ្មែរ

សម័យនោះណាម្នាក់ទទួលស្គាល់ការទទួលខុសត្រូវចំពោះសកម្មភាព ឬ អំពើដែលខ្លួនបានធ្វើឡើយ ក្រៅពីទំលាក់កំហុសទៅអ្នកឯទៀត ។ ជាការពិតណាស់ ខ្មែរយើងភាគច្រើនរួមទាំងសម្តេច សីហនុ ផងតែងនាំគ្នាប្តោលទោសលោក លន់ នល់ ចំពោះព្រឹត្តិការណ៍ខែ មីនា ១៩៧០ ដែលនាំប្រទេសកម្ពុជា យើងធ្លាក់ចូលក្នុងភ្លើងសង្គ្រាម ។ ចំណែកឯលោក លន់ នល់ ត្រូវបក្សពួកគាត់ស្តីបន្ទោសថាជាអ្នកទទួលខុសត្រូវធំជាងគេ ក្នុងការដួលរលំនៃរបបសាធារណរដ្ឋខ្មែរ ។ នាយទាហានថ្នាក់ឧត្តមសេនីយជាច្រើននាក់ ដែលខ្ញុំបានជួបនាទសវត្សរ៍ឆ្នាំ ១៩៨០ មិនដែលទទួលស្គាល់អំពីការខ្វះខាតនូវសមត្ថភាព ឬ ភាពបរាជ័យរបស់ពួកគាត់ឡើយ ក្រៅពីលើកទោសដាក់កំហុសទៅលើលោក លន់ នល់ តែម្នាក់ឯងប៉ុណ្ណោះ ។ រីឯមេដឹកនាំខ្មែរក្រហមវិញ មិនដែលទទួលស្គាល់ការទទួលខុសត្រូវរបស់ខ្លួនទេ ចំពោះអំពើកាប់សម្លាប់ប្រជាពលរដ្ឋខ្មែរគ្នាឯងនោះ ។ ពួកគេច្រើនតែទំលាក់កំហុសទៅលើភ្នាក់ងារសម្ងាត់វៀតណាម ដែលគេចោទថាមកធ្វើវិទ្ធង្សនា កាប់សម្លាប់ប្រជាពលរដ្ឋខ្មែរទៅវិញ ។

ចំណុចសំខាន់ គេមិនត្រូវភ្លេចថារបបគ្រប់គ្រងរដ្ឋដែលអាចគង់វង្ស រឹងប៉ឹង និង រុងរឿងឡើងបាន អាស្រ័យលើការចូលរួមគាំទ្រពីប្រជាពលរដ្ឋ ។ របប ប៉ុលពត មិនបានគិតគូរដល់ប្រជាពលរដ្ឋនោះទេ ទើបត្រូវដួលរលំយ៉ាងឆាប់រហ័សបែបនេះ ។ ពួកគេគិតថាឲ្យតែមានអំណាច អ្វីៗគេអាចធ្វើបានទាំងអស់ រួមទាំងការកាប់សម្លាប់មនុស្ស និង រំលោភសិទ្ធិមនុស្សផង ។ មេដឹកនាំខ្មែរក្រហម តែងតែឃោសនាមិនដាច់ពីមាត់ថា ពួកគេធ្វើបដិវត្តន៍ដើម្បីរំដោះជាតិឲ្យជាតិមានសេរីភាព ឲ្យប្រជាជនមានសុភមង្គល នៅពេលដែលគេគិតតែពីកាប់សម្លាប់ប្រជាជនទាំងនោះ ។ ពួកគេយកពាក្យស្នេហាជាតិធ្វើជារនាំង ដើម្បីកាប់សម្លាប់ជាតិឯងទៅវិញ ។ មេរៀនចុងក្រោយដែលយើងត្រូវរៀនសូត្រនោះគឺ គប្បីផ្តល់សិទ្ធិ សេរីភាព

និង ឯករាជភាពដល់ពួកប្រវត្តិវិទូក្នុងការសរសេរកត់ត្រាប្រវត្តិសាស្ត្រ ។ កាលពីសម័យមុន អ្នកដឹកនាំខ្មែរមួយចំនួន តែងព្យាយាមកែប្រែប្រវត្តិសាស្ត្រ ដើម្បីលើកកំពស់តួបុគ្គលរបស់ខ្លួន សកម្មភាពរបស់ខ្លួន ឬ របបរបស់ខ្លួនរហូតដល់ហ៊ានកែបំភ្លៃការពិត ឬ បំផ្លាញចោលនូវដានរបស់អ្នកមុនៗ នេះមិនទាន់គិតដល់គូប្រឆាំង ឬ គូសត្រូវដែលគេត្រូវតែបំភ្លេចចោលកុំឲ្យឃើញស្រមោលតទៅទៀតផង។ តើគេអាចសិក្សាពីអតីតកាល ដើម្បីលើកយកជាបទពិសោធន៍បានឬទេ? ប្រសិនបើប្រវត្តិសាស្ត្រត្រូវគេបំភ្លៃរួចទៅហើយនោះ ។

ដោយលើកយកមេរៀនពីអតីតកាលនេះ ខ្ញុំយល់ឃើញថា យើងគប្បីសម្លឹងទៅអនាគតក្នុងន័យប្រាកដនិយម ។ ខ្ញុំសរសេរវគ្គនេះដើម្បីគូសសំគាល់នូវភាពធ្ងន់ធ្ងរនៃមហាវិនាសកម្ម ដោយខ្ញុំនៅរក្សាកូនចិត្តនឹកសង្ឃឹមថាតម្លៃខូចខាតដែលខ្មែរយើងបានបង់ហួសទៅហើយនោះ នៅក្នុងព្រឹត្តិការណ៍ដ៏សង្វេគខ្លោចផ្សាកន្លងមក អាចនឹងជួយកែឆ្នៃការបាត់បង់ ឬ មហន្តរាយទាំងនោះ ឲ្យក្លាយទៅជាទុន ដើម្បីលើកកំពស់សីលធម៌នៃការដឹកនាំ និង កសាងប្រព័ន្ធសតិសម្បជ្ញៈមួយ បង្កើតជាចរិយាធម៌ ឬ គុណធម៌នយោបាយ ដែលត្រូវតែស្ថិតនៅជាប់ជាប្រចាំ ជួយការពារកុំឲ្យយើងភ្លេចខ្លួន ដោយយើងមិនធ្វើការប្រុងប្រយ័ត្ន មិនបណ្តែតបណ្តោយឲ្យកំហុសចាស់ពីអតីតកាលអាចកើតមាន និង អាចឲ្យមហាសោកនាដកម្មវិលកើតជាថ្មីឡើងវិញបាន ។ ខ្ញុំសង្ឃឹមថា អំពើខុសឆ្គង ឬ ភាពអន់ថយ ឬ ចំណុចខ្សោយទាំងប៉ុន្មានពីអតីតកាលនោះ អាចនឹងជួយជាស់តឿនក្រើនរំលឹកយើងរាល់គ្នា ឲ្យប្រុងប្រយ័ត្នជានិច្ច ។

វគ្គទី ៤
ជីវិតនៅទីក្រុងប៉ារីស
(ទសវត្សរ៍ឆ្នាំ ១៩៨០)

ដំណើរគ្រាដំបូងតាមយន្តហោះ

គ្រាន់តែចូលក្នុងយន្តហោះភ្លាម បន្ទាប់ពីបានលើកដៃធ្វើសញ្ញាលាគ្នាជាច្រើនរយដងមកនោះ ខ្ញុំក៏លែងបានឃើញមុខឪពុកខ្ញុំ បងៗខ្ញុំទាំងពីរ ប្អូនខ្ញុំពីរនាក់ទៀត តាំងពីពេលនោះជារៀងរហូតមក ។ នារីជនជាតិបារាំងដ៏ស្រស់ក្មេងម្នាក់ បានចង្អុលបង្ហាញកន្លែងអង្គុយរបស់ខ្ញុំនៅក្នុងយន្តហោះ ។ នារីនោះជាអ្នកបំរើសេវាតាមយន្តហោះម្នាក់ ក្នុងចំណោមពីរនាក់ ដែលនៅឈរអមមាត់ទ្វារយន្តហោះ ចាំទទួលស្វាគមន៍អ្នកដំណើរ ។ ជាការគួរឲ្យភ្ញាក់ផ្អើល ខ្ញុំត្រូវទៅអង្គុយនៅកន្លែងមួយជិតកន្លែងកូនលោកចៅហ្វាយស្រុកម្នាក់ ដែលធ្លាប់ធ្វើការនៅស្រុកកំណើតរបស់ខ្ញុំ ។ ដោយសារនេះជាលើកទីមួយដែលខ្ញុំមានភ័ព្វសំណាងបានជិះយន្តហោះ ខ្ញុំពុំដឹងថាតើគេពាក់ខ្សែក្រវ៉ាត់សុវត្ថិភាពយ៉ាងដូចម្តេចទេ ។ ក៏ប៉ុន្តែកូនលោកចៅហ្វាយស្រុកក៏មានការគួរសមចំពោះខ្ញុំ ដោយជួយពាក់ខ្សែក្រវ៉ាត់នោះឲ្យ ។ ពួកយើងគឺ ជាក្រុមអ្នកដំណើរដែលត្រូវចេញដំណើរតាមជើងយន្តហោះ អ៊ុយ តេ អា (UTA) ពីភ្នំពេញ ទៅទីក្រុងប៉ារីសតាំងពីមួយថ្ងៃកន្លងរួចទៅហើយឯណោះ ។ ក៏ប៉ុន្តែពុំដឹងមានមូលហេតុអ្វីទើបជើងយន្តហោះរបស់ពួកយើងត្រូវលើកមកថ្ងៃនេះវិញ ។ ដូច្នេះការធ្វើដំណើររបស់ពួកយើង ត្រូវទៅឈប់សំរាកនៅទីក្រុងបាងកកមួយយប់ មុន

នឹងបន្តដំណើរតទៅទៀត ។ យន្តហោះដែលយើងជិះពីភ្នំពេញ ទៅបាងកកនៅថ្ងៃនោះគឺជាយន្តហោះធុនប៊ូអ៊ីង ៧០៧ ។ កូនលោកចៅហ្វាយស្រុកដែលអង្គុយជិតខ្ញុំនោះ គេមិនចាំបាច់ឈប់សំរាកនៅទីក្រុងបាងកកទេ ។ ពួកគេត្រូវបន្តដំណើរដោយត្រង់ឆ្ពោះទៅទីក្រុងប៉ារីសតែម្តង ។ ពួកយើងមកដល់រាជធានីនៃប្រទេសថៃនៅវេលាល្ងាចថ្ងៃដដែល ។

បន្ទាប់ពីបានបំពេញបែបបទខាងអន្តោប្រវេសន៍រួចមក ពួកយើងត្រូវជិះមីនីប៊ុស (Minibus) ចេញពីអាកាសយានដ្ឋានដនមឿង ទៅកាន់សណ្ឋាគារមួយឋិតនៅកណ្តាលក្រុងបាងកក ។ នៅសម័យនោះ ព្រលានយន្តហោះដនមឿងនៃទីក្រុងបាងកកនៅមានទំហំតូចនៅឡើយ ហើយក៏ពុំទាន់មានភាពទំនើបដូចបច្ចុប្បន្ននេះទេ ។ ការធ្វើដំណើរពីព្រលានយន្តហោះទៅទីក្រុង ហាក់ដូចជាវែងឆ្ងាយណាស់ព្រោះផ្លូវក៏ពុំទាន់ល្អ ហើយក៏ពុំទាន់មានអគារធំៗដូចសព្វថ្ងៃនេះដែរ ។ នៅតាមផ្លូវខ្ញុំសង្កេតឃើញផ្ទះឈើខ្លះ និង វត្តអារាមខ្លះមិនខុសគ្នាប៉ុន្មានពីទិដ្ឋភាពនៅប្រទេសខ្មែរយើងឡើយ ។

ពួកយើងត្រូវស្នាក់នៅក្នុងសណ្ឋាគារមួយឈ្មោះ ម៉ង់ដារីន (Mandarin) ដែលផ្តល់ឲ្យយើងនូវសេវាស្នាក់នៅ និង អ្នបអាហារគ្រប់យ៉ាង ។ សណ្ឋាគារនោះឋិតនៅក្បែរតំបន់នៃសាកលវិទ្យាល័យដូឡាឡុងកន ។ នៅក្នុងសណ្ឋាគារនេះ ខ្ញុំជួបជាលើកដំបូងនូវប្រណិតភាពសម្រាប់ជីវិតខ្ញុំ ។ តាំងពីដើមមក ខ្ញុំពុំដែលមានគ្រែពូកអ្វីពិតប្រាកដទេគឺ ធ្លាប់តែទទួលទានដំណេកលើកន្ទេល ក្រាលលើក្តារតែប៉ុណ្ណោះ ហើយខ្ញុំក៏ពុំដែលមានបន្ទប់ទឹកអ្វីស្រួលបួលដែរ ។ ខ្ញុំធ្លាប់តែងូតទឹកពាងដែលមានរបាំងបន្តិចបន្តួច ។

បន្ទាប់ពីទទួលទានបាយល្ងាចរួច អ្នកដំណើរមួយចំនួនមិនចូលសំរាកភ្លាម

ទេ គេនាំគ្នាចេញទៅដើរលេងខាងក្រៅ មើលភ្លើងក្នុងទីក្រុង ឬ ដើរកំសាន្តតាមរង្គសាលដែលនៅក្បែរសណ្ឋាគារនោះ ។ ផ្ទុយពីអ្នកឯទៀត ខ្ញុំដើរតម្រង់ទៅបន្ទប់ខ្ញុំតែម្តង ។ ខ្ញុំចង់ឆ្លៀតឱកាសឲ្យបានយូរ ដើម្បីក្រេបជញ្ជក់នូវភាពប្រណិត និង ប្រើឲ្យឆ្អែតនូវគ្រឿងសង្ហារឹមទំនើបៗទាំងឡាយដូចជា សាឡុង គ្រែពូក ម៉ាស៊ីនត្រជាក់ ទូរទស្សន៍ និង គ្រឿងសង្ហារឹម ឬ អសង្ហារឹមឯទៀត ដែលខ្ញុំមិនធ្លាប់បានប្រើសោះ ។ នោះគឺ ជាលើកទីមួយ ដែលខ្ញុំទៅងូតទឹក សំអាតរាងកាយនៅក្នុងបន្ទប់ទឹកដ៏ទំនើប ។ ខ្ញុំហាក់ដូចជាមានការអៀនខ្មាស់ខ្លះចំពោះខ្លួនឯង ។ នៅប្រទេសយើង ឬ នៅឯផ្ទះយើងៗមានទម្លាប់យ៉ាងហោចណាស់ក៏ស្លៀកក្រមាដែរ ដើម្បីងូតទឹក មិនដូចជាទម្លាប់របស់អ្នកបស្ចឹមប្រទេស ដែលគេតែងលែងខ្លួនទទេនៅពេលជំរះកាយក្នុងបន្ទប់ទឹកនោះទេ ។ ពេលនោះក៏ជាលើកទីមួយដែរ ដែលខ្ញុំអាចទទួលទានដំណេក លើគ្រែដ៏មានពូកក្រាស់ ប្រកបដោយភួយ និង កម្រាលដ៏សស្អាត ។ កាលនោះ ខ្ញុំមិនទាន់ស្គាល់របៀបរបបនៃការទទួលទានដំណេកឲ្យបានត្រឹមត្រូវនោះទេ ។ តាមធម្មតា គេចូលទៅសម្រាកក្នុងភួយ ដែលគេក្រាលជាស្រេចនៅលើពូក ។ ចំពោះខ្ញុំនៅពេលនោះ ខ្ញុំស្មានតែភួយនោះជាកម្រាលពូក ដូច្នេះខ្ញុំក៏ទទួលទានដំណេកនៅពីលើ ឬ នៅក្រៅភួយទៅវិញ ។ ដោយសារខ្ញុំរកភួយមិនឃើញ និងដោយសារតែម៉ាស៊ីនត្រជាក់ ដែលខ្ញុំមិនទាន់ចេះបន្ថយ ឬ បន្ថែមកម្លាំង ខ្ញុំទទួលរងរងារអស់មួយយប់ ។

ព្រឹកឡើង ខ្ញុំក៏ដឹងថាមិនមែនមានតែខ្ញុំទេ ដែលមិនធ្លាប់រស់នៅក្នុងសណ្ឋាគារដ៏ធំបែបនេះ ។ អ្នកដំណើរមួយចំនួនធំ នាំគ្នានិយាយកំប្លែងអំពីការភ័ន្តច្រឡំក្នុងការប្រើប្រាស់កំរាលគ្រែ ជំនួសភួយដូចខ្ញុំដែរ ។ តាមពិត អ្នករួមដំណើរជាមួយខ្ញុំមួយចំនួនធំ សុទ្ធតែចេញមកពីក្រុមគ្រួសារអ្នកស្រុកសាមញ្ញ មិនមែនសុទ្ធតែជាគ្រួសារអ្នកមានទេ ។ ដូច្នេះការស្នាក់អាស្រ័យរបស់យើង នៅក្នុងសណ្ឋាគារនោះ

ជាគំហើញដំបូងបង្អស់នូវអ្វីដែលហៅថាប្រណិតភាព ។ ក្នុងចំណោមអ្នករួមដំណើរ មាននារីម្នាក់អមដំណើរដោយកូនតូចៗពីរនាក់ផង ទំនងជាមានស្វាមីធ្វើការជាអ្នកការទូត ។ គាត់ប្រាកដជាធ្លាប់ធ្វើដំណើរចេញចូល ទៅក្រៅប្រទេសញឹកញាប់ណាស់ ។ នារីនោះបានណែនាំពន្យល់ពួកយើង អំពីរបៀបរបបទទួលទានអាហារ របៀបកាន់សមស្លាបព្រា ឬ ទទួលទានដំណេកតាមបែបស៊ីវិល័យ ។ គាត់តែងតែសើចកក្អាកក្អាយជាញឹកញាប់ នៅពេលដែលគាត់ឮពាក្យកំប្លែងរបស់ពួកយើងអំពីការភ័ន្តច្រឡំ ក្នុងការប្រើប្រាស់ឧបករណ៍ផ្សេងៗនៅក្នុងបន្ទប់ ។

ស្អែកឡើង នៅពេលដែលពួកយើងត្រឡប់ទៅព្រលានយន្តហោះវិញនោះ នារីនោះក៏បានជួយណែនាំពន្យល់យើង ឲ្យចេះបំពេញបែបបទអន្តោប្រវេសន៍ ក្នុងការបន្តដំណើរតទៅទៀត ។ តាមធម្មតាក្នុងការធ្វើដំណើរ យើងតែងមាននារីជនជាតិថៃអមដំណើរ និង ជួយពន្យល់យើងយ៉ាងលំអិតអំពីបែបបទដែលយើងត្រូវបំពេញ ។ ក៏ប៉ុន្តែ ចំពោះពួកយើង ដែលចេះដឹងភាសាបន្តិចបន្តួច យើងមិនអាចយល់ច្បាស់លាស់អំពីក្រឹត្យក្រមនៃការធ្វើដំណើរនោះបានឡើយ ។ ដូច្នេះនារីខ្មែរដែលមានកូនពីរនាក់នោះ បានជួយពន្យល់បន្ថែមជាលំអិត ។ ការណែនាំរបស់គាត់មានប្រយោជន៍ខ្លាំងណាស់ចំពោះយើង ។ លើសពីនេះទៅទៀត ពួកយើងត្រូវបង់ពន្ធអាករព្រលានយន្តហោះផង ។ ខ្ញុំពុំបានត្រៀមប្រាក់សំរាប់បង់ពន្ធអាករនេះទេ ។ ដូច្នេះ នារីខ្មែរនោះក៏មានចិត្តល្អ ជួយចេញប្រាក់បង់ថ្លៃអាករជំនួសខ្ញុំ ។ ខ្ញុំជំពាក់គុណនារីខ្មែរនោះច្រើនណាស់ ចំពោះការជួយណែនាំរបស់គាត់ និង ចំពោះតំលៃពន្ធអាករព្រលានយន្តហោះ ដែលគាត់ជួយចេញឲ្យខ្ញុំដោយសប្បុរស ។ តែគួរឲ្យស្តាយជាពន់ពេក ដែលខ្ញុំមិនបានសួរឈ្មោះ និង អាស័យដ្ឋានរបស់គាត់ ។ ដូច្នេះខ្ញុំក៏មិនស្គាល់គាត់ រហូតដល់បច្ចុប្បន្នកាលនេះ ។ ខ្ញុំមិនដឹងថានារីនោះនៅរស់ ឬ ស្លាប់ទៅហើយនៅសម័យ ប៉ុល ពត ។

នៅក្នុងយន្តហោះ ខ្ញុំសប្បាយនឹងសេវាកម្មនៅលើអាកាសនេះណាស់ ដែលមានទាំងសេវាបំរើម្ហូបអាហារ កេសជ្ជៈ និង ការឈប់សំចតនៅជាច្រើនដំណាក់នៅក្នុងប្រទេសមួយចំនួន នៅពេលយើងឆ្លងកាត់ទម្រាំទៅដល់ប្រទេសបារាំង ។ ខ្ញុំសប្បាយនឹងសេវាកម្មទាំងអស់នោះ ដោយភ្លេចខ្លួនថាការធ្វើដំណើរតាមផ្លូវអាកាសលើកនេះ នឹងនាំខ្ញុំទៅពិភពមួយថ្មីអស់រយៈពេលមួយដ៏យូរអង្វែង ។ ការផ្សងព្រេងពិតប្រាកដរបស់ខ្ញុំចាប់ផ្តើមឡើង នៅពេលដែលនារីបំរើតាមយន្តហោះប្រកាសតាមឧឃោសនសព្ទថា បន្តិចទៀតនេះយន្តហោះនឹងចុះចតនៅប្រទេសបារាំង ។ នារីនោះនិយាយថា "អស់លោកអ្នកកំពុងឆ្លងកាត់ទីក្រុងស៊ូរិកនៃប្រទេសស្វីស ក្នុងរយៈពេលបន្តិចទៀតលោកអ្នក នឹងទៅដល់ទីក្រុងប៉ារីស" ។ គឺនៅពេលនោះ ទើបខ្ញុំចាប់អារម្មណ៍ចំពោះទីដៅចុងក្រោយនៃការធ្វើដំណើររបស់ខ្ញុំ ។ ថ្ងៃនោះគឺ ថ្ងៃទី ៨ ខែ ៨ ឆ្នាំ ១៩៧៣ ជាតួលេខមួយដែលស្រួលចាំជាទីបំផុត ។ នៅថ្ងៃនោះ យន្តហោះបានចុះចតនៅអាកាសយានដ្ឋានទីក្រុងប៉ារីស ឈ្មោះអកលី (Orly) ព្រោះអាកាសយានដ្ឋានស្គាលដឺហ្គោល (Charles de Gaulle) មិនទាន់កើតនៅឡើយទេ ។

ជីវិតផ្សងព្រេងនៅទីក្រុងប៉ារីស

តាមពិត ខ្លួនខ្ញុំមិនបានដឹងថា តើខ្ញុំត្រូវចេញទៅទីកន្លែងណាទេ នៅពេលចេញពីអាកាសយានដ្ឋានអកលីនោះ ។ នៅច្រកចេញចូលនៃក្រុមប៉ូលីសអន្តោប្រវេសន៍ ខ្ញុំបានបំពេញបែបបទ ដោយចុះនូវអាស័យដ្ឋានមួយ ដែលខ្ញុំមិនធ្លាប់ស្គាល់ទាល់តែសោះ ដោយខ្ញុំគ្រាន់តែចម្លងតគ្នា ពីអ្នករួមដំណើរជាជនជាតិខ្មែរដូចគ្នាឯទៀត ដែលគេហុចពីមួយទៅមួយជាហូរហែ ។ ក្រោយពីបានបំពេញបែបបទរួច

ហើយ ខ្ញុំក៏ដើរចេញទៅក្រៅនៃអគារអាកាសយានដ្ឋាន តាមពីក្រោយនិស្សិតខ្មែរម្នាក់ ដែលទំនងជាមានអាយុប្រហាក់ប្រហែលខ្ញុំដែរ ។ និស្សិតខ្មែរនោះ ហាក់ដូចជាធ្លាប់ធ្វើដំណើរចេញចូលទីក្រុងប៉ារីសយ៉ាងញឹកញាប់ណាស់ ព្រោះគេដូចជាស្គាល់ទីកន្លែងយ៉ាងច្បាស់លាស់ ។ គេបាននិយាយប្រាប់ខ្ញុំថា នេះមិនមែនជាការធ្វើដំណើរលើកទីមួយរបស់គេនោះទេ ។ និស្សិតនោះ មានបងប្អូន និង មិត្តភក្តិពីរឬ បីនាក់មកទទួលនៅអាកាសយានដ្ឋាន ។

នៅពេលដែលនិស្សិតនោះ កំពុងរង់ចាំរថយន្តរបស់បងប្អូន ដែលត្រូវជូនចេញពីអាកាសយានដ្ឋានទៅទីក្រុងប៉ារីសនោះ ខ្ញុំក៏ដាច់ចិត្តសុំឲ្យជួយដោះស្រាយបញ្ហាបន្ទាន់របស់ខ្ញុំ ។ បញ្ហាដ៏ធំគឺ ខ្ញុំមិនស្គាល់ទិសតំបន់អ្វីទាំងអស់ ជាពិសេស ខ្ញុំមិនដឹងថាតើខ្ញុំត្រូវទៅទីណាឲ្យពិតប្រាកដទេ ។ ខ្ញុំលូកក្នុងហោប៉ៅទាញយកក្រដាសមួយសន្លឹក ដែលខ្ញុំបានកត់អាស័យដ្ឋាននៃទីកន្លែង ដែលខ្ញុំអាចទៅរក ។ ខ្ញុំក៏បង្ហាញនិស្សិតនោះ នូវអាស័យដ្ឋានរបស់គ្រួសារខ្មែរមួយ ដែលធ្លាប់រស់នៅទីក្រុងភ្នំពេញ ជាអ្នកជិតខាងគ្នា ឈ្មោះគ្រួសារលោកវេជ្ជបណ្ឌិត ស៊ូ ណែម ។

លោកវេជ្ជបណ្ឌិត ស៊ូ ណែម បានទទួលអាហារូបករណ៍មកបន្តវិជ្ជាឯកទេសខាងវិជ្ជាពេទ្យនៅទីក្រុងប៉ារីស កាលពីពីរឆ្នាំមុន ។ អាស័យដ្ឋាននោះគឺ លេខ ២ វីឡា ដឺ បែលឡែរ (2 Villa de Bel Air) នៅសង្កាត់ ១២ ទីក្រុងប៉ារីស ។ ខ្ញុំសួរនិស្សិតនោះថា ស្គាល់អាស័យដ្ឋាននោះឬទេ? តើត្រូវធ្វើដូចម្តេច ទើបអាចទៅដល់ទីនោះ? យុវជននោះ និង បងប្អូនរបស់គេ មិនគ្រាន់តែស្គាល់អាស័យដ្ឋាននោះច្បាស់លាស់ប៉ុណ្ណោះទេ ថែមទាំងមានចិត្តសប្បុរស ជានាជូនខ្ញុំទៅជួបលោកវេជ្ជបណ្ឌិត ស៊ូ ណែម តាមរថយន្តរបស់ពួកគេផង ។ ខ្ញុំមានសេចក្តីត្រេកអរណាស់ចំពោះកាយវិការដ៏ប្រពៃរបស់ក្រុមយុវជននេះ ហើយក៏ប្រញាប់ប្រញាល់រត់ចូលទៅក្នុងរថយន្តភ្លាម ។ ក្រុមយុវជនទាំងនោះ បានខិតខំលើកទឹកចិត្ត កុំឲ្យខ្ញុំមានការ

ព្រួយបារម្ភអ្វី ក៏ប៉ុន្តែខ្ញុំនៅតែខ្វល់ខ្វាយក្នុងចិត្ត ព្រោះខ្ញុំមិនដឹងនិយាយប្រាប់លោកវេជ្ជបណ្ឌិត ស៊ូ ណែម ដោយរបៀបណា ។ ពួកយើងមិនដែលស្គាល់ ឬ មិនដែលបាននិយាយរកគ្នា កាលយើងនៅឯប្រទេសខ្មែរនៅឡើយទេ ។ ក្រុមយុវជនទាំងនោះ បានជួយសង្គ្រោះខ្ញុំយ៉ាងខ្លាំង ដោយបាននាំខ្ញុំចូលមកដល់ផ្ទះលោកវេជ្ជបណ្ឌិត ស៊ូ ណែម ។ គួរឲ្យស្តាយ ខ្ញុំមិនបានសួរឈ្មោះ ឬ អាស័យដ្ឋានរបស់យុវជនទាំងនោះ ។ រហូតមកដល់ពេលនេះ ខ្ញុំក៏ពុំបានស្គាល់អ្នកដែលបានធ្វើអំពើល្អ ចំពោះខ្ញុំនេះជារៀងដរាប ។

នៅពេលដែលគាត់បើកទ្វារភ្លាម លោកវេជ្ជបណ្ឌិត ស៊ូ ណែម ប្រហែលមិនបាននឹកគិតពីការមកដល់របស់ខ្ញុំ នៅក្នុងផ្ទះរបស់គាត់នោះឡើយ ។ ក៏ប៉ុន្តែជាកុសលល្អ ភរិយារបស់គាត់បាននឹកដល់កិច្ចសន្ទនា ដែលគាត់បានធ្វើជាមួយឪពុកខ្ញុំកាលពីមួយខែមុន ។ ឪពុកខ្ញុំធ្លាប់បានប្រាប់ភរិយាលោកវេជ្ជបណ្ឌិត ស៊ូ ណែម ថាខ្ញុំមានគំរោងធ្វើដំណើរមកប្រទេសបារាំងនៅពេលខាងមុខ ។ ខ្ញុំមិនប្រាកដថាលោកវេជ្ជបណ្ឌិតមានការភ្ញាក់ផ្អើល ដោយសប្បាយចិត្ត ឬ មិនសប្បាយចិត្តចំពោះភាពចៃដន្យនៃវត្តមានរបស់ខ្ញុំនេះឡើយ ។ ក៏ប៉ុន្តែ លោកស្រីជាភរិយារបស់គាត់បានបង្ហាញភាពស្និទ្ធស្នាលរាក់ទាក់ ។ លោកស្រីចេញមកឈរក្បែរស្វាមី ដោយមានទឹកមុខញញឹម រួចហៅខ្ញុំចំឈ្មោះ ហាក់ដូចជាយើងធ្លាប់ស្គាល់គ្នាជាយូរយារណាស់មកហើយ ។ លោកស្រីធ្វើឲ្យខ្ញុំមានការកក់ក្តៅក្នុងចិត្ត ទោះបីជាយើងមិនធ្លាប់ជិតស្និទ្ធពីមុនយ៉ាងណាក៏ដោយ ។ គាត់នាំខ្ញុំចូលក្នុងផ្ទះ ដោយក្តីរីករាយ ។

ផ្ទះលោកវេជ្ជបណ្ឌិត ស៊ូ ណែម មានបន្ទប់ទទួលភ្ញៀវមួយ បន្ទប់ទទួលទានដំណេកបី បន្ទប់ទឹកពីរ និង ផ្ទះបាយតូចមួយ ។ នៅក្នុងបន្ទប់ទទួលភ្ញៀវ មានមនុស្ស ៥ ឬ ៦ នាក់ នៅក្នុងវ័យអាយុ ៣០ ឆ្នាយឆ្នាំ កំពុងនាំគ្នាលេងបៀ ។ ពួកគេសុទ្ធតែជាអ្នកមានសំណាង បានទទួលអាហារូបករណ៍ពីរដ្ឋាភិបាលបារាំង

ឲ្យមកធ្វើកម្មសិក្សា ឬ បន្តវិជ្ជាបន្ថែមនៅទីក្រុងប៉ារីស ។ ពួកគេច្រើនជាវេជ្ជបណ្ឌិត ដូចលោក ស៊ូ ណែម ដែរ ដែលត្រូវសិក្សាផ្នែកមុខជំនាញឯកទេសនៃវិជ្ជាពេទ្យ ។ លោកស្រី ស៊ូ ណែម បានណែនាំខ្ញុំឲ្យស្គាល់មនុស្សទាំងនោះ ដែលហាក់ដូចជាមិនសូវយកចិត្តទុកដាក់ចំពោះវត្តមានរបស់ខ្ញុំ ដោយពួកគេកំពុងតែជក់អារម្មណ៍ក្នុងល្បែងរបស់គេ ។ ក្រោយពីបាននិយាយមួយម៉ាត់ពីរម៉ាត់ជាមួយខ្ញុំ លោកវេជ្ជបណ្ឌិត ស៊ូ ណែម ក៏ត្រឡប់ទៅចូលរួមលេងល្បែងជាមួយក្រុមមិត្តភក្តិរបស់គាត់ ដោយទុកឲ្យភរិយានៅសំណេះសំណាលជាមួយខ្ញុំ ។

ខ្ញុំដើរត្រង់ឆ្ពោះទៅផ្ទះបាយដែលនៅទីនោះ ខ្ញុំទម្លាក់វ៉ាលីសទុក ។ នៅក្នុងវ៉ាលីសនោះ មានអង្ករ ១៥ គីឡូក្រាម និង សាច់ងៀតមួយចំនួន ។ ខ្ញុំនិយាយលេងសាសងពាក្យសំដីមួយរយៈជាមួយលោកស្រី ស៊ូ ណែម ដោយនាំព័ត៌មានថ្មីៗពីប្រទេសកម្ពុជា ។ នៅពេលទទួលទានបាយថ្ងៃត្រង់មកដល់ ខ្ញុំក៏ជួយរៀបចំទីកន្លែងសំរាប់ទទួលទានបាយទាំងអស់គ្នា ។ តាមពិត យើងទទួលទានបាយផ្ទាល់លើកំរាលក្រដាសកាសែត ដែលយើងក្រាលលើឥដ្ឋ ។ យើងទាំងអស់គ្នាចូលរួមបាយជុំគ្នាដំកង់ជាវង់ដ៏ធំមួយ ។ នៅពេលបាយរួច អ្នកខ្លះបន្តលេងបៀតទៅទៀត អ្នកខ្លះសំរាកដេកថ្ងៃ អ្នកខ្លះត្រឡប់ទៅផ្ទះពួកគេវិញ ។ ដោយខ្ញុំជាមនុស្សថ្មី និងក្មេងជាងគេ ខ្ញុំក៏ជួយលាងចានលោកស្រី ស៊ូ ណែម ផងដែរ ។

លោកវេជ្ជបណ្ឌិត ស៊ូ ណែម មានវ័យ ៣០ ប្លាយឆ្នាំ ។ គាត់មានសម្បុរខ្មៅដូចលោក លន់ នល់ មានគាត់ធំមាំលើសពីជនជាតិខ្មែរធម្មតា ។ គាត់ជាមនុស្សមានសុខភាពល្អ រាងក្រអាញ សមរម្យ មិនធាត់កំប៉ែងកំប៉ោង ។ លោកវេជ្ជបណ្ឌិតនេះ មានប្រជាប្រិយភាពណាស់ ក្នុងចំណោមសហគមន៍ខ្មែរនិយមរបបសាធារណរដ្ឋនៅប្រទេសបារាំង ។ គាត់មានទំនាក់ល្អជាមួយរដ្ឋាភិបាលខ្មែរលោក លន់ នល់ ។ គាត់ជាអ្នកគាំទ្រយ៉ាងខ្លាំងក្លាចំពោះរបបសាធារណរដ្ឋ និង ប្រឆាំង

យ៉ាងចេញមុខចំពោះរបបរាជានិយម ។

ខ្ញុំមិនបានដឹងថាគាត់មានវិជ្ជាឯកទេសអ្វីច្បាស់លាស់នោះទេ ក៏ប៉ុន្តែខ្ញុំឃើញគាត់ឧស្សាហ៍ព្យាយាមធ្វើកិច្ចការ ដែលគាត់យកពីមហាវិទ្យាល័យពេទ្យមកធ្វើនៅផ្ទះ ។ នៅពេលទំនេរ គាត់ឆ្លៀតលេងបៀម្នាក់ឯង ឬ លេងបៀជាមួយមិត្តភក្តិ ។ លោក ស៊ូ ណែម ចូលចិត្តលេងភ្នាល់ក្នុងល្បែងប្រណាំងសេះ ដែលគេហៅថា ជាក់សេ (Tiercé) ។ ក្នុងល្បែងនេះ គាត់មានវិធីសាស្ត្រត្រឹមត្រូវ ដោយសិក្សាតាមកាសែតជំនាញខាងកីឡាប្រណាំងសេះនេះ ។ គាត់ចាំឈ្មោះសេះល្បីៗស្ទើរតែទាំងអស់ ។ ក្រៅពីការសិក្សារៀនសូត្រផ្នែកវិជ្ជាពេទ្យនេះ លោកវេជ្ជបណ្ឌិត ស៊ូ ណែម ក៏ជាប់វល់ក្នុងការកិច្ចផ្សេងទៀតខ្លាំងណាស់ដែរ ។ នៅក្នុងផ្ទះគាត់ សម្លេងទូរស័ព្ទរោទ៍មិនចេះឈប់ ដោយសារមូលហេតុជាច្រើនដូចជា ដំណើរមកដល់ប្រទេសបារាំងនៃក្រុមមិត្តភក្តិ ដែលគាត់ត្រូវទៅទទួល ការរៀបចំលេងល្បែងនានា ឬ បុណ្យទាននៅស្ថានទូតខ្មែរ ឬ ការហៅរកឲ្យគាត់ជួយបំពេញឯកសារបែបបទផ្សេងៗ ។ មិត្តភក្តិរបស់គាត់ចេញចូលផ្ទះគាត់មិនដាច់ ទាំងថ្ងៃទាំងយប់ អ្នកខ្លះពីរ ឬ បីដងក្នុងមួយថ្ងៃ ។ លោកវេជ្ជបណ្ឌិត ស៊ូ ណែម មានទំនាក់ទំនងល្អជាមួយអ្នកជិតខាងរបស់គាត់ ។ ពួកគេមិនដែលមកតវ៉ាអំពីការរំខានណាមួយឡើយ ។

លោកស្រី ស៊ូ ណែម មានអាយុប្រហែលជា ៣០ ឆ្នាំបន្តិចបន្តួច ហើយមានមាឌតូចជាងស្វាមីរបស់គាត់ ។ លោកស្រីមិនមែនជានារីដែលមានរូបសម្រស់ខ្លាំងក្លានោះទេ ក៏ប៉ុន្តែគាត់មានមុខមាត់ជាស្ត្រីខ្មែរ ដែលមានទឹកមុខស្រស់ញញឹមជានិច្ច ។ លោកស្រីជាមេផ្ទះដ៏ប្រពៃ ដែលយកចិត្តទុកដាក់ថែរក្សាគ្រួសារយ៉ាងខ្ជាប់ខ្ជួន ។ លោកស្រីជាអ្នកពូកែនិយាយ គាត់មានរឿងនិយាយមិនចេះចប់ ។ មួយថ្ងៃៗ គាត់ចំណាយពេលជាច្រើននិយាយតាមទូរស័ព្ទ ។

លោកស្រីទទួលរាប់អានខ្ញុំភ្លាមៗ ហើយមិនយូរប៉ុន្មាន យើងក៏ក្លាយទៅជាមិត្តជិតស្និទ្ធ ឬ ជាដៃគូក្នុងការងារផ្ទះទាំងមូល ។ លោកស្រីទើបមកដល់ប្រទេសបារាំងប្រមាណបីខែ មុនខ្ញុំតែប៉ុណ្ណោះ ។ គាត់មានកូនតូចៗពីរនាក់ ប្រុសម្នាក់ ស្រីម្នាក់ ។ គាត់មិនបានយកកូនស្រីតូចរបស់គាត់ មកនៅជាមួយឯប្រទេសបារាំងនោះទេ ។ គាត់យកតែកូនប្រុសច្បងអាយុប្រាំឆ្នាំ មកនៅជាមួយ ។

នៅក្នុងផ្ទះបាយនៅថ្ងៃទីមួយដែលខ្ញុំមកដល់ប្រទេសបារាំងនោះ ខ្ញុំព្យាយាមរៀនជិះម៉ែត្រគឺ រទេះភ្លើងរត់ក្រោមដី ដោយខិតខំមើលផែនទី ព្រោះខ្ញុំចង់ចេះធ្វើដំណើរដោយខ្លួនឯង ដោយមិនចាំបាច់ឲ្យមានគេជូនទៅណាមកណាឡើយ ។ កាលខ្ញុំនៅស្រុកខ្មែរ ខ្ញុំគ្រោងថានៅថ្ងៃទីមួយ ពេលមកដល់ភ្លាម ខ្ញុំត្រូវធ្វើដំណើរទៅការិយាល័យអន្តោប្រវេសន៍នៅទីក្រុងប៉ារីស ដើម្បីសុំលិខិតអនុញ្ញាតស្នាក់នៅភ្លាម ។ ក៏ប៉ុន្តែតាមពិត បែបបទនៃការសុំលិខិតអនុញ្ញាតស្នាក់នៅនោះមានសភាពស្មុគស្មាញ មិនមែនងាយស្រួលដូចខ្ញុំស្មាននោះទេ ។ ខ្ញុំត្រូវធ្វើដំណើរដោយខ្លួនឯង ដោយត្រូវនាំយកទៅជាមួយនូវឯកសារមួយចំនួនដូចជា លិខិតបញ្ជាក់ធនធានលិខិតស្នាក់នៅ និង វិញ្ញាបនប័ត្ររបស់សាលារៀន ដែលខ្ញុំមានបំណងចូលរៀន ។ ដូច្នេះគំរោងផែនការដែលខ្ញុំគិតនៅស្រុកខ្មែរនោះ មិនបានសំរេចភ្លាមៗទេ ។

ម្យ៉ាងទៀត បញ្ហាសំខាន់មួយទៀតនោះគឺ ខ្ញុំត្រូវដោះស្រាយរកទីកន្លែងស្នាក់នៅជាអចិន្ត្រៃយ៍រយៈពេលវែងផង ។ លោក និង លោកស្រីវេជ្ជបណ្ឌិត ស៊ូ ណែម មានចិត្តល្អ ដោយបានទទួលស្វាគមន៍ខ្ញុំ ក៏ប៉ុន្តែនៅផ្ទះរបស់គាត់នោះ ពុំមានបន្ទប់ ឬ គ្រែណាមួយដែលនៅទំនេរឡើយ ។ ក្នុងរយៈពេលបីថ្ងៃខាងមុខ ប្រសិនបើខ្ញុំអាចរង់ចាំ បន្ទប់មួយអាចនៅទំនេរ ដោយហេតុថានិស្សិតម្នាក់ដែលកំពុងស្នាក់នៅនោះ នឹងវិលទៅនៅទីកន្លែងផ្សេងនាពេលខាងមុខ ។ មនុស្សម្នាក់ទៀតដែលនៅក្នុងបន្ទប់នោះដែរ ជាមន្ត្រីជាន់ខ្ពស់នៅក្នុងរបបសាធារណរដ្ឋខ្មែរ ។ នៅពេលដែល

ខ្ញុំទៅដល់ និស្សិតដែលត្រូវរើទៅនៅកន្លែងផ្សេងនោះ មិនបាននៅក្នុងបន្ទប់នោះទេ គេកំពុងតែទៅដើរលេងនៅក្រៅក្រុង តែគេនឹងត្រឡប់មកវិញនៅថ្ងៃស្អែក ដើម្បីរៀបចំខោអាវអីវ៉ែអីវ៉ាន់ទៅនៅកន្លែងថ្មីរបស់គេ ។ ដូច្នេះយប់ទីមួយនៅប្រទេសបារាំងនេះ ខ្ញុំអាចសំរាកនៅក្នុងបន្ទប់ទំនេរនោះបានមួយយប់ ក៏ប៉ុន្តែស្អែកឡើង ខ្ញុំត្រូវចេញទៅរកសណ្ឋាគារ ដើម្បីសំរាកយ៉ាងហោចក៏បីថ្ងៃដែរ ទើបអាចវិលត្រឡប់មកនៅផ្ទះលោកវេជ្ជបណ្ឌិត ស៊ូ ណែម វិញ ។

បន្ទាប់ពីពេលបាយថ្ងៃត្រង់រួចមក លោកវេជ្ជបណ្ឌិត ស៊ូ ណែម បានជូនដំណើរខ្ញុំទៅចែកចាយសំបុត្រ និង វត្ថុអនុស្សាវរីយ៍ដែលខ្ញុំនាំយកមកពីប្រទេសខ្មែរទៅចែកជូនញាតិមិត្តខ្មែរៗ ដែលស្នាក់នៅក្នុងសង្កាត់នានាក្នុងទីក្រុងប៉ារីស ។ លោកវេជ្ជបណ្ឌិត ស៊ូ ណែម ហាក់ដូចជាស្គាល់អ្នកទទួលលិខិត និង អ្នកទទួលវត្ថុអនុស្សាវរីយ៍ទាំងនោះស្ទើរតែទាំងអស់ ។ លោកវេជ្ជបណ្ឌិតបរវេយន្តចំណាស់បន្តិចទៅហើយនោះ ឆ្លងកាត់សង្កាត់នានាតាមផ្លូវដ៏ធំទូលាយ តែពោរពេញទៅដោយរថយន្តយ៉ាងណែនណាន់តាន់តាប់ ។ ដោយសារការធ្វើដំណើរតាមរថយន្តដែលត្រូវឈប់ញឹកញាប់ដោយសារភ្លើងសញ្ញាចរាចរ ក្រហម ខៀវ បិទបើកជាច្រើនកន្លែងនោះ បានធ្វើឲ្យខ្ញុំកើតជម្ងឺពុលរថយន្តស្ទើរទ្រាំពុំបាន ។ នៅពេលនោះខ្ញុំគិតតែខំបិទភ្នែក ដោយមិនបានឆ្លៀតឱកាសមើលទិដ្ឋភាពដ៏ស្រស់បំព្រងនៃទីក្រុងប៉ារីសឡើយ ។

លោកវេជ្ជបណ្ឌិត ស៊ូ ណែម ហាក់ដូចជាសប្បាយរីករាយក្នុងចិត្ត ក្នុងការជួយបំរើសេវានានា ជូនដល់សមាគមខ្មែរនៅប្រទេសបារាំងនោះណាស់ ។ ចំពោះខ្ញុំគាត់ធ្វើហាក់ដូចជាគាត់ និង ខ្ញុំ ជាបងប្អូនបង្កើតនឹងគ្នាដូច្នោះដែរ ។ នៅពេលយើងត្រឡប់ដល់ផ្ទះវិញ ម្ហូបអាហារពេលល្ងាចត្រូវបានរៀបចំហើយជាស្រេច ។ ជាថ្មីម្តងទៀត ខ្ញុំជួយធ្វើការប្រពន្ធលោក ស៊ូ ណែម ក្នុងការរៀបចំទីកន្លែងបរិភោគអា

ហារពេលល្ងាច ដូចពីពេលព្រឹកដែរ ។ ដោយសារតែមានការខុសពេលវេលារវាងប្រទេសខ្មែរ និង ប្រទេសបារាំង នៅពេលទទួលទានអាហារពេលល្ងាចរួចហើយ ខ្ញុំហាក់ដូចជាមានភាពងោកងុយយ៉ាងខ្លាំងស្ទើរតែបើកភ្នែកពុំរួច ហើយបន្ទាប់មក ខ្ញុំក៏លង់លក់ទទួលទានដំណេកយ៉ាងស្កប់ស្កល់រហូតទល់ភ្លឺ ។

ពេលព្រឹកឡើងខ្ញុំភ្ញាក់មុនគេ នៅពេលដែលអ្នកឯទៀតកំពុងតែនៅលង់លក់នៅឡើយ ។ ពេលងូតទឹកដុះខ្លួនរួចហើយ ខ្ញុំក៏សំរេចចិត្តដើរចេញទៅក្រៅផ្ទះតែម្នាក់ឯង ។ ខ្ញុំមានបំណងដើរជុំវិញតំបន់ជិតៗផ្ទះនោះ ដែលកំពុងបិតនៅក្នុងសភាពស្ងាត់ជ្រងុំនាពេលព្រឹកព្រហាមនៅឡើយ ។ ខ្ញុំដើរតាមផ្លូវ វីឡា ដឺ បែលឡែរ (Villa de Bel Air) រួចបត់ឆ្វេងឆ្ពោះទៅមហាវិថី ដឺវ៉ុំងសែន (de Vincennes) ។ ខ្ញុំមិនហ៊ានទៅឆ្ងាយទេ ព្រោះខ្លាចវង្វេងផ្លូវ ។ ខ្ញុំពុំឃើញមានសកម្មភាពអ្វីជាធំដុំនៅឡើយទេ ព្រោះធម្មតាជីវភាពប្រចាំថ្ងៃដ៏ប្រញឹករបស់ប្រជាជននៅទីក្រុងប៉ារីសនឹងត្រូវចាប់ផ្តើមក្នុងពេលមួយទៅពីរម៉ោងទៀតឯណោះ ។ នៅចម្ងាយប្រហែលជាម្តែម៉ែត្រពីផ្ទះ ខ្ញុំសង្កេតឃើញផ្ទះលក់នំប៉័ងចាប់ផ្តើមបើកលក់ហើយ ក៏ប៉ុន្តែនៅមិនទាន់មានអតិថិជនចេញចូលច្រើននៅឡើយទេ ។ ហាងឯទៀតដែលនៅតាមមហាវិថីក៏នៅមិនទាន់បើកទ្វារដែរ ។

នៅតាមចិញ្ចើមផ្លូវ ខ្ញុំមានការភ្ញាក់ផ្អើលជាខ្លាំង ដោយសង្កេតឃើញមានទឹកហូរឥតឈប់ឈរ ។ តាមពិត គេបង្ហូរទឹកនេះ ដើម្បីលាងសំអាតចង្ហូរផ្លូវ ។ ខ្ញុំមានអារម្មណ៍ដូចជាមនុស្សចម្លែក មករស់នៅក្នុងទីក្រុងធំ ដូចពាក្យនិយាយទូទៅថាអ្នកស្រែចូលក្រុងដូច្នោះដែរ ។ មែន ខ្ញុំជាជនបរទេសមករស់នៅក្នុងប្រទេសដទៃដែលអ្វីៗខុសប្លែកពីស្រុកខ្មែរទាំងអស់ សូម្បីតែក្លិនដែលហើរចេញពីធុងសំរាម ឬ ពីផ្ទះបាយក៏ជាការចម្លែកសំរាប់ខ្ញុំដែរ ។ ខ្ញុំត្រូវប្រើពេលវេលាពីពីរទៅបីថ្ងៃទើបស៊ាំនឹងក្លិននោះ ។ អ្វីដែលខ្ញុំចាប់អារម្មណ៍ទីមួយនោះគឺ ទំហំដ៏ធំធេងនៃហេដ្ឋារចនាសម្ព័ន្ធ

ដែលខ្ញុំពុំធ្លាប់ជួបប្រទះសោះដូចជា៖ វិថី រុក្ខវិថី មហាវិថី ស្ពាន ផ្លូវក្រោមដី និង ប្រព័ន្ធទូរគមនាគមន៍ អគ្គិសនី ឬ ប្រព័ន្ធទឹកស្អាតជាដើម ។ ភាពផ្ទុយស្រឡះគ្នារវាងប្រទេសខ្មែរដ៏តូច ដែលមានភាពក្រីក្រ ហើយដែលស្ថិតនៅក្នុងសង្គ្រាមផង និង ប្រទេសបារាំងនាពេលនោះមានកម្រិតខុសគ្នាដូចមេឃ និង ដី ។ ខ្ញុំគិតក្នុងចិត្តថាគឺហេដ្ឋារចនាសម្ព័ន្ធនេះហើយ ដែលជាមូលដ្ឋាននៃការអភិវឌ្ឍ ។

នៅពេលខ្ញុំត្រឡប់មកផ្ទះវិញ លោកវេជ្ជបណ្ឌិត ស៊ូ ណែម និង ភរិយាគាត់ កំពុងទទួលទានអាហារពេលព្រឹក ។ ខ្ញុំក៏ចូលរួមតុជាមួយពួកគាត់ ដោយនាំយកនូវនំប៉័ងក្តៅស្រួយបួនដើមមកជាមួយ ដែលខ្ញុំបានទិញពីហាងលក់នំប៉័ងក្បែរផ្ទះ ។ នំប៉័ងបារាំងមានរសជាតិឆ្ងាញ់ពិសារណាស់ ខ្ញុំចូលចិត្ត ហើយខ្ញុំនឹកថាខ្ញុំអាចទទួលទាននំប៉័ងនេះទទេមួយដើមម្នាក់ឯងក៏បាន ។ បន្ទាប់ពីទទួលទានអាហារពេលព្រឹករួច លោក និង លោកស្រីវេជ្ជបណ្ឌិត ស៊ូ ណែម បានបបួលខ្ញុំជិះរថយន្ត ទៅលេងមិត្តកក្តិរបស់គាត់ និង ទៅផ្សារមេឃមួយនៅក្នុងសង្កាត់ ១២ ទៀត ។ ដូច្នេះខ្ញុំក៏ត្រូវបានចេញក្រៅម្តងទៀត រួចយើងវិលត្រឡប់មកផ្ទះវិញ នៅពេលថ្ងៃត្រង់ ។

នៅពេលរសៀល និស្សិតខាងកុំព្យូទ័រដែលបំរុងគ្រែទុកឲ្យខ្ញុំនោះ បានត្រឡប់ពីដំណើរកំសាន្តរបស់គេមកវិញ ។ និស្សិតនោះឈ្មោះ បែល គេត្រឡប់មកផ្ទះវិញ ដើម្បីរៀបចំខោអាវ និង ប្រដាប់ប្រដារ ដើម្បីរើទៅនៅទីក្រុងកុមព្យែង (Compiègne) ។ បែល មានអាយុច្រើនជាងខ្ញុំ ហើយគេក៏ជួយបង្រៀនខ្ញុំឲ្យចេះជិះម៉ែត្រូ ។ ពួកយើងទិញសំបុត្រម៉ែត្រូ និង ផែនទីក្រុងប៉ារីសមួយច្បាប់ ។ យើងទាំងពីរនាក់ធ្វើដំណើរតាមរទេះភ្លើងក្រោមដី តាមខ្សែបន្ទាត់នៃដំណើរក្រោមដីនោះ ទៅតាមស្ថានីយជាច្រើន ។ ក្នុងឱកាសនោះ ខ្ញុំក៏ឆ្លៀតទៅរកជួលសណ្ឋាគារដើម្បីស្នាក់នៅបណ្តោះអាសន្ន ។ យើងរកបានសណ្ឋាគារមួយដែលមានឈ្មោះថា តេមីនុស ដឺ ឡា ប៉ក ដកឡេអង់ (Terminus de la Porte d'Orléans) ។

បន្ទប់សណ្ឋាគារដែលខ្ញុំជួលនោះ ជាបន្ទប់តូចដែលមានតែគ្រែដេកមួយ និង កន្លែងងូតទឹកមួយតែប៉ុណ្ណោះ ។ ដូច្នេះ នៅយប់ទីពីរនៅប្រទេសបារាំង ខ្ញុំសំរាកនៅសណ្ឋាគារ ។ ព្រឹកឡើង ខ្ញុំទៅផ្ទះលោក ស៊ូ ណែម រហូតទទួលទានបាយរួច ទើបត្រឡប់មកសណ្ឋាគារនេះវិញ ។ តាំងពីពេលដែលខ្ញុំបានជួប បែល នៅលើកទីមួយនោះ ខ្ញុំក៏បែកពីយុវជននេះរហូតមក ។ នៅទីបំផុត ខ្ញុំក៏ចេញពីសណ្ឋាគារមកនៅជាមួយលោក ស៊ូ ណែម វិញ នៅពេល បែល លែងស្នាក់នៅទីនោះជាស្ថាពរ ។

ក៏ប៉ុន្តែ ថ្វីបើខ្ញុំរកបានកន្លែងស្នាក់នៅជាប់លាប់យ៉ាងណាក៏ដោយ ក៏ខ្ញុំនៅមានការខ្វល់ខ្វាយអំពីរឿងមួយទៀតគឺ មធ្យោបាយរស់នៅៗប្រទេសបារាំង ។ បញ្ហាចោទឡើងថា តើខ្ញុំអាចរស់នៅ និង ចិញ្ចឹមខ្លួនឯងបានតាមវិធីណា? ពីប្រទេសកម្ពុជា ខ្ញុំបានទទួលទិដ្ឋាការបារាំងឲ្យមកស្នាក់នៅមិនលើសពីបីខែឡើយ ។ ខ្ញុំយល់ថារឿងទិដ្ឋាការនេះ អាស្រ័យលើស្ថានភាពហិរញ្ញវត្ថុ ។ ខ្ញុំគិតថា ប្រសិនបើខ្ញុំមានការធ្វើ ខ្ញុំអាចរកប្រាក់កាសខ្លះ ហើយខ្ញុំច្បាស់ជានឹងទទួលការអនុញ្ញាតឲ្យស្នាក់នៅដ៏យូរមិនខានឡើយ ។ ដូច្នេះខ្ញុំត្រូវធ្វើយ៉ាងណារកការធ្វើជាបន្ទាន់ ។ បើសិនជាខ្ញុំមានការធ្វើ ខ្ញុំអាចបញ្ជាក់អំពីប្រាក់ចំណូលរបស់ខ្ញុំ នៅពេលទៅដាក់ពាក្យសុំបន្តច្បាប់ស្នាក់នៅក្នុងប្រទេសបារាំងតទៅទៀត ។ ម្យ៉ាងទៀត ជាការដាក់ស្តែង ខ្ញុំត្រូវទៅរកការធ្វើឲ្យបាន ព្រោះថាប្រាក់បន្តិចបន្តួចដែលខ្ញុំបានយកពីប្រទេសខ្មែរមកនោះ ខ្ញុំបានចាយវាយស្ទើរតែទាំងអស់ ។ គ្រាន់តែមកដល់ប្រទេសបារាំងមួយអាទិត្យ ខ្ញុំបានចាយអស់ជាងពាក់កណ្តាលទៅហើយ ។ ម្យ៉ាង ខ្ញុំចំណាយបង់ថ្លៃសណ្ឋាគារ និង ទិញរបស់របរជាវត្ថុអនុស្សាវរីយ៍ ផ្ញើទៅប្រទេសខ្មែរជូនឪពុកម្តាយ បងប្អូនខ្ញុំ ដែលខ្ញុំមានការនឹករលឹកជាខ្លាំង ។ ម្យ៉ាងទៀត ពេលមកដល់ភ្លាម ខ្ញុំសង្កេតឃើញរបស់របរអ្វីក៏ល្អខុសប្លែកពីនៅប្រទេសខ្មែរ ហើយដែលចេះតែទាក់

ទាញចិត្តខ្ញុំឲ្យចេះតែចង់បានចង់ទិញ ដើម្បីផ្ញើទៅឪពុកម្តាយ បងប្អូនឯទីបធ្លាយ ។ ដូច្នេះ ខ្ញុំត្រូវការរកការងារជាបន្ទាន់ជៀសមិនរួច ។

ជាដំបូងខ្ញុំខំរកការធ្វើ

ដំណាក់កាលទីមួយ ខ្ញុំគិតថាខ្ញុំត្រូវតែទាក់ទងជាមួយសមាគមវិជ្ជាជីវៈខាងផ្នែកគណនេយ្យ អេស សេ អេហ្វ (SCF) ជាជាច់ខាត ។ កាលពីនៅស្រុកខ្មែរ ខ្ញុំធ្លាប់បានសរសេរសំបុត្រទាក់ទងទៅសមាគម អេស សេ អេហ្វ ដើម្បីឲ្យ សមាគមនោះជួយរកការងារឲ្យធ្វើម្តងរួចហើយ ។ សមាគមនោះឲ្យយោបល់ថា ខ្ញុំត្រូវមកបង្ហាញខ្លួនដោយផ្ទាល់នៅចំពោះមុខនិយោជក ដែលគេត្រូវការធ្វើសម្ភាសន៍ មុននឹងរើសឲ្យធ្វើការ ។ ដូច្នេះ ខ្ញុំក៏សំរេចចិត្តទៅជួបសមាគមនេះ នៅឯទីស្នាក់ការ ដោយសង្ឃឹមថា គេនឹងជួយរកការងារឲ្យខ្ញុំធ្វើ ។ នៅពេលខ្ញុំទៅដល់ទីស្នាក់ការ មន្ត្រីសមាគមទទួលខ្ញុំយ៉ាងរាក់ទាក់ ។ ក៏ប៉ុន្តែសមាគមមិនអាចជួយខ្ញុំបានទេ នៅពេលនោះ ព្រោះខែ សីហា ជាខែនៃវិស្សមកាលដែលក្រុមហ៊ុននានាត្រូវបិទទ្វារឈប់សំរាកស្ទើរតែទាំងអស់ ។ ខ្ញុំក៏ពុំបាននឹកដល់ពេលវេលានៃការឈប់សំរាករបស់ប្រជាជនបារាំងនោះឡើយ ។ តែមន្ត្រីសមាគមបានផ្តល់យោបល់ឲ្យខ្ញុំរង់ចាំដល់ខែ កញ្ញា ដើម្បីទាក់ទងគ្នាជាថ្មីម្តងទៀត ព្រោះពេលនោះក្រុមហ៊ុនបារាំងនឹងចាប់បើកធ្វើការឡើងវិញ ។ ដូច្នេះខ្ញុំក៏គ្មានជំរើសអ្វី ក្រៅពីរង់ចាំមួយខែទៀតតែប៉ុណ្ណោះ ។ ក៏ប៉ុន្តែសេចក្តីត្រូវការខាងលុយកាក់របស់ខ្ញុំ ចេះតែកើនឡើងហូរហែតឈប់ឈរ ។ ដូច្នេះទំរាំនឹងទៅរកជំនួយពីសមាគម អេស សេ អេហ្វ ទៀតនោះ ខ្ញុំក៏ចាប់ផ្តើមដើរគោះទ្វារការិយាល័យជំនាញការគណនេយ្យ ដែលខ្ញុំប្រទះ ឃើញតាមផ្លូវ និង ដែលមិនទាន់បិទទ្វារសំរាក ។ ខ្ញុំចាប់ផ្តើមដើររកនៅក្បែរៗផ្ទះ ។

និយោជកជាច្រើនឆ្លើយប្រាប់ខ្ញុំថា គេមិនត្រូវការបុគ្គលិកបន្ថែមទៀតទេ ឯអ្នកឯទៀតនិយាយថាអ្នកឯងគួរតែទៅរកការធ្វើឯស្ថានទូតអ្នកឯងទៅ ។

នៅពាក់កណ្តាលខែ កញ្ញា ខ្ញុំត្រឡប់ទៅជួបមន្ត្រីសមាគម អេស សេ អេហ្ម្តងទៀត ។ លើកនេះខ្ញុំមានភ័ព្វសំណាងល្អ ដោយបានជួបនារីចំណាស់ម្នាក់អាយុប្រមាណជាង ៥០ ឆ្នាំ ឈ្មោះលោកស្រី ស្ហាកឡូ (Charlot) ដែលជាប្រធានផ្នែករកការងារឲ្យធ្វើរបស់សមាគម ។ លោកស្រីរើរកឃើញសំបុត្រដែលខ្ញុំ ផ្ញើពីប្រទេសកម្ពុជា និង សំណុំលិខិតផ្ទាល់ខ្លួនរបស់ខ្ញុំ ។ គាត់ពិនិត្យមើលបញ្ជីជ្រើសរើសបុគ្គលិកដែលពួកនយោជកផ្ញើមកសមាគម រួចគាត់និយាយមកខ្ញុំថា "អ្នកគួរតែធ្វើការក្នុងទីក្រុងប៉ារីសនៅជិតៗផ្ទះរបស់អ្នក" ។ ដើម្បីបានការធ្វើភ្លាមៗ ខ្ញុំនិយាយជំរាបលោកស្រី ស្ហាកឡូ ថា ខ្ញុំត្រៀមខ្លួនទទួលធ្វើការងារអ្វីក៏បាន ការងារទាបតូចក៏បាន ។ តាមពិតបើពិនិត្យបទពិសោធន៍នៅកម្ពុជា ខ្ញុំជាគណនេយ្យករពេញសិទ្ធិក៏ប៉ុន្តែនៅទីនេះ ខ្ញុំត្រៀមទទួលការងារតូចទាបឋានៈត្រឹមជំនួយការក៏អាចទទួលបាន ។ លោកស្រី ស្ហាកឡូ ទូរស័ព្ទទៅនិយោជកបីនាក់ ដើម្បីរៀបចំសំរួលណាត់ពេលវេលាឲ្យខ្ញុំទៅជួប ។ លោកស្រី ស្ហាកឡូ ហាក់ដូចជាមាននិស្ស័យជាមួយខ្ញុំ ។ គាត់ហៅខ្ញុំថា "អ្នកប្រុសតូច" "Mon petit" និង និយាយពន្យល់យ៉ាងលំអិតអំពីអាស័យដ្ឋាន ជាទីដែលខ្ញុំត្រូវទៅជួបនិយោជក ដើម្បីធ្វើសម្ភាសន៍ចូលធ្វើការ ។

សូមបញ្ជាក់ថា នៅសម័យនោះ ការងារផ្នែកគណនេយ្យនៅប្រទេសបារាំងសម្បូណ៌ណាស់ យើងមិនពិបាករង់ចាំអស់ពេលដ៏យូរនោះឡើយ ។ ម្យ៉ាងទៀត ខ្ញុំក៏គ្មានបំណងជាក់លក្ខខណ្ឌអ្វីចំពោះការងារនោះទេ ។ ការណាត់ជួបលើកទីមួយ ជាការណាត់ធ្វើសម្ភាសន៍ដើម្បីតំណែងជំនួយការគណនេយ្យករ នៅក្នុងខុទ្ទកាល័យជំនាញការគណនេយ្យឯករាជ្យមួយ ។ នៅពេលចប់សម្ភាសន៍គេប្រាប់ឲ្យខ្ញុំរង់ចាំចម្លើយដែលនឹងផ្តល់នៅពេលក្រោយ ។ ការណាត់លើកទីពីរ ក៏សំរាប់មុខតំ

ណែងជំនួយការគណនេយ្យករដែរ ក៏ប៉ុន្តែគឺ ជាការងារមួយ ដែលស្ថិតនៅក្នុងក្រុមហ៊ុនទេសចរណ៍ស្ថិតនៅក្នុងតំបន់ប៉ាឡេរ៉ូយ៉ាល់ (Palais Royal) ក្នុងសង្កាត់ទីមួយនៃទីក្រុងប៉ារីស ។ ក្រុមហ៊ុននោះ ស្ថិតនៅក្បែរសារមន្ទីរលូវ្រ (Louvre) និងសួនទ្វីលឺរី (Tuillerie) ។

ធ្វើដំណើរតាមម៉ែត្រូ ខ្ញុំឈប់នៅស្ថានីយប៉ាឡេរ៉ូយ៉ាល់ ។ ពីស្ថានីយប៉ាឡេរ៉ូយ៉ាល់ ខ្ញុំដើរសសៀរតាមវិថីលូវ្រ (Louvre) ។ បន្ទាប់ពីបានឆ្លងផ្លូវ ពីមួយទៅមួយរហូតដល់ផ្លូវឈ្មោះវិថី ដឺ ឡេស្ហែល (de l'Echelle) ។ នៅកាច់ជ្រុងវិថីនេះ មានធនាគារមួយដាក់សញ្ញាភ្លើងពណ៌ជាអក្សរ បារាំងថា Change (ប្តូរប្រាក់) ។ មកដល់កាច់ជ្រុងធនាគារនេះបត់ស្តាំបន្តិច ខ្ញុំក៏ទៅដល់មុខអាគារនៃក្រុមហ៊ុនទេសចរណ៍មួយមានដាក់សញ្ញាថា ហ្វារ៉ូសហ្វ្រង់ (Pharos France) ដែលមានអាស័យដ្ឋានលេខ ២ វិថី ដឺ ឡេស្ហែល (de l'Echelle) ។ ជាការគួរឲ្យឆ្ងល់ដែរចំពោះតួលេខ ២ នេះ ព្រោះនៅក្នុងបញ្ជីជាតិ ខ្ញុំកើតនៅថ្ងៃទី ២ ខែ វិច្ឆិកា ហើយខ្ញុំកំពុងតែស្នាក់នៅផ្ទះលេខ ២ វីឡា ដឺ បែល ឡែរ (2 Villa de Bel Air) ។ ម្យ៉ាងទៀត នេះជាការណាត់ជួបសម្ភាសន៍លើក ទី ២ របស់ខ្ញុំដែរ ។

ក្រុមហ៊ុនទេសចរណ៍នោះជាក្រុមហ៊ុនតូច និង គ្រប់គ្រងបែបគ្រួសារ ។ គឺជាសហគ្រាសដែលមានបុគ្គលិកចំនួនតិចជាង ១០ នាក់ ក៏ប៉ុន្តែមានសកម្មភាពការងារជាប់រវល់មិនចេះឈប់ឈរ ។ តាមទ្វារកញ្ចក់ ខ្ញុំអាចមើលពីក្រៅឃើញនារីក្មេងៗពីរនាក់កំពុងឈរជជែកគ្នាដែលម្នាក់ទំនងជាអតិថិជន ។ នៅក្បែរនោះមានបុរសវ័យក្មេងម្នាក់ទៀត កំពុងនិយាយទូរស័ព្ទ ។ នៅបន្ទប់ឯក្រោយ ខ្ញុំឃើញបុរសវ័យចំណាស់បន្តិច កំពុងពិនិត្យសំណុំលិខិតទាំងឡាយក្រោមចង្កៀងបំភ្លឺដ៏តូចមួយដែលដាក់នៅលើតុការិយាល័យរបស់គាត់ ។ នៅពេលខ្ញុំចូលទៅដល់ខាងក្នុង នារីក្មេងម្នាក់ដែលមានពាក់វ៉ែនតាសផង បានបញ្ឈប់ការសន្ទនារបស់គាត់ ដើម្បីសួរ

នាំខ្ញុំ រួចចង្អុលបង្ហាញឲ្យខ្ញុំដើរតាមគាត់ឡើងជណ្តើរតូចមួយទៅជាន់ខាងលើ ។ ប៉ុន្មាននាទីក្រោយមក ខ្ញុំបានដឹងថា នារីក្មេងនោះឈ្មោះ អង់ទាន់ណែត (Antoinette) ដែលជាបុត្រីរបស់ម្ចាស់ហាងទេសចរណ៍នោះ ។

អង់ទាន់ណែត ជាកូនស្រីច្បងក្នុងចំណោមកូនស្រីពីរនាក់ របស់ថៅកែធំនៃហាងនោះ ។ ចំណែកឯបុរសក្មេង ដែលឈរនិយាយទូរស័ព្ទនោះ ឈ្មោះ រីស្ហា (Richard) ជាប្តីរបស់នាង អង់ទាន់ណែត ។ បុរសចាស់ដែលកំពុងអានសំណុំលិខិតនោះ ឈ្មោះលោក ម៉ែឡាតូ (Mélatos) ជាឪពុកមានាង ។ លោក ម៉ែឡាតូ ធ្លាប់ធ្វើជាមេធាវីនៅប្រទេសក្រិក គាត់មានសញ្ញាប័ត្រថ្នាក់បណ្ឌិតខាងច្បាប់ ។

នៅឯជាន់ខាងលើនោះនាង អង់ទាន់ណែត បានប្រញាប់ ប្រញាល់បង្ហាញរូបខ្ញុំចំពោះស្ត្រីបីនាក់ បន្ទាប់មកនាងក៏ត្រឡប់ទៅធ្វើការវិញ ។ ក្នុងចំណោមស្ត្រីបីនាក់នោះ មានម្នាក់ឈ្មោះ ហេឡែន អាមីញែល (Helène Amielle) ដែល ជាម្តាយរបស់ អង់ទាន់ណែត ឯនារីម្នាក់ទៀតគឺ ជាម្តាយមីងរបស់នាង ។ ស្ត្រីទីបីឈ្មោះ អ្នកស្រី ដឺបែហ្ស (Debaize) ជានារីដែលមាន អាយុតិចជាងគេ ។ អ្នកស្រី ដឺបែហ្ស មានអាយុ ៤០ ឆ្នាំបន្តិចបន្តួច ។ គាត់ជាប្រធានក្រុមគណនេយ្យនៃក្រុមហ៊ុននេះ ។ គឺអ្នកស្រី ដឺបែហ្ស នោះហើយ ដែលជាអ្នកសម្ភាសន៍ និង ជាអ្នកសំរេចជ្រើសរើសរូបខ្ញុំ ឬ អត់ ។ ក៏ប៉ុន្តែ ជាការគួរឲ្យឆ្ងល់អ្នកស្រី ដឺបែហ្ស មិនគ្រាន់តែមិនធ្វើសម្ភាសន៍ខ្ញុំប៉ុណ្ណោះទេ គាត់បែរជាមកធ្វើការរៀបរាប់ដោយត្រួសៗអំពីការងារដែលខ្ញុំត្រូវធ្វើ ប្រសិនបើខ្ញុំសុខចិត្តចូលធ្វើការក្នុងក្រុមហ៊ុនជាមួយគាត់ ។ អ្នកស្រីក៏បានឲ្យខ្ញុំដឹងពីសកម្មភាពការងាររបស់ក្រុមហ៊ុនទាំងមូលដែរ ។

អ្នកស្រី ដឺបែហ្ស គ្រប់គ្រងការងារគណនេយ្យ ដោយមានជំនួយការពីរនាក់ ម្នាក់គឺ លោកស្រី ម៉ែឡាតូ ដែលត្រូវជាប្អូនថ្លៃរបស់ អ្នកស្រី ហេឡែន អាមីញែល និង ម្នាក់ទៀតឈ្មោះ ហ្សេសួអា (Jesua) ដែលមានអាយុជិតចូលនិវត្តន៍ទៅ

ហើយ តែប៉ុន្មានខែខាងមុខទៀតប៉ុណ្ណោះ ។ លោកស្រី ម៉េឡាតូ បំពេញការងារផ្នែកគណនេយ្យទូទៅ និង គណនេយ្យចំណូល ។ លោក ហ្សេសួអា បំពេញការងារដូចជា អ្នកទទួលខុសត្រូវបេឡា និង ទំនាក់ទំនងធនាគារ ។ នៅពេលដែលខ្ញុំទៅធ្វើសម្ភាសន៍នោះ លោក ហ្សេសួអា ពុំមានវត្តមាននៅទីនោះទេ ។ លោក ស្រី អាមីញែល ដែលជាភរិយាលោកថៅកែធំមានដើមកំណើត ជាជនជាតិក្រិក គាត់មិនមែនជាបុគ្គលិកប្រចាំថ្ងៃក្រុមគណនេយ្យនេះទេ ក៏ប៉ុន្តែគាត់មកជួយធ្វើការម្តងម្កាលដើម្បីត្រួតពិនិត្យការទារប្រាក់ជំពាក់ពីអតិថិជន ។ ជួនកាល លោកស្រី អាមីញែល និង លោកស្រី ម៉េឡាតូ សន្ទនាគ្នាជាភាសាក្រិក ដោយសារអ្នកស្រីទាំងពីរចេះនិយាយភាសានេះយ៉ាងស្ទាត់ជំនាញ ។

ការងារដែលខ្ញុំត្រូវធ្វើនាពេលខាងមុខ ជាការងារជំនួយការផ្ទាល់របស់អ្នកស្រី ដឺបែហ្ស គឺ រាល់កិច្ចការរបស់គាត់ទាំងអស់រាប់តាំងពីការចុះបញ្ជីការ ការកែតម្រូវគណនេយ្យ និង ការត្រៀមលិខិតបង់ពន្ធដារ ការងារផ្នែកសង្គមកិច្ច ការទារប្រាក់ជំពាក់ រហូតដល់ការធ្វើបញ្ជី ឬ តុល្យការប្រចាំឆ្នាំ ។ បើនិយាយឲ្យខ្លី ការងារអ្វីដែលអ្នកស្រីប្រធានធ្វើ ខ្ញុំត្រូវចេះធ្វើទាំងអស់ ។ ដូច្នេះខ្ញុំត្រូវធ្វើការក្រោមបង្គាប់ផ្ទាល់របស់គាត់ ។ ខ្ញុំនឹកក្នុងចិត្តថាការងារទាំងអស់នេះ ខ្ញុំអាចធ្វើបានទាំងអស់លើកលែងតែការងារខាងពន្ធដារ និង ខាងសង្គមកិច្ច ដែលមានលក្ខណៈខុសគ្នាពីការងារនៅឯស្រុកខ្មែរ ។ អ្នកស្រី ដឺបែហ្ស ឲ្យយោបល់ថា រឿងនេះគ្មានបញ្ហាអ្វីទេព្រោះជាដំបូងយើងអាចរៀនធ្វើការក្នុងផ្នែកនេះបាន ។ ក្រុមហ៊ុននេះបានស្នើផ្តល់ដល់ខ្ញុំនូវប្រាក់បៀវត្សប្រចាំខែចំនួន ១៤០០ ហ្វ្រង់ ។ នេះគឺ ជាប្រាក់បៀវត្សសំរាប់តួនាទីទាបបង្អស់ខាងផ្នែកវិជ្ជាជីវៈគណនេយ្យ ក៏ប៉ុន្តែ ចំពោះខ្ញុំ ខ្ញុំគិតថាសមល្មមសំរាប់កសាងជីវិតថ្មី នៅក្នុងប្រទេសបារាំងនេះហើយ ។ ដូច្នេះ ខ្ញុំក៏ប្រញាប់ប្រញាល់ទទួលយកការងារនេះភ្លាម ដោយគ្មានបង្អែបង្អង់ឡើយ ។ ឃើញដូច្នេះ

អ្នកស្រី ដឺបែហ្សូ ចង់ឲ្យខ្ញុំចូលធ្វើការភ្លាមនៅរំពេចនោះតែម្តង ក៏ប៉ុន្តែខ្ញុំស្នើថាសូមរង់ចាំដល់ថ្ងៃស្អែក ព្រោះខ្ញុំត្រូវការរៀបចំខ្លួនប្រាណឲ្យសមរម្យមុននឹងចូលធ្វើការ ។ មុននឹងបញ្ចប់កិច្ចសម្ភាសន៍របស់យើង អ្នកស្រី ដឺបែហ្សូ បាននាំខ្ញុំទៅជួបលោក ហ្សក អាមីញែល (Georges Amielle) នៅក្នុងការិយាល័យរបស់គាត់ ។ លោក ហ្សក អាមីញែល ជាថៅកែធំក្នុងក្រុមហ៊ុននេះ គាត់មានអាយុជាង ៥០ ឆ្នាំទៅហើយ ។ គាត់មានលក្ខណៈជាជនជាតិមកពីខាង មេឌីទែរ៉ាណេ (Méditerranée) ។ គាត់ពាក់វ៉ែនតា មានឧទាបក្រអាញ និយាយភាសាពីរ ឬ បីថែមពីលើភាសាបារាំង និង ក្រិក ។ លោកថៅកែធំចាប់ដៃខ្ញុំរលាក់ ហើយសរសើរអ្នកស្រី ដឺបែហ្សូ ដែលបានជ្រើសរើសបុគ្គលិកបានយ៉ាងឆាប់រហ័សយ៉ាងនេះ ។ លោកថៅកែធំទទួលស្វាគមន៍ខ្ញុំជាសមាជិកថ្មីនៃបុគ្គលិករបស់គាត់ ។

អ្នកប្រុសតូច

ខ្ញុំចាកចេញពីក្រុមហ៊ុនហ្វារ៉ូសហ្វ្រង់ (Pharos France) ដោយសេចក្តីត្រេកអរ និង ក្តីរំភើបឥតឧបមា ។ ខ្ញុំសប្បាយចិត្តណាស់ ។ ខ្ញុំដើរផង លោតផងម្តងៗ ។ នៅពេលជិតទៅដល់ក្បែរស្ថានីយម៉ែត្រូ ខ្ញុំឆ្លៀតទិញក្រវ៉ាត់កមួយដែលមានតម្លៃដប់ហ្វ្រង់ (10 Francs)[51] ព្រោះក្រវ៉ាត់កដែលខ្ញុំយកមកពីស្រុកខ្មែរនោះមិនត្រូវនឹងម៉ូតទំនើបនៅប្រទេសបារាំងនោះទេ ។ ខ្ញុំមិនប្រញាប់ទៅផ្ទះវិញភ្លាមទេ ខ្ញុំក៏មិនបន្តទៅធ្វើសម្ភាសន៍នៅកន្លែងទីបីផ្សេងទៀតដែរ ព្រោះខ្ញុំបានសំរេចថា ធ្វើការនៅក្នុងក្រុមហ៊ុនហ្វារ៉ូសហ្វ្រង់នេះហើយ ខ្ញុំមិនត្រូវកែប្រែចិត្តខ្ញុំទៀតឡើយ ។ ដូច្នេះ ខ្ញុំក៏ដើរទៅក្នុងហាងលក់ស្រាបៀរ រួចបញ្ជាទិញស្រាបៀរ លាយនឹងទឹកលី

[51] នៅសម័យនោះ ១ ដុល្លារអាមេរិក មានតម្លៃប្រហែល ៣ ហ្វ្រង់ ក្រោយមក ១ ដុល្លារស្មើ ៧ ហ្វ្រង់។

ម៉ូណាតដែលពួកបារាំងតែងហៅថាប៉ាណាស្ហេ (Panachée) មួយកែវយ៉ាងត្រជាក់ និង នំសាំងវិចជាក់សាច់ក្រកមួយដុំផង ។ នោះគឺជាអាហារថ្ងៃត្រង់ ដ៏ធ្ងាញ់ពិសាមួយរបស់ខ្ញុំនៅប្រទេសបារាំង មិនគិតពីម្ហូបអាហារថ្ងៃត្រង់ប្រចាំថ្ងៃ ដែលខ្ញុំបានទទួលពីគ្រួសារលោក ស៊ូ ណែម ទេនោះ ។

នៅពេលត្រឡប់មកផ្ទះវិញ ថ្ងៃរសៀលណាស់ទៅហើយ ពុំមានមនុស្សម្នាច្រើនគ្នាទេ ។ អ្នកស្រី ស៊ូ ណែម កំពុងតែធ្វើម្ហូបនៅឯផ្ទះបាយដូចធម្មតា ។ គាត់មិនដែលដឹងថា ខ្ញុំធ្វើអ្វីខ្លះទេនៅពេលខ្ញុំចេញទៅក្រៅផ្ទះរាល់ថ្ងៃ ហើយគាត់ក៏មិនដែលសួរនាំពីសកម្មភាពរបស់ខ្ញុំដែរទេ ។ គាត់មិនដែលនឹកគិតដល់ថា ខ្ញុំអាចរកការងារធ្វើបានយ៉ាងឆាប់រហ័សបែបនេះទេ និង ជាពិសេសការងារនៅក្នុងការិយាល័យនោះឡើយ ។ ជាទូទៅ និស្សិតខ្មែរភាគច្រើន ដែលមកស្នាក់នៅប្រទេសបារាំងដោយខ្លួនឯង ដោយគ្មានជំនួយពីរាជរដ្ឋាភិបាល ច្រើនតែនាំគ្នាទៅធ្វើការនៅក្នុងភោជនីយដ្ឋានចិន ។ ខ្លះជាអ្នករត់តុ ខ្លះជាអ្នកលាងចាន ។

នៅពេលខ្ញុំប្រាប់គាត់ថា ខ្ញុំទើបតែរកបានការងារធ្វើជាជំនួយការផ្នែកគណនេយ្យនៅក្នុងក្រុមហ៊ុនទេសចរណ៍មួយនៅសង្កាត់លេខមួយ ទីក្រុងប៉ារីស អ្នកស្រី ស៊ូ ណែម មានសេចក្តីត្រេតអរជាអតិបរមា គាត់ទះដៃ និង ទជាក់ជើងលោតឡើងទៅលើ ពោរពេញទៅដោយអំណរ ។ គាត់និយាយថា "មូលី បើខ្ញុំជាម្តាយប្អូនឯង ខ្ញុំនឹងលើកប្អូនឯងទូលតែម្តង" ។ តាំងពីថ្ងៃនោះមក ដើម្បីជួយសំរាលបន្ទុកចំណាយប្រចាំផ្ទះ ខ្ញុំបានសន្យាថានឹងជូនប្រាក់ទៅគាត់ចំនួន ២០០ ហ្វ្រង់ក្នុងមួយខែ ។ អ្នកស្រីយល់ព្រមភ្លាម ។

ព្រឹកស្អែកឡើង ខ្ញុំរៀបចំខ្លួនចេញទៅធ្វើការ ដោយស្លៀកពាក់អាវធំ និងចងក្រវ៉ាត់កដែលធ្វើឲ្យអ្នកនៅក្នុងផ្ទះទាំងប៉ុន្មានមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ព្រោះ

ពួកគេធ្លាប់តែឃើញខ្ញុំស្លៀកក្រមានៅផ្ទះ និង ជួយលាងចានតែប៉ុណ្ណោះ ។ មិត្តភក្តិ របស់លោកវេជ្ជបណ្ឌិត ស៊ូ ណែម មួយចំនួនដែលជាកូនមន្ត្រីធំៗ ដែលធ្លាប់រស់នៅ លើគំនរទ្រព្យសម្បត្តិ ប្រហែលជាមិនដែលនឹកដល់ថា ខ្ញុំអាចកែប្រែរូបរាងយ៉ាងឆាប់ រហ័សដូច្នេះទេ ព្រោះខ្ញុំជាកូនអ្នកក្រ ប្រហែលមិនអាចធ្វើអ្វីកើតក្រៅពីបោសសំអាត និង ជួយលាងចាននោះឡើយ ។ ឥឡូវពួកគេចាប់ផ្តើមយល់ថា ខ្ញុំជាយុវជនមួយ រូប ដែលមានសមត្ថភាពគ្រប់គ្រាន់ ។

នៅការិយាល័យ ខ្ញុំបានត្រូវសហសេវិកទាំងឡាយទទួលរាប់រកយ៉ាងឆាប់ រហ័ស ។ ពួកនារីចាស់ៗទាំងនោះ ស្រឡាញ់រាប់អានខ្ញុំ ដូចអ្នកស្រី ស្លាកឡូ នៅ សមាគម អេស សេ អេហ្វ ដែរ ។ ពួកគេហៅខ្ញុំថា "អ្នកប្រុសតូច" ជាថ្មីម្តងទៀត ។ ខ្ញុំខិតខំធ្វើការងាររបស់ខ្ញុំណាស់ ដើម្បីចិញ្ចឹមជីវិតផង ដើម្បីឲ្យសមនឹងទំនុកចិត្ត និង ការរាប់អានរបស់មេកើយរបស់ខ្ញុំផង ។ ខ្ញុំធ្វើរាល់ការងារទាំងអស់ដែលអ្នកស្រី ជឺបែហ្ស ដាក់ឲ្យធ្វើ ។ ជួនកាលខ្ញុំធ្វើការ ជំនួសលោក ហ្សេសួអា ដោយទៅបំពេញ ការងារនៅឯធនាគារ ជាពិសេសធនាគារមួយដែលបិតនៅជិតមហោស្រពអូប៉េរ៉ា (Opera) ។ ខ្ញុំបានសាងនូវទំនាក់ទំនងជិតស្និទ្ធជាមួយក្រុមគណនេយ្យរបស់យើង ។

នៅពេលសំរាកបាយថ្ងៃត្រង់ ពួកនារីៗរៀបចំម្ហូបអាហាររបស់គាត់នៅក្នុង ផ្ទះបាយដ៏តូចមួយជាប់នឹងកន្លែងធ្វើការ ។ ចំណែកខ្ញុំ ខ្ញុំចូលចិត្តដើរតាមវិថីនានា ចូលទៅទទួលទានសាំងវិច និង ស្រាបៀរនៅកន្លែងលក់ស្រាបៀរមួយក្នុងតំបន់ នោះ ។ ចាប់ពីខ្ញុំចូលធ្វើការមក ខ្ញុំចំណាយលុយកាក់យ៉ាងប្រយ័ត្នប្រយែងបំផុត ព្រោះខ្ញុំពុំមាននៅសល់ប្រាក់ច្រើនទៀតទេនៅដំណាច់ខែ កញ្ញា នោះ ។ ខ្ញុំចំណាយ ប្រាក់តែទៅលើអ្វីដែលចាំបាច់បំផុត ឬ ដៀសពុំរួចដូចជា ប័ណ្ណមេត្រូ និង ម្ហូបអា ហារថ្ងៃត្រង់ ។ បន្ថែមលើនេះនៅពេលខ្ញុំចាប់ផ្តើមចូលធ្វើការ ខ្ញុំបានចំណាយប្រាក់ ទិញអាវរងារមួយ ត្រៀមនឹងរដូវត្រជាក់ ដែលនឹងធ្លាក់មកដល់នាពេលខាងមុខ ។

នៅតែពីរថ្ងៃទៀតដល់ថ្ងៃដាច់ខែបើកលុយ ខ្ញុំក៏អស់លុយរលើងពីខ្លួន ។ ថ្ងៃនោះ ខ្ញុំមិនធ្វើដូចធម្មតាទេ គឺខ្ញុំមិនចូលក្នុងហាងដូចមុនៗឡើយ ផ្ទុយទៅវិញ ខ្ញុំទិញតែនំសាំងវិចមួយ ដែលគេដាក់លក់នៅតាមចិញ្ចើមផ្លូវនៅក្បែរហាងធំមួយឈ្មោះ លូវ្រ (Louvre) ។ ខ្ញុំញញឹមទៅរកអ្នកលក់ នៅពេលខ្ញុំបើកកាបូបប្រាក់ ដកយកកាក់មានតម្លៃ ៥ ហ្រ្វង់ដែលជាកាក់ចុងក្រោយរបស់ខ្ញុំ ។ អ្នកលក់ក៏ញញឹមមកខ្ញុំវិញ ទំនងដូចជាដឹងថា ខ្ញុំមានតែ ៥ ហ្រ្វង់នេះទេ ។ នៅពេលល្ងាចមុននឹងចេញពីធ្វើការ ខ្ញុំដាច់ចិត្តសុំការអនុញ្ញាតពីអ្នកស្រី ដឺបែហ្ស សុំបើកប្រាក់មុនចំនួន ២០០ ហ្រ្វង់ ។ អ្នកស្រីប្រធានហាក់ដូចជាមិនយល់ថា ហេតុអ្វីបានជាខ្ញុំសុំបើកប្រាក់មុនយ៉ាងនេះ បើនៅតែពីរថ្ងៃទៀតតែប៉ុណ្ណោះ យើងនឹងបើកប្រាក់ខែទៅហើយ ។

បារាំងថាខ្ញុំធ្វើការខុសច្បាប់

ខ្ញុំសប្បាយចិត្តនឹងធ្វើការនៅក្រុមហ៊ុន ហ្វារ៉ូសហ្រ្វង់ (Pharos France) នេះណាស់ ។ ក៏ប៉ុន្តែ ក្តីសប្បាយរបស់ខ្ញុំនោះ មិនបានឋិតឋេរយូរវែងឆ្ងាយឡើយ ។ បញ្ហាមិនមែនដោយសារខ្ញុំមានទំនាស់ជាមួយមេកើយរបស់ខ្ញុំ ឬ ជាមួយមិត្តរួមការងារនោះទេ ក៏ប៉ុន្តែបញ្ហាដ៏ធ្ងន់ធ្ងរដែលខ្ញុំត្រូវប្រឈមជាបន្ទាន់នោះគឺ បញ្ហាលក្ខណៈច្បាប់នៃការរស់នៅរបស់ខ្ញុំនៅប្រទេសបារាំង ។ តាមច្បាប់ ខ្ញុំគ្មានសិទ្ធិប្រកបការងារណាមួយនៅក្នុងប្រទេសបារាំងទេ ។ ខ្ញុំមិនមែនជាជនអន្តោប្រវេសន៍ស្របច្បាប់ ។ ខ្ញុំគ្មានប័ណ្ណសន្តិសុខសង្គម និង គ្មានទាំងលិខិតអនុញ្ញាតឲ្យធ្វើការផង ។ ដូច្នេះអ្នកស្រី ដឺបែហ្ស ទើបតែនឹងដឹងថា ខ្ញុំជាអ្នកធ្វើការខុសច្បាប់ ព្រោះគាត់ពុំអាចកសាងសំណុំលិខិតផ្ទាល់ខ្លួនរបស់ខ្ញុំឲ្យបានត្រឹមត្រូវ ។ តាមច្បាប់បារាំង និយោជកដែលរើសយកអ្នកធ្វើការខុសច្បាប់ នឹងត្រូវទទួលទោស ។ ប៉ុន្តែផ្ទុយទៅវិញ និយោជក

របស់ខ្ញុំ សុខចិត្តជួយរកវិធីដោះស្រាយ ដោយរក្សាទុកខ្ញុំឲ្យធ្វើការ និង ដោយលើកទឹកចិត្តឲ្យខ្ញុំខំរកវិធីរត់ការតាមផ្លូវច្បាប់ ដើម្បីឲ្យមានសិទ្ធិធ្វើការពេញទីនៅក្នុងប្រទេសបារាំង ។ ដូច្នេះអ្នកស្រីទទួលឲ្យខ្ញុំធ្វើការដោយលួចលាក់សិន ទម្រាំដល់ពេលដែលខ្ញុំអាចទទួលឯកសារផ្លូវការ និង មានច្បាប់ស្នាក់អាស្រ័យនៅត្រឹមត្រូវឡើងវិញ ។

នៅពេលនោះ ខ្ញុំធ្វើការដោយយកប្រាក់សុទ្ធ និង ដោយគ្មានឈ្មោះក្នុងបញ្ជីបុគ្គលិកស្របច្បាប់របស់ក្រុមហ៊ុនឡើយ ។ មានពេលមួយនោះ អ្នកស្រីឲ្យខ្ញុំចូលទៅលបសម្ងំពួននៅក្នុងផ្ទះបាយ ក្នុងរយៈពេលពេញមួយថ្ងៃ ដើម្បីលាក់ខ្លួនកុំឲ្យមន្ត្រីត្រួតពិនិត្យអធិការកិច្ចការងាររបស់រដ្ឋាភិបាលរកឃើញ នៅពេលមន្ត្រីនោះចុះមកឆែកឆេររកអ្នកធ្វើការខុសច្បាប់ នៅក្នុងក្រុមហ៊ុន ។ មិនតែប៉ុណ្ណោះ ដើម្បីជួយសំរួលការងាររបស់ខ្ញុំ ថៅកែរបស់ខ្ញុំ ជាពិសេសនារីចាស់ៗនៅក្នុងផ្នែកគណនេយ្យទាំងនោះ បានរៀបចំកិច្ចព្រមព្រៀងការងារមួយច្បាប់ ដែលខ្ញុំអាចយកទៅសុំច្បាប់ពីអាជ្ញាធរបារាំង ។ ពួកគាត់ទុកពេលឲ្យខ្ញុំគ្រប់គ្រាន់ ដើម្បីទៅរត់ការ ឬ បំពេញបែបបទនានា ក្នុងន័យកែសំរួលស្ថានភាពរបស់ខ្ញុំឲ្យត្រឹមត្រូវតាមច្បាប់ឡើងវិញ ។

តាមច្បាប់នៃប្រទេសបារាំង ជនបរទេសដែលមានបំណងចូលមកធ្វើការត្រូវមានកិច្ចព្រមព្រៀងការងារ និង ត្រូវសុំទិដ្ឋាការអន្តោប្រវេសន៍ពីស្ថានទូតបារាំងនៅក្នុងប្រទេសរបស់ខ្លួនជាមុនសិន មុននឹងមកជាន់លើទឹកដីបារាំង ។ នៅពេលមកដល់ប្រទេសបារាំង ជនបរទេសនោះ ត្រូវដាក់ពាក្យសុំប័ណ្ណអនុញ្ញាតឲ្យធ្វើការ និង ប័ណ្ណអនុញ្ញាតឲ្យស្នាក់នៅ ដែលចេញដោយមន្ទីរអន្តោប្រវេសន៍ និង ក្រសួងការងារបារាំង ។ ចំពោះករណីរបស់ខ្ញុំ ជាករណីដែលមានលក្ខណៈផ្ទុយស្រឡះពីច្បាប់ទាំងស្រុង ។ ខ្ញុំចូលមកក្នុងទឹកដីបារាំង ដោយគ្មានកិច្ចសន្យាការងារ និង ដោយមានទិដ្ឋាការមិនមែនជាទិដ្ឋាការអន្តោប្រវេសន៍ ។ ម្យ៉ាងទៀត ការងារដែលខ្ញុំកំពុង

ធ្វើនោះ គឺជាការងារមាននៅក្នុងបញ្ជីហាមឃាត់មិនឲ្យជនបរទេសធ្វើ ។ ដូច្នេះ ខ្ញុំមានលទ្ធភាពតិចតួចណាស់ក្នុងការកែប្រែស្ថានភាពរបស់ខ្ញុំពីខុសច្បាប់ឲ្យទៅស្របច្បាប់វិញ ។

នៅពេលនោះទើបខ្ញុំដឹងថា ហេតុអ្វីបានជាជនរួមជាតិខ្ញុំមួយចំនួនត្រូវបង្ខំចិត្តលបលួចធ្វើការជាអ្នកលាងចាននៅក្នុងភោជនីយដ្ឋានចិននានា ។ ដោយសារមានការលំបាកក្នុងការសុំប័ណ្ណការងារនេះហើយ ទើបខ្ញុំឃើញជនជាតិខ្មែរមួយចំនួន ដែលពុំមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ សុខចិត្តវិលត្រឡប់ទៅប្រទេសខ្មែរយើងវិញ ជាជាងរស់នៅដោយខុសច្បាប់ ដែលអាចឲ្យប៉ូលីសបារាំងចាប់ដាក់គុក ។ ចំពោះអ្នកទាំងនោះ គេស្ថិតនៅក្នុងរង្វង់និតិក្រមមួយដែលវិលនៅមួយកន្លែង ។ ក្រសួងអន្តោប្រវេសន៍អាចចេញប័ណ្ណស្នាក់នៅឲ្យខ្ញុំ ប្រសិនបើខ្ញុំអាចបង្ហាញពីធនធានរបស់ខ្ញុំក្នុងការស្នាក់អាស្រ័យនៅប្រទេសបារាំងនេះ ។ ខ្ញុំអាចបង្ហាញពីធនធានរបស់ខ្ញុំបាន ប្រសិនបើខ្ញុំអាចធ្វើការ ក្នុងករណីខ្ញុំអត់អាហារូបករណ៍ ។ បើខ្ញុំមិនអាចធ្វើការ ខ្ញុំក៏មិនអាចបង្ហាញពីធនធានរបស់ខ្ញុំបានដែរ ហើយខ្ញុំក៏មិនអាចធ្វើការបាន ប្រសិនបើគ្មានប័ណ្ណស្នាក់អាស្រ័យនៅ ។ ក៏ប៉ុន្តែចំពោះខ្ញុំៗបានសំរេចចិត្តថា ទោះបីជាមានហេតុការណ៍អ្វីកើតឡើងយ៉ាងណាក៏ដោយ ខ្ញុំមិនវិលត្រឡប់ទៅប្រទេសកម្ពុជាវិញទេ នៅពេលដែលសង្គ្រាមកំពុងតែឆេះសន្ធោសន្ធៅនៅឡើយនោះ ។ ប័ណ្ណការងារជាបញ្ហាស្លាប់រស់របស់ខ្ញុំ ។ ខ្ញុំប្តេជ្ញារកឲ្យបាននូវប័ណ្ណការងារនោះ ។

សុំសិទ្ធិជ្រកកោននយោបាយ

ការិយាល័យប៉ូលីសអន្តោប្រវេសន៍របស់បារាំងបានត្រួតពិនិត្យករណីរបស់ខ្ញុំយ៉ាងហ្មត់ចត់ណាស់ តាំងពីពេលដែលខ្ញុំបានដាក់ពាក្យស្នើសុំការស្នាក់អាស្រ័យជាអចិន្ត្រៃយ៍នៅប្រទេសបារាំង ។ នៅពេលកន្លងមក ខ្ញុំបានទទួលការអនុញ្ញាតបណ្តោះអាសន្នឲ្យស្នាក់អាស្រ័យនៅតែមួយរយៈ មិនលើសពីប្រាំមួយខែឡើយ ទម្រាំមានសេចក្តីសំរេចជាចុងក្រោយរបស់អាជ្ញាធរបារាំង ។ បើគ្មានប័ណ្ណស្នាក់អាស្រ័យនៅជាអចិន្ត្រៃយ៍ទេ ខ្ញុំក៏ពុំមានសិទ្ធិធ្វើការ បានន័យថា ខ្ញុំក៏ពុំមានប្រភពធនធាន ឬ បានន័យថា ខ្ញុំនឹងត្រូវចាប់បញ្ជូនត្រឡប់ទៅប្រទេសខ្មែរវិញ ។ ជាច្រើនលើកច្រើនគ្រា ខ្ញុំមិនបានទទួលការសំរេចណាមួយពីអាជ្ញាធរបារាំងនៅឡើយទេ ។ លើកនេះ ខ្ញុំសំរេចធ្វើដំណើរទៅកាន់ការិយាល័យអន្តោប្រវេសន៍ជាថ្មីម្តងទៀត ដោយមានការប្តេជ្ញាចិត្តយ៉ាងមុឹងម៉ាត់ជាទីបំផុត ។ នៅពេលខ្ញុំទៅដល់ការិយាល័យអន្តោប្រវេសន៍នោះ ខ្ញុំត្រូវបានទទួលលេខរៀងឲ្យរង់ចាំ ដែលគេនឹងប្រើដើម្បីហៅឈ្មោះខ្ញុំ តាមលំដាប់លេខជាបន្តបន្ទាប់ ។ ផ្ទុយពីអ្នកឯទៀត ដែលកំពុងអង្គុយរង់ចាំដោយស្ងៀមស្ងាត់ ខ្ញុំមានអារម្មណ៍ជ្រួលច្របល់ប្លែកពីសព្វៗដង ។ នៅទីបំផុតលើកនេះក៏ដូចជាលើកមុនដែរ នារីបារាំងមួយរូប ដែលជាមន្ត្រីទទួលពិនិត្យករណីរបស់ខ្ញុំបានប្រាប់ខ្ញុំថា ខ្ញុំគ្មានសិទ្ធិធ្វើការ និង គ្មានសិទ្ធិស្នាក់នៅក្នុងប្រទេសបារាំងនោះទេ ។ ក៏ប៉ុន្តែ ភ្លាមៗនោះ ខ្ញុំក៏ដាក់ជូននារីនោះ នូវលិខិតសរសេរដោយដៃដែលខ្ញុំសរសេរភ្លាមៗ នៅពេលរង់ចាំនោះគឺ ជាលិខិតស្នើសុំសិទ្ធិជ្រកកោនផ្នែកនយោបាយនៅប្រទេសបារាំង ។ ខ្ញុំជឿជាក់យ៉ាងច្បាស់ថា មានតែក្នុងហានៈជាជនភៀសខ្លួនទេ ទើបខ្ញុំអាចមានសិទ្ធិធ្វើការផង និង ស្នាក់នៅផង ។ ខ្ញុំបានលើកឡើងនូវហេតុផលមួយចំនួនតូច ដើម្បីជាមូលដ្ឋាននៃពាក្យសុំសិទ្ធិជ្រកកោននោះ ។ ខ្ញុំ

សំអាងហេតុផលថា ខ្ញុំស្ថិតនៅក្នុងគណបក្សនយោបាយ ដែលប្រឆាំងនឹងរដ្ឋាភិបាល ។ ខ្ញុំប្រឆាំងរដ្ឋាភិបាល លន់ នល់ ដែលខ្ញុំមិនអាចទទួលបានថាជារដ្ឋាភិបាលត្រឹមត្រូវតាមច្បាប់របស់ខ្ញុំឡើយ ហើយខ្ញុំក៏មិនព្រមចូលរួមជាមួយរដ្ឋាភិបាលក្រៅស្រុករបស់សម្តេច សីហនុ ដែលមានពួកខ្មែរក្រហមជាកំលាំងនោះឡើយ ។ នារីបារាំងដែលទទួលករណីរបស់ខ្ញុំនោះ បានប្រាប់ឲ្យខ្ញុំនៅចាំទៀត ដើម្បីគាត់មានឱកាសទៅស្នើសេចក្តីសំរេចពីចៅហ្វាយនាយរបស់គាត់ ។ មួយរយៈក្រោយមក គាត់ក៏ចេញសេចក្តីអនុញ្ញាតបណ្តោះអាសន្នឲ្យខ្ញុំស្នាក់នៅ ទម្រាំមានសេចក្តីសំរេចអំពីពាក្យសុំសិទ្ធិជ្រកកោនខាងផ្នែកនយោបាយរបស់ខ្ញុំនោះ ។

ខ្ញុំទទួលបៀមទុក្ខសោករបស់ខ្ញុំតែម្នាក់ឯង ។ ខ្ញុំមិនបានប្រាប់នរណាម្នាក់ឲ្យដឹងពីកង្វល់របស់ខ្ញុំនេះទេ ហើយខ្ញុំក៏មិនប្រាប់នរណាឲ្យដឹងអំពីការសុំសិទ្ធិជ្រកកោននយោបាយរបស់ខ្ញុំនេះដែរ ។ អ្នកដែលនៅជាមួយទាំងប៉ុន្មាន រាប់ទាំងលោកវេជ្ជបណ្ឌិត ស៊ូ ណែម និង ភរិយាគាត់ផង ក៏ពុំបានដឹងពីរឿងរ៉ាវរបស់ខ្ញុំដែរទេ ។ ពួកគេនៅតែបន្តយល់ឃើញថា ខ្ញុំជាយុវជនខ្មែរដ៏កម្រម្នាក់ដែលមានភ័ព្វសំណាងបានធ្វើការក្នុងការិយាល័យនៅក្នុងប្រទេសបារាំង ។ ខ្ញុំធ្លាប់បានសរសេរសំបុត្រទៅឪពុកម្តាយ បងប្អូនខ្ញុំនៅប្រទេសខ្មែរ និង ជាពិសេស ទៅបងប្រុសខ្ញុំទាំងពីរនាក់ ។ នៅក្នុងសំបុត្រទីមួយ បន្ទាប់ពីខ្ញុំមកដល់ប្រទេសបារាំង ខ្ញុំបានសរសេរសំបុត្ររៀបរាប់អំពីការធ្វើដំណើរតាមយន្តហោះរបស់ខ្ញុំ និង កិច្ចស្វាគមន៍ដ៏រាក់ទាក់ដែលគ្រួសារលោកវេជ្ជបណ្ឌិត ស៊ូ ណែម បានធ្វើចំពោះខ្ញុំ ។ តាមធម្មតា គេត្រូវចំណាយពេល ៥ ថ្ងៃ ដើម្បីផ្ញើសំបុត្រពីប្រទេសបារាំងទៅប្រទេសខ្មែរ និង ត្រូវចំណាយពេលមួយអាទិត្យដើម្បីផ្ញើសំបុត្រពីប្រទេសខ្មែរ ទៅប្រទេសបារាំងវិញ ។ ដូច្នេះ យើងប្តូរលិខិតឆ្លងឆ្លើយគ្នាមួយដងក្នុងពីរសប្តាហ៍ ដើម្បីរៀបរាប់ទៅវិញទៅមកនូវហេតុការណ៍រៀងៗខ្លួន ។ តាមរយៈការផ្លាស់ប្តូរលិខិតឆ្លងឆ្លើយនេះ ទោះជាខ្ញុំផ្ញើទៅបង

ប្រុសខ្ញុំក៏ដោយ ក៏នៅទីបញ្ចប់សំបុត្ររបស់ខ្ញុំនោះ នឹងត្រូវបញ្ជូនទៅដល់ផ្សារដើម គដែលនៅពេលនោះ ពួកគេអង្គុយដំកង់ជុំវិញអ្នកអានសំបុត្រ ដែលគេជ្រើសរើស ក្នុងចំណោមក្មេងៗដែលជាប្អូនៗរបស់ខ្ញុំនោះ ។ ពួកគេតែងហ៊ោរសប្បាយនៅពេល ដែលពួកគេដឹងថា ខ្ញុំបានជួបនឹងជ័យជំនះអ្វីមួយ ដូចជានៅពេលដែលខ្ញុំសរសេរ ប្រាប់ពួកគេថាខ្ញុំរកការបានធ្វើនៅប្រទេសបារាំង ។ ពួកគេចាត់ទុករូបខ្ញុំជាក្តីសង្ឃឹម របស់ពួកគេម្នាក់ៗ ។ សូមបញ្ជាក់ថា បន្ទាប់ពីខ្ញុំរកការបានធ្វើនោះមកខ្ញុំក៏ចាប់ផ្តើម ធ្វើប្រាក់កាសខ្លះទៅដល់ពួកគេ ។ នៅពេលដែលខ្ញុំនិយាយអំពីទុក្ខលំបាករបស់ខ្ញុំ ពួកគេក៏កើតទុក្ខគ្រប់គ្នាៗដែរ ។ ខ្ញុំដឹងថា ឪពុកម្តាយ បងប្អូនខ្ញុំទាំងអស់នោះ រស់ នៅក្នុងលក្ខណៈលំបាកលំបិនជាងខ្ញុំទៅទៀត ព្រោះពួកគេរស់នៅក្នុងប្រទេសដែល កើតសង្គ្រាមប្រឈមមុខមហន្តរាយស្លាប់រស់ជារៀងរាល់ថ្ងៃ ។ ដូច្នេះ ខ្ញុំគិតថាខ្ញុំមិន គួរនាំព័ត៌មានដ៏អាក្រក់ណាមួយដល់ពួកគេឡើយ ។

ខ្ញុំបានប្រឹងប្រែងជាអតិបរមា ដើម្បីទាមទារលក្ខន្តិកៈជាជនភៀសខ្លួន ។ ខ្ញុំ ខិតខំទាក់ទងជាច្រើនដងជាមួយនឹងក្រសួងការបរទេសបារាំង ជាពិសេស ជាមួយ នឹងការិយាល័យជនភៀសខ្លួន ដែលខ្ញុំបានដាក់ពាក្យជាផ្លូវការ ។ ខ្ញុំបានធ្វើសេចក្តី រាយការណ៍យ៉ាងលំអិតអំពីហេតុផលខាងនយោបាយ ដែលតម្រូវឲ្យខ្ញុំសុំសិទ្ធិជ្រក កោននយោបាយនេះ ។ ខ្ញុំប្រកាន់គោលជំហរថា ខ្ញុំជាបក្សពួកខាងលោក ចៅ សៅ ដែលបានបណ្តេញលោក អ៊ិន តាំ ពីគណបក្សប្រជាធិបតេយ្យ ឥឡូវលោក អ៊ិន តាំ បានក្លាយជានាយករដ្ឋមន្ត្រីនៃរបប លន់ នល់ ។ ដូច្នេះ ខ្ញុំបារម្ភខ្លាចលោក អ៊ិន តាំ ប្រើអំណាចគំរាមកំហែងដល់អាយុជីវិតរបស់ខ្ញុំ ។ ខ្ញុំស្រាវជ្រាវសុំឲ្យអ្នកតំណាង រាស្ត្របារាំងជួយគាំទ្រពាក្យសុំជាជនភៀសខ្លួនរបស់ខ្ញុំ ។ ខ្ញុំសរសេរសំបុត្រទៅ លោកស្រី នីកូល ដឺ អូតក្លុក (Nicole de Hauteclocque) ដែលមានស្វាមីឈ្មោះ លោកសេនាប្រមុខ ឡឺក្លែរ (Leclerc) ។ នៅពេលនោះ លោកស្រីជាស្ត្រីមេម៉ាយ

ដោយសារលោកសេនាប្រមុខ ឡឺក្លែរ បានទទួលមរណភាពទៅហើយ ។ លោក ស្រីនីកូល ដឺ អូតក្លុក ជាអ្នកតំណាងរាស្ត្រសង្កាត់លេខ ១៤ ទីក្រុងប៉ារីស ។ លោកស្រីធ្លាប់បានសរសេរសំបុត្រលើកទឹកចិត្តមកខ្ញុំដែរ ។ នៅក្នុងរយៈពេលនោះ ខ្ញុំមិនសូវបានធ្វើការដាប់លាប់ទេ គឺអវត្តមានជាញឹកញាប់ ក៏ប៉ុន្តែចៅហ្វាយនាយ របស់ខ្ញុំ ជាពិសេស អ្នកស្រី ដឺបៃហ្សេ មានចិត្តសន្តោសយោគយល់ដល់ខ្ញុំជាខ្លាំង ។ ពួកគាត់តែងគាំទ្ររាល់ការខំប្រឹងប្រែងរបស់ខ្ញុំ និង ជួយលើកទឹកចិត្តខ្ញុំជានិច្ច ។

ជីវិតថ្មីជាអ្នកទីក្រុងប៉ារីស

ដោយសារការខំប្រឹងប្រែងឥតមានខ្លាចនឿយហត់ និង ដោយសារមានការ គាំទ្រយ៉ាងខ្លាំងក្លាយ៉ាងនេះហើយ ទើបខ្ញុំចេះតែរុករុលទៅមុខបាន ។ នៅទីបញ្ចប់ ខ្ញុំក៏ត្រូវបានក្រុមប៉ូលីសអន្តោប្រវេសន៍កោះហៅជាថ្មីម្តងទៀត ។ ម្តងនេះ មន្ត្រីដែល ទទួលជួបខ្ញុំគឺ ជានាយប៉ូលីសភេទប្រុស ។ នៅពេលជួបភ្លាម លោកមេប៉ូលីសទាញ យកសំបុត្រឆ្លងដែនរបស់ខ្ញុំទៅទុកនៅក្នុងថតតុរបស់គាត់ ដែលធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលយ៉ាងខ្លាំង ។ នៅពេលនោះខ្ញុំក៏ដាក់ជូនគាត់នូវពាក្យសុំបណ្ណាអនុញ្ញាតស្នាក់អាស្រ័យម្តងទៀត ។ លោកនាយអានយ៉ាងយកចិត្តទុកដាក់នូវពាក្យសុំរបស់ខ្ញុំនោះ ហើយ មួយរំពេចនោះ គាត់យកបិចឆូតលុបពាក្យថា "សញ្ជាតិខ្មែរ" ដោយគាត់សរសេរ ជំនួសវិញថា "ជនភៀសខ្លួនខ្មែរ" ។ ការលុបពាក្យសញ្ជាតិខ្មែរនេះ ធ្វើឲ្យខ្ញុំមានក្តី រន្ធត់ស្ទើរគាំងបេះដូង ព្រោះគ្រាន់តែមួយប៉ប្រិចភ្នែកប៉ុណ្ណោះខ្ញុំក៏បាត់បង់នូវសញ្ជាតិ ខ្មែរដ៏ជាទីស្នេហារបស់ខ្ញុំ ។ តាមពិត អាជ្ញាធរបារាំងបានសំរេចផ្តល់សិទ្ធិជ្រកកោន ឲ្យខ្ញុំរួចទៅហើយ គ្រាន់តែខ្ញុំពុំទាន់ដឹង នៅពេលទៅសុំបណ្ណាអនុញ្ញាតស្នាក់អាស្រ័យ នោះ ។ ដូច្នេះនៅឆ្នាំ ១៩៧៤ នៅពេលដែលសង្គ្រាមកំពុងតែឆាបឆេះប្រទេស

ខ្មែរនៅឡើយ ខ្ញុំប្រហែលក្លាយខ្លួនជាជនភៀសខ្លួនមួយមុនគេនៅក្នុងប្រទេសបារាំង ។ អស់រយៈពេលមិនដល់មួយឆ្នាំផង ខ្ញុំក៏បានទទួលនូវអ្វីៗដែលខ្ញុំចាំបាច់ត្រូវមានគឺ លក្ខន្តិកៈជាជនភៀសខ្លួន លិខិតអនុញ្ញាតឲ្យធ្វើការ និង លិខិតអនុញ្ញាតឲ្យស្នាក់នៅជាអចិន្ត្រៃយ៍ ។

នៅខែ ឧសភា ១៩៧៤ ខ្ញុំក៏បានសំរេចចេញពីផ្ទះលោកវេជ្ជបណ្ឌិត ស៊ូ ណែម មកជួលបន្ទប់មួយនៅក្នុងសង្កាត់លេខ ១៤ នៃទីក្រុងប៉ារីស ។ បន្ទប់នោះស្ថិតនៅក្នុងអាគារនៃតំបន់មួយឈ្មោះថា អាឡេស្យា (Alésia) ដែលមានអាស័យដ្ឋានលេខ ២០ ផ្លូវមូឡាំងវ៉ែរ (Moulin Vert) ។ អាគារដែលខ្ញុំស្នាក់នៅនោះស្ថិតនៅក្នុងតំបន់ស្ងាត់ល្អ និង ស្អាតបាត ។ អាគារនេះ ប្រកបដោយផ្ទះល្វែងជាច្រើន ក៏ប៉ុន្តែនៅជាន់ខាងក្រោមពុំមានផ្ទះល្វែងទេមានតែបន្ទប់ជួលសំរាប់និស្សិត ។ ពេលចូលទៅក្នុងអាគារ គេមើលពុំឃើញបន្ទប់និស្សិតទាំងនោះទេ ព្រោះបាំងជញ្ជាំងនៃច្រកចូលទៅល្វែងខាងក្នុងបន្ទប់របស់ខ្ញុំ ដែលស្ថិតនៅខាងក្រោយគេបង្អស់គឺ ជាបន្ទប់ដែលមានត្រែមួយ ទូរទឹកកកតូចមួយ ។ បន្ទប់ទឹក និង បង្គន់ស្ថិតនៅខាងក្រៅដែលអាចប្រើប្រាស់រួមជាមួយអ្នកឯទៀត ។ ជាមួយនឹងការរស់នៅដោយខ្លួនឯង ខ្ញុំសប្បាយចិត្តនឹងសេរីភាពនេះណាស់ ជាពិសេសខ្ញុំនឹកថាខ្ញុំនឹងមានលទ្ធភាពបន្តការសិក្សាតទៅទៀត ។ ខ្ញុំចំណាយប្រាក់មួយខែ ៣៩៩ ហ្រ្វង់ សំរាប់ថ្លៃឈ្នួលផ្ទះ ដែលមានតម្លៃជិតពីរដងនៃថ្លៃឈ្នួលផ្ទះ កាលខ្ញុំស្នាក់នៅជាមួយលោក ស៊ូ ណែម ។ ក៏ប៉ុន្តែ ផ្ទះថ្មីរបស់ខ្ញុំនោះ ក៏មានបញ្ហាដែរ ព្រោះគ្មានផ្ទះបាយ ។ ដូច្នេះខ្ញុំត្រូវទិញចង្ក្រានអគ្គិសនីដ៏តូចមួយ ដើម្បីដាំទឹក ឬ កំដៅទឹកដោះគោសំរាប់ការស្រស់ស្រូបអាហារពេលព្រឹក ។ តាមធម្មតា ខ្ញុំគ្មានសិទ្ធិដាំស្ល ឬ ធ្វើម្ហូបអាហារនៅក្នុងបន្ទប់នេះទេ ។

អាឡេស្សា ជាតំបន់មួយដែលមានសកម្មភាពដ៏រស់រវើក ។ ខ្ញុំ ប្រទះឃើញ នូវអ្វីៗ ដែលខ្ញុំត្រូវការគឺ ខ្ញុំអាចទៅលេងសួនច្បារក៏បាន ទៅផ្សារមេឃក៏បាន ទៅ ទិញអីវ៉ាន់នៅតាមហាងក៏បាន ចូលមើលភាពយន្តក៏បាន ឬ ចូលតាមតៀមការហ្វេ ភោជនីយដ្ឋាន ឱសថដ្ឋាន ធនាគារ បណ្ណាគារ ជាងកាត់សក់ជាដើម ។ល។ គេអាចដើរពី អាឡេស្សា ទៅ ប៉ុកដកឡេអង់ (Porte d'Orléans) ក៏បាន ឬ ក៏ដើរទៅ ម៉ុងប៉ាណាស់ (Montparnasse) ក៏បាន ។ បើនិយាយឲ្យខ្លី តំបន់នោះ គឺ ជាតំបន់ស្រួលចាយលុយ ឬ ចាយលុយឆាប់អស់ ។ ខ្ញុំចូលចិត្តរស់នៅក្នុងតំបន់ នោះណាស់ តែខ្ញុំក៏មិនដែលភ្លេចទៅលេងផ្ទះលោកវេជ្ជបណ្ឌិត ស៊ូ ណែម ដែរ ។ រស់នៅម្នាក់ឯងយ៉ាងនេះយូរៗទៅ ខ្ញុំក៏នឹកទៅដល់ម្ហូបខ្មែរ ដែលអ្នកស្រី ស៊ូ ណែម ធ្លាប់ធ្វើឲ្យខ្ញុំទទួលទាន ។ ចាប់តាំងពីខ្ញុំមកនៅ អាឡេស្សា ខ្ញុំទទួលទានម្ហូបបារាំង នៅពេលថ្ងៃត្រង់ ហើយនៅពេលល្ងាចខ្ញុំទទួលទានម្ហូបអាហារចំអិនរួចស្រេច ដែល មានដាក់លក់នៅតាមហាងនានា ។ នៅពេលដំបូង ខ្ញុំមិនសូវស្គាល់ម្ហូប និង កេសដ្ឋ:បារាំងប៉ុន្មានឡើយ ។ ចាប់តាំងពីពេលដែលខ្ញុំមានហាន:ជាអ្នកធ្វើការពេញ សិទ្ធិ និង ជាអ្នកទីក្រុងប៉ារីសម្នាក់មក ខ្ញុំមិនទទួលទានសាំងវិចដូចពីមុនទៀតទេ ។ ឥឡូវអស់រយ:ពេលមួយឆ្នាំមកហើយ ខ្ញុំទទួលទានតែសាច់គោ និង ដំឡូងចៀន ស្តេកហ្រ្វីត (Steak Frite) នៅក្នុងភោជនីយដ្ឋានមួយនៅទល់មុខកន្លែងខ្ញុំធ្វើការ ។ នៅក្នុងភោជនីយដ្ឋាននេះ យើងដើរទៅជ្រើសរើសម្ហូបដោយខ្លួនយើង គ្មានអ្នកបំរើ ទេ ។ រាល់ៗដង ខ្ញុំមិនផ្លាស់ប្តូរមុខម្ហូបរបស់ខ្ញុំឡើយគឺ ស្តេកហ្រ្វីត ជាប់ជានិច្ច រហូតដល់ស្ត្រីអ្នកធ្វើម្ហូប លើកស្តេកហ្រ្វីត ហុចមកឲ្យខ្ញុំ ដោយមិនចាំបាច់សួរ នាំដូចអ្នកឯទៀតនោះឡើយ ។ ចំពោះកេសដ្ឋ:វិញ ខ្ញុំចាប់ផ្តើមទទួលទានទឹកដោះ គោជំនួសទឹកសុទ្ធ ព្រោះខ្ញុំកម្រមានឱកាសទទួលទានទឹកដោះគោនៅប្រទេសខ្មែរ ណាស់ ។ មួយឆ្នាំក្រោយមក ខ្ញុំទទួលទានស្រាបៀរជំនួសទឹកដោះគោ ហើយ

បន្ទាប់មកទៀត ស្រាសទំពាំងបាយដូ ដែលមានពពុះជំនួសស្រាបៀរ ហើយនៅចុងបញ្ចប់ ខ្ញុំច្រើនទទួលទានស្រាក្រហមទំពាំងបាយដូរហូតរៀងមក ។

នៅឆ្នាំទីមួយនៃជីវិតជាអ្នកទីក្រុងប៉ារីសរបស់ខ្ញុំៗប្រើពេលជាច្រើន ដើម្បីស្វែងរកសិទ្ធិរស់នៅតាមច្បាប់ ឬ ស្របច្បាស់នៅប្រទេសបារាំង និង ដើម្បីខិតខំធ្វើសមាហរណកម្មជីវភាពថ្មីរបស់ខ្ញុំក្នុងសង្គមបារាំង ។ តែឆ្នាំទីមួយនោះ ក៏ជាឆ្នាំដែលខ្ញុំនឹកស្រុកយ៉ាងខ្លាំងណាស់ដែរ ។ ខ្ញុំសរសេរសំបុត្រទៅឪពុកម្តាយខ្ញុំថា ខ្ញុំរង់ចាំសំបុត្រពីស្រុកខ្មែរ ដូចក្មេងដែលរង់ចាំម្តាយមកពីផ្សារយ៉ាងនោះដែរ ។ ខ្ញុំសរសេរយ៉ាងនេះ ដោយនឹកដល់ការរស់នៅឯស្រុកខ្មែរ ដែលស្ត្រីជាម្តាយទាំងឡាយតែងទៅផ្សាររាល់ព្រឹក នៅពេលដែលក្មេងៗជាកូនតែងទន្ទឹងរង់ចាំឯផ្ទះមើលផ្លូវម្តាយត្រឡប់មកវិញ ក្រែងនឹងបាននំចំណីដ៏ផ្អែមពិសា ឬ ឈ្ងុយឆ្ងាញ់ ។ ចំពោះខ្ញុំ នៅពេលបានទទួលសំបុត្រពីស្រុកខ្មែរម្តងៗ ខ្ញុំក៏មានភាពរីករាយក្នុងចិត្តដូចក្មេងៗទាំងនោះដែរ ។ ក៏ប៉ុន្តែ ជាបន្តបន្ទាប់ ដំណឹងដែលមកពីប្រទេសខ្មែរទាំងប៉ុន្មាន សុទ្ធតែជាដំណឹងមិនល្អទាំងអស់ ព្រោះសភាពការណ៍នៃសង្គ្រាមនៅកម្ពុជាកាន់តែធ្ងន់ធ្ងរឡើងពីមួយថ្ងៃទៅមួយថ្ងៃ ។ តែទោះជាយ៉ាងណាក៏ដោយ ខ្ញុំក៏នៅតែមានការរីករាយនឹងទទួលដំណឹងពីឪពុកម្តាយ បងប្អូនរបស់ខ្ញុំជានិច្ច ។

ចំពោះការងាររបស់ខ្ញុំវិញ ថៅកែ និង ថៅហ្វាយនាយរបស់ខ្ញុំ ពេញចិត្តការងារខ្ញុំណាស់ ចំណែកប្រាក់ខែរបស់ខ្ញុំ ក៏ចេះតែឡើងជាលំដាប់គឺពី ១៤០០ ហ្រ្វង់ ទៅ ១៦០០ ហ្រ្វង់ រហូតដល់ ២០០០ ហ្រ្វង់ នៅដើមឆ្នាំ ១៩៧៥ ។ ឯមុខងាររបស់ខ្ញុំក៏ឡើងឋានៈដែរ ។ នៅដើមឆ្នាំ ១៩៧៥ នោះខ្ញុំក៏ឡើងឋានៈជាគណនេយ្យករពេញសិទ្ធិ ។ ខ្ញុំមានទំនាក់ទំនងល្អជាមួយអ្នកស្រី ដឺបៃហ្សូ ដែលធ្វើឲ្យមិត្តភាពរវាងយើងទាំងពីរកាន់តែរឹងមាំឡើង ។ ខ្ញុំអាចហៅឈ្មោះផ្ទាល់របស់គាត់គឺ គ្រីស្យាន (Christiane) បាន ។ គ្រីស្យាន ជាមិត្តដ៏កម្រ ដែលខ្ញុំស្រឡាញ់រាប់អានរហូតមក

ដល់សព្វថ្ងៃនេះ អស់រយៈពេលជាច្រើនទសវត្សរ៍មកហើយ ។ ទោះជាប់បំពេញការងារក៏ដោយ ក៏ខ្ញុំខិតខំឆ្លៀតរកសាលារៀនបន្ថែមទៀតដែរ ជាពិសេសនៅវិទ្យាស្ថានជាតិបច្ចេកទេសសេដ្ឋកិច្ច និង គណនេយ្យ ។ យើងសិក្សារៀងៗខ្លួន តែក្នុងមួយអាទិត្យម្តង យើងជួបជុំគ្នាជាក្រុម ជាមួយសាស្ត្រាចារ្យជំនាញរបស់យើង ។ គឺតាមរយៈការសិក្សាជាក្រុមនេះហើយ ទើបខ្ញុំមានមិត្តម្នាក់ទៀតឈ្មោះ គ្រីស្យង់ ឡឺដេ (Christian Leday) ។ គ្រីស្យង់ ឡឺដេ ជាគណនេយ្យករមួយរូបធ្វើការនៅក្នុងរោងចក្រមួយនៅតំបន់ នរ៉ម៉ង់ឌី (Normandie) ។ គ្រីស្យង់ និង ភរិយា មានកូនពីរនាក់ ។ ខ្ញុំឧស្សាហ៍ទៅលេងស្រុករបស់គ្រីស្យង់នោះណាស់ ។ ស្រុកនោះនៅក្បែរទីក្រុងមួយឈ្មោះ ឡែក្ល (L'aigle) ។ ពួកយើងឧស្សាហ៍ប្តូរវត្ថុអនុស្សាវរីយ៍គ្នាទៅវិញទៅមក នៅពេលបុណ្យណូអែល ឬ ចូលឆ្នាំថ្មី ។ មានពេលខ្លះគ្រីស្យង់ និង ភរិយា បបួលខ្ញុំទៅសំរាកដើរលេងកំសាន្ត ឬ បោះតង់ នៅតំបន់ប្រីតាញ (Bretagne) គ្រីស្យង់ តែងនិយាយចំអន់លេងឲ្យខ្ញុំថា "មូលីឯងសមជារដ្ឋមន្ត្រីក្រសួងការបរទេសដ៏ល្អម្នាក់ នៅពេលណាមួយមិនខាន" ។

ដោយសារខ្ញុំមានការងារច្រើន និង ដោយសារខ្ញុំចេះតែខ្វល់ខ្វាយចំពោះសុខទុក្ខរបស់បងប្អូន ឪពុកម្តាយខ្ញុំឯស្រុកខ្មែរ ខ្ញុំក៏រៀនមិនបានខ្ជាប់ខ្ជួនឡើយ ។ នៅចុងឆ្នាំ ១៩៧៤ ខ្ញុំប្រឡងប្រចាំឆ្នាំធ្លាក់ ។ ក្នុងពេលជាមួយគ្នានោះដែរ និស្សិតខ្មែរមួយចំនួន ត្រូវបង្ខំចិត្តវិលត្រឡប់ទៅប្រទេសខ្មែរវិញ ដោយសារអ្នកខ្លះបានបញ្ចប់ការសិក្សា ឬ ត្រូវអស់អាហារូបករណ៍ ឬ គ្មានលទ្ធភាពបន្តការសិក្សា ដោយគ្មានសិទ្ធិធ្វើការយកប្រាក់ចិញ្ចឹមជីវិត ។ និស្សិតដែលត្រូវត្រឡប់មកស្រុកខ្មែរវិញនោះ ត្រូវបាត់បង់ជីវិតស្ទើរតែទាំងអស់នៅក្នុងរបបខ្មែរក្រហម ។ ផ្ទុយពីនេះទៅវិញ មានបងប្អូនជនជាតិខ្មែរមួយចំនួនបានគេចចេញពីស្រុកខ្មែរ ហើយបានមកដល់ប្រទេសបារាំង តែប៉ុន្មានខែប៉ុណ្ណោះមុនរបបសាធារណរដ្ឋខ្មែរដួលរលំ ។ ក្នុង

ចំណោមនោះ មានសហសេវិករបស់ខ្ញុំម្នាក់នៅកូមិន្នខ្មែរឈ្មោះ ផាន់ សូរិយាស៊ី ផងដែរ ។ សូរិយាស៊ី បាននាំប្រពន្ធ និង កូនចំនួនពីរនាក់មកជាមួយ ។ ក្រោយមក សូរិយាស៊ី បានបញ្ជូនកូនទាំងពីរនាក់នោះត្រឡប់ទៅស្រុកខ្មែរវិញជាមួយជីតារបស់គេ ដែលមានលទ្ធភាពមកប្រទេសបារាំងក្នុងរយៈពេលដ៏ខ្លី តែប៉ុន្មានថ្ងៃមុនខ្មែរក្រហម ចូលភ្នំពេញតែប៉ុណ្ណោះ ។ សូរិយាស៊ី បានក្លាយទៅជាមិត្តជិតស្និទ្ធរបស់ខ្ញុំ ហើយរាល់ពេលឈប់សំរាក យើងតែងចំណាយពេលវេលាជាមួយគ្នាមិនដែលដាច់ ។

សប្បាយលាយទឹកភ្នែក នៅថ្ងៃ ១៧ មេសា ១៩៧៥

នៅដើមឆ្នាំ ១៩៧៥ នោះ លោក ស៊ូ ណែម ទាំងប្រពន្ធទាំងកូនបានត្រឡប់មកប្រទេសកម្ពុជាវិញ ។ ខ្ញុំពុំបានជូនដំណើរពួកគាត់ទៅព្រលានយន្តហោះទេ ។ ក៏ប៉ុន្តែ ប៉ុន្មានថ្ងៃមុនពេលគាត់ចេញដំណើរ ខ្ញុំបានជួបលោកស្រី ស៊ូ ណែម ដែរ ហើយខ្ញុំបានផ្ញើសំបុត្រ និង ប្រាក់កាសខ្លះទៅឪពុកម្តាយខ្ញុំនៅភ្នំពេញទៀតផង ។ តាំងពីពេលនោះមក ខ្ញុំពុំដែលបានជួបគាត់ទៀតឡើយ ។ ដោយសារលោក ស៊ូ ណែម ជាមនុស្សសំខាន់ម្នាក់នៃរបបសាធារណរដ្ឋ គាត់ប្រហែលជាត្រូវខ្មែរក្រហមសម្លាប់បាត់ទៅហើយ ។

នៅថ្ងៃទី ១៧ មេសា ១៩៧៥ ក៏ដូចជាថ្ងៃឯទៀតដែរ នៅពេលឈប់សំរាកទទួលទានអាហារថ្ងៃត្រង់ ខ្ញុំតែងធ្វើដំណើរទៅធនាគារនៅក្បែរសាលមហោស្រពអូប៉េរា (Opera) ដូចធម្មតា ដើម្បីយកមូលប្បទានប័ត្រនានារបស់ក្រុមហ៊ុនទៅបញ្ចូលក្នុងគណនី ។ បន្ទាប់ពីធ្វើការនេះនៅឯធនាគាររួចហើយ ខ្ញុំតែងតែត្រឡប់មកតាមវិថី ដឺ ឡេស្ហែល (de l'Echelle) ដើម្បីទទួលទានអាហារថ្ងៃត្រង់នៅក្នុង

ភោជនីយដ្ឋានគ្មានអ្នកបំរើ (Self Service Restaurant) ដែលស្ថិតនៅចំពីមុខកន្លែងធ្វើការរបស់ខ្ញុំ ។ នៅថ្ងៃទី ១៧ ខែ មេសានោះ ខ្ញុំដើរតាមវិថីនានា ដើម្បីទៅទទួលទានអាហារថ្ងៃត្រង់ ក៏ប៉ុន្តែ ផ្ទុយពីសព្វៗដង ខ្ញុំមិនប្រញាប់ត្រឡប់ទៅធ្វើការវិញទេ ខ្ញុំដើរតាមវិថី ដេ ពៀរ៉ាមីដ (Des Pyramides) រហូតទៅដល់រុក្ខវិថី ដឺឡូប៉េរ៉ា (De l'Opera) ។ នៅត្រង់កាច់ជ្រុងនោះ នៅត្រង់ច្រកចូលស្ថានីយម៉ែត្រូ ដេ ពៀរ៉ាមីដ មានតូបលក់កាសែតមួយ ដែលនៅទីនោះ ខ្ញុំក៏ទិញកាសែត ឡឺម៉ុង (Le Monde) មួយច្បាប់ ។ នៅទំព័រទីមួយ ខ្ញុំឃើញគេសរសេរអក្សរធំៗថា ទីក្រុងភ្នំពេញ បានត្រូវធ្លាក់ក្នុងកណ្តាប់ដៃខ្មែរក្រហមទៅហើយ ។ តាមពិត ដំណឹងស្តីពីការដួលរលំនៃរបប លន់ នល់ មិនធ្វើឲ្យខ្ញុំមានការសង្ស័យអ្វីប៉ុន្មានទេ ព្រោះខ្ញុំមានជំនឿថារបបនេះ រង់ចាំតែថ្ងៃខែនៃសេចក្តីស្លាប់តែប៉ុណ្ណោះ ។ ប្រតិកម្មរបស់ខ្ញុំភ្លាមៗ ក្នុងពេលនោះគឺ បង្ហូរទឹកភ្នែកមកដោយឯកឯង ទាំងមិនដឹងខ្លួន ។ នោះគឺ ទឹកភ្នែកនៃអំណរ ។ ខ្ញុំអរ ព្រោះភ្លើងសង្គ្រាមត្រូវរលត់ ។ អស់រយៈពេលជាច្រើនឆ្នាំមកហើយ ខ្ញុំរក្សាបាននូវភាពរឹងមាំ ទឹកចិត្តខ្លាំងក្លា ព្រោះខ្ញុំមិនងាយបង្ហូរទឹកភ្នែកដោយស្រួលៗឡើយ ។ ក៏ប៉ុន្តែនៅពេលនេះ ខ្ញុំទប់ទឹកភ្នែកលែងបានដោយសារតែខ្ញុំមានសេចក្តីរំភើប និង ត្រេកអរខ្លាំងពេក ។ ខ្ញុំងើបមុខ សម្លឹងមើលមេឃនៃទីក្រុងប៉ារីស ហើយលាន់មាត់ទាំងទឹកភ្នែកថា "ព្រះអើយ នៅទីបំផុតសង្គ្រាមបានត្រូវបញ្ចប់" ។ គឺទីបញ្ចប់នៃសង្គ្រាមដ៏សាហាវ និង ទីបញ្ចប់នៃទុក្ខវេទនារបស់ប្រជាពលរដ្ឋខ្មែរនេះហើយ ដែលធ្វើឲ្យខ្ញុំត្រេកអរគ្រប់ទីបំផុតគ្មាន ។ ក្តីអំណររបស់ខ្ញុំមានទំហំធំធេងណាស់ ដែលធ្វើឲ្យខ្ញុំមានសុភមង្គលមិនអាចរកពាក្យអ្វីមកថ្លែងបានឡើយ ។ ដោយកាន់កាសែត ឡឺម៉ុង ជាប់នៅដៃផង ខ្ញុំមិនដើរដូចធម្មតាទេម្តងនេះគឺ ខ្ញុំរត់យ៉ាងលឿនដើម្បីនាំដំណឹងដ៏ល្អនោះ ទៅប្រាប់មិត្តភក្តិនៅកន្លែងធ្វើការ ។ នៅពេលទៅដល់ ពួកយើងជំនុំគ្នាអំពីសភាពការណ៍នៅកម្ពុជា ។

ពួកយើងមិនបានធ្វើការទៀតទេ ។ យើងជជែកគ្នារហូតដល់ម៉ោងចេញពីធ្វើការតែម្តង ។ មិត្តភក្តិជាច្រើន បានចូលរួមសប្បាយរីករាយជាមួយខ្ញុំ ។ ក៏ប៉ុន្តែបន្តិចម្តងៗ សេចក្តីត្រេកអររបស់យើង ក៏បានរសាត់ចេញទៅ ដោយយើងចាប់ផ្តើមទទួលបាននូវដំណឹងស្តីអំពីអំពើសាហាវយង់ឃ្នងរបស់ពួកខ្មែរក្រហម ។ ខ្ញុំចាប់ធ្ងល់យ៉ាងខ្លាំងចំពោះអ្វីៗដែលពួកខ្មែរក្រហមចាប់ធ្វើ ហើយខ្ញុំក៏ចាប់ផ្តើមមានការសង្ស័យ ចំពោះជោគជ័យរបស់ពួកខ្មែរក្រហមនេះដែរ ។ ពិភពលោកមានការភ្ញាក់ផ្អើលចំពោះវិធានការណ៍បណ្តេញប្រជាពលរដ្ឋចេញពីរាជធានីភ្នំពេញ ដែលពួកខ្មែរក្រហមចាត់ឡើងយ៉ាងព្រៃផ្សៃ ។ ខ្ញុំចាប់កើតមានអារម្មណ៍ច្របូកច្របល់គឺ ម្យ៉ាងអបអរសាទរ ចំពោះការបញ្ចប់សង្គ្រាមដ៏រ៉ាំរ៉ៃ ម្យ៉ាងភ្លាមៗនោះ ខ្ញុំក៏ចាប់ផ្តើមព្រួយបារម្ភ ចំពោះវាសនារបស់ឪពុកម្តាយ និង បងប្អូនជាទីស្រឡាញ់របស់ខ្ញុំនៅឯស្រុកខ្មែរដែរ ។

តាំងពីថ្ងៃនោះមក ខ្ញុំតែងទទួលនូវដំណឹងអាក្រក់ស្តីពីចំនួនកើនឡើងឥតឈប់ឈរនៃជនភៀសខ្លួនដែលបង្ខំចិត្តរត់ចូលស្ថានទូតបារាំង ព្រមទាំងការកាប់សម្លាប់ទាហាន និង មន្ត្រីនៃរបបសាធារណរដ្ឋ ការកាប់សម្លាប់សកម្មជននៃគណបក្សឯទៀត រួមផ្សំជាមួយនឹងការជន្លៀសប្រជាពលរដ្ឋចេញពីទីក្រុងដែលគ្មាននរណានឹកដល់ ។ ដំណឹងដែលយើងបានទទួលមួយទៀតគឺ ការបិទស្ថានទូតបរទេសលោកខាងលិចទាំងអស់នៅភ្នំពេញ ។ ក្រោយមក យើងលែងបានទទួលដំណឹងអ្វីច្រើនដូចមុនៗទៀតទាំងអស់ ក្រៅពីព័ត៌មានស្តីពីជនភៀសខ្លួនដែលរត់ទៅសុំសិទ្ធិជ្រកកោននៅស្ថានទូតបារាំង និង ការចរចារវាងមន្ត្រីស្ថានទូតបារាំងជាមួយខ្មែរក្រហមដើម្បីរំដោះជនភៀសខ្លួនទាំងនោះតែប៉ុណ្ណោះ ។

មិនយូរប៉ុន្មាន ពួកខ្មែរក្រហមបានសំរេចជោគជ័យ ទាំងស្រុងក្នុងការកាត់ផ្តាច់ប្រទេសកម្ពុជាពីពិភពលោកទាំងមូល ។ គ្មានអ្នកយកព័ត៌មានណាម្នាក់ អាចធ្វើដំណើរបានដោយសេរីនៅក្នុងប្រទេសនេះបានទៀតឡើយ ។ ជាមួយគ្នានោះ ម៉ា

ស៊ីនឃោសនារបស់ខ្មែរក្រហម នៅតែបន្តធ្វើការឃោសនាអំពីមហាជោគជ័យរបស់ពួកគេយ៉ាងខ្លាំងក្លាដដែល ។ ពួកគេបដិសេធព័ត៌មានស្តីពីអំពើព្រៃផ្សៃរបស់ពួកគេដែលលេចឮចេញមកក្រៅប្រទេសទាំងអស់ថា គ្រាន់តែជាការឃោសនាបោកកុហករបស់ចក្រពត្តិអាមេរិក ប្រឆាំងបដិវត្តន៍កម្ពុជាតែប៉ុណ្ណោះ ។

ប៉ុន្មានខែមុនជ័យជំនះរបស់ខ្មែរក្រហម និស្សិតខ្មែរស្ទើរតែទាំងអស់នៅទីក្រុងប៉ារីស បានប្តេជ្ញាគាំទ្ររណសិរ្សរបស់សម្តេច នរោត្តម សីហនុ ដែលមានខ្មែរក្រហមជាឆ្អឹងខ្នងហើយដែលមានឈ្មោះថា រណសិរ្សរួបរួមជាតិកម្ពុជា (FUNK) ។ ចលនាគាំទ្ររបស់និស្សិតទាំងនេះ កាន់តែធំធាត់ និង សកម្មឡើង ដោយសារនៅទីបំផុត រដ្ឋាភិបាលនៃសាធារណរដ្ឋបារាំងរបស់លោកប្រធានាធិបតី ហ្ស៊ីស្កា ដេស្តាំង (Giscard d'Estaing) ប្រកាសទទួលស្គាល់រដ្ឋាភិបាលក្រៅប្រទេសរបស់សម្តេច នរោត្តម សីហនុ នៅខែ មេសា ១៩៧៥ គឺនៅមួយសប្តាហ៍មុនថ្ងៃដួលរលំនៃរបបលន់ នល់ ។ គេអាចហៅថា ការទទួលស្គាល់នេះ ជាការទទួលស្គាល់នៅនាទីចុងក្រោយបង្អស់ ។

ក្នុងពេលកន្លងមក ខ្ញុំធ្លាប់បានត្រូវគេអញ្ជើញចំនួនបី ឬ បួនដងដែរឲ្យចូលរួមប្រជុំជាមួយពួកខ្មែរក្រហម ។ ខ្ញុំមិនសូវបានទៅចូលរួមប្រជុំទេ ដោយហេតុថា ខ្ញុំមិនចូលចិត្តច្រៀងបទទង់ក្រហមរបស់ពួកខ្មែរក្រហមទាល់តែសោះ ។ ចម្រៀងបទទង់ក្រហមនោះ ជាចម្រៀង ដែលគេត្រូវច្រៀងនៅពេលបញ្ចប់អង្គប្រជុំម្តងៗ ដោយថែមទាំងត្រូវលើកដៃស្តាំឡើងជាសញ្ញាប្តេជ្ញាចិត្តទៀតផង ។ បទចម្រៀងនោះ ចាប់ផ្តើមដូចជា "ឈាមក្រហមផ្ទៅក្រាលនៅលើប្រឹថពី ឈាមដែលពលីគឺឈាមប្រជាជន....” ។ នៅលើកនេះ ខ្មែរក្រហមបានរៀបចំអង្គប្រជុំធំមួយដើម្បីអបអរសាទរនូវជ័យជំនះរបស់ពួកគេ ។ ខ្ញុំគិតថា ខ្ញុំគួរតែចូលរួមប្រជុំក្រែងបានទទួលដំណឹងថ្មីៗពីប្រទេសកម្ពុជា ។ ដូច្នេះ ខ្ញុំក៏ទៅចូលរួមអបអរសាទរជ័យ

ជំនះរបស់ខ្មែរក្រហមដែរ ។ នៅពេលនោះ ខ្ញុំសង្កេតឃើញអ្នកគាំទ្រ និង អ្នកជិតស្និទ្ធជាមួយរបប លន់ នល់ ភាគច្រើន បាននាំគ្នាទៅគាំទ្រខ្មែរក្រហមវិញម្តង ។ នេះជាការបត់បែននយោបាយ ឲ្យទាន់ពេលវេលារបស់ពួកគេ ។ គួរឲ្យស្តាយ នៅទីបញ្ចប់នៃអង្គប្រជុំដ៏ធំនោះ ខ្ញុំមិនបានទទួលដំណឹងអ្វីទាំងអស់ពីស្រុកខ្មែរទេ ផ្ទុយទៅវិញខ្ញុំគ្រាន់តែបានទទួលការឃោសនាលើកសរសើរអង្គការ និង ថ្នាក់ដឹកនាំខ្មែរក្រហមតែប៉ុណ្ណោះ ។

មិនចូលបដិវត្តន៍ព្រោះជាប់កំអែលមូលធននិយម

ជាច្រើនខែបន្ទាប់ពីជ័យជំនះរបស់ពួកគេ ពួកខ្មែរក្រហមនៅតែបន្តធ្វើការបញ្ចុះបញ្ចូលនិស្សិត ឬ ជនរួមជាតិដែលរស់នៅប្រទេសបារាំងឲ្យត្រឡប់ទៅប្រទេសកម្ពុជាវិញ ។ ពួកគេចាត់តាំងក្រុមកម្មាភិបាល និង សកម្មជនឲ្យដើរគោះទ្វារតាមផ្ទះ ដើម្បីធ្វើការបញ្ចុះបញ្ចូលនោះ ។ ក្រុមមួយ ដែលដឹកនាំដោយលោកស្រី ហ៊ឹង អ៊ុន តែងតែមកគោះទ្វារផ្ទះខ្ញុំរាល់ល្ងាច ដើម្បីអូសទាញខ្ញុំឲ្យគាំទ្រអង្គការរបស់គេ និង បបួលខ្ញុំឲ្យវិលត្រឡប់ទៅប្រទេសខ្មែរវិញ ។ ពួកគេតែងតែឃោសនាថា កម្ពុជាថ្មីគឺ ជាសង្គមយុត្តិធម៌ និង មានជីវភាពថ្មីល្អប្រសើរ ។ នៅពេលដែលខ្ញុំសាកសួរពួកគេថា ហេតុអ្វីបានប្រជាជននៃកម្ពុជាថ្មី មិនអាចផ្លាស់ប្តូរលិខិតឆ្លើយឆ្លង ឬ ទាក់ទងជាមួយនឹងឪពុកម្តាយបងប្អូនបាន ពួកគេឆ្លើយថា ប្រជាជនថ្មីនៅក្នុងកម្ពុជាថ្មីវល់ជាប់ដៃកសាងប្រទេសជាតិ គ្មានពេលឯណាមកសរសេរកំណាព្យកាព្យឃ្លោង ឬ សំបុត្រឆ្លងឆ្លើយទាក់ទងគ្នាលេងនោះទេ ។ ដើម្បីឈប់ឲ្យពួកក្រុមនោះមកទាក់ទងខ្ញុំទៀត ខ្ញុំបានប្រាប់ពួកក្រុមខ្មែរក្រហមនោះថាខ្ញុំនៅជាប់កំអែលមូលធននិយមក្រាស់ណាស់ ខ្ញុំមិនទាន់អាចចូលទៅបំរើបដិវត្តន៍បាននៅឡើយទេ ។

បន្ទាប់ពីខ្មែរក្រហមផ្តួលរលំរបប លន់ នល់ ភ្លាម ខ្ញុំធ្លាប់បានធ្វើពាក្យសុំទៅពួកខ្មែរក្រហមឲ្យទទួលស្គាល់នូវសញ្ជាតិខ្មែររបស់ខ្ញុំឡើងវិញ ក៏ប៉ុន្តែពួកគេមិនដែលឆ្លើយតបមកវិញម្តងណាឡើយ ។ តាមពិតទៅ ខ្ញុំមានសំណាងណាស់ ដែលបានកាត់ចំណងជាមួយពួកខ្មែរក្រហមទាន់ពេលវេលា ។ ជនរួមជាតិមួយចំនួនបានសុខចិត្តវិលត្រឡប់ទៅប្រទេសខ្មែរវិញ ហើយក៏ត្រូវបាត់ខ្លួន ឬ ក៏ជាប់ការទាក់ទងគ្នាជារៀងរហូត នៅពេលជាន់ទឹកដីខ្មែរភ្លាម ។ ចំពោះជនរួមជាតិមួយចំនួនដែលត្រូវបង្ខំចិត្តបន្តរស់នៅប្រទេសបារាំង ពួកគេទទួលរងទុក្ខវេទនា ដោយសារការព្រាត់ប្រាសបងប្អូនញាតិមិត្តជាទីស្រឡាញ់ ។ ពួកគេត្រូវបន្តធ្វើការប្រយុទ្ធ ដើម្បីជីវភាពប្រចាំថ្ងៃ ជាពិសេសស្វែងរកលក្ខន្តិកៈជាជនភៀសខ្លួន និង ខិតខំរកការងារធ្វើឲ្យបាន ។ បើប្រៀបធៀបជាមួយជនរួមជាតិទាំងនោះ ខ្ញុំហាក់ដូចជាមានសំណាងជាងពួកគេទាំងនោះណាស់ ។

ស្ថានភាពជនភៀសខ្លួនខ្មែរនៅទីក្រុងប៉ារីស

មុនពេលទីក្រុងភ្នំពេញធ្លាក់ក្នុងកណ្តាប់ដៃខ្មែរក្រហម មិត្តភក្តិរបស់ខ្ញុំមួយចំនួនដែលធ្វើការក្នុងក្រុមហ៊ុនកូមិន្តខ្មែរ តែងផ្ញើសំបុត្រមកខ្ញុំយ៉ាងទៀងទាត់ ដើម្បីឲ្យខ្ញុំដឹងពីសភាពការណ៍ទាំងឡាយដែលកើតនៅក្នុងប្រទេសកម្ពុជា ។ ក្នុងចំណោមអ្នកទាំងនោះ មាននារីចំណាស់ម្នាក់ឈ្មោះ ម៉ារី ហ៊ុម បានជូនដំណឹងមកខ្ញុំថា គាត់មានក្មួយស្រីម្នាក់ និង ប្តីរបស់ក្មួយស្រីនោះ កំពុងរស់នៅក្នុងប្រទេសបារាំងនេះដែរ ។ អ្នកស្រី ម៉ារី ហ៊ុម បានផ្តាំឲ្យខ្ញុំជួយមើលក្មួយគាត់ទាំងពីរនាក់នេះផង ក្នុងករណីដែលអ្នកទាំងពីរត្រូវការឲ្យខ្ញុំជួយ ។ ប្តីប្រពន្ធទាំងពីរនាក់នោះ រស់នៅដោយមធ្យោបាយផ្ទាល់ខ្លួន និង ដោយបានទទួលប្រាក់ឧបត្ថម្ភពីរដ្ឋាភិបាល លន់ នល់

រហូតដល់ថ្ងៃទី ១៧ មេសា ១៩៧៥ ។ រហូតមកដល់ពេលនោះ ប្តីប្រពន្ធទាំងពីរនាក់ មិនដែលមានការទាក់ទងជាមួយខ្ញុំឡើយ ។ ជាមួយនឹងការដួលរលំនៃរបបសាធារណរដ្ឋ អ្នកទាំងពីរក៏ពុំមានធនធានគ្រប់គ្រាន់សំរាប់រស់នៅតទៅទៀត ។ ពួកគេត្រូវការរកការងារធ្វើ ។ នៅពេលនោះ ទើបពួកគេសុំឲ្យខ្ញុំជួយ ។ ក្មួយស្រីរបស់អ្នកស្រី ម៉ារី ហ៊ុម នោះ ឈ្មោះ សូនី ឯប្តីនាងឈ្មោះ ឃឹម ខាន់កែវ ។ អ្នកទាំងពីរសុទ្ធតែចេញមកអំពីគ្រួសារអ្នកធំនៅប្រទេសខ្មែរ ។ ឃឹម ខាន់កែវ ជាចៅរបស់លោកអតីតនាយករដ្ឋមន្ត្រី ឃឹម ទិត ។ ឃឹម ខាន់កែវ ជាអ្នកជិតស្និទ្ធនឹងលោក លន់ ណុន ដែលត្រូវជាប្អូនលោក លន់ នល់ ។ ឯចំណែក សូនី ជាកូនរបស់លោក សាវ៉ាត ហ៊ុម ដែលជារដ្ឋលេខាធិការម្នាក់នៃរបប លន់ នល់ ។ លោក សាវ៉ាត ហ៊ុម ធ្លាប់ធ្វើជាចៅហ្វាយខេត្តនៅខេត្តកំពង់ធំផង ។ ចាប់តាំងពីថ្ងៃជ័យជំនះរបស់ពួកខ្មែរក្រហមមក អ្នកទាំងពីរខិតខំស្វះស្វែងរកការងារធ្វើដែរ តែរកពុំបាន ។ ថ្ងៃមួយ ឃឹម ខាន់កែវ ស្នើសុំជួបខ្ញុំ ។ គេមានលក្ខណៈខ្មែរសុទ្ធ សម្បុរស្រអែម ប្រកបដោយសក់រួញអង្គាជីដ៏ក្រាស់ ។ ឃឹម ខាន់កែវ ជាមនុស្សចូលចិត្តនិយាយច្រើនគឺ និយាយមិនចេះឈប់ ។ គាត់មានអាយុច្រើនជាងខ្ញុំតែជាការគួរសម គាត់ហៅខ្ញុំបងទៅវិញ ។ គាត់និយាយសរសើរលើកដើងខ្ញុំថា ខ្ញុំជាមនុស្សមានសំណាង ចេះកសាងជីវិតបានល្អ និង ប្រកបដោយជោគជ័យនៅប្រទេសបារាំង ។ មួយរំពេចនោះ ខ្ញុំក៏រាប់អានគាត់ភ្លាម ។ គាប់ជួនក៏ជាសំណាងល្អរបស់គាត់ដែរ ព្រោះនៅពេលដែលគាត់បង្ហាញខ្លួន ចំពោះមុខខ្ញុំនោះ ខ្ញុំកំពុងត្រូវការរកជំនួយការម្នាក់ ។ ព្រោះថាអស់រយៈច្រើនខែមកហើយ ដែលខ្ញុំត្រូវបានតម្លើងឋានៈ ជាប្រធានក្រុមគណនេយ្យជំនួសអ្នកស្រី ដឺបៃហ្សូ ដែលចេញទៅធ្វើការជានាយកក្រុមគណនេយ្យនៃក្រុមហ៊ុនលក់ពេជ្រមួយ នៅទីក្រុងប៉ារីស ។ ដូច្នេះកន្លែងចាស់របស់ខ្ញុំក៏

នៅទំនេរដែរ ។ ភ្លាមៗនោះខ្ញុំក៏ទទួលជ្រើសរើសយក ឃឹម ខាន់កែវ ជាជំនួយការ របស់ខ្ញុំតាំងពីថ្ងៃនោះរៀងមក ។

នៅក្នុងប្រទេសបារាំង ខ្ញុំពុំសូវមានមិត្តភក្តិច្រើនទេ ក៏ប៉ុន្តែមិត្តភក្តិដែលខ្ញុំ មានទាំងប៉ុន្មាននោះ សុទ្ធតែជាមិត្តភក្តិដ៏ជិតស្និទ្ធ ដែលមានភក្តីភាពយ៉ាងស្មោះស រាងគ្នា និង គ្នា ហើយដែលអាចពឹងពាក់គ្នាបាន ។ គ្រីស្យាន ដឺបៃហ្សេ (Chris tiane Debaize) និង ប្តីរបស់គាត់ឈ្មោះ រ៉ូឡង់ រូស្សូ (Roland Rousseau) ជាមិត្តភក្តិនៅក្នុងប្រភេទមិត្តដ៏ល្អកម្រកបាន ។ នៅគ្រាដំបូង ដែលខ្ញុំបានជួបពួក គេទាំងពីរនាក់ អ្នកទាំងពីរមិនបានរស់នៅជាមួយគ្នាទេគឺ គ្រីស្យាន រស់នៅក្នុង ទីក្រុងម៉ុងត្រើយ (Montreuil) ឯរ៉ូឡង់ រស់នៅទីក្រុងព្យែរហ្វីត (Pierrefitte) ជាយក្រុងខាងជើងទីក្រុងប៉ារីស ។ អ្នកទាំងពីរស្រឡាញ់គ្នាយ៉ាងខ្លាំង ទោះបីជា មានការប៉ះទង្គិចពាក្យសំដីរវាងគ្នាជាញឹកញាប់យ៉ាងណាក៏ដោយ ក៏មិនអាចបំបែក បំបាក់សេចក្តីស្នេហារបស់គេទាំងពីរបានឡើយ ។ ជារឿយៗ នៅពេលគេដើរកំសាន្ត នៅស្រុកស្រែនាចុងសប្តាហ៍ ឬ ចេញទៅទទួលទានអាហារពេលល្ងាចតាមភោជ នីយដ្ឋានធំៗ ពួកគេទាំងពីរតែងនាំខ្ញុំទៅជាមួយ ។ កាលសម័យនោះ រ៉ូឡង់ ជា អធិការនៃក្រុមហ៊ុនធានារ៉ាប់រងលើអាយុជីវិត ។ មិត្តភក្តិខ្ញុំជាច្រើនតែងនិយាយ ចំអន់ឲ្យគាត់ថា "ជាមនុស្សលក់ខ្យល់" ។ រ៉ូឡង់ ធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹង ការិយាល័យមេធាវី និង ការិយាល័យជំនាញគណនេយ្យ ។ សូមរំលឹកថា មុនពេល ដែល គ្រីស្យាន ចេញទៅធ្វើការនៅកន្លែងផ្សេង គាត់បានសំរួលជាមួយថៅកែធំនៅ ក្រុមហ៊ុនទេសចរណ៍ ឲ្យខ្ញុំទៅកាន់តំណែងជំនួសគាត់ដែលជាប្រធានក្រុមគណ នេយ្យ ។ ដូច្នេះហើយ បានជានៅខែ កក្កដា ១៩៧៥ ខ្ញុំត្រូវបានឡើងឋានៈជាគណ នេយ្យករថ្នាក់ទី២ (Comptable 2^{em} Echelon) ។ តាមរបៀបរបបនៅប្រទេស បារាំង ឋានៈវិជ្ជាជីវៈនេះសមរម្យចំពោះខ្ញុំណាស់ ក៏ប៉ុន្តែប្រាក់ខែ ២៣០០ ហ្រ្វង់

ក្នុងមួយខែមិនសមស្របនឹងលក្ខន្តិកៈវិជ្ជាជីវៈឡើយ ។ ថៅកែរបស់ខ្ញុំដឹងច្បាស់ថា ខ្ញុំពិតជាមានគុណសម្បត្តិ ដើម្បីបំពេញមុខងារនេះ ក៏ប៉ុន្តែគាត់ក៏ដឹងដែរថា ប្រសិនបើប្រៀបធៀបទៅនឹងអ្នកឯទៀត ដែលបំពេញមុខនាទីដូចគ្នានេះ ប្រាក់ខែខ្ញុំប្រាកដជាទាបជាងគេ ។ រ៉ូឡង់ សប្បាយចិត្តនឹងការឡើងឋានៈរបស់ខ្ញុំ ក៏ប៉ុន្តែគាត់ក៏មានការអាក់អន់ចិត្តចំពោះប្រាក់ខែដ៏តូចទាបរបស់ខ្ញុំ ។

ទោះបីជាគាត់លែងធ្វើការនៅក្រុមហ៊ុនទេសចរណ៍នេះយ៉ាងណា ក៏ដោយ ក៏គ្រីស្យាន តែងមកលេងខ្ញុំជាញឹកញាប់ ។ ចំណែកខ្ញុំវិញ ខ្ញុំក៏ខិតខំពង្រឹងនូវមិត្តភាពរបស់យើងគឺរវាងគាត់ និង ខ្ញុំក៏ដូចជាជាមួយ រ៉ូឡង់ ស្វាមីគាត់ដែរ ។ យើងបន្តដើរលេងជាមួយគ្នា ទូរស័ព្ទឆ្លងឆ្លើយគ្នាជាញឹកញាប់រហូតដល់ក្លាយជាមនុស្សជិតស្និទ្ធ ដូចជារស់នៅក្នុងរង្វង់គ្រួសារតែមួយយ៉ាងដូច្នោះដែរ ។ ក្នុងល្ងាចមួយនាខែកញ្ញា ១៩៧៥ រ៉ូឡង់ និង គ្រីស្យាន បានបបួលខ្ញុំជិះរថយន្តទៅទទួលទានអាហារពេលល្ងាចនៅទីក្រុងប៉ារីស ។ នៅពេលនោះ រ៉ូឡង់ និយាយប្រាប់ខ្ញុំថា គាត់រកការងារថ្មីឲ្យខ្ញុំធ្វើ គឺជាការងារដែលល្អប្រសើរសំរាប់ខ្ញុំនៅទីក្រុងព្យែរហ្វីតជាទីក្រុងដែលគាត់ស្នាក់អាស្រ័យនៅ ។ គាត់បានរៀបចំឲ្យខ្ញុំទៅជួបប្រធានក្រុមហ៊ុនថ្មីនៅរសៀលថ្ងៃបន្ទាប់ ។ នៅពេលទទួលទានអាហារពេលល្ងាចនោះ រ៉ូឡង់ មិនបាននិយាយអ្វីច្រើនអំពីក្រុមហ៊ុនថ្មី និង ការងារថ្មីដែលខ្ញុំត្រូវធ្វើនោះទេ ។

ឡើងឋានៈដោយមិនដឹងខ្លួន

ដូចបានគ្រោងទុកស្អែកឡើង រ៉ូឡង់ បានទៅទទួលខ្ញុំពីក្រុមហ៊ុនទេសចរណ៍ហ្វារ៉ូសហ្រ្វង់ (Pharos France) ។ គាត់បររថយន្តនាំខ្ញុំពីទីក្រុងប៉ារីស មកទីក្រុង

ដ៏តូចមួយនោះ ដែលមានប្រជាពលរដ្ឋភាគច្រើនជាកម្មករ ឬ ជាអ្នកធ្វើការថ្នាក់កណ្តាល ។ ពេលនោះគឺជាលើកទីមួយហើយដែលខ្ញុំបានធ្វើដំណើរ ឆ្លងកាត់ជាយក្រុងផ្នែកខាងជើងនៃទីក្រុងប៉ារីស ។ នៅក្នុងរថយន្ត រ៉ូឡង់ ព្យាយាមណែនាំពន្យល់ខ្ញុំឲ្យស្គាល់ពីភូមិសាស្ត្រនៃតំបន់នោះ គាត់ប្រាប់ឈ្មោះ និង សកម្មភាពរបស់ទីក្រុងនានាដែលយើងឆ្លងកាត់ ។ ក៏ប៉ុន្តែនៅពេលនោះ ខ្ញុំមិនបានចាប់អារម្មណ៍អ្វីធំដុំឡើយ ព្រោះខ្ញុំកំពុងខ្វល់ខ្វាយត្រៀមខ្លួនទៅធ្វើសម្ភាសន៍ជាមួយថៅកែថ្មី ។ តាមពិតខ្ញុំត្រូវសម្ភាសន៍ជាមួយប្រធានក្រុមហ៊ុនម្នាក់ ដែលគ្រប់គ្រងក្រុមហ៊ុនពីរ មួយឈ្មោះក្រុមហ៊ុន ម៉ុតុង (Motton) និង មួយទៀតឈ្មោះក្រុមហ៊ុន តេប៉េប៉េ (TPP) ។ ខ្ញុំត្រូវប្រុងប្រៀបខ្លួនទៅធ្វើការនៅក្នុងក្រុមហ៊ុនទាំងពីរនេះ ដែលមានការិយាល័យជាប់គ្នានៅដើមផ្លូវតែមួយ ។ មុននឹងទៅជួបថៅកែធំថ្មី រ៉ូឡង់ បានផ្តល់យោបល់ដ៏សំខាន់មួយដល់ខ្ញុំគឺ កុំឲ្យប្រាប់គេតាមត្រង់ថា ខ្ញុំបានទទួលប្រាក់ខែប៉ុន្មាននៅក្នុងក្រុមហ៊ុនទេសចរណ៍ ហ្វារ៉ូសហ្វ្រង់ ។ រ៉ូឡង់ ចតរថយន្តតាមផ្លូវដ៏ចង្អៀតមួយឈ្មោះ ផ្លូវ ដឺ ប៉ារីស (de Paris) នៅចំពីមុខអាគាររបស់ក្រុមហ៊ុនដែលមានដាក់សញ្ញាថា អង់ ដ្រេ ម៉ុតុង (André Motton SA) ។ ពួកយើងនាំគ្នាឡើងជណ្តើរឆ្ពោះទៅជាន់ទីមួយដែលនៅពេលនោះ យើងបានទទួលស្វាគមន៍ពីលោកប្រធានធំ អង់ដ្រេ ម៉ុតុង (André Motton) ពីភរិយារបស់គាត់ឈ្មោះ អានី ម៉ុតុង (Annie Motton) និង ពីគណនេយ្យករចាស់ដែលខ្ញុំត្រូវជំនួសឈ្មោះ ដានីញែល ឡាហ្សា (Daniel Lazard) ។ រ៉ូឡង់ ហាក់ដូចជាស្គាល់អ្នកទាំងនោះយ៉ាងជិតស្និទ្ធ ។ បន្ទាប់ពីបង្ហាញរូបខ្ញុំដល់អ្នកទាំងនោះ និង បន្ទាប់ពីបាននិយាយពាក្យកំប្លុកកំប្លែងពីរបីម៉ាត់រួចហើយ រ៉ូឡង់ ក៏ចេញទៅក្រៅ ដើម្បីទុកឱកាសឲ្យអ្នកទាំងនោះ ធ្វើសម្ភាសន៍ខ្ញុំ ។

យើងជួបជុំគ្នានៅក្នុងបន្ទប់ការិយាល័យរបស់លោក ម៉ុតុង ។ បន្ទប់នោះមានទំហំមធ្យម ហើយតាំងនៅចន្លោះការិយាល័យលេខាធិការ និង ការិយាល័យ

គណនេយ្យ ។ នៅក្នុងបន្ទប់នោះ ពុំមានកន្លែងអង្គុយរង់ចាំ ឬ សាឡុងទទួលភ្ញៀវទេ ។ ខ្ញុំអង្គុយលើកៅអីមួយដែលអ្នកស្រី ម៉ុតុង បានទាញយកមកបន្ថែមនៅខាងក្រោយលោកប្រធាន ។ លោក ម៉ុតុង បានពន្យល់ថា គាត់កំពុងត្រូវការរកមនុស្សម្នាក់មកធ្វើជាគណនេយ្យករជំនួសលោក ឡាហ្សា (Lazard) ដែលបានសំរេចលាចេញ និង រើទៅរស់នៅឯខេត្តខាងត្បូងនៃប្រទេសបារាំង ។ គាត់បានរ៉ាយរ៉ាប់ប្រាប់ខ្ញុំពីសកម្មភាពការងាររបស់ក្រុមហ៊ុនរបស់គាត់ទាំងពីរ ដែលមានបុគ្គលិកទាំងអស់ចំនួនជិត ២០០ នាក់ ។

បន្ទាប់មក លោក ឡាហ្សា ដែលជាគណនេយ្យកចាស់ បានបង្ហាញខ្ញុំនូវការងាររបស់គាត់ និង សួរខ្ញុំពីរបៀម៉ាត់អំពីញ្ហាពន្ធដារ បញ្ហាសង្គមកិច្ច និង ច្បាប់ការងារ ។ នៅទីបញ្ចប់នៃកិច្ចសន្ទនា លោក ម៉ុតុង បានសំរេចផ្តល់ការងារឲ្យខ្ញុំធ្វើក្នុងឋានៈជាគណនេយ្យកររដើមខ្សែ (Comptable Principal) ក្នុងរយៈពេលសាកល្បងបីខែ និង ស្នើឲ្យប្រាក់បៀវត្សដំបូងប្រចាំខែចំនួន ៤៥០០ ហ្វ្រង់គឺស្មើពីរដងនឹងប្រាក់ខែដែលខ្ញុំទទួលនៅក្រុមហ៊ុន ហ្វារ៉ូសហ្វ្រង់ ។ គាត់សន្យាថានៅពេលចប់ការសាកល្បង ខ្ញុំនឹងត្រូវតម្លើងឋានៈជាប្រធានគណនេយ្យកសំរាប់ក្រុមហ៊ុនទាំងពីរ ដែលមានប្រាក់បៀវត្សប្រចាំខែ ៥០០០ ហ្វ្រង់ ។ ខ្ញុំយល់ថា នេះជាសំណាងដ៏ល្អឥតខ្ចោះ ដែលខ្ញុំមិនដែលនឹកដល់ទាល់តែសោះ ។ ពេលនោះ ខ្ញុំមិនបានបណ្តោយឲ្យឱកាសកន្លងផុតទៅដោយទទេៗនោះទេ ។ ខ្ញុំយល់ព្រមទទួលតាមភ្លាម ។ យើងបានព្រមព្រៀងថា ខ្ញុំត្រូវចូលមកធ្វើការនៅថ្ងៃទី ៣ វិច្ឆិកា ១៩៧៥ ដើម្បីឲ្យខ្ញុំមានឱកាសគ្រប់គ្រាន់សំរាប់លាឈប់ពីការងារក្រុមហ៊ុនទេសចរណ៍ ហ្វារ៉ូសហ្វ្រង់ ។ បន្ទាប់មក យើងទាំងអស់គ្នា ក៏នាំគ្នាដើរទៅមើលអាគារផ្សេងៗ និង ការិយាល័យនានា ។ ពួកយើងចុះទៅកាន់ទីធ្លា ដែលព័ទ្ធជុំវិញទៅដោយសំណង់ឃ្លាំង សំណង់ជម្រកកម្មករ រួចដើរទៅផ្នែកខាងក្រោយទៀត ដែល

នៅទីនោះ មានរោងជាងជួសជុលរថយន្ត និង សម្ភារៈបច្ចេកទេសនានា ។ នៅជាន់ខាងក្រោម ជាប់នឹងមាត់ផ្លូវ ក្រុមហ៊ុនមានបន្ទប់តាំងលក់សម្ភារៈថ្មីៗដូចជាគ្រឿងប្រដាប់បន្ទប់ទឹក និង ប្រដាប់ផ្ទះបាយជាច្រើន ដែលគេអាចមើលពីក្រៅតាមជញ្ជាំងកញ្ចក់ ។ នៅចុងបញ្ចប់ យើងនាំគ្នាទៅទទួលទានការ្វេនៅហាងមួយ ដែលកាន់កាប់ដោយជនជាតិអាល់ហ្សេរី ឬ ទុយណេស៊ី ដែលយើងតែងហៅថាមីៗ ។ ទីបំផុត រ៉ូឡង់ ក៏មករួមទទួលទានការ្វេជាមួយយើង ដើម្បីអបអរសាទរដល់កិច្ចព្រមព្រៀងការងារថ្មីរបស់ខ្ញុំ ។

អង់ជ្រៃ ម៉ុត្តុង ជាមនុស្សដែលកសាងជីវិតដោយខ្លួនឯង ។ នៅពេលដែលខ្ញុំទៅជួបគាត់ដំបូងនោះ គាត់ស្ថិតនៅក្នុងវ័យ ៤០ ឆ្នាំ គាត់រៀបការតាំងពីអាយុ ១៨ ឆ្នាំ ជាមួយនឹងប្រពន្ធគាត់ ដែលកាលនោះមានអាយុតែ ១៦ ឆ្នាំប៉ុណ្ណោះ ។ អ្នកទាំងពីរមានកូនស្រីពីរនាក់ ។ អ្នកស្រី ម៉ុត្តុង តែងតែធ្វើការជាជំនួយការ ឬ ជាលេខាធិការរបស់ប្តីគាត់ ។ លោក ម៉ុត្តុង រៀនមិនចប់វិទ្យាល័យទេ គាត់ចេញមកធ្វើការតាំងពីក្មេង ធ្វើជាជាងធ្វើបន្ទប់ទឹក ជាងធ្វើផ្ទះបាយ និង ជាជាងប្រក់ផ្ទះ ។ គាត់ចាប់ផ្តើមជាអ្នកស៊ីឈ្នួលគេ ប៉ុន្តែក្រោយមក គាត់ក៏បើកក្រុមហ៊ុនធ្វើម្ចាស់ការខ្លួនឯងតែម្តង ។ កាលពីពីរឆ្នាំមុន គាត់ក៏បានជួបដៃគូពីរនាក់ ម្នាក់ឈ្មោះ មីស្សែល កាមុស (Michel Camus) ជាវិស្វករខាងសំណង់ និង ម្នាក់ទៀតឈ្មោះ ហ្សាក់ ហ្វុងតែន (Jacque Fontaine) ជាអ្នកជំនាញខាងសូរិយោដី ។ ពួកគេបានស្រុះស្រួលគ្នាបង្កើតជាក្រុមហ៊ុនថ្មីមួយទៀតឈ្មោះ តេប៉េប៉េ (TPP) ដែលនៅក្នុងនោះ គ្រួសារ ម៉ុត្តុង មានភាគហ៊ុនចំនួន ៨០ ភាគរយ ។ ចំណែកឯដៃគូពីរនាក់នោះ គឺ កាមុស និង ហ្វុងតែន ជាអ្នកគ្រប់គ្រងការងារប្រចាំថ្ងៃ ព្រោះម្យ៉ាងពួកគេមានជំនាញផង និង ម្យ៉ាងទៀតពួកគេបាននាំនូវអតិថិជនពីក្រុមហ៊ុនចាស់របស់ពួកគេ

ផង ។ កាមុស និង ហ្វុងតែន ជាមិត្តជិតស្និទ្ធគ្នា ដែលធ្លាប់ធ្វើការជាមួយគ្នាអស់រយៈពេលយ៉ាងយូរ នៅក្នុងក្រុមហ៊ុនសាធារណការមួយដែលត្រូវក្សយធន ។

នៅពេលនោះ លោក ម៉ុតុង ក៏បានកែប្រែក្រុមហ៊ុនរបស់គាត់ ឲ្យក្លាយទៅជាក្រុមហ៊ុនពាណិជ្ជកម្ម ដែលមានឈ្មោះថា ក្រុមហ៊ុនអនាមិក ម៉ុតុង (Motton SA) ដោយមានភរិយាគាត់ និង ញាតិមិត្តគាត់ជាសមាជិកភាគហ៊ុន ។ ក្រុមហ៊ុនទាំងពីរ ធ្វើការបំរើអតិថិជនដ៏ធំមួយគឺ ក្រុមហ៊ុនរដ្ឋឈ្មោះស៊ីក (SCIC) ។ ក្រុមហ៊ុនលោក ម៉ុតុង ទទួលការផ្នែកទុយោហ្គាស ម៉ាស៊ីនកំដៅ និង ប្រក់ដំបូលចំណែកឯក្រុមហ៊ុន តេប៉េប៉េ ធ្វើការផ្នែកសាធារណការ ជាពិសេសផ្លូវតូចៗ និងកន្លែងចតរថយន្ត ។

ថៅកែចាស់របស់ខ្ញុំលោក អាមីញ្រែល ខឹងសម្បារនឹងខ្ញុំយ៉ាងខ្លាំងចំពោះសេចក្តីសំរេចចិត្តរបស់ខ្ញុំឈប់ធ្វើការជាមួយគាត់ ។ ក៏ប៉ុន្តែតាមពិតទៅ នោះជាសិទ្ធិរបស់ខ្ញុំ ព្រោះពួកយើងរស់នៅក្នុងសង្គម និង ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី ជាទីដែលយើងធ្វើអ្វីៗទៅតាមកំលាំងនៃទីផ្សារគឺ ទីណាគេឲ្យប្រាក់ច្រើន យើងនឹងទៅធ្វើការនៅទីនោះ ។ តែទោះជាយ៉ាងណាក៏ដោយ ក៏ខ្ញុំមិនភ្លេចគុណក្រុមហ៊ុនទេសចរណ៍ហ្វារ៉ូសហ្រ្វង់ ដែលបានរើសខ្ញុំយកមកធ្វើការនៅលើកដំបូង ទោះជាខ្ញុំមិនទាន់មានសិទ្ធិធ្វើការក៏ដោយ ។ នៅទីបំផុត ការចាកចេញរបស់ខ្ញុំក៏ត្រូវបានស្រុះស្រួលគ្នា ពុំមានបញ្ហាអ្វីឡើយ ព្រោះខ្ញុំបានដាក់ពាក្យសុំលាឈប់ក្នុងរយៈពេលដ៏សមគួរត្រឹមត្រូវតាមច្បាប់អស់ហើយ ។

នៅថ្ងៃទី ៣ វិច្ឆិកា ១៩៧៥ ខ្ញុំក៏ចាប់ផ្តើមទៅធ្វើការ នៅក្រុមហ៊ុន ម៉ុតុង នៅទីក្រុងព្យែរហ្វីត ។ ខ្ញុំចេញដំណើរពីព្រឹក ដោយជិះម៉ែត្រូនៅស្ថានីយ អាឡេស្សា (Alésia) ទៅស្ថានីយដឺឡាហ្គាឌុយណ័រ (La Gare du Nord) ដើម្បីបន្តជិះ

រទេះភ្លើងពីក្រុងប៉ារីស ទៅទីក្រុងព្យែរហ្វីត ។ បើមិននិយាយពីពេលវេលារង់ចាំ យើងធ្វើដំណើរពីប៉ារីស ទៅព្យែរហ្វីត តែជប់ប្រាំនាទីតែប៉ុណ្ណោះ ។ ពីស្ថានីយរថភ្លើងខ្ញុំដើរតាមផ្លូវអស់រយៈពេលដប់នាទីទៀត ទើបដល់កន្លែងធ្វើការ ។ នៅពេលខ្ញុំទៅដល់ ថៅកែធំ និង ភរិយាគាត់ បានចាប់ផ្តើមធ្វើការជាស្រេច ។ គាត់កំពុងមើលការបែងចែកភារកិច្ចដល់កម្មករទាំងអស់ និង ត្រួតពិនិត្យការចេញដំណើរបស់ពួកគេ ឆ្ពោះទៅកាន់ការដ្ឋាននីមួយៗនៅក្នុងក្រុង និង ជាយក្រុង ។

មុននឹងចាប់ផ្តើមការងារដំបូងរបស់ខ្ញុំ អ្វីដែលថៅកែឲ្យខ្ញុំធ្វើនោះគឺ គាត់នាំខ្ញុំទៅទទួលទានការហ្វេនៅតៀមការហ្វេមីៗជាថ្មីម្តងទៀត ។ ការងារនៅថ្ងៃទីមួយរបស់ខ្ញុំនោះ បានត្រូវសំរួលយ៉ាងខ្លាំង ព្រោះលោក ឡាហ្សា ប្រញាប់ប្រញាល់ប្រគល់ការងារឲ្យខ្ញុំ ដើម្បីគាត់បានចេញដំណើរយ៉ាងឆាប់រហ័សទៅកន្លែងថ្មីរបស់គាត់ ។ ខ្ញុំចំណាយពេលពេញមួយថ្ងៃជាមួយគាត់រៀនសូត្រពីគាត់នូវការងារជំនាញមួយចំនួន ។ ឡាហ្សា មានអាយុច្រើនជាងខ្ញុំ តែគាត់ពុំទាន់មានភរិយាទេ នៅពេលនោះ ។ ខ្ញុំមិនបានដឹងចំណេះវិជ្ជារបស់គាត់ដល់កំរិតណាទេ ប៉ុន្តែគាត់ហាក់បីដូចជាមានការឈ្លាសវៃក្នុងល្បិចកលមួយចំនួន ក្នុងការបង់ពន្ធដារឲ្យបានតិច ។ បន្ទាប់ពីចប់ការងារហើយ យើងទាំងអស់គ្នាក៏ចាកចេញទៅទទួលទានអាហារពេលល្ងាច ។ យើងទទួលទានស្រា និង ស្តាប់ភ្លេងជាច្រើនកន្លែង នៅទីក្រុងព្យែរហ្វីតផង នៅទីក្រុងប៉ារីសផង ។ ឡាហ្សា ទទួលទានស្រា រីកា (Ricard) ស្រាបៀរ ស្រាក្រហម និង ស្រាគោញាក់យ៉ាងច្រើន ។ ឡាហ្សា ហាក់ដូចជាមានកំលាំងមាំមួន ហើយគាត់អាចផឹកស្រាពេញមួយយប់ក៏បាន ។ ខ្ញុំខំព្យាយាមធ្វើដូចគាត់ដែរ ក៏ប៉ុន្តែខ្ញុំមិនមានបទពិសោធន៍ដូចគាត់ឡើយ ដូច្នេះខ្ញុំក៏ស្រវឹងស្រាយ៉ាងត្រឡប់ត្រឡិនមិនដឹងខ្លួន ហើយមិនអាចត្រឡប់ទៅផ្ទះ នៅឯ អាឡេស្សា បានឡើយ ។

ស្អែកឡើង យើងក៏បែកគ្នា ហើយតាំងពីពេលនោះមក ខ្ញុំក៏ពុំដែលឮឈ្មោះ ឡាហ្សា រហូតរៀងមក ។ ក្នុងឋានៈជាគណនេយ្យករប្រចាំក្រុមហ៊ុន ក្រៅពីការងារ ប្រចាំថ្ងៃផ្នែកគណនេយ្យ ខ្ញុំមានការទទួលខុសត្រូវមួយទៀតគឺ ផ្តល់មតិណែនាំ ឲ្យថៅកែខ្ញុំបំពេញភារកិច្ចរបស់គាត់ឲ្យបានត្រឹមត្រូវតាមច្បាប់ និង បទដ្ឋាននានា ជាពិសេសឲ្យត្រឹមត្រូវតាមច្បាប់ពាណិជ្ជកម្ម និង ច្បាប់ការងាររបស់បារាំង ។ លោក ម៉ុតុង និង ភរិយាតែងចាត់ទុកខ្ញុំជាទីប្រឹក្សាផ្នែកច្បាប់ និង ពន្ធដារ ។ នៅ ពេលនោះ ខ្ញុំប្រហែលជាបញ្ញវន្តតែម្នាក់គត់ នៅក្នុងក្រុមហ៊ុនដែលធ្វើឲ្យមុខនាទី របស់ខ្ញុំ បានទទួលការគោរព និង លើកកំពស់ជាពិសេស ។ ដើម្បីជួយគណនេយ្យករ ឲ្យបំពេញភារកិច្ចរបស់ខ្លួនឲ្យបានត្រឹមត្រូវហ្មត់ចត់នោះ ក្រុមហ៊ុនបានជួលមេធាវី ម្នាក់ និង អ្នកជំនាញការគណនេយ្យម្នាក់ទៀត ដើម្បីឲ្យខ្ញុំពិគ្រោះយោបល់តាម ត្រូវការ ។ បន្ថែមលើនេះ អ្នកជំនាញការគណនេយ្យនោះជួយពិនិត្យបញ្ជីហិរញ្ញវត្ថុ របស់ខ្ញុំ នៅរាល់ដំណាច់ឆ្នាំសារពើពន្ធនានា មុននឹងបញ្ជូនទៅ ក្រសួងពន្ធដារ ។

ក្រោយពីខ្ញុំបានធ្វើការសាកល្បងគ្រប់បីខែហើយលោក ម៉ុតុង ក៏បាន បញ្ចូលឈ្មោះខ្ញុំជាម្ចាស់ភាគហ៊ុនមួយ នៅក្នុងក្រុមហ៊ុនរបស់គាត់ ក៏ប៉ុន្តែតាមពិត ទៅ ខ្ញុំគ្រាន់តែប្រគល់ឈ្មោះឲ្យគាត់តែប៉ុណ្ណោះ ដោយខ្ញុំពុំបានបង់ប្រាក់កាសអ្វី ឡើយ ។ ប្តូរនឹងភាគហ៊ុននោះ ខ្ញុំក៏បានចុះហត្ថលេខាលើក្រដាស "ស" មួយសន្លឹក ដែលលោក ម៉ុតុង រក្សាទុកក្នុងទូដែករបស់គាត់យ៉ាងប្រយ័ត្នប្រយែងជាទីបំផុត ។ ដោយសារទំនាក់ទំនងការងារល្អ ខ្ញុំក៏បានក្លាយជាមិត្តជិតស្និទ្ធជាមួយលោក ដែល ម៉ាន់ (Delman) មេធាវី និង លោក ហុឡង់ដែរ (Hollander) អ្នកជំនាញការ គណនេយ្យផងដែរ ។ ខ្ញុំក៏ក្លាយជាដៃគូដ៏ជិតស្និទ្ធ ច្បាស់លាស់របស់អ្នកទាំងពីរ ដោយហេតុថាលោក ម៉ុតុង បានផ្តល់សិទ្ធិពេញទីដល់ខ្ញុំចំពោះរាល់ករណីដែលទាក់ ទងនឹងច្បាប់ទម្លាប់គណនេយ្យ និង បញ្ហាពន្ធដារ ។

នៅក្នុងក្រុមហ៊ុនរបស់គាត់ លោក ម៉ុត្តុង ធ្វើការជាមួយនឹងញាតិមិត្តរបស់គាត់ ។ គាត់ប្រើឪពុកក្មេកគាត់ ដែលគេហៅថា "ណូណូ" (No No) ជាអ្នកបើកបរ រថយន្ត ឯប្អូនថ្លៃរបស់គាត់ឈ្មោះ ហ្សង់ ប៉ូល (Jean Paul) ជាអ្នកកាន់កាប់ឃ្លាំង ។ ប្អូនថ្លៃគាត់ម្នាក់ទៀតគឺ ប្តីរបស់ប្អូនស្រីគាត់ឈ្មោះ ដានីញែល (Daniel) ជាជាង ជួសជុលរថយន្តរបស់ក្រុមហ៊ុន ។ ជារៀងរាល់ថ្ងៃ នៅពេលចប់ការងារ ឲ្យតែមាន ឱកាស ដានីញែល តែងតែរកវិធីជួបជុំគ្នាអបអរសាទរអ្វីមួយ ដើម្បីនាំគ្នាផឹកស្រា ។ ញាតិមិត្តទាំងអស់នោះមិនយូរប៉ុន្មានបានក្លាយជាមិត្តជិតស្និទ្ធរបស់ខ្ញុំ ។ អ្នកទាំង នោះធ្វើអំពើល្អជាច្រើនចំពោះខ្ញុំ ។ ជាច្រើនដងក្នុងមួយអាទិត្យ។ អ្នកទាំងនោះ ច្រើនស្រវឹងស្រា ជាពិសេស ដានីញែល ។ លោក ម៉ុត្តុង មិនដែលចាត់ទុកអ្នកទាំង នោះថាជា ឪពុកក្មេក ឬ ប្អូនថ្លៃទេ គាត់ចាត់ទុកអ្នកទាំងនោះជាកម្មករ ឬ អ្នកធ្វើ ការដូចគេដូចឯងដែរ មិនតែប៉ុណ្ណោះ គាត់មានភាពហ្មត់ចត់ ម៉ិតម៉ែជាងកម្មករ ឬ អ្នកធ្វើការឯទៀតផង ។ ជាញឹកញាប់ ខ្ញុំតែងឮសម្លេងស្រែកដេរ ឬ ស្តីបន្ទោស ខ្លាំងៗ ដែលថៅកែខ្ញុំស្រែកដាក់អ្នកទាំងនោះ ដែលគេអាចស្តាប់ឮពីចម្ងាយរាប់រយ ម៉ែត្រ ។ អ្នកទាំងនោះ ទោះជាយ៉ាងណាក៏ដោយ ក៏ហាក់ដូចជាស្រឡាញ់រាប់អាន ថៅកែខ្ញុំខ្លាំងណាស់ ពួកគេតែងហៅឈ្មោះគាត់បែបស្រឡាញ់ថា "ដេដេ"(DéDé) ។

អស់រយៈពេលបីសប្តាហ៍ បន្ទាប់ពីខ្ញុំចូលធ្វើការក្រុមហ៊ុនរបស់គាត់មក លោក ម៉ុត្តុង បានរកឲ្យខ្ញុំនូវផ្ទះមួយដែលមានមួយបន្ទប់ មានតម្លៃឈ្នួលថោកជាង បន្ទប់ខ្ញុំជួលនៅឯទីក្រុងប៉ារីសទៅទៀត ។ ផ្ទះនោះ ស្ថិតនៅទីក្រុង ជិតខាងមួយ ឈ្មោះថាទីក្រុង ស្តាំង (Stains) នៅលេខ ៦ ផ្លូវ ប៉ូល ឡង់ហ្សឺវ៉ាំង (Paul Langevin) ។ ផ្ទះនេះស្ថិតនៅក្នុងតំបន់ជាប់គ្នារវាងទីក្រុងសាកសែល (Sarcelles) ស្តាំង និង ព្យែរហ្វីត ។ ផ្ទះនោះស្ថិតនៅ ជាន់ទី ៣ ដែលជាជាន់ខ្ពស់ផុតពីគេ នៅ ក្នុងអាគារមួយដែលមានភាពស្ងប់ស្ងាត់ និង សួនច្បារដ៏លំអផង ។ ផ្ទះនេះ មិន

មានគ្រឿងសង្ហារឹមអ្វីទេគឺ ជាតួផ្ទះទទេ ក៏ប៉ុន្តែខ្ញុំចំណាយប្រាក់ឈ្នួលតែ ៣០០ ហ្រ្វង់ ប៉ុណ្ណោះក្នុងមួយខែ ។ មុននឹងចូលនៅ លោក ម៉ុត្តុង បានបញ្ជាកម្មករ របស់គាត់ឲ្យជួយសំអាត និង លាបពណ៌បន្ទប់ឲ្យថ្មីឡើងវិញ ។ គាត់ប្រើឪពុក ក្មេកគាត់ ណូ ណូ ឲ្យយកវ៉ាយន្តរបស់ក្រុមហ៊ុនទៅដឹកអីវ៉ែអីវ៉ាន់របស់ខ្ញុំនៅទីក្រុង ប៉ារីសមកផ្ទះថ្មីនោះ ។ តាមខ្ញុំស្មាន ណូ ណូ ប្រហែលជាមានការខកចិត្តជាខ្លាំង នៅពេលដែលគាត់ឃើញថាខ្ញុំគ្មានអីវ៉ែអីវ៉ាន់អ្វីធំដុំច្រើនទេ មានតែសំលៀកបំពាក់ សៀវភៅ និង ប្រដាប់ប្រដាបន្តិចបន្តួចតែប៉ុណ្ណោះ ។ នៅថ្ងៃជាមួយនោះ លោក ម៉ុត្តុង បានអនុញ្ញាតឲ្យខ្ញុំឈប់សំរាកពេញមួយថ្ងៃ ដើម្បីរកទិញតុ ទូ គ្រែ ពូក ខ្នើយ និង អ្វីៗ ដែលខ្ញុំត្រូវការសំរាប់ប្រើប្រាស់នៅក្នុងផ្ទះ ។ គាត់ចាត់ឲ្យបុគ្គលិកម្នាក់ ដែលស្គាល់កន្លុកកន្លៀត ដែលអាចរករបស់របរតម្លៃថោកសមរម្យ ឲ្យជួយនាំខ្ញុំទៅ ទិញរបស់ទាំងនោះ ។ ថ្ងៃនោះ យើងទៅទិញរបស់របរនោះនៅទីក្រុង សាំង ដឺនី (Saint-Denis) ដែលជាទីក្រុងធំជាងគេនៅតំបន់នោះ ។ មិនតែប៉ុណ្ណោះថៅកែ របស់ខ្ញុំបានប្រើប្អូនថ្លៃគាត់ ដានីញែល ឲ្យមកជួយក្រាលកំរាលព្រំឲ្យខ្ញុំផង ។ ដូច្នេះមិនយូរប៉ុន្មាន ខ្ញុំក៏បានរស់នៅក្នុងផ្ទះមួយ ដែលពោរពេញទៅដោយគ្រឿង ប្រណិត ។

បន្ទាប់ពីបានធ្វើការសាកល្បងអស់រយៈពេលបីខែមក ខ្ញុំក៏ត្រូវបានទទួល ការតែងតាំងជាប្រធានគណនេយ្យពេញសិទ្ធិ ដោយបានទទួលប្រាក់ខែចំនួន ៥០០០ ហ្រ្វង់ ក្នុងមួយខែ ។ ការឡើងកាន់ឋានៈពីបុគ្គលិកធម្មតា ទៅជាអ្នកមាន ក្របខ័ណ្ឌខ្ពស់នេះ ជាករណីពិសេស សំរាប់ខ្ញុំដែលជាជនភៀសខ្លួនម្នាក់ក្នុងយុវវ័យ នាសម័យនោះ ។ ម្យ៉ាងទៀតខ្ញុំក៏បានទទួលការទុកចិត្ត និង ការស្រឡាញ់រាប់អាន យ៉ាងជ្រាលជ្រៅ ពីថៅកែព្រមទាំងដៃគូរបស់គាត់ពីរនាក់ទៀត នៅក្នុងក្រុមហ៊ុន តេប៉េប៉េ ផងដែរ ។ នៅក្នុងការគ្រប់គ្រងក្រុមហ៊ុន ខ្ញុំបានក្លាយទៅជាមនុស្សម្នាក់

ដែលមិនអាចបាត់មុខបាន ។ ថៅកែរបស់ខ្ញុំធ្វើការពិគ្រោះជាមួយខ្ញុំរាល់ពេលវេលាដែលគាត់រើសបុគ្គលិកថ្មី ឬ បណ្តេញបុគ្គលិកណាចោល ឬ នៅពេលដែល គាត់ដាក់ទណ្ឌកម្ម ឬ តម្លើងឋានៈដល់បុគ្គលិកទាំងអស់ ។

ខ្ញុំតែងផ្តល់យោបល់ថា តើនៅពេលណាត្រូវតម្លើងឋានៈ និង ថានៅពេលណាត្រូវតម្លើងប្រាក់ខែឲ្យបុគ្គលិក ។ ខ្ញុំជាអ្នកចុះហត្ថលេខាលើឯកសារជាច្រើនក្នុងនាមជានិយោជកសំរាប់បុគ្គលិក ឬ កម្មករដែលត្រូវការឯកសារ ដើម្បីយកទៅបើកប្រាក់សន្តិសុខសង្គម ឬ ប្រាក់សំណងគ្រោះថ្នាក់ការងារ ឬ ឯកសារចូលនិវត្តន៍ និង ឈប់សំរាកប្រចាំឆ្នាំជាដើម ។ ក្នុងឋានៈជាប្រធានគណនេយ្យ ខ្ញុំចូលរួមក្នុងការចរចាជាមួយអ្នកតំណាងធនាគារក្នុងការខ្ចីប្រាក់ ឬ ឥណទានឯទៀតៗ ។ ជួនកាល ខ្ញុំក៏ចូលរួមចុះពិនិត្យដល់ទីកន្លែងដែលកម្មកររធ្វើការ ។ ជាញឹកញយខ្ញុំចូលរួមទទួលទានបាយថ្ងៃត្រង់ ឬ បាយល្ងាចជាមួយថៅកែរបស់ខ្ញុំ ដែលគាត់រៀបចំទទួលអតិថិជនរបស់គាត់ ជាការទទួលទានអាហារបែបធុរកិច្ច ។

ជាមួយនឹងការសិក្សាផ្នែកគណនេយ្យរបស់ខ្ញុំ ខ្ញុំក៏ឆ្លៀតទៅរៀនបើកបរយន្តនៅក្រៅពេលម៉ោងធ្វើការ ។ ប្រហែលបី ឬ បួនអាទិត្យក្រោយមក ខ្ញុំក៏បានទទួលប័ណ្ណបើកបរយន្តនៅពេលចូលប្រឡងលើកទីមួយ ។ គ្រាន់តែឃើញប័ណ្ណបើកបររបស់ខ្ញុំ លោក ម៉ុតុង សប្បាយចិត្តណាស់ ។ គាត់ផ្តល់រថយន្តរបស់ក្រុមហ៊ុនឲ្យខ្ញុំបើកបរភ្លាម ។ រថយន្តនោះ មានពណ៌លឿង ខៀវ និង ផ្លាកសញ្ញារបស់ក្រុមហ៊ុនត្រូវបានខ្ញុំប្រើរហូតដល់ពេលខ្ញុំមានរថយន្តផ្ទាល់ខ្លួន ដែលខ្ញុំបានត្រៀមទិញនៅពេលខាងមុខ ។ ដើម្បីទិញរថយន្តនេះ ថៅកែបានចាត់ឲ្យដានីញែល នាំខ្ញុំដើរទៅរកមើលក្នុងចំណោមរថយន្តចាស់ៗដែលគេដាក់លក់នៅតាមហាងជួសជុលរថយន្តនានា ។ ពេលខ្ញុំជួប ដានីញែល ភ្លាម គាត់និយាយថា បើសិនជាខ្ញុំសុខចិត្តចំណាយប្រាក់តែ ២៥០០ ហ្វ្រង់ គាត់អាចជួយកែកុនរថយន្ត

នោះឲ្យល្អដូចរថយន្តថ្មីសន្លាងបាន ។ ឮដូច្នេះខ្ញុំក៏យល់ព្រម ។ ព្រឹកឡើងនៅថ្ងៃបន្ទាប់ ដានីញែល បានចូលមកក្នុងការិយាល័យខ្ញុំ ដើម្បីបបួលខ្ញុំទៅទីក្រុងសាំងដឺនី ដោយប្រាប់ខ្ញុំថា ឲ្យយកមូលប្បទានប័ត្រទៅជាមួយផង ។ បន្ទាប់មក ដានីញែល ក៏បររថយន្តរបស់គាត់ ដែលជារថយន្តសណ្តោងទៅហាងជួសជុលរថយន្តមួយដែលមានដាក់លក់រថយន្តថ្មី និង ចាស់មួយចំនួន ។ នៅពេលទៅដល់ទីនោះ ដានីញែល នាំខ្ញុំទៅផ្នែកខាងក្រោយនៃហាងជួសជុល ហើយចង្អុលទៅរថយន្តមួយដែលគ្របដណ្តប់ដោយធូលី និង សម្រាមយ៉ាងក្រាស់មើលស្ទើរមិនយល់ ។ រថយន្តនោះជារថយន្ត ម៉ាក ប៊ីហ្សូ ២០៤ (Peugeot 204) បែបរថយន្តសំរាប់គ្រួសារ ។ ដានីញែល ចង្អុលប្រាប់ខ្ញុំថានេះហើយជារថយន្តរបស់អ្នកឯង ។ ខ្ញុំធ្លាក់ថ្លើមក្តុកនឹកអន់ចិត្តថាម្តេចក៏មកទិញរថយន្តប្រភេទនេះទៅវិញ ។ ខ្ញុំមានការស្ទាក់ស្ទើរមិនចង់ប្រគល់មូលប្បទានប័ត្រចំនួន ២៥០០ ហ្រ្វង់នោះទេ ។ ម្យ៉ាងទៀត រថយន្តនោះ មានគ្រឿងម៉ាស៊ីនខូច និង គ្មានធុងអាគុយផង ។ ក៏ប៉ុន្តែ ដោយមានការធានាពី ដានីញែល ថារថយន្តនេះសមរម្យហើយ ខ្ញុំក៏សុខចិត្តបង់ប្រាក់គ្រប់ចំនួននោះទៅ ។ នៅទីបញ្ចប់ ពួកយើងសណ្តោងអូសរថយន្តដែលយើងទើបតែទិញរួចនោះមករោងជាងនៃក្រុមហ៊ុនរបស់យើងវិញដើម្បីធ្វើការជួសជុល និង កែលំអ ។

ដានីញែល ជាមនុស្សមានការងាររវល់យ៉ាងមមាញឹក ។ នៅខាងក្រៅរោងជាង គាត់មានរថយន្តពីរ ឬ បីគ្រឿងជានិច្ច ដែលត្រូវចតរង់ចាំការជួសជុល ។ រថយន្តភាគច្រើនជារបស់មន្ត្រីនៃក្រុមហ៊ុន ដែលជាអតិថិជនរបស់យើង ។ តាមពិត រោងជួសជុលនេះ បំពេញការងារមួយផ្នែកដែរ ក្នុងទំនាក់ទំនងសាធារណៈរបស់ក្រុមហ៊ុន ។ លោក ម៉ុត្តុង តែងយកចិត្តទុកដាក់ចំពោះអតិថិជនធំៗរបស់គាត់ដោយជួសជុលរថយន្តរបស់អ្នកទាំងនោះ ដោយឥតគិតថ្លៃ ។ ធ្វើបែបនេះ ទើបគាត់

ទទួលបាននូវកិច្ចសន្យាការងាររបស់គាត់ជាច្រើន ។ ដូច្នេះការជួសជុលរថយន្ត របស់ខ្ញុំ មិនមានអាទិភាពខ្ពស់សំរាប់ ជានីញែល ទេ ។ អស់រយៈពេលមួយខែ ក្រោយមក ជានីញែល ក៏ចាប់ផ្តើមជួសជុល និង កែលំអរថយន្តរបស់ខ្ញុំ ឲ្យមាន សភាពដូចរថយន្តថ្មីដូច្នោះមែន ។ ជានីញែល បានដូរម៉ាស៊ីន និង បាញ់ថ្នាំថ្មី ធ្វើឲ្យ រថយន្តចាស់ក្លាយជារថយន្តមួយថ្មី ដូចទើបចេញពីហាងយ៉ាងដូច្នោះដែរ ។ ខ្ញុំមាន សេចក្តីត្រេកអរជាអនេកចំពោះរថយន្តថ្មី ដែលខ្ញុំមិនធ្លាប់មានទាល់តែសោះ ។ ដោយសាររថយន្តនោះ មានសភាពស្អាតល្អពេក សហការីម្នាក់បានសុំប្តូររថយន្ត នោះជាមួយនឹងរថយន្ត 2CW ដ៏ថ្មី ដែលគាត់ទើបតែទិញចេញពីរោងចក្រ ។ ប៉ុន្តែ ខ្ញុំស្រឡាញ់រថយន្ត ប៊ីហ្សូ ២០៤ (Peugeot 204) នោះខ្លាំងពេក ខ្ញុំក៏ប្រកែក មិនព្រមដូរ ។ ជារៀងរាល់ថ្ងៃ នៅពេលមកដល់កន្លែងធ្វើការ ខ្ញុំតែងចតរថយន្តនៅ ទីកន្លែងណា ដែលខ្ញុំអាចមើលឃើញ តាមបង្អួចកញ្ចក់ពីការិយាល័យខ្ញុំជានិច្ច ។

ក្នុងរយៈពេលជាច្រើនឆ្នាំ ដែលខ្ញុំធ្វើការក្នុងក្រុមហ៊ុនម៉ុតូង ខ្ញុំតែងបាន ទទួលការស្រឡាញ់រាប់អានពីគ្រប់មជ្ឈដ្ឋានរាប់ទាំងថៅកែខ្ញុំ និង ដៃគូរបស់គាត់ពីរ នាក់ទៀតផង ។ តាមធម្មតានៅរៀងរាល់ពេលដែលខ្ញុំមកដល់កន្លែងធ្វើការ បន្ទាប់ ពីខ្ញុំបានទទួលទានអាហារពេលព្រឹករួចហើយ ដែលមានដូចជាកាហ្វេខ្មៅក្តៅ និង នំខ្ញះៗ ខ្ញុំបើកបររថយន្តយ៉ាងប្រញាប់មកការិយាល័យរបស់ខ្ញុំ ។ ខ្ញុំមកដល់នៅ ចន្លោះម៉ោង ៨មនា០ និង ៨មនា៥ ព្រឹក ។ ជាញឹកញាប់លោក ម៉ុតូង តែងមកដល់ ការិយាល័យមុនខ្ញុំ ឯការិយាគាត់មកតាមក្រោយ ។ ពេលអ្នកស្រីមកដល់ ទាំងប្តី ទាំងប្រពន្ធតែងនាំខ្ញុំទៅទទួលទានកាហ្វេម្តងទៀតនៅហាងមីៗ ។ នៅពេលនោះ ដៃគូរបស់គាត់គឺ លោក កាមុស និង ហ្វុងតែន បានមករួមទទួលទានកាហ្វេជាមួយ យើង ឬ ជួនកាលនៅពេលខ្លះ ខ្ញុំទៅទទួលទានការហ្វេជាមួយអ្នកទាំងពីរនាក់នោះ ដោយគ្មានវត្តមានរបស់ថៅកែ ។ ការទទួលទានកាហ្វេពេលព្រឹកនេះ ជាឱកាសឲ្យ

យើងនិយាយពីការងាររបស់ក្រុមហ៊ុនខ្លះ ឬ និយាយលេងពីនេះពីនោះក៏មាន ។ ដូច្នេះ ក្នុងមួយថ្ងៃៗ ខ្ញុំក៏ទទួលទានការហ្វេជាច្រើនពែង ព្រោះនោះជាពិធីការទូតតាមការអញ្ជើញជាញឹកញាប់ក្នុងមួយថ្ងៃៗ ។ ការទទួលទានការហ្វេនៅហាងមីៗ មុននឹងចាប់ផ្តើមការងារ ក៏បានក្លាយទៅជាកិច្ចប្រតិបត្តិប្រចាំថ្ងៃរបស់ខ្ញុំអស់ពេលជាច្រើនឆ្នាំ ។

ចែកឲ្យដាច់មនោសញ្ចេតនា និង ការងារ

នៅពេលបាយថ្ងៃត្រង់ ខ្ញុំតែងទៅចូលរួមទទួលទានអាហារជាមួយគ្រួសារលោក ម៉ុតុង នៅក្នុងភោជនីយដ្ឋានក្បែរនោះ ឬ បើពុំនោះទេ ខ្ញុំទៅជាមួយលោក កាមុស និង ហ្វុងតែន ដែលនាំខ្ញុំទៅភោជនីយដ្ឋានគ្មានអ្នកបំរើ (Self Service Restaurant) នៅក្បែរនោះ ឯក្រុងសាក សែល (Sarcelles) ។ គ្រួសារ ម៉ុតុង ទទួលទានបាយនៅវេលាម៉ោងមួយរសៀល ព្រោះគាត់ត្រូវរង់ចាំកូនស្រីគាត់ពីរនាក់ គឺ ប៉ាទ្រីស្យា (Patricia) និង សេលីន (Céline) ចេញពីសាលា ។ ដូច្នេះជាញឹកញាប់ ខ្ញុំទទួលទានបាយរួមជាមួយអ្នកទាំងនោះ ដែលមានម្ហូបអាហារដូចៗគ្នា ។ នៅភោជនីយដ្ឋាននេះ ខ្ញុំមិនបង់ប្រាក់ភ្លាមទេ គ្រាន់តែឲ្យគេកត់ត្រាទុក រួចបូកសរុបទើបខ្ញុំទូទាត់បង់ប្រាក់មួយខែម្តង ។ ក៏ប៉ុន្តែនៅភោជនីយដ្ឋានគ្មានអ្នកបំរើ ខ្ញុំត្រូវចេញប្រាក់ភ្លាមៗ ។ នៅទីនោះ ពួកយើងមានការរីករាយច្រើន ព្រោះស្ថិតនៅ ក្នុងបរិយាកាសប្រជាប្រិយ និង មានម្ហូបឆ្ងាញ់ៗ ដែលមាននារីម្នាក់រាងធាត់បន្តិច ឈ្មោះអ្នកស្រី ហ្គ្វីហ្សុង (Goujon) ជាអ្នកលើកម្ហូបឲ្យយើង ។

បន្តិចម្តងៗ ពួកយើងក៏កាន់តែជិតស្និទ្ធគ្នាឡើង ពួកយើងកាន់តែស្រឡាញ់រាប់អានគ្នាឡើង ។ ក៏ប៉ុន្តែ នៅពេលបាយម្តងៗ ខ្ញុំមានការពិបាកក្នុងចិត្តថា តើគួរចេញទៅទទួលទានអាហារជាមួយក្រុមណា? ជាមួយថៅកែធំ ជាមួយគ្រួសារថៅ

កែធំ ឬ ទៅជាមួយអ្នកដៃគូរបស់គាត់ទាំងពីរនាក់នោះ? ប្រសិនបើអ្នកទាំងនោះមិនមានទំនាស់ផលប្រយោជន៍រវាងគ្នា និង គ្នាទេនោះ ខ្ញុំក៏គ្មានអ្វីគួរឲ្យព្រួយបារម្ភដែរ ។ ក៏ប៉ុន្តែ ប្រសិនបើអ្នកទាំងនោះ មានទំនាស់ជាមួយគ្នា ខ្ញុំត្រូវតែប្រុងប្រយ័ត្នជានិច្ច គឺមិនត្រូវបង្ហាញរូបភាពថា ខ្ញុំចូលចិត្តក្រុមម្ខាងជាងក្រុមម្ខាងទៀតឡើយ ។ ខ្ញុំត្រូវថែរក្សាអព្យាក្រឹតភាពរបស់ខ្ញុំ ។ តាមធម្មតានៅពេលណាដែលក្រុមទាំងពីរមានមតិខ្វែងគ្នា ពួកគេតែងសុំឲ្យខ្ញុំផ្តល់មតិជាចុងក្រោយ ។ តាមរូបភាពជាក់ស្តែង ខ្ញុំទោរទន់ទៅខាងក្រុមលោកថៅកែធំ ខាងផ្នែកមនោសញ្ចេតនាយ៉ាងច្រើន ព្រោះពួកគេរាប់អានខ្ញុំដូចជាសមាជិកក្រុមគ្រួសាររួចទៅហើយ ។ ក៏ប៉ុន្តែ ចំពោះការងារវិញ ខ្ញុំមានទំនោរទៅរកអ្នកដៃគូទាំងពីរនាក់នោះ ព្រោះអ្នកទាំងនោះបានរៀនសូត្រច្រើន ចេះដឹងច្រើន ធ្វើអ្វីៗច្រើនធ្វើតាមច្បាប់ មិនសូវចេះកេងប្រវ័ញ្ចអ្វីប៉ុន្មានឡើយ ។ ផ្ទុយទៅវិញ ថៅកែធំចូលចិត្តអួតអាងខាងផ្លូវសម្ភារៈដូចជា៖ ឡានល្អ សំលៀកបំពាក់ល្អ ម្ហូបអាហារថ្លៃៗ ដើរលេងសប្បាយច្រើន និង ប្រើល្បិចកលជាច្រើន ដើម្បីរកប្រាក់ចំណេញសំរាប់ក្រុមហ៊ុនគាត់ ។ ជាញឹកញាប់នៅវេលាចេញទៅទទួលទានអាហារថ្ងៃត្រង់ អ្នកដៃគូរបស់ថៅកែធំគឺ លោក កាមុស និង លោក ហ្វុងតែន តែងនាំគ្នាមកស្រែកហៅ នៅមុខការិយាល័យរបស់ខ្ញុំថា "មូលី ដល់ម៉ោងបាយហើយ" ។ ជាពិសេស នៅរាល់ថ្ងៃសៅរ៍ នៅពេលដែលយើងផ្អាកការងារនៅក្នុងការិយាល័យ អ្នកទាំងពីរតែងបើករថយន្តនាំខ្ញុំទៅមើលការដ្ឋាននានា ដើម្បីត្រួតពិនិត្យការងាររបស់កម្មករ ដែលនៅទីបញ្ចប់ម្តងៗពួកយើងតែងទៅទទួលទានអាហារថ្ងៃត្រង់ទាំងអស់គ្នា ។ នៅពេលនោះ យើងចាប់ផ្តើមទទួលទានអាហារ តាំងពីថ្ងៃត្រង់រហូតដល់ម៉ោងបី ឬ បួនរសៀលទើបចប់ ។ គឺនៅពេលនោះហើយ ដែលយើងជជែកគ្នាលេងផង យើងនិយាយពីការងារផង ជាពិសេស ជាឱកាសឲ្យខ្ញុំបានស្គាល់នូវទឹកដៃនៃម្ហូបអាហារដ៏មានរសជាតិរបស់បារាំង រួមផ្សំនឹងស្រាដ៏ល្អៗ និង

ដ៏មានតម្លៃ ។ តាំងពីពេលនោះមក ខ្ញុំជាប់ចិត្តនឹងម្ហូបអាហារ និង ភេសជ្ជៈបារាំង យ៉ាងខ្លាំង ។

ទំនាក់ទំនងរវាងថៅកែធំជាមួយដៃគូរបស់គាត់ទាំងពីរនាក់នោះ មិនយូរប៉ុន្មានក៏មានការល្អក់កករវាងគ្នា ដោយហេតុថាថៅកែធំអាងលើអំណាចជាប្រធានក្រុមហ៊ុន ចាត់ការដោយអត្តនោម័តតែម្នាក់ឯង ។ អ្នកដៃគូទាំងពីរនាក់យល់ថាពួកគេជាអ្នកធ្វើការសំខាន់ៗ ដូចជាផ្នែកទំនាក់ទំនងសាធារណៈទាក់ទាញអតិថិជន ស្វែងរកទីផ្សារ និង ការងារបច្ចេកទេសទាំងអស់ ។ លោក កាមុស ដែលមានតំណែងជានាយកបច្ចេកទេស និង លោក ហ្វុងតែន ជានាយកនៃកិច្ចប្រតិបត្តិការ យល់ថា ពួកគេពុំសូវបានទទួលផលប្រយោជន៍ឲ្យសមស្របទៅតាមទំហំការងារបស់គេឡើយ ឯចំណែកថៅកែធំគឺ លោកម៉ុត្តុង គាត់ជាអ្នកកាន់មូលប្បទានប័ត្រអាចចាយវាយស្រេចតែចិត្ត ។

តាមពិតទៅ គ្រួសាររបស់លោក ម៉ុត្តុង មានចិត្តសប្បុរសល្អជាមួយខ្ញុំណាស់ ពួកគេតែងហៅរកខ្ញុំឲ្យចូលរួមបាយល្ងាចនៅផ្ទះរបស់គេនៅទីក្រុងសាកសែល ហើយបន្ទាប់មក នៅទីក្រុងព្យែរហ្វីត ។ នៅពេលមានបុណ្យទានសំខាន់ៗដូចជា បុណ្យខួបកំណើត បុណ្យណូអែល ឬ បុណ្យចូលឆ្នាំថ្មីជាដើម ពួកគេមិនដែលភ្លេចហៅខ្ញុំឡើយ ។ លោកស្រី ម៉ុត្តុង ចូលចិត្តនិយាយរឿងពីកូនស្រីគាត់ប្រាប់ខ្ញុំមិនដែលដាច់ ។ កូនស្រីនោះឈ្មោះនាង ប៉ាទ្រីស្យា មានអាយុ ១០ ឆ្នាំតិចជាងខ្ញុំ ។ នាងកំពុងរៀនវិជ្ជាផ្នែកគណនេយ្យដែរ ។ ជាញឹកញយ នៅពេលយើងទទួលទានការហ្វៅនៅតៀមការហ្វៅមីៗ លោកស្រី ម៉ុត្តុង តែងនិយាយពីសកម្មភាពរបស់ប៉ាទ្រីស្យាប្រាប់ខ្ញុំ មិនតែប៉ុណ្ណោះ លោកស្រីបានសុំឲ្យខ្ញុំជួយបង្រៀនគណនេយ្យ និង ធ្វើលំហាត់ឲ្យប៉ាទ្រីស្យាផង ។ ដូច្នេះ ជាញឹកញាប់ ប៉ាទ្រីស្យា តែងមកជួបខ្ញុំនៅកន្លែងធ្វើការ ។ នៅពេលខ្លះទៀត ខ្ញុំទៅជួយបង្រៀននាងដល់ផ្ទះ ។ នៅចុងសប្តាហ៍មួយនោះ ខ្ញុំ

បានបើករថយន្តជូន ប៉ាទ្រីស្យា ទៅលេងផ្ទះដីជូនដីតានាងនៅឯទីក្រុងសេដង់ (Sédan) ដែលនៅទល់ដែនជាប់ ប្រទេសបែលហ្សិក ។

ខ្ញុំចាំបានថា នៅពេលឈប់សំរាកនារដូវក្តៅមួយនោះ អ្នកស្រី ម៉ុត្តុង បានទូរស័ព្ទពីផ្ទះសំរាករបស់គាត់នៅទីក្រុងសាំងរ៉ាហ្វាអែល (Saint-Raphael) ដែលស្ថិតនៅភាគខាងត្បូងនៃប្រទេសបារាំងក្បែរទីក្រុងនីស (Nice) ដើម្បីឲ្យខ្ញុំទៅសំរាកវិស្សមកាលជាមួយពួកគាត់ ។ នៅថ្ងៃនោះ ក្រោយដែលគាត់និយាយរួច គាត់ហុចទូរស័ព្ទទៅឲ្យ ប៉ាទ្រីស្យា ដើម្បីនិយាយហៅខ្ញុំដោយផ្ទាល់មាត់ឲ្យទៅឈប់សំរាករួមគ្នា ។ នៅទីបំផុតខ្ញុំក៏យល់ព្រមតាមសំណើ ។ ខ្ញុំបើកបររថយន្តតែម្នាក់ឯងឆ្លងកាត់ផ្លូវប្រវែង ១០០០ គ.ម.។ ក្នុងដំណើរនេះ ខ្ញុំក៏ឆ្លៀតចូលទៅលេងលោកស្រី ម៉េឡាតូ ដែលធ្លាប់ធ្វើការជាមួយខ្ញុំ នៅក្នុងក្រុមហ៊ុនទេសចរណ៍ ហ្វារ៉ូសហ្វ្រង់ ព្រោះអ្នកស្រីចូលនិវត្ត ហើយបានមករស់នៅក្នុងតំបន់ឡាប្រ៉ូវ៉ង់ (La Provence) អស់រយៈពេលជាច្រើនឆ្នាំមកហើយ ។ ទំនាក់ទំនងរវាងខ្ញុំ និង គ្រួសារលោក ម៉ុត្តុង មានសភាពជិតស្និទ្ធពេក រហូតខ្ញុំហ៊ាននិយាយលេងជាមួយមិត្តភក្តីខ្មែរៗថា លោកស្រី ម៉ុត្តុង ជាម្តាយក្មេករបស់ខ្ញុំយ៉ាងដូច្នោះដែរ ។

ទោះបីជាខ្ញុំរៀនធ្លាក់នៅឆ្នាំ ១៩៧៤ ក៏ដោយ ក៏ខ្ញុំបានបន្តការសិក្សារបស់ខ្ញុំតទៅទៀតនៅវិទ្យាស្ថានជាតិបច្ចេកទេសសេដ្ឋកិច្ច និង គណនេយ្យ ។ នៅឆ្នាំ ១៩៧៦ ខ្ញុំបានប្រឡងជាប់ដោយជោគជ័យ ។ តាំងពីខ្ញុំបានចូលធ្វើការជាមួយក្រុមហ៊ុន ម៉ុត្តុង មកកំរិតជីវភាពរបស់ខ្ញុំ បានឡើងខ្ពស់ជាលំដាប់ ។ ឥឡូវនេះ ខ្ញុំជួលនារីជនជាតិបារាំងចំណាស់បន្តិចម្នាក់ មួយថ្ងៃពីរ ឬ បីម៉ោងឲ្យមកបោសសំអាតផ្ទះ និង បោកអ៊ុតខោអាវឲ្យខ្ញុំ ។ ជួនកាលនារីនោះ ចំអិនម្ហូបអាហារទុកឲ្យខ្ញុំផង ។ ជាទម្លាប់ប្រសិនបើខ្ញុំចូលដល់ក្នុងផ្ទះ ខ្ញុំឃើញមានការតុបតែងផ្ទះដោយផ្កាស្រស់ៗនោះ ខ្ញុំត្រូវដឹងថា នារីអ្នកបំរើនោះនឹងសុំឲ្យខ្ញុំតម្លើងប្រាក់ម៉ោងរបស់គាត់មិនខាន

ឡើយ ។ និយាយរួមមក ខ្ញុំមានការងារធ្វើក៏ល្អ មានប្រាក់ខែសមរម្យ ។ ខ្ញុំ រស់នៅក្នុងផ្ទះដែលមានសម្ភារៈគុទ្ធជារបស់ខ្ញុំ និង មានរថយន្តដ៏ថ្មីសន្លាងមួយ ដែលខ្ញុំបានបញ្ជាទិញពីរោងចក្រ ។ រថយន្តម៉ាក រ៉ឺណូ ៥ ឡឺ កា (Renault 5 le Car)នោះ មានវាយតួលេខរៀង ដែលកំណត់ឲ្យដឹងពីចំនួនរថយន្តផលិតចេញពីរោងចក្រផង ។ រថយន្តបែបនេះ គេមិនផលិតច្រើនទេគឺ តែមួយចំនួនតូចប៉ុណ្ណោះ ។

បើក្រឡេកមើលខ្លួនឯងដែលជាជនភៀសខ្លួនម្នាក់នោះ និង បើប្រៀបធៀបជាមួយជនរួមជាតិជាជនភៀសខ្លួនខ្មែរឯទៀតផង ខ្ញុំគិតថាខ្ញុំមានភ័ព្វសំណាង និង បុព្វសិទ្ធិជាងអ្នកទាំងនោះឆ្ងាយណាស់ ។ ក៏ប៉ុន្តែ នៅពេលខ្ញុំកាន់តែមានភាពធូរធារ និង ភាពសម្បូរសប្បាយខាងផ្លូវសម្ភារៈឡើងកាលណា កាលនោះខ្ញុំហាក់ដូចជាកាន់តែទទួលរងនូវសម្ពាធខាងផ្លូវសតិអារម្មណ៍មួយយ៉ាងខ្លាំងដែរ ។ គឺខ្ញុំកើតមានក្តីកង្វល់ក្នុងចិត្ត ចំពោះទុក្ខវេទនាដែលប្រជាពលរដ្ឋខ្មែរទាំងមូលកំពុងជួបប្រទះ នៅក្រោមរបប ប៉ុល ពត ។ ម្យ៉ាងទៀត ខ្ញុំមានអារម្មណ៍មិនស្រួលក្នុងចិត្តឥតឧបមា ព្រោះតែខ្ញុំជាប់ទំនាក់ទំនងជាមួយឪពុកម្តាយ បងប្អូនខ្ញុំ ដែលរស់នៅឯប្រទេសកម្ពុជាទាំងស្រុង ។ ខ្ញុំមានចិត្តចង់ចែករំលែកនូវភាពធូរធារសម្បូណ៌សប្បាយរបស់ខ្ញុំដល់មនុស្សជាទីស្រឡាញ់ទាំងឡាយរបស់ខ្ញុំទាំងនោះ ។ ទុក្ខលំបាកខាងផ្លូវចិត្តនោះកាន់តែមានទម្ងន់ធ្ងន់ឡើងៗ នៅពេលដែលប្រព័ន្ធផ្សព្វផ្សាយពិភពលោកបានចាប់ផ្តើមធ្វើឲ្យយើងកាន់តែដឹងច្បាស់ នូវអំពើសាហាវឃោរឃៅរបស់ខ្មែរក្រហមចំពោះប្រជាពលរដ្ឋខ្មែរ ។ នៅពេលដែលខ្ញុំកាន់តែចូលជ្រៅទៅៗក្នុងសង្គមរបស់បារាំងគឺ បន្ទាប់ពីបានធ្វើសមាហរណកម្មប្រកបដោយជោគជ័យ និង នៅពេលដែលខ្ញុំយល់ថា ខ្ញុំត្រូវបានទទួលការរាប់អានដោយស្មើមុខពីសំណាក់មិត្តភក្តិ ឬ អ្នកដែលនៅជុំវិញខ្ញុំ ជាពិសេស ពីជនជាតិបារាំងនោះ ខ្ញុំក៏កាន់តែត្រូវការឲ្យខ្ញុំខំការពារប្រភពដើមកំណើតឈាមជ័រខ្មែររបស់ខ្ញុំដែរ ។ ខ្ញុំគឺតថាខ្ញុំមិនអាចផ្តាច់

ឫសគល់របស់ខ្ញុំបាននោះទេ ។ ដូច្នេះ ដើម្បីឲ្យមានតុល្យភាពក្នុងជីវិត ជាពិសេសក្នុងផ្លូវសេតិអារម្មណ៍ ខ្ញុំបានសំរេចចិត្តថា ខ្ញុំត្រូវតែចាប់ផ្តើមធ្វើទំនាក់ទំនងជាមួយសហគមន៍ខ្មែរនៅប្រទេសបារាំងឡើងវិញ ។

វិលមកជួបសហគមន៍ខ្មែរវិញ

ចាប់តាំងពីពេលដែលខ្មែរក្រហមបានទទួលជ័យជំនះមក ខ្ញុំមិនដែលទាក់ទងជាមួយខ្មែរណាម្នាក់សោះក្រៅពីមិត្តកក្តីខ្មែរបី ឬ បួននាក់ ព្រោះខ្ញុំហាក់ដូចជាមានការជិនឆ្អន់ចំពោះអ្នកដឹកនាំខ្មែរសម័យនោះ ដែលធ្វើឲ្យកម្ពុជារលំរលាយ ។ ដើម្បីធ្វើឲ្យមានទំនាក់ទំនងជាមួយសហគមន៍ខ្មែរឡើងវិញ ខ្ញុំក៏ពឹងពាក់មិត្តកក្តិជិតស្និទ្ធដូចជា ផាន់ សូរិយាស៊ី និង ឃឹម ខាន់កែវ ដែលឥឡូវនេះប្រពន្ធគាត់ឈ្មោះ នាង សូនី បានក្លាយមកជាជំនួយការផ្ទាល់ម្នាក់របស់ខ្ញុំនៅឯក្រុមហ៊ុន តេប៉េប៉េ ។ មិនយូរប៉ុន្មាន ឃឹម ខាន់កែវ ក៏នាំឲ្យស្គាល់មិត្តកក្តិរបស់គេម្នាក់ឈ្មោះ អ៊ឹង យូតឹកលីន ។ អ៊ឹង យូតឹកលីន ក៏បានក្លាយជាមិត្តជិតស្និទ្ធដែលខ្ញុំតែងតែជួបជាញឹកញាប់មិនសូវខាន ។ នៅពេលដែលនាង សូនី លាឈប់ពីក្រុមហ៊ុន តេប៉េប៉េ ខ្ញុំក៏ជ្រើសរើសស្ត្រីខ្មែរម្នាក់ទៀតជាជំនួយការ ឈ្មោះអ្នកស្រី ឱម វឌ្ឍនា ដែលមិនគ្រាន់តែជាជំនួយការរបស់ខ្ញុំប៉ុណ្ណោះទេ តែក៏ជាមនុស្សដែលខ្ញុំទុកចិត្តអាច និយាយរឿងអាថ៌កំបាំង ឬ ការសម្ងាត់ជាមួយបាន។

ជីវិតជាអ្នកទីក្រុងប៉ារីសរបស់ខ្ញុំ បានគ្របដណ្តប់ដោយការតស៊ូគឺ ការតស៊ូដើម្បីឲ្យមានជីវភាពសមរម្យផង ដើម្បីធ្វើសមាហរណកម្មនៅក្នុងសង្គមលោកខាងលិចឲ្យបានជោគជ័យផង ដែលជាកត្តាមួយធំចម្បងក្នុងការជួយពង្រឹងបុគ្គលិក

លក្ខណៈរបស់ខ្ញុំ និង ពង្រឹងអត្តចរិតរបស់ខ្ញុំឲ្យក្លាយជាមនុស្សមានការទទួល ខុសត្រូវ និង ជាមនុស្សសេរីពិតប្រាកដផង ។ ម្យ៉ាងទៀត ជីវិតខ្ញុំសម័យនោះក៏បានទទួលរងនូវការគាបសង្កត់ពីព្រឹត្តិការណ៍ដ៏ខ្លោចផ្សាដែលកំពុងកើតមាននៅប្រទេសកម្ពុជា និង ដែលបានចងភ្ជាប់តួអង្គខ្ញុំ ទៅជាមួយវាសនាប្រជាជាតិ និង ប្រជាពលរដ្ឋកម្ពុជារបស់ខ្ញុំដែរ ។ ក្នុងហានៈជាកូនខ្មែរម្នាក់ ខ្ញុំពុំអាចរស់នៅយកសុខតែម្នាក់ឯង ដោយមិនឈឺឆ្អាល ឬ មិនញាប់ញ័រ ចំពោះអ្វីៗដែលកើតមាននៅប្រទេសខ្ញុំ ចំពោះមាតុភូមិខ្ញុំ និង ចំពោះប្រជារាស្ត្រខ្ញុំនោះឡើយ ។ ជាញឹកញាប់ ខ្ញុំតែងប្រឈមមុខចំពោះជំរើសពីរគឺ ទីមួយ តើខ្ញុំត្រូវបន្តរស់នៅយ៉ាងសង្ហារសមសួនសប្បាយរីករាយនៅក្នុងប្រទេសបារាំង ដោយរៀបការជាមួយនារីបារាំង និង បង្កបង្កើតជាក្រុមគ្រួសារនៅប្រទេសបារាំង ព្រមទាំងសុខចិត្តបំភ្លេចឈាមជ័រជាខ្មែរ ឬ ទីពីរ តើខ្ញុំសុខចិត្តធ្វើពលីកម្មនូវអ្វីៗទាំងអស់រួមទាំងអាយុជីវិត ដោយសុខចិត្តចូលរួមដៃជាមួយអ្នកស្នេហាជាតិខ្មែរ ធ្វើការស្តារ និង កសាងប្រជាជាតិខ្មែរឡើងវិញ ។ ប្រសិនបើខ្ញុំរៀបការជាមួយនារីបារាំង ខ្ញុំប្រហែលជានឹងឧទ្ទិស ឬ ចំណាយនូវថាមពលរបស់ខ្ញុំសំរាប់គ្រួសារបារាំងរបស់ខ្ញុំ ដោយបោះបង់ឬសគល់ និង ប្រកពដើមខ្មែរផង ។ បើខ្ញុំធ្វើយ៉ាងនេះ ខ្ញុំប្រហែលជាលាជាច់អាល័យពីកម្ពុជា ព្រោះបើខ្ញុំមានគ្រួសារ ខ្ញុំត្រូវទទួលខុសត្រូវទាំងស្រុងចំពោះគ្រួសារខ្ញុំ ដោយខ្ញុំមិនអាចបែកពីគ្រួសារនោះ និង មិនអាចទៅបំរើបុព្វហេតុខ្មែរណាមួយបានឡើយ ។ នៅទីបំផុត ខ្ញុំបានធ្វើការជ្រើសរើសមួយយ៉ាងច្បាស់លាស់ណាស់គឺ ខ្ញុំប្តេជ្ញាថែរក្សាអត្តសញ្ញាណរបស់ខ្ញុំ និង ផ្សារភ្ជាប់អនាគតរបស់ខ្ញុំជាមួយភ័ព្វព្រេងសំណាងរបស់កម្ពុជាទាំងមូល ។ ដោយសារការជ្រើសរើសយ៉ាងច្បាស់នេះហើយ ទើបខ្ញុំព្យាយាមពន្យល់មិត្តភក្តិបារាំងដែលមានការជិតស្និទ្ធជាមួយខ្ញុំទាំងឡាយឲ្យដឹងពីឆន្ទៈ និង សេចក្តីប្តេជ្ញាចិត្តរបស់ខ្ញុំថា ខ្ញុំត្រូវតែត្រឡប់ទៅកម្ពុជាវិញនៅថ្ងៃណាមួយមិនខាន ។ យ៉ាងនេះ

ហើយ ទើបខ្ញុំចាប់ផ្តើមចូលរួមធ្វើសកម្មភាពបំរើសង្គមជាគុណប្រយោជន៍ដល់សហគមន៍ខ្មែរនៅប្រទេសបារាំងជាមុនសិន ។

បន្ថែមលើការងារទទួលខុសត្រូវផ្នែកវិជ្ជាជីវៈរបស់ខ្ញុំ ខ្ញុំក៏ចំណាយពេលវេលាក្រៅម៉ោងធ្វើការស្ម័គ្រចិត្តបំរើសកម្មភាពសង្គមកិច្ច សម្រាប់សហគមន៍ខ្មែរនៅប្រទេសបារាំងជាបន្តរៀងមក ។ បើនិយាយឲ្យខ្លី ជីវិតជាអ្នកទីក្រុងប៉ារីសរបស់ខ្ញុំនោះ មិនមានសភាពហ៊ឺហាហ៊ឹកហ៊ាក់ ឬ មានលក្ខណៈជាអ្នកដើរលេងឡួយថ្ងូយដូចអ្នកខ្លះអាចគិតឃើញនោះឡើយ ។

វគ្គទី ៥
សម្រែកស្រែករកសេរីភាព
(ទសវត្សរ៍ឆ្នាំ ១៩៨០)

មួយឆ្នាំបន្ទាប់ពីដំយុដំនះរបស់ខ្មែរក្រហមមក សហគមន៍ខ្មែរនៅប្រទេសបារាំងបានឃើញសភាពការណ៍កាន់តែច្បាស់ឡើងនៅក្នុងប្រទេសកម្ពុជា ។ របបខ្មែរក្រហមបានក្លាយទៅជារបបផ្តាច់ការមួយ ដែលប្រព្រឹត្តអំពើសាហាវយង់ឃ្នង និង អមនុស្សធម៌ជាទីបំផុតនៅក្នុងពិភពលោក ដែលពួកនេះមិនអាចប្រកែកបានឡើយ ។ ជនភៀសខ្លួនខ្មែរទាំងឡាយ ដែលបន្តិចម្តងៗនាំគ្នារត់ចេញពីប្រទេសកម្ពុជាបាននាំមកជាមួយពីមួយថ្ងៃទៅមួយថ្ងៃនូវភ័ស្តុតាងយ៉ាងច្បាស់ក្រឡែតពីអំពើព្រៃផ្សៃនៃរបបខ្មែរក្រហមនោះ ។ ជនភៀសខ្លួនទាំងនោះ បានរៀបរាប់យ៉ាងលំអិតអំពីជីវភាពប្រចាំថ្ងៃដ៏លំបាកអស្ចារ្យ អំពីការបង្អត់អាហារ និង អំពីការកាប់សម្លាប់ទៅលើជនស្លូតត្រង់ ដែលពួកខ្មែរក្រហមបានធ្វើយ៉ាងយង់ឃ្នងបំផុត ។ ជនរួមជាតិខ្មែរដែលតាមដានសភាពការណ៍នៅកម្ពុជាយល់ច្បាស់ណាស់ថា គេពុំអាចសង្ឃឹមថា អ្នកដឹកនាំខ្មែរក្រហមអាចនឹងផ្តល់នូវសេរីភាព សិទ្ធិ និង សេចក្តីថ្លៃថ្នូររបស់មនុស្សជូនប្រជាពលរដ្ឋខ្មែរបានឡើយ ។ ជាពិសេស ជនរួមជាតិទាំងនោះមិននឹកសង្ឃឹមថា អ្នកដឹកនាំខ្មែរក្រហមអាចនឹងបើកចំហរប្រទេស ឲ្យមានទំនាក់ទំនងជាមួយពិភពលោកសោះឡើយ ។ ជាប្រពៃណីរៀងមក ជនរួមជាតិខ្មែរដែលជាពុទ្ធសាសនិកជនតែងរត់ទៅជ្រកក្រោមម្លប់ព្រះពុទ្ធសាសនា នៅពេលដែលជួបប្រទះទុក្ខព្រួយណាមួយ ដោយចិញ្ចឹមកូនចិត្តថាពេលវេលាធូរស្រាលក្នុងជីវិត និង អនាគតភ្លឺស្វាងអាចនឹងកើតមកវិញ នៅថ្ងៃណាមួយមិនខាន។ នៅប្រទេសបារាំង បងប្អូនជន

រួមជាតិទាំងនោះនាំគ្នាទៅវត្តអារាម ដើម្បីបង្កើតឡើងវិញនូវប្រព័ន្ធទំនាក់ទំនងគ្នា ផ្នែកសង្គមនៅគ្រាដំបូង និង ជាប្រព័ន្ធទំនាក់ទំនងផ្នែកនយោបាយនៅគ្រាបន្ទាប់ ។ ដោយសារការគ្រប់គ្រងប្រទេសដ៏ចម្លែករបស់ពួកខ្មែរក្រហម ខ្មែរនៅប្រទេសបារាំង គ្រប់ជាន់ថ្នាក់ក៏ដូចជាប្រជាពលរដ្ឋខ្មែរភាគច្រើននៅឯប្រទេសកម្ពុជាដែរ បានបាត់បង់នូវអ្វីៗទាំងអស់ ជាពិសេសគឺ ការបាត់បង់ទឹកដី ធ្វើឲ្យពួកគេក្លាយជាមនុស្ស ឬ ក្រុមអ្នកអត់ស្រុក ឬ អ្នកអត់នគរ ។

ជាតិជាជនកៀសខ្លួន គ្មានអ្នកតូច គ្មានអ្នកធំ

មន្ត្រីជាន់ខ្ពស់រាប់តាំងពីរដ្ឋមន្ត្រី អ្នកការទូត ឧត្តមសេនីយ នាយទាហាន ឬ ក៏អ្នកធ្វើការធម្មតា ឬ កូនទាហាន សុទ្ធតែធ្លាក់ខ្លួនទៅជាជនកៀសខ្លួន ដែលមានសិទ្ធិប្រហាក់ប្រហែលៗគ្នា ។ នៅប្រទេសបារាំង មនុស្សជាទូទៅមានអារម្មណ៍ថាពួកគេស្ថិតនៅក្នុងសភាពការណ៍ដូចៗគ្នា មានសិទ្ធិស្មើៗគ្នា ដែលគ្មានអ្នកតូច អ្នកធំ អ្នកខ្ពស់ អ្នកទាប ដូចសម័យមុនឡើយ ។

ដើម្បីផ្តល់ទស្សនៈរបស់ខ្លួនលើអនាគតប្រទេសកម្ពុជា ឬ ដើម្បីបញ្ចេញមតិស្តីពីការកសាងជាតិឡើងវិញ អ្នកនយោបាយជើងចាស់មួយចំនួនយកវេទិកានៃពិធីបុណ្យសាសនាជាដើម ដើម្បីសំដែងមតិទាំងនោះ ឲ្យសាធារណជនបានដឹងឮ ។ ក្នុងចំណោមអ្នកនយោបាយជើងចាស់ទាំងនោះ មានលោកតា សឺន សាន ដែលជាអតីតរដ្ឋមន្ត្រីទីមួយរបស់សម្តេច សីហនុ ក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ ដែលបានសាកល្បងដោយបរាជ័យក្នុងការធ្វើជាមេអណ្តើកផ្សះផ្សាគ្នា ស្វែងរកដំណោះស្រាយវិបត្តិកម្ពុជាដោយសន្តិវិធីនៅទសវត្សរ៍ឆ្នាំ ១៩៧០ ។ ពេលមួយនោះ លោកតា សឺន សាន បានចូលរួមក្នុងពិធីបុណ្យព្រះពុទ្ធសាសនាមួយ ។ គាត់និយាយថារបបខ្មែរ

ក្រហមជារបបមួយ ដែលនឹងដើរទៅដល់ជញ្ជាំង ហើយលោកតាអំពាវនាវឲ្យសហគមន៍ខ្មែរនៅប្រទេសបារាំងត្រៀមខ្លួនទៅបន្តវេន នៅពេលដែលខ្មែរក្រហមដួលរលំនៅថ្ងៃណាមួយពុំខាន ។ ពាក្យថា ខ្មែរក្រហមដើរទៅដល់ជញ្ជាំង ក៏ចូលទៅក្នុងខួរក្បាលខ្មែរមួយចំនួនធំ ។ ក៏ប៉ុន្តែអ្នកនយោបាយមួយចំនួន និយាយផ្ទួញឲ្យលោកតា សឺន សាន ថាខ្មែរក្រហមមិនគ្រាន់តែដល់ជញ្ជាំងទេ តែវានឹងបុកទម្លាយជញ្ជាំងនោះ ។

នៅសម័យនោះ ខ្ញុំហាក់ដូចជាមិនសូវអើពើនឹងបុណ្យទានខាងផ្នែកព្រះពុទ្ធសាសនាប៉ុន្មានឡើយ ។ ក៏ប៉ុន្តែ ឃឹម ខាន់កែវ និង តឹកលីន ច្រើនតែនិយាយឲ្យខ្ញុំដឹងនូវអ្វីៗដែលកើតឡើង ឬ ព្រឹត្តិការណ៍សង្គមទាំងឡាយ ដែលសហគមន៍ខ្មែរនៅប្រទេសបារាំងបានចាត់ចែងឡើង ។ ពួកគេបាននិយាយប្រាប់ខ្ញុំអំពីទស្សនៈលោកតា សឺន សាន ក្នុងការថែរក្សាការពារនូវអត្តសញ្ញាណខ្មែរ និង អំពីការកសាងប្រទេសកម្ពុជាឡើងវិញ ។ ខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះទស្សនៈជាតិនិយម និង ការកសាងប្រទេស និង សង្គមជាតិឡើងវិញណាស់ ។ យ៉ាងណាក៏ដោយ ខ្ញុំហាក់ដូចជាចង់ដឹងថា តើខ្មែរយើងដែលរស់នៅក្រៅប្រទេស អាចធ្វើសកម្មភាពអ្វីបានខ្លះ ដើម្បីធ្វើឲ្យប្រទេសកម្ពុជាយើងវិលត្រឡប់មករកមាគ៌ាដ៏ត្រឹមត្រូវវិញ ។

ហេតុដូច្នេះ ទើបខ្ញុំស្នើឲ្យ ឃឹម ខាន់កែវ និង តឹកលីន នាំខ្ញុំទៅជួបលោកតា សឺន សាន ភ្លាមៗដោយពុំមានគ្រោងទុកជាមុន ។ ថ្ងៃមួយនោះ យើងនាំគ្នាទៅផ្ទះលោកតា សឺន សាន នៅផ្ទះលេខ ៤៥ ស្ងួន ផ្លូវអាកាស្យា ក្នុងសង្កាត់ ១៧ ទីក្រុងប៉ារីស ដែលជាសង្កាត់អភិជនមួយប្រកបដោយសណ្តាប់ធ្នាប់ហើយក៏មិននៅឆ្ងាយពីវិមាន ហ្សាល ដឺ ហ្គោល ដែរ ។ យើងគោះទ្វារផ្ទះ និង សាកសួរចង់ជួបលោកតា សឺន សាន ក៏ប៉ុន្តែមានសម្លេងមួយឆ្លើយពីក្នុងផ្ទះមកថា "លោកមិននៅទេ" ។ នៅពេលនោះ ខ្ញុំដូចជាចង់ជួបលោកតាមែនទែន ។ ក៏ប៉ុន្តែ ខ្ញុំមិនអាចទៅជួបលោក

តាបានស្រួលៗយ៉ាងដូច្នេះទេ ព្រោះគាត់ជាមនុស្សសំខាន់ ជាអ្នកធំម្នាក់ ។ តាម ធម្មតា យើងត្រូវទូរស័ព្ទទៅមុន ដើម្បីសុំណាត់ជួប ។

សឺន សាន ជានរណា?

លោកតា សឺន សាន មានដើមកំណើតចេញពីគ្រួសារខ្មែរដើចំណាស់មួយ នៅកម្ពុជាក្រោម (ខ្មែរនៅកូសាំងស៊ីនផ្នែកខាងត្បូងនៃប្រទេសវៀតណាម) ។ តាម ជីវប្រវត្តិផ្លូវការ លោកតា សឺន សាន កើតថ្ងៃទី ០៥ តុលា ១៩១១ នៅទីក្រុង ភ្នំពេញមិនមែននៅកម្ពុជាក្រោមដូចអ្នកខ្លះជឿនោះទេ ។ លោកតា និយាយភាសា ខ្មែរ ដោយមិនមានសំនៀងខ្មែរកម្ពុជាក្រោមទេ តែមានសំនៀងដូចជនជាតិវៀត ណាមនិយាយខ្មែរ ពីព្រោះតាំងពីតូច លោកតារស់នៅជាមួយមេដោះជនជាតិវៀត ណាម[52] ។ លោកឪពុករបស់លោកតាគឺ លោកឧកញ៉ា សឺន សាច់ ដែលបាន ចេញពីកម្ពុជាក្រោមមកទីក្រុងភ្នំពេញ ដើម្បីបន្តការសិក្សាក្រោមការឧបត្ថម្ភ របស់ ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សុជានុវង្ស ។ ក្រោយមកឧកញ៉ា សឺន សាច់ បានទៅធ្វើការ ផ្ទាល់ជាមួយព្រះអង្គម្ចាស់ នរោត្តម សុរាម្រឹត កាលព្រះអង្គមិនទាន់ឡើងគ្រងរាជ្យ នៅឡើយ ហើយដែលកាលនោះទ្រង់កាន់តំណែងជារដ្ឋមន្ត្រីក្រសួងកសិកម្ម ។ ព្រះ ករុណាព្រះបាទ នរោត្តម សុរាម្រឹត ជាព្រះវររាជបិតានៃ សម្តេច សីហនុ ។ គ្រួសារ ត្រកូល សឺន ជាគ្រួសារមួយដែលខ្មែរកម្ពុជាក្រោមភាគច្រើនស្គាល់ស្ទើរទាំងអស់ ព្រោះជាត្រកូលល្បីល្បាញមួយ ដែលចេញពីបុព្វបុរសម្នាក់ឈ្មោះចៅហ្វាយ គុយ ។

[52] នេះជារឿងដំណាលប្រាប់ខ្ញុំ ដោយស្ត្រីជំនឹតម្នាក់របស់លោកតា សឺន សាន កាលពួកយើងនៅជួបជុំគ្នា ចុងទសវត្សរ៍ឆ្នាំ ១៩៧០ នៅប្រទេសបារាំង ។

លោកចៅហ្វាយ គុយ ជាចៅហ្វាយស្រុកព្រះត្រពាំង បានសុខចិត្តបូជាជីវិតប្តូរនឹងការថែរក្សានូវព្រះពុទ្ធសាសនាថេរវាទសំរាប់ជនរួមជាតិខ្មែរកម្ពុជាក្រោម ។

កាលនៅពីក្មេងលោក សឺន សាន ជាយុវជនខ្មែរមួយរូប ដែលបានប្រឡងជាប់សញ្ញាប័ត្រពីសាលាដ៏ល្បីល្បាញរបស់បារាំងមួយឈ្មោះថា សាលាជាន់ខ្ពស់ខាងពាណិជ្ជកម្ម (H.E.C: Hautes Etudes Commerciales)ក្នុងឆ្នាំ ១៩៣៣ ។ នៅឆ្នាំ ១៩៣៤ ពេលត្រឡប់មកពី ប្រទេសបារាំងវិញ លោក សឺន សាន ត្រូវបានទទួលតំណែងជាអភិបាលរងខេត្តបាត់ដំបង[53] ។ ពីឆ្នាំ ១៩៣៧ ដល់ឆ្នាំ ១៩៣៩ គាត់បានផ្លាស់ទៅធ្វើជាអភិបាលរងខេត្តព្រៃវែង ដែលជាខេត្តកំណើតរបស់ខ្ញុំ ។ ដោយគាត់មានបំណងចង់ប្រើប្រាស់នូវចំណេះវិជ្ជា ដែលគាត់រៀនខាងផ្នែកពាណិជ្ជកម្ម លោក សឺន សាន បានលាឈប់ពីរាជការ មកធ្វើការក្នុងក្រុមហ៊ុនរបស់ឪពុកក្មេកក្នុងក្រុមហ៊ុន ឡឺ ប៊ឺទី ប៉ារីស (Le Petit Paris) ។ ក្នុងឆ្នាំ ១៩៤០ នៅពេលដែលជប៉ុនចរចាជាមួយបារាំង ដើម្បីទិញអង្ករខ្មែរ អាជ្ញាធរបារាំងក៏បានចាត់តាំងលោកឲ្យចូលរួមក្នុងគណៈប្រតិភូបារាំងទៅកាន់ទីក្រុងតូក្យូ ។

នៅឆ្នាំ ១៩៤៦ ក្រោមការដឹកនាំរបស់ព្រះអង្គម្ចាស់ យុត្តិវង្ស រដ្ឋាភិបាលរបស់គណបក្សប្រជាធិបតេយ្យក៏បានត្រូវបង្កើតឡើង ឯលោក សឺន សាន ក៏ត្រូវបានតែងតាំងជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ ។ ចាប់តាំងពីឆ្នាំ ១៩៤៦ រហូតដល់ឆ្នាំ ១៩៦៨ លោកកាន់តំណែងជារដ្ឋមន្ត្រីជាច្រើនលើកច្រើនគ្រា ជាពិសេសកាន់តំណែងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាឧបនាយករដ្ឋមន្ត្រី ជារដ្ឋមន្ត្រីក្រសួងការបរទេស និង ជារដ្ឋមន្ត្រីទី១ ។

[53] កាលសម័យនោះ គេហៅអភិបាលរងខែត្រថា កូឈួយខែត្រ ។

នៅក្នុងដំនាន់សភាជាតិ ចេញពីគណបក្សប្រជាធិបតេយ្យពីឆ្នាំ ១៩៥១ ដល់ ១៩៥២ លោកត្រូវជាប់ឆ្នោត ជាអ្នកតំណាងរាស្ត្រមណ្ឌលភ្នំពេញ និង ជាប្រធានរដ្ឋសភា ។ លោក សឺន សាន ជាអ្នកបង្កើតធនាគារជាតិកម្ពុជានៅឆ្នាំ ១៩៥៥ និង កាន់តំណែងជាទេសាភិបាលនៃធនាគារនេះរហូតដល់ឆ្នាំ ១៩៦៨ ។ លោក សឺន សាន ជាមនុស្សជិតជិតម្នាក់ដ៏កម្រ និង ជាទីប្រឹក្សាដ៏ទុកចិត្តម្នាក់ខាងផ្នែកសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរបស់សម្តេច សីហនុ ក្នុងសម័យសង្គមរាស្ត្រនិយម ។ មនុស្សទុកចិត្តម្នាក់ទៀតគឺ សម្តេច ប៉ែន នុត ដែលបានរួមដង្ហែរសម្តេច សីហនុ ក្នុងពេលកៀសព្រះអង្គទៅរស់នៅក្នុងប្រទេសចិន និង បន្ទាប់មកដង្ហែព្រះអង្គមករស់នៅប្រទេសកម្ពុជា ក្រោមរបបខ្មែរក្រហមទៀតផង ។

លោកតា សឺន សាន ជាអ្នកកាន់ព្រះពុទ្ធសាសនា ។ កូនចៅលោកតានិយាយថា លោកតាចាប់ថ្វាយបង្គំព្រះយ៉ាងទៀងទាត់ តាំងពីពេលដែលកូនប្រុសច្បងរបស់គាត់បានស្លាប់ ក្នុងគ្រោះថ្នាក់ចរាចរណ៍មួយក្នុងប្រទេសកម្ពុជា និង តាំងពីពេលដែលលោកលាលែងពីតំណែងរាជការក្នុងឆ្នាំ ១៩៦៨ ។ នៅក្នុងប្រទេសបារាំងសម័យទស្សវត្សរ៍ឆ្នាំ ១៩៧០ នោះ មនុស្សជាច្រើននិយាយថាលោកតាថ្វាយបង្គំព្រះ មួយថ្ងៃពីរដង ហើយគាត់រៀចាកមិនពិសាស្រាទេ ទោះបីជាគាត់ផ្លាប់ពិសាស្រាល្អៗយ៉ាងណាក៏ដោយ ។ នៅសម័យនោះ ទោះបីជានៅប្រទេសបារាំងក៏ដោយ ក៏លោកតា សឺន សាន នៅមានការគោរពរាប់អានពីជនរួមជាតិខ្មែរមួយភាគដៃរ ដែលធ្លាប់ធ្វើជាមន្ត្រីរាជការ ។ នៅខែ មិថុនា ១៩៧៦ លោកតា សឺន សាន បានបង្កើតសមាគមមួយដែលមានឈ្មោះហៅថា សមាគមទូទៅខ្មែរនៅបរទេស ហៅកាត់ថា អា ហ្សេ កា អឺ (AGKE: Association Générale des Khmers à l'Etranger) ។

សមាគមទូទៅខ្មែរនៅបរទេស

លក្ខន្តិកៈនៃសមាគមបានគូសបញ្ជាក់នូវគោលបំណងដូចតទៅ៖ "ថែរក្សាព្រះពុទ្ធសាសនា វប្បធម៌ និង អារ្យធម៌ខ្មែរ គាំទ្រពង្រឹងឯកភាពជាតិ និង ភាតរភាពរវាងខ្មែរទាំងអស់ និង ផ្តល់នូវការជួយសង្គ្រោះគ្នា ទាំងខាងស្មារតី ទាំងផ្លូវចិត្ត ទាំងផ្លូវកាយ និង ផ្លូវសម្ភារៈ" ។ ក្នុងចំណោមស្ថាបនិករបស់សមាគមទាំងអស់ ខ្ញុំសង្កេតឃើញមានឥស្សរជនជាច្រើន ដែលខ្លះធ្លាប់កាន់តំណែងជានាយករដ្ឋមន្ត្រី ជារដ្ឋមន្ត្រី ឬ មន្ត្រីជាន់ខ្ពស់នៃរបប សីហនុ និង របប លន់ នល់ ដូចជា៖ ឯ.ឧ. ទេព ផន ឯ.ឧ. ស៊ឹម វ៉ា ឯ.ឧ. នង គីមនី ឯ.ឧ. យ៉ែម សំបូរ ឯ.ឧ. ចាយ ធុល ឯ.ឧ. អ៊ិន តាំ ឯ.ឧ. សុន វ៊ឺនសៃ ឯ.ឧ. ប៉ុន អ៊ុក ឯ.ឧ. សុខ ឆុង ឯ.ឧ. គន់ វិច ឧត្តមសេនីយ គង់ ធុច ឧត្តមសេនីយ ស្រី សាម៉ន លោក ជួន អ៊ិន លោក កែ ណុល លោក នេត្រ គួន លោក សាយ បូរី លោក សាយ បូរាណ លោក នាង ផង់ លោក ទ្រឿង មាលី វេជ្ជ. សិប ហៀង អ្នកស្រី ថែន ជឿន អ្នកស្រី សួនកាសេត ។ល។ សមាជិកភាពនេះ ធ្វើឲ្យមានការចាប់អារម្មណ៍ណាស់ ដែលហាក់បង្ហាញឲ្យឃើញថា សមាគមនេះបានប្រមូលផ្តុំនូវមន្ត្រីជាន់ខ្ពស់ អ្នកនយោបាយ និង បញ្ញវន្តមិនមែនកុម្មុយនីស្តមួយចំនួនធំ ។ ក្នុងសម័យនោះ សមាគម អា ហ្សេ កា អឺ ជាសមាគមខ្មែរតែមួយគត់ ដែលមានលក្ខណៈគួរឲ្យទុកចិត្តបាននៅក្នុងប្រទេសបារាំង ហើយដែលបានធ្វើឲ្យមានការចូលរួមពីសំណាក់ខ្មែរអ្នកជាតិនិយមទាំងអស់ រាប់តាំងពីអ្នករាជានិយម អ្នកប្រជាធិបតេយ្យ រហូតដល់អ្នកស្រឡាញ់ សាធារណរដ្ឋផង ។ ដោយពុំទាន់មានវត្តមានរបស់សម្តេច សីហនុ លោកតា សឺន សាន បានត្រូវគេមើលឃើញថា ជាឥស្សរជនដ៏កម្រមួយរូបនៅក្រៅប្រទេស ដែលអាចប្រមូលការគាំទ្រពីប្រជាពលរដ្ឋខ្មែរបាន ។

ខ្មែរក្រហមប្រមូលយកជ័យជំនះ ១៧ មេសា តែម្នាក់ឯង

បន្ទាប់ពីជោគជ័យរបស់គេនៅខែ មេសា ១៩៧៥ ពួកខ្មែរក្រហមមិនបានប្រញាប់ប្រញាល់យាង សម្តេច សីហនុ និង អញ្ជើញសម្តេច ប៉ែន នុត ដែលជាព្រះប្រមុខរដ្ឋ និង ជានាយករដ្ឋមន្ត្រីរបស់ពួកគេ ឲ្យនិវត្តចូលប្រទេសកម្ពុជាភ្លាមនោះឡើយ ។ ពួកខ្មែរក្រហមរង់ចាំរហូតដល់ពេលអ្នកដឹកនាំរបស់ពួកគេម្នាក់គឺ លោក ខៀវ សំផន មកធ្វើទស្សនកិច្ចនៅប្រទេសចិនក្នុងខែ សីហា ១៩៧៥ ទើបគេយល់ព្រមឲ្យសម្តេចយាងនិវត្តទៅកម្ពុជាវិញ ។ យោងតាមសេចក្តីថ្លែងការណ៍ផ្លូវការចុះថ្ងៃទី ១៨ សីហា ១៩៧៥ លោក ខៀវ សំផន បានជួបជាមួយមេដឹកនាំចិនគឺ លោក តេង ស៊ាវពីង និង លោក ហួរ គួហ្វេង ។

គណៈប្រតិភូរបស់ខ្មែរក្រហមកាលនោះមានជាអាទិ៍ លោក អៀង សារី ឧបនាយករដ្ឋមន្ត្រី លោក សារិន ឆាក រដ្ឋមន្ត្រីក្រសួងការបរទេស ភរិយាលោក អៀង សារី គឺ អ្នកស្រី អៀង ជិរិទ្ធ រដ្ឋមន្ត្រីក្រសួង សង្គមកិច្ច លោក គាត ឈន់[54] និង លោក ជួន ប្រសិទ្ធ សមាជិកបំរុងនៃការិយាល័យនយោបាយរបស់គណៈកម្មាធិការកណ្តាលរណសិរ្សរួបរួមជាតិកម្ពុជា ។ ខ្ញុំជឿថាប្រហែលជាដោយមានអនុសាសន៍ពី លោក តេង ស៊ាវពីង ទើបនៅទីបំផុត ពួកខ្មែរក្រហមយល់ព្រមកំណត់ថ្ងៃ ខែ ពេល វេលា ដើម្បីសម្តេច សីហនុ និង សម្តេច ប៉ែន នុត យាង និង អញ្ជើញទៅប្រទេសកម្ពុជាវិញ ។ ពួកគេបានកំណត់យកថ្ងៃទី ៩ ខែ កញ្ញា ១៩៧៥ ជាថ្ងៃយាង និង អញ្ជើញនិវត្តនៃសម្តេចទាំងពីរ ទោះបីជាសមាជពិសេសរបស់ពួកគេដែលបានរៀបចំឡើង បន្ទាប់ពីជ័យជំនះនៅទីក្រុងភ្នំពេញ នៅថ្ងៃទី ២៥-២៦-២៧ មេសា

[54] នេះជាការលើកឡើងតាមបណ្តាញសារព័ត៌មានអន្តរជាតិដែលខ្ញុំបានអានប៉ុណ្ណោះ ជាពិសេសទីភ្នាក់ងារចិនថ្មី ឬ ស៊ីនហួ

១៩៧៥ បានទទួលស្គាល់ជាឯកច្ឆ័ន្ទថា "សម្តេច សីហនុ ជាព្រះប្រមុខរដ្ឋ និង ជាប្រធានរណសិរ្សរួមរួបជាតិកម្ពុជា ជាឥស្សរជនស្នេហាជាតិដ៏ឧត្តុង្គឧត្តមម្នាក់ ដែលបានរួមចំណែកធ្វើឲ្យបដិវត្តន៍របស់ពួកគេទទួលជោគជ័យ ក្នុងការតស៊ូរំដោះប្រទេសកម្ពុជាទាំងមូល" ។

សម្តេច សីហនុ យាងទៅទីក្រុងញូវយ៉ក

នៅខែ កញ្ញា ១៩៧៥ ក្រោយដែលបានស្នាក់នៅមួយសប្តាហ៍ក្នុងប្រទេសកម្ពុជា សម្តេច សីហនុ ត្រូវបានអង្គការចាត់តាំងឲ្យយាងទៅទីក្រុងញីវយ៉ក (New York) ដើម្បីថ្លែងសុន្ទរកថានៅក្នុងអង្គការសហប្រជាជាតិក្នុងឋានៈព្រះអង្គជាព្រះប្រមុខរដ្ឋ ។ ក្នុងដំណើរយាងទៅអង្គការសហប្រជាជាតិនោះ សម្តេចត្រូវបានអមដំណើរដោយមន្ត្រីខ្មែរក្រហម និង បានយាងឆ្លងកាត់ប្រទេសបារាំង ។ នៅក្នុងប្រទេសបារាំងនោះ អ្នកយកព័ត៌មាននៃទូរទស្សន៍បារាំង បានធ្វើសម្ភាសន៍ជាមួយព្រះអង្គ ដើម្បីចង់ដឹងអំពីជីវភាពជាក់ស្តែងពិតប្រាកដនៃរបបខ្មែរក្រហមនៅក្នុងប្រទេសកម្ពុជា ។ កាលនោះ សម្តេចនៅការពាររបបខ្មែរក្រហមនៅឡើយ ដោយទ្រង់ពិពណ៌នាជីវភាពនៅទីក្រុងភ្នំពេញថា មានសន្តិភាពបរិបូណ៌ មានការរៀបចំល្អ មានសន្តិសុខពិតប្រាកដ ។ល។ សម្តេចមានបន្ទូលថា មុខងារព្រះអង្គជាប្រមុខរដ្ឋគឺ គ្រាន់បើជាងសម្តេចមហាក្សត្រីយានី អេលី ហ្សាប៊ែតទី ២ (Elisabeth II) នៃប្រទេសអង់គ្លេសបន្តិច ដោយហេតុថាព្រះអង្គអាចយាងបំពេញបេសកកម្មក្រៅប្រទេស ដូចជាឯកអគ្គរាជទូតគោចរមួយនៃប្រទេសកម្ពុជានៅក្នុងពិភពលោក ។ កាលនោះ ដោយទន្ទឹងរង់ចាំដំណឹងពីប្រទេសកម្ពុជាជាយូរមកហើយ ខ្ញុំបានត្រៀមរៀបចំកាមេរ៉ាភាព

យន្ត ១៦ មម ថតសេចក្តីសម្ភាសន៍របស់សម្តេច ពីទូរទស្សន៍បារាំង អង់តែន ២ ព្រោះនៅសម័យនោះ យើងពុំទាន់មានម៉ាស៊ីនថត វីស៊ីអែរ (VCR) នៅឡើយទេ ។

ក៏ប៉ុន្តែ នៅខែ តុលា ១៩៧៥ កាសែតរបស់បារាំងឈ្មោះ ឡឺហ្វីហ្គារ៉ូ (Le Figaro) និង ឡាគ្រ័រ (La Croix) បានចុះផ្សាយអត្ថបទពីរគឺ៖ មួយចុះថ្ងៃទី ១៥ ខែ តុលា ដែលសរសេរដោយលោក ហ្សង់ប៊ូដារីយ៉ា (Jean Boudaria) និង មួយទៀតចុះថ្ងៃទី ២៤ ដែលសរសេរដោយបុព្វជិតកាតូលីក ហ្វ្រង់ស័រ ប៉ុងសូ (François Ponchaud) ដែលធ្លាប់រស់នៅប្រទេសកម្ពុជាយ៉ាងយូរ ហើយក៏ជាអ្នកឯកទេសខាងបញ្ហាខ្មែរផងដែរ ។ អត្ថបទទាំងពីរបានរៀបរាប់អំពីការបំផ្លិចបំផ្លាញប្រទេសខ្មែរ ការកាប់សម្លាប់ និង ការបង្ខំឲ្យធ្វើការជាទម្ងន់ ដែលពួកខ្មែរក្រហមប្រព្រឹត្តមកលើប្រជាពលរដ្ឋខ្មែរ ។ ព័ត៌មានទាំងនោះ បានធ្វើឲ្យពិភពលោកទាំងមូលមានការភ្ញាក់ផ្អើលរំជើបរំជួលកាន់តែខ្លាំង ជាពិសេស សហគមន៍ខ្មែរនៅបរទេស ។ នៅខែ តុលា ១៩៧៥ មានការវាយតម្លៃថាមានជនភៀសខ្លួនចំនួនបួនម៉ឺននាក់បានមកដល់ប្រទេសថៃ ។

ព្រះអង្គសុំលាលែងពីតំណែងប្រមុខរដ្ឋនៃរបបខ្មែរក្រហម

បន្ទាប់ពីដំណើរយាងទៅអង្គការសហប្រជាជាតិ សម្តេច សីហនុ ក៏យាងត្រឡប់ទៅភ្នំពេញយ៉ាងស្ងៀមស្ងាត់ ។ តាំងពីពេលនោះមក ពិភពលោកក៏លែងទទួលដំណឹងអ្វីសោះពីព្រះអង្គរហូតដល់ខែ មេសា ១៩៧៦ ។ ពេលនោះ សម្តេចទ្រង់បានផ្សព្វផ្សាយតាមវិទ្យុជាតិនូវការសុំលាលែងរបស់ព្រះអង្គ ពីតំណែងប្រមុខរដ្ឋនៃរបបខ្មែរក្រហម ។ នៅឆ្នាំនោះគឺ ឆ្នាំ ១៩៧៦ ពួកខ្មែរក្រហមបានជ្រើសរើស

រដ្ឋធម្មនុញ្ញថ្មី ដោយប្តូរឈ្មោះប្រទេសកម្ពុជាទៅជា "កម្ពុជាប្រជាធិបតេយ្យ" ដោយមានលោក ប៉ុល ពត ជានាយករដ្ឋមន្ត្រី ។ លោក ខៀវ សំផន ត្រូវបានជ្រើសរើសជាប្រធានរដ្ឋ (Président du Présidium) គឺប្រមុខរដ្ឋជំនួសសម្តេច សីហនុ ។ ពួកខ្មែរក្រហមសន្យាថា នឹងថ្វាយប្រាក់សោធនចំនួន ៨០០០ ដុល្លារ ក្នុងមួយឆ្នាំ ចំពោះព្រះអង្គ ក៏ប៉ុន្តែតាមពិតពួកខ្មែរក្រហមពុំបានចំណាយប្រាក់មួយដុល្លារណាតាមពាក្យសន្យានោះឡើយ ។ តាមព័ត៌មាន ដែលលេចចេញពីលោកខាងលិចថា ប៉ុន្មានអាទិត្យមុននឹងព្រះអង្គលាឈប់ពីតំណែងប្រមុខរដ្ឋ សម្តេច សីហនុ បានទទួលលោកឯកអគ្គរាជទូតនៃប្រទេសស៊ុយអែត ដែលបានរៀបរាប់អំពីជំនួបនោះនៅក្នុងបណ្តាញសារព័ត៌មានអន្តរជាតិ[55] ។ ចាប់ពីពេលនោះរហូតមក ពួកយើងនៅខាងក្រៅកម្រនឹងបានទទួលព័ត៌មានអំពីព្រះអង្គ ឬ ពីសហការីរបស់ព្រះអង្គណាស់ ដោយនៅពេលនោះ ពួកខ្មែរក្រហមកំពុងអនុវត្តនយោបាយប្រល័យពូជសាសន៍យ៉ាងពេញទំហឹង ។ ពិភពលោកត្រូវរង់ចាំរហូតដល់ខែ មករា ១៩៧៩ ទើបឃើញ សម្តេច សីហនុ លេចចេញឆ្លោះឡើងវិញ ដើរតួនាទីដ៏សំខាន់នៅក្នុងឆាកនយោបាយខ្មែរជាថ្មីម្តងទៀត ។

សកម្មភាពរបស់សមាគម អា ហ្សេ កា អឺ

សកម្មភាពរបស់សមាគម អា ហ្សេ កា អឺ មានតាំងពីផ្នែកសង្គមកិច្ច សាសនា វប្បធម៌ រហូតដល់សកម្មភាពនយោបាយ ។ ក្នុងចំណោមការផ្តួចផ្តើមគំនិតទីមួយរបស់សមាគម មានការធ្វើក្នុងទំនាក់ទំនងអន្តរជាតិ ដូចជាបានធ្វើពាក្យបណ្តឹងចុះថ្ងៃទី ២៧ កញ្ញា ១៩៧៦ ផ្ញើជូនលោកអគ្គលេខាធិការអង្គការសហប្រជា

[55] A Correspondent, Waging War on the Land, Far Eastern Economic Review, March 26, 1976, pp. 24-25.

ជាតិដើម្បីសុំមានឲ្យការស៊ើបអង្កេតពីករណីរំលោភសិទ្ធិមនុស្សនៅកម្ពុជា ។ អគ្គលេខាធិការអង្គការសហប្រជាជាតិ មិនបានឆ្លើយតបជាវិជ្ជមានទេ ដោយលោកសំអាងថាអង្គការសហប្រជាជាតិមិនអាចធ្វើអ្វីបានឡើយ ប្រសិនបើគ្មានការយល់ព្រម និង សហប្រតិបត្តិការពីរដ្ឋាភិបាលខ្មែរក្រហម ។ សមាគម អា ហ្សេ កា អឺ ក៏បានលើកបញ្ហារំលោភសិទ្ធិមនុស្សនេះ ទៅសុំអន្តរាគមន៍ពីអង្គការនិរទោសអន្តរជាតិ (Amnesty International) ដោយជឿជាក់ថាយ៉ាងហោចណាស់ ក៏សម្លេងនៃប្រជាពលរដ្ឋខ្មែរដ៏ស្លូតត្រង់អាចត្រូវបានគេដឹងឮដែរ ។ សកម្មភាពដទៃទៀតរបស់សមាគម រួមមានការបង្កើតឡើងវិញនូវរបាំព្រះរាជទ្រព្យដែលមានព្រះអង្គម្ចាស់ក្សត្រី នរោត្តម វជ្ជ៉ា ជាតារាឯក ។ សកម្មភាពមួយទៀត មានការកសាងវត្តអារាមសំរាប់ព្រះសង្ឃខ្មែរគង់នៅទីក្រុងប៉ារីស ។ បន្តបន្ទាប់មក ការសំដែងរបាំព្រះរាជទ្រព្យ មិនគ្រាន់តែបង្ហាញនូវការខំប្រឹងប្រែងរបស់សមាគម អា ហ្សេ កា អឺ ក្នុងការការពារវប្បធម៌ ប្រពៃណីខ្មែរប៉ុណ្ណោះទេ ថែមទាំងបានក្លាយជាមធ្យោបាយសំរាប់ឲ្យសមាគមរៃអង្គាសប្រាក់កាស ដើម្បីនាំទៅជួយគាំទ្រសកម្មភាពយោធារបស់យុទ្ធជនមួយក្រុម ដែលមានឈ្មោះថា ខ្មែរសេរីកា នៅតាមព្រំដែនខ្មែរ-ថៃផង ។

ឃឹម ខាន់កែវ និង តឹកលីន បានចូលរួមក្នុងសមាគមនេះ តាំងពីដើមដំបូងមកម្ល៉េះ ។ អ្នកទាំងពីរចូលរួមយ៉ាងទៀងទាត់ នៅក្នុងអង្គប្រជុំប្រចាំសប្តាហ៍របស់សមាគម ហើយនៅពេលខ្លះទៀត ពួកគេចំណាយពេលវេលាទៅជួយធ្វើការសមាគមនៅក្នុងការិយាល័យ ។ ឃឹម ខាន់កែវ ដែលជាមនុស្សពូកែប្រាជ្ញព្រោក ចេះរកវិធីបានចូលទៅជិតលោកតា សឺន សាន ។ ឃឹម ខាន់កែវ និយាយបញ្ចុះបញ្ចូលលោក សឺន សាន ឲ្យដឹងពីសកម្មភាពការងាររបស់ខ្ញុំ ដោយបានលើកសរសើរអំពីចំណេះដឹង គុណសម្បត្តិ និង សីលធម៌ខ្ពស់របស់ខ្ញុំ ដែលធ្វើឲ្យលោកតា សឺន សាន ចង់បានខ្ញុំឲ្យទៅធ្វើការជាមួយគាត់ដើម្បីជាផលប្រយោជន៍ជាតិ ។ ដូច្នេះ ឃឹម

ខាន់កែវ ក៏បានដើរតួជាអ្នកនាំពាក្យពីខ្ញុំទៅលោកតា សឺន សាន ពីលោកតា សឺន សាន មកខ្ញុំ ។ គេនិយាយប្រាប់ខ្ញុំថា គេគោរព និង ស្រឡាញ់លោកតា ដោយសារគាត់មានសេចក្តីក្លាហាន ជាមនុស្សស្អាតស្អំ និង ជាអ្នកជាតិនិយម ។ គេនិយាយប្រាប់លោកតាថា គេគោរពស្រឡាញ់ខ្ញុំ ព្រោះខ្ញុំបានទទួលជោគជ័យផ្នែកវិជ្ជាជីវៈ និង មានសេចក្តីស្នេហាជាតិខ្ពស់ ។ គឺជាការច្បាស់ណាស់ដែល ខាន់កែវ បង្កលក្ខណៈឲ្យលោកតា សឺន សាន ចង់ជួបខ្ញុំ និង ឲ្យខ្ញុំចង់ជួបលោកតា សឺន សាន ។ នៅទីបំផុត លោកតាបានស្នើឲ្យ ខាន់កែវ បញ្ចុះបញ្ចូលខ្ញុំ ឲ្យចូលទៅក្នុងសមាគម អា ហ្សេ កា អឺ ។ លោកតា សឺន សាន បានត្រៀមខ្លួន ទទួលខ្ញុំគ្រប់ពេលវេលា នៅផ្ទះរបស់គាត់ ។ ដូច្នេះ ខាន់កែវ ក៏រៀបចំកម្មវិធីឲ្យខ្ញុំ និង លោកតាបានជួបគ្នា ។

ជំនួបជាមួយលោកតា សឺន សាន

ខ្ញុំត្រូវទៅជួបលោកតា សឺន សាន នៅគេហដ្ឋានរបស់គាត់នៅផ្លូវ អាកាស្យា (Accacias) នៅល្ងាចថ្ងៃអាទិត្យមួយ នាខែ កញ្ញា ១៩៧៦ ។ តាមធម្មតា នៅពេលឈប់សំរាក ខ្ញុំមិនស្លៀកពាក់អាវធំចងក្រវ៉ាត់ ដែលខ្ញុំតែងតែស្លៀកពាក់នៅរាល់ថ្ងៃធ្វើការទេ ។ ដូច្នេះ ខ្ញុំទៅជួបលោក សឺន សាន អតីតរដ្ឋមន្ត្រីទីមួយនៃប្រទេសខ្មែរគឺ មន្ត្រីធំម្នាក់ធ្លាប់កាន់តំណែងជារដ្ឋមន្ត្រីក្រសួងការបរទេសនៅថ្ងៃដែល ខ្ញុំកើត ក្នុងសំលៀកបំពាក់មិនសូវសមរម្យទេគឺ អាវយឺត (T-shirt) និង ខោជីន (Jean) ។ តាមពិតទៅ ខ្ញុំមិនសូវបានយកចិត្តទុកដាក់ និង យល់ដឹងច្បាស់លាស់អំពីរបៀបរបបពិធីការប៉ុន្មានឡើយ ។ ក៏ប៉ុន្តែ ខ្ញុំទៅដល់ទាន់ពេលវេលាល្អណាស់ ។ ខ្ញុំចុចកណ្តឹងផ្ទះដែលជាផ្ទះល្វែង ប្រកបដោយការតុបតែងដ៏ប្រណិតតាមរបៀបអភិជន ។ នៅពេលដែលទ្វារបើកហើយ ខ្ញុំក៏ត្រូវនាំទៅបន្ទប់ទទួលភ្ញៀវដែល នៅ

ក្នុងនោះ លោកតា សឺន សាន ក្នុងសំលៀកបំពាក់អាវធំបីជាន់ចងក្រវ៉ាត់ ឈរចាំទទួលខ្ញុំជាស្រេច ។ នៅអមជាមួយគាត់ មាននារីអាយុសាមសិបប្លាយឆ្នាំម្នាក់ ពាក់វ៉ែនតាមីញ៉ូបឈ្មោះអ្នកស្រី សួន កាសេត ជាអ្នកចាំកត់ត្រា និង ដោយមានកូនប្រុសរបស់លោកតាម្នាក់ឈ្មោះ មុនា ដែលជាស្តាបត្យករជាអ្នកបំរើគ្រឿងកេសជ្ជៈ ។

ឆ្លើយតបនឹងគារវកិច្ចដោយលើកដៃសំពះបែបប្រពៃណីរបស់ខ្ញុំ លោកតាលូកចាប់ដៃខ្ញុំរលាក់យ៉ាងកក់ក្តៅ ។ ខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះបុគ្គលិកលក្ខណៈរបស់លោកតា ដែលខ្ញុំមិនដែលបានជួបនិយាយជាមួយដោយផ្ទាល់ឡើយ ។ ខ្ញុំឃើញលោកតាហាក់ដូចជានៅក្មេងជាងអាយុ ។ នៅពេលនោះ ខ្ញុំទើបមានអាយុ ២៦ ឆ្នាំ ឯលោកតា មានអាយុ ៦៥ ឆ្នាំ ។ គាត់មានរាងខ្ពស់ ចំណែកឯត្រចៀកទាំងសងខាងរបស់គាត់មានសណ្ឋានវែង ដែលតាមជំនឿរបស់ខ្មែរយើងថាជាមនុស្សអាយុវែង ។ យ៉ាងណាក៏ដោយ នៅពេលជួបគ្នាគ្រាដំបូងនោះ លោកតាមហាក់ដូចជាមនុស្សមានកម្លាំងខ្សោយ ក៏ប៉ុន្តែនៅពេលក្រោយៗមកអស់រយៈច្រើនឆ្នាំ ដែលបានធ្វើការជាមួយគ្នា ខ្ញុំសង្កេតឃើញថាលោកតាមានអំណត់អត់ធ្មត់ក្នុងការងារ ។ តាមពិត ខ្ញុំមិននឹកស្មានថាខ្ញុំត្រូវបានទទួលកិត្តិយស ដោយបានទទួលការស្វាគមន៍រាក់ទាក់យ៉ាងកក់ក្តៅពីលោកតាយ៉ាងនេះឡើយ ។

លោកតា សឺន សាន បានធ្វើការរៀបរាប់យ៉ាងវែងអំពីស្ថានភាពនយោបាយនៅកម្ពុជានៅក្នុងរបបគ្រប់គ្រងនីមួយៗកន្លងមក ។ លោកតាគូសបញ្ជាក់ថា រាល់ដងដែលខ្មែរបែកបាក់ ប្រទេសជាតិតែងទន់ខ្សោយ ហើយអាចទទួលរងគ្រោះរលាយបាត់ពីផែនដីផង ។ យ៉ាងនេះហើយ ទើបកាលពីប៉ុន្មានឆ្នាំមុនគឺ មុនពេលដែលរបបសាធារណរដ្ឋដួលរលំ លោកតាបានព្យាយាមដោយមិនខ្លាចនឿយហត់ដើម្បីបញ្ចុះបញ្ចូលសម្តេច សីហនុ លោក លន់ នល់ និង អ្នកគាំទ្រទាំងសងខាងដូចជា សហរដ្ឋអាមេរិក និង ប្រទេសចិនជាដើម ឲ្យចូលមកចរចាគ្នាតាមសន្តិវិធី

វិញ ។ ក៏ប៉ុន្តែលោកតាមិនបានទទួលជោគជ័យ ដោយសារពុំមានការគាំទ្រខ្លាំងក្លា នៅពីខាងក្រោយ ដូច្នេះក៏គ្មាននរណាស្តាប់ និង ធ្វើតាម ។ នៅទីបញ្ចប់ ខ្មែរក្រហមក៏ឡើងកាន់អំណាច ដោយបង្កើតរដ្ឋអំណាចដ៏ឃោរឃៅមួយ ដែលកាប់សម្លាប់ និង រំលោភសិទ្ធិមនុស្សលើប្រជាពលរដ្ឋឯង ។ ក្នុងជំនួបលើកដំបូងនោះ មែនទែនទៅ យើងនិយាយគ្នាច្រើនអំពីបញ្ហានយោបាយ ជាងបញ្ហាសង្គមកិច្ច និង វប្បធម៌ ។

ចំពោះខ្ញុំវិញ ខ្ញុំគ្រាន់តែបានរៀបរាប់យ៉ាងខ្លីៗអំពីបទពិសោធន៍របស់ខ្ញុំខាងផ្នែកនយោបាយនៅក្នុងជួរគណបក្សប្រជាធិបតេយ្យ ជាពិសេសទំនាក់ទំនងផ្ទាល់របស់ខ្ញុំជាមួយលោក ចៅ សៅ ។ លោកតា សឺន សាន ចាប់អារម្មណ៍ជាពិសេសចំពោះចំណុចនេះ ព្រោះគាត់ធ្លាប់ស្គាល់លោក ចៅ សៅ ច្បាស់លាស់ណាស់ ដោយហេតុថា លោក ចៅ សៅ ធ្លាប់ធ្វើការនៅក្រោមបង្គាប់របស់លោកតា ដែលមានជំនឿទុកចិត្ត និង ទទួលស្គាល់ថាលោក ចៅ សៅ ជាសហការីដែលមានសមត្ថភាពខ្ពស់ ។ ខ្ញុំបានជំរាបលោកតា សឺន សាន ថាខ្ញុំមិនមែនជាអ្នកប្រឆាំងនឹងរបបរាជានិយមទេ ដែលនេះជាចំណុចខុសគ្នារវាងខ្ញុំ និង លោក ចៅ សៅ ។ នៅទីបញ្ចប់នៃជំនួបគ្នានោះ ខ្ញុំបានប្តេជ្ញាផ្តល់ការគាំទ្រចំពោះលោកតា សឺន សាន ហើយនឹងចូលរួមក្នុងសមាគម អា ហ្សេ កា អឺ ។ នៅពេលនោះ លោកតា សឺន សាន បានប្រាប់ទៅលោកស្រី សួន កាសេត ឲ្យជួយសំរួលការងារ ដើម្បីឲ្យខ្ញុំចូលរួមក្នុងការបោះពុម្ពផ្សាយនូវព្រឹត្តិប័ត្រប្រចាំខែរបស់សមាគម អា ហ្សេ កា អឺ ដែលមានឈ្មោះថា លិខិតជូនដំណឹង ។ លិខិតជូនដំណឹងនេះ ត្រូវបានផ្សព្វផ្សាយជូនដល់សហគមន៍ខ្មែរទាំងអស់ និង ជូនដល់បណ្តាញសារព័ត៌មាននៅក្នុងប្រទេសបារាំងផង ។

ខំធ្វើការដើម្បីសហគមន៍ខ្មែរ

ចាប់តាំងពីថ្ងៃនោះមក ខ្ញុំខឹតខំធ្វើការនៅក្នុងសមាគម អា ហ្សេ កា អឺ ដោយយកចិត្តទុកដាក់ជាទីបំផុត ។ ខ្ញុំចំណាយពេលវេលាក្រៅម៉ោងធ្វើការជាច្រើនម៉ោងក្នុងមួយថ្ងៃៗដើម្បីបំរើសមាគមនេះ ។ សមាគម អា ហ្សេ កា អឺ ក៏ដូចជាសមាគមខ្មែរឯទៀតដែរ មានសមាជិក និង អ្នកគាំទ្រច្រើន ក៏ប៉ុន្តែ សមាជិកដែលសកម្មការងារ និង អ្នកស្ម័គ្រចិត្តមកជួយធ្វើការងារមានចំនួនតិចតួចប៉ុណ្ណោះ ព្រោះម្នាក់ៗសុទ្ធតែជាប់រវល់ក្នុងការងារចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់ពួកគេ ។

នៅគ្រាដំបូង ខ្ញុំទទួលភារកិច្ចក្នុងការបោះពុម្ពផ្សាយព្រឹត្តិប័ត្រតែម្នាក់ឯង ។ ក្នុងហានៈជាអ្នកទទួលខុសត្រូវផ្នែកផ្សព្វផ្សាយនោះ ខ្ញុំពុំមានដៃគូ ឬ អ្នកជំនួយការច្រើនទេគឺ ខ្ញុំត្រូវប្រមែប្រមូលព័ត៌មានដោយខ្លួនឯង និង សរសេរអត្ថបទភាគច្រើនដោយឯងខ្លួន មិនតែប៉ុណ្ណោះ ខ្ញុំត្រូវវាយអក្សរ កែសំរួលអត្ថបទ ធ្វើការបោះពុម្ព និងផ្ញើនូវលិខិតជូនដំណឹងទាំងនោះតាមប្រៃសណីយ៍ទៅសមាជិកគ្រប់ៗរូប ដោយខ្លួនឯងផង ។ ជួនកាលខ្ញុំក៏បានទទួលជំនួយពីមិត្តភក្តិដែលមកពីផ្នែកដទៃ ដែលជាទូទៅគឺជាមនុស្សដដែលៗគឺ ពីពួកកូនចៅលោកតា សឺន សាន ផ្ទាល់ ព្រោះសមាគមបានយកផ្ទះលោកតាជាទីស្នាក់ការកណ្តាល ។ នៅចុងសប្តាហ៍សមាជិកជាច្រើន បានមករួមប្រជុំដើម្បីស្តាប់របាយការណ៍អំពីសកម្មភាពរបស់សមាគម ឬ អំពីការវិវត្តផ្នែកនយោបាយនៅប្រទេសកម្ពុជា ដែលធ្វើឡើងដោយលោកតា សឺន សាន ។ បន្ទាប់ពីការប្រជុំម្តងៗ ខ្ញុំមិនត្រឡប់ទៅផ្ទះវិញទេគឺ នៅបន្តការងារនៅក្នុងការិយាល័យរបស់សមាគមតទៅទៀត ។ ទោះជាខ្ញុំមានភារកិច្ចទទួលខុសត្រូវផ្នែកលិខិតជូនដំណឹងយ៉ាងណាក៏ដោយ ក៏ខ្ញុំនៅមានការងារឯទៀតនៅក្នុងសមាគមនេះ

ដែរ ។ ក្រៅពីការបង់ប្រាក់វិភាគទានខ្ញុំក៏បានស្ម័គ្រចិត្តធ្វើសកម្មភាពផ្សេងៗជាច្រើន នៅក្នុងសមាគមដូចជាការងារកំប៉ិកកំប៉ុកនៅក្នុងការិយាល័យ និង ជួយដឹកជញ្ជូន សមាជិកឯទៀតដែលគ្មានយានជំនិះដិះត្រឡប់ទៅផ្ទះដោយខ្លួនឯង ឬ ទៅសួរសុខទុក្ខជនភៀសខ្លួន ដែលកាន់តែមានចំនួនច្រើនឡើងនៅប្រទេសបារាំង ឬ ក៏ធ្វើដំណើរទៅតាមខេត្ត ដើម្បីបង្កើតសាខារបស់សមាគម ឬ ដើម្បីប្រារព្ធពិធីបុណ្យសាសនា ឬ ក៏រួមដំណើរជាមួយលោកតា សឺន សាន ដែលមានកម្មវិធីជួបជុំជាមួយប្រជាពលរដ្ឋខ្មែរនៅទូទាំងស្រុកបារាំង ។

កាលសម័យនោះ សមាគម អា ហ្សេ កា អឺ ជាសមាគមដ៏សំខាន់មួយមែនពិត ដែលមានអ្នកធំ អ្នកតូចជាច្រើនចូលរួម ក៏ប៉ុន្តែសមាគមនោះ ក៏មានការប្រណាំងប្រជែងពីសមាគមឯទៀតដែរ ដែលចេះតែមានចំនួនកើនឡើងស្អេកស្កះដូចផ្សិត ។ សមាគមមួយចំនួនតូច បានប្តេជ្ញាផ្តល់ការគាំទ្រដល់យុទ្ធជនប្រឆាំងខ្មែរក្រហមនៅទល់ដែនខ្មែរ-ថៃ ។ បើតាមឯកសារប្រវត្តិរបស់ចលនា រ. ជ. រ. ប. ខ. (រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ) បានឲ្យដឹងថា បន្ទាប់ពីរបបសាធារណរដ្ឋដួលរលំនៅថ្ងៃទី ១៧ មេសា ១៩៧៥ មក មានទាហានខ្មែរសាធារណរដ្ឋមួយចំនួនពុំបានទម្លាក់អាវុធឡើយ ហើយបង្កើតជាក្រុមប្រដាប់អាវុធនៅខែ វិច្ឆិកា ១៩៧៥ ។ ក្រុមយុទ្ធជនទាំងនោះមានជាអាទិ៍ ក្រុមលោក កេត រ៉ែត (ស័ក្តិ ៥ សាធារណរដ្ឋ) ក្រុមលោក សេក សំអៀត ដែលជាឧត្តមសេនីយម្នាក់នៃរបបសាធារណរដ្ឋ និង លោក ឃួន ថៃ ។ នៅឆ្នាំ ១៩៧៦ មានក្រុមដទៃទៀតដូចជា៖ ក្រុម អៀ ងួន ក្រុមលោក ព្រុំ វិត ក្រុមលោក យក់ ម៉ន លោក កាន់ វណ្ណា លោក លី ធាង ចេក លោក គីរីរម្យ និង កែវ ជួន ជាដើម ។ ក្រុមទាំងនោះច្រើនជាក្រុមស្វយ័តរកស៊ីកាប់ឈើលក់ ឬ រកត្បូង ដើម្បីចិញ្ចឹមចលនា ដោយធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រុមឧត្តមសេនីយថៃ ។

នៅទីក្រុងប៉ារីស មានសមាគមខ្មែរមួយឈ្មោះ មូលខ្មែរ ដែលបង្កើតឡើងដោយអតីតឧត្តមសេនីយសាធារណរដ្ឋពីរនាក់ និង អ្នកជំនាញការហិរញ្ញវត្ថុធនាគារមួយរូប បានធ្វើការទាក់ទងជាមួយក្រុមយុទ្ធជនទាំងនោះ ។ នៅខែ កុម្ភៈ ១៩៧៧ សមាគមមូលខ្មែរ បានធ្វើការសាកល្បងបង្រួបបង្រួមក្រុម កេត រ៉ែត និង អៀ ងួន ឲ្យចូលគ្នា ។ ក៏ប៉ុន្តែ នៅខែ ឧសភា ១៩៧៧ ជាដំបូងក្រុម សេក សំអៀត និង ឃួន ថៃ និង បន្ទាប់មកនៅខែ តុលា ១៩៧៧ ក្រុមលោក កេត រ៉ែត បានត្រូវរំលាយចោល ។ នៅខែ វិច្ឆិកា ឆ្នាំដដែលក៏មានចលនាបង្រួបបង្រួមរវាងក្រុមលោក អ៊ឹម ឈូដេត ជាមួយក្រុមលោក សេក សំអៀត ដែរ ។

ចលនាតស៊ូខ្មែរសេរីកា

លោក អ៊ឹម ឈូដេត ជាអតីតវរសេនីយឯកនៃសាធារណរដ្ឋខ្មែរ ។ មុនស្រុកធ្លាក់ គាត់កាន់តំណែងជាអនុព័ន្ធការពារប្រទេស នៅអមស្ថានទូតខ្មែរប្រចាំទីក្រុងបាងកក ។ នៅក្នុងមុខតំណែងនេះ គាត់មានភ័ព្វសំណាងបានធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងមេបញ្ជាការជាន់ខ្ពស់នៃកងទ័ពថៃ ។ គាត់មានការជិតស្និទ្ធជាមួយលោក ឧត្តមសេនីយ គ្រឿងស័ក្តិ ឆោមចំណាន ដែលជាមេបញ្ជាការជាន់ខ្ពស់បំផុតនៃកងទ័ពថៃ ហើយដែលបានឡើងកាន់តំណែងជានាយករដ្ឋមន្ត្រីនៃប្រទេសថៃ ក្រោយរដ្ឋប្រហារយោធាមួយក្នុងខែ តុលា ១៩៧៧ ។ លោក អ៊ឹម ឈូដេត ស្គាល់អ្នកដឹកនាំថៃច្បាស់លាស់ជាទីបំផុត ដែលអាចឲ្យគាត់ចេញចូលជួបលោក គ្រឿងស័ក្តិ បានគ្រប់ពេលវេលា ។ លោក អ៊ឹម ឈូដេត និយាយភាសាថៃយ៉ាងស្ទាត់ជំនាញ ព្រោះធ្លាប់បានរៀនរហូតដល់មធ្យមសិក្សានៅក្នុងសាលាថៃ ។ បន្ថែមលើនេះ លោក អ៊ឹម ឈូដេត ត្រូវបានខ្មែរភាគច្រើនស្គាល់ថាជាអ្នកនិពន្ធប្រលោមលោកយ៉ាងល្បីល្បាញ ។

គាត់និពន្ធប្រលោមលោកខ្មែរជាច្រើន ក៏ប៉ុន្តែប្រលោមលោកដែលល្បីជាងគេនោះ មានចំណងជើងថា "ករិយាពីរ" ។

បន្ទាប់ពីការដួលរលំនៃរបបសាធារណរដ្ឋ លោក អ៊ឹម ឈូដេត មិនបានចេញពីប្រទេសថៃទេ ។ គាត់បន្តរៀបចំបណ្តាញក្រុមយុទ្ធជន ដើម្បីតស៊ូស្វែងរកសេរីភាពជាបន្តទៀត ។ នៅពេលដែលពួកឧត្តមសេនីយថៃបានសំរេចច្បាស់ថាយកនយោបាយគាំទ្រចលនារួបរួមរបស់ក្រុមយុទ្ធជនខ្មែររួចហើយ ពួកឧត្តមសេនីយថៃទាំងនោះ ក៏ស្វែងរកអ្នកដឹកនាំនយោបាយខ្មែរម្នាក់ ដើម្បីដឹកនាំចលនាតស៊ូប្រឆាំងខ្មែរក្រហម ។ នៅពេលនោះ លោក អ៊ឹម ឈូដេត បានផ្តល់មតិជូនលោក គ្រឿង ស័ក្តិ ថាគួរអញ្ជើញលោកតា សឺន សាន ឲ្យមកធ្វើការបង្រួបបង្រួមក្រុមយុទ្ធជនទាំងនោះ ព្រោះបើតាមការយល់ដឹងរបស់គាត់ លោកតា សឺន សាន ជាវរជនខ្មែរមួយរូបដែលនៅមានភាពគ្រាន់បើ និង ស្អាតស្អំជាងគេ ។ នេះជាការអះអាងរបស់លោក អ៊ឹម ឈូដេត ប្រាប់រូបខ្ញុំ និង ប្រាប់អ្នកតស៊ូឯទៀតនៅពេលក្រោយជាបន្តបន្ទាប់ ។ ក៏ប៉ុន្តែ បើតាមលោកតា សឺន សាន មនុស្សដែលមកទាក់ទង ក្នុងហានៈជាមេអណ្តើករវាងលោកតា សឺន សាន និង អាជ្ញាធរយោធាថៃនោះ ឈ្មោះ ឡេ កុក ទុយ (Le Quoc Tuy)[56] ដែលជាមេដឹកនាំក្រុមវៀតណាមសេរីប្រឆាំងក្រុងហាណូយ ។

នៅទីបំផុត ខ្ញុំបានដឹងនៅពេលក្រោយៗមកទៀតថា វរសេនីយឯកថៃម្នាក់ឈ្មោះ ឆាវលិត យុងឆៃយុទ្ធ បានធ្វើដំណើរមកទីក្រុងប៉ារីស ដើម្បីទាក់ទងផ្ទាល់ជាមួយលោកតា សឺន សាន និង ស្នើលោកតាឲ្យមកបង្កើតចលនាតស៊ូនៅទល់ដែនខ្មែរ-ថៃ ។ លោកវរសេនីយឯករូបនេះដែលក្រោយៗមកបានក្លាយទៅជានាយករដ្ឋមន្ត្រីនៃប្រទេសថៃ កាលសម័យនោះ ជាអ្នកជំនាញការក្នុងបញ្ហាខ្មែរ ។ លោក

[56] The Memoirs of Son Sann, Cambodia Daily Press, 2011, p.127.

ឆាវលិត ជានាយទាហានថៃម្នាក់ ដែលមានឥទ្ធិពលយ៉ាងខ្លាំង និង ដែលមានសមត្ថភាពទាញយកផលប្រយោជន៍យ៉ាងសម្បើម សំរាប់ប្រទេសថៃ តាមរយៈការលូកដៃផ្ទាល់ចូលក្នុងជម្លោះនៅកម្ពុជា ។

ជាដំបូង ខ្ញុំមិនបានដឹងថាលោក ឆាវលិត បានមកទាក់ទងសមាគម អាហ្សេ កា អឺ និង មិនបានដឹងថា សមាគមបានផ្តល់ការគាំទ្រហិរញ្ញវត្ថុជាសម្ងាត់ដល់យុទ្ធជននៅតាមជាយដែនទេ ព្រោះនោះជានយោបាយជាន់ខ្ពស់ ដែលមានតែមនុស្សតិចតួច ហើយជិតជិតបំផុតជាមួយលោកតា សឺន សាន ប៉ុណ្ណោះទើបបានដឹង ។ តាមពិតទៅ លោកតា សឺន សាន បានធ្វើសកម្មភាព "នយោបាយជាន់ខ្ពស់" នេះ តែជាមួយមនុស្សមួយក្តាប់តូចដែលគាត់ទុកចិត្ត ដែលសុទ្ធសឹងតែជាសមាជិកសកម្មនៅក្នុងសមាគម និង ជាមួយកូនចៅរបស់លោកតាខ្លះៗប៉ុណ្ណោះ ។ ក្នុងចំណោមអ្នកទាំងនោះ ក្រៅពីអ្នកស្រី សួន កាសេត ខ្ញុំក៏អាចរាប់បន្ថែមនូវកូនប្រសាលោកតា សឺន សាន ម្នាក់គឺ លោកបណ្ឌិតឱសថសាស្ត្រ ធាយ ហាន់ចេង ដែលធ្លាប់កាន់តំណែងជារដ្ឋលេខាធិការក្រសួងសុខាភិបាល ក្នុងសម័យសង្គមនាទសវត្សរ៍ឆ្នាំ ១៩៦០ ។ លោក ធាយ ហាន់ចេង បំរើលោកតាផ្ទាល់ ដូចជាអង្គរក្ស ឬ ក៏លេខា ឬ ក៏ប្រធានខុទ្ទកាល័យផ្ទាល់ក៏បាន ។ ឲ្យតែលោកតាប្រើ លោក ធាយ ហាន់ចេង ធ្វើជូនទាំងអស់ ។ នៅថ្ងៃមួយដែលលោកតា សឺន សាន មានសុខភាពមិនល្អនិយាយឮពុំបាននៅក្នុងអង្គប្រជុំ លោកតានិយាយដាក់ត្រចៀកកូនប្រសា ហើយកូនប្រសានោះ ក៏និយាយបន្តដូចជានិយាយដាក់មេក្លែយ៉ាងដូច្នោះ ។

ក្រោយមក ខ្ញុំក៏ឃើញមនុស្សម្នាក់ទៀត ជាមនុស្សជិតស្និទ្ធនឹងលោកតាដែរ ដែលជាអតីតមន្ត្រីជាន់ខ្ពស់ក្នុងរាជការស៊ីវិលខ្មែរ ឈ្មោះលោក នាង ជិនហន ។ ជាមួយនោះ ក៏មានឧត្តមសេនីយសម័យសាធារណរដ្ឋម្នាក់ ដែលគេស្គាល់ថាជាអ្នកមានសមត្ថភាពគ្រាន់បើ ក្នុងជួរកងទ័ពរបស់លោក លន់ នល់ ឈ្មោះលោកឧត្តម

សេនីយ ដៀន ដែល ។ បន្ទាប់ពីបានប្រជុំជាមួយគ្នាច្រើនដងមក ខ្ញុំសំគាល់ឃើញ លោកឧត្តមសេនីយរូបនេះ មានគោលជំហរនយោបាយល្អ ព្រោះគាត់ប្រកាន់ថា កងទ័ពត្រូវតែបំរើលទ្ធិប្រជាធិបតេយ្យ ។

លោក នាង ជិនហន ជាមន្ត្រីជាន់ខ្ពស់មួយរូប ដែលបានទទួលសញ្ញាប័ត្រ ចេញពីសាលាភូមិន្ទរដ្ឋបាល ហើយធ្លាប់បានបំរើការជាប្រធានលេខាធិការដ្ឋានរបស់ សម្តេច សីហនុ ក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ ។ នៅប្រទេសបារាំងគាត់ធ្វើការសិក្សា បន្ថែម ផ្នែកវិទ្យាសាស្ត្រនយោបាយ និង ធុរកិច្ច ហើយបានទទួលសញ្ញាប័ត្រទាំង ពីរផ្នែកនេះទៀតផង ។ លោក នាង ជិនហន មានជំនាញខ្ពស់ខាងផ្នែករដ្ឋបាល ហើយគាត់អាចសរសេរសុន្ទរកថានយោបាយជាភាសាបារាំងបានយ៉ាងល្អ ។ លោក នាង ជិនហន មានទំនាក់ទំនងជិតស្និទ្ធជាមួយអ្នកស្រី សួន កាសេត ។ ចំណែកឯ អ្នកស្រី សួន កាសេត ក៏ធ្លាប់ជាមន្ត្រីបំរើការផ្ទាល់នៅក្នុងខុទ្ទកាល័យរបស់សម្តេច សីហនុ ក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ ដែរ ក្នុងឋានៈជាអ្នកទទួលខុសត្រូវផ្នែកការផ្សាយ នៃព្រឹត្តិប័ត្រប្រចាំខែឈ្មោះ កាំបូជ្យា (Kambuja) ។ អ្នកស្រី សួន កាសេត បាន ទទួលការអប់រំរបៀបបារាំង ហើយកើតចេញពីត្រកូលអ្នកធំខ្មែរ ដែលធ្លាប់កាន់តំ ណែងជារដ្ឋមន្ត្រី និង ឯកអគ្គរាជរដ្ឋទូតជាដើម ។ អ្នកស្រីនិយាយភាសាបារាំង បានយ៉ាងស្ទាត់ជំនាញ និយាយភាសាខ្មែរក៏ល្អដែរ ក៏ប៉ុន្តែគាត់មិនចេះអាន និង សរសេរអក្សរខ្មែរទេ ។ អ្នកស្រី សួន កាសេត រៀបការជាមួយមន្ត្រីជាន់ខ្ពស់ក្រសួង កសិកម្មម្នាក់ ហើយមានកូនបីនាក់ ដែលគាត់នាំយកមករស់នៅជាមួយនៅប្រទេស បារាំង បន្ទាប់ពីពួកខ្មែរក្រហមបានកាន់កាប់ទីក្រុងភ្នំពេញ ដោយទុកចោលស្វាមីឲ្យ នៅទីនោះ ។ តាំងពីពេលខ្មែរក្រហមចូលកាន់កាប់ប្រទេសនោះរហូតមក អ្នកស្រីពុំ ដែលបានទទួលដំណឹងពីស្វាមីសោះឡើយ ។

ដោយសារសមាគមខ្មែរនានានៅប្រទេសបារាំង កើតមានឡើងច្រើនដូច ផ្សិត អ្នកខ្លះផ្តួចផ្តើមគំនិតឲ្យមានការសំរបសំរួលសកម្មភាពរបស់សមាគមទាំង នោះដូចជាការបង្កើតគណៈកម្មាធិការទំនាក់ទំនងមួយឈ្មោះ សេ ដេ អិល (CDL: Comité de Liaison) ឬ គណៈកម្មការដើម្បីឯករាជ្យអព្យាក្រឹតជាដើម ។ ទោះ ជាយ៉ាងនោះក្តី ក៏មកដល់ឆ្នាំ ១៩៧៩ គេអាចរាប់ឃើញថាមានសមាគមខ្មែរ ប្រហែលជា ១៥០ បានត្រូវបង្កើតនៅក្នុងប្រទេសបារាំង ដែលនៅក្នុងនោះចំនួន ពាក់កណ្តាលមាននៅក្នុងទីក្រុងប៉ារីស និង ជាយក្រុងនេះ ។ ពួកខ្មែរៗដែលបង្កើត សមាគមទាំងនេះ ប្រហែលនឹកគិតថាសកម្មភាពនយោបាយរបស់ខ្លួនអាចនឹងធ្វើ ឲ្យមានឧបសគ្គ ឬ ផលប៉ះពាល់ដល់ទង្វើរបស់ពួកខ្មែរក្រហមនៅក្នុងប្រទេសបាន ដោយគ្រាន់តែធ្វើការជជែកគ្នា បោះពុម្ពផ្សាយ ឬ ចេញផ្សាយនូវសេចក្តីថ្លែង ការណ៍ព្រឹត្តិប័ត្រព័ត៌មាន ឬ ធ្វើសន្និសីទព័ត៌មានជាដើម ។ ចំពោះខ្ញុំៗមានភាព ច្បាស់លាស់ក្នុងចិត្តរបស់ខ្ញុំជាស្រេចថា ដើម្បីរំដោះទឹកដីខ្មែរចេញពីពួកខ្មែរក្រហម មានតែសកម្មភាពជាក់ស្តែង នៅលើសមរភូមិតែប៉ុណ្ណោះគឺ នៅលើទឹកដីខ្មែរផ្ទាល់ មិនមែនធ្វើសកម្មភាពពីចម្ងាយ រាប់ពាន់គីឡូម៉ែត្រពីប្រទេសខ្មែរនោះឡើយ ។ ដោយសារមានការប្តេជ្ញាចិត្តច្បាស់លាស់យ៉ាងនេះ ទើបខ្ញុំសំរេចចិត្តថា ត្រូវត្រៀម ខ្លួនដើម្បីធ្វើអ្វីមួយឲ្យបានខិតទៅជិតប្រទេសខ្មែរ ឬ យ៉ាងហោចណាស់ ទៅធ្វើការ ផ្ទាល់ជាមួយយុទ្ធជនដែលស្នេហាសេរីភាព នៅលើសមរភូមិដោយផ្ទាល់តែម្តង ។ សេចក្តីសំរេចទីមួយរបស់ខ្ញុំគឺសុំលាឈប់ពីការងារនៅក្នុងក្រុមហ៊ុន ម៉ុតូង ទាំងពីរ ។

ឃ្លាតកាយ ណាយចិត្ត

ថ្ងៃនោះជាថ្ងៃដែលពោរពេញទៅដោយក្តីសោកសៅ និង ភាពតានតឹងក្នុង ចិត្តចំពោះក្រុមគ្រួសារថៅកែខ្ញុំ ។ នៅពេលដែលខ្ញុំប្រគល់លិខិតលាលែងរបស់ខ្ញុំ

ក្នុងខែ តុលា ១៩៧៨ នោះ អ្នកស្រី ម៉ុត្តុង បង្ហូរទឹកភ្នែកដោយក្តីក្តុកក្តួល ។ ខ្ញុំនិយាយប្រាប់ពួកគេថា អនាគតរបស់ខ្ញុំនៅឯស្រុកខ្មែរ មិនមែននៅស្រុកបារាំងនេះទេ ។ ខ្ញុំមិនអាចរស់នៅយកសុខតែម្នាក់ឯង នៅពេលដែលខ្ញុំដឹងថាប្រជារាស្ត្រខ្ញុំ និង ប្រទេសជាតិខ្ញុំកំពុងជួបប្រទះនូវសោកនាដកម្មដែលមិនធ្លាប់មានសោះនៅក្នុងប្រវត្តិសាស្ត្រនៃមនុស្សជាតិ ។ តាមពិត នៅពេលនោះ ខ្ញុំនៅមិនទាន់មានគំនិតអ្វីច្បាស់លាស់ថា តើពេលណា និង ធ្វើយ៉ាងដូចម្តេច ដើម្បីវិលត្រឡប់មកប្រទេសកម្ពុជា និង តំបន់ទល់ដែនវិញនោះនៅឡើយទេ ។ បន្ទាប់ពីលាចេញពីក្រុមហ៊ុនម៉ុត្តុង នោះមក ខ្ញុំក៏បានទៅធ្វើការនៅក្រុមហ៊ុនពីរទៀត ទី១ ឈ្មោះ ឡា ទ្រីពឺរី ដឺ ឡា វីឡែត (La Triperie de la Villette) និង មួយទៀត ឈ្មោះ អាឡេន ប្រាឡេ (Allen-Bradley) ដែលជាក្រុមហ៊ុនអាមេរិកាំង មុននឹងចេញដំណើរជាស្ថាពរពីប្រទេសបារាំង ។ ក៏ប៉ុន្តែសេចក្តីសំរេចលាលែងរបស់ខ្ញុំចេញពីក្រុមហ៊ុន ម៉ុត្តុង នេះគឺខ្ញុំធ្វើឡើងដោយបង្ខំចិត្ត ដើម្បីកាត់ចំណងមនោសញ្ចេតនារវាងខ្ញុំ និង គ្រួសារនេះព្រោះបើពុំនោះទេ ខ្ញុំប្រហែលជានៅជាប់ជំពាក់នឹងបញ្ហាផ្ទាល់ខ្លួន ហើយមិនអាចផ្ទង់ស្មារតី ឬ សតិអារម្មណ៍របស់ខ្ញុំ ឆ្ពោះទៅធ្វើអ្វីមួយ ដែលខ្ញុំយល់ថាត្រូវតែធ្វើនៅពេលអនាគតនោះឡើយ ។ ចំពោះខ្ញុំនាពេលនោះ អ្វីៗក៏ដោយក៏ត្រូវចាប់ផ្តើមពីពាក្យមួយឃ្លាថា "ឃ្លាតកាយណាយចិត្ត" ។

ខ្មែរក្រហមមានជម្លោះជាមួយប្រទេសជិតខាង

ចំណែកឯនៅប្រទេសកម្ពុជាវិញ របបខ្មែរក្រហមដ៏កាចឃោរឃៅនោះ ចាប់ផ្តើមធ្វើឲ្យលេចឃើញនូវវិនាសកម្ម ដែលកាន់តែរីកធំឡើងៗឥតឈប់ឈរ ។ តាម

រយៈសារព័ត៌មានអន្តរជាតិ ខ្ញុំបានទទួលដំណឹងថារហូតដល់ឆ្នាំ ១៩៧៧ ប្រជាពលរដ្ឋខ្មែរប្រមាណ មួយលានពីរសែននាក់ បានត្រូវបាត់បង់ជីវិត ដោយសារការអត់អាហារ ការបង្ខំឲ្យធ្វើការជាទម្ងន់ ឬ ដោយសារការកាប់សម្លាប់ ។ ជនភៀសខ្លួនខ្មែររាប់សិបពាន់នាក់បានរត់មកស្នាក់នៅក្នុងទឹកដីថៃ និង វៀតណាម ។ ជាមួយគ្នានោះ ពួកខ្មែរក្រហមក៏ត្រូវជួបប្រទះនូវការប្រឆាំងផ្នែកអាវុធពីក្នុងស្រុកផង និងប៉ះទង្គិចខាងផ្លូវអាវុធជាមួយប្រទេសជិតខាងផងគឺ ប្រទេសថៃ និង វៀតណាម ។

ជម្លោះជាមួយប្រទេសថៃ អាចនិយាយថាមានឫសគល់ខាងផ្នែកមនោគមវិជ្ជា ព្រោះថាប្រទេសទាំងពីរប្រកាន់មនោគមវិជ្ជាខុសគ្នា បន្ថែមលើជម្លោះដណ្តើមទឹកដីគ្នាទៀតផង ។ ម្យ៉ាងប្រទេសកម្ពុជា នាពេលនោះ ប្រកាន់យកបបកុម្មុយនីស្តដ៏តឹងតែង រីឯប្រទេសថៃជាប្រទេសសេរី ជាសម្ព័ន្ធមិត្តជិតស្និទ្ធជាមួយសហរដ្ឋអាមេរិក ហើយក៏ធ្លាប់ទៅច្បាំងប្រឆាំងកុម្មុយនីស្តនៅវៀតណាមទៀតផង ។ ម្យ៉ាងទៀត ចាប់ពីខែ តុលា ១៩៧៦ ដោយសាររដ្ឋប្រហារ ប្រទេសថៃបានត្រូវដឹកនាំដោយរដ្ឋាភិបាលស្តាំនិយមប្រឆាំងនឹងកុម្មុយនីស្តយ៉ាងដាច់ខាតមួយ ។ ដូច្នេះរដ្ឋាភិបាលថៃថ្មីនេះ មានគោលនយោបាយប្រឆាំងប្រទេសខ្មែរកុម្មុយនីស្ត ឈ្មោះកម្ពុជាប្រជាធិបតេយ្យ ដែលគេយល់ថាអាចផ្តល់ជម្រកដល់ពួកថៃកុម្មុយនីស្ត ឲ្យវាយប្រហារប្រឆាំងរបបនយោបាយរបស់គេ ។ ម្យ៉ាងទៀត រដ្ឋាភិបាលថៃសម័យនោះ ក៏មានយុទ្ធវិធីផ្តល់ការគាំទ្រដល់ចលនាខ្មែរទាំងឡាយ ដែលប្រឆាំងខ្មែរក្រហមកុម្មុយនីស្តជាពិសេស ដល់ពួកខ្មែរសេរី និង ខ្មែរសេរីកា ។

កាលពីដំបូង នៅក្នុងជម្លោះរវាងខ្មែរក្រហម និង ថៃ ប្រទេសវៀតណាមដែលធ្លាប់ជាយុទ្ធមិត្តរបស់ខ្មែរក្រហម បានគាំទ្រពួកខ្មែរក្រហមយ៉ាងពេញទំហឹង ។ កាលនោះក្នុងឆ្នាំ ១៩៧៦ នៅពេលដែលខ្មែរក្រហម ប្រកាសថាមានយន្តហោះអាមេរិកទម្លាក់គ្រាប់បែក នៅក្នុងខេត្តសៀមរាប ទាំងទីក្រុងហាណូយ ទាំងទីក្រុង

ប៉ៃកាំង សុទ្ធតែបានស្រែកបន្ទរតាមការចោទប្រកាន់របស់ខ្មែរក្រហម[57]។ ក៏ប៉ុន្តែទីក្រុងហាណូយ ហាក់ដូចជាបង្ហាញនូវការចាប់អារម្មណ៍លើការទម្លាក់គ្រាប់បែកនោះខ្លាំងជាងទីក្រុងប៉ៃកាំងទៅទៀត ។ នៅខែ មីនា ១៩៧៦ បណ្តាញព័ត៌មានអន្តរជាតិ បានផ្សព្វផ្សាយថាវៀតណាម បានផ្តន្ទាទោសការទម្លាក់គ្រាប់បែកយ៉ាងធ្ងន់ធ្ងរនេះ នៅក្នុងសេចក្តីថ្លែងការណ៍មួយរបស់ខ្លួន ដែលមានសេចក្តីជាអាទិ៍ "សហរដ្ឋអាមេរិកនៅតែបន្តប្រើប្រាស់ទឹកដីថៃ ដើម្បីធ្វើការប្រឆាំងកម្ពុជា លាវ និងវៀតណាម ។ ពួកគេគាំទ្រពួកខ្មែរប្រតិកិរិយា[58] ដែលរស់នៅលើទឹកដីថៃ ហើយលួចបញ្ជូលពួកនេះមកកម្ពុជាវិញ ដើម្បីធ្វើវិទ្ធង្សនា និង សកម្មភាពបំផ្លិចបំផ្លាញបដិវត្តន៍កម្ពុជា" ។

នៅសម័យនោះ ប្រទេសកុម្មុយនីស្តទាំងពីរគឺ វៀតណាម និង កម្ពុជាប្រជាធិបតេយ្យ ឈរកៀកគ្នាទប់ទល់ជាមួយសត្រូវរួម ទោះបីជាប្រទេសកុម្មុយនីស្តទាំងពីរនេះ ចាប់ផ្តើមមានជម្លោះទល់ដែនជាបណ្តើរៗរួចមកហើយក៏ដោយ ចាប់តាំងពីខែ ឧសភា ១៩៧៥ ។ កាលពីខែ សីហា ១៩៧៥ នៅពេលដែលមេដឹកនាំកុម្មុយនីស្តវៀតណាម ឡេ យន់ មកធ្វើទស្សនកិច្ចនៅទីក្រុងភ្នំពេញ ភាគីទាំងពីរ វៀតណាម និង ខ្មែរក្រហម បានព្រមព្រៀងថានឹងដោះស្រាយជម្លោះនោះដោយសន្តិវិធី ។ បណ្តាញព័ត៌មានអន្តរជាតិបានផ្សព្វផ្សាយថា ជនភៀសខ្លួនខ្មែររាប់ពាន់នាក់ដែលបានរត់ទៅជ្រកនៅតាមបណ្តាខេត្តជិតខាងនានា ក្នុងប្រទេសវៀតណាមបានត្រូវបញ្ជូនត្រឡប់មកកម្ពុជាប្រជាធិបតេយ្យវិញ ។ មួយចំនួនត្រូវបានចាប់បញ្ជូនមក

[57] Nayan Chanda, The Barbarous Raid Mystery, Far Eastern Economic Review, March 12, 1976, p. 14.

[58] តាមពិតទៅ តាំងពីសម័យសង្គមរាស្ត្រនិយមមកម្ល៉េះ ប្រទេសថៃ តែងតែជួយចិញ្ចឹមក្រុមខ្មែរសេរី ឲ្យធ្វើការប្រឆាំងរដ្ឋាភិបាលខ្មែរ ។ នៅសម័យខ្មែរក្រហម ក៏មានក្រុមខ្មែរប្រដាប់អាវុធ ជ្រកកោននៅលើទឹកដីថៃដែរ ។ ចំពោះខ្មែរសេរី ឬ សេរីកា ប្រទេសកុម្មុយនីស្តតែងហៅពួកទាំងនោះថាជាពួកប្រតិកិរិយា ។

ឲ្យខ្មែរក្រហម ។ ក៏ប៉ុន្តែជនភៀសខ្លួនមួយចំនួនដែលចេញផុតពីខេត្តទល់ដែនចូលជ្រៅទៅក្នុងប្រទេសវៀតណាម ក៏បានរស់នៅបន្តទៅទៀត ។

នៅក្រុងហូជីមិញ (អតីតទីក្រុងព្រៃនគរ) មានជនភៀសខ្លួនប្រហែលមួយម៉ឺននាក់ ភាគច្រើនរស់នៅ តាមវត្តអារាម ។ បណ្តាញព័ត៌មានទាំងនោះបញ្ជាក់ថា ក្នុងចំណោមនោះ មានជនភៀសខ្លួនប្រមាណតែប៉ុន្មានរយនាក់ប៉ុណ្ណោះ ដែលអាចទទួលការអនុញ្ញាតឲ្យចេញទៅរស់នៅប្រទេសបារាំង មុនពេលវៀតណាមផ្តាច់ចំណងទាក់ទងជាមួយទីក្រុងភ្នំពេញ ។

យុទ្ធសាស្ត្រចិននាំឲ្យថៃ និង ខ្មែរក្រហមផ្តាកជម្លោះ

នៅខែ សីហា ១៩៧៦ ប្រទេសថៃ និង របបខ្មែរក្រហមបានសាកល្បងកែលំអឡើងវិញនូវទំនាក់ទំនងគ្នា ដោយសុខចិត្តបើកច្រកព្រំដែន ដើម្បីធ្វើពាណិជ្ជកម្ម ទោះបីជាជម្លោះព្រំដែននៅតែបន្តកើតមានយ៉ាងណាក៏ដោយ ។ ក៏ប៉ុន្តែនៅឆ្នាំ ១៩៧៧ ទំនាក់ទំនងថៃ និង ខ្មែរក្រហមបានត្រូវខូតខាតដោយសារមានការប៉ះទង្គិចខាងផ្នែកយោធា ដែលបង្កឲ្យមានការបាញ់កាំភ្លើងធំ និង ការវាយប្រហារផ្លូវអាកាសពីខាងកងទ័ពថៃផង ។ នៅថ្ងៃទី ២៨ មករា ១៩៧៧ អ្នកស្រុកថៃចំនួន ៦០ នាក់ បានត្រូវខ្មែរក្រហមសម្លាប់ ។ ចាប់តាំងពីពេលនោះមក ប្រទេសថៃក៏បិទច្រកព្រំដែនជាមួយកម្ពុជាឡើងវិញ ។ នៅខែ វិច្ឆិកា រដ្ឋាភិបាលថៃបានធ្វើការតវ៉ាតាមផ្លូវការមួយច្បាប់ទៅអាជ្ញាធរខ្មែរក្រហម ។ ខ្មែរក្រហមបានចេញសេចក្តីថ្លែងការណ៍ ៨ ទំព័រ អះអាងថា ប្រទេសថៃជាអ្នកទទួលខុសត្រូវក្នុងការកាប់សម្លាប់នេះ និង ថាព្រឹត្តិការណ៍ទាំងនោះ បានកើតឡើងលើទឹកដីខ្មែរ ។ ចាប់តាំងពីពេលនោះមក ខ្មែរក្រហមក៏សម្ងំស្ងៀម ។ មន្ត្រីថៃជាជំបូងអះអាងថា មានទាហានខ្មែរក្រហមបានឆ្លងកាត់ទល់ដែន ចូលទៅកាប់សម្លាប់ និង បំផ្លិចបំផ្លាញទ្រព្យសម្បត្តិប្រជា

ពលរដ្ឋថៃ ។ ក្រោយមក អ្នកវិភាគស្ថានការណ៍យោធានៅទីក្រុងបាងកក បានបកស្រាយថា តំបន់អារញ្ញប្រថេតជាទីដែលមានការកាប់សម្លាប់នោះគឺ ជាសំបុកខ្មែរប្រឆាំងកុម្មុយនីស្ត ដែលគេហៅថាខ្មែរសេរី[59] ហើយដែលកំពុងតែធ្វើការតស៊ូ ដើម្បីរំដោះប្រទេសកម្ពុជាពីក្រុមខ្មែរក្រហម ។ គេចង់បកស្រាយថា ប្រសិនបើមានការប៉ះទង្គិចគ្នាមែន ការប៉ះទង្គិចគ្នានោះកើតឡើងដោយសារក្រុមខ្មែរសេរីដែលប្រឆាំងនឹងក្រុមខ្មែរក្រហម មិនមែនដោយសារកងកម្លាំងរបស់រដ្ឋាភិបាលថៃឡើយ ។

គេប៉ាន់ស្មានថា ក្រុមខ្មែរសេរីមានចំនួនប្រមាណ ២០០០ នាក់ នៅតាមតំបន់ព្រំដែន បានធ្វើការទាក់ទងជាមួយនាយទាហានថៃ និង អ្នកជំនួញខ្មែរ-ថៃមួយចំនួន ។ ជាការពិតណាស់ ដែលមានយុទ្ធជនខ្មែរសេរី កំពុងប្រតិបត្តិការនៅក្នុងតំបន់អារញ្ញប្រថេត ។ ពួកនេះ បានយកទឹកដីថៃ ដើម្បីធ្វើសង្គ្រាមទ័ពព្រៃវាយប្រហារលើពួកខ្មែរក្រហម ក្នុងបំណងធ្វើសកម្មភាពទាក់ទាញរកជំនួយបន្ថែម និង ធាឆៅទាហានខ្មែរក្រហមនេះផង ។ ការវាយឆ្មក់តាមរបៀបទ័ពព្រៃរបស់ក្រុមខ្មែរសេរីទាំងនេះ បានធ្វើឲ្យខ្មែរក្រហមមានប្រតិកម្មខឹង និង វាយតបចូលទឹកដីថៃវិញ ។ ចាប់តាំងពីខែ មីនា ដល់ខែ តុលា ១៩៧៧ ការប៉ះទង្គិចខាងផ្លូវអាវុធកាន់តែកើនឡើង និង ខ្លាំងក្លាឡើង ហើយរាលដាលចូលដល់ខេត្តត្រាតនៃប្រទេសថៃ ។

ដើម្បីឆ្លើយតបចំពោះការវាយប្រហាររបស់ពួកខ្មែរក្រហម ថៃបានបញ្ជូនការណ្តតប្រដាប់អាវុធ និង កប៉ាល់ហោះចម្បាំងទៅកាន់តំបន់នោះ ។ មេបញ្ជាការកំពូលនៃកងទ័ពថៃ ឧត្តមសេនីយ គ្រឿងស័ក្តិ ប្រកាសថាកងទ័ពប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវនយោបាយវាយតបតទៅវិញ ចំពោះអំពើឈ្លានពានទាំងឡាយណា មកលើទឹកដីថៃដើម្បីការពារអធិបតេយ្យ និង សិទ្ធិអំណាចរបស់ប្រជាពលរដ្ឋថៃ ។

[59] Norman Peagam, Political Stability at Stake, Questions after the Massacre, Far Eastern Economic Review, February 11, 1977, p. 9-10.

ការវាយប្រហារកើតឡើងចំពេលដែល ប៉ុល ពត កំពុងបញ្ចប់ទស្សនកិច្ចជាបងប្អូន ក្នុងរយៈពេល ៥ ថ្ងៃនៅប្រទេសកូរ៉េខាងជើង និង ចាប់ផ្តើមទស្សនកិច្ចជាផ្លូវការនៅប្រទេសចិន ចាប់ពីថ្ងៃ ២៨ កញ្ញា ១៩៧៧ ។ គាប់ជួនពេលជាមួយនោះដែរ អតីតនាយករដ្ឋមន្ត្រីថៃ គុគ្រឹត ប្រាមោជ ក៏បានទៅធ្វើទស្សនកិច្ចជាផ្លូវឯកជននៅទីក្រុងប៉េកាំង និង បានជួបពិភាក្សាយ៉ាងស្និទ្ធស្នាលជាមួយប្រធាន ហួ គួ ហ្វេង ។ ប្រហែលជានៅពេលនោះ ចិនចាប់ផ្តើមធ្វើអន្តរាគមន៍ ដើម្បីបញ្ឈប់នូវជម្លោះរវាងប្រទេសថៃ និង ខ្មែរក្រហម ក្នុងន័យបង្កើតឲ្យបាននូវសម្ព័ន្ធភាពថ្មីមួយប្រឆាំងសូវៀត និង វៀតណាម ។ នៅថ្ងៃទី ២០ តុលា ១៩៧៧ ក្រុមយោធាថៃដែលបានទម្លាក់រដ្ឋាភិបាលរបស់លោក សេនី ប្រាមោជ កាលពីថ្ងៃទី ៦ តុលា ១៩៧៦ បានឡើងកាន់អំណាចឡើងវិញ ដោយទម្លាក់រដ្ឋាភិបាលស្តាំនិយមប្រឆាំងកុម្មុយនីស្តនិយមរបស់លោក តានីន ក្រៃវិឈៀន និង លើកលោកឧត្តមសេនីយ គ្រឿងស័ក្តិ ឲ្យកាន់តំណែងជានាយករដ្ឋមន្ត្រី ។ លោកឧត្តមសេនីយ គ្រឿងស័ក្តិ ធ្លាប់ថ្លែងជាញឹកញាប់ជាសាធារណៈថា គាត់មានទស្សនៈកែលំអទំនាក់ទំនងជាមួយប្រទេសឥណ្ឌូចិនកុម្មុយនីស្ត ។ ទំនាក់ទំនងល្អជាភារកិច្ចដ៏សំខាន់របស់លោកនាយករដ្ឋមន្ត្រីថ្មីរូបនេះ ។

នៅខែ វិច្ឆិកា ១៩៧៧ មួយថ្ងៃមុនឧត្តមសេនីយ គ្រឿងស័ក្តិ ឡើងកាន់តំណែងជាផ្លូវការ វិទ្យុខ្មែរក្រហមបានផ្សាយនូវសេចក្តីថ្លែងការណ៍មួយអំពាវនាវឲ្យថៃចូលមកចរចា ដើម្បីកែលំអទំនាក់ទំនងរវាងប្រទេសទាំងពីរ ។ សេចក្តីថ្លែងការណ៍នោះ បានទទូចឲ្យប្រទេសថៃជួបជាមួយមន្ត្រីខ្មែរក្រហមនៅទីក្រុងវៀងច័ន្ទ ។ ខ្មែរក្រហមនិយាយថា ពួកគេបានធ្វើសេចក្តីអញ្ជើញនេះជាលើកដំបូងនៅពេលដែលលោក អៀង សារី ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេសខ្មែរក្រហម បានជួបជាមួយនឹងលោក ឧបឌិត បាចរិយាគុណ រដ្ឋមន្ត្រីក្រសួងការបរទេសថៃ នៅអង្គការ

សហប្រជាជាតិ កាលពីថ្ងៃទី ១២ តុលា ១៩៧៧ ។ ពួកថៃបានស្វាគមន៍សេចក្តីអំពាវនាវនេះ ។ អ្នកវិភាគនយោបាយជាច្រើនយល់ថា ការផ្លាស់ប្តូរជាបន្ទាន់នៃយុទ្ធសាស្ត្ររបស់ខ្មែរក្រហមនោះ ប្រាកដជាលទ្ធផលនៃនយោបាយចិនដែលចាប់តាំងពីឆ្នាំ ១៩៧៥ មកខឹតខំជួយជំរុញឲ្យមានទំនាក់ទំនងល្អរវាងថៃ និង ខ្មែរក្រហម ។

នៅចុងខែ មករា ១៩៧៨ រដ្ឋាភិបាលដែលមានការគាំទ្រពីក្រុមយោធាបានចាត់បញ្ជូនគណៈប្រតិភូការទូតជាន់ខ្ពស់របស់ប្រទេសថៃ ដែលដឹកនាំដោយលោករដ្ឋមន្ត្រីការបរទេស ឧបឌិត បាចរិយាគុណ មកទីក្រុងភ្នំពេញដើម្បីកែសម្រួលឡើងវិញនូវទំនាក់ទំនងខ្មែរក្រហម-ថៃ និង ដោះស្រាយដោយសន្តិវិធីនូវជម្លោះទល់ដែន ។ នៅក្នុងសុន្ទរកថា ដែលថ្លែងក្នុងឱកាសលៀងសាយភោជន៍ទទួលគណៈប្រតិភូថៃ លោក អៀង សារី បានបញ្ជាក់ឲ្យដឹងនូវមូលហេតុនៃការផ្លាស់ប្តូរនយោបាយរបស់ខ្មែរក្រហម ។ គាត់និយាយថារដ្ឋាភិបាលណាក៏ដោយនៅក្នុងតំបន់ ទោះជាកុម្មុយនីស្ត ឬ មិនមែនកុម្មុយនីស្តសុទ្ធតែមានផលប្រយោជន៍ ក្នុងការគាំទ្រខ្មែរក្រហម ក្នុងសង្គ្រាមប្រឆាំងកងទ័ពឈ្លានពានរបស់វៀតណាម ដែលគេហៅថាពួកពង្រីកទឹកដីលេបទឹកដីដែលមានមហិច្ឆតាឥតឈប់ឈរ ។ នៅពេលនោះគឺជាពេលដែលកងទ័ពខ្មែរក្រហម និង កងទ័ពវៀតណាម កំពុងវាយប្រហារគ្នាយ៉ាងខ្លាំងក្លានៅតាមទល់ដែន ។ អៀង សារី និយាយថា "ប្រសិនបើកម្ពុជាប្រជាធិបតេយ្យរបស់យើងមិនបានសុខសន្តិភាពទេ ដោយសារអំពើរំលោភឈ្លានពាន ឬ ដោយសារការជ្រៀតជ្រែកបញ្ហាផ្ទៃក្នុងនោះ ប្រទេសឯទៀតនៅក្នុងអាស៊ីភាគអាគ្នេយ៍នេះ ក៏មិនមានសន្តិភាព និង សន្តិសុខដែរ" ។ ចំពោះទំនាក់ទំនងទ្វេភាគីវិញ អៀង សារី បន្តក្នុងសុន្ទរកថារបស់គាត់ថា "យើងមិនត្រូវធ្វើអ្វីរំលោភលើសន្តិសុខគ្នាទៅវិញទៅមកនោះទេ ដូចជាសកម្មភាពឈ្លបយកការណ៍ ឬ ធ្វើអំពើវិទ្ធង្សនាគ្រប់យ៉ាង យើងមិនត្រូវអនុញ្ញាតឲ្យនរណាម្នាក់ប្រើប្រាស់ទឹកដីយើងដោយផ្ទាល់ ឬ ដោយប្រយោលក្នុង

ប្រការណាក៏ដោយ..... ដែលផ្ទុយពីសេចក្តីថ្លែងការណ៍រួមថៃ-កម្ពុជា នាខែ តុលា ១៩៧៥" ។ លោក អៀង សារី ចង់រំលឹកទៅដល់សកម្មភាពសម្ងាត់របស់ក្រុមខ្មែរមិនមែនកុម្មុយនីស្ត ឬ ខ្មែរសេរី ដែលផ្ទុងផ្តើម និង គាំទ្រដោយឧត្តមសេនីយថៃមួយចំនួន ។ យុទ្ធជនអ្នកតស៊ូប្រឆាំងខ្មែរក្រហមទាំងនោះ ត្រូវបានជ្រើសរើសក្នុងចំណោមជនភៀសខ្លួនខ្មែរ ដែលរស់នៅក្នុងជំរុំក្នុងប្រទេសថៃ នៅតាមតំបន់ទល់ដែន ។ ឆ្លើយតបចំពោះសុន្ទរកថារបស់លោក អៀង សារី រដ្ឋមន្ត្រីការបរទេសថៃ បាននិយាយថា "គឺ ជាការគួរឲ្យសោកស្តាយណាស់ ដែលយើងមានការមិនយល់គ្នានាពេលកន្លងមក ហើយមានអំពើខ្លះបានកើតឡើងដោយ ដៃមនុស្សទី ៣" ។

នរណាជាដៃទី៣?

នៅទីក្រុងបាងកក ឧត្តមសេនីយ គ្រឿងស័ក្តិ នាយករដ្ឋមន្ត្រីថៃបាននិយាយប្រាប់អ្នកសារព័ត៌មានអំពីតួនាទី "ដៃមនុស្សទី៣" ដែលគាត់ហាក់ដូចជាទទួលស្គាល់ថា ខ្មែរក្រហមមិនមែនជាអ្នកទទួលខុសត្រូវចំពោះការប៉ះទង្គិចនៅតាមទល់ដែននោះឡើយ ។ ក៏ប៉ុន្តែរដ្ឋាភិបាលថៃមិនបានបង្ហើបឲ្យដឹងថា តើនរណាដែលស្ថិតនៅពីក្រោយ "ដៃមនុស្សទី៣" នោះឡើយ ។ រឿងរ៉ាវដ៏ចម្លែករបស់កម្លាំងទីបី ឬ ដៃមនុស្សទី៣នេះ បានត្រូវបណ្តាញសារព័ត៌មានថៃ ទម្លាយឲ្យដឹងពីរខែក្រោយមក ។ រឿងនោះត្រូវបែកធ្លាយ នៅពេលដែលអាជ្ញាធរថៃចាប់បានគ្រឿងអាវុធមួយចំនួននៅស្រុកអារញ្ញប្រាថេត ។

កាលនោះគឺ នៅល្ងាចថ្ងៃទី ២០ ធ្នូ ១៩៧៧[60] នៅតាមផ្លូវក្នុងស្រុកអារញ្ញ ប្រាថេត ក្រុមកាយរិទ្ធដែលគេដាក់ឲ្យធ្វើការជួយប៉ូលីស បានរកឃើញគ្រឿងយុទ្ធ ភ័ណ្ឌដែលមានកាំភ្លើងAK 47 កាំភ្លើង M16 គ្រាប់បែក និង ស្បៀងមួយចំនួនដែល ត្រូវដឹកតាមរថយន្តប៊ុស (Bus) មួយ ដោយមានជនជាតិខ្មែរ ៣០ នាក់ និង ព្រះ សង្ឃ ៤ អង្គ ។ ប៉ូលីសបានចាប់រថយន្តនោះ ដោយស្មានថាជាការរត់ពន្ធគ្រឿងអា វុធ ហើយឃាត់ខ្លួនមនុស្សទាំងអស់នៅពេលនោះ ។ នៅទីបំផុតក្រុមខ្មែរទាំងនេះក៏ បានបង្ហាញនូវអត្តសញ្ញាណរបស់ខ្លួនថា ពួកគេជាសមាជិកចលនាតស៊ូខ្មែរប្រឆាំង កុម្មុយនីស្ត ដែលបានទទួលការគាំទ្រពីបញ្ជាការនៃកិច្ចប្រតិបត្តិការសន្តិសុខផ្ទៃក្នុង ថៃ (Internal Security Operations Command) អាយ អេស អូស៊ី (ISOC) ។ នៅពេលនោះ នាយប៉ូលីសក៏បានធ្វើការទាក់ទងជាមួយអង្គភាព អាយ អែស អូ ស៊ី ជាបន្ទាន់ ។ ស្អែកឡើង នាយទាហានថ្នាក់វរសេនីយឯករបស់អាយ អែស អូ ស៊ី ក៏បានមកដល់ទីកន្លែងទាំងព្រឹកព្រលឹម ហើយក៏បានសំរួលឲ្យមានការដោះលែង យុទ្ធជនខ្មែរទាំង ៣០ នាក់នោះ ។

ពួកខ្មែរទាំងនោះជាសមាជិកចលនាតស៊ូខ្មែរ ដែលបានទទួលការឧបត្ថម្ភ យ៉ាងខ្លាំង ពីព្រះសង្ឃថៃមួយអង្គព្រះនាមព្រះគ្រូ គិទិវុទ្ធោ ចៅអធិការវត្តចិត្តាផាវន្ត នៅជាប់មាត់សមុទ្រក្បែរទីក្រុងប៉ាតាយ៉ានៃប្រទេសថៃ ។ ព្រះសង្ឃថៃអង្គនេះ មាន ព្រះនាមល្បីល្បាញ ដោយលោកចេញមុខបង្ហាញគោលជំហរនយោបាយស្តាំជ្រុល និយមប្រឆាំងកុម្មុយនីស្តរបស់ព្រះអង្គ ។ លោកធ្លាប់ទេសនាពន្យល់ឧបាសកឧបា សិកាថា "សម្លាប់ពួកកុម្មុយនីស្តមិនបាបទេ" ។ ព្រះសង្ឃអង្គនេះធ្លាប់បញ្ចេញមតិ ថា លោកមិនខ្លាចលះបង់ស្បង់ចីវរ ដើម្បីកាន់អាវុធតស៊ូច្បាំងទល់ជាមួយកុម្មុយ នីស្តក្នុងការការពារជាតិ សាសនា និង រាជបល្ល័ង្កថៃ ។ ព្រះអង្គដើរតួនាទីដ៏សំខាន់

[60] Richard Nations, Busload of Trouble, Far Eastern Economic Review, March 10, 1978, p.10.

ក្នុងយុទ្ធសាស្ត្រប្រឆាំងកុម្មុយនីស្តរបស់ប្រទេសថៃ ។ ហេតុដូច្នេះ ទើបព្រះគ្រូ គិទិ វុទ្ធោ ធ្វើសកម្មភាពចិញ្ចឹមចលនាតស៊ូខ្មែរសេរី ឬ ខ្មែរសេរីកាយ៉ាងពេញទំហឹង ។ លោក អ៊ឹម ឈូដេត ដែលជាមេដឹកនាំចលនាខ្មែរសេរីកាម្នាក់ដែរនោះ គោរពប្រណិប័តព្រះគ្រូ គិទិវុទ្ធោ ជាគ្រូរបស់គាត់ផ្ទាល់ ។ មនុស្សរបស់លោក អ៊ឹម ឈូដេត មួយចំនួនធំ ដែលគេស្គាល់ថាជាសមាជិកចលនារាជសីហ៍ សុទ្ធតែធ្លាប់មកស្នាក់អាស្រ័យនៅវត្តចិត្តាផាវន្ត ដែលនៅទីនោះពួកគេតែងទទួលបាននូវម្ហូបអាហារ និងប្រាក់កាសពីព្រះគ្រូព្រះចៅអធិការ គិទិវុទ្ធោ ជានិច្ច ។

តាមធម្មតាព្រះគ្រូចៅអធិការអង្គនេះ មានខ្សែបណ្តាញរបស់លោកក្នុងចំណោមក្រុមស៊ើបការសំងាត់ថៃ ដែលបង្កប់ខ្លួននៅតាមជាយដែនខ្មែរ-ថៃ ។ បណ្តាញនេះ ជាអ្នកសម្រឹតសម្រាំងជ្រើសរើសជនកៀសខ្លួន ដែលឆ្លងដែនចូលមកក្នុងប្រទេសថៃតាមជំរុំក្តី ឬ ក្រៅជំរុំក្តី ហើយដែលចង់ចូលរួមចលនាតស៊ូខ្មែរប្រឆាំងកុម្មុយនីស្ត ។ នៅពេលណាដែលខ្សែបណ្តាញបានត្រួតពិនិត្យ តាមរយៈការធ្វើសម្ភាសន៍ជាច្រើនលើកច្រើនសាមក និង ដឹងច្បាស់ថាជនកៀសខ្លួនខ្មែរនោះប្រាកដជាមានបំណងចង់ចូលរួមក្នុងចលនាប្រឆាំងកុម្មុយនីស្តមែន ខ្សែបណ្តាញនឹងនាំជនកៀសខ្លួនទៅស្នាក់នៅវត្តចិត្តាផាវន្តជាបណ្តោះអាសន្ន ដើម្បីរង់ចាំជួបអ្នកទទួលខុសត្រូវខ្មែរសេរី ឬ ខ្មែរសេរីកា ។ តាមធម្មតា មនុស្សចំណូលថ្មីមិនទាន់អាចជួបព្រះគ្រូចៅអធិការភ្លាមទេ នៅពេលមកដល់វត្តចិត្តាផាវន្ត ។ ក៏ប៉ុន្តែ ព្រះគ្រូចាត់ចែងឲ្យទំនុកបំរុងបាយទឹកនំចំណីមិនឲ្យខ្វះឡើយ ។ មនុស្សសំខាន់ អាចដើរលេងតាមឆ្នេរសមុទ្ររបស់វត្ត និង ទទួលប្រាក់កាសខ្លះសម្រាប់ចាយវាយ ក្នុងរយៈពេលរង់ចាំនេះ ។

ច្រើនថ្ងៃបន្ទាប់មក ទើបអ្នកទទួលខុសត្រូវខ្មែរទៅដល់វត្តចិត្តាផាវន្ត ។ នៅ

ពេលដែលអ្នកទទួលខុសត្រូវខ្មែរ ទទួលយកមនុស្សថ្មីនោះថាជាសមាជិករបស់គេហើយ ទើបគេទាំងអស់គ្នានាំគ្នាទៅថ្វាយបង្គំលោកគ្រូចៅអធិការ ដើម្បីធ្វើពិធីស្បថស្បែសច្ចាប្រណិធាន ប្តេជ្ញាមិនក្បត់គ្នា និង សុំពរជ័យពីព្រះអង្គ។ អ្វីដែលគួរឲ្យចាប់អារម្មណ៍នោះគឺ ព្រះគ្រូ គិទិវុទ្ធោ ចាត់ឲ្យមានពិធីផឹកទឹកសម្បថ ដើម្បីឲ្យសមាជិកថ្មីប្តេជ្ញាធ្វើការចូលរួមតស៊ូដើម្បីរំដោះជាតិខ្មែរ និង ដើម្បីកសាងប្រទេសកម្ពុជាជាសាធារណរដ្ឋ ឲ្យមានសេរីភាពបរិបូណ៌ និង លទ្ធិប្រជាធិបតេយ្យពិតប្រាកដ ។ នៅសម័យនោះ គ្មាននរណានឹកថា ប្រទេសយើងអាចវិលមកយករបបរាជានិយម ជាពិសេស របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញដូចសព្វថ្ងៃនេះទេ ។ ម្យ៉ាងទៀតអ្នកណាក៏ដឹងដែរថា តាំងពីសម័យសង្គមរាស្ត្រនិយមរបស់សម្តេច នរោត្តម សីហនុ ក្នុងទសវត្សរ៍ឆ្នាំ ១៩៥០ និង ១៩៦០ មកម្ល៉េះ ប្រទេសថៃធ្លាប់ធ្វើជាជំរករបស់ក្រុមខ្មែរសេរីដឹកនាំដោយលោក សឺង ង៉ុក ថាញ់ ដែលសម្តេច សីហនុ ចោទថា ជាពួកសាធារណរដ្ឋប្រឆាំងព្រះរាជបល្ល័ង្កខ្មែរ ។ ដូច្នេះការជួយគាំទ្រអ្នកសាធារណរដ្ឋនិយមខ្មែរ ក៏អាចជាទម្លាប់របស់អ្នកនយោបាយថៃ ប្រឆាំងរបបគ្រប់គ្រងរាជានិយមខ្មែរបានយ៉ាងដូច្នោះដែរ ។ ក្នុងសកម្មភាពប្រឆាំងកុម្មុយនីស្តរបស់លោក ព្រះគ្រូ គិទិវុទ្ធោ ប្រាកដជាមានកិច្ចសហការដ៏ជិតស្និទ្ធពីកងទ័ពថៃមិនលែងឡើយ ។ លោកពិតជា សមាជិកដ៏សំខាន់មួយរូបនៃអ្វីដែលហៅថា "ដៃមនុស្សទី៣" ឬ "កម្លាំងទី៣" ដែលប្រើប្រាស់កងកម្លាំងប្រដាប់អាវុធខ្មែរសេរី ឬ ខ្មែរសេរីកា បង្កឲ្យមានការប៉ះទង្គិច ខាងផ្លូវអាវុធជាញឹកញាប់ជាមួយខ្មែរក្រហម ធ្វើឲ្យពួកខ្មែរក្រហមនេះវាយបកសងសឹកវិញទៅលើអ្នកស្រុកថៃ នៅតាមបណ្តាភូមិនានាជាប់ទល់ដែនខ្មែរ-ថៃ ។ ដូច្នេះ ឧត្តមសេនីយ គ្រឿងស័ក្តិ ប្រាកដជាដឹងថានរណាជា "ដៃមនុស្សទី៣" ឬ "កម្លាំងទី៣" នេះ ។

តាមពិតតាំងពីពេលពាក់កណ្តាលខែ មិថុនា ១៩៧៦ មកម្ល៉េះ នៅប្រទេស

បារាំង ខ្ញុំក៏បានឃើញអត្ថបទនៅក្នុងសារព័ត៌មានបារាំងមួយចំនួន និយាយអំពីចលនាតស៊ូតាមផ្លូវអាវុធប្រឆាំងនឹងក្រុមខ្មែរក្រហមនៅក្នុងប្រទេសកម្ពុជា ឧទាហរណ៍ដូចជា អត្ថបទស្តីអំពីយុទ្ធជនសម្ងាត់មួយក្រុមដើរឈ្លប និង ឃាតឈ្លាតក្នុងព្រៃក្នុងប្រទេសខ្មែរ ។ ក្រុមនោះមានមេដឹកនាំសុទ្ធតែជាអតីតនាយទាហាននៃរបបសាធារណរដ្ឋខ្មែរ ដែលធ្វើការតស៊ូ ដើម្បីរំដោះប្រទេសកម្ពុជាឲ្យមានសេរីភាព និង លទ្ធិប្រជាធិបតេយ្យឡើងវិញ ។

បើយើងសិក្សាឲ្យស៊ីជំរៅ អំពីយុទ្ធសាស្ត្រប្រឆាំងកុម្មុយនីស្តរបស់ថៃ "ដៃមនុស្សទី៣" ឬ "កម្លាំងទី៣" នេះជាកម្លាំងដែលបញ្ជាការកិច្ចប្រតិបត្តិការសន្តិសុខផ្ទៃក្នុងថៃ (អាយ អេស អូ ស៊ី) បង្កើតឡើង ដើម្បីទប់ទល់ដំណើររុលទៅមុខនៃប្រទេសឥណ្ឌូចិនទាំងបីនាសម័យនោះគឺ លាវ វៀតណាម និង កម្ពុជាប្រជាធិបតេយ្យ ។ បញ្ជាការកិច្ចប្រតិបត្តិការសន្តិសុខផ្ទៃក្នុងថៃ ប្រាកដជាបានអនុវត្តគោលនយោបាយរបស់ក្រុមប្រឹក្សាសន្តិសុខជាតិរបស់ប្រទេសថៃ ដែលអនុញ្ញាតឲ្យមានការលួចលាក់ចិញ្ចឹមកងកម្លាំង ដែលពីមុនមានឈ្មោះខ្មែរសេរី ឬ ក្រោយមកមានឈ្មោះថាខ្មែរសេរីកា ក៏ដូចជាលួចចិញ្ចឹមកងកម្លាំងវៀតណាមសេរី និង ឡាវសេរីដែរ ។ សកម្មភាពនៃអង្គភាពពិសេសរបស់កងទ័ព និង សកម្មភាពរបស់ព្រះគ្រូគិទិវិទ្ធោ ជារួមមានការជួយចិញ្ចឹមកងកម្លាំងដែលហៅថា "ខ្មែរសេរីកា" ទាំងអស់ ។ សមាជិកមួយចំនួននៃចលនាតស៊ូហៅថា រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ(រ.ជ.រ.ប.ខ) បាននិយាយប្រាប់ខ្ញុំយ៉ាងហូរហែ អំពីការពាក់ព័ន្ធរបស់អាជ្ញាធរថៃក្នុងជីវិតតស៊ូរបស់ពួកគេ ។

ទាហានថៃជួយយុទ្ធជនសេរីកា

សមាជិកម្នាក់ឈ្មោះ ឡេង បានរៀបរាប់ប្រវត្តិរបស់គាត់ ប្រាប់ខ្ញុំដូចតទៅ ៖ នៅខែ មេសា ១៩៧៥ នៅពេលដែលខ្មែរក្រហម ចូលដល់ទីរួមខេត្តបាត់ដំបង ប្រជាពលរដ្ឋទាំងអស់បានត្រូវពួកខ្មែរក្រហមជម្លៀស ឲ្យទៅរស់នៅស្រុកស្រែទាំងអស់ ។ ក្នុងសម័យនោះ ឡេង ជាសិស្សថ្នាក់ទីបញ្ចប់នៃវិទ្យាល័យ ។ ឡេង បានត្រូវខ្មែរក្រហមចាត់ឲ្យធ្វើការក្នុងក្រុមចល័ត ដែលត្រូវរើទីតាំងពីស្រុកមួយទៅស្រុកមួយឥតឈប់ឈរ ។ ក្នុងខែ កក្កដា ១៩៧៧ ឡេង ត្រូវបានគេប្រើឲ្យធ្វើជាអ្នកវាស់ដីនៅទំនប់កំពីងពួយ ភាគខាងលិចនៃប្រទេសកម្ពុជា ។ នៅទីនោះ ជាញឹកញាប់នៅពេលយប់ គេតែងឃើញយុទ្ធជនសេរីកាចំនួនបួន ឬ ប្រាំនាក់ ក្នុងសំលៀកបំពាក់ខ្មៅដូចខ្មែរក្រហម តែងមកធ្វើការឃោសនាបំផុសបំផុលប្រឆាំងខ្មែរក្រហម ។ ពួកយុទ្ធជនទាំងនោះ មានមូលដ្ឋានសម្ងាត់ដែលគ្មាននរណាដឹងឡើយ ។ ដោយមិនអាចទ្រាំទ្រចំពោះទារុណកម្មដែលពួកខ្មែរក្រហមធ្វើមកលើខ្លួន ដោយសារការខ្វះខាត និង ដោយចង់បានសេរីភាពផង ឡេង ព្រមជាមួយមិត្តរួមការងារម្នាក់ទៀតឈ្មោះ ជា បានសំរេចចិត្តលបរត់ចេញពីការត្រួតត្រារបស់ខ្មែរក្រហម ទៅរកមូលដ្ឋានសម្ងាត់របស់អ្នកតស៊ូនៅតាមព្រំដែនខ្មែរ-ថៃ ។

ដើម្បីត្រៀមដំណើរនោះ ពួកគេចាប់ផ្តើមលបលួចអង្ករយកទៅលាក់ទុកនៅក្នុងព្រៃ ។ ក្រោយដែលគេសន្សំបានអង្ករប្រហែលកន្លះគីឡូក្រាម ពួកគេក៏លបដាំបាយ ។ ថ្ងៃមួយគេលួចរត់ចេញពីភូមិ ។ បន្ទាប់ពីបានដើរដោយជើងទទេឆ្លងកាត់វាលស្រែដ៏ធំល្វឹងល្វើយ និង ព្រៃជ្រៅយ៉ាងក្រាស់អស់រយៈពេលមួយសប្តាហ៍ យុវជនដ៏ក្លាហានទាំងពីរនាក់ បានមកដល់ទល់ដែន ព្រោះពួកគេស្គាល់ទីនោះជាតំបន់

ភ្នំបន្ទាត់ ។ ពួកគេមិនដឹងថាមូលដ្ឋានពួកសេរីកានោះស្ថិតនៅតំបន់ណាទេ ក៏ប៉ុន្តែគេបានប្តេជ្ញាចិត្តថា ត្រូវតែទៅរួបរួមជាមួយពួកអ្នតស៊ូទាំងនោះ ប្រឆាំងខ្មែរក្រហមប៉ុល ពត ។ អស់ជាច្រើនថ្ងៃ ពួកគេមិនឃើញមានផ្ទះ ឬ ភូមិអ្នកស្រុកណាមួយសោះ ។ ពួកគេហេវហត់អស់កម្លាំងខ្លាំងណាស់ នៅពេលចូលទៅដល់ភូមិដាច់ស្រយាលមួយ ។

ពេលនោះ ពួកគេមិនទាន់ដឹងថា ខ្លួនបានចូលទៅក្នុងទឹកដីថៃនៅឡើយទេ ។ ព្រឹកនោះ នៅពេលឃើញផ្ទះទីមួយដំបូងបង្អស់ ពួកគេក៏ស្ទុះចូលទៅ ។ នៅក្នុងផ្ទះ មនុស្សម្នាក់កំពុងអង្គុយទទួលទានអាហារពេលព្រឹក ។ បុរសនោះ ជាមន្ត្រីនគរបាលព្រំដែនរបស់ថៃ ។ នៅពេលដែលក្រឡេកឃើញយុវជនខ្មែរទាំងពីរនាក់ភ្លាមនោះ នគរបាលថៃនេះមានការតក់ស្លុតណាស់ ព្រោះអ្នកទាំងពីរនាក់នោះចូលទៅដល់ទូដែលផ្ទុកទៅដោយកាំភ្លើង ។ នគរបាលថៃនឹកសង្ស័យថា ប្រហែលជាពួកខ្មែរក្រហមរំលោភឆ្លងដែនចូលមក ដោយហេតុតំបន់នេះជាតំបន់មានការប៉ះទង្គិចជាញឹកញាប់ជាមួយពួកខ្មែរក្រហម ។ ក៏ប៉ុន្តែយុវជនខ្មែរទាំងពីរនាក់នោះ មិនមានបំណងអាក្រក់អ្វីទៅលើរូបនគរបាលថៃនេះទេ ហើយថែមទាំងមិនដឹងខ្លួនថាពួកគេកំពុងឈរក្បែរទូកាំភ្លើងនោះទៀតផង ។ ម្យ៉ាងទៀត ពួកគេក៏មិនទាន់ដឹងថាកំពុងជាន់លើទឹកដីថៃផង ។ ដោយសារការខំប្រឹងធ្វើដំណើរជាច្រើនថ្ងៃនោះ ពួកគេអស់កម្លាំងខ្លាំងពេក មិនអាចហើបមាត់និយាយ ឬ ធ្វើកាយវិការអ្វីបានដោយស្រួលឡើយ ។

នគរបាលថៃនោះ ក៏ហៅជំនួយការខ្មែររបស់គាត់ឲ្យជួយបកប្រែ ព្រោះអ្នកទាំងពីរនាក់នោះមិនចេះនិយាយភាសាថៃសោះ ។ នៅទីបំផុត នគរបាលថៃក៏បានដឹងថា យុវជនខ្មែរទាំងពីរនាក់នោះ គ្មានចេតនាអាក្រក់ ឬ សកម្មភាពអមិត្តមកលើរូបគាត់ឡើយ ។ គាត់ក៏ឲ្យរៀបបាយទឹកឲ្យអ្នកទាំងពីរទទួលទាន រួចទើបបញ្ជូនទៅ

ទីស្នាក់ការនគរបាល ដើម្បីសួរចម្លើយ ព្រោះគេនៅសង្ស័យថាយុវជនទាំងពីរអាច ជាទាហានខ្មែរក្រហមមកបន្លំស៊ើបការណ៍ ។ នៅទីស្នាក់ការនគរបាលថៃ ឡេង និង ជា បានត្រូវគេដាក់ខ្នោះ និង ចងមុខបិទភ្នែក ។ មន្ត្រីនគរបាលម្នាក់ទៀតជាអ្នកសួរ ចម្លើយ ដោយជួនកាលមានទាំងភ្ជង់កាំភ្លើងផងតាមបច្ចេកទេសឈ្លេចសួរចម្លើយ ដើម្បីបញ្ជាក់ឲ្យច្បាស់ថាប្រាកដជាអ្នករត់ចេញពីខ្មែររបបក្រហម និង ពិតជាមិនមែន ទាហានខ្មែរក្រហមទេ ។ សំណួរមានជាអាទិដូចជាតើអ្នកឯងជាទាហានខ្មែរក្រហម ឬ?តើអង្គភាពអ្នកឯងនៅត្រង់ចំណុចណា ? តើមេអ្នកឯងឈ្មោះអ្វី ? ក៏ប៉ុន្តែចម្លើយ របស់អ្នកទាំងពីរនៅតែដដែលៗមិនផ្លាស់ប្តូរអ្វីឡើយគឺ៖ ពួកខ្ញុំមិនមែនជាទាហាន ខ្មែរក្រហមទេ ហើយក៏មិនស្គាល់មេទ័ពខ្មែរក្រហមណាម្នាក់ដែរ ពួកខ្ញុំដើរកក្រុម ខ្មែរតស៊ូប្រឆាំងខ្មែរក្រហម ព្រោះពួកខ្ញុំចង់ទៅចូលរួមជាមួយយុទ្ធជនសេរីកា ។ បន្ទាប់ពីសួរចម្លើយយ៉ាងយូរ យុវជនខ្មែរទាំងពីរនាក់នោះ ត្រូវបានគេបញ្ជូនតាមរថ យន្តទៅទីស្នាក់ការនគរបាលស្រុក ប្រចាំស្រុកប៉ុងណាំរ៉ង ដែលពួកគេទាំងពីរនាក់ បានទៅដល់នៅវេលាថ្ងៃត្រង់ ។ នៅទីនោះ ពួកគេមិនបានត្រូវដាក់ខ្នោះ ឬ ចងមុខ ដូចពីមុនទៀតទេ មិនតែប៉ុណ្ណោះថែមទាំងបានទទួលបាយទឹកជាថ្មីម្តងទៀតផង ។ ទោះបីជានៅមិនទាន់ដឹងអំពីជោគវាសនារបស់ពួកគេយ៉ាងណាក៏ដោយ ដោយសារ អត់ឃ្លានជាយូរថ្ងៃមកហើយនោះ អ្នកទាំងពីរគិតតែខំទទួលទានម្ហូបអាហារឲ្យបាន ច្រើន ។ នៅជាមួយខ្មែរក្រហម ពួកគេត្រូវធ្វើការងារជាទម្ងន់ ហើយទទួលទានតែ បបរតែប៉ុណ្ណោះ ។ នគរបាលនៅតែបន្តសួរសំណួរដដែលៗ ឯចម្លើយវិញ ក៏នៅតែ ដដែលៗមិនផ្លាស់ប្តូរអ្វីឡើយ ។

នៅពេលដែលពួកនគរបាលទាំងនោះ អស់មានក្តីមន្ទិលសង្ស័យលើយុវជន ខ្មែរទាំងពីរនាក់នោះហើយ និង ក្រោយពីដឹងថាពួកគេទាំងពីរនាក់ ពិតជាមាន បំណងទៅចូលរួមចលនាតស៊ូប្រឆាំងខ្មែរក្រហមប្រាកដមែន ទើបពួកនគរបាល

បញ្ជូនដំណឹងទៅនាយទាហានថៃម្នាក់ឲ្យធ្វើការស៊ើបសួរបន្តទៅទៀត ។ ពេលនោះ គេដឹកអ្នកទាំងពីរយ៉ាងរហ័ស ទៅក្នុងបរិវេណនៃទីបញ្ជាការទ័ពពិសេសថៃមួយ ដែលគ្មាននរណាអាចដឹងទីកន្លែងច្បាស់លាស់បានឡើយ ព្រោះទីកន្លែងនោះមានសភាពហាក់ដូចជាផ្ទះសម្បែងរបស់អ្នកស្រុកធម្មតា ។ អង្គភាពយោធាពិសេសនេះមានមួយឈុតដែលមានថ្នាក់ដឹកនាំម្នាក់ និង នាយទាហានពីរនាក់ ។ ពួកទាហានទាំងនោះមិនស្លៀកពាក់ ឬ បង្ហាញសញ្ញាថាពួកគេជាកងទ័ពនោះឡើយ ។ នៅទីនោះ ឡេង និង ជា ត្រូវទាហានថៃឃុំឃាំងក្នុងរថយន្តដ៏ធំមួយ អស់រយៈពេលប្រហែលមួយសប្តាហ៍ ។ នៅពេលនោះ អ្នកទាំងពីរនាក់ក៏បានសំគាល់ថាមានជនជាតិខ្មែរពីរនាក់ទៀតធ្វើការនៅទីនោះដែរ ជាអ្នកដាំបាយ ដាំតែ ឬ បោសសំអាត ។ នៅក្នុងបរិវេណទីស្នាក់ការទាហានឈុតពិសេសនេះ ឡេង និង មិត្តរបស់គេ មិនត្រូវជាប់ខ្នោះទៀតឡើយ ។ ក្រោយមក ទើបគេអនុញ្ញាតឲ្យអ្នកទាំងពីរទៅរស់នៅបន្ទប់មួយក្បែរនោះ ។ ក្នុងនោះ គេឲ្យទៅជួយធ្វើការដូចខ្មែរពីរនាក់ទៀតនោះដែរគឺ ជួយដាំបាយ និង បោសសំអាត ។ បន្ទាប់មកក្រុមយោធាក៏ធ្វើសម្ភាសន៍អ្នកទាំងពីរម្តងទៀតដែលមានសំណួរខ្លះដូចសំណួររបស់នគរបាលដែរ តែមានមួយចំនួនទៀតមានលក្ខណៈច្បាស់លាស់ជាង ដូចជាសំណួរថាតើអ្នកទាំងពីរនាក់ចេះធ្វើអ្វីខ្លះ? ចេះនិយាយភាសាអ្វីខ្លះ? មួយខែបន្ទាប់មក ក្រោយពីបានរស់នៅក្រោមការត្រួតពិនិត្យយ៉ាងហ្មត់ចត់នោះ ទាហានថៃក៏សួរ ឡេង និង ជា ថាតើអ្នកទាំងពីរនាក់ចង់ទៅចូលរួមជាមួយក្រុមសេរីកាមែន ឬ ក៏ចង់ទៅកាន់ជំរុំជនភៀសខ្លួន ឬ ក៏ចង់វិលត្រឡប់ទៅប្រទេសកម្ពុជាវិញ ។

នៅពេលដែលយោធាថៃប្រាកដក្នុងចិត្តថា ឡេង និង ជា ពិតជាចង់ចូលរួមក្នុងក្រុមសេរីកាមែន ពួកគេក៏ដឹកអ្នកទាំងពីរទៅកន្លែងយោធាមួយទៀត នៅក្នុងទីរួមខេត្តត្រាត ។ ពីត្រាត គេបញ្ជូនតាមរថយន្ត ទៅបរ៉ាយ ជាទីកន្លែងដឹករកត្បូង

នៅក្នុងខេត្តច័ន្ទបូរី ។ នៅបរ៉ាយ ពួកថៃនាំពួកគេទាំងពីរនាក់ទៅកន្លែងមួយឆ្ងាយពីគេឯង ។ នៅទីនោះ គេឃើញមានឃ្លាំងមួយដ៏ធំ ដែលគេទុកស្បៀងរាប់រយបាវ ។ នៅក្នុងឃ្លាំងនោះ គេឃើញកម្មករប្រមាណជាប់នាក់និយាយភាសាខ្មែរ កំពុងប្រញឹកដៃលី ឬ សែងបាវអង្ករ ត្រីងៀត ប្រេងឆា និង របស់របរជាច្រើនមុខទៀត ។ ប៉ុន្មាននាទីក្រោយមក អ្នកទាំងនោះក៏នាំស្បៀងទាំងនោះ ធ្វើដំណើរចូលព្រៃបាត់ទៅ ។ កន្លះម៉ោងក្រោយមក មនុស្សមួយក្រុមទៀតក៏មកដល់ ។ ក្នុងចំណោមនោះ ឡេង អាចសំគាល់ឃើញមិត្តចាស់របស់គេម្នាក់ឈ្មោះ ភាព ដែលទំនងដូចជាមេផ្នែកព័ស្តុការនៃក្រុមទាំងពីរ ។ នៅពេលគេអាចនិយាយខ្មែរបានជាមួយ ភាព ទើបឡេងដឹងថា នៅទីបំផុតខ្លួនបានជួបជាមួយនឹងក្រុមអ្នកតស៊ូខ្មែរមែន ។ ក៏ប៉ុន្តែ ភ្លាមនោះ ឡេង និង ជា មិនអាចចូលទៅជាមួយនឹងពួកខ្មែរទាំងនោះបានទេ ព្រោះពួកគេត្រូវរង់ចាំរហូតដល់យោធាថៃមួយឈុតទៀត ក្នុងសំលៀកបំពាក់ស៊ីវិល លេចចេញពីក្នុងព្រៃមក ដោយជិះម៉ូតូជប៉ុនផង មកប្រាប់ឲ្យពួកគេទាំងពីរនាក់ដើរតាមយុទ្ធជនខ្មែរអ្នកតស៊ូទៅមូលដ្ឋានរបស់គេ នៅប៉ុន្មានគីឡូម៉ែត្រឆ្ងាយពីនោះ ។ នៅពេលគេដើរដល់ជើងភ្នំបន្ទាត់ ឡេង ឃើញខ្នមមួយ ដែលមានប្រក់សំពត់ប្លាស្ទីកទំហំប្រាំម៉ែត្របួនជ្រុង ប្រដាប់ដោយគ្រឿងសម្ភារៈពេទ្យបន្តិចបន្តួច ដែលនោះជាផ្ទះពេទ្យរបស់អ្នកតស៊ូ ។ នៅក្នុងផ្ទះពេទ្យនេះ មានពេទ្យខ្មែរជាអ្នកគ្រប់គ្រង ពួកគេកំពុងព្យាបាលអ្នកជម្ងឺខ្មែរ ប្រាំ ឬ ប្រាំមួយនាក់ ដែលកំពុងមានជម្ងឺគ្រុនចាញ់ ។ បន្ទាប់ពីដើរអស់រយៈពេលពីរម៉ោងមកទៀត ដោយឆ្លងកាត់អូរ និង ឡើងចុះទួលខ្ពស់ជាច្រើនមក នៅទីបំផុត ទាំងអស់គ្នាក៏ឡើងទៅដល់កំពូលភ្នំ ។

នៅពេលគេទៅដល់ច្រកចូលនៃទីបញ្ជាការយោធា ដែលស្ថិតក្នុងព្រៃលើភ្នំនោះ ឡេង សង្កេតឃើញទាហានខ្មែរកាន់កាំភ្លើងនៅដៃ ឈរតាមដើមឈើធំៗ នៅក្នុងព្រៃដ៏ក្រាស់ ដែលពន្លឺថ្ងៃស្ទើតែជ្រៀតចូលពុំបាន ។ នៅក្នុងជំរុំយោធានោះ

ឡេង ឃើញខ្ទមឫស្សីបួន ។ ខ្ទមមួយជារបស់មេទ័ពខ្មែរ និង ខ្ទមមួយទៀតជារបស់ក្រុមយោធាថៃ ដែលឈរជើងនៅទីនោះ ដើម្បីប្រមូលព័ត៌មាន និង ដើម្បីសំរបសំរួលផ្តល់ការគាំទ្រផ្នែកភស្តុភារដល់ក្រុមអ្នកតស៊ូ ។ នៅទីបំផុត គេក៏នាំ ឡេង ឲ្យទៅជួបនឹងមេដឹកនាំខ្មែរគឺ លោកវរសេនីយ ព្រុំ វិត ដែលទទួលស្វាគមន៍ ឡេង យ៉ាងរាក់ទាក់ និង កក់ក្តៅ ។ លោកវរសេនីយ បានត្រូវកូនចៅគាត់ ហៅថា "លោកតា" ។ គាត់មានបុគ្គលិកលក្ខណៈគួរឲ្យចាប់អារម្មណ៍គឺ មានសម្បុរខ្មៅ តែរូបរាងមាំទាំខែងរែង ស្លៀកខោខ្លី និង បង់កក្រមា ។

លោកតាមានការគោរពរាប់អានពីកូនចៅគាត់ ដោយសារគាត់ជាមេទ័ពដែលមានគោលការណ៍ច្បាស់លាស់គឺជាអ្នកតស៊ូដែលគោរពវិន័យ ។ នៅពេលនោះ សមាជិកចលនាទទួលស្គាល់ថា លោកតាបានយកជីវិតមកបំរើផលប្រយោជន៍រួម និង ដើម្បីរំដោះប្រទេសកម្ពុជាឲ្យចេញពីអំណាចផ្តាច់ការរបស់ពួកខ្មែរក្រហម ។ នេះជាករណីដែលបង្ហាញថានៅពេលនោះ ប្រាកដជាមានកងទ័ពខ្មែរសេរី ឬ សេរីកាដែលទទួលការឧបត្ថម្ភគាំទ្រដោយទាហានថៃ ។

មែនទែនទៅ នៅសម័យនោះ ចលនាតស៊ូប្រឆាំងខ្មែរក្រហម ទោះជាមានការចងកំហឹង និង ស្អប់ខ្ពើមខ្មែរក្រហមដល់កំរិតណាក៏ដោយ ក៏មិនអាចធ្វើសកម្មភាពអ្វីធំដុំ ដែលអាចឲ្យពួកប្រល័យពូជសាសន៍នេះ រង្គោះរង្គើ ឬ ព្រួយបារម្ភបានឡើយ ។ ម្យ៉ាង ការក្តាប់យ៉ាងណែននូវការគ្រប់គ្រងប្រជាពលរដ្ឋឲ្យរស់នៅតាមរបៀបសមូហភាពដ៏តឹងតែង មានធ្វើការជាទម្ងន់ និង បាយរួមជាដើមរបស់រដ្ឋអំណាចខ្មែរក្រហម[61] បង្កើតឧបសគ្គដ៏ធំដល់រាល់ការប៉ុនប៉ងរើបំរះ ឬ ការបះបោរពីសំណាក់ចលនា ឬ ក្រុមប្រឆាំងណាមួយ ដែលមានទីជំរកនៅតាមទល់ដែន ជា

[61] សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន បានវាយតម្លៃត្រឹមត្រូវល្អណាស់ចំពោះឧបសគ្គនៃការរើបំរះ នៅក្នុងសៀវភៅក្រោមចំណងជើង "១៣ ទសវត្សរ៍ នៃដំណើរកម្ពុជា" ការផ្សាយរបស់កាសែតប្រជាជនឆ្នាំ ១៩៩៦ ទំព័រ ២៣៤-២៣៧ ។

ពិសេស នៅទល់ដែនខ្មែរ-ថៃ ។ ម្យ៉ាងទៀត ជំនួយដែលប្រទេសថៃផ្តល់ដល់ចលនាតស៊ូប្រឆាំងខ្មែរក្រហមមានកំរិតតិចតួចណាស់ ។ ថៃត្រូវតែមានការប្រុងប្រយ័ត្នខ្ពស់ក្នុងសកម្មភាពប្រឆាំងខ្មែរក្រហមរបស់ពួកគេ ព្រោះនៅពីក្រោយខ្មែរក្រហមមានប្រទេសចិនដ៏ធំមហិមា ដែលមានឥទ្ធិពលដ៏ខ្លាំងចំពោះសន្តិសុខផ្ទាល់របស់ប្រទេសថៃ ។

នៅសម័យនោះ ប្រទេសថៃកំពុងស្ថិតនៅក្នុងបរិបទនៃតំបន់មួយដែលទាមទារឲ្យមានកិច្ចសហការល្អជាមួយប្រទេសចិន ជាជាងធ្វើសកម្មភាពប្រឆាំងប្រទេសដ៏ធំនៃទ្វីបអាស៊ីនេះ ។ ដូច្នេះ នៅសម័យនោះ ប្រទេសថៃមិនអាចជាបង្អែកដ៏រឹងមាំសម្រាប់ធ្វើការផ្តួលរំលំរបបប្រល័យពូជសាសន៍កម្ពុជាប្រជាធិបតេយ្យបានឡើយ ។ ថៃជួយចិញ្ចឹមដោយលួចលាក់នូវកម្លាំងខ្មែរសេរី ឬ ខ្មែរសេរីកាដើម្បីយកធ្វើជាឧបករណ៍ទុកសម្រាប់ជាថ្នូរដោះដូរជាមួយខ្មែរក្រហម និង ចិនក្នុងការរក្សាសន្តិសុខរបស់គេតែប៉ុណ្ណោះ ។ កម្លាំងតស៊ូដែលអាចផ្តួលរំលំរបប ប៉ុល ពត បាន មានតែកម្លាំងខ្មែរអ្នកតស៊ូផ្ទៃក្នុង ហើយដែលមានការគាំទ្រពីប្រទេស ដែលហ៊ានចេញមុខវាយប្រហាររបបនេះតែប៉ុណ្ណោះ ។ ព្រឹត្តិការណ៍ដែលកើតមានជាបន្តបន្ទាប់ក្រោយៗមក បានបញ្ជាក់នូវនិន្នាការនៃសច្ចធម៌នេះ ។

ជម្លោះរវាងខ្មែរក្រហម និង វៀតណាម

ប្រសិនបើជម្លោះរវាងខ្មែរក្រហម និង ថៃ មានប្រភពដើមចេញពីមនោគមវិជ្ជាកុម្មុយនីស្ត ប្រឆាំងលទ្ធិមូលធននិយម ជម្លោះរវាងខ្មែរក្រហម និង វៀតណាម ដែលជាយុទ្ធមិត្តជាមួយគ្នានោះ កើតឡើងដោយសារមូលហេតុដទៃជាច្រើន ។

ម្យ៉ាង មហាប្រទេសកុម្មុយនីស្តពីរគឺចិន និង សហភាពសូវៀត[62] ដែលមានឥទ្ធិពលលើខ្មែរក្រហម និង វៀតណាម មានជម្លោះរវាងគ្នានិងគ្នា ។ ជម្លោះរវាងមហាប្រទេសកុម្មុយនីស្តនោះ បានជះផលប៉ះពាល់ទៅលើប្រទេសដែលដើរតាមពួកគេ ។

ការខ្វែងគំនិតគ្នារវាងចិន និង សហភាពសូវៀត មានរាប់សិបឆ្នាំមកហើយ គឺ មានតាំងពីទសវត្សរ៍ឆ្នាំ ១៩៦០ មកម្ល៉េះ ។ ជាដំបូង មានការខ្វែងគំនិតគ្នាក្នុងមនោគមវិជ្ជាកុម្មុយនីស្តនេះ ដែលបានចាប់ផ្តើមឡើងទៅទសវត្សរ៍ឆ្នាំ ១៩៥០ នៅពេលដែលសហភាពសូវៀត បោះបង់លែងប្រកាន់យកនូវរបបស្តាលីននិយម ឬ បន្ទាប់ពីលោកសេនាប្រមុខ ស្តាលីន ទទួលមរណភាពទៅ ។ ប្រទេសចិនបានចោទសហភាពសូវៀតថា ជាអ្នកសើរើនិយម ។ ចិនផ្តន្ទាទោសសហភាពសូវៀតចំពោះអ្វីដែលគេហៅថាអនុត្តរភាពរបស់សូវៀតនៅក្នុងពិភពលោក ។ ចិនប្រឆាំងនឹងនយោបាយរបស់សហភាពសូវៀតនៅអឺរ៉ុបខាងកើត ជាពិសេស ចំពោះព្រឹត្តិការណ៍នៅឆេកូស្លូវ៉ាគី នាឆ្នាំ ១៩៦៨ ។ ចិនចាត់ទុកសហភាពសូវៀតថា ជាសង្គមចក្រពត្តិ និង ថានយោបាយក្រៅប្រទេសរបស់សហភាពសូវៀត ជានយោបាយវាតទី ឬ អនុត្តរភាពនិយម ។

ជម្លោះទល់ដែនរវាងមហាប្រទេសទាំងពីរដែលបានផ្ទុះឡើងនៅឆ្នាំ ១៩៦៩ រឹតតែនាំឲ្យចិនមើលឃើញថា សហភាពសូវៀតគំរាមកំហែងយ៉ាងខ្លាំង ទៅលើសន្តិ

[62] សហភាពសូវៀត ជាបណ្តុំប្រទេសកាន់លិទ្ធិកុម្មុយនីស្ត ចំនួន ១៥ ដែលមានរដ្ឋធានីរួមនៅទីក្រុង ម៉ូស្គូ ក្រោមអំណាចរបស់គណបក្សកុម្មុយនីស្ត ។ ក្រោយសង្គ្រាមត្រជាក់ត្រូវបញ្ចប់ នៅពេលដែលសហភាពសូវៀតដួលរលំ ក្នុងឆ្នាំ១៩៩១ ប្រទេសទាំង ១៥ នោះបានប្រកាសជារដ្ឋឯករជ្យគឺ: រុស្សី (Russia) អ៊ុយក្រែន (Ukraine) ម៉ុលដាវី (Moldova) បេឡារុស(Belorussia) អាមេនី (Amenia) អាស៊ែបៃហ្សង់ (Azerbaijan) កាហ្សាក់ស្តាន (Kazakhstan) អ៊ូសបេគីស្តាន (Uzbekistan) តួកម៉េនីស្តាន(Turkmenistan) កៀហ្ស៊ីស៊ីស្តាន(Kyrgystan) តាជីគិស្តាន (TajiKistan) អេសតូនី (Estonia) ឡាត់វី (Latvia) លីធួនី (Lithuania) ។ នៅក្នុងសង្គ្រាមត្រជាក់ សហភាពសូវៀតជាមេនៃប្តូកលោកកុម្មុយនីស្តប្រឆាំងនិងប្តូកលោកសេរី ដែលមានសហរដ្ឋអាមេរិកជាមេដឹកនាំ ។

សុខរបស់គេ ។ ចិនយល់ឃើញថា ពួកគេមានផលប្រយោជន៍យ៉ាងខ្លាំង ក្នុងការធ្វើសហប្រតិបត្តិការជាមួយសហរដ្ឋអាមេរិក និង លោកខាងលិច ដើម្បីប្រឆាំងនិងអនុត្តរភាពរបស់សហភាពសូវៀត ។ ម្យ៉ាងទៀត មេដឹកនាំចិនមើលឃើញថាកិច្ចសហប្រតិបត្តិការនោះ អាចនាំប្រទេសចិនទៅរកទំនើបភាវូបនីយកម្មដែលជាដំហានដ៏ចាំបាច់ឆ្ពោះទៅអភិវឌ្ឍប្រទេសជាតិរបស់គេឲ្យរីកចំរើនផង ។ លោក តេង ស៊ាវពីង[63] ដែលបានគេចខ្លួនរួចផុតយ៉ាងអស្ចារ្យពីការសម្លាប់ នាសម័យបដិវត្តន៍វប្បធម៌ ជាស្ថាបត្យករនៃទំនើបភាវូបនីយកម្មនេះ ។ មេដឹកនាំចិនរូបនេះ បានបញ្ចេញពាក្យសុភាសិតរបស់គាត់ថា "ឆ្មាសម្បុរអ្វីក៏បានដែរ ឲ្យតែវាចាប់កណ្តុរ" ។ ទំនើបភាវូបនីយកម្មបួនយ៉ាងរបស់ប្រទេសចិននោះគឺ៖ ទំនើបភាវូបនីយកម្មនៃកសិកម្ម ទំនើបភាវូបនីយកម្មនៃឧស្សាហកម្ម ទំនើបភាវូបនីយកម្មនៃបច្ចេកវិជ្ជា និង ទំនើបភាវូបនីយកម្មនៃផ្នែកការពារប្រទេស ។ នយោបាយទំនើបភាវូបនីយកម្មទាំងបួនយ៉ាងនេះ បានដើរស្របគ្នាជាមួយទ្រឹស្តីរបស់ចិនដែលគេហៅថា "ទ្រឹស្តីលោកបី" ដែលនៅក្នុងនោះ ចិនចាត់ទុកសហរដ្ឋអាមេរិក និង សហភាពសូវៀតជាលោកទី១ ប្រទេសអភិវឌ្ឍនៃលោកខាងលិចដូចជា៖ បារាំង អង់គ្លេស អាល្លឺម៉ង់ អូស្ត្រាលី និងកាណាដាជាលោកទី២ ហើយចំណែកឯប្រទេសកំពុងលូតលាស់ឯទៀត ជាលោកទី៣ ឬ តតិយលោក ។ ដោយប្រើយុទ្ធវិធីឡោមព័ទ្ធស្រុកស្រែឲ្យជាប់អស់ ដើម្បីឈានទៅវាយយកទីក្រុង មេដឹកនាំចិន បានធ្វើការលួងលោមអន្ទង លោកទី២ និងលោកទី៣ ឲ្យរួមគ្នាទប់ទល់នឹងឥទ្ធិពលលោកទី១ ។ ក៏ប៉ុន្តែ នៅសម័យនោះ ចិនបានវិភាគឃើញថា ក្នុងលោកទី១ មានការខុសគ្នារវាងសហភាពសូវៀត និងសហរដ្ឋអាមេរិក ។ នៅសម័យនោះ ចិនសំគាល់ថាសហភាពសូវៀត ជាមហា

[63] ពីដំបូង គេហៅមេដឹកនាំចិនរូបនេះថា តេង ស៊ាវពិង (Teng Xiaoping) ក្រោយមកគេហៅថា ដេង ហ្សៅពីង (Deng Xiaoping) ទៅវិញ។

អំណាចវាយលុកគេ (Offensive power) រីឯសហរដ្ឋអាមេរិកគ្រាន់តែជាមហាអំណាចរង់ចាំការពារខ្លួន (Defensive power) តែប៉ុណ្ណោះ ។ ដូច្នេះ សហការជាមួយសហរដ្ឋអាមេរិកមិនមានគ្រោះថ្នាក់ដល់ចិនទេ ។ ជាពិសេស ចាប់តាំងពីសហរដ្ឋអាមេរិក បានដកកងទ័ពចេញពីវៀតណាម ។ ដូច្នេះចិនមានផលប្រយោជន៍យ៉ាងខ្លាំងក្នុងការទាក់ទងអូសទាញឲ្យសហរដ្ឋអាមេរិក និង ប្រទេសលោកខាងលិចរាប់រកខ្លួន ដើម្បីទប់ទល់នឹងការរីកចម្រើនទីនិយមរបស់សហភាពសូវៀត ។

ចាប់តាំងពីប្រទេសឥណ្ឌូចិនកុម្មុយនីស្តទាំងបី (លាវ វៀតណាម កម្ពុជា) បានទទួលជ័យជំនះនៅឆ្នាំ ១៩៧៥ ចិនដែលធ្លាប់តែនិយាយថាទំនាក់ទំនងរវាងវៀតណាម និង ចិន[64] មានការជិតស្និទ្ធគ្នាដូចជាធ្មេញ និង បបូរមាត់ បានមើលឃើញថាវៀតណាមឈរនៅក្នុងជួរសហភាពសូវៀតទៅវិញ មិនឈរនៅខាងចិនឡើយ ។ អ្នកវិភាគនយោបាយនៅលោកខាងលិច បានអះអាងថាប្រទេសវៀតណាម ទោះបីជាបានទទួលជំនួយដ៏ច្រើនសន្ធឹកសន្ធាប់ និង កិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធជាមួយចិនអស់ជាច្រើនឆ្នាំក៏ដោយ ក៏វៀតណាមនៅតែមិនទាន់អាចបំភ្លេចបាននូវអនុស្សាវរីយ៍ដ៏ជូរចត់ ស្តីពីការត្រួតត្រារបស់ចិនលើវៀតណាមអស់រយៈពេលមួយពាន់ឆ្នាំកន្លងមកនោះឡើយ ។ អ្នកវិភាគនយោបាយទាំងនោះអះអាងទៀតថានៅពេលដែលអ្នកដឹកនាំវៀតណាម ឡេ យន់ ទៅធ្វើទស្សនកិច្ចនៅប្រទេសចិន ក្នុងខែ កញ្ញា ១៩៧៥ លោក តេង ស៊ាវពីង បានអំពាវនាវម្តងរួចហើយឲ្យវៀតណាមដកខ្លួនថយចេញពីឥទ្ធិពលសូវៀត ។ គេបន្ថែមទៀតថា នៅពេលលោក ឡេ យន់ ធ្វើទស្សនកិច្ចនៅប្រទេសចិនម្តងទៀតក្នុងខែ វិច្ឆិកា ១៩៧៧ អ្នកដឹកនាំវៀតណាមរូបនេះ បានសង្កេតឃើញថានយោបាយទំនើបភាវូបនីយកម្មរបស់

[64] ចំណុចទាំងឡាយដែលខ្ញុំលើកមកសរសេរនេះ ជាការវិភាគនយោបាយចេញផ្សាយតាមសារព័ត៌មាន លោកខាងលិចដែលខ្ញុំបានអាន ។

ចិន មានភាពលំអៀង ឬ មានភាពអនុគ្រោះទៅលោកខាងលិច ។ ពេលនោះ លោក ឡេ យន់ បានឲ្យចិនដឹងថាក្រុងហាណូយ មិនទាន់ត្រៀមខ្លួនដកចេញពីឥទ្ធិពលសូវៀតនៅឡើយទេ ។ អ្នកវិភាគនយោបាយបានគូសបញ្ជាក់ថាអ្នកដឹកនាំវៀតណាមមានការមិនពេញចិត្ត ព្រោះថាចាប់តាំងពីឆ្នាំ ១៩៧៥ មក ចិនមិនដែលផ្តល់ជំនួយយោធាដល់វៀតណាមទេ ផ្ទុយទៅវិញ ចិនបានផ្តល់ជំនួយយោធាដល់ខ្មែរក្រហមយ៉ាងសន្ធឹកសន្ធាប់ ។ លើសពីនេះទៅទៀត នៅពេលដែលខ្មែរក្រហមមានជម្លោះទល់ដែនជាមួយវៀតណាមនៅខែ ធ្នូ ១៩៧៧ ចិនគាំទ្រខ្មែរក្រហមដោយស្រែកបន្ទរថាវៀតណាមជាអ្នកឈ្លានពានកម្ពុជា ។ ចិនគាំទ្រខ្មែរក្រហម និងសរសើរខ្មែរក្រហមចំពោះការខំប្រឹងប្រែងការពារបូរណភាពទឹកដីរបស់ខ្លួន ។

នៅថ្ងៃទី ៣០ ធ្នូ ១៩៧៧ ខ្មែរក្រហម បានប្រកាសកាត់ផ្តាច់ចំណងការទូតជាមួយវៀតណាមជាបណ្តោះអាសន្ន នៅពេលដែលមានការវាយប្រហារគ្នាយ៉ាងខ្លាំងក្លានៅតាមទល់ដែន ។ ខ្មែរក្រហមបានចោទវៀតណាមថា ប៉ុនប៉ងបង្កើតគណបក្សកុម្មុយនីស្តថ្មីមួយក្នុងចំណោមជនក្បត់បក្ស ។ នៅក្នុងបទសម្ភាសន៍ជាមួយអ្នកសារព័ត៌មានយូហ្គោស្លាវីនៅភ្នំពេញ នាយករដ្ឋមន្ត្រីខ្មែរក្រហម ប៉ុល ពត បានឲ្យដឹងថា វៀតណាមមានបំណងដាក់បញ្ចូលប្រទេសកម្ពុជាទៅក្នុងសហព័ន្ធឥណ្ឌូចិន[65] ដែលនៅក្នុងនោះ ជនជាតិវៀតណាមរាប់លាននាក់អាចមករស់នៅក្នុងទឹកដីខ្មែរ ។ ប៉ុល ពត យល់ឃើញថា តែនៅក្នុងរយៈពេលសាមសិបឆ្នាំតែប៉ុណ្ណោះ ប្រជាពលរដ្ឋខ្មែរអាចនឹងក្លាយទៅជាជនជាតិភាគតិច ។ ជាធម្មតា ប្រទេសវៀតណាមបានបដិសេធនូវពាក្យចោទប្រកាន់នោះ ហើយបានបកស្រាយថាក្រុមខ្មែរក្រហមកំពុងបង្កើតបញ្ហាផ្ទៃក្នុងដោយខ្លួនឯង ។

[65] Nayan Chanda, Vietnam Prepares for a Long War, Far Eastern Economic Review, April 21, 1978, pp.17-22.

អ្នកជំនាញខាងកុម្មុយនីស្តឥណ្ឌូចិនបានបកស្រាយថាគណបក្សកុម្មុយនីស្តខ្មែរមានពីរខ្សែ[66] ។ ខ្សែទី១ ជាអ្នកជិតស្និទ្ធជាមួយវៀតណាម និង គាំទ្ររណសិរ្សរួមប្រឆាំងច្រក្រពត្តិនិយម ។ ខ្សែនេះប្រកាន់គោលជំហរសាមគ្គីបដិវត្តន៍ ខ្មែរ លាវ និង វៀតណាម ។ ខ្សែទី២គឺ ជាក្រុមដែលចាត់ទុកសម្តេច សីហនុ ថាជាសក្តិភូមិ គឺជាមុខសញ្ញាដែលត្រូវតែកំទេច រួមទាំងការទម្លាក់ពីអំណាចផង ។ ពួកនេះប្រកាន់គោលនយោបាយរបស់បក្សកុម្មុយនីស្តមួយដែលគេថា ឯករាជ្យ មិនចំណុះបក្សខាងក្រៅ ជាពិសេស បក្សវៀតណាម ។ វៀតណាមបានគាំទ្រខ្សែទី១ តាំងពីដើមរៀងមក ។ អ្នកជំនាញខាងកុម្មុយនីស្តឥណ្ឌូចិនបានអះអាងថា អ្នកដឹកនាំវៀតណាមតែងរំលឹកថា នៅពេលដែលខ្មែរក្រហមនៅទន់ខ្សោយនៅឡើយ ពួកខ្មែរក្រហម បានសុំឲ្យវៀតណាមធ្វើសង្គ្រាមជំនួសខ្លួន វៀតណាមក៏ធ្វើតាម ។ បន្ទាប់ពីវៀតណាម បានកំទេចប្រតិបត្តិការយោធារបស់ លន់ នល់ ឈ្មោះ ចេនឡាទី២ ពួកខ្មែរក្រហម ក៏សុំឲ្យវៀតណាមដកខ្លួនថយចេញ វៀតណាមក៏ព្រមធ្វើតាម ។ ក៏ប៉ុន្តែ ប៉ុល ពត មិនដែលទទួលស្គាល់ថា វៀតណាមបានជួយខ្លួននៅគ្រាដំបូងនៃសង្គ្រាមប្រឆាំង លន់ នល់ នោះឡើយ ។ ដូច្នេះទីក្រុងហាណូយ ក៏ខឹងសម្បារយ៉ាងខ្លាំងចំពោះ ប៉ុល ពត ព្រោះអ្នកដឹកនាំវៀតណាមយល់ថា ខ្មែរក្រហមរមិលគុណ ។ អ្នកជំនាញបានមើលឃើញថា អ្នកដឹកនាំវៀតណាមចង់ឲ្យមានទំនាក់ទំនងពិសេសរវាងវៀតណាម និង កម្ពុជា ដូចរវាង វៀតណាម និង លាវ ដែរ បំណាច់បានជួយខ្មែរក្រហមឲ្យបានជោគជ័យជាស្ថាពរ លើកងទ័ពសាធារណរដ្ឋ លន់ នល់ ។ អ្នកជំនាញទាំងនោះបានធ្វើវិភាគថា យោងតាមបទពិសោធន៍ពីមុនមក ពួកខ្មែរតែងមានការព្រួយបារម្ភខ្លាចក្រែងវៀតណាម ដែលមានប្រជាពលរដ្ឋរហូតដល់៧០លាននាក់នោះ អាចហៀរចូលមកលើទឹកដីខ្មែរ ។ អ្នកដឹកនាំជាតិនិយមខ្មែរភាគច្រើន

[66] Asiaweek, Where does it leave Sihanouk, April 21, 1978 p.15.

ធ្លាប់រំលឹកថា ទឹកដីវៀតណាមខាងត្បូងបច្ចុប្បន្នធ្លាប់ជាទឹកដីខ្មែរ ។ ទឹកដីនេះបានត្រូវបាត់បង់ទៅ ដោយសារតែការហូរចូលមកក្នុងទឹកដីខ្មែរនៃពួកអន្តោប្រវេសន៍វៀតណាម ។ តាមពិតទៅ គណបក្សកុម្មុយនីស្តឥណ្ឌូចិន ដែលរួមមានវៀតណាម ខ្មែរ និង លាវកុម្មុយនីស្ត ធ្លាប់បានចេញសេចក្តីថ្លែងការណ៍បង្កើតសហព័ន្ធនៃប្រទេសទាំងបី បន្ទាប់ពីបានរំដោះចេញពីអំណាចត្រួតត្រារបស់បារាំង ។ ក៏ប៉ុន្តែចាប់តាំងពីរំលាយគណបក្សកុម្មុយនីស្តឥណ្ឌូចិននៅឆ្នាំ ១៩៥១ មក គំនិតបង្កើតសហព័ន្ធនេះក៏ត្រូវបានបោះបង់ចោលទៅ ។ ពួកអ្នកវិភាគអះអាងថា ដោយឈរលើមូលដ្ឋានយុទ្ធមិត្ត យុទ្ធសាមគ្គី អ្នកដឹកនាំវៀតណាមទទូចឲ្យមានទំនាក់ទំនងពិសេសជាមួយលាវ និង កម្ពុជា ។ ពួកអ្នកវិភាគរៀបរាប់ថា ក៏ប៉ុន្តែពួកខ្មែរក្រហមឆ្លើយតបទៅវៀតណាមវិញថា ពួកគេមិនចង់បានទំនាក់ទំនងពិសេសអ្វីទេ ទំនាក់ទំនងធម្មតាគ្រប់គ្រាន់ណាស់ទៅហើយ ។

បើនិយាយតាមអ្នកវិភាគបញ្ហាបក្សកុម្មុយនីស្តឥណ្ឌូចិនដែលថា បក្សកុម្មុយនីស្តខ្មែរមានពីរខ្សែនោះ បក្សរបស់ ប៉ុល ពត គឺ ប្រាកដជាមិនមែនខ្សែទី១ ដែលមានទំនាក់ទំនងល្អជាមួយវៀតណាមនោះឡើយ ។ ប៉ុល ពត ស្អប់ខ្ពើមណាស់ចំពោះយុទ្ធមិត្តរបស់គាត់ដែលធ្លាប់រៀនសូត្រនៅហាណូយ ។ គួរកត់សំគាល់ដែរថា ក្រុមកុម្មុយនីស្តខ្សែទី១នេះ ក៏ធ្លាប់ផ្តល់ការគាំទ្រជាយុទ្ធវិធី ឬ កលយុទ្ធ ដល់សម្តេច សីហនុ ដោយសារនយោបាយអព្យាក្រឹតភាពរបស់ព្រះអង្គ ។ ផ្ទុយទៅវិញ ក្រុមខ្សែទី២ដែលមាន ប៉ុល ពត នៅក្នុងនោះ បានបង្ហាញឲ្យឃើញនូវនយោបាយជាតិនិយមមួយ ដើម្បីបក្សកុម្មុយនីស្តខ្មែរឯករាជ្យពីវៀតណាម និង មានគោលនយោបាយប្រឆាំងនឹងរបបសម្តេច សីហនុ ផង ។ អ្នកបដិវត្តន៍កុម្មុយនីស្តរាប់ពាន់នាក់ ដែលធ្លាប់សិក្សារៀនសូត្រ និង ស្នាក់នៅក្នុងប្រទេសវៀតណាមខាងជើង តាំងពីឆ្នាំ ១៩៥៤ ត្រូវបានអ្នកវិភាគវាយតម្លៃថា ជាក្រុមខ្សែទី១ ដែលមានគោលជំហរ

សម្រុះសម្រួល និង សហការជាមួយសម្តេច សីហនុ ។ បន្ទាប់ពីព្រឹត្តិការណ៍ ១៨ មីនា ១៩៧០ ភ្លាម អ្នកទាំងនោះបានចូលរួមយ៉ាងសកម្ម ក្នុងរណសិរ្សរួបរួមជាតិកម្ពុជា ដែលមានសម្តេច សីហនុ ជាប្រធាន ។ ចាប់ពីឆ្នាំ ១៩៧១ មក អ្នកបដិវត្តទាំងនោះ បានចាប់ផ្តើមវិលត្រឡប់មកកម្ពុជាវិញ ។ ភ្លាមៗនោះ ប៉ុល ពត បានធ្វើការព្រមានដល់អ្នកបដិវត្តទាំងនោះថា ពួកគេត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់មជ្ឈឹមបក្សគឺ នៅក្រោមបញ្ជាផ្ទាល់របស់ ប៉ុល ពត ហើយមិនត្រូវមកបង្កាប់បញ្ជា ប៉ុល ពត ឡើយ ។ ដូច្នេះ ពួកអ្នកបដិវត្តទាំងនោះបានត្រូវ ប៉ុល ពត ចាត់ទុកជាមុខសញ្ញា ដែលត្រូវកំទេចតាមនយោបាយសម្រឹតសម្រាំងបក្សជាបន្តបន្ទាប់ ។ ដោយសារការកាប់សម្លាប់ជាទូទៅដែល ប៉ុល ពត យកមកអនុវត្ត ដើម្បីក្តាប់អំណាចរបស់ខ្លួន រួមទាំងការកាប់សម្លាប់កម្មាភិបាលជាន់ខ្ពស់របស់បក្សកុម្មុយនីស្តខ្មែរផង ចលនាប្រឆាំងផ្ទៃក្នុងក៏លេចចេញឡើងជារូបរៀង និង ទ្រង់ទ្រាយផ្សេងៗ តូចក៏មាន ធំក៏មាន តែភាគច្រើនជាការតស៊ូសម្ងាត់ ។

ចលនាតស៊ូផ្ទៃក្នុងប្រឆាំង ប៉ុល ពត

តាំងពីចុងឆ្នាំ ១៩៧៤[67] ក្រុមអ្នកតស៊ូមួយ នៅខេត្តកោះកុងដែលដឹកនាំដោយលោក សាយ ភូថង លោក ទៀ បាញ់ និង លោក រ៉ុង ផ្លាមកៃសន ព្រមទាំងកងទ័ពប្រមាណ ២ កងវរសេនាតូច និង ប្រជាពលរដ្ឋមួយចំនួនផង បានផ្តាច់ខ្លួនពីពួក ប៉ុល ពត ចូលទៅរស់នៅក្នុងប្រទេសថៃ ។ ចំណែកនៅឯភូមិភាគ

[67] ក្រុមស្រាវជ្រាវ ឆយ យីហ៊ាង ប្រែង ពីសិដ្ឋ លេង ណៃគីម មុិល វាសនា ភិន ណារ៉ុង ម៉ម សារិត ជា មុនីឫទ្ធិ គិន ភាៈ ក្នុងសៀវភៅ ក្រោមចំណងជើង "សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន, នាយករដ្ឋមន្ត្រីប្រសូតចេញពីត្រកូលកសិករ", រោងពុម្ព ពន្លឺពេជ្រ, ភ្នំពេញ ២០០៧ ទំព័រ ៧៩ ។

ឡៀសាន ក្នុងខេត្តតេនគីរី ចាប់តាំងពីចុងឆ្នាំ ១៩៧៥[68] ក៏មានចលនាប្រឆាំង ប៉ុល ពត ដែរដែលមានលោក ប៊ុន មី លោក ប៊ូ ថង និង លោក ស៊ើយ កែវ ជាអ្នកដឹកនាំ នៅក្នុងតំបន់មួយ ដែលមានប្រជាពលរដ្ឋមួយចំនួន និង កងកម្លាំងប្រមាណ ២ កងវរសេនាតូចផង ។ ចលនាប្រឆាំងទាំងនោះ បានធ្វើឲ្យ ប៉ុល ពត រឹតតែចង កំហឹង និង បង្កើនការបោសសំអាតផ្ទៃក្នុងកាន់តែសាហាវឡើងៗ និង ក្នុងទ្រង់ទ្រាយកាន់តែធំ ។ ជាមួយគ្នានោះ ការប៉ះទង្គិចខាងផ្លូវអាវុធជាមួយវៀតណាម ក៏កាន់តែញឹកញាប់ឡើង ។

ក្នុងចំណោមការតស៊ូរើបំរះចេញពីរបប ប៉ុល ពត ប្រវត្តិតស៊ូរបស់ប្រធានសេនាធិការកងវរសេនាធំមួយរូប ដែលនៅកំពុងស្ថិតក្នុងភាពយុវវ័យនៅឡើយ នៅសម័យនោះ បានបង្ហាញនូវការប្តេជ្ញាចិត្តដ៏មុះមត់ និង សេចក្តីក្លាហានដ៏រឹងមាំអស្ចារ្យកម្រមាន នៅក្នុងប្រវត្តិសាស្ត្រកម្ពុជា រហូតដល់សម្រេចជោគជ័យផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត បានទាំងស្រុង ។ ប្រវត្តិតស៊ូនោះគឺ ជាប្រវត្តិរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន បច្ចុប្បន្នជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង ជាអ្នកដឹកនាំខ្មែរជំនាន់ក្រោយមួយរូបចេញពីត្រកូលកសិករ ដែលគួបដិបក្ខខាងនយោបាយស្ទើរទាំងអស់ វាយតម្លៃខុសខាងសមត្ថភាពការងារដឹកនាំ ។

ហ៊ុន សែន ចេញប្រឆាំង ប៉ុល ពត

ក្រោយព្រឹត្តិការណ៍ ១៨ មីនា ១៩៧០ យុវជន ហ៊ុន ប៊ុនណាល់ កាលនោះមានអាយុ ១៨ ឆ្នាំ បានស្ម័គ្រចិត្តចូលរួមក្នុងរណសិរ្សរួបរួមជាតិកម្ពុជា ដែលមាន

[68] ដូចយោងខាងលើ ។

សម្តេច នរោត្តម សីហនុ ជាប្រធានតាមសេចក្តីអំពាវនាវរបស់ព្រះអង្គផ្សាយតាមវិទ្យុប៉េកាំង ឲ្យប្រជារាស្ត្រត់ចូលព្រៃម៉ាគី ក្រោកឡើងកាន់អាវុធប្រឆាំងពួកលន់ នល់-សិរិមតៈ ដែលបានធ្វើរដ្ឋប្រហារទម្លាក់សម្តេចពីតំណែងព្រះប្រមុខរដ្ឋ ។ នៅពេលចូលរួមចលនាតស៊ូនោះ យុវជននេះបានប្តូរឈ្មោះជា ហ៊ុន សំរេច ហើយត្រូវបានចាត់ឲ្យចូលទៅហ្វឹកហាត់ ធ្វើជាយុទ្ធជននៃកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា[69] ។

ពីរសប្តាហ៍ក្រោយមកយុវជន ហ៊ុន សំរេច បានទទួលមុខនាទីជាមេបញ្ជាការកងអនុសេនាតូច ដែលមានទាហាន ៣៦ នាក់នៅក្រោមបញ្ជា ។ តាមរយៈថ្វីដៃដឹកនាំ និង ជោគជ័យជាបន្តបន្ទាប់នៅលើសមរភូមិប្រយុទ្ធនៅចុងឆ្នាំ ១៩៧៤ នាយទាហានដ៏ក្មេងនេះ បានត្រូវតម្លើងតួនាទីជាមេបញ្ជាការកងវរសេនាតូច បញ្ជាលើយុទ្ធជន ៥០០ នាក់ ។ គឺនៅក្នុងតួនាទីថ្មីនេះហើយ ដែលមេបញ្ជាការរូបនេះបានប្តូរឈ្មោះជាថ្មីម្តងទៀតពី ហ៊ុន សំរេច មកជា ហ៊ុន សែន រហូតមក ។ មួយថ្ងៃមុនកងទ័ពរណសិរ្សរួបរួមជាតិកម្ពុជា រំដោះទីក្រុងភ្នំពេញពីរបបសាធារណរដ្ឋខ្មែររបស់លោក លន់ នល់ គឺ នៅព្រឹកថ្ងៃទី ១៦ មេសា ១៩៧៥ យុវមេបញ្ជាការ ហ៊ុន សែន បានទទួលរងរបួសភ្នែកខាងឆ្វេង នៅលើសមរភូមិខេត្តកំពង់ចាមហើយត្រូវបានបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យ ។ ក្នុងរយៈពេលចូលរួមក្នុងជួររណសិរ្សរួបរួមជាតិកម្ពុជា លោក ហ៊ុន សែន បានសង្កេតឃើញជាតុពិតនៃរណសិរ្សនេះ ដែលមិនមែនដឹកនាំដោយសម្តេច នរោត្តម សីហនុ នោះទេ តែស្ថិតនៅក្រោមការគ្រប់គ្រងទាំងស្រុងរបស់ខ្មែរក្រហម ។ ជាមួយគ្នានេះ នយោបាយកាប់សម្លាប់ និង អំពើ

[69] នេះជាឈ្មោះផ្លូវការ នៅសម័យនោះ របស់កងទ័ពរណសិរ្សរួបរួមជាតិកម្ពុជា ដែលមានសម្តេច នរោត្តម សីហនុ ជាប្រធាន (Forces Armées Populaires de Libération Nationale du Kampuchea) ក្រោយ មកមានឈ្មោះជាកងទ័ពបដិវត្តកម្ពុជា ។

រំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងររបស់ខ្មែរក្រហម មកលើប្រជាពលរដ្ឋខ្មែរដ៏ស្លូតត្រង់ បានធ្វើឲ្យលោកមេបញ្ជាការ ហ៊ុន សែន ចងកំហឹងយ៉ាងខ្លាំង និង មានគំនឹតរើបំរះចេញពីរបបព្រៃផ្សៃប្រល័យជាតិឯងនោះ ។ នៅខែ សីហា ឆ្នាំ ១៩៧៥ លោក ហ៊ុន សែន ត្រូវបានតម្លើងតួនាទីជាប្រធានសេនាធិការនៃកងវរសេនាធំ ដែលឈរជើងនៅស្រុកមេមត់ ខេត្តកំពង់ចាម ក្នុងតំបន់ ២១ នៃភូមិភាគបូព៌ា និង ដែលមានទាហានក្រោមបញ្ជាចំនួន ២០០០ នាក់ ។ តួនាទីថ្មីនៅក្នុងជួរកងទ័ព រឹតតែផ្តល់មធ្យោបាយបន្ថែមគឺ កងកម្លាំងយោធាកាន់តែច្រើន បង្កើនលទ្ធភាពដល់លោក ហ៊ុន សែន ឲ្យធ្វើការតស៊ូប្រឆាំងរបបប្រល័យពូជសាសន៍ ប៉ុល ពត ។

ក្នុងសម័យនោះ ការគ្រប់គ្រងរបស់ខ្មែរក្រហមមានចែកជា៖ អង្គការមជ្ឈឹម ដែលនៅក្រោមអំណាចផ្ទាល់របស់ ប៉ុល ពត និង ភូមិភាគមួយចំនួន ។ ភូមិភាគនីមួយៗចែកជាតំបន់ ឯតំបន់ចែកជាស្រុក ។ ក្នុងឆ្នាំ ១៩៧០-១៩៧៥ ភូមិភាគនីមួយៗសុទ្ធតែស្វយ័ត និង មានកងទ័ពផ្ទាល់របស់ខ្លួន ។ ចាប់ពីថ្ងៃជ័យជំនះ ១៧ មេសា ១៩៧៥ មក មជ្ឈឹមបង្កើនការសម្រឹតសម្រាំងកម្មាភិបាលក្នុងជួរគណបក្សកុម្មុយនីស្តកម្ពុជា និង ប្រើអំណាចទៅក្តាប់ឲ្យណែននូវការគ្រប់គ្រងភូមិភាគទាំងអស់ ។ ប៉ុល ពត មានការចាំបាច់ត្រូវធ្វើការបោសសំអាតកម្មាភិបាលភូមិភាគបូព៌ា ដែលភាគច្រើនធ្លាប់បានទៅសិក្សារៀនសូត្រ អស់រយៈពេលជាច្រើនឆ្នាំ នៅវៀតណាម ឬ ដែលមានទំនាក់ទំនងយ៉ាងល្អជាមួយទីក្រុងហាណូយ ។ ភូមិភាគបូព៌ាមានខេត្តមួយចំនួនជាប់ជាមួយប្រទេសវៀតណាមដូចជាខេត្ត ព្រៃវែង ស្វាយរៀង ទឹកដីខ្លះក្នុងខេត្តកំពង់ចាម និង ខេត្តកណ្តាល ព្រមទាំងមានលោក សោ ភឹម ដែលធ្លាប់ជាអ្នកតស៊ូប្រឆាំងអាណានិគមនិយមបារាំងក្នុងទសវត្សរ៍ឆ្នាំ ១៩៤០ ជាលេខាបក្ស ។ ម្យ៉ាងទៀតចាប់តាំងពីពេលប្រកាសរដ្ឋធម្មនុញ្ញ[70] នៃកម្ពុជាប្រជាធិប

[70] របបកម្ពុជាប្រជាធិបតេយ្យបានអនុម័តរដ្ឋធម្មនុញ្ញថ្មីនេះនៅខែ មករា ១៩៧៦ ។

តេយ្យរបស់ខ្មែរក្រហមនៅខែ មេសា ១៩៧៦ មក លោក សោ កឹម ក៏ទទួលមុខតំណែងជាអនុប្រធាននៃគណៈប្រធានរដ្ឋដែលមានលោក ខៀវ សំផន ជាប្រធាន។ នៅខែ មេសា ១៩៧៦ នោះដែរ ប្រធានកងពលធំម្នាក់នៃភូមិភាគបូព៌ាឈ្មោះ ចាន់ ចក្រី[71] បានត្រូវចោទប្រកាន់ថាប៉ុនប៉ងធ្វើរដ្ឋប្រហារ ។ ចាន់ ចក្រី ត្រូវបានចាប់ខ្លួននៅខែ ឧសភា ហើយដោយសារការរៀបធ្វើទារុណកម្មសួរចម្លើយខ្លាំងពេក ចាន់ ចក្រី ក៏បង្ខំចិត្តឆ្លើយសារភាព ។ ក្នុងចម្លើយសារភាព ចាន់ ចក្រី ធ្វើឲ្យមានការពាក់ព័ន្ធដល់កម្មាភិបាលសំខាន់ៗមួយចំនួន និង ប្រទេសវៀតណាមផង ។ នៅឆ្នាំ ១៩៧៧ យុទ្ធមិត្តរបស់លោក ហ៊ុន សែន ប្រមាណ ៥០ នាក់ បានត្រូវចាប់ខ្លួនជាបន្តបន្ទាប់ ។

នៅពាក់កណ្តាលអធ្រាត្រថ្ងៃទី ២០ ឈានចូលទី ២១ មិថុនា ១៩៧៧ លោក ហ៊ុន សែន និង មនុស្សជំនឹតបួននាក់ទៀត បានសម្រេចចិត្តចេញដំណើរឆ្លងកាត់ព្រំដែន ចូលទៅក្នុងប្រទេសវៀតណាម ដើម្បីសុំជំនួយពីកងទ័ពប្រទេសជិតខាងនេះ ដែលកំពុងមានទំនាស់ជាមួយរបប ប៉ុល ពត ផងនោះ ឲ្យមកជួយរំដោះប្រជាពលរដ្ឋខ្មែរពីអំពើប្រល័យពូជសាន៍ ប៉ុល ពត ឲ្យទាន់ពេលវេលា ។ គួរបញ្ជាក់ថានៅសម័យនោះ ប្រទេសវៀតណាម ទោះបីជាកំពុងមានការប៉ះទង្គិចខាងផ្លូវយោធាដ៏ញឹកញាប់ជាមួយកម្ពុជាប្រជាធិបតេយ្យយ៉ាងណាក៏ដោយ ក៏អាជ្ញាធរវៀតណាមនៅបន្តចាប់បញ្ជូនមកកម្ពុជាវិញនូវជនភៀសខ្លួនខ្មែរ ដែលលបលួចឆ្លងកាត់ទល់ដែនចូលក្នុងទឹកដីវៀតណាម លើកលែងតែជនភៀសខ្លួនណា ដែលបានចូលជ្រៅទៅដល់ទីរួមខេត្ត ឬ ទីក្រុងសំខាន់ៗ ដូចជាទីក្រុងព្រៃនគរជាដើម ទើបរួចខ្លួន ។ ដូច្នេះលោក ហ៊ុន សែន បានគិតក្នុងចិត្តជាស្រេចថា ប្រសិនបើវៀតណាមមិនជួយ ហើយបែរជាបញ្ជូនពួកលោកមកកម្ពុជាវិញនោះ លោកនឹងរកវិធីធ្វើអត្ត

[71] ចាន់ ចក្រី ក៏កាន់តំណែងជាលេខាបក្សតំបន់ ២៤ នៃភូមិភាគបូព៌ាដែរ យោងតាមឯកសារតុលាការ អ.ស.ប-កម្ពុជា ។

ឃាតសម្លាប់ខ្លួនឯងភ្លាមមិនឲ្យធ្លាក់ចូលក្នុងកណ្តាប់ដៃ ប៉ុល ពត វិញបានឡើយ ។ ជាមួយនិងក្តីបារម្ភខ្លាចក្រែងអាជ្ញាធរវៀតណាមចាប់បញ្ជូនមកឲ្យ ប៉ុល ពត ក៏មានគ្រោះថ្នាក់ដល់អាយុជីវិតមួយទៀតគឺ គ្រាប់មីនដែលបង្កប់ពាសពេញនៅតាមទល់ដែនខ្មែរ-វៀតណាម ដែលអាចបង្កក្តីអន្តរាយដោយមិនដឹងខ្លួននៅពេលឆ្លងកាត់ ។

នៅវេលាម៉ោង ២ ទៀបភ្លឺថ្ងៃទី ២១ មិថុនា ១៩៧៧ ក្រុមលោក ហ៊ុន សែន បានឆ្លងចូលទៅក្នុងទឹកដីវៀតណាមដោយសុវត្ថិភាព រួចក៏សម្រាកនៅទីនោះរង់ចាំដល់ពេលភ្លឺ ទើបបន្តដំណើរតទៅទៀត ។ ព្រឹកឡើង ក្រុមលោក ហ៊ុន សែន នាំគ្នាធ្វើដំណើរតាមផែនទី ឆ្ពោះទៅភូមិមួយឈ្មោះ ហលី ក្នុងស្រុក ឡុក និញ ។ ក្រុមអ្នកភ្លាហានទាំងនោះ បានទៅដល់នៅម៉ោងប្រហែល ១៤មនា០ នាទី ។ ជាទូទៅ វាសនារបស់ជនជាតិខ្មែរ ដែលឆ្លងដែនដោយខុសច្បាប់ ចូលទៅក្នុងទឹកដីប្រទេសជិតខាង មានមិនសូវខុសគ្នាឡើយ ។ ពួកគេត្រូវឃាត់ខ្លួន ចាប់សួរចម្លើយ និង ជាប់ឃុំឃាំងមួយរយៈពេល ទម្រាំអាជ្ញាធរនៃប្រទេសជិតខាងនោះធ្វើសេចក្តីសម្រេចជាចុងក្រោយ ទៅតាមករណីនីមួយៗ ។ នៅសម័យនោះ ជនរួមជាតិខ្មែរដែលឆ្លងចូលក្នុងទឹកដីថៃ ក៏ជួបប្រទះរឿងរ៉ាវបែបនេះ អ្នកដែលឆ្លងចូលក្នុងទឹកដីវៀតណាមក៏ជួបប្រទះរឿងរ៉ាវដូចគ្នាដែរ ។ កាលពេលនោះ អ្វីដែលខុសគ្នាគឺនៅប្រទេសថៃ អាជ្ញាធររបស់គេ មានអង្គការចាត់តាំងសម្ងាត់ចាំទទួលអ្នកស្ម័គ្រចិត្តឲ្យចូលទៅបំរើចលនាប្រឆាំង ប៉ុល ពត នៅពេលដែលរដ្ឋាភិបាលថៃ មិនមានលទ្ធភាពចេញមុខវាយប្រហារក្នុងទ្រង់ទ្រាយធំ ដើម្បីផ្តួលរំលំរបបខ្មែរក្រហមសោះនោះ ។ ចំណែកនៅឯប្រទេសវៀតណាម ពេលវេលាហាក់ដូចជាមិនទាន់មកដល់ដើម្បីប្រទេសនេះចេញមុខជួយផ្តួលរំលំរបប ប៉ុល ពត នៅឡើយទេ ។ គេត្រូវរង់ចាំដល់ដំណាច់ឆ្នាំ ១៩៧៧ នៅពេលដែលអ្នកដឹកនាំខ្មែរក្រហមប្រកាសជាសធារណៈថា ពួកគេកំពុងធ្វើសង្គ្រាមប្រឆាំងវៀតណាមឈ្លានពាន និង ប្រកាសផ្តាច់ចំណង

ការទូតរវាងប្រទេសទាំងពីរ ។ ដូច្នេះ ករណីក្រុមលោក ហ៊ុន សែន ក៏ស្ថិតនៅក្នុងបរិបទនៃទំនាក់ទំនងរវាងវៀតណាម និង កម្ពុជាប្រជាធិបតេយ្យនាសម័យនោះ ។ ក្រុមរបស់លោកត្រូវបានអាជ្ញាធរវៀតណាម សង្ស័យថាជាពួកទាហានស៊ើបការណ៍ឲ្យ ប៉ុល ពត ដូច្នេះត្រូវសួរចម្លើយ សួរហើយសួរទៀត ពីកន្លែងមួយទៅកន្លែងមួយ ពីទីស្នាក់ការភូមិហាលី ទៅមន្ទីរឃុំឃាំងស្រុកឡុកនិញ រហូតទៅជាប់ក្នុងមន្ទីរឃុំឃាំងយោធាខេត្តសុងបៃ អស់រយៈពេល ២២ ថ្ងៃ ។ ដោយសារចម្លើយដដែលៗ និង ការយល់ដឹងយ៉ាងច្បាស់លាស់អំពីបញ្ហា និង ភូមិសាស្ត្រយោធារបស់លោក ហ៊ុន សែន អាជ្ញាធរវៀតណាមក៏ចាប់ផ្តើមជឿថាលោកពិតជានាយទាហានជាន់ខ្ពស់ម្នាក់ ដែលកំពុងស្វែងរកជំនួយ ដើម្បីធ្វើការតស៊ូប្រឆាំងរបបប្រល័យពូជសាសន៍ ប៉ុល ពត មែន ។

នៅថ្ងៃទី ២៧ កញ្ញា ១៩៧៧ លោក ហ៊ុន សែន ត្រូវបានអនុញ្ញាតឲ្យជួបជាមួយនាយទាហានថ្នាក់ឧត្តមសេនីយនៃអគ្គសេនាធិការកងទ័ពវៀតណាម និងជាសមាជិកការិយាល័យនៃគណបក្សកុម្មុយនីស្តមួយរូប ។ នៅក្នុងជំនួបនោះលោក ហ៊ុន សែន បានស្នើសុំឲ្យប្រទេសវៀតណាម ឈប់ចាប់បញ្ជូនជនភៀសខ្លួនដែលឆ្លងចូលមកក្នុងទឹកដីវៀតណាមទៅឲ្យ ប៉ុល ពត វិញ ព្រមទាំងផ្តល់សិទ្ធិជ្រកកោននយោបាយដល់កម្មាភិបាលខ្មែរក្រហមណា ដែលមានបំណងរត់ចេញពីរបបប្រល័យពូជសាសន៍ មករស់នៅៗក្នុងប្រទេសវៀតណាម ។ សំណើសុំទាំងពីរចំណុចនេះ ខាងអាជ្ញាធរវៀតណាមអាចផ្តល់បានភ្លាម ។ ជាមួយគ្នានោះ លោក ហ៊ុន សែន ក៏ទទូចសុំឲ្យវៀតណាមផ្តល់ជំរកសុវត្ថិភាព និង ជំនួយយោធា ជាពិសេស អាវុធ និង ស្បៀងដល់ចលនាតស៊ូ ឬ ដល់កងកម្លាំងថ្មី ដែលត្រូវកសាងដើម្បីវាយរំដោះប្រជាពលរដ្ឋខ្មែរពីរបបប្រល័យពូជសាសន៍ ប៉ុល ពត ។ តាមពិតទៅគឺ ចំណុចចុងក្រោយទាំងនេះទេ ដែលលោក ហ៊ុន សែន ប្រាថ្នាចង់បានជាងគេ

ព្រោះជាគោលបំណងចម្បងនៃការកៀសខ្លួនរបស់ពួកលោក នៅក្នុងទឹកដីវៀតណាមនាពេលនោះ ។ ក៏ប៉ុន្តែប្រទេសវៀតណាមបដិសេធ ព្រោះគេជៀសវាងការចោទប្រកាន់ពីបទជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់កម្ពុជា ។ ជំហរបែបនេះ ធ្វើឲ្យលោក ហ៊ុន សែន មានការសោកស្តាយជាខ្លាំង ។

នៅក្នុងឆ្នាំ ១៩៧៧ កងទ័ពវៀតណាម និង កងទ័ពខ្មែរក្រហមមានការប៉ះទង្គិចគ្នារឹតតែញឹកញាប់ និង ទ្រង់ទ្រាយធំ ជាពិសេស នៅខែ មេសា គឺ នៅពេលដែលកងទ័ពខ្មែរក្រហម ធ្វើការវាយប្រហារយ៉ាងព្រហើន លើទីប្រជុំជនវៀតណាម នៅ ទិញបៀន និង ភូមិមួយចំនួន នៅក្នុងខេត្តអានយ៉ាង តាមដងទន្លេមេគង្គ ដែលធ្វើឲ្យជនស៊ីវិលស្លាប់អស់ជាច្រើននាក់ ។ វៀតណាមធ្វើការវាយតបវិញរួមទាំងការទំលាក់គ្រាប់បែកតាមយន្តហោះផង ជាមួយនិងការព្យាយាមចរចាដែរ តែពុំបានសំរេច ។ នៅថ្ងៃទី ២៤ កញ្ញា ១៩៧៧ ពួកខ្មែរក្រហមបើកការវាយប្រហារទ្រង់ទ្រាយធំជាលើកទី២ នៅតែនិញ ដោយធ្វើឲ្យជនស៊ីវិលបាត់បង់ជីវិតអស់ច្រើនរយនាក់។ នៅក្នុងខែ តុលា និង វិច្ឆិកា កងទ័ពវៀតណាម បានវាយប្រហារតបវិញយ៉ាងខ្លាំងនៅខេត្តស្វាយរៀង ។ នៅខែ ធ្នូ កងទ័ពនេះបន្តវាយក្នុងទ្រង់ទ្រាយធំ តាមទល់ដែន នៅខេត្តកំពង់ចាម ក្រចេះ និង តាកែវ ដែលធ្វើឲ្យកងទ័ពខ្មែរក្រហមទទួលបរាជ័យជាដំណំ ។ ក្នុងការវាយបកវិញនោះ កងទ័ពវៀតណាមបានចូលមកកាន់កាប់ស្រុកស្នួលនៃខេត្តក្រចេះ ស្រុកទ្រមូង[72] ស្រុកពញាក្រែក ស្រុកត្បូងឃ្មុំ ស្រុកមេមត់នៃខេត្តកំពង់ចាម ។ ឆ្លៀតក្នុងពេលនោះ លោក ហ៊ុន សែន ក៏បានចូលមកពិនិត្យសភាពការណ៍ផ្ទាល់នៅលើទឹកដីខ្មែរ ។ ក៏ប៉ុន្តែ លោក ហ៊ុន សែន មានការខកចិត្តជាខ្លាំង ដោយកងទ័ពវៀតណាមនោះ ដកថយទៅវិញមិនទុកឱកាសឲ្យចលនាប្រឆាំងខ្មែរក្រហមមានទីជម្រកសុវត្ថិភាព ដើម្បីកសាងកម្លាំង

[72] បច្ចុប្បន្ន ស្រុកទ្រមូង ត្រូវបានបញ្ចូលក្នុងស្រុកមេមត់ ។

ឬ ទុកជាតំបន់រំដោះរបស់ពួកគេឡើយ ។ ជាមួយនោះ យុវរមេបញ្ជាការយោធារូបនេះក៏មានអំណរខ្លះដែរ ដោយកងទ័ពវៀតណាមយល់ព្រមអនុញ្ញាតឲ្យប្រជាពលរដ្ឋខ្មែរ ដែលរត់ចូលទឹកដីវៀតណាម អាចរស់នៅលើទឹកដីរបស់ប្រទេសគេបាន ។

ខ្មែរក្រហមផ្តាច់ទំនាក់ទំនងការទូត

នៅថ្ងៃទី ៣១ ធ្នូ ១៩៧៧ លោក ខៀវ សំផន ប្រធានគណៈប្រធានរដ្ឋកម្ពុជាប្រជាធិបតេយ្យ បរិហារការឈ្លានពានរបស់វៀតណាមជាសាធារណៈ រីឯលោក អៀង សារី រដ្ឋមន្ត្រីក្រសួងការបរទេសខ្មែរក្រហមក៏បានចេញសេចក្តីប្រកាសកាត់ផ្តាច់ទំនាក់ទំនងការទូតជាមួយប្រទេសវៀតណាម ។ ជម្លោះរវាងរបបខ្មែរក្រហម ប៉ុល ពត ជាមួយប្រទេសវៀតណាម បានឈានដល់ដំណាក់កាលថ្មីតម្រូវឲ្យវៀតណាមប្រកាន់យកនយោបាយគាំទ្រដោយចំហរ ដល់ចលនាតស៊ូខ្មែរប្រឆាំងរបបប្រល័យយពូជសាសន៍យ៉ាងដាច់ខាត ។

បើតាមបណ្តាញសារព័ត៌មានលោកខាងលិច ដែលចេញផ្សាយនាសម័យនោះថា នៅខែ មករា ១៩៧៨ កងទ័ពវៀតណាមវាយដេញទ័ពខ្មែរក្រហមចូលមកក្នុងទឹកដីខ្មែរប្រមាណចម្ងាយ ៣០-៤០ គីឡូម៉ែត្រ ។ ជនភៀសខ្លួនខ្មែរដែលបានទៅដល់ជំរុំបេនសាំង នៃខេត្តតៃនិញ នៅពេលដដែលនោះ និយាយថាមានជនជាតិខ្មែរប្រមាណមួយម៉ឺននាក់ បានរត់ឆ្លងកាត់ទល់ដែនចូលទៅក្នុងប្រទេសវៀតណាម ។ នៅក្នុងជំរុំនោះ មានការប្រជុំនយោបាយ រៀបចំដោយសមាជិកនៃគណបក្សកុម្មុយនីស្តខ្មែរ ដែលបណ្តុះបណ្តាលដោយក្រុងហាណូយ ។ បញ្ហាដូចជាការ

ស្ម័គ្រចិត្តត្រឡប់ចូលទៅកម្ពុជាវិញ ដើម្បីវាយប្រហាររបប ប៉ុល ពត ដើម្បីសងសឹក ចំពោះការកាប់សម្លាប់ឪពុក ម្តាយ បង ប្អូន កូន ចៅខ្លួន ឬ ធ្វើការផ្លាស់ប្តូររដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ត្រូវបានលើកឡើងមកធ្វើការផ្លាស់ប្តូរមតិគ្នា ។ នៅក្នុងជំរុំនេះ ក៏មានធ្វើការអប់រំឡើងវិញដល់ទាហានខ្មែរក្រហម ដែលវៀតណាមចាប់បានដើម្បីឲ្យកែខ្លួនទៅជាពលរដ្ឋល្អវិញ និង ដើម្បីឲ្យយល់ដឹងពីធាតុពិតរបស់ ប៉ុល ពត និង ធ្វើខ្លួនឲ្យទៅជាកម្មាភិបាលម៉ាកឡេនីនពិតប្រាកដ ។

នៅខែ មករា នោះដែរ ប៉ុល ពត បង្កើនការបោសសំអាតនៅភូមិភាគបូព៌ា ។ ចំណែកនៅឯប្រទេសវៀតណាមវិញ លោក ហ៊ុន សែន បានជួបនាយទាហានជាន់ខ្ពស់ដែលជាមេបញ្ជាការយោធភូមិភាគទី៧ និង ជាតំណាងបក្ស និង រដ្ឋវៀតណាម ដែលនាំដំណឹងថារដ្ឋាភិបាលវៀតណាមបានអនុញ្ញាតឲ្យលោក ហ៊ុន សែន កសាងកម្លាំងទ័ព ដោយរើសក្នុងចំណោមជនភៀសខ្លួនខ្មែរ និង ដោយខាងការីវៀតណាមផ្តល់ជំនួយយោធាមានអាវុធ គ្រាប់រំសេវ ស្បៀង និង ការហ្វឹកហ្វឺន ព្រមទាំងជំនួយហិរញ្ញវត្ថុផង ដោយឡែកចំពោះបញ្ហានយោបាយ វៀតណាមសុំការីកម្ពុជាដោះស្រាយខ្លួនឯង ។ ដោយមានការគាំទ្រយ៉ាងរឹងមាំយ៉ាងនេះ លោក ហ៊ុន សែន ក៏ចាប់ទទួលកម្មាភិបាលខ្មែរក្រហមដែលរត់ចោលជួរ និង កសាងកម្លាំងជាបន្តបន្ទាប់ ។

នៅថ្ងៃ ១៤ មីនា ១៩៧៨ កងទ័ពខ្មែរក្រហម ប៉ុល ពត បានបើកការវាយប្រហារនៅខេត្តមាត់ជ្រូក ឬ ចូវដុក ធ្វើឲ្យជនស៊ីវិលវៀតណាមស្លាប់ និង របួសជាច្រើននាក់ ។ ជាមួយគ្នានោះវិទ្យុកម្ពុជាប្រជាធិបតេយ្យបានផ្សព្វផ្សាយនូវការប្តេជ្ញាចិត្តរបស់កម្មាភិបាលខ្មែរក្រហម ប៉ុល ពតក្នុងការកាប់សម្លាប់ផ្តាច់ពូជក្នាក់ងារ ពួកវាតទីនិយម បរិវារ និង វៀតណាមឈ្លានពានឲ្យអស់ពីអង្គភាព និង ឲ្យអស់ពីទឹកដីកម្ពុជាជារៀងរហូត ។ ការបោសសំអាតនៅភូមិភាគបូព៌ាកាន់តែសាហាវឡើង ឯការរើបំរះផ្ទៃក្នុងក៏កាន់តែសកម្មដែរ ។ ចលនាបះបោរជាទូទៅ ក៏បានងើបឡើង

នៅក្នុងភូមិភាគបូព៌ាទាំងមូល ។ ក្រោយដែលលោក សោ ភឹម ទទួលមរណភាព ទៅ ចលនាបះបោរប្រឆាំង ប៉ុល ពត នៅភូមិភាគបូព៌ានេះ ត្រូវបានដឹកនាំដោយ លោក ហេង សំរិន និង លោក ជា ស៊ីម ។ នៅខែ មេសា ១៩៧៨ កងទ័ពវៀត ណាមប្រមាណមួយសែននាក់ បានត្រូវរាយការណ៍ថាបានប្រមូលផ្តុំគ្នានៅតាមទល់ ដែនវៀតណាម-កម្ពុជា ។ វៀតណាម បានអំពាវនាវឲ្យទាហានខ្មែរក្រហមក្រោក ឡើងកាន់អាវុធ ប្រឆាំងនឹងមេខ្មែរក្រហមប្រល័យពូជសាសន៍វិញ ។ យុទ្ធសាស្ត្រថ្មី របស់វៀតណាមបានផ្តល់ផ្លែផ្កាល្អណាស់ ដោយសារនៅផ្ទៃក្នុងរបបខ្មែរក្រហមមាន ការរពើតរពើងបះបោរយ៉ាងខ្លាំង ។

រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា

នៅខែ វិច្ឆិកា ១៩៧៨ ប្រជាពលរដ្ឋខ្មែររាប់សែននាក់ បានរត់ទៅប្រទេស វៀតណាម ។ នៅខែ វិច្ឆិកា នោះដែរ កម្លាំងតស៊ូប្រឆាំង ប៉ុល ពត បានជួបជុំគ្នា ដើម្បីពិភាក្សារៀបចំចាត់តាំងអង្គការនយោបាយ សម្រាប់ដឹកនាំការតស៊ូផ្តួលរំលំ របប ប៉ុល ពត ។ ក្រុមខ្មែរអ្នកតស៊ូ ៤ ក្រុម បានចូលរួមប្រជុំគឺ៖ ១. ក្រុមមកពី កម្លាំងបះបោរនៅភូមិភាគបូព៌ា តំណាងដោយលោក ហេង សំរិន និង លោក ជា ស៊ីម ២. ក្រុមភូមិភាគឦសាន ដោយលោក ប៊ុន មី និង លោក ប៊ូ ថង ៣. កម្លាំង ផ្តាច់ខ្លួនកសាងថ្មីដោយលោក ហ៊ុន សែន ៤. ក្រុមកម្មាភិបាលដែលស្នាក់នៅ ប្រទេសវៀតណាមតាំងពីសន្និសីទទីក្រុងហ្សឺណែវ ១៩៥៤ ដោយលោក ប៉ែន សុវណ្ណ លោក រស់ សម័យ និង លោក ម៉ុក សាគុណ ។ ឯក្រុមទី ៥ ដែលដឹកនាំ ដោយលោក សាយ ភូថង បានយល់ព្រមចូលរួមការតស៊ូ តែមិនទាន់ចេញមុខ ។

នៅពេលនោះ កម្លាំងថ្មីរបស់លោក ហ៊ុន សែន បានចាប់ផ្តើមពី១កងអនុសេនាធំ ហើយរីកធំធាត់យ៉ាងឆាប់រហ័ស រហូតដល់ ២៨ កងវរសេនាតូច ដែលមានកម្លាំងសរុបប្រមាណ ១០ ០០០ នាក់ ។ នៅថ្ងៃទី ២ ធ្នូ ១៩៧៨ អ្នកតស៊ូទាំង ៥ ក្រុម បានប្រកាសបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលមានលោក ហេង សំរិន ជាប្រធាន ។ នៅថ្ងៃទី ២៥ ធ្នូ ១៩៧៨ កងទ័ពវៀតណាមចំនួនមួយសែនប្រាំម៉ឺននាក់ និង កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលហៅតាមពាក្យសាមញ្ញថាកងទ័ព ហេង សំរិន ទាំងអស់ប្រមាណពីរម៉ឺននាក់ បានវាយប្រហារជាទ្រង់ទ្រាយធំសម្រុក ចូលមកក្នុងប្រទេសខ្មែរ ហើយដណ្តើមទីក្រុងភ្នំពេញ បានទាំងស្រុងនៅថ្ងៃទី ៧ មករា ១៩៧៩ ។ ប៉ុល ពត និង កងទ័ពពិសេសរបស់ខ្មែរក្រហមបានរត់រហូតទៅដល់ទល់ដែនថៃ ដែលនៅទីនោះពួកគេបានទទួលការគាំទ្រពីចិន និង ថៃ ឲ្យរៀបចំកងទ័ពសាជាថ្មីឡើងវិញ ដើម្បីបន្តសង្គ្រាមមួយតទៅទៀត ដែលគេហៅថា "សង្គ្រាមរំដោះជាតិ" ។ នៅថ្ងៃទី ៨ មករា ១៩៧៩ រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានបង្កើតរដ្ឋាភិបាលបណ្តោះអាសន្នមួយ ដែលហៅថាក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា ដោយមានលោក ហេង សំរិន ជាប្រធាន លោក ប៉ែន សុវណ្ណ ជាអនុប្រធាន និង ជារដ្ឋមន្ត្រីក្រសួងការពារប្រទេស លោក ហ៊ុន សែន ជាសមាជិក និង រដ្ឋមន្ត្រីក្រសួងការបរទេស លោក ជា ស៊ីម ជាសមាជិក និង ជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ព្រមទាំងសមាជិក ៥ រូបទៀត ដែលកាន់តំណែងជារដ្ឋមន្ត្រីសំខាន់ៗគឺ ក្រសួងឃោសនាការ ព័ត៌មាន និង វប្បធម៌ ក្រសួងសិក្សាធិការ ក្រសួងសង្គមកិច្ច សុខាភិបាល និង ក្រសួងសេដ្ឋកិច្ច និង ជីវភាព ។ នៅថ្ងៃទី ១១ មករា ១៩៧៩ ថ្នាក់ដឹកនាំរណសិរ្ស និង ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា បានមកដល់ទីក្រុងភ្នំពេញ ។

ប៉ុល ពត ស្នើសុំឲ្យសម្តេច សីហនុ ជួយ

គួររំលឹកអំពីតួនាទីរបស់សម្តេច នរោត្តម សីហនុ ម្តងវិញ ។ ក្រោយពីព្រះអង្គលាលែងតំណែងប្រមុខរដ្ឋកម្ពុជាប្រជាធិបតេយ្យនៅខែ មីនា ១៩៧៦[73]មក ខ្មែរក្រហមក៏បោះបង់ព្រះអង្គចោល ។ ពួកប៉ុល ពត បានវាយប្រហារជាសាធារណៈលើរបបសង្គមរាស្ត្រនិយមរបស់សម្តេចថាជារបបសក្តិភូមិផ្តាច់ការ ព្រមទាំងធ្វើការបោសសំអាតកាប់សម្លាប់អ្នកសីហនុនិយមស្ទើរទាំងអស់ទៀតផង ។ ក្រៅពីឃាត់ឃាំងព្រះអង្គ មិនឲ្យយាងចេញពីព្រះរាជដំណាក់ ពួកខ្មែរក្រហម ប៉ុល ពត បានសម្លាប់ព្រះរាជវង្សានុវង្ស ដែលមានរួមទាំងព្រះរាជបុត្រាបុត្រីផ្ទាល់ចំនួន ៥ ព្រះអង្គ និង ព្រះរាជនត្តាផ្ទាល់(ចៅ)ចំនួន ១៤ ព្រះអង្គផង[74] ។ នៅពេលដែលពួកខ្មែរក្រហមត្រូវការព្រះអង្គ ពួកគេយកចិត្តទុកដាក់ថ្វាយម្ហូបចំណីសមរម្យ តែនៅពេលមិនត្រូវការ ពួកគេក៏មិនរវីរវល់អ្វីទាំងអស់ ។ សម្តេច នរោត្តម សីហនុ បានផ្សព្វផ្សាយតាមសៀវភៅដែលទ្រង់ព្រះរាជនិពន្ធក្នុងឆ្នាំ ១៩៨៦ ក្រោមចំណងជើង "អ្នកជាប់គុកខ្មែរក្រហម" ថាព្រះអង្គទ្រង់ជ្រាបអំពីជម្លោះរវាងកម្ពុជាប្រជាធិបតេយ្យជាមួយវៀតណាម ដោយសារព្រះអង្គស្តាប់ព័ត៌មានផ្សាយចេញពីវិទ្យុអន្តរជាតិដូចជា វិទ្យុអង់គ្លេស ប៊ីប៊ីស៊ី វិទ្យុបារាំង ហ្វ្រង់អាំងទែ វិទ្យុអូស្ត្រាលី ឬ វិទ្យុអាឡឺម៉ង់ជាដើម តាមវិទ្យុទទួលសម្លេងមួយគ្រឿងដែលលោក ខៀវ សំផន ថ្វាយព្រះអង្គ ។

---

[73] តាំងពីខែ មករា ១៩៧៦ របបខ្មែរក្រហម ប៉ុល ពត បានអនុម័តរដ្ឋធម្មនុញ្ញថ្មី ដែលបង្កើតរដ្ឋកម្ពុជាប្រជាធិបតេយ្យ ក៏ប៉ុន្តែមិនទាន់ប្រកាសឲ្យប្រើ ។ ក្នុងនោះ មានតំណែងប្រធានគណៈប្រធានរដ្ឋជំនួស ជំណែងប្រមុខរដ្ឋ ។ សម្តេច នរោត្តម សីហនុ បានដាក់ពាក្យលាលែងពីតំណែងប្រមុខរដ្ឋ នៅខែ មីនា និង ត្រូវបានជំនួសដោយលោក ខៀវ សំផន នៅខែ មេសា ១៩៧៦ នៅពេលដែលរដ្ឋធម្មនុញ្ញថ្មីចូលជាធរមាន ។

[74] Norodom Sihanouk, Les Prisonniers des Khmers Rouges, Edition Cameron, 1986, p. 320.

នៅថ្ងៃទី ១ មករា ១៩៧៨ ក្រោយពីព្រះអង្គតើនពីផ្ទុំ ដោយមានការយឺតយ៉ាវជាងធម្មតា ព្រោះតែព្រះអង្គសោយថ្នាំឲ្យផ្ទុំលក់ពីល្ងាច និង បន្ទាប់ពីទ្រង់បានទទួលដំណឹងតាមវិទ្យុថា កម្ពុជាប្រជាធិបតេយ្យបានផ្តាច់ចំណងការទូតជាមួយប្រទេសវៀតណាម ព្រមទាំងបានរុញច្រានកងទ័ពឈ្លានពាននេះចេញពីទឹកដីកម្ពុជាផង សម្តេចទ្រង់ប្រញាប់ប្រញាល់សរសេរសំបុត្រមួយច្បាប់ ជូនអង្គការខ្មែរក្រហម[75] ដ៏ជាទីគោរព ដើម្បីថ្លែងការកោតសរសើរអំពីជោគជ័យរបស់កងទ័ពបដិវត្តកម្ពុជា និង ស្នើថា ព្រះអង្គត្រៀមព្រះកាយបំរើអង្គការ ប្រសិនបើមាតុប្រទេសត្រូវការ ។ ស្អែកឡើងអង្គការ បានផ្សាយតាមវិទ្យុនូវសារសរសើររបស់សម្តេច ក៏ប៉ុន្តែមិនផ្សាយអំពីការស្នើគ្រាព្រះទ័យបំរើអង្គការជាថ្មីរបស់ព្រះអង្គឡើយ ។ សម្តេចសីហនុ បានសង្កេតឃើញថា នៅចន្លោះថ្ងៃទី ១ មករា ១៩៧៨ និង ទី ១ ធ្នូ ១៩៧៨ ប្រទេសវៀតណាមតែងតែប្រកាសតាមវិទ្យុក្រុងហាណូយ និង វិទ្យុក្រុងហូជីមិញ សុំឲ្យធ្វើការដោះស្រាយជម្លោះតាមការចរចា ។ ជាចម្លើយតបវិញ វិទ្យុខ្មែរក្រហម ប៉ុល ពត ផ្សាយថាគ្មានអ្វីចរចានោះទេ ព្រោះវៀតណាមឈ្លានពាន និងលុកលុយកម្ពុជាប្រជាធិបតេយ្យដ៏ស្លូតត្រង់ និង ដែលស្នេហាសន្តិភាព ។ សម្តេចទ្រង់សង្កេតទៀតថា ជម្លោះកាន់តែធំធាត់កាលណា កាលនោះទូទឹកកករបស់ព្រះអង្គ ក៏កាន់តែសម្បូណ៌ទៅដោយម្ហូបចំណីល្អៗដែរ ដោយសារតែខ្មែរក្រហមកាន់តែយកចិត្តទុកដាក់ជាមួយព្រះអង្គខ្លាំងឡើងៗ ។

នៅពេលថ្ងៃលិចនាថ្ងៃទី ៥ មករា ១៩៧៩ លោកប្រធានគណៈប្រធានរដ្ឋ ខៀវ សំផន បានមកយាងសម្តេច ពីព្រះដំណាក់នៅក្រោយវត្តបុទមវត្តី ទៅជួប ប៉ុល ពត នៅវិមានរដ្ឋាភិបាល ឯវត្តភ្នំដែលសព្វថ្ងៃបានក្លាយជាទីស្នាក់ការនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។ សម្តេចធ្លាប់បានជួប ប៉ុល ពត តែម្តងគត់គឺ នៅពេលព្រះ

[75] Norodom Sihanouk, Les Prisonniers des Khmers Rouges, op. cit., p. 248.

អង្គយាងមកធ្វើទស្សនកិច្ចនៅឆ្នាំ ១៩៧៣ នៅក្នុងតំបន់រំដោះ នាសម័យសង្គ្រាមប្រឆាំងរបប លន់ នល់ ។ តាំងពីពេលនោះមក ព្រះអង្គមិនដែលបានជួបមេដឹកនាំកំពូលនៃរបបប្រល័យពូជសាសន៍នេះទេ ។ ដូច្នេះ នេះជាជំនួបលើកទី២ ។ នៅពេលយាងទៅដល់ ប៉ុល ពត ដោយទឹកមុខញញឹម ឈរចាំព្រះអង្គជាស្រេច នៅមាត់ទ្វារធំ ដោយរួមជាមួយមានលោក អៀង សារី និង សម្តេច ប៉ែន នុត ដែលអញ្ជើញទៅដល់មុនព្រះអង្គ ។ ជាការគួរឲ្យភ្ញាក់ផ្អើលសម្រាប់ព្រះអង្គ ប៉ុល ពត មុននឹងអោបរឹបសម្តេចតាមទម្លាប់ ម្តងនេះគាត់លើកដៃសំពះ ដោយបន្ទុចដង្គង់បន្តិចជាការគោរពផង[76] ។ ដោយឡែកលោក អៀង សារី លើកដៃសំពះទាំងបង្ខំចិត្ត តែតាមលក្ខណៈឆ្មើងឆ្មៃរបស់គាត់ៗមិនបន្ទន់ខ្លួនបន្តិចណាឡើយចំពោះសម្តេច ដែលជាអតីតព្រះមហាក្សត្រខ្មែរ ។ ប៉ុល ពត ថ្វាយសម្តេចឲ្យគង់ខាងស្តាំដៃរបស់គាត់លើកៅអីពូកដ៏ក្រាស់ ដែលគេសម្រាប់ទទួលភ្ញៀវជាន់ខ្ពស់ថ្នាក់ប្រមុខរដ្ឋ ឬ ប្រមុខរដ្ឋាភិបាល ។ យុវជនខ្មែរក្រហមក្នុងសំលៀកបំពាក់ដ៏សង្ហារ ញាប់ដៃញាប់ជើងបំរើទឹកតែ និង នំ ចំណីជាមួយនិងទឹកក្រូចពោធិសាត់ច្របាច់ស្រស់ៗ ។ សម្តេចបានរៀបរាប់ក្នុងសៀវភៅនោះថា ដោយព្រះអង្គខានបានសោយជាយូរមកហើយ ទឹកក្រូចនេះមានឱជារសខ្លាំងណាស់ នាំឲ្យព្រះអង្គសោយហើយសោយទៀតអស់ជាងដប់កែវ ក្នុងរយៈពេលជាងបួនម៉ោងនៃកិច្ចសន្ទនាគ្នានោះ[77]។

តាមពិតទៅ ប៉ុល ពត ចង់ជួបសម្តេច ដើម្បីបញ្ជាក់ផ្ទាល់មាត់ថែមទៀតថា តើព្រះអង្គយល់ព្រមយាងចេញ ទៅការពារកម្ពុជាប្រជាធិបតេយ្យនៅអង្គការសហប្រជាជាតិ ដូចរបាយការណ៍របស់ លោក ខៀវ សំផន មែនឬទេ? នៅចំពោះមុខការវាយប្រហារដ៏ខ្លាំងក្លា និង ការរុលទៅមុខយ៉ាងឆាប់រហ័សនៃកងទ័ពវៀត

[76] Norodom Sihanouk, Les Prisonniers des Khmers Rouges, op.cit, p. 317.

[77] ដូចយោងខាងលើ ។

ណាម ។ បើតាមអ្វីដែល ប៉ុល ពត ទូលព្រះអង្គនោះ សម្តេចត្រូវយាងទៅ អ.ស.ប រួចត្រឡប់មកគង់នៅទីក្រុងប៉េកាំងវិញមិនលើសពីបីខែទេ ជារយៈពេលដែល ប៉ុល ពត ប៉ាន់ស្មានថាខ្មែរក្រហមអាចវាយបណ្តេញកងទ័ពវៀតណាម ឲ្យចេញអស់ពីទឹកដីខ្មែរបាន ។ ដូច្នេះទោះជានៅក្នុងភាពអាសន្នក៏ដោយ ក៏ ប៉ុល ពត នៅតែមានអំនួត និង នឹកថាទាហានរបស់ខ្លួន អាចទប់ទល់ជាមួយកងទ័ពវៀតណាមបាន ។ មែនទែន សម្តេច សីហនុ ក៏ទ្រង់សព្វព្រះទ័យចំពោះគំនឹតឲ្យព្រះអង្គយាងទៅ អ.ស.ប.នេះណាស់ដែរ ព្រោះនោះជាលទ្ធភាពអាចឲ្យព្រះអង្គស្វែងរកសេរីភាពជាថ្មីឡើងវិញបាន ។ ក្រោយពេលសម្តេចលាឈប់ពីដំណែងប្រមុខរដ្ឋនាឆ្នាំ ១៩៧៦ ព្រះអង្គធ្លាប់សុំចេញទៅប្រទេសចិន ដើម្បីព្យាបាលព្រះរោគ តែខ្មែរក្រហមមិនអនុញ្ញាត ។

នៅក្នុងជំនួបនោះ ប៉ុល ពត ទូលព្រះអង្គថា រសៀលថ្ងៃស្អែកនឹងមានយន្តហោះចិនមួយគ្រឿងមកដឹកសម្តេច អ្នកម្នាងម៉ូនិច ព្រះរាជបុត្រ និង ព្រះញាតិ ព្រមទាំងអ្នកហែរហមរបស់ព្រះអង្គឆ្ពោះទៅប្រទេសចិន ។ នៅពេលនោះ លោក អៀង សារី បាននិយាយទៅកាន់ ប៉ុល ពត ថាយន្តហោះចិននោះ មិនមានកន្លែងសម្រាប់ទាំងអស់គ្នាទេ មានតែកន្លែងថ្វាយសម្តេច និង ជូនអ្នកម្នាងតែប៉ុណ្ណោះ ។ ក៏ប៉ុន្តែ ប៉ុល ពត បានបញ្ជាដាច់ខាតឲ្យលោក អៀង សារី ស្នើទៅភាគីចិនឲ្យដួលសំរួលរកកន្លែងឲ្យគ្រប់ដើម្បីបានចេញទៅទាំងអស់គ្នា ។

រំលេកព្រះដំណាក់វិញ សម្តេចនៅតែមិនទាន់អស់ព្រះទ័យ ខ្លាចក្រែងអ្វីដែលលោក អៀង សារី និយាយថាយន្តហោះមិនមានកន្លែងសម្រាប់គ្រប់គ្នានោះជាកលល្បិចរបស់ខ្មែរក្រហម ដើម្បីឃាត់ទុកព្រះរាជបុត្រ និង ព្រះញាតិវង្សឯទៀតជាចំណាប់ខ្មាំង កុំឲ្យព្រះអង្គមានសេរីភាពអាចធ្វើអ្វីតាមព្រះទ័យរបស់ព្រះអង្គបាន ។ ស្អែកឡើងព្រឹកថ្ងៃទី ៦ មករា លោក អៀង សារី បញ្ជូនបេសកជនមកទូលថាយន្ត

ហោះនោះ មានកន្លែងគ្រប់សម្រាប់ចេញដំណើរទាំងអស់គ្នា ពេលនោះទើបព្រះអង្គ ឈប់ព្រួយព្រះទ័យ ។ បន្ថែមលើដំណឹងដ៏ល្អនេះ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ របស់ ប៉ុល ពត បានថ្វាយប្រាក់បេសកកម្មចំនួន២ហ្មឺនដុល្លារអាមេរិកទៀតផង ។ សម្តេច សីហនុ អ្នកម្នាង ម៉ូនិច[78]ព្រះរាជបុត្រ[79] និង ព្រះញាតិឯទៀត ព្រមទាំងអ្នក ហែរហមទាំងអស់របស់ព្រះអង្គ ក៏ដូចជាសម្តេច ប៉ែន នុត បានទៅដល់ប្រទេសចិន នៅយប់ថ្ងៃទី ៦ មករា ១៩៧៩ ដោយសុវត្ថិភាព[80] ។ នៅល្ងាចថ្ងៃទី ៧ មករា ១៩៧៩ ចិនរៀចំដប់លៀងទទួលសម្តេច តែអារម្មណ៍ពួកចិនកំពុងខ្វាយខ្វល់អំពី ការដួលរលំនៃរបប ប៉ុល ពត ឯនោះទេ ។

នៅថ្ងៃ ទី ៨ មករា ១៩៧៩ សម្តេច បានធ្វើសន្និសីទសារព័ត៌មានមួយ អស់រយៈពេល៦ម៉ោង នៅទីក្រុងប៉េកាំងនៅចំពោះមុខអ្នកកាសែតអន្តរជាតិចំនួន ២០០ នាក់ ក្នុងគោលបំណងធំបង្អស់គឺ ការពារបុព្វហេតុដ៏ត្រឹមត្រូវនៃកម្ពុជាប្រជា ធិបតេយ្យ ដែលរងគ្រោះដោយអំពើឈ្លានពានពីសាធារណរដ្ឋសង្គមនិយមវៀត ណាម ។ ក៏ប៉ុន្តែនៅទីបញ្ចប់ សន្និសីទសារព័ត៌មាននោះ ក៏ត្រឡប់ក្លាយទៅជាវេទិ កាសម្រាប់សម្តេច សីហនុ ថ្កោលទោសយ៉ាងធ្ងន់ធ្ងរដល់របបប្រល័យពូជសាសន៍ ខ្មែរក្រហមទៅវិញ តាមរយៈសំណួរដេញដោលយ៉ាងតឹងតែង ពីសំណាក់អ្នក កាសែតអន្តរជាតិទាំងនោះ ។

---

[78] កាលនោះ សម្តេចម៉ែ សម្តេចយាយ នៅជាអ្នកម្នាង មិនទាន់ឡើងជាសម្តេច នៅឡើយទេ ។

[79] ព្រះរាជបុត្រនោះគឺ ព្រះករុណាសម្តេចព្រះបរមនាថ សីហមុនី និង សម្តេច នរិន្ទ្រពង្ស ដែលសុគត នៅប្រទេសបារាំង នៅឆ្នាំ ២០០៣ ។

[80] ក្នុងបេសកកម្មក្រៅប្រទេសរបស់សម្តេច សីហនុ នៅពេលនោះ អង្គការ ប៉ុល ពត បានចាត់មន្ត្រីជាន់ខ្ពស់ ៣ នាក់ ឲ្យធ្វើដំណើរតាមជាប់រហូតដល់ទីក្រុង ញីវយ៉ក ស.រ.អា គឺ៖ លោក ជួន ប្រសិទ្ធ លោក គាត ឈន់ និង កញ្ញា ប៉ុក ម៉ូណា ។

បន្ទាប់មក សម្តេច និង អ្នកម្នាង រួមទាំងមន្ត្រីជាន់ខ្ពស់ខ្មែរក្រហមមាន លោក ជួន ប្រសិទ្ធ និង លោក គាត ឈន់[81] ផង ក៏ធ្វើដំណើរទៅកាន់ទីក្រុងញ៉ាវយ៉ាក ដើម្បីចូលរួមប្រជុំក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ ស្តីពីការលុកលុយកម្ពុជាប្រជាធិបតេយ្យ ដោយកងទ័ពវៀតណាម ដូចព្រះអង្គបានសន្យាជាមួយ ប៉ុល ពត មេដឹកនាំកំពូលរបស់ខ្មែរក្រហមយ៉ាងដូច្នេះមែន ។ ក្នុងដំណើរបស់ព្រះអង្គ ទៅកាន់ទីក្រុងញ៉ាវយ៉ាកលើកនេះ សម្តេច សីហនុ បានវាស់ស្វង់នូវទំហំដ៏ធំធេងនៃការស្អប់ខ្ពើមរបស់សាធារណមតិអន្តរជាតិ ចំពោះរបប ប៉ុល ពត ។ ការដែលព្រះអង្គទទួលមុខនាទីជាអ្នកនាំពាក្យ ឬ អ្នកតំណាងឲ្យរបបនេះ មិនបានលើកកិត្តិយសរបស់ព្រះអង្គឡើយ ។ ការបាត់បង់ព្រះរាជបុត្រា បុត្រី ព្រះរាជនត្តា និង បុគ្គលជាទីស្រឡាញ់របស់ព្រះអង្គ ធ្វើឲ្យព្រះអង្គធ្លាក់ទឹកព្រះទ័យជាខ្លាំង ។ ម្យ៉ាងទៀត ទោះជាស្ថិតនៅក្នុងសភាពដុនដាបយ៉ាងខ្លាំងណាស់ទៅហើយក៏ដោយ ក៏ពួកខ្មែរក្រហមនៅតែប្រកាន់ឫកពាដ៏គឃ្លើនចំពោះព្រះអង្គទៀត ។ ទាំងនេះរឹតតែធ្វើឲ្យសម្តេចសម្រេចព្រះទ័យរត់ចោលពួក ប៉ុល ពត ដើម្បីរំដោះព្រះអង្គ និងស្វែងរកសេរីភាពឲ្យធំទូលាយ ។

ភាពគឃ្លើនរបស់ខ្មែរក្រហមចំពោះព្រះអង្គ

នៅក្នុងសៀវភៅរបស់ព្រះអង្គនោះ[82] សម្តេច សីហនុ សរសេរថា ទឹកពីរតំណក់ចុងក្រោយ ដែលធ្វើឲ្យទឹកហៀរចេញពីកែវនោះគឺ ជាហេតុផលទ្រាំពុំបាន

[81] នេះជាការលើកឡើងដោយសម្តេចព្រះ នរោត្តម សីហនុ ក្នុងសៀវភៅរបស់ព្រះអង្គ ក្រោមចំណងជើង អ្នកជាគុកខ្មែរក្រហម

[82] Norodom Sihanouk, Les Prisonniers des Khmers Rouges, op.cit, p. 341.

ជំរុញឲ្យព្រះអង្គរកវិធីគេចចេញពីការត្រួតត្រាឃ្លាំមើលរបស់ខ្មែរក្រហម ។ តំណក់ទឹកទី១៖ លោក ជួន ប្រសិទ្ធ ទូលសម្តេចថា ភារកិច្ច និង បេសកកម្មរបស់ព្រះអង្គនៅក្រុមប្រឹក្សាសន្តិសុខ បន្ទាប់មកទៀតនាពេលខាងមុខ នៅមហាសន្និបាតអង្គការសហប្រជាជាតិលើកនេះ ត្រូវតែទទួលមហាជោគជ័យ ព្រោះតាំងពីឆ្នាំ ១៩៧៥ រហូតមកមិត្ត អៀង សារី បានប្រមែប្រមូលនូវការគោរពស្រឡាញ់រាប់អាន និង ការគាំទ្រដ៏ធំធេងពីសំណាក់សមាជិកភាគច្រើន ចំពោះរបបកម្ពុជាប្រជាធិបតេយ្យរួចទៅហើយ ។ ឮសំដីអំនួតបែបនេះ សម្តេច នឹកថាបើរបប ប៉ុល ពត មានប្រជាប្រិយភាពនៅលើឆាកអន្តរជាតិមែន និង ប្រសិនបើ ប៉ុល ពត មិនត្រូវការព្រះអង្គទេនោះ ម្ល៉េះសម ប៉ុល ពត មិនមកសុំឲ្យព្រះអង្គចេញពីក្នុងស្រុកមកក្រៅប្រទេសដូច្នេះទេ ឬ ប៉ុល ពត អាចធ្វើឃាតព្រះអង្គចោលផងក៏បាន ។ តំណក់ទឹកទី២៖ ពីទីក្រុងប៉េកាំង សម្តេច សីហនុ បានទទួលសារមួយច្បាប់ ទូលព្រះអង្គថានៅពេលចប់ការពិភាក្សានៅក្រុមប្រឹក្សាសន្តិសុខរួចហើយ សូមឲ្យសម្តេច ដឹកនាំ "ជាបណ្តោះអាសន្ន" នូវគណៈប្រតិភូរបស់កម្ពុជាប្រជាធិបតេយ្យ ចូលរួមមហាសន្និបាត អ.ស.ប លើកទី ៣៤ តទៅទៀតសិន ទម្រាំប្រធានគណៈប្រតិភូពេញសិទ្ធិ គឺលោក អៀង សារី ធ្វើដំណើរមកដល់ទីក្រុងញូវយ៉ក ។ ចំណុចនេះសម្តេច ដែលជាអតីតមហាក្សត្រ និង ប្រមុខរដ្ឋខ្មែរមិនអាចទទួលយកបានឡើយ ។ ព្រះអង្គប្រាកដជាមិនអាចបន្តដង្ហែរមេខ្មែរក្រហមតទៅទៀត ជាពិសេស នៅបន្តហែរហមអៀង សារី ដែលជាបុគ្គលត្រូវគេមាក់ងាយទូទាំងសាកលលោក និង គួរឲ្យស្អប់ខ្ពើមជាទីបំផុត ដោយមានហាន:ត្រឹមតែជាអនុប្រធានទេនោះ ។ ចំណុចពីខាងលើនេះជាមូលហេតុនាំព្រះអង្គឲ្យសំរេចព្រះទ័យគេចចេញពីខ្មែរក្រហម ។

បានពួក អេហ្វ ប៊ី អាយ ជួយរំដោះព្រះអង្គ

បន្ទាប់ពីបានបញ្ចប់បេសកកម្មនៅក្រុមប្រឹក្សាសន្តិសុខ ដោយជោគជ័យរួចមក នៅវេលាម៉ោង ២ ហៀបភ្លឺថ្ងៃទី ១៤ មករា ១៩៧៩ ដោយបានណាត់គ្នាជាមុនជាមួយភ្នាក់ងារសម្ងាត់ អេហ្វ ប៊ី អាយ (FBI: Federal Bureau of Investigation) របស់អាមេរិក សម្តេច សីហនុ បានលបយាងចេញពីសណ្ឋាគារដ៏ធំ និង ថ្លៃជាងគេនៅទីក្រុងញ៊ីវយ៉ក ជាមួយវ៉ាលីសមួយតែមួយព្រះអង្គឯង តាមរថយន្តឆ្ពោះទៅស្ថានតំណាងអចិន្ត្រៃយ៍របស់ ស.រ.អា ប្រចាំអង្គការសហប្រជាជាតិ ដែលមានលោកឯកអគ្គរដ្ឋទូត អង់ឌ្រូវ យ៉ង់ (Andrew Young)[83] ជាប្រមុខ ។ ព្រឹកឡើងថ្ងៃទី ១៤ នោះ អាជ្ញាធរអាមេរិក ក៏ជួយនាំអ្នកម្នាងជាព្រះជាយាឲ្យបានមកជួបជុំជាមួយព្រះអង្គដោយសុវត្ថិភាព ។ មុននឹងបែកពីខ្មែរក្រហម អ្នកម្នាង ម៉ូនិច បានប្រគល់ប្រាក់ ២ ហ្មឺនដុល្លារដែលជាប្រាក់បេសកកម្មទៅឲ្យមន្ត្រីជាន់ខ្ពស់ខ្មែរក្រហមវិញ ។ តាមពិតទៅ លោកឯកអគ្គរដ្ឋទូត អង់ឌ្រូវ យ៉ង់ ក៏បានយកចិត្តទុកដាក់ជួយរំដោះសម្តេច និង អ្នកម្នាងពីអំណាចខ្មែរក្រហម ប៉ុល ពត ដែរ ដោយបញ្ជូនឲ្យទៅត្រួតពិនិត្យព្រះសុខភាពភ្លាមនៅមន្ទីរពេទ្យដ៏ធំមួយ ក្នុងទីក្រុងញ៊ូវយ៉ក ។ យាងទៅដល់មន្ទីរពេទ្យ សម្តេច សីហនុ និង អ្នកម្នាង បន្តស្វែងរកសេរីភាពតទៅទៀត ។ រំពេចនោះព្រះអង្គសរសេរលិខិតសុំសិទ្ធិជ្រកកោននៅ ស.រ.អា ។ ដោយពុំមានចម្លើយពី ស.រ.អា ព្រះអង្គក៏សុំទៅ ប្រទេសបារាំងឲ្យផ្តល់លិខិតឆ្លងដែនបារាំងពីរច្បាប់មួយសម្រាប់ព្រះអង្គផ្ទាល់ មួយច្បាប់ទៀតសម្រាប់អ្នកម្នាងជាព្រះជាយា ព្រោះព្រះអង្គមិនចង់កាន់លិខិតឆ្លងដែនរបស់ខ្មែរក្រហមតទៅទៀតឡើយ ។ បារាំងឆ្លើយមកសម្តេចវិញថា ប្រទេសបារាំងថ្វាយសិទ្ធិជ្រកកោនតែ

[83] Norodom Sihanouk, Les Prisonniers des Khmers Rouges, op.cit, p. 342.

មានលក្ខខណ្ឌគឺ សម្តេចមិនត្រូវធ្វើសកម្មភាពនយោបាយ និង ទាក់ទងជាមួយអ្នកកាសែតឡើយនៅលើទឹកដីបារាំង ។ ចម្លើយនេះធ្វើឲ្យព្រះអង្គមិនពេញព្រះទ័យទាល់តែសោះ ។ គាប់ជួននៅពេលនោះ មេដឹកនាំចិនលោក តេង ស៊ាវពីង បានទៅធ្វើទស្សនកិច្ចនៅ ស.រ.អា និង បានស្នើសម្តេចយាងនិវត្តទៅប្រទេសចិនវិញ ។

ទីបំផុតព្រះអង្គព្រមយាងត្រឡប់ទៅស្រុកចិនវិញ

សម្តេច សីហនុ បានសរសេរក្នុងសារណារបស់ព្រះអង្គ ដែលបកប្រែជាភាសាអង់គ្លេសដោយលោក ជូលីយ៉ូ ជេលជ្រេស (Julio A. Jeldres)[84] ថានៅថ្ងៃទី ៣១ មករា ១៩៧៩ លោក តេង ស៊ាវពីង បានយាងសម្តេចទៅសោយអាហារពេលល្ងាច នៅវិមានទទួលភ្ញៀវរដ្ឋរបស់អាមេរិក ប្លែរ ហៅស្យ៍ (Blair House) នៅទីក្រុងវ៉ាស៊ិនតោន ។ នៅឱកាសនោះ មេដឹកនាំចិនរូបនេះបានស្នើសម្តេចឲ្យព្រះអង្គទទួលធ្វើជាមេដឹកនាំនៃមហាណាសិរ្សបង្រួបបង្រួមជាតិ និង ជាប្រមុខរដ្ឋកម្ពុជាប្រជាធិបតេយ្យឡើងវិញ ដោយលោក តេង ស៊ាវពីង ទូលព្រះអង្គថា ឥឡូវនេះមេដឹកនាំទាំងអស់នៃរបបកម្ពុជាប្រជាធិបតេយ្យសន្យាថា មិនធ្វើឲ្យមានកំហុសខុសឆ្គងដូចមុនទៀតឡើយ ។ ម្យ៉ាងទៀតមេដឹកនាំខ្មែរក្រហមទាំងនោះទទួលស្គាល់កំហុសថា បន្ទាប់ពីជ័យជំនះឆ្នាំ ១៩៧៥ ពួកគេបានរំលាយរណសិរ្សរួបរួមជាតិកម្ពុជាចោល ដោយយកចំណេញសម្រាប់តែភាគីរបស់ពួកខ្លួនតែឯង នេះបើតាមសំដីលោក តេងស៊ាវពីង ។ សម្តេច ប្រកែកពុំព្រមទទួលតាមសំណើនេះទេ ទោះបីជាលោក តេង ស៊ាវពីង ខំពន្យល់ព្រះអង្គយ៉ាងណាក៏ដោយ ។ នៅទី

[84] Norodom Sihanouk, Shadow Over Angkor, Memoirs of His Majesty the King of Cambodia, translated by Ambassador Julio A. Jeldres, Monument Books, Phnom Penh, 2005, p. 205-206.

បំផុតមេដឹកនាំចិន ក៏លះបង់គំនឹតស្នើសុំឲ្យសម្តេចធ្វើជាប្រមុខរដ្ឋកម្ពុជាប្រជាធិបតេយ្យសាជាថ្មី និង ឈប់ពាក់ព័ន្ធព្រះអង្គជាមួយខ្មែរក្រហមតទៅទៀត ។ ក៏ប៉ុន្តែ លោក តេង ស៊ាវពីង ទទូចសុំតែចំណុចមួយទេគឺ សុំឲ្យព្រះអង្គវិលត្រឡប់ទៅគង់នៅប្រទេសចិនវិញ រហូតដល់ពេលព្រះអង្គ អាចយាងវិលទៅកម្ពុជាវិញបាន ព្រមទាំងជានាថារដ្ឋាភិបាលចិនថ្វាយសេរីភាពគ្រប់យ៉ាង ទាំងនៅក្នុងប្រទេសចិន ទាំងនៅក្នុងទស្សនកិច្ចម្តងម្កាលរបស់ព្រះអង្គនៅក្រៅពីប្រទេសចិន ។ ហេតុដូច្នេះហើយ បានជាសម្តេច សីហនុ ព្រមយាងទៅប្រទេសចិនវិញ ម្តងនេះក្នុងឋានៈព្រះអង្គជាមនុស្សសេរី ដែលរួចចាកពីអំណាចខ្មែរក្រហមរហូតមក ។

អរផង ភ័យផង ចំពោះជ័យជំនះ ៧ មករា

សហគមន៍ខ្មែរនៅប្រទេសបារាំង ក៏ដូចជាប្រជាពលរដ្ឋខ្មែរទាំងមូលនោះដែរ បានទទួលអបអរសាទរចំពោះការដួលរលំនៃរបបខ្មែរក្រហម ។ ក៏ប៉ុន្តែ ដំណឹងដែលថាកងទ័ពវៀតណាមជាអ្នកផ្តួលរំលំរបប ប៉ុល ពត និង ថាកងទ័ពវៀតណាមរាប់សែននាក់នេះកាន់កាប់ទឹកដីខ្មែរ បានធ្វើឲ្យអំណរសាទរ និង ក្តីសប្បាយរបស់សហគមន៍ខ្មែរទាំងនោះក្លាយជាក្តីបារម្ភ និង ការភ័យខ្លាចរបស់ពួកគេក្នុងការបាត់បង់ទឹកដីកម្ពុជាទាំងមូលទៅវិញ ។ មែនទែនទៅ ខ្មែរនៅក្រៅប្រទេសភាគច្រើនហាក់ដូចជាមិនបាននឹកនាដល់គ្រោះមហន្តរាយនៃការវិលត្រឡប់របស់ ប៉ុល ពត មកកាន់អំណាចវិញឡើយ ។ សហគមន៍ខ្មែរនៅក្រៅប្រទេសទាំងនោះទទួលស្គាល់ថា ខ្មែរក្រហមពិតជាបានប្រព្រឹត្តឧក្រិដ្ឋកម្មកាប់សម្លាប់ជ្រោពលរដ្ឋខ្មែរមែន ក៏ប៉ុន្តែ ការកាន់កាប់ទឹកដីខ្មែរដោយកងទ័ពវៀតណាមគឺ ជាសញ្ញានៃការបាត់បង់ព្រលឹងជាតិខ្មែរ ។ ការមិនអាចទទួលយកបាននូវការលុកលុយរបស់បរទេសនេះ បាន

បង្កើតឡើងនូវស្មារតីស្នេហាជាតិ និង ជាតិនិយមនៃខ្មែរនៅក្រៅប្រទេសដែលបានរួបរួមគ្នាជាក្រុម ជាសមាគម ហើយបានជំរុញឲ្យពួកគេទាំងនោះ នាំគ្នាចូលប្រឡូកធ្វើសកម្មភាពនយោបាយឡើង ។ នៅសម័យនោះ និន្នាការទូទៅនៅក្រៅប្រទេសគឺវៀតណាមឈ្លានពានកម្ពុជា មិនមែនមកជួយយកអាសារប្រជាជនកម្ពុជាឲ្យរួចចាកពីរបបប្រល័យពូជសាសន៍ឡើយ ។ ខ្មែរភាគច្រើននៅក្រៅប្រទេសរួមទាំងរូបខ្ញុំផងមិនបាននឹកដល់ថាបើគ្មានប្រល័យពូជសាសន៍ ក៏គ្មានអំពើឈ្លានពានរបស់បរទេសនេះដែរ ។ ម្យ៉ាងទៀត បើរង់ចាំឲ្យក្រុមអ្នកតស៊ូខ្មែរនៅទិសខាងលិច ដែលពឹងពាក់ថៃមកជួយរំដោះ មិនដឹងជាត្រូវរង់ចាំប៉ុន្មានឆ្នាំទៀត បើថៃនៅពេលនោះលំអៀងទៅខាងចិន ដែលផ្តល់ការគាំទ្រយ៉ាងរឹងមាំដល់ ប៉ុល ពត ។ នៅសម័យនោះ ថៃមិនមានឆន្ទៈនយោបាយ និង មធ្យោបាយផ្នែកទ័ពអាចមកវាយរំដោះប្រជាពលរដ្ឋខ្មែរពីរបបប្រល័យពូជសាសន៍ ប៉ុល ពត សោះឡើយ ។ ដូច្នេះតើ ប៉ុល ពត អាចបន្តកាប់សម្លាប់ខ្មែរប៉ុន្មានហ្មឺន ប៉ុន្មានសែននាក់ទៀត បើខ្មែរយើងត្រូវរង់ចាំចលនាតស៊ូនៅជាយដែនថៃមកជួយរំដោះនោះ ?

វិលត្រឡប់មកនិយាយអំពីចលនានៅប្រទេសបារាំងម្តងវិញ នាដើមឆ្នាំ ១៩៧៩ នោះ ។ ភ្លាមៗនោះ មានការរៀបចំប្រជុំនៅច្រើនកន្លែង ។ ខ្ញុំក៏បានទទួលការអញ្ជើញឲ្យចូលរួមប្រជុំមួយដែរ ។ សេចក្តីអញ្ជើញដែលខ្ញុំបានទទួលតាមប្រៃសណីយមួយនោះ មិនមានបញ្ជាក់ពីអង្គការ ដែលរៀបចំប្រជុំនោះទេ គេគ្រាន់តែឲ្យដឹងពីពេលវេលា ទីកន្លែង និង កម្មវត្ថុនៃអង្គប្រជុំតែប៉ុណ្ណោះ ។ អាស័យដ្ឋាននៃអង្គប្រជុំគឺ ឋិតនៅផ្លូវ ហ្វូបួ សាំង-ដឺនី (Faubourg Saint-Denis) ជាកន្លែងមួយដែលគួរឲ្យឆ្ងល់ ។ នៅពេលដែលខ្ញុំទៅដល់កន្លែងនោះ ខ្ញុំមិនហ៊ានចូលទៅភ្លាមទេ ព្រោះជាហាងលក់សៀវភៅ និង ប្រដាប់ប្រដាសំរាប់ផ្លូវភេទ (Sex Shop) ហើយម្យ៉ាងទៀត នៅខាងក្នុងមានមនុស្សតែពីរបីនាក់ប៉ុណ្ណោះ ។ ខ្ញុំដើរចុះដើរឡើង រោ

ជារច្រើនដង ព្រោះខ្ញុំនឹកថាកន្លែងនេះមិនគួរជាទីកន្លែង ដែលត្រូវពិភាក្សាពីរឿងនយោបាយស្រុកទេសនោះឡើយ ។ នៅពេលដែលខ្ញុំសំរេចថាចូលទៅខាងក្នុងនោះ មានអ្នកលក់ម្នាក់ជាជនជាតិខ្មែរ ប្រាប់ខ្ញុំថាឲ្យដើរចូលទៅខាងក្នុង ដែលនៅទីនោះ ខ្ញុំឃើញយុវជនខ្មែរបួន ឬ ប្រាំនាក់ ដែលមានអាយុប្រហាក់ប្រហែលខ្ញុំដែរ ហើយដែលខ្ញុំមិនដែលស្គាល់សោះនោះ កំពុងជជែកគ្នាអំពីអំពើឈ្លានពានរបស់វៀតណាមមកលើកម្ពុជា ។ ខ្ញុំមានការខកចិត្តជាខ្លាំង ដោយខ្ញុំពុំបានឮអ្វីជាខ្លឹមសារ ឬ យុទ្ធសាស្ត្រអ្វីជាក់លាក់ ដែលអាចធ្វើឲ្យពាក្យពេចន៍ស្នេហាជាតិ ឬ អ្នកជាតិនិយមនោះ អាចក្លាយជាសកម្មភាពជាក់ស្តែងក្នុងការប្រយុទ្ធប្រឆាំងនឹងកងទ័ពវៀតណាមឈ្លានពាននោះឡើយ ។ ម្យ៉ាងទៀត ខ្ញុំមិនអាចផ្ទង់ស្មារតីជជែកពិភាក្សាអំពីបញ្ហាប្រទេសជាតិអស់នោះ នៅចំពោះមុខគំនរសៀវភៅ និង រូបភាពអាសអាភាសដែលគរទុក និង ព្យួរពេញរណេងរណោងពាសពេញទីនោះបានឡើយ ។ ខ្ញុំយល់ឃើញថារវាងខ្មែរ និង វៀតណាម ប្រាកដជាមានអរិភាពយ៉ាងខ្លាំងក្លាមែន ព្រោះសូម្បីតែនៅក្នុងហាងលក់សៀវភៅ និង ប្រដាប់ប្រដាសំរាប់ផ្លូវភេទបែបនេះ ក៏គេនាំគ្នានិយាយអំពីនយោបាយ និង ការតស៊ូប្រឆាំងនឹងវៀតណាមដែរ ។ នៅពេលនោះ ខ្មែរយើងនៅក្រៅប្រទេសភាគច្រើន មិនទទួលយកគំនឹតថាកងទ័ពវៀតណាមទាំងនោះមកជួយរំដោះខ្មែរយើង ឲ្យរួចពីការកាប់សម្លាប់របស់ពួកប្រល័យពូជសាសន៍ប៉ុល ពត នោះទេ ។

អបអរសាទរព្រះអង្គ ដែលនៅគង់ព្រះជន្មនៅឡើយ

ខ្មែរមួយចំនួនធំ ដោយរាប់ទាំងលោកតា សឺន សាន ផងមានការធូរស្បើយក្នុងចិត្តនៅពេលដែលដឹងថា សម្តេច សីហនុ នៅគង់ព្រះជន្មនៅឡើយ ហើយបាន

រត់រួចពីកងទ័ពវៀតណាម ។ នៅថ្ងៃ ៨ មករា ១៩៧៩ លោកតា សឺន សាន បានផ្ញើសារទូរលេខមួយច្បាប់ក្នុងនាមព្រឹទ្ធាចារ្យខ្មែរនៅប្រទេសបារាំង ទៅថ្វាយព្រះអង្គថា៖ "ឯ.ឧ. នង គិមនី ឯ.ឧ. ញឹក ជូឡុង ឯ.ឧ. ចាយ ធុល ឯ.ឧ. ប៊ុន អ៊ុក និងទូលបង្គំ មានសេចក្តីត្រេកអរជាខ្លាំង ដោយដឹងថាព្រះអង្គបានយាងមកដល់ទីក្រុងប៉េកាំង ស្តុប[85] ជនរួមជាតិខ្មែរនៅបរទេសភាគច្រើនណាស់ រួមទាំងនាយទាហានជាន់ខ្ពស់ផងមានជំនឿលើអង្គសម្តេច ដើម្បីបណ្តេញជាបន្ទាន់នូវរបប ប៉ុល ពត ដែលពិភពលោកផ្តន្ទាទោស និង ដើម្បីឲ្យកងទ័ពវៀតណាមខាងជើងទាំងអស់ ដកចេញពីប្រទេសកម្ពុជា ឆ្ពោះទៅសម្រេចមហាសាមគ្គីជាតិក្នុងក្របខ័ណ្ឌកម្ពុជាអព្យាក្រឹត្យពិតប្រាកដ និង ឯករាជ្យ ស្តុប ដោយគោរពជាទីបំផុត ស្តុបបញ្ចប់ សឺន សាន[86]" ។ ដោយបានទទួលដំណឹងថា សម្តេច យាងទៅទីក្រុងញូវយ៉ក លោកតា សឺន សាន ក៏ធ្វើដំណើរទៅរកជួបព្រះអង្គ នៅសហរដ្ឋអាមេរិក ។ ក៏ប៉ុន្តែ នៅពេលលោកតាទៅរកសម្តេចឯសណ្ឋាគារនាទីក្រុងញូវយ៉កនោះ ភ្នាក់ងារសម្ងាត់អាមេរិកបានរំដោះព្រះអង្គឲ្យគង់នៅក្នុងមន្ទីរពេទ្យមួយ ដែលមិនអាចទៅជួបបាន ។ លោកតា សឺន សាន បានត្រឹមតែជួបព្រះអង្គតាមទូរស័ព្ទតែប៉ុណ្ណោះ ។

នយោបាយជាន់ខ្ពស់របស់លោកតា សឺន សាន

នៅពេលត្រឡប់ពីទីក្រុងញូវយ៉កវិញ នៅចុងខែ មករា ១៩៧៩ លោកតា សឺន សាន បានបញ្ជូនឧត្តមសេនីយ ជៀន ដែល ឲ្យទៅប្រទេសថៃ រួចចុះទៅដល់

[85] នៅក្នុងសារទូរលេខ ដោយគេមិនអាចប្រើខណ្ឌសញ្ញាបាន គេប្រើអក្សរ (STOP) ស្តុបជំនួសខណ្ឌសញ្ញា និង (STOPEND) ស្តុបបញ្ចប់ ជំនួសសញ្ញាខណ្ឌចប់ ។

[86] Son Sann (Télégramme 00740 de) à SAR Norodom Sihanouk c/o Ministère des Affaires Etrangères, le 8 octobre 1979, RP Chine, Pékin.

សមរភូមិនៅតាមទល់ដែនខ្មែរ-ថៃ ដើម្បីប្រមែប្រមូលចងក្រងកម្លាំងតស៊ូទាំងអស់ ដែលនៅរប៉ាត់រប៉ាយគ្នានោះឲ្យទៅជាកម្លាំងរួបរួមជាតិមួយក្នុងការតស៊ូរំដោះជាតិ ។ លោកតា សឺន សាន បានប្រាប់ពួកយើងនៅពេលក្រោយៗមកទៀតថា លោកតាបានទូលសម្តេច សីហនុ តាមទូរស័ព្ទឲ្យជ្រាបអំពីសេចក្តីសំរេចបង្កើតកម្លាំងតស៊ូ ហើយបានស្នើសុំឲ្យព្រះអង្គដឹកនាំចលនាតស៊ូរំដោះជាតិនេះ ដែលប្រុងនឹងបង្កើតនោះ ។ បើតាមសំដីលោកតា សឺន សាន សម្តេច សីហនុ មិនព្រមទទួលមុខនាទីដឹកនាំចលនាតស៊ូនេះទេ ព្រោះព្រះអង្គមិនមានបំណងនឹងធ្វើសកម្មភាពនយោបាយណាមួយឡើយនៅពេលនោះ ។ លោកតា សឺន សាន បញ្ជាក់ថា សម្តេចក៏មិនបានប្រឆាំងគំនិតបង្កើតចលនាតស៊ូនេះដែរ គ្រាន់តែសុំកុំអាលយកព្រះនាមព្រះអង្គមកប្រើតែប៉ុណ្ណោះ ។

តាមរយៈលោកឧត្តមសេនីយ ដៀន ដែល លោកតា សឺន សាន បានផ្ញើសារមួយច្បាប់ទៅជូនមេៗយុទ្ធជនសេរីកាទាំងអស់ ដើម្បីណែនាំថា លោក ដៀន ដែល ទទួលបេសកកម្មពីលោកតាឲ្យមកបង្កើតកងទ័ពរំដោះជាតិមួយដោយប្រមូលយុទ្ធជនទាំងអស់ នៅតាមជាយដែន មុននឹងឈានទៅបង្កើតអង្គការចាត់តាំងខាងនយោបាយមួយ ដើម្បីដឹកនាំការតស៊ូរំដោះជាតិ ។ លោកតា បានគូសបញ្ជាក់ថា បើមិនធ្វើតាមនេះទេ យុទ្ធជនទាំងនោះមិនអាចសង្ឃឹមថា នឹងទទួលនូវជំនួយពីប្រទេសជាមិត្តឡើយ ។ ដូច្នេះ ជំនួយជាកត្តាគន្លឹះនៃការអូសទាញប្រមែប្រមូលកម្លាំងនេះ ព្រោះបើគ្មានជំនួយពីខាងក្រៅទេ យុទ្ធជនទាំងនោះ មិនអាចសង្ឃឹមធ្វើសកម្មភាពអ្វីឲ្យធំដុំបានឡើយ ។

តាមពិតលោកតា សឺន សាន បានធ្វើការបញ្ចុះបញ្ចូលអំពាវនាវដល់មេដឹកនាំក្រុមអ្នកតស៊ូទាំងអស់នៅតាមជាយដែននោះ ឲ្យមករួបរួមគ្នាដើម្បីបង្កើតជាកងទ័ពនៅក្នុងរណសិរ្សមួយប្រឆាំងវៀតណាម ។ ឧត្តមសេនីយ ដៀន ដែល ឈ្មោះ

ចម្បាំងហៅថា ដែល ដេវី បានធ្វើដំណើរពីទីក្រុងប៉ារីស ក្នុងនាមជាបេសកជនរបស់លោកតា សឺន សាន ដើម្បីនាំសាររបស់លោកតា មកជូនយុទ្ធជនសេរីកានៅលើសមរភូមិ ។ លោកឧត្តមសេនីយបានទទួលជោគជ័យដោយបានទទួលការស្វាគមន៍ ពីក្រុមយុទ្ធជនសេរីកាស្ទើរទាំងអស់ ។

នៅថ្ងៃទី ៥ មីនា ១៩៧៩ អ្នកតស៊ូខ្មែរ ១៦ នាក់[87] បានជួបជុំគ្នានៅលើទឹកដីខ្មែរ ។ អ្នកទាំងនោះ សុទ្ធតែជាមេដឹកនាំក្រុមអ្នកតស៊ូ ដែលមាន៖ ១. លោក អ៊ឹម ឈូដេត ២. លោក កេត រ៉ែត ៣. លោក សុខ សេរី ៤. លោក ក្រវ៉ាញ ផល ៥. លោក មហាក្រៃ ៦. លោក លុច ផៃ ៧. លោក ទួន ចាយ ៨. លោក សែន សុខស្មី ៩. លោក ដែល ដេវី ១០. លោក សេក សំអៀត ១១. លោក កែវ សាវុធ ១២. លោក ចាយ សីលា ឬ ម៉ៅ ហម ១៣. លោក មួន សុភ័ណ ១៤. ញ៉ែម ភួង ១៥. លោក បែន រី ១៦. លោក សៀម សំអុន ។ អ្នកដឹកនាំទាំង ១៦ រូបនេះបានស្រុះស្រួលគ្នាបង្កើតជាកងទ័ពមួយឈ្មោះថា កងកម្លាំងជាតិរំដោះប្រជាពលរដ្ឋខ្មែរ ។ គេទាំងអស់គ្នា បានចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍បង្កើតកងទ័ពនេះ ដោយបានគូសបញ្ជាក់អំពីហេតុផល ឬ មូលហេតុ ដែលនាំឲ្យកងទ័ពកកើតឡើង និងដោយបានធ្វើការអំពាវនាវ ឲ្យខ្មែរគ្រប់និន្នាការចូលមករួបរួមជាមួយយុទ្ធជនសេរីកា ដើម្បីបង្កើតរណសិរ្សយោធា និង នយោបាយមួយ នៅពេលក្រោយ ដែលគេនឹងឲ្យឈ្មោះថា រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ (រ.ជ.រ.ប.ខ.) ដើម្បីរំដោះកម្ពុជាឲ្យចេញពីការកាន់កាប់របស់បរទេស និង ដើម្បីឲ្យប្រជាពលរដ្ឋខ្មែរធ្វើការជ្រើសរើសដោយសេរីនូវរបបនយោបាយគ្រប់គ្រងប្រទេសរបស់ខ្លួន ។ ក្រុមយុទ្ធជនសេរីកាទាំងនោះបានសុំឲ្យលោកតា សឺន សាន ធ្វើជាអ្នកដឹកនាំរបស់ពួកគេក្នុងបេសកកម្មបង្រួបបង្រួមជនរួមជាតិខ្មែរ[88] ដោយក្រុមយុទ្ធជនទាំងនោះប្រគល់ជូនលោកតានូវ

[87] KPNLF Bulletin No. 4, March 12, 1983 p. 1.
[88] KPNLF Bulletin no. 4, "Declaration of the KPNLAF, March 5, 1979" op. cit, p.3.

អំណាចគ្រប់យ៉ាងដើម្បីបំពេញបេសកកម្មនេះ ។ ក៏ប៉ុន្តែនៅក្នុងសេចក្តីថ្លែងការណ៍របស់ក្រុមយុទ្ធជនសេរីកាទាំងនោះ ពួកគេបានបើកទ្វារចំហរថ្វាយសម្តេច សីហនុ ក្រែងថ្ងៃណាមួយ សម្តេចនឹងយាងចូលរួមធ្វើការតស៊ូជាមួយ ដោយទុកលទ្ធភាពថ្វាយព្រះអង្គ ចូលមកធ្វើការដឹកនាំចលនាតស៊ូនៅពេលណាក៏បាន ។ នៅក្នុងសេចក្តីថ្លែងការណ៍របស់ក្រុមយុទ្ធជនសេរីកានោះ មានថ្លែងជាអាទិថា៖ "រ.ជ.រ.ប.ខ. នឹងបំរើឥស្សរជនខ្មែរណា ដែលគោរពគោលការណ៍របស់ពួកគេ ហើយដែលអាចបង្កើតឲ្យមានសាមគ្គីភាពនៃខ្មែរទាំងអស់" ។ ឥស្សរជនខ្មែរនាពេលនោះ សំដៅលើអង្គសម្តេច សីហនុ នេះតែម្តង ។ ទទួលបានសំណូមពររបស់យុទ្ធជនសេរីកាទាំងនោះរួចហើយ លោកតា សឺន សាន មិនទាន់សម្រេចចិត្តភ្លាមទេ ។ លោកតាប្រើពេលវេលាប្រហែលពីរខែ ដើម្បីថ្លឹងថ្លែងថាតើគួរទៅដឹកនាំយុទ្ធជនសេរីកាទាំងនោះដែរឬទេ? ម្យ៉ាង លោកតានៅស្ទាក់ស្ទើរក្នុងចិត្ត ដោយមិនទាន់ដឹងច្បាស់ថា តើសម្តេច សីហនុ មានបំណងយ៉ាងណា? តើព្រះអង្គយាងមកដឹកនាំចលនាតស៊ូដែរឬទេ? ក្រោយមក នៅថ្ងៃទី ២៩ មេសា ១៩៧៩ លោកតា សឺន សាន ដែលមានអាយុ ៦៨ ឆ្នាំ បានយល់ព្រមតាមសំណើរបស់អ្នកតស៊ូទាំង ១៦ នាក់ ដើម្បីចូលទៅរៀបចំចលនា រ.ជ.រ.ប.ខ. នេះឡើង ។

ការសម្រេចចិត្តរបស់លោកតា សឺន សាន ទាំងនេះក៏សុទ្ធតែជា "នយោបាយជាន់ខ្ពស់" ដែលគ្មាននរណាដឹងឮសោះឡើយ ក្រៅតែពីអ្នកដែលនៅជិតជិតប៉ុន្មាននាក់តែប៉ុណ្ណោះ ។ សមាជិកភាគច្រើននៅក្នុងសមាគមមិនបានដឹងរឿងសម្ងាត់ទាំងអស់នោះទេ ។ រឿងនេះ ក៏ដូចជារឿងសម្ងាត់ដែលលោកតា សឺន សាន ធ្វើដំណើរ ទៅទីក្រុងញូវយ៉ក ដើម្បីជួបសម្តេច សីហនុ ។ នៅពេលត្រឡប់ពីទីក្រុងញូវយ៉កមកវិញ ទើបលោកតាកោះប្រជុំសមាជិកសកម្ម ដើម្បីផ្តល់ព័ត៌មានខ្លះៗតែប៉ុណ្ណោះ ។ មែនទែនទៅ លោកតា សឺន សាន និង មនុស្សជំនិតៗឃុំគ្រងព័ត៌មាន

បានល្អណាស់គឺ អ្វីដែលអាចឲ្យដឹង និង អ្វីដែលរក្សាជាការអាថ៌កំបាំង ។ គេឲ្យដឹងចំពោះនរណាដែលស្មោះត្រង់ពិតប្រាកដ ជាពិសេស អ្នកណាដែលមានការទុកចិត្តពីក្រុមគ្រួសាររបស់លោកតា តាមរបៀបធ្វើការដោយបើកចំហរផងដោយការសម្ងាត់ផង ។ នៅពេលដែលលោកតា សឺន សាន បញ្ជូនឧត្តមសេនីយ ដៀន ដែល ទៅទល់ដែនខ្មែរ-ថៃ លោកតាមិនបានឲ្យពួកយើងដឹងឡើយ ។ តាមពិតទៅពួកយើងក្មេងៗ ដែលស្ម័គ្រចិត្តមកធ្វើការជាមួយលោកតា សឺន សាន មិនដែលទាមទារចង់ដឹងចង់ឮអំពីការសម្ងាត់អ្វីទេ ។ ក៏ប៉ុន្តែជួនកាលយើងក៏មានការភ្ញាក់ផ្អើលខ្លះដែរនៅពេល ដែលយើងទទួលដំណឹងអំពីការសម្ងាត់ដែលលោកតាលាក់បាំងយ៉ាងជិតនោះ ត្រូវបានខ្វះខ្វាយទៅក្រៅៗពីរង្វង់សមាគមយើង ដែលនាំឲ្យពួកយើងម្តងៗមានការខ្មាស់អៀនយ៉ាងខ្លាំង ។ យើងមានការខ្មាស់អៀន ព្រោះថាទោះបីជានៅធ្វើការផ្ទាល់ជាមួយលោកតាក៏ដោយ ក៏មិនបានដឹងរឿងរ៉ាវធំដុំអ្វី ដូចអ្នកនៅក្រៅដែលគេទទួលបានព័ត៌មានសម្ងាត់ៗទាន់ពេលវេលា ។

លោកតា សឺន សាន និង សម្តេច សីហនុ តាមមាគ៌ាទីទៃៗ

នៅថ្ងៃទី ៨ មេសា ១៩៧៩ សមាគម អា ហ្សេ កា អឺ បានបើកប្រជុំមហាសន្និបាតលើកទី១របស់ខ្លួន ។ លោកតា សឺន សាន បានត្រូវជ្រើសតាំងតាមផ្លូវការជាប្រធានសមាគម លោក នង គឹមនី អតីតរដ្ឋមន្ត្រីជាអនុប្រធាន ឯចំណែកលោក ទ្រឿង មាលី ជាអគ្គលេខាធិការ ។ លោក ចាយ ធុល អតីតរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ និង រូបខ្ញុំ ត្រូវបានតែងតាំងជាស្នងការគណនេយ្យ[89] ។ សមាគមនេះបន្ត

[89] នេត គុណ, សាយ ឫរី, សេចក្តីកត់ហេតុនៃការិយាល័យរៀបចំបោះឆ្នោតជ្រើសរើសគណកម្មាធិការនាយកសំរាប់ឆ្នាំ ១៩៧៩-៨០ថ្ងៃទី ៨/៤/៧៩ ។

សកម្មភាពជាធម្មតាគឺ លើកតម្កើងការពារវប្បធម៌ជាតិ ព្រះពុទ្ធសាសនា និង ស្វែងរកជំនួយពីសហគមន៍ខ្មែរនៅប្រទេសបារាំង និង ផ្តល់ជំនួយដល់ជនភៀសខ្លួនខ្មែរដែលទើបមកដល់ថ្មីៗ ។ ក៏ប៉ុន្តែតាមផ្លូវសម្ងាត់វិញ សមាគមនេះ ក៏ចាប់ផ្តើមជ្រើសរើសអ្នកស្នេហ្គ្រចិត្តឲ្យចូលទៅបំរើក្នុងចលនាតស៊ូរំដោះជាតិដែរ ។

ចំពោះសម្តេច នរោត្តម សីហនុ វិញ ជាដំបូងព្រះអង្គហាក់ដូចជានៅស្ងាក់ស្ងើរក្នុងសកម្មភាពនយោបាយណាមួយ ។ ប៉ុន្តែក្រោយមក ព្រះអង្គក៏ប្តូរព្រះទ័យទៅវិញ ។ ព្រះអង្គប្រហែលជាយល់ឃើញថាកងទ័ពជាតិរំដោះប្រជាពលរដ្ឋខ្មែរ (ក.ជ.រ.ប.ខ.) ជាក្រុមយោធាមួយ ដែលបង្កើតឡើងដោយពួកឧត្តមសេនីយសាធារណរដ្ឋដែលបានទម្លាក់ព្រះអង្គនៅឆ្នាំ ១៩៧០ គឺជាក្រុមដែលមិនអាចឲ្យព្រះអង្គលើកលែងទោសឲ្យបានឡើយ ។ ប្រហែលជាព្រះអង្គទតឃើញថាក្រុមលោកតា សឺន សាន ភាគច្រើនជាអ្នកសាធារណរដ្ឋ ទើបព្រះអង្គមិនឆ្លើយតបតាមសំណើរបស់លោកតា ។ ព្រះអង្គក៏ចាប់ផ្តើមនូវសកម្មភាពមួយចំនួន ។ ពេលនោះ សម្តេចទ្រង់គង់នៅទីក្រុងប៉េកាំងផង និង ទីក្រុងព្យុងយ៉ាងនៃប្រទេសកូរ៉េខាងជើងផង ដែលនៅទីនោះមហាមិត្តរបស់ព្រះអង្គគឺ លោកសេនាប្រមុខ គីម អ៊ីលស៊ុង បានថ្វាយដល់ព្រះអង្គនូវវិមានដ៏ធំស្តឹមស្តែមួយដើម្បីទ្រង់គង់ប្រថាប់នៅ ។ ការដែលព្រះអង្គសំរេចព្រះទ័យចេញមកធ្វើនយោបាយឡើងវិញ និង ការដែលព្រះអង្គមិនព្រមដឹកនាំកម្លាំងតស៊ូ ដែលមានលោកតា សឺន សាន ជាមេកើយនោះ បានបង្ខំឲ្យសមាជិក អា ហ្សេ កា អឺ ខ្លះ ដែលជាអ្នកសីហនុនិយមដាច់ខាត ឬ ដែលជាសមាជិករាជវង្សានុវង្សដូចជាព្រះអង្គម្ចាស់ក្សត្រី នរោត្តម វជ្ជ៉ា បានលាចេញពីសមាគម ។ ដូច្នេះក្រុមរបាំប្រពៃណីនៅទីក្រុងប៉ារីស ក៏បានត្រូវបំបែកជាពីរគឺ មួយជាក្រុមសីហនុនិយម និង មួយទៀតជាក្រុម សឺន សាននិយម ។ រីឯសមាគមខ្មែរមិនមែនកុម្មុយនីស្តនៅប្រទេសបារាំង ក៏បែកជាពីរក្រុមធំៗ ដូចក្រុមរបាំប្រពៃណីនេះដែរ ។

នៅខែ កក្កដា ១៩៧៩ សម្តេច សីហនុ បានផ្ញើសារទី១របស់ព្រះអង្គទៅជូនជនរួមជាតិនៅក្រៅប្រទេស ដោយបានសំដែងនូវការខកព្រះទ័យរបស់ព្រះអង្គចំពោះអង្គការសហប្រជាជាតិ ដែលមិនបានអនុញ្ញាតឲ្យព្រះអង្គទៅថ្លែងក្នុងនាមជនភៀសខ្លួនខ្មែរ និង ដើម្បីឲ្យព្រះអង្គបានថ្លែងអំពីផែនការរបស់ព្រះអង្គសំរាប់អនាគតដើម្បីដោះស្រាយបញ្ហាខ្មែរ ។ ព្រះអង្គបានស្នើពីទីក្រុងព្យុងយ៉ាង តាមសារចុះថ្ងៃទី ១២ កក្កដា ១៩៧៩ ឲ្យបង្កើតជាបន្ទាន់នូវរណសិរ្សរួបរួមខ្មែរដើម្បីសង្គ្រោះជាតិ និង រដ្ឋាភិបាលបណ្តោះអាសន្ននៃកម្ពុជាឯករាជ្យ អព្យាក្រឹត្យ ដែលហៅតាមអក្សរកាត់ជាភាសាបារាំងថា ហ្វ៊ុកសាណា (FUKSANA: Front Uni Khmer pour le Salut National) និង ហ្គូបប៊ិចសុិន (GOUPECIN: Gouvernement Provisoire de l'Etat du Cambodge Indépendant)[90]។ សម្តេចបានស្នើថា ឲ្យសមាគមខ្មែរនៅបរទេសទាំងអស់ ក្លាយជាផ្នែករបស់ហ្វ៊ុកសាណា (FUKSANA) ហើយឲ្យសមាគមទាំងនោះចាត់តាំងតំណាងរបស់ខ្លួន ទៅចូលរួមក្នុងសមាជជាតិមួយ ដែលនឹងត្រូវរៀបចំឡើងនៅប្រទេសបារាំង ឬ នៅសហរដ្ឋអាមេរិក ។ នៅក្នុងសមាជជាតិនេះ សម្តេច សីហនុ ស្នើជាផ្លូវការដាក់បេក្ខភាពជាប្រធាននៃរណសិរ្ស និង ជារដ្ឋមន្ត្រីក្រសួងការបរទេសរបស់ ហ្គូបប៊ិចសុិន (GOUPECIN) ។ នៅក្នុងសារទី២ នៅថ្ងៃដដែល សម្តេចបានស្នើថាគោលការណ៍ថ្មីនៃរដ្ឋធម្មនុញ្ញរបស់កម្ពុជាមិនត្រូវយករាជានិយម ឬ សាធារណរដ្ឋទេ ក៏ប៉ុន្តែឲ្យយកយ៉ាងខ្លីត្រឹមតែ"កម្ពុជា" ។ ប្រមុខរដ្ឋនឹងត្រូវហៅថាប្រមុខរដ្ឋនៃកម្ពុជា ហើយដែលត្រូវតែងតាំងឡើងជាផ្លូវការក្រោយការបោះឆ្នោតជាទូទៅមួយ ក្រោមការត្រួតពិនិត្យរបស់អង្គការសហប្រជាជាតិ ដោយអ្នកតំណាងរាស្ត្រ និង ព្រឹទ្ធសភា ។ ទង់ជាតិ និង ភ្លេងជាតិត្រូវយកដូច

[90] Norodom Sihanouk (Message du Prince) A Tous Ses Compatriotes A l'Etranger, Pyong-Yang, le 12 juillet 1979.

ទង់ជាតិ និង ភ្លេងជាតិមុនរដ្ឋប្រហារ ១៩៧០ តែភ្លេងជាតិនោះ យកតែវគ្គទី២គឺ ចាប់ពីប្រាសាទសីលាកំបាំងកណ្តាលព្រៃ..តែប៉ុណ្ណោះ ។ នៅក្នុងកម្មវិធីនយោបាយ របស់រណសិរ្ស និង រដ្ឋាភិបាលដែលសម្តេចស្នើនោះ សម្តេច បានសុំឲ្យមានការ គោរពសិទ្ធិមនុស្ស និង ធម្មនុញ្ញអង្គការសហប្រជាជាតិ ព្រមទាំងការគោរពលទ្ធិ ប្រជាធិបតេយ្យបែបលោកខាងលិចមួយរយភាគរយ ឲ្យមានសេរីភាពក្នុងការធ្វើ ដំណើរចំពោះអ្នកការសែតជាតិ និង អន្តរជាតិជាដើម ។ល។ ចំពោះនយោបាយ ក្រៅប្រទេស សម្តេចស្នើលើកយកគោលការណ៍បញ្ចសីលា ដោយមានទំនាក់ទំនង ល្អ និង សហប្រតិបត្តិការល្អជាមួយប្រទេសទាំងអស់នៅក្នុងពិភពលោក លើកលែង តែជាមួយប្រទេសអ៊ីស្រាអែល និង កូរ៉េខាងត្បូងរបស់លោក ប៉ាក់ ជុងហ៊ី ចេញ ។ នៅក្នុងសារទី២នេះ សម្តេចបានសុំឲ្យមានការតែងតាំងព្រះអង្គជានាយករដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងការបរទេស ហើយប្រសិនបើព្រះអង្គត្រូវបានតែងតាំងតាម សំណើមែននោះ ក្នុងហានៈព្រះអង្គជានាយករដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងការបរ ទេសព្រះអង្គនឹងចាត់វិធានការផ្នែកការទូត និង តាមផ្លូវមិត្តភាព ដើម្បីសាកល្បងធ្វើ ឲ្យមានការដកកងទ័ពវៀតណាមចេញពីកម្ពុជា ដោយគ្មានការបង្ហូរឈាមខ្មែរ[91] ។

នៅថ្ងៃជាមួយគ្នានោះដែរគឺ ថ្ងៃទី ១២ កក្កដា ១៩៧៩ សម្តេច បានផ្ញើសារ ទី៣របស់ព្រះអង្គអំពាវនាវឲ្យភាគីខ្មែរ ដែលមានជម្លោះខាងផ្លូវអាវុធឲ្យនាំគ្នាទំលាក់ អាវុធចោល និង បញ្ឈប់នូវការតស៊ូខាងមនោគមវិជ្ជារបស់ខ្លួន ដោយសម្តេចបាន អញ្ជើញលោក ប៉ុល ពត អៀង សារី និង អ្នកទទួលខុសត្រូវឯទៀតនៃរបបប្រល័យ ពូជសាសន៍ឲ្យដកខ្លួនដោយសុវត្ថិភាពទៅនៅប្រទេសចិន។ ជាមួយគ្នានោះ សម្តេច

[91] Norodom Sihanouk (Deuxièm Message du Prince) A Tous Ses Compatriotes A l'Etranger, Pyong-Yang, le 12 juillet 1979.

បានអញ្ជើញក្រុមលោក ហេង សំរិន ឲ្យត្រឡប់ទៅទីក្រុងព្រៃនគរ និង ហាណូយ វិញ[92] ។

សមាជិកជាច្រើននៃសមាគម អា ហ្សេ កា អឺ មានការមិនសប្បាយចិត្ត ចំពោះការផ្តួចផ្តើមគំនិតថ្មីរបស់សម្តេច សីហនុ នេះ ជាពិសេសចំពោះគំនិត បង្កើតរណសិរ្សថ្មី នៅពេលដែលគេបានបង្កើតកងទ័ពជាតិរំដោះប្រជាពលរដ្ឋខ្មែរទៅហើយនោះ ហើយដែលកងទ័ពនេះនឹងត្រូវដឹកនាំតាមផ្លូវនយោបាយដោយរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ ។ លោកតា សឺន សាន បានឲ្យដឹងថា នៅក្នុងសេចក្តីប្រកាសបង្កើតកងទ័ពជាតិរំដោះប្រជាពលរដ្ឋខ្មែរ កងទ័ពនេះបានត្រៀមខ្លួនបំរើឥស្សរជនជាន់ខ្ពស់ខ្មែរមួយរូប ដែលក្នុងន័យនេះ គេចង់និយាយថាត្រៀមខ្លួនបំរើសម្តេច សីហនុ ។ នៅពេលនោះ លោកតា សឺន សាន ដែលជាអតីតរដ្ឋមន្ត្រីទីមួយម្នាក់របស់សម្តេចសីហនុ បានកោះប្រជុំសមាជិក ដើម្បីជជែកពិភាក្សាអំពីសំណើរបស់សម្តេច ។ គំនិតថានឹងចាត់វិធានការផ្នែកការទូត និង ជាផ្លូវមិត្តភាព ដើម្បីសាកល្បងឲ្យទទួលបាននូវការដកកងទ័ពវៀតណាមចេញពីកម្ពុជា ដោយមិនឲ្យមានការបង្ហូរឈាមខ្មែរនោះ បានធ្វើឲ្យក្រុមគ្រួសាររលោកតា សឺន សាន និង ក្រុមដែលនៅជុំវិញលោកតាមានការមិនសប្បាយចិត្ត ។ ពួកអ្នកទាំងនោះយល់ថា វិធានការនេះ និង គំនិតនេះគ្រាន់តែជាការរវើរវាយមួយ ដែលមិនអាចក្លាយជាការពិតបានឡើយ ។ ពួកអ្នកទាំងនោះ យល់ថាបើគ្មានការគាបសង្កត់យ៉ាងខ្លាំងខាងផ្លូវយោធាទេនោះ កងទ័ពវៀតណាមប្រាកដជាមិនត្រូវដកចេញពីកម្ពុជាបានឡើយ ។

ទោះបីជាយ៉ាងនោះក្តី សម្តេច សីហនុ នៅតែបន្តផ្ញើសារចេញមកជូនជនរួមជាតិជាបន្តបន្ទាប់ ។ នៅក្នុងសារមួយនោះ ព្រះអង្គស្នើសុំឲ្យមានការតែងតាំងអតីត

[92] Norodom Sihanouk (Troisième Message du Prince) A Tous Ses Compatriotes A l'Etranger, Pyong-Yang, le 12 juillet 1979.

ទីប្រឹក្សារបស់ព្រះអង្គគឺលោកតា ញឹក ជូឡុង និង លោកតា សឺន សាន ជាអ្នកព្រាងលក្ខន្តិក:កម្មវិធីនយោបាយ សេចក្តីថ្លែងការណ៍ប្រកាសបង្កើតរណសិរ្សរួបរួមជាតិរបស់ព្រះអង្គ ។ សេចក្តីព្រាងទាំងនេះ នឹងត្រូវដាក់ជូនសមាជជាតិអនុម័តនៅពេលខាងមុខ ។ ក៏ប៉ុន្តែព័ត៌មានស្តីពីប្រតិកម្ម ឬ ការមិនសប្បាយចិត្តដែលលេចចេញពីទីក្រុងប៉ារីស ដែលសម្តេចទទួលនៅពេលនោះ បានបង្ហាញថាមិនមានការគាំទ្រដល់ការផ្តួចផ្តើមគំនិតរបស់ព្រះអង្គប៉ុន្មានឡើយ ដែលធ្វើឲ្យព្រះអង្គមិនសប្បាយព្រះទ័យ ។

នៅក្នុងសារទី៨ សម្តេច មានបន្ទូលថា៖ "នៅទីក្រុងប៉ារីសបច្ចាមិត្ររបស់ខ្ញុំគេកំពុងធ្វើការមួលបង្កាច់មកលើរូបខ្ញុំ ដើម្បីធ្វើវិច្ឆេទកម្មលើគំរោងរៀបចំសមាជជាតិ និង ការបង្កើតរដ្ឋាភិបាលបណ្តោះអាសន្នដែលខ្ញុំបានស្នើ" "ខ្ញុំពុំមានមហិច្ឆតាអ្វីផ្ទាល់ខ្លួនទេ" ។ "ដោយសារមហាមិត្តភាពជាពិសេស ដែលខ្ញុំមានជាមួយសាធារណរដ្ឋប្រជាមានិតចិន ជាមួយលោកប្រធានាធិបតី គីម អ៊ីលស៊ុង ការរស់នៅរបស់ខ្ញុំទាំងផ្លូវកាយទាំងផ្លូវចិត្តទាំងផ្លូវសម្ភារៈគឺ មានភាពសម្បូរសប្បាយជាងកាលទសវត្សរ៍ឆ្នាំ ១៩៥០-១៩៦០ ទៅទៀត" ។ "វាំងរបស់ខ្ញុំនៅព្យុងយ៉ាងមានទំហំប្រាំដង និង មានភាពប្រណិតជាងមហាប្រាសាទខេមរិន្ទទៅទៀត" ។ មហាប្រាសាទខេមរិន្ទជាព្រះរាជដំណាក់នៅក្នុងព្រះបរមរាជវាំងនៅទីក្រុងភ្នំពេញ[93] ។ នៅក្នុងសារទី៩ របស់សម្តេចចុះថ្ងៃទី ២១ កក្កដា ១៩៧៩ សម្តេច សីហនុ បានបង្ហាញពីគោលដំហររបស់ព្រះអង្គខុសពីគោលដំហរលោកតា សឺន សាន គឺព្រះអង្គមានគំរោងបង្កើត និង ដឹកនាំគណបក្សនយោបាយផ្សេងពី លោកតា សឺន សាន នៅក្នុងការបោះ

[93] Norodom Sihanouk (Huitième Message du Prince) A Ses Compatriotes A l'Etranger (undated)?.

ឆ្នោតណាមួយនៅពេលអនាគត[94] ។ នៅទីបំផុតសមាគម អា ហ្សេ កា អឺ បានសំរេចថា នឹងឆ្លើយតបទៅនឹងលិខិតអញ្ជើញរបស់សម្តេច ។

លោកតា សឺន សាន មិនចង់ជាប់ជំពាក់ដោយផ្ទាល់ក្នុងការប៉ះទង្គិចពាក្យសំដីជាមួយសម្តេច សីហនុ ទេ ។ ក៏ប៉ុន្តែកិរិយារបស់លោកតាជាអ្នកប្រឆាំងសម្តេច សីហនុ យ៉ាងខ្លាំងក្លាបំផុតនាសម័យនោះ ។ លោកយាយ សឺន សាន ចាត់ទុកសម្តេច សីហនុ ថាជាអ្នកទទួលខុសត្រូវទាំងស្រុង ចំពោះជោគវាសនារបស់ប្រទេសខ្មែរដែលកំពុងជួបប្រទះនូវវិបត្តិដ៏ធ្ងន់ធ្ងរនៅពេលនោះ ។ លោកយាយបានបន្ទោសសម្តេច សីហនុ ថាព្រះអង្គបិតនៅក្រោមឥទ្ធិពលនៃមនុស្សនៅជុំវិញមួយចំនួនដែលមានអ្នកម្នាង ម៉ូនិច[95] និង លោកយាយ ប៉ុម ជាមាតាអ្នកម្នាងជាមេកើយ ។ តាមពិតទៅលោកយាយ សឺន សាន មានកក្តីភាពយ៉ាងស្មោះចំពោះម្ចាស់ក្សត្រី នរលក្ខណ៍ ដែលជាព្រះជាយាមួយអង្គទៀតរបស់សម្តេច សីហនុ ។ ផ្ទុយពីអ្នកម្នាង ម៉ូនិច ដែលចេញពីត្រកូលរាស្ត្រសាមញ្ញធម្មតា ព្រះអង្គម្ចាស់ក្សត្រី នរលក្ខណ៍ ប្រសូតចេញពីត្រកូលក្សត្រនៅក្នុងរាជវង្សានុវង្ស ។ ម្យ៉ាងទៀតព្រះអង្គម្ចាស់ក្សត្រី នរលក្ខណ៍ បានទទួលសេចក្តីស្រឡាញ់ពេញព្រះរាជហឫទ័យពីសម្តេចមហាក្សត្រី យានី កុសុមៈ ជាព្រះវរាជមាតានៃសម្តេច សីហនុ ។ សម្តេច សីហនុ បានយាងចេញពីព្រះបរមរាជវាំងទៅគង់នៅវិមានចំការមនជាមួយអ្នកម្នាង ម៉ូនិច ប្រហែលតាំងពីដើមទសវត្សរ៍ឆ្នាំ ១៩៦០ មកម្ល៉េះ ។ ដូច្នេះនៅក្នុងរង្វង់សមាគម ក៏មានអ្នកប្រឆាំង និង អ្នកគាំទ្រសំណើរបស់សម្តេច សីហនុ ឲ្យមានការកោះប្រជុំសមាជជាតិនេះដែរ ។ នៅចុងបំផុត សមាគមបានសំរេចចាត់តាំងសមាជិកក្មេងៗ ឬ យុវសមា

[94] Norodom Sihanouk (Neuvième Message du Prince) A Ses Compatriotes A l'Etranger, Pyong-Yang, le 21 juillet 1979.

[95] នៅសម័យសង្គមរាស្ត្រនិយម សម្តេចម៉ែ សម្តេចយាយ តែងត្រូវបានប្រជាពលរដ្ឋខ្មែរហៅព្រះនាមថាជា អ្នកម្នាងម៉ូនិច ។

ជិកនៃសមាគមជាអ្នកធ្វើលិខិតឆ្លើយតបទៅសម្តេច ។ រូបខ្ញុំត្រូវបានទទួលបន្ទុកតាក់តែងអត្ថបទជាភាសាខ្មែរនៃការឆ្លើយតបនោះ ។

សេចក្តីព្រាងសំបុត្ររបស់ខ្ញុំនោះ បានត្រូវសមាគមអនុម័តទទួលយកទាំងស្រុង ។ នៅក្នុងលិខិតឆ្លើយតបទៅនឹងសម្តេច សីហនុ នោះ ខ្ញុំបានថ្លែងនូវក្តីរំភើបថ្វាយព្រះអង្គ ចំពោះការដែលសម្តេចយកព្រះទ័យទុកដាក់ចំពោះវាសនាជាតិ ទោះបីជាមានឧបសគ្គរាំងស្ទះជាច្រើនយ៉ាងណាក៏ដោយ ។ ខ្ញុំបានគូសបញ្ជាក់នូវសេចក្តីប្តេជ្ញាចិត្តរបស់យើងទាំងអស់គ្នា ក្នុងការរំដោះប្រទេសកម្ពុជាឲ្យចេញពីនឹមយួនឈ្លានពាន ។ ខ្ញុំបានគូសបញ្ជាក់ថែមទៀតនូវសាមគ្គីជាឆ្អូងមួយនៃកម្លាំងស្នេហាជាតិទាំងអស់ លើកលែងតែពួកខ្មែរក្រហមចេញគឺ សាមគ្គីភាពនោះហើយដែលអាចធ្វើឲ្យបច្ចាមិត្តមានការភ័យខ្លាច ។ ក្នុងលិខិតនោះ ខ្ញុំផ្តល់មតិថាខ្មាំងសត្រូវកំពុងប្រើល្បិចឲ្យខ្មែរឈ្លោះនឹងខ្មែរគឺ គេធ្វើការបំបែកបំបាក់សាមគ្គីជាតិនោះហើយ ។ លិខិតនោះ[96] ចុះថ្ងៃទី ៨ សីហា ១៩៧៩ មានលោក ទ្រឿង មាលី ជាអ្នកចុះហត្ថលេខាក្នុងនាមជាអគ្គលេខាធិការសមាគម អា ហ្សេ កា អឺ និង ជាតំណាងក្រុមយុវជននៃសមាគមនេះ ដែលមកពីទីក្រុងប៉ារីស ទូលូ លីល ប្រ៊ូវ៉ែង់ កូដាហ្សួរ និងទីក្រុងទួរ ។ លោក ទ្រឿង មាលី នឹងនាំយកលិខិតនេះទៅថ្វាយសម្តេចនៅទីក្រុងព្យុងយ៉ាង និង ទៅចូលរួមសមាជជាតិ ដែលនឹងត្រូវកោះប្រជុំនោះ ។

នៅទីបំផុត សមាជមួយបានត្រូវធ្វើឡើងនៅខែ កញ្ញា ១៩៧៩ នៅប្រទេសកូរ៉េខាងជើង តែមិនមែននៅប្រទេសបារាំង ឬ នៅស.រ.អា ដូចដែលសម្តេច សីហនុ បានគ្រោងក្នុងសាររបស់ព្រះអង្គលើកទី១នោះឡើយ ។ លោក ទ្រឿង មាលី បានធ្វើដំណើរទៅកាន់ទីក្រុងព្យុងយ៉ាង ក្នុងឋានៈជាអ្នកតំណាងសមាគម អា ហ្សេ កា

[96] ទ្រឿង មាលី អគ្គលេខាធិការ ស.ខ.ប. [ទូលថ្វាយសម្តេច នរោត្តម សីហនុ] ប៉ារីសថ្ងៃ ៨ សីហា ១៩៧៩ ។

អឺ ក៏ប៉ុន្តែនៅពេលដែលលោកត្រឡប់មកពីព្យុងយ៉ាងវិញ គាត់ក៏បែកចិត្តពី អា ហ្សេ កា អឺ មកផ្តល់ការគាំទ្រថ្វាយសម្តេច សីហនុ ជាដរាបតមក ។ នៅទីក្រុងព្យុងយ៉ាង សម្តេច សីហនុ មិនបានទទួលជោគជ័យក្នុងការបង្កើតរណសិរ្ស ឬ រដ្ឋាភិបាល បណ្តោះអាសន្នតាមបំណងព្រះអង្គឡើយ ។ សមាជនោះបានត្រូវបញ្ចប់ ដោយ គ្រាន់តែមានការបង្កើតនូវសហព័ន្ធមួយឈ្មោះថា សហព័ន្ធខ្មែរអ្នកជាតិនិយម ដែល មានសម្តេច នរោត្តម សីហនុ ជាប្រធាន ។ តាំងពីពេលនោះមក លោក ទ្រឿង មាលី ក៏បានលាឈប់ពីតំណែងអគ្គលេខាធិការសមាគមអា ហ្សេ កា អឺ ដើម្បីមក បំរើចលនាសីហនុនិយមវិញ ។ ដូច្នេះសមាគម អា ហ្សេ កា អឺ ក៏បានជ្រើសរើស លោកបណ្ឌិត ឆាយ ហាន់ចេង កូនប្រសារលោកតា សឺន សាន ឲ្យឡើងកាន់ តំណែងជាអគ្គលេខាធិការជំនួសលោក ទ្រឿង មាលី តទៅ ។

លោកតាប្រកាសបង្កើតរណសិរ្ស

នៅចន្លោះពេលនោះ លោកតា សឺន សាន បានត្រៀមរៀបចំធ្វើដំណើរមក ប្រទេសថៃ ។ ដោយមានមនុស្សជំនិតពីរ ឬ បីនាក់ទៅជាមួយផង លោកតាបាន ចេញដំណើរពីទីក្រុងប៉ារីសជាសម្ងាត់មិនឲ្យពួកយើងដឹងទៀតឡើយ ។ ដោយមាន ការគាំទ្រពីក្រុមយោធាថៃ លោកតា សឺន សាន ក៏បានសំរេចដូចបំណងក្នុងការ បង្កើតជាផ្លូវការនូវរណសិរ្សមួយ ដែលមានឈ្មោះថារណសិរ្សជាតិរំដោះប្រជាពល រដ្ឋខ្មែរ "រ.ជ.រ.ប.ខ."[97] ។ រណសិរ្សនេះ ត្រូវបានប្រកាសជាសាធារណៈនៅថ្ងៃទី ៩ តុលា ១៩៧៩ នៅលើទឹកដីខ្មែរជាប់ខេត្តត្រាតនៃប្រទេសថៃនៅលើភ្នំបន្ទាត់ក្នុងភូមិ

[97] Son Sann, Front National du Peuple khmer, Décision No. 79/01/FNL, Territoire Khmer, le 09 Octobre 1979.

មួយឈ្មោះភូមិសុខសាន្ត ដែលបិតនៅក្រោមការត្រួតត្រារបស់លោកវរសេនីយ ព្រុំ វិត ។

តាមឯកសារផ្លូវការ មានចលនាអ្នកជាតិនិយមចំនួនប្រាំ[98] បានចូលរួមក្នុងរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរនេះ ។ ចលនាទាំងប្រាំនោះគឺ៖ ១. រណសិរ្សរួបរួមជាតិរំដោះសាធារណរដ្ឋខ្មែរ ដែលគេស្គាល់ថាជាចលនា រក្សាសម្បុក ដោយមានលោក រក្សា សម្បុក ជាអ្នកដឹកនាំ ២. ចលនាកុកស ៣. ចលនាឃ្លាំងមឿង ៤. ចលនានេនរោង ៥. ចលនាបក្សីចាំក្រុង ។ ឯកសារនោះបានចែងថាមានប្រជាពលរដ្ឋចាត់ឲ្យតំណាងមកពីខេត្ត ១៥ ចូលមករួបរួមបង្កើតជាផ្លូវការនូវរណសិរ្សរំដោះប្រជាពលរដ្ឋខ្មែរនោះ ។ លោកតា សឺន សាន បានត្រូវជ្រើសរើសជាប្រធាន ឯលោកតា ឈាន វ៉ែម ជាអ្នកប្រជាធិបតេយ្យម្នាក់ និង ជាអតីតនាយករដ្ឋមន្ត្រី ត្រូវបានជ្រើសរើសជាអនុប្រធាន ។ ភ្លាមៗនោះ រណសិរ្សបានចេញសេចក្តីប្រកាសចំនួនបី ដែលបានទទួលការគាំទ្រពីអ្នកចូលរួមប្រជុំ ។ សេចក្តីប្រកាសទី១ ចែងអំពីការបង្កើតរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ (រ.ជ.រ.ប.ខ.) ។ សេចក្តីសំរេចទី២ ទទួលស្គាល់កងទ័ពជាតិរំដោះប្រជាពលរដ្ឋខ្មែរ ដែលបង្កើតឡើងកាលពីថ្ងៃទី ៥ មីនា ១៩៧៩[99] ឯសេចក្តីសំរេចទី៣ ប្រកាសតែងតាំងឧត្តមសេនីយ ដៀន ដែលជានាយសេនាធិការ[100] ។ រចនាសម្ព័ន្ធរបស់រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ (រ.ជ.រ. ប.ខ.) មានគណៈកម្មាធិការប្រតិបត្តិមួយ ក្រុមប្រឹក្សាជាតិមួយ ក្រុមប្រឹក្សាព្រឹទ្ធាចារ្យមួយ (មនុស្សចាស់ទុំ) និង ក្រុមប្រឹក្សាយោធាមួយ[101] ។

[98] Proclaimation of the Khmer People's National Liberation Front, Khmer Teeritory, October 9, 1979
[99] Son Sann, Front National de Libération du Peuple Khmer, Décision No. 79/02/FNL, Territoire Khmer, le 9 octobre 1979.
[100] Son Sann, Front National de Libération du Peuple Khmer, Décision No. 79/03/FNL, Territoire Khmer, le 9 octobre 1979.
[101] Son Sann, Front National de Libération du Peuple Khmer, Décision No. 79/01/FNL, op. cit.

នៅក្នុងសុន្ទរកថា នៃការបង្កើតរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរនោះ លោកតា សឺន សាន បានថ្លែងថា សុខចិត្តទទួលតំណែងជាប្រធានរណសិរ្សក្នុងពេលនេះ[102] ដើម្បីឲ្យរណសិរ្សនោះចាប់ផ្តើមដំណើរការ ក៏ប៉ុន្តែនៅពេលណាមួយដ៏សមស្រប លោកតានឹងស្នើសុំឲ្យមានការតែងតាំងឥស្សរជនដ៏ទៃផ្សេងវិញ ឲ្យមកដឹកនាំចលនាតស៊ូរហូតទទួលជ័យជំនះ ព្រោះថានៅពេលនេះ លោកតាមានអាយុច្រើនណាស់ហើយគឺ ៦៨ ឆ្នាំ ។ លោកតាស្នើនូវគោលការណ៍ចម្បងនៃកម្មវិធីនយោបាយរបស់រណសិរ្សគឺ គោលការណ៍នៃលទ្ធិជាតិនិយម សង្គមនិយមព្រះពុទ្ធសាសនាដោយយកធម៌កណ្តាល អព្យាក្រឹត្យពិតប្រាកដ ឯករាជ្យជាតិ អធិបតេយ្យភាពរបស់ប្រជាពលរដ្ឋ បូរណភាពទឹកដី និង ការរួមរស់ល្អជាមួយអ្នកជិតខាង និងដោយសន្តិភាព ។

នៅទីបំផុតលោកតា សឺន សាន បានធ្វើសេចក្តីអំពាវនាវសូមឲ្យជនរួមជាតិខ្មែរទាំងក្រៅ និង ក្នុងប្រទេសរួបរួមគ្នាដើម្បីប្រមូលផ្តុំកម្លាំងជាតិទាំងអស់ទៅរំដោះជាតិឲ្យរួចផុតពីសត្រូវទាំងឡាយ ដោយមិនត្រូវយកបញ្ហាផ្ទាល់ខ្លួនជាធំឡើយ ។ ចំពោះអង្គការសហប្រជាជាតិ ចំពោះប្រទេសមហាអំណាច និង ចំពោះប្រទេសទាំងឡាយនៅអាស៊ីអគ្នេយ៍ លោកតា សឺន សាន បានអំពាវនាវសុំឲ្យជួយប្រជាពលរដ្ឋខ្មែរឲ្យទាន់ពេលវេលា ដើម្បីឲ្យរួចចាកពីអាណានិគមវៀតណាមខាងជើង ដោយសុំឲ្យមានការកោះប្រជុំនូវសន្និសីទអន្តរជាតិមួយ ដែលប្រទេសអាស៊ានបានស្នើសុំ គឺ សន្និសីទមួយដែលមានគោលបំណងបញ្ឈប់ការបាញ់គ្នាជាបន្ទាន់ ដើម្បីឲ្យអង្គការមនុស្សធម៌អន្តរជាតិនាំនូវម្ហូបអាហារ និង ថ្នាំពេទ្យមកជួយដល់កម្ពុជា និង ផ្តល់ដល់ប្រជាពលរដ្ឋខ្មែរ ដែលកំពុងរងគ្រោះ ព្រមទាំងសុំឲ្យកងទ័ពវៀតណាមដកថយចេញពីកម្ពុជា និង ជំនួសដោយកងទ័ពអង្គការសហប្រជាជាតិដើម្បីឲ្យអង្គការសហ

[102] Son Sann, President of the Khmer Pedople's National Liberation Front, Speech, Khmer Territory, October 9, 1979.

ប្រជាជាតិនេះ រៀបចំការបោះឆ្នោតជាទូទៅមួយ ។ នៅទីបញ្ចប់ លោកតា សឺន សាន បានសុំឲ្យប្រទេសកម្ពុជាក្លាយជាប្រទេសអព្យាក្រិត្យ ។ ចំពោះប្រទេសវៀតណាម និង ប្រទេសលាវ លោកតា សឺន សាន ថ្លែងថា "ពួកវៀតណាមបានលើកទ័ពចូលមកកម្ពុជាដើម្បីជួយរំដោះប្រជាពលរដ្ឋខ្មែរ ឲ្យរួចអំពីរបបសាហាវឃោរឃៅរបស់ខ្មែរក្រហម ឥឡូវនេះប្រជាពលរដ្ឋខ្មែរសុំឲ្យវៀតណាមដកកងទ័ពចេញពីកម្ពុជា"[103] ។ "ដោយមានជំនួយពីអង្គការសហប្រជាជាតិ និង ដោយមានជំនួយពីប្រទេសទាំងឡាយដែលស្នេហាសេរីភាព និង សិទ្ធិមនុស្ស ប្រជាពលរដ្ឋខ្មែរនឹងដោះស្រាយបញ្ហាខ្មែរក្រហមដោយខ្លួនឯង បន្ទាប់ពីការដកកងទ័ពរបស់វៀតណាមអស់ពីប្រទេសកម្ពុជា ។ ប្រជាពលរដ្ឋវៀតណាម និង កម្ពុជា ត្រូវនាំគ្នាពន្លត់ភ្លើងកម្មពៀរដែលនាំឲ្យយើងស្អប់ខ្ពើមគ្នាអស់រយៈពេលច្រើនសតវត្សមកហើយ..." ។

ដើម្បីផ្សព្វផ្សាយនូវសេចក្តីប្រកាសបង្កើត រ.ជ.រ.ប.ខ. នេះ លោកតា សឺន សាន បានអញ្ជើញក្រុមសារព័ត៌មានអន្តរជាតិ ដែលមានទីតាំងនៅទីក្រុងបាងកក នៃប្រទេសថៃ ឲ្យចូលមកយកព័ត៌មានផ្ទាល់នៅក្នុងពិធីនោះ ។ ប៉ុន្មានថ្ងៃ ឬ សប្តាហ៍ក្រោយមក ព័ត៌មានស្តីពីការបង្កើតរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរនេះ ក៏បានត្រូវផ្សព្វផ្សាយទូទាំងពិភពលោក ។ នៅទីក្រុងប៉ារីស នៅថ្ងៃទី ១២ តុលា ១៩៧៩ ខ្ញុំក៏បានចូលរួមក្នុងពិធីប្រកាសរណសិរ្សនេះ ដែលរៀបចំឡើងដោយសមាគម អាហ្សេ កា អឺ ។ នៅក្នុងឱកាសនោះ លោក ជុន អ៊ុក អតីតរដ្ឋមន្ត្រី បានធ្វើសន្និសីទសារព័ត៌មានមួយ ក្នុងឋានៈជាអ្នកតំណាងរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរនៅក្នុងសណ្ឋាគារមួយឈ្មោះមេរីឌីយែន (Méridienne) ។ លោក ជុន អ៊ុក ផ្សព្វផ្សាយអំពីអំពើប្រល័យពូជសាសន៍របស់ពួកខ្មែរក្រហមទៅលើប្រជាពលរដ្ឋខ្មែរ និងការលុកលុយរបស់កងទ័ពវៀតណាមខាងជើងចូលមកទឹកដីកម្ពុជាដែលគ្មានគោល

[103] Son Sann, President of the Khmer People's National Liberation Front, Speech, op. cit.

បំណងអ្វីក្រៅពីលេបយកទឹកដីខ្មែរទាំងមូលឡើយ ។ សន្និសីទសារព័ត៌មាននោះ បានត្រូវបណ្តាញសារព័ត៌មានបារាំងជាច្រើនយកទៅផ្សាយបន្ត ។ សរុបសេចក្តីទៅ ការផ្សព្វផ្សាយនេះ ជាជោគជ័យផ្នែកទំនាក់ទំនងសាធារណៈរបស់លោកតា សឺន សាន និង រ.ជ.រ.ប.ខ. ។ សូមបញ្ជាក់ថា នៅសម័យនោះ រ.ជ.រ.ប.ខ. មានលក្ខណៈគួរឲ្យទុកចិត្តបានជាងសហព័ន្ធខ្មែរអ្នកជាតិនិយមរបស់សម្តេច នរោត្តម សីហនុ ដែលបានបង្កើតក្នុងខែ កញ្ញា ១៩៧៩ នៅប្រទេសកូរ៉េខាងជើង ។ ផ្ទុយពីសហព័ន្ធអ្នកជាតិនិយមខ្មែររបស់សម្តេច សីហនុ រ.ជ.រ.ប.ខ. បានត្រូវបង្កើតឡើងនៅលើទឹកដីខ្មែរ ហើយបានប្រមូលផ្តុំអ្នកតស៊ូពិតប្រាកដមែនទែនដែលបិតនៅក្រោមបញ្ជារបស់ឧត្តមសេនីយម្នាក់ដែលមានគេស្គាល់ច្រើននៅក្នុងរបបសាធារណរដ្ឋ ។ បន្ថែមលើនេះ លោកតា សឺន សាន កាលសម័យនោះ ត្រូវបានគេមើលឃើញថា ជាមនុស្សមិនបានជាប់ជំពាក់ក្នុងរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ក្នុងឆ្នាំ ១៩៧០ ។ ម្យ៉ាងទៀត លោកតា សឺន សាន ក៏ពុំបានជាប់ជំពាក់ក្នុងការជួយជ្រោមជ្រែងឲ្យខ្មែរក្រហមឡើងមកកាន់អំណាចនៅឆ្នាំ ១៩៧៥ ដែរ ។ ឆ្នាំទី១នៃកំណើត រ.ជ.រ.ប.ខ. បានត្រូវទទួលស្គាល់ដោយសារការប្រមូលនូវការគាំទ្រជាច្រើន ពីសហគមន៍ខ្មែរនៅក្រៅប្រទេសទូទាំងពិភពលោក ។

ក៏ប៉ុន្តែលោកតា អ៊ិន តាំ ដែលជាមេដឹកនាំម្នាក់ក្នុងរដ្ឋប្រហារ ១៩៧០ ទម្លាក់សម្តេច សីហនុ និង ជាសមាជិកស្ថាបនិកម្នាក់របស់សមាគម អា ហ្សេ កា អឺ បានចាកចេញពីសមាគមនេះ ទៅចូលរួមជាមួយសម្តេច សីហនុ ។ លោកតា អ៊ិន តាំ មិនសប្បាយចិត្តនឹងការតែងតាំងឧត្តមសេនីយ ជៀន ដែល ឲ្យធ្វើជាអ្នកដឹកនាំកងទ័ពជាតិរំដោះប្រជាពលរដ្ឋខ្មែរ ។ លោកតា អ៊ិន តាំ តវ៉ាថា លោកតា សឺន សាន មិនបានគោរពតាមពាក្យសន្យា ដែលថានឹងតែងតាំងគាត់ឲ្យដឹកនាំកងទ័ពតាំងពីកាលជួបចរចាគ្នា ដើម្បីបង្កើតសមាគម អា ហ្សេ កា អឺ មកម្ល៉េះ ។ លោកតា សឺន

សាន បានសារភាពថាបានសន្យាថានឹងតែងតាំងលោក អ៊ិន តាំ ជាអគ្គមេបញ្ជាការនៃកងទ័ពជាតិរំដោះប្រជាពលរដ្ឋខ្មែរ (ក.ជ.រ.ប.ខ.) ។ នៅពេលនេះ លោកតាបានតែងតាំងលោកឧត្តមសេនីយ ដៀន ដែល ធ្វើត្រឹមតែនាយសេនាធិការនៃកងទ័ពតែប៉ុណ្ណោះ មិនមែនជាអគ្គមេបញ្ជាការទេ ។ ដោយសារការមិនយល់គ្នានេះ លោកតា អ៊ិន តាំ ក៏បានបែកចេញពីលោកតា សឺន សាន ហើយបានទៅចូលរួមបំរើសម្តេច សីហនុ ដើម្បីរៀបចំកងទ័ពសីហនុនិយមមួយតាំងពីពេលនោះរៀងមក ។

នៅថ្ងៃទី ១៥ តុលា ១៩៧៩ លោកតា សឺន សាន បានចេញក្រឹត្យជាផ្លូវការបង្កើតនូវស្ថាប័នមួយចំនួន ដែលមានលក្ខណៈប្រហាក់ប្រហែលនឹងរដ្ឋាភិបាលដ៏តូចមួយដែរ[104] ។ ស្ថាប័នទី១នោះគឺ គណៈកម្មាធិការប្រតិបត្តិហៅកាត់ជាអក្សរបារាំង (COMEX) ។ គណៈកម្មាធិការប្រតិបត្តិនេះ ជាអ្នកទទួលខុសត្រូវលើការងារសំខាន់ៗដូចជាការងារផ្នែកនយោបាយ ការទូត និង រដ្ឋបាល ។ សមាជិកនៃគណៈកម្មាធិការម្នាក់ៗ មានក្រសួងដែលស្ថិតនៅក្នុងអំណាចក្នុងរង្វង់តួនាទីរបស់ខ្លួន ។ នៅពេលនោះ រណសិរ្សបានបង្កើតក្រសួងចំនួនប្រាំពីរនៃគណៈកម្មាធិការប្រតិបត្តិ ដែលមានសមាជិកប្រាំពីររូបជាអ្នកទទួលខុសត្រូវ ។ ក្រសួងទាំងប្រាំពីរនោះគឺ៖ ១. ក្រសួងមហាផ្ទៃ ២. ក្រសួងការបរទេស ៣. ក្រសួងកិច្ចការយោធា ៤. ក្រសួងវប្បធម៌ និង សាសនា ៥. ក្រសួងហិរញ្ញវត្ថុ និង អភិវឌ្ឍន៍ ៦. ក្រសួងព័ត៌មាន និង ឃោសនាការ ៧. ក្រសួងយុត្តិធម៌ ។ នៅពេលនោះដែរ លោកតា សឺន សាន បាន តែងតាំងសមាសភាពនៃគណៈកម្មាធិការប្រតិបត្តិដូចតទៅ៖[105] ១. លោកតា ឈាន វ៉ែម ជាអនុប្រធាន ២. លោក នាង ជិនហន

[104] Son Sann, Front National de Libération du Peuple Khmer, Décision No. 79/04/FNL, Territoire Khmer, le 15 octobre 1979.
[105] Son Sann, Front National de Libération du Peuple Khmer, Décision No. 79/05/FNL, Territoire Khmer, le 15 octobre 1979.

ជាអគ្គលេខាធិការ ៣. លោក ជៀន ដែល ជាសមាជិកទទួលបន្ទុកកិច្ចការយោធា ៤. អ៊ឹម ឈូ ដេត ទទួលបន្ទុកក្រសួងមហាផ្ទៃ ៥. លោក ព្រុំ វិត ទទួលបន្ទុកកិច្ចការសង្គមកិច្ច វប្បធម៌ និង សាសនា ៦. លោក ងួន ពីទូរ៉ែត ទទួលបន្ទុកខាងព័ត៌មានឃោសនាការ និង អតីតយុទ្ធជន ។ ចំណែកលោកស្រី សួន កាសេត លោក សឺន ស៊ូប៊ែរ៉ែ ដែលជាកូនប្រុសច្បងរបស់លោកតា សឺន សាន និង លោក សឺន មុនា កូនប្រុសម្នាក់ទៀត បានទទួលការតែងតាំងជាអ្នកទទួលបន្ទុកផ្នែកបេសកកម្មពិសេសរបស់គណៈកម្មាធិការប្រតិបត្តិ[106] ។

ខ្ញុំជាសកម្មជន រ.ជ.រ.ប.ខ.

ជាមួយនឹងការកកើតនៃ រ.ជ.រ.ប.ខ. សមាគម អា ហ្សេ កា អឺ បានក្លាយទៅជាទីស្នាក់ការទីពីររបស់រណសិរ្សនេះ នៅទីក្រុងប៉ារីសប្រទេសបារាំង ជាទីដែលលោកតា សឺន សាន ស្នាក់នៅម្តងៗក្នុងចន្លោះនៃការស្នាក់អាស្រ័យរបស់លោកតានៅតាមទល់ដែនខ្មែរ-ថៃ និង ក្នុងទីក្រុងបាងកក ។ គឺនៅទីក្រុង ប៉ារីសនេះហើយដែលលោកតា សឺន សាន អាចផ្តួចផ្តើមគំនិតការទូតអ្វីមួយ ឬ សកម្មភាពនយោបាយថ្មីអ្វីមួយ ។ ដូចនេះ សមាគម អា ហ្សេ កា អឺ ក៏បានក្លាយជាសាខាមួយរបស់ រ.ជ.រ.ប.ខ. ប្រចាំទ្វីបអឺរ៉ុប ។ ចាប់ពីពេលនោះតមក ខ្ញុំមិនមែនគ្រាន់តែធ្វើការឲ្យតែសមាគមមួយមុខនោះទេគឺ ខ្ញុំមានការងារធ្វើកាន់តែច្រើនឡើងថែមទៀត ។ ខ្ញុំធ្វើការឲ្យ រ.ជ.រ.ប.ខ. ក្នុងឋានៈជាអ្នកឃោសនាដ៏សកម្មម្នាក់ផង ។ ខ្ញុំធ្វើដំណើរដោយមិនខ្លាចនឿយហត់ទូទាំងប្រទេសបារាំងរួមជាមួយ លោកបណ្ឌិត ឆាយ ហាន់ចេង ក្នុងការប្រឹងប្រែងស្វែងរកការគាំទ្រ ពីសំណាក់អាណិកជនខ្មែររស់នៅ

[106] Son Sann, Front National de Libération du Peuple Khmer, Décision No. 79/06/FNL, Territoire Khmer, le 15 octobre 1979.

ប្រទេសបារាំងឲ្យដល់ រ.ជ.រ.ប.ខ. ។ ជាញឹកញាប់ខ្ញុំតែងយករូបថត រូបស្លាយ ឬ ខ្សែភាពយន្តដែលផ្ញើតាមត្រង់ពីទីក្រុងបាងកក និង ដែលភាគច្រើនគ្មានចំណងជើង ឬ បទពន្យល់អ្វីទាំងអស់ មកធ្វើអត្ថាធិប្បាយដោយបញ្ចូល សម្លេង និង ភ្លេង កំដរតាមការយល់ដឹងផ្ទាល់របស់ខ្ញុំ ។ ជួនកាលខ្ញុំត្រូវធ្វើអត្ថាធិប្បាយលើរូបភាពដែលខ្ញុំមិនបានដឹងន័យពិតប្រាកដផង ។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ខ្ញុំបានខិតខំកែលំអធ្វើឲ្យការផ្សព្វផ្សាយ ឬ ការបញ្ចាំងភាពយន្តទាំងនោះ មានលក្ខណៈអាជីព ដែលធ្វើឲ្យអ្នកចូលរួមមានការពេញចិត្តជានិច្ច ។ ខ្ញុំបានបញ្ចូលសម្លេងរបស់ខ្ញុំក្នុងខ្សែភាពយន្តឯកសារទំហំ ១៦ ម.ម.មួយ ដោយមានអមដោយភ្លេងពិណពាទ្យ និង បទអត្ថាធិប្បាយប្រកបដោយខ្លឹមសារប្រវត្តិសាស្ត្រ និង បន្លឺសម្លេងឡើងចុះដែលធ្វើឲ្យអ្នកទស្សនាមានក្តីរំភើបយ៉ាងខ្លាំង ។ ចំពោះអាណិកជនខ្មែរស់នៅប្រទេសបារាំង ដែលបានទស្សនាខ្សែភាពយន្តនោះ ពួកគេតែងទន្ទឹងរង់ចាំដំណឹងនានាពីប្រទេសខ្មែរ ។

ខ្សែភាពយន្តឯកសាររបស់ខ្ញុំនោះ ធ្វើឲ្យមនុស្សចាស់ៗទប់ទឹកភ្នែកមិនបានចង់វិលទៅស្លាប់នៅស្រុកខ្មែរវិញ ។ អ្នកខ្លះនឹកស្រុកខ្លាំងពេក ក៏កើតមានសេចក្តីស្នេហាជាតិមួយកំរិតថែមទៀត ។ តាមរយៈរូបភាពក្នុងខ្សែភាពយន្ត គេអាចមើលឃើញក្តីលំបាកវេទនារបស់ឃុទ្ធជន រ.ជ.រ.ប.ខ. និង ប្រជាពលរដ្ឋ ដែលរស់នៅក្នុងតំបន់កាន់កាប់ដោយ រ.ជ.រ.ប.ខ. នេះ ។ គេអាចមើលឃើញរូបភាពរបស់លោកតា សឺន សាន ដែលទៅធ្វើទស្សនកិច្ចនៅក្នុងតំបន់ទាំងនោះ ។ រូបលោកតាហាក់ដូចជាស្គមស្គាំង ដែលអាចឲ្យអ្នកមើលយល់ថាលោកតាប្រហែលជារស់នៅជាប្រចាំក្នុងតំបន់នោះពិតប្រាកដមែន ។ យើងទាំងអស់គ្នាគោរពលោកតា ចំពោះសេចក្តីក្លាហាន និង ស្មារតីលះបង់ខ្ពស់របស់លោកតា ដែលសុខចិត្តចូលមកធ្វើការដឹកនាំចលនាតស៊ូ ក្នុងវ័យចំណាស់ទៅហើយ ។ មែនទែនទៅ នៅសម័យនោះ យើងមិន

ដែលគិតថា លោកតាស់នៅឯទីក្រុងបាងកកម្តងណាឡើយ ។ តាមពិតពួកយើងទទួលព័ត៌មានបន្តិចបន្តួច ពីរណសិរ្សតែតាមរយៈបណ្ឌិត ឆាយ ហាន់ចេង តែប៉ុណ្ណោះ ។ លោក ឆាយ ហាន់ចេង ជាប្រធានផ្នែកព័ត៌មាន ដែលជាអ្នកចាត់ចែងតែម្នាក់គត់ក្នុងការចំរាញ់ និង ជ្រើសរើសព័ត៌មាន តើព័ត៌មានណាអាចត្រូវប្រាប់អ្នកណាម្នាក់អំពីសកម្មភាពរបស់ រ.ជ.រ. ប.ខ. ។

នៅក្នុងសមាគម អា ហ្សេ កា អឺ ឬ នៅក្នុង រ.ជ.រ.ប.ខ. នៅប្រទេសបារាំង លោកបណ្ឌិត ឆាយ ហាន់ចេង កាន់តែមានតួនាទីសំខាន់ឡើង ដោយសារតែគ្រប់គ្រងបានព័ត៌មានទាំងអស់ទាក់ទងនឹង រ.ជ.រ.ប.ខ. ។ សមាជិកសកម្មមួយចំនួនបន្ទោសថា គាត់មិនបាននិយាយការពិតនៅពេល ដែលលោកតា សឺន សាន និងកូនពីរនាក់គឺ លោក សឺន ស៊ូប៊ែរ៉ែ លោក សឺន មុនា ព្រមដោយលោកស្រី សួន កាសេត និង លោក នាង ជិនហន ធ្វើដំណើរចេញពីទីក្រុងប៉ារីសទៅប្រទេសថៃ ។ សមាជិកមួយចំនួនទៀតនឹកគិតថាការ ដែលគេមិនឲ្យដឹងព័ត៌មានសំខាន់ៗ ទាំងនោះប្រហែលជាដោយសារក្រុមលោកតា សឺន សាន មិនទុកចិត្ត ទោះបីជាពួកគេខិតខំបំរើសមាគម អា ហ្សេ កា អឺ និង រ.ជ.រ.ប.ខ. យ៉ាងណាក៏ដោយ ។ សមាជិកទាំងនោះយល់ថា ពួកគេគួរតែបានដឹងព័ត៌មានទាំងនោះ ព្រោះយ៉ាងហោចណាស់ពួកគេអាចទៅជូនដំណើរលោកតា សឺន សាន និង កូនចៅគាត់នៅឯព្រលានយន្តហោះផងដែរ ។ សមាជិកទាំងនោះជឿថា ការចេញដំណើរទាំងនោះគឺជាបេសកកម្មស្នេហាជាតិ ដូច្នេះពួកគេគួរតែទៅជូនដំណើរជាកិត្តិយស ។ ចំពោះខ្ញុំនៅគ្រាដំបូងខ្ញុំក៏មានអារម្មណ៍យ៉ាងដូច្នេះដែរ ព្រោះថាខ្ញុំមិនដែលបានដឹងឮផ្នាល់អំពីការងារសំខាន់ៗសោះឡើយ ។ ក៏ប៉ុន្តែ បន្តិចម្តងៗខ្ញុំចេះតែនឹកថាបញ្ហាទាំងអស់នោះទាក់ទងទៅនឹងសន្តិសុខ និង សុវត្ថិភាពរបស់អ្នកចេញទៅតស៊ូ ព្រោះកិច្ចការទាំងអស់នេះ អាចប៉ះពាល់ដល់អាយុជីវិតអ្នកទាំងនោះផង ។ យ៉ាងនោះហើយ

ទើបខ្ញុំបានរំសាយចិត្តមួហ្មងទាំងនោះ ហើយក៏ទទួលយកគំនឹតថានេះ ជាការងារចាត់ចែងធម្មតារបស់ថ្នាក់ដឹកនាំតែប៉ុណ្ណោះ ។ ចំណុចនេះគួសបង្ហាញពីរបៀបរបបធ្វើការរបស់លោកតា សឺន សាន ដែលមានភាពអត្តនោម័ត និង ដែលជាកត្តានាំឲ្យមានការមិនយល់ មិនទុកចិត្តគ្នានៅក្នុងចលនា សឺន សាននិយមនេះរហូតមក ។

ព្រះអង្គទាមទារចរចាផ្ទាល់ជាមួយវៀតណាម

នៅចន្លោះពេលនោះ ខ្ញុំក៏បានដំណឹងពីសារព័ត៌មានបារាំងដែរថា សម្តេច នរោត្តម សីហនុ ក្នុងឋានៈព្រះអង្គជាប្រធានសហព័ន្ធខ្មែរអ្នកជាតិនិយម បានធ្វើសារមួយច្បាប់ពីដំណាក់របស់ព្រះអង្គ នៅទីក្រុងព្យុងយ៉ាងនៃប្រទេសកូរ៉េខាងជើង ទៅជូនលោកនាយករដ្ឋមន្ត្រីវៀតណាមខាងជើង ផាំ វ៉ាន់ដុង ដើម្បីស្នើឲ្យវៀតណាមធ្វើការចរចាផ្ទាល់ជាមួយព្រះអង្គ ក្នុងន័យនាំមកប្រទេសកម្ពុជាវិញនូវឯករាជភាព និង អព្យាក្រឹតភាព ។ តាមឯកសាររបស់ព្រះអង្គដែលបានផ្សព្វផ្សាយជាសាធារណៈនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ថាកាលនោះនៅឆ្នាំ ១៩៧៩ សម្តេច សីហនុ បានធ្វើសារ ៣ ច្បាប់ ទៅជូនលោកនាយករដ្ឋមន្ត្រី ផាំ វ៉ាន់ដុងគឺ៖ សារទី១ ចុះថ្ងៃទី ៧ តុលា សារទី២ ចុះថ្ងៃទី ២៣ តុលា និង សារទី៣ ចុះថ្ងៃទី ១១ វិច្ឆិកា ១៩៧៩ ។ នៅក្នុងសារចុះថ្ងៃទី ៧ តុលា ១៩៧៩ សម្តេចបានរំលឹកមេដឹកនាំវៀតណាមអំពីជំនួយច្រើនរូបភាព ដែលព្រះអង្គបានផ្តល់ដល់ការតស៊ូរបស់ប្រជាជនវៀតណាមក្នុងសង្គ្រាមប្រឆាំងចក្រពត្តិអាមេរិក នាសម័យដែលទ្រង់កាន់អំណាច ដូចជា៖ ការផ្តល់ទីជំរកសម្រាប់ឈប់សម្រាក និង ព្យាបាលអ្នករបួស ឬ អ្នកជម្ងឺព្រមទាំងការអនុញ្ញាតឲ្យប្រើប្រាស់កំពង់ផែព្រះសីហនុ ដើម្បីដឹកជញ្ជូនអាវុធយុទ្ធភណ្ឌ

ដល់កងទ័ពវៀតកុងជាដើម ។ ជំនួយទាំងនេះ នាំឲ្យប្រទេសកម្ពុជាត្រូវទទួលការចោទប្រកាន់ថាបានបោះចោលអព្យាក្រឹតភាពរបស់ខ្លួន ហើយត្រូវទទួលរងនូវការវាយប្រហារតាមដើងគោក និង តាមផ្លូវអាកាសពីកងទ័ពអាមេរិក និង វៀតណាមខាងត្បូង រហូតដល់កើតមានរដ្ឋប្រហារថ្ងៃ ១៨ មីនា ១៩៧០ ។

ក្នុងសាររបស់ព្រះអង្គនោះសម្តេច សីហនុ ស្នើសុំឲ្យមេដឹកនាំវៀតណាមធ្វើការចរចាជាមួយព្រះអង្គ ដើម្បីកសាងឡើងវិញនូវឯករាជ្យ និង អព្យាក្រឹតភាពនៃកម្ពុជា និង ដើម្បីឲ្យមានឡើងវិញនូវទំនាក់ទំនងដ៏រាក់ទាក់ និង ប្រកបដោយផ្លែផ្ការវាងកម្ពុជា និង វៀតណាម និង រវាងប្រជាជនទាំងពីរ ។ សម្តេចបន្ថែមថា ព្រះអង្គមិនជាក់លក្ខខណ្ឌអ្វីទេគឺ អាចជួបគ្នានៅទីក្រុងហាណូយក៏បាន នៅទីក្រុងព្យុងយ៉ាងក៏បាន ឬ នៅទីក្រុងប្រាកក៏បាន ។ សម្តេច សីហនុ បញ្ជាក់ថាព្រះអង្គជាអ្នកដឹកនាំខ្មែរតែមួយគត់ ដែលបានប្រជាជនខ្មែរទាំងមូលទទួលស្គាល់ ហើយព្រះអង្គក៏ជាអ្នកតំណាងខ្មែរស្នេហាជាតិទាំងអស់ផងដែរ ។ សម្តេច សីហនុ ព្រមានថានឹងមានផលអាក្រក់ដ៏ធ្ងន់ធ្ងរ ប្រសិនបើអ្នកដឹកនាំវៀតណាម មិនព្រមចាប់ដៃចរចាជាមួយព្រះអង្គទេនោះ ។

នៅថ្ងៃ ២៣ តុលា ដដែល សម្តេច ទ្រង់ផ្ញើសារមួយទៀត ទៅជូនលោកនាយករដ្ឋមន្ត្រី ផាំ វ៉ាន់ ដុង ។ នៅក្នុងសារទី២នេះ ព្រះអង្គរំលឹកនូវខ្លឹមសារនៃសារមុន ក៏ប៉ុន្តែសម្តេចតវ៉ាថា មិនត្រឹមតែមិនបានទទួលចម្លើយពីលោកនាយករដ្ឋមន្ត្រីប៉ុណ្ណោះទេ ឯកអគ្គរដ្ឋទូតវៀតណាម ថែមទាំងបានថ្លែងនៅចំពោះមុខអ្នកកាសែតអាមេរិក តាមរយៈសន្និសីទកាសែតនៅទីក្រុងប៉េកាំងថា ព្រះអង្គគ្រាន់តែជា "បុគ្គលឯកជនម្នាក់" ហើយដែលរដ្ឋាភិបាលទីក្រុងភ្នំពេញបានផ្តន្ទាទោសថាជា "សត្រូវនៃប្រជាជនខ្មែរ" ទៀតផង ។ នៅក្នុងសារទី៣ ចុះថ្ងៃទី ១១ វិច្ឆិកា ១៩៧៩ សម្តេចចោទសួរថាតើសារលើកនេះនឹងនៅតែគ្មានចម្លើយទៀត ឬ យ៉ាងណា? ព្រះអង្គនៅ

តែទទូចឲ្យមានការចរចាគ្នារវាងវៀតណាម និង ព្រះអង្គ ដែលជារដ្ឋបុរសមានការទទួលខុសត្រូវ បើពុំដូច្នោះទេ សម្តេចព្រមានថា ព្រះអង្គនឹងត្រូវបង្ខំព្រះទ័យធ្វើការតស៊ូរំដោះជាតិរហូតដល់ទីបំផុត ។ ទាំងសារទី១ ទាំងសារទី២របស់ព្រះអង្គ ពុំបានទទួលចម្លើយណាមួយឡើយ ពីលោកនាយករដ្ឋមន្ត្រី ផាំ វ៉ាន់ ដុង នៃប្រទេសវៀតណាម ។ ចំណែកឯសារទី៣ បានត្រូវផ្ញើត្រឡប់មកវិញ ដោយមិនទាំងត្រូវបើកស្រោមផង ។ ដូច្នេះ បំណងរបស់សម្តេច ក្នុងការស្វែងរកការចរចាក៏ពុំបានសម្រេចដូចក្តីប្រាថ្នារបស់ព្រះអង្គ ។ ប្រហែលជាដោយសារមេដឹកនាំវៀតណាមមិនបានយកចិត្តទុកដាក់ចំពោះព្រះអង្គបែបនេះហើយ ទើបនៅទីបំផុតសម្តេច សីហនុ សម្រេចបង្កើតកងទ័ព និង រណសិរ្សរំដោះជាតិផ្ទាល់របស់ព្រះអង្គ មុននឹងចូលរួមជាថ្មីម្តងទៀតជាមួយខ្មែរក្រហមក្នុងរដ្ឋាភិបាលចម្រុះត្រីភាគីនាឆ្នាំ ១៩៨២ ។

សម្តេច សីហនុ យាងមកដល់ទីក្រុងប៉ារីស

នៅថ្ងៃ ២៥ វិច្ឆិកា ១៩៧៩ សម្តេចបានយាងមកដល់ទីក្រុងប៉ារីស ដែលព្រះអង្គគ្រោងថានឹងគង់ប្រថាប់នៅក្នុងរយៈពេលបីខែ ។ សម្តេចត្រូវបានទទួលបដិសណ្ឋារកិច្ចពីរដ្ឋាភិបាលបារាំងក្នុងឋានៈជាមិត្តម្នាក់របស់ប្រទេសបារាំង ។ នៅពេលយាងមកដល់ទីក្រុងប៉ារីសសម្តេចក៏ធ្វើដូចលោកតា សឺន សាន ដែរគឺបានថ្លែងអំពាវនាវឲ្យខ្មែរអ្នកជាតិនិយមទាំងអស់ ត្រូវខិតខំធ្វើយ៉ាងណាឲ្យគេទទួលស្គាល់ថាខ្មែរអ្នកជាតិនិយមជាក្រុមដ៏ហ្មត់ចត់បំផុត ។ ព្រះអង្គថ្លែងថា "យើងត្រូវតែធ្វើឲ្យគេមានទំនុកចិត្តដល់ក្រុមខ្មែរអ្នកជាតិនិយម" "ទាំងនេះគឺ ជាគោលបំណងរបស់ខ្ញុំក្នុងការស្នាក់អាស្រ័យរយៈពេល ៣ ខែ នៅប្រទេសបារាំងនេះ" ។ "ខ្ញុំជឿថា ខ្ញុំនឹងសំរេចគោលដៅនេះ"។ នៅក្នុងសេចក្តីអំពាវនាវរបស់ព្រះអង្គនោះ សម្តេចថ្លែងថា៖

"ជនរួមជាតិជាច្រើន បានទទូចសុំឲ្យខ្ញុំលះបង់ចោលនូវការរស់នៅក្រៅប្រទេសរបស់ខ្ញុំ ដើម្បីចូលរួមជាមួយពួកគេក្នុងកិច្ចប្រតិបត្តិការជួយសង្គ្រោះប្រជាជាតិយើងដែលកំពុងឋិតនៅក្នុងមហន្តរាយ តែខ្ញុំសូមបញ្ជាក់យ៉ាងច្បាស់ថា ខ្ញុំមិនមែនមកទីក្រុងប៉ារីសនេះ ដើម្បីដណ្តើមតំណែងដឹកនាំណាមួយឡើយ ខ្ញុំគ្រាន់តែជាអ្នកស្នេហាជាតិម្នាក់ ដែលនឹងខិតខំគ្រប់បែបយ៉ាងជាមួយនឹងអ្នកស្នេហាជាតិឯទៀត និងប្រជាពលរដ្ឋខ្មែរ ដើម្បីបំពេញករណីយកិច្ច ដែលខ្មែរអ្នកស្នេហាជាតិម្នាក់ៗត្រូវបំពេញ" ។ សម្តេច សីហនុ គូសបញ្ជាក់ថា សហព័ន្ធខ្មែរអ្នកជាតិនិយមរបស់ព្រះអង្គកំពុងអនុវត្តនយោបាយសហការគ្នាល្អជាមួយអង្គការទាំងឡាយណា ដែលមិនមែនជាសមាជិកសហព័ន្ធ (ទាំងនោះរួមទាំងចលនា រ.ជ.រ.ប.ខ. របស់លោកតា សឺន សាន ផង) នៅក្នុងគោលការណ៍ដ៏ពិសិដ្ឋសំរាប់ជួយសង្គ្រោះជាតិ ។

បានទទួលដំណឹងពីម្តាយខ្ញុំ

ទស្សនកិច្ចរបស់អតីតព្រះរាជា និង ព្រះប្រមុខរដ្ឋខ្មែរនោះបានលើកទឹកចិត្តយ៉ាងខ្លាំងក្លាដល់អ្នកគាំទ្ររបស់ព្រះអង្គនៅប្រទេសបារាំង ។ ក៏ប៉ុន្តែចំពោះខ្ញុំ ក៏ដូចជាអ្នកគាំទ្រលោកតា សឺន សាន មួយចំនួនដែរ វត្តមានរបស់សម្តេចនៅប្រទេសបារាំងមិនបានធ្វើឲ្យយើងផ្លាស់ប្តូរគោលជំហរ បែកចិត្តរាយមាយ ឬ មានភាពឃ្លេងឃ្លាងនៅក្នុងសតិអារម្មណ៍ឡើយ ។ ក៏ប៉ុន្តែ អ្វីដែលកន្ត្រាក់អារម្មណ៍ខ្ញុំឲ្យញាប់ញ័ររំភើបនោះគឺ សំបុត្រមួយច្បាប់ដែលខ្ញុំបានទទួលពីប្រទេសថៃ ។ សំបុត្រនោះ បានមកដល់ចំពេលនៃទស្សនកិច្ចរបស់សម្តេច សីហនុ នៅប្រទេសបារាំងតែម្តងគឺ ជាសំបុត្ររបស់បងថ្លៃស្រីខ្ញុំឈ្មោះ ទេពធីតា ភរិយាបងប្រុសទីពីររបស់ខ្ញុំ ដែលទើបតែធ្វើដំណើរមកដល់ដំរុំជាយដែនខ្មែរ-ថៃ ។ បងស្រីទេពធីតា មិនមានអាស័យដ្ឋាន

ថ្មីរបស់ខ្ញុំនៅទីក្រុងស្តាំងនោះទេ ក៏ប៉ុន្តែគាត់ផ្ញើសំបុត្រទៅអាស័យដ្ឋានចាស់នៅទីក្រុងប៉ារីស ដោយគ្រាន់តែសរសេរឈ្មោះផ្លូវ គ្មានដាក់លេខផ្ទះទេថា "អៀង មូលីផ្លូវមូឡាំងវែរ (Moulin Vert Paris France)" ។ ជាសំណាងល្អ និង ដោយសារប្រព័ន្ធប្រៃសណីយនៃប្រទេសបារាំងដំណើរការល្អ និង មានប្រសិទ្ធភាពខ្ពស់ សំបុត្រនោះក៏ត្រូវបានបញ្ជូនទៅអាស័យដ្ឋានថ្មីរបស់ខ្ញុំ នៅឯទីក្រុងស្តាំង ។ គួរបញ្ជាក់ថាមុននឹងរើមកនៅទីក្រុងស្តាំងនោះ ខ្ញុំបានទៅចុះឈ្មោះប្រាប់អាស័យដ្ឋានថ្មីរបស់ខ្ញុំ នៅឯមន្ទីរប្រៃសណីយចាស់នៅទីក្រុងប៉ារីស ។ ហេតុដូច្នេះហើយទើបគេអាចបញ្ជូនសំបុត្រនោះ ទៅអាស័យដ្ឋានថ្មីរបស់ខ្ញុំបាន ។ បងស្រី ទេពធីតា សរសេរសំបុត្រយ៉ាងខ្លី ប្រហែលជាគាត់ស្ថិតនៅក្នុងភាពប្រញាប់ប្រញាល់ ។ ក៏ប៉ុន្តែគាត់បានរៀបរាប់អំពីទុក្ខវេទនារបស់ប្រជាពលរដ្ឋយើង និង អំពីមរណភាពឪពុកខ្ញុំក្នុងខែធ្នូ ១៩៧៥ ព្រមទាំងការបាត់បង់ជីវិតរបស់បងប្អូនខ្ញុំបួននាក់ទៀតនៅក្នុងឆ្នាំ ១៩៧៧ ។ ជាមួយនោះ គាត់ក៏រៀបរាប់អំពីជីវភាពដ៏លំបាក តោកយ៉ាករបស់ម្តាយខ្ញុំដែលនៅរស់រានមានជីវិតនៅឡើយ ។ សេចក្តីក្នុងសំបុត្រ បានជំរុញខ្ញុំឲ្យប្តេជ្ញាចិត្តធ្វើពលីកម្មគ្រប់យ៉ាងដើម្បីសេរីភាព ។ ឃ្លាដ៏សំខាន់ក្នុងសំបុត្រនោះសរសេរថា "រាល់ៗយប់ តាំងពីពេលភ្នំពេញត្រូវដួលរលំមក ទោះជាត្រូវជន្លៀសដោយបង្ខំឲ្យទៅរស់នៅឯស្រែក៏ដោយ ក៏ពុក (ឪពុករបស់ខ្ញុំ) នៅតែថ្វាយបង្គំព្រះបន់ស្រន់ឲ្យព្រះអង្គជួយថែរក្សាប្អូន (ខ្ញុំ) ឲ្យបានសេចក្តីសុខគ្រប់ប្រការ ដើម្បីឲ្យប្អូន (ខ្ញុំ) អាចជួយរំដោះពួកយើងចេញពីអំណាចផ្តាច់ការរបស់ពួកខ្មែរក្រហម" ។ សេចក្តីនៃសំបុត្រនេះ មានន័យពិតប្រាកដជាសេចក្តីអំពាវនាវសុំឲ្យជួយយកអាសារអាយុជីវិត និង ជួយរំដោះពួកគេឲ្យមានសេរីភាពឡើងវិញ ។

ធាតុពិតនៃជ័យជំនះ ៧ មករា

ដោយសារមនុស្សមិនអាចរស់នៅបានដោយខ្វះសេចក្តីថ្លៃថ្នូរ ដោយសេចក្តីថ្លៃថ្នូរមិនអាចកើតមានដល់មនុស្សបាន បើមនុស្សស្ថិតនៅជាទាសកររនោះ ទាំងនេះក៏ជាកត្តាដ៏ចម្បងដែលជំរុញមនុស្ស ឲ្យធ្វើការរើបំរះរំដោះខ្លួនឲ្យមានសេរីភាព ។ សេរីភាព និង សេចក្តីថ្លៃថ្នូរ ជាវត្ថុធាតុធម្មជាតិរបស់មនុស្ស ដែលគេនាំមកជាមួយតាំងពីកំណើតរហូតដល់ពេលគេអស់ជីវិតលាចាកលោកនេះ ដោយគ្មាននរណាអាចឆក់ប្លន់ ឬ បង្ខំដកហូតបានឡើយ ។ របបប្រល័យពូជសាសន៍បស់ ប៉ុល ពត មិនគ្រាន់តែបានយកប្រជាពលរដ្ឋខ្មែរទូទាំងប្រទេសជាទាសកររបស់ខ្លួនតែប៉ុណ្ណោះទេ តែពួកគេបានយកការកាប់សម្លាប់ជនរួមជាតិឯង ជាវិធីការពារអំណាចរបស់ខ្លួនទៀតផង ។ អ្វីដែល ប៉ុល ពត ប្រកាសថាគេធ្វើនយោបាយដើម្បីបំរើផលប្រយោជន៍ប្រជាជន និង ប្រជាជាតិខ្មែរនោះ ក៏ប្រែក្លាយទៅជាមហាវិនាសកម្មដ៏ធំធេងចំពោះជាតិមាតុភូមិទាំងមូលទៅវិញ ។ មហន្តរាយដែលបង្កើតឡើងដោយ ប៉ុល ពត នៅពេលនោះ មិនអាចបញ្ចប់បានឡើយ បើមិនផ្តួលរំលំរបបប្រល័យពូជសាន៍នេះ ឲ្យទាន់ពេលវេលាទេ និង ដោយប្រើគ្រប់មធ្យោបាយទេនោះ ។ មធ្យោបាយនោះមានរួមទាំងការពឹងពាក់កម្លាំងបរទេសឲ្យជួយគាំទ្រផង ។ ការតស៊ូប្រឆាំង ប៉ុល ពត ក៏លេចចេញឡើងតាមច្រើនរូបភាព ដោយចំហរក៏មាន ដោយសម្ងាត់ក៏មាន ។ កម្លាំងតស៊ូខ្លះរត់ទៅទិសខាងលិច រកជំនួយពីថៃ ។ កម្លាំងតស៊ូខ្លះរត់ទៅទិសខាងកើត រកជំនួយពីវៀតណាម ។ កម្លាំងតស៊ូដែលរត់ទៅទិសខាងលិច ឯទល់ដែនខ្មែរ-ថៃ នឹកសង្ឃឹមថាថៃអាចជួយផ្តួលរំលំ ប៉ុល ពត បាន ។ ក៏ប៉ុន្តែ នៅក្នុងបរិបទនយោបាយតំបន់នាសម័យនោះ ថៃមិនហ៊ានចេញមុខជួយវាយខ្មែរក្រហម ឲ្យដួលរលំបានឡើយ ព្រោះនៅពីក្រោយពួកប្រល័យពូជសាសន៍នេះមានចិនឈរជាបង្អែក

ដ៏រឹងមាំ ។ ផ្ទុយទៅវិញ អ្នកតស៊ូដែលរត់ទៅពឹងវៀតណាម មានលទ្ធភាពវាយផ្ទួលរំលំច្រើនជាង ដោយសារ ប៉ុល ពត បានយកវៀតណាមជាសត្រូវសួរពូជផង និង បានបង្កទំនាស់ទល់ដែនជាញឹកញាប់ រហូតដល់មានសង្គ្រាមទ្រង់ទ្រាយធំរវាងគ្នា និង គ្នាទៀតផង ។ ជាមួយគ្នានោះ វៀតណាមក៏មានទំនាស់ជាមួយចិនយ៉ាងខ្លាំងក្លាដែរ ។ នៅទីបំផុតវៀតណាម ក៏បានលើកទ័ពមកជួយវាយផ្ទួលរំលំរបប ប៉ុល ពត នៅថ្ងៃទី ៧ មករា ១៩៧៩ ។ ក៏ប៉ុន្តែ ដោយសារអរិភាពអស់រយៈច្រើនសតវត្ស មកហើយរវាងខ្មែរ និង វៀតណាមនោះ អន្តរាគមន៍របស់កងទ័ពនៃប្រទេសជិតខាងនេះ ក៏ត្រូវបានប្រជាពលរដ្ឋខ្មែរមួយចំនួន ជាពិសេសជនភៀសខ្លួនខ្មែរនៅក្រៅប្រទេសមានការសង្ស័យ និង ចោទប្រកាន់ថាជាការរំលោភឈ្លានពានកម្ពុជាទៅវិញ ។ ព្រឹត្តិការណ៍ទាំងឡាយ ដែលបានកើតឡើងជាហូរហែ បានបញ្ជាក់ឲ្យឃើញថា បើគ្មានអំពើប្រល័យពូជសាសន៍ដ៏សាហាវអស្ចារ្យរបស់ ប៉ុល ពត ទេ អ្វីដែលត្រូវចោទប្រកាន់ថាជាអំពើឈ្លានពានរបស់វៀតណាមមកលើកម្ពុជា ក៏ប្រាកដជាពុំអាចកើតមានបានឡើយ ។

ទៅតាមចលនាវិលចុះវិលឡើងនៃប្រវត្តិសាស្ត្រកម្ពុជានាសម័យនោះ ការស្វែងរកសេរីភាពប្រាកដជាគ្មានពណ៌សម្ឃុរនយោបាយឡើយ ។ ទាំងអ្នករត់ទៅលិច ទាំងអ្នករត់ទៅកើតសុទ្ធតែមានបំណងចង់ជួយយកអាសាអាយុជីវិតប្រជាពលរដ្ឋខ្មែរ ពីរបបប្រល័យពូជសាសន៍ទាំងអស់ ។ ក៏ប៉ុន្តែ កម្លាំងខាងកើត មានលទ្ធភាព និង មានប្រសិទ្ធភាពជាង ។ ពួកយើងដែលនៅក្នុងយុវវ័យ នាសម័យនោះ សុទ្ធតែមានបេះដូងពុះកញ្ជ្រោលទៅដោយសេចក្តីស្នេហាជាតិ និង ការស្រែកឃ្លានរកសេរីភាព ។ ក៏ប៉ុន្តែ បន្ទាប់ពីការដួលរលំនៃរបបប្រល័យពូជសាសន៏មក សកម្មភាពនយោបាយរបស់យើងម្នាក់ៗ ស្ថិតនៅក្នុងបរិបទនៃសង្គ្រាមត្រជាក់ផង និង ជម្លោះនៅក្នុងតំបន់ផង ។ ដូច្នេះហើយ សេចក្តីស្នេហាជាតិរបស់យើង ជួនកាលវិល

បញ្ជ្រាសទិសគ្នាទៅវិញទៅតាមបក្សសម្ព័ន្ធ ឬ ប្តូកនយោបាយដែលយើងឈរជើង។

វគ្គទី ៦
ចេញទៅធ្វើសង្គ្រាម
(ទសវត្សរ៍ឆ្នាំ ១៩៨០)

នៅពេលដែលកងទ័ពវៀតណាម និង កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះកម្ពុជាបានវាយដណ្តើមទីក្រុងភ្នំពេញ និង ទឹកដីស្ទើរទាំងមូលនៃប្រទេសយើងមក ប្រទេសវៀតណាម ប្រកាសថាសភាពការណ៍នយោបាយនៅកម្ពុជាមិនអាចប្រែត្រឡប់វិញបានឡើយ ។ ដូចនេះក្រុមប្រទេសប្រឆាំងវៀតណាមមានជាអាទិ៍ ប្រទេសចិន អាស៊ាន និង សហរដ្ឋអាមេរិក បាននាំគ្នាបង្កើតរណសិរ្សមួយថ្មី ដើម្បីទប់ទល់ចំពោះដំណើរលឿនទៅមុខនៃសម្ព័ន្ធភាពវៀតណាម-សូវៀត ចូលទៅក្នុងតំបន់អាស៊ីភាគអគ្នេយ៍ ។ ប្រទេសទាំងនោះប្រកាន់ថា ការវាយប្រហារផ្តួលរំលំរបប ប៉ុល ពត ជាការរុលទៅមុខ និង ការពង្រីកឥទ្ធិពលនៃប្លុកលោកខាងកើតដែលកាលនោះមានសហភាពសូវៀតជាមេក្លោង ។ មិនយូរប៉ុន្មាន ប្រទេសកម្ពុជាបានក្លាយទៅជាសមរភូមិប្រយុទ្ធមួយ ដែលមហាអំណាចនាំគ្នាមកសាកកម្លាំង និងរុញច្រានដណ្តើមយកប្រទេសខ្មែរជារណបរៀងៗខ្លួន ។ ឯប្រជាពលរដ្ឋខ្មែរជាទូទៅក៏ក្លាយជាចំណាប់ខ្មាំងនៃការដណ្តើមឥទ្ធិពលគ្នានេះ ។

ចិន និង អាស៊ាន ត្រៀមកម្លាំងវាយបក

ក្រុមចលនាប្រទេសប្រឆាំងវៀតណាម ជាពិសេស ប្រទេសចិន នៅពេលនោះ ត្រូវការរៀបចំកងទ័ពខ្មែរក្រហមជាថ្មីឡើងវិញដែលយ៉ាងហោចណាស់ ក៏អាច

ធានៅបុករុករំខានកងទ័ពវៀតណាម ឲ្យចូលមកធ្វើការចរចាស្វែងរកដំណោះស្រាយបញ្ចប់ជម្លោះជាមួយពួកគេដែរ ។ បន្ថែមលើនេះ នៅសម័យនោះ ក្រុមប្រទេសប្រឆាំងវៀតណាមទាំងនោះ ក៏មានការយល់ឃើញថា អ្នកដឹកនាំខ្មែរទាំងឡាយណា ក្រៅពីក្រុមខ្មែរក្រហមចេញ ដែលអាចឲ្យប្រជាពលរដ្ឋខ្មែរជឿទុកចិត្ត និង ដែលអាចទទួលការគាំទ្រពីសហគមន៍អន្តរជាតិបាន ត្រូវតែចូលមកដឹកនាំចលនាតស៊ូខ្មែរប្រឆាំងនឹងវៀតណាមនេះ ។ នៅសម័យនោះ គេសម្លឹងឃើញមេដឹកនាំខ្មែរមិនមែនកុម្មុយនីស្ត ជាពិសេសសម្តេច សីហនុ និង លោកតា សឺន សាន ។ គេយល់ឃើញថា កងទ័ពខ្មែរក្រហមត្រូវតែពង្រឹងសមត្ថភាពសាជាថ្មីឡើងវិញ ។ ចំណែកយុទ្ធជនខ្មែរមិនមែនកុម្មុយនីស្តដែលនៅបែកខ្ញែកគ្នាត្រូវតែរួបរួមគ្នាឡើង ។ ក្នុងផ្នែកការទូត ចលនាតស៊ូត្រូវតែអង្គុយលើអាសនៈជាតំណាងប្រទេសកម្ពុជានៅអង្គការសហប្រជាជាតិ ។ ដូច្នេះកិច្ចការជាបន្ទាន់ ដែលក្រុមប្រទេសប្រឆាំងវៀតណាមជាពិសេស សហរដ្ឋអាមេរិក និង អាស៊ាន ត្រូវធ្វើនោះគឺ ត្រូវជួយរៀបចំចលនាតស៊ូខ្មែរមិនមែនកុម្មុយនីស្តឲ្យរឹងមាំ ដោយសារខ្មែរក្រហមកំពុងតែបាត់បង់នូវការគាំទ្រពីប្រជាពលរដ្ឋខ្មែរ និង ពីសហគមន៍អន្តរជាតិ ។

អ្នកដឹកនាំ រ.ជ.រ.ប.ខ. បានប្រមើលឃើញថា មានចរន្តនៃការបង្រួបបង្រួមអ្នកតស៊ូមិនមែនកុម្មុយនីស្ត ។ អ្នកដឹកនាំទាំងនោះ ក៏បានសាកល្បងចាប់ផ្តើមជំរុញពង្រឹងកម្លាំងរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ ឲ្យក្លាយទៅជាចលនាខ្មែរអ្នកជាតិនិយមតែមួយគត់ ជាជំនួសកម្លាំងខ្មែរក្រហម ។ នៅថ្ងៃទី ២៣ វិច្ឆិកា ១៩៧៩ ប្រធាន រ.ជ.រ.ប.ខ. បានបើកសន្និសីទសារព័ត៌មានមួយនៅលើទឹកដីខ្មែរ លើកសំណើសុំឲ្យយុទ្ធជនប្រដាប់អាវុធទាំងអស់ រួមទាំងយុទ្ធជននៃរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាផង ដែលកំពុងនៅជាមួយកងទ័ពវៀតណាមឲ្យជួបជុំគ្នាជាបន្ទាន់ ដើម្បីធ្វើការសិក្សាស្វែងរកកិច្ចព្រមព្រៀងរួមគ្នាមួយ ឈានទៅបញ្ចប់ទុក្ខ

វេទនារបស់ប្រជាពលរដ្ឋខ្មែរ និង កសាងឡើងវិញនូវប្រទេសកម្ពុជាឯករាជ្យ ដែលខ្មែរម្នាក់ៗអាចទទួលយកបាន ។ ទីកន្លែងជួបប្រជុំគ្នាអាចធ្វើនៅក្នុងតំបន់អព្យាក្រឹតមួយក៏បាន ឬ នៅទីក្រុងប៉ារីសប្រទេសបារាំងក៏បាន[107] ។

រ.ជ.រ.ប.ខ. បានគាំទ្រសេចក្តីសំរេចរបស់អង្គការសហប្រជាជាតិចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ១៩៧៩ ដែលមានចំណុចសំខាន់ៗដូចតទៅ៖ - អំពាវនាវឲ្យគ្រប់ភាគីនៅក្នុងជម្លោះសហការគ្នាតាមគ្រប់មធ្យោបាយដែលអាចធ្វើបាន ដើម្បីសម្រួលដល់ការខំប្រឹងប្រែងផ្នែកមនុស្សធម៌ (ចំណុច ៤) - អំពាវនាវសូមឲ្យភាគីទាំងអស់នៅក្នុងជម្លោះ បញ្ចប់ជម្លោះ(ចំណុចទី ៦) - អំពាវនាវឲ្យមានការដកកងទ័ពបរទេសចេញពីកម្ពុជាព្រមទាំងអំពាវនាវដល់រដ្ឋទាំងអស់មិនត្រូវឈ្លានពាន ឬ ជៀតជ្រែកកិច្ចការផ្ទៃក្នុងនៃប្រទេសនៅអាស៊ីភាគអាគ្នេយ៍ឡើយ (ចំណុច ៧) - អំពាវនាវដល់រដ្ឋទាំងអស់ មិនត្រូវជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃប្រទេសកម្ពុជា (ចំណុច ៩) -សំរេចថាប្រជាពលរដ្ឋខ្មែរ ត្រូវមានសិទ្ធិជ្រើសរើសរដ្ឋាភិបាលរបស់ខ្លួនតាមលទ្ធិប្រជាធិបតេយ្យ ដោយគ្មានការជ្រៀតជ្រែកពីខាងក្រៅ (ចំណុច ១០) និង - ស្នើឲ្យអគ្គលេខាធិការអង្គការសហប្រជាជាតិស្វែងរកគ្រប់លទ្ធភាព ដើម្បីរៀបចំសន្និសីទអន្តរជាតិមួយស្តីពីកម្ពុជា ដែលជាមធ្យោបាយមួយនៃការអនុវត្តសេចក្តីសំរេចនេះ (ចំណុច ១២) ។ តាមពិតទៅ ការប្រកាសបង្កើត រ.ជ.រ.ប.ខ. នៅថ្ងៃទី ៩ តុលា ១៩៧៩ គឺធ្វើឡើងឲ្យទាន់ពេលវេលា ដើម្បីត្រៀមចូលរួមប្រជុំសន្និសីទមួយនៃអង្គការសហប្រជាជាតិ ដែលត្រូវកោះប្រជុំ និង ចេញសេចក្តីសំរេចនៅថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៧៩ ខាងមុខ ។

នៅសម័យនោះ ក្រុមអ្នកជាតិនិយមគឺ ក្រុមមិនមែនកុម្មុយនីស្តត្រូវការឲ្យមានការចាត់តាំងរឹងមាំ និង មានឯកភាពគ្រប់គ្រាន់ ដើម្បីប្រមូលកម្លាំងគ្រប់យ៉ាង

[107] Son Sann, President of the Khmer People's National Liberation Front, Press Conference, Khmer Territory, November 23, 1979.

និង ធនធានគ្រប់ប្រភេទ ។ នៅពេលនោះ ប្រសិនបើលោកតា សឺន សាន និង សម្តេច សីហនុ អាចរួបរួមគ្នាក្នុងចលនាតស៊ូតែមួយបាននោះគឺជាមហាសាមគ្គីភាព ដ៏ប្រពៃបំផុត ។ ក៏ប៉ុន្តែអស់រយៈពេលជាច្រើនខែកន្លងមក ឥស្សរជនធំៗទាំងពីររូប បានជ្រើសរើសផ្លូវដើរទីទៃៗពីគ្នា ដែលនាំឲ្យមានការរិះគន់ពីមជ្ឈដ្ឋាននានា ។ នៅក្នុងសន្និសីទសារព័ត៌មានមួយនៅលើទឹកដីខ្មែរនាភូមិសុខសាន្តលោកតា សឺន សាន ថ្លែងថា ជាច្រើនលើកច្រើនសារលោកតាបានស្នើទូលថ្វាយសម្តេច សីហនុ ឲ្យយាងមកដឹកនាំរ.ជ.រ.ប.ខ ។ ពេលស្នើចុងក្រោយនោះគឺ នៅខែ មីនា ១៩៧៩ ពេលដែលព្រះអង្គប្រកែកមិនព្រមទទួលតួនាទីដឹកនាំរបស់រណសិរ្សនេះ ។

មេដឹកនាំអ្នកជាតិនិយមប៉ះទង្គិចពាក្យសំដីគ្នា

ប៉ុន្មានខែមុននោះ សម្តេច សីហនុ បានទ្រង់បង្កើតចលនាតស៊ូរបស់ព្រះអង្គ នៅទីក្រុងព្យុងយ៉ាងដែលមានឈ្មោះថាសហព័ន្ធខ្មែរអ្នកជាតិនិយម ដោយទ្រង់បានប្រមែប្រមូលសមាគមខ្មែរក្រៅប្រទេសមួយចំនួន ។ នៅទីក្រុងប៉ារីស កាសែតបារាំងខ្លះរាប់ទាំងកាសែតឡឺម៉ុង (Le Monde) ផង បានធ្វើការផ្សព្វផ្សាយសេចក្តីថ្លែងការណ៍ និង សេចក្តីអំពាវនាវរបស់លោកតា សឺន សាន ជាពិសេស កាសែតឡឺម៉ុង ចេញថ្ងៃទី ១៨ ធ្នូ ១៩៧៩ ។ កាសែតផ្សាយថាសម្តេច សីហនុ ប្រកែកមិនព្រមដឹកនាំ រ.ជ.រ.ប.ខ. នោះ ព្រោះព្រះអង្គយល់ថាមិនទាន់ដល់ពេលវេលា ប៉ុន្តែ ក្រោយមកព្រះអង្គបែរជាបង្កើតសហព័ន្ធខ្មែរអ្នកជាតិនិយម ជាចលនាផ្ទាល់របស់ព្រះអង្គទៅវិញ ។ ការផ្លាស់ប្តូរព្រះទ័យរបស់ព្រះអង្គត្រូវបានលោកតា សឺន សាន ធ្វើការរិះគន់យ៉ាងខ្លាំង ។ កាសែតឡឺម៉ុង បានចុះផ្សាយសំដីលោកតា សឺន សាន ថា "នៅពេលដែលសម្តេច សីហនុ ដូរព្រះទ័យចុះឡើងនេះ មានខ្មែរទាំងស្រីទាំងប្រុសកំពុងស្លាប់ជារៀងរាល់ថ្ងៃ ។ យុទ្ធជនអ្នកតស៊ូដែលកាន់អាវុធតាំងពីឆ្នាំ ១៩៧៥

រៀងមក មិនព្រមទម្លាក់អាវុធ ដូចសម្តេចចង់បាននោះទេ និង មិនខ្លាចស្លាប់ក្នុងការធ្វើដំណើរជ្រៀតចូលជ្រៅទៅក្នុងទឹកដីខ្មែរ ដើម្បីនាំស្បៀងទៅផ្តល់ជូនប្រជាពលរដ្ឋខ្មែរដែលកំពុងមានការខ្វះខាត ។ តើយើងត្រូវរង់ចាំឬ? តើ ត្រូវនៅត្រែងត្រាងឬ? ឬ ត្រូវលោតចុះទៅក្នុងទឹក ដើម្បីជួយសង្គ្រោះប្រជាពលរដ្ឋ ខ្មែរដែលកំពុងលង់ទឹកនោះ? ខ្ញុំ (សឺន សាន) បានសុខចិត្តមករួបរួមជាមួយយុទ្ធជនទាំងនោះ ។ ខ្ញុំមិនបានបង្ខំពួកគេទេ ឬ ដាក់លក្ខខណ្ឌណាដល់ពួកគេទេ ពួកយើងធ្វើការសម្រេចរួមគ្នា" ។ នៅក្នុងកាសែតនោះលោកតា សឺន សាន បន្តទៀត ថា៖ "ពួកយើងកំពុងបន្តនូវអ្វីដែលយើងបានចាប់ផ្តើមធ្វើ ។ ប្រសិនបើអ្នកឯទៀតចង់ចូលមកជួយតាមផ្លូវណាក៏ដោយ អ្នកទាំងនោះអាចធ្វើបានដោយសេរី ទោះជាត្រូវធ្វើសកម្មភាពផ្សេងគ្នាក៏ដោយ ព្រោះសកម្មភាពរបស់គេ និង សកម្មភាពរបស់យើង សុទ្ធតែអាចបំពេញឲ្យគ្នាទៅវិញទៅមកបាន" ។ នៅសម័យនោះ អ្នកជិតជិត និង លោកតា សឺន សាន ដែលមិនចូលចិត្តសម្តេច សីហនុ តែងព្យាយាមអូសទាញលោកតាឲ្យដើរតួជាអ្នកប្រណាំងប្រជែងជាមួយសម្តេច ក្នុងការដឹកនាំចលនាតស៊ូអ្នកជាតិនិយមមិនមែនកុម្មុយនីស្ត ។ ពួកគេតែងបន្ទោសព្រះអង្គថាជាអ្នកទទួលខុសត្រូវកំពូលដែលនាំឲ្យមានវិបត្តិធ្ងន់ធ្ងរដល់ប្រទេសជាតិយ៉ាងនេះ ។ ចំណែកឯសម្តេច សីហនុ វិញ ព្រះអង្គក៏ពិតជាមានការលំបាកក្នុងទទួលយកការដឹកនាំរណសិរ្ស របស់លោកតា សឺន សាន ព្រោះនៅក្នុងរណសិរ្សនោះ នាយទាហានជាន់ខ្ពស់មួយចំនួន រាប់តាំងពីឧត្តមសេនីយ ដៀន ដែល ផង សុទ្ធតែជាអ្នកសាធារណរដ្ឋដែលមានសមានចិត្តតិចតួចណាស់ចំពោះព្រះអង្គ ។ ការយកថ្ងៃទី ៩ តុលា ១៩៧៩ ជាថ្ងៃប្រកាសបង្កើតរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ អាចធ្វើឲ្យសម្តេចឈ្វេងយល់ថារណសិរ្សនេះមានគោលដៅនាំយករបបសាធារណរដ្ឋមកវិញ ព្រោះថ្ងៃ ៩ តុលា ជាថ្ងៃខួបកំណើតនៃសាធារណរដ្ឋរបស់លោកសេនាប្រមុខ លន់ នល់

ដែលបានផ្តួលរំលំរបបរាជានិយមរបស់ព្រះអង្គ ។ សាធារណរដ្ឋខ្មែរត្រូវបានប្រកាសឡើងជាលើកទី១នៅថ្ងៃទី ៩ តុលា ឆ្នាំ ១៩៧០ បន្ទាប់ពីមានរដ្ឋប្រហារទម្លាក់សម្តេច សីហនុ នៅថ្ងៃទី ១៨ មីនា ១៩៧០ ។ ដូច្នេះការស្នើយោងព្រះអង្គឲ្យមកដឹកនាំរ.ជ.រ.ប.ខ.របស់លោកតា សឺន សាន នោះ អាចត្រូវបកស្រាយថាជាសំណើលាក់ពុត មិនមែនដោយចិត្តបរិសុទ្ធឡើយ ។ ម្យ៉ាងទៀត សម្តេចក៏ប្រកាន់ឥរិយាបថមួយថាក្នុងហាន:ព្រះអង្គជាអតីតមហាក្សត្រ និង មេដឹកនាំខ្មែរផង ព្រះអង្គត្រូវគង់នៅឲ្យផុតពីជម្លោះ ដែលអាចជាស្ពានផ្សារភ្ជាប់គូបដិបក្ខ ក្នុងដំណោះស្រាយនយោបាយណាមួយ ដែលអាចកើតមាននាពេលខាងមុខ ។ ជាមួយគ្នានោះដែរ ការគាំទ្ររបស់ប្រទេសថៃ និង អង្គការប្រទេសអាស៊ាន ជាការគាំទ្រចាំបាច់បំផុតសំរាប់ចលនាតស៊ូមិនមែនកុម្មុយនីស្ត ។ នៅសម័យនោះ សម្តេច សីហនុ មិនទាន់ទទួលបាននូវការគាំទ្រទាំងអស់នោះនៅឡើយទេ ។

ខ្មែរក្រហមខំកែមុខមាត់ថ្មី

ចំពោះពួកខ្មែរក្រហមវិញ ពួកគេក៏ចាប់ផ្តើមធ្វើការផ្សព្វផ្សាយអំពីការផ្លាស់ប្តូរក្នុងកងទ័ព និង ក្នុងរដ្ឋាភិបាលរបស់គេដែរ ។ លោក ខៀវ សំផន ត្រូវទទួលបានមុខនាទីនយោបាយដ៏សំខាន់គឺ ជាប្រធាន និង ជានាយករដ្ឋមន្ត្រីនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ក៏ប៉ុន្តែ ប៉ុល ពត នៅតែបន្តកាន់អំណាចជាប្រធានកងទ័ពដដែល។ សមាជិកឯទៀតនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យមាន:[108] លោក អៀង សារី ជាឧបនាយករដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងការបរទេស លោក សុន សេន ជាឧបនាយករដ្ឋមន្ត្រី និង រដ្ឋមន្ត្រីការពារប្រទេស លោក ជួន ជុំ ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច លោកស្រី អៀង ធីរិទ្ធ ជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច លោកស្រី យន់ យ៉ាត

[108] Alan Dawson, New Khmer Rouge govt announced, Lineup, Bangkok Post, December 28, 1979.

ជារដ្ឋមន្ត្រីក្រសួងអប់រំ លោក គាត ឈន់ រដ្ឋមន្ត្រីប្រចាំទីស្តីការគណៈរដ្ឋមន្ត្រី លោក ជួន ម៉ុម ជារដ្ឋមន្ត្រីក្រសួងវិទ្យាសាស្ត្រ លោក ធុច រិន ជារដ្ឋលេខាធិការក្រសួងព័ត៌មាន លោក ស គិមល្មុត ជារដ្ឋលេខាធិការក្រសួងបរិក្ខារ និង ដឹកជញ្ជូន លោក ឈន ហៃ រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍[109] ។

ការរៀបចំសមាសភាពគណៈរដ្ឋមន្ត្រីថ្មីរបស់ពួកខ្មែរក្រហមនោះគឺ ជាការសាកល្បងរបស់ពួកគេ ដើម្បីបង្ហាញមុខមាត់ថ្មីនៃថ្នាក់ដឹកនាំដែលត្រូវចោទប្រកាន់ថាមានដៃប្រឡាក់ឈាម ។ គួរបញ្ជាក់ថារដ្ឋមន្ត្រីខ្មែរក្រហមពីរនាក់គឺ លោក ជួន ជុំ ជួន ម៉ុម និង មន្ត្រីការទូតជាន់ខ្ពស់របស់ខ្មែរក្រហមឈ្មោះ ជួន ប្រសិទ្ធ សុទ្ធតែជាបងប្អូននឹងគ្នា ដែលចេញពីត្រកូលឧកញ៉ាវាំង ជួន ដែលជាមន្ត្រីធំម្នាក់ធ្លាប់មានឥទ្ធិពលស្មើរស្មើស្តេចផែនដី ក្នុងសម័យព្រះករុណាព្រះបាទ ស៊ីសុវត្ថិ និង ព្រះបាទ មុនីវង្ស ព្រោះតែឧកញ៉ាវាំង ជួន បានទទួលការគាំទ្រពីអាជ្ញាធរអាណាព្យាបាលបារាំងប្រចាំប្រទេសកម្ពុជា ។ នៅពេលក្រោយៗមក ទើបខ្ញុំដឹងថា លោកតា ឈាន វ៉ែម ដែលកាលនោះជាអនុប្រធាន រ.ជ.រ.ប.ខ. ក៏ជាបងប្អូនថ្លៃរបស់បងប្អូន ជួន ទាំង ៣ នាក់នេះដែរ ។

រត់ការឲ្យបងថ្លៃស្រី បានចេញពីជំរុំ

ក្រៅពីការងារដ៏មមាញឹក ដើម្បីជួយគាំទ្រ រ.ជ.រ.ប.ខ. នោះ ខ្ញុំក៏ត្រូវជាប់រវល់ និង មានកង្វល់យ៉ាងខ្លាំងក្នុងការជួយដោះស្រាយបញ្ហាបងថ្លៃស្រីរបស់ខ្ញុំគឺទេពធីតា ដែលទើបធ្វើដំណើរមកដល់ជំរុំជនភៀសខ្លួនឯជាយដែន ។ តាំងពីបានទទួលសំបុត្រពីគាត់កាលណា ខ្ញុំយល់ថា ខ្ញុំមានការទទួលខុសត្រូវទាំងស្រុងក្នុងការជួយ

[109] Alan Dawson, New Khmer Rouge govt announced, Lineup, op. cit.

ជ្រោមជ្រែងបងស្រី ទេពធីតា ឲ្យបានចេញពីជំរុំជនភៀសខ្លួន ។ ខ្ញុំក៏ចាប់ផ្តើមរត់ការធ្វើសំបុត្រស្នាម គ្រប់យ៉ាងនៅសាលាក្រុងស្តាំង (Stains) ដើម្បីជានាយកបងស្រី ទេពធីតា មកប្រទេសបារាំង ។ តាមពិតទៅ បងថ្លៃស្រីរបស់ខ្ញុំនោះមិនមែនមកដល់ជំរុំជនភៀសខ្លួនតែម្នាក់ឯងនោះទេគឺ គាត់មកជាមួយបុរសម្នាក់ឈ្មោះ សេង លាង ហាក់ ដែលកាលនោះមានអាយុ ៣៨ ឆ្នាំ ។ បុរសនោះ ជាអ្នកស្រុកភូមិស្នាយពលរបស់ខ្ញុំដែរ ហើយដែលស្រឡាញ់បងទេពធីតា នៅពេលដែលរបប ប៉ុល ពតត្រូវដួលរលំទៅ ។ ដោយកាលនោះ ខ្ញុំមិនបានដឹងទំនាក់ទំនងរបស់អ្នកទាំងពីរនោះ ខ្ញុំសរសេរឈ្មោះ សេង លាងហាក់ នោះថាជាបងប្អូនជីដូនមួយរបស់បង ទេពធីតា នៅក្នុងសំបុត្រជានារបស់ខ្ញុំ ។ ខ្ញុំខិតខំសរសេរសំបុត្រទៅស្ថានទូតបារាំងនៅទីក្រុងបាងកក ដើម្បីសុំទិដ្ឋាការឲ្យក្រុមគ្រួសារបងទេពធីតា បានមករស់នៅៗប្រទេសបារាំង ។ ក្នុងពេលនោះ ខ្ញុំក៏សរសេរសំបុត្រទៅក្រុមកាកបាទក្រហមអន្តរជាតិ ឲ្យជួយធ្វើអន្តរាគមន៍ ដើម្បីឲ្យគ្រួសារបងថ្លៃស្រីរបស់ខ្ញុំនោះ បានមករស់នៅជាមួយខ្ញុំឯប្រទេសបារាំងដែរ ។ ក៏ប៉ុន្តែសំបុត្រទាំងអម្បាលម៉ានរបស់ខ្ញុំនោះ ពុំដែលមានចម្លើយឆ្លើយតបមកវិញឡើយ ។

ខ្ញុំចេះតែបន្តសរសេរសំបុត្រទៅអាជ្ញាធរបារាំងនៅទីក្រុងប៉ារីស និង នៅទីក្រុងបាងកកឲ្យជួយផ្តល់ទិដ្ឋាការដល់ពួកគេ ។ ជាមួយនោះ ខ្ញុំក៏ផ្តល់លុយកាក់ខ្លះដល់អ្នកទាំងនោះដែរ ។ ជីវភាពរស់នៅរបស់ជនភៀសខ្លួននៅក្នុងជំរុំឈ្មោះជំរុំមានជ័យ០០៧ ជួបប្រទះគ្រោះថ្នាក់ខ្លាំងណាស់ ដោយសារមានជនប្រដាប់អាវុធជាច្រើនក្រុម ដែលគ្មានសណ្តាប់ធ្នាប់ ។ នៅពេលមានជម្លោះបន្តិចបន្តួចក៏ធ្វើឲ្យមានការផ្ទុះអាវុធបាញ់សម្លាប់គ្នាភ្លាម ដោយមិនទាន់និយាយពីអំពើលួចប្លន់ និង រំលោភលើនារីភេទផង ។ មេដឹកនាំរបស់ជំរុំ០០៧ នោះ មិនបានចូលរួមជាមួយរ.ជ.រ.ប.ខ. ទេ ។ ម្យ៉ាងទៀត ជនភៀសខ្លួនដ៏ស្លូតត្រង់ទាំងនោះមិនត្រឹមតែភ័យបារម្ភអំពីសុវត្ថិ

ភាពក្នុងការរស់នៅក្នុងជំរុំតែប៉ុណ្ណោះទេ ក៏ប៉ុន្តែនៅមានក្តីបារម្ភជាប់ជានិច្ចខ្លាចក្រែងអាជ្ញាធរថៃចាប់បញ្ជូនទៅចាក់ចោលនៅឯតំបន់ព្រះវិហារថែមទៀត ។ ក្នុងពេលមុននោះបន្តិច ពួកទាហានថៃបានបញ្ជូនជនភៀសខ្លួនខ្មែរទៅឲ្យស្លាប់រាប់ពាន់នាក់រួចទៅហើយគឺស្លាប់ដោយអត់អាហារ ឬ ថ្នាំពេទ្យ ឬ ជាន់មីន នៅតំបន់ព្រះវិហារ ។ តាមពិតទៅ ជនភៀសខ្លួនរស់នៅក្នុងជំរុំមានការភិតភ័យជាប់ជានិច្ច ព្រោះចេះតែឮពាក្យចចាមអារាមកំញើញគំរាមឥតឈប់ឈរ ។ ជាភ័ព្វសំណាងល្អបងថ្លៃស្រីរបស់ខ្ញុំនោះមិនបានស្នាក់អាស្រ័យយូរប៉ុន្មានទេនៅក្នុងជំរុំ ០០៧ នោះ ។ ពីរ ឬ បីសប្តាហ៍ក្រោយមកខាងគ្រួសារថ្មីរបស់គាត់ បាននាំបងថ្លៃស្រីខ្ញុំនោះ ចេញមករស់នៅក្នុងជំរុំ ខៅ-អ៊ី-ដាង នៅក្នុងទឹកដីថៃវិញ ។

នៅក្នុងលិខិតរបស់គាត់នាខែ កុម្ភៈ ១៩៨០ នោះ បងទេពធីតា បានផ្ញើសំបុត្រមកខ្ញុំចេញពីជំរុំថ្មី ខៅ-អ៊ី-ដាងតែម្តង ។ នៅក្នុងសំបុត្រនោះ បងថ្លៃស្រីរបស់ខ្ញុំសំដែងការព្រួយបារម្ភខ្លាចអាជ្ញាធរថៃមិនអនុញ្ញាតឲ្យចេញពីជំរុំនេះ ព្រោះឮពាក្យចចាមអារាមថា ជនភៀសខ្លួននឹងត្រូវរស់នៅក្នុងជំរកសង់អំពីឈើ ដែលអាចជាសញ្ញាថា អ្នកទាំងនោះអាចនឹងត្រូវស្នាក់អាស្រ័យនៅៗក្នុងជំរុំសំរាប់រយៈពេលវែង ។ នេះគ្រាន់តែជាពាក្យចចាមអារាមតែប៉ុណ្ណោះ ។ ម្យ៉ាងទៀត បងស្រីទេពធីតាឃើញជនភៀសខ្លួន ដែលមានលុយកាក់មានទ្រព្យសម្បត្តិស្តុកស្តម្ភ គេអាចរត់ការចេញទៅប្រទេសទីបីបានភ្លាមៗ ។ ជាមួយគ្នានេះដែរ ទីតាំងជំរុំ ខៅ-អ៊ី-ដាង ក៏ស្ថិតនៅមិនឆ្ងាយពីព្រំដែន ដែលគេអាចឮសម្លេងគ្រាប់ផ្លោង ឬ គ្រាប់កាំភ្លើងនៅពេលប្រយុទ្ធគ្នាបាន ។ ទាំងនេះសុទ្ធតែជាមូលហេតុធ្វើឲ្យបងថ្លៃស្រីខ្ញុំចង់ចេញពីជំរុំនេះឲ្យបានឆាប់ ។ បងទេពធីតា ស្នើឲ្យខ្ញុំទាក់ទងជាមួយមន្ត្រីរបស់រ.ជ.រ.ប.ខនៅប្រទេសថៃ ដើម្បីជួយធ្វើអន្តរាគមន៍ឲ្យគាត់បានចេញពីជំរុំឆាប់ៗ និង ឲ្យបានធ្វើដំណើរទៅរស់នៅឯប្រទេសបារាំងបានជាបន្ទាន់ ។

ក៏ប៉ុន្តែនាសម័យនោះ ខ្ញុំមិនមានបំណងចង់ឲ្យអង្គការ រ.ជ.រ.ប.ខ.មកជាប់ជំពាក់ក្នុងបញ្ហាផ្ទាល់ខ្លួនរបស់ខ្ញុំឡើយ ។ ខ្ញុំគិតថាការចូលមកជួយ រ.ជ.រ.ប.ខ.គឺជាការចូលរួមចំណែកមួយរបស់ខ្ញុំ ដើម្បីរំដោះជាតិ មិនមែនដើម្បីយក រ.ជ.រ.ប.ខ. មកធ្វើការជាប្រយោជន៍ឯកជននោះឡើយ ។ ម្យ៉ាងទៀត ខ្ញុំក៏មិនបានដឹងថាអាចមានថ្នាក់ដឹកនាំណារបស់ រ.ជ.រ.ប.ខ. ដែលអាចមានឥទ្ធិពលជួយដោះស្រាយនាំជនភៀសខ្លួនចេញពីជំរុំវៃបានឡើយ ។ បើពិចារណាឲ្យហ្មត់ចត់ទៅ រ.ជ.រ.ប.ខ. មានបេសកកម្មរំដោះប្រទេស ប្រសិនបើ រ.ជ.រ.ប.ខ. គិតតែពីនាំជនភៀសខ្លួនចេញពីជំរុំ ទៅប្រទេសទីបីនោះ ធ្វើដូចម្តេចអាចនឹងសំរេចបេសកកម្មរបស់ខ្លួនបាន ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំក៏ខិតខំសរសេរសំបុត្រទៅក្រសួងការបរទេសបារាំងសុំឲ្យរដ្ឋាភិបាលបារាំង ជួយធ្វើអន្តរាគមន៍យកគ្រួសារថ្មីរបស់បងថ្លៃស្រីខ្ញុំ បានមករស់នៅឯប្រទេសបារាំង ។ ជាថ្មីទៀត សំបុត្ររបស់ខ្ញុំក៏នៅតែគ្មានចម្លើយ ។ ខ្ញុំមានការពិបាកក្នុងចិត្តជាខ្លាំង ព្រោះខ្ញុំមិនអាចជួយបងទេពធីតាឲ្យបានសំរេចដូចបំណង ។ ខ្ញុំនឹកថាខ្ញុំជាសាច់ញាតិម្នាក់របស់គាត់ដែលនៅរស់ក្នុងប្រទេសបារាំង ដែលគួរតែអាចជួយយកមកបាន ព្រោះខ្ញុំស្គាល់គេស្គាល់ឯងច្រើនណាស់នៅសម័យនោះ ។ ចំពោះខ្លួនខ្ញុំផ្ទាល់ ខ្ញុំក៏មានការខកចិត្តយ៉ាងខ្លាំងណាស់ដែរ ។

នៅក្នុងសំបុត្រមួយនោះ បងទេពធីតាបានរៀបរាប់ថាក្រុមគ្រួសារគាត់ និងក្រុមគ្រួសារខ្ញុំបានធ្វើដំណើរត្រឡប់ទៅស្រុកកំណើតខ្ញុំទាំងអស់គ្នា ក្រោយដែលភ្នំពេញត្រូវដួលរលំភ្លាម ។ ក្នុងចំណោមសំបុត្រជាច្រើនច្បាប់ សំបុត្រមួយច្បាប់បានរៀបរាប់អំពីស្ថានភាពរបស់ក្រុមគ្រួសារគាត់ និង ក្រុមគ្រួសារខ្ញុំ នៅពេលដែលបែកភ្នំពេញភ្លាម ។ បន្ទាប់ពីបានទៅដល់ភូមិស្នាយពលមួយថ្ងៃ ពួកខ្មែរក្រហមបានកោះហៅឪពុកគាត់ និង ឪពុកមារបស់ខ្ញុំដែលជាស្វាមីអ្នកគ្រូសាម៉ឺឌី ឲ្យទៅរៀន

សូត្រទាំងយប់ ។ តាំងពីពេលនោះមក ពួកគាត់ក៏បាត់ដំណឹងរហូត ។ នៅពេលនោះបងទេពធីតា និង បងស៊ីនឿនក៏បាននាំទារិកាជាកូនស្រីដែលទើបនឹងកើតបានបួន ឬ ប្រាំថ្ងៃមុននោះ ទៅជាមួយឯស្រុកកំណើតរបស់ខ្ញុំដែរ ។ ដោយសារខ្វះទឹកដោះ និង ខ្វះថ្នាំពេទ្យ ទារិកានោះក៏បាត់បង់ជីវិតទៅ ។ នៅឆ្នាំ ១៩៧៧ ពួកខ្មែរក្រហមបានបញ្ជូនបងប្រុសស៊ីនឿនឲ្យទៅរៀនសូត្រនយោបាយ ហើយក៏ត្រូវពួកខ្មែរក្រហមបញ្ឆោតយកទៅសម្លាប់ចោលទៅ ។ ប៉ុន្មានខែក្រោយមកទៀត ម្តាយ និង បងស្រីរបស់បងទេពធីតា ក៏ត្រូវខ្មែរក្រហមយកទៅសម្លាប់យ៉ាងសាហាវព្រៃផ្សៃជាទីបំផុត ។

តាមការរៀបរាប់របស់បងថ្លៃស្រីរបស់ខ្ញុំនោះ ខ្មែរក្រហមជាទូទៅសុទ្ធតែមាននយោបាយកាប់សម្លាប់ប្រជាពលរដ្ឋឯងទាំងអស់ ។ បន្ទាប់ពីរបប ប៉ុល ពត បានដួលរលំ បងថ្លៃស្រីខ្ញុំក៏បានរៀបការជាមួយលោក សេង លាងហាក់ ដែលបានបបួលគាត់ឲ្យមករស់នៅមួយរយៈឯទីក្រុងភ្នំពេញវិញ ។ នៅទីបំផុត អ្នកទាំងពីរក៏នាំគ្នារត់មកជំរុំជនភៀសខ្លួនឯទល់ដែនវិញ ។ មកដល់ទល់ដែនភ្លាម សេង លាងហាក់ ក៏ដាក់ពាក្យសុំទៅរស់នៅសហរដ្ឋអាមេរិក ។ តាមបងទេពធីតាបានឲ្យដឹងថា សេង លាងហាក់ នោះ ជាមនុស្សប្រច័ណ្ឌខ្លាំងណាស់ ព្រោះថាទោះជាធ្លាប់បានរស់នៅយ៉ាងវេទនាក្នុងរបបខ្មែរក្រហមយ៉ាងណាក៏ដោយ ក៏បងថ្លៃស្រីរបស់ខ្ញុំនោះនៅរក្សាសម្រស់ផូរផង់របស់គាត់ដែរ ។ ជាភ័ព្វសំណាងល្អរបស់ពួកគាត់ សហរដ្ឋអាមេរិកក៏ផ្តល់ទិដ្ឋាការឲ្យទៅរស់នៅជាជនភៀសខ្លួនតទៅ ។

បាតុកម្មប្រឆាំង ៧ មករា នៅទីក្រុងប៉ារីស

នៅទីក្រុងប៉ារីសសហគមន៍ ខ្មែរភាគច្រើនចាត់ទុកថ្ងៃទី ៧ មករា ជាថ្ងៃនៃការឈ្លានពានរបស់វៀតណាមមកលើទឹកដីកម្ពុជា ដោយមិនបានគិតថាជាថ្ងៃដែល

វៀតណាមមកជួយយកអាសាពីការកាប់សម្លាប់របស់ខ្មែរក្រហមឡើយ ។ ជារៀងរាល់ឆ្នាំ នៅពេលថ្ងៃ ឬ ខួបកំណើត ៧ មករានេះ សមាគមអា ហ្សេ កា អឺ ព្រមទាំងសហគមន៍ខ្មែរឯទៀត តែងសហការគ្នារៀបចំធ្វើបាតុកម្មសំដែងការប្រឆាំងចំពោះកងទ័ពវៀតណាម និង ទាមទារឲ្យកងទ័ពនេះ ដកថយចេញពីប្រទេសខ្មែរ ។ នៅថ្ងៃខួបឆ្នាំទីមួយនោះ នាខែ មករា ឆ្នាំ១៩៨០ បាតុកម្មប្រឆាំងនេះ ប្រព្រឹត្តិនៅចំកណ្តាលទីក្រុងប៉ារីស ក្នុងតំបន់ទេសចរណ៍មួយដ៏សំខាន់ នៅតួអេ ហ្វែល (Tour Eiffel) ។ ពួកបាតុករជួបជុំគ្នាយ៉ាងកុះករ ប្រកបដោយបដាសរសេរ ពាក្យស្លោកជាភាសាខ្មែរ បារាំង និង អង់គ្លេស ប្រឆាំងការឈ្លានពានរបស់វៀតណាម ។ ពួកគេចាប់ផ្តើមថ្លែងសុន្ទរកថាជាបន្តបន្ទាប់ មុននឹងដង្ហែក្បួនតាមដងវិថីនៃទីក្រុងប៉ារីស ។

ខ្ញុំមានការរំភើបចិត្តជាខ្លាំង ក្នុងការចូលរួមធ្វើបាតុកម្មនេះជាមួយមិត្តភក្តិរបស់ខ្ញុំគឺ៖ តិកលីន ខាន់កែវ និង សូរិយោស៊ី ។ សូរិយោស៊ី រៀបចំរថយន្តរបស់គេដោយប្រដាប់គ្រឿងបំពងសំឡេង ដែលមានឧគ្ឃោសនស័ព្ទ(មីក្រូ) និង សម្ភារៈឯទៀតផង ។ នៅពេលដែលសូរិយោស៊ីបររថយន្តរបស់គេ និង មិត្តភក្តិឯទៀតដើរហែរតាមក្រោយចែកខិតប័ណ្ណនោះ ខ្ញុំអង្គុយក្នុងរថយន្តក្បែរសូរិយោស៊ី ស្រែកតាមឧឃោសនស័ព្ទ ឲ្យអ្នកហែរឯទៀតស្រែកបន្ទរតាម ។ ពាក្យស្លោកដែលត្រូវស្រែកនោះមានចាប់ពីពាក្យស្លោកស្នេហាជាតិ ដូចជាដីខ្មែរត្រូវតែខ្មែរនៅ រហូតដល់ពាក្យទាមទារឲ្យបរទេសឈ្លានពានចេញពីទឹកដីខ្មែរ ឬ ពាក្យថ្កោលទោសរបបកុម្មុយនីស្តជាដើម ។ ខ្ញុំខំស្រែកខ្លាំងៗជាប់តាមផ្លូវរហូតដល់ខ្ញុំត្រូវស្អែកកនិយាយលែងឮ ឬ ឮ ខ្សាវៗ ។ បាតុករទាំងអស់នាំគ្នាទៅឈប់នៅមុខស្ថានទូតវៀតណាម ដោយចាត់ឲ្យអ្នកតំណាងក្នុងនោះ មានខ្លួនខ្ញុំមួយរូបផង នាំញត្តិទៅជូនមន្ត្រីតំណាងស្ថានទូតនេះ ។

នៅឱកាសធ្វើបាតុកម្មនោះ ខ្ញុំក៏ជួបមិត្តថ្មីម្នាក់ដែលធ្វើដំណើរពីខេត្តខាង

ស្បូងនៃប្រទេសបារាំងមកចូលរួមដែរ ។ មិត្តនោះគឺ ទេព ជារ៉ុង ដែលទើបតែរើផ្ទះពីខេត្តទូលូ (Toulouse) មករស់នៅឯទីក្រុងប៉ារីស ។ នៅទូលូ សមាគម អា ហ្សេ កា អឺ មានសមាជិកសកម្មជាច្រើន ហើយក៏មានសកម្មភាពគាំទ្រយ៉ាងខ្លាំងក្លាណាស់ដែរ ។ មុននេះបន្តិច មានសមាជិកសកម្មម្នាក់ឈ្មោះ ប៊ុន សាយ ទើបតែស្ម័គ្រចិត្តទៅចូលរួមធ្វើការតស៊ូជាមួយលោកតា សឺន សាន ឯប្រទេសថៃ ។ មុនពេល ប៊ុន សាយ ចេញដំណើរទៅនោះ គាត់បានចូលមកលាខ្ញុំឯទីក្រុងស្តាំង ហើយខ្ញុំក៏មានឱកាសធ្វើបាយជូនជាកិត្តិយស ចំពោះគាត់ដែលមានសេចក្តីក្លាហាន ហ៊ានលះបង់អ្វីៗគ្រប់យ៉ាងនៅប្រទេសបារាំង ទៅធ្វើការតស៊ូដើម្បីជាតិ ។ ខ្ញុំតែងតែមានការស្រឡាញ់ និង គោរពចំពោះអ្នកស្ម័គ្រចិត្តចេញទៅធ្វើការតស៊ូដើម្បីប្រទេសជាតិជានិច្ច ។

ទេព ជារ៉ុង ជាកូនប្រុសម្នាក់ ក្នុងចំណោមកូនប្រុសៗឯទៀតរបស់លោកឧកញ៉ា ទេព ផន ដែលធ្លាប់កាន់តំណែងជារដ្ឋមន្ត្រីក្រសួងការបរទេសនៅក្នុងរជ្ជកាលទី១នៃព្រះករុណាសម្តេច នរោត្តម សីហនុ ។ ក្នុងចំណោមមុខតំណែងជាន់ខ្ពស់ទាំងឡាយ មុខតំណែងជាចៅហ្វាយក្រុងភ្នំពេញ (អភិបាលក្រុង) បានធ្វើឲ្យឧកញ៉ា ទេព ផន ល្បីឈ្មោះជាងគេក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ ។ លោកធ្លាប់បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា ទៅចូលរួមប្រជុំក្នុងសន្និសីទស្តីពីឥណ្ឌូចិន នៅទីក្រុងហ្សឺណែវនាឆ្នាំ ១៩៥៤ ។ ឧកញ៉ា ទេព ផន ជាមនុស្សជិតស្និទ្ធជាមួយសម្តេច ប៉ែន នុត និង លោកតា សឺន សាន ។ លោកក៏ជាសមាជិកស្ថាបនិកមួយរូបដែរនៃសមាគម អា ហ្សេ កា អឺ ។ នៅមុនឆ្នាំ ១៩៧០ ទាំងឧកញ៉ា ទេព ផន ទាំងលោកតា សឺន សាន សុទ្ធសឹងតែជាមន្ត្រីជាន់ខ្ពស់ដែលគេតែងគោរពកោតខ្លាច ព្រោះមានទំនាក់ទំនងជិតស្និទ្ធជាមួយព្រះបរមរាជវាំង ។ គ្រួសារទាំងពីរនេះ រាប់បញ្ចូលទាំងគ្រួសារមួយចំនួនតូចទៀតផង សុទ្ធតែជាត្រកូលអភិជន

ដ៏ខ្ពង់ខ្ពស់ នៅក្នុងប្រទេសកម្ពុជានាសម័យនោះ ។ ក្រោយពីបានចូលរួមក្នុងបាតុកម្មរួច ទេព ដារ៉ុង ក៏តែងចូលរួមប្រជុំជាញឹកញាប់នៅក្នុងសមាគម អា ហ្សេ កា អឺ និង បានរួមចំណែកជួយបំរើការងារដ៏មានប្រយោជន៍ដល់សមាគមនេះតរៀងមក ។

ពួកយើងនៅទីក្រុងប៉ារីស

នៅសម័យដែលយើងជួបគ្នានោះ ទេព ដារ៉ុង កំពុងប្រកបអាជីវកម្មជាអ្នកធ្វើរូបគំរូ (Modeling Shop) សំណង់ដូចជា៖ រូបផ្ទះវីឡា សាលារៀន ឬ អាគារផ្សេងៗដទៃទៀត ។ គាត់ធ្វើរូបគំរូទាំងនោះតាមប្លង់ ដែលស្ថាបត្យករ (Architect) គូររួចហើយ មុនយកទៅសាងសង់ ។ តាំងពីគាត់ចូលធ្វើការជាអ្នកស្ម័គ្រចិត្តបំរើ អា ហ្សេ កា អឺ មក ទេព ដារ៉ុង ច្រើនតែបិទទ្វារហាងរបស់គាត់ និង ចំណាយពេលវេលាជាច្រើនមកធ្វើការឲ្យសមាគម ពោលគឺគាត់ទុកមុខរបរចិញ្ចឹមជីវិតរបស់គាត់ជាការងារបន្ទាប់បន្សំទៅវិញ ។ ការងារក្នុងសមាគមទាំងនោះ មានដូចជា៖ ចូលរួមប្រជុំនានា ជួយរៀបចំសន្និសីទ ឬ ជូនដំណើរបណ្ឌិត ឆាយ ហាន់ចេង ទៅតាមខេត្តនានានៃប្រទេសបារាំង ។

ជាធម្មតា នៅពេលរួចពីការងារក្នុងក្រុមហ៊ុនស្ទើរតែរាល់ល្ងាច ខ្ញុំតែងទូរស័ព្ទហៅ ដារ៉ុង ឲ្យមកជួបជុំគ្នានៅផ្ទះលោកតា សឺន សាន ជាមួយមិត្តភក្តិឯទៀត ដើម្បីជួយធ្វើការតូចតាចកំប៊ិកកំប៉ុកមួយចំនួននៅក្នុងសមាគមដូចជា៖ វាយអង្គុលីលេខ បិទតែមសំបុត្រ ឬ យកសំបុត្រទៅផ្ញើ ឬ ថតចម្លងឯកសារ ឬ ទូរស័ព្ទទៅណាត់ពេលសុំជួបអាជ្ញាធរបារាំងជាដើម ។ ក្រោយពីពេលដែលយើងបញ្ចប់ការងារក្រៅម៉ោងធ្វើការរបស់យើងនេះហើយ ពួកយើងតែងបបួលគ្នាទៅទទួលទានអាហារពេលល្ងាចនៅភោជនីយដ្ឋានមួយឈ្មោះ "នាគនៅទិសខាងជើង" (Dragon du Nord) ដែលស្ថិតនៅតំបន់ឈ្មោះថា "ស្ថានីយរថភ្លើងទិសខាងជើង" (La Gare

du Nord) ។ ម្ចាស់ភោជនីយដ្ឋាននេះឈ្មោះ សុខ វ៉ាន់ធី ក៏បានក្លាយជាមិត្តជិតស្និទ្ធរបស់ខ្ញុំម្នាក់ទៀត ព្រោះតែខ្ញុំឧស្សាហ៍មកទទួលទានអាហារពេលល្ងាចជាញឹកញាប់ផង និង ធ្លាប់នាំភ្ញៀវជាច្រើននាក់មកភោជនីយដ្ឋានរបស់គាត់ផង ។

សុខ វ៉ាន់ធី ជាអាជីវករដ៏កម្រម្នាក់ ដែលរកទទួលទាន ដោយមិនចាំបាច់ជួលបុគ្គលិកឲ្យមកធ្វើការ ព្រោះថាអ្វីៗគាត់ និង ភរិយាធ្វើស្ទើរតែទាំងអស់ ។ ម្យ៉ាង គាត់ចូលចង្ក្រានធ្វើម្ហូបដោយខ្លួនឯង ឯភរិយារបស់គាត់មានការៈបំរើភ្ញៀវ និង គិតបញ្ជី ។ តាមពិតទៅ សុខ វ៉ាន់ធី មិនដែលធ្វើម្ហូបម្ហាអ្វីទេកាលគាត់រស់នៅឯប្រទេសកម្ពុជា ។ គាត់មិនមែនជាមេចុងភៅអាជីពនោះឡើយ ។ កាលនៅឯស្រុកខ្មែរគាត់រកទទួលទានខាងផ្នែកសំណង់ ធ្លាប់ដេញថ្លៃបាននូវកុងត្រាសាងសង់វាលយន្តហោះនៅកោះពូលូវ៉ៃ (Poulo Wai) ។

សុខ វ៉ាន់ធី ធ្លាប់បានធ្វើការសិក្សានៅសហរដ្ឋអាមេរិក ហើយបានទទួលបរិញ្ញាបត្រខាងវិស្វកម្ម ។ គាត់ធ្លាប់រៀបការជាមួយស្ត្រីជនជាតិអាមេរិកម្នាក់ ។ ប៉ុន្តែពួកគាត់ត្រូវលែងលះគ្នានៅប៉ុន្មានឆ្នាំ ដែលបានវិលមកប្រទេសកម្ពុជាវិញ ក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ ។ សុខ វ៉ាន់ធី គេចរួចពីរបប ប៉ុល ពត ហើយបានទទួលសិទ្ធិជ្រកកោនជាជនភៀសខ្លួននៅប្រទេសបារាំង បន្ទាប់ពីរបបសាធារណរដ្ឋរបស់លោកប្រធានាធិបតី លន់ នល់ បានដួលរលំទៅមិនយូរប៉ុន្មាន ។ គាត់មករស់នៅប្រទេសបារាំងជាមួយភរិយាទីពីររបស់គាត់ ដែលធ្លាប់ជាអ្នកទទួលភ្ញៀវនៅក្នុងភ្នាក់ងារធ្វើដំណើររបស់តៃវ៉ាន់មួយនៅភ្នំពេញ ។ នៅទីក្រុងប៉ារីស សុខ វ៉ាន់ធី ទិញបានភោជនីយដ្ឋានមួយ ដែលគាត់យកមកកែឆ្នៃជាភោជនីយដ្ឋានខ្មែរ នៅផ្លូវមួយឈ្មោះ ម៉ូបើស្ស៍ (Maubeuge) នៅជិតស្ថានីយរថភ្លើងខាងជើង (La Gare du Nord) ។ ដំបូងឡើយ ខ្ញុំចូលទៅភោជនីយដ្ឋាននេះតែម្នាក់ឯង បន្ទាប់ពីបានអានអត្ថបទក្នុងកាសែតបារាំង ដែលលើកសរសើរពីគុណភាពខ្ពស់នៃម្ហូបអាហាររបស់មេចុងភៅនៃ

កោជនីយដ្ឋាននោះ ។ គេសរសើរថាម្ហូបមានរសជាតិឆ្ងាញ់ពិសា ឯសេវាបំរើអតិថិជនក៏ល្អ ។

នៅពេលដំបូង សុខ វ៉ាន់ធី មានការភ្ញាក់ផ្អើលជាខ្លាំង ព្រោះឃើញរូបខ្ញុំចូលមកក្នុងកោជនីយដ្ឋានរបស់គាត់ ដែលធម្មតាមានតែអ្នកទេសចរណ៍បរទេស ឬ អតិថិជនជនជាតិបារាំងតែប៉ុណ្ណោះ ។ គាត់មានការចាប់អារម្មណ៍ចំពោះអាកប្បកិរិយារបស់ខ្ញុំ ដែលសំដែងខុសប្លែកពីយុវជនឯទៀត ព្រោះអ្នកទាំងនោះចូលចិត្តនិយាយពីរឿងស្រីស្រា ឬ ដើររាំច្រៀងតាមរង្គសាល ។ ផ្ទុយទៅវិញ ខ្ញុំនិយាយរកគាត់តែអំពីរឿងស្រុកទេស ពីការរំដោះជាតិ និង អំពីការកសាងកម្ពុជាឡើងវិញតែប៉ុណ្ណោះ ។

តាំងពីថ្ងៃដែលយើងបានជួបគ្នាដំបូង សុខ វ៉ាន់ធី និង ខ្ញុំ ក៏បានរាប់អានគ្នាជាមិត្តភក្តិដ៏ជិតស្និទ្ធតរៀងមក ។ ភោជនីយដ្ឋានរបស់គាត់ ក៏ក្លាយជាទីកន្លែងដែលពួកយើងតែងមកជួបជុំគ្នាជាអចិន្ត្រៃយ៍ បន្ទាប់ពីផ្ទះ លោកតា សឺន សាន ។ ក្រោយពេលដែលរ.ជ.រ.ប.ខបានត្រូវប្រកាសជាសាធារណៈរួចមក ពួកយើងនាំគ្នាមកធ្វើការនៅការិយាល័យផ្សាយព័ត៌មានរបស់ រ.ជ.រ.ប.ខ. នៅផ្លូវមួយឈ្មោះ ហ្វ្រេកែល (Passage Fréquel) ក្នុងសង្កាត់លេខ ២០ នៃទីក្រុងប៉ារីស ។ ជាញឹកញាប់ដោយមានគ្នីគ្នាប្រមាណ ២ ឬ ៣ នាក់មកជាមួយក្នុងនោះមាន ទេព ដារ៉ុង ផង ខ្ញុំតែងមកទទួលទានអាហារពេលល្ងាចនៅភោជនីយដ្ឋាន "នាគនៅទិសខាងជើង" នៅម៉ោង ១០ ឬ ១១ យប់ ព្រោះថានៅពេលនោះ ម្ចាស់ហាង សុខ វ៉ាន់ធី រយាលដៃពីអតិថិជនធម្មតារបស់គាត់ ដូច្នេះមានពេលអាចទទួលពួកយើងបានដោយស្រួល ។ ពួកយើងយកកន្លែងគាត់ជាកន្លែងជជែកគ្នារឿងនយោបាយផង និង ជាកន្លែងទទួលទានអាហារផង ។ កាលណាចូលក្នុងភោជនីយដ្ឋាននេះម្តងៗ ពួកយើងមិនដែលចេញទៅវិញមុនម៉ោង ១ យប់ ឬ ក៏ទៀបភ្លឺនៅល្ងាចថ្ងៃសុក្រ ឬ ថ្ងៃ

សៅរ៍ឡើយ ។ សុខ វ៉ាន់ធី ធ្វើមុខម្ហូបណាដែលយើងចង់ទទួលទាន និង បញ្ចេញស្រាក្រហម ឬ ស្រាសបារាំងដែលហាងគាត់មានយកមកឲ្យពួកយើងវាយតម្លៃគុណភាព ឬ វាយតម្លៃរសជាតិ ។

លោកតាថ្លែងថា សត្រូវនៃសត្រូវ គឺជាមិត្ត

ក្នុងហាន:ពួកយើងជាអ្នកឃោសនាឲ្យមូលហេតុដ៏ឧត្តុង្គឧត្តមមួយ ពួកយើងតែងតែត្រូវការនូវព័ត៌មានខាងផ្នែកយោធា នយោបាយ ឬ ការទូតពីសមរភូមិមុខ ។ ក្នុងខែ មករា ១៩៨០ លោក ថុន អ៊ុក អ្នកនាំពាក្យផ្លូវការរបស់ រ.ជ.រ.ប.ខ.ប្រចាំនៅទីក្រុងប៉ារីសបានធ្វើដំណើរទៅប្រទេសថៃ ហើយបានចូលទៅកាន់តំបន់រំដោះរបស់ រ.ជ.រ.ប.ខ.នៅលើទឹកដីខ្មែរ ។ នៅថ្ងៃ ៥ មករា ១៩៨០ លោក ថុន អ៊ុក បានចូលរួមជាមួយលោកតា សឺន សាន ក្នុងពិធីបញ្ចប់វគ្គសិក្សាលើកទី១នៃកងកម្លាំងពិសេសនៅក្នុងភូមិស្រោចស្រង់ក្រឡ ដែលធ្លាប់បានទទួលរងការវាយប្រហាររបស់កងទ័ពវៀតណាមនៅថ្ងៃ ៨ ធ្នូ ១៩៧៩ ។

លោកតា សឺន សាន ឆ្លៀតឱកាសដែលមានវត្តមានរបស់លោក ថុន អ៊ុក នាពេលបិទវគ្គនោះ បានសង្កត់ធ្ងន់អំពីសារប្រយោជន៍នៃការគាំទ្ររបស់សហគមន៍ខ្មែរនៅបរទេសដល់ចលនាតស៊ូរបស់គាត់ ។ លោកតាប្រធាន រ.ជ.រ.ប.ខ. បានសំដែងការកោតសរសើរដល់យុទ្ធជន រ.ជ.រ.ប.ខ. ដែលបានស្ម័គ្រចិត្តចូលមកបំរើកងកម្លាំងពិសេសហើយក៏ជាលើកទីមួយ ដែលលោកតាបានបង្ហើបជាសាធារណៈឲ្យដឹងនូវចេតនាធ្វើសហការជាមួយកងកម្លាំងទាំងអស់ ដែលកំពុងធ្វើការតស៊ូប្រឆាំងកងទ័ពវៀតណាមដោយរួមទាំងកម្លាំងខ្មែរក្រហមផង ។ លោកតាមានប្រសាសន៍

ថា៖ "សត្រូវនៃសត្រូវរបស់យើងគឺជាមិត្តរបស់យើង"[110] ។ ក្នុងន័យនេះហើយ ដែលយើង អាចដឹងថាលោកតាមានបំណងចូលរួមជាមួយខ្មែរក្រហម ព្រោះថាខ្មែរក្រហមជាសត្រូវស្លាប់រស់របស់វៀតណាម ។ ក៏ប៉ុន្តែការអះអាងនេះក៏ប្រឆាំងនឹងគោលការណ៍ទីពីររបស់រ.ជ.រ.ប.ខ. ដែលចែងថាសត្រូវស្លាប់រស់ទីពីររបស់យើងគឺ របបប្រល័យពូជសាសន៍ខ្មែរក្រហមនេះឯង ។ ដូច្នេះការអះអាងថាសត្រូវនៃសត្រូវជាមិត្តនោះប្រាកដ ពិបាកពន្យល់ និង ទទួលយកបានណាស់ ជាពិសេសចំពោះករណីខ្មែរក្រហមនេះ ។

ប្រទេសចិននៅសម័យនោះ ទំនងជាមហាអំណាចមួយ ដែលប្រឆាំងនឹងវត្តមានកងទ័ពវៀតណាមនៅលើទឹកដីខ្មែរខ្លាំងជាងគេ និង សកម្មជាងគេក្នុងការជំរុញឲ្យមានកងកម្លាំងចម្រុះខ្មែរមួយដ៏រឹងមាំខ្លាំងក្លា ក្នុងការធ្វើសង្គ្រាមយូរអង្វែងប្រឆាំងកងទ័ពដ៏ខ្លាំងពូកែរបស់ក្រុងហាណូយ ។ ប្រទេសដែលគាំទ្រមួយចំនួនអាចបង្កើបឲ្យថ្នាក់ដឹកនាំរ.ជ.រ.ប.ខ.ដឹងថារណសិរ្សនេះអាចនឹងទទួលជំនួយគ្រប់គ្រាន់តែក្នុងករណីចូលរួមតស៊ូជាមួយខ្មែរក្រហមតែប៉ុណ្ណោះ ។

ទស្សនកិច្ចរបស់លោក ជុន អ៊ុក នៅក្នុងតំបន់រំដោះក្នុងទឹកដីខ្មែរបានបង្កើនឡើងនូវកម្លាំងចិត្តថ្មីថែមទៀតដល់ពួកយើង ដែលជាអ្នកឃោសនា ឲ្យខិតខំបង្កើនការឃោសនាថារ.ជ.រ.ប.ខ.ជាចលនាអ្នកជាតិនិយមពិតៗ ជាចលនាមិនមែនកុម្មុយនីស្តដែលមានរចនាសម្ព័ន្ធត្រឹមត្រូវ និង មានអ្នកដឹកនាំប្រកបដោយសមត្ថភាព ។ យើងឃោសនាថា យើងមានរដ្ឋបាល និង កងទ័ពត្រឹមត្រូវពិតប្រាកដជាក់ស្តែងនៅលើសមរភូមិ ។ នៅពេលនោះ បើប្រៀបធៀបទៅនឹងសហពន្ធខ្មែរនៅទីក្រុងព្យុងយ៉ាងរបស់សម្តេច សីហនុ រណសិរ្សយើងហាក់ដូចជាមានប្រៀបជាង ។

[110] Son Sann, President of the People's National Liberation Front, Speech, at the Closing Ceremony of the Political, Warfare Training and the Graduation of the 1st Group of Special Forces, Khmer Territory, January 5, 1980, KPNLF Bulletin No. 2, February 1980, p. 16.

ស្ថាប័ន និង សមាជនៃរ.ជ.រ.ប.ខ.

ដោយប្រមើលឃើញជាមុនថា រ.ជ.រ.ប.ខ. អាចដើរតួនាទីដ៏សំខាន់នៅក្នុងអនាគតនៃប្រទេសកម្ពុជា ថ្នាក់ដឹកនាំ រ.ជ.រ.ប.ខ. បានចាប់ផ្តើមគំនិតចាត់តាំងស្ថាប័នសំខាន់ៗនៃចលនាតស៊ូនេះ ។ នៅពេលជាមួយគ្នានោះ រ.ជ.រ.ប.ខ. ក៏ទាមទារកតួនាទីសំខាន់នៅក្នុងចលនារួបរួមចម្រុះណាមួយក្នុងពេលអនាគត ព្រមជាមួយនឹងការខិតខំស្វែងរកការគាំទ្រដ៏រឹងមាំ និង ច្បាស់លាស់ ។ នៅខែ មីនា ១៩៨០ រ.ជ.រ.ប.ខបានបង្កើតក្រុមប្រឹក្សាព្រឹទ្ធាចារ្យ[111] (Conseil des Sages)ដែលមានសមាសភាពរួមទាំងអតីតនាយករដ្ឋមន្ត្រី២រូបគឺ៖ លោក ស៊ឹម វ៉ា និង លោក ហ៊ុយ គន្ធុល និង អតីតរដ្ឋមន្ត្រី៤រូបគឺ៖ លោក នង គិមនី ចាយ ធុល លឹម គ្រី និង ជុន អ៊ុក ។ លោកឧត្តមសេនីយ សូកាំ ខូយ ដែលឡើងកាន់តំណែងជាប្រធានាធិបតីជំនួសលោក លន់ នល់ នៅថ្ងៃទី ១ មេសា ១៩៧៥ បានចូលរួមក្នុងក្រុមប្រឹក្សាព្រឹទ្ធាចារ្យនេះនៅខែ ធ្នូ ១៩៨០ ។

ដើម្បីបង្កើតនូវមូលដ្ឋាននយោបាយ និង លក្ខណៈស្របច្បាប់របស់ខ្លួនរ.ជ.រ.ប.ខ បានរៀបចំនូវសមាជជាតិលើកទី១នៅខែ មេសា ១៩៨១ នៅលើទឹកដីខ្មែរក្នុងភូមិស្រោចស្រង់ ។ សមាជជាតិនេះ មានគណៈប្រតិភូមកពី ២៤ ខេត្តក្រុងចូលរួម លើកលែងតែខេត្តពីរចេញគឺ៖មណ្ឌលគីរី និង រតនគីរី ។ នៅលើឯកសារនៃវត្តមានគណៈប្រតិភូចូលរួមមានចែងថា៖ "គណៈប្រតិភូមកពីខេត្ត៖កំពត កណ្តាល កោះកុង កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ ក្រចេះ កំពង់សោម ជំរុំខៅ-អ៊ី-ដាង ចលនាហនុមាន២៥៧ ចលនារាជសីចតុមុខ តាកែវ ប៉ៃលិន បន្ទាយឆ្មារ បាត់ដំបង

[111] Son Sann, Front National de Libération du Peuple Khmer, Décision No. 80/03/FNL, Territoire Khmer, le 11 mars 1980.

ព្រៃវែង ព្រះវិហារ ពោធិសាត់ ភ្នំពេញ រណសិរ្សខ្មែរអង្គរ១០០៧ ស្នឹងត្រែង ស្វាយរៀង សៀមរាប ឧត្តរមានជ័យ អ្នកភូមិស្រោចស្រង់ និង គណៈប្រតិភូខ្មែរអ៊ីស្លាម" ។ នៅឱកាសបើកសមាជនេះ លោកតាប្រធានបានគូសបង្ហាញនូវចំណុចសំខាន់ៗនៃកម្មវិធីនយោបាយរបស់រ.ជ.រ.ប.ខ. និង បានលើកឡើងចំណុចដ៏សំខាន់ពីរចំណុចពិសេស ដែលទាក់ទងនឹងផលប្រយោជន៍ជាតិគឺ៖[112] ១. លទ្ធភាពនៃការចូលរួមរបស់រ.ជ. រ.ប.ខ. នៅក្នុងរដ្ឋាភិបាលជាតិបណ្តោះអាសន្នមួយ និង ២. គោលជំហររបស់រ.ជ.រ.ប.ខ. ចំពោះអំពើឧក្រិដ្ឋ ដែលពួកខ្មែរក្រហមបានប្រព្រឹត្តមកលើប្រជាពលរដ្ឋខ្មែរ ។ នៅលើចំណុចទី១ លោកតាបានភ្ជាប់ការចូលរួមរបស់រ.ជ.រ.ប.ខ.ណាមួយនៅក្នុងរដ្ឋាភិបាលជាតិបណ្តោះអាសន្ន ទៅជាមួយនឹងការកាន់កាប់អាសនៈរបស់កម្ពុជានៅអង្គការសហប្រជាជាតិ (អ.ស.ប) ឬ សិទ្ធិជាអ្នកតំណាងស្របច្បាប់នៃកម្ពុជា នៅក្នុងសន្និសីទអន្តរជាតិណាមួយនាពេលខាងមុខ ។

ដោយហេតុថារ.ជ.រ.ប.ខ. បានរៀបចំយុទ្ធសាស្ត្រសំដៅដោះស្រាយវិបត្តិនៅកម្ពុជាតាមផ្លូវនយោបាយ វត្តមានរបស់រ.ជ.រ.ប.ខ. នៅលើឆាកអន្តរជាតិត្រូវបានចាត់ទុកជាអាទិភាពខ្ពស់បំផុតរបស់ចលនារំដោះជាតិនេះ ។ រ.ជ.រ.ប.ខ. មានជំនឿថានឹងមានសន្និសីទអន្តរជាតិមួយ ក្នុងខែ ឬ ឆ្នាំខាងមុខមិនខានឡើយ ។ សន្និសីទនោះ នឹងនាំដល់ការដកកងទ័ពវៀតណាមចេញពីកម្ពុជា ព្រមទាំងនាំឲ្យមានការបោះឆ្នោតជាទូទៅមួយផង ។ នៅក្នុងករណីនេះ បញ្ហាតំណាងស្របច្បាប់នៃប្រទេសកម្ពុជាដើម្បីចូលរួមក្នុងសន្និសីទអន្តរជាតិនោះ ប្រាកដជានឹងត្រូវលើកយកមកពិភាក្សា ។ តើគេនឹងជ្រើសយករបបភ្នំពេញ ដែលមានការទទួលស្គាល់ដោយប្រទេសមួយចំនួនក្នុងប្លុកកុម្មុយនីស្ត ឬ យករបបកម្ពុជាប្រជាធិបតេយ្យរបស់ខ្មែរក្រហមឲ្យធ្វើជាតំណាងប្រជាជាតិខ្មែរ? នៅលើចំណុចនេះ ថ្នាក់ដឹកនាំរ.ជ.រ.ប.

[112] Son Sann, Speech delivered at the Opening Session of the Congress, KPNLF Bulletin, Special Issue no. 4, April 1980, pp. 3-11.

ខ. យល់ឃើញថា ប្រសិនបើយើងខឹតខំធ្វើការខាងការទូតឲ្យអន្តរជាតិទទួលស្គាល់ និង ប្រសិនបើកងទ័ពរបស់រ.ជ.រ.ប.ខ.ខឹតខំបង្កើនសមត្ថភាពធ្វើសកម្មភាពយោធាខ្លាំងក្លា ឲ្យក្លាយខ្លួនជាកម្លាំងទីបី ដែលមិនមែនកុម្មុយនីស្តនោះ រ.ជ.រ.ប.ខ. អាចឈរឈ្មោះជាតំណាងប្រជារាស្ត្រ និង ប្រជាជាតិខ្មែរបាននៅលើឆាកអន្តរជាតិ ។ ប្រសិនបើរ.ជ.រ.ប.ខ.ត្រូវបានអន្តរជាតិទទួលស្គាល់ និង អាចតំណាងឲ្យកម្ពុជាបាននោះ រ.ជ.រ.ប.ខ.នឹងបន្តស្ថិតនៅជារណសិរ្សតទៅទៀត ដោយមិនចាំបាច់បង្កើតរដ្ឋាភិបាលឡើយ ។ ក៏ប៉ុន្តែ ប្រសិនបើមានការចាំបាច់ត្រូវបង្កើតរដ្ឋាភិបាលជាតិបណ្តោះអាសន្នណាមួយនោះ រ.ជ.រ.ប.ខ. នឹងបង្កើតឡើងភ្លាមនូវរដ្ឋាភិបាលជាតិនោះ ។ នៅសម័យនោះ ថ្នាក់ដឹកនាំរ.ជ.ប.ខ.គិតត្រឹមតែបង្កើតរដ្ឋាភិបាលជាតិនិយម (A Nationalist Government) ដែលគ្មាន ខ្មែរក្រហមចូលរួម និង ដែលឆ្លុះបញ្ចាំងពីឆន្ទៈនៃប្រជារាស្ត្រខ្មែរភាគច្រើនតែប៉ុណ្ណោះ ។ ក៏ប៉ុន្តែមានអ្នកគាំទ្រក្នុងមជ្ឈដ្ឋានអន្តរជាតិមួយចំនួន បានលើកទឹកចិត្តឲ្យលោកតា សឺន សាន រួមកម្លាំងជាមួយខ្មែរក្រហម ដើម្បីធ្វើការប្រយុទ្ធប្រឆាំងនឹងកងទ័ពវៀតណាមនៅកម្ពុជា ។ នៅពេលនោះ លោកតាប្រធានរ.ជ.រ.ប.ខ. ត្រូវប្រឈមមុខនឹងជំរើសពីរ៖ ជំរើសទី១ ឬមួយត្រូវចូលរួមកម្លាំងជាមួយខ្មែរក្រហម ទើបបានទទួលជំនួយពីខាងក្រៅខ្លះ ។ ជំរើសទី២ ឬមួយបង្កើតរដ្ឋាភិបាលខ្មែរតែឯកឯងដោយគ្មានជំនួយពីក្រៅសោះ ។ ជំរើសទី២នេះ ហាក់ដូចជាមិនអាចទទួលយកបានឡើយ ព្រោះថាបើគ្មានជំនួយទេ រ.ជ.រ.ប.ខ. មិនអាចធ្វើសកម្មភាពអ្វីបានឡើយ ព្រមទាំងអាចនឹងត្រូវរលំរលាយពុំខាន ។

នៅចំពោះមុខសភាពការណ៍បែបនេះ ច្បាស់ណាស់លោកតាប្រធានត្រូវជ្រើសយកជំរើសទី១ ដែលតម្រូវឲ្យមានការចរចាតថ្លៃខ្លះ ។ ដូច្នេះលោកតាប្រធាន រ.ជ.រ.ប.ខ. ក៏យកសមាជជាមូលដ្ឋាននៃយុទ្ធវិធី សំរាប់ការតថ្លៃផ្នែកនយោបាយ

នោះ ។ កាលណាចេញទៅក្រៅ លោកតាតែងមានប្រសាសន៍ថា លោកតានិយាយក្នុងនាមប្រជាពលរដ្ឋ ក្នុងនាមកងទ័ព និង ក្នុងនាមចលនាតស៊ូជានិច្ច ។ ដើម្បីឲ្យអ្នកក្រៅមើលឃើញថា លោកតាពិតជាអ្នកប្រជាធិបតេយ្យមែនៗនោះ លោកតាត្រូវតែធ្វើការពិគ្រោះជាមួយប្រជាពលរដ្ឋ តាមរយៈនៃអង្គសមាជនេះ ។ ជាញឹកញាប់ លោកតាតែងរៀបចំជាសមាជ ជាអង្គប្រជុំ ជាសន្និបាត ដើម្បីសុំយោបល់ ឬ សុំការយល់ព្រមជាដើម ។ ជារឿយៗ នៅពេលបើកអង្គប្រជុំ លោកតាតែងបង្ហាញជាមុននូវទិសដៅអ្វី ដែលលោកតាចង់ឲ្យអង្គប្រជុំសម្រេច ឬ អនុម័ត ។ នៅពេលពិគ្រោះយោបល់ លោកតាប្រធានធ្វើការឧទ្ទេសនាមជាមុន រួចស្តាប់មតិគាំទ្រមួយចំនួន និង ទីបញ្ចប់សុំឲ្យអង្គប្រជុំលើកដៃគាំទ្រ ។ សមាជរបស់ រ.ជ.រ.ប.ខ.នាឆ្នាំ ១៩៨០ នោះ មានសភាពបែបនេះ ។ នៅទីបញ្ចប់លោកតា សឺន សាន បានស្នើឲ្យអង្គសមាជអនុញ្ញាតទុកជាមុន ឲ្យគណៈកម្មាធិការប្រតិបត្តិ រ.ជ.រ.ប.ខ. អាចបង្កើតរដ្ឋាភិបាលជាតិបណ្តោះអាសន្នមួយ នាពេលខាងមុខដ៏សមស្រប ។ ការស្នើសុំជាមុនឲ្យសមាជិកសន្និបាត ឬ គណៈកម្មការ ប្រគល់សិទ្ធិសំរេចអ្វីមួយ នៅពេលខាងមុខដល់លោកតាប្រធាន ជាសញ្ញាសំគាល់របស់លោកតា នៅក្នុងយុទ្ធវិធីនយោបាយដែលលោកតានឹងប្រើជាប្រចាំសំរាប់ឆ្នាំក្រោយៗជាបន្តបន្ទាប់មកទៀត ។

ទាក់ទងនឹងសមាជជាតិរបស់ រ.ជ.រ.ប.ខ. ឆ្នាំ ១៩៨០ សមាជនេះបានចេញសេចក្តីសំរេចមួយ ដូចមានចំណុចពីរសំខាន់ៗតទៅ៖ ១. អនុញ្ញាតឲ្យគណៈកម្មាធិការប្រតិបត្តិដែលយើងហៅកាត់ថា "កូមុិច" បង្កើតក្នុងករណីចាំបាច់នូវរដ្ឋាភិបាលជាតិបណ្តោះអាសន្នមួយ ដែលតំណាងឲ្យប្រជាពលរដ្ឋខ្មែរទាំងមូល (ចំណុចទី៥) ២. អនុញ្ញាតឲ្យអ្នកដឹកនាំ រ.ជ.រ.ប.ខ. ប្រាប់ទៅពួកខ្មែរក្រហមថារ.ជ.រ.ប.ខ. មិនចូលរួមក្នុងរណសិរ្សរួបរួមណាមួយជាមួយក្រុមខ្មែរក្រហមទេ ក៏ប៉ុន្តែបញ្ជាក់ថាគោលដៅចម្បងរបស់ រ.ជ.រ.ប.ខ.គឺ រំដោះប្រទេសកម្ពុជា និង ប្រជាពលរដ្ឋខ្មែរពី

ការកាន់កាប់របស់យួនឈ្លានពាន ។ រ.ជ.រ.ប.ខ. នឹងមិនធ្វើការវាយប្រហារទៅលើពួកខ្មែរក្រហមទេ ប្រសិនបើកងទ័ពនៃពួកនេះ មិនធ្វើការវាយប្រហារយើងមុន មិនធ្វើទុក្ខបុកម្នេញប្រជាពលរដ្ឋខ្មែរ និង មិនរាំងរាជល់សកម្មភាពរបស់យើង (ចំណុចទី៦)[113] ។

នៅឆ្នាំ ១៩៨០ នោះ អង្គសមាជបានអនុម័តសេចក្តីសំរេចមួយចំនួនទាក់ទងនឹងផ្នែកនយោបាយ យោធា សេដ្ឋកិច្ចព្រមទាំងសង្គមកិច្ច និង សាសនា ។ នៅលើចំណុចនយោបាយ អង្គសមាជបានសំរេចផ្តល់អំណាចពេញទីដល់ រ.ជ.រ.ប.ខ. ដែលដឹកនាំដោយគណៈកម្មាធិការប្រតិបត្តិមួយឈ្មោះថា "កូមិច" (COMEX : Comité Exéculif) រហូតដល់រំដោះប្រទេសបានទាំងស្រុង ។ គួររំលឹកថានៅខែ ធ្នូ ១៩៧៩ គណៈកម្មាធិការប្រតិបត្តិបានធ្វើការកែសំរួលសមាសភាពខ្លះ ដោយមានបញ្ចូលសមាជិកថ្មី ម្នាក់ដែលទើបរត់ចេញពីភ្នំពេញ មករួបរួមជាមួយ រ.ជ.រ.ប.ខ. ឈ្មោះលោក ហ៊ឹង គន្ធុន[114] ។ លោក ហ៊ឹង គន្ធុន ត្រូវបានតែងតាំងជាប្រតិភូទទួលបន្ទុកកិច្ចការសេដ្ឋកិច្ច ។ ក្រោយមកដោយសារលោក ងួន ពីទូរ៉ែត បានសុំលាឈប់ការងារយោសនា បានត្រូវធ្លាក់មកលោក អ៊ឹម ឈូដេត រីឯលោក ព្រុំ វិត ទទួលយកការងារមហាផ្ទៃវិញ ។ ចំណែកលោក កែវ សៅវុធ (តាជួន) ទទួលបន្ទុកកិច្ចការសាសនា ។ តាមពិតទៅលោក ងួន ពីទូរ៉ែត ដែលជាអ្នកសីហនុនិយមច្បាស់លាស់បានលាឈប់នោះ ក៏ប្រហែលជាមើលឃើញថារបៀបរបបការងារដឹកនាំរបស់ រ.ជ.រ.ប.ខ. មិនអាចឲ្យរណសិរ្សនេះរីកចំរើនបានឡើយ ។

សមាជបានថ្កោលទោសរបបភ្នំពេញ ដែលប៉ុនប៉ងរៀបចំធ្វើការបោះឆ្នោតដោយសំអាងថាបោះឆ្នោតដោយមានវត្តមានកងទ័ពបរទេសនៅលើទឹកដីខ្មែរ មិន

[113] Resolution, the National Congress of the Khmer People's National Liberation Front, Held in Plenary Session in the Khmer Territory, April 25, 1980, KPNLF Bulletin, Special Issue no. 4, op. cit.
[114] Son Sann, Front National de Libération du Peuple Khmer, Décision No. 79/07/FNL, Territoire Khmer, le 17 Décembre 1979.

អាចយកជាបានការឡើយ (ចំណុចទី៣) ។ ចំណុចសំខាន់ៗឯទៀតនៃសេចក្តីសំរេចរបស់រ.ជ.រ.ប.ខ.នោះមានជាអាទិ៍ សេចក្តីអំពាវនាវដល់អ្នកដឹកនាំខ្មែរគ្រប់ជាន់ថ្នាក់ និង ដល់អ្នកស្នេហាជាតិគ្រប់និន្នាការនយោបាយ រួមទាំងអ្នកដែលបង្ខំចិត្តសហការជាមួយរបបភ្នំពេញផងឲ្យជួយគាំទ្ររ.ជ.រ.ប.ខ.ក្នុងការតស៊ូប្រឆាំងនឹងយួនខាងជើងឈ្លានពាន (ចំណុចទី៤) ។ សមាជសំរេចគាំទ្រដោយឥតសំចៃនូវសេចក្តីសំរេចរបស់អង្គការសហប្រជាជាតិចុះថ្ងៃទី ១៤ វិច្ឆិកា ១៩៧៩ ដែលបានឆ្លើយតបជាឯកច្ឆ័ន្ទ ចំពោះសំណូមពររបស់ប្រជាពលរដ្ឋខ្មែរទាំងមូលតាមរយៈញត្តិចេញមកពីគ្រប់ខេត្តផ្តល់ដល់អង្គសមាជ (ចំណុចទី៧) និង ស្នើសុំឲ្យអគ្គលេខាធិការអង្គការសហប្រជាជាតិខឹតខំប្រឹងប្រែងគ្រប់យ៉ាង ដើម្បីធ្វើការកោះប្រជុំជាបន្ទាន់នូវសន្និសីទអន្តរជាតិមួយ ស្របតាមសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិចុះថ្ងៃទី ១៤ វិច្ឆិកា ឆ្នាំ១៩៧៩ និង តាមសំណូមពររបស់ប្រជារាស្ត្រខ្មែរទាំងមូល (ចំណុចទី៨) សមាជគាំទ្រឥតសំចៃនូវសកម្មភាពការទូតទាំងអស់របស់អាស៊ាន ដោយរាប់ទាំងរបស់គណៈកម្មការអឺរ៉ុប(European Commission) រហូតដល់មានដំណោះស្រាយចុងក្រោយនៃបញ្ហាកម្ពុជា សមស្របតាមសេចក្តីសំរេចរបស់អង្គការសហប្រជាជាតិចុះថ្ងៃទី ១៤ វិច្ឆិកា ១៩៧៩ (ចំណុចទី៩) និង គាំទ្រផែនការបង្កើតតំបន់សុវត្ថិភាពមួយនៅតាមបណ្តោយព្រំដែនខ្មែរ-ថៃ ក្រោមការឧបត្ថម្ភរបស់អង្គការសហប្រជាជាតិដើម្បីអនុញ្ញាតឲ្យជនភៀសខ្លួនខ្មែរមានសន្តិសុខ និង ទទួលបាននូវជំនួយមនុស្សធម៌ ពីអង្គការក្នុងពិភពលោកបានផង (ចំណុចទី១០) ។ នៅទីបញ្ចប់ សមាជបានធ្វើការថ្កោលទោសរាល់ការប៉ុនប៉ងទាំងឡាយណា ក្នុងការធ្វើឲ្យមានការព្រមព្រៀងជាមួយក្រុងហាណូយ ឬ ក្រុងភ្នំពេញ ដើម្បីធ្វើមាតុភូមិនិវត្តន៍ជនភៀសខ្លួនខ្មែរ ដែលអាចជាការរំលោភសិទ្ធិមនុស្ស និង ផ្ទុយពីសេចក្តីសំរេចរបស់អង្គការសហប្រជាជាតិចុះថ្ងៃទី ១៤ វិច្ឆិកា ១៩៧៩ (ចំណុចទី១១)" ។

សេចក្តីសំរេចផ្នែកនយោបាយរបស់សមាជនោះ ក៏មានចែងទៀតថា "ក្រោយពីការបោះឆ្នោតជាទូទៅ ក្រោមការត្រួតពិនិត្យរបស់អង្គការសហប្រជាជាតិ នៅលើទឹកដីខ្មែរទាំងមូលមក សមាជជាតិថ្មីមួយទៀត នឹងសំរេចពីរបបគ្រប់គ្រងប្រទេសរបស់ប្រជាពលរដ្ឋខ្មែរ" ។ នៅសម័យនោះ រាល់ការសំរេចរបស់សមាជត្រូវបានអនុម័តដោយលើកដៃ ។ ដោយឡែក សេចក្តីសំរេចមួយដែលប្រកាសផ្តល់អំណាចពេញទីដល់រ.ជ.រ.ប.ខ. ដឹកនាំដោយគណៈកម្មាធិការប្រតិបត្តិមួយ ឬ កូមុិច ដោយមិនបានចែងថាដឹកនាំដោយប្រធាន ក៏ក្លាយទៅជាប្រភព នៃជម្លោះដណ្តើមអំណាចគ្នារវាងប្រធាន និង សមាជិកមួយចំនួននៃគណៈកម្មាធិការប្រតិបត្តិ ឬ កូមុិច នៅពេលក្រោយៗមកទៀត ។ នៅឆ្នាំ ១៩៨៣ ដើម្បីកុំឲ្យមានជម្លោះអាចកើតមានបាននោះ លោកតា សឺន សាន បានកោះប្រជុំនូវអង្គសន្និបាតមួយដើម្បីឲ្យអង្គសន្និបាតប្រគល់អំណាចពេញទីដល់ប្រធាន តាមវិធីអនុម័តដោយលើកដៃដដែល ។ ម្យ៉ាងទៀត គំនិតដែលថានឹងកោះប្រជុំសមាជថ្មីមួយនៅក្នុងប្រទេសខ្មែរក្រោយពីការបោះឆ្នោតជាទូទៅនោះ ជាគំនិតដែលមិនអាចធ្វើបានគឺជាគំនឹតមិនប្រាកដនិយម ព្រោះថា រ.ជ.រ.ប.ខ. ត្រូវកែប្រែរូបរាងរបស់ខ្លួនឲ្យទៅជាគណបក្សនយោបាយមួយ ដែលមានកម្មវិធីនយោបាយច្បាស់លាស់ រួមទាំង ជំរើសនូវរបបគ្រប់គ្រងរដ្ឋផង ដើម្បីត្រៀមខ្លួនចូលទៅប្រកួតប្រជែងក្នុងការបោះឆ្នោតជាទូទៅដោយសេរីមួយក្នុងពេលខាងមុខ ។

ដោយបានទទួលការលើកសរសើរ ពីសំណាក់បណ្តាញសារព័ត៌មានអន្តរជាតិ ចំពោះជោគជ័យនៃការរៀបចំសមាជជាតិនៅលើទឹកដីខ្មែរ រ.ជ.រ.ប.ខ. បានលេចមុខចេញលើឆាកអន្តរជាតិថា ជាចលនាតស៊ូមួយគួរឲ្យទុកចិត្តបាន ។ តាមរយៈសមាជជាតិនាខែ មេសា ១៩៨០ នោះ អ្នកដឹកនាំទាំងអស់នៃចលនា រ.ជ.រ.ប.ខ. នៅតែរឹងទទឹងចំពោះការប៉ុនប៉ងរបស់ប្រទេសគាំទ្រមួយចំនួន ដែលបង្ខំឲ្យចូល

រួមក្នុងរណសិរ្សរួបរួមជាមួយខ្មែរក្រហម ។ ក៏ប៉ុន្តែបញ្ហាអាសនៈរបស់កម្ពុជានៅអង្គការសហប្រជាជាតិក៏បានក្លាយទៅជាបញ្ហាដ៏ក្តៅគគុក ដែលត្រូវដោះស្រាយជាបន្ទាន់ ហើយក៏ត្រូវបានក្លាយជាទិសដៅនៃការតស៊ូខាងផ្លូវទូតរវាងអ្នកគាំទ្រ និងអ្នកប្រឆាំងកងទ័ពវៀតណាមនៅកម្ពុជា ។ របបភ្នំពេញដែលកើតឡើងដោយមានកងទ័ពវៀតណាមជាបង្អែកយ៉ាងរឹងមាំនោះ កំពុងត្រៀមរៀបចំការបោះឆ្នោតមួយដើម្បីកែប្រែលក្ខន្តិកៈពីរបបមួយ ដែលកើតឡើងដោយសារកម្លាំងកងទ័ពបរទេសមកជារបបមួយ ដែលកើតឡើងដោយសារការបោះឆ្នោតជាសកលទៅវិញ ។

ចំណែកឯពួកខ្មែរក្រហម ដែលមានឈ្មោះល្បីក្នុងពិភពលោកដោយសារការកាប់សម្លាប់ប្រជាពលរដ្ឋខ្លួនឯង ពុំមានសមត្ថភាពការពារអាសនៈរបស់ខ្លួននៅអង្គការសហប្រជាជាតិបានទៀតឡើយ ។ អាសនៈនោះ ពួកខ្មែរក្រហមបានកាន់កាប់តាំងពីឆ្នាំ ១៩៧៥ រហូតមក បន្ទាប់ពីការដួលរលំនៃរបប លន់ នល់ ។

នៅពេលនោះ ដោយសារ រ.ជ.រ.ប.ខ. លេចមុខធ្លោឡើងនៅលើឆាកអន្តរជាតិ បានធ្វើឲ្យប្រទេសដែលប្រឆាំងនឹងការលុកលុយរបស់វៀតណាមនៅកម្ពុជា ជាពិសេសប្រទេសចិន ថៃ ស.រ.អា និង ក្រុមប្រទេសអាស៊ានឯទៀត ចាប់ផ្តើមផ្តួផ្តងឲ្យមានការបង្កើតរដ្ឋាភិបាលខ្មែរមួយ ដោយមានលោកតា សឺន សាន ជាអ្នកដឹកនាំ និង ដោយឲ្យមានការរួបរួមជាមួយខ្មែរក្រហម ។ ក៏ប៉ុន្តែ រ.ជ.រ.ប.ខ. នៅតែចចេសរឹងទទឹង ដោយសំអាងថាក្នុងនាមប្រជាពលរដ្ឋខ្មែរ ដែលបានទទួលរងគ្រោះដោយសារខ្មែរក្រហម រ.ជ.រ.ប.ខ. មិនអាចចូលរួមជាមួយពួកប្រល័យពូជសាសន៍នេះបានឡើយ ។ ជំហរនេះក៏បានបញ្ចាក់សាឡើងវិញ នៅក្នុងសមាជឆ្នាំ ១៩៨០ នោះ ។ ជាមួយគ្នានោះ ថ្នាក់ដឹកនាំ រ.ជ.រ.ប.ខ.ក៏ប្រមើលមើលមធ្យោបាយគ្រប់យ៉ាងដើម្បីពង្រឹងចលនាតស៊ូនេះ ។

សម្តេច សីហនុ លាឈប់ពីតំណែងប្រធានសហព័ន្ធខ្មែរ

ចំណែកឯសម្តេច សីហនុ ព្រះអង្គហាក់ដូចជាអន់ព្រះទ័យខ្លះចំពោះជំនួយអន្តរជាតិបន្តិចបន្តួច ដែលទ្រង់ទទួលបានពីមជ្ឈដ្ឋានអន្តរជាតិដែលគាំទ្រព្រះអង្គ។ សម្តេចទ្រង់ស្ថិតនៅចំពោះសភាពការណ៍ប្រឈមពីរយ៉ាងគឺ៖ ម្យ៉ាង ព្រះអង្គមិនត្រូវធ្វើសហការណាមួយជាមួយពួកខ្មែរក្រហមទៀតឡើយ រីឯម្យ៉ាងទៀត ព្រះអង្គក៏មិនត្រូវបណ្តែតបណ្តោយឲ្យលោកតា សឺន សាន ចេញមុខជាអ្នដឹកនាំចលនាមិនមែនកុម្មុយនីស្តតែម្នាក់ឯងបានឡើយ ។ ក្នុងប៉ុន្មានខែកន្លងមកសម្តេច សីហនុ ទ្រង់តែងតែប្រកាសថា ព្រះអង្គមិនមានបំណងធ្វើការជាមួយពួកឃាតករ ដែលបានកាប់សម្លាប់ប្រជារាស្ត្រតទៅទៀតទេ ។ ជាមួយនោះព្រះអង្គក៏យល់ថាពេលវេលាមិនទាន់មកដល់ទេ សម្រាប់ឲ្យព្រះអង្គទទួលតួនាទីដឹកនាំចលនា រ.ជ.រ.ប.ខ. ដែលបង្កើតឡើងដោយលោកតា សឺន សាន និង ដែលមានមេដឹកនាំយោធាភាគច្រើនសុទ្ធតែជាពួកនាយទាហានពាក់ព័ន្ធក្នុងដួងប្រហារឆ្នាំ ១៩៧០ ។ នៅសម័យនោះ ក្រុមប្រទេសដែលគាំទ្រចលនាតស៊ូប្រឆាំងវៀតណាម ក៏បានធ្វើការគាបសង្កត់កាន់តែខ្លាំងឡើង ដើម្បីបង្ខំឲ្យ រ.ជ.រ.ប.ខ. រួមកម្លាំងជាមួយពួកខ្មែរក្រហម ទោះបីជាសម្តេច សីហនុ មិនចូលរួមក៏ដោយ ។ មែនទែន សហព័ន្ធខ្មែររបស់សម្តេច ពុំបានធ្វើឲ្យខ្មែរយើងមានការភ្ញាក់ផ្អើលប៉ុន្មានឡើយ ។ ម្យ៉ាងទៀត ក្នុងមួយរយៈពេលដែលព្រះអង្គចេញមកដឹកនាំសហព័ន្ធខ្មែរ ដែលទ្រង់បានបង្កើតនៅទីក្រុងព្យុងយ៉ាងនោះ សម្តេច សីហនុ ពុំទទួលបាននូវការគាំទ្រដុំកំភួនឡើយ ។ ជាមួយនោះ ឥស្សរជននយោបាយខ្មែរដ៏ល្បីល្បាញម្នាក់ដែលធ្លាប់បំរើព្រះអង្គជាយូរមកហើយគឺសម្តេច ប៉ែន នុត បានបែរមកគាំទ្រ រ.ជ.រ.ប.ខ.របស់លោកតា សឺន សាន ទៅវិញ ។ តាមពិតទៅ សម្តេច ប៉ែន នុត បានប្រកែកពុំព្រមចូលរួមដឹកនាំចលនា ឬ ស្ថាប័នរបស់អតីតព្រះ

មហាក្សត្រនោះទេ ។ ក្នុងពេលនោះសម្តេច សីហនុ ទ្រង់សំរេចលាឈប់ពីមុខតំណែងប្រធានសហព័ន្ធខ្មែរក្នុងន័យលាឈប់ពីនយោបាយ ។

នៅខែ ឧសភា ១៩៨០ សម្តេចបានផ្ញើសារជាច្រើនច្បាប់ទៅអ្នកគាំទ្ររបស់ព្រះអង្គ ។ នៅក្នុងសារចុះថ្ងៃទី ២០ ឧសភា ១៩៨០ ផ្ញើជូនលោកតា អ៊ិន តាំ សម្តេចបានសំដែងអំណរគុណ ចំពោះភក្តីភាពរបស់លោកតាចំពោះព្រះអង្គ និងបានសុំអភ័យទោស ចំពោះសេចក្តីសំរេចលាលែងពីតំណែងប្រធានសហព័ន្ធខ្មែរអ្នកជាតិនិយមរបស់ព្រះអង្គ ព្រមទាំងទុកលទ្ធភាពឲ្យលោកតា អ៊ិន តាំ ធ្វើការពិចារណាថា តើគួរត្រូវបន្តតំណែងអគ្គលេខាធិការសហព័ន្ធនេះតទៅទៀត ឬ គួរលាឈប់ពីតំណែងអគ្គលេខានេះ[115]? នៅក្នុងសារទូរលេខមួយច្បាប់ទៀតចុះថ្ងៃទី ១៩ ឧសភា ផ្ញើជូនសហការីដ៏ជិតស្និទ្ធរបស់ព្រះអង្គគឺ៖ លោក ខែក វ៉ាន់ឌី លោកវរសេនីយឯក ទឹម ណាំង លោកវរសេនីយឯក ប៊ូ ហិល និង លោកស្រី ជួន សៅឌី (ឥឡូវនេះជា លោកស្រី សាយ ប៊ូរី) សម្តេចបានបង្ហើបឲ្យដឹងពីឧបសគ្គជាច្រើនរបស់ព្រះអង្គ ។ សេចក្តីនៃទូរលេខមានចែងជាអាទិថា៖[116] "សូមមេត្តាបញ្ជូននូវការរាប់អានរបស់ខ្ញុំ ជូនលោក គង់ ស៊ីលាស់ និង ចលនាមូលីណាកា ជូនលោក អ៊ិន សាខន និង ចលនារណសិរ្សអង្គរ ថ្វាយអ្នកអង្គម្ចាស់ អង្គឌួង សុវណ្ណគីរី និងចលនារបស់លោក ជូនលោក អ៊ូ សារឿន និង ចលនារំដោះខ្មែរអព្យាក្រឹត្យ ជូនលោកវរសេនីយឯក វ៉ាន់ សៅយុទ្ធ និង រណសិរ្សរំដោះអ្នកជាតិនិយម និងជូនចលនារំដោះជាតិ និង រណសិរ្សទាំងអស់ដែលបានផ្ញើលិខិត និង ញ្ញត្តិគាំទ្រក្នុងរយៈពេលនៃការស្នាក់អាស្រ័យរបស់ខ្ញុំនៅប្រទេសបារាំង ដែលខ្ញុំសូមឆ្លើយតបជូនដូចតទៅ៖ ក្រៀមក្រំ ជាពន់ពេក និង អៀនខ្មាស់ជាទីបំផុត ដោយខ្ញុំពុំបានធ្វើការ

[115] Samdech Sihanouk (Telegramme en date du 20 mai 1980 de) à Son Excellece In Tam, Bulletin Mensuel de Documentation no. 4, Juillet 1980.
[116] Samdech Sihanouk (Télégramme en date du 19 mai 1980 de) à Mr. KHEK Vandy, Colonel TIM Naing, Colonel BUOR Hell, Mme CHUON Saodi, Bulletin Mensuel de Documentation no. 4, Juillet 1980.

ជូនអស់លោកឲ្យបានជាវិជ្ជមាន និង ជួយអស់លោកឲ្យជាក់ស្តែងបានដោយហេតុ ថាៈ ទី១- ខ្ញុំពុំមានទ្រពសម្បត្តិធនធានគ្រប់គ្រាន់ ហើយសព្វថ្ងៃរស់នៅបាន ក៏អាស្រ័យដោយការទទួលឲ្យស្នាក់នៅដ៏សប្បុរសរបស់លោកប្រធានាធិបតី គីម អ៊ិល ស៊ុង នៃប្រទេសកូរ៉េខាងជើងតែប៉ុណ្ណោះ-ស្តុប- ទី២- ការខឹតខំទាក់ទងរបស់ ខ្ញុំជាមួយរដ្ឋាភិបាល បារាំង ស.រ.អា និង ចិន ក្នុងការស្វែងរកជំនួយជូនអស់លោក ត្រូវទទួលបរាជ័យទាំងអស់-ស្តុប- ទី៣-ប្រទេសថៃ និង ប្រទេសចិន គេតម្រូវ ឲ្យអស់លោកចូលរួមទាំងស្រុងជាមួយខ្មែរក្រហម ទើបអស់លោកអាចទទួលជំនួយ ពីប្រទេសចិនបាន-ស្តុប- ទី៤-ប្រទេសថៃមិនចូលចិត្តខ្ញុំទេ ហើយមិនអនុញ្ញាត ឲ្យខ្ញុំជាន់ទឹកដីគេទេ-ស្តុប-ខ្ញុំគោរពអស់លោក គាំទ្រអស់លោកយ៉ាងខ្លាំងក្លាបំផុត ហើយខ្ញុំមានករណីយកិច្ចសូមផ្តល់យោបល់ជូនអស់លោក សូមឲ្យយកតំរាប់តាម ឯកឧត្តម សឺន សាន និង រណសិរ្សរបស់គាត់ ឬ បើល្អជាងនេះទៅទៀតចូល រួមជាមួយគាត់ ដើម្បីទទួលបាននូវជំនួយដ៏ចាំបាច់ទាំងឡាយពីប្រទេសចិន ពី ប្រទេសថៃ និង ពី សេ អ៊ី អា របស់សហរដ្ឋអាមេរិក-ស្តុប-សូមអស់លោកកុំប្រាប់ គេថា អស់លោកធ្វើការតស៊ូ ដើម្បីសីហនុ ព្រោះថាបើធ្វើការតស៊ូដើម្បីសីហនុនោះ អស់លោកប្រាកដជាពុំបានទទួលជំនួយអ្វីពីប្រទេសចិន និង ពុំទទួលការការពារពី រដ្ឋាភិបាលថៃឡើយគឺ ការការពារដែលអស់លោកកំពុងត្រូវការខានពុំបាន-ស្តុប-អស់លោកត្រូវធ្វើការជាមួយ ប្រទេសចិន និង រដ្ឋាភិបាលថៃ បើមិនដូច្នេះទេ អស់ លោកនឹងពុំមានមធ្យោបាយ សំរាប់ធ្វើការតស៊ូឡើយ" ។

នៅសម័យនោះពួកយុវជនដូចខ្ញុំយល់ថាសម្តេច សីហនុ មានព្រះទ័យមិន នឹងន់សោះ ព្រោះក្នុងកាលកន្លងមក ព្រះអង្គបានជូរព្រះទ័យជាច្រើនដងច្រើនគ្រា មកហើយ ។ ការសំរេចព្រះទ័យរបស់ព្រះអង្គថាដកព្រះកាយចេញពី "នយោបាយ" នោះអាចគ្រាន់តែបង្ហាញនូវការបរាជ័យមួយ ឬ ក៏ជាការគិតគូរដ៏មានល្បិចកលផ្នែក

នយោបាយមួយរបស់ព្រះអង្គតែប៉ុណ្ណោះ ។ តើការគិតគូរផ្នែកនយោបាយរបស់ព្រះអង្គនោះ ជាការគិតគូរដើម្បីយកចំណេញសំរាប់តួព្រះអង្គផ្ទាល់ ឬ ដើម្បីជាផលប្រយោជន៍ដល់មូលហេតុជាតិ? ការវិវត្តផ្នែកនយោបាយនាពេលក្រោយមកទៀតនឹងបញ្ជាក់អំពីធាតុពិតនៃការគិតគូរនយោបាយនេះ ។

តាមពិតតាំងពីព្រះអង្គ បានរំដោះព្រះកាយរួចចេញពីការត្រួតត្រារបស់ពួកខ្មែរក្រហមមក សម្តេច សីហនុ បានបញ្ជូនសញ្ញាមួយចំនួន ដើម្បីម្យ៉ាងឲ្យប្រជារាស្ត្រខ្មែរយល់នូវព្រះទ័យសោកស្តាយ និង ខ្លោចផ្សាជាអនេករបស់ព្រះអង្គ ចំពោះទុក្ខវេទនា និង មហាវិនាសកម្ម ដែលបង្កឡើងដោយពួកខ្មែរក្រហម ព្រោះថាសូម្បីតែសម្តេចព្រះអង្គឯងក៏ត្រូវជាប់បង្ខាំងក្នុងព្រះរាជវាំង ជាអ្នករងគ្រោះដោយរបបប៉ុល ពត ដែរ ។ ម្យ៉ាងទៀត ព្រះអង្គក៏មានបំណង ឲ្យប្រជារាស្ត្រយល់នូវព្រះទ័យស្នេហាជាតិរបស់ព្រះអង្គ ដែលទ្រង់នៅតែដើរតួនាទីក្នុងប្រពៃណីជាប្រមុខរបស់ខ្មែរក្នុងព្រះឋានៈជាអតីតព្រះមហាក្សត្រដែលខ្មែរធ្លាប់គោរពស្មើព្រះអាទិទេពទេនោះ ។ ចំពោះអ្នកដឹកនាំក្រុងហាណូយ ព្រះអង្គបង្ហាញសញ្ញាថា ប្រសិនទទួលយកព្រះអង្គជាដៃគូនោះ ព្រះអង្គនឹងជួយរៀតណាម ឲ្យបញ្ចប់ជម្លោះនៅកម្ពុជាដោយសន្តិវិធី និង មិត្តភាព ។ ចំពោះចលនាតស៊ូ និង សម្ព័ន្ធមិត្ត ដែលកំពុងធ្វើការតតាំងប្រឆាំងក្រុងហាណូយ ព្រះអង្គបង្ហាញសញ្ញាថា ព្រះអង្គអាចនឹងផ្លាស់ប្តូរគោលជំហរពីការតស៊ូប្រឆាំងទៅជាសហការជាមួយក្រុងហាណូយវិញក៏បាន ប្រសិនបើចលនាតស៊ូ និង សម្ព័ន្ធភាពទាំងនោះមិនយកចិត្តទុកដាក់ចំពោះព្រះអង្គទេនោះ ។

ពេលនោះលោកតា ដើរតួឯក

ដោយធ្វើជាមិនយល់ ឬ ដោយមានចេតនាកេងយកចំណេញផងក៏មិនដឹង លោកតា សឺន សាន បានចាប់យកពាក្យអំពាវនាវរបស់សម្តេច សីហនុ ចំពោះអ្នក

គាំទ្រ ដែលព្រះអង្គណែនាំឲ្យមកចូលរួមជាមួយរ.ជ.រ.ប.ខ.ជាការគាំទ្រពិតប្រាកដ របស់សម្តេច ។ នៅរដូវក្តៅនាឆ្នាំ ១៩៨០ លោកតា សឺន សាន បានត្រឡប់មក កាន់ទីក្រុងប៉ារីសវិញ ។ វគ្គមានរបស់លោកតាបានលើកទឹកចិត្តដល់ពួកយើងយ៉ាង ខ្លាំងអស្ចារ្យ ព្រោះថានៅពេលដែលគ្មានតួអង្គសម្តេច សីហនុ នៅក្នុងឆាកនយោ បាយខ្មែរ លោកតា សឺន សាន បានលេចឡោះឡើងជាអ្នកដឹកនាំអ្នកជាតិនិយមតែ ម្នាក់គត់ ដែលគួរឲ្យទុកចិត្តបាន ។

ខ្ញុំបានចំណាយពេលស្ទើរតែទាំងអស់របស់ខ្ញុំ ចូលរួមក្នុងក្រុមអ្នកជំនួយការ របស់លោកតា ដើម្បីរៀបចំកម្មវិធីប្រជុំការងារ ឬ សន្និសីទកាសែត ឬ ធ្វើទស្សនកិច្ច ទៅតាមសហគមន៍ខ្មែរទូទាំងប្រទេសបារាំង ។ នៅថ្ងៃទី ១០ កក្កដា ១៩៨០ លោកតា សឺន សាន បានអញ្ជើញទៅធ្វើបទអន្តរាគមន៍នៅចំពោះមុខសាស្ត្រាចារ្យ និង និស្សិតនៃសាលាយោធាបារាំង (Ecole Militaire) ដែលនៅក្នុងឱកាសនោះ លោកតាបានធ្វើការថ្កោលទោសពួកកុម្មុយនីស្តអាស៊ីមានខ្មែរក្រហម និង ក្រុងហា ណូយ ។ លោកតាថ្កោលទោសខ្មែរក្រហម ចំពោះអំពើប្រល័យពូជសាសន៍ឯងដែល គេមិនដែលឃើញមានសោះ នៅក្នុងប្រវត្តិសាស្ត្រពិភពលោក ។ លោកតាថ្កោល ទោស ចំពោះក្រុងហាណូយ ដែលលោកតាចោទថា កំពុងបន្តអំពើប្រល័យពូជ សាសន៍ តាមរយៈការកេងប្រវ័ញ្ចជំនួយអន្តរជាតិ តាមរយៈអំពើលួចប្លន់ តាមរយៈ អំពើគំរាមកំហែងដល់ប្រាសាទអង្គរ តាមរយៈការដាក់ឲ្យប្រើនូវប្រាក់ "រៀលក្លែង ក្លាយ" តាមរយៈការដាក់បង្ខំឲ្យប្រើនូវរដ្ឋធម្មនុញ្ញខុសច្បាប់ តាមរយៈការរៀបចំនូវ ការបោះឆ្នោតមិនត្រឹមត្រូវ តាមរយៈការបង្កើតតុលាការបដិវត្ត និង ការដាក់គុក តាមរបៀប ប៉ុល ពត ។ លោកតា សឺន សាន ថ្លែងក្នុងឱកាសនោះថា ប្រសិនបើ ចលនា រ.ជ.រ.ប.ខ. បានទទួលជំនួយគ្រប់គ្រាន់ដើម្បីបោះដំហានទៅមុខ និង ដើម្បី បំរើ ការពារប្រជាពលរដ្ឋខ្មែរនោះ រ.ជ.រ.ប.ខ.នឹងបានទទួលការគាំទ្រកាន់តែខ្លាំង

ឡើងពីប្រជាពលរដ្ឋ នាំឲ្យប្រជាពលរដ្ឋខ្មែរអោចក្រោកឈរឡើង និង ឈប់សហការជាមួយក្រុងហាណូយតទៅទៀត ។ លោកតាប្រធានថ្លែងថា៖ "វៀតណាម នឹងជួបការលំបាកផ្ទៃក្នុងកាន់តែធ្ងន់ធ្ងរឡើង ហើយពួកគេនឹងទទួលយកនូវសេចក្តីសំរេចរបស់អង្គការសហប្រជាជាតិចុះថ្ងៃទី ១៤ វិច្ឆិកា ១៩៧៩ ដែលក្នុងនោះតម្រូវឲ្យក្រុងហាណូយដកកងទ័ពរបស់ខ្លួនឲ្យអស់ពីកម្ពុជា ដើម្បីឲ្យប្រជារាស្ត្រខ្មែរសំដែងឆន្ទៈរបស់ខ្លួនដោយសេរី" ។ លោកតាប្រធានចង់និយាយថា ប្រសិនបើ រ.ជ.រ.ប.ខ. ទទួលជំនួយគ្រប់គ្រាន់ពីប្រទេសលោកសេរី ចលនានេះអាចនឹងធ្វើជាគំរូគេក្នុងការតស៊ូប្រឆាំងកុម្មុយនីស្តសំរាប់តំបន់នានាឯទៀតនៅក្នុងពិភពលោក ។ ក្នុងន័យនេះ លោកតាមានប្រសាសន៍តាមពាក្យបុរាណខ្មែរថា៖ "ភ្លើងឆេះពីសំរាម" សំរាមរបស់ពួកយុទ្ធជនសេរីមូចាហេឌីន (Mujaheddin) អាហ្គានីស្តាន នឹងបង្កើតជាភ្លើងអគ្គីភ័យក្នុងតំបន់មជ្ឈឹមបូព៌ា រីឯសំរាម រ.ជ.រ.ប.ខ. នឹងបង្កើតជាអគ្គីភ័យនៅកម្ពុជា ។ ដូច្នេះ "សូមប្រទេសលោកសេរីមេត្តាជួយយើងខ្ញុំ និង សូមជួយយើងខ្ញុំជាបន្ទាន់"[117] ។

ដើម្បីបង្ហាញថាលោកតាជាអ្នកដឹកនាំអ្នកជាតិនិយម ដែលបានទទួលបានការគាំទ្រពីខ្មែរគ្រប់និន្នាការនយោបាយនោះ លោកតា សឺន សាន បានសំអាងទៅលើសេចក្តីប្រកាសគាំទ្រពីសម្តេច សីហនុ (ទ្រង់ថ្លែងក្នុងខែ ឧសភា ១៩៨០) និង លោកសេនាប្រមុខ លន់ នល់ ។ លោកតាថ្លែងថា៖ "សម្តេចសីហនុ និង លោកសេនាប្រមុខ លន់ នល់ បានសុំឲ្យយុទ្ធជនអ្នកជាតិនិយមទាំងអស់ចូលរួមជាមួយ រ.ជ. រ.ប.ខ. ។ ក្នុងនាមយុទ្ធទាំងនោះ ខ្ញុំសូមសំដែងអំណរគុណដល់ឥស្សរជនជាន់ខ្ពស់ទាំងពីរូបនេះ" ។

[117] Son Sann, Conférence sur les Perspectives Cambodgiennes, A l'Ecole Militaire, le 10 Juillet 1980, Bulletin du Front National de Libération du Peuple Khmer no. 7, Juillet 1980, pp. 9-13.

ជំរុំ រ.ជ.រ.ប.ខ. រងការវាយប្រហារ

នៅក្នុងពេលដែល រ.ជ.រ.ប.ខ. កំពុងស្វែងរកជំនួយអន្តរជាតិ កងទ័ពក្រុងហាណូយ បានសាកល្បងវាយបំផ្លាញកងកម្លាំងយោធានៃចលនាអ្នកជាតិនិយម ។ នៅថ្ងៃទី ២៣ មីនា ១៩៨០ ពួកគេវាយប្រហារមកលើភូមិសុខសាន្ត ដោយបានបាញ់កាំភ្លើងធំធុន ១០៥ មម និង ១២២ មម ដែលក្នុងនោះត្រូវបានចោទប្រកាន់ថាមានបង្កប់ទៅដោយជាតិឧស្ម័នធ្វើឲ្យប្រជាពលរដ្ឋស៊ីវិលភ័យស្លន់ស្លោ ហើយត្រូវជំលៀសចេញទៅនៅក្នុងតំបន់ផ្សេងដែលមានសុវត្ថិភាពជាង ។ ចាប់ពីថ្ងៃទី ២៥ ទៅ ២៧ មេសា ១៩៨០ កងទ័ពវៀតណាមវាយប្រហារជាថ្មីទៀតទៅលើភូមិសុខសាន្ត នៅចំពេលដែលរ.ជ.រ.ប.ខ. កំពុងធ្វើសមាជជាតិរបស់ខ្លួនក្នុងតំបន់មួយផ្សេងពីទីនោះ ។ រ.ជ.រ.ប.ខ. បានធ្វើការថ្កោលទោសការវាយប្រហារនេះថាជាការបន្តអំពើប្រល័យពូជសាសន៍ ដែលប្រព្រឹត្តឡើងដោយពួកវៀតណាមខាងជើងទៅលើប្រជារាស្ត្រខ្មែរ ។ ឆ្លៀតក្នុងឱកាសនោះ រ.ជ.រ.ប.ខ. ក៏អំពាវនាវសុំជំនួយបន្ថែម ។ នៅសម័យនោះ រ.ជ.រ.ប.ខ. បានធ្វើការប្តឹងថ្លែងពាក្យពេចន៍ណាស់ ដោយប្រើតែពាក្យ កងទ័ពវៀតណាមខាងជើង ព្រោះជាកងទ័ពកុម្មុយនីស្ត និង មិនចេញឈ្មោះកងទ័ពរបស់លោក ហេង សំរិន - ហ៊ុន សែន ទេ ដោយចង់បង្ហាញឲ្យឃើញថាសង្គ្រាមសម័យនោះ មិនមែនជាសង្គ្រាមរវាងខ្មែរ និង ខ្មែរនោះឡើយ ។

សេចក្តីប្រកាសរបស់រ.ជ.រ.ប.ខ.បានថ្លែងជាអាទិថា៖ "រ.ជ.រ.ប.ខ. មានមោទនភាពចំពោះកងកម្លាំងរបស់ខ្លួន ហើយមិនខ្លាចនឹងប្រកាសជាថ្មីម្តងទៀតថា រ.ជ.រ.ប.ខ.មិនខ្វះអ្នកស្ម័គ្រចិត្តកាន់អាវុធ ដែលមានសេចក្តីក្លាហាន និង ការប្តេជ្ញាចិត្តដ៏រឹងមាំដូចយុទ្ធជននៅសុខសាន្តនោះឡើយ ។ អ្វីដែលខ្វះខាតគឺ កាំភ្លើង និង ជាពិសេស គ្រាប់រំសេវ ។ សូមមេត្តាផ្តល់ដល់ រ.ជ.រ.ប.ខ. នូវកាំភ្លើង និង គ្រាប់រំសេវ

ទាំងនោះឲ្យបានចំនួនគ្រប់គ្រាន់ ។ រ.ជ.រ.ប.ខ. នឹងមានលទ្ធភាពបង្កវិបត្តិកាន់តែធ្ងន់ធ្ងរឡើងដល់កងទ័ពឈ្លានពានវៀតណាមខាងជើង ដើម្បីបានស្រោចស្រង់ជាតិសាសន៍ និង ប្រជាជាតិខ្មែរ" ។

ការវាយប្រហារដោយកងទ័ពវៀតណាមប្រមាណជាង ៣០០០ នាក់ទៅលើភូមិខ្មែរដ៏សុខសាន្តមួយបានបង្កក្តីលំបាកដល់ រ.ជ.រ.ប.ខ. ក៏ប៉ុន្តែជាមួយគ្នានោះក៏បានបង្ហាញថា ចលនានេះបានក្លាយជាកម្លាំងមួយ ដែលកងទ័ពវៀតណាមត្រូវតែទទួលស្គាល់ និង បំផ្លាញចោលឲ្យបាន ។ នៅពេលដែលការវាយប្រហារដោយកម្លាំងមានសភាពកាន់តែខ្លាំងក្លាឡើង យើងក៏ចាប់ផ្តើមឮពាក្យស្តីពីការចរចាបញ្ចប់សង្គ្រាមដែរ ទោះបីជាភាគីនីមួយៗមានយុទ្ធសាស្ត្រផ្សេងៗគ្នាក៏ដោយ ។ តាមការស្នើធ្វើការចរចាជាមួយប្រទេសអាស៊ាន ក្រុងហាណូយមានបំណងស្វែងរកការទទួលស្គាល់ជាអន្តរជាតិជូនដល់របបក្រុងភ្នំពេញ ដែលបានឡើងកាន់អំណាចបន្ទាប់ពីការដួលរលំនៃរបបប៉ុលពត ។

ពីថ្ងៃទី ១៧ ដល់ ១៨ កក្កដា រដ្ឋមន្ត្រីនៃប្រទេសវៀតណាម លាវ និង កម្ពុជា (រដ្ឋាភិបាល ហេង សំរិន នៅភ្នំពេញ) បានជួបប្រជុំគ្នានៅទីក្រុងវៀងច័ន្ទ ។ ដោយមានការគាំទ្រពីប្រទេស លាវ និង វៀតណាម រដ្ឋាភិបាល ហេង សំរិន បានលើកសំណើដើម្បី "កាត់បន្ថយភាពតានតឹង និង ដើម្បីកែប្រែព្រំប្រទល់ថៃ-កម្ពុជាឲ្យទៅជាព្រំប្រទល់មួយប្រកបដោយសន្តិភាព និង មិត្តភាព" ។ ក៏ប៉ុន្តែពួកយើងនៅទីក្រុងបាងកកវាយតម្លៃថា រដ្ឋមន្ត្រីនៃប្រទេសទាំងបីនិយាយពីបញ្ហាជនភៀសខ្លួន ដើម្បីឲ្យរបបភ្នំពេញបានទទួលការទទួលស្គាល់ពីអន្តរជាតិ ។ សំណើនោះមានជាអាទិ៍៖ "ការបង្កើតតំបន់គ្មានកងទ័ព នៅតំបន់ទល់ដែនចន្លោះប្រទេសកម្ពុជា និង ថៃ និង បង្កើតគណៈកម្មការចម្រុះ ដើម្បីអនុវត្តកិច្ចព្រមព្រៀងជានាសន្តិភាព និង ស្ថេរភាពនៅតំបន់ទល់ដែន -ការចរចាដើម្បីឲ្យជនភៀសខ្លួនទៅតាំងទីឲ្យ

ឆ្ងាយពីទល់ដែន ដើម្បីជៀសវាងការប៉ះអាវុធគ្នា -ដកអាវុធពីកងទ័ព ប៉ុល ពត និង កងកម្លាំង "ប្រតិកិរិយា" ទាំងអស់ និង បញ្ជូនពួកគេទាំងនេះទៅក្នុងជំរុំដោយឡែក -ចែកជំនួយអន្តរជាតិដល់ខាងក្នុងប្រទេសកម្ពុជា មិនមែននៅតាមទល់ដែនគឺចែកជំនួយតាមកិច្ចព្រមព្រៀងរវាងអង្គការអន្តរជាតិជាមួយរដ្ឋាភិបាល ហេង សំរិន នៅភ្នំពេញ ។

ពួកបរទេសថា លោកតាក្បាលរឹង

តាំងតែពីពេលដែលបានត្រូវប្រកាសជាសាធារណៈនាខែ តុលា ១៩៧៩ រ.ជ.រ.ប.ខ. បានរងនូវការគាបសង្កត់ពីសំណាក់អ្នកគាំទ្រអន្តរជាតិរបស់ខ្លួន ជាពិសេសពីប្រទេសចិន និង ប្រទេសថៃ ឲ្យចូលរួមជាមួយខ្មែរក្រហម ។ ថ្នាក់ដឹកនាំ រ.ជ.រ.ប.ខ.តែងតែប្រកាសឲ្យដឹងជាសាធារណៈនូវបំណងរបស់ រ.ជ.រ.ប.ខ. ក្នុងការបង្កើតរដ្ឋាភិបាលមួយ ដែលមានមុខមាត់សមរម្យគ្រាន់បើជាងខ្មែរក្រហមហើយតែងតែប្រកែកពុំព្រមចូលរួមជាមួយពួកប្រល័យពូជសាសន៍នេះជានិច្ច ។ ទាំងនេះធ្វើឲ្យប្រទេសថៃជាក់ការគាបសង្កត់ទៅលើ រ.ជ.រ.ប.ខ.។ ការគាបសង្កត់ធ្ងន់ធ្ងរបែបជាទណ្ឌកម្ម តែងតែធ្វើឡើងដោយក្រុមយោធាថៃ ។ ជារួមការគាបសង្កត់នោះ មានការកាត់ផ្តាច់ជំនួយផ្នែកស្បៀងអាហារ ថ្នាំពេទ្យ និង គ្រាប់រំសេវ នៅពេលណាដែលអនុសាសន៍ទាំងឡាយរបស់ក្រុមយោធាទាំងនោះ មិនត្រូវបានអនុវត្តទាំងស្រុង ។

តាំងពីខែ កុម្ភៈ ដល់ មិថុនា ១៩៨០ លោកតា សឺន សាន ដែលពួកបរទេសឲ្យឈ្មោះថាជាអ្នកនយោបាយក្បាលរឹង (Stubborn politician) បានទប់ទល់មិនព្រមធ្វើតាមការគាបសង្កត់របស់ក្រុមយោធាថៃដែលបង្ខំឲ្យធ្វើសម្ព័ន្ធភាពជាមួយខ្មែរក្រហម ។ លោកតាបានធ្វើឲ្យពួកថៃមិនសប្បាយចិត្ត ធ្វើឲ្យពួកគេផ្តាច់ស្បៀងទាំងស្រុងដល់ រ.ជ.រ.ប.ខ. ។ នៅពេលនោះ កងទ័ពរបស់ រ.ជ.រ.ប.ខ. ស្ថិតនៅក្នុង

សភាពការណ៍មួយ ដែលស្ទើរតែដាច់ពោះទាំងអស់ទៅហើយ ។ ការចេញដំណើរ របស់លោកតា សឺន សាន ទៅទ្វីបអឺរ៉ុប នៅរដូវក្តៅនាឆ្នាំ ១៩៨០ មានគោលដៅ ឲ្យលោកតាមានសេរីភាព បន្ថែមលើសកម្មភាពស្វែងរកជំនួយពីលោកខាងលិចផង និង ឲ្យលោកតាស្ថិតក្រៅពីការគាបសង្កត់របស់ថៃផង ។ ក្នុងខែ កញ្ញា ១៩៨០ នៅពេលដែលលោកតាសួរទៅសហការីជាសមាជិកកូមុិចថា តើពេលវេលាសម ស្របឬនៅ ដើម្បីឲ្យលោកតាវិលត្រឡប់កាន់មូលដ្ឋានវិញ? នៅក្នុង ចម្លើយចុះថ្ងៃទី ៤ តុលា ១៩៨០ លោក នាង ជិនហាន អគ្គលេខាធិការ លោក ហ៊ីង គន្ធុន សមាជិកកូមុិច លោកឧត្តមសេនីយ ជៀន ដែល នាយសេនាធិការកងទ័ពបាន ឆ្លើយថា៖[118] "គណៈកម្មាធិការប្រតិបត្តិ កូមុិច និង ជំរុំ ទាំងអស់ចង់បានលោក ប្រធានត្រឡប់មកវិញណាស់ ។ ពួកយើងនឹកលោកប្រធានណាស់ ។ ក៏ប៉ុន្តែក្នុង កាលៈទេសៈបច្ចុប្បន្នជាការល្អបំផុត ប្រសិនបើលោកប្រធានអាចបន្តធ្វើការ ដោយ ចល័ត ឬ ធ្វើទំនាក់ទំនង ឬ ចាត់ការពីខាងក្រៅ ព្រោះនៅឯនោះ លោកប្រធានមាន សេរីភាពជាង និង មានលទ្ធភាពទទួលជោគជ័យច្រើនជាង ។ សភាពការណ៍ ដែល យើងធ្លាប់ជួបប្រទះពីខែ កុម្ភៈ រហូតខែ មិថុនា ១៩៨០ (ថៃផ្តាច់ស្បៀង) យើង នៅចងចាំជានិច្ច ។ ការខំប្រឹងប្រែងរបស់យើងខ្ញុំ ធ្វើឡើងដើម្បីឲ្យសំរេចនូវការ ណែនាំដ៏ខ្ពង់ខ្ពស់របស់លោកប្រធានក្នុងដំណើរឆ្ពោះទៅមុខ" ។ សូមបញ្ជាក់ថា ចាប់ពីខែកុម្ភៈ ដល់ខែ មិថុនា ១៩៨០ យោធាថៃបានកាត់ផ្តាច់ស្បៀងដល់កងទ័ព រ.ជ.រ.ប.ខ.។ ក្នុងសារនេះ ក៏មានរាយការណ៍ជូនលោកតាប្រធានអំពីការប៉ុនប៉ង ទាក់ទងជាមួយសហភាពសូវៀត តាមរយៈអ្នកកាសែតអូស្ត្រាលីម្នាក់ឈ្មោះ ណែល ដេវីស (Neil Devis) ។ លោក ណែល ដេវីស (Neil Devis) បានផ្តល់ព័ត៌មាន អំពីការគិតគូរថ្មីរបស់សហភាពសូវៀត ក្នុងការដោះស្រាយបញ្ហាកម្ពុជា ។ អ្នក

[118] Neang Chin Han, Hing Kunthon, Dien Del, Note d'Information du 4 Octobre 1980.

កាសែតរូបនេះ បានទទួលរងគ្រោះរហូតដល់ស្លាប់ ដោយសារគ្រាប់កាំភ្លើងដៃលទាហានបាញ់គ្នា នៅពេលកំពុងថតយកព័ត៌មានផ្ទាល់ក្នុងរដ្ឋប្រហារយោធាថៃ នៅទីក្រុងបាងកកនាឆ្នាំ ១៩៨៥ ។

ក្រុមកូមុិច ជ្រើសរើសសមាជិកថ្មី

ទោះបីជាគាត់ស្ថិតនៅក្រោមការគាបសង្កត់ឲ្យរួមរួបជាមួយខ្មែរក្រហមក្តី ក៏លោកតា សឺន សាន ត្រូវមានការប្រុងប្រយ័ត្នចំពោះសកម្មភាពរបស់សហការីនៅក្នុងរង្វង់កូមុិចដែរ ដែលនៅក្នុងនោះមានសមាជិកសំខាន់ៗខ្លះ ចាប់ផ្តើមបង្កើតឥទ្ធិពលផ្ទាល់ខ្លួនទៅលើចលនានេះជាបណ្តើរៗទៅហើយ ។ នៅក្នុងពេលអវត្តមានរបស់ប្រធាន រ.ជ.រ.ប.ខ. ក្រុមកូមុិច បានជ្រើសរើសសមាជិកថ្មីម្នាក់ នៅទីក្រុងបាងកក ឈ្មោះលោក ហ្គាហ្វា ពាងម៉េត អតីតអនុព័ន្ធសារព័ត៌មានរបស់ស្ថានទូតខ្មែរប្រចាំទីក្រុងវ៉ាស៊ិនតោន សហរដ្ឋអាមេរិក ដែលជាបញ្ញវន្តម្នាក់ជិតស្និទ្ធជាមួយលោក លន់ ណុន ប្អូនប្រុសដ៏ល្បីឈ្មោះរបស់លោក លន់ នល់ អតីតប្រធានាធិបតីនៃសាធារណរដ្ឋខ្មែរ ។ សម័យនោះ យើងហៅបញ្ញវន្តរូបនេះត្រឹមតែឈ្មោះ ហ្គាហ្វា តែប៉ុណ្ណោះ ។ តាមឯកសារផ្ទៃក្នុងរបស់ រ.ជ.រ.ប.ខ. ដែលខ្ញុំរកឃើញនៅពេលក្រោយៗមក គេបានរាយការណ៍ថា នៅពេលដែលលោក លន់ ណុន ស្លាប់នៅឆ្នាំ ១៩៧៥ ហ្គាហ្វា បានទាក់ទងស្នេហា ជាមួយប្រពន្ធរបស់លោក លន់ ណុន ទោះបីជា ហ្គាហ្វា មានប្រពន្ធសញ្ជាតិអាមេរិករួចហើយក៏ដោយ ។ ក៏ប៉ុន្តែតាមទ្រឹស្តីរបស់ រ.ជ.រ.ប.ខ. នាពេលនោះដែលថា អ្វីដែលកន្លងមកហើយត្រូវតែបំភ្លេចចោលទៅនោះ លោក ហ្គាហ្វា ក៏ត្រូវបានអនុញ្ញាតឲ្យចូលជាសមាជិក រ.ជ.រ.ប.ខ. ហើយត្រូវបានបង្ហាញជូនលោកតា សឺន សាន តាមសារចុះថ្ងៃទី ៤ តុលា ១៩៨០[119] ។

[119] Neang Chin Han, Hing Kunthon, Dien Del, Note d'Information, op. cit.

សមាជិកគណៈកម្មាធិការប្រតិបត្តិកូមុិចនៅបាងកក អបអរសាទរចំពោះ ហ្គាហ្វា និង លើកសរសើរថាហ្គាហ្វាជាសមាសភាពមួយដ៏ឆ្នើម ព្រោះមានសញ្ញាប័ត្របណ្ឌិតផ្នែកនយោបាយមកពីសហរដ្ឋអាមេរិកផង ។ សារនោះបានជំរាបលោក តា សឺន សាន ថា ហ្គាហ្វា នឹងទៅធ្វើការជាមួយលោកឧត្តមសេនីយ ដៀន ដែល នៅក្នុងតំបន់កណ្តាលជាការសាកល្បង ។ នៅសម័យនោះ រ.ជ.រ.ប.ខ. ចែកចេញជាបីតំបន់ ។ តំបន់នីមួយៗស្ថិតនៅក្រោមការទទួលខុសត្រូវនៃនាយទាហានមួយរូបគឺ៖ តំបន់កណ្តាលស្ថិតនៅក្រោមលោកឧត្តមសេនីយ ដៀន ដែល តំបន់ខាងជើង លោកវរសេនីយឯក អ៊ឹម ឈូដេត និង តំបន់ខាងត្បូងនៅក្រោមលោកវរសេនីយទោ ព្រុំ វិត ។ សូមបញ្ជាក់ថាឋានន្តរសក្តិឧត្តមសេនីយ ឬ វរសេនីយទាំងនោះ ជាឋានន្តរសក្តិចាស់តាំងសម័យសាធារណរដ្ឋខ្មែរមកម្ល៉េះ ។

ការិយាល័យផ្សាយព័ត៌មាន រ.ជ.រ.ប.ខ. នៅក្រៅប្រទេស

ជាមួយគ្នានោះដែរ រ.ជ.រ.ប.ខ. ក៏បានបង្កើតការិយាល័យផ្សាយព័ត៌មាននៅអឺរ៉ុប សហរដ្ឋអាមេរិក និង ជប៉ុន ។ នៅទីក្រុងឡុងដ៍នៃប្រទេសអង់គ្លេសការិយាល័យផ្សាយព័ត៌មានបានត្រូវដឹកនាំដោយលោក ប៉ែន រ៉ន[120] ដែលជាអតីតមន្ត្រីនៃធនាគារជាតិខ្មែរ ធ្លាប់ធ្វើការក្រោមបង្គាប់លោកតា សឺន សាន កាលលោកតាកាន់តំណែងជាអគ្គទេសាភិបាលក្នុងទសវត្សរ៍ឆ្នាំ១៩៥០-១៩៦០ ។ ឯសមាជិកឯទៀតនៃការិយាល័យផ្សាយព័ត៌មាននៅប្រទេសអង់គ្លេសនោះមានជាអាទិ៍ បណ្ឌិត ឡៅ ម៉ុង ហៃ បណ្ឌិត ប៊ិច ប៊ុន ថាត បណ្ឌិត ហេង ផល្លាសម្បត្តិ លោក នៅ កាណុន

[120] Son Sann, Front National de Libération du Peuple Khmer, Décision no. 80/05/FNL, Territoire Khmer, le 9 Octobre 1980.

លោក ម៉ឹង ភោគ លោក ជា ប៊ុននី លោក អ៊ឹង ប៊ុន គួង និង លោក តាន់ មៀន ។

ចំណែកឯការិយាល័យប្រចាំសហរដ្ឋអាមេរិក ស្ថិតនៅក្រោមការទទួលខុសត្រូវរបស់លោកវរសេនីយឯកកងទ័ពអាកាស សង្វារ ដឺឡូប៉េស[121]និង មានសមាជិកមួយចំនួនដូចជា៖ លោកស្រី ណាប ប៉ាវ៉ាមូន លោក សុខ សុវណ្ណគុណ លោក ភោគ សូផាត និង លោក ព្រុំ ហ៊ិន ជាដើម ។

ការិយាល័យប្រចាំទីក្រុងប៉ារីស ប្រទេសបារាំង បានត្រូវបង្កើតជាផ្លូវការ ដោយមានលោកតា លឹម គ្រី អតីតរដ្ឋមន្ត្រីក្រសួងយុត្តិធម៌សម័យសម្តេច សីហនុ ជាប្រធាន ។ សូមរំលឹកថា ការិយាល័យប្រចាំក្រុងប៉ារីសនេះ ត្រូវបានទទួលស្គាល់ ដោយគណៈកម្មាធិការប្រតិបត្តិ កូមុិច ជាផ្លូវការនៅខែ តុលា ១៩៨១ តែប៉ុណ្ណោះ ទោះបីជាការិយាល័យនេះ បានបើកទ្វារធ្វើការតាំងតែពីខែ តុលា ១៩៧៩ មកម្ល៉េះ ។ មេដឹកនាំ រ.ជ.រ.ប.ខ. មួយចំនួនដែលមានឥទ្ធិពលនៅក្នុងកូមុិច នៅទីក្រុងបាងកក មានការអល់អែកក្នុងការទទួលស្គាល់សមាសភាពការិយាល័យនេះ ព្រោះគេយល់ឃើញថាសមាសភាពនោះសុទ្ធតែជាមនុស្សជិតស្និទ្ធជាមួយលោកតា សឺន សាន ជាជាងមានកក្តីភាពចំពោះអង្គការ ឬ ស្ថាប័នដឹកនាំរបស់ រ.ជ.រ.ប.ខ. ដែលមានឈ្មោះថា កូមុិច ។

តាមការរៀបចំរចនាសម្ព័ន្ធរបស់ការិយាល័យផ្សាយព័ត៌មាន ប្រចាំនៅទីក្រុងប៉ារីសនេះ លោកតា លឹម គ្រី[122] ជាប្រធាន ដែលមានឧបការី និង ទីប្រឹក្សាមួយចំនួន ក្នុងនោះខ្លួនខ្ញុំជាឧបការីទទួលបន្ទុកកិច្ចការរដ្ឋបាល ។ សហសេវិកមួយចំនួនទៀត ដែលមានការទទួលខុសត្រូវផ្នែកផ្សេងៗគ្នានោះមាន៖ លោក នេត គួន

[121] Son Sann, Front National de Libération du Peuple Khmer, Décision no. 80/07/FNL, Territoire Khmer, le 31 Décembre 1980.
[122] Son Sann, Front National de Libération du Peuple Khmer, Décision no. 81/03/FNL, Territoire Khmer, le 12 Octobre 1981.

លោក សំ សុខ លោកស្រី លាង គឹមសេង និង លោក ចាយ សេរីវុធ ។ លោក សាយ បូរាណ មន្ត្រីតុលាការដ៏មានសមត្ថភាព ដែលគេរកបានដោយកម្រនៅកម្ពុជា ធ្លាប់ធ្វើជាអគ្គលេខាធិការនៃការិយាល័យនេះ បន្តជួយធ្វើការងារក្នុងឋានៈជាទីប្រឹក្សា ។

សម្តេច សីហនុ ត្រៀមចូលរួមជាថ្មីជាមួយខ្មែរក្រហម

គ្រាន់តែមួយខែបន្ទាប់ពីព្រះអង្គប្រកាសឈប់ធ្វើនយោបាយសម្តេច សីហនុ បានប្តូរព្រះទ័យព្រះអង្គជាថ្មីម្តងទៀតនៅខែ មិថុនា ១៩៨០ ដោយព្រះអង្គប្រកាសថា ព្រះអង្គត្រៀមព្រះកាយចូលរួមជាមួយពួកខ្មែរក្រហម ។ សម្តេចស្នើថា ព្រះអង្គនឹងបង្កើតរដ្ឋាភិបាលបណ្តោះអាសន្នបង្រួបបង្រួមគណបក្សជាច្រើន ជាមួយខ្មែរក្រហម ក្នុងនោះក៏មានអ្នកតំណាង រ.ជ.រ.ប.ខ.ដែរ ប្រសិនបើពួក រ.ជ.រ.ប.ខ. ចង់ចូលរួម ។ ជាមួយនោះ ក៏មានរួមទាំងអ្នកគាំទ្ររដ្ឋាភិបាល ហេង សំរិន នៅភ្នំពេញផង ប្រសិនបើមានអ្នកខ្លះចង់ចូលរួម ដោយសម្តេចដាក់លក្ខខណ្ឌឲ្យពួកខ្មែរក្រហម ក្លាយខ្លួនមកត្រឹមតែគណបក្សនយោបាយ មិនឲ្យនៅជារដ្ឋាភិបាលដែលមានកងទ័ពតទៅទៀតឡើយ ។ សំណើនេះមានតម្លៃស្មើការរំលាយកម្លាំងយោធារបស់ខ្មែរក្រហមដែរ ។ នៅក្នុងសេចក្តីសម្ភាសន៍ផ្តល់ដល់ទស្សនាវដ្តីប្រចាំសប្តាហ៍ញ៊ីវស្វីក (Newsweek) សម្តេចបានប្រកាសឲ្យដឹងជាថ្មីម្តងទៀតនូវសំណើរបស់ព្រះអង្គ ។

នោះក៏គាប់ជួនចំពេលដែលលោកនាយករដ្ឋមន្ត្រីចិន ហ្សាវ ហ្ស៊ីយ៉ាង (Zao Ziyang) ទៅធ្វើទស្សនកិច្ចនៅប្រទេសថៃ និង ជួបសន្ទនាអំពីបញ្ហាកម្ពុជាជាមួយលោកនាយករដ្ឋមន្ត្រីថៃ ប្រេម ទិនស៊ុឡានន្ត (Prem Tinsulanonda) ក្នុងខែ កុម្ភៈ ១៩៨១ ។ នៅពេលនោះ ប្រទេសថៃ និង ចិន កំពុងសម្លឹងរកមធ្យោ

បាយកោះប្រជុំសន្និសីទអន្តរជាតិមួយស្តីពីកម្ពុជា ដូចមានចែងក្នុងសេចក្តីសំរេចទាំងឡាយរបស់អង្គការសហប្រជាជាតិ ។ សូមបញ្ជាក់ថា នៅថ្ងៃទី ២២ តុលា ១៩៨០ មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័តសេចក្តីសំរេចថ្មីមួយទៀត ដែលមានខ្លឹមសារដូចសេចក្តីសំរេចចុះថ្ងៃទី ១៤ វិច្ឆិកា ១៩៧៩ នោះដែរ ។ នៅថ្ងៃទី ១ កុម្ភៈ ១៩៨១ លោកនាយករដ្ឋមន្ត្រីចិន ហ្សាវ ហ្ស៊ីយ៉ាង បានបញ្ជាក់ពីគោលជំហររបស់រដ្ឋាភិបាលចិន ពាក់ព័ន្ធនឹងការតស៊ូខ្មែរ បន្ទាប់ពីត្រូវបានក្រុមប្រទេសអាស៊ានគាបសង្កត់ ឲ្យចិនជួយជំរុញឲ្យមានការផ្លាស់ប្តូររដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម) ។ ចិនត្រៀមខ្លួនដើម្បីគាំទ្ររដ្ឋាភិបាលថ្មីដែលនឹងត្រូវដឹកនាំដោយលោកតា សឺន សាន ឬ សម្តេច សីហនុ ។

សេចក្តីបញ្ជាក់របស់លោកនាយករដ្ឋមន្ត្រីចិននេះ ជាសញ្ញាភ្លើងខៀវឲ្យមានការផ្លាស់ប្តូររដ្ឋាភិបាលខ្មែរក្រហមថ្មី ក៏ប៉ុន្តែការដែលចិនមិនបានបញ្ជាក់ឲ្យច្បាស់ថា រដ្ឋាភិបាលថ្មីនោះ ត្រូវស្ថិតនៅក្រោមការដឹកនាំរបស់វរជនខ្មែរណាមួយច្បាស់លាស់ទេគឺ សម្តេច សីហនុ ឬ លោកតា សឺន សាន ។ ភាពមិនច្បាស់លាស់នេះបានក្លាយទៅជាយុទ្ធវិធីដ៏ល្អមួយសំរាប់ពួកខ្មែរក្រហម យកទៅប្រើនៅពេលពួកគេធ្វើការចរចា ឬ តថ្លៃជាមួយសម្តេចសីហនុ និង ជាមួយលោកតា សឺន សាន ។ យុទ្ធវិធីនោះគឺ បើលោកតា សឺន សាន តឹងតែងពេក គេលួងលោមសម្តេច សីហនុ ឬ បើសម្តេចតឹងតែងពេក គេទៅយកចិត្តទុកដាក់ជាមួយលោកតា សឺន សាន ម្តងវិញ ។

ពួកខ្មែរក្រហមសំគាល់ឃើញថា លោកតា សឺន សាន ជាមនុស្សតឹងរ៉ឹងរឹងរូស ចំណែកឯសម្តេច សីហនុ មានជំហរទន់ភ្លន់ស្រួលធ្វើការជាមួយជាង នៅក្នុងរដ្ឋាភិបាលចម្រុះណាមួយនាពេលអនាគត ។ ដូច្នេះ ពួកខ្មែរក្រហមប្រើល្បិច ធ្វើឲ្យអ្នកដឹកនាំមិនមែនកុម្មុយនីស្តទាំងពីរូបប្រកួតប្រជែងគ្នា ។ ប្រសិនបើលោកតា

សឺន សាន នៅតែប្រកែកពុំព្រមចូលជាមួយពួកខ្មែរក្រហម ពួកនេះនឹងទៅចរចាជាមួយសម្តេច សីហនុ ដែលទ្រង់ត្រៀមចូលរួមជាមួយខ្មែរក្រហមរួចជាស្រេច ។ គោលការណ៍ត្រីភាគីនិយម បានក្លាយទៅជាយុទ្ធវិធីមួយនៃការរៀបចំរដ្ឋាភិបាលចម្រុះថ្មីនៃពួកខ្មែរក្រហម ។

មូលហេតុមិនចូលគ្នានៃក្រុម សឺន សាន និង សីហនុ

តាមការស្រាវជ្រាវ និង វិភាគក្រោយៗមក ទើបខ្ញុំអាចយល់ដឹងថា ហេតុអ្វីបានជាលោកតា សឺន សាន និង សម្តេច សីហនុ ដែលជាមេដឹកនាំខ្មែរមិនមែនកុម្មុយនីស្ត មិនអាចចូលរួមក្នុងចលសនាតស៊ូតែមួយបាន ។ តាមពិតទៅ បន្ទាប់ពីបានរំដោះព្រះអង្គចេញពីពួកខ្មែរក្រហម ប៉ុល ពត រួចមក នាដើមឆ្នាំ ១៩៧៩ នោះ សម្តេចឪ ឬ សម្តេចតានៃយើងព្រះអង្គមានបំណងដកព្រះកាយទៅគង់នៅ ស.រ.អា ឬ នៅប្រទេសបារាំងឯណោះទេ ។ ក៏ប៉ុន្តែដោយសារប្រទេសទាំងពីរនេះ មិនបានឆ្លើយតបតាមសំណើរបស់ព្រះអង្គ និង ដោយមានការទទូចពីមេដឹកនាំចិន តេង ស៊ាវពីង សម្តេច សីហនុ ក៏ព្រមយាងត្រឡប់ទៅគង់នៅប្រទេសចិនវិញនាដើមឆ្នាំ ១៩៧៩ ដូចខ្ញុំបានសរសេរខាងលើរួចហើយ ។

ចំណុចសំខាន់ដែលសម្តេច សីហនុ មិនទាន់ចូលរួមសកម្មភាពនយោបាយណាមួយនាពេលនោះ ព្រោះព្រះអង្គកំពុងព្រួយព្រះទ័យយ៉ាងខ្លាំងចំពោះការបាត់បង់កូនចៅជាទីស្រឡាញ់របស់ព្រះអង្គ ដែលមេដឹកនាំចិនសន្យាថានឹងខឹតខំរកឲ្យឃើញ ។ ម្យ៉ាងទៀត សម្តេចក៏ប្រហែលជារង់ចាំប្រតិកម្មរបស់វៀតណាម ក្នុងការស្វែងរកការចរចាគ្នាមួយ បន្ទាប់ពីព្រះអង្គផ្ញើលិខិតបីច្បាប់ទៅជូនលោកនាយករដ្ឋមន្ត្រី ផាំ វ៉ាន់ដុង នៃប្រទេសវៀតណាមក្នុងខែ តុលា ១៩៧៩ នោះ ។ ជាមួយគ្នានោះ ទំនងជាដើម្បីបើកផ្លូវឲ្យមានការចរចានេះ សម្តេច សីហនុ ក៏បានស្នើឲ្យទុក

អាសនៈកម្ពុជាឲ្យនៅទំនេរ ទាំងនៅអង្គការសហប្រជាជាតិ ទាំងនៅក្នុងចលនាមិនចូលបក្សសម័ន្ធ ដែលគ្រោងប្រជុំនៅទីក្រុងឡាហាវ៉ានៅប្រទេសគុយបា ។ តាមពិត គោលជំហរទុកកៅអីកម្ពុជាឲ្យនៅទំនេរ ជាគោលជំហរដែលរដ្ឋាភិបាលភ្នំពេញចង់បាន ដែលផ្ទុយពីគោលជំហររបស់ចិន អាស៊ាន ខ្មែរក្រហម និង ពួកយើងនៅក្នុងក្រុមលោកតា សឺន សាន ។ ជាមួយនិងគោលជំហរទុកកៅអីកម្ពុជាឲ្យនៅទំនេរ សម្តេច សីហនុ ក៏សុំឲ្យមានការដកអាវុធពីគ្រប់ក្រុមខ្មែរប្រដាប់អាវុធទាំងអស់ ជាពិសេសពីក្រុមខ្មែរក្រហម ហើយដើម្បីជាការដោះដូរជាមួយការដកកងទ័ពវៀតណាមទាំងអស់ចេញពីកម្ពុជា ព្រះអង្គសុំឲ្យមានកងកម្លាំងអន្តរជាតិរក្សាសន្តិភាព ឬ ជាអក្សរកាត់ហៅថា អាយ កឺ ខេ អេហ្វ (IPKF: International Peace Keeping Forces) មកប្រតិបត្តិការធ្វើជាប៉ូលីស និង ការពារប្រជាពលរដ្ឋខ្មែរនៅកម្ពុជាក្នុងរយៈពេលយ៉ាងតិច ៥ ឆ្នាំ ។ គោលជំហររបស់ព្រះអង្គនេះ ធ្វើឲ្យប្រទេសចិនមិនសប្បាយចិត្ត ហើយចិនក៏ចាប់ផ្តើមលើកសរសើរក្រុមលោកតា សឺន សាន ដែលព្រះអង្គរាប់បញ្ចូលក្នុងចង្កោមខ្មែរខៀវ ឬ ខ្មែរសេរីដោយរាប់ទាំងពួក លន់ នល់ ផង[123] ។

នៅសម័យនោះ ប្រទេសចិនមានគោលជំហរប្រឆាំងវៀតណាមយ៉ាងដាច់ខាត ពង្រឹងកងទ័ពខ្មែរក្រហមឲ្យរឹងមាំតាមការផ្តល់ជំនួយយោធា និង ប្រឆាំងរាល់ការប៉ុនប៉ងណាមួយក្នុងការដកអាវុធពួកនេះ ។ ចំណែកឯខាងការទូត ចិនត្រូវរកវិធីការពារកៅអីកម្ពុជាប្រជាធិបតេយ្យនៅអង្គការសហប្រជាជាតិ កុំឲ្យធ្លាក់ទៅរដ្ឋាភិបាលភ្នំពេញ ។ ដូច្នេះចិនត្រូវជួយរៀបចំមុខមាត់ថ្មីឲ្យរដ្ឋាភិបាលខ្មែរក្រហមមានលក្ខណៈសមរម្យស្អាតបាត ដែលអន្តរជាតិអាចទទួលយកបាន ដោយរកវិធីទាញយកមេដឹកនាំខ្មែរមិនមែនកុម្មុយនីស្តដូចជាលោកតា សឺន សាន ជាដើមឲ្យមកចូល

[123] Norodom Sihanouk, A Sad Deterioration of My Relationship with the People's Republic of China, the Cup to the Dregs, a handwritten manuscript published on www.norodomsihanouk.info p.6.

រួមជាមួយពួកខ្មែរក្រហម ។ នៅពេលដែលសម្តេច សីហនុ ធ្វើឲ្យចិនមិនសប្បាយចិត្ត ដោយសារគោលជំហររបស់ព្រះអង្គមិនជាប់ខាត ក្នុងការប្រឆាំងវៀតណាម ព្រមទាំងចង់ឲ្យមានការដកអាវុធពីពួកខ្មែរក្រហមផងនោះ ចិនដោយមានកិច្ចសហការពីប្រទេសអាស៊ាន ជាពិសេសថៃ និង សិង្ហបុរីផង ក៏លើកលោកតា សឺន សាន ឲ្យលេចឡោះឡើងថា ជាមេដឹកនាំខ្មែរមិនមែនកុម្មុយនីស្តតែមួយគត់ដែលគួរជាទីទុកចិត្ត និង ជាទីសង្ឃឹមរបស់ចលនាតស៊ូប្រឆាំងវៀតណាម ។ នៅពេលនោះ លោក តា សឺន សាន ក៏នឹកថា ចិន និង អាស៊ាន លែងត្រូវការសម្តេច សីហនុ ទៀតហើយ ។ក៏ដើរតួនាទីដឹកនាំផ្តាច់មុខតែម្នាក់ឯងតែម្តង ។ មិនតែប៉ុណ្ណោះកូនចៅលោកតាក៏ធ្វើយុទ្ធនាការវាយប្រហារសម្តេច តាមពាក្យសំដី ដែលធ្វើឲ្យព្រះអង្គខ្ទាល់ជាខ្លាំង ។

សម្តេចសរសេរក្នុងសៀវភៅរបស់អង្គថា៖ "ក្នុងឆ្នាំ ១៩៧៩-១៩៨០ លោក សឺន សាន វាយប្រហារខ្ញុំតាមពាក្យសំដី និង ចោទប្រកាន់នៅចំពោះមុខសារព័ត៌មានអន្តរជាតិ និង ជនភៀសខ្លួនខ្មែរថា ខ្ញុំសម្ងំនៅស្ងៀមឈរនៅមាត់ច្រាំងយករួចខ្លួន នៅពេលដែលនាវាកម្ពុជាកំពុងលិចលង់" ។ លោក សឺន សាន អះអាងថាខ្លួនគាត់ៗមិនញញើតនិងលោតចូលក្នុងទន្លេ ជាមួយអ្នកដើរតាមគាត់ដែលគាត់ហៅថាប្រជាពលរដ្ឋខ្មែរ ដើម្បីជួយយកអាសាកម្ពុជា[124] ។ នៅពេលដែលលោកតា សឺន សាន កំពុងបញ្ចេញមុខមាត់លើឆាកអន្តរជាតិជាមេដឹកនាំខ្មែរមិនមែនកុម្មុយនីស្តតែមួយគត់ ដែលបានទទួលការគាំទ្រពីប្រទេសចិន និង ក្រុមអាស៊ានឲ្យត្រៀមដឹកនាំរដ្ឋាភិបាលថ្មីរបស់កម្ពុជាប្រជាធិបតេយ្យ សម្តេច សីហនុ ក៏យល់ថាគេកំពុងផាត់ព្រះអង្គពីឆាកនយោបាយ ។ ព្រះអង្គក៏សំដែងមតិជាសាធារណៈថា បើយកលោក សឺន សាន មកឲ្យដើរតួសំខាន់ជំនួសព្រះអង្គ អ្នកដែលបានចំណេញគឺវៀតណាម

[124] Norodom Sihanouk, Following the Historical Inter-Cambodian Summit of Singapore, Sihanouk's Enemies Lay into Him Tooth and Nail, The Cup to the Dregs, op. cit, p.4.

ព្រោះថា ប្រសិនបើគេឲ្យប្រជាពលរដ្ឋខ្មែរជ្រើសរើសរវាង សឺន សាន និង របប ហេង សំរិន គេនឹងរើសយករបប ហេង សំរិន តែបើឲ្យជ្រើសរើសរវាង សីហនុ និង របប ហេង សំរិន គេនឹងរើសយក សីហនុ ដោយគ្មានបង្អែបង្អង់ឡើយ ។ សម្តេច ផ្សព្វផ្សាយថាតាមព័ត៌មាន ដែលព្រះអង្គបានទទួលតាមរយៈអ្នកការសែតលោកខាង លិច ប្រជារាស្ត្រខ្មែរភាគច្រើននៅក្នុងប្រទេសនៅតែមានភក្តីភាពចំពោះព្រះអង្គជា និច្ច ទោះជាមានការឃោសនាបន្តុះបង្អាប់ ឬ បន្ទាបបន្ថោកបំផ្លាញព្រះកិត្តិនាមព្រះ អង្គជាច្រើនឆ្នាំដោយពួកបច្ចាមិត្រយ៉ាងណាក៏ដោយ[125] ។

តាមពិត ប្រទេសចិនមិនបានបោះបង់សម្តេច សីហនុ ទេ គេគ្រាន់តែលើក ដំកើងលោកតា សឺន សាន មួយរយៈដើម្បីបង្កប្រតិកម្មឲ្យព្រះអង្គស្ទុះចូលមកសហ ការជាមួយខ្មែរក្រហមវិញតែប៉ុណ្ណោះ ។ នៅខែ វិច្ឆិកា ១៩៨០ នៅក្នុងជំនួបរវាង មេដឹកនាំចិន តេង ស៊ាវពីង ជាមួយលោកនាយករដ្ឋមន្ត្រី លី ខ្វាន់ យូ នៃប្រទេស សិង្ហបូរី មេដឹកនាំទាំងពីរបានពិភាក្សា និង ឯកភាពគ្នាលើគោលការណ៍នៃការ បង្កើតរដ្ឋាភិបាលថ្មីមួយនៃកម្ពុជាប្រជាធិបតេយ្យ ។ គោលការណ៍នោះមាន ៣ ចំណុចគឺ៖ ១. គ្រប់ការប្រឹងប្រែងទាំងឡាយត្រូវធ្វើឡើង ដើម្បីឲ្យមានសម័ន្ធភាព នៃកម្លាំងតស៊ូនានា ឆ្ពោះទៅបង្កើតរដ្ឋាភិបាលនៃរណសិរ្សរួបរួមមួយ ដឹកនាំដោយ សម្តេច សីហនុ ឬ លោក សឺន សាន ។ រដ្ឋាភិបាលនេះត្រូវតែរាប់បញ្ចូលទាំងកង កម្លាំងនៃគណបក្សកុម្មុយនីស្តផង (ពួក ប៉ុល ពត) ។ ការប្រើឈ្មោះកម្ពុជាប្រជា ធិបតេយ្យ ឬ មិនប្រើឈ្មោះកម្ពុជាប្រជាធិបតេយ្យ អាចលើកយកមកសិក្សាតទៅ ទៀត ។ អ្នកតំណាងកម្ពុជាប្រជាធិបតេយ្យចូលរួមក្នុងរដ្ឋាភិបាលចម្រុះត្រូវតែទទួល បាននូវការយល់ព្រមពីភាគីនានា ក៏ប៉ុន្តែបេក្ខជនត្រូវតែសម្រេចជ្រើសរើសឡើង

[125] Norodom Sihanouk, To Eliminate Me to Son Sann's Advantage Would Only Help the Viets..., Editorial - BMD November – December 1981, handwritten manuscript, published on www.norodomsihanouk.info. May 14, 2004.

ដោយភាគីកម្ពុជាប្រជាធិបតេយ្យខ្លួនឯង ។ គ្មាននរណាអាចបង្គាប់បញ្ជាភាគីនេះបានឡើយ- ២. អាស៊ាន ស.រ.អា និង ប្រទេសឯទៀតអាចប្រឹងប្រែងរួមគ្នាដើម្បីបង្កើតឲ្យមានកងទ័ពមិនមែនកុម្មុយនីស្តមួយនៅកម្ពុជា ។ ក៏ប៉ុន្តែលក្ខខណ្ឌជាមុននោះ តម្រូវឲ្យកងទ័ពនេះ ប្រកាន់គោលជំហរដាច់ខាតប្រឆាំងវៀតណាម និង របបហេង សំរិន ក្នុងការប្រយុទ្ធដើម្បីថែរក្សាឯករាជ្យជាតិ និង ដើម្បីរំដោះជាតិ ព្រមទាំងតម្រូវឲ្យកងទ័ពនេះ ជៀសវាងកុំសមគំនឹតជាមួយវៀតណាម និង របបអាយ៉ងហេង សំរិន ដើម្បីប្រឆាំងបក្សកុម្មុយនីស្តកម្ពុជា (ខ្មែរក្រហម) ។ កងទ័ពមិនមែនកុម្មុយនីស្តនេះ អាចស្ថិតនៅក្រោមបញ្ជាសម្តេច សីហនុ ឬ លោក សឺន សាន ។ គ្រប់បញ្ហារាប់ទាំងបញ្ហាបុគ្គលិក ឬ យុទ្ធជនផង កងទ័ពនេះត្រូវដោះស្រាយដោយខ្លួនឯង ។ យ៉ាងណាក៏ដោយមិនត្រូវធ្វើអ្វីទាំងអស់ដែលធ្វើឲ្យទន់ខ្សោយដល់កម្លាំងតស៊ូទាំងអស់ដែលកំពុងកើតមាននៅពេលបច្ចុប្បន្ន- ៣. ប្រទេសចិនបានប្រកាសយ៉ាងច្បាស់លាស់រួចថា បន្ទាប់ពីកងទ័ពវៀតណាមដកចេញពី កម្ពុជាអស់ហើយ ទាំងប្រព័ន្ធនយោបាយ ទាំងឈ្មោះប្រទេស ទាំងថ្នាក់ដឹកនាំនៃកម្ពុជា នឹងត្រូវសម្រេចដោយប្រជាជនកម្ពុជាខ្លួនឯង តាមរយៈការបោះឆ្នោតមួយ ដោយសេរី និងតាមបែបប្រជាធិបតេយ្យក្រោមការត្រួតពិនិត្យរបស់អន្តរជាតិ ។ ប្រទេសចិនគ្មានបំណងបង្កើតរដ្ឋជារណបរបស់ខ្លួនណាមួយ នៅទីណាមួយក្នុងពិភពលោកនោះឡើយ ។ គោលការណ៍បីចំណុចនេះ បញ្ជាក់យ៉ាងច្បាស់ថា ចិន និង សិង្ហបុរីបានព្រមព្រៀងគ្នារួចហើយ ដើម្បីរៀបចំរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យថ្មីដឹកនាំដោយឥស្សរជនមិនមែនកុម្មុយនីស្ត ក្នុងលក្ខខណ្ឌដែលមិនឲ្យខូចខាតទាល់តែសោះដល់កម្លាំងខ្មែរក្រហម ទាំងកម្លាំងនយោបាយ ទាំងកម្លាំងទ័ព ។ ភាគីទាំងពីរបានទុកលទ្ធភាពឲ្យអាស៊ាន ស.រ.អា និង ប្រទេសលោកខាងលិចជួយបង្កើតកងទ័ពខ្មែរមួយទៀត ដែលជាកងទ័ពមិនមែនកុម្មុយនីស្ត ក៏ប៉ុន្តែកងទ័ពនេះ មិនត្រូវ

ប្រឆាំងកងកម្លាំងរបស់ខ្មែរក្រហមជាដាច់ខាត ។ ជាការច្បាស់ណាស់ គោលនយោបាយចិន មិនត្រឹមតែការពារខ្មែរក្រហមកុំឲ្យរលំរលាយប៉ុណ្ណោះទេ តែថែមទាំងនាំមេដឹកនាំខ្មែរមិនមែនកុម្មុយនីស្ត មកជួយពង្រឹងខ្មែរក្រហមទៀតផង ។ ចំណុចជាយុទ្ធវិធីនោះគឺ គេមិនបានកំណត់ឲ្យច្បាស់ថាតើតួអង្គមួយណា សម្តេច សីហនុ ឬ លោកតា សឺន សាន ដែលត្រូវដឹកនាំរដ្ឋាភិបាលថ្មី និង បញ្ជាកងទ័ពមិនមែនកុម្មុយនីស្ត? យុទ្ធវិធីនេះធ្វើឲ្យមេដឹកនាំទាំងពីររូបប្រណាំងប្រជែងគ្នា ដើម្បីដណ្តើមតួនាទីដឹកនាំ ព្រោះថាមេដឹកនាំណា ដែលមានភាពទន់ភ្លន់ជាងគេ មេដឹកនាំនោះនឹងមានឧត្តមភាព ។ លើសពីនេះទៅទៀត ថ្នាក់ដឹកនាំចិននៅតែព្យាយាមអូសទាញសម្តេច សីហនុ ឲ្យយាងចូលមកសហការជាមួយខ្មែរក្រហមវិញ ទោះបីជាជួនកាល ពួកគេមិនពេញចិត្តចំពោះគោលជំហរនយោបាយខ្លះៗរបស់ព្រះអង្គយ៉ាងណាក៏ដោយ ។

សម្តេច សីហនុ បានពន្យល់អំពីមូលហេតុ ដែលនាំព្រះអង្គឲ្យសុខចិត្តរួមមកសហការជាមួយខ្មែរក្រហមនោះថា មួយគឺដើម្បីបានជំនួយមកជួយកងទ័ពសីហនុនិយម និង មួយទៀតគឺ ព្រះអង្គមិនអាចបោះបង់ចោលមហាមិត្តចិនដែលបានជួយគាំទ្រព្រះអង្គយ៉ាងខ្លាំងក្លាក្នុងឆ្នាំ ១៩៧០-១៩៧៥ ក្នុងសង្គ្រាមប្រឆាំងពួក លន់ នល់ ។ ព្រះអង្គបានរំលឹកថា ស្ត្រីកំពូលចិន ដែលព្រះអង្គគោរពយ៉ាងខ្លាំងគឺ លោកជំទាវកិរិយាសពនាយករដ្ឋមន្ត្រី ជូ អេនឡាយ តែងទូលព្រះអង្គឲ្យបំភ្លេចទុក្ខសោករបស់ព្រះអង្គ ដែលកើតឡើងដោយសារការបាត់បង់កូនចៅជាទីស្រឡាញ់របស់ព្រះអង្គ ដើម្បីអាចប្រមូលហាមពលមកធ្វើការរំដោះប្រទេសជាតិ ព្រោះព្រះអង្គ ប្រាកដជាទ្រង់ជ្រាបថាតើឧត្តមប្រយោជន៍របស់ប្រទេសជាតិនៅទីណា[126]។ ចិនក៏ប្រាកដជាបានទូលសម្តេចឲ្យទ្រង់ជ្រាបអំពីខ្លឹមសារនៃជំនួប តែង

[126] Norodom Sihanouk, The Leading Role of People's Republic of China and Asean in the Process of Building Up Democratic Kampuchea's CGDK, The Cup to the Dregs, op. cit, p.12.

ស៊ាវពីង - លី ខ្វាន់ យូ ជាពិសេសចំណុចទាំង៣នៃគោលការណ៍ខាងលើ ។ ដូច្នេះនៅពេលសម្តេច សីហនុ សម្រេចព្រះទ័យយាងចូលមកសហការជាមួយខ្មែរក្រហមវិញ ព្រះអង្គយល់ច្បាស់ណាស់នូវអ្វីដែលព្រអង្គអាចធ្វើបាន ។

លោកតាមិនអាចបង្រួបបង្រួមអ្នកជាតិនិយម

អស់រយៈពេលជាយូរមកហើយ ដែលថ្នាក់ដឹកនាំ រ.ជ.រ.ប.ខ. បានយល់ដឹងអំពីផលវិបាកនៃគោលការណ៍ត្រីភាគីនិយមនេះ ហើយបានព្យាយាមជៀសវាងគេចចេញ ។ មេដឹកនាំ រ.ជ.រ.ប.ខ. បានព្យាយាមបង្រួបបង្រួមយុទ្ធជនអ្នកជាតិនិយមមិនមែនកុម្មុយនីស្តឲ្យរួបរួមគ្នាប្រយុទ្ធក្រោមទង់តែមួយរបស់រ.ជ.រ.ប.ខ.។ មែនទែនទៅ ស្ទើរតែទាំងអស់នៃចលនាប្រដាប់អាវុធនៅលើសមរភូមិ បានមកសំដែងកក្តីភាពចំពោះ រ.ជ.រ.ប.ខ. និង បានចូលរួមក្នុងសមាជជាតិរ.ជ.រ.ប.ខ. ដែលប្រព្រឹត្តិទៅក្រោមអធិបតីភាពលោកតា សឺន សាន ក្នុងទឹកដីខ្មែរពីថ្ងៃទី ២៤-២៥ មេសា ១៩៨០ រួចទៅហើយ ។ ក៏ប៉ុន្តែ នៅមានចលនាមួយចំនួន នៅរក្សាឯករាជភាពរបស់ខ្លួន ឬ សំដែងភាពទោរទន់ទៅរកសម្តេច សីហនុ ។ ចលនាទាំងនោះមានចលនាមូលីណាកាដឹកនាំដោយ លោក គង់ ស៊ីលាស់ ក្រោយមកបន្ទាប់ពីលោក គង់ ស៊ីលាស់ ចូលមរណភាពយ៉ាងចម្លែកនាខែ សីហា ១៩៨០ បានត្រូវដឹកនាំដោយលោក ញ៉ែម សុផុន និង ចលនាឈ្មោះរណសិរ្សខ្មែរអង្គររបស់លោក អ៊ិន សាខន ។

នៅខែ មករា ១៩៨១ លោកតា សឺន សាន បានមកជួបជាមួយលោក ញ៉ែម សាផុន ចំនួនពីរដងនៅក្នុងជំរុំនងចាន់ ដោយសង្ឃឹមថាអ្នកដឹកនាំមូលីណាកានឹងចូលរួមជាមួយរ.ជ.រ.ប.ខ. ។ ក៏ប៉ុន្តែ នៅទីបំផុត ការខំប្រឹងប្រែងរបស់លោកតាប្រធានរ.ជ.រ.ប.ខ.ក៏ក្លាយជាអាសាឥតការ ព្រោះលោក ញ៉ែម សុផុន បាន

នាំចលនារបស់គាត់ទៅចូលជាមួយសម្តេច សីហនុ ។ មូលីណាកាក៏បានក្លាយជាឆ្នើងខ្នងដ៏រឹងមាំនៃកងទ័ពសីហនុនិយម ។ ដោយមានការគាំទ្រផ្នែកយោធានេះ សម្តេច សីហនុ ក៏បានបង្កើតចលនាផ្ទាល់របស់ព្រះអង្គ ដែលមានឈ្មោះថា ហ៊ុន សុិន ប៊ិច (FUNCINPEC) (រណសិរ្សរួបរួមជាតិដើម្បីកម្ពុជា ឯករាជ្យ អព្យាក្រឹត្យ សន្តិ និង សហប្រតិបត្តិការ) ជាអក្សរកាត់ចេញពីភាសាបារាំង ។ ហ៊ុន សុិន ប៊ិច បានត្រូវប្រកាសបង្កើតនៅទីក្រុងព្យុងយ៉ាងកូរ៉េខាងជើង ក្នុងខែ មីនា ១៩៨១ ។ ចូលរួមក្នុងរណសិរ្សនេះមានចលនា ៣ គឺ៖ មូលីណាកា ឧត្តរទិស និង ឃ្លាំងមឿង[127] ។ គួរចាប់អារម្មណ៍ថាចលនាឃ្លាំងមឿងមានទាំងនៅក្នុង ហ៊ុន សុិន ប៊ិច មានទាំងនៅក្នុង រ.ជ.រ.ប.ខ. ។ ម្យ៉ាងទៀត អ្នកតស៊ូចាស់ៗដូចជា៖ តាមុាំង តាលួត លោក ទួន ចាយ លោក ជា ឈុត ជាដើម សុទ្ធតែជាយុទ្ធមិត្តស្លាប់រស់ជាមួយគ្នា ទោះបីជាពួកគេស្ថិតនៅក្នុងរណសិរ្សទីទៃៗពីគ្នាក៏ដោយ ។ ហេតុដូច្នេះហើយ ទើបលោកឧត្តមសេនីយ ជៀន ដែល បានផ្តាំផ្ញើឲ្យលោកតា សឺន សាន ពិនិត្យឲ្យបានហ្មត់ចត់ថា តើអ្នកណាខ្លះដែលស្មោះស្ម័គ្រច្បាស់លាស់ជាមួយ រ.ជ.រ.ប.ខ. មុននឹងផ្តល់អាវុធឲ្យនៅពេលដែលលោកឧត្តមសេនីយរូបនេះ បង្ខំចិត្តលាតំណែងជានាយអគ្គសេនាធិការ ក.ជ.រ.ប.ខ. បន្ទាប់ពីមានឃាតកម្មលើតាលួតនៅថ្ងៃទី ១១ ខែ តុលា ១៩៨២ ។

គួរកត់សំគាល់ថា ការខំប្រឹងប្រែងបង្រួបបង្រួមប្រមែប្រមូលយុទ្ធជនអ្នកជាតិនិយមមិនមែនកុម្មុយនីស្តរបស់មេដឹកនាំរ.ជ.រ.ប.ខ. ហាក់ដូចជាបានទទួលការលើកទឹកចិត្តពីបណ្តាប្រទេសអាស៊ាន ។ នៅពេលមកដល់ទីក្រុងបាងកក នៅថ្ងៃទី ១ មករា ១៩៨១ លោក រ៉ាឆារ៉ាតណាម (Rajaratnam) ឧបនាយករដ្ឋមន្ត្រីនៃប្រទេសសិង្ហបូរី បានប្រកាសជាសាធារណៈថារដ្ឋាភិបាលសិង្ហបូរីអបអរសាទរគំនិត

[127] Norodom Sihanouk, The Birth of Funcinpec-The First Summit of the Three Khmer Anti-Vietnamese Colonialist Leaders and the "Dragon Lady", the Cup to the Dregs, op. cit, p.9

ដែលឲ្យលោកតា សឺន សាន ជាអ្នកដឹកនាំចលនាតស៊ូប្រឆាំងនឹងការកាន់កាប់ប្រទេសកម្ពុជាដោយកងកម្លាំងបរទេស ។ ជាមួយគ្នានេះដែរ លោក កាឡូស្សរ៉ូមុឡូស (Calos Romulos) រដ្ឋមន្ត្រីក្រសួងការបរទេសហ្វីលីពីន ក៏បានបញ្ជាក់ជូនលោក រដ្ឋមន្ត្រីក្រសួងការបរទេសជប៉ុន អ៊ីតូ (Ito) ថាក្រុមប្រទេសអាស៊ាន អាចនឹងទទួលស្គាល់លោកតា សឺន សាន ។ តាមពិតទៅ ដូចមានចែងរួចហើយខាងលើថា ចិន និង អាស៊ាន តាមរយៈជំនួប តេង ស៊ាវពីង-លី ខ្វាន់ យូ កាលពីខែ វិច្ឆិកា ១៩៨០ កន្លងទៅ បានព្រមព្រៀងគ្នាឲ្យសម្តេច សីហនុ ឬ លោកតា សឺន សាន ជាអ្នកដឹកនាំរដ្ឋាភិបាលថ្មីនៃកម្ពុជាប្រជាធិបតេយ្យ មិនមែនឲ្យលោកតា សឺន សាន តែម្នាក់ឯង ដោយបំភ្លេចចោលសម្តេច សីហនុ នោះទេ ។

ដោយសារការអះអាងមិនអស់សេចក្តីរបស់លោកឧបនាយករដ្ឋមន្ត្រី ប៉ាធា ប៉ាតណាម នៃប្រទេសសិង្ហបូរី និង លោក កាឡូស្សរ៉ូមុឡូស រដ្ឋមន្ត្រីក្រសួងការបរទេសហ្វីលីពីននេះហើយ ដែលធ្វើឲ្យលោកតា សឺន សាន យល់ច្រឡំនឹកស្មានថា សម្តេច សីហនុ បាត់ការគាំទ្រពីចិន និង អាស៊ាន អស់ទៅហើយ ។ ដូច្នេះលោកតា ក៏ចេះតែបន្តដើរតួឯកតែម្នាក់ឯង លើឆាកអន្តរជាតិ ដែលធ្វើឲ្យសម្តេច សីហនុ រឹតតែអាក់អន់ព្រះទ័យថែមទៀតចំពោះ រ.ជ.រ.ប.ខ. និង អ្នកដឹកនាំនៃចលនាតស៊ូនេះ ។

លោកតាថ្លែងថា ដើម្បីបត់ស្តាំ ត្រូវសៀរឆ្វេងបន្តិច

នៅខែ មេសា និង ឧសភា ១៩៨១ លោកតា សឺន សាន ធ្វើដំណើរទៅសហរដ្ឋអាមេរិក បន្ទាប់មកលោកតាធ្វើដំណើរទៅពិគ្រោះយោបល់ជាមួយសហគមន៍ខ្មែរអ្នកគាំទ្រ រ.ជ.រ.ប.ខ. លើបញ្ហាចូលរួមក្នុងរដ្ឋាភិបាលចម្រុះ ដើម្បីការពារអា

សនៈកម្ពុជានៅអង្គការសហប្រជាជាតិ ។ នៅក្នុងសន្និបាតមួយរបស់ រ.ជ.រ.ប.ខ. ក្នុងក្រុងអាលីងតុន (Arlington) សហរដ្ឋអាមេរិក លោកតាប្រធានថ្លែងថា៖ "ប្រជារាស្ត្រខ្មែរមានការភ័យខ្លាចខ្មែរក្រហម ។ នៅពេលដែលគេដឹងថាសម្តេច សីហនុ សំរេចថាចូលរួមជាមួយខ្មែរក្រហម ពួកគេមានក្តីបារម្ភចំពោះសេចក្តីសំរេច របស់សម្តេចណាស់ ដូច្នេះមានប្រជារាស្ត្រមួយចំនួន ក៏នាំគ្នាទៅគាំទ្រកងទ័ពវៀតណាមទៅវិញ[128]។ ចំណែកពួកខ្មែរក្រហម គេមិនត្រូវអនុញ្ញាតឲ្យពួកនេះវិលត្រឡប់មកកាន់អំណាចវិញឡើយ" ។ បន្ថែមលើនេះ លោកតាប្រធានបានបង្ហើបជាសាធារណៈលើកដំបូងឲ្យដឹងថាមានប្រទេសមួយចំនួន បានឲ្យរ.ជ.រ.ប.ខ.ចាត់វិធានការដើម្បីទៅដណ្តើមយកអាសនៈកម្ពុជានៅអង្គការសហប្រជាជាតិ ។ លោកតា សឺន សាន បានជំរាបអង្គសន្និបាតថាមានរដ្ឋាភិបាលនៃប្រទេសជាមិត្តមួយចំនួនបានស្នើឲ្យរ.ជ.រ.ប.ខ.បង្កើតរដ្ឋាភិបាលថ្មី ដោយមានការចូលរួមខ្លះពីពួកខ្មែរក្រហមគឺ រដ្ឋាភិបាលថ្មីដែលមានលោកតា សឺន សាន ជាប្រមុខ ។ លោកតាបានថ្លែងថាឆ្លើយទៅសំណើរបស់ខ្មែរក្រហម ដែលស្នើឲ្យលោកតាចូលរួមក្នុងរដ្ឋាភិបាលខ្មែរក្រហមថ្មីនោះ លោកតាទាមទារឲ្យខ្មែរក្រហមប្រគល់ក្រសួងទាំងអស់ឲ្យមកលោកតា បើមិនដូច្នេះទេ សូមឲ្យពួកខ្មែរក្រហមយកក្រសួងទាំងអស់នោះសំរាប់ខ្មែរក្រហមខ្លួនឯងចុះ ។ លោកតាបានជំរាបអង្គសន្និបាតថា គាត់ធ្វើដំណើរមកដល់ផ្លូវបត់ហើយ ។ លោកតានឹងធ្វើការបត់បែនគឺ ផ្លាស់ប្តូរពីមិនចូលរួមជាមួយខ្មែរក្រហម មកត្រឹមចូលរួមដោយមានលក្ខខណ្ឌជាមួយខ្មែរក្រហមវិញ ។ ក៏ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ លោកតាជានាថា រ.ជ.រ.ប.ខ. នឹងមិនបត់ធ្វេងជាដាច់ខាតគឺ រ.ជ.រ.ប.ខ.នឹងបត់ទៅស្តាំយ៉ាងពិតប្រាកដ ។ លោកតាប្រធានមានប្រសាសន៍ថា "ដើម្បីបត់ស្តាំឲ្យបាន

[128] សឺន សាន, ប្រសាសន៍ថ្លែងក្នុងឱកាសមហាសន្និបាតនៃប្រជាពលរដ្ឋនៅសហរដ្ឋអាមេរិក, រ ជ រ ប ខ ខែកក្កដា ១៩៨១ ទំព័រ ៣-៩ ។

ស្រួល កុំឲ្យក្រឡាប់ ត្រូវតែបត់ស្តាំដោយសៀវឆ្វេងបន្តិច" ។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ គោលបំណងរបស់លោកតាគឺធ្វើយ៉ាងណាដើម្បីពង្រឹងរ.ជ.រ.ប.ខ.។ ការបង្កើតរដ្ឋាភិបាលចម្រុះជាមួយខ្មែរក្រហម គ្រាន់តែជាវិធីដើម្បីរក្សាកៅអីរបស់កម្ពុជានៅអង្គការសហប្រជាជាតិ និង ដើម្បីពង្រឹងកម្លាំងរបស់ រ.ជ.រ.ប.ខ. តែប៉ុណ្ណោះ ។

ចូលទ្រុងខ្លា លោកតាសុំដំបងមួយ

បន្ទាប់ពីទស្សនកិច្ចនៅសហរដ្ឋអាមេរិក លោកតា សឺន សាន បានវិលត្រឡប់ទៅប្រទេសបារាំងវិញ ។ បន្ថែមលើទស្សនកិច្ច នៅប្រទេសអាឡឺម៉ង់នាខែឧសភា លោកតាប្រធានបានធ្វើទស្សនកិច្ចនៅប្រទេស ហុល្លង់នៅថ្ងៃទី ១៦ មិថុនា ដែលនៅទីនោះ លោកតាបានជួបជាមួយលោកប្រធាននាយកដ្ឋានកិច្ចការអាស៊ី និង អូសេអានីនៃក្រសួងការបរទេស ។ លោកតា សឺន សានបានជំរាបគូសន្ទនានូវលក្ខខណ្ឌរបស់លោកតាក្នុងការចូលរួមដឹកនាំរដ្ឋាភិបាល "កម្ពុជាប្រជាធិបតេយ្យ" ថ្មីមួយដើម្បីការពារកៅអីកម្ពុជាប្រជាធិបតេយ្យនេះ នៅអង្គការសហប្រជាជាតិ[129] ។ លក្ខខណ្ឌនោះមានជាអាទិ៍ -ក្រសួងចំនួនភាគច្រើនជាច់ខាតត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវនៃក្រុមអ្នកជាតិនិយម (គឺពួកអ្នកមិនមែនកុម្មុយនីស្ត)-មេដឹកនាំដ៏ល្បីឈ្មោះរបស់ខ្មែរក្រហម មិនត្រូវអនុញ្ញាតឲ្យចូលក្នុងរដ្ឋាភិបាលចម្រុះនេះឡើយ (ឧទាហរណ៍៖ ប៉ុល ពត នួន ជា តាម៉ុក អៀង សារី ជាដើម) -ចំណុចចុងក្រោយ - រ.ជ.រ.ប.ខ.ត្រូវតែមានកម្លាំងមាំទាំគ្រប់គ្រាន់ ។ ចំពោះចំណុចចុងក្រោយនេះ លោកតាប្រធានរ.ជ.រ.ប.ខ.បានសុំថា៖ ឲ្យផ្តល់ជំនួយមនុស្សធម៌ជា

[129] ទស្សនកិច្ចរបស់លោក សឺន សាន ប្រធាន រ.ជ.រ.ប.ខ. នៅប្រទេសប៉េអ៊ីបា កាលពីថ្ងៃទី១៦ មិថុនា ១៩៨១, ព្រឹត្តិបត្រ រ. ជ. រ. ប. ខ. ខែ កក្កដា ១៩៨១ ទំព័រ ១៨-១៩ ។

បន្ទាន់ដល់ប្រជារាស្ត្រស៊ីវិលចំនួន ១០០០០០ នាក់ ផ្តល់ជំនួយផ្នែកការទូត និងនយោបាយ ដើម្បីឲ្យរ.ជ.រ.ប.ខ.រឹតតែមានសកម្មភាពខ្លាំងក្លាឡើង ព្រមទាំងសុំជំនួយហិរញ្ញវត្ថុឲ្យបានគ្រប់គ្រាន់ ដើម្បីឲ្យរ.ជ.រ.ប.ខអាចបំពេញការងារដោយជោគជ័យ ។ ចំពោះលក្ខខណ្ឌទាំងនេះ លោកតា សឺន សាន មានប្រសាសន៍ថា៖ "បើអស់លោកឲ្យខ្ញុំចូលក្នុងទ្រុងខ្លា សូមប្រគល់ដំបងមកឲ្យខ្ញុំផង" ។ ជាការពិតណាស់ព្រោះថាបើគ្មានដំបងទេ លោកតានឹងត្រូវ "ខ្លា" ខ្មែរក្រហម "ឆី" ជាចំណីមិនខានឡើយ ។

លោកតាប្រកាសថា ខ្ញុំស្ម័គ្រចិត្តចេញទៅតស៊ូ

នៅក្នុងការស្នាក់នៅទ្វីបអឺរ៉ុប លោកតា សឺន សាន បានសម្លឹងរកអ្នកមានសមត្ថភាព ដើម្បីរើសយកទៅធ្វើការជាសហការីផ្ទាល់របស់លោកតា ក្នុងវិស័យសំខាន់ៗដូចជា៖ ការទូត ហិរញ្ញវត្ថុ និង យោធា ដើម្បីត្រៀមខ្លួនជួយធ្វើការនៅពេល ដែលលោកតាអាចនឹងទទួលតំណែងជាន់ខ្ពស់ក្នុងរដ្ឋាភិបាលថ្មី ដែលនឹងត្រូវបង្កើតឡើង នាពេលខាងមុខ ។ ថ្មីៗមុននេះ លោកតាប្រធានទើបតែបានទទួលការគាំទ្រ ដ៏វិសេសពីសម្តេច ប៉ែន នុត ដែលជាកល្យាណមិត្តដ៏ច្បាស់លាស់ជាយូរមកហើយរបស់លោកតា ។ សម្តេច ប៉ែន នុត បានបញ្ជូនកូនប្រុសទាំងបួនរូបរបស់សម្តេចឲ្យមកបំរើ រ.ជ.រ.ប.ខ. ។ បុត្ររបស់សម្តេច ប៉ែន នុត ទាំងបួននាក់នោះគឺ៖ លោក ប៉ែន ថុល លោក ប៉ែន ថាល់ លោក ប៉ែន ញ៉ាច និង លោក ប៉ែន ធុឡា ។ បុត្រទាំងបួននាក់នោះ បានទៅរស់នៅផ្សេងៗពីគ្នាបន្ទាប់ពីបានរួចចេញពីរបប ប៉ុល ពត មក ដោយលោក ប៉ែន ថុល នៅប្រទេសជប៉ុន លោក ប៉ែន ញ៉ាច និង លោក ប៉ែន ធុឡា ទៅនៅប្រទេសកាណាដា ឯលោក ប៉ែន ថាល់ នៅប្រទេសបារាំង ។ លោក ប៉ែន ថាល់ ដែលប្រហែលជាកូនសំណព្វចិត្តរបស់សម្តេច ប៉ែន នុត បាន

ស្ម័គ្រចិត្តចូលបំរើ រ.ជ.រ.ប.ខ. នៅសមរភូមិមុខនាពេលខាងមុខ ។ ចាប់ពីបានស្ម័គ្រចិត្តមក គាត់ចាប់ផ្តើមបង្ហាញមុខបណ្តើរៗនៅពេលមានអង្គប្រជុំខ្លះរបស់ រ.ជ.រ.ប.ខ. នៅទីក្រុងប៉ារីស មុននឹងចេញដំណើរជាស្តាពរទៅសមរភូមិមុខ ។

ក្នុងចំណោមសហសេវិករបស់ខ្ញុំទាំងឡាយ នៅប្រទេសបារាំង លោកតា សឺន សាន បានសម្លឹងយកលោក សាយ បូរាណ ជាជំនួយការរបស់លោកតា ។ លោក សាយ បូរាណ កាលនោះអាយុប្រហែលជា ៤០ ឆ្នាំ នៅលីវ មានចំណេះចេះដឹងជ្រៅជ្រះ និង ជាមនុស្សមានការអត់ធ្មត់ក្នុងការងារ ។ លោក សាយ បូរាណ ធ្លាប់ធ្វើការទាំងយប់អធ្រាត ដើម្បីបោះពុម្ពផ្សាយព្រឹត្តិប័ត្រ រ.ជ.រ.ប.ខ. ។ ជួនកាលគាត់មិនទាំងវិលទៅផ្ទះវិញផង នៅពេលជាប់ដៃក្នុងការងារ ។ គាត់សម្រាកក្នុងការិយាល័យរ.ជ.រ.ប.ខ. នៅប៉ារីសតែម្តង ។ នៅពេលដែលលោកតាប្រធានជ្រើសរើសរូបគាត់ឲ្យទៅបំរើការងារឯសមរភូមិមុខនោះ លោក សាយ បូរាណ មិនបានប្រកែក ឬ ឆ្លើយតបឲ្យច្បាស់លាស់ថា ពេលណាគាត់អាចឈប់ធ្វើការនៅឯប្រទេសបារាំង និង ទៅធ្វើការផ្ទាល់ជាមួយលោកតានោះទេ ។ តាមពិតលោក សាយ បូរាណ ជាមនុស្ស ដែលខ្ញុំមានការជិតស្និទ្ធជាងគេនៅទីក្រុងប៉ារីសនេះ ព្រោះស្ទើរតែរាល់ល្ងាចនៅពេលយើងបញ្ចប់ការងារក្រៅម៉ោងធ្វើការ នៅឯការិយាល័យរ.ជ.រ.ប.ខ.រួចហើយ យើងតែងនាំគ្នាទៅទទួលទានអាហាររួមគ្នា ជួនកាលនៅភោជនីយដ្ឋានរបស់លោក សុខ វ៉ាន់ធី ឬ ភោជនីយដ្ឋានចិនផ្សេងៗទៀត មិនសូវខានឡើយ ។ លោក សាយ បូរាណ បានដឹងច្បាស់ណាស់នូវមនោសញ្ចេតនាអ្នកជាតិនិយមរបស់ខ្ញុំ ។ ប្រហែលជាលោក សាយ បូរាណ ជំរាបរឿងខ្ញុំដល់លោកតា សឺន សាន ថាខ្ញុំស្ម័គ្រចិត្តបោះបង់ចោលការងារខ្ញុំឯស្រុកបារាំង ដើម្បីទៅបំរើ រ.ជ.រ.ប.ខ.ឯសមរភូមិមុខ បានជានៅក្នុងអង្គប្រជុំមួយនៃសមាជិក រ.ជ.រ.ប.ខ. លោកតា សឺន សាន បានប្រកាសជាសាធារណៈថា រូបខ្ញុំបានស្ម័គ្រចិត្តទៅធ្វើការជាមួយលោកតានៅឯសមរ

ភូមិមុខ ដែលធ្វើឲ្យខ្ញុំស្រឡាំងកាំង ព្រោះខ្ញុំមិនដែលនិយាយរឿងនេះផ្ទាល់ជាមួយលោកតាប្រធានម្តងណាឡើយ ។ ម្យ៉ាងទៀត ខ្ញុំក៏មិនដែលបាននិយាយអំពីបំណងរបស់ខ្ញុំ ក្នុងការវិលទៅមាតុប្រទេសវិញជាមួយកូនប្រសារលោកតាប្រធាន លោក បណ្ឌិត ឆាយ ហាន់ចេង ជាមុនផងទេ ។

ដោយសារលោកតាប្រកាសជាសាធារណៈ នៅចំពោះមុខសមាជិក រ.ជ.រ.ប.ខ. រាប់រយនាក់យ៉ាងនេះ ខ្ញុំក៏គ្មានសំដែងអ្វីក្រៅពីការយល់ព្រមដោយតុណ្ហីភាពតែប៉ុណ្ណោះ ។ មែនទែនទៅ ការចេញដំណើរទៅកាន់សមរភូមិមុខធ្វើជាយុទ្ធជនដើម្បីសេរីភាព ជាបំណងដែលខ្ញុំប៉ងប្រាថ្នាយូរមកហើយ ។ តាំងពីពេលនោះមក ការស្រមៃចង់វិលត្រឡប់មកកាន់មាតុភូមិខ្មែរវិញរបស់ខ្ញុំ ក៏ចាប់ផ្តើមលេចចេញជារូបរាងឡើងបន្តិចម្តងៗ ។ តាមគំរោង ខ្ញុំនឹងត្រូវចេញដំណើរពីទីក្រុងប៉ារីសទៅក្រុងបាងកក ដោយរួមដំណើរជាមួយលោក ប៉ែន ថាល់ ។ ក៏ប៉ុន្តែ ពួកយើងមិនទាន់ត្រូវចេញដំណើរភ្លាមទេ ពួកយើងត្រូវចេញទៅតាមខេត្ត ជួបប្រជុំជាមួយសមាជិកអ្នកគាំទ្ររបស់យើងក្នុងប្រទេសបារាំង ដើម្បីលាគ្នាអស់ជាច្រើនខែទៀតសិន ។

ក្រុមកូមុិច បង្កើតបញ្ហាចំរូងចំរាស់ថ្មី

នៅចន្លោះពេលនេះ នៅតំបន់ដែលរ.ជ.រ.ប.ខ.កាន់កាប់ ក៏កើតមានបញ្ហាចំរូងចំរាស់ជាថ្មីទៀត ក្នុងពេលអវត្តមានរបស់លោកតា សឺន សាន ។ ដោយសារសមាជិកខ្លះនៃគណៈកម្មាធិការប្រតិបត្តិកូមុិច បានរើសសមាជិកថ្មីម្នាក់ទៀតមកពីប្រទេសបារាំងដែរ ឈ្មោះលោក ឱក សិរីសោភក្តិ ឲ្យចូលមកធ្វើការក្នុងរណសិរ្ស ។ លោក សោភក្តិ បានចេញពីប្រទេសបារាំង នៅថ្ងៃទី ២២ មេសា ១៩៨១ ហើយនៅថ្ងៃទី ១១ ឧសភា ១៩៨១ បានត្រូវអនុញ្ញាតឲ្យចូលតំបន់កណ្តាល ដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់លោកឧត្តមសេនីយ ដៀន ដែល ។ សោភក្តិ និង

សមាជិកថ្មីមួយចំនួនទៀត ដែលទើបតែរត់ចេញមកពីតំបន់កាន់កាប់ដោយរដ្ឋាភិបាល ហេង សំរិន ឬ ដែលទើបចេញពីជំរុំជនភៀសខ្លួន បានត្រូវចាត់ឲ្យធ្វើពិធីសច្ចាប្រណិធានជាយុទ្ធជន រ.ជ.រ.ប.ខ. ក្រោមអធិបតីភាពលោកឧត្តមសេនីយ ជៀន ដែល និង លោក ហ៊ីង គន្ធុន នៅថ្ងៃទី ១០ មិថុនា ១៩៨១ ។ វត្តមានរបស់សោភក្តិ នៅក្នុងសមរភូមិមុខ អាចជាសញ្ញាដ៏ល្អមួយដល់ជនភៀសខ្លួន ឬ មន្ត្រីរបស់ រ.ជ.រ.ប.ខ. ឲ្យដឹងថា រ.ជ.រ.ប.ខ. មានការគាំទ្រយ៉ាងខ្លាំងក្លាពីសហគមន៍ខ្មែរនៅបរទេស ដូច្នេះពួកគេមិនត្រូវរត់ទៅបរទេសទេ ។ រត់ទៅបរទេសធ្វើអ្វី បើមានយុវជនបញ្ញវន្តនៅបរទេសនាំគ្នាចូលបំរើ រ.ជ.រ.ប.ខ. យ៉ាងនេះទៅហើយនោះ ។

ក៏ប៉ុន្តែ ករណីរបស់ សោភក្តិ បានក្លាយទៅជាប្រធានបទនៃការចំរូងចំរាស់ខ្វែងគំនិតគ្នា មិនទុកចិត្តគ្នាក្នុងផ្ទៃក្នុងនៃថ្នាក់ដឹកនាំរបស់រ.ជ.រ.ប.ខ. ទៅវិញ ។ ជាពិសេស រវាងថ្នាក់ដឹកនាំនៅបាងកក ទល់ដែន និង អ្នកជិតស្និទ្ធជាមួយលោកតា សឺន សាន នៅប្រទេសបារាំង ។ ប្រការដែលមិនប្រក្រតីនោះគឺ សោភក្តិ ដែលរស់នៅឯប្រទេសបារាំងនេះ ពុំបានទាក់ទងជាមុនជាមួយការិយាល័យរ.ជ.រ.ប.ខ. នៅទីក្រុងប៉ារីស មុននឹងធ្វើដំណើរទៅជួបថ្នាក់ដឹកនាំនៅឯប្រទេសថៃ ។ តាមធម្មតា អ្នកតំណាងរ.ជ.រ.ប.ខ. នៅទីក្រុងប៉ារីស ត្រូវណែនាំឲ្យថ្នាក់ដឹកនាំនៅបាងកកស្គាល់សមាជិកថ្មីនោះជាមុនៗនឹងគេអនុញ្ញាត ឲ្យចូលទៅស្គាល់ទីស្នាក់ការកណ្តាល រ.ជ.រ.ប.ខ. ឬ ចូលទៅក្នុងតំបន់រំដោះរបស់រ.ជ.រ.ប.ខ.។ លោក សិរីសោភក្តិ ធ្វើដំណើរដល់ទីហាមឃាត់ទាំងនោះ ដោយគ្មានការអនុញ្ញាត ឬ ដឹងឮជាមុនពីលោកតា សឺន សាន សោះឡើយ ។

កាលសម័យនោះ សម្រាប់អ្នករស់នៅឯបរទេស ការចេញដំណើរទៅចូលរួមក្នុងរណសិរ្សជួរមុខ អាចចាត់ទុកជាកិត្តិយសខ្ពង់ខ្ពស់ណាស់ ព្រោះអ្នកទាំងនោះអាចចាត់ទុកជាមនុស្សរកបានដោយកម្រ ។ ម្យ៉ាងដោយសារពួកគេភាគច្រើនមិន

អាចធ្វើបាន ព្រោះជាប់ដំពាក់ក្នុងការរស់នៅចិញ្ចឹមជីវិតប្រចាំថ្ងៃ ឬ ជាប់ដំពាក់ក្នុងគ្រួសារ ម្យ៉ាងទៀត ដោយត្រូវឆ្លងកាត់ការជ្រើសរើសពិនិត្យពិចារណាយ៉ាងហ្មត់ចត់ណាស់ ជាពិសេសអ្នកដែលចេញពីសហរដ្ឋអាមេរិក ឬ អឺរ៉ុប ។ សមាជិករ.ជ.រ.ប.ខ. ទាំងអស់ មានការគោរពកោតស្ញប់ស្ញែងចំពោះអ្នកស្នំគ្រចិត្តទៅធ្វើពលីកម្មគ្រប់បែបយ៉ាង ដើម្បីបុព្វហេតុជាតិនៅសមរភូមិមុខនេះណាស់ ។ ពួកយើង នៅទីក្រុងប៉ារីសកាលពីមុនក៏ធ្លាប់ស្គាល់ សោភក្តិ ច្បាស់លាស់ដែរតែស្គាល់ក្នុងឋានៈជាអ្នកប្រណាំងប្រជែងគ្នា មិនមែនស្គាល់ក្នុងឋានៈជាអ្នកគាំទ្រដ៏ស្មោះស្ម័គ្រចំពោះ រ.ជ.រ.ប.ខ.នោះទេ ។

លោក ឱក សិរីសោភក្តិ ធ្លាប់ធ្វើការយ៉ាងសកម្មក្នុងសមាគម ឬ ក្រុមនយោបាយ ដែលពួកយើងធ្លាប់ស្គាល់ថា ជាអ្នកប្រណាំងប្រជែងយ៉ាងចេញមុខជាមួយ រ.ជ.រ.ប.ខ. ។ ដូច្នេះការដែល សិរីសោភក្តិ លេចមុខទៅជាយុទ្ធជនស្នំគ្រចិត្តរបស់ រ.ជ.រ.ប.ខ.នៅលើសមរភូមិនោះ បានធ្វើឲ្យសមាជិករ.ជ.រ.ប.ខ.មួយចំនួននៅប្រទេសបារាំង មានការខកចិត្ត និង អាក់អន់ចិត្ត ហើយគិតថាមិនគួរគេអនុញ្ញាតឲ្យអ្នកក្រៅ ចូលទៅក្នុងបេះដូងរ.ជ.រ.ប.ខ.យ៉ាងស្រួលៗដូច្នេះសោះ ។ គួរកត់សំគាល់ថានៅក្នុងតំបន់រំដោះ សោភក្តិ បានខិតខំសរសេរអត្ថបទចុះផ្សាយក្នុងព្រឹត្តិប័ត្រ រ.ជ.រ.ប.ខ. កោតសរសើររ.ជ.រ.ប.ខ. ដោយរៀបរាប់ពីជោគជ័យជាច្រើនរបស់ រ.ជ.រ.ប.ខ. រួមមានការរៀបចំជាភូមិស្រុក ប្រកបដោយរបៀបរៀបរយ និង ការខិតខំអប់រំបណ្តុះបណ្តាលដល់យុទ្ធជន ទាំងទាហានទាំងស៊ីវិលឲ្យមានសមត្ថភាពខ្ពស់ក្នុងការតស៊ូដើម្បីរំដោះជាតិ ។ ក៏ប៉ុន្តែ នៅចុងខែ កក្កដា ១៩៨១ សោភក្តិ បានវិលត្រឡប់មកទីក្រុងប៉ារីសវិញ ដោយបានបង្ហាញហេតុផលថា៖[130] រៀបចំក្រុម

[130] ឱក សិរី សោភក្តិ, លិខិតជូនចមពោះលោកប្រធាន សឺន សាន ប្រធានរណៈស្សេជាតិរំដោះប្រជាពលរដ្ឋខ្មែរ - សមរភូមិមុខ - ក្រេតីយ៍ ថ្ងៃទី ១ មេសា ឆ្នាំ ១៩៨២ ។

គ្រួសារឲ្យស្រួលបួលសិន ដើម្បីអាចឲ្យទៅរស់នៅជាយូរអង្វែងក្នុងដួរ.ជ.រ.ប.ខ.ត ទៅ -ធ្វើជាសាក្សី ចំពោះមុខសហគមន៍ខ្មែរនៅប្រទេសបារាំង ឲ្យដឹងពីការពិតនៃ សកម្មភាពរបស់រ.ជ.រ.ប.ខ.នៅក្នុងប្រទេសកម្ពុជា ជាពិសេស សោកក្តី មានបំណង សុំឲ្យរ.ជ.រ.ប.ខ. ជាក់ទិសដៅឃោសនាតម្រង់ទៅក្រុមយុវជន ដើម្បីអូសទាញអ្នក ទាំងនោះ ឲ្យជួយគាំទ្ររ.ជ.រ.ប.ខ.ឲ្យបានច្រើនថែមទៀត ។ ហេតុផលចុងក្រោយ លោក សោកក្តី វិលមកប្រទេសបារាំងវិញនោះគឺ ចង់កែសម្រួលករណីរបស់ខ្លួនជា មួយនឹងការិយាល័យរ.ជ.រ.ប.ខ. នៅទីក្រុងប៉ារីសនេះ ជាពិសេស ដើម្បីកែលំអ ទំនាក់ទំនងផ្ទាល់ជាមួយលោកតា សឺន សាន និង សហការីរបស់លោកតាផង ។ តាមពិតទៅ សោកក្តី មិនមែនជាមនុស្ស ដែលអាចចូលទៅជិតលោកតាបានស្រួល ៗនោះទេ ហើយក៏មិនមែនអាចជាមនុស្សជំនិតរបស់លោកតាបានឡើយ ។ ក៏ប៉ុន្តែ សោកក្តី មានទំនាក់ទំនងល្អ និង ជិតស្និទ្ធជាមួយសមាជិកសំខាន់ៗនៃគណៈកម្មាធិ ការប្រតិបត្តិ ឬ កូមុិច ដូចជា៖ លោក នាង ជិន ហាន អគ្គលេខាធិការ លោក ហ៊ីង គន្ធុន និង លោកឧត្តមសេនីយ ជៀន ដែល ជាដើម ។

ករណីរបស់លោក សិរីសោកក្តី បានបង្ហាញឲ្យឃើញថាការិយាល័យ រ.ជ.រ. ប.ខ. ប្រចាំទីក្រុងប៉ារីស ដែលស្ថិតនៅក្រោមឥទ្ធិពលរបស់អ្នកគាំទ្រ ឬ សមាជិកគ្រួ សាររលោកតា សឺន សាន មិនបានគ្រប់គ្រងផ្តាច់មុខទៅលើបណ្តាញទាំងអស់ ដែល អាចផ្តល់ការគាំទ្រដ៏ឧត្តុង្គឧត្តមដល់រ.ជ.រ.ប.ខ.នោះទេ ។ ផ្ទុយទៅវិញករណីនេះ បញ្ជាក់ថាសមាជិកសំខាន់ៗនៅក្នុងថ្នាក់ដឹកនាំរបស់ រ.ជ.រ.ប.ខ. មិនមែនសុទ្ធតែធ្វើ ការតែជាមួយលោកតា សឺន សាន ឬ ជាមួយមនុស្សជំនិតរបស់លោកតានៅប៉ារីស នោះទេ ពួកគេក៏មានបណ្តាញរបស់គេ ដែលអាចជួយពង្រឹងឥទ្ធិពលរបស់រណសិរ្ស ផង និង ឥទ្ធិពលផ្ទាល់របស់ពួកគេផង ។ ម្យ៉ាងទៀត ករណីនេះសឲ្យឃើញថា រ.ជ.រ.ប.ខ. មិនមែនជារបស់ផ្តាច់មុខរបស់លោកតា សឺន សាន ឯការគ្រប់គ្រងព័ត៌

មានមកពីរណសិរ្សរបស់កូនប្រសារលោកតា ក៏មិនប្រាកដជាមានផលប្រយោជន៍ប៉ុន្មានដែរ ព្រោះថាអ្នកក្រៅគេក៏អាចទទួលព័ត៌មានផ្ទាល់ពីទីស្នាក់ការកណ្តាលរ.ជ.រ.ប.ខ.បានដែរ ។ តែយ៉ាងណាក៏ដោយ ក៏ករណីលោក ឱក សិរីសោភក្តិ នេះត្រូវបានគណៈកម្មាធិការប្រតិបត្តិ ឬ កូមុិច លើកយកមកពិភាក្សានៅពេលក្រោយៗមកទៀត ។

សន្និសីទអន្តរជាតិមួយស្តីពីកម្ពុជា

តាំងពីពេលដំបូងនៃជម្លោះនៅកម្ពុជានោះមក អង្គការសហប្រជាជាតិតែងតែថែរក្សាគោលជំហរដ៏ទៀងទាត់របស់ខ្លួន ស្របតាមសេចក្តីសំរេចរបស់មហាសន្និបាត ដែលតម្រូវឲ្យមានការកោះប្រជុំសន្និសីទអន្តរជាតិមួយស្តីពីកម្ពុជា ដើម្បីស្វែងរកកិច្ចព្រមព្រៀងលើការដកកងទ័ពវៀតណាមចេញពីទឹកដីខ្មែរ និង វិធានការទាំងឡាយ ដើម្បីរក្សាសណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ ការគោរពសិទ្ធិមនុស្សជាពិសេស ដើម្បីរៀបចំការបោះឆ្នោតជាទូទៅមួយក្រោមការត្រួតពិនិត្យរបស់អង្គការសហប្រជាជាតិ ។ មហាសន្និបាតអង្គការសហប្រជាជាតិ បានចេញសេចក្តីសំរេចពីរលើករួចមកហើយគឺ ក្នុងខែ វិច្ឆិកា ១៩៧៩ និង ក្នុងខែ តុលា ១៩៨០ ។ នៅខែ មិថុនា ១៩៨១ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ បានចេញសំណើតាមផ្លូវទូត ដើម្បីស្ទាបស្ទង់ដល់ប្រទេសសមាជិកទាំងអស់ថាតើពេលវេលាអាចសមស្រប ឬ នៅ? ដើម្បីកោះប្រជុំសន្និសីទអន្តរជាតិនោះ[131] ។

នៅថ្ងៃទី ១៨ មិថុនា ១៩៨១ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិបានអញ្ជើញប្រទេសសមាជិកឲ្យចូលរួមប្រជុំ នៅទីស្នាក់ការអង្គការសហប្រជាជាតិនៅទីក្រុងញ៊ីវយ៉កនៅថ្ងៃទី ១៣ ខែ កក្កដា ១៩៨១ ។ ប្រទេសវៀតណាម និង

[131] Nations Unies, Rapport de la Conférence Internationale sur le Kampuchea, New York, 1981.

កម្ពុជាប្រជាធិបតេយ្យ បានត្រូវអញ្ជើញឲ្យចូលរួមក្នុងឋានៈជាភាគីដាប់ដំពាក់ក្នុងជម្លោះ ។ កម្ពុជាប្រជាធិបតេយ្យតំណាងដោយខ្មែរក្រហម បានចូលរួមប្រជុំ ក៏ប៉ុន្តែវៀតណាម មិនបានចាត់តំណាងឲ្យចូលរួមទេ ។ ប្រទេសសមាជិកទាំងអស់ចំនួន ៧៩ ប្រទេសបានចាត់តំណាងឲ្យចូលរួម ។ នៅសម័យប្រជុំពេញអង្គលើកដំបូង ប្រតិភូប្រទេសសឹង្ហបូរី បានស្នើសុំឲ្យក្រុមនយោបាយខ្មែរបីក្រុមចូលរួមប្រជុំគឺ៖ ១. រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ (រ.ជ.រ.ប.ខ.) ២. ហ៊ុន សុិន ប៊ិច (Funcin pec) ៣. គណបក្សប្រជាជនបដិវត្តន៍កម្ពុជា ឬ (រដ្ឋាភិបាល ហេង សំរិន)ឲ្យចូលរួមប្រជុំ តែមិនឲ្យមានសិទ្ធិបោះឆ្នោត ។ សន្និសីទបានព្រមឲ្យរ.ជ.រ.ប.ខ. និង ហ៊ុន សុិន ប៊ិច ចូលរួមតាមសំណើ ក៏ប៉ុន្តែបដិសេធមិនព្រមឲ្យតំណាងរដ្ឋាភិបាល ហេង សំរិន ចូលប្រជុំឡើយ[132] ។ តាមសំណើរបស់ហ្វីលីពីន ដោយមានការគាំទ្រពីប្រទេសសេណេហ្គាល់ (Senegal) អូស្ត្រាលី (Australia) វ៉េណេហ្ស៊ុយអេឡា (Venezuela) បែលហ្ស៊ិក (Belgique) អង្គសន្និសីទបានជ្រើសតាំងលោករដ្ឋមន្ត្រីក្រសួងការបរទេសអូទ្រីស វីល្លីបាដ ប៉ា (Willibard Pahr) ជាប្រធានសន្និសីទ ។ សន្និសីទនេះ បានចេញសេចក្តីប្រកាសអះអាងជាថ្មីនូវភាពមិនអាចរំលោភបាននៃរដ្ឋសមាជិកទាំងអស់ទៅលើ ឯករាជភាព អធិបតេយ្យភាព និងបូរណភាពទឹកដី ដោយគូសបញ្ជាក់នូវភាតព្វកិច្ចរបស់រដ្ឋសមាជិកទាំងអស់ ក្នុងការគោរពសិទ្ធិនៃប្រទេសជិតខាង ។ សេចក្តីប្រកាសនេះ បានថ្កោលទោសប្រទេសវៀតណាម ដែលបានលុកលុយ និង កាន់កាប់ទឹកដីកម្ពុជា និង កត់សំគាល់នូវផលវិបាកធ្ងន់ធ្ងរ ដែលអាចកើតមាន ដោយសារភាពតានតឹងនៅក្នុងតំបន់អាស៊ីភាគអាគ្នេយ៍ ។ តាំងពីពេលដែលបានចូលរួមប្រជុំក្នុងសន្និសីទនេះ ចលនាអ្នកជាតិ

[132] Nations Unies, Rapport de la Conférence Internationale sur le Kampuchea, op. cit.

និយមទាំងពីរគឺរ.ជ.រ.ប.ខ.របស់លោកតា សឺន សាន និង ហ៊ុន សុិន បុិច របស់សម្តេច សីហនុ បានស្ថិតនៅជារណសិរ្សពីរដោយឡែកពីគ្នាជារៀងរហូត ។

ជំនួប សឺន សាន - សីហនុ

នៅថ្ងៃទី ៣ សីហា ១៩៨១ លោកតា សឺន សាន ទៅគាល់សម្តេច សីហនុ នៅព្រះដំណាក់នាក្រុង មូហ្សាំង (Mougins) ឯតំបន់មាត់សមុទ្រភាគខាងត្បូងនៃប្រទេសបារាំង ។ ជំនួយការ និង ទីប្រឹក្សាដ៏ជិតស្និទ្ធទាំងឡាយរបស់លោកតា ផ្តល់យោបល់ឲ្យលោកតាប្រធាន ប្រកាន់គោលដំហររឹងប៉ឹងនៅចំពោះព្រះកត្តិអតីតព្រះប្រមុខរដ្ឋ ព្រោះថាលោកតានាពេលនោះ មិនមែនជាមនុស្សសាមញ្ញធម្មតាដូចពេលមុនទៀតទេ ដោយសារលោកតាទទួលបានតួនាទីជាអ្នកដឹកនាំដែលមានការទទួលស្គាល់រួចទៅហើយ នៅក្នុងចលនាតស៊ូប្រឆាំងវៀតណាម ចំណែកសម្តេច សីហនុ ទ្រង់គង់ជាបុគ្គលឯកជនតែប៉ុណ្ណោះ[133] ។ នាសម័យនោះ ជនភៀសខ្លួនខ្មែរមួយចំនួនបានសម្លឹងឃើញលោកតា សឺន សាន ដូចជានាយករដ្ឋមន្ត្រីជាប់ឆ្នោតរួចទៅហើយ នៅរង់ចាំតែចូលកាន់តំណែងតែប៉ុណ្ណោះ បន្ថែមលើតួនាទីជាប្រធានចលនាអ្នកជាតិនិយម រ.ជ.រ.ប.ខ.ដែលមានប្រទេសមួយចំនួនទទួលស្គាល់ផង ។ តាមពិតគោលបំណងរបស់លោកតា សឺន សាន គឺ ចង់បានការគាំទ្រជាសាធារណៈរបស់សម្តេច សីហនុ ក្នុងការខឹតខំរបស់លោកតា ដើម្បីប្រមែប្រមូលនិងច្របាច់បញ្ចូលគ្នាតែមួយនូវកងកម្លាំងអ្នកជាតិនិយមនានា ។ ធ្វើយ៉ាងនេះ ដើម្បីជៀសវាងនូវទ្រឹស្តី "ត្រីភាគីនិយម" (Tripartism) នៅពេលដែលត្រូវបង្កើតរដ្ឋាភិបាលចម្រុះជាមួយខ្មែរ

[133] នេះជាការវាយតំលៃសភាពការណ៍ខុស ព្រោះតាមការព្រមព្រៀងគ្នារវាងលោក តេង ស៊ាវពីង និង លី ខ្វាន់ យូ បានចែងថា រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យថ្មីនឹងត្រូវដឹកនាំដោយ សម្តេច សីហនុ ឬ លោក សឺន សាន មិនមែន សឺន សាន តែម្នាក់ឯងនោះទេ ។

ក្រហម ។ បន្ទាប់ពីជំនួបជាមួយសម្តេច សីហនុ លោកតា សឺន សាន បានផ្សព្វ ផ្សាយជាសាធារណៈថា សម្តេចបានគាំទ្រការខឹតខំប្រឹងប្រែងរបស់លោកតាក្នុងការ បង្កើតរដ្ឋាភិបាលចម្រុះ ដែលតំណាងឲ្យកម្លាំងចលនាតស៊ូទាំងអស់ប្រឆាំងនឹងការ លុកលុយ និង ការកាន់កាប់ប្រទេសខ្មែរដោយកងទ័ពវៀតណាម ។ មេដឹកនាំទាំង ពីរូប បានសម្តែងទស្សនៈថា ពួកខ្មែរក្រហមនឹងវិលមកកាន់អំណាចវិញ នៅពេល ដែលកងទ័ពវៀតណាមដកចេញពីកម្ពុជា ។ ទាំងនោះជាគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរចំពោះ ប្រជារាស្ត្រខ្មែរ ដែលប្រឆាំងដាច់ខាតនឹងការវិលត្រឡប់មកវិញនៃរបបប្រល័យពូជ សាសន៍ឯងនេះ ។ នៅក្នុងជំនួបនោះ លោកតា សឺន សាន បានទូលសម្តេចអំពី លក្ខខណ្ឌ ដែលតម្រូវឲ្យមានការជានាជាមុនពីមហាប្រទេសនានាដល់អាយុជីវិត របស់ប្រជារាស្ត្រខ្មែរ[134] ។ លោកតាប្រធានបានស្នើសុំកុំឲ្យសម្តេច សីហនុ បង្កើត រណសិរ្សថ្មីមួយទៀត ប្រសិនបើសម្តេចគាំទ្រការខឹតខំរបស់លោកតា ។ ក៏ប៉ុន្តែ សម្តេច សីហនុ នាពេលនោះមិនបានត្រៀមព្រះអង្គ ដើម្បីបោះបង់រណសិរ្សថ្មីរបស់ ព្រះអង្គឈ្មោះ ហ៊ុន សុន ប៊ុច នោះឡើយ ។ សម្តេចបានបំភ្លឺថា ព្រះអង្គគាំទ្រការ ខឹតខំរបស់លោកតា សឺន សាន តែក្នុងករណីណា ដែលលោកតាទទួលស្គាល់ រណសិរ្ស ហ៊ុន សុន ប៊ុច របស់ព្រះអង្គតែប៉ុណ្ណោះ ។

ត្រឡប់មកកាន់មូលដ្ឋានវិញ លោកតា សឺន សាន បានចាប់ផ្តើមធ្វើការ ពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ ដែលរស់នៅក្រោមការគ្រប់គ្រងរបស់រ.ជ.រ.ប. ខ. ។ ពីថ្ងៃទី ២៤ ទៅ ២៥ សីហា ១៩៨១ លោកតាអញ្ជើញទៅភូមិស្រែចស្រង់ នៅបន្ទាយអំពិល ដែលជាទីបញ្ជាការកងទ័ពរ.ជ.រ.ប.ខ.រួចទៅជំរុំនងចាន់ និង រិទ្ធី

[134] សឺន សាន, សេចក្តីប្រកាស ចំពោះមុខសារព័ត៌មាននានា ក្រោយពីការជួបសន្ទនាជាមួយ សម្តេច ន. សីហនុ, ព្រឹត្តិបត្រ រ ជ រ ប ខ ខែ កញ្ញា ១៩៨១ ទំព័រ ១៦ ។

សែន ។ នៅក្នុងអង្គប្រជុំសាធារណៈទាំងឡាយ លោកតាប្រធានបានពន្យល់ថាវិបត្តិនៅកម្ពុជា អាចនឹងត្រូវដោះស្រាយបានតាមដំណោះស្រាយនយោបាយ ដែលនឹងកើតចេញពីសន្និសីទអន្តរជាតិមួយ ។ ដូច្នេះ លោកតាស្នើសុំការយល់ព្រមជាមុនពីសំណាក់ប្រជាពលរដ្ឋនូវវិធានការ និង លក្ខខណ្ឌដែលនឹងត្រូវលើកឡើងក្នុងការបង្កើតរដ្ឋាភិបាលចម្រុះ ។ លោកតាស្នើថា៖ "សូមបងប្អូនមេត្តាលើកដៃ ប្រសិនបើបងប្អូនយល់ព្រមលើចំណុចខាងក្រោម៖ ១. មិនអនុញ្ញាតឲ្យមានការបង្កើតរណសិរ្សថ្មីអ្វីក្រៅពីរ.ជ.រ.ប.ខ.ទៀតឡើយ ។ (លោកតាចង់សំដៅថាមិនត្រូវឲ្យមានការបង្កើត ហ៊ុន សុិន ប៊ុច ថែមលើ រ.ជ.រ.ប.ខ.ទៀតទេ) ២. សុំ ឲ្យបន្ថែមកម្លាំងដល់ រ.ជ.រ.ប.ខ. ឲ្យស្មើនឹងកម្លាំងខ្មែរក្រហម ឬ ៣. ក្នុងករណីដែលមានការបង្កើតរដ្ឋាភិបាលចម្រុះជាមួយខ្មែរក្រហមសមាជិក រ.ជ.រ.ប.ខ. ត្រូវតែទទួលបានកៅអីច្រើនជាងគេ និង សំខាន់ៗជាងគេ ៤. ក្នុងពេលអនាគត ប្រសិនបើមានឧបសគ្គណាមួយកើតឡើងតើសមាជិក រ.ជ.រ.ប.ខ. ត្រូវការឲ្យលោកតាបន្តបេសកកម្មដឹកនាំតទៅទៀតឬទេ? " សំណួរទាំង៤ចំណុចខាងលើនេះ សុទ្ធតែត្រូវ បានសំរឹតសំរាំងឡើង ដើម្បីឲ្យចម្លើយគាំទ្រតបមកវិញនោះបានក្លាយជាលក្ខខណ្ឌដែលលោកតានឹងយកទៅប្រើ នៅក្នុងពេលចរចាបង្កើតរដ្ឋាភិបាលចម្រុះនាពេលខាងមុខ ។ ឆ្លើយតបចំពោះសំណួរទាំងបួនចំណុច អ្នកចូលរួមក្នុងអង្គប្រជុំទាំងឡាយសុទ្ធតែបានលើកដៃគាំទ្រទាំងអស់ ។

ជំនួប សឺន សាន- សីហនុ- ខៀវ សំផន នៅ សឺង្ហបុរី

នៅទីបញ្ចប់ ប្រទេសចិន និង អាស៊ាន បានស្រុះស្រួលគ្នារៀបចំឲ្យអ្នកដឹកនាំខ្មែរប្រឆាំងវៀតណាមទាំងបីរូប បានជួបពិភាក្សាគ្នានៅប្រទេសសឺង្ហបុរី ក្នុងខែកញ្ញា ១៩៨១ ។ អ្វីដែលលោកតា សឺន សាន ចង់ជៀសចេញនោះគឺទ្រឹស្តី "ត្រីភាគី

និយម" នៅទីបំផុតក៏ពុំអាចគេចរួច ។ នៅថ្ងៃទី ៤ កញ្ញា ១៩៨១ នៅក្នុងប្រទេសសឹង្ហបុរី សម្តេច សីហនុ លោកតា សឺន សាន និង លោក ខៀវ សំផន បានជួបជុំគ្នា និង ចុះហត្ថលេខាលើសេចក្តីប្រកាសរួមមួយ ដែលក្នុងនោះមេដឹកនាំទាំងបីបានព្រមព្រៀងគ្នាលើចំណុចពីរសំខាន់ក្រៅពីការគាំទ្រសេចក្តីថ្លែងការណ៍ និង សេចក្តីសម្រេចរបស់សន្និសីទអន្តរជាតិស្តីពីកម្ពុជា ព្រមទាំងអំពាវនាវឲ្យបណ្តាប្រទេសដែលស្នេហាសន្តិភាពទាំងអស់គាំទ្រសេចក្តីថ្លែងការណ៍ និង សេចក្តីសំរេចទាំងនេះ[135] ។ ចំណុចសំខាន់ទាំងពីរនោះគឺ៖ ១. សំដែងបំណងបង្កើតរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ក្នុងគោលដៅបន្តការតស៊ូប្រយុទ្ធគ្រប់រូបភាព ដើម្បីរំដោះប្រទេសកម្ពុជាចេញពីអំពើឈ្លានពានរបស់រៀតណាម ២. បង្កើតគណៈកម្មការចំពោះកិច្ច ដើម្បីសិក្សាអំពីគោលការណ៍ និង បែបបទដែលអាចនាំទៅសម្រេចគោលដៅរដ្ឋាភិបាលចម្រុះខាងលើ ។

បន្ទាប់ពីមានការចុះហត្ថលេខាលើសេចក្តីប្រកាសរួមនេះមក មានការព្រមព្រៀងគ្នាជាមួយរដ្ឋមន្ត្រីការបរទេសនៃប្រទេសថៃ សឹង្ហបុរី និង ម៉ាឡេស៊ីថា រដ្ឋាភិបាលចម្រុះត្រីភាគីកម្ពុជាប្រជាធិបតេយ្យថ្មីនេះ នឹងត្រូវបង្កើតឡើងក្នុងពេលឆាប់ៗ ដោយមានលោកតា សឺន សាន ជានាយករដ្ឋមន្ត្រី ហើយក្នុងឋានៈជានាយករដ្ឋមន្ត្រីចាត់តាំងនេះ (Prime Minster-designated) លោកតាត្រូវដឹកនាំគណៈប្រតិភូខ្មែរទៅចូលរួមមហាសន្និបាតអង្គការសហប្រជាជាតិឲ្យទាន់ពេលវេលា ។ យោងតាមសេចក្តីប្រកាសរួមនេះដែរ មេដឹកនាំទាំង៣រូបបានចាត់តាំងតំណាងរៀងៗខ្លួនឲ្យចូលរួមក្នុងគណៈកម្មការចំពោះកិច្ច (Adhoc-Committee) ដែលក្នុងនោះ ខាងសម្តេច សីហនុ មាន៖ លោកតា អ៊ិន តាំ លោក ប្ជរ ហ៊ែល និង លោក ចក់ សារឿន

[135] HRH Samdech Norodom Sihanouk, HE Mr. Son Sann, HE Mr. Khieu Samphan, Singapore, Joint Statement, 2-4 September 1981.

ឯខាងលោកតា សឺន សាន មាន៖[136] លោក ហ៊ឹង គន្ធុន លោក នាង ជិនហន និង លោក ហ្គាហ្វា ពាងម៉ែត ឯចំណែកខាងលោក ខៀវ សំផន មាន៖ លោកស្រី អៀង ធីរិទ្ធ លោក សួង ស៊ីខឿន និង លោក ពេជ ប៊ុនរ៉ែត ។

តស៊ូមតិគ្នាក្នុងគណៈកម្មការចំពោះកិច្ច

គណៈកម្មការចំពោះកិច្ចនេះបានជួបប្រជុំជាលើកទី១ នៅថ្ងៃទី ១៣ កញ្ញា ១៩៨១ នៅទីក្រុងបាងកកប្រទេសថៃ និង បានប្រជុំជាបន្តបន្ទាប់នៅថ្ងៃទី ១៨-២២, ២៦ និង ២៨ កញ្ញា ១៩៨១ ដោយពុំបានឈានដល់ការព្រមព្រៀងគ្នាណាមួយឡើយ ។ បើតាមលោកតា អ៊ិន តាំងបានឲ្យដឹងថា សម្តេច សីហនុ បានណែនាំឲ្យអ្នកតំណាងព្រះអង្គ នៅឲ្យស្ងៀមក្នុងអង្គប្រជុំ មិនចាំបាច់បញ្ចេញមតិអ្វីទាំងអស់ ហើយចាំតែគាំទ្ររាល់ការស្រុះស្រួលឬព្រមព្រៀងណាមួយរវាងរ.ជ.រ.ប.ខ. និង ខ្មែរក្រហមគឺ បានន័យថាឲ្យតែភាគីទាំងពីរស្រុះស្រួលគ្នា ខាងភាគីសម្តេចចាំតែគាំទ្រតែប៉ុណ្ណោះ ។ គោលជំហររបស់សម្តេចនេះជាវិធីដ៏ស្រួលបំផុត ដោយសារព្រះអង្គបានជ្រាបអស់ហើយនូវមូលដ្ឋាននៃកិច្ចព្រមព្រៀងរវាង ចិន និង អាស៊ាន តាមរយៈជំនួប តេង ស៊ាវពីង-លី ខ្វាន់ យូ កាលពីខែ វិច្ឆិកា ១៩៨០ ។

នៅថ្ងៃទី ២ តុលា ឆ្នាំ ១៩៨១[137] លោកតា សឺន សាន បានផ្ញើអនុស្សារណៈមួយទៅជូនក្រសួងការបរទេសថៃ ដើម្បីសរុបសភាពការណ៍នៃការចរចារបស់គណៈកម្មការចំពោះកិច្ចជូនម្ចាស់ផ្ទះជ្រាប ។ អនុស្សារណៈនោះ បានពន្យល់ពីគោលជំហរខ្វែងគ្នារវាង រ.ជ.រ.ប.ខ. និង ខ្មែរក្រហម ។ ខាង រ.ជ.រ.ប.ខ.ឈរលើគោលការណ៍ថារដ្ឋាភិបាលចម្រុះមានលក្ខណៈជាអន្តរកាលតែប៉ុណ្ណោះ ។ ឯទស្សន

[136] Son Sann, Décision, Singapour, le 5 Septembre 1981.
[137] Front National de Libération du Peuple Khmer, Memorandum Presented by Mr. Son Sann, President of the KPNLF to the Ministry of Foreign Affairs of the Royal Govenement of Thailand, October 2, 1981

ទានរបស់រដ្ឋាភិបាលចម្រុះនេះ ត្រូវផ្តោតលើការស្វែងរកដាប្រចាំនូវដំណោះស្រាយ នយោបាយ ។ រដ្ឋាភិបាលចម្រុះនេះ ត្រូវមានស្ថាប័នផ្ទាល់របស់ខ្លួនដែលមានអំណាចពេញទី ដែលមិនត្រូវចំណុះឲ្យអង្គការណាមួយក្នុងរង្វង់រដ្ឋនៃរបបខ្មែរក្រហមកម្ពុជាប្រជាធិបតេយ្យនោះឡើយ ។ ម្យ៉ាងទៀត លោកតាក៏បានរៀបរាប់ពីគោលជំហររបស់ខ្មែរក្រហមដែរ ដែលទាមទារថារដ្ឋាភិបាលថ្មី គ្រាន់តែជារដ្ឋាភិបាលបន្តពីរដ្ឋាភិបាលនៃរបបកម្ពុជាប្រជាធិបតេយ្យតែប៉ុណ្ណោះ ដែលមានទស្សនទានជាការតស៊ូតាមកម្លាំងទ័ពដ៏លើសលប់ ហើយរាល់រចនាសម្ព័ន្ធ កម្មវិធីនយោបាយ ស្ថាប័ន និង របៀបរបបដំណើរការទាំងឡាយ ត្រូវតែបន្តពីរបបខ្មែរក្រហមទាំងអស់តទៅទៀត ។ ម្យ៉ាងទៀតក្រុមខ្មែរក្រហមបានទទូចថា រដ្ឋាភិបាលចម្រុះត្រូវមានមូលដ្ឋានលើប្រព័ន្ធត្រីភាគីនិយម ក្នុងនោះភាគីនីមួយៗមានភាពស្មើគ្នា ឯការសំរេចទាំងឡាយត្រូវអនុវត្តតាមការយល់ព្រមជាឯកច្ឆ័ន្ទ ឬ កុងសង់ស៊ីស (Consensus) ។

រ.ជ.រ.ប.ខ រក្សាគោលជំហរថា ទាំងសមាសភាព ទាំងរចនាសម្ព័ន្ធ ទាំងដំណើរការរបស់រដ្ឋាភិបាលចម្រុះថ្មី ត្រូវតែមានវិធានការ និង នីតិវិធី ពិសេសដែលឆ្លើយតបទៅនឹងសភាពការណ៍នៃប្រទេសដែលកំពុងស្ថិតនៅក្នុងសង្គ្រាម ជាពិសេសក្នុងពេលមួយរយៈ ដើម្បីឲ្យរដ្ឋាភិបាលនេះអាចប្រមែប្រមូល និង ពង្រីកកម្លាំងភាគីទាំងអស់ក្នុងការតស៊ូរំដោះជាតិ ។ រ.ជ.រ.ប.ខ ស្នើថាគ្រប់សកម្មភាពរបស់រដ្ឋាភិបាលត្រូវគោរព និង អនុវត្តតាមសេចក្តីសំរេចរបស់អង្គការសហប្រជាជាតិ និង សេចក្តីប្រកាសរបស់សន្និសីទអន្តរជាតិស្តីពីកម្ពុជាចុះថ្ងៃទី ១៧ កក្កដា ១៩៨១ នៅទីក្រុងញ៉ីវយ៉ក ។

នៅថ្ងៃទី ៤ តុលា ១៩៨១[138] គណៈកម្មការចំពោះកិច្ច បានជួបប្រជុំគ្នាជាថ្មីម្តងទៀត ។ ម្តងនេះ ខាងភាគីខ្មែរក្រហម បានសង្កត់ធ្ងន់ទៅលើគោលការណ៍ ៤

[138] Translation (into English) of the Official Record of the Sixth Ad Hoc Meeting held on October 4, 1981 under the Presidency of Mme. Ieng Thirith of Democratic Kampuchea.

ចំណុចៈ ១-រដ្ឋាភិបាលចម្រុះត្រូវតែឈរលើគោលជំហរមហាសាមគ្គីពិតប្រាកដ ២-រដ្ឋាភិបាលនេះត្រូវឈរលើគោលការណ៍ត្រីភាគី ។ ទាំងរចនាសម្ព័ន្ធ ទាំងសមាសភាពត្រូវយកភាពតំណាងស្មើគ្នាជាធំ ៣-រាល់បញ្ហាសំខាន់ៗ ត្រូវដោះស្រាយតាមការសំរេចជាឯកច្ឆ័ន្ទ នៅក្នុងរដ្ឋាភិបាល ៤-និរន្តរភាព ឬ ការបន្តរបស់រដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ និង និរន្តរភាពឬការបន្តជារដ្ឋសមាជិកនៃអង្គការសហប្រជាជាតិរបស់កម្ពុជាប្រជាធិបតេយ្យ ជាលក្ខណៈស្របច្បាប់នៃរដ្ឋាភិបាលចម្រុះនេះ ។ គោលការណ៍ទាំងនេះ ទាត់ចោលទាំងអស់នូវសំណើរបស់ភាគី រ.ជ.រ.ប.ខ. ។ អ្នកតំណាងរ.ជ.រ.ប.ខ. (ខាងលោកតា សឺន សាន) បានស្នើសុំរក្សាសិទ្ធិឆ្លើយតបចំពោះចំណុចទាំងបីដំបូងរបស់ខ្មែរក្រហម ព្រោះចំណុចទាំងនេះ ទាក់ទងនឹងបញ្ហាការចាត់តាំងតួនាទីរបស់នាយករដ្ឋមន្ត្រី និង សមាសភាពរបស់រដ្ឋាភិបាលចម្រុះ ។ ចំណែកឯចំណុចទីបួនរបស់ខ្មែរក្រហមទាក់ទងនឹងនិរន្តរភាព នៃរដ្ឋកម្ពុជាប្រជាធិបតេយ្យនោះ តំណាងលោកតា សឺន សាន បានសុំឲ្យក្រុមនេះ ផ្តល់ព័ត៌មានឲ្យបានទូលំទូលាយថា តើស្ថាប័នរបស់រដ្ឋកម្ពុជាប្រជាធិបតេយ្យនោះ មានរូបរាងកិនភាគ បែបបទ របៀបរបប ជាក់ស្តែងយ៉ាងដូចម្តេចខ្លះ? សូមបញ្ជាក់ថាក្នុងការចរចាគ្នាលើកនេះ ក៏ដូចជាលើកមុនៗដែរ ដូចមានក្នុងកំណត់ហេតុនៃកិច្ចប្រជុំស្រាប់ តំណាងរបស់សម្តេច សីហនុ យល់ព្រមតាមពួកខ្មែរក្រហមទៅលើគ្រប់ចំណុច រួមទាំងទុកឲ្យខាង រ.ជ.រ.ប.ខ. នៅឯកោម្នាក់ឯង ដែលជាកត្តាធ្វើឲ្យគោលជំហរចរចានៃភាគីនេះមានភាពទន់ខ្សោយជាទីបំផុត ។ នៅជាមួយគ្នានោះ ខាងក្រុមខ្មែរក្រហម ក៏យកឥរិយាបថរបស់សម្តេច សីហនុ មកធ្វើការគាបសង្កត់ឲ្យ រ.ជ.រ.ប.ខ. បន្ទន់គោលជំហររបស់ខ្លួន ។ កលវិធីបែបនេះ ត្រូវបានក្រុមខ្មែរក្រហមយកមកប្រើប្រកបដោយជោគជ័យ ។ នៅក្នុងប្រព័ន្ធត្រីភាគីនិយម បើគេបូកខ្មែរក្រហមជាមួយសម្តេច សីហនុ គេនឹងបានពីរភាគីទល់នឹងមួយភាគី (ខ្មែរក្រហម +

សម្តេច សីហនុ = ២ភាគី ទល់នឹងភាគី រ.ជ.រ.ប.ខ.) ។ ផ្ទុយទៅវិញ បើគ្មានក្រុម សម្តេច សីហនុ ទេគឺ ក្នុងប្រព័ន្ធទ្វេភាគីនិយមវិញនោះ ខ្មែរក្រហមប្រាកដជាត្រូវតែទល់ផ្ទាល់ជាមួយរ.ជ.រ.ប.ខ. មួយទល់ និង មួយតែប៉ុណ្ណោះ ។ ដោយសារមានប្រៀបបែបនេះ ទើបក្រុមខ្មែរក្រហមទទូចទាមទារយកប្រព័ន្ធត្រីភាគីនិយមមកជាមូលដ្ឋាននៃការចរចាបង្កើតរដ្ឋាភិបាលចម្រុះ ។ ក៏ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏ រ.ជ.រ.ប.ខ. នៅតែចចេសរឹងរូសទប់ទល់នឹងប្រព័ន្ធត្រីភាគីនិយមនេះ ។ ដូច្នេះ គោលបំណងនៃការបង្កើតរដ្ឋាភិបាលចម្រុះឲ្យបានទាន់ពេលវេលា សំរាប់ចូលប្រជុំមហាសន្និបាតប្រចាំឆ្នាំរបស់អង្គការសហប្រជាជាតិក៏ត្រូវបរាជ័យ ។ តាមពិតទៅ ទាំងខាងខ្មែរក្រហម ទាំងខាងភាគីសម្តេច សីហនុ សុទ្ធតែបានយល់ដឹងនូវគោលការណ៍ដែលបានព្រមព្រៀងគ្នារួចហើយរវាងលោក តេង សាវពីង និង លោក លី ខ្វាន់ យូ ។ ដូច្នេះ មានតែខាងលោកតា សឺន សាន ទេ ដែលមិនបានយល់ដឹងទាំងស្រុង ហើយក៏ចេះតែទាមទារដោយឥតបានផលអ្វីទាំងអស់ ។

ក្នុងរយៈពេលនៃការចរចាបង្កើតរដ្ឋាភិបាលចម្រុះ លោកតាប្រធាន រ.ជ.រ.ប.ខ. នៅតែទាមទារយ៉ាងទៀងទាត់សុំឲ្យមានការផ្តល់ជំនួយ និង ឲ្យរ.ជ.រ.ប.ខ.បានទទួលកៅអីក្នុងគណៈរដ្ឋមន្ត្រីចំនួនភាគច្រើនជាច់ខាត និង ជំទាស់មិនឲ្យមេខ្មែរក្រហម ដែលល្បីឈ្មោះជាមេធំៗនៃរបបដែលកាប់សម្លាប់ប្រជារាស្ត្រឯងចូលក្នុងរដ្ឋាភិបាលថ្មីចម្រុះនេះឡើយ[139] ។ អ្វីដែល រ.ជ.រ.ប.ខ. ស្នើនោះគឺការសុំឲ្យបង្កើតក្រុមប្រឹក្សាជាតិមួយ ដែលមានសម្តេច សីហនុ ជាប្រធាន ដែលក្នុងឋានៈនេះព្រះអង្គជាប្រមុខរដ្ឋ ដើម្បីធានានូវនិរន្តរភាព បន្តលក្ខណៈស្របច្បាប់របស់រដ្ឋកម្ពុជាប្រជាធិប

[139] តាមការព្រមព្រៀង តេង សាវពីង - លី ខ្វាន់ យូ កម្ពុជាប្រជាធិបតេយ្យ ឬ ខ្មែរក្រហមអាចដាក់សមាជិក ណាក៏បាននៅក្នុងរដ្ឋាភិបាលថ្មី គ្មានអ្នកណាអាចបង្ហាប់បញ្ជាបានឡើយ (The Three Points of Principle concerning the Kampuchean Question set forth by Vice-Chairman Deng Xiaoping During his Talks with Prime Minister Lee Kuan Yew on 11 November 1980, attached document, letter of Deng Xiaoping to Lee Kuan Yew dated May 28, 1981).

តេយ្យ និង ធានានូវឯករាជ្យ អធិបតេយ្យ ឯកភាព និង បូរណភាពទឹកដីជាតិនៃប្រទេសកម្ពុជាមួយ ដែលប្រកាន់អព្យាក្រឹតភាពមិនចូលបក្សសម្ព័ន្ធ ។ អព្យាក្រឹតភាពនេះ នឹង ត្រូវធានាដោយអន្តរជាតិ ។ ក្រុមប្រឹក្សាជាតិនោះមានតួនាទីផ្តល់មតិដល់រដ្ឋាភិបាលចម្រុះតែប៉ុណ្ណោះ ។ ចំណែកឯរដ្ឋាភិបាលចម្រុះ ដែលមានលោក តា សឺន សាន ជានាយករដ្ឋមន្ត្រីនឹងមានភារកិច្ច និង សមត្ថកិច្ចទូលំទូលាយ ដើម្បីដឹកនាំនយោបាយជាតិ និង ប្រើប្រាស់សិទ្ធិអំណាចលើគ្រប់វិស័យ នៅក្នុងរយៈពេលនៃការតស៊ូរំដោះជាតិ ។ សំណើនេះ គួសបញ្ជាក់យ៉ាងច្បាស់នូវលក្ខណៈបណ្តោះអាសន្ននៃរដ្ឋាភិបាល ដែលនឹងបំពេញតួនាទីត្រឹមតែក្នុងរយៈកាលឆ្លងកាត់ ឬ អន្តរកាលតែប៉ុណ្ណោះ[140] ។ ម្យ៉ាងទៀត សំណើនេះបានពង្រឹងតួនាទីរបស់នាយករដ្ឋមន្ត្រីដែលមានអំណាចទទួលយល់ព្រម ឬ ច្រានចោលសំណើតែងតាំងតំណែងសមាជិករដ្ឋាភិបាលណាមួយពីភាគីឯទៀត ។ ក្នុងន័យនេះលោកតា សឺន សាន អាចទាត់ចោលសំណើតែងតាំងមេដឹកនាំខ្មែរក្រហមល្បីៗដូចជា ប៉ុល ពត អៀង សារី នួន ជា តាម៉ុក ឬ អ្នកល្បីៗ ឯទៀត ។

នៅថ្ងៃទី ២៨ តុលា ១៩៨១ គណៈកម្មការចំពោះកិច្ច បានជួបប្រជុំគ្នាជាថ្មីទៀតជាលើកទី៧ ដោយពុំទទួលលទ្ធផលអ្វីទាំងអស់ ។ នៅថ្ងៃបន្ទាប់នារសៀលថ្ងៃទី ២៩ តុលា ១៩៨១[141] អ្នកតំណាងរបស់រ.ជ.រ.ប.ខ.ត្រូវបានកោះហៅឲ្យទៅប្រជុំជាបន្ទាន់នៅឯក្រសួងការបរទេសថៃ ។ នៅទីនោះ មន្ត្រីក្រសួងការបរទេសថៃលើកសំណួរឲ្យអ្នកតំណាងរ.ជ.រ.ប.ខ. ឆ្លើយជាបន្ទាន់ថាតើទទួល ឬ មិនទទួលនូវគំនិតនៃការបង្កើតរដ្ឋាភិបាលចម្រុះជាមួយខ្មែរក្រហម ។ មន្ត្រីក្រសួងការបរទេសថៃ សុំឲ្យតំណាងរ.ជ.រ.ប.ខ.នាំចម្លើយផ្ទាល់ពីលោកតា សឺន សាន ឲ្យបានរួសរាន់ក្នុងរយៈ

[140] Memorandum presented by Mr. Son Sann, President of the K.P.N.L.F to the Ministry of Foreign Affairs of the Royal Thai Government, October 2, 1981.

[141] KPNLF, Confidential Notes on the Formation of the Coalition Government of Democratic Kampuchea, November 1981.

ពេលប៉ុន្មានម៉ោងតែប៉ុណ្ណោះ ។ ក្រសួងការបរទេសថៃដាក់ឱសានវាទនៅល្ងាច ២៩ តុលា នោះជាកំហឹត បើពុំនោះទេនឹងបិទផ្លូវចរចាតទៅទៀត ។ មន្ត្រីនោះទូន្មានថា ក្នុងការចរចា បើភាគីរ.ជ.រ.ប.ខ. មិនអាចទទួលយកចំណុចទាំងអស់ យ៉ាងហោចណាស់ក៏អាចទទួលយក ដោយរក្សាសិទ្ធិតវ៉ាបាន ដើម្បីកុំឲ្យការចរចានោះគាំងស្ទះ ។

ពួកថៃហាក់ដូចជាធុញទ្រាន់ចំពោះពួកខ្មែរ ដែលនៅជ្រុំជើងមិនដើរទៅមុខសោះក្នុងការចរចាបង្កើតរដ្ឋាភិបាលចម្រុះនេះ ។ នៅរសៀលនោះ លោកតា សឺន សាន បានផ្តល់ចម្លើយជូនលោក កាសេម កាសេមស៊ីរី លេខាធិការអចិន្ត្រៃយ៍នៃក្រសួងការបរទេសថៃ (បាឡាត់ក្រសួង) តាមរូបភាពចម្លើយផ្ទាល់មាត់ (Oral Reply) ដែលមានន័យសង្ខេបដូចតទៅ៖ ទី១ យល់ព្រមលើគោលការណ៍បង្កើតរដ្ឋាភិបាលចម្រុះជាមួយខ្មែរក្រហម តែសូមរក្សាសិទ្ធិតវ៉ា (Accepting with reservations)តាមការទូន្មានរបស់មន្ត្រីថៃ ។ ទី២ ទទួលយកជាគោលការណ៍នូវចំណុច ១, ២, និង ៣ នៃអង្គប្រជុំគណៈកម្មការចំពោះកិច្ចកាលពីថ្ងៃទី ៤ និង ២៨ តុលា ១៩៨១ ដោយរក្សាសិទ្ធិមួយគឺ ឯ.ឧ. សឺន សាន មិនទទួលតួនាទីណាមួយទាំងអស់ក្នុងរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ (ទាំងក្នុងក្រុមប្រឹក្សាជាតិ ទាំងក្នុងគណៈរដ្ឋមន្ត្រី) ។ ទី៣ ស្នើសុំបំភ្លឺជាបន្ទាន់ដល់ប្រជាពលរដ្ឋ ចំពោះគោលជំហរថ្មីនេះ ។ តាមចម្លើយនេះ លោកតា សឺន សាន ចាក់បណ្តោយតាមពួកថៃគឺទទួលយកទាំងអស់នូវចំណុចដែលខ្មែរក្រហមលើកឡើងទាំងប៉ុន្មាន ក៏ប៉ុន្តែលោកតាដាក់លក្ខខណ្ឌមួយវិញ ។ លក្ខខណ្ឌនោះគឺលោកតាមិនទទួលមុខតំណែងអ្វីទាំងអស់ ។ មិនតែប៉ុណ្ណោះ លោកតា សឺន សាន ថែមទាំងស្នើសុំទៅបំភ្លឺប្រជារាស្ត្រ ចំពោះគោលជំហរថ្មីនេះទៀតផង ។ យោងតាមយុទ្ធវិធីថ្មីដែលក្រសួងការបរទេសថៃបានចង្អុលបង្ហាញគឺ កុំប្រឆាំងតែអាចរក្សាសិទ្ធិតវ៉ា (Agree with reservations) ឬ

យល់ព្រមដោយមានលក្ខខណ្ឌនោះមក លោកតា សឺន សាន ក៏យល់ព្រមតាមមតិក៏ប៉ុន្តែ លោកតាយករូបលោកតាផ្ទាល់មកប្រើជាសន្លឹកបៀ "អាត់" នៅក្នុងការចរចាបន្តមកទៀត ។

បើលោកតាមិនធ្វើ ព្រះអង្គក៏មិនធ្វើ

គណៈកម្មការចំពោះកិច្ច បានជួបប្រជុំជាច្រើនលើកទៀត នៅថ្ងៃទី ៣១ តុលា និង ថ្ងៃទី ១៤ វិច្ឆិកា ១៩៨១ ។ បន្ទាប់ពីបានរួមប្រជុំអស់ចំនួន ៩ លើកមក គណៈ កម្មការចំពោះកិច្ច ក៏ត្រូវបរាជ័យពុំអាចស្វែងរកការស្រុះស្រួលគ្នាបានឡើយ ។ ដោយឃើញគោលជំហររបស់លោកតា សឺន សាន មិនចូលរួមផ្ទាល់បែបនេះ សម្តេច សីហនុ បានផ្ញើសារទូរលេខមួយច្បាប់ចុះថ្ងៃទី ២០ វិច្ឆិកា ១៩៨១ ជូនលោកតា អ៊ិន តាំ ដែលមានន័យជាអាទិថាៈ "ខ្ញុំមិនអាចទទួលជាប្រធានប្រេស៊ីឌីយ៉ូម (ប្រធានរដ្ឋ ដែលជាមុខតំណែងស្នើឡើងដោយខ្មែរក្រហម) បានទេ ព្រោះថាផលប្រយោជន៍ដ៏ឃ្យូរអង្វែងរបស់ប្រជារាស្ត្រខ្មែរ តម្រូវឲ្យយើងនៅក្រៅកម្ពុជាប្រជាធិបតេយ្យ"[142] ។ បើតាមលោកតា អ៊ិន តាំ សម្តេចបារម្ភថាបើព្រះអង្គសុខចិត្តចូលធ្វើការជាមួយខ្មែរក្រហម ដោយគ្មានលោកតា សឺន សាន ខ្លួនឯងចូលរួម ទុកឲ្យតែកូនចៅរបស់លោកតាចូលរួមនោះ លោកតា សឺន សាន អាចនឹងដើរឃោសនាយកចំណេញម្នាក់ឯងថា លោកតាមិនដែលជាប់ពាក់ព័ន្ធជាមួយខ្មែរក្រហមទេ និង ថាមានតែលោកតាទេ ដែលមានបាតដៃស្អាតមិនប្រឡាក់ឈាម ។ មែនទែនទៅ បើគ្មានការចូលរួមរបស់លោកតា សឺន សាន ទេ រដ្ឋាភិបាលចម្រុះថ្មី ក៏មិនខុសពីរាជ

[142] អ៊ិន តាំ, ឆ្នាំខួបទី៥ នៃរដ្ឋាភិបាលចម្រុះត្រីភាគី និង សម្លេងភ្នំពេញ, ទស្សនាវដ្តី នគរខ្មែរ ឆ្នាំទី ៩ លេខ ៩៨ ខែ មិថុនា ១៩៨៦ ទំព័រ ២ ។

រដ្ឋាភិបាលរួបរួមជាតិកម្ពុជា (GRUNK)[143] ដែលសម្តេច សីហនុ បានបង្កើតនៅទីក្រុងប៉េកាំងកាលពីឆ្នាំ ១៩៧០ ហើយដែលនៅទីបំផុតបាននាំ ប៉ុល ពត ឲ្យមកកាន់អំណាចនៅខែ មេសា ១៩៧៥ នោះឡើយ ។ បើគិតឲ្យសព្វគ្រប់ទៅ ការចូលរួមដោយផ្ទាល់របស់លោកតា សឺន សាន នៅក្នុងរដ្ឋាភិបាលចម្រុះអាចឲ្យរដ្ឋាភិបាលនោះទទួលទំនុកចិត្តច្រើន ព្រោះថា រ.ជ.រ.ប.ខ.ជាតួបន្លាស់មួយដែលអន្តរជាតិអាចទទួលយកបានផង និង ជាតួអង្គថ្មីលើឆាកនយោបាយក្នុងប្រទេសផង ។ ដូច្នេះ សេចក្តីសំរេចរបស់លោកតា សឺន សាន ថាមិនចូលរួមដោយផ្ទាល់ក្នុងរដ្ឋាភិបាលចម្រុះបានក្លាយជាឧបសគ្គចំបងក្នុងការបង្កើតរដ្ឋាភិបាលថ្មីនេះ ព្រោះថាបើលោកតាមិនចូលរួម សម្តេច សីហនុ ក៏មិនចូលរួមដែរ ។

ថ្ងៃទី ២២-២៣ វិច្ឆិកា រដ្ឋាភិបាលនៃប្រទេសសឹង្ហបូរី បានស្នើរូបមន្តមួយដែលហៅថា "រូបមន្តចម្រុះធូររលុង (Loose coalition) ដែលនៅក្នុងរូបមន្តនេះ រដ្ឋាភិបាលចម្រុះមានគោលដៅចម្បងតែមួយគត់គឺ ការបន្តការតស៊ូប្រឆាំងនឹងការកាន់កាប់ប្រទេសកម្ពុជាដោយវៀតណាម បន្ទាប់មករដ្ឋាភិបាលនេះ នឹងត្រូវរំសាយដោយស្វ័យប្រវត្តិ ដើម្បីឲ្យមានការរៀបចំបោះឆ្នោត ដែលត្រូវរៀបចំឡើងដោយអង្គការសហប្រជាជាតិ" ។ រូបមន្តថ្មីនេះ បង្ហាញលក្ខណៈបណ្តោះអាសន្នរបស់រដ្ឋាភិបាលចម្រុះសមស្របតាមគោលដំហររបស់ រ.ជ.រ.ប.ខ. ដែលធ្លាប់លើកឡើងក្នុងគណៈកម្មការចំពោះកិច្ច ។ រ.ជ.រ.ប.ខ.បានគាំទ្ររូបមន្តនេះ ដោយគ្មានជជែកតវ៉ាអ្វីឡើយ ។ ចំណែកឯពួកខ្មែរក្រហម គេនៅតែប្រកាន់គោលដំហររឹងមាំរបស់ពួកគេដោយឈរលើគោលការណ៍ ៤ យ៉ាងគឺ៖ ១. គោលការណ៍ត្រីភាគីនិយម ២. គោលការណ៍ស្មើភាព និង មិនមានប្រៀបលើគ្នា ៣. គោលការណ៍សំរេចឯកច្ឆ័ន្ទចំពោះកិច្ចការសំខាន់ៗ ៤. គោលការណ៍ច្បាប់របស់រដ្ឋកម្ពុជាប្រជាធិបតេយ្យ- រដ្ឋាភិបាល

[143] Gouvernement Royal d'Union Nationale du Kampuchea (GRUNK).

ចម្រុះ ដែលនឹងត្រូវបង្កើត ត្រូវស្ថិតនៅក្រោមអំណាចច្បាប់របស់រដ្ឋកម្ពុជាប្រជាធិបតេយ្យ ដែលជារដ្ឋសមាជិករបស់អង្គការសហប្រជាជាតិ ។ បន្ថែមលើនេះ ខ្មែរក្រហមទាមទារកាន់កាប់ការងារខាងការបរទេសរបស់រដ្ឋាភិបាល និង ស្នើតែងតាំងលោក អៀង សារី ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស ដែលផ្ទុយទាំងស្រុងនឹងជំហររបស់រ.ជ.រ.ប.ខ. ។

ខ្មែរក្រហមទទួលការគាំទ្រពីសម្តេច សីហនុ

ដើម្បីគាបសង្កត់រ.ជ.រ.ប.ខ ឲ្យទទួលយកជំហររបស់ពួកគេ និង ឲ្យបន្ធន់ឥរិយាបថ ខ្មែរក្រហមក៏បានទៅគាល់សម្តេច សីហនុ ដើម្បីឲ្យសម្តេចស្រុះស្រួលយល់ព្រមតាមពួកគេ ។ សម្តេចក៏យល់ព្រមតាម ។ នៅក្នុងអនុស្សារណៈចុះថ្ងៃទី ៧ ឧសភា ១៩៨២[144] ផ្ញើជូនក្រសួងការបរទេសថៃ ខ្មែរក្រហមប្រកាន់គោលការណ៍ទាំង ៤ ខាងលើ ដោយលើកយកកិច្ចព្រមព្រៀងជាមួយសម្តេច សីហនុ នាខែ កុម្ភៈ ១៩៨២ ជាការគាំទ្រដល់គោលជំហររបស់ពួកគេ ។ ខ្មែរក្រហមទំលាក់កំហុសលើលោកតា សឺន សាន ថាជាអ្នកធ្វើឲ្យរាំងស្ទះដល់ការបង្កើតរដ្ឋាភិបាលចម្រុះ ។ អនុស្សារណៈរបស់ខ្មែរក្រហមនោះ មានសេចក្តីជាអាទិដូចតទៅ៖ "នៅក្នុងជំនួបជាមួយឯកឧត្តម ខៀវ សំផន ប្រធានគណៈប្រធានរដ្ឋ និង ជានាយករដ្ឋមន្ត្រីនៃកម្ពុជាប្រជាធិបតេយ្យ កាលពីថ្ងៃទី ២១ និង ២៣ កុម្ភៈ ១៩៨២ សម្តេចព្រះនរោត្តម សីហនុ បានទ្រង់ព្រមទទួលនូវគោលការណ៍ទាំងអស់(ខាងលើ)នៅពេលនេះ មានតែឯកឧត្តម សឺន សាន ទេ ដែលទាំងទស្សនវិស័យ ក៏ដូចជាសកម្មភាពជាក់ស្តែង មិនទាន់ទទួលយកនូវគោលការណ៍ខាងលើទាំងនោះនៅឡើយ" ។

[144] Democratic Kampuchea, Memorandum by the Democratic Party Concerning the "Declaration of the Formation of the Coalition Government of Democratic Kampuchea, Confidential Document, May 7, 1982.

នៅសម័យនោះ ក្រុមខ្មែរក្រហមបានទទួលការគាំទ្រយ៉ាងខ្លាំងពីឧត្តមសេនីយមួយចំនួននៃកងទ័ពជើងគោកថៃ ជាពិសេស ពីលោកឧត្តមសេនីយ ឆាវលិត យុងឆៃយុទ្ធ ដែលកាលគាត់នៅពាក់សក្តិវរសេនីយឯក បានទៅជួយរៀបចំនាំលោកតា សឺន សាន ឲ្យមកធ្វើជាអ្នកដឹកនាំចលនាតស៊ូមិនមែនកុម្មុយនីស្តក្នុងឆ្នាំ ១៩៧៩ ។ តាមពិតទៅឧត្តមសេនីយ ឆាវលិត ប្រើសន្លឹកបៀខ្មែរច្រើនសន្លឹកក្នុងពេលតែមួយ ដើម្បីក្តាប់ឲ្យណែននូវកូនសោរសំរាប់ដោះស្រាយបញ្ហាកម្ពុជា ។ លោក ឆាវលិត ត្រូវបានទទួលស្គាល់ថា ជាអ្នកយុទ្ធសាស្ត្រថៃដ៏សំខាន់ម្នាក់ ក្នុងការបង្ក្រាបពួកថៃក្រហម ឬ ថៃកុម្មុយនីស្ត ។ នៅទីបំផុត ឧត្តមសេនីយ ឆាវលិត ក៏ជាអ្នកធ្វើការគាបសង្កត់លើលោកតា សឺន សាន ឲ្យទទួលយកលក្ខខណ្ឌទាំងអស់របស់ខ្មែរក្រហមផងដែរ ។

ខ្ញុំជូនលោកតា ទៅជួបទូតអាមេរិក ជាលើកដំបូង

នៅដើមឆ្នាំ ១៩៨២ លោកតា សឺន សាន ធ្វើដំណើរឡើងចុះពីមូលដ្ឋានរបស់គាត់ពីទីក្រុងបាងកកទៅទីក្រុងប៉ារីស និង រដ្ឋធានីនានានៃទ្វីបអឺរ៉ុប ។ នៅថ្ងៃទី ១៩ មីនា ១៩៨២ លោកតាបានអញ្ជើញទៅជួបលោកឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក អ៊ីវ៉ាន់ ហ្គាល់ប្រេត (Evan Galbraith) នៅទីក្រុងប៉ារីស[145] ។ ពេលនោះជាលើកទី១ដែលខ្លួនខ្ញុំត្រូវបានឲ្យទៅហែរហមលោកតាក្នុងឋានៈជាអ្នកជំនួយការ ទៅជួបលោកឯកអគ្គរដ្ឋទូត ។ នោះក៏ជាលើកទី១ដែលខ្ញុំបានចូលទៅក្នុងពិភពការទូត ។ ដូចរាល់ៗដងលោកបណ្ឌិត ឆាយ ហាន់ចេង ជាអ្នកបើកបររថយន្តនាំពួកយើងទៅកាន់ស្ថានទូត ចំណែកឯខ្ញុំៗមានភារកិច្ចជាអ្នកកត់ត្រាការពិភាក្សាទាំង

[145] Ieng Mouly, Compte-rendu de l'entretien du Président du FNLPK avec l'Ambassadeur des Etats Unis en France, Paris, le 19 mars 1982.

មូលរវាងលោកតា និង លោកទូតសហរដ្ឋអាមេរិក ។ តាមពិតទៅ នៅក្នុងជំនួបនោះ លោកតា សឺន សាន បានទៅសុំជំនួយមនុស្សធម៌មានថ្នាំពេទ្យ សំលៀកបំពាក់ និង គ្រាប់រំសេវ សំរាប់កងទ័ព និង ប្រជារាស្ត្រនៃភូមិរំដោះគឺភូមិសុខសាន្ត១ និង សុខសាន្ត២ ដែលត្រូវកងទ័ពហាណូយវាយកំទេច ។ លោក តា សឺន សានក៏បានធ្វើការថ្កោលទោសកងទ័ពវៀតណាម ដែលបានប្រើប្រាស់អាវុធគីមី នៅពេលវាយប្រហារមកលើភូមិរបស់រ.ជ.រ.ប.ខទាំងនោះ ។ លោកតាសន្យាជាមួយលោកទូតសហរដ្ឋអាមេរិកថា នៅពេលណាបានលទ្ធផលពីមន្ទីរពិសោធន៍ស្តីពីជាតិគីមីទាំងនោះ លោកតានឹងផ្សព្វផ្សាយជាសាធារណៈ ។

នៅក្នុងពេលលោកតា សឺន សាន ស្នាក់អាស្រ័យនៅប្រទេសបារាំង ខ្ញុំក៏បានជួយរៀបចំសន្និសីទកាសែតជាច្រើន ជូនលោកតានៅទីក្រុងប៉ារីស និង បានជូនដំណើរលោកតាប្រធាន ទៅធ្វើទស្សនកិច្ចតាមខេត្តនានា ។ នៅរាល់ការប្រជុំជាសាធារណៈទាំងឡាយ លោកតា សឺន សាន តែងបង្ហាញរូបខ្ញុំ និង លោក ប៉ែន ថាល់ ចំពោះអ្នកចូលរួមទាំងឡាយថាជាអ្នកស្មគ្រគិត្ត ទៅធ្វើការតស៊ូនៅសមរភូមិមុខ ។ តាមពិតទៅ លោកតា សឺន សាន ក៏មានផែនការពង្រឹងបុគ្គលិកផ្ទាល់របស់លោកតាឲ្យបានឆាប់រហ័សដែរ ដើម្បីត្រៀមទទួលការងារដែលនឹងមានកាន់តែច្រើនឡើងៗបន្ទាប់ពីការបង្កើតរដ្ឋាភិបាលចម្រុះ និង ដើម្បីត្រៀមទទួលជំនួយបរទេសដែលអាចនឹងកើនឡើងនោះ ។ វត្តមានរបស់ខ្ញុំនៅក្បែរលោកតា និង នៅលើសមរភូមិមុខ អាចនឹងជួយលោកតាឲ្យកាន់តែក្តាប់បានកាន់តែខ្លាំងឡើងនូវចលនា រ.ជ.រ.ប.ខ.ដែលកំពុងតែមានការរីកចំរើន ។ ការប្រជុំជាសាធារណៈចុងក្រោយបង្អស់បានធ្វើឡើងនៅទីក្រុងទូលូហ្ស (Toulouse) ដែលក្នុងចំណោមសមាជិក រ.ជ.រ.ប.ខ. ខ្ញុំមានមិត្តភក្តិជាច្រើននាក់ ។

ខ្ញុំ និង បង ប៉ែន ថាល់ ចេញទៅសមរភូមិ

ការចេញដំណើររបស់អ្នកស្ម័គ្រចិត្តលើកនេះ មិនដូចការចេញដំណើរមុនៗទេ ការចេញដំណើររបស់ពួកយើងគឺ លោក ប៉ែន ថាល់ និង ខ្ញុំ ត្រូវបានផ្សព្វផ្សាយតាមទំព័រសារព័ត៌មាន ។ តាមការរៀបចំទុកជាមុន ពួកយើងត្រូវចេញដំណើរពីទីក្រុងប៉ារីសទៅទីក្រុងបាងកក នៅថ្ងៃទី ១៨ ឧសភា ១៩៨២ ។ ក៏ប៉ុន្តែ លោកតា សឺន សាន ត្រូវបានចេញដំណើរទៅមុន ព្រោះលោកតាត្រូវប្រញាប់ទៅមើលការខុសត្រូវលើការចរចាបង្កើតរដ្ឋាភិបាលចម្រុះ ។ ចំពោះរូបខ្ញុំ ខ្ញុំពុំបានត្រៀមលក្ខណៈអ្វីពិសេសសំរាប់ការចេញដំណើរនោះទេ លើកលែងតែខ្ជប់យកសៀវភៅ និង ខោអាវខ្លះៗតែប៉ុណ្ណោះ ព្រោះខ្ញុំត្រូវប្រគល់ផ្ទះរបស់ខ្ញុំនោះទៅប្រគេនព្រះតេជគុណព្រះគ្រូ ស សាស្ត្រ ឲ្យព្រះអង្គប្រើប្រាស់ជាកុដិបណ្តោះអាសន្នរបស់ព្រះអង្គ ទម្រាំលោកនិមន្តទៅគង់នៅវត្តណាមួយ ។ ដូច្នេះ ខ្ញុំក៏ប្រមែប្រមូលរបស់របររបស់ខ្ញុំដែលគ្មានអ្វីក្រៅពីសៀវភៅមើល ខោអាវក្រាស់ៗសំរាប់រដូវរងារ ឯកសារប្រចាំគ្រួសារ និង កែវ ចានល្អៗខ្លះ ទុកដាក់ក្នុងហិបដែកធំៗពីរ រួចយកទៅផ្ញើទុកក្នុងផ្ទះលោកទេព ដារ៉ុង ។ ខ្ញុំសំរេចលក់រថយន្ត Renault 5 Le Car របស់ខ្ញុំឲ្យបងរបស់ដារ៉ុងឈ្មោះ ទេព សំប៊ុនណា តែសុំឲ្យគាត់ចាំទទួលយករថយន្តនោះ នៅឯអាកាសយានដ្ឋាន នៅថ្ងៃខ្ញុំឡើងយន្តហោះតែម្តង ។

នៅល្ងាចថ្ងៃសៅរ៍ទី ១៥ ឧសភា ១៩៨២ លោកតា លឹម គ្រី អតីតរដ្ឋមន្ត្រីយុត្តិធម៌ (សម័យសង្គមរាស្ត្រនិយម) ប្រធានការិយាល័យផ្សាយព័ត៌មានរបស់ រ.ជ.រ.ប.ខ.ប្រចាំទីក្រុងប៉ារីស បានរៀបចំពិធីជប់លៀងលាគ្នាមួយជូនជាកិត្តិយសដល់រូបខ្ញុំ និង លោក ប៉ែន ថាល់ ។ ដោយមានសមាជិកចូលរួមប្រហែល ៥០ នាក់ ។ នោះជាឱកាសដ៏រំភើបសំរាប់រូបខ្ញុំ នៅពេលដែលលោកតា លឹម គ្រី ថ្លែងសង្កថា

ដោយឥតព្រាងទុកលើកសរសើរសេចក្តីក្លាហាន ព្រមទាំងលើកកំពស់ពលីកម្មដល់អាយុជីវិតរបស់ពួកយើងទាំងពីរនាក់ ។ ជាការឆ្លើយតប ចំពោះការកោតសរសើរទាំងនេះ បង ប៉ែន ថាល់ ស្នើឲ្យខ្ញុំនិយាយជំនួស ។ ខ្ញុំក៏ក្រោកឡើង រួចហូតចេញពីហោប៉ៅអាវនូវអត្ថបទសរសេរដៃមួយច្បាប់ ដែលខ្ញុំបានត្រៀមជាស្រេច ។ ខ្ញុំបានសំដែងនូវមនោសញ្ចេតនាដឹងគុណ ចំពោះសហសេវិកទាំងឡាយដែលបានធ្វើការជាមួយគ្នាអស់រយៈពេលជាច្រើនឆ្នាំ និង ចំពោះមិត្តភាពដែលបានផ្តល់ដល់ពួកយើង ព្រមទាំងចំពោះស្មារតីស្នេហាជាតិដែលគេមានចំពោះប្រទេសជាតិ ព្រោះថាសហសេវិកទាំងអស់នោះ សុទ្ធតែបានចំណាយពេលវេលាដ៏មានតម្លៃធនធានប្រាក់កាស និង សម្ភារៈ ដើម្បីចូលរួមគាំទ្រការតស៊ូដ៏ឃ្លាតឆ្ងាយសំរាប់ប្រជាជាតិយើង ។ សុន្ទរកថារបស់ខ្ញុំមានន័យជាអាទិថា៖[146] "ក្នុងកាលៈទេសៈដែលប្រទេសជាតិកំពុងត្រូវបរទេសជិះជាន់កាន់កាប់ដូចសព្វថ្ងៃនេះ យើងជាកុលបុត្រខ្មែរមានករណីយកិច្ចធ្វើពលីកម្ម ដើម្បីជួយស្រោចស្រង់កេរដំណែលដូនតាយើងកុំឲ្យសាបសូន្យ ។ យើងទាំងអស់គ្នា បានឆ្លើយតបទៅនឹងសេចក្តីត្រូវការនៃមាតុប្រទេស ដោយសុខចិត្តជួយឧបត្ថម្ភទាំងខាងសម្ភារៈ ទាំងខាងសតិអារម្មណ៍ដល់ការតស៊ូរបស់ប្រជារាស្ត្រយើង ដោយចូលមករួបរួមក្នុងជួររណសិរ្សជាតិរំដោះប្រជារាស្ត្រខ្មែរ" ។ នៅពេលខ្ញុំអានសុន្ទរកថានេះចប់ ខ្ញុំក៏បានលើកយកមកបន្ថែមនូវពាក្យស្លោករបស់អ្នកដឹកនាំជាតិបារាំងសម័យសង្គ្រាមលោកទី១ ឈ្មោះលោក ហ្សក ក្លេម៉ង់សូ (Georges Clemenceau) ដែលមានសេចក្តីជាអាទិថា៖ "បើធ្វើត្រឹមតែជាវីរបុរសមិនទាន់គ្រប់គ្រាន់ទេ អ្វីដែលយើងចង់បានគឺ ជ័យជំនះនៅក្នុងសង្គ្រាម" ។

នៅព្រលានយន្តហោះនាថ្ងៃទី ១៨ ឧសភា ១៩៨២ មានជនជាតិខ្មែរប្រមាណ ១០០ នាក់ មកជូនដំណើររបស់ពួកយើង ។ ថ្ងៃនោះ ជាព្រឹត្តិការណ៍ប្រវត្តិ

[146] អៀង មូលី អត្ថបទសរសេរដៃ គ្មានចុះថ្ងៃ ខែ ។

សាស្ត្រមួយសំរាប់ជីវិតខ្ញុំ ។ ក្នុងចំណោមហ្វូងមនុស្ស ខ្ញុំសង្កេតឃើញឥស្សរជនមួយក្រុមដឹកនាំដោយលោកតា ស៊ឹម វ៉ា អតីតនាយករដ្ឋមន្ត្រី និង ជាអ្នកនយោបាយប្រឆាំងសម្តេច សីហនុ យ៉ាងស្លាប់រស់មួយរូប ។ ក្នុងនោះ ក៏មានព្រះសង្ឃជាច្រើនអង្គដែលនិមន្តមកសូត្រជយន្តោ ប្រោះព្រំផ្តល់ពរជ័យដល់ពួកយើង សុំឲ្យយើងទាំងពីរនាក់ទទួលជ័យជំនះគ្រប់យ៉ាង។ លោកតា ស៊ឹម វ៉ា សំដែងការកោតសរសើរចំពោះសេចក្តីសំរេចរបស់ខ្ញុំ ក្នុងការលះបង់ភាពសុខស្រួលនៅទីក្រុងប៉ារីស ដើម្បីទៅធ្វើការតស៊ូនៅសមរភូមិមុខ ដោយលោកតាមានប្រសាសន៍ថា៖ "ការលះបង់នេះជាសេចក្តីស្នេហាជាតិមាតុភូមិដ៏បរិសុទ្ធបំផុត" ។ នៅពេលច្រើនខែក្រោយបន្ទាប់មក លោកតា ស៊ឹម វ៉ា បានសរសេរសំបុត្រមួយច្បាប់មកខ្ញុំមានសេចក្តីជាអាទិ ថា៖ "ដោយសារអ៊ុំមានអាយុច្រើន អ៊ុំពុំមានលទ្ធភាពធ្វើការលះបង់ (payer le luxe) ទៅនៅសមរភូមិមុខ ដើម្បីបំរើមាតុភូមិយើងបានឡើយ" ។ មិត្តខ្ញុំ រ៉ូឡង់ រូស្សូ (Roland Rousseau) ដែលបានមកជូនដំណើរដែរនោះ មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ព្រោះឃើញមនុស្សច្រើនពេក មកជូនពរពួកយើង ។ លោក សុខ វ៉ាន់ធី ម្ចាស់ភោជនីយដ្ឋាន "នាគទិសខាងជើង" (Dragon du Nord) បានមកចាប់ដៃខ្ញុំចាប់ហើយចាប់ទៀត មិនចង់លែងប្រកបដោយពាក្យពេចន៍សោកស្តាយ ដោយការបែកគ្នា ព្រមទាំងជូនពរឲ្យជួបតែជ័យជំនះ ។ នៅពេលហៀបនឹងឡើងយន្តហោះ បង វ៉ាន់ធី ចាប់ដៃខ្ញុំ បង្ខំឲ្យខ្ញុំដោះនាឡិកាដៃខ្ញុំម៉ាក Timex មានតម្លៃ ១០០ ហ្វ្រង់ ទៅឲ្យគាត់ ។ ខ្ញុំមានការភ្ញាក់ផ្អើលដែរ ដោយមិនដឹងគាត់ចង់យកទៅធ្វើអ្វី បើនាឡិកានោះ មានតម្លៃថោកយ៉ាងនេះ ។ ក៏ប៉ុន្តែបង វ៉ាន់ធី និយាយថាទុកជាវត្ថុអនុស្សាវរីយ៍ ។ នៅពេលខ្ញុំហុចនាឡិកាខ្ញុំទៅឲ្យគាត់ៗក៏ហុចនាឡិកាគាត់មកឲ្យខ្ញុំវិញទុកជាការដោះដូរគ្នា ។ នៅពេលនោះ ខ្ញុំមិនបានចាប់អារម្មណ៍អ្វីប៉ុន្មានទេចំពោះនាឡិ

ការបស់បង វ៉ាន់ធី នោះ ខ្ញុំក៏ពាក់ជាប់នៅដៃភ្លាម ។ ក្រោយមក ទើបខ្ញុំដឹងថានាឡិកានោះ មានតម្លៃជិតពីរម៉ឺនដុល្លារឯនោះ ព្រោះជានាឡិកាម៉ាករ៉ូឡិច (Rolex) ។

យើងទាំងពីរនាក់បង ប៉ែន ថាល់ និង ខ្ញុំ បានលាមិត្តភក្តិអ្នកជូនដំណើរទាំងអស់ ដោយក្តីអាឡោះអាល័យ ។ បន្ទាប់មក យើងនាំគ្នាដើរទៅបញ្ជរអន្តោប្រវេសន៍ ដើម្បីឲ្យនគរបាលត្រួតពិនិត្យឯកសារធ្វើដំណើរ និង បោះទិដ្ឋាការចេញ រួចនាំគ្នាអង្គុយរង់ចាំយន្តហោះ នៅក្នុងបរិវេណតំបន់អន្តរជាតិនៅសាលរង់ចាំ ។ នៅពេល ដែលយើងកំពុងរង់ចាំឡើងជិះយន្តហោះនោះ យើងក៏ឃើញមិត្តនារីរបស់យើងម្នាក់ឈ្មោះនាង ដាវ៉ាវិចិត្រ បានមកដល់ ព្រោះតែចង់ជួបមុខពួកយើងនៅនាទីចុងក្រោយ ។ នៅពេលនោះ យើងពុំបានដឹងថា ដាវ៉ាវិចិត្រ បានដើរតាមពីក្រោយពួកយើងជាប់រហូត ដោយពុំមានប័ណ្ណសំគាល់ខ្លួនអ្វីមកជាប់នឹងខ្លួនឡើយ ។ ប៉ុន្តែយើងដឹងថានាង ដាវ៉ាវិចិត្រ ជាអ្នកពូកែនិយាយ បានមាត់បានក អាចបញ្ចុះបញ្ចូលនគរបាលអន្តោប្រវេសន៍ឲ្យអនុញ្ញាតឲ្យនាងឆ្លងកាត់តំបន់ត្រួតពិនិត្យបាន ។ ក៏ប៉ុន្តែនៅពេលដែលពួកយើងចូលទៅក្នុងយន្តហោះបាត់ទៅ ហើយនៅពេលត្រូវវិលត្រឡប់ចេញទៅវិញនោះ នាង ដាវ៉ាវិចិត្រ ក៏ត្រូវឆ្លងកាត់តំបន់ត្រួតពិនិត្យម្តងទៀត ។ ម្តងនេះនគរបាលអន្តោប្រវេសន៍ជាអ្នកត្រួតពិនិត្យថ្មី មិនបានដឹងថាតើនាងត្រូវបានអនុញ្ញាតឲ្យឆ្លងកាត់តំបន់អន្តរជាតិដោយមាត់ទទេទេនោះ ក៏បានសួរកប័ណ្ណសំគាល់ខ្លួន ។ ដោយគ្មានប័ណ្ណសំគាល់ខ្លួនជាប់មកជាមួយ ដាវ៉ាវិចិត្រ ក៏ត្រូវនគរបាលឃាត់ខ្លួន អស់រយៈពេលជាច្រើនម៉ោង នៅក្នុងវាលយន្តហោះ ហ្សាល ដឺហ្គោល (Charles de Gaulle) ។ មែនទែនទៅ ខ្ញុំដឹងរឿងវ៉ាវថា ដាវ៉ាវិចិត្រត្រូវប៉ូលីសបារាំងឃាត់ខ្លួននេះ បន្ទាប់ពីពួកយើងបានធ្វើដំណើរមកដល់ទីក្រុងបាងកកតាមរយៈសំបុត្រ ដែលដាវ៉ាវិចិត្រ ផ្ញើមកពួកយើងតាមក្រោយតែប៉ុណ្ណោះ ។

បង ប៉ែន ថាល់ ថាៈ កុំឲ្យបាត់បង់សេចក្តីថ្លៃថ្នូរ

នៅលើយន្តហោះ ខ្ញុំកាន់តែស្គាល់បង ប៉ែន ថាល់ ច្បាស់ឡើងៗគឺគាត់ជាអ្នកចេះដឹងជ្រៅជ្រះណាស់ ។ គាត់ធ្លាប់បានសិក្សានៅទីក្រុងទូលូហ្ស(Toulouse) មានសញ្ញាប័ត្រជាន់ខ្ពស់ខាងផ្នែកពាណិជ្ជកម្ម និង ចេះភាសាបារាំង និង អង់គ្លេសយ៉ាងស្ទាត់ជំនាញ ។ នៅក្នុងរយៈពេលនៃការហោះហើរ ទោះបីជាពួកយើងទិញសំបុត្រយន្តហោះថ្នាក់ថោកជាងគេ (Economy class) យ៉ាងណាក៏ដោយ ក៏បង ប៉ែន ថាល់ ចេះនិយាយបញ្ចុះបញ្ចូលនារីអ្នកបំរើឲ្យមកផ្តល់ឲ្យយើងនូវស្រាសាំប៉ាញ និង ស្រាល្អៗជាបន្តបន្ទាប់ ដែលជាសេវាសំរាប់ថ្នាក់ធុរកិច្ច (Bussiness class) ឬ ថ្នាក់ខ្ពស់ជាងទៀត ។ នៅក្នុងរបប ប៉ុល ពត បង ប៉ែន ថាល់ បានបាត់បង់ប្រពន្ធ និង កូនស្រីជាទីស្រឡាញ់របស់គាត់ ។ តាមរយៈការសន្ទនាគ្នា ខ្ញុំអាចមើលឃើញគាត់ជាមនុស្ស ដែលមានវិបត្តិខាងផ្លូវចិត្តយ៉ាងធំធេង ។ គាត់ច្បាស់ជាទទួលនូវទារុណកម្មដ៏ធ្ងន់ធ្ងរ ដែលតម្រូវឲ្យយកសុរាមកជាគ្រឿងបន្លប់ទុក្ខ ឬ ដើម្បីបំភ្លេចបទពិសោធន៍ដ៏ចុកចាប់ ក្នុងរយៈពេលឆ្លងកាត់នាសម័យរបបប្រល័យពូជសាសន៍ ។ ជាមួយគ្នានោះ ខ្ញុំក៏មើលឃើញភាពក្លាហានអង់អាចមុះមុតរបស់គាត់ដែរ ។ ទើបតែរំដោះខ្លួនផុតពីរបប ប៉ុល ពត មិនទាន់បានប៉ុន្មានផង ឥឡូវគាត់ស្ម័គ្រចិត្តចូលមកបំរើ រ.ជ.រ.ប.ខ. នៅសមរភូមិមុខ ទុកចោលកូនប្រុសម្នាក់រស់នៅជាមួយមិត្តភក្តិឯទីក្រុងប៉ារីសទៀតផង ។ ភ្លាមៗនោះ យើងទាំងពីរនាក់ ក៏កាន់តែមានភាពជិតស្និទ្ធគ្នាឡើងក្នុងមិត្តភាព និង ភាតរភាព ។ បង ប៉ែន ថាល់ និយាយដោយសង្កត់ពាក្យថាៈ "ប្អូនប្រុស យើងអាចបាត់បង់អ្វីៗទាំងអស់បាន តែយើងមិនអាចបាត់បង់សេចក្តីថ្លៃថ្នូរបានឡើយ" ។ "ឥឡូវយើងសុខចិត្តដាក់ជីវិតយើងរៀងៗខ្លួននៅក្នុងកន្ត្រកតែមួយគឺ យើងជិះទូកតែមួយជាមួយគ្នា" ។

នៅលើអាកាសវេហា ខ្ញុំគិតមមៃតែទៅលើការតស៊ូរំដោះជាតិ រំដោះកម្ពុជាពីការកាន់កាប់របស់បរទេស រំដោះប្រជារាស្ត្រខ្មែរឲ្យមានសេរីភាព និង លទ្ធិប្រជាធិបតេយ្យ ។ ខ្ញុំអត់បាននឹកឃើញឧបសគ្គអ្វីទាំងអស់ ឬ អំពីបារាំយអ្វីនៅក្នុងការតស៊ូនេះឡើយ ។ ម្យ៉ាងទៀត ខ្ញុំក៏មិនមានគំនិតអ្វីជាក់លាក់ថាតើការតស៊ូរំដោះជាតិនេះត្រូវការពេលវេលាវែងរហូតដល់ណាដែរទេ ។ ក៏ប៉ុន្តែ ខ្ញុំមានគំនិតមួយយ៉ាងសាមញ្ញ គឺ ខ្ញុំនឹងដាក់ផុកជីវិតខ្ញុំក្នុងរយៈពេល ១០ ឆ្នាំ ។ ខ្ញុំស្ម័គ្រចិត្តចំណាយពេល ១០ ឆ្នាំ ដើម្បីមកបំរើចលនាតស៊ូ ជាពិសេស រ.ជ.រ.ប.ខ. ដោយគ្មានគំនិតចង់បានអ្វីក្រៅតែចង់ឃើញទឹកដីដូនតាខ្មែរមកជាទឹកដីខ្មែរវិញ និង ប្រជាពលរដ្ឋខ្មែរមានសិទ្ធិសំរេចវាសនាខ្លួនដោយខ្លួនឯងតែប៉ុណ្ណោះ ។ មែនទែនទៅ គំនិតខ្ញុំនាសម័យនោះជាគំនិតផ្សងព្រេងពេកណាស់ ។ ដំណឹងដែលថា ម្តាយខ្ញុំនៅរស់រានមានជីវិតនៅឡើយ ធ្វើឲ្យខ្ញុំមានកម្លាំងចិត្តយ៉ាងខ្លាំង ។ ខ្ញុំគិតថាអំណោះតទៅ ខ្ញុំក៏អាចចូលទៅជួយរំដោះម្តាយបង្កើតខ្ញុំ និង ទៅចូលរួមរំដោះទឹកដីកំណើតរបស់ខ្ញុំមកវិញផង ។ មកដល់ចំណុចនេះខ្ញុំហាក់ដូចជាមានកាតព្វកិច្ចមួយដែលត្រូវតែបំពេញ ជាពិសេសនៅពេលដែលខ្ញុំនឹកដល់សំបុត្ររបស់បងស្រី ទេពធីតា ដែលសរសេរជាអាទិថាៈ "ទោះជាត្រូវជន្លៀសទៅនៅស្រុកស្រែក៏ដោយ ក៏ពុក(ឪពុករបស់ខ្ញុំ)នៅតែថ្វាយបង្គំព្រះសំបូងសំរូងបន់ស្រន់សូមឲ្យទេវតា និង វត្ថុសក្តិសិទ្ធិទាំងឡាយក្នុងលោកតាមជួយថែរក្សារូបប្អូន(រូបខ្ញុំ) ឲ្យបានសេចក្តីសុខគ្រប់ប្រការដើម្បីប្អូន អាចមកជួយរំដោះពួកយើងឲ្យរួចពីកណ្តាប់ដៃពួកផ្តាច់ការ...." ។

ខកចិត្ត ពេលជាន់ទឹកដីថៃ ថ្ងៃដំបូង

នៅព្រឹកថ្ងៃទី ១៩ ឧសភា ១៩៨២ យន្តហោះរបស់យើងក៏បានមកចុះចតនៅអាកាសយានដ្ឋានដ៏ធំមឿង ទីក្រុងបាងកកនៃប្រទេសថៃ ។ មិនដូចជាអ្នក

ដំណើរធម្មតាឯទៀតៗទេ ពួកយើងមានមនុស្សរង់ចាំនៅជណ្តើរយន្តហោះ ។ នៅជាមួយមន្ត្រីថៃម្នាក់ ខ្ញុំក្រឡេកឃើញលោក នាង ជិនហន អគ្គលេខាធិការ រ.ជ.រ.ប.ខ. កំពុងនាំគ្នាចាំទទួលពួកយើង ។ បន្ទាប់ពីសំដែងការគួរសមរវាងគ្នារួចហើយ លោក នាង ជិនហន (និយាយជាភាសាបារាំងដ៏ឥតខ្ចោះរបស់គាត់) បានបង្ហាញពួកយើងដល់មន្ត្រីថៃនោះ ដែលមានឋានន្តរសក្តិជាវរសេនីយឯក (សក្តិប្រាំ) តែមានសំលៀកបំពាក់ស៊ីវិល ។ លោកសក្តិប្រាំថៃនេះជាមន្ត្រីយោធាដែលមានតួនាទីមើលការខុសត្រូវលើក្រុមអ្នកតស៊ូរ.ជ.រ.ប.ខ.យើង ។ គាត់មានទឹកមុខញញឹមញញែមរាក់ទាក់នឹងពួកយើងណាស់ ។ យើងស្គាល់តែឈ្មោះសំងាត់របស់គាត់ ដែលគាត់ប្រើប្រាស់សំរាប់ធ្វើទំនាក់ទំនងជាមួយពួកយើងតែប៉ុណ្ណោះ យើងមិនស្គាល់ឈ្មោះពិតប្រាកដរបស់គាត់ទេ ។ ពួកយើងត្រូវបានណែនាំឲ្យហៅលោកសក្តិប្រាំថា៖ "លោក ម៉ុល" ។

លោក ម៉ុល ប្រមូលលិខិតឆ្លងដែនរបស់យើងយកទៅបោះត្រាទិដ្ឋាការនៅការិយាល័យអន្តោប្រវេសន៍ រួចនាំពួកយើងទៅយកវ៉ាលីស ។ បន្ទាប់មក គាត់នាំពួកយើង ដើរទៅរកថយន្តដ៏ចំណាស់របស់គាត់ ។ ទោះជាមានឋានន្តរសក្តិរហូតដល់ថ្នាក់វរសេនីយឯក ដែលជាឋានៈជាន់ខ្ពស់មួយរបស់កងទ័ពថៃយ៉ាងណា ក៏ដោយ ក៏លោក ម៉ុល មិនមានអ្នកបើកបរទេ ។ គាត់បររថយន្តដោយខ្លួនឯង ។ លោក ម៉ុល នាំពួកយើងមកឆ្ងាយពីព្រលានយន្តហោះដនមឿង ឆ្ពោះទៅកាន់តំបន់មួយឈ្មោះបាងកកណាយ ។ បន្ទាប់ពីឆ្លងកាត់ផ្លូវដ៏ចង្អៀតជាច្រើន យើងក៏ចូលផ្លូវធំមួយឈ្មោះ ចារ៉ាន់ សានិតវង្ស (Charan Sanitwong) រួចបត់ចូលច្រកមួយឈ្មោះ "សយ" (Soi) លេខ ២២ គឺ សយ រដ្ឋាសា (Soi 22 Rathasa) ។ ចូលតាមច្រកនោះ ប្រហែលមួយរយម៉ែត្ររថយន្តក៏ឈប់នៅមុខកូមិគ្រឹះមួយ ដែលមានរបងព័ទ្ធជុំវិញយ៉ាងជិត ដែលគេពុំអាចមើលឃើញសកម្មភាពអ្វីនៅខាងក្នុងបរិ

វេណបានឡើយ ។ ភ្លាមនោះទ្វាររបងក៏បើកឡើង លោក ម៉ុល បររថយន្តចូលទៅ ឈប់ខាងក្នុង ។ យុវជនខ្មែរពីរនាក់ ចេញមកទទួលពួកយើង និង ជញ្ជូនវ៉ាលីស ចេញពីរថយន្ត ។ ទីបំផុត ពួកយើងក៏បានធ្វើដំណើរមកទីដៅរបស់យើង ។

ភូមិគ្រឹះនេះ ដែលមានលក្ខណៈមិនប្លែកពីផ្ទះអ្នកស្រុកសាមញ្ញឯទៀត នៅ ក្នុងតំបន់នោះ ជាទីស្នាក់ការធំរបស់ រ.ជ.រ.ប.ខ. និង និវេសនដ្ឋានរបស់លោកតា សឺន សាន និង សហការីសំខាន់ៗរបស់លោកតាប្រចាំនៅទីក្រុងបាងកក ។ ផ្ទះនេះ ត្រូវបានជួលពីមន្ត្រីយោធាថៃមួយរូបទៀតគឺ លោកវរសេនីយឯក ស៊ុជិនដា ក្រាប្រា យង្គ (Suchinda Kraprayung) ដែលនៅពេលនោះ មានតួនាទីជានាយទាហាន ទី២ បន្ទាប់ពីលោកឧត្តមសេនីយ ធាវលិត ។ នៅទសវត្សរ៍ឆ្នាំ ១៩៩០ លោក ស៊ុជិនដា ឡើងឋានៈរហូតដល់នាយឧត្តមសេនីយ (ផ្កាយ ៤) និង ឡើងកាន់ តំណែងជានាយករដ្ឋមន្ត្រីផង ។ ចំណែកលោក ម៉ុល វិញ ក្រោយមក ទើបយើងដឹង ឈ្មោះពិតប្រាកដថា សុម៉េធ ទៀនផេង (Sumet Tiengpheng) ។ ក្នុង ទសវត្សរ៍ឆ្នាំ ១៩៩០ គាត់ឡើងដល់ឧត្តមសេនីយត្រី (ផ្កាយ២) រហូតដល់ចូល និវត្តន៍ ។ តាមភាសាថៃ គេហៅត្រឹមឧត្តមសេនីយត្រី តែតាមពិតមានផ្កាយពីរ ព្រោះ ក្នុងកងទ័ពថៃគ្មានសក្តិផ្កាយមួយទេ នៅក្រោមផ្កាយពីរមានតែថ្នាក់វរសេនីយ ឯកពិសេសតែប៉ុណ្ណោះ ។

ពួកយើងមកដល់ចំពេលអ្នកនៅក្នុងផ្ទះ កំពុងស្រស់ស្រូបអាហារពេល ព្រឹក ។ នៅតុបាយ ខ្ញុំក្រឡេកឃើញលោកឧត្តមសេនីយ សក់ ស៊ុតសាខន កំពុង អង្គុយពិសាកាហ្វេផង និង ជក់បារីហុយទ្រលោមផង ។ លោកឧត្តមសេនីយ សក់ ស៊ុតសាខន ធ្លាប់ធ្វើជាមេដឹកនាំកំពូលចុងក្រោយគេបង្អស់នៃរបបសាធារណរដ្ឋ របស់លោក លន់ នល់ ។ បន្ទាប់ពីការដួលរលំនៃរបបសាធារណរដ្ឋ លោកឧត្តមសេ នីយបានទៅរស់នៅមួយរយៈឯសហរដ្ឋអាមេរិក ។ ប៉ុន្មានខែមុន គាត់បានស្ម័គ្រចិត្ត

មកបំរើរ.ដ.រ.ប.ខ. ។ នៅពេលដែលលោកឧត្តមសេនីយកំពុងពិសាការហ្វេនោះ យើងក៏ដឹងថា នៅឯជាន់ខាងលើផ្ទះ លោកតា សឺន សាន កំពុងជាប់រវល់ត្រៀមចេញដំណើរទៅទីក្រុងតូក្យូនៃប្រទេសជប៉ុន ។ ពេលឃើញពួកយើងភ្លាម អ្នកស្រី សួន កាសេត មានសេចក្តីត្រេកអរណាស់ ជាពិសេស ពេលឃើញបង ប៉ែន ថាល់ ដែលអ្នកស្រីធ្លាប់ស្គាល់ជាយូរមកហើយ ។ អ្នកស្រី សួន កាសេត ហៅបង ប៉ែន ថាល់ ថា "បងថាល់ៗ" យ៉ាងពេញមាត់ បង្ហាញពីភាពស្និទ្ធស្នាលរវាងអ្នកទាំងពីរ ។ អ្នកស្រីក៏ត្រូវប្រញាប់ចេញដំណើរជាមួយលោកតា សឺន សាន ទៅទីក្រុងតូក្យូដែរ ។ លោកតា សឺន សាន ក៏មានការរីករាយ ដោយឃើញយើងមកដល់ តែលោកតាគ្មានពេលនិយាយលេងជាមួយពួកយើងឲ្យបានច្រើនទេ ព្រោះប្រញាប់ចេញដំណើរ ។ លោកតាផ្តាំឲ្យបង ប៉ែន ថាល់ ទៅសំរាកនៅក្នុងបន្ទប់ជាមួយគាត់ ព្រោះនៅមានគ្រែទំនេរមួយ ។ ចំណែករូបខ្ញុំ លោកតាទុកឲ្យអគ្គលេខា នាង ជិនហន ចាត់ចែងរកកន្លែងឲ្យ ។ ក៏ប៉ុន្តែលោកអគ្គលេខា ហាក់ដូចជាមិនសូវរវល់អើពើអ្វីប៉ុន្មានទេ ។ គាត់និយាយបែបប្រហើរថានៅខាងលើបែបមានកន្លែងទំនេរ ។ លោក ប៊ុន សាយ និង លោក ហ៊ីង គន្ធុន ដែលយើងធ្លាប់មានទំនាក់ទំនងល្អជាមួយគ្នា ក៏ហាក់ដូចជាមិនសូវអើពើចំពោះវត្តមានរបស់ពួកយើងដែរ ។ ពួកគាត់និយាយមករកពួកយើងបែបចុងមាត់ចុងក ។ សំដែងភាពរាក់ទាក់ជាងគេមករកខ្ញុំ ហាក់ដូចជាធ្លាប់ស្គាល់គ្នាជាយូរមកហើយគឺលោកឧត្តមសេនីយ សក់ ស៊ុតសាខន ។ លោកឧត្តមសេនីយប្រាប់ឲ្យខ្ញុំនៅជាមួយគាត់នៅជាន់ខាងលើ ។ នៅពេលដែលគណៈប្រតិភូចេញទៅព្រលានយន្តហោះផុតទៅ ដោយមានលោក ម៉ុល ជាអ្នកជូនដំណើរផង ពួកយើងក៏នាំគ្នាឡើងទៅជាន់ខាងលើ ។ បង ប៉ែន ថាល់ ចូលទៅក្នុងបន្ទប់របស់លោកតា សឺន សាន ដែលនៅជ្រៅទៅខាងក្នុងផ្ទះ ហើយដែលនៅចំពីមុខបន្ទប់មួយទៀតជាទីដែលលោក ហ្គាហ្វា ស្នាក់នៅផង ធ្វើការផង ។ ខ្ញុំ និង លោកឧត្តមសេនីយ សក់

ស៊ុតសាខន ស្នាក់នៅក្នុងបន្ទប់ដែលទំនងជាបន្ទប់ទទួលភ្ញៀវដ៏ធំល្ហល្ហៅ ព្រោះគ្មានតុទូអ្វីទាំងអស់ លើកលែងតែគ្រែបត់មួយ និង ទូខោអាវរុំព័ទ្ធដោយសំពត់កៅស៊ូមួយដែលជារបស់ផ្ទាល់ខ្លួនរបស់លោកឧត្តមសេនីយ ។ នៅជាន់ខាងក្រោម គេបានរៀបចំឲ្យមានបន្ទប់ទទួលភ្ញៀវ ដែលនៅទីនោះលោកតា សឺន សាន អាចទទួលភ្ញៀវសំខាន់ៗបាន ។ ជាមួយនោះដែរក៏មានបន្ទប់ប្រជុំ និង ការិយាល័យរបស់លោកអគ្គលេខា នាង ជិនហាន និង បុគ្គលិករបស់គាត់ ព្រមទាំងបន្ទប់បាយ និង បន្ទប់ទឹក ។

ឥឡូវនៅជាន់ខាងលើ ខ្ញុំអាចទម្រេតខ្លួនបានព្រោះមានកន្លែងទូលំទូលាយ ប៉ុន្តែគ្មានខ្នើយ ភួយ មុង កន្ទេល ពូក ឬ កន្សែង ឬ ក្រមាឡើយ ។ ដូច្នេះសេចក្តីត្រូវការជាបន្ទាន់របស់ខ្ញុំគឺ ត្រូវប្រញាប់ប្រញាល់ទៅផ្សារ ដើម្បីស្វែងរកទិញរបស់ប្រើប្រាស់ដ៏ជាចាំបាច់ទាំងនោះ ។ យុវជនម្នាក់ ក្នុងចំណោមយុវជនពីរនាក់ ដែលបានបើកទ្វាររបងចាំទទួលស្វាគមន៍ពួកយើង បានសុខចិត្តនាំខ្ញុំទៅទិញរបស់របរទាំងអស់នោះ នៅឯផ្សារក្នុងតំបន់ក្បែរផ្ទះ ។ យុវជននោះ ជាជនពិការដៃជើងម្ខាងដោយសារគ្រាប់មីនឈ្មោះ សុវណ្ណ ។ សុវណ្ណ មានរាងមាំ សម្បុរខ្មៅលក្ខណៈខ្មែរ ទឹកមុខញញឹម និយាយមករកពួកយើងដោយមានការគួរសមជានិច្ច ។ សុវណ្ណចេះនិយាយភាសាថៃបានយ៉ាងស្ទាត់ជំនាញ ។ សុវណ្ណ បានត្រូវអនុញ្ញាតឲ្យមករស់នៅៗទីស្នាក់ការកណ្តាលរបស់រ.ជ.រ.ប.ខ. នៅទីក្រុងបាងកក ព្រោះនោះគឺជាគុណបំណាច់ចំពោះពលីកម្ម ដែលយុវជននេះបានបំពេញជូនរណសិរ្ស ។ ក្នុងភាពយុវវ័យ ទោះបីជាទទួលរងគ្រោះដាច់ដើងយ៉ាងណាក៏ដោយ ក៏យើងហាក់មើលមិនឃើញនូវពិការភាពរបស់គេដែរ ព្រោះសុវណ្ណពាក់ដើងសិប្បនិមិត្ត និង ដើរបានស្មើល្អដូចមនុស្សធម្មតាយ៉ាងដូច្នោះ ។

ខ្ញុំទៅទិញអីវ៉ាន់ប្រើប្រាស់ ដោយចាយវាយប្រាក់ផ្ទាល់ខ្លួនឯងព្រោះខ្ញុំគិតថានេះជារឿងកំប៉ិកកំប៉ុកផ្ទាល់ខ្លួនតែប៉ុណ្ណោះ ។ ធាតុអាកាសពេលព្រឹកនៅទីក្រុង

បាងកក ហាក់ដូចជាក្តៅស្អុះស្អាប់ខ្លាំងណាស់ ព្រោះខ្ញុំខានជួបរដូវក្តៅបែបនេះអស់រយៈពេលជាង ៩ ឆ្នាំមកហើយ ។ ខ្ញុំបែកញើសជាប់ ដូច្នេះជាញឹកញយខ្ញុំតែងតែបបួលអ្នកដើរជាមួយឲ្យចូលក្នុងហាង ឬ ទីកន្លែងណាដែលមានម៉ាស៊ីនត្រជាក់ ។ ក៏ប៉ុន្តែ ដោយហេតុថាពួកយើងដើរតាមផ្លូវតូចៗនោះ រានលក់អីវ៉ាន់ទាំងឡាយគ្មានម៉ាស៊ីនត្រជាក់ទេ ដូច្នេះទាល់តែពួកយើងដើរទៅតាមផ្លូវធំៗ ទើបមានហាង និង សណ្ឋាគារ ឬ អាគារដែលមានម៉ាស៊ីនត្រជាក់ ។ តែទោះជាយ៉ាងណាក៏ដោយ ក៏ខ្ញុំចូលចិត្តគយគន់មើលមនុស្សម្នាទាំងឡាយដែលកំពុងធ្វើដំណើរកកកុញតាមផ្លូវ ។ ព្រោះខ្ញុំឃើញហ្វូងមនុស្សទាំងនោះ មានមុខមាត់ហាក់ដូចជាជនជាតិខ្មែរយើងដែរ ។ នៅពេលនោះ ខ្ញុំគួរសោរភាពថាសម្រស់នារីជនជាតិថៃហាក់មិនទាន់ទាក់ទាញអារម្មណ៍របស់ខ្ញុំនៅឡើយទេ ព្រោះភ្នែកខ្ញុំនៅមានទម្លាប់គាប់ចិត្តតែទៅលើនារីអឺរ៉ុបនៅឡើយ ។ ខ្ញុំមើលមិនឃើញនារីថៃស្អាតទាល់តែសោះ ។ ស្អាតយ៉ាងដូចម្តេច បើច្រមុះកំពិតៗយ៉ាងនេះ ដោយភ្លេចគិតថាខ្លួនខ្ញុំក៏មានច្រមុះកំពិតដែរ ។ នារីថៃអ្នកលក់មានអាកប្បកិរិយារួសរាយរាក់ទាក់ និង គួរសមទន់ភ្លន់គួរឲ្យចូលចិត្ត ។

សុវណ្ណ បានប្រាប់ពួកយើងឲ្យប្រយ័ត្នកុំឲ្យពួកថៃដឹងថា ពួកយើងជាជនជាតិខ្មែរ ។ ក៏ប៉ុន្តែ នៅពេលនិយាយគ្នាជាមួយសុវណ្ណនោះ យើងមិនអាចនិយាយអ្វីក្រៅពីភាសាខ្មែរបានឡើយ ព្រោះសុវណ្ណមិនចេះបារាំង ឯយើងក៏មិនចេះថៃ ។ ដូច្នេះ នៅពេលឮយើងនិយាយជាមួយ សុវណ្ណ ពួកនាងៗអ្នកលក់តែងសួរ សុវណ្ណ ថា និយាយភាសាអ្វី? សុវណ្ណឆ្លើយបំភ្លៃថានិយាយភាសា "ម៉ាឡេ ភូមា ឬ ហ្វីលីពីន ជាដើម" ។ សុវណ្ណមិនចង់ឲ្យពួកគេដឹងថាពួកយើងជាខ្មែរ ព្រោះបើកាលណាពួកថៃដឹងថាយើងជាខ្មែរ ពួកគេនឹងមើលងាយពួកយើងភ្លាម ។ ពួកថៃ ចាត់ទុកជនភៀសខ្លួនខ្មែរ ជាមនុស្សថោកទាបជាងខ្លួន ។

ខ្ញុំចូលចិត្ត និង ជក់អារម្មណ៍លើស្ថាបត្យកម្មរបស់ថៃ ជាពិសេស វត្តអារាម និង អាគារសាធារណៈ ដែលមានរចនាបថប្រហាក់ប្រហែលខ្មែរយើងដែរ ហើយ ដែលខ្ញុំខានជួបប្រទះអស់រយៈពេលច្រើនឆ្នាំមកហើយ ។ បើគិតពីឆ្នាំ ១៩៧៣ ដែលខ្ញុំបានស្គាល់ទឹកដីថៃជាលើកដំបូងរហូតមក ខ្ញុំឃើញប្រទេសថៃមានការផ្លាស់ប្តូរច្រើនណាស់ មានការលូតលាស់គួរឲ្យកត់សំគាល់ ។ ចំណុចនេះ ធ្វើឲ្យខ្ញុំនឹកស្រណោះស្រុកខ្មែរ នឹកដល់ការខូចខាតរបស់ខ្មែរដែលជាមហាវិនាសកម្មមួយក្នុងរយៈពេលប៉ុន្មានទសវត្សរ៍នេះ ដោយសារសង្គ្រាម និង ដោយសារអស្ថិរភាពនយោបាយ និង អំណាចផ្តាច់ការ ។

នៅក្នុងអវត្តមានរបស់លោកតា សឺន សាន ខ្ញុំមានអារម្មណ៍ថា ពួកយើងហាក់ដូចជាមិនបានទទួលការស្វាគមន៍ឲ្យបានកក់ក្តៅឡើយ ទោះជាយើងមកដល់ចំថ្ងៃដ៏ក្តៅហែងនាខែ ឧសភា នោះយ៉ាងណាក៏ដោយ ។ កាលពីម្តេចួនម៉ោងមុនពេលយើងចេញដំណើរពីទីក្រុងប៉ារីសមក សន្ទុះទឹកចិត្តយើងឡើងខ្ពស់ត្រដែតរហូតដល់យើងប្តេជ្ញាថាលះបង់អ្វីៗទាំងអស់ ទាំងអាយុជីវិត ដើម្បីធ្វើការតស៊ូសង្គ្រោះប្រជាពលរដ្ឋ និង ប្រជាជាតិខ្មែរ ។ ក៏ប៉ុន្តែ ភាពប៉ក់រវើយដែលយើងបានទទួលនៅពេលមកដល់ទីក្រុងបាងកក បានធ្វើឲ្យខ្ញុំសន្និដ្ឋានថាអ្នកដែលមកមុនយើង ប្រហែលមិនជឿថាយើងមកធ្វើការតស៊ូដើម្បីជាតិទេ ពួកគេគ្មានជំនឿលើសុឆន្ទៈរបស់ពួកយើងឡើយ ។ អ្នកទាំងនោះ ប្រហែលជាយល់ថាពួកយើងអាចនឹងធ្វើឲ្យពួកគេបាត់បង់មុខមាត់ បុណ្យសក្តិ ឬ ឥទ្ធិពលដែលគេកំពុងមាននៅក្នុងរង្វង់រ.ជ.រ.ប.ខ.មិនខានឡើយ ។ ពួកគេប្រហែលជាយល់ថាពួកយើងអាចមកដណ្តើមតួនាទី ឬ ការងាររបស់ពួកគេមិនខានឡើយ ។ មែនទែនទៅ នៅពេលនោះ មិនមែនតែពួកយើងដែលទើបមកថ្មីនេះទេ ដែលពួកគេមានការសង្ស័យ សូម្បីតែ ឧត្តមសេនីយ សក់ ស៊ុតសាខន ដែលមកដល់មុនពួកយើង ក៏ទទួលស្វាគមន៍ដ៏

សោះកក្រោះមិនខុសពីពួកយើងដែរ ។ លោកឧត្តមសេនីយ សក់ ស៊ុតសាខន អតីតអ្នកទទួលខុសត្រូវខ្ពស់បំផុតជាចុងក្រោយនៃរបបសាធារណរដ្ឋខ្មែរ ក៏បានជួបបញ្ហាមិនទុកចិត្តគ្នានេះដែរ ពីសំណាក់យុទ្ធមិត្តដែលបានចូលមកធ្វើការមុន ។ ពួកគេវាយតម្លៃពួកយើងថា ជាមនុស្សរបស់លោកតា សឺន សាន មិនមែនមកធ្វើការតស៊ូក្នុងគំនិតលះបង់អ្វីទេ តែទំនងជាមកតាមផែនការពង្រឹងក្រុមលោកតាប្រឆាំងតទល់ជាមួយក្រុមមួយ ទៀតគឺ ពួកកូមុិច ដែលមាន លោក ជៀន ដែល លោក ហ៊ឹង គន្ធន និង លោក នាង ជិនហន ជាមេខ្លោង ។ ជាសំណាងល្អដែរដែល បង ប៉ែន ថាល់ ធ្លាប់ស្គាល់ និង មានភាពជិតស្និទ្ធជាមួយអ្នកទាំងបីនាក់នោះ ទើបទីបំផុតពួកអស់លោកទាំងនោះ បានទទួលស្គាល់រូបខ្ញុំថាជា "ប្អូនប្រុសម្នាក់របស់ ប៉ែន ថាល់" ។

ច្បាស់ណាស់ហើយថាក្រុមយោធាថៃបានអនុញ្ញាតឲ្យអ្នកដឹកនាំរ.ជ.រ.ប.ខ. រស់នៅ និង ដឹកនាំចលនាតស៊ូពីទីក្រុងបាងកក ។ អ្នកដឹកនាំរបស់យើងសម័យនោះធ្វើដំណើរញឹកញាប់ពីបាងកកទៅទល់ដែនខ្មែរថៃ ឬ ទៅក្នុងទឹកដីខ្មែរតែម្តង ។ កាលពួកយើងនៅទីក្រុងប៉ារីស ពេលណាគេនិយាយអំពីតំបន់រំដោះ ឬ អំពីធ្វើការក្នុងតំបន់រំដោះ យើងមិនដែលគិតថា តំបន់រំដោះទាំងនោះមានរួមទាំងទីក្រុងបាងកកឡើយ ។ យើងស្មានតែតំបន់រំដោះទាំងអស់សុទ្ធតែនៅក្នុងទឹកដីខ្មែរទាំងអស់ ។ តាមការគ្រប់គ្រងរបស់យោធាថៃ ពួកយើងត្រូវរស់នៅក្នុងផ្ទះសុវត្ថិភាពមួយ ដែលមានការការពារ ឬ យាមកាមដោយយោធាថៃម្នាក់ ឬ ពីរនាក់ស្លៀកពាក់ជាជនស៊ីវិល និង ដែលគ្មានកាន់អាវុធ ។ យោធាថៃនោះអាចធ្វើជាអ្នកយាមការពារយើងផង ឬ អាចធ្វើជាអ្នកបើកបរឲ្យយើងផង ។ យើងមិនអាចចេញក្រៅផ្ទះ ដែលយើងហៅថាផ្ទះសុវត្ថិភាព ដោយគ្មានការអនុញ្ញាត ឬ ដោយគ្មានការជូនដំណើរពីយោធាថៃយ៉ាងហោចណាស់ក៏មួយនាក់បានឡើយ ។ ជាទូទៅ ពួកយើងអាចចេញក្រៅផ្ទះ

បានតាមរថយន្ត ដោយមានយោធាថៃជាអ្នកបើកបរឲ្យឬទៅជាមួយពួកគេ ។ យើងមានទម្លាប់ហៅអ្នកបើកបរឲ្យយើងនោះ ដែលជាយោធាថា "ហួណា" ។ ពាក្យថៃ "ហួ" មានន័យថា "ក្បាល" រីឯពាក្យ "ណា" ថា "មុខ" បានន័យថា "អ្នកដឹកមុខ" ឬ "អ្នកដឹកនាំ" ។ ដោយសារពួកយើងស្ថិតនៅក្រោមការគ្រប់គ្រងរបស់យោធាថៃ យើងហៅទាហានថៃទាំងអស់ថា "ហួណា" គឺ តាំងពីអ្នកបើកបរហូតដល់លោក ម៉ុល ឬ ឧត្តមសេនីយ ធាវលិត ថា ហួណា ហួណា ទាំងអស់ ។

នៅសម័យនោះ រដ្ឋាភិបាលថៃមានគោលនយោបាយប្រឆាំងយ៉ាងខ្លាំងក្លា ចំពោះជនអន្តោប្រវេសន៍ខុសច្បាប់មកពីប្រទេស កម្ពុជា លាវ និង វៀតណាម ។ ប្រសិនបើប៉ូលីសថៃ ឆែកឆេរទៅឃើញថា ជនជាតិណាមួយ ក្នុងចំណោមជនជាតិមកពីប្រទេសទាំងបី គ្មានច្បាប់អនុញ្ញាតឲ្យស្នាក់នៅ ឬ គ្មានឯកសារបញ្ជាក់អត្តសញ្ញាណទេនោះ ជននោះនឹងត្រូវឃាត់ខ្លួនរួចបញ្ជូនទៅពន្ធនាគារតែម្តង ។ ជនជាតិខ្មែរដែលផ្សងសំណាងលបលួចរស់នៅដោយខុសច្បាប់ នៅក្រៅជំរុំកៀសខ្លួន ឬ នៅទីក្រុងបាងកក ត្រូវស្ថិតនៅក្រោមការភ័យខ្លាចជារៀងរាល់ថ្ងៃ ។ ពួកគេខ្លាចប៉ូលីសចាប់ឃុំ ឬ ចាប់ដាក់គុក ។ គួរកត់សំគាល់ថាខ្មែរយើងភាគច្រើន មានមុខមាត់ប្រហាក់ប្រហែលជនជាតិថៃដែរ ។ ពួកគេអាចធ្វើដំណើរទៅទីណាក៏បាន ប្រសិន បើគ្មានការឆែកឆេរកអត្តសញ្ញាណប័ណ្ណ ឬ ប្រសិនបើគ្មាននរណាដឹងថាជាជនជាតិខ្មែរ ។ ក៏ប៉ុន្តែ ប្រសិនបើមានថៃណានិយាយរកខ្មែរយើងដែលចេះភាសាថៃ ខ្មែរយើងនោះ អាចនិយាយថៃបាន ដោយមានសំនៀងប៉ែឡាំ ដែលអាចឲ្យគេសង្ស័យថា ជាជនបរទេសបាន ។ ជនជាតិថៃភាគច្រើនៗតែរាយការណ៍ទៅប៉ូលីសភ្លាម កាលបើដឹងថាមានជនសង្ស័យខុសច្បាប់ដូចជាខ្មែរយើងជាដើម ។ ប៉ូលីសនឹងធ្វើការឆែកឆេរភ្លាម ។ ខ្មែរយើងដែលរស់នៅខុសច្បាប់ក្នុងទឹកដីថៃ មានការភ័យខ្លាចណាស់ ។ យ៉ាងនេះ ទើប សុវណ្ណ ហាមមិនឲ្យពួកយើងភ្លាត់ភ្លេចខ្លួនឲ្យគេដឹង

ថាយើងជាជនជាតិខ្មែរ ទោះបីជាយើងមកពីប្រទេសបារាំងក៏ដោយ ។ ម្យ៉ាងយើងដើរដោយមានតែខ្មែរគ្នាយើង ដោយគ្មានទាហានថៃ "ហួណា" មកជាមួយផង ។ ម្យ៉ាងទៀត យើងក៏គ្មានឯកសារសំគាល់ខ្លួននៅជាប់នឹងខ្លួនផង ព្រោះលោក ម៉ុល ដែលបានយកលិខិតឆ្លងដែនរបស់យើង ទៅបោះត្រាទិដ្ឋាការចូលប្រទេសថៃនោះ បានទុកឯកសារនោះ មិនប្រគល់ឲ្យត្រឡប់មកយើងវិញទេ ។ ដូច្នេះ ពួកយើងក៏មានលក្ខណៈមិនខុសពីជនភៀសខ្លួនខ្មែរឯទៀត ដែលនៅក្រៅច្បាប់ដែរ ដែលប៉ូលីសថៃអាចឆែកឆេរ និង ចាប់ខ្លួនបានគ្រប់ពេលវេលា ។ ក៏ប៉ុន្តែ បន្ទាប់ពីមានការបង្កើតរដ្ឋាភិបាលចម្រុះត្រីភាគីរួចមក នៅឆ្នាំ ១៩៨២ ទើបលោក ម៉ុល ប្រគល់ឯកសារធ្វើដំណើររបស់យើងមកវិញទាំងអស់ ។

ចាប់ពីថ្ងៃទីមួយដែលខ្ញុំជាន់ទឹកដីថៃនៅទីក្រុងបាងកក ខ្ញុំហាក់ដូចជាចាប់ផ្តើមលោតចូលទៅក្នុងតំបន់ក្តៅគគុកនៃភ្នក់ភ្លើងសង្គ្រាម ។ ខ្ញុំគិតថា បើខ្ញុំមិនអាចធ្វើដំណើរដោយសេរីផង តើខ្ញុំអាចបំពេញបេសកកម្មរបស់ខ្ញុំដោយជោគជ័យដៃឬទេ? ខ្ញុំចេះតែគិតហើយគិតទៀតថា បើយើងស្ថិតនៅក្រោមការគ្រប់គ្រងរបស់យោធាថៃបែបនេះ តើយើងអាចពង្រីកចលនាតស៊ូរបស់យើងឲ្យធំធាត់តទៅទៀតបានឬទេ? មានសំណួរជាច្រើនចោទឡើងនៅក្នុងខួរក្បាលរបស់ខ្ញុំ ដូចជាថាតើយើងត្រូវដោះស្រាយបញ្ហាមិនយល់ចិត្តគ្នាមិនទុកចិត្តគ្នា ជាមួយសហសេវិកទាំងឡាយដែលបានចូលមកបំរើ.ជ.រ.ប.ខ.មុនយើងយ៉ាងដូចម្តេច?ចំណោទទាំងនេះ ធ្វើឲ្យខ្ញុំខ្វល់ខ្វាយយ៉ាងខ្លាំង នេះមិនទាន់និយាយដល់រូបភាពធំនៃការតស៊ូរបស់យើងមួយទៀត គឺ សង្គ្រាមរំដោះជាតិ និង សង្គ្រាមទប់ទល់កុំឲ្យពួកខ្មែរក្រហមវិលត្រឡប់មកកាន់អំណាចវិញផង ។ ដោយសារធាតុអាកាសក្តៅផង ដោយសារខុសពេលវេលាគ្នារវាងម៉ោងពេលប្រទេសបារាំង និង ប្រទេសថៃផង ខ្ញុំដេកមិនលក់សោះ ។ ជាមួយនោះ នៅមានសម្លេងរំខានរបស់ "តុកតុក" រថកង់បី ដែលបើកកាត់មុខផ្ទះមិនដាច់

មកបន្ថែមទៀត ។ ជាការគួរឲ្យចាប់អារម្មណ៍ រាល់រថកង់បី "តុកតុក" តែងតែរោទ៍ ម៉ាស៊ីនបង្កើនល្បឿន នៅពេលមកដល់ផ្ទះរបស់ពួកយើង ។ ទោះយ៉ាងណាក៏ដោយ ខ្ញុំសំរេចចិត្តប្តេជ្ញាធ្វើអ្វីៗក្នុងឋានៈជាកុលបុត្រម្នាក់របស់កម្ពុជា ។ រាល់បញ្ហាសុទ្ធតែមានដំណោះស្រាយ ទោះតាមរូបភាពអ្វីក៏ដោយ ។

លោកតា យិន អ៊ុច (ជីតាខ្ញុំខាងម្តាយ) ១៨៩០?-១៩៥០
(លោកតា ទទួលមរណភាពនៅពេលខ្ញុំនៅជាទារកនៅឡើយ)



លោកយាយ ហ៊ូ ឌិ (ជីដូនខ្ញុំខាងឪពុក)
(លោកយាយទទួលមរណភាពច្រើនឆ្នាំ
មុនខ្ញុំចាប់កំណើតមកម្ល៉ះ)



លោកយាយ អ៊ុង គូ
(ជីដូនខ្ញុំខាងម្តាយ ១៨៩៥-១៩៧៩
លោកយាយទទួលមរណភាពក្នុងជន្មាយុ ៨៤ ឆ្នាំ
ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩)



ឪពុកខ្ញុំឈ្មោះ អៀង មុត (១៩១៥ -១៩៧៥)

(ទទួលមរណភាពនៅសម័យ ប៉ុល ពត ដោយអត់អាហារក្នុងជន្មាយុ ៦០ ឆ្នាំ)



ម្តាយខ្ញុំឈ្មោះ អ៊ុច សុខា (១៩២៦-២០១២)
(ទទួលមរណភាពក្នុងជន្មាយុ ៨៦ ឆ្នាំ ដោយជរាពាធ)



បងប្រុសទី១ ឈ្មោះ អៀង ឈឿន
(ហៅបងនាង ស្លាប់កាលអាយុ ៣២ ឆ្នាំ)



បងប្រុសទី២ ឈ្មោះ អៀង ស៊ីនឿន
(ហៅបងផាត ស្លាប់កាលអាយុ ៣០ ឆ្នាំ)



ប្អូនប្រុសឈ្មោះ អៀង ណារ៉ើន
(ស្លាប់កាលអាយុ ១៨ ឆ្នាំ)

ប្អូនប្រុសឈ្មោះ អៀង វុធឿន
(ស្លាប់កាលអាយុ ១៥ ឆ្នាំ)

(បងប្អូនទាំងអស់នេះ ត្រូវបានរបប ប៉ុល ពត យកទៅសម្លាប់)

ក្រុមយុវនៃនិស្សិតមហាវិទ្យាល័យពាណិជ្ជសាស្ត្រឆ្នាំសិក្សា ១៩៦៦-៦៨

ទស្សនកិច្ចសិក្សានៅទីក្រុងកែប នៅឆ្នាំ ១៩៦៧
រូបពីឆ្វេងទៅស្តាំគឺ៖ អៀង មូលី ស៊ុន សារ៉ុម នូ វ៉ាន់ថន
និង សារុន ឈឿន

កន្លែងហ្វឹកហាត់នៃកងទ័ពចលនាតស៊ូមិនមែនកុម្មុយនីស្ត នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៧០
នៅតំបន់ភ្នំបន្ទាត់ មុនការបង្កើតកងទ័ពជាតិរំដោះប្រជាពលរដ្ឋខ្មែរ



ប្រជាពលរដ្ឋខ្មែរដែលជួបប្រទះភាពអត់ឃ្លាន នាំគ្នាធ្វើដំណើរមកកាន់តំបន់ជាយដែន
ខ្មែរ-ថៃ ដើម្បីស្វែងរកជំនួយខាងផ្នែកស្បៀង និង ថ្នាំសង្កូវ បន្ទាប់មក
គេនាំគ្នាជីកជញ្ជួនជំនួយមនុស្សធម៌ទាំងនោះចូលមកក្នុងប្រទេសវិញ



អតីតនាយទាហានជាន់ខ្ពស់នៃរបបសាធារណរដ្ឋ និង អ្នកតស៊ូមួយចំនួន
កំពុងជួបជុំគ្នានៅទីក្រុងបាងកកប្រទេសថៃ នៅដើមឆ្នាំ ១៩៧៩
ដើម្បីសិក្សារកវិធីបង្កើតកងទ័ពជាតិរំដោះប្រជាពលរដ្ឋខ្មែរ
រូបពីឆ្វេងទៅស្តាំ ទី១ លោក អ៊ឹម ឈូដេត ទី២ លោក ចក់ បូរី និង ទី៣ លោក ជៀន ដែល
(កំពុងអានឯកសារ) រូបនៅខាងស្តាំបំផុត (កំពុងអានឯកសារដែរ) លោក កែវ ជួន
ប្រធានចលនាបក្សីចាំក្រុង មានដំរុំនៅក្នុងស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ក្បែរស្រុកណាំយឺន
ខេត្តឧប៊ុនរ៉ាចថានី ប្រទេសថៃ

ពីឆ្វេងទៅស្តាំរូបទី៣ លោក អ៊ឹម ឈូដេត លោក សេក សំអៀត
លោក ជៀន ដែល និង លោក កែវ ជួន

លោក ជៀន ដែល (ពាក់វ៉ែនតា) ចែកអំណោយដល់ជនភៀសខ្លួនខ្មែរនៅដើមឆ្នាំ ១៩៨០
(តាមបណ្តោយទល់ដែនខ្មែរ-ថៃ)

(រូបពីឆ្វេងទៅស្តាំ) លោក ហ្គាហ្សា, លោក អៀជួ គិមម៉េង
លោក ចក់ បូរី និង លោក ព្រុំ វិត

ពីធីសច្ចាប្រណិធានរបស់កងទ័ព នៅទសវត្សរ៍ឆ្នាំ ១៩៨០

និង ពិធីសច្ចាប្រណិធាននៃកម្មសិក្សាការីនៃសាលាសង្គ្រាមនយោបាយ

សមាជជាតិលើកទី១ នៃរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ
បានប្រារព្ធឡើងនៅលើទឹកដីខ្មែរ កាលពីខែ មេសា ១៩៨០
ដោយមានការចូលរួមពីថ្នាក់ដឹកនាំ តំណាងប្រជាពលរដ្ឋ កងកម្លាំងប្រដាប់អាវុធ និង
អ្នកសារពត៌មានអន្តរជាតិ

រូបពីឆ្វេងទៅស្តាំនៅជួរខាងមុខ៖ លោក អ៊ឹម ឈូដេត លោក ហ៊ីង គុន្តុន
លោក ជៀន ដែល (ក្នុងឯកសណ្ឋានយោធា) និង លោកតាប្រធាន សឺន សាន
កំពុងថ្លែងទៅកាន់អង្គសមាជ

នៅទសវត្សរ៍ឆ្នាំ ១៩៧០ មានការជួបជុំបងប្អូនខ្មែរ នៅទីក្រុង ម៉ង់ ឡាស្លូលី (Mantes-la-Jolie) ប្រទេសបារាំង

រូបពីស្តាំទៅឆ្វេង៖ រូបទី១ លោក ឡុក សែម ទី២ រូបអ្នកនិពន្ធ (អៀង មូលី) ទី៣ លោក ផាន់ សូរីយាស៊ី និង រូបទី ៤ លោក សុខ ឌីវថ្លៃន

ដំណើរកំសាន្ត ក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ នៅទីក្រុងមាត់សមុទ្រ ឌៀព (Dieppe) រូបថតអ្នកនិពន្ធរាប់ពីឆ្វេងទៅស្តាំ ទី៣ អង្គុយជួរខាងមុខ

សកម្មភាពបំរើរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ នៅប្រទេសបារាំង និង អឺរ៉ុប

វាគ្មិនក្នុងអង្គប្រជុំផ្តល់ពត៌មាន ជូនជនរួមជាតិខ្មែរនៅទីក្រុងប៉ារីស នារដូវក្តៅឆ្នាំ ១៩៨០
រូបពីឆ្វេងទៅស្តាំ៖ ទី១ អ្នកនិពន្ធ (អៀង មូលី)
ទី២ លោកអតីតនាយករដ្ឋមន្ត្រី ស៊ឹម វ៉ា ទី៣ លោកអតីតរដ្ឋមន្ត្រីទី១ សឺន សាន
និង ទី៤ លោកអតីតនាយករដ្ឋមន្ត្រី ឈាន វ៉ែម

សន្និសីទកាសែតនៅប្រទេសហុល្លង់រួមជាមួយលោកតា សឺន សាន

ចូលរួមក្នុងគណៈប្រតិភូ រ.ជ.រ.ប.ខ. ទៅប្រជុំអង្គការសហប្រជាជាតិនៅទីក្រុងញ៊ីវយ៉ក នាទសវត្សរ៍ឆ្នាំ ១៩៨០ (ថតជាមួយលោក ចាយ សេរីវុឌ្ឍ)

ដឹកនាំគណប្រតិភូមកពីសាយធូ ទៅចូលរួមប្រជុំនៅប្រទេសបារាំងឆ្នាំ ១៩៨៤ រូបដូរទី១ និង ទី២ ពីស្តាំទៅឆ្វេង ភិក្ខុ ហេង មណីចិន្តា និង អ្នកនិពន្ធ (អៀង មូលី)

នៅទីស្នាក់ការ រ.ជ.រ.ប.ខ. នៅម៉ាយ៉ាឡាប់ ទីក្រុងបាងកក នៅពេលទទួលទានអាហារ
ពេលព្រឹក (ឆ្នាំ ១៩៨៣)

រូបពីឆ្វេងទៅស្តាំ៖ ទី១ លោកឧត្តមសេនីយ សក់ ស៊ុតសាខន (កំពុងអានសារពត៌មាន)
ទី២ លោក ប៉ែន ថាល់ និង ទី៣ លោក ស៊ូ គិមស៊ុន

អ្នកនិពន្ធ (អៀង មូលី) កំពុងថ្លែងទៅកាន់ជនភៀសខ្លួន នៅជំរុំណាំយឺន ឬ បក្សីចាំក្រុង
នៅពេលដែលលោក ប៉ែន ថាល់ និង កែវ ជួន អង្គុយស្តាប់ជាមួយអ្នកដឹកនាំឯទៀត (ឆ្នាំ ១៩៨៣)

រូបភាពសំណង់ខ្លះ នៅក្នុងជំរុំអំពិល នៅឆ្នាំ ១៩៨៤ នៅលើទឹកដីខ្មែរ

សេនាធិការរបស់តំបន់ប្រតិបត្តិការសឹក ២០៣

សាលាបឋមសិក្សាស្រោចស្រង់

សកម្មភាពទ្រទ្រង់ព្រះពុទ្ធសាសនានៅជំរុំ សាយធូ ទសវត្សរ៍ឆ្នាំ ១៩៨០-១៩៩០

រូបអ្នកនិពន្ធ ថ្លែងសង្កថា នៅពេលដែលព្រះគ្រូ ពិន សែម និង លោក ប៉ែន ថុល កំពុងស្តាប់

ពិធីចែកសញ្ញាបត្រនៅជំរុំសាយធូ

ទស្សនកិច្ចរបស់អ្នកនិពន្ធ (អៀង មូលី) នៅជំរុំប្រទ្វិសែន (ឆ្នាំ ១៩៨៤)

កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ នៅជំរុំសាយធូ (ឆ្នាំ ១៩៨៥)

ដំណើរទស្សនកិច្ចនៅក្នុងតំបន់រំដោះ

ការពិភាក្សាជាមួយលោកមេបញ្ជាការ ខូ ឈា នៅទីបញ្ជាការឈានមុខក្នុងទឹកដីខ្មែរចម្ងាយ ៤ គ.ម ពីជំរុំសាយធូ មុននឹងធ្វើដំណើរចូលទៅក្នុងតំបន់បន្ទាយឆ្មារ-ថ្មពួក (ខែធ្នូ ១៩៩០)

យើងធ្វើដំណើរតាមម៉ូតូ

ទស្សនកិច្ចនៅក្នុងតំបន់រំដោះ

រូបពីឆ្វេងទៅស្តាំ ៖ រូបទី២ លោកបណ្ឌិត ឡៅ ម៉ុងហៃ រូបទី៤ លោក ប៉ែន ថុល រូបទី៥ លោក ឡាយ ខែក រូបទី៦ លោក សុគន្ធ រូបទី៧ អ្នកនិពន្ធ (អៀង មូលី) (ខែធ្នូ ១៩៩០)

អ្នកនិពន្ធ (អៀង មូលី) និង លោក ឡាយ ខែក កំពុងពិនិត្យការខ្វះខាតពាងស្តុកទឹក នៅតំបន់ថ្មពួក

នៅឆ្នាំ១៩៩០ បានទទួលយុទ្ធជនដែលចូលមករួបរួម ឈប់ច្បាំងគ្នានៅលើទឹកដីខ្មែរ

ត្រួតពិនិត្យគ្រឿងសព្វាវុធដែលប្រមូលបានពីទីលានប្រយុទ្ធ

ចុះសួរសុខទុក្ខប្រជាពលរដ្ឋនៅតំបន់ឆ្ពួក បន្ទាយឆ្មារ ឆ្នាំ ១៩៩០



លើកទឹកចិត្តកុមារឲ្យខំរៀនសូត្រ

ទស្សនកិច្ចនៅតំបន់រំដោះ (ថ្ពក-បន្ទាយឆ្មារ ខែ ធ្នូ ១៩៩០)



ទស្សនកិច្ចនៅប្រាសាទ បន្ទាយឆ្មារ



នេះជាទស្សនកិច្ចលើកទី៣ ដែលខ្ញុំបានធ្វើនៅប្រាសាទបន្ទាយឆ្មារ លើកទី១ នៅឆ្នាំ ១៩៨៣ លើកទី២ នៅឆ្នាំ ១៩៨៩ និង នៅពេលនេះនៅឆ្នាំ ១៩៩០



វគ្គទី ៧
លោកអគ្គលេខា
(ទសវត្សរ៍ឆ្នាំ ១៩៨០-១៩៩០)

តួនាទីជាអគ្គលេខាធិការនៃ រ.ជ.រ.ប.ខ. ជាតួនាទីដ៏សំខាន់មួយនៅក្នុងរណសិរ្សទោះបីជាតួនាទីនោះ គ្មានសិទ្ធិបោះឆ្នោតក្នុងការសំរេចណាមួយរបស់គណៈកម្មាធិការប្រតិបត្តិ ឬ កូមុិច យ៉ាងណាក៏ដោយ ។ អគ្គលេខាធិការជា អ្នកសំរបសំរួលការងារទាំងអស់ទាំងផ្នែកហិរញ្ញវត្ថុ នយោបាយ ការទូត និង រដ្ឋបាល ។ អគ្គលេខាធិការជាតំណាងរបស់ រ.ជ.រ.ប.ខ. នៅចំពោះមុខអាជ្ញាធរថៃ ជាពិសេសចំពោះក្រុមយោធាថៃដែលទទួលបន្ទុកការងារកម្ពុជា ។ នៅពេលអវត្តមានរបស់ប្រធាន និង នៅក្នុងករណីដែលអនុប្រធានអសកម្ម អគ្គលេខាជាមនុស្សទីពីរនៅតាមខ្សែបញ្ជានៃចលនាតស៊ូរបស់យើង ។ តាមធម្មតា អគ្គលេខាជាមនុស្ស ជិតជិតបំផុតរបស់ប្រធាន ដែលត្រូវតែធ្វើការជាមួយគ្នាយ៉ាងស្អិតរមួត ទើបអាចទទួលជោគជ័យបាននៅក្នុងបេសកកម្មដើម្បីបុព្វហេតុជាតិ ។ ក៏ប៉ុន្តែ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ ដោយសារកត្តាមួយចំនួន ទំនាក់ទំនងរវាងលោកតា សឺន សាន និងលោកអគ្គលេខា នាង ជិនហន ត្រូវបានធ្លាក់ដល់កំរិតមួយ ដែលធ្វើឲ្យបាត់បង់នូវការទុកចិត្តគ្នាទៅវិញទៅមក រហូតបង្កើតបានជាទំនាស់ផ្ទៃក្នុងដែលធ្វើឲ្យ រ.ជ.រ.ប.ខ. ក្នុងហានៈជាចលនាតស៊ូអ្នកជាតិនិយមមិនមែនកុម្មុយនីស្តដ៏ធំទៅជាទន់ខ្សោយទៅវិញ ។ នៅទីបំផុត នៅចុងឆ្នាំ ១៩៨៧ លោក នាង ជិនហន ក៏ត្រូវបង្ខំឲ្យបោះបង់ចោលមុខតំណែងដ៏សំខាន់នេះ ។

ពួកជក់ខ្សៀ និង មនុស្សជាភ្នែក ជាត្រចៀករបស់លោកតា

លោក នាង ជិនហន ជាមនុស្សមានសមត្ថភាព សមនឹងទទួលមុខនាទីជាអគ្គលេខារ.ជ.រ.ប.ខ.នេះណាស់ ។ គាត់ជាមន្ត្រីពូកែខាងគ្រប់គ្រងផ្នែករដ្ឋបាល មានជំនាញយ៉ាងច្បាស់លាស់ខាងក្រដាសស្នាម ។ តាំងពីដើមដំបូង គាត់ខំព្យាយាមរៀបចំរបៀបរបបការងាររដ្ឋបាលរបស់ រ.ជ.រ.ប.ខ. ប្រហាក់ប្រហែលគ្នានឹងរបៀបរបបការងាររបស់ប្រទេសដ៏តូចមួយ ដោយមានក្បួនច្បាប់ និង ទំរង់បែបបទច្បាស់លាស់ ទោះជាសេចក្តីសំរេច ឬ ក្រឹត្យ ឬ ក្រមច្បាប់ក្តី ។ លោក នាង ជិនហន បានរៀបរៀងជាសេចក្តីសំរេចមួយចំនួន ដែលក្រោយមកត្រូវបានកែប្រែជាក្រម-ច្បាប់របស់រ.ជ.រ.ប.ខ.។ ទំនាក់ទំនងការងាររដ្ឋបាលនេះ មានគោលបំណងការពារ កុំឲ្យមានការរំលោភអំណាច និង កំណត់បទបញ្ជាសំរាប់ការងាររបស់សមូហភាព ។ គាត់ចេះរៀបចំរចនាសម្ព័ន្ធទាំងអស់របស់ការិយាល័យរ.ជ.រ.ប.ខ. ប្រចាំនៅទីក្រុងបាងកក ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់គាត់ បើមិនជាក់ស្តែងយ៉ាងហោចណាស់ក៏នៅលើក្រដាសដែរ ទាំងនេះរួមទាំងការដាក់ឲ្យនៅក្រោមឱវាទផ្ទាល់របស់គាត់នូវកូនលោកតា សឺន សាន និង មន្ត្រីជំនួយការផ្ទាល់របស់លោកតាប្រធានផង ។

ដើម្បីពង្រឹងកម្លាំងរបស់គាត់បន្ថែមទៀត បន្ទាប់ពីពួកខ្ញុំទៅដល់ទីក្រុងបាងកកភ្លាម លោក នាង ជិន ហន បានសម្រេចផែនការក្នុងការសុំឲ្យលោកតា សឺន សាន ចេញសេចក្តីសំរេចតែងតាំងអគ្គលេខារងពីរនាក់ទៀតគឺ៖ ១. លោក ប៊ុន សាយ ទទួលបន្ទុកខាងហិរញ្ញវត្ថុ និង ២. លោក ហ្គាហ្វា (Gaffar) ទទួលបន្ទុកទំនាក់ទំនងក្រៅប្រទេស (External Relations) ។ បន្ថែមលើនេះ លោក នាង ជិនហន មានភាពជិតស្និទ្ធជាមួយឧត្តមសេនីយ ជៀន ដែល ដែលជាមេទ័ពរបស់

រណសិរ្ស និង ជាមួយលោក ហ៊ីង គន្ធុន ដែលជាសមាជិកគណៈកម្មាធិការប្រតិបត្តិ ឬ កូមុិច ទទួលបន្ទុកផ្នែកសេដ្ឋកិច្ច និង ជាតំណាងកូមុិច ប្រចាំកងទ័ព ។ ឧត្តមសេនីយ ជៀន ដែល និង លោក ហ៊ីង គន្ធុន ភាគច្រើនស្នាក់នៅក្នុងទីបញ្ជាការកងទ័ព រ.ជ.រ.ប.ខ. នៅជំរុំអំពិលលើទឹកដីខ្មែរជាប់នឹងព្រំប្រទល់ថៃ ។ អ្នកដឹកនាំទាំងពីរនាក់នេះ ស្រឡាញ់រាប់អានគ្នាបានល្អណាស់គឺម្នាក់ទទួលបន្ទុកចាត់ការខាងផ្នែកយោធា និង ម្នាក់ទៀត ខាងការងារស៊ីវិល ។

លោក នាង ជិនហាន និង លោក ហ៊ីង គន្ធុន នាំគ្នាបង្កើតជាក្រុមអ្នកជក់ខ្សៀ ព្រោះពួកគាត់ចូលចិត្តជក់ខ្សៀ ដោយអុចបង្គុយថ្នាំជក់មកពីប្រទេសខាងលិច ។ លោក ហ៊ីង គន្ធុន ទទួលទានអាហារតែពីរពេលទេក្នុងមួយថ្ងៃ ដើម្បីជាទីរំលឹកដល់សម័យកំសត់កម្រក្នុងរបប ប៉ុល ពត គឺ អាហារពេលព្រឹក និង អាហារពេលល្ងាច ។ គាត់មិនទទួលទានអាហារថ្ងៃត្រង់ទេ ។ លោក ហ៊ីង គន្ធុន មិនចូលចិត្តទទួលទានបបរសេទេ ព្រោះគាត់យល់ឃើញថាបបរសេជាតំណាងរបប ប៉ុល ពត ។ តាមពិតទៅ លោក នាង ជិនហាន ជាមនុស្សដែលគួរតែក្លាយជាអគ្គលេខាដ៏ល្អសម្រាប់រ.ជ.រ.ប.ខ.នេះណាស់ ។ ក៏ប៉ុន្តែ គាត់បំពេញតួនាទីនេះបានជោគជ័យ ឬ បរាជ័យ អាស្រ័យលើទំនាក់ទំនងរបស់គាត់ជាមួយអាជ្ញាធរថៃផង អាស្រ័យលើទំនុកចិត្តដែលគាត់ទទួលពីលោកតាប្រធានផង។ ក្នុងពេលកន្លងមក លោកអគ្គលេខាបានទទួលការស្រឡាញ់រាប់អានពីលោកតា សឺន សាន តាមរយៈទំនាក់ទំនងល្អ និង ជិតស្និទ្ធរបស់គាត់ជាមួយអ្នកស្រី សួន កាសេត ដែលជាជំនួយការដ៏ស្មោះត្រង់របស់លោកតាប្រធាន ។ អ្នកស្រី សួន កាសេត ត្រូវបានលោកតាចាត់ទុកជាក្មែកជាត្រចៀកផ្ទាល់របស់គាត់គឺ បើអ្នកស្រីថាមនុស្សនេះល្អ លោកតាក៏ថាល្អ បើអ្នកស្រីថាអាក្រក់ លោកតាក៏ថាអាក្រក់ ។ លោក នាង ជិនហាន លោកឧត្តមសេនីយ ជៀន ដែល លោក ហ៊ីង គន្ធុន លោក ហ្គាហ្វា និង លោក ប៊ុន សាយ

បានបង្កើតជាក្រុមមួយ ដែលហាក់ដូចជាអ្នកកាន់អំណាចជាក់ស្តែងនៅក្នុងជួរ រ.ជ.រ.ប.ខ. (នេះប្រសិនបើមានអំណាចមែន) នៅពេលដែលលោកតា សឺន សាន សម្រេចបាននូវការទទួលស្គាល់នៅលើឆាកអន្តរជាតិ និង មានប្រជាប្រិយភាពក្នុងចំណោមអ្នកគាំទ្រ រ.ជ.រ.ប.ខ.ទាំងឡាយ ។

អ្វីដែលហៅថា "ទៅគោរពទង់ជាតិ"

នៅទីក្រុងបាងកក អ្នកធ្វើការក្នុងការិយាល័យរ.ជ.រ.ប.ខ. តែងនាំគ្នាមកទទួលទានអាហារពេលព្រឹក ជុំគ្នានៅជុំវិញតុបួនជ្រុងទ្រវែងមួយយ៉ាងទៀតទាត់ ។ នៅទីនោះ គេផ្តាស់ប្តូរគ្នាទៅវិញទៅមកនូវព័ត៌មាន ដែលគេម្នាក់ៗទទួលបានតាមរយៈការអានសារព័ត៌មាន ស្តាប់វិទ្យុអន្តរជាតិ ឬ តាមទំនាក់ទំនងខាងក្រៅដែលគេម្នាក់ៗទទួលបានរៀងៗខ្លួន ។ ពេលទទួលទានអាហារពេលព្រឹកនោះ ក៏ជាឱកាសឲ្យគេនិយាយពាក្យកំប្លុកកំប្លែងរវាងគ្នា និង គ្នាដែរ ។ ចំពោះមន្ត្រីសំខាន់ៗនៃ រ.ជ.រ.ប.ខ. ពេលទទួលទានអាហារព្រឹករួមគ្នារាល់ៗពេលនេះ ក៏ជាឱកាសឲ្យពួកគេធ្វើការវាយតម្លៃ លើកសរសើរ ឬ ធ្វើការរិះគន់ទៅលើសហការីមួយចំនួនដែរ ជាពិសេស គេតែងធ្វើការរិះគន់ចំពោះអ្នកអវត្តមាននៅពេលនោះ ។ បើនិយាយឲ្យស្រួលស្តាប់ គេនិយាយដើមគ្នា ។ បន្ទាប់ពីទទួលទានអាហារពេលព្រឹករួចហើយ គេនាំគ្នាអានសារព័ត៌មាន ជាពិសេស សារព័ត៌មានបាងកកប៉ុស្ត (Bangkok Post) ឬ ដឺណេស្ជិន (The Nation) ។ លោក នាង ជិនហន ញាប់ដៃញាប់ជើង កាត់ និងថតចម្លងទំព័រកាសែតទាំងនោះ ទុកជាឯកសារប្រចាំថ្ងៃ (Press cutting)។

នៅវេលាម៉ោង ៨ ព្រឹកគត់ គេម្នាក់ៗចូលម្តងម្នាក់ក្នុងបន្ទប់មួយដើម្បីប្រារព្ធពិធីមួយ ដែលគេនិយាយបែបកំប្លែងលេងថា "ទៅគោរពទង់ជាតិ" ។ តាមពិត នៅពេលម៉ោង ៨ រាល់ៗព្រឹក លោកតាប្រធាន សឺន សាន តែងចូលមកដល់បន្ទប់នោះ

ដែលជាធម្មតា ជាបន្ទប់ទទួលទានអាហារផង ជាកន្លែងធ្វើការរបស់លោកតាផង ។ លោកតា អង្គុយនៅនឹងមួយកន្លែង ពិសាអាហារពេលព្រឹករបស់គាត់ ។ ម្នាក់ម្តងៗ មន្ត្រីសំខាន់ៗរបស់រណសិរ្សចូលទៅសំដែងការគួរសម ចំពោះលោកតាប្រធាន និង ធ្វើរបាយការណ៍ជូនគាត់ ចំពោះសភាពការណ៍ទាំងឡាយដែលគេបានដឹង ។ តាម ធម្មតា ប្រសិនបើលោកតាប្រធានមិនទទួលភ្ញៀវទេ លោកតាប្រធានអង្គុយរាប់ ម៉ោងនៅក្នុងបន្ទប់នោះ អានឯកសារផង ឬ ធ្វើការប្រជុំការងារជាមួយក្រុមបុគ្គលិក សំខាន់ៗផង មុននឹងដកថយទៅបន្ទប់ឯកជនរបស់គាត់វិញ ។

នៅពេលបាយថ្ងៃត្រង់លោកតាប្រធានមានវត្តមានម្តងទៀត នៅក្នុងបន្ទប់ អាហារនេះជាថ្មី ដើម្បីពិសាអាហាររួមជាមួយមន្ត្រីសំខាន់ៗដែលមានរូបខ្ញុំផង ។ លោកតាប្រធានមិនចាប់ផ្តើមទទួលទានអាហារទេ ប្រសិនបើមិនទាន់ជុំគ្នា ។ លោក តាប្រកាន់ឥរិយាបថបែបនេះ នៅពេលបាយល្ងាចដែរ ដែលកំណត់យ៉ាងទៀងទាត់ នៅម៉ោង ៧ ល្ងាច ។ ពេលបាយម្តងៗ ជាឱកាសមួយទៀត ឲ្យលោកតាប្រធាន និង សហការីរបស់គាត់ផ្លាស់ប្តូរមតិ ឬ ទស្សនៈគ្នាលើបញ្ហាមួយចំនួន រាប់តាំងពី ស្ថានការណ៍អន្តរជាតិ រហូតដល់បញ្ហាដែលកើតមាននៅក្នុងជំរុំជនភៀសខ្លួន ។ ពេលទទួលទានអាហាររួចហើយ មន្ត្រីមួយចំនួននាំគ្នាដកខ្លួនថយទៅបន្ទប់របស់ គេរៀងៗខ្លួន ។ អ្នកខ្លះ "ដេកថ្ងៃ" ជាប្រការមួយដែលលោកតាមិនចូលចិត្តទាល់តែ សោះ ។ អ្នកខ្លះ ដែលជាមនុស្សជិតស្និទ្ធរបស់លោកតា នៅបន្តអង្គុយនិយាយលេង ជាមួយលោកតាតទៅទៀតគឺ នៅពេលនោះហើយ ដែលមនុស្សជិតស្និទ្ធរបស់លោក តាផ្តល់មតិ ឬ ធ្វើការវាយតម្លៃលើលទ្ធផលការងាររបស់សហសេវិកឯទៀត ឬ បើ និយាយឲ្យស្រួលស្តាប់គឺ ជាពេលដែលមនុស្សជំនិតរបស់លោកតាប្រធាន និយាយ ដើមសហសេវិកឯទៀតឲ្យលោកតាស្អប់ ឬ ឲ្យលោកតាស្រឡាញ់ ។ លោកប្រធាន មិនចូលចិត្តសមាជិកណា ដែលដើរលេងយប់ ឬ ចូលបា ច្រៀងរាំ ឬ ផឹកស្រាជា

ដើម ។ ជារឿយទូទៅ ពួកយើងមិនទទួលទានគ្រឿងស្រវឹងនៅពេលបាយទេ ក៏ប៉ុន្តែ ក៏នៅមានសហសេវិកខ្លះ ទ្រាំពុំបានលបក្រេបស្រាវិស្គីឬស្រាបៀរដោយលួចលាក់ ។ មែនទែនទៅ លោកតាប្រធានមិនចង់ឲ្យការរស់នៅរបស់ពួកយើងនៅបាងកក មានលក្ខណៈខុសគ្នាខ្លាំងពេកពីជីវភាពរបស់យុទ្ធជន ដែលកំពុងធ្វើការតស៊ូនៅជួរមុខ ។

ចលនាតស៊ូខ្មែរ ក្រោមការគ្រប់គ្រងរបស់យោធាថៃ

ក្រុមយោធាថៃបានរៀបចំរចនាសម្ព័ន្ធរបស់គេ ក្នុងទំនាក់ទំនងជាមួយពួកយើង និង ខ្មែរពីរក្រុមទៀតគឺ៖ ក្រុម ហ៊ុន សុិន ប៊ិច និង ខ្មែរក្រហម ។ នៅកំរិតទីស្នាក់ការរ.ជ.រ.ប.ខ.ប្រចាំទីក្រុងបាងកក គេមានអង្គភាព TF 315 ដែលស្ថិតនៅក្រោមអំណាចផ្ទាល់របស់លោកឧត្តមសេនីយ ធាវលិត ដែលនៅពេលនោះ ត្រូវបានតម្លើងឋានៈជាឧបការី-អគ្គសេនាធិការនៃកងទ័ពជើងគោកនៅខែតុលា ១៩៨២ ថ្នាក់ឧត្តមសេនីយផ្កាយបី ។ ក្រោយមកនៅឆ្នាំ ១៩៩៦ លោកឧត្តមសេនីយ ធាវលិត ក៏ឡើងកាន់តំណែងជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រថៃ ។ លោក វរសេនីយ សុមេធ ទៀនផេង ដែលមានឈ្មោះសម្ងាត់ថា "លោក ម៉ុល" ជាមន្ត្រីទំនាក់ទំនងរវាងកងទ័ពថៃជាមួយ រ.ជ.រ.ប.ខ. រាយការណ៍ផ្ទាល់ទៅលោកឧត្តមសេនីយ ធាវលិត ។ លោក ម៉ុល ជាអ្នកអនុញ្ញាតឲ្យយើងអាចធ្វើដំណើរពីបាងកកទៅទល់ដែន ឬ ពីទល់ដែនមកបាងកក ។ លោក ម៉ុល ក៏ជាអ្នកនាំប្រាក់ជំនួយប្រចាំខែមកបើកឲ្យពួកយើងដែរ ។ រាល់បញ្ហាទាំងឡាយនៅក្នុងទីស្នាក់ការរបស់យើង ត្រូវដោះស្រាយតាមរយៈការិយាល័យរបស់លោក ម៉ុល ។ លោក ម៉ុល ធ្វើជាមេធំលើក្រុម "ហួណា" ដែលនៅប្រចាំការក្នុងទីស្នាក់ការរបស់យើង ។ ហួណាទាំងនោះ មានរួមទាំងអ្នកបើកបរ និង អ្នកយាមកាម ឬ តាមដានពួកយើងផង ។

នៅទល់ដែន ក៏មានក្រុមការងារពីរទៀតគឺ អង្គភាព ៨០ (TF80) និង អង្គភាព ៨៣៨ (TF838) ។ អង្គភាព TF80 មានភារកិច្ចគ្រប់គ្រងលើជនភៀសខ្លួនខ្មែរទាំងអស់ ចំណែកឯអង្គភាព TF838 មានភារកិច្ចសម្របសម្រួល និង គាំទ្រគ្រប់សកម្មភាពនៃយុទ្ធជនអ្នកតស៊ូទាំងអស់ រួមទាំងភារកិច្ចត្រួតត្រាលើកម្លាំងខ្មែរប្រឆាំងវៀតណាមឯទៀតផង ។ ក្រុមការងារទាំងពីរនេះមានទីតាំងនៅទីប្រជុំជនស្រុកអារញ្ញប្រថេត ដែលនៅសម័យនោះស្ថិតនៅក្នុងខេត្តប្រាជិនបុរី (បស្ចឹមបុរី) ។ ក្រុមការងារ TF80 ជារចនាសម្ព័ន្ធបើកចំហរ មានទំនាក់ទំនងជាមួយសាធារណជនរាប់ទាំងអង្គការក្រៅរដ្ឋាភិបាលជាតិ និង អន្តរជាតិផង (NGO+UN) ។ អង្គភាព TF80 នេះ ស្ថិតនៅក្រោមអំណាចរបស់ឧត្តមបញ្ជាការនៃកងទ័ពថៃ (Thai Armed Forces Supreme Command) ។ ចំណែកឯអង្គភាព TF838 ជារចនាសម្ព័ន្ធយោធាសម្ងាត់គឺ ជាបញ្ជាការដ្ឋាននៅទល់ដែន ជាអ្នកគ្រប់គ្រងលើបណ្តាញយោធាថៃដែលត្រូវចាត់ទៅប្រចាំការនៅតាមមូលដ្ឋានរបស់អ្នកតស៊ូខ្មែរ ។

តាមបទបញ្ជារបស់ក្រុមយោធាថៃ នៅពេលណាដែលពួកយើងត្រូវការធ្វើដំណើរទៅទល់ដែន យើងត្រូវដាក់ពាក្យសុំទៅលោក ម៉ុល តាមរយៈហួណាអ្នកបើកបរ ដែលនៅប្រចាំការជាមួយពួកយើង ។ បើលោក ម៉ុល អនុញ្ញាត គាត់នឹងផ្ញើសារទៅអង្គភាពឯទល់ដែន ។ បន្ទាប់មក ហួណាអ្នកបើកបររថយន្តនឹងបើកបររថយន្តនាំយើងទៅអារញ្ញប្រថេត ។ នៅទីនោះ អង្គភាពTF80 នឹងចេញសំបុត្រអនុញ្ញាតឲ្យយើងចូលទៅក្នុងជំរុំជនភៀសខ្លួន ។ ចំណែកឯអង្គភាពTF 838 ក៏នឹងចេញសំបុត្រអនុញ្ញាតឲ្យយើងចូលទៅក្នុងមូលដ្ឋានរបស់ពួកយើងនៅឯទល់ដែន ឬ ជួនកាលអង្គភាពនេះ ចាត់ឲ្យភ្នាក់ងារនេះធ្វើដំណើរទៅជាមួយយើង ។ ក៏ប៉ុន្តែ ប្រសិនបើយើងចង់នាំជនបរទេសជាអ្នកកាសែត ឬ ជាអង្គការក្រៅរដ្ឋាភិបាល (NGO)ទៅធ្វើទស្សនកិច្ចនៅក្នុងជំរុំជនភៀសខ្លួន ពួកយើងត្រូវទៅសុំលិខិតអនុញ្ញាតពីឧត្តមបញ្ជា

ការនៃកងទ័ពថៃ ទើបអង្គភាព TF 80 អនុញ្ញាតឲ្យចូលក្នុងជំរុំដនកៀសខ្លួនបាន ។

រដ្ឋាភិបាលចម្រុះត្រីភាគីកើត ក្រោមគំនាបយោធាថៃ

នៅសម័យដែលខ្ញុំបានមកដល់ទីក្រុងបាងកកនោះ បញ្ហាបង្កើតរដ្ឋាភិបាលចម្រុះត្រីភាគីជាបញ្ហាមួយ ដែលភាគីពាក់ព័ន្ធកំពុងដោះស្រាយ ។ ថ្នាក់ដឹកនាំ រ.ជ.ប.រ.ខ. កំពុងស្ថិតនៅក្រោមការគាបសង្កត់ពីអាជ្ញាធរថៃ ដើម្បីឲ្យមានការព្រមព្រៀងយ៉ាងឆាប់រហ័សក្នុងការបង្កើតរដ្ឋាភិបាលចម្រុះនោះ ។ នៅក្នុងអំឡុង ខែ ឧសភា ១៩៨២ ទាំងមូលនោះ នាយទាហានថៃជាច្រើននាក់បានមកជួបសន្ទនាជាមួយមេដឹកនាំយើង ។ ក្នុងចំណោមនោះ ជាពិសេស មានលោកឧត្តមសេនីយ ឆាវលិត ។ រ.ជ.រ.ប.ខ.មានការខ្វល់ខ្វាយយ៉ាងខ្លាំង ដោយសារជំហររបស់រណសិរ្ស ពុំសូវបានទទួលការគាំទ្រពីសំណាក់ថ្នាក់ដឹកនាំយោធាថៃទាំងឡាយឡើយ ។ មែនទែនទៅ នាយទាហានថៃភាគច្រើនសុទ្ធតែនៅពីក្រោយខ្មែរក្រហម ដែលប្រកាន់គោលជំហរវឹងត្អឹងបំផុត ។ ពួកមេទ័ពថៃទាំងនោះសម្គាល់ថាលោកតា សឺន សាន មិនប្រកាន់គោលជំហរឲ្យបានទន់ភ្លន់សោះ ក្នុងការចរចាបង្កើតរដ្ឋាភិបាលចម្រុះនោះ ។ ពួកនាយទាហានថៃទាំងនោះយល់ថា ការប្រកាន់ឥរិយាបថរបស់លោកតា ជាឧបសគ្គធ្វើឲ្យរាំងស្ទះដល់ការចរចា ។ ចំពោះលោកតា សឺន សាន លោកតាបានខឹតខំសាកល្បងបង្ហាញហេតុផលថា លោកតាមានចេតនាចូលរួមក្នុងរដ្ឋាភិបាលចម្រុះ មិនមែនមិនចង់ចូលដូចការប៉ាន់ស្មានរបស់អាជ្ញាធរយោធាថៃនោះទេ ។

នៅថ្ងៃទី ៧ ឧសភា ១៩៨២ រ.ជ.រ.ប.ខ.បានសំរេចជាគោលការណ៍ទទួលយករួចទៅហើយនូវសំណើរបស់ក្រសួងការបរទេសថៃ ដែលក្នុងនោះរួមមានទាំងគោលការណ៍ ៤ ប្រការរបស់ខ្មែរក្រហម ដែលក្នុងពេលកន្លងមក រ.ជ.រ.ប.ខ. តែងតែប្រកែកពុំព្រមទទួល ។ គោលការណ៍ទាំង ៤ ប្រការនោះគឺ៖ ១- ត្រីភាគី

និយម (Tripartism) ២- ស្មើភាព និង គ្មានប្រៀបលើគ្នា (Equality and Non-preponderance) ៣- គោលការណ៍សម្រេចដោយឯកច្ឆ័ន្ទលើបញ្ហាសំខាន់ៗ (Consensus on important matters) និង ៤- រដ្ឋាភិបាលចម្រុះត្រូវបង្កើតលើមូលដ្ឋានច្បាប់នៃរដ្ឋកម្ពុជាប្រជាធិបតេយ្យ ដែលជារដ្ឋសមាជិកនៃអង្គការសហប្រជាជាតិ (CGDK must be based on legal status of Democratic Kampuchea)[147] ។ នៅក្នុងកំណត់ជំនួយស្មារតីចុះថ្ងៃទី ៧ ឧសភា ១៩៨២ ផ្ញើជូនលោករដ្ឋមន្ត្រីក្រសួងការបរទេសថៃ សិទ្ធិ សារ៉ែតសីលា លោកតាប្រធាន រ.ជ.រ.ប.ខ. បានបញ្ជាក់ថា លោកតាយល់ព្រមទាំងស្រុង (in toto) លើសំណើរបស់ក្រសួង ព្រមទាំងស្នើសុំកុំឲ្យមានការកែប្រែ ឬ ធ្វើវិសោធនកម្មណាមួយឡើយលើសំណើនោះ ។ មែនទែនទៅ លោករដ្ឋមន្ត្រីក្រសួងការបរទេសថៃ មានការពេញចិត្តចំពោះការយល់ព្រមទទួលយករបស់រ.ជ.រ.ប.ខ. ។ ក៏ប៉ុន្តែ សំណើកិច្ចព្រមព្រៀងនោះ ពុំត្រូវបានគេយកមកប្រើការតទៅទៀតឡើយ ព្រោះកងទ័ពថៃមានគោលដំហរផ្សេងពីក្រសួងការបរទេស ។ ប្រការដែលគួរឲ្យកត់សម្គាល់នោះគឺ ក្រសួងការបរទេសថៃ ក៏ដូចជាប្រទេសសមាជិកអាស៊ានឯទៀត ទទួលយកនូវសំណើមួយចំនួនរបស់រ.ជ.រ.ប.ខ. ក្នុងការរៀបចំរដ្ឋាភិបាលចម្រុះខ្មែរត្រីភាគី ក៏ប៉ុន្តែកងទ័ពថៃមានការយល់ឃើញផ្សេង ព្រោះពួកគេឈរនៅពីក្រោយខ្មែរក្រហម ដោយដើរតាមបន្ទាត់នយោបាយរបស់ចិន ។ ជាពិសេសក្រុមឧត្តមសេនីយ ប្រាកដជាអនុវត្តតាមកិច្ចព្រមព្រៀង តេង ស៊ាវពីង-លី ខ្វាន់ យូ ដែលផ្តល់ការអនុគ្រោះដល់ខ្មែរក្រហមរួចទៅហើយ ។

នៅថ្ងៃទី ២៥ ឧសភា ១៩៨២ លោកឧត្តមសេនីយ ឆាវលិត បានមកជួបលោកតា សឺន សាន នៅម៉ោង ១២:៣០ នាទីទាំងកណ្តាលអធ្រាត្រដោយឥតព្រាង

[147] Memorandum by the Democratic Kampuchea Party Concerning the Declaration of the Formation of the Coalition Government of Democratic Kampuchea, op. cit.

ទុក ដែលធ្វើឲ្យយើងមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ។ ឧត្តមសេនីយថៃរូបនេះនាំមកជាមួយ នូវសេចក្តីព្រាងសេចក្តីថ្លែងការណ៍ស្តីពីការបង្កើតរដ្ឋាភិបាលចម្រុះត្រីភាគីកម្ពុជាប្រជាធិបតេយ្យ ដើម្បីសុំឲ្យលោកតា សឺន សាន ទទួលយក ។ លោកមេទ័ព ឆាវលិត ដាក់កំហិតឲ្យ រ.ជ.រ.ប.ខ.ធ្វើតាម បើពុំនោះទេនឹងត្រូវទទួលទណ្ឌកម្ម ។ ថ្នាក់ដឹកនាំរ.ជ.រ.ប.ខ. បានពិនិត្យឃើញថាពង្រាងនេះ មានលក្ខណៈខុសគ្នាយ៉ាងខ្លាំងពីពង្រាងដើមនៃក្រសួងការបរទេសថៃដែលរ.ជ.រ.ប.ខ. បានទទួលយល់ព្រមរួចហើយ ។ នៅថ្ងៃព្រឹកទី ២៨ ឧសភា ១៩៨២ លោកតា សឺន សាន បានផ្ញើជូនផ្ទាល់ដៃទៅលោកឧត្តមសេនីយ ឆាវលិត នូវកំណត់សម្គាល់មួយជំរាបមេទ័ពថៃរូបនេះថាពង្រាងថ្មីនេះ មានលក្ខណៈខុសគ្នាខ្លាំងណាស់ពីសេចក្តីព្រាងសំណើដំបូងរបស់ប្រទេសថៃ (គឺសំណើនៃក្រសួងការបរទេសថៃ) ដែលយើងបានទទួលយករួចហើយ ។ លើសពីនេះទៅទៀតពង្រាងថ្មីរបស់លោក ឆាវលិត នេះ ហាក់ដូចជាមានការលំអៀងទៅតែខាងខ្មែរក្រហម ដោយមិនបានគិតគូរដល់រ.ជ.រ.ប.ខ. និងហ៊ុន សុិន ប៊ុច ឡើយ និង ពុំបានគោរពដល់គោលការណ៍នយោបាយជាមូលដ្ឋាននៃរដ្ឋាភិបាលចម្រុះសោះ ។ ដើម្បីចង់បង្ហាញថា រ.ជ.រ.ប.ខ. នៅតែមានបំណងចូលរួមក្នុងរដ្ឋាភិបាលត្រីភាគីនោះ លោកតាប្រធានសរសេរថានឹងជំរាបលោក ឆាវលិត ពីដំណោះស្រាយមួយនាពេលខាងមុខដ៏ខ្លី[148] ។

ដំណោះស្រាយដែលលោកតា សឺន សាន មានបំណងលើកឡើងនោះគឺជារូបមន្តដ៏សាមញ្ញមួយ ដែលក្នុងនោះ សម្តេច នរោត្តម សីហនុ ទ្រង់នឹងត្រូវថ្វាយហានៈជាប្រមុខរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ ចំណែកឯលោកតានឹងកាន់តំណែងជានាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ (លោកតាមិនចង់មានឈ្មោះជានាយករដ្ឋមន្ត្រីនៃកម្ពុជាប្រជាធិបតេយ្យទេ តែជានាយករដ្ឋមន្ត្រីនៃរដ្ឋាភិ

[148] Observation of Mr. Son Sann on the Draft Proposal entitled "Declaration of the Formation of the Coalition Government of Democratic Kampuchea"as provided by Major General Chaovalit, May 27, 1982.

បាលចម្រុះ ដែលហាក់ដូចជាស្ថាប័នថ្មីមួយទៀតផ្សេងពីកម្ពុជាប្រជាធិបតេយ្យ ដែលមានឈ្មោះល្បីពាក់ព័ន្ធនឹងអំពើប្រល័យពូជសាសន៍) ក្នុងនោះលោក ខៀវ សំផន នឹងកាន់តំណែងជាឧបនាយករដ្ឋមន្ត្រី ។ ដើម្បីបំពេញតួនាទីរបស់ខ្លួន រដ្ឋាភិបាលចម្រុះនេះនឹងបង្កើតគណៈកម្មាធិការពីរគឺ មួយទទួលបន្ទុកកិច្ចការយោធា និង មួយទៀតខាងការទូត ។ គណៈកម្មាធិការនីមួយៗមានសមាជិកពីររូបមកពីភាគីនីមួយៗនៃភាគីទាំងបី ។ ក្នុងន័យនេះ រ.ជ.រ.ប.ខ.យល់ព្រមទទួលយកគោលការណ៍ត្រីភាគីនិយម ស្មើភាពគ្នា មិនមានប្រៀបលើគ្នា និង គោលការណ៍កុងសង់ស៊ីសលើបញ្ហាសំខាន់ៗ ។ ក៏ប៉ុន្តែពួកខ្មែរក្រហមនៅតែពុំព្រមទទួលយករូបមន្តនេះ ។ មិនតែប៉ុណ្ណោះពួកខ្មែរក្រហម បានធ្វើការគាបសង្កត់ដោយកម្លាំងយោធាមកលើ រ.ជ.រ.ប.ខ. ថែមទៀត ដើម្បីបង្ខំឲ្យរ.ជ.រ.ប.ខ.ទទួលយកតាមរូបមន្តរបស់ពួកគេ ។ នៅក្នុងអនុស្សរណៈរបស់លោកតាប្រធាន ផ្ញើជូនលោកឧត្តមសេនីយ ឆាវលិត ចុះថ្ងៃទី ១ មិថុនា ១៩៨២[149] លោកតាបានរាយការណ៍ ជូនលោកមេទ័ពថៃថាមានការប៉ះទង្គិចគ្នាចំនួនពីរដងរវាងកងទ័ពខ្មែរក្រហម និង កងទ័ព រ.ជ.រ.ប.ខ.នៅថ្ងៃទី ២១ និង ២៩ ឧសភា ១៩៨២ នៅក្នុងតំបន់ដែលជាតំបន់រំដោះរបស់ រ.ជ.រ.ប.ខ. ។ ការប៉ះទង្គិចលើកទីមួយនោះបានកើតឡើងនៅពេលក្រុមខ្មែរក្រហមចំនួន ២៥ នាក់ បានត្រូវរកឃើញ កំពុងជីករណ្តៅដើម្បីដាក់មីនក្នុងទឹកដីរបស់ រ.ជ.រ.ប.ខ. ។ ពួកខ្មែរក្រហមបានបាញ់រះមកលើកងកម្លាំង រ.ជ.រ.ប.ខ. នៅពេលដែលមេបញ្ជាការម្នាក់របស់ពួកយើង បានប្រាប់ឲ្យពួកនេះបញ្ឈប់ការជីករណ្តៅដាក់មីននោះជាបន្ទាន់ ។ លើកទីពីរមានការប៉ះទង្គិចខាងផ្លូវអាវុធរវាងក្រុមខ្មែរក្រហមចំនួន ៣០ នាក់ ដែលបានរំលោភចូលមកក្នុងទឹកដី រ.ជ.រ.ប.ខ. ជាមួយកងកម្លាំងរបស់យើង នៅតំបន់កណ្តាល ។ អនុស្សរណៈនោះ មានសេចក្តីជាអាទិថាៈ "ការ

[149] Memorandum presented by Mr. Son Sann to Major-General Chaovalit Yongchaiyuth, the Royal Thai Armed Forces, June 1, 1982.

វាយប្រហាររបស់ពួកខ្មែរក្រហមមកលើកងកម្លាំងរបស់យើង មិនមែនមានជាលើកទីមួយនោះឡើយ ។ ពួកខ្មែរក្រហមជាញឹកញាប់តែងរំលោភចូលមកទឹកដីដែលយើងកាន់កាប់ បន្ទាប់មកតែងធ្វើការវាយប្រហារដោយអាវុធ ដែលកើតមានច្រើនលើករួចទៅហើយក្នុងពេលកន្លងមក" ។ អនុស្សរណៈនោះ បន្តទៀតថា " .....ការវាយប្រហាររបស់ពួកខ្មែរក្រហមមកលើកងកម្លាំងយើងនេះ តែងតែត្រូវបានរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ចថៃជានិច្ច ។ នៅពេលបច្ចុប្បន្ន កងទ័ពខ្មែរក្រហមកំពុងដីកដីដាក់មីន នៅចំពីមុខជំរុំរ៉ិទ្ធីសែនរបស់យើងផង ។ នៅពេលដែលយើងកំពុងតែតវ៉ាយ៉ាងខ្លាំងចំពោះឧប្បទ្វហេតុទាំងនេះ យើងក៏ត្រូវថ្លែងនូវការព្រួយបារម្ភរបស់យើង ចំពោះហេតុការណ៍ទាំងនេះ ដែលអាចធ្វើឲ្យមានការគាំងដំណើរដល់ការចរចាបង្កើតរដ្ឋាភិបាលចម្រុះខ្មែរនេះដែរ" ។ ភាគីថៃពុំបានធ្វើប្រតិកម្មអ្វីឡើយចំពោះអនុស្សរណៈនេះទេ ។ ពួកថៃមិនធ្វើការឆ្លើយតបអ្វីទាំងអស់ ។ ការមិនឆ្លើយតបទាំងនេះជាវិធីមួយនៃការគាបសង្កត់ថែមទៀតដើម្បីបង្ខំឲ្យរ.ជ.រ.ប.ខ.ចូលក្នុងសម្ព័ន្ធភាពជាមួយខ្មែរក្រហម ។

នៅពេលដែលថ្នាក់ដឹកនាំរ.ជ.រ.ប.ខ.នៅតែសំដែងការមិនពេញចិត្ត ចំពោះការគាបសង្កត់ទាំងនេះ រ.ជ.រ.ប.ខ.ក៏បានសម្រេចជាចុងក្រោយថានឹងទទួលយកនូវរូបមន្តណាមួយ ដែលស្នើចេញមកពីរដ្ឋាភិបាលរបស់ក្រុមប្រទេសអាស៊ាន (ASEAN) ។ ដោយទទួចភ្ជាប់ជាមួយនូវការសុំជំនួយ លោកតា សឺន សាន ធ្លាប់ថ្លែងជាសាធារណៈថា៖" សុំផ្តល់ដំបងឲ្យខ្ញុំមួយមុននឹងឲ្យខ្ញុំចូលក្នុងទ្រុងខ្លា" លោកតា សឺន សាន ប្រៀបប្រដូចការចូលធ្វើសម្ព័ន្ធភាពជាមួយខ្មែរក្រហម ដូចគ្នានឹងការចូលក្នុងទ្រុងខ្លាយ៉ាងដូច្នោះដែរ ។ លោកតាសុំដំបងគឺសុំជំនួយឲ្យភាគីរ.ជ.រ.ប.ខ.។ លោកតាប្រធានរ.ជ.រ.ប.ខ. បានភ្ជាប់ការចូលរួមរបស់រ.ជ.រ.ប.ខ.ទៅក្នុងរដ្ឋាភិបាលចម្រុះជាមួយនឹងការផ្តល់ជំនួយដ៏រឹងមាំឲ្យដល់ចលនាតស៊ូនេះ ។ នៅក្នុងអនុស្សា

រណៈចុះថ្ងៃទី ២ មិថុនា ១៩៨២[150] ដែលមានវាយត្រាដាក់ថាសម្ងាត់ផងនោះ ហើយដែលផ្ញើជូនផ្ទាល់ទៅលោកឧត្តមសេនីយ ឆាវលិត លោកតាតវ៉ាថា រ.ជ.រ.ប.ខ. មានការខកចិត្តជាខ្លាំង ព្រោះទោះបីជា រ.ជ.រ.ប.ខ.ប្រកាន់យកគោលជំហរទន់ភ្លន់ និង បានធ្វើសម្បទានយ៉ាងច្រើនយ៉ាងណាក៏ដោយ ក៏រដ្ឋាភិបាលចម្រុះនៅតែបង្កើតមិនទាន់បាន ។ ម្យ៉ាងទៀតពួកខ្មែរក្រហមនៅតែប្រកាន់ជំហររឹងត្អឹង ហើយជាមួយគ្នានោះ ហាក់ដូចជាគ្មាននរណាម្នាក់អាចជួយបន្ធន់គោលជំហររបស់ពួកនេះសោះ រឹងជំនួយក៏មិនទាន់បានផ្តល់ដល់ពួកយើង ដែលយើងកំពុងត្រូវការជាបន្ទាន់លើសមរភូមិមុខនោះ ។ លោកតាប្រធានបានស្នើដូចតទៅ៖ "១. យើងខ្ញុំនឹងទទួលយកមកពិនិត្យនូវរាល់សំណើត្រឹមត្រូវ និង យុត្តិធម៌ណាដែលចេញពីរដ្ឋាភិបាលនៃប្រទេសអាស៊ាន ហើយដែលមិនឃ្លាតឆ្ងាយពេកពីស្មារតីនៃសំណើរបស់ប្រទេសថៃនៅដើមខែ ឧសភា- ២. ដើម្បីរកដំណោះស្រាយបញ្ហាកម្ពុជា ដោយអនុលោមតាមសេចក្តីថ្លែងការណ៍នៃសន្និសីទអន្តរជាតិស្តីពីកម្ពុជា (ICK) និង តាមសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ ការទទួលយល់ព្រមរបស់ខ្ញុំចំពោះសំណើរបស់រដ្ឋាភិបាលនៃប្រទេសអាស៊ាននឹងត្រូវធ្វើឡើងស្របពេលជាមួយគ្នានឹងសេចក្តីប្រកាសរបស់រដ្ឋាភិបាលនៃប្រទេសអាស៊ាននោះ ស្តីពីការផ្តល់ជំនួយដល់ រ.ជ.រ.ប.ខ. ដូចដែលបានសន្យា ហើយនៅថ្ងៃដែលខ្ញុំចុះហត្ថលេខាលើពង្រាងដែលស្នើដោយប្រទេសអាស៊ាននោះ ថ្ងៃនោះក៏ជាថ្ងៃដែលជំនួយជាកញ្ចប់ត្រូវបានផ្តល់ដល់ រ.ជ.រ.ប.ខ. ដែរ" ។

នៅថ្ងៃទី ២ មិថុនា នោះដែរ លោកតាបានចុះហត្ថលេខាសុខចិត្តទទួលយកនូវសេចក្តីថ្លែងការណ៍ បង្កើតរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យដែលឧត្តមសេនីយ ឆាវលិត បានប្រគល់ដល់លោកតាជាថ្មីទៀត ។ ឯកសារចុះហត្ថលេខា

[150] Memorandum presented by Mr. Son Sann to Major-General Chaovalit Yongchaiyuth, the Royal Thai Armed Forces, June 2, 1982.

ទទួលយកនោះ បានត្រូវបញ្ជូនជាពិសេសទៅឧត្តមសេនីយ ឆាវលិត ដោយផ្ទាល់ ។ រូបមន្តដែលលោកតា សឺន សាន ទទួលនោះ មានគ្រោងតំណែងជាប្រធានកម្ពុជាប្រជាធិបតេយ្យថ្វាយសម្តេច សីហនុ និង អនុប្រធានជូនលោក ខៀវ សំផន ចំណែកឯលោកតា សឺន សាន ជានាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ។ ជាមួយគ្នានោះ ក៏មានគ្រោងបង្កើតគណៈកម្មាធិការសម្របសម្រួលចំនួន ៥ ទៀតគឺ៖ ការបរទេស ហិរញ្ញវត្ថុ និង សេដ្ឋកិច្ច ការពារប្រទេស វប្បធម៌ និង សិក្សាធិការ ព្រមទាំងការងារសុខាភិបាល និង សង្គមកិច្ច ។ នៅថ្ងៃទី ៣ មិថុនា ១៩៨២ លោកតា សឺន សាន នៅបន្តព្យាយាមធ្វើវិសោធនកម្មលើឯកសារដែលលោកតាយល់ព្រមរួចហើយ កាលពីមួយថ្ងៃមុននោះ ដោយស្នើឲ្យលុបពាក្យ ប្រធាន និង អនុប្រធានសម្រាប់សម្តេច សីហនុ និង លោក ខៀវ សំផន មកជា "ប្រមុខរដ្ឋវិញ" ។ លោកតាក៏បានស្នើទៅលោកឧត្តមសេនីយ ឆាវលិត ឲ្យកំណត់ចំនួនគណៈកម្មាធិការសម្របសម្រួលនោះពី ៥ មកតែ ២ វិញប៉ុណ្ណោះគឺ៖ ការបរទេស និង កាពារជាតិ[151] ។ បន្ថែមលើនេះទៀត នៅពេលចុះហត្ថលេខាយល់ព្រមទទួលរូបមន្ត លោកតានៅតែប្រយ័ត្នប្រយែងមិនទទួលស្គាល់ទាំងសម្តេច សីហនុ ទាំងលោក ខៀវ សំផន ថាជាអ្នកដឹកនាំភាគីដែលឥស្សរជនទាំងពីរជាតំណាងនោះ។ លោកតាទទួលស្គាល់មេដឹកនាំទាំងពីររូប នោះត្រឹមតែជាតួបុគ្គលប៉ុណ្ណោះ ។ នៅលើឯកសារដែលរៀបចំឡើងដោយឧត្តមសេនីយ ឆាវលិត ហើយដែលបញ្ជាក់ថា លោកតានឹងត្រៀមជួបដៃគូពីរអង្គទៀតគឺ សម្តេច សីហនុ និង លោក ខៀវ សំផន នោះ លោកតាបានឆូតលុបពាក្យ "មេដឹកនាំ ហ៊ុន សុន ប៊ុច" និង "មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ" ចេញ រួចហើយសរសេរផ្ទាល់ដៃជំនួសវិញថា "សម្តេច សីហនុ" និង "ឯកឧត្តម ខៀវ សំផន" ដោយបំភ្លេចចោលនូវតួនាទីផ្លូវការ

[151] Memorandum presented by Mr. Son Sann to Major-General Chaovalit Yongchaiyuth, June 3, 1982.

របស់អ្នកដឹកនាំទាំងពីរ[152]។ ការធ្វើបែបនេះប្រហែលជាលោកតាយល់ថាជាការអាចជៀសវាងនូវអ្វីដែលហៅថា "ត្រីកាគីនិយម" ។ ក៏ប៉ុន្តែ តាមពិតទៅ លោកតាត្រូវបានទទួលបរាជ័យទាំងអស់ ។

កលល្បិចរបស់លោកតា ដែលពួកថៃមើលឃើញថាកំប៉ិកកំប៉ុកនោះមិនបានធ្វើឲ្យមេទ័ពថៃព្រួយបារម្ភអ្វីឡើយ ព្រោះថានៅទីបំផុត នៅថ្ងៃទី ១២ មិថុនា ១៩៨២ លោកតាសុខចិត្តទទួលយកនូវពង្រាងថ្មី ស្នើដាថ្មីដោយឧត្តមសេនីយ ឆាវលិត ដែលតាមរយៈនោះ ពួកខ្មែរក្រហម បានសម្រេចជោគជ័យទាំងស្រុង ដូចដែលគេប៉ងប្រាថ្នាជាយូរមកហើយ ។ សម្តេច សីហនុ ត្រូវបានជាប្រធានកម្ពុជាប្រជាធិបតេយ្យ លោក ខៀវ សំផន ជាអនុប្រធានកម្ពុជាប្រជាធិបតេយ្យ រីឯលោក តា សឺន សាន ជានាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ។ រូបមន្តថ្មីនេះ មានបង្កើតគណៈកម្មាធិការសម្របសម្រួល ៤ (ដូចក្រសួង) គឺ៖ ហិរញ្ញវត្ថុ និង សេដ្ឋកិច្ច ការពារប្រទេស វប្បធម៌ និង អប់រំ សុខាភិបាល និង សង្គមកិច្ច បន្ថែមលើការបរទេសដែលត្រូវរៀបចំដោយលក្ខណៈពិសេស[153] ។ មែនទែនទៅ កិច្ចការបរទេសត្រូវបានរៀបចំពិសេស ឲ្យស្ថិតនៅក្រោមការកាន់កាប់ផ្ទាល់នៃពួកខ្មែរក្រហម ព្រោះគេបានរៀបចំឲ្យក្រសួងការបរទេសស្ថិតនៅក្រោមអំណាចរបស់អនុប្រធានកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន ។ ដូច្នេះ ពួកខ្មែរក្រហមបានទទួលជ័យជំនះ លើសហួសពីគោលការណ៍ដែលថាស្មើភាព និង ភាពមិនមានប្រៀបលើគ្នាទៅទៀតផង ។

ដោយសារមានការគាំទ្រដ៏រឹងមាំពីប្រទេសចិន និង ពីឧត្តមសេនីយថៃដ៏មានអំណាច ពួកខ្មែរក្រហមបានសំរេចជោគជ័យក្នុងការនាំយកសម្តេច សីហនុ ឲ្យ

[152] Son Sann to General Chaovalit, (A kind of Memo) June 2, 1982.
[153] Samdech Norodom Sihanouk, H.E. Mr. Son Sann, H.E. Mr. Khieu Samphan, CGDK, Declaration of the Formation of the Coalition Government of Democratic Kampuchea, Kuala Lumpur, 22nd of June 1982.

ចូលក្នុងសម្ព័ន្ធភាពជាមួយពួកគេម្តងទៀត ។ ក៏ប៉ុន្តែ ការយល់ព្រមចូលរួមរបស់លោកតា សឺន សាន ក្នុងរដ្ឋាភិបាលចម្រុះត្រីភាគីនេះ បានបង្ហាញឲ្យឃើញឥទ្ធិពលដ៏មហិមារបស់ចិន ក្នុងការធ្វើឲ្យពួកខ្មែរក្រហមអាចរស់រានមានជីវិតឡើងវិញខាងផ្លូវនយោបាយ ។ នៅទីបំផុត លោកតា សឺន សាន បានចុះហត្ថលេខាលើឯកសារមួយ ដែលអាចបង្ហាញដល់ដៃគូអន្តរជាតិគឺ៖ ចិន អាស៊ាន ស.រ.អា និង ប្រទេសឯទៀតថាលោកតាសុខចិត្តហើយ ព្រោះលើកនេះ លោកតាសរសេរ "ជូនភាគីណាដែលពាក់ព័ន្ធ"(To whom it may concern)[154] ដែលផ្ទុយពីកាលមុនដែលលោកតាសរសេរផ្ញើរទៅ "ឧត្តមសេនីយ ឆាវលិត" (To General Chaovalit) ។ លក្ខខណ្ឌដែលលោកតា សឺន សាន លើកឡើងទាំងអម្បាលម៉ាន ជាពិសេស ការទាមទារសុំ ឲ្យមានភ្ជាប់នូវសេចក្តីប្រកាសផ្តល់ជំនួយរបស់ក្រុមប្រទេសអាស៊ានដល់ភាគីរ.ជ.រ.ប.ខ. នៅពេលលោកតាចុះហត្ថលេខាលើសេចក្តីប្រកាសបង្កើតរដ្ឋាភិបាលចម្រុះនោះ ក៏ត្រូវសោបរលោបអាសាបង់គឺ គ្មានបានផលប្រយោជន៍អ្វីទាំងអស់ ។ នេះក៏ជាបរាជ័យមួយសម្រាប់ថ្នាក់ដឹកនាំរបស់ក្រុមយើងដែរ ។

លោកតាឲ្យខ្ញុំរៀបចំប្រព័ន្ធគណនេយ្យ

នៅក្នុងរយៈពេលនៃការចរចាគ្នានោះ ដែលទំហំការងារនៅក្នុងការិយាល័យ រ.ជ.រ.ប.ខ.កាន់តែរីកនិងកើនឡើងឥតឈប់ឈរនោះ លោកតា សឺន សាន បានស្នើឲ្យ ហ្គាហ្វា ចែករំលែកការងារខ្លះមកឲ្យខ្ញុំជួយធ្វើ តែ ហ្គាហ្វា បានឆ្លើយថា "មូលីមានការងារច្រើនណាស់" ដោយមិនទាំងបានសួរខ្ញុំជាមុនផង តើខ្ញុំរវល់ឬយ៉ាងណានោះឡើយ។ តាមពិតទៅ ហ្គាហ្វា ពុំមានបំណងចែករំលែកការងារឲ្យខ្ញុំធ្វើទេ ព្រោះប្រហែលគេមិនចង់ឲ្យខ្ញុំដឹងអំពីការងារធំដុំអ្វីឡើយ ។ មែនទែនទៅ ចាប់ពីពេលខ្ញុំ

[154] Son Sann, To Whom It May Concern, (A kind of Memo) June 12, 1982.

មកដល់ទីក្រុងបាងកក ខ្ញុំគ្មានការងារអ្វីក្រៅពីជួយបកប្រែអត្ថបទភាសាបារាំង មកភាសាខ្មែរម្តងម្កាលប៉ុណ្ណោះ ។ ជាផ្លូវការ ខ្ញុំត្រូវបានតែងតាំងជា "ធារីបេសកកម្ម" "Chargé de mission" ទទួលបន្ទុកការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៅពីថ្ងៃទី ១១ មិថុនា ១៩៨២[155] ។

ក្នុងហាន:នេះ ខ្ញុំបានទទួលការណែនាំផ្ទាល់ពីលោកតា សឺន សាន ឲ្យរៀបចំប្រព័ន្ធគណនេយ្យ និង ត្រួតពិនិត្យផ្នែកហិរញ្ញវត្ថុដើម្បីធ្វើឲ្យការបែងចែក ឬ ការផ្គត់ផ្គង់ផ្នែកកស្តុកា រួមទាំងផ្នែកហិរញ្ញវត្ថុ ដល់គ្រប់អង្គភាពនានានៃរ.ជ.រ.ប.ខ. ប្រព្រឹត្តិទៅដោយតម្លាភាព ។ តាមពិត អ្វីដែលខ្ញុំធ្វើនោះគ្រាន់តែជាការគិតគូរមួយផ្នែកតែប៉ុណ្ណោះ មិនអាចយកជាការអនុវត្តន៍ជាក់ស្តែង ជាវិធានការណាមួយនោះទេ ។

នៅថ្ងៃទី ១២ មិថុនា ១៩៨២[156] ខ្ញុំបានធ្វើអនុស្សារណៈមួយជូនលោកតា សឺន សាន ដោយបង្ហាញពីទស្សនៈរបស់ខ្ញុំលើផ្នែកត្រួតពិនិត្យហិរញ្ញវត្ថុដែលត្រូវមានរចនាសម្ព័ន្ធយ៉ាងដូចម្តេចខ្លះ ។ ខ្ញុំមានគំរោងបង្កើតផ្នែកត្រួតពិនិត្យហិរញ្ញវត្ថុមួយ ដែលស្ថិតនៅក្រោមអំណាចផ្ទាល់របស់ប្រធានគណៈកម្មាធិការប្រតិបត្តិគឺ លោកតា សឺន សាន និងប្រព័ន្ធគណនេយ្យមួយ ដែលមានឧបករណ៍ទ្រទ្រង់ (បញ្ជី សម្ភារៈ) និង របៀបនិតិវិធីនៃការចេញរបាយការណ៍ហិរញ្ញវត្ថុ ។ នៅក្នុងប្រព័ន្ធនោះ ខ្ញុំសាកល្បងបញ្ចូលក្បួនគណនេយ្យខាងគិតគូរតម្លៃ (Cost Accounting) ទៅក្នុងប្រព័ន្ធនៃរដ្ឋបាលសាធារណៈដែលអាចដឹងភ្លាមនូវប្រភព និង ប្រភេទនៃចំណាយ និង ចំណូល ។ លោកតា សឺន សាន បានគាំទ្រគំនិតនេះ ដោយចារផ្ទាល់ដៃថា៖"សូមដាក់ឲ្យប្រើនូវប្រព័ន្ធនេះឲ្យបានមុនពេលជំនួយមកដល់ជៀសវាង

[155] Son Sann, Front National de Libération du Peuple Khmer, Décision no. 82/07/FNL, Territoire Khmer, 11 juin 1982.
[156] Ieng Mouly, Memo à Son Excellence le Président, Memo 82/01 IM, 12 juin 1982.

កុំឲ្យការងារកើនឡើងគរជាន់លើគ្នា...” ។ នៅខែ កញ្ញា ១៩៨២ លោកតាប្រធាន បានចុះហត្ថលេខាលើសេចក្តីសម្រេចបង្កើតថវិការ.ជ.រ.ប.ខ. និង បានតែងតាំង មន្ត្រី ៣ នាក់ ឲ្យទទួលខុសត្រូវគឺ៖ ១. លោក នាង ជិនហន ជាអណាប័កដើមខ្សែ, ២. លោក ប៊ុន សាយ ជាហិរញ្ញិក, ៣. ខ្ញុំ (អៀង មូលី) ជាអ្នកត្រួតពិនិត្យ (Controller)។ ក៏ប៉ុន្តែប្រព័ន្ធគណនេយ្យដែលខ្ញុំបានបង្កើតនោះពុំបានត្រូវយក មកប្រើប្រាស់ឡើយ ព្រោះរ.ជ.រ.ប.ខ. ត្រូវបង្ខំចិត្តដោះស្រាយបញ្ហាស្លាប់រស់ជា បន្ទាន់ផ្សេងៗទៀត ។ តាមពិតទៅគំនិតរបស់ខ្ញុំនេះ មិនត្រូវបានសហសេវិករបស់ ខ្ញុំសប្បាយចិត្ត នឹងទទួលយកនោះឡើយ ព្រោះប្រព័ន្ធនេះអាចធ្វើឲ្យប៉ះពាល់ដល់ ទម្លាប់របស់គេដែលធ្លាប់មានពីមុនៗមកក៏បាន ។ ម្យ៉ាងទៀត សំណើខ្ញុំនោះអាចថា មានឧត្តមគតិល្អ ក៏ប៉ុន្តែប្រព័ន្ធនោះក៏មិនអាចអនុវត្តជាក់ស្តែងបានឡើយ ព្រោះថា តាមច្បាប់នៅប្រទេសថៃ រ.ជ.រ.ប.ខ.គ្រាន់តែជាអង្គការចាត់តាំងសម្ងាត់ ពុំមានលក្ខ ន្តិក:ខាងផ្លូវច្បាប់ណាមួយច្បាស់លាស់ឡើយ ។ លោក ប៊ុន សាយ និយាយប្រាប់ ខ្ញុំឲ្យសាកល្បងទៅបើកគណនីផ្ទាល់ខ្លួនលមើលនោះ ខ្ញុំនឹងដឹងថាតើមានបញ្ហាអ្វី ខ្លះ ព្រោះថា រហូតមកដល់ថ្ងៃនេះ ពុំទាន់មាននរណាអាចមានគណនីផ្ទាល់ខ្លួននៅ ក្នុងធនាគារថៃណាមួយនៅឡើយទេ ។ នៅពេលនោះ សូម្បីតែ រ.ជ.រ.ប.ខ. ក៏ត្រូវ បង្ខំចិត្តប្រើប្រាស់គណនីឯកជនរបស់មិត្តភក្តិម្នាក់ ដែលជាជនជាតិថៃដើមកំណើត ចិនសិនដែរ ។ តែចំពោះខ្ញុំវិញ ខ្ញុំគ្មានបញ្ហាអ្វីទេក្នុងការបើកគណនីផ្ទាល់ខ្លួននៅក្នុង ធនាគារថៃនោះ ព្រោះថាមុននឹងចេញដំណើរពីប្រទេសបារាំងមកកាន់ប្រទេសថៃ ខ្ញុំបានទាក់ទងធនាគាររបស់ខ្ញុំ ជួយសម្រួលឲ្យខ្ញុំអាចបើកគណនីនៅប្រទេសថៃ បាន ។ ខុសពីអ្នកឯទៀត គ្រាន់តែមកដល់ទីក្រុងបាងកកភ្លាម ខ្ញុំក៏អាចមានគណនី ផ្ទាល់ខ្លួននៅធនាគារថៃយ៉ាងឆាប់រហ័ស ។ ក្រោយមក គណនីផ្ទាល់ខ្លួនរបស់ខ្ញុំនេះ ក៏ត្រូវយកមកប្រើប្រាស់ សម្រាប់ការងារកាកបាតក្រហម រ.ជ.រ.ប.ខ. ដែលត្រូវ

បង្កើតឡើងនៅឆ្នាំ ១៩៨៤ ។ តាំងពីពេលនោះមក ឈ្មោះខ្ញុំ និង លេខគណនីខ្ញុំ ត្រូវបានបោះពុម្ព លើក្រដាសផ្លូវការនៃកាកបាតក្រហមរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ (រ.ជ.រ.ប.ខ.) ជារៀងរហូតមក ។

ខ្ញុំថា៖ ការចូលរួមក្នុងត្រីភាគី មិនមែនជាជោគជ័យទេ

នៅថ្ងៃទី ២០ មិថុនា ១៩៨២ លោកតា សឺន សាន លោក ហ្គាហ្វា លោកស្រី សួន កាសេត និង បង ប៉ែន ថាល់ ចេញដំណើរពីទីក្រុងបាងកក ឆ្ពោះទៅទីក្រុងកូឡាឡាំពួនៃប្រទេសម៉ាឡេស៊ី ដើម្បីចូលរួមក្នុងការប្រកាសបង្កើតរដ្ឋាភិបាលចម្រុះត្រីភាគីកម្ពុជាប្រជាធិបតេយ្យ ជាមួយមេដឹកនាំពីររូបទៀតគឺ៖ សម្តេច សីហនុ និង លោក ខៀវ សំផន ។ នៅថ្ងៃនោះ ក៏ជាលើកទីមួយដែរ ដែលខ្ញុំសរសេរសំបុត្រទៅ ទេព ជារ៉ុង នៅឯប្រទេសបារាំង ដើម្បីឲ្យដឹងពីសភាពការណ៍នៅទីក្រុងបាងកកអស់ជាច្រើនសប្តាហ៍កន្លងមក ចាប់តាំងពីខ្ញុំមកដល់ទីក្រុងនេះ ។ ខ្ញុំរៀបរាប់អំពីការមិនទុកចិត្តគ្នា ក្នុងចំណោមថ្នាក់ដឹកនាំរបស់យើង និង អំពីការយល់ឃើញផ្ទាល់ខ្លួនរបស់ខ្ញុំ លើករណីបង្កើតរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ។ ខ្ញុំសរសេរជាអាទិថា "ជីវភាពរស់នៅជាមួយលោកប្រធាន សឺន សាន មិនមែនជាការលំបាកពេកនោះទេ ប្រសិនបើយើងមិនមានមហិច្ឆតាធំធេងពេក" ។ "ខ្ញុំត្រូវបានលោកប្រធានចាត់តាំងឲ្យបង្កើតនូវប្រព័ន្ធត្រួតពិនិត្យហិរញ្ញវត្ថុមួយ ដែលធ្វើឲ្យមេៗខ្លះមិនសប្បាយចិត្ត"... "សមាជិក រ.ជ.រ.ប.ខ. ទាំងអស់ត្រូវដឹងពីមូលហេតុពិតប្រាកដថាហេតុអ្វីបានជាសមាជិករ.ជ.រ.ប.ខ.សុខចិត្តចូលរួមក្នុងរដ្ឋាភិបាលចម្រុះ។ តាមពិតទៅ ការចូលរួមនេះជាមធ្យោបាយតែមួយគត់ ដែលអាចឲ្យ រ.ជ.រ.ប.ខ. ទទួលបាននូវជំនួយអន្តរជាតិ ដែលយើងកំពុងត្រូវការជាចាំបាច់ នៅចំពោះមុខបញ្ហាដ៏លំបាកគ្រប់យ៉ាង ទាំងខាងក្នុងទាំងខាងក្រៅ" ។ នៅក្នុងសំបុត្រទី២ ចុះ ថ្ងៃ

ទី ២៣ មិថុនា ទៅ ទេព ជារ៉ុង ជាភាសាបារាំង ខ្ញុំសរសេរថា៖"តាមយោបល់ខ្ញុំផ្ទាល់ ការចូលរួមបង្កើតរដ្ឋាភិបាលចម្រុះនេះ មិនអាចនិយាយបានថាជាជោគជ័យដ៏ត្រចះត្រចង់របស់យើងទេ ។ ក៏ប៉ុន្តែចាប់ពីពេលនេះទៅ យើងគ្រាន់តែអាចសង្ឃឹមថា នឹងមានដំណោះស្រាយនយោបាយចំពោះបញ្ហាកម្ពុជា" ។ "លោកប្រធានបានត្រូវទទួលការគាបសង្កត់ខ្លាំងណាស់ ដើម្បីទទួលយកនូវរូបមន្តនៃរដ្ឋាភិបាលចម្រុះនេះ ។ យើងនឹងរង់ចាំមើលតើយើងអាចដកខ្លួនផុតពីសភាពការណ៍បច្ចុប្បន្ន ដែលមិនអនុគ្រោះដល់យើងទាល់តែសោះ" ។ "ជារ៉ុង អាចនៅចាំបានឬទេ ដូចដែលខ្ញុំធ្លាប់ប្រាប់ ជារ៉ុង កាលពីពេលមុននោះថា នៅពេលណាដែលយើងសុខចិត្តចូលរួមជាមួយខ្មែរក្រហមនោះ ក៏ព្រោះតែលោកប្រធានមិនអាចពឹងលើ..... (ខ្ញុំចង់និយាយថា "ពឹងលើសមត្ថភាពយើង និង ពឹងលើមេដឹកនាំផ្ទៃក្នុងរបស់យើង") ។ តែទោះជាយ៉ាងណាក៏ដោយ យើងទាំងអស់គ្នាត្រូវតែមានការប្រុងប្រយ័ត្នខ្ពស់ ។ យើងត្រូវតែទទួលយកចំណុចបត់បែននេះថាជាមេរៀន ហើយត្រៀមប្រឈមនឹងហេតុការណ៍បន្ទាន់ទាំងអស់ដែលអាចកើតមាន ។ ការតស៊ូជាការលំបាក និង វែងឆ្ងាយសម្រាប់យើងទាំងអស់គ្នា"[157]។ ខ្ញុំបានប្រាប់ ជារ៉ុង ថាគណៈប្រតិភូរបស់ រ.ជ.រ.ប.ខ. នឹងត្រូវចាត់តាំងឲ្យចេញទៅស្វែងរកការគាំទ្រពីគ្រប់តំបន់ក្នុងពិភពលោក ជូនចំពោះរដ្ឋាភិបាលចម្រុះថ្មីនេះ ។

សមាសភាពរដ្ឋាភិបាលត្រីភាគី ដែលថៃទទួលស្គាល់មុនគេ

ការចុះហត្ថលេខាប្រកាសបង្កើតរដ្ឋាភិបាល បានបើកផ្លូវឲ្យរដ្ឋាភិបាលថៃទទួលស្គាល់លោកតា សឺន សាន ជានាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ។ ដោយសារការទទួលស្គាល់នេះ រ.ជ.រ.ប.ខ. អាចទាក់ទងដោយចេញ

[157] Ieng Mouly [Lettre à Tep Darong] le 23-6-82.

មុខជាមួយក្រសួងការបរទេសថៃ និង ជាមួយអង្គទូតនានាដែលមានស្ថានទូតប្រចាំនៅទីក្រុងបាងកក ។ រ.ជ.រ.ប.ខ. ក៏អាចបើកគណនីផ្ទាល់របស់ខ្លួនបាន ដោយប្រើលិខិតទទួលស្គាល់ ដែលលោកឧត្តមសេនីយ ប្រេម ទិនស៊ុឡានន្ត[158] (Prem Tinsulanond) ផ្ញើជូនលោកតា សឺន សាន ជាឯកសារសំអាង ។ ដោយសារលោក ហ្គាហ្វា ជាអ្នករៀបចំឯកសារបើកគណនី ដូច្នេះលោក ហ្គាហ្វា បានដាក់ឈ្មោះខ្លួនឯងជាមួយនឹងឈ្មោះលោក ប៊ុន សាយ និង លោកឧត្តមសេនីយ សក់ ស៊ុតសាខន ជាអ្នកប្រើប្រាស់គណនីនេះ ។ នៅពេលជាមួយគ្នានោះ លោកតា សឺន សាន ក៏បានតែងតាំងលោក ហ្គាហ្វា ជាប្រធានខុទ្ទកាល័យនាយករដ្ឋមន្ត្រី បន្ថែមលើការកិច្ចក្នុងការទាក់ទងជាអចិន្ត្រៃយ៍ជាមួយប្រទេសជាមិត្ត ជាពិសេស ជាមួយប្រទេសអាស៊ាន និង សហរដ្ឋអាមេរិក ។

លើកលែងតែលោក អ៊ឹម ឈូដេត ចេញ មន្ត្រីជាន់ខ្ពស់របស់រ.ជ.រ.ប.ខ. ដូចជាឧត្តមសេនីយ ដៀន ដែល លោក ហ៊ីង គន្ធុន លោក នាង ជិនហន ជាដើមហាក់ដូចជាមិនស្ទុះស្ទាចង់ចូលរួមក្នុងរដ្ឋាភិបាលនោះ ឬ ក៏មិនចង់ឲ្យមានសារសំខាន់ដល់រដ្ឋាភិបាលនេះឡើយ ។ ទាំងនេះក៏ប្រហែលជាដោយសារតែពួកគេមិនចង់ចូលរួមធ្វើជាដៃគូជាមួយខ្មែរក្រហម និង ជាមួយសម្តេច សីហនុ ។ នៅទីបំផុត ឈ្មោះមន្ត្រីដែលត្រូវបញ្ចូលក្នុងបញ្ជីសមាជិករដ្ឋាភិបាល ក៏មានត្រឹមតែមន្ត្រីថ្នាក់មធ្យម ។ នៅខែ កក្កដា ១៩៨២ នៅពេលដែលរដ្ឋាភិបាលចម្រុះត្រូវប្រកាសសមាសភាពជាផ្លូវការ លោក ប៊ុន សាយ ត្រូវបានតែងតាំងជាសមាជិកគណៈកម្មាធិការសម្របសម្រួលខាងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លោក អ៊ឹម ឈូដេត ជាសមាជិកខាងការពារជាតិ លោកវេជ្ជបណ្ឌិត ប៊ូ ខេង ជាសមាជិកខាងសុខាភិបាល និង សង្គមកិច្ច លោក ធួយ វី សាស្ត្រាចារ្យ ជាសមាជិកខាងអប់រំជាតិ ។

[158] Prem Tinsulanonda (General), Prime Minister of Thailand, Letter to His Excellency Mr. Son Sann, Prime Minister of the Coalition Government of Democratic Kampuchea, July 29, B.E 2525 (1982).

លោកវេជ្ជបណ្ឌិត ប៊ូ ខេង និង លោក ធួយ វី បានចូលរួមក្នុងរ.ជ.រ.ប.ខ. ជាច្រើនឆ្នាំមកហើយៗកំពុងរស់នៅក្រោមការគ្រប់គ្រងរបស់ឧត្តមសេនីយ ជៀន ដែល និង លោក ហ៊ីង គន្ធុន ក្នុងជំរុំអំពិល ។ ក្រោយពេលដែលរដ្ឋាភិបាលចម្រុះបានត្រូវប្រកាស និង បង្កើតជាផ្លូវការ រដ្ឋាភិបាលនេះក៏ត្រូវបានទទួលស្គាល់ជាផ្លូវការពីអង្គការសហប្រជាជាតិ និង ពីប្រទេសជាច្រើននៅក្នុងពិភពលោក ។ សមាជិកគណៈកម្មាធិការសម្របសម្រួល ត្រូវបានទទួលស្គាល់ជារដ្ឋមន្ត្រី តាមពិធីការដែលមានឋានៈខ្ពស់ជាងមន្ត្រីឯទៀត ។ ដូច្នេះ នៅក្នុងរ.ជ.រ.ប.ខ. មន្ត្រីថ្នាក់ទាបត្រូវបានទទួលឋានៈខ្ពស់ជាង មន្ត្រីជាន់ខ្ពស់នៃរណសិរ្ស ដោយយោងតាមពិធីការរបស់រដ្ឋាភិបាល ។

ខ្ញុំ និង បង ប៉ែន ថាល់ ទៅបំពេញបេសកកម្មនៅអាហ្វ្រិក

នៅខែ តុលា ១៩៨២ បង ប៉ែន ថាល់ និង ខ្ញុំ ត្រូវបានចាត់តាំងឲ្យចេញទៅបំពេញបេសកកម្មនៅទ្វីបអាហ្វ្រិក ដើម្បីស្វែងរកការគាំទ្រជូនចំពោះរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យថ្មីនេះ ។ ដើម្បីរៀបចំដំណើររបស់យើងៗត្រូវត្រឡប់ទៅទីក្រុងប៉ារីសសិន ដែលនៅទីនោះ ទើបយើងអាចទទួលយកទិដ្ឋាការ និង សំបុត្រយន្តហោះរបស់យើង ។ ខ្ញុំបានដឹងថាប្រទេសម៉ាឡេស៊ីបានជួយរៀបចំដំណើររបស់យើង ។ ពួកយើងត្រូវចេញទៅបីប្រទេសគឺ ប្រទេសនីហ្សេ (Niger) ប្រទេសហ្គាណា (Ghana) និង ប្រទេសម៉ាលី (Mali) ។ ពីទីក្រុងប៉ារីស យើងហោះទៅនីហ្សេ (Niger) តាមយន្តហោះអែរអាហ្វ្រិក (Air Afrique) ដែលមិត្តបារាំងយើងខ្លះនិយាយលេងហៅថា "យន្តហោះ អែរប្រហែល..." ព្រោះគ្រាន់តែប្រហែលៗមិនប្រាកដថាអាចហោះ ឬ អាចមិនហោះ(?)តាមកាលវិភាគរបស់ខ្លួនឡើយ ។

យើងគ្រោងទៅប្រទេសនីហ្សេមួយថ្ងៃ ។ យើងបានទៅដល់ទីក្រុងនីញ៉ាម៉េ (Niamey) ពេលល្ងាច ។ នោះគឺជាលើកទីមួយ ដែលខ្ញុំធ្វើដំណើរទៅកាន់ ទ្វីបអាហ្វ្រិក ។ នៅពេលនោះ ខ្ញុំនៅមិនទាន់ដឹងខ្លួនថាពួកយើងត្រូវធ្វើដំណើរទៅបំពេញបេសកកម្មជាអ្នកតំណាងប្រជាជាតិមួយនៅឡើយទេ ។ យើងចុះពីយន្តហោះ ដោយដើរលាយឡំជាមួយអ្នកដំណើរឯទៀតយ៉ាងសាមញ្ញបំផុត ។ យើងចេញទៅយកវ៉ាលីស ហើយជួលតាក់ស៊ីជិះឆ្ពោះទៅរកសណ្ឋាគារខ្នាតអន្តរជាតិមួយដែលមានអ្នកគ្រប់គ្រងជាជនជាតិបារាំង ។ នៅម៉ោងប្រហែល ៤ ល្ងាច ខ្ញុំទូរស័ព្ទទៅក្រសួងការបរទេស ដើម្បីសុំណាត់ជួបមន្ត្រីជាន់ខ្ពស់ ។ ខ្ញុំត្រូវបានទទួលការណាត់ ឲ្យជួបជាមួយមន្ត្រីជាអគ្គនាយកក្រសួងការបរទេសនៃប្រទេសនីហ្សេ (Niger) នៅថ្ងៃស្អែកពេលព្រឹក ។ ក៏ប៉ុន្តែ នៅពេលដែលខ្ញុំបានទទួលការណាត់ឲ្យជួបរួចហើយនោះ ទើបខ្ញុំនឹកឃើញថា ពួកយើងពុំមានលិខិតផ្លូវការការទូតណាមួយបញ្ជាក់ថា ពួកយើងជាអ្នកតំណាងរដ្ឋាភិបាលចម្រុះសោះឡើយ ។ ខ្ញុំនឹកហួសចិត្តថាមិនគួរធ្វេសប្រហែស មិនបានត្រៀមឯកសារដូច្នេះទេ ។ តាមពិតទៅ ខ្ញុំនៅមិនទាន់មានបទពិសោធន៍ខាងផ្នែកការទូតនៅឡើយ ។ នេះជាការងាររដ្ឋលើកទីមួយរបស់ខ្ញុំ ។ ដោយខ្ញុំបានយកជាប់ទៅជាមួយ នូវម៉ាស៊ីនអង្គុលីលេខផ្ទាល់ខ្លួនរបស់ខ្ញុំៗក៏ចាប់ផ្តើមវាយអត្ថបទលិខិតការទូត លើក្រដាសផ្លូវការរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលចម្រុះ ។ វាយរួចហើយ ខ្ញុំក៏ចុះហត្ថលេខាខ្លួនឯង ដោយធ្វើត្រាប់តាមហត្ថលេខាលោកតា សឺន សាន នាយករដ្ឋមន្ត្រី ។

ពួកយើងទាំងពីរនាក់ បង ប៉ែន ថាល់ និង ខ្ញុំ ត្រូវបានបង្ហាញតាមកំណត់ការទូតថា ជាសមាជិកខុទ្ទកាល័យនាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ជូនទៅមន្ត្រីពិធីការនៃក្រសួងការបរទេស ។ លោកអគ្គនាយកទទួលពួកយើងយ៉ាងរាក់ទាក់ណាស់ ។ គាត់ជាមនុស្សពូកែនិយាយៗ ពីនោះពីនោះឥតឈប់

ឈរ ។ នៅលើការិយាល័យ ខ្ញុំឃើញមានគរទៅដោយកាសែតជាភាសាបារាំងរបស់បារាំងឈ្មោះឡឺម៉ុង ឌីប្លូម៉ាទិច (Le Monde Diplomatique) ។ តាមពិតទៅ ភាគច្រើនបញ្ហាវន្តនៅក្នុងប្រទេសកំពុងអភិវឌ្ឍ រួមទាំងរូបខ្ញុំផងចូលចិត្តអានកាសែតបារាំងនេះណាស់ ។ លោកអគ្គនាយក និយាយភាសាបារាំងបានយ៉ាងស្ទាត់ជំនាញ ។ បង ប៉ែន ថាល់ ធ្វើបទអត្ថាធិប្បាយពីសភាពការណ៍ទូទៅនៅកម្ពុជា ។ គាត់សង្កត់ធ្ងន់ពីការតស៊ូរបស់ប្រជាជនកម្ពុជា ដើម្បីរំដោះចេញពីការកាន់កាប់របស់កងទ័ពវៀតណាម ។ បន្ទាប់មកបង ប៉ែន ថាល់ ទុកឲ្យខ្ញុំពន្យល់ពីយន្តការ និង សមាសភាពនៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ។

ជាដំបូងខ្ញុំ ពន្យល់ថា ក្រុមយើងជាក្រុមអ្នកជាតិនិយមដែលដឹកនាំដោយលោក សឺន សាន បច្ចុប្បន្នជានាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ។ ខ្ញុំបញ្ជាក់ថា "ពួកយើងមានកងទ័ព មានអង្គការចាត់តាំងនយោបាយ និងមានប្រជាពលរដ្ឋផ្ទាល់ខ្លួនរបស់ពួកយើង.." "មុនពេលដែលវៀតណាមចូលមកឈ្លានពានកម្ពុជា ពួកខ្មែរក្រហមជាសត្រូវស្លាប់រស់របស់យើង ដោយសារពួកនេះបានកាប់សម្លាប់ប្រជាពលរដ្ឋយើងអស់រាប់លាននាក់" ។ "ក៏ប៉ុន្តែនៅក្រោមអំណាចវៀតណាម ប្រទេសយើងអាចនឹងរលាយចេញពីផែនដី ប្រសិនបើខ្មែរមិនរួបរួមគ្នាការពារទឹកដីទេ ។ ហេតុនេះហើយ ទើបក្រុមយើងបានចូលរួមក្នុងរដ្ឋាភិបាលចម្រុះជាមួយសម្តេច សីហនុ និង ពួកខ្មែរក្រហមតាមរូបមន្តដ៏ទូលំទូលាយមួយ ដែលក្នុងនោះភាគីនីមួយៗមានស្វ័យភាពមានកងទ័ព និង មានអង្គការចាត់តាំងនយោបាយផ្ទាល់របស់ខ្លួន" ។ "រដ្ឋាភិបាលនេះ មានក្រសួងរបស់ខ្លួនដែលមានឈ្មោះថា"គណៈកម្មាធិការសម្របសម្រួល" ។ ខ្ញុំបន្តទៀតថា៖ "នៅក្នុងគណៈកម្មាធិការនីមួយៗមានរដ្ឋមន្ត្រីមួយនាក់មកពីភាគីនីមួយៗ ។ ដូច្នេះក្នុងគណៈកម្មាធិការមួយមានរដ្ឋមន្ត្រី ៣ នាក់ ដែលម្នាក់ៗដើរតួនាទីតែក្នុងរង្វង់ភាគីរបស់ខ្លួនតែប៉ុណ្ណោះ គ្មាន

អំណាចទៅលើកាគីឯទៀតឡើយ ។ រដ្ឋមន្ត្រីរបស់ រ.ជ.រ.ប.ខ.មានអំណាចតែក្នុងជួរ រ.ជ.រ.ប.ខ. រដ្ឋមន្ត្រី ហ៊ុន សុិន ប៊ិចមានអំណាចតែក្នុង ហ៊ុន សុិន ប៊ិច ឯរដ្ឋមន្ត្រីរបស់ខ្មែរក្រហម ក៏មានអំណាចតែក្នុងរង្វង់ខ្មែរក្រហមដូច្នោះដែរគឺ គ្មានអំណាចទៅលើកាគីផ្សេងឯទៀតទេ ។ រដ្ឋាភិបាលចម្រុះ មានរដ្ឋមន្ត្រីការពារប្រទេស ៣ រូប រដ្ឋមន្ត្រីអប់រំ ៣ រូប រដ្ឋមន្ត្រីសេដ្ឋកិច្ច ហិរញ្ញវត្ថុ ៣ រូប រដ្ឋមន្ត្រីសុខាភិបាល និងសង្គមកិច្ច ៣ រូប ។ លើកលែងតែក្រសួងការបរទេស ដែលស្ថិតនៅក្រោមអំណាចផ្ទាល់របស់អនុប្រធានកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន ។ នៅពីលើគណៈរដ្ឋមន្ត្រីនេះ មានគណៈរដ្ឋមន្ត្រីស្នូលមួយទៀត (Inner Cabinet)[159] ដែលរួមមានសម្តេចនរោត្តម សីហនុ ជាប្រធានកម្ពុជាប្រជាធិបតេយ្យ លោក ខៀវ សំផន ជាអនុប្រធានកម្ពុជាប្រជាធិបតេយ្យ និង លោក សឺន សាន ជានាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ។ នៅទីបញ្ចប់ខ្ញុំបញ្ជាក់ថា "គោលបំណងរបស់រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ មិនមែនស្វែងរកដំណោះស្រាយយោធានោះទេ ។ កងកម្លាំងរបស់យើងទាំងអស់នឹងបង្ខំឲ្យវៀតណាមចូលមកចរចា ព្រោះថាពួកយើងកំពុងធ្វើការតស៊ូប្រយុទ្ធ ដើម្បីឲ្យមានការអនុវត្តសេចក្តីសំរេចរបស់អង្គការសហប្រជាជាតិ ដែលតម្រូវឲ្យវៀតណាមដកកងទ័ព ចេញពីកម្ពុជា និង ដើម្បីឲ្យមានការបោះឆ្នោតទូទៅនៅកម្ពុជា" ។

លោកអគ្គនាយកហាក់ដូចជាយកចិត្តទុកដាក់ស្តាប់ណាស់ ហើយហាក់ដូចជាទទួលយកនូវអ្វីដែលយើងបានរ៉ាយរ៉ាប់ទាំងអស់នោះ ។ លោកអគ្គនាយកបានស្នើឲ្យយើងជួបផ្ទាល់ជាមួយលោករដ្ឋមន្ត្រីក្រសួងការបរទេសទៀតផង ។ គាត់បញ្ចេញកាយវិការយ៉ាងសាមញ្ញបំផុតគឺ គាត់ដើរទៅបើកទ្វារបន្ទប់គាត់ ហើយដើរបង្ហួសទៅបើកទ្វារបន្ទប់មួយទៀត ដែលនៅជាប់ជាមួយនោះ ។ ក៏ប៉ុន្តែ លោករដ្ឋ

[159] Samdech Norodom Sihanouk, H.E. Mr. Son Sann, H.E. Mr. Khieu Samphan, CGDK, Declaration of the Formation of the Coalition Government of Democratic Kampuchea , op. cit.

មន្ត្រីមិននៅក្នុងបន្ទប់នោះទេ ។ ដូច្នេះ យើងក៏លាលោកអគ្គនាយកត្រឡប់ទៅសណ្ឋាគាររបស់ពួកយើងវិញ ដោយនឹកសង្ឃឹមថាមិត្តនីហ្សេរបស់យើងនឹងយល់ពីបញ្ហារបស់យើង និង គាំទ្រយើង ព្រោះថាសារដែលយើងនាំទៅជាមួយនោះគឺ ជាសារសន្តិភាព ។ អ្វីដែលយើងចង់បានគឺ លទ្ធិប្រជាធិបតេយ្យពិតប្រាកដសម្រាប់ប្រទេសយើង សម្រាប់ប្រជាពលរដ្ឋយើង ។ យើងមិនត្រូវការឲ្យខ្មែរក្រហមត្រឡប់មកកាន់អំណាចវិញឡើយ ។

នៅរសៀលនៃថ្ងៃដដែល ពួកយើងក៏ចេញដំណើរឆ្ពោះទៅប្រទេសហ្គាណា (Ghana) គឺ ជាប្រទេសមួយដែលប្រើភាសាអង់គ្លេស ។ យើងធ្វើដំណើរឆ្លងកាត់ប្រទេសបួគីណាហ្វាសូ (Burkina Faso) ដែលនៅសម័យនោះមានឈ្មោះថា អូត វ៉ុលតា (Haute Volta) ។ យើងធ្វើការហោះហើរមិនយូរប៉ុន្មាន ក៏ទៅដល់ទីក្រុងអាក្រា (Accra) នៃប្រទេសហ្គាណា ។ នៅពេលដែលយន្តហោះៗកាន់ តែជិតទៅដល់ ខ្ញុំសង្កេតឃើញទេសភាពពណ៌ខៀវបៃតងកាន់តែច្បាស់ឡើងៗ ដែលអាចបញ្ជាក់ថា ប្រទេសនេះមានភាពសម្បូរណ៌សប្បាយជាងប្រទេសនីហ្សេ ។ នៅពេលយន្តហោះចុះចត ខ្ញុំសង្កេតពីលើយន្តហោះឃើញរថយន្តលីមូស៊ីនដ៏ប្រណិតម៉ាកម៉ែកស៊ីដែស (Mercedes) ខ្មៅមួយគ្រឿងចត ហាក់បីដូចជារង់ចាំមន្ត្រី ជាន់ខ្ពស់វីអាយភី (VIP) ណាម្នាក់នៅទីនោះ ។ នៅពេលដែលយើងកំពុងដើរចេញពីយន្តហោះលាយឡំជាមួយអ្នកដំណើរឯទៀតឆ្ពោះត្រង់ទៅបញ្ជរអន្តោប្រវេសន៍ មន្ត្រីជនជាតិហ្គាណាពីរនាក់ស្លៀកពាក់ស៊ីវិលដើរស្ទាក់មុខយើង ហើយនិយាយថា៖ "តើលោកទាំងពីរជាទូតមកពីកម្ពុជាឬ?" ខ្ញុំមិនច្បាស់ថាអ្នកណាជាទូតនោះទេ ក៏ប៉ុន្តែប្រញាប់ប្រញាល់ឆ្លើយថា "បាទ ! បាទ ! ពិតមែនហើយ" ។ រំពេចនោះ មន្ត្រីម្នាក់ក៏ប្រញាប់ប្រញាល់យកលិខិតឆ្លងដែន និង សំបុត្រយន្តហោះរបស់ពួកយើងទៅបោះត្រាទិដ្ឋាការចូល ឯមន្ត្រីម្នាក់ទៀតនាំពួកយើងចូលទៅក្នុងបន្ទប់វីអាយភី

នៅព្រលានយន្តហោះនោះ ។ មន្ត្រីទាំងពីរនាក់នោះជាមន្ត្រីពិធីការមកពីក្រសួងការបរទេសហ្គាណា ដែលមានការកិច្ចមកទទួលពួកយើងនៅអាកាសយានដ្ឋាន ។

ផ្លាស់ឋានៈពីជនភៀសខ្លួន ទៅជាអ្នកការទូត

នៅក្នុងបន្ទប់រីអាយកីនោះ ពួកយើងបានត្រូវរាយការណ៍ ឲ្យដឹងពីកម្មវិធីនៃការស្នាក់អាស្រ័យរបស់យើង ។ ពួកយើង ត្រូវទៅស្នាក់នៅក្នុងសណ្ឋាគារដ៏ធំខ្នាតអន្តរជាតិមួយនៅចំកណ្តាលក្រុង ដោយយើងជាអ្នកចេញលុយ ឯណ្ងាចនេះ ពួកយើងនឹងទៅជួបជាមួយអគ្គនាយកក្រសួងការបរទេស ។ យើងត្រូវសម្រាកនៅទីក្រុងអាក្រា (Accra) មួយយប់ រួចនឹងចេញដំណើរទៅប្រទេសម៉ាលីទៀត ។ ក្រោយពេលដែលមន្ត្រីពិធីការ បានប្រមូលវ៉ាលីស និង បំពេញបែបបទអន្តោប្រវេសន៍រួចហើយ មន្ត្រីទាំងនោះក៏នាំពួកយើងឆ្ពោះទៅរកវ៉ាយន្តលីម៉ូស៊ីនម៉ែកស៊ីដែស (Mercedes) ខ្មៅដែលរង់ចាំនៅខាងក្រៅស្រាប់ ។ ខ្ញុំចូលទៅអង្គុយនៅផ្នែកខាងក្រោយ ហើយរៀបចំខ្លួនឲ្យសមហាន: ព្រោះមិនដែលនឹកស្មានសោះថាអាចត្រូវទទួលបដិសណ្ឋារកិច្ចបែបនេះសោះ ។ តាមពិតទៅ ខ្ញុំធ្លាប់តែគិតថាខ្លួនឯងជាជនភៀសខ្លួន ឬ ត្រឹមតែជាមន្ត្រីនៃរដ្ឋាភិបាលក្រៅស្រុកមួយប៉ុណ្ណោះ មិនដែលគិតថាខ្លួនជាមន្ត្រីការទូត ដែលកំពុងតែជាអ្នកតំណាងនៃប្រជាជាតិម្តងណាឡើយ ។

នៅពេលចូលជួបជាមួយលោកអគ្គនាយក យើងនិយាយក្នុងន័យដដែលដូចយើងធ្លាប់និយាយនៅនីហ្សេរីយ៉ាងដូច្នោះដែរ លើកលែងតែនៅហ្គាណា យើងនិយាយជាភាសាអង់គ្លេស ។ នៅពេលទៅដល់ភ្លាមនោះ លោកអគ្គនាយក និយាយថា កាលពីអាទិត្យមុន គាត់ក៏បានទទួលគណៈប្រតិភូមកពីកម្ពុជាដែរគឺ គណៈប្រតិភូមកពីរដ្ឋាភិបាលភ្នំពេញ ។ តាមពិតទៅរបបក្រុងភ្នំពេញក៏មមាញឹក ក្នុងការស្វែងរកការគាំទ្រខាងការទូតពីប្រទេសនានានៅទ្វីបអាហ្វ្រិក (Afrique) ដែរ ។

លោកអគ្គនាយកហាក់ដូចជាចង់រង្វេងមិនច្បាស់ថាខាងណាជារដ្ឋាភិបាល ក្នុងស្រុក ខាងណាជារដ្ឋាភិបាលក្រៅស្រុកឡើយ ។ ក៏ប៉ុន្តែ ពួកយើងយល់ថា នៅទីបញ្ចប់ ប្រទេសហ្គាណាគាំទ្រខាងយើង ។ នៅពេលយប់ យើងមិនហ៊ានចេញក្រៅសណ្ឋាគារទេ ដោយសារប្រទេសហ្គាណាទើបកើតមានរដ្ឋប្រហារក្នុងពេលថ្មីៗ ។ នៅសណ្ឋាគារក៏មានកងកម្លាំងប្រដាប់អាវុធឈរយាមដែរ ។

មន្ត្រីពិធីការបានប្រាប់ពួកយើងឲ្យភ្ញាក់ពីព្រឹក ដើម្បីត្រៀមចេញទៅព្រលានយន្តហោះ នៅម៉ោងបួនហៀបភ្លឺ ។ ដូច្នេះយើងក៏ត្រៀមខ្លួន ។ បង ប៉ែន ថាល់ គាត់ជាអ្នកចូលចិត្តពិសាស្រា ។ ទោះជានៅពេលព្រឹកព្រហាម ក៏គាត់ចូលចិត្តពិសាស្រាវីស្គីសូដាទឹកកកដែរ គាត់មិនពិសាអាហារពេលព្រឹកដូចយើងតាមធម្មតាទេ ។ នៅពេលដែលយើងរង់ចាំរថយន្ត ដែលត្រូវនាំយើងទៅព្រលានយន្តហោះនោះ គាត់នៅតែបន្តពិសាស្រាវីស្គីរហូត ។ យើងរង់ចាំរថយន្តតាំងពីម៉ោង ៤ រហូតដល់ម៉ោង ៨ ព្រឹក ទើបឃើញរថយន្តមកដល់ ។ នៅពេលទៅដល់ព្រលានយន្តហោះ យើងត្រូវអង្គុយរង់ចាំក្នុងបន្ទប់ វីអាយភី បន្តទៅទៀតទម្រាំឡើងជិះយន្តហោះ ។ យើងនៅរង់ចាំអស់ជាច្រើនម៉ោង ។ បង ប៉ែន ថាល់ សប្បាយនឹងពិសាស្រាវីស្គីនេះណាស់ ដែលគេដាក់បំរើក្នុងបន្ទប់វីអាយភី ។ ពេលខ្ញុំហៅកាហ្វេ គាត់ហៅ វីស្គី ។

នៅពេលយើងឡើងជិះយន្តហោះនោះ ធាតុអាកាសហាក់ដូចជាកាន់តែក្តៅខ្លាំងឡើងដែលពិបាកនឹងទ្រាំ ។ ពួកយើងបានត្រូវអញ្ជើញឲ្យអង្គុយនៅកៅអីជួរទីមួយក្នុងហាន:ជាភ្ញៀវរបស់រដ្ឋាភិបាលហ្គាណា ។ យើងត្រូវហោះហើរ ពីហ្គាណាទៅប្រទេសកូតឌីវ័រ ឬ អាយវ៉ឺរីខូស (Ivry Coast) ដើម្បីរង់ចាំជើងយន្តហោះក្នុងរយៈពេលបីថ្ងៃ មុននឹងបន្តទៅប្រទេសម៉ាលីដែលជាបេសកកម្មចុងក្រោយរបស់ពួកយើង ។ មុននឹងទៅដល់ប្រទេសកូតឌីវ័រនោះ យើងក៏ត្រូវឆ្លង កាត់ប្រទេសអូតវ៉ុលតាម្តងទៀត ។ នៅពេលយន្តហោះចុះចត ដើម្បីទទួលអ្នកដំណើរថែមទៀត បង ប៉ែន

ថាល់ ប្រាប់ខ្ញុំថាគាត់ចេញទៅក្នុងព្រលានយន្តហោះមួយភ្លែត ដើម្បីចង់ឃើញថា តើនៅប្រទេសអូតវ៉ុលតានេះមានអ្វីលក់ខ្លះ? ខ្ញុំមិនចេញទេ ខ្ញុំនៅអង្គុយនៅនឹងកន្លែងក្នុងយន្តហោះ។ កន្លះម៉ោងក្រោយមកបង ប៉ែន ថាល់ ត្រឡប់មកវិញ ដោយបីស្រាវីស្គីមួយដបមកផង ។ គាត់បន្តពិសាស្រាហូតពីអូតវ៉ុលតារហូតដល់យន្តហោះចុះចតនៅកូតឌីវ័រ។

បង ប៉ែន ថាល់ ដួលសន្លប់ តែគាត់ថាអត់ឈឺអ្វីទេ?

ដោយយើងត្រូវរង់ចាំក្នុងរយៈពេល ៣ ថ្ងៃ ទើបមានជើងយន្តហោះដឹកនាំយើងបន្តទៅប្រទេសម៉ាលីនោះ ខ្ញុំគិតថាគួរតែឆ្លៀតឱកាសចេញទៅដើរលេងនៅឯទីក្រុងអាប៊ីដហ្សង់ (Abidjan) ផងដែរ ។ យន្តហោះចុះចតដោយសុវត្ថិភាព នៅអាកាសយានដ្ឋានអាប៊ីដហ្សង់ ។ ដោយហេតុពួកយើងពុំមានទិដ្ឋាការចូលប្រទេសកូតឌីវ័រ យើងក៏ត្រូវដើរបន្តកន្ទុយគ្នាតម្រង់ទៅបញ្ជរអន្តោប្រវេសន៍ ដើម្បីសាកល្បងសុំទិដ្ឋាការនៅព្រលានយន្តហោះតែម្តង ។ ខ្ញុំដើរពីមុខបង ប៉ែន ថាល់ តាមដួរទៅមុខយ៉ាងយឺតៗ ដោយសារមានអ្នកដំណើរជាច្រើននាក់ធ្វើដំណើរទៅទីដៅតែមួយ ។ នៅពេលនោះ យើងកាន់តែខិតជិតដល់បញ្ជរនគរបាលអន្តោប្រវេសន៍ទៅហើយ ខ្ញុំឮសូរសម្លេងដួលកឹងយ៉ាងខ្លាំងនៅពីក្រោយខ្នង ។ នៅពេលបែរទៅក្រោយ ខ្ញុំឃើញបង ប៉ែន ថាល់ ដួលច្រងាងៗឥតកំរើកបាត់បង់ស្មារតីទាំងស្រុង ។ គាត់ដួលសន្លប់ព្រោះប្រហែលជាជាតិសុរាឡើងខ្លាំងបូកផ្សំនឹងធាតុអាកាសនៅទ្វីបអាហ្វ្រិកក្តៅខ្លាំងផង ធ្វើឲ្យសិរីរាង្គទ្រាំទ្រពុំបាន ។ ខ្ញុំកិតភ័យខ្លាំងណាស់ ។ ខ្ញុំស្រែកហៅរកជំនួយជាបន្ទាន់ ហើយខិតខំធ្វើចលនារាងកាយគាត់ឲ្យដឹងខ្លួនឡើងវិញ ។ ខ្ញុំស្រែកសុំឲ្យគេជួយរកតាក់ស៊ីដើម្បីដឹកគាត់ទៅពេទ្យជាបន្ទាន់ ។ នៅពេលនោះ មនុស្សជាច្រើនក៏ផ្អើលឆោឡោ ចំណែកមន្ត្រីនគរបាលក៏ជួយជ្រោមជ្រែងសម្រួលរកតាក់ស៊ីឲ្យនាំទៅ

មន្ទីរពេទ្យដែរ ។ នៅពេលដើរចេញទៅខាងក្រៅព្រលានយន្តហោះ បង ប៉ែន ថាល់ ចាប់ដឹងខ្លួនខ្លះៗហើយ ។ នៅតាមផ្លូវ ឆ្ពោះទៅទីក្រុងអាប៊ីដហ្សង់បង ប៉ែន ថាល់ ដឹងខ្លួនទាំងស្រុងតែម្តង ។ គាត់សួរខ្ញុំថា៖ "យើងជិះតាក់ស៊ីទៅណា?" ខ្ញុំឆ្លើយថា "យើងទៅពេទ្យ" ។ គាត់សួរតទៀតថា "អ្នកណាឈឺស្អី?" ខ្ញុំព្យាយាមពន្យល់គាត់ថា ពេលមុននេះបន្តិចគាត់ដួលសន្លប់មិនដឹងខ្លួន ។ ប៉ុន្តែបង ប៉ែន ថាល់ និយាយថា គាត់អត់មានឈឺអ្វីផង ។ តាមការណែនាំរបស់អ្នកបើកតាក់ស៊ី យើងធ្វើដំណើរទៅគ្លីនិកឯកជនរបស់ជនជាតិបារាំងមួយ ។ នៅពេលទៅដល់បង ប៉ែន ថាល់ មានអាការៈជាសះស្បើយទាំងស្រុង ។ នៅពេលគិលានុប្បដ្ឋាយិកាសួរបង ប៉ែន ថាល់ ឆ្លើយថាគាត់អត់មានឈឺអ្វីទេ ហើយក៏និយាយកំប្លែងលេងជាមួយនារីនោះទៅវិញ ។ មែនទែន ពួកយើងចំណាយប្រាក់ប្រមាណ ២០០ ហ្វ្រង់បារាំង ចោលទទេ ដោយគ្មានបានការអ្វីទាំងអស់ ។

ពួកយើងនាំគ្នាវិលត្រឡប់មកព្រលានយន្តហោះវិញ ដើម្បីមកប្រមូលយកវ៉ាលីសរបស់យើង ។ ចូលទៅក្នុង ពួកនគរបាលអន្តោប្រវេសន៍សំដែងការងឿងឆ្ងល់ថា ហេតុអ្វីបានជាពួកយើងអាចចេញទៅក្រៅបាន ដោយគ្មានទិដ្ឋាការចូលប្រទេសកូតឌីវ័រយ៉ាងនេះ ។ ស្នងការនគរបាលនៅទីនោះនាំយើងទៅក្នុងការិយាល័យ ហើយសួរដេញដោលពួកយើងអស់រយៈពេលជាច្រើនម៉ោង ទោះបីយើងបានបង្ហាញឯកសារផ្លូវការដឹងថា ពួកយើងជាមន្ត្រីការទូត ដែលត្រូវបំពេញបេសកកម្មនៅទ្វីបអាហ្វ្រិក ហើយកំពុងរង់ចាំជើងយន្តហោះបន្តដំណើរទៅប្រទេសម៉ាលីក៏ដោយ ។ នៅទីបំផុតលោកស្នងការបាននាំយើងទៅស្នាក់នៅសណ្ឋាគារមួយ ដែលស្ថិតនៅក្នុងបរិវេណព្រលានយន្តហោះ ដោយឲ្យយើងទទួលបន្ទុកចេញសោហ៊ុយស្នាក់នៅ ។ សណ្ឋាគារនោះជាសណ្ឋាគារអន្តរជាតិ ដែលយើងស្នាក់នៅទម្រាំមានជើងយន្តហោះទៅប្រទេសម៉ាលី ក្នុងរយៈពេលពីរយប់ ។ នៅទីនោះ យើងមិនអាចចេញទៅ

ទីក្រុងទៀតទេ តែយើងអាចដើរគយគន់ឥវ៉ាន់ល្អៗតាមហាងលក់របស់របរប្រណិត ដែលរួចពន្ធបាន (Duty Free Shop) ។

យុវជនជនជាតិតូហ្គោ

នៅពេលបាយល្ងាច យើងបានប្រទះឃើញយុវជនស្បែកខ្មៅម្នាក់ ដែលកំពុងទម្រេតខ្លួនលើកៅអីក្នុងបរិវេណរង់ចាំយន្តហោះ ។ យុវជននោះ បានមកចាំជើងយន្តហោះទៅម៉ាលីដូចពួកយើងដែរ អស់រយៈពេលពីរថ្ងៃមកហើយ ។ យើងរាប់រកយុវជននោះ ដែលជាជនជាតិតូហ្គោ (Togolais) ។ ដោយក្តីអាណិត យើងក៏នាំឲ្យទៅរួមអាហារពេលល្ងាចជាមួយពួកយើង ។ ពួកយើងឲ្យគេរួមតុជាមួយ និងបើកឲ្យទទួលទានអាហារដោយសេរី ។ ពួកយើងចូលចិត្តអាហារបារាំង មានសាច់គោចៀន (Steak) និង ដំឡូងបារាំងចៀន ។ យើងមិនបានប្រាប់យុវជននោះថាយើងជានរណាទេ ។ ប្រហែលដោយសារអត់អាហារជាច្រើនថ្ងៃមកហើយ ទើបយុវជននោះទទួលទានអាហារបានច្រើន ព្រោះថានៅក្នុងតំបន់ឆ្លងកាត់អន្តរជាតិ (Transit Area) នោះ ម្ហូបម្ហាមានតម្លៃថ្លៃណាស់ ។ ខ្ញុំមិនហ៊ានទទួលទានភេសជ្ជៈដែលមានជាតិសុរាទេ ទោះបីជាម្ហូបតម្រូវរកស្រាក្រហម ឬ ស្រាបៀក៏ដោយ ព្រោះខ្ញុំមិនចង់នាំបង ប៉ែន ថាល់ ឲ្យស្រក់ទឹកមាត់ចង់ទទួលទានស្រាទៀត ។ ដូច្នេះ ខ្ញុំក៏ហៅត្រឹមតែទឹកសុទ្ធ ។ ក៏ប៉ុន្តែផ្ទុយទៅវិញបង ប៉ែន ថាល់ ហៅស្រាបៀរដែលធ្វើឲ្យខ្ញុំហួសចិត្តយ៉ាងខ្លាំង ។ ខ្ញុំនឹកខឹងបង ប៉ែន ថាល់ ជាខ្លាំង ហើយគិតក្នុងចិត្តថា គួរតែបញ្ជូនគាត់ទៅប្រទេសបារាំងវិញ ទុកឲ្យខ្ញុំបន្តបេសកកម្មតែម្នាក់ឯង ។ ក៏ប៉ុន្តែ នៅចំពោះមុខយុវជនតូហ្គោឡេ ខ្ញុំក៏មិនហ៊ាននិយាយអ្វីទាំងអស់ ។

ពីរថ្ងៃបន្ទាប់មក ពួកយើងចេញដំណើរទៅប្រទេសម៉ាលី ។ មន្ត្រីពិធីការពីរនាក់នៃក្រសួងការបរទេសម៉ាលី បានមកទទួលពួកយើង ។ ពួកគេនាំយើងឆ្ពោះទៅ

បន្ទប់រីអាយកី ប្លែកពីអ្នកដំណើរឯទៀតៗ ។ នៅពេលយើងកំពុងដើរជាមួយមន្ត្រីពិធីការទៅបន្ទប់រីអាយកីនោះ យុវជនតូហ្គោឡេដែលនៅជាប់ឆ្ងាយពីក្រោយយើងប្រញាប់ប្រញាល់ស្រែកប្រាប់យើងថា: "អេ ! អេ ! កុំទៅខាងនោះ ខុសហើយ ! អ្នកត្រូវទៅខាងនេះវិញ" ។ ប៉ុន្តែពួកយើងធ្វើដូចជាមិនឮ ហើយក៏បន្តដំណើរជាមួយមន្ត្រីពិធីការទៅបន្ទប់ទទួលភ្ញៀវរីអាយកីតទៅទៀត ។ នៅពេលដែលពួកគេបានប្រមូលវ៉ាលីសរបស់ពួកយើង និង បំពេញបែបបទអន្តោប្រវេសន៍សម្រាប់ពួកយើងរួចហើយ មន្ត្រីពិធីការបាននិយាយប្រាប់យើងថា មានយុវជនម្នាក់កំពុងអង្គុយរង់ចាំអស់លោកឯកន្លែងយកវ៉ាលីស (Carrousel) ។ នៅពេលដែលមន្ត្រីពិធីការកំពុងប្រមូលអីវ៉ាន់ពួកយើងនោះ យុវជនម្នាក់នោះ មកបេះដៃពួកមន្ត្រីចេញដោយចោទសួរថា៖ "តើពួកលោកយកវ៉ាលីសពួកម៉ាកខ្ញុំទៅណា? ពួកលោកចង់លួចវ៉ាលីសមិត្តខ្ញុំឬ?" មន្ត្រីពិធីការនៅទីបញ្ចប់ ក៏បានប្រាប់ការពិតថា ពួកយើងជាបេសកជនការទូតខ្មែរ មកបំពេញបេសកកម្មនៅប្រទេសម៉ាលី ។ តាមពិតទៅយុវជននោះស្រឡាញ់រាប់អានពួកយើង មានភក្តីភាពចំពោះយើង ហើយការពារមិនឲ្យពួកយើងបាត់បង់វ៉ាលីសរបស់ពួកយើងតែប៉ុណ្ណោះ ។

មន្ត្រីពិធីការដែលមានភារកិច្ចជូនដំណើរពួកយើង តែងមកជួបពួកយើងក្នុងអាការៈស្រស់ស្រាយរំភើយក្នុងអារម្មណ៍គ្មានខ្វល់ពីអ្វីឡើយ ។ គាត់រាក់ទាក់ជាមួយពួកយើងណាស់ តែគាត់មិនសូវគោរពម៉ោង ពេលប៉ុន្មានឡើយ ។ បើគាត់ណាត់ជាមួយយើងម៉ោង ៨ ត្រូវគិតថា ម៉ោង ៨:៣០នាទី ឬ ម៉ោង ៩:០០ ទើបឃើញមុខ ។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ នៅទីបំផុតមន្ត្រីពិធីការនោះក៏បានជួយសម្រួលឲ្យពួកយើងបានជួបសន្ទនាការងារ ជាមួយលោកអគ្គលេខាធិការនៃក្រសួងការបរទេស ។ ក្រសួងការបរទេសស្ថិតនៅក្នុងបរិវេណនៃអាគាររដ្ឋាភិបាល ដែលមានការយាមកាមយ៉ាងហ្មត់ចត់ណាស់ ។ នៅពេលជួបសន្ទនាគ្នានោះ បង ប៉ែន ថាល់ ទុក

លទ្ធភាពឲ្យខ្ញុំនិយាយតែម្នាក់ឯង ឆ្លងឆ្លើយជាមួយលោកអគ្គលេខាធិការ ។ ខ្ញុំធ្វើការពន្យល់បង្ហាញជាភាសាបារាំង ដោយបានលើកអំពីអត្ថន័យនៃការតស៊ូរបស់ពួកយើងដើម្បីរំដោះជាតិ និង ពន្យល់ពីហេតុផលថា ហេតុអ្វីបានជាមេដឹកនាំអ្នកជាតិនិយមរបស់ពួកយើង សុខចិត្តចូលរួមក្នុងរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ។ ការចូលរួមនោះ ជាមធ្យោបាយបង្រួបបង្រួមកម្លាំងទាំងអស់របស់ជាតិ ។ គូសន្ទនានារបស់យើង ហាក់ដូចជាមានការយល់ដឹងនូវសភាពការណ៍នៃការតស៊ូរបស់យើង ។ យើងមានសេចក្តីសង្ឃឹមថា រដ្ឋាភិបាលម៉ាលីនឹងជួយគាំទ្រយើង ។

នៅពេលរសៀលដែលយើងហៀបនឹងចេញដំណើរចេញពីប្រទេសម៉ាលី ខ្ញុំឮសម្លេងទូរស័ព្ទរោទ៍ឡើង នៅក្នុងបន្ទប់សណ្ឋាគារ ។ ខ្ញុំស្គាល់សម្លេងអ្នកហៅនោះភ្លាមគឺយុវជនតូហ្គោឡេដែលជិះយន្តហោះជាមួយពួកយើងមកពីកូដឌីវ័រ ។ យុវជននេះបានស្រាវជ្រាវពត៌មាន ហើយដឹងថាពួកយើងស្នាក់នៅក្នុងសណ្ឋាគារនេះ ។ គេព្យាយាមធ្វើដំណើរចម្ងាយ ២០ គ.ម ដោយថ្មើរជើង ដួនកាលដោយសុំឡានគេជិះផងមករកពួកយើង ។ យុវជននេះ ចង់ពិនិត្យឲ្យពិតប្រាកដថាយើងមានសុវត្ថិភាពមែនឬទេ ? ម្យ៉ាងទៀតយុជននេះ ក៏ចង់ចំណាយពេលចុងក្រោយជាមួយពួកយើងដែរ ។ ដូច្នេះយើងក៏នាំយុវជននោះ ទៅទទួលទានបាយល្ងាចទាំងអស់គ្នាម្តងទៀត ។

នៅយប់ចុងក្រោយនោះ មន្ត្រីពិធីការនាំពួកយើងទៅទស្សនារបាំប្រពៃណីម៉ាលីដែលគេថាសំដែងដោយបវរកញ្ញាម៉ាលី ។ បវរកញ្ញាទាំងនោះមែនទែនទៅ ជានារីខ្មៅមាឌធំធាត់ៗ ។ ពួកនាងៗរាំរបាំញាក់ចង្កេះ ។ ពេលចប់រាត្រីដើរកំសាន្តយុវជនតូហ្គោឡេ ក៏បានលាពួកយើងត្រឡប់ទៅទីកន្លែងរបស់គេវិញ ។ ព្រឹកស្អែកឡើង មន្ត្រីពិធីការក៏មកទទួលពួកយើងទៅព្រលានយន្តហោះ ដើម្បីត្រឡប់ទៅប្រទេសបារាំងវិញ ។ នៅតាមផ្លូវទៅព្រលានយន្តហោះ មន្ត្រីពិធីការក្រឡេកឃើញស្ត្រី

ម៉ាលីម្នាក់កំពុងដើរតាមចិញ្ចើមផ្លូវ ។ មន្ត្រីនោះ ប្រាប់ពួកយើងថា នាងជាប្អូនជីដូនមួយ ហើយចង់រួមដំណើរជាមួយពួកយើងទៅព្រលានយន្តហោះដែរ ព្រោះមិនដែលទៅទីនោះឡើយ ។ ដូច្នេះនៅទីបំផុត យើងក៏យល់ព្រមឲ្យនារីនោះមកជិះរថយន្តជាមួយពួកយើងនៅផ្នែកខាងក្រោយទាំងបីនាក់ ។ យើងបានបញ្ចប់បេសកកម្មរបស់យើងនៅទ្វីបអាហ្វ្រិក ប្រកបដោយមនោសញ្ចេតនាសប្បាយរីករាយ និង ពេញចិត្តចំពោះអ្វីដែលយើងបានធ្វើ ។ ក្នុងដំណើរនៅអាហ្វ្រិកនេះ ខ្ញុំមានអារម្មណ៍ទទួលបាននូវអនុស្សាវរីយ៍ដែលមិនអាចបំភ្លេចបាន ចំពោះមិត្តភាព និង បដិសណ្ឋារកិច្ចដ៏រាក់ទាក់ ដែលជនជាតិអាហ្វ្រិកបានផ្តល់ដល់ពួកយើង រួមទាំងរូបភាពនៃការបំពេញការងារបែបរំភើយសប្បាយៗ យ៉ាងស្រណុកសុខស្រួលនៃមន្ត្រីអាហ្វ្រិក ។

តាលួតត្រូវគេលួចបាញ់សម្លាប់នៅជំរុំអំពិល

នៅចុងខែ តុលា ឆ្នាំ ១៩៨២ ខ្ញុំក៏ត្រឡប់ទៅកាន់ទីក្រុងបាងកកវិញ ។ នៅក្នុងពេលអវត្តមានរបស់ពួកយើង មានហេតុការណ៍មួយចំនួនបានកើតឡើងនៅក្នុងជួរ.ជ.រ.ប.ខ. ដែលជាសញ្ញាបង្ហាញការចេញដំណើរចុះខ្សោយនៃចលនានេះ ។ តាមសេចក្តីប្រកាសព័ត៌មានមួយចុះថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៨២[160] មានអំពើឃាតកម្មមួយបានកើតឡើងនៅក្នុងមូលដ្ឋានយោធារ.ជ.រ.ប.ខ. នៅអំពិលទៅលើរូបលោក សៀម សំអុន ហៅតាលួត ប្រពន្ធ និង កងការពាររបស់គាត់ ។ តាលួតជាសមាជិកស្ថាបនិកម្នាក់នៃរ.ជ.រ.ប.ខ. និង ជាប្រធានជំរុំឬទ្ធីសែន ដែលជាជំរុំធំជាងគេមួយនៅជាប់ទល់ដែនខ្មែរ-ថៃ ។ មូលដ្ឋានយោធាអំពិល ស្ថិតនៅក្រោមការត្រួតត្រារបស់ឧត្តមសេនីយ ជៀន ដែល ដែលត្រូវទទួលការចោទប្រកាន់ថា ជាអ្នករៀបចំអំពើឃាតកម្មនេះ ។ ជាប្រតិកម្មភ្លាមៗនៃកងកម្លាំងគាំទ្រតាលួត ដែលមាន

[160] Front National de Libération du Peuple Khmer, Communiqué de Presse, le 15 Octobre 1982.

លោក លឿង ស៊ីណាក់ ហៅ តាមុាំង ជាមេបញ្ជាការ និង លោក ខូ ឈា ជាមេបញ្ជាការរង បានវាយប្រហារបកតបវិញយ៉ាងខ្លាំងក្លា ។ ដឹកនាំប្រយុទ្ធដោយមេបញ្ជាការរង ខូ ឈា កងកម្លាំងនេះបានធ្វើឲ្យបញ្ជាការដ្ឋានរបស់ឧត្តមសេនីយ ជៀន ដែល ខូចខាតជាដំណំ ទាំងអាយុជីវិតមនុស្ស ទាំងសម្ភារៈ ។

ខ្ញុំធ្លាប់រស់នៅក្នុងមូលដ្ឋានយោធាអំពិលមួយរយៈដែរ មុនពេលចេញទៅបំពេញបេសកកម្មនៅទ្វីបអាហ្វ្រិក ។ នៅពេលនោះ ខ្ញុំមានការកិច្ចទៅបង្រៀនវិជ្ជាគណនេយ្យដល់ក្រុមយោធារបស់រ.ជ.រ.ប.ខ ។ នៅក្នុងឱកាសនៃការស្នាក់អាស្រ័យរបស់ខ្ញុំនៅជំរុំអំពិលនោះ អគ្គសេនាធិការកងទ័ពបានចាត់យុទ្ធជនម្នាក់ឈ្មោះ "យក្ស" ហៅ "អាយក្សៗ" ដោយសារគេមានមាឌធំ និង ខ្មៅ ដូចយក្សឲ្យមកថែទាំខ្ញុំដូចជាយាមរក្សាសន្តិសុខ រៀបចំម្ហូបអាហារ និង បោកខោអាវជាដើម ។ អាយក្សបានត្រូវស្លាប់ដោយសារការវាយប្រហារគ្នានោះ រីឯផ្ទះសំណាក់ដែលខ្ញុំធ្លាប់ស្នាក់នៅនោះក៏ឆេះអស់ដែរ ។ ខ្ញុំមានការសោកស្តាយខ្លាំងណាស់ ចំពោះការបាត់បង់ទាំងអាយុជីវិត និង ទ្រព្យសម្បត្តិទាំងនោះ ជាពិសេសចំពោះការបាត់បង់ជីវិតរបស់អាយក្ស ដែលខ្ញុំមានការស្រឡាញ់រាប់អានយ៉ាងខ្លាំង។ ការប្រយុទ្ធគ្នានេះកើតមានឡើង ម្ខាងក្រោមការដឹកនាំដោយមេបញ្ជាការដែលមានបទពិសោធន៍ នៅលើសមរភូមិផ្ទាល់ ម្ខាងទៀតដោយមេបញ្ជាការដែលធ្លាប់បញ្ជាកងទ័ពនៃរដ្ឋាភិបាល ។

ការបាត់បង់ជីវិតរបស់តាលួត បានធ្វើឲ្យកើតមានការសង្ស័យនៅក្នុងចំណោមយុទ្ធជន ដែលធ្លាប់ប្រកាសខ្លួនឯងថាជាកងទ័ពសេរីកាតាំងពីមុនពេលរ.ជ.រ.ប.ខ. ចាប់កំណើតមកម្ល៉េះគឺ ក្នុងក្រុមដែលដំបូងកាន់អាវុធប្រឆាំងខ្មែរក្រហមក្រោយមកប្រឆាំងវៀតណាម ។ ពួកគេសង្ស័យថា ឧត្តមសេនីយ ជៀន ដែល មានផែនការកំចាត់អ្នកតស៊ូចាស់ៗទាំងនោះម្តងមួយៗ ដើម្បីដាក់ជំនួសដោយមនុស្សថ្មីជាជំនិតរបស់គាត់វិញ និង ដើម្បីធានាក្តាប់អំណាចយោធាទាំងមូល ។ ឧប្បត្តិ

ហេតុនេះ បានបង្ខំឲ្យលោកតា សឺន សាន បញ្ឈប់បេសកកម្មនៅអង្គការសហប្រជាជាតិ ហើយធ្វើដំណើរជាបន្ទាន់ទៅទីក្រុងបាងកក រួចបង្ហួសដំណើរទៅកន្លែងកើតហេតុ ។ នៅថ្ងៃទី ១៥ តុលា ១៩៨២ លោកតាប្រធាន បានទៅធ្វើជាអធិបតីក្នុងពិធីបុណ្យបង្សុកូលបញ្ចុនកុសល ដល់អ្នកស្លាប់ទាំងអស់នោះ ។ នៅពេលនោះ លោកតា សឺន សាន ក៏បានជួបជាមួយមន្ត្រីសំខាន់ៗរបស់រ.ជ.រ.ប.ខ. មានឧត្តមសេនីយ សក់ ស៊ុតសាខន លោក ហ៊ឹង គន្ធុន តាមុាំង ឬ លឿង ស៊ីណាក់ លោក ឡាយ ខែក ដើម្បីស្តាប់របាយការណ៍របស់អស់លោកទាំងនោះ ។ តាមុាំង ឬ លឿង ស៊ីណាក់ ជាមេបញ្ជាការតំបន់ ២០១ ដែលមានលោក ខូ ឈា ជាមេបញ្ជាការរង និង លោក ឡាយ ខែក ជានាយសេនាធិការ ។ តាមុាំង និង តាលួត ជាអ្នកដឹកនាំកំពូលនៃចលនាតស៊ូប្រឆាំងខ្មែរក្រហមមួយ ដែលមានឈ្មោះថា "ចលនា ននេ រោង" ។ ចលនានេនរោង ជាចលនាស្នូលមួយ ដែលចូលរួមបង្កើត រ.ជ.រ.ប.ខ. ។

បង្កើតគណកម្មាធិការ ជំនួសលោក ជៀន ដែល

ដើម្បីបន្ធូរភោពតានតឹង លោកតាប្រធាន បានសម្រេចដកឧត្តមសេនីយ ជៀន ដែល ចេញពីតំណែងនាយអគ្គសេនាធិការកងទ័ព ។ ដើម្បីជំនួស លោកតាបានតែងតាំងគណៈកម្មាធិការបណ្តោះអាសន្នមួយឲ្យដឹកនាំកងទ័ព ក្នុងនោះមានឧត្តមសេនីយ សក់ ស៊ុតសាខន ជាប្រធាន ឧត្តមសេនីយ ថាច់ រ៉ង ជាសមាជិក លោក ជា ឈុត សមាជិក និង លោក ហ៊ឹង គន្ធុន សមាជិក[161] ។ ឧត្តមសេនីយ ថាច់ រ៉ង ធ្លាប់កាន់តំណែងជាមេបញ្ជាការនៃកងកម្លាំងពិសេស (Special Forces) នៅសម័យ លន់ នល់ ។ លោក ថាច់ រ៉ង បានមកដល់ទីក្រុងបាងកក

[161] សេចក្តីអំពាវនាវរបស់ប្រធានណោសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ អគ្គមេបញ្ជាការនៃកងទ័ពជាតិរំដោះប្រជាពលរដ្ឋខ្មែរ អំពិល ថ្ងៃទី ១៨ ខែ តុលា ១៩៨២ ។

កាលពីខែ កញ្ញា ១៩៨២ ។ កាលខ្ញុំនៅឯប្រទេសបារាំង លោក សាយ បូរាណ ធ្លាប់និយាយប្រាប់ខ្ញុំ ថាលោក ថាច់ រ៉ែង ជាទាហានមួយរូប ទោះជាពាក់ស័ក្តិធំក៏ដោយ ក៏នៅព្យាយាមទៅរៀននៅមហាវិទ្យាល័យច្បាប់ រហូតទទួលបាននូវសញ្ញាប័ត្របរិញ្ញាបត្រច្បាប់ទៀតផង ។ ដោយសារគាត់មានជំនាញប្រឆាំងទ័ពព្រៃ ឧត្តមសេនីយ ថាច់ រ៉ែង ជាអ្នកគាំទ្រទ្រឹស្តីធ្វើសង្គ្រាមទ័ពព្រៃ ។ សមាជិកម្នាក់ទៀតគឺ លោក ជា ឈុត (ឈ្មោះផ្លូវការ ជា វិទ្ធីឈុត) ជាប្រធានជំរុំជ័ំធំទី ២ នៅទល់ដែនគឺជំរុំនងចាន់ ។ លោក ជា ឈុត មិនធ្លាប់ធ្វើជាមេបញ្ជាការយោធាទេ កាលពីសម័យមុន តែគាត់ជាមិត្តរួមអាវុធជាមួយតាមុាំង និង តាលួត ។ សមាសភាពក្នុងគណៈកម្មាធិការនេះ ដែលមានឈ្មោះថា "គណៈកម្មាធិការបណ្តោះអាសន្នរបស់អគ្គសេនាធិការនៃរ.ជ.រ.ប.ខ." មានតុល្យភាពល្អរវាងនាយទាហានអាជីព និង អ្នកតស៊ូចាស់ ។ តុល្យភាពមួយ ដែលលោកតាប្រធានចង់បានជាយូរមកហើយ ។ ម្យ៉ាងទៀត លោកតាចង់ឃើញកងទ័ពរ.ជ.រ.ប.ខ. សកម្មជាងមុន និង មុតស្រួចនៅទីលានប្រយុទ្ធ ជ្រៀតចូលឲ្យបានជ្រៅទៅក្នុងទឹកដីខ្មែរ ឲ្យស្របតាមនយោបាយ និងចក្ខុវិស័យនៃការតស៊ូរំដោះជាតិ ។ ក៏ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក៏ឧត្តមសេនីយ ជៀន ដែល នៅតែរក្សាឥទ្ធិពលរបស់គាត់បាននៅក្នុងគណៈកម្មាធិការថ្មីនេះ តាមរយៈលោក ហ៊ីង គន្ធន ដែលជាមិត្តភក្តិរបស់គាត់ ។ សូមបញ្ជាក់ថា នៅពេល ដែលលោកតា សឺន សាន ចុះទៅធ្វើបុណ្យបញ្ចុនកុសលបន្ទាន់នៅជំរុំអំពិល នាថ្ងៃទី ១៥ តុលា ១៩៨២ នោះ លោកឧត្តមសេនីយ ជៀន ដែលពុំបានមកជួបលោកតាទេ ។

ការបែកបាក់គ្នាលើកទីមួយ ក្នុងជួរ រ.ជ.រ.ប.ខ.

នៅថ្ងៃទី ១៧ តុលា ឧត្តមសេនីយ ជៀន ដែល បានសរសេរសំបុត្រផ្ទាល់ដៃផ្ញើជូនលោកតាប្រធានដែលមានសេចក្តីដូចតទៅ៖[162] "ខ្ញុំបាទសូមអភ័យទោសដោយមិនបានមកទទួល និង ជួបលោកប្រធាន មកពីខ្ញុំបាទមិនស្រួលខ្លួន មិនស្រួលចិត្ត ។ ក្នុងឱកាសដ៏អាប់អួរនេះ ខ្ញុំបាទសូមលោកប្រធានមេត្តាយោគយល់ដល់រូបខ្ញុំបាទ ឲ្យបានសំរាកខ្លះមួយរយៈសិន ។ ខ្ញុំបាទសន្យាជួយសម្របសម្រួលកិច្ចការរបស់គណៈកម្មាធិការ ដែលលោកប្រធាន និង អស់លោកតែងតាំងឲ្យអស់ពីសមត្ថភាព និង លទ្ធភាព" ។ អវត្តមានរបស់ឧត្តមសេនីយ ជៀន ដែល នៅថ្ងៃទី ១៥ តុលា ១៩៨២ ក្នុងឱកាសបុណ្យបង្សុកូលជូនជនរងគ្រោះ ជាសញ្ញាបង្ហាញពីការបែកបាក់មួយនៅក្នុងជួរកងទ័ព រ.ជ.រ.ប.ខ. ។ នៅថ្ងៃទី ១៩ តុលា ១៩៨២ ឧត្តមសេនីយ ជៀន ដែល បានផ្ញើលិខិតសរសេរផ្ទាល់ដៃជាភាសាបារាំងលាយឡំជាមួយភាសាខ្មែរជូនលោកតា សឺន សាន ដើម្បីបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់គាត់ក្នុងការធ្វើពលីកម្មគ្រប់បែបយ៉ាង ដើម្បីបុព្វហេតុជាតិ[163] ។ ក្នុងលិខិតនោះ លោកឧត្តមសេនីយរូបនេះសរសេរថា៖ "ខ្ញុំបាទមិនលះបង់ការប្រយុទ្ធដើម្បី Cette noble Cause (បុព្វហេតុដ៏ឧត្តុង្គឧត្តមនេះ) ហើយសន្យាជួយឲ្យអស់ពីសមត្ថភាព ។ ខ្ញុំបាទព្រមធ្វើពលីកម្មដកខ្លួនពេលនេះ ក៏ដើម្បីប្រយោជន៍ ដើម្បីអនាគតដ៏ប្រសើររបស់រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរយើង សូមមេត្តាជួយធ្វើយ៉ាងណាកុំឲ្យពលីកម្មរបស់ខ្ញុំបាទទៅជាឥតន័យ" ។ លោកឧត្តមសេនីយសំដែងមតិថា ការសម្រេចចិត្តរបស់លោកតាប្រធានឲ្យគាត់ឈប់ពីមុខតំណែងនេះ ដោយសារតែជឿ

[162] ជៀន ដែល, សំបុត្រផ្ញើជូនលោកប្រធាន, បន្ទាយអំពិល, ថ្ងៃ 17-10-82 ។

[163] ជៀន ដែល, សំបុត្រផ្ញើជូនលោកប្រធាន, បន្ទាយអំពិល, ថ្ងៃ 19-10-82 ។

ថា ប្រទេសផ្តល់ជំនួយយល់ថាឧត្តមសេនីយ ជៀន ដែល មានកំហុស ហើយគេនឹងផ្តល់ជំនួយនៅពេលមានការដោះដូរនោះ ។ ម្យ៉ាងទៀត លោក ជៀន ដែល ក៏បានផ្តាំផ្ញើផងដែរថា ប្រសិនបើមានមធ្យោបាយកងទ័ព រ.ជ.រ.ប.ខ. អាចបំពេញបេសកកម្មបានយ៉ាងប្រសើរ ។ ជាមួយគ្នានេះ លោកឧត្តមសេនីយ បានដាស់តឿនលោកតាប្រធានឲ្យមានការប្រុងប្រយ័ត្នក្នុងការចែកចាយអាវុធ ដោយពិនិត្យឲ្យច្បាស់លាស់ថា អ្នកណាខ្លះដែលច្បាស់លាស់ដាច់ខាត "ជាមួយរណសិរ្សយើង" ។ តាមការយល់ឃើញរបស់លោក ជៀន ដែល ការដកក្របគាត់ចេញពីតំណែងនាយអគ្គសេនាធិការជាការគាបសង្កត់របស់បរទេស[164] ។ ក៏ប៉ុន្តែ ព្រឹត្តិការណ៍ឃាតកម្មលើរូបតាលួត នៅថ្ងៃទី ១១ តុលា ១៩៨២ នោះ ជាមូលហេតុគ្រប់គ្រាន់មួយសម្រាប់លោកតា សឺន សាន ឲ្យសម្រេចដកលោក ជៀន ដែល ព្រោះលោកតាប្រធានយល់ថាលោកឧត្តមសេនីយរូបនេះ ជាមេក្លោងមួយដែលនាំឲ្យមានការបែកបាក់នៅក្នុងចលនា ។

តាមពិតទៅ តាំងពីឆ្នាំ ១៩៧៩ រហូតមក លោកឧត្តមសេនីយ ជៀន ដែល បានពង្រឹងអំណាចរបស់លោក ជានាយអគ្គសេនាធិការនៃកងទ័ពជាតិរំដោះប្រជាពលរដ្ឋខ្មែរ (ក.ជ.រ.ប.ខ.) ដោយសារការបង្កើតអង្គភាពថ្មីៗដែលមានកក្តីភាពចំពោះលោកឧត្តមសេនីយផ្ទាល់ ។ ដោយសារមានអំណាចក្នុងការបែងចែកគ្រឿងអាវុធយុទ្ធភ័ណ្ឌ និង ភស្តុភាក្នុងជួរកងទ័ព លោកឧត្តមសេនីយអាចផ្តល់ការយោគយល់ ផ្តល់ការអនុគ្រោះដល់មេបញ្ជាការណាដែលជិតជិត ឬ មានកក្តីភាពជាងអ្នកឯទៀត ។ លើសពីនេះទៅទៀត ដោយសារលោកឧត្តមសេនីយ ជៀន ដែល មានទំនាក់ទំនងជិតស្និទ្ធជាមួយលោក ហ៊ីង គន្ធុន លោក នាង ជិនហន និង លោក ហ្គាហ្វា លោកមេទ័ពរូបនេះអាចធ្វើឲ្យមានគ្រោះថ្នាក់ដល់ការដឹកនាំរបស់លោកតា

[164] ជៀន ដែល, សំបុត្រផ្ញើជូនលោកប្រធាន, បន្ទាយអំពិល, ថ្ងៃ 19-10-82, op. cit. ។

សឺន សាន ។ ក៏ប៉ុន្តែ ដោយព្រឹត្តិការណ៍នៃឃាតកម្មលើរូបតាលួត មានសភាពធ្ងន់ធ្ងរពេកនោះ ទើបមិត្តជិតស្និទ្ធរបស់លោក ជៀន ដែល ខាងលើបានដូរគោលជំហរក្នុងកលយុទ្ធមួយ មកគាំទ្រសេចក្តីសម្រេចដកមុខតំណែងនេះវិញ ។

ម្យ៉ាងទៀត ក្រុមអ្នកគាំទ្រលោកតា សឺន សាន បានចោទលោក ជៀន ដែល ថាក្នុងឋានៈជាមេដឹកនាំម្នាក់ លោកឧត្តមសេនីយមានជីវភាពរស់នៅខ្ពស់ជាច់ឆ្ងាយពេកពីជនភៀសខ្លួន ឬ ពីយុទ្ធជនធម្មតានៃ ក.ជ.ប.ខ. ។ តាមពិតទៅ ការរស់នៅតាមដំរុំនៅទល់ដែន មិនមែនជាការរស់នៅបែបធម្មតាឡើយ ។ លោក ឧត្តមសេនីយ ជៀន ដែល ចូលចិត្តពិសាស្រា ជាពិសេសស្រាវីស្គី ដែលផ្ទុយទៅវិញ លោកតា សឺន សាន បានទូន្មានឲ្យកាន់សិលប្រាំតាមធម្មព្រះពុទ្ធ និង ណែនាំឲ្យរស់នៅក្នុងភាពសាមញ្ញ ។

ការផ្លាស់ប្តូរថ្នាក់ដឹកនាំកងទ័ពនេះ បានធ្វើឲ្យមានតុល្យភាពឡើងវិញរវាងកងកម្លាំងទាំងអស់ ទាំងថ្មី ទាំងចាស់ ទាំងអ្នកតស៊ូដែលឡើងកាន់អាវុធតស៊ូដោយខ្លួនឯង ទាំងនាយទាហាន ដែលធ្លាប់បញ្ជាកងទ័ពនាសម័យសាធារណរដ្ឋ ។ លោកតា សឺន សាន នឹកសង្ឃឹមថាថ្នាក់ដឹកនាំថ្មីនៃកងទ័ព និង ជួយជំរុញឲ្យមានការឯកភាព និង ការកែប្រែក្បួនប្រយុទ្ធ ពីបែបកងទ័ពស្រុក ឲ្យទៅជាកលយុទ្ធនៃកងទ័ពព្រៃវិញ ។ នៅជំនាន់នោះ លោកតា សឺន សាន តែងស្តាប់ការបកស្រាយដ៏ដែលៗរបស់លោកឧត្តមសេនីយ ថាច់ រ៉េង អំពីគុណសម្បត្តិនៃទ្រឹស្តី "អារញ្ញសង្គ្រាម" ថាជាវិធីដ៏ល្អបំផុតក្នុងការប្រយុទ្ធប្រឆាំងនឹងកងទ័ពវៀតណាម ។ ក៏ប៉ុន្តែទោះបីជាគាត់សុខចិត្តដកខ្លួនថយ ឈប់កាន់តំណែងជានាយអគ្គសេនាធិការយ៉ាងណាក៏ដោយ ក៏លោក ជៀន ដែល បន្តវត្តមានរស់នៅក្នុងមូលដ្ឋានយោធានេះតទៅទៀត ។ វត្តមាននេះ ធ្វើឲ្យការងាររបស់គណៈកម្មាធិការបណ្តោះអាសន្នអគ្គសេនាធិការមានការលំបាក មិនអាចប្រព្រឹត្តិទៅដោយស្រួលៗឡើយ ។

នគរបាលថៃ លបចុះមកឆែឆេរទីស្នាក់ការរបស់យើង

នៅខែ តុលា ១៩៨២ នោះ ក្នុងរយៈពេលដែលពួកខ្ញុំកំពុងបំពេញបេសកកម្មនៅក្រៅប្រទេសមានឧបទ្ទវហេតុមួយទៀតបានកើតឡើង ។ នគរបាលថៃ បានចុះមកឆែកឆេរទីស្នាក់ការរបស់យើងនៅក្រុងបាងកក ។ ពួកនគរបាលទាំងនោះពុំបានដឹងទេថា ពួកយើងជាចលនាតស៊ូខ្មែរដែលបានទទួលការអនុញ្ញាតពីកងយោធាថៃឲ្យមកដឹកនាំការតស៊ូនៅចំកណ្តាលរាជធានីបាងកក ។ ហេតុការណ៍នោះបានកើតឡើង នៅពេលដែល សុវណ្ណ យុវជនពិការជើងមួយបានជួលរថតាក់ស៊ី "តុកតុក" ដឹកសុទ្ធតែវិទ្យុទាក់ទង ថកគី វ៉កគី (Talky-Walky) ពីហាងមួយ យកមកទុកនៅទីស្នាក់ការរបស់យើង ។ នគរបាលថៃ ហៅឲ្យរថតុកតុកឈប់ ដើម្បីឆែកឆេរតែរកមិនឃើញមានអ្វីដែលខុសច្បាប់ឡើយ ។ ក៏ប៉ុន្តែ នគរបាលរូបនោះសង្ស័យថាប្រហែលជាគេកំពុងរកឃើញបណ្តាញរត់អាកៀនមួយដ៏ធំ ដូច្នេះគេក៏រាយការណ៍ទៅមេរបស់គេ ។ ក្រុមនគរបាល ក៏តាមដានដឹងពីទីកន្លែងដែលពួកយើងស្នាក់នៅ ។ ទាំងយប់ ក្រុមនគរបាលដាក់រាយគ្នាព័ទ្ធទីស្នាក់ការរបស់យើង ដោយស្ងាត់ៗគ្មាននរណាម្នាក់ដឹងឡើយ ។ ព្រឹកឡើង ពេលហៀបភ្លឺក្រុមនគរបាលប្រដាប់អាវុធលោតផ្លោះរបងចូលទៅក្នុងបរិវេណនៃបរវេសនដ្ឋានរបស់យើង ហើយរំពេចនោះពួកគេបានចូលទៅគ្រប់បន្ទប់ និង ត្រួតត្រាទ្វារចេញចូលទាំងអស់បានទាំងស្រុង ។ មិនយូរប៉ុន្មាន ឧត្តមសេនីយនគរបាលថៃបានមកដល់ទីកន្លែង ជាមួយនឹងអ្នកយកព័ត៌មានទូរទស្សន៍ថៃផង ។ ពួកគេសង្ឃឹមថា នឹងរកឃើញនូវក្រុមអ្នករត់អាកៀនមួយដ៏ធំនៅក្នុងទីក្រុងបាងកក ។ ក៏ប៉ុន្តែ ផ្ទុយទៅវិញគេរកមិនឃើញនូវអ្វីដែលគួរឲ្យសង្ស័យនោះទេ ។ ពួកនគរបាលរកឃើញតែទីបញ្ជាការនៃចលនាតស៊ូខ្មែរដ៏ធំមួយ ។ ពួកគេធ្វើការឆែកឆេរមិនបានយូរប៉ុន្មានទេ ដោយសារមន្ត្រីរបស់រ.ជ.រ.ប.ខ.

បានទាក់ទងជាបន្ទាន់ទៅមន្ត្រីទំនាក់ទំនងនៃក្រុមយោធាថៃគឺ លោក ម៉ុល និង លោកវរសេនីយឯក ស៊ុជិន្តា ដែលជាម្ចាស់ផ្ទះជួលឲ្យពួកយើង ហើយដែលបានធ្វើអន្តរាគមន៍ភ្លាមៗ ទៅក្រុមនគរបាលថៃ ។ (សូមបញ្ជាក់ថា លោកវរសេនីយ ស៊ុជិន្តា ពេលក្រោយមក ក៏ឡើងសក្តិជាឧត្តមសេនីយ ស៊ុជិន្តា ក្រាប្រយង្គ ដែលបានចូលរួមដឹកនាំរដ្ឋប្រហារមួយទម្លាក់លោកនាយករដ្ឋមន្ត្រី ឆាទិឆាយ ឈុនហាវ៉ាន់ ពីតំណែងនៅឆ្នាំ ១៩៩១ រួចក៏បានឡើងជានាយករដ្ឋមន្ត្រីនៃប្រទេសថៃ នៅឆ្នាំ ១៩៩២)ឧបទ្ទវហេតុនេះ ក៏ត្រូវបញ្ចប់ភ្លាមៗនៅថ្ងៃនោះ ។ ក៏ប៉ុន្តែបណ្តាញព័ត៌មានថៃ ក៏បានផ្សព្វផ្សាយយ៉ាងទូលំទូលាយនូវការសម្ងាត់ស្តីពីទីតាំងនៃទីបញ្ជាការចលនាតស៊ូខ្មែរ ដែលជាការប៉ះពាល់យ៉ាងខ្លាំងដល់សុវត្ថិភាពរបស់ពួកយើង ។ នៅទីបំផុត កងយោធាថៃបានសម្រេចជួលទីស្នាក់ការថ្មីឲ្យពួកយើង ដែលស្ថិតនៅក្នុងតំបន់បាងខេន នាជាយក្រុងបាងកក ។

យើងរើមកនៅម៉ាយ៉ាឡាប់

ផ្ទះថ្មីរបស់ពួកយើងជាផ្ទះរបស់អតីតរដ្ឋមន្ត្រី និង នាយអគ្គសេនាធិការកងទ័ពថៃឈ្មោះលោកឧត្តមសេនីយ "ម៉ាយ៉ាឡាប់" ។ ផ្ទះនោះ ជាភូមិគ្រឹះមួយក្នុងចំណោមភូមិគ្រឹះបី ដែលស្ថិតនៅក្នុងបរិវេណតែមួយនៃគ្រួសារ "ម៉ាយ៉ាឡាប់" នៅជាប់ឆ្ងាយពីអ្នកស្រុកឯទៀត ។ អាជ្ញាធរយោធាថៃតម្រូវឲ្យយើងរើផ្ទះនៅថ្ងៃទី ១ វិច្ឆិកា ១៩៨២ ។ តាមធម្មតា នៅផ្ទះថ្មីនេះខ្ញុំត្រូវទៅរស់នៅក្នុងបន្ទប់ធំរួមមួយជាមួយលោកឧត្តមសេនីយ សក់ ស៊ុតសាខន លោកឧត្តមសេនីយ ថាច់ រ៉ែង និង បង ប៉ែន ថាល់ ។ ដូចមុនដែរ យើងត្រូវរើរបស់របរយើងម្នាក់ៗយកទៅជាមួយឯផ្ទះថ្មី ។ របស់របរទាំងនោះ គ្មានអ្វីប្លែកទេគឺ ខោអាវ ពូក រនាប(ព្រោះពួកយើងគ្មានគ្រែដេក

ទេ) និង ទូកៅស៊ូផ្លាស្ទិកតែប៉ុណ្ណោះ ។ លោកឧត្តមសេនីយ សក់ ស៊ុតសាខន មានបុព្វសិទ្ធលើសយើងបន្តិច ព្រោះមានគ្រែដែកបត់មួយ ។

ខ្ញុំចូលធ្វើការក្នុងកងទ័ព

ដោយសារមានការផ្លាស់ប្តូរបញ្ជាការយោធា ខ្ញុំក៏ត្រូវទទួលភារកិច្ចថ្មីនៅមូលដ្ឋានយោធាអំពិល ។ លោកឧត្តមសេនីយ សក់ ស៊ុតសាខន និង ឧត្តមសេនីយ ថាច់ រ៉េង បានស្នើឲ្យខ្ញុំធ្វើការជាមួយពួកគាត់ ។ ខ្ញុំក៏យល់ព្រមតាម ។ ដូច្នេះ នៅថ្ងៃទី ៧ វិច្ឆិកា ១៩៨២ សមាជិកទាំងអស់នៃគណៈកម្មាធិការបណ្តោះអាសន្ន អគ្គសេនាធិការ បានសម្រេចតែងតាំងឲ្យខ្ញុំបានជាលេខាធិការនៃគណៈកម្មាធិការនេះ[165]។

ដោយខ្ញុំត្រូវចេញទៅរស់នៅឯជំរុំអំពិលភ្លាមៗបែបនោះ ខ្ញុំក៏អត់បានរស់នៅឲ្យបានយូរបន្តិចក្នុងផ្ទះថ្មីដែលមានម៉ាស៊ីនត្រជាក់តទៅទៀតឡើយ ។ ជំរុំអំពិលមិនមែនគ្រាន់តែជាមូលដ្ឋានយោធាទេ តែក៏ជាទីជ្រកកោននៃជនភៀសខ្លួនខ្មែររាប់ពាន់នាក់ដែរ ។ ជនរួមជាតិទាំងនោះ ដែលស្វែងរកសេរីភាព មានជំនឿថាអំពិលជាទីកន្លែងដែលគេអាចទទួល និង លើកតំកើងនូវតម្លៃនៃសិទ្ធិមនុស្ស ។ តាមពិតទៅ ជំរុំនេះស្ថិតនៅលើទឹកដីខ្មែរជាប់ និង ព្រំប្រទល់ជាមួយប្រទេសថៃក្នុងខេត្តបន្ទាយមានជ័យ ។ ជនភៀសខ្លួនខ្លះ សង់ទីជម្រកតែប៉ុន្មានម៉ែត្រប៉ុណ្ណោះពីទល់ដែន ដែលកំណត់បានដោយសារអូរតូចមួយ ។ មូលដ្ឋានអំពិល បានត្រូវរៀបចំឡើងជាភូមិសម្រាប់អ្នកស្រុករស់នៅផង ជាទីតាំងយោធាផង ។ បន្ទាយយោធានៅជាប់ដោយឡែកពីប្រជាពលរដ្ឋស៊ីវិល លើកលែងតែក្រុមគ្រួសារមន្ត្រីសំខាន់ៗ

[165] សក់ ស៊ុតសាខន, សេចក្តីសម្រេចនៃគណៈកម្មាធិការបណ្តោះអាសន្ននៃអគ្គសេនាធិការនៃកងទ័ពជាតិរំដោះប្រជាពលរដ្ឋខ្មែរ, អំពិល, ថ្ងៃទី៨ ខែ វិច្ឆិកា ១៩៨២ ។

និង នាយទាហាន ។ នៅអគ្គសេនាធិការដ្ឋាននោះ មានក្រុមអាវុធហត្ថ ក្នុងឯក សណ្ឋានប៉ារ៉ា ធ្វើការយោមកាមយ៉ាងហ្មត់ចត់ ។

អ្នកស្រុកនាំគ្នាធ្វើផ្ទះ ភាគច្រើនពី ឫស្សី និង ស្លឹក ។ មូលដ្ឋានអំពិលនេះ មានការរៀបចំជាផ្លូវថ្នល់ខ្វាត់ខ្វែង មានប្រឡាយ និង លូទឹក ព្រមទាំងបង្គន់អនា ម័យផង ។ ទីកន្លែងធ្វើការ ទាំងស៊ីវិល ទាំងទាហាន មានការថែទាំយ៉ាងស្អាតសម រម្យ មានទីធ្លាធំទូលាយ អាចធ្វើការប្រជុំមីទ្ទឹងសំខាន់ៗសម្រាប់មនុស្សរាប់ពាន់នាក់ បាន ។ មុនទៅដល់អគ្គសេនាធិការដ្ឋាន ដែលជាទីស្នាក់នៅរបស់លោកឧត្តមសេ នីយ ជៀន ដែល គេឃើញមានសំណង់ក្នុងបរិវេណធំទូលាយ ដែលមានទាំងទី លានហ្វឹកហាត់ ឬ ជាកីឡាដ្ឋានមួយផងនោះគឺ ជាសាលានាយទាហាននៃកងទ័ព រ.ជ.រ.ប.ខ. ។ សាលានេះ ជ្រើសរើសយុវជនមកអប់រំហ្វឹកហ្វឺនតាមកម្មវិធីអប់រំនាយ ទាហានសម័យមុនសង្គ្រាម ។ អ្នកស្រុកនៅក្នុងមូលដ្ឋាននេះ បានទទួលម្ហូបអាហារ ការថែទាំសុខភាព និង ជំនួយផ្នែកអប់រំកំរិតបឋមសិក្សាពីអង្គការសហប្រជាជាតិ និង អង្គការអន្តរជាតិក្រៅរដ្ឋាភិបាលមួយចំនួន ។ អ្នកដឹកនាំរ.ជ.រ.ប.ខ. ជាពិសេស លោកឧត្តមសេនីយ ជៀន ដែល និង លោក ហ៊ីង គន្ធុន មានបំណងយកមូលដ្ឋាន អំពិលនេះជាទីតាំងបង្ហាញអំពីគំរូនៃការគ្រប់គ្រងផ្នែករដ្ឋបាល នាពេលអនាគត នៅពេលប្រទេសកម្ពុជាបានត្រូវរំដោះទាំងស្រុង ។

ចាប់តាំងពីខ្ញុំចាកចេញពីប្រទេសបារាំង និង បានចូលរួមតស៊ូផ្ទាល់ជាមួយ យុទ្ធជន ខ្ញុំធ្លាប់មកស្នាក់នៅជាច្រើនលើកមកហើយ នៅក្នុងមូលដ្ឋានអំពិលនេះ ។ ការស្នាក់នៅរបស់ខ្ញុំ នៅអំពិលលើកចុងក្រោយគឺ តែប៉ុន្មានសប្តាហ៍ មុនពេលខ្ញុំ ចេញទៅបំពេញបេសកកម្មនៅទ្វីបអាហ្វ្រិក ។ ពេលនោះ ខ្ញុំមានភារកិច្ចមកបង្រៀន វិជ្ជាគណនេយ្យដល់ទាហាន រ.ជ.រ.ប.ខ. ។ លើកនេះ ពេលខ្ញុំទៅដល់លោក ឧត្តមសេនីយ ជៀន ដែល ឈប់ស្នាក់នៅក្នុងបរិវេណអគ្គសេនាធិការទៀតហើយ ។

គាត់ទើបសង់ផ្ទះថ្មីរបស់គាត់អំពីឈើ ដែលនៅចំពីមុខមានសួនផ្កាកូឡាបផង ។ បើប្រៀបធៀបទៅនឹងប្រជាពលរដ្ឋធម្មតា ផ្ទះលោកឧត្តមសេនីយអាចចាត់ទុកជាភូមិគ្រិះមួយបាន ដែលល្អប្លែក និង ប្រកបដោយសម្ភារៈល្អប្រណិត ។ ចាប់តាំងពីលាឈប់ពីមុខតំណែងនាយអគ្គសេនាធិការ លោកឧត្តមសេនីយចំណាយពេលភាគច្រើនរបស់គាត់ ថែទាំផ្កាកូឡាបដែលមានច្រើនប្រភេទនៅក្នុងសួន ។

នៅក្នុងបរិវេណអគ្គសេនាធិការដ្ឋាន មានផ្ទះសំណាក់មួយចំនួននៅហូរហែជាប់នឹងជាយរបង ។ នៅចំកណ្តាល មានរោងធំមួយ ដែលអាចជាកន្លែងទទួលភ្ញៀវសំខាន់ៗ ឬ ជាកន្លែងទទួលទានអាហាររួមគ្នាផងក៏បាន ។ នៅខាងមុខរោងមានស្រះធំមួយដែលចំកណ្តាលស្រះមានក្បូស (Kiosk) មួយ ដែលសង់តាមរចនាបថបូរាណ ។ ពេលណាយើងចូលទៅក្នុងក្បូសនោះ យើងអាចទទួលបាននូវម្លប់ត្រជាក់ ជាពិសេសខ្យល់ត្រជាក់ដែលអាចភាយចេញពីផ្ទៃទឹកស្រះនៅខាងក្រោម ។ ផ្ទះសំណាក់របស់ខ្ញុំមានសភាពថ្មោងថ្មី ដែលទើបតែធ្វើរួចហើយៗមានទំហំធំជាងផ្ទះឯទៀត ព្រោះផ្ទះសំណាក់នេះ មិនមែនសម្រាប់តែខ្ញុំម្នាក់ឯងនោះទេ តែសម្រាប់លោកឧត្តមសេនីយ ថាច់ រ៉េង និង លោកវរសេនីយ ចក់ បូរី ផង ។ ដើម្បីជួយថែរក្សាសុវត្ថិភាពរបស់ខ្ញុំៗត្រូវបានទទួលអង្គរក្សម្នាក់ឈ្មោះ ចំរើន ដែលជាខ្មែរមកពីកម្ពុជាក្រោម ។ ចំរើនធ្លាប់បំរើកងទ័ពវៀតណាមខាងត្បូងមានឋានៈជាអនុសេនីយឯក (សក្តិបី) នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ ។ ចំរើនមានការកិច្ចខាងម្ហូបអាហារ និង សំអាតសម្លៀកបំពាក់របស់ខ្ញុំ ក្រៅពីការងារផ្នែកសន្តិសុខ ។ ចំរើននិយាយភាសាវៀតណាមស្ទាត់ជំនាញណាស់ ហើយចំរើន និយាយភាសាខ្មែរដោយមានសំនៀងកម្ពុជាក្រោម ។ ខ្ញុំនៅចាំបានថា នៅពេលមួយនោះ ដែលខ្ញុំត្រូវទៅធ្វើសម្ភាសន៍ជនជាប់ឃុំឃាំងសញ្ជាតិវៀតណាមម្នាក់ ខ្ញុំបានចាត់ឲ្យចំរើនជាអ្នកបកប្រែភាសាពីភាសាវៀតណាមមកភាសាខ្មែរ ។ ពេលខ្ញុំសួរជនជាតិវៀតណាមជា

ភាសាខ្មែរ ចំរើន បកប្រែជាវៀតណាមបានល្អណាស់ តែពេលជនជាតិវៀតណាមឆ្លើយជាភាសាវៀតណាមមកខ្ញុំនោះ ចំរើនក៏គ្រាន់តែនិយាយភាសាវៀតណាមមកខ្ញុំវិញតែប៉ុណ្ណោះ ពុំបានបកជាភាសាខ្មែរមកខ្ញុំវិញឡើយ ។ តាំងពីពេលនោះមក ខ្ញុំក៏ឈប់យក ចំរើន ជាអ្នកបកប្រែឲ្យខ្ញុំតទៅទៀត ។ ក្រោយមក ចំរើន ក៏ត្រូវផ្លាស់ឲ្យទៅ នៅជាមួយវរសេនីយ ចក់ ហ៊ូរី ។ ច្រើនឆ្នាំក្រោយមក ចំរើន ក៏ទទួលទិដ្ឋាការឲ្យទៅរស់នៅសហរដ្ឋអាមេរិក ។ នៅពេលដែល ចំរើន បានផ្លាស់ចេញទៅ ខ្ញុំបានទទួលអង្គរក្សថ្មីឈ្មោះ ស្រី នួន ដែលធ្លាប់ធ្វើទាហាននៃកងទ័ពពិសេសរបស់លោក ថាច់ រ៉េង កាលគាត់នៅធ្វើមេបញ្ជាការកងទ័ពពិសេស (Special Force) ។ ចាប់តាំងពីពេលនោះមក ខ្ញុំក៏យក ស្រី នួន មកធ្វើជាអង្គរក្សរបស់ខ្ញុំរហូតដល់គាត់ចូលនិវត្ត ។

ក្រុមមេទ័ពថ្មី ខំបញ្ចេញថ្វីដៃ

ក្រោមការដឹកនាំរបស់គណៈកម្មាធិការអគ្គសេនាធិការថ្មី រ.ជ.រ.ប.ខ.ហាក់ដូចជាបានផ្លាស់ប្តូរទស្សនវិស័យយោធាពីរបៀបប្រយុទ្ធបែបទ័ពស្រុក មកជារបៀបទ័ពព្រៃវិញ ។ វារៈបញ្ជា បានតម្រង់បេសកកម្មប្រយុទ្ធឆ្ពោះទៅ៖ ១.គាបសង្កត់ដើម្បីឲ្យមានការដកកងទ័ពវៀតណាមទាំងអស់ចេញពីទឹកដីកម្ពុជា ២. កំចាត់ជនក្បត់ទាំងអស់ដែលបំផ្លាញប្រទេស បំផ្លាញប្រពៃណី និង ទំនៀមទម្លាប់ជាតិ ហើយដែលចង់ដាក់ប្រទេសក្នុងរបបកុម្មុយនីស្ត ៣. អភិវឌ្ឍនធនធាន និង ស្ថាប័នចាំបាច់ និង សំខាន់ៗទាំងឡាយ ដើម្បីទ្រទ្រង់ឯករាជ្យជាតិ យុត្តិធម៌សង្គម និង សុខុមាលភាពរបស់ប្រជារាស្ត្រ ។ គោលដៅសំខាន់នៃរ.ជ.រ.ប.ខ.គឺ ឆ្ពោះទៅកាត់ផ្តាច់ខ្សែបណ្តាញគមនាគមន៍ និង ភស្តុភារបស់កងទ័ពវៀតណាម ធ្វើឲ្យទីតាំងនៃកងទ័ពនេះនៅឯកោផង និង ត្រូវកំទេចផង ។

តាមពិតទៅ អាជ្ញាធរថៃ ជាពិសេសលោកឧត្តមសេនីយ ឆាវលិត បានផ្តល់យោបល់ដល់កងកម្លាំងខ្មែរអ្នកជាតិនិយមមិនមែនកុម្មុយនីស្ត (ក.ជ.រ.ប.ខ. និង កងទ័ពសីហនុនិយម) ឲ្យត្រៀមរៀបចំខ្លួនទប់ទល់នឹងការវាយប្រហារក្នុងទ្រង់ទ្រាយធំរបស់កងទ័ពវៀតណាម ក្នុងរដូវប្រាំងខាងមុខ ។ នៅខែ កញ្ញា ១៩៨២ ក្នុងជំនួបជាមួយឧត្តមសេនីយ សក់ ស៊ុតសាខន និង ថាច់ រ៉ែង (ខាង ក.ជ.រ.ប.ខ.) ព្រមជាមួយឧត្តមសេនីយ ទៀប បែន និង លោក តុល ឡោះ (ខាងកងទ័ពសីហនុនិយម) លោកឧត្តមសេនីយ ឆាវលិត ទូន្មានថាកងទ័ពទាំងពីរ មិនត្រូវនៅស្ងៀមទេ[166] ។ លោកមេទ័ពថៃណែនាំឲ្យកងទ័ពទាំងពីរ ចេះបំបែកខ្លួន នៅពេលខ្មាំងវាយសម្រុកខ្លាំង ។ លោក ឆាវលិត ផ្តល់អនុសាសន៍ថា កម្លាំង ១/៣ ត្រូវចាត់ឲ្យចេញទៅប្រតិបត្តិការនៅខាងមុខទីតាំង ត្រូវធ្វើតាមរបៀបទ័ពព្រៃ ត្រូវប្រឹងធ្វើសង្គ្រាមចិត្តសាស្ត្រ ហើយមិនត្រូវធ្វើអ្វីទៀតឡើយ ។ តាមលោកឧត្តមសេនីយ ឆាវលិត កម្លាំង ១/៣ ត្រូវបញ្ជូនចូលក្នុងប្រទេសខ្មែរ ១/៣ ត្រូវធ្វើការហ្វឹកហាត់បំពាក់បំប៉នបច្ចេកទេសយោធា និង ១/៣ ត្រូវទុករក្សាការពារមូលដ្ឋាន និងទីតាំងខាងក្រោយ ។

នៅក្នុងក្របខ័ណ្ឌនៃទស្សនវិស័យយោធាថ្មី កងទ័ព រ.ជ.រ.ប.ខ. ហាក់ដូចជាសកម្ម ចេះផ្តើមគំនិតចេញវាយប្រយុទ្ធច្រើនជាងមុន ។ គឺនៅក្នុងបរិបទយោធាថ្មីនេះហើយ ដែលខ្លួនខ្ញុំផ្ទាល់បានឃើញ និង បានធ្វើជាសាក្សីនូវអ្វីដែលហៅថាសង្គ្រាម ។ តាមពិតទៅ ខ្ញុំបានឃើញទិដ្ឋភាពទាំងពីរនៃសង្គ្រាមគឺ ទាំងចំណុចល្អ ទាំងចំណុចអាក្រក់ ។ នៅពេលមានជ័យជំនះ ចិត្តយើងពុះកញ្ជ្រោល អបអរសាទរ តែនៅពេលបរាជ័យ ចិត្តយើងក៏ភ័យរន្ធត់ញាប់ញ័រយ៉ាងដូច្នោះដែរ ។ កាលពេលមុនៗ ខ្ញុំយល់ដឹងពីចម្បាំងតែតាមឯកសារ ឬ របាយការណ៍យោធា ឬ ដោយបាន

[166] Sak Sutsakhan, Compte-rendu de la rencontre avec le Général Chao le 10 Septembre 1982.

ស្តាប់យុទ្ធជនដំណាលពីបេសកកម្មរបស់ពួកគេ ។ តែចាប់តាំងពីខ្ញុំចូលមកធ្វើការក្នុងជួរអគ្គសេនាធិការ ក.ជ.រ.ប.ខ. ខ្ញុំក៏ចូលទៅក្នុងបេះដូងនៃម៉ាស៊ីនសង្គ្រាមគឺសង្គ្រាមជាក់ស្តែង ទាំងទីកន្លែង ទាំងពេលវេលាតែម្តង ។ នៅពេលដែលឃើញយុទ្ធជនចេញដំណើរទៅសមរភូមិមុខ ខ្ញុំមានមោទនភាព និង ទឹកចិត្តអបអរសាទរចំពោះទឹកចិត្តក្លាហានអង់អាចរបស់គេទាំងឡាយនោះ ។ ក៏ប៉ុន្តែ នៅរាល់សមរភូមិនោះ ក៏មិនមែនមានតែជ័យជំនះនោះទេ ។ ពេលណាយុទ្ធជនត្រឡប់មកវិញដោយនាំមកនូវជ័យជំនះ យើងលោតកញ្ឆេងអបអរសាទរ លើកសរសើរពួកគេថាយុទ្ធជននៃសេរីភាព ។ នេះជាជ្រុងល្អ ជ្រុងសប្បាយរីករាយនៃសង្គ្រាម ។ ក៏ប៉ុន្តែក៏មានអ្នកស្លាប់នៅលើទីលានប្រយុទ្ធ ចោលប្រពន្ធកូននៅខាងក្រោយ ។ នៅពេលទៅជួបក្រុមគ្រួសារនៃយុទ្ធជនដែលបានពលីទាំងនោះ ខ្ញុំមានអារម្មណ៍ក្តុកក្តួលក្រៃលែងមិនអាចទប់ចិត្តដ៏ខ្លោចផ្សានោះបានឡើយ ។ ភ្លាមៗនោះខ្ញុំយល់ថា "បញ្ជូនមនុស្សឲ្យទៅធ្វើសង្គ្រាមជារឿងស្រួលណាស់ ក៏ប៉ុន្តែការបាត់បង់អាយុជីវិតមនុស្សជារឿងទុក្ខសោកដ៏ធំធេង ជារឿងគួរឲ្យសោកស្តាយជាអតិបរិមា" ។ ក៏ប៉ុន្តែ នៅក្នុងចិត្តខ្ញុំៗក៏យល់ដែរថា សេរីភាព និង សេចក្តីថ្លៃថ្នូរមិនអាចរកបានយ៉ាងស្រួលនោះទេ ។ គេត្រូវតែបង់ថ្លៃអ្វីមួយ ដើម្បីឲ្យបានមកវិញនូវសេរីភាព និង សេចក្តីថ្លៃថ្នូរនេះ ។

នៅចុងឆ្នាំ ១៩៨២ រ.ជ.រ.ប.ខ. បានបង្កើនសកម្មភាពទ័ពព្រៃយ៉ាងខ្លាំងក្លា[167] ។ កិច្ចប្រតិបត្តិការវាយឆ្មក់ បានធ្វើឡើងនៅតំបន់ខាងកើតជាំក្សាន្តនៃខេត្តព្រះវិហារ នៅតំបន់ប៉ៃលិននៃខេត្តបាត់ដំបង នៅថ្មពួក និង បន្ទាយឆ្មារនៃខេត្តបន្ទាយមានជ័យ ។ កងកម្ម៉ង់ដូ រ.ជ.រ.ប.ខ. បានវាយឆ្មក់ទៅលើទីតាំងកងទ័ពវៀតណាម នៅបន្ទាត់បុស ចម្ងាយ ២៥ គ.ម ខាងកើតមូលដ្ឋានអំពិលរបស់យើង ។

[167] Khmer People's National Liberation Front, Press Release, Khmer Territory, December 17, 1982.

នៅចុងឆ្នាំ ១៩៨២ លោក ជា ឈុត បើកកិច្ចប្រតិបត្តិការនៅយោងដង្គំ ចម្ងាយ ៧ គ.ម ខាងកើតជំរុំនងចាន់ ។ គាត់ដាក់ឈ្មោះកិច្ចប្រតិបត្តិការនោះថា "កិច្ចប្រតិបត្តិការយោងដង្គំ" ។ បន្ទាប់ពីវាយប្រយុទ្ធគ្នាអស់រយៈពេលពីរសប្តាហ៍ កងកម្លាំងរបស់លោក ជា ឈុត បានដណ្តើមយកបានទាំងស្រុងនូវទីតាំងយោងដង្គំ ។ នៅក្នុងរបាយការណ៍របស់គាត់ផ្ញើជូនលោកតាប្រធាន សឺន សាន ចុះថ្ងៃទី ២៥ មករា ១៩៨៣ លោកឧត្តមសេនីយ ថាច់ រ៉ែង សរសេរថា៖ "ខែ មករា នេះ បានបញ្ជាក់ឲ្យឃើញនូវការឆ្លើមតំនិតយោធារបស់យើង ក្នុងការវាយទៅលើកងទ័ពវៀតណាម ។ ក្នុងអំឡុងខែនេះ គ្រប់ជំរុំយើង បានបញ្ជូនកងកម្លាំងឲ្យចូលទៅក្នុងទឹកដីខ្មែរ[168]" ។ បន្ទាប់មកលោកឧត្តមសេនីយក៏បានធ្វើរបាយការណ៍យោធាតាមជំរុំនីមួយៗ តាមតំបន់នីមួយៗ ។

កិច្ចប្រតិបត្តិការយោងដង្គំ ក៏ជាឱកាសមួយឲ្យខ្ញុំអាចទៅធ្វើទស្សនកិច្ចនៅក្នុងភូមិខ្មែរជ្រៅក្នុងទឹកដីខ្មែរ ដែលមានលក្ខណៈខុសប្លែកពីជំរុំជនភៀសខ្លួននៅតាមទល់ដែនខ្មែរ-ថៃ ។ អស់រយៈពេលជាយូរមកហើយ ដែលខ្ញុំមានបំណងជាន់ទឹកដីខ្មែរនៅក្នុងតំបន់ ដែលយើងហៅថាតំបន់ខ្ចាំងកាន់កាប់ ។ គ្រាន់តែឃើញទេសភាពនៃទឹកដីរបស់ជូនតាយើង ឃើញរាងដំបូលផ្ទះខ្មែរ ក្នុងភូមិខ្មែរ ដែលមានដាំដំណាំនានាដូចជា ចេក ល្ហុង ឬ ស្វាយ ធ្វើឲ្យចិត្តខ្ញុំពុះកញ្ជ្រោល និងកើតក្តីសង្ឃឹមក្នុងចិត្តសង្ឃឹមថាថ្ងៃណាមួយនឹងបានរំដោះ និង មករស់នៅលើទឹកដីនៃមាតុភូមិខ្ញុំមិនខាន ។ ខ្ញុំរំភើបខ្លាំងណាស់ នៅពេលដែលឃើញទង់ជាតិខៀវក្រហម និង រូបអង្គរសេកំពូលបី បក់រវិចនៅលើទីតាំងដែលទើបរំដោះបាន ។ នោះគឺជាទង់ជាតិខ្មែរ ដែលយើងធ្លាប់ប្រើមុនរបបសាធារណរដ្ឋរបប លន់ នល់ នៅមុនឆ្នាំ ១៩៧០ ។ ជោគជ័យនៅយោងដង្គំ ប្រហែលជាជ័យជំនះកំពូល និង ចុងក្រោយ

[168] Thach Reng, Compte-rendu pour l'information du Président du FNLPK, le 25 janvier 1983.

របស់ក.ជ.រ.ប.ខ. ។ បណ្តាញព័ត៌មានលោកខាងលិចបានផ្សព្វផ្សាយយ៉ាងទូលំទូលាយពីជ័យជំនះនេះ ។ វិទ្យុប៊ីប៊ីស៊ី (BBC)វិទ្យុអូស្ត្រាលី វិទ្យុសម្លេងសហរដ្ឋអាមេរិក វី អូ អេ (VOA) និង បណ្តាញទីភ្នាក់ងារសារព័ត៌មានសំខាន់ៗ សុទ្ធតែបានផ្សព្វផ្សាយអនុគ្រោះដល់រ.ជ.រ.ប.ខ.ទាំងអស់ ។ លោកឧត្តមសេនីយ ថាច់ រ៉ែង បានផ្តល់បទសម្ភាសន៍ផ្ទាល់ជាមួយវិទ្យុសម្លេងសហរដ្ឋអាមេរិក (VOA) ។ សូមបញ្ជាក់ថាចាប់តាំងពីឆ្នាំ ១៩៧៥ ដែលរបបកុម្មុយនីស្តបានឈ្នះសង្គ្រាមនៅប្រទេសទាំងបីនៃឥណ្ឌូចិនគឺ៖ លាវ វៀតណាម និង កម្ពុជា វិទ្យុ វី អូ អេ បានជំនួសវិទ្យុប៉េកាំងវិញ ។ ប្រជាពលរដ្ឋស្តាប់វិទ្យុសម្លេងសហរដ្ឋអាមេរិកកាន់តែច្រើនឡើងៗ ធ្វើឲ្យវិទ្យុនេះ មានប្រជាប្រិយភាពជាងវិទ្យុកុម្មុយនីស្តនៅក្នុងចំណោមប្រជាពលរដ្ឋខ្មែរ ទាំងនៅជាយដែនទាំងនៅក្នុងប្រទេស ។ នៅថ្ងៃទី ៣០ ធ្នូ ១៩៨២ លោកឧត្តមសេនីយ ថាច់ រ៉ែង និង លោក ជា ឈុត បាន ធ្វើជាអធិបតីនៃពិធីប្រគល់ទង់ជាតិ ជូនយុទ្ធជនដែលបានទទួលជ័យជំនះ ។

ទ័ពយើងខ្លាំង ឬ ខ្សោយ អាស្រ័យលើលោក ឆាវលិត

កិច្ចប្រតិបត្តិការយោងដង្គំ ក៏ជាឱកាសមួយឲ្យខ្ញុំបានរៀនសូត្រអំពីភាពផុយស្រួយនៃបេសកកម្មប្រយុទ្ធរបស់យើង ។ ប្រតិបត្តិការនេះ បានធ្វើឲ្យខ្ញុំដឹងពីសមត្ថភាពយោធារបស់ពួកយើងគឺ ពឹងផ្អែកទាំងស្រុងលើការគាំទ្រផ្នែកភស្តុភាពីប្រទេសថៃ ។ លោកឧត្តមសេនីយ ឆាវលិត ជាអ្នកកាន់កាប់យ៉ាងណែន នូវវាសនារបស់យើង ។ មេទ័ពថៃរូបនេះ ដើរតួជាគន្លឹះចំពោះរាល់កិច្ចប្រតិបត្តិការយោធារបស់យើង ។ ក្នុងពេលកន្លងមក ប្រសិនបើយើងអាចទទួលជោគជ័យខ្លះៗនោះ នោះក៏អាស្រ័យលើការគាំទ្ររបស់លោក ឆាវលិត ដែរ ។ នៅក្នុងរបាយការណ៍ជូនលោកតាសឺន សាន លោកឧត្តមសេនីយ ថាច់ រ៉ែង សរសេរថា៖ "ក្នុងរយៈពេលនៃកិច្ចប្រតិ

បត្តិការយោងដង្កំ អស់លោកហួណាថៃគ្រប់លំដាប់ថ្នាក់ (ហួណា ឬ មេកើយ) បានធ្វើសហការយ៉ាងល្អជាមួយយើង ។ អាជ្ញាធរថៃបានឆ្លើយតបជាវិជ្ជមាន និងភ្លាមៗចំពោះសំណើបន្ទាន់របស់យើង ។ ហួណាជីវ (ឧត្តមសេនីយ ឆាវលិត) ទោះបីជាដាប់វល់យ៉ាងណា ក៏អនុញ្ញាតឲ្យឧត្តមសេនីយ ថាច់ រ៉ែង ចូលជួប ហើយបានព្រមផ្តល់ឲ្យយើងនូវដំបងពិសេសមួយចំនួន (កាំភ្លើងពិសេស) ដែលអាចឲ្យយើងទប់ទល់ជាមួយការវាយប្រហារលើកទី៤នៃកងទ័ពវៀតណាម" ។ តាមពិតទៅ កងទ័ពថៃ បានប្រគល់ឲ្យយើងនូវកាំភ្លើងបាញ់រថក្រោះអំប្រុស្ស (Ambrust)មួយចំនួន ដែលមានប្រសិទ្ធភាពល្អក្នុងការប្រយុទ្ធជាមួយរថក្រោះ ធ្វើឲ្យទាហានរបស់យើងមានទឹកចិត្តខ្ពស់ក្នុងការប្រយុទ្ធ ។ ខ្ញុំឮគេនិយាយប្រាប់ថា កាំភ្លើងបាញ់រថក្រោះនោះ បានមកពីប្រទេសសឹង្ហបូរី ។ មែនទែនទៅ កាំភ្លើងបាញ់រថក្រោះអំប្រុស្សនោះ មានប្រសិទ្ធភាពមែន ក៏ប៉ុន្តែនៅពេលអស់គ្រាប់ កាំភ្លើងនោះក៏ទៅជាអាសាឥតការ ។ ក្រោយមក បន្ទាប់ពីបានប្រើដោយជោគជ័យ ខ្ញុំឮគេថារដ្ឋាភិបាលសឹង្ហបូរីទាមទារឲ្យប្រមូលយកកាំភ្លើងនោះ ពីសមរភូមិទៅវិញ នោះប្រហែលជាមានប្រតិកម្មពីក្រុងហាណូយក៏មិនដឹង ។ កងទ័ពថៃ ក៏ប្រមូលយកកាំភ្លើងបាញ់រថក្រោះនោះទាំងអស់ ដែលធ្វើឲ្យយុទ្ធជនយើងខកចិត្តយ៉ាងខ្លាំងចំពោះជំនួយក្រៅប្រទេសនេះ ។ ម្យ៉ាងទៀត ប្រសិនបើពិនិត្យឲ្យស៊ីជម្រៅតទៅទៀត ខ្ញុំអាចឃើញថាកងទ័ពថៃមិនមែនសុទ្ធតែឆ្លើយតប ជាវិជ្ជមានចំពោះសំណើររបស់យើងនោះទេ ឧទាហរណ៍ដូចជា៖ តាមសំណើរបស់លោកឧត្តមសេនីយ ថាច់ រ៉ែង ផ្ញើជូនលោកឧត្តមសេនីយ ឆាវលិត នៅខែ ធ្នូ ១៩៨២ នោះ យើងស្នើគ្រាប់ B40 ចំនួន ៥០០ គ្រាប់ យើងទទួលបានតែ ១០២ គ្រាប់ យើងស្នើគ្រាប់ M60 ចំនួន ៤០០គ្រាប់ យើងទទួលបានតែ ៨៥គ្រាប់ យើងស្នើគ្រាប់ DK85 ចំនួន ៤០០ គ្រាប់យើងអត់

បានទទួលមួយគ្រាប់ឡើយ[169] ។

លោក សក់ ស៊ុតសាខន និង ក្រុមលោក ជៀន ដែល

ដោយសារវត្តមានរបស់លោកឧត្តមសេនីយ ថាច់ រ៉េង នៅលើសមរភូមិ លោកឧត្តមសេនីយ សក់ ស៊ុតសាខន ហាក់ដូចជាដើរតួបន្ទាប់បន្សំទៅវិញ ។ តាមពិតទៅ លោកឧត្តមសេនីយ សក់ ស៊ុតសាខន ត្រូវគេទទួលស្គាល់ថាជានាយទាហានការទូតជាជាងនាយទាហានប្រយុទ្ធ ។ លោកឧត្តមសេនីយរូបនេះ ខឹតខំធ្វើការយកចិត្តទុកដាក់សម្របសម្រួល ដើម្បីអាចឲ្យធ្វើការបានជាមួយគ្រប់ភាគី ។ ចាប់តាំងពីបានមកកាន់តំណែងជាប្រធានគណៈកម្មាធិការអគ្គសេនាធិការ លោកឧត្តមសេនីយ សក់ ស៊ុតសាខន ខឹតខំទាក់ទាញទឹកចិត្តនាយទាហាន និងមន្ត្រីស៊ីវិលជិតស្និទ្ធជាមួយលោកឧត្តមសេនីយ ជៀន ដែល ដែលនៅសម័យនោះ ហាក់ដូចជាមេក្លោង ដែលអាចទាញខ្សែញាក់ឲ្យសហការ ឬ ឲ្យប្រឆាំងនឹងសកម្មភាពរបស់គណៈកម្មាធិការអគ្គសេនាធិការនៅក្នុងមូលដ្ឋានយោធាអំពិល ។ លោកឧត្តមសេនីយ សក់ ស៊ុតសាខន ហាក់ដូចជាពឹងផ្អែកទាំងស្រុង ទៅលើកិច្ចសហការរបស់អ្នកទាំងនោះ ដើម្បីឲ្យបេសកកម្មរបស់គាត់បានជោគជ័យ ។ បើពួកមេបញ្ជាការជិតស្និទ្ធជាមួយលោក ជៀន ដែល ទាំងនោះ គេទទួលស្គាល់ គេចាត់ទុកគាត់ជាមេ គាត់ពិតជាបានសម្រេច ។ លោកឧត្តមសេនីយប្រើប្រាស់ពេលវេលាមួយភាគធំលើការងារក្រដាសស្នាម ហើយយូរៗម្តង គាត់ចេញទៅពិនិត្យសភាពការណ៍នៅទីលានខាងមុខ តាមដំរុំនានា ។

លោកឧត្តមសេនីយ សក់ ស៊ុតសាខន ជានាយទាហានមានពាក្យសំដីទន់ភ្លន់ គាត់មិនដែលប្រើពាក្យអាមឺង ចំពោះនាយទាហានណាម្នាក់ឡើយ ។ លោក

[169] Thach Reng, To General Chavalit Yongchaiyuth, (A kind of Memo) Bangkok, December 28, 1982.

ឧត្តមសេនីយ មិនចេះនិយាយដើមគេ ហើយក៏ជាបុគ្គលម្នាក់ដែលគួរឲ្យដើរជាមួយណាស់ ។ លោកឧត្តមសេនីយចូលចិត្តពិសាបារី ។ នៅពេលរួចពីការងារ គាត់ចូលចិត្តពិសាស្រាវីស្គីលាយសូដាទឹកកក ឬ ស្រាបៀរ ។ តាមរយៈការងារនៅក្នុងគណៈកម្មាធិការអគ្គសេនាធិការនេះ បន្តិចម្តងៗ លោកឧត្តមសេនីយ សក់ ស៊ុតសាខន បានចាប់ដៃសហការជាមួយលោក ហ៊ីង គន្ធន យ៉ាងជិតស្និទ្ធ ។

វៀតណាមវាយបកវិញ

ជោគជ័យខាងយោធារបស់រ.ជ.រ.ប.ខ.មិនមានអាយុវែងឆ្ងាយឡើយ ដោយកងទ័ពវៀតណាមបានវាយតបវិញយ៉ាងខ្លាំងក្លា ។ ក្នុងកិច្ចប្រតិបត្តិការវាយបកវិញនេះ កងទ័ពវៀតណាម (កាលសម័យនោះ ប្រាកដជាមានកងទ័ពរដ្ឋកម្ពុជាចូលរួមពុំខានឡើយ តែខ្ញុំសរសេរនេះ ដោយយោងតាមឯកសារផ្លូវការរបស់ រ.ជ.រ.ប.ខ. ដែលមានលក្ខណៈប្រឆាំងកងទ័ពវៀតណាម) បានប្រើកម្លាំង ៦.០០០ នាក់ ប្រដាប់ដោយអាវុធធុនធ្ងន់ និង រថក្រោះ តេ៥៤ តេ៥៩ និង រថពាសដែក APC M116 ទៀតផង ។ មិនគ្រាន់តែដណ្តើមយកបានទីតាំង ដែលពួកគេបាត់បង់តែប៉ុណ្ណោះទេ ក៏ប៉ុន្តែ កងទ័ពនេះក៏វាយប្រហារយ៉ាងខ្លាំងមកលើជំរុំនងចាន់ ។

ដើម្បីជួយលើកទឹកចិត្តយុទ្ធជននៅនងចាន់ ខ្ញុំត្រូវបានចាត់ឲ្យទៅស្នាក់នៅក្នុងជំរុំនោះ ជាមួយលោក ប៉ែន ធុឡា កូនពៅរបស់សម្តេច ប៉ែន នុត ។ សហការីនៅក្នុងជំរុំនិយាយថា វត្តមានរបស់យើងខ្ញុំនៅក្នុងជំរុំ អាចជួយលើកទឹកចិត្តប្រជាពលរដ្ឋ កុំឲ្យមានការភិតភ័យ ព្រោះគេជឿថា ប្រសិនបើមានហេតុការណ៍អ្វីមួយកើតឡើង ថ្នាក់ដឹកនាំរ.ជ.រ.ប.ខ.ប្រាកដជាយកចិត្តទុកដាក់ជួយដោះស្រាយមើលថែទាំសុខទុក្ខរបស់ជនភៀសខ្លួន ។ និយាយតាមពិតទៅ ខ្លួនខ្ញុំផ្ទាល់មិនដឹងថា តើអាចនឹងជួយបានយ៉ាងដូចម្តេចឡើយ ។ បើអាចធ្វើបាននោះគឺ គ្រាន់តែជួយ

ផ្សព្វផ្សាយព័ត៌មានដល់បណ្តាញសារព័ត៌មានអន្តរជាតិ អំពីការវាយប្រហារណាមួយមកលើជំរុំ និង ស្នើសុំជំនួយមនុស្សធម៌ពីអង្គការសហប្រជាជាតិ រួមទាំងសហគមន៍អន្តរជាតិ ព្រមទាំងប្រទេសជាមិត្តតែប៉ុណ្ណោះ ។ ដូច្នេះខ្ញុំក៏មករស់នៅបណ្តោះអាសន្ននៅក្នុងជំរុំនងចាន់ នៅក្នុងផ្ទះសំណាក់មួយដែលនៅជាប់ផ្ទះលោក ជា ឈុត ក្នុងបរិវេណមួយ ដែលមានការយាមកាមយ៉ាងហ្មត់ចត់ជាទីបំផុត ។ នៅពេលជាមួយនោះ លោកឧត្តមសេនីយ ថាច់ វ៉ង ជាប់រវល់ជូនដំណើរអ្នកស្រី សួន កាសេត ទៅធ្វើទស្សនកិច្ចតាមជំរុំ ពីជំរុំមួយទៅជំរុំមួយ ឬ ទៅសម្រាកនៅឯក្រុងបាងកក ។

ជារៀងរាល់ថ្ងៃលោក ជា ឈុត តែងទៅត្រួតពិនិត្យទីតាំងទាំងឡាយ នៅក្រៅជំរុំតាមខ្សែត្រៀមនានានៅក្នុងទឹកដីខ្មែរ ។ ខ្ញុំក៏តែងរួមដំណើរទៅត្រួតពិនិត្យនោះ មិនដែលខានឡើយ ។ ពួកយើងមានទម្លាប់ចេញពីជំរុំឆ្ពោះទៅតំបន់ទួលផ្នឹកដែលជាទួលតូចមួយហើយដែលក្រុមលោក ជា ឈុត មកបោះជាទីតាំងបញ្ជាការឈានមុខ ។ នៅទីនោះ មានផ្លូវថ្មីរជើងតម្រង់ទៅទឹកដីកាន់កាប់ដោយកងទ័ពវៀតណាម និង កងទ័ពរដ្ឋាភិបាលភ្នំពេញ ដែលនៅពេលនោះយើងហៅថារបប ហេង សំរិន ។ យើងតែងចេញដំណើរតាមម៉ូតូ ដោយមានកងការពារហែហម ប្រដាប់ដោយអាវុធគ្រប់ដៃ ។ ម៉ូតូមួយមានទាហានពីរនាក់ ។ លោក ជា ឈុត បើកម៉ូតូ 125cc Endura ខ្លួនឯង រីឯខ្ញុំជិះពីក្រោយឱបចង្កេះ ។ ពេលធ្វើដំណើរម្តងៗគេឮសូរសម្លេងម៉ូតូលាន់រំពងរញ្ជួយមេឃរញ្ជួយដី មិនមែនធ្វើដំណើរលបៗស្ងាត់ៗនោះឡើយ ។ នៅសម័យនោះ អ្នកកាសែតអន្តរជាតិខ្លះ ហៅពួកយើងថាជាកងម៉ូតូទ័ពព្រៃ (Moto-riding guerilla men) ។ នៅពេលជាប់ដៃប្រយុទ្ធគ្នាម្តងៗគឺនៅទួលផ្នឹកនេះហើយដែលលោក ជា ឈុត ចេញមកបញ្ជាទ័ពតាមវិទ្យុទាក់ទង ។ ម្យ៉ាងទៀតគឺ នៅទួលនេះហើយដែលពួកយើង ចាំសង្កេតឃ្លាំមើលចលនារបស់កងទ័ព

បច្ចាមិត្ត ។ ដូច្នេះទួលផ្នឹកនេះ ក៏ជាគោលដៅនៃការបាញ់ផ្លោងកាំភ្លើងធំពីសំណាក់កងទ័ពវៀតណាម និង កងទ័ព ហេង សំរិន ដែរ ។

ថ្ងៃមួយនោះ ពេលពួកយើងកំពុងស្តាប់របាយការណ៍យោធា បច្ចាមិត្តក៏បាញ់គ្រាប់ ១០៧ មម មកលើទីតាំងរបស់យើងនៅទួលផ្នឹក។ គ្រាប់ស្ទើរទាំងអស់សុទ្ធតែផ្ទុះនៅប្រមាណ១០០ម ឬ ២០០មពីយើង ធ្វើឲ្យបាក់មែកឈើ និង ដើមឈើតូចៗជាច្រើន ក៏ប៉ុន្តែមិនមានប៉ះពាល់អាយុជីវិតមនុស្សទេ ។ ជាមួយគ្នានោះ ក៏មានពីរគ្រាប់ធ្លាក់ចូលក្នុងបរិវេណនៃទីបញ្ជាការឈានមុខរបស់យើងដែរ ។ ក៏ប៉ុន្តែ ជាសំណាងល្អ គ្រាប់ទាំងពីរនោះមិនផ្ទុះដូចគ្រាប់ឯទៀតទេ ។ កងទ័ពរបស់លោក ជា ឈុត ហាក់ដូចជាភ្លាហានណាស់ មិនមានការតក់ស្លុតចំពោះការបាញ់ផ្លោងនេះឡើយ ។ ទាហានម្នាក់ទៅរើសយកគ្រាប់រ៉ុំកែតនោះ ដាក់លើជើងសិប្បនិមិត្ត ព្រោះគ្មានជើងមែនទែន ហើយសាកល្បងបាញ់បកទៅម្ចាស់ដើមវិញ។ នៅពេលដែលត្រូវចុចថ្មភ្លាម គ្រាប់នោះបញ្ចេញសម្លេងគ្រហឹមឡើង ធ្វើឲ្យពួកយើងទាំងមេទាហានទាំងកូនទាហានខំសម្លឹង ដោយមិនដាក់ភ្នែកទៅរកគ្រឿងប្រល័យមនុស្សដ៏មានមហិទ្ធិរិទ្ធនោះ ។ គ្រាប់រ៉ុំកែតនោះ ក៏ស្ទុះហោះរឹងតម្រង់ទៅរកទីតាំងសត្រូវវិញក្រោមស្នូទេះដៃនៃអ្នកឈរមើលទាំងឡាយ ។ រួចមកខ្ញុំក៏ឮសូរសម្លេងផ្ទុះគ្នាំងនៅប៉ុន្មានគីឡូម៉ែត្រឯនាយពីយើង ។ ខ្ញុំនឹកថាប្រហែលអាចមានមនុស្សរបួស ឬស្លាប់មិនខានឡើយ ។ ក្រុមយើងហាក់ដូចជាមិនទាន់ស្កប់ស្កល់ ហើយនៅតែស្រែកឃ្លានស្វែងរកនូវជ័យជំនះថ្មីថែមទៀត ។ ពួកគេក៏រៀបចំបាញ់គ្រាប់ទីពីរ ។ ម្តងនេះនៅពេលចុចរួច គ្រាប់រ៉ុំកែតក៏ងើបឡើង តែមិនស្ទុះហោះដូចមុនទៀតទេ ។ គ្រាប់នោះ ចាប់ផ្តើមរលេចុះរលេឡើងយ៉ាងយឺតៗ ដោយបញ្ចេញសម្លេងគ្រហឹមកំញើញយ៉ាងរន្ថើន ។ រួចគ្រាប់នោះក៏តម្រង់ក្បាលមករកពួកយើង នៅលើទួលផ្នឹកដែលនៅជិតទីបាញ់នោះ។ មនុស្សស្ទើរទាំងអស់ នាំគ្នាស្ទុះទៅរកកន្លែងការពារយ៉ាងប្រញាប់

ប្រញាល់។ ខ្ញុំហាក់ដូចជាគ្មាននឹកភ័យខ្លាចអ្វីឡើយ ក៏ប៉ុន្តែខ្ញុំសង្កេតឃើញអ្នកនៅជុំវិញខ្ញុំខ្លះក្រាប ខ្លះពួននៅពីក្រោយដើមឈើធំៗ ។ ខ្ញុំចុះទៅខាងក្រោយទួល ។ ក្នុងរយៈពេលដ៏ខ្លីប៉ុណ្ណោះ ពួកយើងហាក់ដូចជានាំគ្នាមកប្រជ្រៀតពួននៅទីដ៏ចង្អៀតមួយ ។ ខ្ញុំឮតែសម្លេងគ្រាប់រោទ៍ រីមនុស្សម្នាឯទៀត ហាក់ដូចជាបាត់មាត់បាត់ក មិនឮនរណានិយាយស្តីអ្វីទាំងអស់ ។ ខ្ញុំជឿថាទាហានមិនតិចទេ ដែលនាំគ្នាសូត្របាលី ឬ ប្រើមន្តការពារខ្លួន ព្រមទាំងបន់ស្រន់ សំបូងសំរួង សុំឲ្យវត្ថុស័ក្តសិទ្ធិជួយយកអាសា ។ បន្ទាប់ពីតម្រង់ក្បាលម្តងទៅឆ្វេងម្តងទៅស្តាំ ព្រមជាមួយសម្លេងរោទ៍ឥតឈប់ គ្រាប់នោះ ទីបំផុត ក៏បែរក្បាលចេញពីពួកយើង ឆ្ពោះទៅទិសខាងកើតម្តងវិញ ។ គ្រាប់រ៉ុំកែត បន្តែមសម្លេងយ៉ាងខ្លាំងស្នូរ "ឈូត ឈូត ឈូត" រួចហោះចេញពីទីបញ្ជាការឈានមុខរបស់ពួកយើង ទៅបុកដើមឈើនៅខាងមុខ ធ្វើឲ្យយុទ្ធជនយើងពីរនាក់ស្លាប់ និង មួយចំនួនទៀតរងរបួស ។ នោះគឺជាគ្រោះថ្នាក់មួយដ៏ធំ ហើយក៏ជាបទពិសោធន៍អាក្រក់មួយសម្រាប់ខ្ញុំ ។ តាមពិតទៅ គ្រាប់រ៉ុំកែតនោះនៅមានសុពលភាពអាចប្រើការបាន ក៏ប៉ុន្តែក្រុមយើងក្រោយពីបាញ់គ្រាប់រ៉ុំកែតមុនរួចហើយ មិនបានផ្លាស់ថ្មថ្មី ធ្វើឲ្យកម្លាំងដែលត្រូវបង្វិលគ្រឿងនៅគូថគ្រាប់វិលមិនពេញកម្លាំង។ ខ្ញុំមានការនឹកស្រណោះអាណិតអាសូរចំពោះយុទ្ធជនដែលស្លាប់ និងរបួសទាំងនោះណាស់ ព្រោះគ្នាគ្មានបានប្រព្រឹត្តិអ្វីខុសសោះ តែត្រូវទទួលរងគ្រោះដោយសារសកម្មភាពមិត្តទៅវិញ ។

រៀងរាល់យប់ ពួកយើងតែងត្រៀមខ្លួនរង់ចាំការវាយប្រហាររបស់កងទ័ពវៀតណាមជាដរាប ។ មែនទែនទៅ ត្រៀមខ្លួនរង់ចាំនោះ មានន័យថាព្រួយបារម្ភចំពោះការវាយប្រហាររបស់សត្រូវដែលនឹងកើតមានឡើងគ្មានកាលកំណត់ ។ នៅពេលចូលដេក សហសេវិកជាច្រើននាំគ្នាដេកទាំងសំលៀកបំពាក់ប៉ាក់ប៉ាក និង អាវុធការពារខ្លួន ។ លោក ប៉ែន ធុទ្ធា ក្នុងសំលៀកបំពាក់ដូចខ្ញុំដែរគឺ អាវយឺត T-Shirt

និង ខោខាវបួយ តែងហៅទាហានមកសួរនាំជានិច្ច ពីទីកន្លែងដែលត្រូវរត់ចេញ តើចេញតាមច្រកណា ទៅតាមណា នៅពេលណា មុនចូលទៅសម្រាក ។ គាត់អត់ងងុយស្ទើររាល់យប់ ។ នៅយប់មួយនោះ ក្នុងជំរុំទាំងមូល គេរាល់គ្នាផ្តើលពីការវាយប្រហាររបស់កងទ័ពវៀតណាម ។ ក្នុងមួយយប់នោះ លោក ប៉ែន ធុឡា អត់បានសម្រាន្តទាល់តែសោះ ។ ផ្ទុយទៅវិញ ខ្ញុំមិនបានខ្វាយខ្វល់អ្វីប៉ុន្មានឡើយ ហើយនៅក្នុងយប់នោះ ខ្ញុំស្រម៉ុកខ្លាំងជាងយប់មុនៗទៅទៀត ។ ជាសំណាងល្អ ពុំមានការវាយប្រហារនៅយប់នោះទេ តែក៏ជាយប់ដែលមានភាពស្ងាត់ជ្រងំជាទីបំផុត ។ ព្រឹកស្អែកឡើង ខ្ញុំត្រូវចេញដំណើរត្រឡប់ទៅបាងកកវិញ ដើម្បីបំពេញភារកិច្ចផ្សេងទៀត ។ ប៉ុន្មានថ្ងៃក្រោយពីពេលដែលខ្ញុំចេញពីជំរុំនងចាន់ផុតទៅ កងទ័ពវៀតណាមក៏ចាប់ផ្តើមវាយប្រហារមកលើជំរុំនោះមែន ។ ក្នុងរយៈពេលតែពីរថ្ងៃប៉ុណ្ណោះ កងទ័ពវៀតណាម ក៏វាយយកបានជំរុំនងចាន់ទាំងមូល ។

របាយការណ៍ផ្ទៃក្នុងរបស់ រ.ជ.រ.ប.ខ. មានសេចក្តីជាអាទិថា៖ "ទោះបីជាយុទ្ធជនយើង មានស្មារតីលះបង់ និង ប្តេជ្ញាចិត្តយ៉ាងណាក៏ដោយ ក៏យុទ្ធជនយើងនៅនងចាន់ នៅទីបញ្ចប់ត្រូវបង្ខំចិត្តដកថយ និង បោះបង់ជំរុំចោលទាំងស្រុងគឺត្រូវបរាជ័យ នៅចំពោះការវាយប្រហារក្នុងទ្រង់ទ្រាយធំលើកទី៤ នៃកងទ័ពវៀតណាម ដែលកើតមានពីថ្ងៃទី ៣១ មករា ដល់ថ្ងៃទី ១ កុម្ភៈ ១៩៨៣"[170] ។

ក្នុងរយៈពេលត្រីមាសទី១នៃឆ្នាំ ១៩៨៣ ជាមួយនឹងការវាយប្រហារនៅនងចាន់ កងកម្លាំងរបស់កងពលលេខ ៥ លេខ ៣០២ និង ៣០៩ របស់វៀតណាម បានបាញ់ផ្លោងវាយប្រហារ និង កំទេចជំរុំនានានៅ ភ្នំឆ័ត្រ ចំការគរ ព្រៃមាន់ដែល ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកខ្មែរក្រហម ព្រមទាំងសីហនុបុរីនៃកងទ័ពរាជានិយម ។ នៅក្នុងសារទូរលេខមួយផ្ញើជូនលោកអគ្គលេខាធិការអង្គការសហ

[170] Sak Sutsakhan, Memorandum à la haute information de Monsieur le Président du FNLPK et Commandant en chef du FANLPK, le 21 février 1983.

ប្រជាជាតិ ហ្សាវី យេ ប៉េរ៉េ ដឺ ក្លូអែលឡា[171] (Javier Perez de Cuellar) លោក តា សឺន សាន បានចោទប្រកាន់ថា ការវាយប្រហាររបស់កងទ័ពវៀតណាម បានធ្វើ ឲ្យមានការបាត់បង់ជីវិត និង បាត់បង់ទីជម្រករបស់ប្រជាពលរដ្ឋស៊ីវិលផង ។ ជាមួយគ្នានោះ ការវាយប្រហារនេះ ក៏បានបង្កឲ្យមានការទម្លាក់កំហុសដាក់គ្នាក្នុងចំណោមមេទ័ពរបស់ រ.ជ.រ.ប.ខ. ។

លោកឧត្តមសេនីយ ថាច់ រ៉ែង ដែលធ្លាប់បានទទួលការលើកសរសើរដោយសារទ្រឹស្តីទ័ពព្រៃរបស់គាត់ ជាពិសេសចំពោះជោគជ័យមួយរយៈខ្លី នៅឯយាងដង្កំ បានបន្ទោសមេបញ្ជាការជំរុំអំពីបរាជ័យនេះ ព្រោះថាគាត់បានផ្តល់ព័ត៌មានច្បាស់លាស់ជាមុនអំពីពេលវេលា និង ទីកន្លែងដែលបច្ចាមិត្តបើកការវាយប្រហារ ។ មេបញ្ជាការជំរុំឆ្លើយតបវិញថាលោក ថាច់ រ៉ែង ពូកែតែខាងនិយាយ ពេលពួកយើងជាប់ដៃប្រយុទ្ធនៅលើសមរភូមិ លោក ថាច់ រ៉ែង មិនដែលនៅចូលរួមប្រយុទ្ធជាមួយពួកយើងឡើយ គាត់រវល់តែជាប់បណ្តើរអ្នកស្រី សួន កាសេត នៅតាមជំរុំ ឬ ទៅបាងកកតែប៉ុណ្ណោះ ។

អនុប្រធានថ្មី រ.ជ.រ.ប.ខ.

ទំនងជាចេះសម្របសម្រួលគ្នាទៅវិញទៅមក មេញ្ញាការជួរមុខទាំងអស់រាប់ទាំងលោក ជៀន ដែល ផងហាក់ដូចជាព្រមទទួលយកលោកឧត្តមសេនីយ សក់ ស៊ុតសាខន ជាមេដឹកនាំយោធារបស់ពួកគេតទៅ ។ នៅខែ ឧសភា ១៩៨៣ លោកតា ឈាន រ៉ែម បានលាឈប់ពីតំណែងអនុប្រធានរ.ជ.រ.ប.ខ. ។ លោកតា

[171] Son Sann, Prime Minister of the Coalition Government of Democratic Kampuchea, Cable Message to UN Secretary-General Perez de Cuellar, 9 April 1983.

សឺន សាន[172] ក៏បានតែងតាំងលោក សក់ ស៊ុតសាខន ជាអនុប្រធានទី១ និង លោក ជៀន ដែល ជាអនុប្រធានទី២ ។ បន្តិចម្តងៗ លោកឧត្តមសេនីយ សក់ ស៊ុតសាខន ក៏បានទទួលការទទួលស្គាល់ពីប្រទេសផ្តល់ជំនួយ ជាពិសេសពីក្រុមអាស៊ាន ។ ដោយមើលឃើញថា មេទ័ពរូបនេះធ្លាប់កាន់តំណែងជាអ្នកទទួលខុសត្រូវកំពូលចុងក្រោយ (ហានៈស្មើប្រមុខរដ្ឋ) និង ជានាយអគ្គសេនាធិការនាសម័យសាធារណរដ្ឋផង ប្រទេសផ្តល់ជំនួយទំនងជាវាយតម្លៃថាលោកឧត្តមសេនីយ សក់ ស៊ុតសាខន អាចជាដៃគូមួយក្នុងកិច្ចប្រតិបត្តិការយោធាប្រឆាំងកងទ័ពវៀតណាម។

អ្នកស្រី សួន កាសេត បានត្រូវអញ្ជើញឲ្យចេញពីទឹកដីថៃ

ក៏ប៉ុន្តែ លោក ថាច់ រ៉ែង និង អ្នកស្រី សួន កាសេត ដែលគេទទួលស្គាល់ថាជាភ្នែកជាត្រចៀករបស់លោកតា សឺន សាន បានសម្គាល់ថា លោក សក់ ស៊ុត សាខន ជាមេដឹកនាំដ៏ទន់ខ្សោយ និង សូញសាញមិនចេះអារកាត់អ្វីឡើយ ។ អ្នកទាំងពីរនេះ តែងព្យាយាមនាំព័ត៌មានផ្ទៃក្នុង ទៅប្រាប់ស្ថានទូតបរទេសរួមទាំងព័ត៌មានអំពីកិច្ចប្រតិបត្តិការយោធា ព្រមទាំងអំពីរបៀបរបបខុសឆ្គងក្នុងការរស់នៅដូចជាការផឹកស៊ី ដើរលេងយប់ជាដើម ដែលព័ត៌មានទាំងនោះ ទោះជាការពិតក៏ដោយ ក៏អាចឲ្យស្ថានទូតបរទេសទាំងនោះមើលស្រាលដល់នាយទាហានរបស់រ.ជ.រ.ប.ខ. ដែរ ។ សកម្មភាពទំនាក់ទំនងជាមួយស្ថានទូតបរទេសជាច្រើនរបស់លោក ថាច់ រ៉ែង និង អ្នកស្រី សួន កាសេត ទាំងនោះ បានធ្វើឲ្យក្រុមឧត្តមសេនីយថៃដែលត្រួតត្រាគ្រប់គ្រងចលនាតស៊ូរបស់យើងនោះមិនសប្បាយចិត្ត ។ សូមបញ្ជាក់ថា ក្នុង

[172] Son Sann, Khmer People's National Liberation Front, Décision no. 83/04/FNL, Territoire Khmer, le 2 Mai 1982.

សម័យនោះ លោក ថាច់ រ៉ង និង អ្នកស្រី សួន កាសេត មានការទាក់ទងជិតស្និទ្ធ ជាមួយក្នាក់ងារសម្ងាត់របស់បារាំង និង សឹង្ហបុរី ។

នៅខែធ្នូ ១៩៨៣ អាជ្ញាធរថៃក៏បានសុំឲ្យអ្នកស្រី សួន កាសេត ចាកចេញ ពីប្រទេសថៃ ។ អ្នកស្រី សួន កាសេត ក៏ត្រូវបង្ខំចិត្តវិលត្រឡប់ទៅប្រទេសបារាំង វិញ ជាទីដែលអ្នកស្រីធ្លាប់ស្នាក់អាស្រ័យនៅរហូតដល់ថ្ងៃចេញមករួមធ្វើការតស៊ូនៅ ជួរមុខនៅឆ្នាំ ១៩៧៩ ។ ការចាកចេញរបស់អ្នកស្រី សួន កាសេត ពិតជាការបាត់ បង់នូវសហការីដ៏មានតម្លៃម្នាក់របស់លោកតា សឺន សាន ។ ចំពោះពួកយើងដែល មានភក្តីភាពចំពោះលោកតាប្រធាន ការបាត់បង់នេះធ្វើឲ្យការខិតខំប្រឹងប្រែងរបស់ ពួកយើង ក្នុងការពង្រឹងក្រុមការងាររបស់លោកតាធ្លាក់ថយមួយកំរិត ។

លោក ថាច់ រ៉ង រត់តាម អ្នកស្រី សួន កាសេត

លោក ថាច់ រ៉ង និង អ្នកស្រី សួន កាសេត មិនបានលាក់លៀមអ្វីឡើយនូវ ទំនាក់ទំនងស្នេហារបស់ពួកគាត់ ។ ប៉ុន្មានថ្ងៃក្រោយពីការចេញដំណើររបស់អ្នក ស្រី សួន កាសេត ទៅប្រទេសបារាំង ខ្ញុំ និង លោក ថាច់ រ៉ង នាំគ្នាទៅតំបន់ កណ្តាលក្រុងបាងកក ដើម្បីអាចនិយាយទាក់ទងជាមួយអ្នកស្រី សួន កាសេត តាមទូរស័ព្ទពីសណ្ឋាគារមួយ ព្រោះបើនិយាយពីកន្លែងពួកយើងស្នាក់នៅៗនៅម៉ា យ៉ាឡាប់ យើងខ្លាចពួកទាហានថៃលបស្តាប់ ។ យើងនាំគ្នាដើរទៅរកសណ្ឋាគារ មួយ នៅតាមផ្លូវសុរិវង្ស ។ នៅពេលដែលលោកឧត្តមសេនីយនិយាយទូរស័ព្ទនោះ ខ្ញុំមិនអាចស្តាប់ឮនូវកិច្ចសន្ទនាគ្នានោះឡើយ ។ ក៏ប៉ុន្តែនៅពេលអ្នកទាំងពីរនិយាយ គ្នាចប់ លោក ថាច់ រ៉ង និយាយមករកខ្ញុំទាំងត្រហេបត្រហាបថា គាត់ត្រូវចេញពី ទឹកដីថៃភ្លាមៗ ពុំអាចរង់ចាំបានឡើយ ។ នោះគឺជាលើកទីមួយហើយ ដែលខ្ញុំ

ឃើញលោកមេទ័ពកងទ័ពពិសេសរបស់របប លន់ នល់ ម្នាក់នេះបាក់ទឹកចិត្តជាទីបំផុត ព្រោះថាគាត់ធ្លាប់តែទេសនា ឲ្យពួកយើងពង្រឹងស្មារតីតស៊ូប្រយុទ្ធជានិច្ច ដើម្បីរំដោះជាតិ ។ ទឹកចិត្តគាត់ធ្លាក់ទាបជាខ្លាំង ដែលបង្ខំឲ្យគាត់បោះបង់ចោលការតស៊ូទាំងស្រុង ។ គាត់បន្ទោសលោកតា សឺន សាន ថាជាមនុស្សទន់ខ្សោយជាមេដឹកនាំកំសាក ដែលមិនហ៊ានការពារកូនចៅឯង នៅចំពោះមុខការគាបសង្កត់របស់ថៃ បណ្តោយឲ្យថៃបណ្តេញអ្នកស្រី សួន កាសេត ចេញពីប្រទេសថៃ ។ រំពេចនោះ ខ្ញុំក៏នាំគាត់ទៅទិញសំបុត្រយន្តហោះ រួចគាត់ក៏ចេញដំណើរទៅប្រទេសបារាំង នៅល្ងាចនោះតែម្តង ។

ការសម្រេចចិត្តដ៏ប្រញាប់ប្រញាល់នោះ ជាការសម្រេចខុសដ៏ធ្ងន់ធ្ងរមួយរបស់លោក ថាច់ រ៉ៃង ដែលពិបាកកែសំរួលឡើងវិញណាស់ ។ ក្រោយពីលោក ថាច់ រ៉ៃង ចេញផុតពីទឹកដីថៃភ្លាម អាជ្ញាធរថៃក៏ចាត់វិធានការហាមឃាត់ លែងអនុញ្ញាតឲ្យវិលត្រឡប់មកជាន់ទឹកដីថៃវិញអស់រយៈពេលយ៉ាងយូរ ។ ដូច្នេះ លោកតា សឺន សាន ក៏បាត់បង់ជំនួយការខាងផ្នែកយោធា ដែលលោកតាយល់ថា មានកក្តីកាពចំពោះលោកតាម្នាក់ថែមទៀត ។ នាយទាហានម្នាក់ ដែលជាអ្នកការពារអំណាចយោធារបស់លោកតា សឺន សាន ទប់ទល់ជាមួយក្រុមប្រឆាំង ដែលមានលោក ជៀន ដែល ជាអ្នកដឹកនាំម្នាក់ ក៏ត្រូវអវត្តមាននៅជួរមុខ និង ក៏អស់លទ្ធភាពជួយពង្រឹងលោកតាប្រធានតទៅទៀតបាន ។ នៅសម័យនោះ លោកតា សឺន សាន ចេះតែស្រែកអំពាវនាវឥតឈប់ឈរឲ្យពង្រឹងវិន័យ និង ឯកភាពក្នុងជួរ.ជ.រ.ប.ខ. ព្រោះលោកតាយល់ថាករណីអ្នកស្រី សួន កាសេត និង លោក ថាច់ រ៉ៃង នេះបានត្រូវឧត្តមសេនីយ៍ថៃខ្លះ និង មន្ត្រី.ជ.រ.ប.ខ.ខ្លះបង្កើតឡើង ដើម្បីព្យាយាមកុំឲ្យលោកតាប្រធានមានលទ្ធភាព លូកដៃចូលក្នុងកិច្ចការប្រចាំថ្ងៃផ្នែកយោធាតែប៉ុណ្ណោះ ។

ចំពោះលោកតា សឺន សាន វិន័យ និង ឯកភាព បានន័យថាទាំងអស់គ្នាត្រូវតែដើរតាមការដឹកនាំរបស់លោកតាជាដាច់ខាត ។ អស់រយៈពេលជាច្រើនឆ្នាំមកហើយ ដែលលោកតាសង្ស័យថាមន្ត្រីខ្លះដូចជាលោក នាង ជិនហន និង ហ្គាហ្វា បានព្យាយាមធ្វើឲ្យលោកតានៅឯកោដាច់ឆ្ងាយពីកងទ័ព និង ពីមនុស្សជំនិតៗរបស់លោកតា ។

មហាសន្និបាតរ.ជ.រ.ប.ខ.

នៅខែ មករា ១៩៨៤ លោកតាប្រធាន ធ្វើដំណើរទៅតាមជំរុំទាំងអស់របស់រ.ជ.រ.ប.ខ.នៅតាមទល់ដែនខ្មែរ-ថៃ ។ នៅជំរុំនីមួយៗ លោកតាស្នើសុំឲ្យប្រជាពលរដ្ឋទាំងទាហានទាំងស៊ីវិល ពិនិត្យផ្តល់នូវអាណត្តិដឹកនាំរ.ជ.រ.ប.ខ.ជូនលោកតាតទៅទៀត ។ នៅទីណាដែលលោកតាស្នើសុំ ប្រជាពលរដ្ឋ និង យុទ្ធជនតែងលើកដៃគាំទ្រជានិច្ច ។ នៅថ្ងៃទី ២៨ មករា ១៩៨៤ រ.ជ.រ.ប.ខ.បានរៀបចំប្រជុំជាមហាសន្និបាតនៅជំរុំអំពិល[173] ។ តាមពិតទៅ លោកតា សឺន សាន មានបំណងរៀបចំជាសមាជ ដែលអាចផ្តល់អំណាចធំទូលាយហើយ ដែលអាចធ្វើវិសោធនកម្មលើបទបញ្ញត្តិទាំងឡាយស្តីពីការដឹកនាំរ.ជ.រ.ប.ខ.។ ក៏ប៉ុន្តែ កាលពីខែ មេសា ឆ្នាំ ១៩៨០ សមាជទី១ បានសម្រេចថារ.ជ.រ.ប.ខ. នឹងរៀបចំសមាជលើកទី២របស់ខ្លួននៅលើទឹកដីខ្មែរ ក្រោយពីបានរំដោះចេញពីការកាន់កាប់របស់កងទ័ពវៀតណាមតែប៉ុណ្ណោះ ។ នៅមហាសន្និបាតនោះ លោកតា សឺន សាន ក៏ត្រូវបានទទួលស្គាល់ឲ្យបន្តដឹកនាំរ.ជ.រ.ប.ខ.តទៅទៀត ។ លោកតាប្រធានថ្លែងថា៖ "ដោយសារអំណាច និង បុព្វសិទ្ធិដែលប្រជាពលរដ្ឋរួមទាំងស៊ីវិល និង ទាហានផ្តល់ដល់ខ្ញុំ នោះគឺជាករណីយកិច្ច និង ការទទួលខុសត្រូវរបស់ខ្ញុំទាំងស្រុង ដើម្បីដឹកនាំរ.ជ.រ.ប.ខ.ឆ្ពោះទៅ

[173] KPNLF Bulletin, February 6, 1982. pp. 18-20.

សម្រេចគោលបំណង និង គោលដៅដែលបានកំណត់រួចហើយ ។ ខ្ញុំត្រូវទទួលខុសត្រូវចំពោះប្រជាជាតិខ្មែរ ទាំងនូវជោគជ័យ ទាំងនូវបរាជ័យនៃបេសកកម្មដ៏ពិសិដ្ឋដែលបងប្អូនជនរួមជាតិបានប្រគល់ឲកយខ្ញុំ” ។ នៅក្នុងឱកាសនោះ លោកតា សឺន សាន ក៏បានប្រកាសបញ្ឈប់គណៈកម្មាធិការអគ្គសេនា ហើយបានប្រកាសតែងតាំង លោកឧត្តមសេនីយ សក់ ស៊ុតសាខន ជានាយអគ្គសេនាធិការពេញទី ដោយមាន លោក ព្រុំ វិត ជានាយអគ្គសេនាធិការងទី១ ទទួលបន្ទុកកិច្ចការយោធា និង លោក ហ៊ីង គន្ធុន ជានាយអគ្គសេនាធិការងទី២ ទទួលបន្ទុកកិច្ចការស៊ីវិល ។ មិនតែប៉ុណ្ណោះ លោកតាបានសម្រេចជោគជ័យក្នុងការសុំឲ្យមហាសន្និបាត ធ្វើវិសោធនកម្មកែសម្រួលតួនាទីរបស់គណៈកម្មាធិការប្រតិបត្តិ ហៅកាត់ថាកូមុិចទៀតផង ។ តាមរយៈវិសោធនកម្មនេះ លោកតា សឺន សាន ត្រូវបាន ក្លាយជាអ្នកដឹកនាំទាំងស្រុងនៃរ.ជ.រ.ប.ខ. ចំណែកឯគណៈកម្មាធិការប្រតិបត្តិ ក៏គ្រាន់តែមានតួនាទីត្រឹមជាជំនួយការរបស់ប្រធានតែប៉ុណ្ណោះ ។

ក្នុងន័យនេះគណៈកម្មាធិការប្រតិបត្តិមិនអាចសម្រេចអ្វីបានឡើយ បើគ្មានការយល់ព្រម ឬ គ្មានការផ្តល់អនុសាសន៍ពីប្រធានរ.ជ.រ.ប.ខ. ។ ដូច្នេះគណៈកម្មាធិការប្រតិបត្តិ មិនអាចបញ្ជាកងទ័ព ឬ ប្រើប្រាស់រដ្ឋបាលស៊ីវិល ឬ ដាក់ចេញនូវបន្ទាត់នយោបាយ ឬ ការណែនាំខាងការទូត ដោយគ្មានការយល់ព្រម ឬ ទទួលអនុសាសន៍ពីប្រធានរ.ជ.រ.ប.ខ.បានឡើយ ។ វិសោធនកម្មនេះ បានឃ្លាតចាកឆ្ងាយពីសេចក្តីសម្រេចដំបូង ដែលផ្តល់តួនាទីដឹកនាំកំពូលដល់គណៈកម្មាធិការប្រតិបត្តិក្នុងលក្ខណៈដឹកនាំជាសមូហភាព មកជាលក្ខណៈដឹកនាំផ្តាច់មុខ (ខ្ញុំមិននិយាយថាផ្តាច់ការទេ) របស់លោកតា សឺន សាន ទៅវិញ ។ តាមសេចក្តីសំរេចរបស់រ.ជ.រ.ប.ខ. ក្រោយពីបានប្រកាសបង្កើតជាផ្លូវការភ្លាម នៅឆ្នាំ ១៩៧៩ បានកំណត់ថាគណៈកម្មាធិការប្រតិបត្តិមានភារកិច្ចដឹកនាំរ.ជ.រ.ប.ខ.ទាំងស្រុង ។ គណៈកម្មាធិ

ការនេះជាអ្នកសម្រេចសកម្មភាពការងារទាំងអស់របស់រណសិរ្ស រួមទាំងដឹកនាំការងារខាងការទូត កំណត់បន្ទាត់នយោបាយ ប្រើប្រាស់រដ្ឋបាល និង បញ្ជាកងទ័ពជាតិរំដោះប្រជាពលរដ្ឋខ្មែរ ។

ខ្ញុំត្រឡប់មកបាងកកវិញ ដើម្បីធ្វើកាកបាតក្រហម

បន្ទាប់ពីគណៈកម្មាធិការបណ្តោះអាសន្ននៃអគ្គសេនាធិការ បានបញ្ចប់ការកិច្ច ខ្ញុំក៏វិលត្រឡប់ទៅកាន់ទីស្នាក់ការធំរបស់រ.ជ.រ.ប.ខ. នៅឯទីក្រុងបាងកកវិញ ដើម្បីទៅជួយការងាររបស់លោក សឺន ស៊ូបែរ្ត កូនលោកតា សឺន សាន ខាងផ្នែកកាកបាតក្រហម ដោយហេតុថា រ.ជ.ប.ខ. ទើបតែបង្កើតអង្គការមនុស្សធម៌នេះជាលើកដំបូង ។ លោក សឺន ស៊ូបែរ្ត ជាប្រធាន ឯខ្ញុំធ្វើជាអគ្គលេខាធិការ និង មិនយូរប៉ុន្មាន បន្ទាប់មកខ្ញុំជាហិរញ្ញិកនៃកាកបាតរ.ជ.រ.ប.ខ.រហូតមក។ វត្តមានរបស់ខ្ញុំនៅទីក្រុងបាងកក បានជួយពង្រឹងឡើងវិញខ្លះនូវទឹកចិត្តនៃមនុស្សជំនិតរបស់លោកតាប្រធានដែលបានធ្លាក់ចុះយ៉ាងខ្លាំង ដោយសារការចាកចេញរបស់លោក ថាច់ រ៉ែង និង លោកស្រី សួន កាសេត ។

សម្តេច ប៉ែន នុត ប្រដៅឲ្យពួកយើងរួបរួមគ្នា

នៅខែ កុម្ភៈ ១៩៨៤ ខ្ញុំធ្វើដំណើរទៅទីក្រុងប៉ារីស ដែលនៅទីនោះ ខ្ញុំបានជួបសម្តេច ប៉ែន នុត អតីតនាយករដ្ឋមន្ត្រីខ្មែរ និង ជាឥស្សរជននយោបាយជាន់ខ្ពស់ដែលខ្មែរភាគច្រើនមានការគោរពកោតខ្លាច។ សម្តេចជារដ្ឋបុរសម្នាក់ដែលធ្លាប់មានកក្តីភាពយ៉ាងស្មោះស្ម័គ្របំផុត ចំពោះសម្តេច សីហនុ និង ចំពោះរាជបល្ល័ង្កខ្មែរ ។ ក៏ប៉ុន្តែ ចាប់ពីពេលដែលបានរួចចេញពីរបបខ្មែរក្រហមមក សម្តេច ប៉ែន នុត

មិនបាននៅបំរើនយោបាយសម្តេច សីហនុ ទៀតទេ ។ សម្តេចបានបញ្ជូនកូនប្រុសទាំង ៤ នាក់របស់សម្តេច ឲ្យមកបំរើ.ជ.រ.ប.ខ.របស់លោកតា សឺន សាន ទៅវិញ ។ នៅក្នុងចិត្តរបស់ខ្ញុំៗមានមោទនភាពណាស់ ដែលបានទៅរាយការណ៍ផ្ទាល់ជូនសម្តេចអំពីលទ្ធនៃមហាសន្និបាត.ជ.រ.ប.ខ. ព្រមទាំងអំពីការតែងតាំងលោក ឧត្តមសេនីយ សក់ ស៊ុតសាខន ជានាយអគ្គសេនាធិការនៃក.ជ.រ.ប.ខ. និងការធ្វើវិសោធនកម្មនៃលក្ខន្តិក:របស់គណៈកម្មាធិការប្រតិបត្តិ (កូមុិច) ដែលត្រូវប្តូរពីការកិច្ចដឹកនាំកំពូល មកជាជំនួយការឲ្យប្រធាន រ.ជ.រ.ប.ខ.ទៅវិញ ។ ខ្ញុំខំពន្យល់សម្តេច ប៉ែន នុត ថាការកែប្រែលក្ខន្តិក:នេះ ធ្វើឡើងក្នុងន័យរក្សាស្ថេរភាពនៃការដឹកនាំរបស់រ.ជ.រ.ប.ខ.តែប៉ុណ្ណោះ ។ តាមពិតទៅ សម្តេច ប៉ែន នុត ជាអ្នកនយោបាយដើងចាស់មានបទពិសោធន៍យ៉ាងបរិបូណ៌ អាចធ្វើវិភាគបានម៉ត់ចត់ណាស់ ។ សម្តេច អាចប៉ាន់ប្រមាណមើលកម្លាំងរបស់ចលនាតស៊ូមិនមែនកុម្មុយនីស្តបានយ៉ាងត្រឹមត្រូវ ។ ទោះបីជាមានអាយុច្រើនយ៉ាងណាក៏ដោយ (ប្រហែលជិត ៨០ ឆ្នាំ)និង ទោះបីជាសម្តេចមានសម្លេងញ័រៗដែលជានិមិត្តសញ្ញានៃបុគ្គលិកលក្ខណៈរបស់សម្តេច ដែលខ្មែរយើងសម្គាល់ជាយូរមកហើយនោះ សម្តេច ប៉ែន នុត មានប្រសាសន៍ចំៗលើបញ្ហា ។ ជាដំបូង សម្តេចសួរថា តើឧត្តមសេនីយ ថាច់ រ៉េង នឹងវិលត្រឡប់ទៅសមរភូមិមុខវិញនៅពេលណា ។ លោក ថាច់ រ៉េង ដែលទៅជាមួយខ្ញុំនាពេលនោះ ឆ្លើយបែបមិនសូវច្បាស់លាស់ថា កំពុងរង់ចាំតែសញ្ញាភ្លើងខៀវពីបាងកកតែប៉ុណ្ណោះ ។ បើបានការអនុញ្ញាតឲ្យចូលទៅថ្ងៃណាពេលណា គាត់អាចចេញដំណើរទៅភ្លាម ព្រោះបានត្រៀមរួចជាស្រេចទៅហើយ ។

មែនទែនទៅ ចាប់តាំងពីចាកចេញពីបាងកកមក លោក ថាច់ រ៉េង បានព្យាយាមដាក់ពាក្យសុំទិដ្ឋាការនៅស្ថានទូតថៃនៅទីក្រុងប៉ារីស តែពាក្យសុំនោះត្រូវបានបដិសេធជានិច្ច ទោះបីជាលោកតា សឺន សាន បានធ្វើអន្តរាគមន៍ជាច្រើនលើកជា

មួយក្រសួងការបរទេសថៃក៏ដោយ ។ សម្តេច ប៉ែន នុត បានឆ្លើយតបមកខ្ញុំយ៉ាងមុឺងម៉ាត់ក្នុងន័យជាអាទិ៍ដូចតទៅនេះ៖ "ខ្ញុំតែងនិយាយថា អស់លោកត្រូវពិនិត្យមើលការរៀបចំផ្ទៃក្នុងរបស់រណសិរ្សនីមួយៗ ។ បញ្ហាផ្ទៃក្នុងនេះ មានសារសំខាន់ណាស់ ។ បើអស់លោកមិនអាចរួបរួមគ្នា (រវាងរ.ជ.ប.ខ. និង ហ៊ុន សុិន ប៊ុច)ទេ អស់លោកក៏ត្រូវតែខឹតខំកែលំអមុខមាត់របស់អស់លោក ។ អស់លោកហាក់ដូចជាមិនយល់នូវអ្វីដែលហៅថា រណសិរ្សប្រយុទ្ធ និង នូវអ្វីដែលហៅថាគណបក្សនយោបាយ ។ នៅក្នុងរណសិរ្ស គេត្រូវប្រមូលកម្លាំងឲ្យបានខ្លាំង ប្រមូលមនុស្សគាំទ្រឲ្យបានច្រើន ដោយមិនរើសអើងអ្វីឡើយ ។ ផ្ទុយទៅវិញ នៅក្នុងគណបក្សនយោបាយ គេត្រូវជ្រើសយកមនុស្ស ដែលស្មោះត្រង់តាមកំរិតនៃការទុកចិត្ត ។ ខ្ញុំនិយាយនេះ ខ្ញុំនិយាយជាទូទៅទេ មិនសំដៅតែរណសិរ្សរបស់អស់លោក ឬ ចំពោះរណសិរ្សមួយទៀតនោះទេ ។ ដើម្បីជៀសវាងការបែកបាក់ជាក្រុម ជាពួកនោះ អស់លោកត្រូវធ្វើការដើម្បីប្រជាពលរដ្ឋខ្មែរទាំងមូល ដើម្បីប្រជាជាតិខ្មែរ មិនមែនសម្រាប់តែក្រុមរបស់អស់លោកនោះឡើយ" ។

បន្ទាប់ពីជំនួបនេះ ខ្ញុំបានរាយការណ៍ភ្លាមទៅលោកតា សឺន សាន ចំពោះការមិនពេញចិត្តរបស់សម្តេច ប៉ែន នុត[174] ។ តាំងពីពេលនោះមក ខ្ញុំក៏ពុំបានដឹងពិតប្រាកដពីមូលហេតុនៃការខកខាន មិនបានយកអនុសាសន៍របស់មហាសន្និបាត រ.ជ.ប.ខ. ដែលបានសម្រេចកែប្រែលក្ខន្តិក:គណៈកម្មាធិការប្រតិបត្តិ ឬ កូមុិចឲ្យមានការកិច្ចបន្ទាប់បន្សំនោះ មកអនុវត្តតទៅទៀតឡើយ ។ សម្តេច ប៉ែន នុត ហាក់ដូចជាមើលឃើញនូវភាពផុយស្រួយនៃការដឹកនាំក្នុងជួរ.ជ.ប.ខ. ហើយសម្តេចក៏មានការចាប់អារម្មណ៍ ចំពោះការបែកបាក់ជាយថាហេតុនៃរ.ជ.ប.ខ.នេះផងដែរ ។

[174] Ieng Mouly, A Son Excellence le Président du Front National de Libération du Peuple Khmer et Premier Ministre du Gouvernement de Coalition du Kampuchea Démocratique, Paris, le 12 mars 1984.

យន្តការរួម រ.ជ.រ.ប.ខ. និង ហ៊ុន សុិន បុិច

នៅខែ មេសា ១៩៨៤ កងទ័ពវៀតណាមបានធ្វើការវាយប្រហារមកលើទីតាំងរ.ជ.រ.ប.ខនៅអំពិល ដែលជាមូលដ្ឋានយោធាផង និង ជាទីជម្រកនៃប្រជាពលរដ្ឋស៊ីវិលប្រមាណ ៣៦.០០០ នាក់ផង ។ កងទ័ពវៀតណាម បានប្រើអាវុធធុនធ្ងន់បាញ់ផ្លោងចូលក្នុងជំរុំ ហើយបានវាយប្រហារក្នុងទ្រង់ទ្រាយធំ លើទីតាំងនានារបស់មូលដ្ឋានអំពិល ។ ក្រោយពីប៉ះទង្គិច និង តេីបប្រយុទ្ធអស់រយៈពេល ១០ ថ្ងៃ កងទ័ពវៀតណាមពុំអាចដណ្តើមទីតាំងរបស់រ.ជ.រ.ប.ខ.បានឡើយ ។ នេះជាជោគជ័យមួយ ដែលធ្វើឲ្យកម្លាំងការពារមូលដ្ឋានអំពិលបានទទួលការកោតសរសើរ និង ការជឿទុកចិត្ត ។ ពេលនោះ លោកឧត្តមសេនីយ សក់ ស៊ុតសាខន និង ដៀន ដែលបានទទួលស្នាដៃល្អខាងផ្នែកយោធា ធ្វើឲ្យ រ.ជ.រ.ប.ខ. បានទទួលជោគជ័យខាងផ្នែកនយោបាយផងដែរ ។

ដើម្បីសម្របសម្រួលសកម្មភាពគាំទ្រកងកម្លាំងខ្មែរតស៊ូមិនមែនកុម្មុយនីស្ត (NCR : Non Communist Resistance) គឺ រ.ជ.រ.ប.ខ. និង ហ៊ុន សុិន បុិច ប្រទេសសមាគមអាស៊ាន បានបង្កើតក្រុមការងារមួយ (Working Group) ដែលមានតំណាងប្រទេសថៃជាប្រធាន ។ នៅពេលនោះ ប្រធានក្រុមការងារគឺលោក ហួណា វិស្ស៊ុ ឬ វិស្ណុ(ឈ្មោះសម្ងាត់) មែនទែន ឈ្មោះពិតប្រាកដគឺ លោកវរសេនីយឯក ស៊ូរ៉ាយុទ្ធ ជូឡាណន្ត (Surayuth Chulanond) ដែលក្រោយមកឡើងឋានៈជាឧត្តមសេនីយ មេទ័ពថៃ និង ឡើងកាន់តំណែងជានាយករដ្ឋមន្ត្រីក្រោយពីក្រុមយោធាបាន ធ្វើរដ្ឋប្រហារទម្លាក់លោក តាក់សុិន ពីតំណែងនៅឆ្នាំ ២០០៦ ។ នៅពេលដែលប្រទេសចិនជួយគាំទ្រយ៉ាងពេញទំហឹងខាងផ្នែកយោធាដល់ក្រុមខ្មែរក្រហមកម្ពុជាប្រជាធិបតេយ្យ ក្រុមការងារបានខិតខំគាំទ្រភាគីខ្មែរមិន

មែនកុម្មុយនីស្ត ។ ក្រុមនេះ បានលើកទឹកចិត្តឲ្យ រ.ជ.រ.ប.ខ. និង ហ៊ុន សុិន ប៊ុិច បង្កើតយន្តការរួមមួយ ដើម្បីសហការគ្នាក្នុងផ្នែកប្រតិបត្តិការ យោធា ឃោសនា និង ទំនាក់ទំនងសាធារណៈ ។

កាលពេលនោះ លោកតា សឺន សាន ហាក់ដូចជាមិនសូវចង់បង្កើតយន្តការរួមនេះប៉ុន្មានទេ ព្រោះការគ្រប់គ្រងរបស់យន្តការមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់លោកតាផង និង ម្យ៉ាងទៀត លោកតានៅមានជំនឿថារ.ជ.រ.ប.ខ.ជាចលនាតស៊ូមានរូបរាងធំធាត់ជាង ហ៊ុន សុិន ប៊ុិច ។ បើបង្កើតយន្តការរួមបានន័យថាជំនួយត្រូវចែកជាពីរស្មើគ្នា នៅពេលដែលរ.ជ.រ.ប.ខ.ធំជាង ត្រូវទទួលចំណែកច្រើនជាង ។ នៅអង្គប្រជុំមួយ ខ្ញុំធ្លាប់ឮលោកឧត្តមសេនីយ សក់ ស៊ុតសាខន បានខិតខំពន្យល់លោកតា សឺន សាន ឲ្យធ្វើសហការជាមួយ ហ៊ុន សុិន ប៊ុិច ដោយប្រៀបប្រដូចថា៖ "បងជួយដឹកដៃប្អូនឲ្យដើរ" ក្នុងន័យបងគឺ រ.ជ.រ.ប.ខ ឯប្អូនគឺ ហ៊ុន សុិន ប៊ុិច ។ នៅថ្ងៃទី ២ ឧសភា ១៩៨៤ ចលនាតស៊ូមិនមែនកុម្មុយនីស្តទាំងពីរ រ.ជ.រ.ប.ខ. និង ហ៊ុន សុិន ប៊ុិច បានបង្កើតគណៈកម្មាធិការមួយសម្រាប់ការផ្សព្វផ្សាយតាមវិទ្យុ ។ គេបាននាំគ្នាបង្កើតវិទ្យុផ្សាយសម្លេងមួយឈ្មោះហៅថា "វិទ្យុសម្លេងខ្មែរ" ។

ពែកមីកូ និង ម៉ាយ៉ាឡាប់

នៅថ្ងៃទី ៧ ឧសភា ១៩៨៤ លោកឧត្តមសេនីយ សក់ ស៊ុតសាខន និង ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ដែលនៅពេលនោះជាព្រះរាជតំណាងសម្តេចសីហនុ បានធ្វើជាអធិបតីនៃពិធីបង្កើតជាផ្លូវការនូវគណៈកម្មាធិការអចិន្ត្រៃយ៍ផ្នែកកិច្ចសហការយោធា (Permanent Military Committee for Coordination) ឬហៅកាត់ថា ពែកមីកូ (Permico) ។ ពួកក្រុមការងារបានប្រគល់តួនាទីប្រធាន

ពែកមីកូ ជូនលោកឧត្តមសេនីយ សក់ ស៊ុតសាខន ។ ក្រោយពីមានការបង្កើតពែកមីកូ នេះជាផ្លូវការមក លោកឧត្តមសេនីយ សក់ ស៊ុតសាខន លោក ហ្គាហ្វា និង សហការីមួយចំនួនទៀត បានរើតវ៉ាន់ចាកចេញពីទីស្នាក់ការ រ.ជ.រ.ប.ខ. នៅម៉ាយ៉ាឡាប់ទៅស្នាក់នៅទីកន្លែងថ្មី ដែលជាទីកន្លែងធ្វើការរបស់ពែកមីកូវិញ ដាច់ដោយឡែកពីពួកយើង ។ តាមពិតទៅក្រុមការងារបានផ្តល់ជំនួយហិរញ្ញវត្ថុសម្រាប់ចំណាយទាំងអស់របស់ពែកមីកូ ។

តាំងពីពេលនោះមក រ.ជ.រ.ប.ខ.ត្រូវបានចែកជាពីរក្រុម ក្រុមពែកមីកូ ដែលជាទីតាំងរបស់លោកឧត្តមសេនីយ សក់ ស៊ុតសាខន ជាក្រុមយោធា និង ក្រុមមួយទៀត ក្រុមម៉ាយ៉ាឡាប់ ជាទីតាំងរបស់លោកតា សឺន សាន ជាក្រុម នយោបាយ ។ ក្រុមពែកមីកូ មានជីវភាពរស់នៅហ៊ឺហាហ៊ឹកហ៊ាក់ជាងក្រុមម៉ាយ៉ាឡាប់ ព្រោះពួកគេមានសេរីភាពធ្វើដំណើរចេញចូលទាំងយប់ទាំងថ្ងៃ អាចចេញទៅកំសាន្តស៊ីផឹកខាងក្រៅបានដោយសេរី ។ ចំណែកខាងក្រុមម៉ាយ៉ាឡាប់ ជីវភាព រស់នៅមានសភាពស្រគត់ស្រគំ មិនចេញក្រៅទៅផឹកស៊ីផ្តេសផ្តាស បាយរួម សម្រាករួម ហើយគ្មានប្រាក់ខែសំរាប់ចំណាយផ្ទាល់ខ្លួនម្នាក់ៗទេ ។ លោកតា សឺន សាន មិនពេញចិត្តចំពោះការចាត់ចែងរបស់ក្រុមការងារ ដែលនាំឲ្យមានការបែងចែកជាក្រុមជាពួកយ៉ាងដូច្នេះទេ ព្រោះថាការនេះអាចធ្វើឲ្យក្រុមយោធាមានលទ្ធភាពផ្តាច់ខ្លួនលែងស្ថិតនៅក្រោមអំណាចគ្រប់គ្រងរបស់លោកតាតទៅទៀត ។ ជាមួយគ្នានោះ លោកតាប្រធានក៏មិនពេញចិត្តចំពោះក្រុមការងារ ដែលចាត់ចែងការងារដោយមិនពិគ្រោះជាមួយលោកតា ឬ ជាមួយសហការីជិតស្និទ្ធជាកូនចៅ ។ ធ្វើយ៉ាងនេះហាក់ដូចជាជួយឲ្យក្រុមយោធាអាចប្រណាំងប្រជែងដណ្តើមអំណាចដឹកនាំ រ.ជ.រ.ប.ខ. ពីលោកតាផង ។

ឯចំណែកលោកឧត្តមសេនីយ សក់ ស៊ុតសាខន ក៏ហាក់ដូចជាកាន់តែលំអៀងបន្តិចម្តងៗទៅរកក្រុមប្រឆាំងគឺ ក្រុមលោក ជៀន ដែល លោក ហ៊ឹង គន្ធុន និង លោក ហ្គាហ្វា ដែលបានប្រមូលផ្តុំទៅនៅជាមួយលោកឧត្តមសេនីយ សក់ ស៊ុតសាខន ឯពែកមីកូ ។ តាមពិតទៅ ក្រុមប្រឆាំងជាមួយលោកតា សឺន សាន ទាំងអស់ បាននាំគ្នាទៅជ្រកក្រោមម្លប់របស់លោកឧត្តមសេនីយ សក់ ស៊ុតសាខន អស់ពេលជាយូរមកហើយ ។ លោកតា សឺន សាន តែងតែយល់ថាក្នុង ហានៈជាប្រធាន រ.ជ.រ.ប.ខ. លោកតាត្រូវតែមានសិទ្ធិទទួលខុសត្រូវទាំងស្រុងក្នុង ជួរ រ.ជ.រ.ប.ខ. រួមទាំងការទទួលខុសត្រូវខាងផ្នែកយោធាផង ។ លោកតា មិនអាចទទួលយកបានទេនូវការបែងចែកភារកិច្ច ជាពិសេស ទុកភារកិច្ចខាងផ្នែកយោធាឲ្យក្រុមយោធាកាន់កាប់ផ្តាច់ចេញពីអំណាចទាំងមូលរបស់ប្រធាន ។ ក្នុងការប៉ុនប៉ងការពារអំណាចបញ្ជាការយោធា លោកតា សឺន សាន ខិតខំស្វែងរកមធ្យោបាយគ្រប់យ៉ាងដើម្បី បញ្ចូលមនុស្សជំនិតរបស់លោកតាដូចជាឧត្តមសេនីយ ថាច់ រ៉ែង ជាដើមឲ្យបានចូលក្នុងរចនាសម្ព័ន្ធកងទ័ពឡើងវិញ ។

ទស្សនកិច្ចនៅកូរ៉េខាងត្បូង

ពីថ្ងៃទី ៥ ទៅ ៨ មិថុនា ១៩៨៤ លោកតា សឺន សាន បានទៅធ្វើទស្សនកិច្ចផ្លូវការជាលើកទី១ នៅសាធារណរដ្ឋកូរ៉េ (កូរ៉េខាងត្បូង) ក្នុងហានៈជានាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ។ ក្នុងហានៈជាសម្ព័ន្ធមិត្តម្នាក់នៃលោកសេរី លោកតាចង់ឲ្យឃើញការខុសគ្នារវាងលោកតា និង សម្តេច សីហនុ ដែលចាប់តាំងពីរដ្ឋប្រហារឆ្នាំ ១៩៧០ មក បានយកទីក្រុងព្យុងយ៉ាង កូរ៉េខាងជើង ជាទីតាំងនៃការគង់ប្រថាប់នៅក្រៅប្រទេសរបស់ព្រះអង្គ ។ ម្យ៉ាងទៀត ពួកយើងចង់បង្ហាញថា កម្ពុជាជាមិត្តជាមួយកូរ៉េទាំងមូល មិនមែនចំពោះកូរ៉េខាងជើងកុម្មុយ

នីស្តតែមួយនោះឡើយ ។ ពីទីក្រុងប៉ារីសប្រទេសបារាំង លោកតានាំលោក ថាច់ រ៉ង ទៅជាមួយក្នុងទស្សនកិច្ចនៅកូរ៉េនេះ ។ តាមពិតទៅ ស្ទើរតែនៅរាល់ទស្សនកិច្ចនានានៅក្រៅប្រទេស លោកតា សឺន សាន ចូលចិត្តបញ្ចេញលោក ថាច់ រ៉ង ពីប្រទេសបារាំង ឲ្យអមដំណើរជាមួយ ដើម្បីបង្ហាញពិភពលោកថាលោក ថាច់ រ៉ង ជាមនុស្សជំនិត និង ដើម្បីបង្ហាញថាលោកតានៅមានមន្ត្រីយោធា ដែលអាចប្រើការបាន ប្រសិនបើមានសេចក្តីត្រូវការក្នុងជួរកងទ័ព ។ ក្រៅពីលោក ថាច់ រ៉ង នៅមានអ្នកអមដំណើរឯទៀតក្នុងពេលនោះគឺ៖ លោក ប៊ុន សាយ លោក ហ្គាហ្វា ពាងម៉ែត លោក សឺន ស៊ូប៊ែរ្ត និង រូបខ្ញុំ អៀង មូលី ។ នៅពេលនោះ ទោះបីខ្ញុំជាសមាជិកម្នាក់នៃខុទ្ទកាល័យនាយករដ្ឋមន្ត្រីក៏ដោយ ហើយប្រហែលជាខ្ញុំមានអាយុក្មេងជាងគេ ទើបគេចាត់ឲ្យខ្ញុំទទួលភារកិច្ចជាមន្ត្រីពិធីការ ។ ដំណើរទស្សនកិច្ចនេះ ក៏ជាឱកាសលើកទី១របស់ខ្ញុំក្នុងការអមដំណើរនាយករដ្ឋមន្ត្រី ក្នុងទស្សនកិច្ចផ្លូវការនៅក្រៅប្រទេស ។ នៅឱកាសនោះ លោកតា សឺន សាន បានជួបពិភាក្សាការងារជាមួយមន្ត្រីជាន់ខ្ពស់ក្នុងរដ្ឋាភិបាលកូរ៉េ រួមទាំងនាយករដ្ឋមន្ត្រីនៃប្រទេសជាមិត្តនេះផង ។

លោកតាប្រធានមានការពេញចិត្តណាស់ចំពោះដំណើរទស្សនកិច្ចជាផ្លូវការនេះ ។ មុនពេលគណៈប្រតិភូត្រឡប់ពីក្រុងសេអ៊ូលវិញនោះ លោកតាបានប្រកាសនៅក្នុងសន្និសីទសារព័ត៌មានមួយថា៖ "ទស្សនកិច្ចរបស់ពួកយើងនៅសាធារណរដ្ឋកូរ៉េ បានទទួលផល និង ផ្លែផ្កាល្អ" ។ តាមពិតទៅ ប្រទេសកូរ៉េខាងត្បូង បានផ្តល់ជំនួយខាងហិរញ្ញវត្ថុខ្លះដល់ចលនាតស៊ូរបស់យើង តាមរយៈស្ថានទូតកូរ៉េប្រចាំទីក្រុងបាងកក ។ ខ្ញុំបានទទួលព័ត៌មានថា ក្នុងឱកាសមួយនោះលោក ហ្គាហ្វា បានត្រូវស្ថានទូតហៅទៅទទួលប្រាក់ នៅពេលអវត្តមានលោកតា សឺន សាន ។ បានប្រាក់ដល់ដៃហើយ លោក ហ្គាហ្វា បានយកមួយចំនួនទៅចែកចាយដល់មេ

ទាហានខ្លះ ដោយគ្មានការអនុញ្ញាតពីប្រធាន និង ដោយពុំបានរាយការណ៍ជូនគាត់ឡើយ ។ ទង្វើនេះ បានធ្វើឲ្យលោកតាប្រធានក្រេវក្រោធយ៉ាងខ្លាំង ។ លោកតា សឺន សាន សម្គាល់ថាអាកប្បកិរិយាបែបនេះ ជាការខ្វះវិន័យ និង ល្មើសលើទំនុកចិត្ត ។ នោះក៏ពង្រីកការថ្នាំងថ្នាក់របស់លោកតាប្រធាន ចំពោះលោក ហ្គាហ្វា ៣ងម៉ែត ថែមមួយកំរិតទៀត ។

លោក ជៀន ដែល បញ្ជាឲ្យបោះបង់ជំរុំអំពិល

លោកតា សឺន សាន មានការបារម្ភយ៉ាងខ្លាំងចំពោះឯកភាពផ្ទៃក្នុងនៃចលនារ.ជ.រ.ប.ខ. ។ ឥទ្ធិពលរបស់លោកតាកាន់តែស្រុតចុះជាលំដាប់ ជាពិសេសក្នុងបណ្តាសមាជិកកូមុិច និង មេទាហានមួយចំនួន ។ រាល់ពេលប្រជុំម្តងៗ លោកតា សឺន សាន តែងតែអំពាវនាវឲ្យពង្រឹងឯកភាព និង សាមគ្គីភាពជានិច្ច ។ បន្ថែមលើសនេះទៅទៀត ឆ្នាំ ១៩៨៤ ជាឆ្នាំមួយដែលរ.ជ.រ.ប.ខ. ត្រូវទទួលរងនូវការវាយប្រហារដ៏ខ្លាំងក្លាពីសំណាក់កងទ័ពវៀតណាម ។ ប្រហែលជាដើម្បីសងសឹកព្រោះពួកគេវាយដណ្តើមបញ្ជាការដ្ឋានក.ជ.រ.ប.ខ.នៅអំពិលមិនបាន ទើបលើកនេះ កងទ័ពវៀតណាមបានបង្កើនការវាយប្រហារកំទេចចោលទាំងអស់នូវជំរុំ រ.ជ.រ.ប.ខ. តាមជាយដែនខ្មែរ-ថៃ ។ នៅថ្ងៃទី ៨ វិច្ឆិកា ១៩៨៤ កងទ័ពនេះ បានវាយប្រហារយ៉ាងខ្លាំងទៅលើកម្លាំងប្រមូលផ្តុំរបស់កងទ័ពនងចាន់ ដែលទើបកសាងឡើងវិញ ។ បន្ទាប់មក នៅថ្ងៃទី ៨ ធ្នូ ១៩៨៤ ជំរុំណាំយឺន ត្រូវទទួលរងការវាយប្រហារ ។ ថ្ងៃទី ១១ ធ្នូ ១៩៨៤ ជំរុំសុខសាន្ត ថ្ងៃទី ២៥ ធ្នូ ជំរុំអូរបុក (ឬ សន្តិសុខ) និង ជំរុំប្រទ្វីសែន ក៏រងការវាយប្រហារដែរ ។ ក៏ប៉ុន្តែ គោលដៅសំខាន់ជាងគេរបស់កងទ័ពវៀតណាមគឺ ជំរុំអំពិលដែលជាបញ្ជាការដ្ឋានដ៏ធំបំផុតរបស់

រ.ជ.រ.ប.ខ ហើយដែលតាំងពីខែ មេសា កន្លងមក ពួកយើងសម្គាល់ថា ជាទីតាំងដែលមានការការពាររឹងមាំ មិនអាចដណ្តើមបានដោយស្រួលៗឡើយ ។ មែនទែនទៅ ចាប់ពីថ្ងៃទី ២២ ធ្នូ មក មូលដ្ឋានអំពិលត្រូវទទួលរងការវាយប្រហារដ៏ធ្ងន់ធ្ងរជាទីលានបង្ហូរឈាមដ៏សាហាវមួយ ។ មកដល់ថ្ងៃទី ៦ មករា ១៩៨៥ ដំរុំ ៥ ក្នុងចំណោមដំរុំទាំង ៨ របស់ រ.ជ.រ.ប.ខ. ត្រូវបែកខ្ញែចក្រោមការវាយប្រហារ ។ ការប្រយុទ្ធគ្នានៅអំពិល ត្រូវបានបន្តរហូតដល់ថ្ងៃ ៨ មករា ១៩៨៥ នៅពេលដែលលោកឧត្តមសេនីយ ជៀន ដែល ចេញបញ្ជាឲ្យយុទ្ធជនរបស់គាត់បោះបង់ចោលដំរុំនៅម៉ោង ១១ ព្រឹក[175]។ នៅពេលរសៀល ទីបញ្ជាការនៃអគ្គសេនាធិការត្រូវបានបោះបង់ ។ ការបាត់បង់ដំរុំអំពិល ជាព្រឹត្តិការណ៍ថ្មីមួយ ដែលតម្រូវឲ្យមានការបំបែកប្រជាពលរដ្ឋស៊ីវិលចេញពីយុទ្ធជនគឺ ស៊ីវិលត្រូវដន្លៀសចូលទឹកដីថៃ ឯទាហានត្រូវពង្រាយតាមជាយដែន ។ ចាប់ពីបានទទួលមេរៀននៃការប្រយុទ្ធនៅអំពិលមក មេដឹកនាំយោធារបស់យើង កាន់តែនាំគ្នានិយាយ ឬ គិតគូរអំពីធ្វើសង្គ្រាមតាមយុទ្ធសាស្ត្រ ឬ កលយុទ្ធទ័ពព្រៃ ។

ការងារដ៏សំខាន់នៅកាកបាតក្រហម

ចាប់តាំងពីពេលបានវិលមករស់នៅឯបាងកកវិញ ខ្ញុំមានការជាប់រវល់យ៉ាងខ្លាំងក្នុងកិច្ចការរបស់កាកបាតក្រហម រ.ជ.រ.ប.ខ. ។ នៅពេលនោះ ខ្ញុំ និង លោក សឺន ស៊ូប៊ែរ៉ែ បានរួមរួបគ្នាធ្វើការបានល្អណាស់ ។ លោក សឺន ស៊ូប៊ែរ៉ែ ដែលជាកូនប្រុសច្បងរបស់លោកតា សឺន សាន ក្នុងហាន:ជាប្រធានមានភារកិច្ចច្រើនខាងផ្នែកទំនាក់ទំនងសាធារណៈ ។ ចំណែកខ្ញុំៗត្រូវបានទទួលលទ្ធភាពឲ្យចាត់ចែងកិច្ចការគ្រប់គ្រងហិរញ្ញវត្ថុផង កិច្ចការប្រតិបត្តិផង ។ ក្នុងសម័យនោះ លោកតា សឺន សាន

[175] Khmer People's National Liberation Front, Military Situation at Banteay Ampil, January 8, 1985 at 2 p.m.

ទទួលបាននូវការគាំទ្រពីជនរួមជាតិនៅក្រៅប្រទេសច្រើនគួរសមដែរ ។ តាមរយៈកេរ្តិ៍ឈ្មោះល្អនៅក្រៅប្រទេសរបស់លោកតាប្រធាននេះ កាកបាតក្រហមរ.ជ.រ.ប.ខ. ក៏ទទួលបាននូវការគាំទ្រខាងហិរញ្ញវត្ថុមួយចំនួន ពីសំណាក់ខ្មែរនៅបរទេស ពីសំណាក់អង្គការអន្តរជាតិនានា និង ពីមូលនិធិខ្លះផង ។

នៅចុងឆ្នាំ ១៩៨៤ កាកបាតក្រហម រ.ជ.រ.ប.ខ. ក៏បានទទួលជំនួយហិរញ្ញវត្ថុពីមូលនិធិអាឡឺម៉ង់មួយឈ្មោះ ខុន រ៉ាដ អាឌិនណៅអែរ (Konrad Adenauer Foundation)[176] ។ ដោយសារជំនួយនេះ ពួកយើងបានបង្កើតពុទ្ធិកសមាគមមជ្ឈមណ្ឌលស្រាវជ្រាវព្រះពុទ្ធសាសនាមួយ និង មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមួយ ។ យើងមានគំនិតថា បន្ទាប់ពីបានធ្លាក់ចូលក្នុងរណ្តៅសង្គ្រាម និង របបកុម្មុយនីស្តផ្តាច់ការមក យើងត្រូវកសាងព្រះពុទ្ធសាសនា វប្បធម៌ និង ទំនៀមទម្លាប់របស់ខ្មែរឲ្យរស់រានមានជីវិតឡើងវិញ ។ យើងជឿថាព្រះពុទ្ធសាសនា និងវប្បធម៌ទំនៀមទម្លាប់ខ្មែរ ជាចំណុចសញ្ញាឲ្យខ្មែរមកភពប្រសព្វជួបជុំគ្នាវិញ ក្នុងនាមជាខ្មែរដែលត្រូវបានបែកបាក់ ខូចខាត រង្វេងចូលទៅក្នុងព្រៃជ្រៅនៃមនោគមវិជ្ជាដែលបានបំបែកខ្មែរជាបក្ស ជាពួក រួចកាប់សម្លាប់គ្នានោះ ។

មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ជួយបណ្តុះបណ្តាលជាងជួសជុលគ្រឿងយន្ត (ឡាន និង ម៉ូតូ) ជាងភ្លើង ជាងជួសជុលវិទ្យុទូរទស្សន៍ ដែលជាតម្រូវការដើម្បីកសាងប្រទេសឡើងវិញ ។ ក្រៅពីនេះ យើងខិតខំឲ្យមានការបង្រៀនភាសាបរទេស ជាពិសេស អង់គ្លេស និង បន្តបន្ទាប់មក ក៏មានបន្ថែមវិជ្ជាកុំព្យូទ័រថែមទៀត ដល់បងប្អូនដែលរស់នៅក្នុងជំរុំទៀតផង ។ និយាយរួមទៅ មូលនិធិ ខុនរ៉ាដ អាឌិនណៅអែរ ដែលនៅពេលនោះ មានលោក វ៉ុលហ្គង់ ហ្វុនអែរ ហ្វា (Wolgang

[176] មូលនិធិអាឡឺម៉ង់នេះ ផ្តល់ជំនួយហិរញ្ញវត្ថុ ក្នុងរង្វង់ ៣០០ ០០០ ម៉ាកអាឡឺម៉ង់ ក្នុងមួយឆ្នាំៗរហូតដល់ពេលមាតុភូមិនិវត្តន៍ ។

Von Erffa)ជាអ្នកតំណាងប្រចាំទីក្រុងបាងកក បានជួយរ.ជ.រ.ប.ខ. ក្នុងការកិច្ចដ៏ធំធេង និង ធ្ងន់ធ្ងរបស់យើងបានល្អណាស់ ។ ដោយសារកាកបាតក្រហមរ.ជ.រ.ប.ខ.មានដំណើរការកាន់តែសកម្មឡើង ខ្ញុំ និង លោក ស៊ូបែរ្ត ហាក់ដូចជាកាន់តែមានស្វ័យភាពច្រើនឡើងៗពីការិយាល័យរបស់លោកអគ្គលេខាធិការ នាង ជិនហន ។ ខ្ញុំកាន់តែមានលទ្ធភាពក្នុងការរៀបចំសម្របសម្រួលសកម្មភាពសំខាន់ៗ ដើម្បីគាំទ្រលោកតា សឺន សាន។ ដោយយកទង់កាកបាតក្រហមមកប្រើ ខ្ញុំរកឃើញមធ្យោបាយធ្វើដំណើរក្នុងទឹកដីថៃកាន់តែស្រួលជាងមុន កាន់តែសេរីជាងមុន ។ ខ្ញុំទិញរថយន្ត មីនីប៊ុស (mini-bus)មួយ និង ជួលជនជាតិថៃម្នាក់ ដែលចេះខ្មែរបន្តិចបន្តួចជាអ្នកបើកបរ ។ ដូច្នេះ នៅទីបញ្ចប់ ខ្ញុំអាចធ្វើដំណើរទៅទីណាក៏បាន ដោយមិនចាំបាច់ឲ្យហួណាថៃអមដំណើរជាមួយដូចមុនឡើយ ។

ពួកទាហានទាមទារឯករាជ្យពីលោកតា សឺន សាន

ការបំបែកប្រជាពលរដ្ឋស៊ីវិលចេញពីយុទ្ធជន បាននាំឲ្យអ្នកដឹកនាំយោធាគឺអស់លោកមេទ័ពឧត្តមសេនីយទាំងឡាយ កើតគំនិតទាមទារកឯករាជ្យពីលោកតា សឺន សាន ដែលនៅតែប្រកាន់ថា ក្នុងឋានៈជាប្រធាន រ.ជ.រ.ប.ខ. លោកតាត្រូវតែមានអំណាចបញ្ជាកងទ័ព ។ តាមការរៀបចំបង្កើតរ.ជ.រ.ប.ខ. តាំងពីដើមមក ប្រធានជាអគ្គមេបញ្ជាការកងទ័ព ។ ក៏ប៉ុន្តែ ដោយមានការគាបសង្កត់ពីក្រុមការងារនៅទីបំផុត លោកតាប្រធាន ក៏ត្រូវបង្ខំចិត្តតែងតាំងលោកឧត្តមសេនីយ សក់ ស៊ុត សាខន ជាអគ្គមេបញ្ជាការកងទ័ព ឯលោកឧត្តមសេនីយ ជៀន ដែល ជានាយអគ្គសេនាធិការ នៅថ្ងៃទី ១ ឧសភា ១៩៨៥ ។ ក្នុងការតែងតាំងនោះ ដើម្បីបញ្ជាក់ថា លោកតាប្រធាននៅតែជាអ្នកដឹកនាំកំពូលរបស់រ.ជ.រ.ប.ខ. នោះក្រឹត្យ

តែងតាំងសរសេរជាអាទិ៍ថា៖ លោកឧត្តមសេនីយ សក់ ស៊ុតសាខន បានទទួលប្រតិភូកម្មផ្ទាល់ពីប្រធានក្នុងមុខតំណែងជាអគ្គបញ្ជាការ ក.ជ.រ.ប.ខ. ។ លោកតាមានជំនឿថា អាចដកប្រតិភូកម្មនេះពេលណាក៏បាន ប្រសិនបើចង់បញ្ឈប់ឧត្តមសេនីយ សក់ ស៊ុតសាខន ពីតំណែងអគ្គបញ្ជាការកងទ័ព ។

លោកឧត្តមសេនីយ សក់ ស៊ុតសាខន កាន់តែទទួលបាននូវភាពស្របច្បាប់ក្នុងឋានៈជាមេដឹកនាំកងទ័ព តាមរយៈក្រឹត្យតែងតាំងថ្មីចុះហត្ថលេខាដោយលោកតា សឺន សាន និង ដោយមានការយល់ព្រមពីកូមុិចផង ។ បន្ថែមលើភារកិច្ចជាប្រធានពែកមីកូ(Permico) លោកឧត្តមសេនីយ ហាក់ដូចជាលេចធ្លោឡើងជាមេដឹកនាំម្នាក់ទៀតនៃចលនាតស៊ូមិនមែនកុម្មុយនីស្ត ក្រៅពីមេដឹកនាំធំៗពីរគឺ លោកតា សឺន សាន និង សម្តេច សីហនុ ។ លោកឧត្តមសេនីយ សក់ ស៊ុតសាខន ប្រាកដជាត្រូវលើកទឹកចិត្តឲ្យងើបឈរឡើង ដើម្បីអនុវត្តយុទ្ធសាស្ត្រយោធារបស់ក្រុមការងារ ដោយដកឃ្លាចេញក្រៅពីរដ្ឋាភិបាលចម្រុះត្រីភាគី ដែលក្រុមអាស៊ានសំឡឹងឃើញកម្លាំងទ័ពទាំងអស់ ស្ថិតនៅក្រោមឥទ្ធិពលរបស់ខ្មែរក្រហម ។ ក្នុងទស្សនៈនេះ ថ្នាក់ដឹកនាំយោធារបស់ចលនាតស៊ូមិនមែនកុម្មុយនីស្ត ត្រូវបានលើកទឹកចិត្តឲ្យត្រួតត្រាលើកងទ័ពទាំងពីររបស់ រ.ជ.រ.ប.ខ. និង ហ៊ុន សុិន ប៊ុច ។

តាមពិតទៅ តាំងពីខែ ឧសភា ១៩៨៥ រៀងមក កងទ័ពត្រូវបានស្ថិតនៅឯករាជ្យរួចទៅហើយ ព្រោះកងទ័ពមានថវិកា មានបុគ្គលិក និង ភស្តុភារបស់ខ្លួនដាច់ដោយឡែក ។ កងទ័ពបានទទួលការគាំទ្រផ្ទាល់ពីអាជ្ញាធរយោធាថៃ ជាពិសេសពីកងទ័ពជើងគោកថៃ និង ពីក្រុមការងារ ។ តែទោះជាយ៉ាងណាក៏ដោយ ក៏លោកតា សឺន សាន នៅតែខំប្រឹងប្រែងរក្សាការពារការគ្រប់គ្រងរបស់លោកតាទៅលើកងទ័ពដោយបន្តព្យាយាមអំពាវនាវឲ្យគោរពឯកភាព និង វិន័យនៅក្នុងជួរទ័ពរបស់គាត់ ។ លោកតាសំឡឹងឃើញការរៀបចំថ្មីផ្នែកយោធារបស់ក្រុមការងារ ឲ្យកងទ័ព

ឯករាជ្យ ចេញពីអំណាចរបស់ ប្រធានរណសិរ្សថាជាការរៀបចំបំបែកបំបាក់មួយ ។ ដូច្នេះ លោកតាហាក់ស្ថិតនៅជាឧបសគ្គចំពោះយុទ្ធសាស្ត្ររបស់ក្រុមការងារ ។

ក្រុម សឺន សាន និង សក់ ស៊ុតសាខន តម្លើងសម្លេងដាក់គ្នា

នៅសម័យនោះ មានការឃោសនាប្រឆាំងគ្នាយ៉ាងខ្លាំងក្លាគឺមួយមកពីក្រុមគាំទ្រលោកតា សឺន សាន និង មួយទៀតមកពីក្រុមគាំទ្រលោកឧត្តមសេនីយ សក់ ស៊ុតសាខន ។ ក្រុមគាំទ្រលោកតា សឺន សាន បានឃោសនាថា ក្រុមមេដឹកនាំយោធាខ្មែរមិនមែនកុម្មុយនីស្ត សុទ្ធតែជាមនុស្សខ្វះសមត្ថភាព មិនអាចរំដោះប្រទេសពីការកាន់កាប់របស់បរទេសឡើយ ។ នៅពេលលោកតា សឺន សាន ជួបជាមួយលោក សិទ្ធី សារ៉ែតសីលា រដ្ឋមន្ត្រីការបរទេសថៃនៅខែ សីហា ១៩៨៥ លោកតាប្រធាន ជំរាបលោករដ្ឋមន្ត្រីថា៖ "យើងចាំបាច់ត្រូវបង្កើនសកម្មភាពទ័ពព្រៃ ត្រូវបង្កើនចលនាសង្គ្រាមចិត្តសាស្ត្រ និង រៀបចំប្រមូលមហាជននៅក្នុងប្រទេស" ។ លោកតាគូសបញ្ជាក់ជំរាបលោករដ្ឋមន្ត្រីការបរទេសថៃថា មេដឹកនាំយោធាខាងចលនាតស៊ូមិនមែនកុម្មុយនីស្តបច្ចុប្បន្ន មិនអាចរៀបចំ និង បំពេញការងារទាំងនេះបានទេ ។ ចំពោះលោកតា សឺន សាន មានតែមនុស្សជំនិតរបស់គាត់ម្នាក់គត់គឺ លោក ថាច់ រ៉ែង ទើបអាចធ្វើកិច្ចការទាំងអស់ខាងលើបាន ។ ប្រឆាំងតបវិញ ក្រុមលោកឧត្តមសេនីយ សក់ ស៊ុតសាខន បានសំដែងគោលជំហរថា លោកតា សឺន សាន គ្មានគំនិតអ្វីក្រៅតែពីចង់ដកលោក សក់ ស៊ុតសាខន រួចដាក់លោក ថាច់ រ៉ែង មកជំនួសជាអគ្គបញ្ជាការក.ជ.ប.រ.ខ.តែប៉ុណ្ណោះទេ ដែលនឹងនាំឲ្យមានការបែកបាក់សាមគ្គីភាពក្នុងជួរយុទ្ធជន ។ ក្រុមលោក សក់ ស៊ុតសាខន បានឃោសនាទៀតថា លោកតា សឺន សាន គិតតែផលប្រយោជន៍ផ្ទាល់ខ្លួនគឺ លើកតម្កើងតែមនុស្សណា ដែលមានភក្តីភាពចំពោះតួបុគ្គល ឬ កូនចៅក្រុមគ្រួសារ ឬ

បក្សពួករបស់លោកតា ។ នៅសម័យនោះ រូបខ្ញុំក៏ត្រូវទទួលការចោទប្រកាន់ថាជាមនុស្ស ឬ ជាដៃជើងរបស់លោកតាម្នាក់ដែរ ។

ពួកតាៗនៅប៉ារីស គាំទ្រលោក សក់ ស៊ុតសាខន

ដោយសារមានការឃោសនាយ៉ាងទូលំទូលាយ ក្រុមលោក សក់ ស៊ុតសាខន ហាក់ដូចជាទាក់ទាញទឹកចិត្ត និង ទទួលបានការគាំទ្រពីក្រុមអ្នកនយោបាយខ្មែរចាស់ៗ ដែលជាសមាជិកនៃក្រុមប្រឹក្សាព្រឹទ្ធាចារ្យរបស់រ.ជ.រ.ប.ខ. ។ ក្រុមប្រឹក្សានោះ មានអតីតនាយករដ្ឋមន្ត្រី ៣ រូបគឺ លោកតា ស៊ឹម វ៉ា លោកតា ឈាន វ៉ែម និង លោកតា ហ៊ុយ គន្ធុល ក្រៅពីនោះ សុទ្ធតែជាអតីតរដ្ឋមន្ត្រីគឺ លោកតា ចាយ ធុល លោកតា ជុន អ៊ុក លោកតា លឹម គ្រី និង លោកតា នង គិមនី ។ ព្រឹទ្ធាចារ្យទាំងអស់នោះ ធ្លាប់កាន់តំណែងនាយករដ្ឋមន្ត្រី និង រដ្ឋមន្ត្រី ក្នុងសម័យមុនឆ្នាំ ១៩៧០ គឺ ចាប់ពីទសវត្សរ៍ឆ្នាំ ១៩៤០ ១៩៥០ ១៩៦០ មកម្ល៉ះ ។

នៅថ្ងៃទី ១៩ មិថុនា ១៩៨៥ ក្រុមប្រឹក្សាព្រឹទ្ធាចារ្យ បានរួមប្រជុំនៅទីក្រុងប៉ារីស ។ អតីតនាយករដ្ឋមន្ត្រី ២ រូបគឺ លោកតា ឈាន វ៉ែម និង លោកតា ហ៊ុយ គន្ធុល បានចូលរួមប្រជុំ ឯអតីតនាយករដ្ឋមន្ត្រីទី ៣ លោកតា ស៊ឹម វ៉ា មិនបានចូលរួមទេ ដោយជាប់ព្យាបាលរោគនៅមន្ទីពេទ្យ តែបានសម្តែងការគាំទ្រចំពោះអង្គប្រជុំ ។ ក្រុមព្រឹទ្ធាចារ្យទាំងនោះ បានចោទប្រកាន់ថា លោកប្រធានធ្វើកិច្ចការអ្វីៗ "តែតាមបញ្ជារបស់ក្រុមគ្រួសារ ឬ មនុស្សជំនិតរបស់លោកស្ទើរតែទាំងស្រុង"។ "ក្រុមគ្រួសារលោកតា មានអំណាចបញ្ជា រហូតដល់ទៅជ្រៀតជ្រែកក្នុងការសម្រេចចិត្ត និង ការរៀបចំនៃរ.ជ.រ.ប.ខ.ផង" ។ ក្រុមលោកតាព្រឹទ្ធាចារ្យចោទថា"អ្វីៗដែល

គេធ្វើទៅនោះ ច្រើនតែសម្រាប់ប្រយោជន៍ផ្ទាល់ខ្លួនរបស់មនុស្សស្មោះត្រង់ចំពោះលោកប្រធាន ជាជាងសម្រាប់សេចក្តីត្រូវការនៃរ.ជ.រ.ប.ខ"[177]។

ក្រុមប្រឹក្សាព្រឹទ្ធាចារ្យបានសម្រេចដកការគាំទ្រពីលោកតាប្រធាន សឺន សាន ជារៀងរហូតដរាបណាមិនមានការផ្លាស់ប្តូររបៀបរបបការងាររបស់គាត់ ដែលក្រុមប្រឹក្សាយល់ថាជាការងារនៅជុំវិញតែតួបុគ្គល បក្សពួក ឬ ក្រុមគ្រួសារ ។ អ្នកចូលរួមប្រជុំទាំងអស់ សុទ្ធតែបានចុះហត្ថលេខាលើសេចក្តីប្រកាសព័ត៌មានលើកលែងតែលោកអតីតរដ្ឋមន្ត្រី នង គិមនី ចេញ ដែលមានឈ្មោះចូលរួមប្រជុំតែអវត្តមាននៅពេលចុះហត្ថលេខា ។ មនុស្សជំនិតរបស់លោកតា សឺន សាន យល់ឃើញថាអ្នកនាំពាក្យដ៏សំខាន់ ដែលជម្រុញឲ្យលោកព្រឹទ្ធាចារ្យទាំងនោះសម្រេចដកការគាំទ្រពីលោកតា សឺន សាន គ្មាននរណាក្រៅពីអគ្គលេខាធិការ នាង ជិនហន នោះទេ បន្ថែមលើសកម្មភាពប្រឆាំងយ៉ាងចេញមុខពីសំណាក់ក្រុមលោក ជៀន ដែល ហ៊ីង គន្ធុន និង ហ្គាហ្វា ។ លោកតាប្រធានបានព្យាយាមទាញយកការគាំទ្រពីក្រុមព្រឹទ្ធាចារ្យមកវិញ ។

នៅថ្ងៃទី ៦ កញ្ញា ១៩៨៥ លោកតាប្រធាន បានអញ្ជើញអស់លោកសមាជិកក្រុមព្រឹទ្ធាចារ្យ មកប្រជុំនៅគេហដ្ឋាននាទីក្រុងប៉ារីសរបស់លោកតា ។ លោកតា ហ៊ុយ គន្ធុល លោកតា លឹម គ្រី និង លោកតា ស៊ឹម វ៉ា មិនបានមកចូលប្រជុំទេ ។ ក្រោយពីពិភាក្សាគ្នាអស់រយៈពេលបីម៉ោងមក អង្គប្រជុំបានព្រមព្រៀងគ្នាថាលោកបណ្ឌិត ឆាយ ហាន់ចេង កូនប្រសារលោកតា សឺន សាន ត្រូវឈប់លូកដៃចូលក្នុងកិច្ចការរ.ជ.រ.ប.ខ.តទៅទៀត[178] ។ ម្យ៉ាងទៀត លោកតា សឺន សាន ត្រូវតែចាត់តាំងអ្នកដឹកនាំវ័យក្មេងម្នាក់អាយុតិចជាង ៥០ ឆ្នាំ ជាអ្នកត្រៀមដឹកនាំរ.ជ.រ.ប.

[177] ចាយ ធុល, ឈាន រ័ម, ហ៊ុយ គន្ធុល, លឹម គ្រី, នង គឹមនី, ជុន អ៊ុក, ស៊ឹម វ៉ា, ឯកសារគ្មានចំណងជើង, ប៉ារីស, ១៩ មិថុនា ១៩៨៥ ។

[178] Pong Kim Koan, Procès-Verbal de la Réunion de Travail, Paris, le 6 Septembre 1985.

ខ.ជាបណ្តើរៗតទៅ ។ លោកតា សឺន សាន ក៏យល់ព្រមតាម ។ បន្ទាប់ពីជួបប្រជុំគ្នានេះ លោកតា សឺន សាន យល់ថាសភាពគានតឹងក្នុងទំនាក់ទំនងជាមួយក្រុមព្រឹទ្ធាចារ្យ បានធូរស្រាល និង មានប្រក្រតីភាពឡើងវិញ ។ តាមពិតទៅ សមាជិកព្រឹទ្ធាចារ្យទាំងអស់នោះសុទ្ធតែជាមិត្ត ឬ ជាសហការីរបស់លោកតា សឺន សាន ជាយូរមកហើយ ។

ស្ងាត់ៗលោក ថាច់ រ៉ែង ត្រឡប់មកបាងកកវិញ

ដោយសារការទទូចសុំដដែលៗពីលោកតា សឺន សាន នៅទីបំផុត លោក ឧត្តមសេនីយ ឆាវលិត ក៏អនុញ្ញាតឲ្យលោក ថាច់ រ៉ែង វិលត្រឡប់មកទីក្រុងបាងកកវិញនៅខែ តុលា ១៩៨៥ ។ ក៏ប៉ុន្តែ ការវិលត្រឡប់នេះ ត្រូវចាត់ទុកជាការសម្ងាត់មិនបើកចំហរគឺ គ្មានការដឹងឮពីក្រសួងការបរទេស ឬ គ្មានទិដ្ឋាការចេញចូលដូចធម្មតាឡើយ ។ នៅពេលគាត់មកដល់ ទាហានថៃពីរនាក់ នៅចាំទទួលនាំចេញពីយន្តហោះ តម្រង់ទៅសណ្ឋាគារតែម្តង ។ ការស្នាក់នៅរបស់លោក ថាច់ រ៉ែង នៅលើទឹកដីថៃលើកនេះ មានលក្ខណៈពិសេស និង រៀបចំឡើងដោយយោធាថៃដាច់ដោយឡែក ។ ខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង នៅពេលរសៀលមួយនោះ ខ្ញុំបានទទួលទូរស័ព្ទពីគាត់ ដែលហៅចេញពីសណ្ឋាគារមួយនៅទីក្រុងបាងកក ។ ដោយសារនោះជាការសម្ងាត់ ខ្ញុំមិនប្រាប់នរណាម្នាក់ទេ ។ ខ្ញុំលបចេញទៅក្រៅ ទៅរកជួបលោក ថាច់ រ៉ែង ភ្លាមៗមួយរំពេច ពេលចប់កិច្ចសន្ទនាដ៏ខ្លីតាមទូរស័ព្ទនោះ ។ លោក ថាច់ រ៉ែង មានទឹកមុខញញឹមពព្រាយ សប្បាយរីករាយខ្លាំងណាស់ ដោយបានវិលមកទីក្រុងបាងកកវិញ ។ គាត់បាននិយាយប្រាប់ខ្ញុំអំពីបេសកកម្មពិសេស និង ជំនួបរបស់គាត់ជាមួយលោកឧត្តមសេនីយ ឆាវលិត ។ នៅរសៀលនោះ

ខ្ញុំមិនត្រឡប់ទៅផ្ទះវិញទេ ព្រោះយើងនាំគ្នានិយាយផ្លាស់ប្តូរយោបល់ពីលទ្ធភាពនៃការងារដែលត្រូវធ្វើនៅចំពោះមុខ រួចយើងនាំគ្នាទៅទទួលទានអាហារល្ងាចនៅភោជនីយដ្ឋានមួយ ដែលនៅមិនឆ្ងាយពីម៉ាយ៉ាឡាប់ ។

នៅទីស្នាក់ការរបស់ពួកយើង គ្មាននរណាម្នាក់ដឹងពីវត្តមានរបស់លោក ថាច់ រ៉ង នៅបាងកកទេ ។ ជារៀងរាល់ថ្ងៃ ខ្ញុំតែងតែមកលបជួបលោក ថាច់ រ៉ង ជាសម្ងាត់មិនដែលដាច់ ។ ក៏ប៉ុន្តែមួយអាទិត្យក្រោយមកលោក ថាច់ រ៉ង ប្រាប់ខ្ញុំឲ្យរកផ្ទះសំណាក់ឲ្យគាត់ ព្រោះគាត់មិនចង់នៅក្នុងសណ្ឋាគារតទៅទៀតទេ ។ លោក ថាច់ រ៉ង មិនបានប្រាប់ខ្ញុំពីមូលហេតុជាក់លាក់ទេ តែខ្ញុំអាចយល់បានថាក្រុមយោធាថៃ លែងទទួលបន្ទុកចេញថ្លៃស្នាក់នៅរបស់គាត់ នៅក្នុងសណ្ឋាគារតទៅទៀតហើយ ។ នៅទីបំផុត ខ្ញុំក៏ទៅជួលបន្ទប់ស្ទូឌីយោ (Studio) នៅក្នុងកុងដូមុយនីញ៉ូមនៅផ្លូវតេជោ ក្បែរមជ្ឈមណ្ឌលពាណិជ្ជកម្មនៅទីក្រុងបាងកក ដោយប្រើឈ្មោះខ្ញុំ និង ប្រើប័ណ្ណឥណទាន (Credit Card) ផ្ទាល់ខ្លួនរបស់ខ្ញុំ ។ អស់រយៈពេលជាច្រើនខែក្រោយមក ក្រុមយោធាថៃក៏យល់ព្រមឲ្យលោក ថាច់ រ៉ង ចេញមុខមកស្នាក់នៅជាមួយពួកយើង នៅម៉ាយ៉ាឡាប់ឯទីស្នាក់ការរបស់យើងឡើងវិញ ។

តាមពិតលោកតា សឺន សាន ប្រឹងប្រែងណាស់ ដើម្បីទាញយកអំណាចគ្រប់គ្រងរ.ជ.រ.ប.ខ.ឡើងវិញ ។ លោកតាព្យាយាមជានិច្ច ដើម្បីធ្វើការរៀបចំការដឹកនាំរ.ជ.រ.ប.ខ. ឲ្យស្ថិតនៅក្រោមការទទួលខុសត្រូវរបស់លោកតាផ្ទាល់ ទាំងផ្នែកនយោបាយ ទាំងផ្នែកយោធា ។ ជាពិសេស លោកតាប្រធានចង់បានមនុស្សជំនិតដូចជាលោក ថាច់ រ៉ង ជាដើម មានមុខនាទីទទួលខុសត្រូវនៅក្នុងជួរកងទ័ពរ.ជ.រ.ប.ខ. ។ ក៏ប៉ុន្តែពាល់ការខឹតខំរបស់លោកតា មិនបានទទួលជោគជ័យទេ

ប្រសិនបើគ្មានការគាំទ្រពីអាជ្ញាធរថៃ ។ នៅពេលលោកតា ជួបពិភាក្សាការងារជាមួយលោករដ្ឋមន្ត្រីការបរទេស សិទ្ធី សាវ៉ែតសិលា[179] (Siddhi Savetsila) នៅពាក់កណ្តាលខែ សីហា ១៩៨៥ លោកតាប្រធានបានលើកយកតួអង្គបុគ្គលសឺន សាន ទៅដាក់ផុកវាយផ្តាច់យកឈ្នះចាញ់តែម្តង ដូចដែលលោកតាធ្លាប់ដាក់លក្ខខណ្ឌនៅឆ្នាំ ១៩៨២ នាពេលចរចាបង្កើតរដ្ឋាភិបាលចម្រុះត្រីភាគីយ៉ាងដូច្នោះដែរ ។ ថ្លែងទៅកាន់លោករដ្ឋមន្ត្រីថៃ លោកតាមានប្រសាសន៍ថា៖ "ខ្ញុំសូមឲ្យប្រទេសជាមិត្តទាំងអស់ ជាពិសេសអាស៊ានជួយខ្ញុំឲ្យអាចរៀបចំរ.ជ.រ.ប.ខ.ឲ្យមានវិន័យរបៀបរៀបរយឡើងវិញ ។ ប្រសិនបើសំណើខ្ញុំទាំងប៉ុន្មាន មិនបានទទួលចម្លើយដូចបំណងទេនោះ ខ្ញុំគ្មានសង្ឃឹមអ្វីក្រៅពីសុំសំដែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅ ចំពោះប្រទេសជាមិត្ត ដែលបានផ្តល់ជំនួយគ្រប់ផ្នែកដល់ចលនាតស៊ូមិនមែនកុម្មុយនីស្ត និង ខ្ញុំស្នើសុំជាចុងក្រោយឲ្យប្រទេសជាមិត្តទាំងនោះមេត្តាកុំទម្លាក់ការទទួលខុសត្រូវមកលើរូបខ្ញុំឲ្យសោះ ក្នុងករណីយដែលប្រទេសកម្ពុជាធ្លាក់ទៅក្នុងដៃកុម្មុយនីស្ត" ។ លោកតាចង់និយាយថាបើប្រទេសអាស៊ានមិនជួយឲ្យលោកតាមានអំណាចគ្រប់គ្រាន់ ដើម្បីរៀបចំរ.ជ.រ.ប.ខ.គឺ ដោះដូរមន្ត្រីសំខាន់ៗតាមគំនិតរបស់លោកតាទេនោះ លោកតាសុំមិនទទួលខុសត្រូវទេ ប្រសិនបើក្រុមមិនមែនកុម្មុយនីស្ត (NCR) ត្រូវទទួលបរាជ័យ ហើយប្រទេសកម្ពុជាត្រូវធ្លាក់ទៅក្នុងរបបកុម្មុយនីស្ត ។

ការបែកបាក់លើកទី២ ក្នុងជួរ រ.ជ.រ.ប.ខ.

ទំនងជាលោកតាយល់ថា បានទទួលសញ្ញាភ្លើងខៀវពីរដ្ឋាភិបាលថៃមួយ

[179] Coalition Government of Democratic Kampuchea, Memorandum, Meeting of H.E. Son Sann with H.E. ACM Siddhi Savetsila, Minister for Foreign Affairs of the Thai Royal Government, August 15, 1985.

អាទិត្យបន្ទាប់ពីបានជួបលោករដ្ឋមន្ត្រីការបរទេសនេះមក លោកតាប្រធានក៏កោះប្រជុំគណៈកម្មាធិការប្រតិបត្តិ (កូមុិច) នៅថ្ងៃទី ២២ សីហា ១៩៨៥ ។ នៅក្នុងពេលប្រជុំកូមុិចលើកនេះ ក្រៅពីសមាជិកពេញសិទ្ធិ ក៏មានការចូលរួមពីគ្រប់មេបញ្ជាការ ក.ជ.រ.ប.ខ. និង ប្រធានជំរុំផងដែរ ។ ក៏ប៉ុន្តែ មនុស្សសំខាន់ពីរនាក់គឺ លោក ហ៊ីង គន្ធុន និង លោក ហ្គាហ្វា អវត្តមាន ។ នៅពេលនោះ ខ្ញុំពុំមានសិទ្ធិចូលរួមប្រជុំទេ ។ របៀបវារៈសំខាន់នៃអង្គប្រជុំ មានចំណុចស្តីពីការរៀបចំសណ្តាប់ធ្នាប់ និង វិន័យឡើងវិញក្នុងជួរ រ.ជ.រ.ប.ខ. ។ សេចក្តីសម្រេចដ៏សំខាន់មួយក្នុងអង្គប្រជុំនោះគឺ ការដកលោក ហ៊ីង គន្ធុន និង លោក ហ្គាហ្វា ពងម៉ែត ពីមុខតំណែងទាំងអស់ក្នុងជួរ រ.ជ.រ.ប.ខ. ។ ក៏ប៉ុន្តែ លោកឧត្តមសេនីយ សក់ ស៊ុតសាខន បានធ្វើអន្តរាគមន៍ថា សុំកុំអាលផ្សព្វផ្សាយសេចក្តីសម្រេចនេះជាសាធារណៈ ដើម្បីទុកពេលមួយរយៈឲ្យសាមីខ្លួនទាំងពីរនាក់កែខ្លួនសិន ។

នៅថ្ងៃជាមួយគ្នានោះដែរ គណៈកម្មាធិការចំពោះកិច្ច (Ad-hoc Commit tee) របស់ ក.ជ.រ.ប.ខ. (KPNLAF) និង កងទ័ពជាតិសីហនុនិយម (ANS : Armée Nationale Sihanoukiste) ឬ កងទ័ពរបស់ ហ៊ុន ស៊ុន ប៊ុច (FUNCINPEC) បានចេញសេចក្តីប្រកាសព័ត៌មានមួយស្តីពីការបង្កើតបញ្ជាការយោធារួម (Joint Military Command) មួយ ដែលមានលោកឧត្តមសេនីយ សក់ ស៊ុតសាខន (KPNLF) ជាអគ្គមេបញ្ជាការ លោកឧត្តមសេនីយ ទៀប បែន (ANS) ជាអគ្គមេបញ្ជាការរង លោកឧត្តមសេនីយ ទួន ចាយ (ANS) ជានាយអគ្គសេនាធិការ និង លោក ហ្គាហ្វា ពងម៉ែត (KPNLF) ជានាយអគ្គសេនាធិការរង[180] ។

[180] Teap Ben (Lt.Gen), Dien Del (Gen), Permanent Military Committee for Coordination, Press Release, Free Cambodia, 22 August, 1985.

ដោយសារវត្តមានរបស់លោក ថាច់ រ៉ែង នៅបាងកក និង ដោយសារកូម៉ិច បានធ្វើការសម្រេចដកតំណែងមនុស្សសំខាន់ទាំងពីរគឺ លោក ហ៊ឹង គន្នុន និង លោក ហ្គាហ្សា ការបែកបាក់ផ្ទៃក្នុងរបស់ រ.ជ.រ.ប.ខ. ក៏កាន់តែរីកធំឡើង ។ ហ្គាហ្សា បានបះបោរតបវិញដោយចំហរ ។ ហ្គាហ្សា ធ្វើសេចក្តីថ្លែងការណ៍ ទាំងតាមទំព័រ កាសែត ទាំងតាមកិច្ចសន្ទនាឯកជន ជាពិសេស តាមទំព័រទស្សនាវដ្តី ហ្វាអ៊ែស្ទេន អ៊ីកូណូមិក (FAR EARTERN ECONOMIC REVIEW) ចុះផ្សាយនៅថ្ងៃទី ២៥ តុលា ១៩៨៥ អំពាវនាវឲ្យអាស៊ានដកការគាំទ្រពីលោកតា សឺន សាន ហើយធ្វើ ការគាបសង្កត់ឲ្យលោកតាលាចេញពីតំណែងប្រធានរ.ជ.រ.ប.ខ. ។ សកម្មភាព ប្រឆាំងរបស់ ហ្គាហ្សា នេះ បានឡើងដល់កំរិតមួយ ដែលមិនអាចផ្សះផ្សាគ្នាបាន ឡើយ ។

បង ប៉ែន ថាល់ ទទួលមរណភាពនៅប៉េកាំង

នៅថ្ងៃទី ៤ ធ្នូ ១៩៨៥ លោកតា សឺន សាន បានកោះប្រជុំគណៈកម្មាធិការប្រតិបត្តិម្តងទៀត ។ លើកនេះ អង្គប្រជុំសម្រេចបណ្តេញលោក ហ៊ឹង គន្នុន និង ហ្គាហ្សា ចេញពីរ.ជ.រ.ប.ខ. តែម្តង ។ សេចក្តីសម្រេចបណ្តេញលើកនេះបានធ្វើ ឲ្យលោកឧត្តមសេនីយ សក់ ស៊ុតសាខន មិនសប្បាយចិត្ត ។ មួយថ្ងៃបន្ទាប់មក ទំនងជាដើម្បីបង្ហាញនូវសាមគ្គីភាពជាមួយសហការី ដែលត្រូវបណ្តេញចេញទាំង ពីរនាក់នោះ លោកឧត្តមសេនីយ ក៏ផ្ញើលិខិតសរសេរផ្ទាល់ដៃជូនលោកតាប្រធាន សុំលាឈប់ពីគ្រប់តំណែងទាំងអស់ក្នុងជួររ.ជ.រ.ប.ខ.គឺ៖[181] ទីប្រឹក្សាយោធារបស់ ប្រធានរ.ជ.រ.ប.ខ. អនុប្រធានរ.ជ.រ.ប.ខ. និង អគ្គមេបញ្ជាការក.ជ.រ.ប.ខ ។

[181] សក់ ស៊ុតសាខន, (លិខិតសម្ងាត់ និង ផ្ទាល់ខ្លួន) ជូន ឯកឧត្តម សឺន សាន, ប្រធានរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ, ថ្ងៃទី ៥ ខែ ធ្នូ ១៩៨៥ ។

នៅ ថ្ងៃទី ៧ ធ្នូ ១៩៨៥ លោកតា សឺន សាន ចេញដំណើរទៅធ្វើទស្សនកិច្ចនៅប្រទេសចិនប្រជាមានិត ។ ក្នុងចំណោមអ្នកអមដំណើរលោកតាប្រធានចំនួន ៥ នាក់ ក៏មានបង ប៉ែន ថាល់ ទៅជាមួយដែរ ។ បង ប៉ែន ថាល់ មានការបារម្ភខ្លាំងណាស់ ចំពោះការបាក់បែកផ្ទៃក្នុងរបស់ក្រុមយើង ។ គាត់និយាយមិនឈប់ជាមួយខ្ញុំថា "យើងត្រូវធ្វើអ្វីមួយ ដែលយើងអាចធ្វើបាន ដើម្បីការពារឯកភាពនៃចលនាតស៊ូរបស់យើង" ។ នៅថ្ងៃគណៈប្រតិភូចេញដំណើរ ខ្ញុំក៏ទៅជូនដំណើរឯអាកាសយានដ្ឋាន ។ នៅថ្ងៃនោះ ក៏ជាថ្ងៃចុងក្រោយដែលខ្ញុំបានឃើញបង ប៉ែន ថាល់ ដែរគឺជាថ្ងៃលាគ្នាចុងក្រោយបំផុត ។ តាមពិតទៅបង ប៉ែន ថាល់ លែងត្រឡប់មកវិញហើយៗហេតុការណ៍មួយដ៏ក្រៀមក្រំបានកើតឡើង ។ នៅពេលទៅដល់អាកាសយានដ្ឋានប៉េកាំង គណៈប្រតិភូក៏នាំគ្នាចេញពីយន្តហោះហើយ នៅពេលឥស្សរជនសំខាន់ៗកំពុងទទួលបដិសណ្ឋារកិច្ចនៅជួរខាងមុខ នៅឯក្រោយឯនេះ បង ប៉ែន ថាល់ ក៏ដួលសន្លប់បាត់ស្មារតីម្តងទៀតដូចកាលនៅអាហ្វ្រិកដែរ ។ តែម្តងនេះ គាត់ដួលក្បាលបោកផ្ទប់ទៅនឹងថ្មក្រាលនៃវាលយន្តហោះបណ្តាលឲ្យបែកក្បាល ។ វេជ្ជបណ្ឌិតចិនខំព្យាយាមរកវិធីឃាត់ឈាមយ៉ាងណា ឈាមនោះក៏មិនឈប់ហូរ ដូច្នេះបង ប៉ែន ថាល់ ក៏ទទួលមរណភាពនៅមន្ទីរពេទ្យក្រុងប៉េកាំងប៉ុន្មានថ្ងៃក្រោយមក ។ ការបាត់បង់បង ប៉ែន ថាល់ បានធ្វើឲ្យខ្ញុំបាត់បង់នូវកល្យាណមិត្តមួយដ៏ថ្លៃថ្លា ។ គាត់មិនមែនគ្រាន់តែជាបង ដែលខ្ញុំចាត់ទុកដូចបងបង្កើតរបស់ខ្ញុំប៉ុណ្ណោះទេ តែគាត់ក៏ជាទីប្រឹក្សារកបានដោយកម្រ ។ រ.ជ.រ.ប.ខ. ក៏បាត់បង់សមាជិកម្នាក់ដ៏មានតម្លៃផងដែរ ។

បក្សប្រហារ ដែលយើងនឹកមិនដល់

ដូចពេលមុនៗដែរ ខ្ញុំតែងចំណាយពេលរវាងទីក្រុងបាងកក និង តំបន់ទល់ដែនខ្មែរ-ថៃគឺ ចេញចូលជាញឹកញាប់ ។ ខ្ញុំតែងទៅជំរុំសាយធូ ពេលណាខ្ញុំអាចទៅបាន ។ ពេលទៅដល់ទីប្រជុំជនអារញ្ញប្រថេតមុននឹងចូលទៅជំរុំ ខ្ញុំតែងទៅឈប់នៅផ្ទះសុវត្ថិភាព (Safe house) ព្រោះនៅទីនោះ ពួកយើងមានបុគ្គលិកខ្មែរជួយធ្វើទំនាក់ទំនងជាមួយអាជ្ញាធរថៃ ដើម្បីសុំលិខិតចេញចូលជំរុំ ឬ ដើម្បីសុំច្បាប់ត្រឡប់ទៅបាងកកវិញ ពេលយើងចេញពីជំរុំ ។ ក្នុងឋានៈជាសមាជិកខុទ្ទកាល័យប្រធាន រ.ជ.រ.ប.ខ.មួយរូប និង ក្នុងឋានៈជាអតីតលេខាធិការរបស់គណៈកម្មាធិការអគ្គសេនាធិការកងទ័ព ខ្ញុំនៅមានអ្នកគោរពរាប់អានច្រើននៅអារញ្ញប្រថេតនោះ ។ ម្យ៉ាងទៀត មន្ត្រីខ្មែរដែលមានការកិច្ចទាក់ទងជាមួយអាជ្ញាធរយោធាថៃ ក៏ធ្លាប់ជាអ្នកធ្វើការក្រោមបង្គាប់ខ្ញុំផង កាលខ្ញុំនៅឯមូលដ្ឋានយោធាអំពិល ។ ដូច្នេះ ពេលមានវត្តមានរបស់ខ្ញុំម្តងៗនៅផ្ទះសុវត្ថិភាពនេះ គេទាំងអស់គ្នាយកចិត្តទុកដាក់ណាស់ ។ មន្ត្រីខ្មែររបស់យើងនោះ រត់ការលឿនទាន់ចិត្ត ក្នុងការទៅសុំលិខិតអនុញ្ញាតផ្សេងៗ ។ ក៏ប៉ុន្តែលើកនេះ ខ្ញុំឆ្ងល់យ៉ាងខ្លាំង ព្រោះទង្វើរបស់មន្ត្រីខ្មែរនោះហាក់ដូចជាខុសប្លែកពីធម្មតា ។ ខ្ញុំឆ្ងល់យ៉ាងខ្លាំង ព្រោះថាខ្ញុំរង់ចាំអស់ជិតមួយថ្ងៃទៅហើយ នៅតែមិនទាន់បានលិខិតអនុញ្ញាតឲ្យត្រឡប់ទៅបាងកកវិញ ។

ថ្ងៃនោះ គឺថ្ងៃទី ១៩ ធ្នូ ១៩៨៥ បន្ទាប់ពីបានទៅជំរុំអស់ពីរយប់ ខ្ញុំត្រូវត្រឡប់ទៅបាងកកវិញ ដូច្នេះត្រូវចូលមកសុំលិខិតអនុញ្ញាតពីអារញ្ញ ទើបអាចធ្វើដំណើរបាន ដៀសវាងការឆែកឆេរពីក្រុមយោធាថៃតាមផ្លូវ ។ ម្តងនេះមន្ត្រីខ្មែរគ្រាន់តែមកប្រាប់ខ្ញុំឲ្យនៅរង់ចាំ រួចក៏បាត់ខ្លួនរហូត ។ ទាល់តែដល់ល្ងាច ទើបមកជួបខ្ញុំម្តងទៀត ដោយយកលិខិតអនុញ្ញាតឲ្យធ្វើដំណើរមកជាមួយ ។ ភ្លាមៗនោះ

ខ្ញុំពុំបានដឹងថាមន្ត្រីខ្មែរនោះបានទទួលបញ្ជាពីការិយាល័យលោក សក់ ស៊ុតសាខន ឲ្យឈប់សហការ ឬ ធ្វើការជាមួយពួកយើងតទៅទៀត ។ នៅវេលាប្រហែលម៉ោង ១០ យប់ ទើបខ្ញុំទៅដល់បាងកក ។ នៅពេលទៅដល់ម៉ាយ៉ាឡាប់ ខ្ញុំឃើញភាពចម្លែកមួយទៀត ព្រោះទ្វារភូមិគ្រឹះត្រូវចាក់សោរ និង មានមនុស្សយាមផង ។ អ្នកយាមនោះគឺ អ្នកបំរើក្មេងៗក្នុងផ្ទះ ដែលពីមុនមកមិនដែលធ្វើការយាមកាមអ្វីទេ ។ ពេលខ្ញុំចូលផុតពីទ្វាររបង លោកឧត្តមសេនីយ ថាច់ រ៉េង ក៏ស្ទុះមកទទួលខ្ញុំ ហើយស្រែកសួរថា៖ "មូលីឯងមិនដឹងថាមានរដ្ឋប្រហារអ្វីទេឬ"? ខ្ញុំសួរថា "រដ្ឋប្រហារអ្វី?" គាត់សួរមកវិញថា "អត់បានមើលកាសែតទេឬ?" ខ្ញុំឆ្លើយថា "ទេ" ។ ទើបលោក ថាច់ រ៉េង រៀបរាប់ថាព្រឹកមិញថ្ងៃទី ១៩ ធ្នូនេះ នៅទីក្រុងបាងកកសារព័ត៌មានបានចេញផ្សាយថា ក្រុមបំបែកខ្លួនក្នុងជួរ.ជ.រ.ប.ខ.ដឹកនាំដោយឧត្តមសេនីយ សក់ ស៊ុតសាខន បានប្រកាសបង្កើតគណៈកម្មាធិការកណ្តាលបណ្តោះអាសន្នដើម្បីសង្គ្រោះ.រ.ជ.រ.ប.ខ (Provisional Central Committee for the Salvation of the KPNLF) ។ នេះជាការបះបោររបស់ក្រុមឧត្តមសេនីយប្រឆាំងលោកប្រធាន សឺន សាន យ៉ាងចេញមុខ ។

មែនទែន នៅថ្ងៃ ១៧ ធ្នូ ១៩៨៥[182] ក្រុមរបស់ឧត្តមសេនីយ សក់ ស៊ុតសាខន បានផ្សព្វផ្សាយដល់អង្គការសារព័ត៌មាន និង បេសកកម្មទូតនានាប្រចាំទីក្រុងបាងកកនូវអនុស្សារណៈមួយស្តីពីប្រកាសរបស់ក្រុមលោកឧត្តមសេនីយថា បានកាន់កាប់ដឹកនាំ.រ.ជ.រ.ប.ខ.ទាំងមូល និង លែងស្ថិតនៅក្រោមអំណាចរបស់លោក តា សឺន សាន តទៅទៀតហើយ ។ ក៏ប៉ុន្តែសារព័ត៌មានទើបតែចេញផ្សាយនៅថ្ងៃទី ១៩ ធ្នូ តែប៉ុណ្ណោះ[183]។ នៅក្នុងវារៈបញ្ជាពិសេសរបស់គាត់ លោកឧត្តមសេនីយ

[182] Huy Kanthoul (H.E.), Khmer People's National Liberation Front, Provisional Central Committee of Salvation, A Verbal Note, December 17, 1985.
[183] Jacques Bekaert, KPNLF split by rebel faction, Bangkok Post, December 19, 1985.

សក់ ស៊ុតសាខន បានបន្ទោសលោកតា សឺន សាន និង គណៈកម្មាធិការប្រតិបត្តិ ឬ កូមុិចថា ប្រើអំណាចផ្តាច់ការ និង គិតតែបង្កជម្លោះផ្ទៃក្នុង និង គិតគូរតែកិច្ចការផ្ទាល់ខ្លួន ។ វារៈបញ្ជានោះមានន័យជាអាទិថាៈ[184] "ចាប់តាំងពីបង្កើតឡើងនៅថ្ងៃទី ៩ តុលា ១៩៧៩ មក រ.ជ.រ.ប.ខ.បានបង្កើតឡើងនូវគណៈកម្មាធិការប្រតិបត្តិមួយ ដែលជាអង្គការកំពូល ដើម្បីដឹកនាំរ.ជ.រ.ប.ខ. ទាំងផ្នែកស៊ីវិល នយោបាយ និង យោធា ក្រោមការដឹកនាំរបស់ឯកឧត្តម សឺន សាន ។ ដូចបងប្អូនជនរួមជាតិបានដឹងរួចហើយថា គណៈកម្មាធិការប្រតិបត្តិបានផ្លាស់ប្តូរបន្តិចម្តងៗ ដោយសារតែទំនាស់ផ្ទាល់ខ្លួន ។ ក្នុងការសង្កេតរបស់ខ្ញុំ (សក់ ស៊ុតសាខន) គណៈកម្មាធិការប្រតិបត្តិដែលភាគច្រើន គ្មានដោះស្រាយបញ្ហាអ្វីក្រៅពីគិតតែដោះស្រាយបញ្ហាតួបុគ្គល ឬ បញ្ហាផ្ទាល់ខ្លួន បានជាប់ដៃក្នុងជម្លោះផ្ទៃក្នុងទាស់ទែងប្រមាថមាក់ងាយគ្នា ដោយឥតប្រយោជន៍ និង មិនបានអនុវត្តបទបញ្ជាវិន័យ ឬ មិនបានចំណាយពេល ដើម្បីរកដំណោះស្រាយចំពោះបញ្ហាធំៗក្នុងការតស៊ូរំដោះជាតិឡើយ ។ ដោយសារតែប្រធានប្រើអំណាចផ្តាច់ការ និង ធ្វើសេចក្តីសម្រេចលើអ្វីៗទាំងអស់តែម្នាក់ឯង.. ... ដោយសារមានញត្តិមួយចំនួនធំ និង ក្រោយពីបានពិភាក្សាផ្លាស់ប្តូរយោបល់គ្នា យ៉ាងល្អិតល្អន់ជាមួយអស់លោក ដែលជាឥស្សរជនខ្មែរអ្នកស្នេហាជាតិរួចមក ខ្ញុំបានសម្រេចបង្កើតគណៈកម្មាធិការកណ្តាលបណ្តោះអាសន្នសង្គ្រោះ រ.ជ.រ.ប.ខ. ដើម្បីជំនួសគណៈកម្មាធិការប្រតិបត្តិ រ.ជ.រ.ប.ខ. .....ដើម្បីបំបាត់ជម្លោះផ្ទៃក្នុង និង ដើម្បីកែឆ្នៃកិច្ចការរបស់រ.ជ.រ.ប.ខ.ឲ្យប្រសើរឡើងព្រមទាំងដើម្បីឲ្យសមស្របតាមទំនុកចិត្ត និង ជំនឿពីប្រទេសជាមិត្តដែលគាំទ្រយើងដែលគេបានដាក់សេចក្តីសង្ឃឹមលើរ.ជ.រ.ប.ខ.ក្នុងការតស៊ូរំដោះប្រទេសយើង" ។ នៅក្នុងសេចក្តីប្រកាសនោះ លោកឧត្តមសេនីយ សក់ ស៊ុតសាខន បានបញ្ជាក់ថារូបលោក

[184] Sak Sutsakhan (General), Khmer People's National Liberation Armed Forces, Provisional Central Committee of Salvation of KPNLF, Special order of the Day, 20 December 1985.

ត្រូវបានតែងតាំងជាប្រធានគណៈកម្មាធិការកណ្តាលបណ្តោះអាសន្ននេះ បានន័យថាជា "ប្រធានរ.ជ.រ.ប.ខ.ថ្មី" ។

ដូច្នេះ ពួកយើងបានដឹងពី "បក្សប្រហារ" នេះពីរថ្ងៃក្រោយដែលគេប្រកាសចេញមុខរួចទៅហើយ ។ ក្រុមមនុស្សជំនិតរបស់លោកតា សឺន សាន យល់ច្បាស់ថា ហ្គាហ្វា ប្រាកដជាអ្នកចេញមុខនាំឲ្យមាន"បក្សប្រហារ"នេះ ព្រោះថា ហ្គាហ្វា មានទំនាក់ទំនងល្អជាមួយក្រុមការងារ និង ជាមួយស្ថានទូតបរទេសមួយចំនួននៅទីក្រុងបាងកក ។ អ្នកឯទៀត គ្រាន់តែដើរតាមក្រោយតែប៉ុណ្ណោះ ។ ក្រុមមនុស្សជំនិតរបស់លោកតាប្រធានយល់ថា ហ្គាហ្វា បានយកលោកឧត្តមសេនីយ សក់ ស៊ុតសាខន ឲ្យលេងល្បែងឲ្យខ្លួន ។ ដើម្បីដោះស្រាយបញ្ហានេះ លោកតា សឺន សាន បានសុំជួបលោកឧត្តមសេនីយ ឆាវលិត នៅរសៀលថ្ងៃនោះ ។ លោកតាប្តេជ្ញាថានឹងបណ្តេញលោក ហ្គាហ្វា និង លោក ហ៊ីង គន្ធុន ចេញពីរ.ជ.រ.ប.ខ. តែនឹងខំព្យាយាមទាញលោកឧត្តមសេនីយ សក់ ស៊ុតសាខន ឲ្យមកចូលជួរខាងលោកតាវិញ ។ លោកតា គិតថានឹងរក្សាទុកតំណែងអគ្គមេបញ្ជាការ ក.ជ.រ.ប.ខ. ជូនលោកឧត្តមសេនីយ សក់ ស៊ុតសាខន ដោយគ្រាន់តែដាក់លក្ខខណ្ឌខ្លះ ។

ជាប្រតិកម្មភ្លាមចំពោះ "បក្សប្រហារ" នោះ លោកតាប្រធានបានចាត់ឲ្យលោក ប៊ុន សាយ អគ្គលេខាធិការរង បញ្ជូនសារអញ្ជើញលោកឧត្តមសេនីយ សក់ ស៊ុតសាខន និង លោក ជៀន ដែល មកជួបប្រជុំផ្ទាល់ជាមួយលោកតា នៅទីស្នាក់ការម៉ាយ៉ាឡាប់ នៅថ្ងៃទី ២០ ធ្នូ ១៩៨៥ ក្នុងឋានៈជាអគ្គមេបញ្ជាការ និង នាយអគ្គសេនាធិការក.ជ.រ.ប.ខ ។ ចំណែកឯពួកយើងម្នាក់ៗ រៀល់ញាប់ដៃក្នុងពេលដែលវិបត្តិនេះចេះតែមានការវិវត្តន៍ទៅ ។ ខ្ញុំត្រូវទទួលភារកិច្ចទាក់ទងជាមួយបណ្តាញសារព័ត៌មាន ដើម្បីចែកចាយឯកសារ ឬ សេចក្តីប្រកាសសារព័ត៌មាន ។ យុទ្ធសាស្ត្ររបស់ពួកយើងនៅពេលនោះគឺ ត្រូវខឹតខំបង្ហាញពិភពលោក ឲ្យដឹងថា

ទោះជាក្រុមបំបែកខ្លួន ធ្វើសកម្មភាពយ៉ាងណាក៏ដោយ លោកតា សឺន សាន នៅតែគ្រប់គ្រងសភាពការណ៍បានគ្រប់យ៉ាងនៅក្នុងជួរ រ.ជ.រ.ប.ខ, ។ នៅក្នុងសេចក្តីប្រកាសព័ត៌មានចុះថ្ងៃទី ២០ ធ្នូ ១៩៨៥ យើងបានប្រកាសថា "គណៈកម្មាធិការបណ្តោះអាសន្នរបស់លោក សក់ ស៊ុតសាខន ជាការចាត់តាំងខុសច្បាប់ និងបានអំពាវនាវដល់អ្នក ដែលជាប់ជំពាក់ទាំងអស់ឲ្យផ្តាច់ខ្លួនចេញពីមេក្លោងនៃ "បក្សប្រហារ"នេះ និង ឲ្យចូលមកក្នុងជួររ.ជ.រ.ប.ខ.វិញ" ។

នៅពេលដែលបានណាត់ជួបគ្នាមកដល់ ទាំងលោក សក់ ស៊ុតសាខន ទាំងលោក ជៀន ដែល មិនបានមកបង្ហាញខ្លួនឡើយ ។ ពួកយើងខកចិត្តខ្លាំងណាស់ដែលលោកឧត្តមសេនីយទាំងពីររូប មិនមកជួបលោកប្រធានរបស់យើង ។ ស្អែកឡើង យើងចេញសេចក្តីប្រកាសព័ត៌មានមួយច្បាប់ទៀតដែលមានសេចក្តីជាអាទិ ថា៖ "ឯកឧត្តម សឺន សាន និង គណៈកម្មាធិការប្រតិបត្តិ នៅតែមានសកម្មភាពជាប្រក្រតី និង កំពុងប្រើអំណាចទាំងមូល ដើម្បីគ្រប់គ្រងស្ថាប័នទាំងអស់ ទាំងស៊ីវិល ទាំងយោធានៃរណសិរ្ស" ។ នៅក្នុងសេចក្តីប្រកាសព័ត៌មាននោះ ក៏មានផ្សព្វផ្សាយផងដែរនូវការដឹងគុណថ្វាយសម្តេច សីហនុ ដែលបានប្រទានការគាំទ្ររបស់ព្រះអង្គ ចំពោះលោកតាប្រធាន ។ ពួកយើងទាំងអស់គ្នាចំណាយពេលពេញមួយថ្ងៃៗទី ២១ ដើម្បីរង់ចាំសញ្ញាពីលោកឧត្តមសេនីយ សក់ ស៊ុតសាខន ក្នុងការជួបទល់មុខគ្នាជាមួយលោកតា សឺន សាន ។ ថ្ងៃបន្ទាប់មក លោកតាប្រធានក៏បានចាត់ឲ្យបញ្ជូនសារអញ្ជើញឧត្តមសេនីយទាំងពីររូប ឲ្យមកជួបគ្នាទៀត ។ នៅក្នុងសារលោកតាប្រធានសរសេរថា៖ "ថ្ងៃនេះ នៅសល់តែមួយថ្ងៃគត់ សំរាប់ឲ្យយើងជួបគ្នាក្នុងឋានៈជាគ្រួសារ ។ ខ្ញុំនៅរង់ចាំអស់លោក" ។ ខុសពីសារលើកមុន ដែលមានលោក ប៊ុន សាយ ជាអ្នកចុះហត្ថលេខា លើកនេះលោកប្រធាន ចុះហត្ថលេខាខ្លួនឯង ។

ក្រុមលោក សក់ ស៊ុតសាខន ឈប់ទទួលលោកតាជាប្រធាន

ចំពោះការអញ្ជើញជាថ្មីនេះ ម្តងនេះ លោកឧត្តមសេនីយទាំងពីររូបបានបញ្ជូនសារឆ្លើយតបមកវិញ ។ ទីមួយ លោក ដៀន ដែល បានឆ្លើយថា ក្នុងហានៈជាទាហានគាត់ ស្ថិតនៅក្រោមអំណាចរបស់លោកឧត្តមសេនីយ សក់ ស៊ុតសាខន គាត់មិនអាចនិយាយជំនួសឧត្តមសេនីយ សក់ ស៊ុតសាខន បានឡើយ ។ ចំណែក លោកឧត្តមសេនីយ សក់ ស៊ុតសាខន វិញ បានឆ្លើយថាគាត់បានត្រៀមខ្លួនជាស្រេចដើម្បីជួបលោកតា សឺន សាន ដោយមានលក្ខខណ្ឌតទៅនេះ៖ ទី១. ជួបគ្នានៅទីកន្លែងអព្យាក្រឹត ទី ២. ភាគីនីមួយៗមានគ្នា ៥ នាក់ចូលរួម ។ តាមការឆ្លើយតបរបៀបនេះ លោកឧត្តមសេនីយទាំងពីររូបបានតាំងខ្លួនជាភាគីមួយស្មើមុខនិង ជាអង្គភាពមួយដាច់ដោយឡែកលែងចំណុះ ឬ នៅក្រោមអំណាចលោកតា សឺន សាន ទៀតហើយ ។ ចំណុចគួរភ្ញាក់ផ្អើលយ៉ាងខ្លាំង ដែលខាងពួកយើងអ្នកគាំទ្រលោកតាប្រធានស្មានមិនដល់នោះគឺ ចម្លើយរបស់លោកឧត្តមសេនីយទាំងពីរផ្ញើជូនលោកតា សឺន សាន[185] [186] នោះ ប្រើពាក្យតែត្រឹមតែឯកឧត្តម សឺន សាន ដោយមិនបានដាក់ឋានៈផ្លូវការជាប្រធានរ.ជ.រ.ប.ខ.ដូចមុនៗនោះឡើយ ។ ចំពោះលោកតា សឺន សាន ចម្លើយបែបនេះ មានតម្លៃស្មើនឹងការប្រមាថមាក់ងាយ ដែលមិនអាចទទួលយកបាន ។

[185] Sak Sutsakhan (General), Message, A Son Excellence Son Sann, le 22 décembre 1985.
[186] Dien Del (Genereal), Message, A Son Excellence Son Sann, le 22 décembre 1985.

ខ្ញុំលួចចេញទៅអារញ្ញទាំងកណ្តាលអធ្រាត្រ

នៅពេលដែលមើលឃើញថា គ្មានទំនងជាអាចឲ្យមេដឹកនាំរ.ជ.រ.ប.ខ.ទាំងពីរនាក់អាចជួបដោះស្រាយបញ្ហាបានទេនោះ ភាគីនីមួយៗខំព្យាយាមរក្សាការគ្រប់គ្រងត្រួតត្រាលើជនភៀសខ្លួនខ្មែរដែលរស់នៅក្នុងជំរុ ជាពិសេស ក្នុងជំរុំសាយធូ ដែលជាជំរុំធំជាងគេបង្អស់នៅតាមទល់ដែនខ្មែរ-ថៃ ។ ចំពោះលោកតា សឺន សាន ការគាំទ្ររបស់ប្រជាពលរដ្ឋស៊ីវិលមានតម្លៃជាអតិបរមា ។ លោកតា ត្រូវការបង្ហាញពិភពលោកថា ទោះជាមានក្រុមប្រឆាំងបំបែកខ្លួនយ៉ាងណាក៏ដោយ ក៏លោកតានៅតែជាមេដឹកនាំស្របច្បាប់របស់រ.ជ.រ.ប.ខ.ដដែល ។ ជាគោលការណ៍ ការគាំទ្រនោះ មានលក្ខណៈជាការគាំទ្រខាងនយោបាយតែប៉ុណ្ណោះទេ ក៏ប៉ុន្តែក៏នៅតែជាការគាំទ្រដ៏សំខាន់ណាស់ ។ ជាទូទៅ ជនរួមជាតិជាជនភៀសខ្លួនទាំងនោះ រស់នៅលើទឹកដីថៃ ហើយទទួលការឧបត្ថម្ភខាងម្ហូបអាហារ និង កន្លែងស្នាក់នៅពីអង្គការសហប្រជាជាតិ ។ ការចេញចូលទៅក្នុងជំរុំមានសារប្រយោជន៍ខ្លាំងណាស់សម្រាប់ពួកយើង ។ មែនទែនទៅ អ្វីៗអាស្រ័យលើអាជ្ញាធរថៃទាំងអស់ ។ គេឲ្យខាងណាចូលទៅទាក់ទងនឹងជនភៀសខ្លួន ខាងនោះនឹងទទួលបានផលល្អក្នុងការគាំទ្រ ។

ចាប់តាំងពីមានការបះបោរបំបែកខ្លួននៃក្រុមលោក សក់ ស៊ុតសាខន មកពាក្យសុំចូលទៅក្នុងជំរុំជនភៀសខ្លួនរបស់យើងទាំងអម្បាលម៉ាន ពុំបានទទួលចម្លើយជាវិជ្ជមានទាល់តែសោះ ។ ដូច្នេះ ខ្ញុំត្រូវលបចេញដំណើរដោយលួចលាក់ទៅអារញ្ញប្រាថេត ទីប្រជុំជននៅជាយដែន ដើម្បីរិះរកវិធីទាក់ទងជាមួយមេៗរបស់យើង ដែលកំពុងរស់នៅក្នុងជំរុំសាយធូ ដើម្បីឲ្យអ្នកទាំងនោះបានដឹងពីសភាពការណ៍ និង សម្របសម្រួលកិច្ចការទប់ទល់ជាមួយក្រុមប្រឆាំងផង ។ ជាមួយនឹងវត្តមានរបស់ខ្ញុំ នៅជាយដែន ខ្ញុំអាចជួយផ្តល់គំនិត ឬ ផ្តល់មតិ ដើម្បីកុំឲ្យគ្នីគ្នា

យើងនៅក្នុងជំរុំចាញ់បោកការឃោសនារបស់ក្រុមលោក សក់ ស៊ុតសាខន ។ មន្ត្រីអន្តរជាតិភាគច្រើនដែលបំរើការងារនៅសាយធូ ច្រើនមានលំនៅស្ថាននៅអារញ្ញប្រាថេត ។ ពួកគេអាចចេញចូលជំរុំកៀសខ្លួនបានដោយសេរី ។ ធម្មតាពួកនេះ គេចេញពីអារញ្ញនៅពេលព្រឹក ហើយវិលត្រឡប់មកវិញនៅពេលល្ងាច ។ ក្នុងចំណោមមន្ត្រីបំរើការឲ្យអង្គការអន្តរជាតិទាំងនោះ ខ្ញុំក៏មានមិត្តភក្តិមួយចំនួន ដែលខ្ញុំអាចពឹងពាក់បាន ។ ខ្ញុំពឹងពួកគេឲ្យនាំយកសំបុត្រខ្ញុំផ្ញើទៅជូនមេៗ និង អ្នកទទួលខុសត្រូវនៅក្នុងជំរុំរបស់យើង និង នាំយកសំបុត្ររបស់ពួកគេមកឲ្យខ្ញុំវិញ ដោយជៀសវាងកុំឲ្យពួកយោធាថៃចាប់បាន ។ ដូច្នេះ វត្តមានរបស់ខ្ញុំ នៅអារញ្ញប្រាកដជាអាចសម្រួលទំនាក់ទំនងរវាងជំរុំ និង ទីស្នាក់ការកណ្តាលរបស់យើងនៅបាងកកបាន ។

ជាការសម្ងាត់ ខ្ញុំក៏លបចេញដំណើរពីបាងកកទៅអារញ្ញប្រាថេត នៅពាក់កណ្តាលអធ្រាត្រ ដោយមិនឲ្យហួណា ដែលនៅយាមពួកយើងដឹងឡើយ ។ នៅពេលទៅដល់អារញ្ញប្រាថេតភ្លាម ខ្ញុំប្រញាប់តម្រង់ទៅផ្ទះអ្នកស្រី អែរណា ហង់រីកសុន (Erna Henrikson) ដែលជាមន្ត្រីនៃស្នងការអង្គការសហប្រជាជាតិខាងជនកៀសខ្លួន (UNHCR) ដែលជាមិត្តចាស់ និង ស្មោះត្រង់បំផុតរបស់ខ្ញុំ ។ អែរណា ត្រូវបានជនកៀសខ្លួនស្គាល់ស្ទើរទាំងអស់ ហើយហៅគាត់ថា "យាយសក់ស" ។ ខ្ញុំទៅដាស់គាត់ៗក្រោកទាំងសើងមមើង រួចខ្ញុំពន្យល់ពីសភាពការណ៍នៅបាងកក ដែលមានការបះបោរបំបែកខ្លួនរបស់ក្រុមលោកឧត្តមសេនីយ សក់ ស៊ុតសាខន ។ ព្រឹកឡើង អែរណា ចេញទៅធ្វើការនៅជំរុំខៅ-អ៊ី-ដាង ទុកខ្ញុំឲ្យនៅក្នុងផ្ទះរបស់គាត់តែម្នាក់ឯង ក្រោយពេលដែលគាត់បានរៀបចំម្ហូបអាហារទុកឲ្យខ្ញុំជាស្រេច ។ រាល់ថ្ងៃ ពេលថ្ងៃ ខ្ញុំលាក់ខ្លួនពួនអាត្មានៅក្នុងផ្ទះ អែរណា មិនចេញទៅខាងក្រៅរហេតរហូតឡើយ ។ ពេលយប់ងងឹតទើបខ្ញុំចេញទៅក្រៅផ្ទះ ។ រាល់យប់ ខ្ញុំបរថយន្ត

របស់អែរណា ដើម្បីទៅរកជួបមន្ត្រីអង្គការអន្តរជាតិ ដែលធ្វើការនៅក្នុងជំរុំសាយធូ ដើម្បីនាំសំបុត្រយកទៅផ្ញើ និង ទៅទទួលសំបុត្រពីសាយធូមកវិញ ។

នៅក្នុងសំបុត្រដែលខ្ញុំផ្ញើទៅអ្នកទទួលខុសត្រូវរបស់ពួកយើងនៅក្នុងជំរុំ គឺអ្នកគាំទ្រលោកតា សឺន សាន ខ្ញុំបានពង្រឹងទឹកចិត្តអ្នកទាំងនោះថា លោកតាប្រធាននៅតែគ្រប់គ្រងបានយ៉ាងរឹងមាំនូវចលនាតស៊ូរបស់យើង ហើយក្រុមយើងទទួលបានការគាំទ្រយ៉ាងធំធេងពីសមាជិក សមាជិការ.ជ.រ.ប.ខ.នៅសហរដ្ឋអាមេរិក នៅអឺរ៉ុប ជប៉ុន និង នៅអូស្ត្រាលី ។ ខ្ញុំបញ្ជាក់ថា លោកតា សឺន សាន នៅតែបានការទទួលស្គាល់ពីសម្តេច សីហនុ ថាជានាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ និង ជាប្រធានរ.ជ.រ.ប.ខ. ។ ជាមួយគ្នានោះ ខ្ញុំក៏ផ្តល់អនុសាសន៍ដល់អ្នកដឹកនាំធំៗទាំងនោះ សម្រាប់សកម្មភាពនានា ដែលត្រូវធ្វើនៅពេលខាងមុខ ។ តាមរយៈអ្នករត់សំបុត្រនោះ ខ្ញុំក៏ទទួលត្រឡប់មកវិញនូវព័ត៌មានពីជំរុំអំពីសកម្មភាពអមិត្តរបស់ក្រុមលោក សក់ ស៊ីតសាខនគឺ ការយោសនាប្រឆាំងលោកតា សឺន សាន ផង ។ តាមរយៈការផ្លាស់ប្តូរសំបុត្រឆ្លងឆ្លើយគ្នានេះ ពួកយើងក៏បានដឹងថា ក្រុមលោក សក់ ស៊ីតសាខន បានដាក់ការគាបសង្កត់យ៉ាងខ្លាំងដល់អស់លោកមេជំរុំទាំងអស់ បង្ខំឲ្យពួកគេរត់ចោលលោកតា សឺន សាន មកចុះចូលខាងពួកឧត្តមសេនីយវិញ ។

ទាហានថៃតាមរកខ្ញុំ

នៅពេលនោះ ក្រុមបំបែកខ្លួនរបស់លោកឧត្តមសេនីយ សក់ ស៊ីតសាខន បានទទួលការគាំទ្រយ៉ាងខ្លាំងពីក្រុមយោធាថៃ ។ ក្រុមបំបែកខ្លួននេះ អាចសុំឲ្យទាហានថៃចាប់មេជំរុំ ដែលប្រឆាំងពួកគេទៅឃុំឃាំងបាន ។ ដូច្នេះ ពួកយើងខ្លះក៏មានការភ័យខ្លាច ឬ បារម្ភយ៉ាងខ្លាំង ។ មិនយូរប៉ុន្មាន វត្តមានលួចលាក់របស់ខ្ញុំនៅ

ក្នុងផ្ទះអែរណា ក៏ត្រូវបែកធ្លាយទៅដល់អង្គភាពពិសេស ៨៣៨ ។ នៅព្រឹកមួយនោះ នៅពេលដែលខ្ញុំកំពុងទទួលទានអាហារពេលព្រឹក នៅឯផ្ទះបាយឯក្រោយឯនោះខ្ញុំឮសម្លេងអែរណាស្រែកខ្លាំងពីបន្ទប់គាត់នៅខាងមុខមកថា៖ "មូលី កុំចេញពីផ្ទះបាយ នៅឲ្យស្ងៀមកុំមាត់កអ្វីឲ្យសោះ មានគេមករកមូលីឯងហើយ" ។ មែនទែនទៅ អែរណា បានក្រឡេកឃើញ ហើយស្គាល់អ្នកបររថយន្តចូលមកក្នុងបរិវេណផ្ទះគាត់ ។ គេនោះជាទាហាននៅក្នុងអង្គភាពពិសេស ៨៣៨ ។ ប៉ុន្មានវិនាទីក្រោយមក រថយន្តក៏មកឈប់នៅជិតជណ្តើរផ្ទះ រួចខ្ញុំឮគេបញ្ឈប់សម្លេងម៉ាស៊ីន។ ទាហាននោះ និយាយមករក អែរណា ជាភាសាថៃ ព្រោះ អែរណា ចេះភាសាថៃយ៉ាងស្ទាត់ជំនាញ ។ ទាហាននោះនិយាយថា គាត់គ្រាន់តែចូលមកលេងសួរសុខទុក្ខ អែរណា តែប៉ុណ្ណោះ ។ ក្រោយពីនិយាយលេងយ៉ាងខ្លីមក ទាហានថៃនោះក៏លាចេញទៅ ។ នៅទីបំផុត ដើម្បីជាការប្រុងប្រយ័ត្នខ្ពស់ ខ្ញុំសម្រេចចិត្តវិលត្រឡប់ទៅបាងកកវិញភ្លាមនៅព្រឹកនោះ ។

នាយទាហានថៃកាន់កាប់ទ័ពយើងដោយផ្ទាល់

នៅពេលដែលខ្ញុំជាប់ដៃនៅអារញ្ញប្រាថេត នៅឯទីក្រុងបាងកកឯនោះវិញ ក្រុមការងារ និង អាជ្ញាធរយោធាថៃ ក៏បានសាកល្បងដោះស្រាយវិបត្តិរបស់ រ.ជ.រ.ប.ខ. តាមវិធីរបស់គេដែរ ។ ពួកគេនៅតែទទូចឲ្យបញ្ចូលលោក ហ្គាហ្វា និង លោក ហ៊ីង គន្ធុន ទៅក្នុងរ.ជ.រ.ប.ខ. ដែលជាចំណុចមិនឲ្យលោកតា សឺន សាន ទទួលយកបាន ។ ក្រុមការងារ និង អាជ្ញាធរយោធាថៃ ក៏នៅតែឲ្យលោកឧត្តមសេនីយ សក់ ស៊ុតសាខន ទទួលយកដដែលវិញនូវមុខនាទីរបស់គាត់ជាអគ្គមេបញ្ជាការនៃ ក.ជ.រ.ប.ខ. ។ ក៏ប៉ុន្តែ លោកតា សឺន សាន នៅតែប្រកាន់ថានឹងប្រគល់តួនាទីជាអគ្គបញ្ជាការកងទ័ពជូនលោក ស៊ុត សាខន តែក្នុងករណីមាន

លក្ខខណ្ឌខ្លះតែប៉ុណ្ណោះ ។ នៅថ្ងៃទី ២៣ ធ្នូ ១៩៨៥ នាពាក់កណ្តាលអធ្រាត លោកតាបានជួបលោកឧត្តមសេនីយ ធាវលិត ដើម្បីបញ្ជាក់ជូនលោកមេទ័ពថៃនូវគោលជំហរនេះ ។ លោក ធាវលិត បានផ្តល់យោបល់សុំឲ្យលោកតា សឺន សាន ខិតខំរិះរកដំណោះស្រាយល្អណា ដែលអាចទទួលយកបានទាំងសងខាង ។ នៅពេលជាមួយគ្នានោះ អង្គភាព ៨៣៨ ក៏បានបញ្ជាឲ្យមេបញ្ជាការក.ជ.រ.ប.ខ. ទាំងអស់ បង្កើតគណៈកម្មាធិការរយោធាបណ្តោះអាសន្នមួយ ដែលមានគ្នា ១០ នាក់ ហៅថា "គណៈកម្មាធិការរយោធា ១០ នាក់" ដែលស្ថិតនៅក្រោមការសម្របសម្រួលរបស់អាជ្ញាធររយោធាថៃ ទម្រាំមានដំណោះស្រាយវិបត្តិថ្នាក់ដឹកនាំ រ.ជ.រ.ប.ខ. ។

នៅថ្ងៃទី ២៤ ធ្នូ ១៩៨៥ ក្រុមលោក សក់ ស៊ុតសាខន បានបញ្ជាដល់មេទ័ព រ.ជ.រ.ប.ខ. ទាំងអស់ ឲ្យផ្តាច់ការទាក់ទងតាមវិទ្យុជាមួយទីស្នាក់ការរបស់លោកតា សឺន សាន ។ ពាក្យចចាមអារាម បានធ្លាយឲ្យដឹងថាអាជ្ញាធរថៃ បានសម្រេចឲ្យលោកតា សឺន សាន ទទួលខុសត្រូវតែចំពោះបញ្ហានយោបាយ និងការទូតតែប៉ុណ្ណោះ ឯលោកឧត្តមសេនីយ សក់ ស៊ុតសាខន ត្រូវទទួលបន្ទុកជាអគ្គមេបញ្ជាការ ក.ជ.រ.ប.ខ. ដែលមានអំណាចត្រួតត្រាទាំងផ្នែកយោធា និងផ្នែកស៊ីវិល ។ នៅថ្ងៃទី ២៥ ធ្នូ ១៩៨៥ លោកតា សឺន សាន សុខចិត្តធ្វើសម្បទានខ្លះ ។ នៅក្នុងអនុស្សារណៈមួយផ្ញើជូនលោកឧត្តមសេនីយ ធាវលិត លោកតាប្រធានស្នើឲ្យលោក ហ៊ឹង គន្ថុន និង លោក ហ្គាហ្វា ចេញទៅឈប់សម្រាកចំនួន ៦ ខែ ។ នៅថ្ងៃទី ២៦ ធ្នូ លោកតាសុំច្បាប់លោកឧត្តមសេនីយ ធាវលិត ទៅធ្វើទស្សនកិច្ចនៅជំរុំសាយធូ ក៏ប៉ុន្តែគ្មានបានទទួលចម្លើយពីលោកឧត្តមសេនីយឡើយ ។ នៅថ្ងៃទី ១ មករា ១៩៨៦ លោកតា សឺន សាន ចេញសេចក្តីប្រកាសមួយ ដាក់គណៈកម្មាធិការបណ្តោះអាសន្នរបស់ក្រុមលោកឧត្តមសេនីយ សក់ ស៊ុតសាខន

ថាជាអង្គការខុសច្បាប់ រួចលោកតាធ្វើពាក្យសុំការអនុញ្ញាតពីឧត្តមសេនីយ ឆាវលិត ដើម្បីទៅធ្វើទស្សនកិច្ចនៅជំរុំសាយធូម្តងទៀត ។ ជាថ្មីម្តងទៀត លោកឧត្តមសេនីយ ឆាវលិត ក៏នៅតែមិនឆ្លើយតបចំពោះសំណើរបស់យើង។ យើងរង់ចាំរហូតដល់ថ្ងៃ ៣ មករា ១៩៨៦ នាពេលល្ងាច ទើបបានទទួលចម្លើយពីខុទ្ទកាល័យរបស់លោក ឆាវលិត ថាលោកឧត្តមសេនីយបានទទួលលិខិតរបស់យើងហើយ តែក៏នៅពុំទាន់សម្រេចអនុញ្ញាត ឬ មិនអនុញ្ញាតនៅឡើយទេ ។ ពួកយើងនាំគ្នាគិតថានេះជាការគាបសង្កត់មួយទៀតមកលើលោកតា សឺន សាន ។

គេប្រើល្បិចកុំឲ្យខ្ញុំជួបលោក សូឡា

នៅថ្ងៃទី ៦ មករា លោកតាប្រធាន បានជួបជាមួយលោក ស្តេហ្វិន សូឡា (Stephen Solarz) សមាជិកសភាសហរដ្ឋអាមេរិក ដែលគេសម្គាល់ថាជាមនុស្សគាំទ្រ រ.ជ.រ.ប.ខ. យ៉ាងចេញមុខជាយូរមកហើយៗក៏ជាស្តាបត្យករនៃការផ្តួចផ្តើមគំនិតរកដំណោះស្រាយបញ្ហាកម្ពុជាមួយរូបផង ។ លោកតា សឺន សាន បានតវ៉ាចំពោះមុខលោក សូឡា អំពីទំនាស់ផ្ទៃក្នុងរបស់រ.ជ.រ.ប.ខ. និង ការគាបសង្កត់របស់ថៃ ។ បន្ទាប់ពីជំនួបជាមួយលោកសូឡារួចមក លោកតាប្រធានបានចាត់ខ្ញុំឲ្យធ្វើដំណើរទៅជំរុំសាយធូក្នុងឋានៈជាតំណាងផ្ទាល់របស់ប្រធាន ដើម្បីរង់ចាំទទួលលោក សូឡា ដែលនឹងត្រូវទៅធ្វើទស្សនកិច្ច នៅជំរុំនោះ នៅថ្ងៃស្អែកគឺថ្ងៃ ៧ មករា ១៩៨៦ ។ ម្តងនេះ អាជ្ញាធរថៃបានចេញច្បាប់អនុញ្ញាតឲ្យខ្ញុំ និង ជំនួយការម្នាក់ចូលទៅជំរុំបាន ។ នាល្ងាចថ្ងៃទី ៦ មករា នោះ ខ្ញុំក៏ចេញដំណើរពីបាងកក ឆ្ពោះទៅអារញ្ញប្រាថេត រួចឈប់សម្រាកនៅផ្ទះយាយសក់ស (Erna Henrikson) ម្តងទៀត រង់ចាំព្រឹកឡើងនឹងបន្តដំណើរទៅជំរុំសាយធូ ។

ព្រឹកថ្ងៃទី ៧ មករា ខ្ញុំក៏ទៅដល់ជំរុំសាយធូដូចបានកំណត់ ។ ពេលឃើញខ្ញុំចូលទៅដល់ក្នុងជំរុំ ពួកអ្នកគាំទ្រយើងបានអបអរសាទរទទួលយ៉ាងខ្ញៀវខ្ញាវពេងអឺងកង ។ ពួកគេសប្បាយចិត្តណាស់ ដោយបានទទួលការលើកទឹកចិត្តយ៉ាងខ្លាំង នៅពេលឃើញវត្តមានរបស់យើង ព្រោះក្នុងពេលដែលយើងមិនបានចូលក្នុងជំរុំមួយរយៈនោះ ក្រុមប្រឆាំងបានធ្វើការយោសនាវាយប្រហារ ឬ បន្ទុះបង្អាប់ ឬ គាបសង្កត់យ៉ាងខ្លាំង ដោយមានការគាំទ្រពីយោធាថៃផង ។ នៅពេលដែលខ្ញុំកំពុងសំណេះសំណាលជាមួយមន្ត្រីរដ្ឋបាលរបស់យើង និង ក្នុងពេលដែលខ្ញុំកំពុងរង់ចាំជួបលោក ឡាយ ខែក ដែលនៅពេលនោះ ជាប្រធានជំរុំសម្លរ និង ជាអ្នកគាំទ្រការពារលោកតា សឺន សាន យ៉ាងដាច់ខាតម្នាក់នោះ ស្រាប់តែមានក្រុមទាហានអាវខ្មៅថៃពីរនាក់ ដើរចូលមកនិយាយប្រាប់ខ្ញុំថា លោកសក្តិ ៥ ជាមេបញ្ជាការថៃប្រចាំជំរុំចង់ជួបពិភាក្សាការងារជាមួយខ្ញុំ នៅទីបញ្ជាការរបស់គាត់ជាបន្ទាន់ ។ ខ្ញុំនឹកក្នុងចិត្តថា ការដែលអាជ្ញាធរថៃចង់ជួបខ្ញុំនេះ ប្រាកដជាមានបញ្ហាសំខាន់ណាស់ហើយ ព្រោះពីមុនៗមក គេមិនដែលឲ្យខ្ញុំជួបទេ ។ ដូច្នេះ ខ្ញុំក៏ប្រញាប់ប្រញាល់ចេញទៅជួបលោកសក្តិ ៥ ទាហានអាវខ្មៅថៃ ដោយមិនទាន់ទាំងបានជួបលោក ឡាយ ខែក ផង ។

នៅពេលខ្ញុំទៅដល់ការិយាល័យរបស់លោកសក្តិ ៥ ថៃនោះ ទាហានថៃម្នាក់បានលើកទឹកត្រជាក់មួយកែវមកផ្តល់ និង សុំឲ្យអង្គុយរង់ចាំយ៉ាងគួរសមរាក់ទាក់ល្អណាស់ រួចទាហាននោះក៏ចេញទៅបាត់ទៅ ។ ខ្ញុំចេះតែអង្គុយរង់ចាំលោកសក្តិ៥ មិនហ៊ានចេញចូលទៅណាឡើយ ក៏ប៉ុន្តែខ្ញុំមិនឃើញលោកសក្តិ ៥ ចេញមុខមកសោះ ។ ខ្ញុំរង់ចាំអស់រយៈពេលប្រហែល ៤ ម៉ោង ទើបទាហានដែលឲ្យខ្ញុំអង្គុយចាំនោះ មកប្រាប់ខ្ញុំវិញថាគ្មានការងារអ្វីសំខាន់ទេ ខ្ញុំអាចចេញទៅវិញបាន ។ តាមពិតទៅ នេះគ្រាន់តែជាល្បិចកលរបស់យោធាថៃដើម្បីបញ្ជៀសខ្ញុំកុំឲ្យមានលទ្ធភាពជួបជាមួយលោក សូឡា តែប៉ុណ្ណោះ ។ ធ្វើយ៉ាងដូច្នេះ ដើម្បីបង្ហាញឲ្យលោក

សូឡា មើលឃើញថា នៅក្នុងជំរុំសាយធូគ្មានអ្នកគាំទ្រលោកតា សឺន សាន ទេ មានតែមនុស្សរបស់លោក សក់ ស៊ុតសាខន ។ នៅពេលដែលខ្ញុំនៅជាប់ក្នុងកលល្បិចរបស់ទាហានថៃនោះ លោកឧត្តមសេនីយ ជៀន ដែល ដែលជាមេដឹកនាំក្រុមប្រឆាំងម្នាក់ទៀត ដែលកំពុងរស់នៅក្នុងជំរុំសាយធូបានបញ្ជូនសារតាមវិទ្យុអំពីជ័យជំនះរបស់ក្រុមគាត់ថា អៀង មូលី ត្រូវបានទាហានថៃចាប់ឃុំឃាំងអស់រយៈពេល ៤ ម៉ោងហើយ អៀង មូលី អត់បានជួបជាមួយលោក សូឡា ទេ ។ ទោះបីជាមានការប៉ះទង្គិចយ៉ាងនេះក្តី លោកឧត្តមសេនីយ ធាវលិត បានជំរាបដល់មន្ត្រីសហរដ្ឋអាមេរិក និង ចិនថាថៃមិនបានផ្លាស់ប្តូរនយោបាយក្នុងបញ្ហារ.ជ.រ.ប.ខ.ទេគឺ ថៃនៅតែទទួលស្គាល់លោកតា សឺន សាន ជាប្រធានរ.ជ.រ.ប.ខ. និង ជានាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យជាដរាប ។ លោកតា សឺន សាន ក៏នៅតែបន្តទទូចសុំទៅធ្វើទស្សនកិច្ចនៅជំរុំសាយធូតទៅទៀត ។

លោកតា សឺន សាន អាចទៅធ្វើទស្សនកិច្ចនៅសាយធូ

នៅថ្ងៃទី ១៤ មករា ១៩៨៦ ពួកយើងបានដាក់ពាក្យសុំរបស់លោកតាទៅសាយធូម្តងទៀតជាលើកទី៣ ដើម្បីទៅធ្វើទស្សនកិច្ចក្នុងរយៈពេលបីថ្ងៃ ។ លោកឧត្តមសេនីយ សក់ ស៊ុតសាខន បានប្រឆាំងនឹងពាក្យសុំធ្វើទស្សនកិច្ចរបស់លោកតាប្រធាននេះ ដោយធ្វើលិខិតដំទាស់មួយច្បាប់ផ្ញើជូនលោកឧត្តមសេនីយ ធាវលិត និង មួយច្បាប់ទៀតជូនលោក សិទ្ធិ សាវេតសិលា រដ្ឋមន្ត្រីការបរទេសថៃ ។ ជាមួយគ្នានោះ នៅឯជាយដែនឯនោះវិញ លោកឧត្តមសេនីយ ជៀន ដែល បានគំរាមដល់ពួកយើងថាអាចនឹងមានការប៉ះទង្គិចគ្នា ប្រសិនបើលោកតា សឺន សាន នៅតែចចេសទៅធ្វើទស្សនកិច្ចនៅសាយធូតទៅទៀត ។ ក៏ប៉ុន្តែ លើកនេះទោះជាមានការប្រឆាំង ក៏ពួកយើងត្រូវបានទទួលជោគជ័យម្តងវិញ ។ អាជ្ញាធរថៃបានសម្រេចឲ្យ

ពួកយើងអាចចូលទៅសាយធូបាន ក៏ប៉ុន្តែគេអនុញ្ញាតឲ្យតែសម្រាប់ទស្សនកិច្ចមួយថ្ងៃមិនមែនសម្រាប់បីថ្ងៃដូចយើងសុំនោះឡើយ ។ នេះជាដំណឹងដ៏ល្អសម្រាប់ពួកយើង ព្រោះថាទស្សនកិច្ចរបស់លោកតាប្រធាននៅក្នុងជំរុំនឹងលើកទឹកចិត្តដល់អ្នកគាំទ្រទាំងអស់ឡើងវិញ ។ ក៏ប៉ុន្តែក្រុមប្រឆាំងនៅតែព្យាយាមរារាំងមិនឲ្យពួកយើងអាចជួបប្រជាពលរដ្ឋ និង អ្នកគាំទ្រពួកយើងនៅឯមូលដ្ឋានបានតទៅទៀត ។

នៅថ្ងៃទី ១៥ មករា ១៩៨៦ ហ្គាហ្វា បានធ្វើដំណើរទៅអារញ្ញប្រាថេត ដើម្បីទៅចាក់សោទ្វារបន្ទប់សម្រាករបស់លោកតា សឺន សាន នៅឯផ្ទះសំណាក់សុវត្ថិភាព និង ដើម្បីប្រមែប្រមូលដកយកវិទ្យុទាក់ទងមួយគ្រឿងគត់ ដែលពួកយើងមានសម្រាប់ទាក់ទងគ្នារវាងទល់ដែន និង ទីស្នាក់ការកណ្តាលនៅទីក្រុងបាងកក ។ ហ្គាហ្វា ធ្វើបែបនេះដើម្បីរារាំងកុំឲ្យលោកតា សឺន សាន ឬ ពួកយើងមកសំណាក់ និង ទាក់ទងគ្នាជាមួយពួកយើងបាន ។ នៅទីបំផុត នៅថ្ងៃទី ១៧ មករា ១៩៨៦ គឺ មួយខែចាប់តាំងពីក្រុមឧត្តមសេនីយធ្វើការបះបោរប្រឆាំង លោកតាប្រធានបានចូលទៅជំរុំសាយធូជាថ្មីវិញ ។ នៅសាយធូ (ជំរុំនីមួយៗដែលរើមកនៅក្នុងបរិវេណសាយធូ បន្ទាប់ពីត្រូវកងទ័ពវៀតណាមវាយបាក់បែកមកនោះ នៅតែរក្សាឈ្មោះជំរុំរបស់ខ្លួនដដែលដូចជា នងចាន់ សម្លារធ្ងាញ់ ដងរែក អូរបុកជាដើម) មានប្រជាពលរដ្ឋជាច្រើននាក់បានមក ទទួលពួកយើងយ៉ាងណែនណាន់តាន់តាប់ ។ មន្ត្រីយោធាថៃ ដែលអមដំណើរពួកយើងនៅពេលនោះ បានប្រាប់ពួកយើងថាគេបានណែនាំលោកឧត្តមសេនីយ ជៀន ដែល ដែលស្នាក់នៅក្នុងជំរុំឲ្យចេញមកទទួលលោកតាប្រធានដែរ តែលោកឧត្តមសេនីយរូបនេះ ឥតបានបង្ហាញមុខឡើយ ។ ឆ្លៀតក្នុងឱកាសនៃទស្សនកិច្ចនេះ លោកតាប្រធានរ.ជ.រ.ប.ខ.បានផ្សព្វផ្សាយឲ្យក្រុមអ្នកគាំទ្រអន្តរជាតិរបស់លោកតា ដឹងថាលោកតាមានបំណងដោះ

ស្រាយជម្លោះផ្ទៃក្នុងនេះ ក្នុងលក្ខណៈគ្រួសារ ក៏ប៉ុន្តែក្រុមប្រឆាំងហាក់ដូចជាមិនយល់ស្របតាមលោកតាទាល់តែសោះ ។

ក្រុម សក់ ស៊ុតសាខន ចង់ឲ្យលោកតាធ្វើប្រធានកិត្តិយស

នៅថ្ងៃ ២៦ មករា ១៩៨៦ លោកឧត្តមសេនីយ ឆាវលិត បានជួបជាមួយលោកតា សឺន សាន ។ បន្ទាប់មកនៅពេលល្ងាច លោកមេទ័ពថៃរូបនេះបានឲ្យរៀបចំធ្វើការប្រជុំគ្នារវាងក្រុមយើង និង ក្រុមប្រឆាំង ដើម្បីឲ្យជជែកគ្នា តើត្រូវបញ្ចប់ជម្លោះផ្ទៃក្នុងយ៉ាងដូចម្តេច? ក្រុមយើងមានលោកតា សឺន សាន ជាអ្នកដឹកនាំ ដោយរួមមានជាអាទិ៍ លោក នាង ជិនហន អគ្គលេខាធិការ លោកវរសេនីយ ព្រុំ វិត លោក ប៊ុន សាយ លោកវរសេនីយ អ៊ឹម ឈូដេត លោកឧត្តមសេនីយ ថាច់ រ៉េង លោកវរសេនីយ ឈឹម ឱមយ៉ុន លោកវរសេនីយកងទ័ពអាកាស សង្វារ ដឺ ឡូប៉ែស និង រូបខ្ញុំ អៀង មូលី ។ ចំណែកឯក្រុមលោកឧត្តមសេនីយ សក់ ស៊ុតសាខន មានលោកឧត្តមសេនីយ សក់ ស៊ុតសាខន ជាអ្នកដឹកនាំ បន្ទាប់មកមានលោកតា ហ៊ុយ គន្ធុល អតីតនាយករដ្ឋមន្ត្រី លោកតា ជុន អ៊ុក អតីតរដ្ឋមន្ត្រី លោក ហ្គាហ្វា លោកវរសេនីយ ចក់ បូរី លោក ប៉ែន ធុឡា និង លោកឧត្តមសេនីយ ប៉ុក សំអាន ។ លោកឧត្តមសេនីយ ឆាវលិត ចាប់ផ្តើមបើកអង្គប្រជុំ ដោយស្នើឲ្យភាគីខ្មែរទាំងពីរបំភ្លេចរឿងចាស់ រឿងដែលកន្លងផុតទៅហើយនោះ និង ឲ្យខំពិភាក្សារកដំណោះស្រាយបញ្ហាបច្ចុប្បន្ន និង អនាគត ដើម្បីបញ្ចប់ជម្លោះក្នុងបរិយាកាសជាបងជាប្អូនក្នុងគ្រួសារតែមួយ ជាពិសេស លោកមេទ័ពថៃរូបនេះប្រដៅ ឲ្យខំរកដំណោះស្រាយក្នុងឋានៈជាខ្មែរអ្នកជាតិនិយម ដែលមានការកិច្ចរំដោះប្រទេស ។ បន្ទាប់មកលោក ឆាវលិត ក៏ចេញបាត់ទៅ ទុកឲ្យភាគីខ្មែរនិយាយគ្នា ។ លោកតាប្រធានផ្តើមការពិភាក្សា ដោយបញ្ជាក់ជាថ្មីថាលោកតានៅរក្សាប្រតិភូកម្មនៃការទទួលខុសត្រូវខាង

កងទ័ព ជូនលោកឧត្តមសេនីយ សក់ ស៊ុតសាខន ដដែល និង សុខចិត្តទទួលយក ការកាត់ផ្តាច់អំណាចយោធា ចេញពីកិច្ចការនយោបាយការទូត និង ហិរញ្ញវត្ថុ ។ បន្ទាប់មក លោកតាសុំឲ្យលោកអគ្គលេខាធិការ នាង ជិនហន សំដែងមតិមុនគេ ទំនងជាចង់ដឹងថាតើលោកអគ្គលេខាមានទំនោរទៅខាងណា? ដូច្នេះលោកអគ្គ លេខា នាង ជិនហន មានការប្រយ័ត្នប្រយែងណាស់ក្នុងការនិយាយស្តី ។ ជាទូទៅ គាត់យោងទាំងស្រុងទៅលើក្រិត្យក្រមរបស់រ.ជ.រ.ប.ខ.គឺ គួសបង្ហាញឲ្យឃើញថា ការបះបោរប្រឆាំងរបស់ក្រុមឧត្តមសេនីយជាការខុសច្បាប់ ឬ ខុសធម្មនុញ្ញរបស់ រ.ជ.រ.ប.ខ. ។ ឆ្លើយតបវិញ ក្នុងនាមភាគីម្ខាងទៀត លោកតា ប៊ុន អ៊ុក មិនគ្រាន់តែមិនព្រមលើកមកជជែកអំពីសំណើខាងលើរបស់លោកតា សឺន សាន ទេ តែយកវេទិកានោះ ចោទប្រកាន់លោកតាប្រធានថា ដឹកនាំរណសិរ្សតាមរបៀប ផ្តាច់ការ យកការតស៊ូរំដោះជាតិទាំងមូល ធ្វើឲ្យមានជាបក្សពួក ឬ គ្រួសារនិយម ។ លោកតា ប៊ុន អ៊ុក ស្នើលោកតា សឺន សាន ឲ្យទទួលយកមុខនាទីជាប្រធានកិត្តិ យស និង សុំឲ្យគណៈកម្មាធិការកណ្តាលបណ្តោះអាសន្នសង្គ្រោះ រ.ជ.រ.ប.ខ.របស់ លោក សក់ ស៊ុតសាខន ដែលទើបបង្កើតថ្មីនេះ ជំនួសគណៈកម្មាធិការប្រតិបត្តិ ឬ កូមុិច តទៅ ។ នៅក្នុងការពិភាក្សានោះ ទាំងលោកតា ប៊ុន អ៊ុក ទាំងលោកតា ហ៊ុយ គន្ធុល ដែលអះអាងថាជាមិត្តរបស់លោកតា សឺន សាន ជាង ៤០ ឆ្នាំមកហើយ ទទូចថាមានតែទទួលយកលក្ខខណ្ឌទាំងពីរខាងលើទេ ទើបអាចបញ្ចប់ជម្លោះ ។ លោកតា ប៊ុន អ៊ុក អះអាងថាហាន:ប្រធានកិត្តិយសសមរម្យណាស់សម្រាប់លោក តា សឺន សាន ព្រោះខ្ពស់ផុតពីគេ ដូចសម្តេចមហាក្សត្រីយានី អេលីហ្សាបេតទី ២ នៃប្រទេសអង់គ្លេស ដើម្បីកុំឲ្យលោកតា សឺន សាន លូកដៃចូលក្នុងការងារតូចតាច របស់ រ.ជ.រ.ប.ខ. ។ ជាទូទៅក្រុមលោកឧត្តមសេនីយ បានមើលឃើញច្បាស់ថា រ.ជ.រ.ប.ខ. មិនអាចរំដោះប្រទេសកម្ពុជាចេញពីការកាន់កាប់របស់កងទ័ពវៀតណាម

បានឡើយ ប្រសិនបើបន្តឲ្យលោកតា សឺន សាន នៅដឹកនាំចលនាតស៊ូនេះតទៅទៀត ដូច្នេះពួកគេអះអាងថាបានធ្វើការពិគ្រោះជាមួយឥស្សរជនអ្នកស្នេហាជាតិ និង អ្នកទទួលខុសត្រូវសំខាន់ៗរបស់រ.ជ.រ.ប.ខ. ហើយយល់ថាត្រូវបញ្ចប់ការដឹកនាំរបស់លោកតាប្រធាន ។

នៅពេលដល់វេនខ្ញុំត្រូវនិយាយ ខ្ញុំលើកជាសំណួរដល់ក្រុមលោក សក់ ស៊ុតសាខន ថាតើអស់លោកឈរលើមូលដ្ឋានស្របច្បាប់អ្វី ទើបអស់លោកសម្រេចថាអស់លោកអាចមកជំនួសឯកឧត្តមប្រធាន និង គណៈកម្មាធិការប្រតិបត្តិយ៉ាងដូច្នេះ? ខ្ញុំបានបញ្ជាក់ទៀតក្នុងន័យថាប្រសិនបើក្នុងអង្គការណាមួយ គេមិនគោរពលក្ខន្តិក: ឬ បទបញ្ជាផ្ទៃក្នុងទេនោះ អង្គការនោះប្រាកដជាមិនអាចដំណើរការឲ្យល្អបានឡើយ ។ ក្រោយពីជជែកគ្នាអស់រយៈពេលយ៉ាងយូរមក ក្រុមលោក សក់ ស៊ុតសាខន នៅតែទាមទារឲ្យលោកតា សឺន សាន ទទួលតួនាទីជាប្រធានកិត្តិយស និង ឲ្យលោកឧត្តមសេនីយ សក់ ស៊ុតសាខន ធ្វើជាប្រធាន រ.ជ.រ.ប.ខ. ព្រមទាំងឲ្យគណៈកម្មាធិការកណ្តាលបណ្តោះអាសន្នសង្គ្រោះរ.ជ.រ.ប.ខ.របស់លោក សក់ ស៊ុតសាខន ជំនួសគណៈកម្មាធិការប្រតិបត្តិ ឬ កូមុិច ។ សំណើនេះ មានលក្ខណៈហួសហេតុពេក ដែលនាំឲ្យក្រុមខាងលោកតា សឺន សាន ទាត់ចោលទាំងស្រុង ។ សំណើនេះមានលក្ខណៈធ្ងន់ធ្ងរជាងគោលជំហររបស់អាជ្ញាធរថៃ ដែលបានគិតគូរួចហើយថា "ការងារនយោបាយ និង ការទូតត្រូវទុកជូនលោកតាប្រធាន សឺន សាន ចំណែកឯបញ្ហាការយោធាទុកជូនលោកឧត្តមសេនីយ សក់ ស៊ុតសាខន"។[187] ដូច្នេះកាគីទាំងពីរ ក៏មិនអាចស្វែងរកឯកភាពស្រុះស្រួលគ្នា ដើម្បីបញ្ចប់ជម្លោះនោះឡើយ ។ នៅពេលដែលលោក ឆាវលិត វិលត្រឡប់មកបិទអង្គប្រជុំកាគីខ្មែរគ្មានពាក្យអ្វីដើម្បីធ្វើសេចក្តីសន្និដ្ឋានចុងក្រោយ ជូនលោកមេទ័ពថៃរូបនេះបានឡើយ ។

[187] Ieng Mouly, Briefing on the meeting held on Saturday, January 26, 1986.

លោកឧត្តមសេនីយ ធាវលិត សួរបញ្ជាក់លោកតា ជុន អ៊ុក ថាហេតុអ្វី បានជាមិនទុកលោកតា សឺន សាន ជាប្រធានដដែល តើខុសគ្នាយ៉ាងដូចម្តេចរវាង ប្រធាន និង ប្រធានកិត្តិយស? ដោយក្រុមលោក សក់ ស៊ុតសាខន មិនចង់ពិភាក្សាតទៅទៀតនោះ លោក ធាវលិត ទាំងមិនសប្បាយចិត្ត បានថ្លែងនៅពេលបិទនោះជាអាទិ៍ថា៖ "ដោយសារអស់លោក ដែលជាក្រុមមិនមែនកុម្មុយនីស្ត មិនអាចរួបរួមគ្នាបាន ប្រទេសកម្ពុជានឹងធ្លាក់ទៅក្នុងកណ្តាប់ដៃកុម្មុយនីស្តជាថ្មីទៀត ។ យើងគ្មានសង្ឃឹមថានឹងឃើញប្រទេសខ្មែរជាប្រទេសសេរីទេ ។ ដោយអស់លោកមិនអាចដោះស្រាយបញ្ហាផ្ទៃក្នុងដោយខ្លួនឯងបាននោះ សូមអស់លោករង់ចាំទទួលអនុវត្តតាមវិធានការ ដែលយើងខ្ញុំនឹងចាត់នៅពេលខាងមុខ" ។ ថ្ងៃនោះជាថ្ងៃដ៏អាម៉ាស់មួយចំពោះយើងជាខ្មែរទាំងអស់គ្នា ។

លោក សក់ ស៊ុតសាខន សុំរៀបចំកូម៉ិចជាថ្មី

នៅពេលរង់ចាំសេចក្តីសម្រេចកាត់ក្តីរបស់លោក ធាវលិត ទីបំផុត នៅថ្ងៃទី ២ កុម្ភៈ ១៩៨៦ លោកឧត្តមសេនីយ សក់ ស៊ុតសាខន ក៏បានមកជួបផ្ទាល់ជាមួយលោកតាប្រធាន នៅស្នាក់ការកណ្តាលរបស់ពួកយើងនៅម៉ាយ៉ាឡាប់ ។ លោកតា សឺន សាន បានជំរាបលោក សក់ ស៊ុតសាខន ថាលោកតាបានត្រៀមខ្លួនរួចហើយដើម្បីប្រគល់ភារកិច្ចជាអគ្គមេបញ្ជាការក.ជ.រ.ប.ខ.ជូនលោកឧត្តមសេនីយ ក៏ប៉ុន្តែក្នុងឋានៈជាប្រធាន រ.ជ.រ.ប.ខ. លោកតាត្រូវតែមានការទទួលខុសត្រូវទាំងស្រុងខាងនយោបាយ ស៊ីវិល និង ហិរញ្ញវត្ថុ ។ លោកតា សុំឲ្យលោកឧត្តមសេនីយជួយចាត់ការឲ្យមានសណ្តាប់ធ្នាប់ និង ធ្វើឲ្យមានវិន័យឡើងវិញនៅក្នុងជួរ.ជ.រ.ប.ខ. ។ លោកឧត្តមសេនីយ សក់ ស៊ុតសាខន នៅពេលនោះ មិនបានបញ្ចេញមតិថា គាំទ្រ

ឬ បដិសេធសំណើរបស់លោកតា សឺន សាន នោះទេ ក៏ប៉ុន្តែ បានសុំទុកឱកាសឲ្យគាត់ បានទៅពិភាក្សាជាមួយក្រុមគាត់ រួចសន្យាថានឹងវិលមកជួបលោកតាប្រធានម្តងទៀតនៅថ្ងៃទី ៧ កុម្ភៈ ១៩៨៦ ។ នៅពេលណាត់ជួបគ្នាមកដល់ លោកឧត្តមសេនីយ ក៏មិនបានមកជួបតាមសន្យាឡើយ ។ ពីរថ្ងៃក្រោយមកទៀត ទើបគាត់មកជួប ។ ម្តងនេះ លោកឧត្តមសេនីយគ្រាន់តែអង្គុយស្តាប់ ។ នៅពេលហៀបចេញត្រឡប់ទៅវិញ លោកឧត្តមសេនីយ ក៏ប្រគល់សំបុត្រមួយច្បាប់ជូនលោកតាប្រធាន ។ នៅក្នុងសំបុត្រនោះលោក សក់ ស៊ុតសាខន លើកសំណើ ៣ ចំណុចគឺ៖[188] ១. ទទួលស្គាល់លោកតា សឺន សាន ជាប្រធាន រ.ជ.រ.ប.ខ. ដែលមានអំណាចលើ ផ្នែកនយោបាយ និង ការទូតតែប៉ុណ្ណោះ ២. លោកឧត្តមសេនីយ សក់ ស៊ុតសាខន ត្រូវដើរតួនាទីជាអគ្គមេបញ្ជាការក.ជ.រ.ប.ខ. ដោយមានអំណាចទាំងស្រុងលើផ្នែកយោធា និង ស៊ីវិល ៣. បង្កើតគណៈកម្មការចំពោះកិច្ចមួយដើម្បីរៀបចំជាថ្មីឡើងវិញនូវគណៈកម្មាធិការប្រតិបត្តិរ.ជ.រ.ប.ខ. ។ ចំពោះលិខិតនេះ អ្វីដែលលោកតា សឺន សាន ទទួលមិនបានគឺការដែលលោក សក់ ស៊ុតសាខន សរសេរមកប្រធានរ.ជ.រ.ប.ខ. ក្នុងឋានៈលោកឧត្តមសេនីយជាប្រធាន "គណៈកម្មាធិការកណ្តាលបណ្តោះអាសន្នសង្គ្រោះ រ.ជ.រ.ប.ខ" ដែលលោកតាប្រធានប្រកាសថា ខុសច្បាប់រួចទៅហើយ តាំងពីថ្ងៃទី ១ មករា ១៩៨៦ មកម្ល៉េះ ។ លើសពីនេះទៅទៀត ការកាត់ផ្តាច់មិនឲ្យលោកតា សឺន សាន ទទួលខុសត្រូវផ្នែកស៊ីវិលជារឿងមួយដែលលោកតាប្រធាននឹកមិនដល់ ព្រោះថាប្រធាន រ.ជ.រ.ប.ខ. តែងតែយកប្រជាពលរដ្ឋស៊ីវិល ជាមូលដ្ឋាននៃការគាំទ្រនយោបាយរបស់គាត់ ជាពិសេសប្រជាពលរដ្ឋស៊ីវិលនៅជំរុំសាយធូ ។ លោកតា សឺន សាន សង្កត់ធ្ងន់ថា យក

[188] ឧត្តមសេនីយ សក់ ស៊ុតសាខន, (លិខិត) ជូនចំពោះ ឯកឧត្តម សឺន សាន, ប្រធានណេសិរ្យជាតិរំដោះប្រជាពលរដ្ឋខ្មែរ ថ្ងៃទី ៩ កុម្ភៈ ១៩៨៦ ។

ប្រជាពលរដ្ឋស៊ីវិល ឲ្យស្ថិតនៅក្រោមអំណាចអគ្គមេបញ្ជាការ អាចធ្វើឲ្យបាត់បង់ជំនួយពីអង្គការសហប្រជាជាតិ ដោយសំអាងលើគោលការណ៍អព្យាក្រឹត្យនៃអង្គការនេះដែលនឹងមិនផ្តល់ ឬ នឹងកាត់ជំនួយដល់ប្រជាពលរដ្ឋស៊ីវិល ប្រសិនបើជំនួយរបស់គេធ្លាក់ដល់ដៃក្រុមប្រដាប់អាវុធ ឬ ជំរុំយោធា ។ ម្យ៉ាងទៀត ចំពោះពួកយើងដែលមានកក្តីភាពចំពោះលោកតាប្រធាន មានតែសមាជរ.ជ.រ.ប.ខ.ទេ ទើបអាចធ្វើការរៀបចំជាថ្មី នូវគណៈកម្មាធិការប្រតិបត្តិ រ.ជ.រ.ប.ខ. ឬ កូមុិចបានគឺ មិនមែនគណៈកម្មការចំពោះកិច្ចថ្មីណាមួយដូចដែលលោក សក់ ស៊ុតសាខន ស្នើនោះឡើយ ។ ដោយសារគោលជំហរមិនគោរពប្រធាន និង គោលជំហររឹងត្អឹងរបស់លោកឧត្តមសេនីយបែបនេះ ពួកយើងយល់ថាពួកប្រឆាំងច្បាស់ជាមានអ្នកខាងក្រៅនៅពីក្រោយពុំខានឡើយគឺ អាជ្ញាធរថៃ និង ក្រុមការងារ ។

រ.ជ.រ.ប.ខ. ធ្លាក់កាន់តែជ្រៅទៅក្នុងជ្រោះនៃវិបត្តិផ្ទៃក្នុង

នៅថ្ងៃទី ១៥ កុម្ភៈ ១៩៨៦ លោកតា សឺន សាន បានកោះប្រជុំគណៈកម្មាធិការប្រតិបត្តិ ឬ កូមុិច ។ ក្រោយពីបានពិភាក្សាគ្នារួចមក គណៈកម្មាធិការនេះបានសម្រេចបញ្ឈប់ជាផ្លូវការ នូវតំណែងអគ្គមេបញ្ជាការក.ជ.រ.ប.ខ.របស់លោកឧត្តមសេនីយ សក់ ស៊ុតសាខន[189] (តាមឯកសារផ្លូវការសេចក្តីសម្រេចនោះបានចែង ថាកូមុិចបានយល់ព្រមទទួលយកពាក្យសុំលាលែងតំណែងអគ្គមេបញ្ជាការរបស់លោក សក់ ស៊ុតសាខន ចុះថ្ងៃ ទី ៥ ធ្នូ ១៩៨៥ ប៉ុន្មានថ្ងៃមុនពេលដែលក្រុមលោកឧត្តមសេនីយធ្វើការបះបោរប្រឆាំងលោកតា សឺន សាន) ។ ខុសពីលោក សក់ ស៊ុតសាខន លោក ជៀន ដែល បានត្រូវដកពីតំណែងទាំងអស់គឺ៖ អនុ

[189] Son Sann, KhmerPeople's National Liberation Front, Décret no. 86/03/FNL, Fait le 15 Février 1986.

ប្រធាន ប្រតិភូគណៈកម្មាធិការប្រតិបត្តិទទួលបន្ទុកកិច្ចការយោធា និង នាយអគ្គសេនាធិការនៃ ក.ជ.រ.ប.ខ.[190] ។

នៅក្នុងឱកាសនោះដែរ កូមុិចនេះក៏បានសម្រេចបង្កើតគណៈកម្មាធិការយោធាមួយ[191] ដែលមាន លោក ព្រុំ វិត ជាប្រធាន លោក កែវ ជួន ជាអនុប្រធានទី១ លោក ជា ឈុត ជាអនុប្រធានទី២ លោក អ៊ឹម ឈូដេត ជាទីប្រឹក្សា និង លោក កេត រ៉ែត ជានាយសេនាធិការចំពោះកិច្ច ដើម្បីដឹកនាំកងទ័ពជំនួសលោក សក់ ស៊ុត សាខន និង លោក ជៀន ដែល ។

ការបង្កើតគណៈកម្មាធិការយោធានេះ ជាសារមួយប្រាប់ទៅក្រុមប្រឆាំងថា ទ្វារនៃការសម្រុះសម្រួលគ្នាបានត្រូវបិទហើយៗជាសញ្ញាថាលោកតាប្រធាន សឺន សាន បានប្តេជ្ញាវាយបកទៅក្រុមប្រឆាំងវិញ មិនខ្លាចមានផលវិបាកអ្វី ដែលអាចកើតមាននៅពេលខាងមុខនោះទេ ។ នៅថ្ងៃទី ២១ កុម្ភៈ លោកឧត្តមសេនីយទោ ថៃឈ្មោះ កាសេម ធម្មគោល ដែលយើងហៅតាមឈ្មោះក្រៅរបស់គាត់ថា "ហួណា កេត" បានជម្រាបលោកតា សឺន សាន ថាសេចក្តីសម្រេចរបស់កូមុិចខាងលើនេះ បានធ្វើឲ្យមានប្រតិកម្មជាអវិជ្ជមានពីក្រុមការងារ គឺ គេមិនអាចទទួលយកបានទេ ទាំងការសម្រេចដកលោក សក់ ស៊ុតសាខន ចេញពីតំណែងអគ្គមេបញ្ជាការ ទាំងការប៉ុនប៉ងបំបាត់ក្រុមប្រឆាំង ។ បន្ទាប់មក មិនយូរប៉ុន្មានក្រុមការងារ ក៏ចាប់ផ្តើមធ្វើការគាបសង្កត់មកខាងយើងថែមទៀតមែន ។

[190] Son Sann, KhmerPeople's National Liberation Front, Décret no. 86/04/FNL, Fait le 15 Février 1986.
[191] Son Sann, KhmerPeople's National Liberation Front, Décret no. 86/06/FNL, Fait le 15 Février 1986.

លោកតាទៅតវ៉ាឯប៉េកាំង តែចិនឲ្យសម្រុះសម្រួល

ចាប់តាំងពីថ្ងៃទី ១៥ ទៅ ២១ មីនា ១៩៨៦ អ្នកដឹកនាំរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ បានទៅជួបជុំគ្នានៅទីក្រុងប៉េកាំងនៃប្រទេសចិន ដើម្បីពិភាក្សាគ្នាសម្រេចលើកសំណើសន្តិភាព ៨ ចំណុចសម្រាប់ដំណោះស្រាយស្វែងរកសន្តិភាពនៅកម្ពុជា ។ នៅក្នុងឱកាសនៃទស្សនកិច្ចនោះលោកតា សឺន សាន ក៏បានលើកបញ្ហាផ្ទៃក្នុងរ.ជ.រ.ប.ខ.ជាមួយដៃគូពីរូបទៀតគឺ សម្តេច សីហនុ និង លោក ខៀវ សំផន ។ សម្តេចព្រះប្រធានកម្ពុជាប្រជាធិបតេយ្យ បានគាំទ្រលោកតា សឺន សាន ជាថ្មីម្តងទៀត ។ ឯលោក ខៀវ សំផន ក៏គាំទ្រដែរ ។ ជាមួយអ្នកដឹកនាំចិន លោកប្រធានក៏បានលើកបញ្ហាផ្ទៃក្នុងរ.ជ.រ.ប.ខ.មកពិភាក្សាដែរ ជាពិសេសលោកតាបានតវ៉ាថាមេទ័ពថៃលោក ធាវលិត និង ក្រុមការងារបានលើកទឹកចិត្តឲ្យលោក សក់ ស៊ុតសាខន បំបែកខ្លួនចេញពីអំណាចគ្រប់គ្រងរបស់ប្រធាន រ.ជ.រ.ប.ខ. និង ឲ្យបង្កើតគណៈកម្មាធិការកណ្តាលបណ្តោះអាសន្នសង្គ្រោះ រ.ជ.រ.ប.ខ. ក្នុងន័យដើម្បីឲ្យយោធាថៃ និង ក្រុមការងារអាចយក ក.ជ.រ.ប.ខ. មកដាក់នៅក្រោមបញ្ជាផ្ទាល់របស់ខ្លួន ។ លោកតាតវ៉ាទៀតថា អាជ្ញាធរយោធាថៃបានបង្កើតគណៈកម្មការយោធាខ្មែរមួយហៅថា គណៈកម្មការមេបញ្ជាការ ១០ នាក់ ដែលមានសមាជិកភាពរបស់មេបញ្ជាការ ក.ជ.រ.ប.ខ. ទាំងអស់ចូលរួម ។ គណៈកម្មការនេះ ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់លោកវរសេនីយ វិស្ណុ (ស៊ូរយុទ្ធ ជូឡាណន្ត) ។ លោកតាលើកសំណួរថា តើអាជ្ញាធរយោធាថៃបង្កើតគណៈកម្មការនេះដើម្បីគោលបំណងអ្វី? បើតាមលោកតាយល់ គឺមិនមែនដើម្បីបំរើផលប្រយោជន៍របស់រដ្ឋាភិបាលចម្រុះត្រីភាគីឡើយ ។ លោកតា សឺន សាន បានជំរាបអ្នកដឹកនាំចិនថា លោកតាបានព្យាយាមអញ្ជើញលោកឧត្តមសេនីយ សក់ ស៊ុតសាខន និង

ជៀន ដែល មកដោះស្រាយបញ្ហា ក្នុងឋានៈជាបងប្អូនក្នុងគ្រួសារតែមួយ តែឧត្តមសេនីយទាំងពីរបែបនេះមិនបានជួយកសាងឯកភាពឡើងវិញឡើយ ។ លោកតាប្រធានជំរាបមេដឹកនាំចិនទៀតថា ប្រសិនបើគ្មានការលើកទឹកចិត្តពីខាងក្រៅទេនោះ មេទ័ព រ.ជ.រ.ប.ខ. ទាំងពីរបែបនេះ ប្រាកដជាមិនហ៊ានប្រកាន់យកគោលជំហរប្រឆាំងបែបនេះទេ ។ លោកតា សឺន សាន បានតវ៉ាទៀតថា ចាប់តាំងពីខែ កុម្ភៈមក លោកឧត្តមសេនីយ ឆាវលិត បានបញ្ជាឲ្យផ្អាកផ្តល់ប្រាក់ឧបត្ថម្ភទាំងអស់ដល់ភាគីរបស់គាត់ ផ្ទុយទៅវិញក្រុមលោក សក់ ស៊ុតសាខន នៅតែបន្តទទួលប្រាក់ឧបត្ថម្ភជាហូរហែតឈប់ឈរឡើយ ។ លោកតាតវ៉ាថាសូម្បីតែជំនួយហិរញ្ញវត្ថុចិនដែលចិនផ្តល់ដល់លោកតាផ្ទាល់ ក៏ពុំបានទទួលផង ។ លោកតាប្រធានបន្ថែមទៀតថា នៅពេលដែលខ្លួនគាត់មិនអាចរកជួបលោកឧត្តមសេនីយ ឆាវលិត ផ្ទាល់នោះ ភរិយារបស់លោក ឆាវលិត ត្រឡប់ទៅជាមកបង្ខំឲ្យលោកតាយល់ព្រមលក់ដីនៃស្ថានទូតខ្មែរនៅទីក្រុងតូក្យូនាប្រទេសជប៉ុនទៅវិញ ។ ក៏ប៉ុន្តែ លោកតាប្រកែក ។ មែនទែនទៅ ខាងក្រុមខ្មែរក្រហម បានយល់ព្រមឲ្យលក់ដីស្ថានទូតនេះ ព្រោះគេយល់ថាបញ្ហានយោបាយសំខាន់ជាងបញ្ហាហិរញ្ញវត្ថុ (គេចង់និយាយថាពួកគេមិនខ្វះលុយកាក់ទេ ក៏ប៉ុន្តែការដែលគេចង់ឲ្យលក់នោះ ព្រោះគេត្រូវការឲ្យលោកឧត្តមសេនីយ ឆាវលិត ជួយគាំទ្រគេតទៅទៀត) ។ ចំណែកឯខាងភាគី សម្តេច សីហនុ ចាំតែព្រមតាម បើភាគីខ្មែរក្រហម និង រ.ជ.រ.ប.ខ. ស្រុះស្រួលគ្នាថាលក់ខាងសម្តេចក៏លក់ ។ ខាង រ.ជ.រ.ប.ខ. លោកតា សឺន សាន ប្រកាន់គោលជំហរថាមិនលក់ទេ តែខាងឧត្តមសេនីយ ជៀន ដែល ចោទប្រកាន់ថា ខាងលោកតាយល់ព្រមលក់ទៅវិញ ។ តាមពិតទៅ លោកតា សឺន សាន បានសម្រេចថាមិនព្រមឲ្យលក់ដីនេះទេ តែលោកតាបានតែងតាំងកូនប្រុសរបស់លោកតាម្នាក់ទៀតឈ្មោះ សឺន មុនា ដែលជាស្ថាបត្យករឲ្យឡើងធ្វើជាអ្នកជំនាញការ ដើម្បីធ្វើការវាយតម្លៃដី

ស្ថានទូតនៅតូក្យូមានតម្លៃពិតប្រាកដប៉ុន្មាន? ត្រង់ចំណុចនេះហើយដែលធ្វើឲ្យក្រុមប្រឆាំងលើកឡើងថា បើមិនព្រមលក់ ហេតុអ្វីបានជាចាត់អ្នកជំនាញការឲ្យទៅវាយតម្លៃដី?

តាមរបាយការណ៍នៃទស្សនកិច្ចនៅប្រទេសចិនបានឲ្យដឹងថាតាំងពីនាយកដ្ឋានកិច្ចការអាស៊ីនៃក្រសួងការបរទេស រហូតដល់លោកអគ្គលេខាបក្សកុម្មុយនីស្តចិន ហ៊ូ យ៉ៅបាង (Hu Yaobang) សុទ្ធតែបានផ្តល់មតិជូនលោកតា សឺន សាន ថា លោកតាត្រូវតែថែរក្សាឲ្យបាននូវឯកភាពផ្ទៃក្នុងរបស់រ.ជ.រ.ប.ខ. ។ លោកអនុរដ្ឋមន្ត្រីក្រសួងការបរទេសចិន លីវ ស៊ូគីង (Liu Shuquing) បានជំរាបលោកតាប្រធានថា "ក្នុងហានៈជាមិត្តរបស់រ.ជ.រ.ប.ខ. ប្រទេសចិនមានការបារម្ភចំពោះវិបត្តិផ្ទៃក្នុងរបស់រណសិរ្សនេះណាស់ ហើយមិនអាចធ្វើអន្តរាគមន៍ ឬ កាត់សេចក្តីយ៉ាងដូចម្តេចទេ" ។ អ្វីដែលចិនអាចធ្វើបានគឺ លើកទឹកចិត្តឲ្យគ្រប់ភាគីក្នុងជម្លោះផ្ទៃក្នុងនេះរួបរួមគ្នាឡើងជៀសវាងកុំឲ្យជម្លោះនោះ ក្លាយទៅជាបំរើផលប្រយោជន៍នៃការឃោសនាប្រឆាំងចលនាតស៊ូឲ្យទៅខាងកងទ័ពឈ្លានពានវៀតណាមទៅវិញ ។ ក្នុងហានៈជាមិត្ត ប្រទេសចិនមានសំណូមពរសូមឲ្យអ្នកដឹកនាំរដ្ឋាភិបាលចម្រុះពង្រឹងសាមគ្គីភាពរវាងគ្នានិងគ្នា និង សូមឲ្យភាគីនីមួយៗនៃរដ្ឋាភិបាលចម្រុះ ពង្រឹងសាមគ្គីភាពផ្ទៃក្នុងរបស់ខ្លួន ។ អ្នកដឹកនាំចិន ជាពិសេសលោកអនុរដ្ឋមន្ត្រីការបរទេសលើកមតិឡើងថាប្រទេសថៃជារណសិរ្សជួរមុខរបស់យើង ។ យើងត្រូវការប្រទេសថៃ ដើម្បីជាច្រកដឹកជញ្ជូនកងទ័ព និង ស្បៀងដល់យុទ្ធជនខ្មែរដែលកំពុងប្រយុទ្ធប្រឆាំងកងទ័ពបរទេសឈ្លានពាន ។ ដូច្នេះសាមគ្គីជាមួយប្រទេសថៃ ជាការចាំបាច់បំផុត ដើម្បីឲ្យសម្រេចជោគជ័យក្នុងការតស៊ូរបស់យើងទាំងអស់គ្នា ។ សរុបសេចក្តីទៅ ប្រទេសចិនបានណែនាំឲ្យលោកតា សឺន សាន ខឹតខំយកចិត្តទុកដាក់ធ្វើការឲ្យបានជិតស្និទ្ធជាមួយលោកឧត្តមសេនីយ ឆាវលិត ។

ជាគោលការណ៍ លោកតា សឺន សាន បានត្រៀមខ្លួនរួចហើយដើម្បីប្រគល់អំណាចឲ្យលោកឧត្តមសេនីយ សក់ ស៊ុតសាខន កាន់តំណែងជាអគ្គមេបញ្ជាការ ក៏ប៉ុន្តែ លោកតានៅតែព្យាយាមបញ្ចូលមនុស្សរបស់គាត់ បានចូលកាន់តំណែងសំខាន់ៗនៅក្នុងជួរកងទ័ព.ជ.រ.ប.ខ. ។ មុនពេលលោកតាប្រធានចេញដំណើរទៅទីក្រុងប៉េកាំង លោកតា សឺន សាន បានស្នើដល់លោកដល់លោក ឆាវលិត ថា ប្រសិនបើលោក សក់ ស៊ុត សាខន ត្រូវបានជាអគ្គមេបញ្ជាការ លោកឧត្តមសេនីយ រូបនេះត្រូវធ្វើការជាមួយលោក អ៊ឹម ឈូដេត និង លោក ឈឹម ឱមយ៉ុន នៅអគ្គបញ្ជាការដ្ឋាន និង ជាមួយលោក ថាច់ រ៉េង នៅសមរភូមិមុខ ឬ នៅឯទល់ដែន ។ សំណើនេះ មានតម្លៃស្មើនឹងការជ្រៀតជ្រែកក្នុងកិច្ចការយោធា ដែលធ្វើឲ្យក្រុមលោក សក់ ស៊ុតសាខន មិនអាចទទួលយកបាន ។ ការដែលលោកតាប្រធានចង់នាំយកលោក ថាច់ រ៉េង មកចូលក្នុងបញ្ជាការយោធាជារឿងមិនអាចយកមកនិយាយបានឡើយសម្រាប់ក្រុមប្រឆាំង ព្រោះថាអស់ពេលជាច្រើនឆ្នាំមកហើយ ដែលលោក ថាច់ រ៉េង បានរិះគន់លោកឧត្តមសេនីយ សក់ ស៊ុតសាខន និងមនុស្សរបស់គាត់ អំពីអសមត្ថភាពក្នុងការដឹកនាំ និង គ្រប់គ្រងក.ជ.រ.ប.ខ.។ ម្យ៉ាងទៀត ទាំងអស់នេះ ក៏ប្រហែលជាយុទ្ធសាស្ត្រមួយរបស់លោក ឆាវលិត ដើម្បីកុំឲ្យមានកងទ័ពខ្មែរអ្នកជាតិនិយមណាមួយ ដែលមានការគាំទ្រពីប្រជាពលរដ្ឋខ្មែរអាចធ្វើការប្រយុទ្ធបានតាមផ្លូវយោធា ។ ពេលនោះ ប្រហែលជាលោក ឆាវលិត និងមិត្តភក្តិអាស៊ានយល់ថាដល់ពេលវេលា ដែលគេត្រូវស្វែងរកដំណោះស្រាយនយោបាយ មិនមែនជាការបង្កើនការវាយប្រហារតាមកម្លាំងយោធាឡើយ ។ ប្រសិនបើគេទុកឱកាសឲ្យក.ជ.រ.ប.ខ.មានឱកាសរៀបចំខ្លួន និង អាចបង្កើនសមត្ថភាពយោធា អាចកើតចេញជាស្ថានភាពយោធាមួយដែលពិបាកគ្រប់គ្រងផង ។ ផ្ទុយទៅវិញ នយោបាយរបស់លោក ឆាវលិត ដែលទុកឲ្យកម្លាំងខ្មែរក្រហមនៅរស់រាន និង

សកម្មប្រយុទ្ធជានយោបាយមួយដែលធ្វើឲ្យប្រទេសចិនសប្បាយចិត្ត ។ នយោបាយបែបនោះ អាចយល់ថាខ្មែរក្រហមមិនអាចជាឧបសគ្គអ្វីធំដុំសម្រាប់ដំណោះស្រាយនយោបាយណាមួយឡើយ ព្រោះអំពើប្រល័យពូជសាសន៍របស់ពួកគេបានត្រូវពិភពលោកទាំងមូលផ្តន្ទាទោស និង ស្អប់ខ្ពើមបំផុត ម្យ៉ាងទៀតព្រោះថាខ្មែរក្រហមពឹងផ្អែកទាំងស្រុងលើជំនួយ និង ការគាំទ្រពីថៃ និង ចិនមួយរយៈកាលរយ ។ ថៃ និង ចិនរួមគ្នាក្នុងការប្រឆាំងនឹងការកាន់កាប់ប្រទេសខ្មែរ ដោយកងទ័ពវៀតណាម ។ ប្រសិនបើចិន និង ថៃប្រាប់ឲ្យខ្មែរក្រហមឈប់ច្បាំង ខ្មែរក្រហមពុំអាចប្រកែកបានទេ ព្រោះខ្មែរក្រហមមិនអាចសុំជំនួយពីប្រទេសណាដទៃក្រៅពីចិន និង ថៃបានឡើយ ។

ចំពោះខ្ញុំៗយល់ថា ប្រទេសថៃលេងសន្លឹកបៀចិន នៅពេលដែលមានបញ្ហាទាក់ទងនឹងសន្តិសុខផ្ទាល់របស់ថៃ ។ ថៃលេងបៀអាស៊ាន និង/ឬ សន្លឹកបៀអាមេរិក កាលណាមានបញ្ហាសន្តិសុខតំបន់ និង/ឬ សន្តិសុខពិភពលោក ។ ខ្ញុំយល់ថាការលេចចេញឡើងនូវក្រុមលោក សក់ ស៊ុតសាខន ដាច់ដោយឡែកពីរដ្ឋាភិបាលចម្រុះ គឺដោយសារកម្លាំងយោធារបស់រដ្ឋាភិបាលនេះ បានស្ថិតនៅក្រោមឥទ្ធិពលផ្តាច់មុខរបស់ខ្មែរក្រហមរួចទៅហើយ ។ ការបង្កើតក្រុមថ្មីមួយ ដែលហាក់ដូចជាមិនពាក់ព័ន្ធជាមួយខ្មែរក្រហមទេនោះ អាចឲ្យសហរដ្ឋអាមេរិកផ្តល់ជំនួយដល់ក្រុមអ្នកជាតិនិយម ឬ ចលនាតស៊ូមិនមែនកុម្មុយនីស្ត បើមិនផ្តល់ជំនួយខាងអាវុធក៏ផ្តល់ជំនួយយោធាក្រៅពីអាវុធផង ។ ចំពោះលោកឧត្តមសេនីយ ឆាវលិត អ្វីក៏ល្អទាំងអស់ឲ្យតែមានជំនួយ ព្រោះជំនួយទាំងនោះ ទាំងមកពីចិន ទាំងមកពីអាមេរិក ឬ មកពីប្រទេសលោកខាងលិចទាំងអស់ សុទ្ធតែត្រូវឆ្លងកាត់ប្រទេសថៃទាំងអស់ ។ ខ្ញុំអាចវាយតម្លៃថាជំនួយទាំងអស់ ដែលឆ្លងតាមថៃនោះត្រូវថៃកាត់យកប្រហែល ៧០% រីឯខាងខ្មែរទទួលបានតែ ៣០% តែប៉ុណ្ណោះ ។

មានគេសរសេរខុសពីរឿងវិបត្តិផ្ទៃក្នុង រ.ជ.រ.ប.ខ.

ចំពោះបញ្ហាវិបត្តិផ្ទៃក្នុងរវាងលោកតា សឺន សាន ជាមួយលោកឧត្តមសេនីយ សក់ ស៊ុតសាខន នោះ ក្នុងពេលថ្មីៗនេះខ្ញុំបានអានសៀវភៅមួយក្រោមចំណងជើងថា "រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ.ជ.រ.ប.ខ." ដែលក្នុងនោះអ្នកនិពន្ធឈ្មោះ គង់ ថាន់ បានសរសេរយ៉ាងប្រថុយប្រថានថា៖ "បុព្វហេតុនៃការបែកបាក់រវាងភាគី សឺន សាន និង សក់ ស៊ុតសាខន ក្នុងជួរ.ជ.រ.ប.ខ. ដែលកើតឡើងតាំងពីឆ្នាំ១៩៨២ មកផ្សំឡើងដោយព្រឹត្តិការណ៍សំខាន់ៗច្រើន យ៉ាងមានជាអាទិ៍៖ ..... ឧត្តមសេនីយ សក់ ស៊ុតសាខន និង ឧត្តមសេនីយ ជៀន ដែល ធ្លាប់ស្នើលោកប្រធាន សឺន សាន ឲ្យដកលោក អៀង មូលី ចេញពីតំណែងអគ្គលេខាធិការ រ.ជ.រ.ប.ខ. តែលោកប្រធានមិនគ្រាន់តែមិនព្រមទេ តែឲ្យលោក អៀង មូលី កាន់លុយរ.ជ.រ.ប.ខ.ថែមទៀត" ។ ជាការគួរឲ្យស្តាយដែលអ្នកនិពន្ធរូបនោះ ដែលខ្ញុំស្គាល់អតីតកាលដ៏ច្បាស់ ពុំបានធ្វើការស្រាវជ្រាវឲ្យស៊ីជំរៅ ឬមកសួរខ្ញុំផ្ទាល់ ព្រោះខ្ញុំក៏អាចផ្តល់ព័ត៌មានច្បាស់លាស់ ដែលអាចនាំឲ្យសៀវភៅនោះ ក្លាយជាសៀវភៅមួយ ដែលគេអាចយកទៅប្រើការជាឯកសារយោង ឬ អាចជាទំនុកចិត្តបាន ។ តាមពិតទៅ ពុំមានទំនាស់រវាងលោកតាប្រធាន សឺន សាន និងឧត្តមសេនីយ សក់ ស៊ុតសាខន នៅឆ្នាំ ១៩៨២ នោះទេ ។ នៅសម័យនោះ នៅពេលដែលលោកឧត្តមសេនីយ សក់ ស៊ុតសាខន បានមកដល់ទឹកដីនៃតំបន់រំដោះរបស់រ.ជ.រ.ប.ខ. ក្រុមលោកឧត្តមសេនីយ ជៀន ដែល បានសម្លឹងឃើញថាលោកតា សឺន សាន មានបំណងយកលោក សក់ ស៊ុតសាខន ឲ្យមកត្រួតពីលើពួកគាត់ ឬ ឲ្យមកជំនួសផងក៏បាន ។ កាលពេលនោះ ក្រុមលោក ជៀន ដែលយល់ថាលោក សក់ ស៊ុតសាខន ជាមនុស្សរបស់លោកតា សឺន សាន ដូច្នេះគ្មាន

ទំនាស់អ្វីរវាងលោកតាប្រធាន និង លោកឧត្តមសេនីយ សក់ ស៊ុតសាខន ដូចសៀវភៅខាងលើបានលើកឡើងនោះទេ ។ ទំនាស់រវាងលោកតា សឺន សាន និង លោកឧត្តមសេនីយ សក់ ស៊ុតសាខន កើតឡើងនៅចុងឆ្នាំ ១៩៨៥ ដោយសារតែលោកតាប្រធាន បានបណ្តេញសហការីជំនិតពីររូបរបស់លោក សក់ ស៊ុតសាខន គឺលោក ហ៊ីង គន្ធុន និង លោក ហ្គាហ្សា ពងម៉េត ពីរ.ជ.រ.ប.ខ. ដែលត្រូវក្រុម លោក តា សឺន សាន ចោទប្រកាន់ថាខ្វះវិន័យ និង ធ្វើការបំបែកបំបាក់ឯកភាពផ្ទៃ ក្នុងរបស់រ.ជ.រ.ប.ខ. ។ ចំណែកឯរូបខ្ញុំ ខ្ញុំបានឡើងមកកាន់តំណែងជាអគ្គលេខាធិការរ.ជ.រ.ប.ខ នៅឆ្នាំ ១៩៨៨ គឺ នៅក្រោយពេលដែលទំនាស់នោះកើតរួចហើយជិតបីឆ្នាំឯណោះ ។ ដូច្នេះ ការបកស្រាយរបស់អ្នកនិពន្ធនៃសៀវភៅដែលមានចំណងជើងថា "រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ និង ដំណើរឆ្ពោះទៅរកសន្តិភាពនោះ" ជាការបកស្រាយខុសពីការពិតខ្លាំងណាស់ ។ ក្រុមលោក សក់ ស៊ុតសាខន បានព្យាយាមសុំចូលមកជំនួសខ្ញុំ នៅក្នុងក្រុមប្រឹក្សាជាតិជាន់ខ្ពស់ កម្ពុជា (SNC) មែនចាប់ពីចុងឆ្នាំ ១៩៩០ ក៏ប៉ុន្តែដោយសារសេកម្មភាពបំបែកខ្លួន របស់ក្រុមគាត់ពីការគ្រប់គ្រងរបស់ប្រធានរ.ជ.រ.ប.ខ. ទើបលោក សក់ ស៊ុតសាខន មិនបានចូលជាសមាជិក អេស អ៊ិន ស៊ី ជារៀងរហូតមក ។ តាមពិតទៅប្រជាប្រិយភាពរបស់ក្រុមឧត្តមសេនីយ សក់ ស៊ុត សាខន - ដៀន ដែល បើប្រៀបធៀបទៅក្រុមលោកតា សឺន សាន នៅមានកំរិតទាប ។ ហេតុដូច្នេះ ទើបក្រុមនេះមានការលំបាកក្នុងការរើសយុទ្ធជនឲ្យចូលទៅបំរើក.ជ.រ.ប.ខ. ។ ក្នុងសៀវភៅដដែលនេះ អ្នកនិពន្ធបានសរសេរថា លោកឧត្តមសេនីយ សក់ ស៊ុតសាខន បានរាយការណ៍ជូនក្រុមការងារ អំពីការលំបាករបស់ក្រុមគាត់ក្នុងការរើសទាហានឲ្យបានគ្រប់តាមការកំណត់មានជាអាទិថាៈ "ក្នុងគោលបំណងទប់ទល់មិនឲ្យប្រជាពលរដ្ឋ និង យុទ្ធជនចូលបំរើ ក.ជ.រ.ប.ខ. លោក អៀង មូលី និង លោក អ៊ឹម

ឈូដេត បានឃោសនាក្នុងខែ តុលា ១៩៨៨ ឲ្យប្រជាពលរដ្ឋរង់ចាំ ព្រោះលោក ប្រធាននឹងបង្កើតស្ថាប័នស៊ីវិលឈ្មោះថា "ស្ថាប័នជាន់ខ្ពស់" ដែលមានប្រាក់ខែ និង សម្ភារៈប្រើប្រាស់គ្រប់គ្រាន់" ។ មែនទែនទៅ នៅសម័យនោះ ខ្ញុំមិនដែលបាន ដឹងពីការរើសទាហានឲ្យទៅបម្រើក្នុងជួរ ក.ជ.រ.ប.ខ. ទេ ដូច្នេះធ្វើដូចម្តេចខ្ញុំអាច ទប់ទល់កុំឲ្យក្រុមលោក សក់ ស៊ុតសាខន ចូលមករើសបាន? រឿងដែលអាចកើត នោះ ប្រហែលជាអាចកើតឡើងតាមរយៈយុទ្ធវិធីទប់ស្កាត់ ឬ ប្រណាំងប្រជែងគ្នា នៅក្នុងចំណោមនាយទាហាន ឬ មេដំរុនៅឯជាយដែនឯនោះទេដែលពួកគេប្រើ ដើម្បីយកឈ្នះរៀងៗខ្លួន ។

លោកតា សឺន សាន ចង់ដកលោក នាង ជិន ហាន

អស់រយៈពេលជាច្រើនខែ លោកតា សឺន សាន នៅតែព្យាយាមទប់ទល់នឹង ការគាបសង្កត់គ្រប់ប្រភេទ ។ លោកតាប្រធាន មិនបានបោះបង់ចោលចិត្តគំនិត ដែលចង់រក្សាក.ជ.រ.ប.ខ.ឲ្យស្ថិតនៅក្រោមអំណាចរបស់លោកតាទេ ។ នៅពេល នោះ ទោះបីជាលោកអគ្គលេខាធិការ នាង ជិនហាន នៅបន្តធ្វើការជាមួយក៏ដោយ ក៏លោកតា សឺន សាន ហាក់ដូចជាមិនទុកចិត្តទាល់តែសោះ ព្រោះថាលោកអគ្គ លេខាធិការ នៅតែបន្តទំនាក់ទំនងយ៉ាងល្អជាមួយក្រុមលោកឧត្តមសេនីយ សក់ ស៊ុតសាខន និង គណៈកម្មាធិការកណ្តាលបណ្តោះអាសន្នសង្គ្រោះរ.ជ.រ.ប.ខ. (PCCS) រហូតមក ។ មិនទុកចិត្តព្រោះថាក្រុមរបស់លោក សក់ ស៊ុតសាខន ត្រូវ បានប្រកាសដោយប្រធានថាជាអង្គការចាត់តាំងខុសច្បាប់ ។ នៅក្នុងកំណត់ ចំណាំសម្ងាត់មួយ លោកអគ្គលេខា នាង ជិនហាន បានផ្តល់មតិជូនលោកតា ប្រធាន សូមឲ្យលោកតាវាយតម្លៃគោលជំហររបស់លោកតាឡើងវិញ ទាំងចំពោះ

មុខលោក ឆាវលិត ទាំងចំពោះក្រុមការងារ ដែលមានលោក ស៊ូរយុទ្ធ ជូឡាណន្ត ជាប្រធាន ។ ក្នុងកំណត់ចំណាំនោះ លោកអគ្គលេខាផ្តល់មតិ ជូនលោកតាប្រធាន ថា សេចក្តីសម្រេចថ្មីៗ ដែលមានការបញ្ចប់មុខនាទីអគ្គមេបញ្ជាការ ក.ជ.រ.ប.ខ. របស់លោក សក់ ស៊ុតសាខន ផងនោះ មិនបានទទួលការគាំទ្រពីលោក ឧត្តមសេនីយ ឆាវលិត និង ពីក្រុមការងារទេ ។ លោកអគ្គលេខា នាង ជិនហន ផ្តល់យោបល់ថាលោកតាប្រធានគួរតែស្ថិតនៅឲ្យខ្ពស់ ផុតពីអ្នកឯទៀតក្នុងហាន:ជាមេដឹកនាំពិតប្រាកដ និង តែមួយគត់នៃរ.ជ.រ.ប.ខ. គឺនៅឲ្យផុតពីជម្លោះ ។ លោក នាង ជិនហន ស្នើថាលោកប្រធានគួរតែចេញទៅក្រៅមួយរយៈ ដូចជាធ្វើដំណើរទៅ អូស្ត្រាលី ឬ ទៅទ្វីបអឺរ៉ុប ។ ទោះជាលោកតាប្រធានមានការសង្ស័យថា លោក នាង ជិនហន មិនមានភក្តីភាពចំពោះលោកតាក៏ដោយ ក៏នៅទីបញ្ចប់ លោកតា សឺន សាន យល់ព្រមតាមយោបល់របស់លោកអគ្គលេខារូបនេះដែរ ។ ដំណើរលើកដំបូងរបស់លោកតា សឺន សាន នៅប្រទេសអូស្ត្រាលីបានទទួលជោគជ័យគួរឲ្យកត់សម្គាល់ ព្រោះបានធ្វើឲ្យប្រកពព័ត៌មានអន្តរជាតិបង្វែរការផ្សព្វផ្សាយពីជម្លោះផ្ទៃក្នុងរបស់ រ.ជ.រ.ប.ខ មកផ្សព្វផ្សាយជាវិជ្ជមានអំពីទស្សនកិច្ចនេះទៅវិញ ។

លោកតា សឺន សាន មិនពេញចិត្តលោក នាង ជិនហន ទេ ព្រោះជាយូរឆ្នាំមកហើយលោក នាង ជិន ហន តែងតែចេញទៅសម្រាកនៅក្រៅម៉ាយ៉ាឡាប់ និងតែងតែចេញចូលពែរមីកូ មិនដែលដាច់ ។ ម្យ៉ាងទៀត នៅពេលដែលពួកយើងមិនអាចចេញចូលជំរុំបាន លោក នាង ជិនហន អាចធ្វើដំណើរទៅទល់ដែនបានជាពិសេស ទៅជំរុំណាំយឺន ដោយមិនចាំបាច់មានការយល់ព្រមពីលោកតាប្រធានផង ។ នៅឆ្នាំ ១៩៨៣ លោកតា សឺន សាន បានចេញបញ្ជាឲ្យលោកអគ្គលេខា នាង ជិនហន សិក្សាស្រាវជ្រាវអំពីដំណោះស្រាយកម្ពុជាដូចជា៖ អំពីការចរចារួចបន្ទាប់មកអំពីការបោះឆ្នោតជាដើម ។ នៅឆ្នាំ ១៩៨៧ លោកតា សឺន សាន

បានចេញលិខិតរំលឹកថាតាំងពីឆ្នាំ ១៩៨៣ រហូតមក លោកតានៅមិនទាន់បានទទួលលទ្ធផលការងារនៃការស្រាវជ្រាវនោះទេ និង បានកំណត់ថ្ងៃចូលឆ្នាំខ្មែរ ១៩៨៧ ឲ្យលោក នាង ជិនហាន ប្រគល់ជូនលោកតានូវគំរោងការស្រាវជ្រាវទាំងនោះជាកំហិត ។ ទាំងនេះ ទំនងជាចំណុចស្តីបន្ទោស ដែលលោកតាប្រធានលើកឡើង សម្រាប់ជាហេតុផលមួយដើម្បីដកលោកអគ្គលេខាធិការពីតំណែងក្នុងពេលខាងមុខ ។

មេទ័ពថៃបញ្ជាឲ្យលោក ថាច់ រ៉ែង ចេញពីទឹកដីថៃ

នៅពេលដែលលោកតា សឺន សាន កំពុងធ្វើទស្សនកិច្ចនៅទ្វីបអឺរ៉ុប នៅទីក្រុងបាងកក អាជ្ញាធរថៃបានចាត់វិធានការមួយជំហានទៀត ដើម្បីកាត់ផ្តាច់លោកតា សឺន សាន ពីការងារយោធា ។ នៅថ្ងៃទី ០៩ មិថុនា ១៩៨៦ ហួណាម៉ុល (សុមេធ ទៀនផេង) បានឲ្យលោក ប៊ុន សាយ អគ្គលេខាធិការរង រ.ជ.រ.ប.ខ. នាំលោក ថាច់ រ៉ែង ទៅជួបលោកឧត្តមសេនីយថៃ កាសេម ធម្មគោល ឬ ហួណា កេត នៅផ្ទះសុវត្ថិភាពស្ថិតនៅកន្លែងមួយឈ្មោះសយអារីយ៍ ឬ ច្រកអារីយ៍ នៅថ្ងៃបន្ទាប់ ។ ស្អែកឡើងនៅថ្ងៃទី ១០ មិថុនា លោក ប៊ុន សាយ ក៏នាំលោក ថាច់ រ៉ែង ទៅជួបលោក កាសេម តាមកាលកំណត់ ។ ពេលទៅដល់ផ្ទះសុវត្ថិភាពនោះ ហួណាម៉ុល បានផ្តល់ដំណឹងថាលោកឧត្តមសេនីយ ជាប់រវល់ក្នុងការងារជាបន្ទាន់ មិនបានមកជួបលោក ប៊ុន សាយ និង ថាច់ រ៉ែង នៅពេលនោះទេ ។ ក៏ប៉ុន្តែ លោកមេទ័ពកាសេម បានផ្តាំឲ្យលោកម៉ុលនាំសារដូចតទៅនេះមកឲ្យមន្ត្រី រ.ជ.រ.ប.ខ.ទាំងពីររូបគឺ៖[192] "សកម្មភាពពិសេស ដែលបានព្រមព្រៀងគ្នារវាងលោកប្រធាន សឺន សាន និង លោកឧត្តមសេនីយ ឆាវលិត បានដល់ទីបញ្ចប់ហើយៗមិនតែ

[192] Boun Say, Note à S.E. le Président du FNLPK, Document Secret, 21 Juin 1986.

ប៉ុណ្ណោះ សកម្មភាពពិសេសនោះ ក៏ជ្រុលជ្រួសហួសពីកិច្ចព្រមព្រៀងនោះផង ។ វត្តមានរបស់ឧត្តមសេនីយ ថាច់ រ៉ែង បានបង្កឲ្យមានការខ្វែងមតិគ្នារវាងក្រសួងការបរទេសថៃ និង កងទ័ពថៃ ។ ក្រោយពីបានពិគ្រោះជាមួយក្រសួងមានសមត្ថកិច្ចនានាមកអាជ្ញាធរថៃ សូមឲ្យលោក ថាច់ រ៉ែង ចាកចេញពីទឹកដីថៃនៅថ្ងៃទី ១២ មិថុនា ១៩៨៦" ។

សារនេះហាក់ដូចជារន្ទះបាញ់ចំពីលើលោក ថាច់ រ៉ែង ។ នៅចំពោះមុខសេចក្តីសម្រេចរបស់អាជ្ញាធរយោធាថៃ ដែលមានលក្ខណៈជាទណ្ឌកម្មដាច់ណាត់ដ៏ធ្ងន់ធ្ងរនេះ លោក ថាច់ រ៉ែង មិនអាចតវ៉ាអ្វីក្រៅពីខំព្យាយាមរំលឹកថា មុនពេលចេញដំណើរ លោកតាប្រធានបានផ្តាំផ្ញើអង្វរករឲ្យអាជ្ញាធរថៃរង់ចាំលោកតាវិលត្រឡប់មកបាងកកវិញសិន មុននឹងសម្រេចរឿងសំខាន់ៗបែបនេះ ។ ជាមួយនោះ លោក ថាច់ រ៉ែង ខំអង្វរអាជ្ញាធរឲ្យអនុញ្ញាតឲ្យគាត់អាចស្នាក់នៅបានរហូតដល់ដំណាច់ខែ មិថុនា ។ ពាក្យសុំទាំងប៉ុន្មានរបស់លោកឧត្តមសេនីយ ថាច់ រ៉ែង បានត្រូវច្រានចោលទាំងអស់នៅពេលរសៀលថ្ងៃនោះ ។ លើកនេះ ក្រុមយោធាថៃចាត់វិធានការកាត់ផ្តាច់ដៃជើងរបស់លោកតា សឺន សាន ទាំងអស់ ។ លោក ថាច់ រ៉ែង ក៏គ្មានជំរើសអ្វីក្រៅពីចាកចេញពីទឹកដីថៃតែប៉ុណ្ណោះ ។

វិបត្តិផ្ទៃក្នុងបានត្រូវបញ្ចប់

នៅទីបំផុត លោកតា សឺន សាន បានត្រូវបង្ខំចិត្តបញ្ចប់វិបត្តិផ្ទៃក្នុងនេះក្នុងជួរ.ជ.រ.ប.ខ. ។ តាមក្រឹត្យចុះថ្ងៃទី ១១ មករា ១៩៨៧ លោកតាប្រធានបានធ្វើប្រតិភូកម្មឡើងវិញក្នុងការផ្តល់អំណាចជាអគ្គមេបញ្ជាការក.ជ.រ.ប.ខ. ជូនលោកឧត្តមសេនីយ សក់ ស៊ុតសាខន ដោយកំរិតឲ្យលោកឧត្តមសេនីយរូបនេះទទួល

បន្ទុកតែត្រឹមការងារផ្នែកកងទ័ពតែប៉ុណ្ណោះ[193] ។ ក្រឹត្យតែងតាំងនេះ ត្រូវមានភ្ជាប់ដោយឧបសម្ព័ន្ធ ដែលមានបីចំណុចមួយផង ដែលកំណត់លក្ខខណ្ឌនៃមុខតំណែងអគ្គមេបញ្ជាការ៖ ១. អគ្គមេបញ្ជាការត្រូវជួយប្រធាន រ.ជ.រ.ប.ខ. ដើម្បីរៀបចំឲ្យមានឡើងវិញនូវឯកភាពច្បាប់ទម្លាប់ និង សណ្តាប់ធ្នាប់ក្នុងក្របខ័ណ្ឌបទបញ្ជាទាំងឡាយរបស់រ.ជ.រ.ប.ខ. ជាពិសេសខាងផ្នែកយោធា ។ ២. អគ្គមេបញ្ជាការត្រូវរាយការណ៍ជូនប្រធានអំពីកិច្ចប្រតិបត្តិយោធាសំខាន់ៗ - អំពីការគ្រប់គ្រងចាត់ចែងប្រើប្រាស់មូលនិធិនៃក.ជ.រ.ប.ខ - អំពីគោលគំនិត និង យុទ្ធសាស្ត្រនៃក.ជ.រ.ប.ខ. - អំពីការបង្កើតថ្មី ឬ ការរំលាយចោលនូវកងឯកភាពណាមួយ ។ ៣. អគ្គមេបញ្ជាការត្រូវលើកសំណើជូនប្រធានអំពីការរៀបចំឡើងវិញ នូវអគ្គបញ្ជាការដ្ឋានក.ជ.រ.ប.ខ. ។ ប្រធានអាចតែងតាំង ឬ បញ្ឈប់នូវមន្ត្រីយោធាជាន់ខ្ពស់នៅក្នុងអគ្គបញ្ជាការដ្ឋាន បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយអគ្គមេបញ្ជាការ ។ លក្ខខណ្ឌទាំងប៉ុន្មានខាងលើនេះ បានបង្ហាញឲ្យឃើញថាលោកតា សឺន សាន នៅតែអាចលូកដៃចូលក្នុងកិច្ចការយោធាបាន ។

នៅពេលបានទទួលឯកសារតែងតាំងប្រកបដោយលក្ខខណ្ឌនេះ លោកឧត្តមសេនីយ សក់ ស៊ុតសាខន បានចារផ្ញើរដៃត្រឡប់មកវិញជាភាសាបារាំង ដែលមានន័យជាអាទិថា៖ "បានឃើញ បានដឹង ឬ និង យល់ព្រមទទួល ក៏ប៉ុន្តែលក្ខខណ្ឌ ដែលមានចែងនៅក្នុងឧបសម្ព័ន្ធនៃការតែងតាំងមុខតំណែងអគ្គមេបញ្ជាការក.ជ.រ.ប.ខ.នេះជាលក្ខខណ្ឌឯកតោភាគីដែលជាក់បង្ខំឲ្យទទួលយក ផ្ទុយពីស្មារតីនៃការចរចា ដែលភាគីទាំងពីរកំពុងធ្វើ" ។ លោកឧត្តមសេនីយ សក់ ស៊ុតសាខន បានចារទៀតថា "ទទួលយកមុខនាទីអគ្គមេបញ្ជាការនេះ ក្នុងស្មារតីគោរព

[193] Son Sann, Khmer People's National Liberation Front, Decree no. 87/01/FNL (Unofficial Translation), January 11, 1987.

វិន័យ និង របៀបរៀបរយតែប៉ុណ្ណោះ" ។ លោកតា សឺន សាន មិនពេញចិត្តសោះចំពោះចំណារនេះ ។ ពួកក្រុមយើងនាំគ្នាគិតស្មានថាច្បាស់ជាលោកអគ្គលេខាធិការ នាង ជិនហន ជាអ្នកណែនាំឲ្យលោកឧត្តមសេនីយ សក់ ស៊ុតសាខន សរសេរចំណុចជាអវិជ្ជមានទាំងនេះ ។ ការប៉ាន់ស្មានរបស់ពួកយើងនេះ រឹតតែធ្វើឲ្យលោកតាប្រធានមានការសង្ស័យខ្លាំងឡើងថែមទៀតចំពោះលោក នាង ជិនហន ។

ទោះបីមានការតែងតាំង និង ការដាក់លក្ខខណ្ឌចំពោះតំណែងអគ្គមេបញ្ជាការរបស់លោក សក់ ស៊ុតសាខន ឲ្យទទួលតែផ្នែកយោធាយ៉ាងណាក៏ដោយ ក៏រ.ជ.រ.ប.ខ. នៅតែមិនទាន់ជម្រះបញ្ហាឲ្យជ្រះស្រឡះបាន ដោយហេតុថាកាគីនីមួយៗនៅតែទាមទារយកសិទ្ធិត្រួតត្រាលើជំរុំជនភៀសខ្លួន ។ ក៏ប៉ុន្តែ ដោយសារការតែងតាំងនេះ ភាគីម្ខាងៗក៏អាចបានចំណេញខ្លះដែរ ។ លោកតា សឺន សាន អាចប្រកាសប្រាប់ពិភពលោកថា អស់មានបញ្ហាផ្ទៃក្នុងៗជួររ.ជ.រ.ប.ខ.ទៀតហើយៗលោកតា បានធ្វើឲ្យមានសណ្តាប់ធ្នាប់ឡើងវិញ នៅក្នុងចលនាតស៊ូរបស់លោកតា ។[194] ម្យ៉ាងទៀត លោកតាប្រធានអាចប្រកាសជាថ្មីថាលោកតាដឹកនាំការតស៊ូ ដោយមានកងទ័ពនៅជាមួយ មិនមែនមានតែក្បាលម៉ាស៊ីននយោបាយនោះទេ ។ ចំពោះលោកឧត្តមសេនីយ សក់ ស៊ុតសាខន វិញ ការតែងតាំងជាផ្លូវការបាននាំមកនូវលក្ខណៈស្របច្បាប់គឺ លែងស្ថិតនៅក្នុងការបះបោរខុសច្បាប់ដូចមុនទៀតហើយ ។ ដូច្នេះ ការតែងតាំងជាថ្មីនេះជាការងាយស្រួលសម្រាប់លោកឧត្តមសេនីយក្នុងការទាក់ទងជាមួយអាជ្ញាធរថៃ និង ប្រទេសផ្តល់ជំនួយ ដើម្បីស្វែងរកការគាំទ្រខាងផ្នែកយោធា ។

[194] KhmerPeople's National Liberation Front, Press Communique, January 18, 1987.

យើងមានអ្នកគាំទ្រ និង អ្នករត់ចោលជួរ

តាមពិតទៅ ចាប់តាំងពីបានទទួលការតែងតាំងជាផ្លូវការ លោកឧត្តមសេនីយ សក់ ស៊ុតសាខន នៅតែបន្តធ្វើការដូចមុន មិនមានធ្វើការផ្លាស់ប្តូរអ្វីឡើយ ។ លើកលែងតែការបញ្ជូនរបាយការណ៍ផ្នែកយោធា ដែលផ្ញើមកជូនប្រធានរ.ជ.រ.ប.ខ.ម្តងម្កាល លោក សក់ ស៊ុតសាខន នៅតែទុកដាក់ខ្លួនជាអ្នកដឹកនាំនៃអង្គការចាត់តាំងមួយដាច់ដោយឡែកពីលោកតា សឺន សាន ។ លោកឧត្តមសេនីយនៅតែបន្តធ្វើការតែងតាំង ដោះដូរ ឬ តម្លើងតួនាទីនៃមន្ត្រីជាន់ខ្ពស់ខាងកងទ័ព ដោយមិនចាំបាច់ផ្តល់ព័ត៌មានដល់លោកតាប្រធានឡើយ ។ ដូច្នេះមេបញ្ជាការយោធាដែលមានភក្តីភាពចំពោះលោកតា សឺន សាន ក៏គ្មានជម្រើសអ្វីក្រៅតែពីធ្វើការក្រោមបញ្ជារបស់លោក សក់ ស៊ុតសាខន តែប៉ុណ្ណោះ ។ ក៏ប៉ុន្តែអស់លោកមេបញ្ជាការទាំងនោះ ចេះរកវិធីមកធ្វើការជាមួយការិយាល័យលោកតា សឺន សាន ដែរ ។ គួររំលឹកថា នៅពាក់កណ្តាលខែ មករា ១៩៨៦ លោក ថាច់ រ៉េង បានឲ្យខ្ញុំដឹងនូវតុល្យការនៃកម្លាំងក.ជ.រ.ប.ខ.គឺ កម្លាំងគាំទ្រលោកតា សឺន សាន មាន ៩.៣៧២ នាក់ ឯកម្លាំងគាំទ្រលោក សក់ ស៊ុតសាខន មានតែ ៣.៨២៨ នាក់តែប៉ុណ្ណោះ ។

តាមពិតទៅ ខ្ញុំមិនដឹងថាមានកម្លាំងគាំទ្រលោកតា សឺន សាន ច្បាស់លាស់ពិតប្រាកដប៉ុន្មានទេ ។ មេបញ្ជាការដែលមានឈ្មោះថាជាអ្នកមានភក្តីភាពចំពោះការដឹកនាំរបស់លោកតា សឺន សាន នោះមាន៖ លោក កែវ ជួន លោក ព្រុំ វិត តាមុាំង ឬ លឿង ស៊ីណាក់ លោក ជា ឈុត លោក ជុំ ឈាង លោក ជា ធាយ៉ា និង លោក រក្សា សំបុក ។ តាំងពីដំបូងរៀងរហូតមក ខ្ញុំតែងតែរក្សាទំនាក់ទំនងយ៉ាងល្អជាមួយអស់លោកមេបញ្ជាការទាំងនោះ ដែលបានប្តេជ្ញាដាច់ខាតថាស្មោះសរ ១០០% គាំទ្រលោកតាប្រធាន សឺន សាន ។ បន្ទាប់ពីនោះមកទៀត លោក លីវ

ណេ ដែលនៅគ្រាដំបូងបានគាំទ្រលោកឧត្តមសេនីយ សក់ ស៊ុតសាខន ក៏ត្រឡប់មកគាំទ្រលោកតា សឺន សាន វិញ ។ លោក ជា ឈុត និង លីវ ណេ ធ្លាប់ត្រូវបានទទួលការចោទប្រកាន់ពីអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិថា បានរំលោភសិទ្ធិមនុស្សនៅក្នុងជំរុំនងចាន់ និង រិទ្ធិសែន ។

នៅឆ្នាំ ១៩៨៨ លោក ជា ឈុត និង លីវ ណេ ត្រូវអាជ្ញាធរយោធាថៃនាំយកមកឲ្យរស់នៅឯបាងកកជាមួយពួកយើង និង ហាមឃាត់មិនឲ្យវិលត្រឡប់ទៅដឹកនាំជំរុំវិញឡើយ ។ ដោយទ្រាំនឹងការឃាត់ឃាំងរបស់ថៃ មិនឲ្យវិលទៅនៅជំរុំ និង ដោយទ្រាំក្នុងការរស់នៅដាច់ឆ្ងាយពីកូនទ័ពរបស់គាត់ពុំបាន លោក ជា ឈុត ក៏សម្រេចចិត្តរំលោភលើបទបញ្ជារបស់អាជ្ញាធរថៃ លបរត់ទាំងយប់ទៅទល់ដែន រួចនាំទ័ពរបស់គាត់ទៅលាក់ខ្លួននៅក្នុងទឹកដីខ្មែរ មុននឹងទៅចូលរួមជាមួយ ហ៊ុន សុិន ប៊ុច នៅឆ្នាំ ១៩៩០ ។

ប្រសិនបើគេអាចសង្កេតឃើញអ្នកគាំទ្រ និង អ្នកមានភក្តីភាពចំពោះលោកតាប្រធាន មានចំនួនច្រើនគួរសមដែរនោះ អ្នករត់ចោលពីក្រុមយើងក៏មានខ្លះដែរ ។ លោកអគ្គលេខា នាង ជិនហន និង អគ្គលេខាធិការរងរបស់គាត់គឺ លោក ប៊ុន សាយ មានវត្តមានកាន់តែញឹកញាប់នៅឯការិយាល័យលោក សក់ ស៊ុតសាខន ហើយពួកគាត់ ចំណាយពេលកាន់តែតិចតួចៗនៅឯម៉ាយ៉ាឡាប់ ។ នៅទីបំផុត លោក ប៊ុន សាយ ក៏បានលាចេញពីតំណែងហិរញ្ញិក និង អគ្គលេខាធិការរងនៃ រ.ជ.រ.ប.ខ. ។ ដោយសារមានការលាលែងរបស់លោក ប៊ុន សាយ លោកតា សឺន សាន បានប្រគល់ការងារផ្នែកហិរញ្ញវត្ថុឲ្យខ្ញុំជាអ្នកទទួលខុសត្រូវវិញ ។ មុននឹងចេញពីមុខតំណែង លោក ប៊ុន សាយ បានប្រគល់ជូនលោកតា សឺន សាន នូវសាច់ប្រាក់ជាដុល្លារសហរដ្ឋអាមេរិកជាច្រើនម៉ឺនដុល្លារ ។ បន្ទាប់មក លោក ប៊ុន សាយ ក៏បានចូលទៅធ្វើការជាមួយលោកឧត្តមសេនីយ សក់ ស៊ុតសាខន ។

ជាមួយនឹងការចាកចេញរបស់លោក ប៊ុន សាយ លោកតា សឺន សាន អាចមើលឃើញជាមុនថាលោកអគ្គលេខា នាង ជិនហន ក៏នឹងបែកចេញមិនខានឡើយ ។ ដូច្នេះលោកតាក៏ចាប់ផ្តើមពិគ្រោះយោបល់រកបេក្ខជនមកជំនួស ។

ទីបំផុតគេហៅខ្ញុំថា៖ លោកអគ្គលេខា

លោកតាមិនអាចបញ្ឈប់លោក នាង ជិនហន ពីតំណែងបានទេ នៅពេលណាដែលមិនទាន់រកបាននូវអ្នកជំនួស ។ ប្រសិនបើមនុស្សជំនិតរបស់គាត់អាចមកជាន់លើទឹកដីថៃបាន លោកតាប្រហែលជានឹងតែងតាំងលោក ថាច់ រ៉ែង ជាអគ្គលេខារ.ជ.រ.ប.ខ.មិនខានឡើយ ។ នោះជាជម្រើសដ៏ល្អសម្រាប់លោកតាប្រធាន ព្រោះលោក ថាច់ រ៉ែង មានដើមកំណើតជាខ្មែរកម្ពុជាក្រោមផង និង មានបទពិសោធន៍ខាងផ្នែកយោធាផង ។ តាមពិតទៅ លោកតាប្រធានមិនបានដឹងទេថា លោក ថាច់ រ៉ែង ធ្លាប់បានជេរប្រមាថ និង មើលងាយលោកតាថា ជាមេដឹកនាំគ្មានសមត្ថភាព នៅពេលដែលលោកតាមិនអាចការពារអ្នកស្រី សួន កាសេត ពីការបង្ខំរបស់ថៃ ឲ្យអ្នកស្រីចាកចេញពីទឹកដីថៃជាបន្ទាន់នោះ ។ មែនទែនទៅជាទម្លាប់ខ្ញុំមិនដែលរាយការណ៍អាក្រក់ណាមួយអំពីលោក ថាច់ រ៉ែង ជូនលោកតាប្រធាន ឬ កូនចៅគាត់ឲ្យបានដឹងឡើយ ។ ដោយសារលោក ថាច់ រ៉ែង មិនអាចមានវត្តមាននៅលើដីថៃបានយ៉ាងនេះ ទើបលោកតា សឺន សាន សម្លឹងទៅរកលោក អ៊ឹម ឈូដេត ដែលជាច្រើនឆ្នាំមកហើយ នៅតែបន្តភក្តីភាពចំពោះលោកតាប្រធាន និងមានទំនាក់ទំនងល្អជាមួយអាជ្ញាធរយោធាថៃផង ។ ក៏ប៉ុន្តែ លោក អ៊ឹម ឈូដេត ប្រកែកពុំព្រមទទួលមុខតំណែងនេះ ។ នៅពេលដែលខ្ញុំបង្ខំគាត់ឲ្យឆ្លើយពីមូលហេតុថាហេតុអ្វីបានជាមិនទទួលតួនាទីជាអគ្គលេខាលោក អ៊ឹម ឈូដេត និយាយ

ថា៖ "ខ្ញុំស្រឡាញ់លោកប្រធាន សឺន សាន ណាស់ ។ លោកជាអ្នកដឹកនាំល្អ ។ ក៏ប៉ុន្តែ ខ្ញុំមិនអាចធ្វើការជាមួយលោកប្រធានតូចបានឡើយ" ។ ចំពោះចម្លើយរបស់លោក អ៊ឹម ឈូដេត នេះ នៅពេលនោះ ខ្ញុំនៅមានការស្រពិចស្រពិលមិនច្បាស់លាស់ថានរណាមួយជា "លោកប្រធានតូច" នោះឡើយ ។ ខ្ញុំចេះតែកាត់ស្មានថាប្រហែលជាលោក សឺន ស៊ូប្តែរ ឬ លោក ថាច់ រ៉េង ។

តាមពិត លោក អ៊ឹម ឈូដេត ដឹងច្បាស់ថាលោកតា សឺន សាន គ្រាន់តែយកគាត់មកប្រើរបៀបជាអាយ៉ងតែប៉ុណ្ណោះ ព្រោះការងារសំខាន់ៗលោកតាប្រធានស្តាប់តែកូនគាត់ ស្តាប់តែលោក ថាច់ រ៉េង ឬ អ្នកស្រី សួន កាសេត តែប៉ុណ្ណោះ ។ ម្យ៉ាងទៀត ប្រហែលជាលោក អ៊ឹម ឈូដេត មិនមានបំណងនៅបន្តការតស៊ូតទៅទៀត ឬ ទំនងជាគាត់មានបំណងនាំគ្រួសារចេញទៅនៅប្រទេសទីបីផង ទើបគាត់ពុំព្រមទទួលមុខតំណែងជាអគ្គលេខាធិការរ.ជ.រ.ប.ខ.នេះ ។ ដោយលោក អ៊ឹម ឈូដេត ប្រកែកយ៉ាងនេះ ទើបលោកតាប្រធានស្នើប្រគល់តំណែងនេះជូនលោក ឈឹម ឱមយ៉ុន ។

លោក ឈឹម ឱមយ៉ុន ជានាយទាហានជាន់ខ្ពស់ធ្លាប់រៀនសូត្រជាមួយលោកឧត្តមសេនីយ ដៀន ដែល ដែរ និង ធ្លាប់កាន់តំណែងជាអនុពន្ធយោធារបស់សាធារណរដ្ឋខ្មែរប្រចាំទីក្រុងព្រៃនគរ រហូតដល់ថ្ងៃខ្មែរក្រហមទទួលជ័យជំនះ ។ លោក ឈឹម ឱមយ៉ុន មាននាយទាហាន ដែលភៀសខ្លួនទៅនៅប្រទេសបារាំងចំនួនច្រើនគួរសមដែរដែលជួយគាំទ្រ ។ លោក ឈឹម ឱមយ៉ុន បានគាំទ្រលោកតា សឺន សាន ជាយូរមកហើយ ។ ក្រុមរបស់គាត់មិនសូវចូលចិត្តលោក ថាច់ រ៉េង ប៉ុន្មានទេ ព្រោះមើលឃើញថាលោក ថាច់ រ៉េង ពូកែតែទ្រឹស្តី ហើយម្យ៉ាងទៀត ក្នុងឋានៈជានាយទាហានធ្លាប់ធ្វើការជាមួយលោកឧត្តមសេនីយ សក់ ស៊ុតសាខន លោក ឈឹម ឱមយ៉ុន នៅតែរក្សាទំនាក់ទំនងល្អ និង គោរពលោក សក់ ស៊ុតសាខន ជាដរាប ។

លោក ឈឹម ឱមយ៉ុន បានត្រឡប់ទៅប្រទេសបារាំងវិញ ក្រោយពេលព្យាយាមធ្វើជាមេអណ្តើកផ្សះផ្សាគ្នាពុំបានសម្រេចរវាងក្រុមលោកតា សឺន សាន និង សក់ ស៊ុតសាខន ។

ក្រោយពីបានទទួលសំណើពីលោកតាប្រធានមក លោក ឈឹម ឱមយ៉ុន បានសរសេរលិខិតមួយច្បាប់យ៉ាងវែងជំរាបលោកតាអំពីគំរោងការ ដែលគាត់អាចធ្វើ ប្រសិនបើកាន់តួនាទីជាអគ្គលេខាធិការ.ជ.រ.ប.ខ. ។ អ្វីជាលក្ខខណ្ឌសំខាន់របស់លោក ឈឹម ឱមយ៉ុន នោះគឺ សុំសិទ្ធិបន្តធ្វើការជាមួយលោក សក់ ស៊ុតសាខន ក្នុងន័យផ្សះផ្សាជានាគ្នារវាងលោកតាប្រធាន និង លោកអគ្គមេបញ្ជាការក.ជ.រ.ប.ខ. ។ គំនិតនេះមិនបានទទួលការគាំទ្រពីលោកតា សឺន សាន ទេ ។ លោកតាមិនចង់បានអ្នកផ្សះផ្សាជានាគ្នាអ្វីទេ ។ អ្វីដែលលោកតាប្រធានចង់បាននោះគឺអ្នកដាច់ខាត ដែលហ៊ានចេញមុខតតាំងជាមួយក្រុមប្រឆាំង ដើម្បីឲ្យអ្នកទាំងនោះទទួលយល់ព្រមស្ថិតនៅក្រោមអំណាចគ្រប់គ្រងរបស់ប្រធានតែប៉ុណ្ណោះ ។ ចំពោះលោកតា សឺន សាន ធ្វើការជិតស្និទ្ធជាមួយក្រុមប្រឆាំងបានន័យថា ស៊ីរៈទាំងសងខាង ខាងនេះក៏ត្រូវ ខាងនោះក៏ត្រូវ ។ គោលជំហរបែបនេះ មិនអាចទទួលយកបានដាច់ខាត ។

ពេលវេលាចេះតែកន្លងផុតទៅអស់ជាច្រើនខែ ក្រុមលោកតាប្រធាននៅតែរកមនុស្សមកជំនួសលោក នាង ជិនហាន មិនបាន ។ បញ្ហានេះ ក៏ក្លាយជាបញ្ហាចម្បង ឬ ជាការប្រញាប់ ។ បើចង់ឲ្យលោក នាង ជិនហាន ចេញ ទាល់តែរកមនុស្សជំនួសឲ្យបាន ។ នៅពេលនោះ ខ្ញុំបានទទួលការទុកចិត្តទុកថ្លើមពីលោកតាប្រធានតាមរយៈទំនាក់ទំនងដ៏ល្អជាលក្ខណៈបងប្អូនរវាងខ្ញុំ និង កូនរបស់លោកតាប្រធាន គឺ លោក សឺន ស៊ូបែរ្ត ដែលមានអាយុបងខ្ញុំចំនួន ៨ ឆ្នាំ ។

នៅខែ មករា ១៩៨៨ លោកតា សឺន សាន បានតែងតាំងខ្ញុំជាអ្នកតំណាងរបស់ប្រធានរ.ជ.រ.ប.ខ.ទទួលបន្ទុករដ្ឋបាលស៊ីវិលប្រចាំជំរុំសាយធូ។ មុខនាទីរបស់ខ្ញុំនៅពេលនោះគឺ ជួយសម្រួលឲ្យមានរដ្ឋបាលកណ្តាលមួយសម្រាប់ជំរុំសាយធូទាំងមូល ដែលពីមុនមកមានរដ្ឋបាលបែកខ្ញែកគ្នាតាមជំរុំតូចៗទាំងឡាយ ។ ជាមួយនេះ ខ្ញុំក៏ជួយរៀបចំឲ្យមានការបោះឆ្នោតជ្រើសរើសប្រធានរដ្ឋបាលកណ្តាលម្នាក់ ។ តាមរយៈការបោះឆ្នោត លោក ឡាយ ខែក ដែលគេស្គាល់ថាជាមនុស្សមានស្វាមីភក្តិបំផុតចំពោះលោកប្រធានរ.ជ.រ.ប.ខ. ត្រូវបានដាប់ជាប្រធានរដ្ឋបាលកណ្តាលជំរុំសាយធូ ។ ប្រហែលជាត្រូវបានលោក សឺន ស៊ូបែរ្ត ផ្តល់គំនិតជូន ទើបនៅទីបំផុត នៅខែ មិថុនា ១៩៨៨ លោកតា សឺន សាន បានសម្រេចប្រគល់តំណែងអគ្គលេខាធិការមករូបខ្ញុំ[195] ។

ខ្ញុំយល់ថាលោកតាប្រធានជឿទុកចិត្តចំពោះរូបខ្ញុំ ពីព្រោះជាយូរឆ្នាំមកហើយ ខ្ញុំបានបង្ហាញភក្តីភាពដ៏ជាប់ខាតរបស់ខ្ញុំចំពោះលោកតា ។ ម្យ៉ាងទៀត ខ្ញុំបានធ្វើការយ៉ាងជិតស្និទ្ធ ឬ ជួយបំពេញគ្នាទៅវិញទៅមកជាមួយលោក សឺន ស៊ូបែរ្ត ។ ខ្ញុំអាចប៉ាន់ស្មាននៅពេលនោះថា ការតែងតាំងខ្ញុំជាអគ្គលេខាធិការ ក៏មានតម្លៃប្រហាក់ប្រហែលតែងតាំងលោក សឺន ស៊ូបែរ្ត ក្នុងដំណែងនេះដែរ ។

នៅពេលថ្ងៃត្រូវផ្ទេរតំណែងមកដល់ ខ្ញុំ និង លោក នាង ជិនហន បានជួបគ្នាតែពីរនាក់នៅក្នុងការិយាល័យរបស់គាត់ ។ នៅពេលនោះ ខ្ញុំមានការភ្ញាក់ផ្អើលជាខ្លាំង ព្រោះលោក នាង ជិនហន មិនបានបញ្ចេញអាកប្បកិរិយាអមិត្តដូចដែលខ្ញុំធ្លាប់គិតក្នុងចិត្តនោះទេ ទាំងចំពោះលោកប្រធាន ទាំងចំពោះរូបខ្ញុំ ។ ផ្ទុយទៅវិញ លោក នាង ជិនហន ជូនពរឲ្យខ្ញុំបានទទួលជោគជ័យក្នុងការកិច្ចថ្មី និង បញ្ជាក់ជា

[195] ចាប់ពីថ្ងៃទី ២១ មិថុនា ១៩៨៨ ឧទ្ធកាល័យនាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ បានចេញកំណត់ទូត ផ្សព្វផ្សាយដល់បេសកកម្មទូតប្រទេសជាមិត្តប្រចាំទីក្រុងបាងកក អំពីការតែងតាំងរូបខ្ញុំជាអគ្គលេខាធិការ រ.ជ.រ.ប.ខ. ។

ថ្មីថាបេសកកម្មរបស់យើងទាំងអស់គ្នា មិនមែនស្វែងរកផលប្រយោជន៍ផ្ទាល់ខ្លួននោះទេ តែត្រូវលើកស្ទួយចលនាតស៊ូរ.ជ.រ.ប.ខ.ឲ្យបានជ័យជំនះ ។ និយាយចំចំណុចនេះ លោក នាង ជិនហន ហាក់ដូចជាផ្តល់មេរៀនស្នេហាជាតិដល់ខ្ញុំយ៉ាងដូច្នេះដែរ ។

ចាប់តាំងពីថ្ងៃខ្ញុំទទួលតំណែងនេះភ្លាម មិត្តភក្តិ ឬ បុគ្គលិកជំនួយការទាំងអស់ដែលនៅជុំវិញខ្ញុំ ចាប់ផ្តើមហៅខ្ញុំថា"លោកអគ្គលេខា"ភ្លាម ដែលនៅពេលនោះខ្ញុំហាក់ដូចជាមិនទាន់ចាប់អារម្មណ៍ប៉ុន្មានថា គេកំពុងនិយាយមករកខ្ញុំ ព្រោះខ្ញុំធ្លាប់តែឮគេហៅលោក នាង ជិនហន ជាទម្លាប់ឃ្យូមកហើយ ។ ទម្រាំខ្ញុំស៊ាំត្រចៀកចំពោះពាក្យ "លោកអគ្គលេខា" នេះ ខ្ញុំត្រូវចំណាយពេលអស់ជាច្រើនខែទៀត ។

ប៉ុន្មានថ្ងៃក្រោយមក ពួកយើងចេញដំណើរទៅធ្វើទស្សនកិច្ច នៅតាមជំរុំជាយដែន ។ នៅជំរុំសុខសាន្ត ដែលជាប់នឹងទឹកដីខេត្តច័ន្ទបុរីនៃប្រទេសថៃ លោកតា សឺន សាន បានបង្ហាញរូបខ្ញុំចំពោះជនភៀសខ្លួនខ្មែររាប់ពាន់នាក់ថាជាអគ្គលេខាធិការថ្មីនៃរ.ជ.រ.ប.ខ. ។ បន្ទាប់មកលោកតាប្រធាន បានណែនាំឲ្យខ្ញុំថ្លែងទៅកាន់ប្រជាពលរដ្ឋទាំងនោះ ។ ខ្ញុំក៏ចាប់ផ្តើមនិយាយទៅកាន់មនុស្សរាប់ពាន់នាក់នោះជាលើកដំបូង ដោយគូសបញ្ជាក់ពីបន្ទាត់នយោបាយរបស់រ.ជ.រ.ប.ខ.និង អំពីផែនការការងាររបស់ខ្ញុំ សម្រាប់ចលនាតស៊ូរបស់យើងនាពេលអនាគត ។ ចំពោះអ្នកស្តាប់ទាំងឡាយ សុន្ទរកថាឥតព្រាងទុករបស់ខ្ញុំនោះ បានធ្វើឲ្យគេចាប់អារម្មណ៍យ៉ាងខ្លាំង ព្រោះពីមុនគេមិនដែលឮខ្ញុំនិយាយជាសាធារណៈបែបនេះសោះ ។ លោក អ៊ឹម ឈូដេត ជាមនុស្សទីមួយដែលក្រោកឈរឡើងចាប់ដៃខ្ញុំ សរសើរមិនដាច់ពីមាត់ថា "បើដឹងថាចេះនិយាយ បានល្អយ៉ាងនេះពីមុនមកម្ល៉េះ មូលី ឯងសមទទួលមុខនាទីជាអគ្គលេខាធិការជាយូរមកហើយ មិនចាំបាច់ទៅរកឯណាវែងឆ្ងាយ

ឡើយ" ។ សរុបសេចក្តីមក ការចេញមុខជួបសាធារណៈជនជាលើកទីមួយរបស់ខ្ញុំ បានទទួលលទ្ធផលល្អ ។

នៅពេលដែលខ្ញុំចាកចេញពីប្រទេសបារាំង មកចូលរួមជាមួយ រ.ជ.រ.ប.ខ. នៅជួរមុខ ខ្ញុំគ្រាន់តែមានគំនិតចូលរួមធ្វើការតស៊ូធ្វើពលីកម្ម ដើម្បីបុព្វហេតុជាតិតែប៉ុណ្ណោះ ។ ខ្ញុំមិនដែលនឹកនាស្វែងរកផលប្រយោជន៍ផ្ទាល់ខ្លួន មុខមាត់ បុណ្យសក្តិ ឬ តំណែងសំខាន់ៗនៅក្នុងចលនារ.ជ.រ.ប.ខ.នេះឡើយ ។ ខ្ញុំយល់ថាការដែលលោកតា សឺន សាន បានប្រគល់មុខតំណែងជាអគ្គលេខាធិការឲ្យខ្ញុំនេះ ពីព្រោះលោកតាគ្មានជំរើសអ្វីក្រៅពីនេះ នៅពេលដែលចលនាតស៊ូរ.ជ.រ.ប.ខ.កំពុងជាប់ជំពាក់ក្នុងជម្លោះផ្ទៃក្នុងឥតឈប់ឈរ ។ ការមិនទុកចិត្តគ្នារវាងថ្នាក់ដឹកនាំកំពូលៗ ការបែកបាក់ប្រេះស្រាំ បាននាំឲ្យចលនាតស៊ូរបស់ពួកយើង ចេះតែធ្លាក់ទន់ខ្សោយជាលំដាប់គ្មានពេលពង្រឹងឡើងវិញបានឡើយ ។ នៅសម័យនោះ គ្មានអ្នកដឹកនាំណាម្នាក់នឹកឃើញរូបមន្ត ដែលអាចឲ្យរួមរស់នៅជាមួយគ្នាបាន ក្រៅពីវិធីកំចាត់គ្នាចេញនោះឡើយ ។ ដោយសារសេភាពទន់ខ្សោយរបស់យើង កត្តាខាងក្រៅចូលមកញាំញីព្រៃងវាសនារបស់យើង ។ ប្រទេសខាងក្រៅ ឬ មហាអំណាចខាងក្រៅសុទ្ធតែមានផលប្រយោជន៍របស់គេ ដែលគេត្រូវតែមាននយោបាយ ឬ គោលដៅទៅសម្រេចឲ្យបាន ដោយគេបត់បែនចុះឡើង ដែលយើងមិនអាចយល់ដឹង ។

បើងាកទៅក្រោយ ២០ ឬ ៣០ ឆ្នាំមុន ខ្ញុំពិតជាយល់ថាការចងក្រងមនុស្សឲ្យក្លាយជាចលនាតស៊ូមួយ ប្រាកដជាលំបាកក្រៃលែង ជាពិសេស ចងក្រងមនុស្សពីគំនរផេះផង់នៃភ្លើងវិនាសកម្ម ។ ខ្ញុំមិនគួរលើកកំហុស ឬ ថ្កោលទោសថ្នាក់ដឹកនាំណាមួយឡើយ ចំពោះការខ្វះខាត ឬ អំពើជាអវិជ្ជមានរបស់អស់លោកទាំងនោះ ។ តែព្រឹត្តិការណ៍ទាំងនោះ ក៏បានផ្តល់ជាបទពិសោធន៍ដ៏ពិសិដ្ឋសម្រាប់ខ្មែរជំនាន់ក្រោយ ។

វគ្គទី ៨
ជំរុំជាយដែន
(ទសវត្សរ៍ឆ្នាំ ១៩៨០-១៩៩០)

នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ នៅពេលដែលខ្ញុំទៅធ្វើការនៅជួរមុខនោះ ជំរុំមួយចំនួន បានត្រូវបង្កើតរួចហើយ ។ ដំបូងឡើយរ.ជ.រ.ប.ខ. បានបោះជំរុំនៅលើទឹកដីខ្មែរ តាមបណ្តោយទល់ដែនខ្មែរ-ថៃ ដើម្បីហ្វឹកហ្វឺនកងទ័ព បន្ទាប់មកដើម្បីជួយធ្វើជាកន្លែងចែកចាយផ្តល់ស្បៀង ដល់ប្រជាពលរដ្ឋភៀសខ្លួនមកតាមតំបន់ទល់ដែន ។ ដោយសារចំនួនជនភៀសខ្លួននៅសម័យនោះ កាន់តែមានចំនួនកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃឥតឈប់ឈរ រ.ជ.រ.ប.ខ.ក៏បានបង្កើតជាហេដ្ឋាចនាសម្ព័ន្ធ និង ជួយសម្រួលដល់ការផ្តល់សេវាទាំងឡាយជាបន្ទាន់ ។ នៅឆ្នាំ ១៩៨២ រ.ជ.រ.ប.ខ.មានជំរុំសំខាន់ៗ៦គឺ៖ ជំរុំអំពិល ជំរុំរិទ្ធិសែន ជំរុំនងចាន់ ជំរុំអូរបុក ជំរុំណាំយឺន និង ជំរុំសុខសាន្ត ។ ក្រោយមក មានបន្ថែមជំរុំពីរទៀតគឺ៖ ជំរុំសម្ករធ្លាញ់ និង ដងរែក ។ ក៏ប៉ុន្តែ នៅឆ្នាំ ១៩៨៤-១៩៨៥ ក្រោយដែលកងទ័ពវៀតណាមបើកការវាយប្រហារក្នុងទ្រង់ទ្រាយធំមក ប្រជាពលរដ្ឋជាជនភៀសខ្លួនទាំងនោះ ក៏ត្រូវបានប្រមូលផ្តុំឲ្យមកស្នាក់នៅក្នុងជំរុំដ៏ធំមួយឈ្មោះជំរុំសាយធូ (Site 2) ។

នៅឆ្នាំ ១៩៨០ ជំរុំសាយធូមានប្រជាពលរដ្ឋចំនួន ១៧០.០០០ នាក់ស្នាក់នៅ ដែលអង្គការសហប្រជាជាតិផ្តល់លក្ខន្តិក:ជាជនជន្លៀសខ្លួន (Displaced persons) ខុសពីជនភៀសខ្លួន (Refugee) ដែលជាលក្ខន្តិក:សម្រាប់អ្នកធ្វើដំណើរ ទៅប្រទេសទីបី ។ ជនជន្លៀសខ្លួនជាប្រជាពលរដ្ឋ ដែលត្រូវរស់នៅក្នុង

ប្រទេស មិនអាចបន្តដំណើរទៅក្រៅប្រទេសទេ ។ អង្គការសហប្រជាជាតិផ្តល់ដល់ប្រជាពលរដ្ឋទាំងនោះនូវការជួយឧបត្ថម្ភបែបសង្គ្រោះបន្ទាន់ មានម្ហូបអាហារ ការថែទាំសុខភាព និង ការអប់រំថ្នាក់មូលដ្ឋាន ឬ បឋមសិក្សា ។ ក្នុងសម័យនោះ អង្គការសហប្រជាជាតិ មានគោលនយោបាយផ្តល់ជំនួយក្នុងលក្ខណៈបណ្តោះអាសន្នតែប៉ុណ្ណោះ ព្រោះអង្គការនេះមិនចង់ឲ្យមានការស្នាក់នៅជាអចិន្ត្រៃយ៍ឡើយ ។ នៅសម័យនោះ រដ្ឋាភិបាលថៃធ្វើការហាមប្រាម មិនឲ្យមានការតាំងទីជំរកជាអចិន្ត្រៃយ៍នៅជិតព្រំដែនខ្មែរ-ថៃលើទឹកដីគេទេ ។ ដូច្នេះទើប រ.ជ.រ.ប.ខ. បានរៀបចំជាគោលនយោបាយ ដែលមិនគ្រាន់តែផ្តល់សន្តិសុខ សុវត្ថិភាព ម្ហូបអាហារ និង ជម្រកប៉ុណ្ណោះទេ ថែមទាំងជួយជនរួមជាតិទាំងនោះ ឲ្យលើកតម្កើង និងពង្រឹងនូវតម្លៃប្រពៃណីជាតិ សេរីភាព និង លទ្ធិប្រជាធិបតេយ្យទៀតផង ។

ជំរុំនៅលើទឹកដីខ្មែរ

រហូតដល់ឆ្នាំ ១៩៨៥ ប្រជាពលរដ្ឋដែលរស់នៅក្នុងជំរុំរ.ជ.រ.ប.ខ.បានរស់នៅជាសហគមន៍ដែលស្នេហាសន្តិភាព មានសេរីភាពក្នុងការធ្វើដំណើរបានខ្លះៗ ព្រោះនៅពេលនោះ អ្នកទាំងនោះមិនទាន់ត្រូវគេបញ្ចូលទៅក្នុងជំរុំសាយធូនៅលើទឹកដីថៃ ដែលគេមិនអាចចេញក្រៅបរិវេណជំរុំបានឡើយ លើកលែងតែមានការអនុញ្ញាតពិសេស ។ ក៏ប៉ុន្តែនៅពេលនោះ ទោះជាគេអាចចេញចូលជំរុំដោយសេរីក៏ដោយ ក៏ភាគច្រើនមិនហ៊ានទៅឆ្ងាយ ព្រោះខ្លាចជាន់មីន លើកលែងតែប្រជាពលរដ្ឋមួយចំនួនតូចប៉ុណ្ណោះ ។ ប្រជាពលរដ្ឋយើង មិនហ៊ានឆ្លងដែនចូលក្នុងទឹកដីថៃទេ ព្រោះខ្លាចតម្រួតថៃចាប់យកទៅធ្វើបាប ។ អ្នកជំរុំនាំគ្នាថែរក្សាប្រពៃណី

ធ្វើបុណ្យទានតាមទម្លាប់ ។ ចាស់ៗទៅវត្ត ឯក្មេងៗទៅសាលារៀន ។ ម្ហូបអាហារ ដូចជាអង្ករ ប្រេងឆា ត្រីប្លាធូ បន្លែស្រស់ ទឹកស្អាត សេវាសុខភាពអនាម័យ និង សេវាសង្គមកិច្ច ត្រូវបានផ្តល់ឲ្យដោយអង្គការសហប្រជាជាតិខាងជួយសង្គ្រោះ បន្ទាន់តាមជាយដែន ហៅកាត់ថាយូអិនប្រូ (UNBRO: United Nations Border Relief Operation) អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ និង ទីភ្នាក់ងារស្ម័គ្រចិត្តទាំង ឡាយ ដោយសារសប្បុរសធម៌របស់សហគមន៍អន្តរជាតិ ។

គ្រួសារជាច្រើនបានបញ្ជូនឪពុក ឬ បងប្រុស ឬ ប្អូនប្រុស ឬ កូនប្រុសធ្វើ ជាទាហានក្នុងជួរ.ជ.រ.ប.ខ. ។ ដើម្បីរក្សាអព្យាក្រឹតភាពរបស់ខ្លួន អង្គការសហ ប្រជាជាតិ យូអិនប្រូ មិនផ្តល់ជំនួយដល់កុមារ ឬ មនុស្សប្រុសទេ អង្គការនេះជួយ តែស្ត្រី និង កុមារីតែប៉ុណ្ណោះ ។ ឯកុមារីនោះទៀត ទាល់តែមានកំពស់ចាប់ពី ១ម១០ឡើងទៅ ទើបអាចទទួលជំនួយបាន ។ នយោបាយរបស់អង្គការសហ ប្រជាជាតិបែបនេះ បង្កផលវិបាកយ៉ាងខ្លាំងដល់គ្រួសារណា ដែលមានសមាជិកតែ កេទប្រុស ឬ ចំពោះគ្រួសារណាដែលមានសមាជិកស្រីតិច តែប្រុសច្រើនជាដើម ។ ដូច្នេះចំពោះគ្រួសារណា ដែលមានស្រីៗច្រើន ពួកគេក៏ទទួលជំនួយជាម្ហូបគ្រប់ គ្រាន់ ឬ អាចដោះដូរលក់ចេញខ្លះផង ។ ខ្ញុំមិនបានដឹងថាក្រោយ មកអង្គការសហ ប្រជាជាតិបានធ្វើការកែសម្រួលបញ្ហានេះដោយវិធីណាទេ ។ តែខ្ញុំដឹងថាមានកូន ក្មេងប្រុសៗមួយចំនួនបានចូលបន្លំធ្វើជាក្មេងស្រី នៅពេលដែលគេចុះទៅរាប់ចំនួន មនុស្សដែលត្រូវទទួលជំនួយ ។

តាមពិតទៅ ករណីបែបនេះក៏មិនមែនមានច្រើនប៉ុន្មានឡើយ ។ អ្នករស់នៅ ជំរុំលើទឹកដីខ្មែរ នៅពេលនោះ ធ្វើផ្ទះភាគច្រើនពីឫស្សីប្រក់ស្លឹក ដែលអង្គការសប្ប រសផ្តល់ឲ្យ ។ គ្រួសារទាហានខ្លះក៏មានផ្ទះឈើដែរ ដោយពួកគេអាចចេញទៅកាប់ ឈើនៅក្រៅជំរុំបាន ។ ជាទូទៅ អ្នកជំរុំនាំគ្នាដាំបន្លែខ្លួនឯង ដើម្បីអាហាររូបត្ថម្ភ

បន្ថែមសម្រាប់គ្រួសាររបស់ពួកគេ ។

ជំរុំនីមួយៗត្រូវបានគ្រប់គ្រងដោយរដ្ឋបាលមួយ ដែលចែកចេញជាផ្នែក ដូចជា៖ ផ្នែកអនាម័យ ឬ សុខាភិបាល អប់រំ វប្បធម៌ ឬ សិល្បៈ និង សន្តិសុខ សណ្តាប់ធ្នាប់ជាដើម ។ តាមធម្មតា ជំរុំនីមួយៗមានប្រធានជំរុំម្នាក់ ដែលជាទូទៅ កាន់មុខនាទីជាមេបញ្ជាការយោធាផង ។ អ្នកជំរុំ ហៅមេជំរុំថា "លោកប្រធាន" ។ លោកប្រធាន មានប្រធានរដ្ឋបាលម្នាក់ជាជំនួយការ ដែលជួយសម្របសម្រួលការ ងារជាមួយផ្នែកផ្សេងៗទៀត និង ជាអ្នកទាក់ទងជាមួយអង្គការសហប្រជាជាតិ ឬ អង្គការក្រៅរដ្ឋាភិបាលនានា ដែលធ្វើការនៅក្នុងជំរុំ ។ ប្រធានរដ្ឋបាលមួយចំនួនធំ ច្រើនចេះនិយាយភាសាបារាំង ឬ ភាសាអង់គ្លេស ឬ ខ្លះទៀតចេះនិយាយភាសា ទាំងពីរតែម្តង ។ នៅជំរុំអំពិល ដែលជាបញ្ជាការដ្ឋានក.ជ.រ.ប.ខ. បានត្រូវដឹកនាំ ខាងផ្នែកយោធាដោយលោកឧត្តមសេនីយ ជៀន ដែល ឯផ្នែកនយោបាយដោយ លោក ហ៊ីង គន្ធុន ។ តែតាមពិតទៅ លោកឧត្តមសេនីយ ជៀន ដែល ជាមេធំជាង គេនៅក្នុងជំរុំនេះ ។

នៅជំរុំអំពិល យើងមានអតីតអ្នករាំរបាំព្រះរាជទ្រព្យពីរនាក់ ម្នាក់ឈ្មោះ ស្រី មុំ ម្នាក់ទៀតឈ្មោះ សាវ៉ៃ ។ ទោះជាអ្នកទាំងពីរត្រូវបានឆ្លងកាត់ការលំបាកគ្រប់ យ៉ាងក្នុងរបប ប៉ុល ពត យ៉ាងណាក៏ដោយក៏សម្រស់របស់ពួកគេ មិនបានបាត់បង់ ប៉ុន្មានឡើយ ។ នារីទាំងពីរបានចំណាយពេលវេលា និង ឋាមពលរបស់ពួកគេ ដើម្បីបង្រៀនក្មេងៗជំនាន់ក្រោយ ឲ្យចេះរាំរបាំប្រពៃណីយនេះ ដែលជាមរតកពី ខ្មែរជំនាន់មុនកុំឲ្យបាត់បង់ ។ សាវ៉ៃ និង ប្តីរបស់នាងឈ្មោះ វ៉ាន់ រឿន បានបង្កើត ក្រុមរបាំប្រពៃណីមួយក្រុមដែលតែងតែរាំជូនភ្ញៀវសំខាន់ៗទស្សនានៅក្នុងទស្សកិច្ច របស់ពួកគេនៅជំរុំអំពិល ។

ជំរុំនីមួយៗមានក្រុមសិល្បៈ រួមទាំងក្រុមតន្ត្រីសម័យ ឬ បូរាណ និង ក្រុម

ល្ងោនបាសាក់ផង ។ បើគ្មានភ្ងៀវសំខាន់ៗទេ ក្រុមតន្ត្រីសម័យ ឬ ល្ងោនបាសាក់តែងតែសំដែងកំដរសាធារណជននៅចុងសប្តាហ៍ ឬ នៅពេលមានពិធីពិសេសណាមួយ[196] ។ ភ្ងៀវបរទេស ដែលបានទស្សនាវប៉ាំប្រពៃណីខ្មែរតែងតែសំដែងការកោតសរសើរដល់សិល្បករ និង សិល្បការិនី អំពីទេពកោសល្យរបស់ពួកគេ ព្រមទាំងគូសបញ្ជាក់ថានយោបាយរបស់រ.ជ.រ.ប.ខ. ដែលខំថែរក្សា និង ធ្វើឲ្យវប្បធម៌ជាតិរស់ឡើងវិញនេះ ក៏ដូចជាការថែរក្សាព្រលឹងជាតិដែរ ព្រោះថាបើអស់ព្រលឹង ជីវិតយើង ក៏គ្មានន័យដែរ ។

នៅជំរុំធំៗដូចជា ឫទ្ធិសែន ឬ នងចាន់ មានផ្សារ ដែលគេអាចទិញលក់របស់របរច្រើងយ៉ាង ដោយប្រើប្រាស់ប្រាក់ថៃ (បាត) ។ ដោយមានការសហការពីអាជ្ញាធរថៃផង ទំនិញថៃត្រូវបានបញ្ចូលក្នុងទឹកដីខ្មែរនៅក្នុងជំរុំ ឬ ចូលជ្រៅទៅក្នុងទូទាំងប្រទេសផង ។ នៅទីផ្សារ គេអាចរកទិញបាននូវសាច់គោ សាច់ជ្រូក មាន់ ត្រី បន្លែ ថ្នាំពេទ្យ សម្លៀកបំពាក់ ភេសជ្ជៈ សូដា បៀរ ស្រា និង ឧបករណ៍កសិកម្មជាដើម ។ តាមពិត នៅជំរុំទាំងពីរនេះ គេអាចរកចំណូលបានជាច្រើន ដោយសារការរត់ពន្ធទំនិញពីថៃចូលក្នុងប្រទេសខ្មែរ ឬ ពីខ្មែរទៅប្រទេសថៃ ។ ជាមួយនោះ គេក៏ឃើញមានហាងគុយទាវ ឬ ហាងលក់បាយ ឬ និង ហាងដូរប្រាក់ ដែលគេអាចសម្គាល់បាន ដោយសារនៅមុខផ្ទះ មានដាក់តាំងជញ្ជីងថ្លឹងមាស រង់ចាំទទួលភ្ងៀវមកដូរមាសយកប្រាក់បាត ឬ ដូរប្រាក់បាតយកមាសខ្មែរជាដើម ។ អ្នកនៅខាងក្នុងស្រុកខ្មែរអាចមកទិញទំនិញ ឬ យកអីវ៉ាន់មកលក់ រួចទិញរបស់របរ ដែលគេត្រូវការយកទៅខាងក្នុងវិញតាមវិធីរត់ពន្ធ ។ តាមចលនារបស់អ្នករត់ពន្ធនេះក៏មានបណ្តាញស៊ើបការណ៍ពីជំរុំទៅខាងក្នុង ពីខាងក្នុងមកជំរុំ សម្រាប់កិច្ចប្រតិបត្តិការយោធា ។ មេជំរុំខ្លះរកប្រាក់ចំណូលបានច្រើនដោយសារការរត់ពន្ធនេះ ដែលគេ

[196] សិល្បករដូចជា នាយសង់ស៊ីស នាយស៊ីត្រូ និង នាយជីវ៉ាន់ស៊ុយ សុទ្ធតែបានបំរើការងារនៅក្នុងជំរុំ រ.ជ.រ.ប.ខ.ទាំងអស់ ។

អាចចិញ្ចឹមទ័ពឯកជនរបស់គេបាន ដោយមិនបាច់ត្រូវការជំនួយពីរ.ជ.រ.ប.ខ. ផងក៏មាន ។

នៅពេលលោកប្រធានជំរុំធ្វើដំណើរម្តងៗ ជាពិសេសប្រធានជំរុំនងចាន់ គេឃើញមានអង្គរក្សប្រដាប់ដោយអាវុធគ្រប់ដៃ ជិះម៉ូតូរាប់សិបគ្រឿងហែរហមយ៉ាងគគ្រឹកគគ្រេង ។ ទោះជាអ្នកជំរុំរស់នៅអាស្រ័យដោយជំនួយរបស់អង្គការសហប្រជាជាតិក៏ដោយ ក៏អ្នករត់ពន្ធបានបញ្ចូលទៅក្នុងទីផ្សារនូវសាច់ប្រាក់ចំនួនច្រើនលានបាត ។ នៅក្នុងជំរុំធំៗទាំងពីរ ក្រៅពីផ្សារ អ្នកជំរុំអាចទៅកំសាន្តនៅតាមរោងភាពយន្ត ដែលជារោងសង់ពីឫស្សីយ៉ាងធំ ។ នៅក្នុងរោងភាពយន្តនោះ គេបញ្ចាំងរឿងខ្មែរតាំងពីសម័យមុនសង្គ្រាម ដោយមានសិល្បករនិយាយបញ្ចូលសម្លេងផ្ទាល់នៅពេលបញ្ចាំងម្តងៗ ។

ខ្ញុំរៀនវិជ្ជាត្រៃវេទ

ជាទូទៅ ប្រជាពលរដ្ឋភាគច្រើនជាអ្នកកាន់ព្រះពុទ្ធសាសនា ។ ក៏ប៉ុន្តែបន្ថែមលើនេះ ក៏មានមនុស្សមួយចំនួននៅជឿលើអារក្ខ អារក្ស អ្នកតា អាគមអូមអាម អប្បិយជំនឿពីបូរមបូរាណ ឬ ការទស្សន៍ទាយតាមក្បួនហោរាស្ត្រផង ។ ក្នុងរយៈពេលនៃការស្នាក់អាស្រ័យនៅរបស់ខ្ញុំ ក្នុងឆ្នាំ ១៩៨២ - ១៩៨៣ នៅក្នុងជំរុំអំពិល ខ្ញុំធ្លាប់បានជួបនាយទាហានថ្នាក់កងវរសេនាតូចជាច្រើន ដែលតែងមកនិយាយលេងសំណេះសំណាលជាមួយខ្ញុំ រាល់ល្ងាចក្រោយបាយរួច ។ ក្នុងចំណោមនាយទាហានទាំងនោះ មានប្រធានកងវរសេនាតូចម្នាក់ឈ្មោះ កែវ វិបុល ធ្លាប់ចេញប្រយុទ្ធនៅសមរភូមិជាច្រើនលើកច្រើនគ្រា ដែលនាំឲ្យគេមានបទពិសោធន៍ល្អខាងយោធា ។ វិបុល មានជំនឿជឿជាក់ថាជោគជ័យរបស់គាត់នៅសមរភូមិបាន

មកដោយសារវត្ថុស័ក្តិសិទ្ធ ជាពិសេសដោយសារឫទ្ធីបារមីនៃវិជ្ជាដែលគាត់បានរៀន និង បានយកមកប្រើអស់រយៈពេលជាច្រើនឆ្នាំមកហើយ ។

វិជ្ជាដែលគាត់រៀននោះ ហៅថា "វិជ្ជាត្រៃវេទ" ។ កែវ វិបុល យល់ថា "វិជ្ជាត្រៃវេទ" មានប្រភពដើមចេញពីព្រហ្មញ្ញសាសនា ។ គាត់ជឿថាវិជ្ជារបស់គាត់បានមកពីព្រះព្រហ្មមុខបួន ។ ក្នុងសម័យនោះ ខ្ញុំក៏កំពុងចង់ដឹងចង់ស្គាល់វិជ្ជាប្លែកៗបែបនេះដែរ ។ ខ្ញុំកំពុងចង់ស្វែងយល់ពីឫទ្ធិអំណាចនៃវត្ថុស័ក្តិសិទ្ធ ឬ ឫទ្ធិបារមីនៃពិភពងងឹតខ្លាំងណាស់ ។ ម្យ៉ាងទៀត ខ្ញុំក៏ចង់ដឹងអំពីវិជ្ជាត្រៃវេទនេះដែរ ។ តាមពិតទៅ ខ្ញុំមិនជឿលើអបិយជំនឿទេ ក៏ប៉ុន្តែខ្ញុំចង់ដឹងអំពីការគោរពប្រតិបត្តិរបស់អ្នកឯទៀតជាខ្លាំង ។ ដោយដឹងពីគោលដំហររបស់ខ្ញុំយ៉ាងនេះ ទើប កែវ វិបុល នាំខ្ញុំឲ្យទៅជួបលោកគ្រូរបស់គាត់ឈ្មោះ គ្រូមៀច ដែលមានតួនាទីជាទីប្រឹក្សាកងវរសេនាតូចរបស់គាត់ផង ។

នាយប់មួយនោះ ខ្ញុំក៏ទៅជួប គ្រូមៀច នៅអាស្រមរបស់គាត់ដែលសង់ឡើងពីឫស្សីប្រក់ស្លឹក ហើយជាទីដែលលោក គ្រូមៀច ស្នាក់នៅផង ។ អាស្រមរបស់លោកគ្រូ ស្ថិតនៅដាច់ពីផ្ទះប្រជាពលរដ្ឋធម្មតា និង មានភាពស្ងាត់ជ្រងុំល្អណាស់ ។ គ្រូមៀច និយាយតិចៗលាយឡំនឹងទឹកមុខញញឹមជានិច្ច ។ គាត់មានសម្បុរខ្មៅ មាឌមាំ ដូចអ្នកស្រែខ្មែរសុទ្ធសាធ ។ នៅពេលដែលគាត់បង្រៀនសិស្ស ឬ ថ្វាយបង្គំ ឬ ធ្វើការស្មឹងស្មាធិ ភាវនា ឬ សមាធិ គាត់ស្លៀក និងដណ្តប់សំពត់សពាក់ឈៀងបញ្ចេញស្មាស្តាំជានិច្ច ។ ក៏ប៉ុន្តែនៅពេលមានពិធីធំៗ គាត់អាចស្លៀកពាក់ស្បង់ចីវរពណ៌លឿងដូចព្រះសង្ឃដែរ ។ នៅពេលខ្ញុំទៅដល់គ្រូមៀច កំពុងជាប់បង្រៀនសិស្សគណរបស់គាត់ ។ នៅក្នុងបរិវេណនៃអាស្រមខាងក្រៅតូប កូនសិស្សខ្លះកំពុងហាត់រៀនវិជ្ជាម្យ៉ាង ដែលខ្ញុំមើលទៅប្រហាក់ប្រហែលនឹងវិជ្ជាគុននិយមចិន "គុងហ្វូ" ។

គ្រូមៀច ចេញមកទទួលខ្ញុំយ៉ាងរាក់ទាក់ រួចនាំខ្ញុំចូលទៅក្នុងអាស្រមរបស់គាត់ ដែលបំភ្លឺដោយពន្លឺព្រឹមៗនៃចង្កៀងប្រេងកាត និង ទៀនមួយចំនួន ។ នៅខាងក្នុងជ្រៅ ខ្ញុំឃើញបដិមារូបព្រះព្រហ្មធ្លាក់ពីឈើជាច្រើនអង្គដាក់តាំងនៅលើអាសនៈជាច្រើនជាន់ ។ អ្វីដែលនាំឲ្យខ្ញុំភ្ញាក់ជាខ្លាំងនោះគឺ ព្រះពុទ្ធបដិមាដ៏ធំតាំងនៅលើអាសនៈខ្ពស់ជាងគេក្រោមក្លស់ពណ៌មាស ដែលដាក់បាំងផង ។ ខ្ញុំឆ្ងល់ណាស់ដែរថា ហេតុដូចម្តេចបានជាគេយកព្រះពុទ្ធ មកលាយឡំក្នុងព្រហ្មញ្ញសាសនាយ៉ាងនេះ? តើនេះជាព្រះពុទ្ធសាសនាមហាយានទេឬ? គ្រូមៀច ពន្យល់ថា ខ្ញុំអាចមានឫទ្ធិអំណាចដ៏អស្ចារ្យ ប្រសិនបើខ្ញុំរៀនវិជ្ជាត្រៃវេទនេះសម្រេច ។ ដើម្បីឲ្យសម្រេចវិជ្ជាត្រៃវេទនេះ សិស្សត្រូវប្រតិបត្តិដូចតទៅ៖ ១. ត្រូវកាន់សីល ៥ ដូចសីល ៥ ក្នុងព្រះពុទ្ធសាសនាដែរគឺ៖ - មិនសម្លាប់ - មិនលួចទ្រព្យសម្បត្តិគេ - មិនកុហកភូតភរ - មិនលួច ឬ រំលោភប្រពន្ធកូនគេ និង មិនសេពសុរា ។ ២. មិនត្រូវគោរព ឬ ថ្វាយបង្គំអារុក្ខ អារក្ស អ្នកតា ឬ បារមីអ្វីដទៃក្រៅពីរូប ព្រះព្រហ្ម និង ព្រះពុទ្ធឡើយ ។ ចំណែករូបព្រះពុទ្ធវិញ មិនត្រូវគោរពថ្វាយបង្គំនៅទីណាដទៃពីក្នុងព្រះវិហារនៃវត្តអារាមឡើយ ។ ៣. មិនត្រូវអួតអាងប្រាប់គេពីវិជ្ជាត្រៃវេទនេះទេ ។ ក្រោយដែលបានពន្យល់ចប់សព្វគ្រប់ហើយ គ្រូមៀច ជួយអុជធូបបីសរសៃ រួចឲ្យខ្ញុំក្រាបបង្គំបីដងចំពោះព្រះពុទ្ធបដិមា និង រូបព្រះព្រហ្មទាំងនោះ ។ បន្ទាប់មក គ្រូមៀច ឲ្យខ្ញុំអង្គុយដូចអ្នកស្មឹងស្មាធិភាវនា និង ប្រុងប្រៀបសូត្រ នមោតស្ស ភគវតោ អរហតោ សម្មា សម្ពុទ្ធស្ស - ឲ្យគ្រប់បីដង ។ បន្ទាប់មក គាត់សូត្រពាក្យបីម៉ាត់គឺ៖ ឧ អៈ មៈ មៈ អៈ ឧ ចុះឡើង៧ ហើយលោកគ្រូឲ្យខ្ញុំទន្ទេញកុំឈប់ ។ ប្រសិនបើខ្ញុំមាននិស្ស័យក្នុងវិជ្ជាត្រៃវេទ បារមីដែលជាគ្រូនឹងយកខ្ញុំជាសិស្សរបស់បារមីនោះ ។ ដូច្នេះ គ្រូមៀច មិនមែនជាគ្រូពិតប្រាកដទេ គាត់គ្រាន់តែជាអ្នកណែនាំសិស្ស ឲ្យគ្រូក្នុងផ្លូវងងឹតទទួលយកតែប៉ុណ្ណោះ ។ គ្រូពិតប្រាកដជាបារមី ដែល

មនុស្សធម្មតាមើលមិនឃើញ ។ បារមីទាំងនោះរួមមានបារមីមេទ័ពល្បីៗ អតីតព្រះមហាក្សត្រដែលគេហៅថាគ្រូតូច និង បារមីព្រះសាវ័ករបស់ព្រះពុទ្ធ ដូចជាព្រះសារីបុត្រ ព្រះមហាមោគ្គលាន ឬ ព្រះនរាយណ៍ ព្រះរាម ព្រះសេវៈ ព្រះវិស្ណុ ព្រះព្រហ្ម ឬ ហនុមានដែលគេហៅថាគ្រូធំ ។ មានតែសិស្សពិសេសមួយចំនួនតូចប៉ុណ្ណោះ ដែលបារមីគ្រូធំអាចទទួលយកធ្វើជាសិស្ស ។ សិស្សពិសេសនោះគឺ ជាអ្នកឧស្សាហ៍ព្យាយាម គោរពប្រណិប័តន៍បានត្រឹមត្រូវ អស់ពេលជាយូរមកហើយ ទើបអាចបានសម្រេច ។ ដោយឃើញមានការយកព្រះពុទ្ធ និង អគ្គសាវ័ករបស់ព្រះអង្គមកច្របូកច្របល់ជាមួយនឹងពិធីដ៏ចម្លែកនេះ បានធ្វើឲ្យខ្ញុំលើកជាសំណួរសួរខ្លួនឯងថា តើកម្រឹតយល់ដឹងរបស់ខ្ញុំក្នុងវិស័យព្រះពុទ្ធសាសនាមានកំរឹតត្រឹមណា? ខ្ញុំចេះតែទន្ទេញធម៌ ឧ អៈ មៈ មៈ អៈ ឧ ដោយគ្មានកំរើក ។

នៅពេលដែលភ្លើងធូបឆេះអស់មួយធូប ខ្ញុំមានអារម្មណ៍ថាមានកម្លាំងអ្វីមួយមកប៉ះដៃខ្ញុំ ។ បើខ្ញុំលែងដៃទាំងពីរ ដែលខ្ញុំកំពុងប្រណម្យនោះឲ្យឃ្លាតចេញពីគ្នា ដៃនោះហាក់ដូចអណ្តែតដោយខ្លួនឯង ហាក់ដូចជាគ្មានកម្លាំងសង្កត់ (Gravity) មកទាញឲ្យធ្លាក់ចុះក្រោមឡើយ ។ ហើយបើខ្ញុំបណ្តោយឲ្យដៃទាំងពីរមានសេរីភាព ធ្វើសកម្មភាពដោយសេរី ដៃទាំងនោះនឹងធ្វើសញ្ញាដូចជាសំពះ ឬ ប្រសិទ្ធីជាដើម ។ ខ្ញុំមានការភ្ញាក់ផ្អើលខ្លាំងណាស់ចំពោះថាមពលងងឹត ដែលខ្ញុំមើលមិនឃើញនោះ ។ នៅពេលដែលវគ្គទីមួយបានបញ្ចប់ទៅនោះ គ្រូមៀច បាននិយាយមកកាន់ខ្ញុំថាល្អណាស់ លោកមាននិស្ស័យហើយៗថាឥឡូវលោកគ្រូខាងផ្នែកងងឹតទទួលលោកធ្វើជាសិស្សរួចហើយ ។ លោក គ្រូមៀច ប្រហែលជាដឹងថាគ្រូខ្ញុំជាអ្វី ឬ ជាអ្នកណា តែចំពោះខ្ញុំៗមិនបានដឹងថាជាអ្នកណាទាល់តែសោះ ។

តាំងពីថ្ងៃនោះមក ខ្ញុំបានចំណាយពេលមួយម៉ោងក្នុងមួយថ្ងៃមករៀនវិជ្ជាត្រៃវេទនេះ ។ ក្នុងរយៈពេលបីសប្តាហ៍កន្លងមក ពាក្យបីម៉ាត់ដែលខ្ញុំទន្ទេញតាំង

ពីលើកដំបូងគឺ ឧ អៈ មៈ មៈ អៈ ឧ បានប្រែជាពាក្យផ្សេងៗដែលខ្ញុំមិនយល់បាន ។ គ្រូមៀច ប្រាប់ខ្ញុំថានោះគឺជាការរៀននិយាយដូចកូនក្មេង ដែលនិយាយមិនទាន់ច្បាស់ដូច្នោះដែរ ។ បន្ទាប់មក ពាក្យដែលមិនច្បាស់ដែលខ្ញុំស្តាប់មិនបាននោះ ក៏ចាប់បន្លឺចេញជាសម្លេង ក ខ គ ឃ ង .... តាមអក្សរខ្មែរ.... បន្ទាប់មកទៀត ..... សម្លេង ក ក៏ចេញជាពាក្យផ្សេងៗក្នុងតួអក្សរ ក រួចពាក្យទាំងអស់ឯទៀតនៃអក្សរ ខ ..... គ ..... ឃ ..... ដែលធ្វើឲ្យខ្ញុំកាន់តែមានការចាប់អារម្មណ៍ជាទីបំផុត ។ ក្រោយដែលខ្ញុំសូត្រពាក្យដែលចេញពីមាត់ខ្ញុំដោយស្វ័យប្រវត្តិនោះ ក្រោយមកក៏ក្លាយទៅពាក្យធម៌ ..... នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស .....។ ប្រការដែលកាន់តែភ្ញាក់ផ្អើលយ៉ាងខ្លាំងនោះគឺ នៅពេលដែលខ្ញុំកំពុងបិទភ្នែកភាវនានូវពាក្យពេចន៍ ឬ បាលី ដែលចេញសម្លេងតាមមាត់ដោយស្វ័យប្រវត្តិនោះ ញាណទាំងប្រាំរបស់ខ្ញុំនៅដឹងទាំងអស់ ខ្ញុំស្តាប់ឮអ្នកនៅខាងក្រៅអាស្រមនិយាយគ្នា ឬ សម្លេងអ្វីដែលកើតមាននៅទីនោះ ។ ខ្ញុំដឹងថាដៃ ឬ ជើងខ្ញុំមានចលនាបែបណាគឺបានន័យថាខ្ញុំនៅមានស្មារតីធម្មតាទាំងអស់ ។ ដូច្នេះខ្ញុំមិនមានអារម្មណ៍ថាកម្លាំងងងឹត ឬ បារមីអ្វីមកចូលសណ្ឋិតក្នុងខ្លួនខ្ញុំ ធ្វើឲ្យខ្ញុំបាត់ស្មារតីនោះឡើយ ។ ដោយសារការឧស្សាហ៍ព្យាយាម ពាក្យបីម៉ាត់ពីដំបូងគឺ ឧ អៈ មៈមៈ អៈ ឧក៏ក្លាយជាពាក្យបាលីដែលខ្ញុំអាចសូត្របានមិនចេះចប់ ។ លើសពីនេះទៅទៀតនោះ ខ្ញុំអាចរើសមុខវិជ្ជាដែលខ្ញុំចង់បានដោយខ្លួនឯង ។ ឧទាហរណ៍ ប្រសិនបើខ្ញុំសុំរៀនបាលីការពារខ្លួន - ខ្ញុំចាប់ផ្តើមសូត្រពាក្យបីម៉ាត់ខាងដើមគឺ៖ ឧ អៈ មៈមៈ អៈ ឧ-សូត្រមិនទាន់ចប់ផង ក៏ក្លាយទៅជានមោតស្ស ភគវតោ អរហតោ សម្មា សម្ពុទ្ធស្ស ពុទ្ធំ ធម្មំ សង្ឃំ សព្វយន្តោ សុខី សុខោ សុខៈ សុខំ ជាដើម សារចុះសារឡើងមិនចេះចប់ ។ ខ្ញុំមិនចេះភាសាបាលីទេ តែខ្ញុំអាចបកស្រាយថា អ្វីដែលខ្ញុំសូត្រនោះគឺ ជាការសុំយកអំណាចរបស់ព្រះពុទ្ធ ព្រះធម៌ និង ព្រះសង្ឃឲ្យមកជួយឲ្យខ្ញុំបានសុខ ។

ពាក្យដែលខ្ញុំសូត្រនេះអាចផ្លាស់ប្តូរទៅពាក្យផ្សេងទៅវិញ ប្រសិនបើខ្ញុំផ្លាស់ប្តូរមុខវិជ្ជា ។ ឧទាហរណ៍ បើខ្ញុំនឹកការនាថាសុំរៀនវិជ្ជាគុននិយម ធម៌ដែលចេញមកមានសំនៀងជាភាសាចិនដែលខ្ញុំស្តាប់មិនបាន ឯដៃខ្ញុំក៏ចេញជាចលនាចុះឡើងទំនងដូចជាចេញក្បាច់គុនចិនដែរ ហើយប្រសិនបើខ្ញុំក្រោកឈរ ខ្ញុំក៏ចេញក្បាច់នេះទាំងជើងលោតចុះ លោតឡើងផង ។ មួយទៀតប្រសិនបើខ្ញុំចង់រៀនវិជ្ជាស្នេហ៍ ពាក្យខ្ញុំការនាក៏ចេញមកលាយឡំនឹងពាក្យពេចន៍ ដែលមានសំនៀងប្រហាក់ប្រហែលភាសាចាម ដែលខ្ញុំមិនយល់ទាល់តែសោះ ។ នៅប្រទេសខ្មែរយើង អស់ពេលជាច្រើនឆ្នាំមកហើយដែលគេដឹងថា ពួកចាមពូកែខាងជាក់ស្នេហ៍ ។

ខ្ញុំចង់សាកល្បងវិជ្ជាត្រៃវេទ

កូនសិស្ស គ្រូមៀច បានសម្រេចវិជ្ជាផ្សេងៗ ។ ខ្លះចេះអង្គុយមើលជតារាសីរបស់មនុស្ស ឬ ទស្សន៍ទាយព្រឹត្តការណ៍ផ្សេងៗ ។ ខ្លះចេះមើលជម្ងឺ ចេះស្រោចទឹក ។ ក្រោយដែលបានរៀនវិជ្ជាត្រៃវេទនេះ ខ្ញុំហាក់ដូចជាមិនចេះខ្លាច នឹកថាមានគេថែរក្សាការពារ ក៏ប៉ុន្តែខ្ញុំមិនដឹងថាចេះខាងអ្វីពិតប្រាកដឡើយ ។ នៅពេលដែលមានទាហានមួយក្រុម ក្រោមបញ្ជារបស់ តាមុាំង បានរាយការណ៍ថាក្រុមគេបានកាន់កាប់តំបន់ប្រាសាទបន្ទាយឆ្មារ នៅស្រុកថ្មពួក ក្នុងខែត្របន្ទាយមានជ័យ ខ្ញុំស្ម័គ្រចិត្តទៅតាម តាមុាំង ទៅធ្វើទស្សនកិច្ចមួយថ្ងៃមួយយប់នៅបន្ទាយឆ្មារ ។ ខ្ញុំអាងលើ គ្រូមៀច ដែលខ្ញុំនឹកថា អាចការពារពួកយើងបាន ប្រសិនបើមានអាសន្នអ្វី ទើបនាំគាត់ទៅរួមដំណើរជាមួយ ។ តែសំណាងយើងមាន ពួកយើងពុំមានជួបនឹងឧបសគ្គអ្វីឡើយ ទាំងទៅទាំងមក ។ ដូច្នេះ ខ្ញុំក៏ពុំបានសាកល្បងវិជ្ជាត្រៃវេទរបស់យើងថាតើស័ក្តសិទ្ធដល់កំរិតណាទេ ។

អាងវិជ្ជាត្រៃវេទ នាំគ្នាទៅគាស់កំណប់

ជាច្រើនខែក្រោយមក លោក កេត រ៉ែត (អតីតវរសេនីយឯកកងទ័ពសាធារណរដ្ឋ លន់ នល់) ដែលខ្ញុំហៅឈ្មោះគាត់ជាសាមញ្ញថា "តារ៉ែត" ជាសិស្សរបស់គ្រូមៀច ដែរ បានមកប្រាប់ខ្ញុំថា អង្គរក្សរបស់គាត់ម្នាក់ដែលចេះវិជ្ជាត្រៃវេទ បានអង្គុយធម៌ ហើយឃើញខ្មោចមិត្តគេពីរនាក់ មកពន្យល់ឲ្យទៅគាស់កំណប់ចំនួនបីបាវ ដែលកាលនៅរស់ ពួកគេទាំងបីនាក់បានកប់នៅក្បែរប្រាសាទស្ដុកកក់ធំ ក្នុងសម័យខ្មែរក្រហម ។ នៅសម័យនោះ ប្រាសាទនេះនៅលើទឹកដីខ្មែរ ។ អង្គរក្សនោះជានាថាគេស្គាល់ទីកន្លែងច្បាស់លាស់ណាស់ ព្រោះគេធ្លាប់ចូលរួមក្នុងការកប់លាក់កំណប់នោះជាមួយមិត្តពីរនាក់ទៀត ដែលស្លាប់ទៅហើយដោយសារក្បត់ទៅលួចគាស់តែរៀងៗខ្លួនខុសពីពាក្យសម្បថ ។ អ្វីដែលអង្គរក្សនោះចង់បានគឺសុំឲ្យពួកយើងជួយសុំច្បាប់ថៃ ឲ្យផ្តល់មធ្យោបាយដឹកជញ្ជូន(រថយន្ត Pick up) និង ច្បាប់ឆ្លងកាត់ទឹកដីថៃ ដើម្បីធ្វើដំណើរពីជំរុំអំពិល ទៅជំរុំវិទ្ធិសែន ។ ដូច្នេះខ្ញុំក៏សុខចិត្តធ្វើតាមគឺ ស្នើសុំឲ្យទាហានប្រចាំការថៃ នាំពួកយើងតាមរថយន្តឆ្ពោះទៅទីនោះ ។

នៅពេលទៅដល់ជំរុំវិទ្ធិសែន តារ៉ែត ចេញទៅជួបលោក ជា ឈុត ប្រធានជំរុំនងចាន់ ដែលបានមកជ្រកនៅបណ្ដោះអាសន្នក្នុងជំរុំវិទ្ធិសែននៅពេលនោះ រួចបន្ទាប់មក តារ៉ែត ក៏ចេញទៅជួបលោក លីវ ណេ ប្រធានជំរុំវិទ្ធិសែនទៀត ។ មេជំរុំទាំងពីរ យល់ព្រមតាមសំណើរបស់យើងភ្លាម ។ យើងទាំងអស់គ្នាសុទ្ធតែជឿស៊ប់ថា នឹងសម្រេចតាមគោលបំណងគឺ ប្រាកដជាគាស់បានកំណប់ដ៏មានតម្លៃមិនខានឡើយ ។ ទោះបីជាពួកយើងមិនទាន់ឃើញកំណប់យ៉ាងណាក៏ដោយ ក៏ពួកយើងមានផែនការបែងចែកកំណប់នោះជាបីចំណែកដែរគឺ ១/៣ ជូនមេជំរុំទាំងពីរ

១/៣ ជូន តារ៉ែត និង កូនចៅជាអង្គរក្ស ដែលបានកប់កំណប់ និង កម្លាំងឯទៀត របស់គាត់ ចំណែកនៅសល់ ១/៣ ជូន រ.ជ.រ.ប.ខ. ដែលមានខ្ញុំជាតំណាងទុកយក មកចំណាយក្នុងការតស៊ូរំដោះជាតិ ។ ទាំងអស់គ្នាសុខចិត្តឲ្យខ្ញុំជាតំណាងផ្ទាល់ របស់ប្រធានរ.ជ.រ.ប.ខ. ដែលមានអំណាចពេញទីក្នុងការបែងចែកកំណប់នោះទៅ អង្គភាពនានារបស់យើង ។ លោក ជា ឈុត និង លីវ ណោ បាននាំទាហានជាង ១០០ នាក់ ដើម្បីរក្សាសន្តិសុខផង ដើម្បីជាកម្លាំងក្នុងការគាស់រំលើងដំបូកមួយ ផង ។ នៅពេលដែលគេប្រាប់ថា កំណប់នោះស្ថិតនៅក្នុងដំបូកមួយកំពស់ប្រមាណ ១ម២០ លោក ជា ឈុត បញ្ជាឲ្យគាស់រំលើងដំបូកនោះភ្លាម ។ នៅពេលដែលពួក ទាហានចាប់ផ្តើមជីករំលើងដំបូកនោះ អ្នកចេះវិជ្ជាត្រៃវេទម្នាក់ក៏ផ្តួចផ្តើមគំនិត អង្គុយសមាធិប្រើវិជ្ជាភ្នែកទិព្វ ដើម្បីពិនិត្យមើលតាមផ្លូវងងឹតនូវការប្រព្រឹត្តិទៅនៃ ការគាស់កំណប់នេះ ។ នៅពេលដែលពួកទាហាន បានគាស់រំលើងអស់ដំបូកមួយ រួចទៅហើយៗបានជីកដីដម្រៅជាងពីរម៉ែត្រទៀតផងនោះ ក៏ពួកយើងនៅតែមិន ឃើញនូវកំណប់ ដែលយើងសង្ឃឹមថាមានតម្លៃខ្ពស់នោះសោះ ។

ពួកអ្នកជីកគាស់កកាយនោះ ធ្វើការតាំងពីម៉ោងបីរសៀល និង ពេញមួយ យប់ រហូតដល់ភ្លឺ ម៉ោងប្រាំព្រឹក ក៏នៅតែរកមិនឃើញ ។ ពួកគេអស់កម្លាំងហេវហត់ ណាស់ ។ ឯខ្ញុំក៏ទ្រាំចាំមើលអស់មួយយប់ ក្រោមទឹកសន្សើម ដោយមិនហ៊ានចេញ ទៅណាឡើយ ។ នៅពេលខ្ញុំសួរអ្នកអង្គុយសមាធិនោះថា ហេតុអ្វីបានជាពួកយើង រកកំណប់នោះមិនឃើញ ។ អ្នកចេះវិជ្ជាត្រៃវេទនោះ និយាយថា បារមីការពារទឹកដី តំបន់នេះគេមិនសប្បាយចិត្តជាមួយពួកយើង ព្រោះយើងអាងអំណាចជាអ្នកធំ អាងកម្លាំង ហើយចូលមកគាស់កកាយ ដោយមិនបានសុំម្ចាស់ទឹកម្ចាស់ដីជាមុន មុននឹងគាស់រំលើងដំបូករបស់គេ ។ អ្នកនោះបន្តទៀតថា ម្ចាស់ទឹកម្ចាស់ដីគេមិន ហ៊ានធ្វើអ្វីពួកយើងទេ ព្រោះយើងសុទ្ធតែមនុស្សអ្នកមានអំណាចតែបារមីបាននាំ

កំណប់ទៅកន្លែងដទៃទៀតផុតទៅហើយ ។

ព្រឹកនោះ តារ៉េត បាននាំខ្ញុំចេញពីកន្លែងគាស់រំលើង ទៅជួបអ្នកចូលរួមម្នាក់នៅក្នុងតំបន់ ដែលមានមនុស្សអ៊ូអរក្នុងភូមិជនភៀសខ្លួនឈ្មោះភូមិព្រៃចាន់ ។ អ្នកចូលរួមនោះ ជាស្ត្រីក្នុងអាយុ ៣០ ឆ្នាំប្លាយ ។ បើគ្រាន់តែក្រឡេកមើលភ្លាម គេអាចដឹងបានថាស្ត្រីនោះ ជាមនុស្សទីក្រុងបែបស៊ីវិល័យ មិនទំនងជាអ្នកចូលរួមអ្វីទេ ។ មែនទែនទៅ នេះជាលើកទីមួយដែលខ្ញុំបានជួប និង សកម្មភាពនៃអបិយជំនឿបែបនេះ ។ យើងបានរៀបចំទៀនធូប និង របស់របរជាអណ្តាប់តាមទម្លាប់ជូនទៅស្ត្រីនោះ ។ នៅពេលដែលគាត់អុជធូបរួច និង ថ្វាយបង្គំរួចហើយ ភ្លាមនោះ ខ្លួនស្ត្រីនោះហាក់ដូចជាកន្ត្រាក់ញ័រ ដែលជាសញ្ញាថា មានបារមីមកចូលក្នុងរូបរបស់គាត់ ។ បន្ទាប់មក សម្លេងខ្សាវៗ បានបន្លឺចេញតាមមាត់ស្ត្រីនោះ ។ បារមីបានបង្ហាញខ្លួនតាមពាក្យសំដីថា "ចៅៗមានការអ្វី? តាជាលោកតាឥសីចៅមានការអ្វីនិយាយភ្លាមៗមក ព្រោះតារវល់ខ្លាំងណាស់ - មានការអ្វីនិយាយមក-តាប្រញាប់ទៅកូឡាលំពួរ ទៅមើលគេប្រជុំអាស៊ានអំពីកម្ពុជា" ។ តារ៉េតជំរាបបារមីអំពីរឿងរ៉ាវរបស់ពួកយើង នៅពេលដែលខ្ញុំកំពុងលួចសើចក្នុងចិត្ត មិនហ៊ានឲ្យគេឃើញពីអាការៈខាងក្រៅ ដោយបានឮលោកតានិយាយពីការប្រជុំអាស៊ាន ។ ខ្ញុំនឹកក្នុងចិត្តថាលោកតា គួរតែរួមដំណើរជាមួយគណៈប្រតិភូរបស់យើងទៅចូលរួមប្រជុំអាស៊ាន ព្រោះថាបញ្ហាកម្ពុជា បានត្រូវប្រកូកប្រកាសទៅដល់ពិភពងងឹតទៅហើយ ។ តែជាការគួរឲ្យភ្ញាក់ផ្អើលចំពោះខ្ញុំគឺ អ្វីដែលលោកតាមហាឥសីប្រាប់យើងនៅពេលនេះ ក៏ដូចគ្នានឹងអ្វីដែលអ្នកអង្គុយធម៌ត្រៃវេទប្រាប់ពួកយើងពេលមុននោះបន្តិចដែរ ។

នៅទីបញ្ចប់ពួកយើងក៏បោះបង់ចោលនូវការស្វែងរកកំណប់នោះទៅ ដោយមានការខកចិត្តយ៉ាងខ្លាំង ។ ខ្ញុំខកចិត្តព្រោះមិនឃើញថាវិជ្ជាត្រៃវេទមានប្រសិទ្ធ

ភាពជាក់ស្តែងអាចជួយឲ្យពួកយើងរកបាននូវកំណប់ ដែលយើងចង់បាននោះឡើយ ។ ក៏ប៉ុន្តែ គ្រូមៀច ពន្យល់ថាប្រសិទ្ធភាពនៃវិជ្ជាត្រៃវេទគឺ អាស្រ័យលើការគោរពប្រណិប័តន៍វិន័យបានជាប់លាប់ឬទេ? ជាពិសេសការកាន់សីលប្រាំ ។ បើយើងមិនបានរក្សាសីលឲ្យបានត្រឹមត្រូវទេ វិជ្ជាត្រៃវេទមិនអាចជួយយើងបានទេ ។ ចំពោះខ្ញុំ តាមពិតទៅ ខ្ញុំមានការលំបាកក្នុងការរក្សាសីលឲ្យបានគ្រប់ទាំងប្រាំនោះណាស់ ។ បើខ្ញុំអាចកាន់បាន ៤ ការវៀរចាកសុរាជាការពិបាក ។ ខ្ញុំមិនមែនជាអ្នកប្រមឹក ឈប់ទទួលទានស្រាមិនបាននោះទេ ។ តែខ្ញុំត្រូវការទទួលទានខ្លះៗនៅពេលជួបជុំជាមួយអង្គទូតជាញឹកញាប់ តាមការអញ្ជើញរបស់ស្ថានទូតនីមួយៗ ក្នុងពិធីបុណ្យប្រចាំប្រទេសជាមិត្តនោះ ។ ចំណុចល្អអំពីវិជ្ជាត្រៃវេទគឺ វិជ្ជានេះបានជាស់តឿនខ្ញុំថាមនុស្សយើង រស់នៅជាមួយពិភពមួយទៀត ដែលងងឹតយើងមើលមិនឃើញ ។ ក្នុងឋានៈជាអ្នកកាន់ព្រះពុទ្ធសាសនា ខ្ញុំបានរៀនសូត្រ ដឹងថាឋានព្រហ្មជាឋានខ្ពស់ជាងគេ មុននឹងឡើងដល់ឋានព្រះនិព្វាន ។ ព្រះភ័ក្ត្រនីមួយៗនៃព្រះព្រហ្មជាតំណាងធម៌មេត្តា ករុណា មុទិតា និង ឧបេក្ខា ដែលអាចយោងមនុស្សឲ្យឡើងទៅជាមនុស្សប្រសើរឧត្តុង្គឧត្តមបំផុតនៅក្នុងលោក ។ នៅទសវត្សរ៍ឆ្នាំ ១៩៩០ នៅពេលដែលខ្ញុំទទួលការកិច្ចសរសេរអំពីកម្មវិធី និង គោលនយោបាយរបស់គណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនា ខ្ញុំបានយកធម៌ទាំងបួននេះជាមូលដ្ឋានដ៏សំខាន់នៃទស្សនវិជ្ជាក្នុងការដឹកនាំ ក៏ដូចជាសេរីភាពនៃឯកត្តបុគ្គល សិទ្ធិមនុស្ស និង លទ្ធិប្រជាធិបតេយ្យរបស់គណបក្សយើងដែរ ។

នៅជំរុំសាយធូ

ក្រោយពេលដែលកងទ័ពវៀតណាម និង កងទ័ព ហេង សំរិន (នៅសម័យនោះ យើងតែងនិយមហៅទ័ពរដ្ឋកម្ពុជាថាកងទ័ព ហេង សំរិន) បានវាយបោស

សំអាតជំរុំនៅតាមទល់ដែនអស់ក្នុងឆ្នាំ ១៩៨៤-១៩៨៥ មក ជនជន្លៀសខ្លួនខ្មែរ ត្រូវបានប្រមូលផ្តុំនៅជំរុំសាយធូនៅក្នុងទឹកដីថៃ ។ នៅពេលនោះ ស្ថានភាពរបស់ជនរួមជាតិទាំងនេះក៏មានការផ្លាស់ប្តូរដែរ ។ ពួកគេត្រូវរស់នៅក្នុងជំរុំដ៏ធំមួយ ដែលមានរបងលួសបន្លាហ៊ុំព័ទ្ធ និង ដោយមានទាហានអាវខ្មៅថៃ "សឿប្រាន" "ខ្លាព្រាន" យាមកាមយ៉ាងតឹងរឹងផង ។ ក្រោយបន្តិចមក អង្គភាព "ខ្លាព្រាន" នេះ បានដូរឈ្មោះមកថា "កងអង្គភាពការពារជនជន្លៀសខ្លួន" "Displaced Persons Protection Unit (DPPU) ឬ ហៅកាត់ឌីភីភីយូ ។ អង្គការសហប្រជាជាតិយូអិនប្រូ បន្តនយោបាយផ្តល់ជំនួយសង្គ្រោះបន្ទាន់ដដែល ដូចកាលនៅលើទឹកដីខ្មែរដែរ គឺ មិនមាននយោបាយជួយក្នុងលក្ខណៈ ឲ្យមានទីជំរកជាអចិន្ត្រៃយ៍នោះឡើយ ។ ក៏ប៉ុន្តែទោះជាយើងយល់នូវនយោបាយរបស់យូអិនប្រូ និង រាជរដ្ឋាភិបាលថៃក្នុងការផ្តល់តែជំនួយសង្គ្រោះបន្ទាន់យ៉ាងណាក្តី ក៏ពួកយើងអ្នកទទួលខុសត្រូវខ្មែរនៅតែមានចេតនាផ្តល់ដល់ជនរួមជាតិទាំងនោះ នូវកម្មវិធីអភិវឌ្ឍន៍ដែលអាចធ្វើពួកគេឲ្យទៅជាពលរដ្ឋល្អ និង ប្រកបដោយការទទួលខុសត្រូវ នាពេលអនាគតក្នុងប្រទេសមួយដែលសេរី និង កាន់លទ្ធិប្រជាធិបតេយ្យ ។

នៅពេលដែលត្រូវប្រមូលមកនៅផ្តុំគ្នាក្នុងជំរុំសាយធូតែមួយក៏ដោយ ក៏ប្រធានជំរុំនានា នៅតែមានការបែកបាក់គ្នាជាពីរក្រុមដដែល ទោះបីជាលោកតា សឺន សាន ព្យាយាមធ្វើការបង្រួបបង្រួម និង ទោះបីជាលោកតាប្រធានបានតែងតាំងលោកឧត្តមសេនីយ សក់ ស៊ុតសាខន ជាអគ្គមេបញ្ជាការក.ជ.រ.ប.ខ.យ៉ាងណាក៏ដោយ ។ អ្នកដឹកនាំជំរុំអំពិល និង ជំរុំរ៉ិទ្ធីសែន នៅតែគាំទ្រលោកឧត្តមសេនីយ សក់ ស៊ុតសាខន ដដែល ព្រោះពួកគេយល់ថា ពួកគេនៅជួរមុខត្រូវតែជួយគាំទ្រកងទ័ព ។ នៅថ្ងៃទី ១៧ ធ្នូ ១៩៨៧ នៅពេលដែលលោកតា សឺន សាន ទៅធ្វើទស្សនកិច្ចនៅជំរុំសាយធូ មានបើកអង្គប្រជុំមួយដែលមានលោកឧត្តម

សេនីយ សក់ ស៊ុតសាខន លោកឧត្តមសេនីយ ជៀន ដែល និង លោក នាង ជិនហន ផង រួមទាំងអ្នកទទួលខុសត្រូវឯទៀតចូលរួម ដើម្បីពិភាក្សាអំពីការរៀបចំស្ថាប័នស៊ីវិលនានា ជាពិសេសការបង្កើតរដ្ឋបាលកណ្តាលមួយនៅសាយធូ ។ នៅពេលប្រជុំនោះ លោកឧត្តមសេនីយ ជៀន ដែល និង អ្នកគាំទ្ររបស់គាត់ នៅតែទទូចសុំឲ្យរដ្ឋបាលសាយធូស្ថិតនៅក្រោមអំណាចរបស់កងទ័ព ក៏ប៉ុន្តែ នៅទីបំផុត លោកឧត្តមសេនីយសុខចិត្តទទួលយកតាមសេចក្តីសម្រេចរបស់ប្រធាន ។ សូមបញ្ជាក់ថា នៅក្នុងអង្គប្រជុំនោះមានការដេកគ្នាយ៉ាងខ្លាំងរវាងលោកតា សឺន សាន និង លោកឧត្តមសេនីយ ជៀន ដែល ដោយសារលោក ជៀន ដែល បានចោទលោកតា សឺន សាន ថាមានបំណងចង់លក់ដីស្ថានទូតខ្មែរនៅឯទីក្រុងតូក្យូនៃប្រទេសជប៉ុន ។ តាមពិតទៅ លោកតាប្រធានមិនបានលក់ដីនោះ ដូចការចោទប្រកាន់ទេ គ្រាន់តែចង់ជួលតាមរបៀប (Leasing)គឺ ជួលសិនមុននឹងលក់ ។

នៅខែ មករា ១៩៨៨ លោកតា សឺន សាន បានតែងតាំងខ្ញុំឲ្យធ្វើជាតំណាងរបស់គាត់ទទួលបន្ទុកខាងរដ្ឋបាលស៊ីវិល[197] ។ ក្នុងហាន:នេះ ដោយឆ្លៀតឱកាស ដែលហាក់ដូចមានឯកភាពផ្ទៃក្នុងដ៏កម្រនាពេលនោះ ខ្ញុំក៏បានកោះអញ្ជើញប្រធានជំរុំទាំងអស់មកជួបជុំគ្នា ដើម្បីធ្វើការបោះឆ្នោតរើសគណៈកម្មាធិការកណ្តាលមួយ ដើម្បីសម្របសម្រួលសកម្មភាពទាំងអស់នៅក្នុងជំរុំសាយធូទាំងមូល ។ សូមបញ្ជាក់ថាប្រធានជំរុំទាំងអស់ នៅតែរក្សាអត្តសញ្ញាណរបស់ខ្លួន និងគ្រប់គ្រងប្រជាពលរដ្ឋរបស់ខ្លួនដែលធ្លាប់រស់នៅក្នុងជំរុំលើទឹកដីខ្មែរ ទោះជាត្រូវបានប្រមូលមករស់នៅក្នុងជំរុំសាយធូយ៉ាងណាក៏ដោយ ។ ម្យ៉ាងទៀត ទាំងយូអិនប្រូ ទាំងអាជ្ញាធរថៃ ក៏មិនជ្រៀតជ្រែកក្នុងការរៀបចំណាមួយរបស់ខាងភាគីខ្មែរដែរនៅសម័យនោះ ។ លោក ធូ ឋុន និង លោក ង៉ែត សូផុន ប្រធានជំរុំរ៉ិទ្ធិសែន និង

[197] Son Sann, Khmer Peoples's National Liberation Front, Décision no.88-01/FNL, Fait le 31 Janvier 1988.

ប្រធានជំរុំអំពិល ដែលជាអ្នកគាំទ្រដ៏សំខាន់របស់លោកឧត្តមសេនីយ សក់ ស៊ុតសាខន ក៏បានចូលរួមក្នុងការបោះឆ្នោតនោះដែរ ។ តាមរយៈការបោះឆ្នោតនេះ លោក ឡាយ ខែក ត្រូវបានជាប់ឆ្នោតជាប្រធានគណៈកម្មាធិការនៃរដ្ឋបាលកណ្តាលរបស់ជំរុំសាយធូទាំងមូល ។ ភ្លាមៗនោះ ខ្ញុំបានទទួលជោគជ័យយ៉ាងធំក្នុងការបង្រួបបង្រួមមេជំរុំទាំងអស់ នៅក្នុងគណៈកម្មាធិការកណ្តាលនេះ ។

ការងារផ្នែកសិទ្ធិមនុស្ស

ក្នុងប៉ុន្មានឆ្នាំកន្លងមកមុននេះ ទាហានមួយចំនួននៃក.ជ.រ.ប.ខ.បានត្រូវទទួលការចោទប្រកាន់ថាបានរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ ដែលជាអំពើផ្ទុយពីគោលការណ៍របស់រ.ជ.រ.ប.ខ. ដែលត្រូវសង្គ្រោះ បំរើ ការពារប្រជាពលរដ្ឋខ្មែរ ។ តាមពិតទៅ ទាហានទាំងនោះភាគច្រើន ជាក្រុមដែលគ្រាន់តែយកឈ្មោះរ.ជ.រ.ប.ខ.មកប្រើ ក៏ប៉ុន្តែរស់នៅរបៀបឯករាជ្យម្ចាស់ការខ្លួនគេ តាមរយៈសកម្មភាពរត់ពន្ធ និង ការគាបសង្កត់យ៉ាងព្រៃផ្សៃទៅលើជនភៀសខ្លួនដែលរត់មកតំបន់ជាយដែនខ្មែរ-ថៃ ។ ដោយសារមានការចោទប្រកាន់បែបនេះ អាជ្ញាធរយោធាថៃ បានដកមេដឹកនាំរ.ជ.រ.ប.ខ.បួននាក់ចេញពីតំបន់ទល់ដែន នៅខែ កុម្ភៈ ១៩៨៨ គឺ លោក ឧត្តមសេនីយ ជៀន ដែល លោក ហ៊ឹង គន្ធុន លោក ជា ឈុត និង លោក លីវ ណោ ។ ដោយមិនបានឲ្យថ្នាក់ដឹកនាំជាន់ខ្ពស់រ.ជ.រ.ប.ខ.ដឹងអ្វីទាំងអស់ អ្នកទាំងបួននាក់នោះ ត្រូវបញ្ជូនតាមឧទ្ធម្ភាគចក្រ មកបន្ទាយកងទ័ពពិសេសថៃនៅខេត្តលុបបូរី ។ ទំនងប្រហែលគ្រាន់តែជានុយ ដើម្បីទាក់ទាញសហសេវិកពីរនាក់ទៀតឲ្យមកជាមួយ លោកឧត្តមសេនីយ ជៀន ដែល និង លោក ហ៊ឹង គន្ធុន ត្រូវបានដោះលែងឲ្យវិលត្រឡប់ទៅកន្លែងដើមវិញ ក្រោយដែលបានសម្រាកនៅក្នុងបន្ទាយកងទ័ពពិសេសក្នុងផ្ទះសុវត្ថិភាពអស់រយៈពេល ២៤ ម៉ោង ។ ចំណែក

លោក ជា ឈុត និង លីវ ណេ ត្រូវបន្តស្ថិតនៅក្នុងបន្ទាយលុបបូរី អស់រយៈពេលមួយសប្តាហ៍ មុននឹងត្រូវបញ្ជូនមកឲ្យរស់នៅជាមួយពួកយើងឯទីក្រុងបាងកក ។

នៅជំរុំសាយធូមានតែជនស៊ីវិលទេ ដែលអាចស្នាក់នៅបានគ្មានទាហានណាម្នាក់អាចនៅទីនោះបានឡើយ ។ ដើម្បីជៀសវាងកុំឲ្យមានអំពើរំលោភសិទ្ធិមនុស្ស ដូចដែលត្រូវបានចោទប្រកាន់ក្នុងពេលកន្លងមក រ.ជ.រ.ប.ខ.ក៏បានផ្តួចផ្តើមគំនិតធ្វើការអប់រំ និង បង្កើតស្ថាប័នការពារសិទ្ធិមនុស្សនេះឡើង ។ ខ្ញុំនឹកថានៅសម័យនោះ ក្នុងចំណោមចលនាតស៊ូតាមជាយដែន រ.ជ.រ.ប.ខ.ប្រហែលជាចលនាតស៊ូខ្មែរតែមួយគត់ដែលបានគិតគូរអំពីបញ្ហាសិទ្ធិមនុស្សនេះ ។ ដំបូងឡើងពួកយើងបង្កើតការិយាល័យសិទ្ធិមនុស្សមួយនៅក្នុងជំរុំ ដែលមានការកិច្ចរាយការណ៍ជូនថ្នាក់ដឹកនាំជាន់ខ្ពស់ រាល់អំពើរំលោភសិទ្ធិមនុស្សដែលកើតមាន និងផ្សព្វផ្សាយឯកសារ ឬ សៀវភៅ ព្រមទាំងធ្វើការអប់រំដល់ជនស៊ីវិល និង ទាហានឲ្យយល់ដឹងអំពីសិទ្ធិមនុស្ស ។ ដោយសារការបង្កើតការិយាល័យសិទ្ធិមនុស្សនេះទើបអង្គការយូអិនប្រូ បានផ្តល់ថវិកាមួយចំនួន ដើម្បីឲ្យពួកយើងបកប្រែ និងបោះពុម្ពផ្សាយជាកូនសៀវភៅរាប់ពាន់ក្បាលស្តីពីសិទ្ធិមនុស្ស ។ ខ្ញុំជឿថា ខ្ញុំជាខ្មែរម្នាក់ ក្នុងសម័យក្រោយរបបប្រល័យពូជសាសន៍ ក្នុងចំណោមខ្មែរមួយចំនួនតូចដែលបានធ្វើការបកប្រែនូវសេចក្តីប្រកាសសកលនៃសិទ្ធិមនុស្ស ពីភាសាអង់គ្លេសមកភាសាខ្មែរ ។ យើងបានបញ្ជូនមកក្នុងស្រុកនូវសៀវភៅ និង ឯកសារផ្សេងៗទៀតស្តីពីសិទ្ធិមនុស្ស ដែលត្រូវបានបងប្អូនមួយចំនួន យកមកធ្វើជាដើមទុនបង្កើតអង្គការក្រៅរដ្ឋាភិបាលខាងសិទ្ធិមនុស្សរហូតដល់សព្វថ្ងៃ ។

លើសនេះទៅទៀត ដោយសារមានមិត្តភក្តិជាច្រើននៅសភាអឺរ៉ុប ជាពិសេស មានជំនួយពីព្រះអង្គម្ចាស់នៃប្រទេសអូទ្រីស ព្រះនាម អុតតូ វ៉ុន ហាប្សបួរ (Otto Von Habsburg) រ.ជ.រ.ប.ខ. បានរៀបចំសន្និទអន្តរជាតិមួយក្រោមប្រធាន

បទ "សិទ្ធិមនុស្សដើម្បីកម្ពុជា" នៅទីក្រុងស្ត្រាបួរ នៃប្រទេសបារាំង ពីថ្ងៃទី ១២ ទៅ ១៤ ធ្នូ ១៩៨៨ ។

គោលបំណងនៃសន្និសីទអន្តរជាតិនោះគឺ ជំរាបសហគមន៍អន្តរជាតិអំពីសភាពការណ៍សិទ្ធិមនុស្សនៅកម្ពុជា បន្ទាប់ពីរបប ប៉ុល ពត និង បន្ទាប់ពីការលុកលុយរបស់កងទ័ពវៀតណាម ។ នៅក្នុងសន្និសីទនោះ លោកតា សឺន សាន[198] ក្រៅពីរៀបរាប់ពីស្ថានភាពនៃការគោរពសិទ្ធិមនុស្សនៅក្នុងជំរុំ បានវាយប្រហារយ៉ាងខ្លាំងទៅលើអំពើរំលោភរបស់កងទ័ពវៀតណាម និង របបរដ្ឋកម្ពុជានៅភ្នំពេញ ។ ចំពោះការចោទប្រកាន់អំពីការរំលោភសិទ្ធិមនុស្សនៅក្នុងជួរ.ជ.រ.ប.ខ. លោកតា សឺន សាន ប្រកាសថា រ.ជ.រ.ប.ខ. បើកទ្វារចំហរឲ្យមានការស៊ើបអង្កេតជានិច្ច ចំពោះរាល់សកម្មភាពរំលោភសិទ្ធិមនុស្ស ដោយអង្គការអន្តរជាតិនានាខាងផ្នែកសិទ្ធិមនុស្ស ។ លោកតាថ្លែងសូមឲ្យអង្គការទាំងនោះ មកជួយបោសសំអាតអំពើខុសឆ្គងទាំងឡាយណា ដែលអាចកើតមាននៅក្នុងរ.ជ.រ.ប.ខ. ។ ក៏ប៉ុន្តែលោកតាភ្លូកភ្លែរ និង តវ៉ាថា "រហូតមកដល់ពេលនេះ គេបោសសំអាតតែមួយជ្រុងតុ ខ្ញុំសូមឲ្យគេសំអាតតុទាំងមូល គ្រប់ជ្រុងទាំងអស់" ។ តាមពិតទៅ លោកតាប្រធានចង់តវ៉ាថាអង្គការអន្តរជាតិចោទប្រកាន់តែខាង សឺន សាន ឯខាង សក់ ស៊ុតសាខន គេហាក់ដូចជាមិនដឹងមិនឮដូចជាករណី ដែលគេឲ្យលោកឧត្តមសេនីយ ដៀន ដែល និង លោក ហ៊ឹង គន្ធុន រួចខ្លួន តែគេដាក់ទណ្ឌកម្មលើលោក ជា ឈុត និង លោក លីវ ណេ ជាកស្តុតាងស្រាប់ ។

នៅក្នុងសម័យនោះ ដោយសារលោកតា សឺន សាន ជារដ្ឋមន្ត្រីទី១នៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ លោកតាមិនបានយកវេទិកានៃសន្និសីទនេះ

[198] Son Sann, Speech delivedred at the International Conference, Human Rights For Cambodia, Survey and Prospects, Strasbourg, France, December 12-14, 1988.

ទៅវាយប្រហារឲ្យបានខ្លាំងក្លាលើអំពើប្រល័យពូជសាសន៍របស់ ប៉ុល ពត ទេ ព្រោះអាចនាំឲ្យទន់ខ្សោយ ឬ ប៉ះពាល់ដល់កម្លាំងប្រយុទ្ធប្រឆាំងកងទ័ពវៀតណាម នៅកម្ពុជា ។ ក៏ប៉ុន្តែ សិទ្ធិមនុស្សបានក្លាយជាមូលដ្ឋានទស្សនវិជ្ជានៃការតស៊ូប្រឆាំងរាល់អំណាចផ្តាច់ការរបស់រ.ជ. រ.ប.ខ. ។ នៅខែ តុលា ១៩៩១ ការគោរពសិទ្ធិមនុស្ស ក៏បានក្លាយទៅជាផ្នែកមួយនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសស្តីពីកម្ពុជា បន្ថែមលើផ្នែកផ្សេងទៀតដូចជា៖ ការបោះឆ្នោត យោធា រដ្ឋបាលស៊ីវិល មាតុភូមិនិវត្តន៍ និង ការស្តារ និង កសាងហេដ្ឋារចនាសម្ព័ន្ធឡើងវិញ ។

គណៈកម្មការយុត្តិធម៌

ជាមួយនឹងការងារផ្នែកសិទ្ធិមនុស្ស រ.ជ.រ.ប.ខ.ក៏យកចិត្តទុកដាក់ចំពោះផ្នែកយុត្តិធម៌ ។ អស់រយៈពេលច្រើនឆ្នាំ វិស័យយុត្តិធម៌មិនត្រូវបានយកចិត្តទុកដាក់ឡើយ ឬ ក៏គ្មានរូបរាងសោះក៏អាចថាបាន ។ លោកតា សឺន សាន បន្ទោសលោក អតីតអគ្គលេខាធិការ នាង ជិនហន ថាមិនបានគិតគូររៀបចំប្រព័ន្ធតុលាការ ឬ ការរៀបចំឲ្យមានច្បាប់ខ្លះៗនៅក្នុងជំរុំ ។ តាមពិតទៅ នៅក្នុងជំរុំដែលមិនស្ថិតក្រោមអធិបតេយ្យរបស់យើង ការរៀបចំប្រព័ន្ធតុលាការពិតជាមិនមែនងាយស្រួលទេ ។ ម្យ៉ាងទៀត កាលពីពេលដែលជំរុំមានទីតាំងនៅលើទឹកដីខ្មែរ ប្រធានជំរុំនីមួយៗធ្វើការគ្រប់គ្រងរបស់គេដូចជាស្តេចត្រាញ់យ៉ាងដូច្នេះដែរ ។ នៅខែ មីនា ១៩៩០ លោកតា សឺន សាន បានតែងតាំងរូបខ្ញុំឲ្យទទួលមុខនាទីជាសមាជិកគណៈកម្មាធិការប្រតិបត្តិទទួលខុសត្រូវខាងផ្នែកយុត្តិធម៌ បន្ថែមលើមុខងារជាអគ្គលេខាធិការទៀត[199] ។ ដូច្នេះនៅជំរុំសាយធូ ពួកយើងក៏ចាប់ផ្តើមរៀបចំឲ្យមានគណៈកម្មការ

[199] សឺន សាន, ណេសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ, ក្រឹត្យលេខ ៩០/០៣/រដក, ធ្វើនៅតំបន់រំដោះ ថ្ងៃទី ១២ មីនា ១៩៩០ ។

យុត្តិធម៌មួយ ដោយយើងមិនបង្កើតសាលាកាត់ក្តីអ្វីទេ ។ គណៈកម្មការយុត្តិធម៌ទទួលពាក្យបណ្តឹង ធ្វើការស៊ើបអង្កេត ធ្វើសវនាការគូក្តី រួចធ្វើអនុសាសន៍ផ្តល់ដល់ទាំងដើមចោទ ទាំងចុងចម្លើយ ។ ដោយយើងគ្មានច្បាប់ យើងបានជាវក្រមព្រហ្មទណ្ឌ និង ក្រមរដ្ឋប្បវេណីថៃយកបកប្រែជាខ្មែរ និង ស្រង់យកចំណុចខ្លះៗមកប្រើ និង អនុវត្តតាមតាមករណីខ្លះៗដែលអាចអនុវត្តបាន ។ ពេលនោះ ខ្ញុំគិតថាចំណាត់ការបែបនេះ ក៏គ្រាន់បើជាងគ្មានច្បាប់ទម្លាប់អ្វីទាំងអស់នោះដែរ ។ រឿងមួយដែលខ្ញុំចាំមិនភ្លេចនោះគឺ ក្រោយដែលបានបកប្រែក្រមព្រហ្មទណ្ឌថៃជាភាសាខ្មែររួចហើយ ប្រធានគណៈកម្មការយុត្តិធម៌នៅជំរុំដងរែក ដែលខ្ញុំចាត់ឲ្យបកប្រែក្រមនោះ ក៏ប្រកាសឲ្យប្រើច្បាប់ដោយខ្លួនឯង ដោយមិនចាំបាច់សុំច្បាប់ពីខាងលើឡើយ ។ ការនេះធ្វើឲ្យខ្ញុំមានការមិនពេញចិត្តយ៉ាងខ្លាំង ។

មានបញ្ញវ័ន្តចូលមកជួយ

ចាប់តាំងពីពេលដែលខ្ញុំចូលមកកាន់តំណែង ជាអគ្គលេខា.ជ.រ.ប.ខ.មក ខ្ញុំក៏មានភ័ព្វសំណាង ដោយមានបញ្ញវ័ន្ត និង អតីតមន្ត្រីដែលមានបទពិសោធន៍ចូលមកជួយធ្វើការផងដែរ ។ ក្នុងនោះមានលោកបណ្ឌិត ឡៅ ម៉ុងហៃ ដែលមានសញ្ញាប័ត្រថ្នាក់បណ្ឌិតសេដ្ឋកិច្ច ហើយបានលះបង់លាចាកក្រុមគ្រួសារនៅប្រទេសអង់គ្លេសមកចូលរួមជួយការងាររបស់យើង នៅឯការិយាល័យទីក្រុងបាងកក ។ លោក ឡៅ ម៉ុងហៃ ទទួលបន្ទុកជួយរៀបចំអត្ថបទទាំងអស់ជាភាសាអង់គ្លេស ។ នៅខែ មីនា ១៩៩០ គាត់ត្រូវបានតែងតាំងជាសមាជិកគណៈកម្មាធិការប្រតិបត្តិទទួលបន្ទុកខាងសេដ្ឋកិច្ច ។

បង ប៉ែន ថុល ដែលជាកូនប្រុសច្បងរបស់សម្តេច ប៉ែន នុត និង ជាបងរបស់សពបង ប៉ែន ថាល់ ក៏បានស្ម័គ្រចិត្តមកជួយធ្វើការនៅជាមួយពួកយើងឯទី

ក្រុងបាងកកដែរ ។ បង ប៉ែន ចុល ធ្លាប់កាន់តំណែងជារដ្ឋលេខាធិការក្រសួងពាណិជ្ជកម្មក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ នាសម័យសង្គមរាស្ត្រនិយមរបស់សម្តេចសីហនុ ។ គាត់ត្រូវបានទទួលការតែងតាំងជាប្រធានខុទ្ទកាល័យនៃប្រធានរ.ជ.រ.ប.ខ. និង ប្រធានខុទ្ទកាល័យរដ្ឋមន្ត្រីទី១នៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ។ លោក ប៉ែន ចុល ជួយខ្ញុំក្នុងការងារផ្នែកការទូត និង ទំនាក់ទំនងអន្តរជាតិ ។ ម្យ៉ាងទៀត បង ប៉ែន ចុល ក៏ទទួលបន្ទុករៀបរៀងអត្ថបទខាងភាសាបារាំងដែរ ។ បន្ទាប់មកទៀត លោក សៀង ឡាប្រេស្ស ដែលជាអ្នកនិយាយព័ត៌មានតាមវិទ្យុសម្លេងស.រ.អា (VOA) ដ៏ល្បីល្បាញក៏បានស្ម័គ្រចិត្តមកជួយធ្វើការនៅជាមួយពួកយើងដែរ ។ នៅពេលគាត់ឡើងនិយាយជាសាធារណៈម្តងៗ អ្នកស្តាប់តែងលាន់មាត់ថា "អូ! សម្លេងស.រ.អា ចាប់ផ្សាយហើយ" ។

ពួកយើងរកវិធីពង្រីកការអប់រំ នៅក្នុងជំរុំ

ជាមួយនឹងវិស័យសិទ្ធិមនុស្ស ក្រុមយើងក៏យកចិត្តទុកដាក់ក្នុងវិស័យអប់រំដែរ ។ យើងយល់ថាការអប់រំ និង ចំណេះវិជ្ជា ធ្វើឲ្យប្រជាពលរដ្ឋយើងមើលឃើញជើងមេឃវែងឆ្ងាយជាងពីបរិវេណជំរុំដែលត្រូវហ៊ុំព័ទ្ធដោយលួសបន្លានេះណាស់ ។ ដោយមានការឧបត្ថម្ភពីអង្គការមូនិធិអាឡឺម៉ង់ឈ្មោះហៅថា ខុនរ៉ាដ អាឌិនណៅអ៊ែរ (Konrad Adenauer Foundation) យើងបានរៀបចំជាមជ្ឈមណ្ឌលស្រាវជ្រាវព្រះពុទ្ធសាសនាមួយនៅជំរុំរ៉ិទ្ធិសែន ដើម្បីធ្វើការស្រាវជ្រាវអំពីប្រយោជន៍នៃព្រះពុទ្ធសាសនា នៅក្នុងសង្គមខ្មែរព្រមជាមួយមូលហេតុនៃការឡើងកាន់អំណាចរបស់ពួកខ្មែរក្រហម និង របបប្រល័យពូជសាសន៍ ។ ព្រះគ្រូ ពិន សែម ចៅអធិការវត្តរិទ្ធិសែន និង ភិក្ខុ ហេង មណីចិន្តា បានជួយឲ្យគំរោងការនេះមានដំណើរការល្អបានលទ្ធផលគួរជាទីពេញចិត្ត ។ ភិក្ខុ ហេង មណីចិន្តា ជាភិក្ខុនៅវ័យក្មេងតែខំយក

ចិត្តទុកដាក់ក្នុងការងារ ។ ពួកយើងបានតែងតាំងលោកឲ្យធ្វើជានាយកនៃមជ្ឈមណ្ឌលស្រាវជ្រាវនេះ ។

ជាមួយនឹងមជ្ឈមណ្ឌលស្រាវជ្រាវខាងព្រះពុទ្ធសាសនា មូនិធិ ខុនរ៉ាដ អាឌិន ណៅអ៊ែរ ក៏ជួយឧបត្ថម្ភសាលាហ្វឹកហាត់បច្ចេកទេសមួយ ដែលយើងបង្រៀនមុខវិជ្ជាខាងផ្នែកជាងជួសជុលរថយន្ត ជាងភ្លើងអគ្គិសនី និង ជាងអេឡិចត្រូនិច ។ ក្រៅពីនោះ យើងក៏មានបើកការបង្រៀនភាសាបរទេស ជាពិសេស ភាសាអង់គ្លេសជូនដល់ប្រជាពលរដ្ឋរស់នៅក្នុងជំរុំនេះផង ។ កម្មវិធីទាំងនោះ មានប្រជាប្រិយភាពណាស់ ។ អ្នកចេះភាសាបរទេសទាំងនោះ អាចមានលទ្ធភាពរកការធ្វើបាននៅក្នុងជំរុំជាមួយអង្គការក្រៅរដ្ឋាភិបាល ឬ អង្គការអន្តរជាតិនានាដែលកំពុងផ្តល់សេវានៅក្នុងជំរុំសាយធូ ។ អ្នកខ្លះទៀតជាប់តេស្តខាងភាសា អាចឲ្យគេចេញទៅរស់នៅប្រទេសទីបីដូចជា នៅកាណាដា ស.រ.អា ចក្រភពអង់គ្លេស ឬ នៅអូស្ត្រាលីបាន ។

មជ្ឈមណ្ឌលស្រាវជ្រាវព្រះពុទ្ធសាសនា ក៏បានចេញផ្សាយនូវព្រឹត្តិប័ត្រមួយឈ្មោះ "ព្រះពុទ្ធសាសនា និង សង្គមខ្មែរ" ព្រមទាំងសៀវភៅឯទៀតទាក់ទងនឹងព្រះពុទ្ធសាសនា លទ្ធិប្រជាធិបតេយ្យ ប្រវត្តិសាស្ត្រ ទំនៀមទម្លាប់ខ្មែរដូចជា៖ ពលរដ្ឋវិជ្ជា លទ្ធិប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនាជាដើម ។ល។ មជ្ឈមណ្ឌលនេះ ក៏បានបោះពុម្ពឡើងវិញនូវវចនានុក្រមខ្មែរសម្តេច ជួន ណាត និង វចនានុក្រមខ្មែរ-បារាំងរាប់ពាន់ក្បាលទៀតផង ។ តែជាការគួរឲ្យស្តាយឯកសារទាំងនោះ រួមទាំងវចនានុក្រមផង បានត្រូវឆេះអស់មួយចំនួនធំ នៅពេលតែប៉ុន្មានខែមុនការធ្វើមាតុភូមិនិវត្តន៍នៃជនភៀសខ្លួន នៅក្នុងជំរុំសាយធូ ដោយអគ្គីភ័យដ៏ធំមួយ ។ ដោយសារមានការឧបត្ថម្ភពីអង្គការអន្តរជាតិ យើងក៏បន្ថែមកម្មវិធី

អប់រំឲ្យឡើងដល់កំរិតមធ្យមសិក្សា ទោះជាអង្គការយូអិនប្រូ និង អាជ្ញាធរថៃ កំណត់តែត្រឹមការសិក្សាបឋមសិក្សាយ៉ាងណាក៏ដោយ ។

ចាប់តាំងពីមកដល់ទីស្នាក់ការរបស់យើង លោកបណ្ឌិត ឡៅ ម៉ុងហៃ ក៏បានផ្តល់យោបល់ឲ្យបង្កើតវិជ្ជាស្ថានមួយ ដើម្បីអប់រំហ្វឹកហ្វឺនក្របខ័ណ្ឌរដ្ឋបាលរបស់យើងសម្រាប់ពេលអនាគត ដែលប្រទេសកម្ពុជាយើងនឹងត្រូវការក្នុងពេលកសាងប្រទេសឡើងវិញ ។ ខ្ញុំ ក៏លើកគំនិតនោះទៅពិភាក្សាជាមួយលោកតា សឺន សាន ដែលគាំទ្រគំនិតនេះភ្លាម ។ ដូច្នេះ យើងក៏ចាត់ឲ្យលោកបណ្ឌិត ឡៅ ម៉ុងហៃ ទទួលបន្ទុកជានាយកនៃវិជ្ជាស្ថាននេះ ដែលមានឈ្មោះថា "វិជ្ជាស្ថានរដ្ឋបាលសាធារណៈ" ។ ក៏ប៉ុន្តែនៅពេលនោះ វិជ្ជាស្ថាននេះ មានតែនាយកម្នាក់ នៅមិនទាន់មានបុគ្គលិកដូចជាសាស្ត្រាចារ្យជំនាញ ដែលមានគុណសម្បត្តិត្រឹមត្រូវគ្រប់គ្រាន់ទាំងអស់ ។ ដើម្បីដោះស្រាយបញ្ហានេះ ខ្ញុំក៏បានស្នើសុំឲ្យអាជ្ញាធរថៃជួយដោះស្រាយបញ្ហាកង្វះខាតគ្រូឧត្តមសិក្សានេះ ។ នៅទីក្រុងបាងកក ខ្ញុំក៏បានទៅជួបលោកអនុប្រធានអគ្គនាយកដ្ឋានអង្គការអន្តរជាតិនៃក្រសួងការបរទេសថៃ ។ ខ្ញុំសុំជំនួយពីរាជរដ្ឋាភិបាលថៃ ដើម្បីអនុវត្តកម្មវិធីអប់រំផ្នែកឧត្តមសិក្សា ដោយម្យ៉ាងសុំបញ្ជូននិស្សិតខ្មែរឲ្យទៅរៀននៅសាកលវិទ្យាល័យថៃ ឬ ម្យ៉ាងទៀតសុំបញ្ជូនសាស្ត្រាចារ្យថៃឲ្យមកបង្រៀននិស្សិតខ្មែរនៅក្នុងជំរុំជនភៀសខ្លួន ។ យើងសុំជំនួយនេះ ដោយយើងប៉ាន់ប្រមាណឃើញសេចក្តីត្រូវការខាងធនធានមនុស្សរបស់ខ្មែរយើង នាពេលអនាគត ។ លោកអនុប្រធានអគ្គនាយកដ្ឋានថៃ ឆ្លើយយ៉ាងត្រង់មកខ្ញុំយ៉ាងដូច្នេះ៖ "ហេតុដូចម្តេចបានជាលោកសុំឲ្យប្រជាពលរដ្ឋលោក ដែលគ្រាន់តែជាជនភៀសខ្លួននោះឲ្យអាចរៀនដល់ឧត្តមសិក្សាបាន បើខ្លួនខ្ញុំផ្ទាល់ខ្ញុំមិនអាចទាំងឲ្យកូនរៀនដល់ថ្នាក់មធ្យមសិក្សាផង នេះមិនទាន់និយាយដល់អ្នកភូមិថៃ ដែលកំពុងរស់នៅក្បែរសោយធូ មិនអាចបញ្ជូនកូនចៅពួកគេ ទៅរៀននៅសាលាបឋមសិក្សា

ផងនោះ" ។ ដូច្នេះអាជ្ញាធរថៃ ក៏ទាត់ចោលសំណើរបស់ពួកយើង ។ ក៏ប៉ុន្តែពួកយើងក៏មិនបាក់ទឹកចិត្តអ្វីដែរ យើងនៅតែព្យាយាមរកមធ្យោបាយ ដើម្បីអនុវត្តកម្មវិធីឧត្តមសិក្សារបស់យើងតទៅទៀត ។ ដោយបានជំនួយហិរញ្ញវត្ថុពីមូលនិធិ ខុន រ៉ាដ អាឌិនណៅអែរ និង ក្រោយៗមក ក៏មានអង្គការក្រៅរដ្ឋាភិបាលឯទៀតជួយផងដែរមាន អង្គការកូអែរ និង សមាគមបារាំងឈ្មោះ អាហ្សៀ ពួ ឡឺ កាំបូដ (ធ្វើសកម្មភាពដើម្បីកម្ពុជា) យើងក៏សម្រេចដោះស្រាយបញ្ហានេះបាន ។ យើងបានសុំច្បាប់ឲ្យយុវជនបារាំងដែលជាសមាជិកសមាគមបារាំងខាងលើ ឲ្យចូលមកបង្រៀននៅក្នុងជំរុំពេលថ្ងៃ ហើយចេញទៅសម្រាកនៅភូមិថៃនៅក្បែរនោះឈ្មោះភូមិតាប្រាយ៉ានៅពេលយប់ ។ យើងជួលផ្ទះឲ្យអ្នកទាំងនោះស្នាក់នៅ និង ផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់ម្ហូបអាហារប្រចាំថ្ងៃផង ។ យុវជនបារាំងទាំងនោះសុទ្ធតែមានសញ្ញាប័ត្រចេញពីសាកលវិទ្យាល័យបារាំង ហើយមកស្ម័គ្រចិត្តបង្រៀននៅវិដ្ឋាស្ថានរដ្ឋបាលសាធារណៈ តាមជំនាញរបស់គេដែលមានមុខវិជ្ជាដូចតទៅ៖ ច្បាប់ សេដ្ឋកិច្ច នយោបាយ ទំនាក់ទំនង និង ជំនួយអន្តរជាតិ ។ ពួកគេបង្រៀនជាភាសាអង់គ្លេស បារាំង ឬ ដោយមានអ្នកបកប្រែមកជាភាសាខ្មែរ ។

តាមពិតទៅ យើងធ្វើដូច្នេះបានក៏ដោយសារតែឧត្តមបញ្ជាការកងទ័ពថៃបានចេញច្បាប់អនុញ្ញាតឲ្យយុវជនទាំងនេះ អាចចេញចូលជំរុំបានតែប៉ុណ្ណោះ ។ បើគ្មានច្បាប់នេះទេ យើងក៏ប្រហែលមិនអាចទទួលផលសម្រេចបានឡើយ ។ ដូច្នេះខាងទាហានថៃ ក៏បានជួយយើងខ្លះដែរ ទោះជារាជរដ្ឋាភិបាលថៃគ្មាននយោបាយជួយសម្រួលយើងក្នុងវិស័យអប់រំថ្នាក់ឧត្តមសិក្សានេះក៏ដោយ ។

លោក បណ្ឌិត ឡៅ ម៉ុងហៃ ខ្លួនឯងក៏ជួយបង្រៀនមុខវិជ្ជាច្បាប់សាធារណៈ ឬ ច្បាប់ធម្មនុញ្ញរដ្ឋបាលសាធារណៈ ផ្នែកសេដ្ឋកិច្ច និង ទំនាក់ទំនងអន្តរជាតិដែរ ។ បន្ថែមលើនេះ វិដ្ឋាស្ថានរដ្ឋបាលសាធារណៈរបស់យើង ក៏បានឆ្លៀត

អញ្ជើញអ្នកកាទូត នៃស្ថានទូតនានា ឬ មន្ត្រីអង្គការសហប្រជាជាតិ ដែលមកធ្វើទស្សនកិច្ចក្នុងជំរុំឲ្យជួយធ្វើបាឋកថា ឬ ផ្តល់បទអត្ថាធិប្បាយលើព្រឹត្តិការណ៍អន្តរជាតិណាមួយ ដែលអាចកើតមាននៅពេលនោះ ជូននិស្សិតនៃវិជ្ជាស្ថានស្តាប់ ។ ក្រៅពីនោះ វិជ្ជាស្ថានបានអញ្ជើញបុគ្គលិកអង្គការអន្តរជាតិ ដែលធ្វើការក្នុងជំរុំឲ្យមកថ្លែង ឬ បង្រៀនអំពីមុខជំនាញដែលគេមាន តាមរយៈការងារ ឬ ការសិក្សារបស់គេថែមទៀត ។ ជួនកាល យើងក៏ទទួលច្បាប់អនុញ្ញាតពីអាជ្ញាធរថៃអាចឲ្យនាំនិស្សិតទៅធ្វើទស្សនកិច្ចសិក្សា នៅប្រទេសថៃម្តងម្កាលក៏មានដែរ ។ តាមធម្មតា យើងរក្សាទុកកន្លែងឲ្យក្របខ័ណ្ឌ រ.ជ.រ.ប.ខ. ដែលជាអ្នកទទួលខុសត្រូវតាមផ្នែកនានានៃជំរុំ ឲ្យចូលរៀននៅវិជ្ជាស្ថានរដ្ឋបាលសាធារណៈនេះ ។ ក៏ប៉ុន្តែក្រោយមក យើងទទួលយកសិស្សមធ្យមសិក្សា ដែលប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សា (បាក់ឌុប) ឲ្យចូលរៀនឆ្នាំទីមួយនៃវិជ្ជាស្ថាន ។

ដើម្បីបំប៉នវិជ្ជាភាសាអង់គ្លេសដល់មន្ត្រីរបស់យើងៗ បញ្ជូនមន្ត្រីទាំងនោះទៅរៀនភាសានេះនៅប្រទេសថៃ ឬ ប្រទេសសឹង្ហបូរី ។ ខ្ញុំនៅចាំបានថាខ្ញុំបានបញ្ជូនយុវជនម្នាក់ពីភូមិសុខសាន្តឲ្យទៅរៀនភាសាអង់គ្លេសនៅសឹង្ហបូរី ។ យុវជននោះមិនចេះភាសាអង់គ្លេសមួយម៉ាត់សោះ ហើយធ្លាប់តែរស់នៅលើភ្នំ មិនដែលស្គាល់ទីក្រុងធំផង ។ បន្ទាប់ពីបានទៅរៀននៅសឹង្ហបូរីអស់រយៈមួយឆ្នាំ យុជននោះត្រឡប់មកវិញ និយាយភាសាអង់គ្លេសបាន តែសំនៀងដូចចិនសឹង្ហបូរីដូច្នោះដែរ ។ តាមបទបញ្ជារបស់អាជ្ញាធរថៃ យើងគ្មានសិទ្ធិអ្វីបញ្ជូនបុគ្គលិកមន្ត្រីរបស់យើងឲ្យទៅធ្វើសិក្ខាសាលា ឬ កម្មសិក្សា ឬ រៀនសូត្រនៅក្រៅជំរុំឡើយ នេះមិនទាន់និយាយដល់ការបញ្ជូនឲ្យទៅប្រទេសក្រៅផង ។ ដូច្នេះ បើយើងចង់បញ្ជូនមន្ត្រីយើងឲ្យចេញទៅបរទេស យើងលួចបញ្ចូលឈ្មោះមន្ត្រីនោះក្នុងបញ្ជីគណៈប្រតិភូដែលត្រូវទៅធ្វើទស្សនកិច្ចនៅបរទេស ដូចជាប្រទេសអាស៊ាន ជប៉ុន ប្រទេសនានា

នៅអឺរ៉ុប អូស្ត្រាលី និង សហរដ្ឋអាមេរិកជាដើម ។ យើងចេញលិខិតឆ្លងដែន និង សុំទិដ្ឋាការពីប្រទេសដែលត្រូវទៅរៀនសូត្រឲ្យដល់មន្ត្រីរបស់យើងទាំងនោះ ។ ពេលត្រឡប់មកវិញ យើងសុំទិដ្ឋាការពីក្រសួងការបរទេសថៃ ដែលជាធម្មតាអាចឲ្យគេរស់នៅលើទឹកដីថៃត្រឹមត្រូវតាមច្បាប់យ៉ាងតិចក៏បីខែដែរ ។ ដូច្នេះមន្ត្រីយើងមិនមែនជាជនអន្តោប្រវេសន៍ខុសច្បាប់ ឬ មិនមានការភ័យខ្លាចតម្រួតថៃចាប់ឃុំឃាំងដូចអ្នកភៀសខ្លួនឯទៀតឡើយ ។

សកម្មជនប្រមូលកម្លាំងជាតិ

ទោះបីជាការចេញចូលជំរុំ មានការត្រួតពិនិត្យយ៉ាងតឹងតែងយ៉ាងណាក៏ដោយ ក៏នៅតែមានចលនាចេញចូលនេះខ្លះៗដែរ ជាពិសេសចំពោះអ្នករត់ពន្ធ សកម្មជននយោបាយ និង ភ្នាក់ងារស៊ើបការណ៍ ។ នៅក្នុងជំរុំ ពួកយើងបំពាក់បំប៉នផ្នែកមនោគមវិជ្ជាមុននឹងបញ្ជូនចូលទៅក្នុងប្រទេសខ្មែរ ។ អ្នកទាំងនោះនឹងត្រូវបញ្ជូនឲ្យទៅធ្វើការជាមួយបណ្តាញផ្ទៃក្នុង ដោយនាំទៅជាមួយនូវឯកសារសម្រាប់ឃោសនាទៅជាមួយផង ។ បន្ទាប់ពីចូលទៅធ្វើការក្នុងប្រទេសបានមួយខែ ឬ ពីរខែមក ភ្នាក់ងារទាំងនោះនាំត្រឡប់មកជំរុំវិញនូវព័ត៌មានស្តីពីសភាពការណ៍នយោបាយ សេដ្ឋកិច្ចសង្គមនៃប្រទេសកម្ពុជា ដើម្បីឲ្យពួកយើងយកជាប្រធានបទនៃការឃោសនានយោបាយរបស់យើង ។ អ្នកខ្លះនាំមកនូវរូបថតនៃភូមិស្រុក ឬ សមាជិកផ្ទៃក្នុង ឬ នៃការប្រជុំសមាជិកគាំទ្រ ដែលគេបានទៅដល់ ឬ ដែលគេបានរៀបចំ ។ ភ្នាក់ងារខ្លះត្រូវទាហានថៃចាប់សួរចម្លើយ មុននឹងត្រូវបានអនុញ្ញាតឲ្យចូលមកក្នុងជំរុំវិញ ។ ភ្នាក់ងារខ្លះធ្វើការឲ្យរណសិរ្សយើងផង ធ្វើការឲ្យទាហានថៃខាងផ្នែកស៊ើបការណ៍ផង ។

នៅជំរុំសាយធូ យើងបានរៀបចំឲ្យមានក្រុមសកម្មជននយោបាយមួយក្រុម ដែលយើងឲ្យឈ្មោះថា "ប្រមូលកម្លាំងជាតិ" ។ ក្រុមនេះរើសអ្នកស្ម័គ្រចិត្តឲ្យធ្វើជាសកម្មជនបណ្តាញផ្ទៃក្នុងនៅក្នុងប្រទេស ។ អ្នកទាំងនោះត្រូវបានបំពាក់បំប៉នវិជ្ជាផ្នែកសិទ្ធិមនុស្ស ខ្លឹមសារនៃសេរីភាព ព្រមទាំងគោលការណ៍ និង កម្មវិធីនយោបាយរបស់រ.ជ.រ.ប.ខ. ។ ជាច្រើនដងក្នុងមួយខែៗយើងរៀបចំសន្និសីទ ឬ ការប្រជុំដើម្បីធ្វើការវាយតម្លៃអំពីការចរចាសន្តិភាព ក្នុងដំណោះស្រាយនយោបាយរបស់កម្ពុជាយើង ។ យើងតែងអញ្ជើញឥស្សរជនសំខាន់ៗមានអង្គទូតជាមិត្ត ឬ មន្ត្រីជាន់ខ្ពស់ក្នុងរណសិរ្សយើង ឲ្យមកធ្វើជាវាគ្មិនសំខាន់ៗក្នុងសន្និសីទ ឬ អង្គប្រជុំនោះ ។ ក្រុមនេះគាំទ្រយើងយ៉ាងសកម្មណាស់ ។

នៅពេលក្រោយៗមកទៀត អ្នកទោសនយោបាយដែលរួចពីការឃុំឃាំងនៅភ្នំពេញក៏ប្រមូលគ្នាមកនៅក្នុងជំរុំភាគច្រើននៅខាងក្រុម "ប្រមូលកម្លាំងជាតិ" នេះ ។ អ្នកខ្លះស្នាក់នៅមួយរយៈ រួចក្រោយពីបានទទួលទិដ្ឋាការ ក៏ចេញទៅរស់នៅឯប្រទេសទីបី ។ អ្នកមួយចំនួនទៀត បន្តរស់នៅជាមួយពួកយើងរហូតដល់ពេលមាតុភូមិនិវត្តន៍ ។

លិខិតប្រចាំសប្តាហ៍របស់អគ្គលេខាធិការ

តាំងពីពេលដែលខ្ញុំឡើងកាន់តំណែង ជាអគ្គលេខាធិការរ.ជ.រ.ប.ខ.ភ្លាម ខ្ញុំចាប់ផ្តើមបោះពុម្ពផ្សាយលិខិតប្រចាំសប្តាហ៍របស់អគ្គលេខាធិការ ដើម្បីជូនដំណឹងពីសកម្មភាពការងារ និង ពីសភាពការណ៍នយោបាយ ការទូត និង យោធាជូនជាពិសេស ដល់សមាជិកដែលរស់នៅក្រៅប្រទេស ។ លិខិតប្រចាំសប្តាហ៍ក៏ត្រូវបញ្ជូនជាសម្ងាត់ មកដល់អ្នកគាំទ្ររបស់យើងនៅក្នុងប្រទេសដែរ ។ តាមធម្មតា ខ្ញុំតែងសរសេរបទអត្ថាធិប្បាយអំពីការរីកចំរើនរបស់យើង ទាំងនៅក្នុងជំរុំ

ក៏ដូចជាទាំងនៅលើការងារផ្នែកការទូត ។ កាលមុនខ្ញុំធ្វើជាអគ្គលេខាធិការ រណសិរ្សរបស់យើងក៏ធ្លាប់បោះពុម្ពផ្សាយព្រឹត្តិប័ត្រព័ត៌មាន ដើម្បីផ្សព្វផ្សាយសកម្មភាពជាភាសាខ្មែរ និង ជាភាសាអង់គ្លេសចែកជូនស្ថានទូតបរទេស និង សមាជិករ.ជ.រ.ប.ខ.នៅក្រៅប្រទេស ។ ក៏ប៉ុន្តែ ព្រឹត្តិប័ត្រនោះ ក៏ត្រូវផ្អាកការផ្សាយ ដោយខ្វះបុគ្គលិកផង ដោយខ្វះការចាត់ចែងការងារច្បាស់លាស់ខ្លះផង រហូតដល់ឈប់ចេញផ្សាយទាំងស្រុង បន្ទាប់ពីមានជម្លោះរវាងលោកតា សឺន សាន និង លោកឧត្តមសេនីយ សក់ ស៊ុតសាខន ។ ខ្ញុំសម្រេចចេញផ្សាយលិខិតប្រចាំសប្តាហ៍នេះដោយទទួលខុសត្រូវផ្ទាល់ខ្លួន មិនបាច់នៅរង់ចាំឲ្យមានគណៈកម្មការ ឬ ក្រុមការងារអ្វីទេ ព្រោះគណៈកម្មការ ឬ ក្រុមការងារនោះ ច្រើនប្រើពេលវេលាជជែកគ្នាច្រើនជាងការធ្វើការឲ្យចេញជាលទ្ធផលជាក់ស្តែង ។ តាមពិតទៅ សមាជិកសមាជិកានៅក្រៅប្រទេស គេរង់ចាំដំណឹងពីពួកយើងនៅបាងកកនេះណាស់ ។ កាលពីមុន គេទទួលដំណឹងម្តងម្កាលតាមសំបុត្ររបស់អគ្គលេខា ឬ អ្នកទទួលខុសត្រូវ ដែលគេស្គាល់ដោយចោះៗ មិនមានលក្ខណៈជាប់លាប់ឡើយ ។ ដូច្នេះ សំបុត្រប្រចាំសប្តាហ៍របស់ខ្ញុំ ក៏ទទួលបានប្រជាប្រិយភាព និង មានការគាំទ្រគួរជាទីគាប់ចិត្ត ។ បន្ទាប់ពីការចេញផ្សាយនៃសំបុត្រប្រចាំសប្តាហ៍នេះ ខ្ញុំបានទទួលជាហូរហែនូវការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុពីបងប្អូន នៅក្រៅប្រទេសទាំងនោះ ដែលមានការពេញចិត្ត និង កាន់តែមានជំនឿឡើងដល់រ.ជ.រ.ប.ខ. ។ ជាមួយនោះក៏លេចចេញនូវការច្រណែនពីសំណាក់អ្នកនៅជិតលោកតា សឺន សាន ខ្លះថា ខ្ញុំកំពុងខិតខំបង្កើតប្រជាប្រិយភាពសម្រាប់សួនតួទៅវិញ ក្រោយមក គេបន្ថែមថាខ្ញុំបង្កើតលទ្ធិតម្កើងបុគ្គលផង (Cult of personality) ។

ប្រធានជំរុំ និង មេទ័ព

ជាទូទៅ ប្រធានជំរុំស៊ីវិលធ្វើការយ៉ាងជិតស្និទ្ធជាមួយដៃគូរបស់គេ នៅក្នុងកងទ័ព ។ នៅពេលដៃគូទាហាន ដែលធម្មតាជាមេបញ្ជាការប្រចាំតំបន់ក្នុងជួរក.ជ.ប.ខ. ត្រូវការបញ្ជូនយុទ្ធជនរបស់គេឲ្យចេញទៅប្រតិបត្តិការនៅក្នុងប្រទេស ប្រធានជំរុំស៊ីវិលត្រូវជួយឧបត្ថម្ភបន្ថែមលើអ្វី ដែលយុទ្ធជនទាំងនោះបានទទួលពីកងទ័ពរួចហើយ នូវស្បៀងអាហារ និង របស់របរប្រើប្រាស់ដែលគេមានដូចជា៖ អង្ករ ត្រីប្លាធូ ថ្នាំពេទ្យ សំពត់ប្លាស្ទីកជាដើម ។ល។ តាមពិតទៅ សាយធូក៏មិនខុសអ្វីពីទឹកន្លែសម្រាប់យុទ្ធជនត្រៀមរៀបចំខ្លួន មុននឹងត្រូវចេញទៅបំពេញបេសកកម្មយ៉ាងជ្រៅនៅក្នុងទឹកដីខ្មែរដែរ ។

លោក ឡាយ ខែក ធ្វើការជាដៃគូយ៉ាងជិតស្និទ្ធជាមួយលោក ខូ ឈា (ដួនកាលហៅថា ខូ ឈាន) ដែលជាមេបញ្ជាការតំបន់ ២០១ បន្ទាប់ពីតាមុាំងស្លាប់ទៅនៅក្នុងបេសកកម្មនាតំបន់ទន្លេសាប ។ ខ្ញុំចូលចិត្តធ្វើការជាមួយអស់លោកទាំងពីរនាក់នេះណាស់ ដោយសារនៅក្នុងអង្គភាពរបស់ពួកគេមានឯកភាពល្អ ហើយចេះជួយគ្នាទៅវិញទៅមកផង ។ អ្នកទាំងពីរបានបង្ហាញសមត្ថភាព និងប្រសិទ្ធភាពក្នុងការដឹកនាំ ។ អ្នករស់នៅក្នុងជំរុំសម្លាធ្ងាញ់ស្តាប់លោក ឡាយ ខែក ជានិច្ច ។ ខ្ញុំនៅចាំថាមានថ្ងៃមួយនោះ លោក ឡាយ ខែក ស្រែកគំរាមឲ្យចោរម្នាក់ទម្លាក់អាវុធចោល ហើយរត់ទាំងញាប់ញ័រ ដោយគ្រាន់តែឮសម្លេងគាត់ស្រែក ។ នៅឆ្នាំ ១៩៩០ យើងបានធ្វើការតែងតាំងលោក ឡាយ ខែក ជាប្រតិភូរងនៃគណៈកម្មាធិការប្រតិបត្តិរ.ជ.ប.ខ.ទទួលបន្ទុកតំបន់រំដោះ ។

លោក ខូ ឈា ទទួលបានជោគជ័យនៅសមរភូមិជាច្រើន ដោយបានរំដោះទឹកដីមួយចំនួន ជាពិសេសតំបន់ប្រាសាទបន្ទាយឆ្មារ និង ថ្មពួក ។ ក្រោយពេល

ដែលកងទ័ពវៀតណាមដកចេញទៅ លោក ខូ ឈា បានមកតាំងទីបញ្ជាការរបស់គាត់នៅលើទឹកដីខ្មែរចម្ងាយប្រហែល ៣ ឬ ៤ គ.ម ពីជំរុំសាយធូ ។

នៅថ្ងៃទី ៣០ កញ្ញា ១៩៨៩ លោក ខូ ឈា បានដឹកនាំធ្វើការវាយប្រហារទៅលើកងទ័ពរដ្ឋកម្ពុជា នៅប៉ែកខាងលិច ដែលធ្វើឲ្យសភាពការណ៍នៅតាមជាយដែនខ្មែរ-ថៃមានការតានតឹងជាខ្លាំង ។ ពួកយើងមានការបារម្ភភ័យខ្លាចមានការបាញ់ផ្លោងតបមកវិញចូលក្នុងជំរុំសាយធូ ។ ស្ត្រីមានផ្ទៃពោះ មនុស្សចាស់ និងកុមារ សុទ្ធតែត្រូវបានឲ្យប្រុងខ្លួនត្រៀមជន្លៀសចេញទៅកន្លែងផ្សេង ។ ក៏ប៉ុន្តែជាភ័ព្វសំណាងល្អ ពុំមានហេតុការណ៍អ្វី ដែលនាំឲ្យមានការជន្លៀសចេញនោះទេ ។ មិនតែប៉ុណ្ណោះ លោក ខូ ឈា ថែមទាំងបានរំដោះបានទីតាំងប្រាសាទបន្ទាយឆ្មារផង ។ គាត់នាំមកទីបញ្ជាការជួរមុខរបស់គាត់នូវអាវុធយុទ្ធភ័ណ្ឌ ព្រមទាំងកូនទាហានរដ្ឋកម្ពុជាដែលរត់ចោលជួរមួយចំនួនផង ។

យកបាយកញ្ចប់ទៅចែកខ្មែរគ្នាឯង ត្រូវយូអិនស្តីបន្ទោស

នៅថ្ងៃទី ៩ តុលា ១៩៨៩ ដែលជាថ្ងៃខួបកំណើតឆ្នាំទី ១០ របស់រ.ជ.រ.ប.ខ. លោក ឡាយ ខែក បានរៀបចំជាទិវាសាមគ្គី ដោយសុំឲ្យប្រជាពលរដ្ឋសាយធូជួយផ្តល់បាយកញ្ចប់យកទៅជូនជនរួមជាតិ ដែលទើបរត់មករួបរួមជាមួយពួកយើង ។ នោះជាការផ្តួចផ្តើមគំនិត ដែលនាំឲ្យមានសន្ទុះស្មារតីសាមគ្គីឡើងខ្ពស់យ៉ាងខ្លាំង ។ ពួកអ្នកជំរុំដែលសុទ្ធតែជាជនកៀសខ្លួននោះ បាននាំគ្នាដាំបាយរៀបចំវេចខ្ចប់ជាមួយម្ហូបម្ហា ដែលគេមានបន្តិចបន្តួច យកទៅផ្តល់ដល់ជនរួមជាតិ ដែលទើបមកចូលរួមជាមួយពួកយើងនាពេលនោះ ។ ពួកគេបានបង្ហាញធម៌សប្បុរសនិង សេចក្តីអាណិតស្រឡាញ់ដ៏ជ្រាលជ្រៅដល់ជនរួមជាតិរបស់គេ ទោះធ្លាប់ជាគូបដិបក្ខគ្នាយ៉ាងណាក៏ដោយ ។ ក៏ប៉ុន្តែសប្បុរសធម៌ និង សាមគ្គីធម៌របស់អ្នកជំរុំ

សាយធូនោះ ក៏ត្រូវទទួលការស្តីបន្ទោសពីអង្គការយូអិនប្រូទៅវិញ ។ លោក តូស៊ីយូគី នីវ៉ា (Toshiyuki Niwa) បានសរសេរសំបុត្រផ្តន្ទាទោសការលួចនាំស្បៀងអង្ករបស់អង្គការយូអិនប្រូចេញក្រៅជំរុំ ដែលជាអំពើខុសពីអព្យាក្រឹតភាពនៃអង្គការនេះ ដែលមិនត្រូវផ្តល់ជំនួយដល់យោធានៃគ្រប់ភាគី ។ ជាទណ្ឌកម្ម លោក នីវ៉ា បានសម្រេចផ្អាកមួយរយៈនូវការឧបត្ថម្ភស្បៀងដល់មន្ត្រីរ.ជ.រ.ប.ខ. ដែលធ្វើការក្នុងជំរុំ និង ដល់ស្ត្រីម៉ែម៉ាយដែលជាមេគ្រួសារ ។ តាមពិតទៅ ពួកយើងមិនបានយកចិត្តទុកដាក់ប៉ុន្មានឡើយ ចំពោះបទបញ្ជារបស់យូអិនប្រូ ព្រោះពួកយើងត្រូវខិតខំដោះស្រាយជួយសង្គ្រោះបន្ទាន់ ដល់ជនខ្វះខាតទាំងនោះ ទោះគេធ្លាប់ជាយុទ្ធជនរត់ចេញមកពីខាងក្នុងប្រទេសក៏ដោយ ។ ជាមួយនោះដែរ ខ្ញុំក៏បានទទួលស្គាល់ថាជំនួយរបស់យូអិនប្រូមួយចំនួន ក៏ត្រូវបានមន្ត្រីរដ្ឋបាលជំរុំលួចយកទៅផ្តល់ដល់យុទ្ធជន ដែលមានស្នាមីកក្តិដល់ពួកគេខ្លះៗដែរ ។

ទទួលបានដំណឹងថាមានទាហានរដ្ឋកម្ពុជាមករួបរួមជាមួយ ខ្ញុំក៏មានចិត្តចង់ទៅជួបពួកគេភ្លាម ។ ខ្ញុំក៏ចេញដំណើរជាប្រញាប់ទៅជំរុំសាយធូ រួចឆ្លងដែនចូលទឹកដីខ្មែរ ត្រង់ចំណុចជំរុំដងរែកចាស់ ។ នៅពេលនោះ ខ្ញុំបានជួបយុទ្ធជនទាំងនោះដែលជាយុវជនក្មេងៗអាយុត្រឹម ២០ ឬ ៣០ ឆ្នាំ ដែលមិនមែនជាទាហានអាជីពផងទេ ។ ពួកគេទាំងអស់មានចំនួន ២១២ នាក់ ។ ក្នុងចំណោមយុវជនទាំងនោះ ក៏មាន ២ ឬ ៣ នាក់មកពីខេត្តព្រៃវែងរបស់ខ្ញុំដែរ ។ ខ្ញុំបង្ហាញខ្លួនចំពោះពួកគេ ក្នុងឋានៈជាអគ្គលេខាធិការរបស់រ.ជ.រ.ប.ខ. និង បានស្វាគមន៍ពួកគេក្នុងជួររ.ជ.រ.ប.ខ. ជាមួយនឹងការពន្យល់អំពីគោលនយោបាយរបស់យើង ដែលមានគោលដៅកសាងកម្ពុជាឯករាជ្យ និង ប្រឆាំងតបតចំពោះការវិលត្រឡប់មកកាន់អំណាចវិញនៃពួកប្រល័យពូជសាសន៍ ប៉ុល ពត ជាដាច់ខាត ។

ដំណើរទៅតំបន់រំដោះ

បន្ទាប់មកខ្ញុំក៏មានគំនិតចង់ធ្វើដំណើរទៅទស្សនាតំបន់នានាដែលកងទ័ព រ.ជ.រ.ប.ខ.ទើបរំដោះបាន ហើយដែលពួកយើងហៅថា "តំបន់រំដោះ" ។ មែនទែន ពួកយើង ត្រូវការជាចាំបាច់ឲ្យមានការរៀបចំជារដ្ឋបាលស៊ីវិល ឲ្យបានឆាប់រហ័ស ព្រោះទាំងនោះជាភស្តុតាងបង្ហាញពីសមត្ថភាពរបស់រ.ជ.រ.ប.ខ. ក្នុងការរំដោះទឹកដី ។ បើគ្មានតំបន់រំដោះដែលត្រូវរៀបចំឲ្យមានរដ្ឋបាលស៊ីវិល ធ្វើការគ្រប់គ្រងប្រជាពលរដ្ឋឲ្យបានត្រឹមត្រូវទេនោះ រ.ជ.រ.ប.ខ.ក៏គ្រាន់តែជាអង្គការតស៊ូដែលគ្មានទឹកដីអ្វីទាំងអស់តែប៉ុណ្ណោះគឺ គ្មានទម្ងន់សម្រាប់ការចរចាសន្តិភាពបន្តិចឡើយ ។ ម្យ៉ាងទៀត ទស្សនកិច្ចរបស់ពួកយើងអាចឲ្យយើងទៅពិនិត្យវាយតម្លៃពីសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋយើង ដែលរស់នៅក្នុងតំបន់ទាំងនោះ និង ជាឱកាសឲ្យយើងនាំជំនួយខ្លះទៅចែកជូនជនរួមជាតិយើងផង ។ យើងក៏បានកំណត់យកថ្ងៃទី ២៨ តុលា ១៩៨៩ ជាថ្ងៃចេញដំណើរ ។ ទស្សនកិច្ចរបស់យើងមានរយៈពេលពីរថ្ងៃទៅបន្ទាយឆ្មារគឺ ខ្ញុំត្រូវសម្រាកនៅភូមិបន្ទាយឆ្មារមួយយប់ ។ ផែនការធ្វើទស្សនកិច្ចនេះត្រូវបានធ្វើឡើងយ៉ាងសម្ងាត់បំផុត ។

ខ្ញុំរំភើបក្នុងចិត្តខ្លាំងណាស់ ចំពោះលទ្ធភាពដែលបានទៅមើលប្រាសាទបន្ទាយឆ្មារម្តងទៀត ដែលខ្ញុំធ្លាប់ទៅលេងម្តងរួចហើយកាលពីឆ្នាំ ១៩៨៣ ។ នៅពេលនោះ ខ្ញុំគ្រាន់តែទៅដល់តួប្រាសាទតែប៉ុណ្ណោះ មិនបានជួបប្រជាពលរដ្ឋទេ ហើយក៏គ្រាន់តែឃើញផ្ទះពីរ ឬ បីខ្នង ដែលគ្មានមនុស្សរស់នៅផង ។ នៅឆ្នាំ ១៩៨៣ នោះ ពួកយើងធ្វើដំណើរទៅបន្ទាយឆ្មារដោយថ្មើរជើង ។ លើកនេះ យើងរៀបចំរទេះគោ ដើម្បីដឹកស្បៀង និង ជំនួយយកទៅចែកជូនអ្នកស្រុកនៅតំបន់នោះ ។ ពួកអ្នកមុខអ្នកការយើងនឹងត្រូវធ្វើដំណើរតាមម៉ូតូ ។

ព្រឹកព្រលឹមថ្ងៃទី ២៨ តុលា ១៩៨៩ យើងក៏ចាប់ចេញដំណើរតាមម៉ូតូគឺ ម៉ូតូ មួយមានគ្នាពីរនាក់ ។ ខ្ញុំជិះម៉ូតូជាមួយលោក ខូ ឈា ដែលជាអ្នកបើកបរ ។ សហការីឯទៀតក៏ជិះតាមគ្នាយ៉ាងនេះ រួមទាំងអស់មានម៉ូតូចំនួនប្រាំគ្រឿង ។ យើងទាំងអស់គ្នា ធ្វើដំណើរតាមផ្លូវរទេះមួយ ដែលមិនមែនជាការងាយស្រួល សម្រាប់ការបើកបរទោចក្រយានយន្តរបស់យើងឡើយ ព្រោះម្យ៉ាងពួកយើងត្រូវ បើកកាត់ផ្លូវ ដែលមានភក់ដោយអន្លើៗ ម្យ៉ាងទៀតយើងត្រូវឆ្លងអូរមួយចំនួនផង ។ ដោយមានការលំបាកខ្លាំងពេក យើងក៏សម្រេចបើកកាត់ផ្លូវរទេះមួយទៀត ដែល អាចជាផ្លូវកាត់ផង តាមការអះអាងរបស់ទាហានដែលនៅយាមតាមតំបន់នោះ ។ តាមពិតទៅ ផ្លូវនេះជាផ្លូវថ្មើរជើងដែលយុទ្ធជនធ្លាប់ប្រើ ក៏ប៉ុន្តែមិនមែនជាផ្លូវ សម្រាប់កង់ ឬ ម៉ូតូអាចប្រើប្រាស់បានឡើយ ។ ផ្លូវបត់ចុះបត់ឡើងឆ្លងកាត់វាល ស្បូវ ឬ ព្រេចកំពស់ស្មើលិចក្បាល ក្នុងព្រៃដែលមានដើមឈើ ទំហំតូច និង មធ្យមជាច្រើនហូរហែជួយបាំងកំដៅថ្ងៃ ។ ដើមឈើខ្លះ ត្រូវដួលរលំកាត់ផ្លូវជាច្រើន កន្លែងដែលជាឧបសគ្គដល់ការធ្វើដំណើររបស់យើង ។ តាមផ្លូវ យើងប្រទះក្រុម ទាហានរ.ជ.រ.ប.ខ.ដែលបោះទីតាំង ឬ ដែលដើរទៅមកនៅក្នុងព្រៃដោយរយៈៗ ។ នៅពេលពួកយើងសួរពួកគេ តើស្ថានភាពផ្លូវមានលក្ខណៈដូចម្តេចដែរ? ទាហាន ទាំងនោះនិយាយថា "ផ្លូវស្រួលទេបង" ។ តាមពិតទៅ សម្រាប់ពួកគេ ផ្លូវនោះ ស្រួលមែន ព្រោះគេអាចដើរ ឬ លោតរំលងលើដើមឈើទាំងឡាយ ដែលនៅដួល ដេកកាត់ផ្លូវនោះបាន តែចំពោះពួកយើងៗត្រូវបញ្ឈប់ម៉ូតូ រួចលើករំលងទើបអាច បន្តដំណើរទៅមុខទៀតបាន ។ ជាមួយគ្នានោះដែរ យើងត្រូវជិះម៉ូតូហោះឆ្លងអូរជា ច្រើន ដែលអាចមានគ្រោះថ្នាក់រាល់ៗដង ។ ម្យ៉ាងទៀតខែ តុលា ជាខែមានភ្លៀង ធ្លាក់ខ្លាំង ដូច្នេះនៅតាមកន្លែងខ្លះនៃផ្លូវនោះ ក៏មានជាំទឹកជាភក់ ឬ ល្បាប់ប៉ប៊ិក ប៉ប៉ាច់ដ៏លំបាកក្នុងការធ្វើដំណើររបស់យើង ។ កន្លែងខ្លះទៀត ក៏រអិលស្មើរចាប់

មិនឈ្នះ ។ កន្លែងខ្លះយើងត្រូវចុះជួយរុញម៉ូតូ កន្លែងខ្លះ យើងត្រូវចុះទាញម៉ូតូរបស់យើងដែលជាប់គាំងដោយដីកក់ ឬ ល្បាប់ ទើបអាចទៅមុខបាន ។

យើងធ្វើដំណើរអស់រយៈពេល ៦ ម៉ោង ដោយរាប់ទាំងការឈប់សម្រាកស្រស់ស្រូបអស់រយៈពេលមួយម៉ោងផង ។ យើងចាប់ផ្តើមជិះកាត់វាលស្រែខ្លះៗដែលនៅចន្លោះព្រៃ ។ វាលស្រែទាំងនោះជាសញ្ញាថាយើងកំពុងខិតចូលជិតដល់ភូមិអ្នកស្រុកហើយ ។ មិនយូរប៉ុន្មានដោយសារសម្លេងកងរំពងនៃគ្រឿងម៉ាស៊ីនម៉ូតូ អ្នកភូមិក៏នាំគ្នាចេញពីផ្ទះ លើកដៃស្វាគមន៍ពួកយើង ។ ទាំងក្មេង ទាំងចាស់ ទាំងស្រីទាំងប្រុស អ្នកស្រុកចេញមកឈរនៅមុខផ្ទះ ទះដៃអបអរសាទរទទួលពួកយើងយ៉ាងសប្បាយរីករាយ ។ នៅទីបំផុត យើងក៏ចូលទៅសម្រាកក្នុងផ្ទះមួយដែលមានសភាពល្អគ្រាន់បើជាងគេ ។ គឺនៅក្នុងផ្ទះនោះហើយដែលពួកយើងជាពិសេសខ្លួនខ្ញុំផ្ទាល់ បានចូលមកទទួលទានដំណេកនៅយប់ទីមួយលើទឹកដីរំដោះ ។

នៅម៉ោងបីរសៀលពួកយើងក៏ចាប់ផ្តើមដើរពិនិត្យមើលសភាពការណ៍ទូទៅនៅក្នុងភូមិ ។ ជាដំបូង យើងជួបមនុស្សម្នាក់ជាអ្នកមុខអ្នកការនៅក្នុងភូមិដែលជាទូទៅគេ ហៅថាកាល់ម៉ាក្ស ព្រោះគាត់ទុកពុកមាត់ពុកចង្កាដូចលោកកាល់ម៉ាក្សដែរ ។ តាមពិត ឈ្មោះគាត់ពិតប្រាកដឈ្មោះ តា៉ា ។ តា៉ា មានរឿងរ៉ាវនិយាយប្រាប់យើងច្រើន ។ គាត់និយាយពីការរស់នៅរបស់គាត់តាមដំនាន់នយោបាយនីមួយៗ តាំងពីសម័យសង្គម សម័យសាធារណរដ្ឋ សម័យខ្មែរក្រហម និងសម័យរដ្ឋកម្ពុជា ។ តា៉ា មានអាយុជាង ៦០ ឆ្នាំ មកហើយ តែគាត់នៅមានសុខភាពមាំមួន ។ តា៉ា មានប្រពន្ធពីរដែលរស់នៅក្រោមដំបូលតែមួយ ។ ពេលពួកយើងទៅដល់ផ្ទះគាត់ៗស្រែកហៅប្រពន្ធ និង កូនៗ ទាំងអស់របស់គាត់ឲ្យចេញមកទទួលយើងយ៉ាងរាក់ទាក់បំផុត ។ ប្រពន្ធគាត់ទាំងពីរនាក់ នាំគ្នាយកអំបោះមកចងដៃពួកយើងតាមទំនៀមទម្លាប់អ្នកស្រុកបន្ទាយឆ្មារ ។ តាមទម្លាប់នៅខេត្តព្រៃវែង

របស់ខ្ញុំ ឪពុក ម្តាយ ឬ ចាស់ទុំនាំគ្នាយកអំបោះចងដៃកូនប្រុសកូនស្រី ឲ្យពរជ័យកូនទាំងនោះ តែនៅពេលមានមង្គលការតែប៉ុណ្ណោះ មិនដូចអ្នកនៅទីនេះទេ ។ តា ប៉ា និង ប្រពន្ធ កូនរបស់គាត់ហៅពួកយើងថា "ឪៗ" តាមទម្លាប់របស់គេដែលចាត់ទុកពួកយើងជាអ្នកមានអំណាច ឬ អ្នកធំ ។

បន្ទាប់ពីសន្ទនាជាមួយ តាប៉ា និង ក្រុមគ្រួសារគាត់រួចហើយ ពួកយើងក៏នាំគ្នា ប្រញាប់ប្រញាល់ទៅមើលប្រាសាទបន្ទាយឆ្មារ កុំឲ្យយប់ងងឹតធ្លាក់មកដល់ទាន់ ។ ឈ្មោះបន្ទាយឆ្មារបានត្រូវបកស្រាយខ្លះៗថាបន្ទាយតូច ដោយយកពាក្យឆ្មារ (តូចណាស់ជាគោល) ។ អ្នកបុរាណវិទ្យាបានសាកល្បងពន្យល់ពីប្រវត្តិរបស់ប្រាសាទបន្ទាយឆ្មារ តាមការយល់ដឹងរបស់ពួកគេ ។ ដោយសារប្រទេសយើងកើតមានសង្គ្រាមញឹកញាប់ពេក យើងមានការលំបាកស្វែងរកឯកសារប្រវត្តិសាស្ត្ររបស់យើងខ្លាំងណាស់ ។ ឯកសារមួយចំនួន យើងអាចរកឃើញនៅឯទ្វីបទីទៃៗ ។ ឯកសារមួយចំនួនធំ យើងរកបានអាស្រ័យដោយការសិក្សាស្រាវជ្រាវរបស់អ្នកប្រាជ្ញបារាំង ឬ អាចរកឃើញតាមសិលាចារឹក ។ ឯកសារមួយចំនួនទៀត យើងរកឃើញតាមរយៈអ្នកប្រវត្តិសាស្ត្រជនជាតិចិន ដែលបានមកដល់ប្រទេសកម្ពុជា ព្រោះថាប្រទេសចិនជាមហាប្រទេស ដែលបញ្ជូនទូតមកមុនគេ ។

ប្រាសាទបន្ទាយឆ្មារ អាចរងគ្រោះដោយជនទុច្ចរិត

ប្រាសាទបន្ទាយឆ្មារ បានត្រូវកសាងឡើងក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី ៧ ដែលជាមហាក្សត្រដ៏អង់អាចមួយព្រះអង្គក្នុងសម័យមហានគរ ដែលធ្វើឲ្យអារ្យធម៌ខ្មែរឡើងខ្ពស់ដល់កំពូលនៅចន្លោះសតវត្សទី ១២ និង ១៣ ។ បើប្រៀបធៀបទៅសភាពដែលខ្ញុំធ្លាប់ឃើញនៅឆ្នាំ១៩៨៣ តួប្រាសាទបានទទួលខូតខាតមួយចំនួន ។ ពួកអ្នកស្រុកនិយាយថា មានជនទុច្ចរិតមកគាស់យករូបចម្លាក់ ធ្វើឲ្យជញ្ជាំងប្រា

សាទបាក់បែកខូតខាត ។ ពួកយើងនាំគ្នាដើរលើគំនរថ្មដែលធ្លាក់គរ ទម្រាំយើងចូលដល់បរិវេណខាងក្នុងនៃប្រាសាទ ។ ខ្ញុំមានអារម្មណ៍ធូរស្រាលយ៉ាងខ្លាំងនៅពេលដែលឃើញបរិវេណខាងក្នុងនេះនៅល្អ និង រឹងមាំ ។ ប្រាសាទបន្ទាយឆ្មារ ក៏ដូចជាប្រាង្គប្រាសាទថ្មជាច្រើនទូទាំងប្រទេសកម្ពុជា បានត្រូវកសាងឡើងដោយបុព្វបុរសខ្មែរទុកជាមរតកឥតកាត់ថ្លៃបានឲ្យកូនចៅជំនាន់ក្រោយ ។ ស្នាដៃរបស់បុព្វបុរសខ្មែរទាំងអស់នោះ ក៏បានក្លាយទៅជាដួងព្រលឹងរបស់ប្រជាជាតិយើងរហូតដល់សព្វថ្ងៃនេះ ។ ដូច្នេះការជួយការពារអភិរក្សមរតកទាំងនេះ ជាភារកិច្ចដ៏ពិសិដ្ឋរបស់ខ្មែរម្នាក់ៗ ។ ប្រាំមួយឆ្នាំក្រោយមកគឺ នៅឆ្នាំ ១៩៩៥ ខ្ញុំបានទៅទស្សនាប្រាសាទបន្ទាយឆ្មារម្តងទៀត ក្នុងឋានៈជារដ្ឋមន្ត្រីក្រសួងព័ត៌មាន ។ ខ្ញុំមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការបំផ្លិចបំផ្លាញ ឬ គាស់រំលើង និង ការរត់ពន្ធរូបចម្លាក់នៃវត្ថុបូរាណដ៏មានតម្លៃមហាសាលទាំងនេះ ។ នៅក្នុងអង្គប្រជុំជាសាធារណៈមួយនៅស្រុកថ្មពួកក្នុងខេត្តបន្ទាយមានជ័យ ខ្ញុំបានលើកយកបញ្ហាការបំផ្លិចបំផ្លាញ គាស់រំលើង និង រត់ពន្ធបុរាណវត្ថុមករំលឹកជាសំឡេងអាជ្ញាធរមូលដ្ឋាន និង សមត្ថកិច្ចទាំងអស់យកចិត្តទុកដាក់ចាត់វិធានការគ្រប់យ៉ាង ដើម្បីបំបាត់អំពើអវិជ្ជមានទាំងនោះ ដែលអាចនាំឲ្យរលំរលាយដល់ដួងព្រលឹងជាតិរបស់យើង ។

នៅពេលនោះ ខ្ញុំបានលើកយករឿងបន្ទាយលង្វែកមកបកស្រាយជូនអង្គប្រជុំស្តាប់ៈ "ក្រោយពេលដែលព្រះអង្គបានវាយបណ្តេញទ័ពសៀមចេញពីអង្គរួចមក ព្រះបាទចៅពញាយ៉ាត បានលើករាជធានីមកក្រុងភ្នំពេញ ដោយបោះបង់ទីក្រុងអង្គរ ។ ក៏ប៉ុន្តែ បន្ទាប់មកនៅពេលព្រះអង្គច័ន្ទឡើងសោយរាជ្យ ព្រះអង្គបានលើករាជធានីពីភ្នំពេញមកតាំងនៅលង្វែក ព្រោះព្រះអង្គយល់ថា ទីនោះមានភូមិសាស្ត្រងាយស្រួលក្នុងការការពារ ប្រសិនបើមានការវាយលុកលុយពីបរទេស ។ ព្រះមហាក្សត្រអង្គនេះ បានចេញព្រះរាជបញ្ជាឲ្យដាំដើមឫស្សីព័ទ្ធជុំវិញបន្ទាយ

លង្វែក ។ នៅសតវត្សទី ១៦ សៀមបានលើកទ័ពលើកទីមួយ មកវាយបន្ទាយលង្វែក ។ ទ័ពបច្ចាមិត្រនេះ បានត្រូវទ័ពខ្មែរទប់ជាប់នៅក្នុងព្រៃឫស្សីអស់ជាច្រើនខែ ។ ដោយសារខ្វះស្បៀង ទ័ពសៀមដកថយទៅវិញ ។ ប៉ុន្មានឆ្នាំក្រោយមក ទ័ពសៀមលើកមកម្តងទៀត ដើម្បីវាយយកបន្ទាយលង្វែក ។ ពួកសៀម ដឹងថាបរាជ័យរបស់ខ្លួននៅលើកទីមួយនោះ ក៏ដោយសារតែព្រៃឫស្សីដែលជាឧបសគ្គមិនឲ្យវាយចូលក្នុងបន្ទាយលង្វែកបាន ដូច្នេះលើកនេះ មេទ័ពសៀមរិះរកមធ្យោបាយបំផ្លាញព្រៃឫស្សីចោលជាមុនសិន មុននឹងវាយលុកចូល ។ ពួកបច្ចាមិត្តក៏បាញ់ទម្លាក់ទៅក្នុងព្រៃឫស្សីនូវប្រាក់ដួង ។ អ្នកស្រុកខ្មែរដែលមិនបានគិតដល់បញ្ហាសន្តិសុខរបស់ប្រទេសជាតិ ក៏នាំគ្នាទៅកាប់ឆ្ការព្រៃឫស្សី ដើម្បីទៅរើសយកប្រាក់ដួងទាំងនោះ ។ ក្រោយដែលព្រៃឫស្សីត្រូវបំផ្លាញដោយអ្នកស្រុកខ្មែរអស់ហើយ ទ័ពសៀម ក៏លើកគ្នាចូលមកវាយលុកយកបន្ទាយលង្វែកបានដោយជោគជ័យ ។ ចម្បាំងបន្ទាយលង្វែកនោះ ក៏ជាបរាជ័យដ៏អាម៉ាស់របស់ខ្មែរយើងនាសម័យនោះ ។ ឥឡូវនេះ យើងកំពុងជួបប្រទះហេតុការណ៍ប្រហាក់ប្រហែលគ្នាដែរ ។ ជនទុច្ចរិតបរទេស គេកំពុងបិតតម្លៃជាប្រាក់ដុល្លារ និង ប្រាក់បាតថៃនៅលើរូបចម្លាក់ សិលាចារឹក ឬ បូរាណវត្ថុ នៅតាមប្រាង្គប្រាសាទនានារបស់យើង ដើម្បីឲ្យខ្មែរដែលភ្លេចខ្លួនទៅគាស់រំលើងយកទៅលក់ឲ្យគេ ។ ដូច្នេះយើងត្រូវតែប្រុងប្រយ័ត្នខ្ពស់ ព្រោះថានៅពេលដែលមរតករបស់ដូនតាយើងបាក់បែកខ្ទេចខ្ទាំអស់ហើយ នោះព្រលឹងជាតិរបស់យើងក៏នឹងរំលាយមិនខានឡើយ ។ ដូច្នេះសូមមេត្តាជួយការពារប្រាសាទបន្ទាយឆ្មារនេះផង” ។

នៅតំបន់រំដោះ ខ្ញុំប្រាប់អ្នកស្រុកឲ្យចាំមើលទង់ជាតិយើង

ព្រឹកស្អែកឡើងថ្ងៃទី ២៩ តុលា ១៩៨៩ ខ្ញុំបានទៅធ្វើអធិបតីនៃពិធីចែកអំណោយដល់ប្រជាពលរដ្ឋ ដែលជាឱកាសដំបូងអាចឲ្យខ្ញុំសំដែងមតិនៅលើទឹកដីនៃតំបន់រំដោះ ។ ខ្ញុំបានរំលឹកពីការខិតខំរបស់ចលនាយើង ក្នុងការតស៊ូដើម្បីឲ្យកម្ពុជាបានក្លាយជាប្រទេសសេរី ប្រកាន់លទ្ធិប្រជាធិបតេយ្យ និង សិទ្ធិមនុស្ស ក៏ដូចជាការលើកតម្កើងប្រពៃណី និង វប្បធម៌ជាតិ ។ តាមពិតទៅ ខ្ញុំដឹងថាអ្វីដែលខ្ញុំនិយាយនៅពេលនោះ អ្នកស្រុកបន្ទាយឆ្មារមិនអាចយល់បានភ្លាមៗទេ ព្រោះបញ្ហារបស់អ្នកស្រុកគឺជីវភាពប្រចាំថ្ងៃរបស់គេជាងបញ្ហាប្រជាធិបតេយ្យ ឬ សិទ្ធិមនុស្ស ។ ក៏ប៉ុន្តែ នៅពេលនោះ ខ្ញុំបានដំរាបអ្នកស្រុកជារបៀបទស្សន៍ទាយដូចធ្លាប់និយាយច្រើនលើកច្រើនសារនៅជំរុំសាយធូថា៖ "បងប្អូនចាំមើល នៅពេលណាដែលទង់ជាតិខៀវ ក្រហម មានប្រាសាទអង្គរកំពូលបីពណ៌សនៅចំកណ្តាលបានត្រូវបង្ហូតនៅភ្នំពេញ នៅពេលនោះប្រទេសយើងនឹងបានសុខសន្តិភាព យើងទាំងអស់គ្នានឹងសុខសប្បាយមិនខានឡើយ" ។ នៅពេលនោះ ខ្ញុំចង្អុលទៅទង់ជាតិដែលត្រូវបានបង្ហូតឡើងនៅពេលនោះ ។ តាំងពី រ.ជ.រ.ប.ខ.បានត្រូវបង្កើតឡើង ពួកយើងបានយកទង់ជាតិខៀវ ក្រហម ប្រាសាទអង្គរកំពូលបីនេះជាទង់ជាតិផ្លូវការរៀងរហូតមក ។ ទង់ជាតិនេះជាទង់ក្នុងសម័យសម្តេច សីហនុ កាលព្រះអង្គកាន់អំណាចមុនពេលមានសង្គ្រាមឆ្នាំ ១៩៧០ ។ នៅឆ្នាំ ១៩៩៣ ក្រោយការបោះឆ្នោតសាកលរួចមក ប្រទេសយើងក៏យកទង់នេះមកប្រើជាថ្មីឡើងវិញ ។ ដូច្នេះអ្វីដែលខ្ញុំទស្សន៍ទាយនៅបន្ទាយឆ្មារនោះ ក៏បានក្លាយជាការពិតមែននៅឆ្នាំ ១៩៩៣ ។

ខ្ញុំធ្វើដំណើរត្រឡប់ទៅទល់ដែនវិញ លាបន្ទាយឆ្មារ ដោយមនោសញ្ចេតនាសប្បាយរីករាយ ទោះជាការធ្វើដំណើរនោះ មានការហត់នឿយយ៉ាងណាក៏

ដោយ ។ តាមពិតទៅ ការធ្វើដំណើរបស់ពួកយើងអាចវាយតម្លៃបានថា៖ ១/៣ ជិះម៉ូតូ ១/៣ ជួយរុញម៉ូតូ និង ១/៣ ទៀតជួយទាញម៉ូតូ ។ រូបភាពដែលថតបានតាមវីឌីអូ (VDO) បង្ហាញពួកយើងជិះម៉ូតូកាត់ព្រៃព្រឹក្សា និង ទំនាក់ទំនងផ្ទាល់របស់ពួកយើងជាមួយប្រជាពលរដ្ឋនៅក្នុងតំបន់រំដោះ បានផ្តល់ផលល្អយ៉ាងខ្លាំងដល់ការងារខាងឃោសនា និង ទំនាក់ទំនងសាធារណៈរបស់ពួកយើង ។ ជាពិសេស រូបភាពទាំងនេះបានធ្វើឲ្យសមាជិករ.ជ.រ. ប.ខ.នៅក្រៅប្រទេសមានសន្ទុះទឹកចិត្តកើនឡើងទៀតជាអតិបរិមា ។ ទាំងអស់នេះ បានជាកត្តានាំនូវសេចក្តីសង្ឃឹមដល់ពួកគេ ក្តីសង្ឃឹមថានឹងបានវិលត្រឡប់ទៅមាតុប្រទេសវិញ នៅថ្ងៃណាមួយមិនខានគឺ វិលទៅប្រទេសខ្មែរដែលឯករាជ្យ និង មានសេរីភាព ។ ចំណុចល្អសំខាន់មួយទៀតនៃទស្សនកិច្ចរបស់ខ្ញុំនេះ បានសឲ្យឃើញថាខាងក្រុមលោកតា សឺន សាន ក៏មានកងទ័ព ដែលកំពុងប្រតិបត្តិការចូលទៅក្នុងប្រទេសដែរ ។ មែនទែន តាំងពីខែ ធ្នូ ១៩៨៥ គឺ នៅពេលដែលមានការបែកបាក់គ្នារវាងក្រុមលោកតា សឺន សាន និង ក្រុមលោកឧត្តមសេនីយ សក់ ស៊ុតសាខន មក មានការសង្ស័យជាប្រចាំថា យុទ្ធជនរ.ជ.រ.ប.ខ.ប្រហែលជាគ្មានសមត្ថភាពធ្វើការប្រយុទ្ធឡើយ ។ វត្តមានរបស់ខ្ញុំនៅក្នុងតំបន់រំដោះក្នុងឋានៈជាអ្នកតំណាងលោកតា សឺន សាន បានជួយលើកកេរ្តិ៍ឈ្មោះរបស់លោកតាមួយកំរិតទៀត ព្រោះថាអស់រយៈពេលច្រើនឆ្នាំមកហើយ ដែលក្រុមប្រឆាំងបានបន្តុះបង្អាប់លោកតាថាជាអ្នកដឹកនាំដែលមានតែឈ្មោះនៃចលនាតស៊ូនៅក្រៅប្រទេសមួយ គ្មានទំនាក់ទំនងជាមួយកងទ័ពណាមួយនៅលើទឹកដីខ្មែរឡើយ ។ តាមការឃោសនារបស់ក្រុមលោកឧត្តមសេនីយ សក់ ស៊ុត សាខន មានតែលោក សក់ ស៊ុតសាខន ទេដែលមានកងទ័ពបញ្ជាក្នុងឋានៈជាអគ្គមេបញ្ជាការក.ជ.រ.ប.ខ. ។ ប្រាកដមែន លោកឧត្តមសេនីយ សក់ ស៊ុតសាខន ជាអគ្គមេបញ្ជាការក.ជ.រ.ប.ខ. ក៏ប៉ុន្តែមេបញ្ជាការជួរមុខមួយចំនួនដូច

ជាលោក ខូ ឈា ជាដើម បានរិះរកវិធីសាស្ត្រក្នុងការបំពេញបេសកកម្មរបស់ខ្លួន ដោយឯករាជ្យម្ចាស់ការខ្លួនឯង ។ តាមធម្មតា គាត់ត្រូវរៀបចំទស្សនកិច្ចក្នុងតំបន់រំដោះ ជូនមេបញ្ជាការថ្នាក់លើក្នុងកងទ័ពជាមុនៗនឹងរៀបចំឲ្យខ្ញុំទៅជាន់ទឹកដីតំបន់រំដោះនោះ តែផ្ទុយទៅវិញលោក ខូ ឈា បានរៀបចំឲ្យខ្ញុំ ។ ទំនាក់ទំនងល្អរបស់ខ្ញុំផ្ទាល់ជាមួយមេបញ្ជាការកងទ័ពទៅជួរមុខ និង ការខិតខំបំពេញបេសកកម្ម ដើម្បីបំរើប្រជាពលរដ្ឋរបស់ខ្ញុំនៅទីបំផុតក៏បានទទួលផលជាវិជ្ជមាន ។ ក្រោយមកមិនយូរប៉ុន្មាន ខ្ញុំបាននិយាយរឿងរ៉ាវអំពីការធ្វើដំណើរទៅតំបន់រំដោះនេះ ជំរាបនាយទាហានជើងចាស់ធ្លាប់មានបទពិសោធន៍ក្នុងសមរភូមិ ដូចជាលោកវរសេនីយ កេត រ៉េត ជាដើម ។ តារ៉េត បន្ទោសខ្ញុំថា ម្តេចក៏ហ៊ានម្ល៉េះ ។ តាមធម្មតា នាយទាហានអាជីពត្រូវរង់ចាំការបោសសំអាតមីនតាមផ្លូវឲ្យស្អាតជាមុនសិន ទើបគេហ៊ានធ្វើដំណើរចូលទៅតំបន់ទាំងនោះ ។

តាមពិតទៅ ជីវភាពរស់នៅនៅក្នុងជំរុំមិនមែនជាជីវភាព ដែលមនុស្សទូទៅតែងប៉ងប្រាថ្នាចង់ទៅរស់នៅនោះទេ ព្រោះថាអ្នករស់នៅក្នុងជំរុំពុំមានសិទ្ធិ និងសេរីភាពឲ្យបានពេញបរិបូរណ៌ដូចមនុស្សរស់នៅក្នុងប្រទេសរបស់ខ្លួនឡើយ ។ អ្នកភៀសខ្លួនទៅរស់នៅក្នុងជំរុំមួយភាគ រត់គេចពីសង្គ្រាម ស្វែងរកសេចក្តីសុខមួយរយៈ រង់ចាំពេលវេលាល្អនឹងវិលចូលក្នុងប្រទេសវិញ មួយភាគទៀតអាចសង្ឃឹមរកផ្លូវភៀសចេញទៅក្រៅ ដើម្បីកសាងជីវភាពថ្មី ។ អ្នករត់ភៀសខ្លួន សុទ្ធតែប្រាថ្នាចង់បានជោគវាសនាឲ្យបានប្រសើរ ជាងកាលដែលគេរស់នៅក្នុងស្រុក ។ ដោយសារសប្បុរសធម៌របស់សហគមន៍អន្តរជាតិ ពួកជនទាំងនោះ បានទទួលការជួយឧបត្ថម្ភខាងផ្នែកស្បៀងអាហារ ទីជំរក សេវាសុខភាពខ្លះ និង ការសិក្សារៀនសូត្រខ្លះៗ ប៉ុណ្ណោះដែលមានត្រឹមលក្ខណៈជាជំនួយសង្គ្រោះបន្ទាន់ ។ ស្ថិតនៅក្នុងបរិបទបែបនេះ ទើបរ.ជ.រ.ប.ខ.ខិតខំបង្កើតបរិយាកាសនយោបាយឲ្យពួកគេយល់ដឹងថាជន

កៀសខ្លួនមិនមែនជាមនុស្សអស់សង្ឃឹមនោះទេ ពួកគេអាចនឹងធ្វើឲ្យក្តីស្រមៃចង់បានសិទ្ធិ សេរីភាពក្លាយទៅជាការពិតបាន ។ ដោយសារការខិតខំស្វែងរកជំណោះស្រាយលើវិបត្តិនៅកម្ពុជា នៅទីបំផុតបងប្អូនជនកៀសខ្លួនមួយចំនួនធំបានវិលមកក្នុងប្រទេសវិញ រួចកសាងជីវិតថ្មីជាពលរដ្ឋនៃប្រទេសឯករាជ្យមួយ ដែលមានសន្តិភាព ។

វគ្គទី ៩
ដំណើរតាមផ្លូវបត់បែនទៅរកសន្តិភាព
(ទសវត្សរ៍ឆ្នាំ ១៩៨០-១៩៩០)

តាំងពីរ.ជ.រ.ប.ខ.ត្រូវបានប្រកាសឡើងនៅថ្ងៃទី ៩ តុលា ១៩៧៩ តរៀងមក ខ្ញុំតែងចងចាំជានិច្ចថាកងទ័ពនៃរណសិរ្សនេះ គ្រាន់តែជាវត្ថុធាតុមួយក្នុងចំណោមវត្ថុធាតុឯទៀតនៃយុទ្ធសាស្ត្ររួម ដើម្បីបញ្ចប់ជម្លោះនៅកម្ពុជា ។ កងទ័ពជាតិរំដោះប្រជាពលរដ្ឋខ្មែរ ឬ ក.ជ.រ.ប.ខ.មានរូបរាងឡើង ដើម្បីជាសញ្ញាបង្ហាញថា ក្រុមយើងប្តេជ្ញាធ្វើការតស៊ូរំដោះប្រទេសឲ្យមានអធិបតេយ្យភាពឡើងវិញ និង ទប់ទល់កុំឲ្យរបបប្រល័យពូជសាសន៍វិលត្រឡប់មកកាន់អំណាចបាន ។ តែតាមពិតទៅ យើងក៏ដឹងដែរថាកម្លាំងទ័ពរបស់ពួកយើង មិនអាចមានសមត្ថភាពវាយរុញច្រានកងទ័ពវៀតណាមឲ្យចេញពីទឹកដីយើង តាមកម្លាំងយោធាបានទេ ។ អ្វីដែលពួកយើងអាចនឹកសង្ឃឹមបាននោះគឺ ដំណោះស្រាយបញ្ហាកម្ពុជាតាមការចរចា ដោះស្រាយតាមផ្លូវនយោបាយ តាមរយៈអន្តរាគមន៍របស់សហគមន៍អន្តរជាតិ ជាពិសេសអន្តរាគមន៍របស់អង្គការសហប្រជាជាតិតែប៉ុណ្ណោះ ។

ផ្ទុយទៅវិញ កងទ័ពខ្មែរក្រហម ដែលបានទទួលការទំនុកបំរុងយ៉ាងពេញទំហឹងពីប្រទេសចិន និង ថៃផង បានខំពង្រឹងកម្លាំងឡើងវិញ ក្រោយពីត្រូវទទួលការខូចខាតបាក់បែកជាដំណំ ក្រោមការវាយប្រហាររបស់កងទ័ពវៀតណាម និងកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ។ តាមរយៈការពង្រឹងកម្លាំងទ័ព និងការបង្កើនឧត្តមភាពយោធានៅក្នុងសមរភូមិលើដៃគូពីរទៀត នៅក្នុងរដ្ឋាភិបាលចម្រុះរបស់ខ្មែរក្រហម បានធ្វើឲ្យពួកយើងប្រមើលមើលឃើញថា ខ្មែរក្រហមជ្រើស

រើសយកដំណោះស្រាយយោធាដើម្បីបញ្ចប់សង្គ្រាមនៅកម្ពុជា ។ បើពួកគេមិនទាន់អាចវាយផ្តួលរំលំរដ្ឋាភិបាលភ្នំពេញ និង បណ្តេញកងទ័ពវៀតណាមចេញបានភ្លាមៗ ពួកខ្មែរក្រហមអាចបន្តធ្វើសង្គ្រាមពង្រិចពង្រិលយូរអង្វែង ដែលគ្មានអ្វីក្រៅពីបន្តទុក្ខវេទនាដល់ប្រជាពលរដ្ឋខ្មែរ ឲ្យតែតែយូរវែងឆ្ងាយតទៅទៀតមិនខានឡើយ ។ ចំណែកឯកងទ័ពវៀតណាម និង កងកម្លាំងរដ្ឋាភិបាលក្រុងភ្នំពេញនាសម័យនោះ បន្ទាប់ពីបានវាយបណ្តេញ ប៉ុល ពត ចេញពីអំណាចរួចមក ក៏ប្រឹងប្រែងវាយកំទេចឲ្យអស់នូវអង្គការចាត់តាំងទាំងនយោបាយ ទាំងយោធារបស់ ប៉ុល ពត ជាមួយនឹងការស្វែងរកវិធីពង្រឹងរដ្ឋអំណាចរបស់រដ្ឋាភិបាលក្រុងភ្នំពេញ រួមទាំងការទទួលបាននូវការទទួលស្គាល់ពីសហគមន៍អន្តរជាតិផង ។

នៅសម័យនោះ ខ្ញុំមើលឃើញថាដំណោះស្រាយតាមកម្លាំងយោធាហាក់ដូចជាមានអាទិភាពខ្ពស់ជាងគេ ដើម្បីបញ្ចប់ជម្លោះរវាងកងទ័ពវៀតណាម និងកងទ័ពខ្មែរក្រហម ។ ក៏ប៉ុន្តែ ជាមួយគ្នានោះ ក៏មានចលនាស្វែងរកការជួបគ្នារវាងសម្តេច សីហនុ ជាមួយថ្នាក់ដឹកនាំរដ្ឋាភិបាលក្រុងភ្នំពេញដែរ ទោះបីព្រះអង្គបានចូលរួមក្នុងរដ្ឋាភិបាលចម្រុះត្រីភាគីក៏ដោយ ។ រាល់ការជួបចរចាណាមួយលើឆាកអន្តរជាតិ អាចចាត់ទុកជាការចាប់ផ្តើមទទួលស្គាល់ខ្លះៗដល់រដ្ឋាភិបាលនៅភ្នំពេញរួចទៅហើយ ។

ទិដ្ឋភាពពីរនៃបញ្ហាកម្ពុជាពិតជាត្រឹមត្រូវ

នៅសម័យនោះ មានការបកស្រាយថាជម្លោះនៅកម្ពុជាមានទិដ្ឋភាពពីរគឺ៖ ទីមួយ ទិដ្ឋភាពអន្តរជាតិដែលពាក់ព័ន្ធដល់វត្តមាន និង ការដកកងទ័ពវៀតណាមចេញពីកម្ពុជា និង ទីពីរ ទិដ្ឋភាពជាតិ ដែលទាក់ទងដល់ការផ្សះផ្សារសម្រុះសម្រួលគ្នារវាងភាគីខ្មែរបដិបក្ខ ។ ជំនួប សីហនុ-ហ៊ុន សែន នៅចុងឆ្នាំ ១៩៨៧ បានចាប់

ផ្តើមធ្វើឲ្យមានបរិយាកាសអនុគ្រោះ ដល់ដំណោះស្រាយផ្នែកទិដ្ឋភាពជាតិនៃជម្លោះនៅកម្ពុជា ។

នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ នោះ ពួកក្រុមយើងនៅក្នុងចលនាតស៊ូមិនសូវមានការពេញចិត្តចំពោះការផ្លាស់ប្តូរគោលជំហរនយោបាយរបស់សម្តេច សីហនុ ប៉ុន្មានទេ ។ ពួកយើងក្រោមការដឹកនាំរបស់លោកតា សឺន សាន តែងតែយល់ថាព្រះអង្គផ្លាស់ប្តូរញឹកញាប់ពេក ។ ជាពិសេស នៅពេលដែលពួកយើងកំពុងរៀបចំទ័ព និង បង្កើតរណសិរ្ស ដើម្បីតបតជាមួយកងទ័ពវៀតណាម សម្តេចទ្រង់គង់នៅស្ងៀម និង ថែមទាំងចង់ទៅចរចាជាមួយមេដឹកនាំទីក្រុងហាណូយទៀតផង ។ តាមលោកតា សឺន សាន រ.ជ.រ.ប.ខ.បានត្រូវរៀបចំឡើង ដើម្បីថ្វាយព្រះអង្គដឹកនាំ ព្រោះថាកាលពីដើមឆ្នាំ ១៩៧៩ នៅទីក្រុងញីវយ៉ក ទោះបីជាលោកតាមិនបានចូលគាល់សម្តេចផ្ទាល់ក៏ដោយ លោកតាក៏បានទូរស័ព្ទទូលពីបំណងបង្កើតចលនាតស៊ូមិនមែនកុម្មុយនីស្តមួយ ដែលអាចឲ្យប្រជាពលរដ្ឋខ្មែរទទួលយកបាន ។

តាមពិតទៅ នៅសម័យនោះ អ្វីដែលលោកតាមានប្រសាសន៍ ពួកយើងក្មេងៗតែងជឿទាំងអស់ ។ ក៏ប៉ុន្តែ តាមការវិភាគក្រោយៗមក ខ្ញុំក៏យល់ដឹងថាសម្តេច សីហនុ មិនចូលរួមជាមួយលោកតា សឺន សាន ក៏ដោយសារព្រះអង្គមានហេតុផលរបស់ព្រះអង្គដែរ ។ ក្រោយដែលសម្តេចទ្រង់បានទទួលសេរីភាពចេញពីក្រុម ប៉ុល ពត រួចហើយ ព្រះអង្គអាចប្រកាន់គោលជំហរថា ក្នុងហានៈជាអតីតព្រះមហាក្សត្រដែលជាទីគោរពសក្ការៈរបស់ប្រជាពលរដ្ឋខ្មែរ ព្រះអង្គត្រូវតែគង់នៅក្នុងស្ថានភាពមួយ ដែលអាចឲ្យព្រះអង្គចាប់ដៃនិយាយជាមួយអ្នកណាក៏បាន ។ ម្យ៉ាងទៀត ព្រះអង្គក៏អាចស្គាល់លោកតា សឺន សាន ច្បាស់លាស់ជាងនរណាទាំងអស់ ព្រោះថាលោកតា សឺន សាន ធ្លាប់ជាសហការី ឬ ទីប្រឹក្សារបស់សម្តេចអស់ពេលជាច្រើនឆ្នាំ កាលព្រះអង្គគង់នៅក្នុងអំណាចនៅឡើយ ។ សម្តេច សីហនុ

ក៏អាចស្គាល់លោកតា សឺន សាន ថាជាអ្នកនយោបាយជើងចាស់មួយរូបដែរ ។ ព្រះអង្គអាចទតឃើញថា អ្នកនយោបាយជួនកាលគេឲ្យអ្វីមួយដែលយើងមិនអាចទទួលយកបាន ។ យ៉ាងណាមិញ ក្នុងករណីដែលលោកតាថាថ្វាយសម្តេច សីហនុ ដឹកនាំរ.ជ.រ.ប.ខ.នោះ ព្រះអង្គក៏ប្រាកដជាពិបាកនឹងទទួលណាស់ ព្រោះថាអ្នកដឹកនាំសំខាន់ៗមួយចំនួនធំនៃរ.ជ.រ.ប.ខ. សុទ្ធតែជាអ្នកសាធារណរដ្ឋ ដែលបានផ្តួលរំលំរបបរាជានិយមរបស់ព្រះអង្គរួចម្តងទៅហើយៗនៅតែបន្តអរិភាព ចំពោះព្រះអង្គផង ។ ខ្ញុំនៅចាំបានថា នៅខែ កក្កដា ១៩៨២ នៅឱកាសដែលសម្តេច សីហនុ យាងទៅធ្វើទស្សនកិច្ចជាលើកទីមួយនៅជំរុំអំពិល មេដឹកនាំជំរុំអំពិលមានជាអាទិ៍ លោកឧត្តមសេនីយ ដៀន ដែល និង លោក ហ៊ឹង គន្ធុន មិនមានបំណងចេញមកទទួលព្រះអង្គ និង ព្រះជាយាទេ ។ ដូចខ្ញុំបានសរសេរ នៅវគ្គមុនៗរួចហើយថានៅទីបំផុតនៅឆ្នាំ ១៩៨១ សម្តេច សីហនុ ក៏ទ្រង់បង្កើតចលនានយោបាយរបស់ព្រះអង្គដែលមានឈ្មោះថា ហ៊ុន សុិន ប៊ុច ។ យ៉ាងដូច្នេះហើយ ទើបចលនាតស៊ូមិនមែនកុម្មុយនីស្តបានត្រូវបង្កើតឡើងពីរផ្សេងគ្នា មួយដឹកនាំដោយលោកតា សឺន សាន និង មួយទៀតដឹកនាំដោយសម្តេច សីហនុ ។ ចលនាមួយចេញដំណើរពីធំមកតូច ចលនាមួយទៀតចេញពីតូចមកធំ ។ មិនតែប៉ុណ្ណោះ ការប្រណាំងប្រជែងគ្នារវាងចលនាតស៊ូមិនមែនកុម្មុយនីស្តទាំងពីរនោះ ក៏បានផ្តល់លទ្ធភាពឲ្យក្រុមខ្មែរក្រហមរៀបចំអង្គការចាត់តាំងនយោបាយ និង យោធាបានមួយរយៈ មុននឹងត្រូវដួលរលំទាំងស្រុងនៅចុងឆ្នាំ ១៩៩៨ ដោយសារនយោបាយឈ្នះ/ឈ្នះរបស់សម្តេច តេជោ ហ៊ុន សែន ។

ចាប់តាំងពីថ្ងៃ ៧ មករា ១៩៧៩ រៀងមក ទាំងខ្មែរក្រហម ទាំងក្រុមខ្មែរមិនមែនកុម្មុយនីស្ត រួមទាំងប្រទេសដែលគាំទ្រផង មិនបានញែកបញ្ហាកម្ពុជាជាពីរទិដ្ឋភាពដូចខាងលើទេគឺ គេចាត់ទុកការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត

ជាអំពើឈ្លានពានរបស់វៀតណាមមកលើអធិបតេយ្យភាពនៃកម្ពុជា ។ តាមយុទ្ធសាស្ត្រនេះ បញ្ហាកម្ពុជាមានតែមួយគត់គឺការដកកងទ័ពវៀតណាមចេញពីកម្ពុជា ។ រ.ជ.រ.ប.ខ.ប្រកាន់គោលជំហរធ្វើការប្រយុទ្ធប្រឆាំងបរទេសឈ្លានពានតាមដំណោះស្រាយមួយ ដែលមានអង្គការសហប្រជាជាតិមកត្រួតពិនិត្យការដកថយនៃកងទ័ពបរទេសនេះ និង បន្ទាប់មក រៀបចំការបោះឆ្នោតដោយសេរីត្រឹមត្រូវ ដើម្បីជ្រើសរើសរបប និង អ្នកដឹកនាំរដ្ឋតាមឆន្ទៈរបស់ប្រជារាស្ត្រខ្មែរ ។ នៅក្នុងអន្តរកាលរ.ជ.រ.ប.ខ.សុំឲ្យមានការចាត់តាំងរដ្ឋាភិបាលចតុភាគីមួយ ដែលមានការចូលរួមពីភាគីខ្មែរទាំងអស់រួមទាំងភាគីរដ្ឋាភិបាលក្រុងភ្នំពេញផង ។

រ.ជ.រ.ប.ខ. ប្រកាន់គោលជំហរដូចខ្មែរក្រហម

គួរចាប់អារម្មណ៍ថាមុនពេលចូលរួមក្នុងរដ្ឋាភិបាលចម្រុះត្រីភាគី រ.ជ.រ.ប.ខ. ជាអ្នកប្រឆាំងខ្មែរក្រហមយ៉ាងស្លាប់រស់ ក៏ប៉ុន្តែនៅក្នុងរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ(ត្រីភាគី) រ.ជ.រ.ប.ខ. ក៏ក្លាយទៅជាមេធាវីការពារយ៉ាងរឹងមាំនូវគោលជំហររបស់រដ្ឋាភិបាលនេះ ដែលជាទូទៅស្ថិតនៅក្រោមឥទ្ធិពលដ៏ខ្លាំងក្លារបស់ខ្មែរក្រហម ។ រ.ជ.រ.ប.ខ.ប្រកាន់គោលជំហរដូចខ្មែរក្រហមដែរគឺ ដាច់ណាត់មិនចរចាជាមួយរដ្ឋាភិបាលក្រុងភ្នំពេញទេ ។ បើត្រូវចរចាគឺ ចរចាតែជាមួយរដ្ឋាភិបាលក្រុងហាណូយតែប៉ុណ្ណោះ ។ គោលជំហរបែបនេះ ក៏មិនខុសពីគោលជំហរដ៏រឹងត្អឹងរបស់ខ្មែរក្រហមឡើយ ។ ចំណែកសម្តេច សីហនុ ទោះជាព្រះអង្គចូលមកគង់ជាប្រធានកម្ពុជាប្រជាធិបតេយ្យ ឬ ជាថ្នាក់ដឹកនាំកំពូលនៃរដ្ឋាភិបាលចម្រុះត្រីភាគីយ៉ាងណាក៏ដោយ ក៏ព្រះអង្គតែងតែរិះរកមធ្យោបាយ ឲ្យមានការជួបចរចាគ្នាជាមួយរដ្ឋាភិបាលក្រុងហាណូយក៏បាន ជាមួយរដ្ឋាភិបាលក្រុងភ្នំពេញក៏បាន ។ ដូចយើងបានឃើញនៅវគ្គមុនៗរួចហើយ សម្តេច សីហនុ បានសាកល្បងរក្សាឯករាជភាពរបស់

ព្រះអង្គពីខ្មែរក្រហមណាស់ដែរ ក៏ប៉ុន្តែដោយសារព្រះអង្គត្រូវការជំនួយសម្រាប់ចលនារបស់ព្រះអង្គ ជាពិសេសជំនួយយោធាសម្រាប់ហ៊ុន សុិន ប៊ិច ទើបព្រះអង្គចូលរួមជាមួយខ្មែរក្រហម និង ជាមួយលោកតា សឺន សាន នៅក្នុងរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ។ តាមពិតទៅ បើព្រះអង្គមានមធ្យោបាយផ្ទាល់ព្រះអង្គដើម្បីធ្វើសកម្មភាពនយោបាយដោយព្រះអង្គឯង ឬ ប្រសិនបើមានមហាអំណាចណាមួយនៃលោកខាងលិច ឬ មហាអំណាចណាក្រៅពីចិនផ្តល់មធ្យោបាយថ្វាយព្រះអង្គ សម្តេចប្រាកដជាគេចចេញពីខ្មែរក្រហមមិនខានឡើយ ។ សម្តេចធ្លាប់បានសម្រេចព្រះទ័យសុំការអនុញ្ញាតពីរដ្ឋាភិបាលស.រ.អា និង បារាំងទៅគង់ភៀសព្រះអង្គនៅប្រទេសទាំងពីរនេះ ក៏ប៉ុន្តែ ដោយមិនបានទទួលចម្លើយតាមសំណើរបស់ព្រះអង្គ ពីប្រទេសមហាអំណាចខាងលិចទាំងពីរនេះ និង ដោយមានការទទូចសុំពីមេដឹកនាំចិន តេង ស៊ាវពីង កាលពីខែ មករា ១៩៧៩ ទើបព្រះអង្គវិលត្រឡប់ទៅគង់នៅប្រទេសចិនវិញ ហើយនៅទីបំផុតក៏ចូលរួមជាមេដឹកនាំរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យតមកទៀត ។

គួរបញ្ជាក់ថាជាមួយនោះ ព្រះអង្គក៏សាកល្បងទាក់ទងជាមួយមេដឹកនាំក្រុងហាណូយ ដើម្បីរកវិធីដោះស្រាយបញ្ហាកម្ពុជាតាមការចរចាគ្នា ដែលធ្វើឲ្យមានការរិះគន់ព្រះអង្គយ៉ាងខ្លាំងពីក្រុមខ្មែរក្រហម និង ពីក្រុមលោកតា សឺន សាន ។ ក្រៅពីនេះ តាមរយៈខ្សែរយៈទំនាក់ទំនងដ៏ធំទូលាយលើឆាកអន្តរជាតិរបស់ព្រះអង្គ សម្តេច ក៏ព្យាយាមជួបចរចាជាមួយថ្នាក់ដឹកនាំរដ្ឋាភិបាលក្រុងភ្នំពេញដែរ ។ តាមសម្តេចតេជោ ហ៊ុន សែន ជំនួប សីហនុ-ហ៊ុន សែន លើកដំបូង គ្រោងធ្វើឡើងនៅប្រទេសបារាំងក្នុងឆ្នាំ ១៩៨៤ ។ ជំនួបនោះគ្រោងរៀបចំឡើងដោយប្រទេសបារាំង ក៏ប៉ុន្តែ ត្រូវអាក់ខានវិញ ដោយសារសភាពការណ៍នៅពេលនោះនៅមិនទាន់អនុគ្រោះ ។ នៅសម័យនោះ ទាំងចិនទាំងប្រទេសអាស៊ាន សុទ្ធតែប្រកាន់គោលជំហរ

ឲ្យដកកងទ័ពវៀតណាមចេញជាមុនសិន ទើបឲ្យមានការជួបចរចាគ្នា ។

ក្រុមលោកតា សឺន សាន រិះគន់សម្តេច សីហនុ

នៅឆ្នាំ ១៩៨៤ នោះ អ្នកគាំទ្រលោកតា សឺន សាន និង រ.ជ.រ.ប.ខ.បានធ្វើការវាយប្រហារសម្តេច សីហនុ យ៉ាងខ្លាំងតាមការរិះគន់ជាសាធារណៈ និង តាមផ្លូវឯកជនជាច្រើនថា សម្តេចជាអ្នកទទួលខុសត្រូវ ចំពោះការឡើងកាន់អំណាចនៃខ្មែរក្រហមក្នុងឆ្នាំ ១៩៧៥ ហើយថា ព្រះអង្គកំពុងបំរើនយោបាយរបស់ចិនកុម្មុយនីស្ត និង ខ្មែរក្រហមតទៅទៀត ។ ដើម្បីឆ្លើយតបទៅនឹងការរិះគន់របស់ក្រុមលោកតា សឺន សាន នេះ សម្តេច សីហនុ បានចេញផ្សាយឯកសារសំណួរចម្លើយចុះថ្ងៃទី ១០ វិច្ឆិកា ១៩៨៤ និង អនុស្សរណៈចុះថ្ងៃទី ១៥ វិច្ឆិកា ១៩៨៤ វាយបកទៅវិញថាប្រសិនបើលោកតា សឺន សាន និង រ.ជ.រ.ប.ខ.ស្អប់ខ្ពើមខ្មែរក្រហមមែន ហេតុដូចម្តេចបានជាសុខចិត្តចូលរួមក្នុងរដ្ឋាភិបាលចម្រុះត្រីភាគីជាមួយពួកនេះ ហើយហេតុអ្វីបានជាលោកតា សឺន សាន សុខចិត្តធ្វើជានាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ? នៅក្នុងឯកសាររបស់ព្រះអង្គនេះ សម្តេច សីហនុ ក៏បានឲ្យដឹងដែរថា ព្រះអង្គបានសុំលាឈប់ពីតំណែងប្រធានកម្ពុជាប្រជាធិបតេយ្យជាច្រើនខែមកហើយ តែទាំងក្រុមប្រទេសអាស៊ាន ទាំងប្រទេសចិន និង ដៃគូឯទៀតនៅក្នុងរដ្ឋាភិបាលចម្រុះ បានសុំឲ្យព្រះអង្គនៅបន្តតំណែងនេះតទៅទៀត ។ សម្តេចសំដែងមតិថា ព្រះអង្គរង់ចាំតែសញ្ញាភ្លើងខៀវពីអ្នកទាំងនោះទេ ដើម្បីលាចេញពីតំណែង ។ សម្តេចបានបន្ទោសក្រុមលោកតា សឺន សាន ថារំលោភលើកិច្ចព្រមព្រៀងត្រីភាគីកូឡាឡាំពួ[200] ដោយធ្វើការវាយប្រហារព្រះអង្គនៅចំពោះមុខសារព័ត៌មានអន្តរជាតិ តាមពាក្យសំដីដ៏សាហាវ និង ដោយប្រមាថជាទីបំផុត ។ ព្រះអង្គ

[200] Norodom Sihanouk, Memorandum, New York, November 15, 1984.

សំដៅចំពោះក្រុមរ.ជ.រ.ប.ខ. នៅប្រទេសបារាំង និង ស.រ.អា ជាពិសេសអ្នកស្រី សួន កាសេត លោកបណ្ឌិត ឆាយ ហាន់ចេង (កូនប្រសារលោកតា សឺន សាន) និង ក្រុមខ្មែរគាំទ្ររ.ជ.រ.ប.ខ. នៅរដ្ឋមីនីសូតា (Minnesota) ស.រ.អាជាដើម[201] ។

ក្រុមរ.ជ.រ.ប.ខ. មានការខកចិត្ត ចំពោះគោលជំហររបស់ប្រទេសបារាំង ដែលប៉ុនប៉ងរៀបចំជំនួប សីហនុ-ហ៊ុន សែន នាឆ្នាំ ១៩៨៤ នោះ ។ ពួករ.ជ.រ.ប.ខ. មើលឃើញលោករដ្ឋមន្ត្រីការបរទេសបារាំង ក្លូត ឆេសសុង (Claude Cheysson) ហាក់ដូចជាលំអៀងខ្លាំងទៅខាងវៀតណាម និង រដ្ឋាភិបាលក្រុងភ្នំពេញ ។ គួរកត់សម្គាល់ថា រាល់ៗពេលដែលសម្តេច សីហនុ ត្រៀមជួបចរចាជាមួយមេដឹកនាំរដ្ឋាភិបាលក្រុងភ្នំពេញ ព្រះអង្គតែងអាងហេតុផលជាលេស ដើម្បីសុំលាឈប់ពីតំណែងប្រធានកម្ពុជាប្រជាធិបតេយ្យនេះ ។

នៅខែ កក្កដា ១៩៨៤ សម្តេច សីហនុ បានប្រកាសជាសាធារណៈថាកងទ័ពខ្មែរក្រហមវាយប្រហារមកលើកងទ័ពរបស់ព្រះអង្គ ។ សម្តេចគំរាមថានឹងលាលែងពីតំណែង ឬ យាងចេញពីសម្ព័ន្ធភាពត្រីភាគី ។ សេចក្តីប្រកាសជាសាធារណៈរបស់ព្រះអង្គជា "ព្រួញមួយបាញ់បានសត្វពីរ" គឺមួយជាសញ្ញាប្រាប់ដៃគូនៅក្នុងរដ្ឋាភិបាលត្រីភាគីរបស់ព្រះអង្គឲ្យដឹងថា បើមានការគាបសង្កត់ទៅលើសម្តេច ដោយកម្លាំងយោធាក្តី ដោយការវាយប្រហារតាមពាក្យសំដីក្តី ព្រះអង្គមិនខ្លាចនឹងដកព្រះអង្គចេញពីដៃគូទាំងនោះឡើយ ។ ឯមួយទៀតក៏ជាសញ្ញាដល់វៀតណាម និង រដ្ឋាភិបាលក្រុងភ្នំពេញថា ព្រះអង្គរក្សាលទ្ធភាពអាចចេញមកចរចាជាមួយពួកគេបានគ្រប់ពេលវេលា ។ គួរកត់សម្គាល់ម្យ៉ាងទៀតថា ចាប់តាំងពីលោកប្រធានាធិបតីថ្មីនៃប្រទេសបារាំងគឺលោក ហ្វ្រង់ស្វ័រ មីតេរ៉ង់ (François Mitterand) នៃគណបក្សសង្គមនិយមបារាំងឡើងកាន់អំណាចនាឆ្នាំ ១៩៨១ មក ប្រទេសបារាំងបានខិតខំ

[201] Norodom Sihanouk's Replies to SonSannian Accusations and Questions in Minneapolis, November 10, 1984.

លើកទឹកចិត្តឲ្យមានការជួបចរចាគ្នាផ្ទាល់រវាងគូបដិបក្ខខ្មែរទាំងពីរ គឺរវាងរដ្ឋាភិបាលចម្រុះត្រីភាគី និង រដ្ឋាភិបាលក្រុងភ្នំពេញ ។

គួររំលឹកដែរថាចាប់តាំងពីឆ្នាំ ១៩៨២ ដល់ឆ្នាំ ១៩៨៥ គឺ ចាប់តាំងពីការបង្កើតរដ្ឋាភិបាលចម្រុះត្រីភាគីមក កងទ័ពនៃភាគីទាំងបីក្នុងរដ្ឋាភិបាលនេះ បានបង្កើនការវាយប្រហារតាមផ្លូវយោធាមកលើកងទ័ពវៀតណាម និង កងទ័ពរដ្ឋាភិបាល ហេង សំរិន ជាប់ជាប្រចាំ ។ ក៏ប៉ុន្តែចាប់ពីឆ្នាំ ១៩៨៥ មក កងទ័ពវៀតណាម និង កងទ័ព ហេង សំរិន បានវាយបកត្រឡប់វិញយ៉ាងខ្លាំងក្លា ។ នៅទីបំផុត កងទ័ពទាំងនេះ បានទទួលជោគជ័យក្នុងការវាយបណ្តេញកងទ័ពត្រីភាគីឲ្យបោះបង់ចោលទីតាំងយោធា ដែលនៅលើទឹកដីខ្មែរ តាមបណ្តោយព្រំដែនខ្មែរ-ថៃ ។ បន្ទាប់ពីការបាក់បែកនេះមក មេទ័ពត្រីភាគីជាពិសេសអតីតឧត្តមសេនីយនៃរបបសាធារណរដ្ឋដូចជាលោកឧត្តមសេនីយ សក់ ស៊ុតសាខន នៃក.ជ.រ.ប.ខ.ជាដើម បានប្រកាសជាសាធារណៈថា ពួកលោកឧត្តមសេនីយបានផ្លាស់ប្តូរកលយុទ្ធពីធ្វើសង្គ្រាមតាមរបៀបទ័ពស្រុក មកធ្វើតាមរបៀបទ័ពព្រៃម្តងវិញ ដូច្នេះមិនចាំបាច់មាន ទីតាំងយោធានៅនឹងកន្លែងឡើយ ។

សហគមន៍អន្តរជាតិទទួលយកសីលធម៌សកលថ្មី

ការវាយប្រហារគ្នាតាមផ្លូវយោធា ដែលចេះតែរីកទ្រង់ទ្រាយធំឡើងៗបានបង្កើតឲ្យមានមហន្តរាយខាងផ្នែកមនុស្សធម៌ដ៏ធំធេង ។ ប្រជាពលរដ្ឋខ្មែរ ដែលទទួលរងគ្រោះដោយសាររបបប្រល័យពូជសាសន៍ ដែលមិនធ្លាប់ឃើញសោះនៅក្នុងប្រវត្តិសាស្ត្រខ្មែរ បានទទួលរងថែមទៀតនូវផលប៉ះពាល់ដោយសារសង្គ្រាម ។ ដើម្បីគេចចេញពីភ្លើងសង្គ្រាម ជនភៀសខ្លួនខ្មែររាប់សែននាក់ បានរត់មកជ្រកនៅតាមតំបន់ជាយដែន ។ មួយភាគធំបានឆ្លងចូលមករកទីជម្រកនៅប្រទេសថៃ ។

ជនកៀសខ្លួនទាំងនោះ បានទទួលការជួយឧបត្ថម្ភម្ហូបអាហារ ទីជម្រក និង ការការពារពីអង្គការសហប្រជាជាតិ ។ ពួកគេក៏នាំមកជាមួយនូវរឿងរ៉ាវផ្ទាល់ខ្លួនរបស់គេម្នាក់ៗស្តីពីឧក្រិដ្ឋកម្មយង់ឃ្នងរបស់ពួក ប៉ុល ពត ក្នុងពេលដែលពួកនេះកាន់អំណាច ។ ពិភពលោកទាំងមូលក៏កាន់តែយល់ដឹងច្បាស់ឡើងនូវធាតុពិតនៃរបបប្រល័យពូជសាសន៍ ។ ជាមួយនឹងវិបត្តិជនកៀសខ្លួនខ្មែរ សហគមន៍អន្តរជាតិហាក់ដូចជាទទួលយកនូវសេតិសម្បជញ្ញៈ និង សីលធម៌សកលមួយថ្មីគឺ ការស្វែងរកនូវការបញ្ចប់ទុក្ខវេទនារបស់ប្រជាពលរដ្ឋខ្មែរជាបន្ទាន់ ។ មហាអំណាចចម្បងៗ ហាក់ដូចជាសម្លឹងឃើញថា ត្រូវដោះស្រាយជម្លោះកម្ពុជាដោយសន្តិវិធី ដែលនៅក្នុងដំណោះស្រាយនោះ រួមមានការទប់ស្កាត់របបខ្មែរក្រហម ប៉ុល ពត មិនឲ្យត្រឡប់មកកាន់អំណាចវិញ និង ការគោរពជាដាច់ខាតនូវសិទ្ធិមនុស្សនៅកម្ពុជា ។

ចរន្តអន្តរជាតិនេះ រឹតតែធ្វើឲ្យពួកខ្មែរក្រហមយល់ថា អនាគតរបស់ពួកគេនឹងត្រូវរលត់រលាយ ប្រសិនបើពួកគេមិនពង្រឹងកម្លាំងយោធានៅលើសមរភូមិឲ្យបានរឹងមាំទេ ។ អនាគតរបស់ខ្មែរក្រហមនោះ ពិតជាស្ថិតនៅលើឧត្តមភាពយោធាតែមួយគត់របស់ពួកគេ ។ ដូច្នេះកលយុទ្ធសំខាន់ទីមួយ និង ងាយស្រួលជាងគេគឺបង្កើនឧត្តមភាពខាងផ្នែកយោធា ទៅលើដៃគូមិនមែនកុម្មុយនីស្តពីរទៀត ទាំងទៅលើ រ.ជ.រ.ប.ខ. ទាំងទៅលើ ហ៊ុន ស៊ិន ប៊ិច ។ ខ្មែរក្រហមរក្សាសម្ព័ន្ធភាពតែខាងផ្លូវនយោបាយតែប៉ុណ្ណោះ ។ ពួកគេមិនខ្លាចនឹងវាយប្រហារដៃគូពីរទៀតតាមកម្លាំងយោធានោះឡើយ ។ ដូចនេះការវាយប្រហារប្រយុទ្ធគ្នា ក៏កើតឡើងរវាងកងទ័ពខ្មែរក្រហម និង កងទ័ពនៃចលនាមិនមែនកុម្មុយនីស្ត ។ នៅសម័យនោះ ចំពោះខ្មែរក្រហម មានតែកម្លាំងយោធាមួយគត់ ដែលអាចធានាអាយុជីវិតឲ្យពួកគេ និង អាចឲ្យគេមានមុខនៅតុចរចានាពេលណាមួយខាងមុខ ។

ភាគីនីមួយៗ និង គោលដំហរក្នុងការធ្វើសង្គ្រាម

គួររំលឹកទៀតថា វៀតណាមក៏ទទួលការគាបសង្កត់កាន់តែខ្លាំងឡើងពីសហគមន៍អន្តរជាតិឲ្យដកកងទ័ពចេញពីកម្ពុជា ។ ជាមួយគ្នានោះ ការផ្សះផ្សាជាតិរវាងភាគីខ្មែរ ក៏ក្លាយទៅជាគន្លឹះនៃដំណោះស្រាយនយោបាយផងដែរ ។ ថ្នាក់ដឹកនាំវៀតណាមធ្លាប់បានប្រកាសថា ប្រសិនបើភាគីខ្មែរទាំងអស់ ក្រោយដែលបានជានាផ្សះផ្សាគ្នា និង រួបរួមគ្នារួចហើយៗស្នើឲ្យវៀតណាមដកទ័ពចេញពីកម្ពុជា វៀតណាមនឹងដកទ័ពចេញពីកម្ពុជាភ្លាម ។ នៅសម័យនោះ ភាគីខ្មែរនៅមិនទាន់អាចជានាផ្សះផ្សាគ្នាបាននៅឡើយទេ ។ ជាពិសេស ភាគីធំៗពីរគឺ ភាគីរដ្ឋាភិបាលក្រុងភ្នំពេញ និង ភាគីខ្មែរក្រហម ។ ភាគីរដ្ឋាភិបាលភ្នំពេញ ឈរលើគោលដំហរថាធ្វើសង្គ្រាម ដើម្បីរំដោះប្រជាពលរដ្ឋខ្មែរពីរបបប្រល័យពូជសាសន៍ ។ ឯវត្តមានកងទ័ពវៀតណាមនៅកម្ពុជាជាការចាំបាច់ ដើម្បីជួយផ្តួលរំលំរបបប្រល័យពូជសាសន៍ប៉ុល ពត ផង និង ដើម្បីជួយទប់ស្កាត់កុំឲ្យរបបសាហាវយង់ឃ្នងនេះ វិលមកកាប់សម្លាប់ប្រជាពលរដ្ឋខ្មែរវិញផង ។ ដូច្នេះកងទ័ពវៀតណាម ជាកងទ័ពសម្ព័ន្ធមិត្តមកជួយការពារប្រជាពលរដ្ឋខ្មែរ មិនមែនជាកងទ័ពបរទេសមកឈ្លានពានកម្ពុជាទេ ។ ភាគីខ្មែរក្រហម និង ដៃគូពីរទៀតប្រកាន់គោលដំហរថា គេធ្វើសង្គ្រាមដើម្បីរំដោះប្រទេសកម្ពុជាពីកងទ័ពវៀតណាមឈ្លានពាន ។ ឈរលើគោលដំហរផ្ទុយគ្នានេះ ការផ្សះផ្សាជានាគ្នាប្រាកដជាមានការលំបាកក្រៃលែង ។ តែទោះជាយ៉ាងណាក៏ដោយ ក៏គំនិតផ្សះផ្សាភាគីខ្មែរនេះ ត្រូវបានលើកឡើងជាបន្តបន្ទាប់ក្នុងបណ្តាប្រទេស ដែលចង់ជួយរកដំណោះស្រាយក្នុងបញ្ហាកម្ពុជា ។

សេអូសេស្កូ ណែនាំឲ្យ ខៀវ សំផន ជានាជាមួយ ហេង សំរិន

នៅខែ សីហា ១៩៨២ សម្តេច សីហនុ និង លោក ខៀវ សំផន បានទៅបំពេញទស្សនកិច្ចនៅប្រទេសរូម៉ានី ដែលនៅសម័យនោះ ជាប្រទេសកុម្មុយនីស្ត ក៏ប៉ុន្តែមានទំនាក់ទំនងល្អជាមួយប្រទេសវៀតណាមផង និង ទំនាក់ទំនងល្អជាមួយរដ្ឋាភិបាលចម្រុះត្រីភាគីកម្ពុជាប្រជាធិបតេយ្យផង ។ នៅក្នុងជំនួបជាមួយលោកប្រធានាធិបតី សេអូសេស្កូ (Ceausescu) លោកប្រធានាធិបតីរូបនេះបានផ្តល់មតិដល់លោក ខៀវ សំផន ឲ្យធ្វើការផ្សះផ្សាជានាគ្នាជាមួយភាគី ហេង សំរិន ព្រោះថា បើគ្មានការជានាផ្សះផ្សាគ្នាជាមួយភាគីនេះទេ បញ្ហាកម្ពុជាមិនអាចដោះស្រាយបានឡើយ ។ លោកប្រធានាធិបតីរូម៉ានី គ្មានជំនឿថា ខ្មែរក្រហមអាចដណ្តើមជ័យជំនះតាមកម្លាំងយោធានោះទេ ។ ចំពោះមតិណែនាំនេះ ខ្មែរក្រហមពុំអាចទទួលយកបានឡើយ ព្រោះថាគោលជំហររបស់ពួកគេគឺបង្ខំឲ្យកងទ័ពវៀតណាមដកទ័ពចេញពីកម្ពុជាជាមុន ។ ខ្មែរក្រហមយល់ថា បើគ្មានកងទ័ពវៀតណាមទេនោះ របប ហេង សំរិន ក៏នឹងដួលរំលំមិនខានឡើយ[202] ។ ខ្មែរក្រហមជឿជាក់ទៀតថា ការដកកងទ័ពវៀតណាមចេញពីកម្ពុជា នឹងបើកផ្លូវឲ្យពួកគេវិលត្រឡប់មកកាន់អំណាចវិញ ។

តាមពិតទៅ ខ្មែរក្រហមគ្រាន់តែដើរតាមយុទ្ធសាស្ត្ររបស់ចិនតែប៉ុណ្ណោះ។ ចិនធ្លាប់ទាមទារឲ្យវៀតណាមដកកងទ័ពចេញពីកម្ពុជាជាមុនសិន មុននឹងមានសន្និសីទអន្តរជាតិមួយស្តីពីកម្ពុជា ។ គួរកត់សម្គាល់ថា ចាប់ពីខែ តុលា ឆ្នាំ ១៩៨២ ចិន និង សូវៀត ចាប់ផ្តើមធ្វើការចរចាគ្នា ដើម្បីឲ្យមានប្រក្រតីភាពក្នុងទំនាក់ទំនងគ្នាឡើងវិញ ។ ការចរចា ចិន និង សូវៀត បើកឲ្យមានទស្សនវិស័យថ្មីនៃការទូត

[202] Résumé des Paroles du Président Nicolae Ceausescu de Roumanie Prononcées lors de Son Entrevue avec Norodom Sihanouk et Khieu Samphan, A Bucarest, en Août 1982.

អន្តរជាតិ ក៏ប៉ុន្តែការចរចាគ្នានេះ បានឲ្យយើងនៅក្នុងដួរ.ជ.រ.ប.ខ. មានការបារម្ភខ្លះដែរ ។ ដោយសារយើងមានការទន់ខ្សោយខាងផ្នែកយោធា យើងក៏មានការព្រួយបារម្ភអំពីដំណោះស្រាយក្រហម ចំពោះបញ្ហាកម្ពុជាគឺថា ប្រសិនបើមហាយក្ស កុម្មុយនីស្តចិន-សូវៀតជានាត្រូវរ៉ូវគ្នា គេអាចបែងចែកផលប្រយោជន៍ ដោយច្រានចោលពួកមិនមែនកុម្មុយនីស្តចេញពីឆាកនយោបាយកម្ពុជា ។ ជាមួយនឹងការព្រួយបារម្ភនេះ យើងក៏យកដំណោះស្រាយក្រហមនៅកម្ពុជានេះ ជាប្រធានបទសម្រាប់ការឃោសនានយោបាយ និង ជាលេសស្វែងរកការគាំទ្របន្ថែមពីលោកខាងលិចថែមទៀតផង ។

ហ៊ុន សែន ថា៖ "វាយផង ចរចាផង"

នៅឆ្នាំ ១៩៨៥ លោកឧបនាយករដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងការបរទេសនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ហ៊ុន សែន បានឡើងកាន់តំណែងជានាយករដ្ឋមន្ត្រី ។ ភ្លាមៗនោះ លោកនាយករដ្ឋមន្ត្រីរូបនេះបានបង្ហាញលក្ខខណ្ឌនៃការបញ្ចប់ជម្លោះនៅកម្ពុជា ដោយសង្កត់ធ្ងន់ទៅលើការរៃអង្គាសរំលំអង្គការចាត់តាំងនយោបាយ និង យោធារបស់ ប៉ុល ពត និង ការផ្សះផ្សាជានាគ្នាជាមួយក្រុម ឬ បុគ្គលដែលទទួលយកក្របខណ្ឌនៃរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន (កាលនោះ លោកមានអាយុ ៣៣ ឆ្នាំ) ប្រាកដជាមើលឃើញថាសត្រូវដ៏ធំនៃរបបរបស់លោកគឺខ្មែរក្រហម ។ ប្រសិនបើខ្មែរក្រហមត្រូវបានវាយកំទេច ក្រុមប្រឆាំងឯទៀតមុខជាងាយផ្តួល ឬ ក៏អាចងាយនឹងផ្សះផ្សាគ្នាបាន ។ មេដឹកនាំខ្មែររូបនេះយល់ច្បាស់ទៀតថា ឧបសគ្គដ៏ធំដែលរារាំងសាធារណរដ្ឋប្រជាមានិតកម្ពុជាមិនឲ្យបានទទួលនូវការទទួលស្គាល់ពីសហគមន៍អន្តរជាតិ គឺវត្តមាននៃកងទ័ពវៀតណាមនៅកម្ពុជា ។ ក៏ប៉ុន្តែលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រកាន់

គោលដំហរដ៏ម៉ឺងម៉ាត់ថា ប៉ុល ពត បានប្រព្រឹត្តិអំពើប្រល័យពូជសាសន៍មកលើប្រជារាស្ត្រខ្មែរ បើគ្មានអំពើប្រល័យពូជសាសន៍ទេ ក៏គ្មានការរើបំរះក្រោកឈរឡើងប្រឆាំង ប៉ុល ពត ដោយប្រជារាស្ត្រខ្មែរដែរ ។ ឯកងទ័ពវៀតណាមមិនមែនមកឈ្លានពានកម្ពុជានោះទេ តែជាកងទ័ពស្មគ្រចិត្តដែលមកជួយប្រជារាស្ត្រខ្មែរដើម្បីផ្តួលរំលំរបបប្រល័យពូជសាសន៍តែប៉ុណ្ណោះ ។ បើគ្មានរបបប្រល័យពូជសាសន៍ ក៏គ្មានវត្តមាននៃកងទ័ពវៀតណាមនេះដែរ ។

គួរកត់សម្គាល់ថា ប្រសិនបើការប្រើកម្លាំងយោធាទៅកាន់កាប់ប្រទេសមួយជាការបំពានលើច្បាប់អន្តរជាតិ អំពើប្រល័យពូជសាសន៍ ក៏ជាអំពើឧក្រិដ្ឋមួយមិនតូចជាងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិឡើយ ។ ដូច្នេះ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រើយុទ្ធសាស្ត្រវាយដណ្តើមការទទួលស្គាល់អន្តរជាតិ ដោយឈរយ៉ាងមាំលើគោលដំហរដ៏ស្របច្បាប់ប្រឆាំងប្រល័យពូជសាសន៍ ។ ជាមួយគ្នានោះ លោកនាយករដ្ឋមន្ត្រីខ្មែរនៃរដ្ឋាភិបាលភ្នំពេញរូបនេះ បានចងភ្ជាប់ការដកកងទ័ពវៀតណាមជាមួយនឹងការផ្តួលរំលំជាស្ថាពរនៃពួកខ្មែរក្រហម ប៉ុល ពត ។ ព្រមគ្នានឹងការប្រើកម្លាំងយោធា ដើម្បីវាយប្រហារ ប៉ុល ពត រដ្ឋាភិបាលភ្នំពេញក៏បើកយុទ្ធនាការស្វែងរកការចរចាតាមរបៀបដែលហៅថា៖ "វាយផង ចរចាផង" (Fight, fight, talk, talk) – គឺ វាយទប់ទល់ ឬ វាយកំទេចខ្មែរក្រហមផង ឯចរចាគឺ ចរចា ដើម្បីទទួលបាននូវការទទួលស្គាល់ផង ។ នៅសម័យនោះ រដ្ឋាភិបាលក្រុងភ្នំពេញប្រាកដជាភាគីតែមួយគត់ ដែលអាចទទួលផលច្រើនជាងគេពីរាល់កិច្ចចរចានានា ។

វៀតណាមមិនយកយូអិន តែសុខចិត្តចរចាជាមួយអាស៊ាន

ចាប់តាំងពីឆ្នាំ ១៩៧៩ មក វៀតណាមប្រកែកពុំព្រមទទួលអនុវត្តតាមសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ នៅរាល់មហាសន្និបាតប្រចាំឆ្នាំ ។ ក៏

ប៉ុន្តែ ប្រទេសនេះ បានជ្រើសយកវេទិកាតំបន់ ដើម្បីចរចាបញ្ឈប់ជម្លោះ ។ ក្រុងហាណូយ ស្នើឲ្យក្រុមប្រទេសអាស៊ានចរចាជាមួយក្រុមប្រទេសឥណ្ឌូចិន (កម្ពុជានៃរដ្ឋាភិបាល ហ៊ុន សែន - លាវ និង វៀតណាម) ។ ក្រុមប្រទេសអាស៊ានមិនបានទទួលយកសំណើនេះទេ ព្រោះគេដឹងសឹងទទួលស្គាល់រដ្ឋាភិបាល ហ៊ុន សែន ។ ជាទូទៅអាស៊ានសង្កត់ធ្ងន់ទៅលើសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ ដែលបង្ខំឲ្យមានការដកកងទ័ពបរទេសចេញពីកម្ពុជា ក៏ប៉ុន្តែអាស៊ានក៏មិនបានបិទទ្វារទាំងស្រុងចំពោះការចរចាគ្នានោះទេ ។ អាស៊ានបានទុកឲ្យសមាជិករបស់គេមួយ គឺប្រទេសឥណ្ឌូណេស៊ី ជាអ្នកចរចាផ្ទាល់ជាមួយវៀតណាម ។ នៅក្នុងសម័យនោះ ប្រទេសឥណ្ឌូណេស៊ី បានដើរតួនាទីយ៉ាងសកម្ម ដើម្បីស្វែងរកសន្តិភាព និងស្ថេរភាពនៅក្នុងតំបន់ ។

គួររំលឹកដែរថាចាប់តាំងពីទសវត្សរ៍ឆ្នាំ ១៩៦០ មក ប្រទេសឥណ្ឌូណេស៊ីមានការមិនទុកចិត្តចំពោះប្រទេសចិន ក្រោយពេលដែលលោកប្រធានាធិបតី ស៊ូ ហាតូ ឡើងមកកាន់អំណាច បន្ទាប់ពីបានគាស់រំលើងបណ្តាញចិនកុម្មុយនីស្តចេញពីប្រទេសនេះ ។ តាំងពីពេលនោះមក ឥណ្ឌូណេស៊ីតែងស្វែងរកយ៉ាងប្រយ័ត្នប្រយែងនូវកម្លាំងទប់ចំពោះឥទ្ធិពលចិននៅក្នុងតំបន់ ។ សកម្មភាពរបស់ឥណ្ឌូណេស៊ី ដែលទាក់ទងជាញឹកញាប់ជាមួយវៀតណាម បានធ្វើឲ្យពួកយើងនៅក្នុងជួរ.ជ.រ.ប.ខ.ជាដំបូងមានការព្រួយបារម្ភ ហើយបាននាំគ្នាគិតថាគំនិតផ្តួចផ្តើមរបស់ឥណ្ឌូណេស៊ី ហាក់ដូចជាលំអៀងទៅរកវៀតណាម ។ ដូច្នេះ ចំពោះរាល់ការចរចារវាងឥណ្ឌូណេស៊ី និង វៀតណាម រ.ជ.រ.ប.ខ. យើងតែងប្រុងប្រយ័ត្នជានិច្ច ។

តាមធម្មតា រាល់ការជួបចរចាគ្នាតែងតែជាឱកាស នាំឲ្យមានសង្ឃឹមចំពោះសន្តិភាព ក៏ប៉ុន្តែភាគីនិមួយៗ ក៏តែងឆ្លៀតប្រើយុទ្ធសាស្ត្ររបស់គេ ដើម្បីដណ្តើមប្រៀប ឬ ឧត្តមភាពជានិច្ចនៅរាល់ជំនួប ។ ចំពោះរដ្ឋាភិបាល ហ៊ុន សែន គោលដៅ

ចម្បងគឺ ដណ្តើមឲ្យបាននូវការទទួលស្គាល់អន្តរជាតិ ព្រោះថារដ្ឋាភិបាលនេះមានជើងជាន់ជាប់លើទឹកដីខ្មែររួចទៅហើយ អ្វីដែលនៅខ្វះខាតនោះគឺ ការទទួលស្គាល់ជាសកលពីសហគមន៍អន្តរជាតិតែប៉ុណ្ណោះ ។ ការទទួលស្គាល់នេះ ជាការចាំបាច់ដើម្បីបញ្ចប់នូវការឡោមព័ទ្ធខាងផ្នែកការទូត និង សេដ្ឋកិច្ច ។ ចំណែកឯក្រុមប្រឆាំង ជាពិសេសក្រុមលោកតា សឺន សាន និង ខ្មែរក្រហមវិញ ពួកនេះប្រកាន់ឥរិយាបថរឹងត្អឹងគឺ ប្រកែកមិនចរចាជាមួយរដ្ឋាភិបាល ហ៊ុន សែន ដោយប្រកាន់ថា បញ្ហាកម្ពុជា កើតឡើងដោយអំពើឈ្លានពានរបស់វៀតណាម ។ ដូច្នេះបញ្ហាសង្គ្រាមនៅកម្ពុជាជាសង្គ្រាមឈ្លានពានរវាងវៀតណាម និង កម្ពុជាប្រជាធិបតេយ្យ មិនមែនជាសង្គ្រាមស៊ីវិលរវាងខ្មែរ និង ខ្មែរនោះទេ ។ ក្រុមប្រឆាំងយល់ថា បើនិយាយចរចាជាមួយរដ្ឋាភិបាល ហ៊ុន សែន បាននិយាយថានៅកម្ពុជាមានរដ្ឋាភិបាលពីរគឺ រដ្ឋាភិបាលចម្រុះត្រីភាគីមួយ និង រដ្ឋាភិបាល ហ៊ុន សែន នៅភ្នំពេញមួយ ដែលអាចនាំទៅរកការបែងចែកទឹកដីខ្មែរជាពីរយ៉ាងដូច្នោះដែរ ។ ដូច្នេះហើយ ទើបរដ្ឋាភិបាលចម្រុះត្រីភាគីទាមទារចរចាផ្ទាល់ជាមួយវៀតណាម ។ ក៏ប៉ុន្តែវៀតណាមក៏ប្រាកដជាមិនអាចមកអង្គុយនិយាយជាមួយរដ្ឋាភិបាលចម្រុះត្រីភាគីបានដែរ ព្រោះថាបើមកអង្គុយចរចា គេនឹងត្រូវទទួលស្គាល់ថា ខ្លួនគេជាអ្នកឈ្លានពានកម្ពុជា មិនមែនមកជួយផ្តួលរំលំរបបប្រល័យពូជសាសន៍ តាមសំណូមពររបស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជានោះឡើយ ។ គោលជំហរទាំងសងខាងនេះមានលក្ខណៈផ្ទុយគ្នាទាំងស្រុង ដែលពិបាកនឹងកែសម្រួលណាស់ ។

គួររំលឹកថា ចាប់ពីចុងឆ្នាំ ១៩៨៥ មក រ.ជ.រ.ប.ខ. បានត្រូវជាប់ជំពាក់ក្នុងបញ្ហាបែកបាក់ផ្ទៃក្នុងយ៉ាងខ្លាំងក្លា ដែលធ្វើឲ្យចលនានេះអស់លទ្ធភាពផ្តួចផ្តើមគំនិតនយោបាយអ្វីមួយបានឡើយ ។ លោកតា សឺន សាន ចំណាយពេលវេលា និងឋាមពលជាច្រើន ដើម្បីវាយបកទៅក្រុមឧត្តមសេនីយ សក់ ស៊ុតសាខន និង ជៀន

ដែល ក្នុងការដណ្តើមយកអំណាចដឹកនាំរ.ជ.រ.ប.ខ.មកវិញ ។ សូមរំលឹកដែរថា ពួកឧត្តមសេនីយបានចោទប្រកាន់លោកតា សឺន សាន ថា ធ្វើការដឹកនាំតាមបែបផ្តាច់ការ និង គ្រួសារនិយម ព្រមទាំងនៅអល់អែកក្នុងការចូលរួមជាមួយចលនារបស់សម្តេច សីហនុ ។ ចំណែកឯខ្លួនខ្ញុំផ្ទាល់ (អៀង មូលី) ក៏បានចំណាយពេលវេលាជាអតិបរមា ដើម្បីជួយពង្រឹងឥទ្ធិពល និង ការដឹកនាំរបស់លោកតា សឺន សាន ក្នុងការរៀបចំបណ្តាញទំនាក់ទំនងផ្ទាល់ជាមួយមេបញ្ជាការយោធា និងមេដំរុំជនភៀសខ្លួនឲ្យគាំទ្រលោកតាប្រធាន ។ និយាយជារួម រ.ជ.រ.ប.ខ.ស្ទើរបាត់ម្ចាស់ការអស់ទៅហើយ ។ នៅពេលជួបអ្នកតំណាងប្រទេសផ្តល់ជំនួយម្តងៗ លោកតា សឺន សាន គ្មានបានផ្តល់គំនិតអ្វីក្រៅពីសុំអង្វរករម្ចាស់ជំនួយឲ្យជួយផ្តល់អំណាចយោធាមកលោកតាវិញតែប៉ុណ្ណោះ ។

មែនទែន ទាំងប្រទេសឥណ្ឌូចិន (វៀតណាម - លាវ - កម្ពុជានៃរដ្ឋាភិបាលហ៊ុន សែន) តាមរយៈសន្និសីទនៃរដ្ឋមន្ត្រីការបរទេស ទាំងក្រុមប្រទេសអាស៊ានសុទ្ធតែបានបង្ហាញនូវសំណើដំណោះស្រាយសន្តិភាពរៀងៗខ្លួន ។ ចាប់ពីថ្ងៃទី ២៣ ទៅ ២៤ មករា ១៩៨៦ នៅទីក្រុងវៀងច័ន្ទនៃប្រទេសលាវ សន្និសីទលើកទី ១២ នៃរដ្ឋមន្ត្រីការបរទេសនៃក្រុមប្រទេសឥណ្ឌូចិន បានគូសបញ្ជាក់នូវទិដ្ឋភាពពីរនៃបញ្ហាកម្ពុជា[203]គឺ៖ ទិដ្ឋភាពផ្ទៃក្នុងតម្រូវឲ្យមានការចរចាផ្ទាល់រវាងភាគីខ្មែរដែលមានមូលដ្ឋានលើការផ្តួលរំលំបនប្រល័យពូជសាសន៍ ប៉ុល ពត ដោយគ្មានការលូកដៃពីប្រទេសដទៃ ដើម្បីសម្រេចទៅរកការព្រមព្រៀងបោះឆ្នោតជាទូទៅមួយបន្ទាប់ពីមានការដកកងទ័ពវៀតណាម និង ទិដ្ឋភាពផ្នែកខាងក្រៅតម្រូវឲ្យមានការដកកងទ័ពវៀតណាមចេញ ដែលត្រូវចងភ្ជាប់ជាមួយការកាត់ផ្តាច់ជំនួយក្រៅប្រទេសដល់ភាគីខ្មែរទាំងអស់ ។ ក្រុមប្រទេសឥណ្ឌូចិនស្វាគមន៍ការបន្តការចរចាគ្នា

[203] Douzième Conférence des Ministres des Affaires Etrangères du Cambodge, du Laos et du Vietnam tenue à Vientiane, Laos, du 23 au 24 Janvier 1986, Points à retenir.

តទៅទៀតរវាងវៀតណាម និង ឥណ្ឌូណេស៊ី ក៏ប៉ុន្តែ ក្រុមប្រទេសឥណ្ឌូចិនទាំងបី ធ្វើសំណូមពរថា រាល់ការចរចាខាងមុខគួរឲ្យមានការចរចារវាងក្រុមឥណ្ឌូចិនផ្ទាល់ ជាមួយក្រុមអាស៊ាន ។ ក្រុមប្រទេសទាំងបី ធ្លាប់បានប្រកាសប្រាប់ពិភពលោកថា វៀតណាម នឹងដកកងទ័ពចេញពីកម្ពុជាឲ្យអស់នៅឆ្នាំ ១៩៩០ ។ ដោយសារបញ្ហាកម្ពុជាត្រូវបានបំបែកចេញជាពីរពីទិដ្ឋភាពយ៉ាងនេះ ទើបលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន មានលទ្ធភាពដោះស្រាយទិដ្ឋភាពនីមួយៗនៃបញ្ហាកម្ពុជាទីទៃពីគ្នា ដោយមិនឲ្យទិដ្ឋភាពមួយមកជាប់ជំពាក់ទិដ្ឋភាពមួយទៀតធ្វើជាឧបសគ្គ ដែលអាចនាំឲ្យរាំងស្ទះដល់ដំណោះស្រាយទាំងមូល ។ ម្យ៉ាងទៀត ដោយបានចង្អុលបង្ហាញពីរយៈពេលវែលាច្បាស់លាស់នៃការដកកងទ័ពវៀតណាមចេញពីកម្ពុជា (ចាប់ផ្តើមពីឆ្នាំ ១៩៨៦ និង អស់ទាំងស្រុងនៅឆ្នាំ ១៩៩០) ក្រុមប្រទេសឥណ្ឌូចិនបានធ្វើឲ្យដង្កាប់នៃការគាបសង្កត់របស់សហគមន៍អន្តរជាតិបានត្រូវបន្ធូរបន្ថយទៀតផង ។

ចំណែកក្រុមប្រទេសអាស៊ានក៏បានស្នើឡើងនូវបែបបទបញ្ចប់ជម្លោះដែរ ។ ជាទូទៅ បែបបទបញ្ឈប់ជម្លោះនៃក្រុមប្រទេសទាំងនេះ គាំទ្រគោលការណ៍ទាំងឡាយ ដែលមានចែងក្នុងសេចក្តីថ្លែងការណ៍របស់សន្និសីទអន្តរជាតិស្តីពីកម្ពុជា (ICK)ដែលមានចំណុចសំខាន់ៗគឺ៖ ការឈប់បាញ់គ្នាដើម្បីឲ្យកងទ័ពបរទេសដកចេញពីកម្ពុជា ក្រោមការត្រួតពិនិត្យ និង ផ្ទៀងផ្ទាត់ដោយអង្គការសហប្រជាជាតិ- ការរៀបចំបោះឆ្នោតដោយសេរី ឬ ការប្រើសិទ្ធិស្វ័យសម្រេចក្រោមការត្រួតពិនិត្យរបស់អង្គការសហប្រជាជាតិ- ការស្តាបនាឡើងវិញ និង ការគោរពឯករាជ្យ បូរណភាពទឹកដី អធិបតេយ្យ និង អព្យាក្រឹតភាពជាតិរបស់កម្ពុជា - កម្មវិធីជួយកសាងឡើងវិញនូវសេដ្ឋកិច្ចជាតិកម្ពុជា និង ការអភិវឌ្ឍន៍សេដ្ឋកិច្ច និង សង្គមនៃប្រទេសនៅក្នុងតំបន់ ។

អាស៊ានឲ្យត្រីភាគីពង្រឹងឯកភាព និង សាមគ្គីភាព

នៅសម័យនោះ ក្រុមប្រទេសអាស៊ានបានផ្តល់អនុសាសន៍ដល់រដ្ឋាភិបាលចម្រុះត្រីភាគីឲ្យខិតខំពង្រឹងសមត្ថភាពយោធា ជៀសវាងការប៉ះទង្គិចផ្ទៃក្នុង បង្កើនការពិភាក្សាពិគ្រោះយោបល់គ្នា ពង្រីកសហប្រតិបត្តិការគ្រប់វិស័យ សម្របសម្រួលសកម្មភាពនៅលើសមរភូមិ ជាពិសេសពង្រីកសកម្មភាពសង្គ្រាមចិត្តសាស្ត្រឲ្យធំទូលាយទៀត ។ ក្រុមប្រទេសអាស៊ាន ប្រមើលមើលថា ក្នុងរយៈពេល ១៨ ខែ គិតតាំងពីដើមឆ្នាំ ១៩៨៦ នេះទៅ ប្រសិនបើកងទ័ពត្រីភាគីអាចទប់ទល់បាន ឬអាចវាយបកទៅលើកងទ័ពវៀតណាម និង ទៅលើកងទ័ពរដ្ឋាភិបាល ហ៊ុន សែន បាននោះ គេអាចសន្មត់ថាវៀតណាមប្រាកដជាសុខចិត្តចូលមកចរចា ដើម្បីដកកងទ័ពចេញពីកម្ពុជាមិនខានឡើយ ។ គោលជំហរអាស៊ាននៅពេលនោះ មានសភាពទន់ភ្លន់ជាងគោលជំហរខ្មែរក្រហម និង គោលជំហរចិន ព្រោះក្រុមអាស៊ានមិនទាមទារឲ្យកងទ័ពវៀតណាមចេញទាំងអស់ មុននឹងមានការចរចាគ្នានោះឡើយ ។

ចំណុចសំខាន់ៗនៃបែបបទរបស់អាស៊ាននាពេលនោះ មានដូចតទៅ៖ -ការដកកងទ័ពវៀតណាមជាតំណាក់ៗ ព្រមជាមួយនឹងការឈប់បាញ់គ្នា ដែលចាប់ផ្តើមចេញពីតំបន់ទល់ដែនថៃ-កម្ពុជា -ជាមួយនឹងការដកកងទ័ពទាំងស្រុង កងកម្លាំងកម្ពុជាទាំងអស់ត្រូវទំលាក់អាវុធ -ត្រូវបង្កើតជាតំបន់សុវត្ថិភាពនៅទីណាដែលមានការដកកងទ័ព -ធ្វើមាតុភូមិនិវត្តន៍ជនភៀសខ្លួនកម្ពុជាក្រោមការត្រួតពិនិត្យរបស់ឧត្តមស្នងការសហប្រជាជាតិខាងជនភៀសខ្លួន(UNHCR) -បង្កើតតំបន់អត់មានយោធា (Dimilitarised Zone) នៅលើទល់ដែនខាងទឹកដីកម្ពុជានៅចន្លោះប្រទេសជិតខាង និង នៅតាមមាត់សមុទ្រ -បង្កើតគណៈកម្មការត្រួតពិនិត្យអន្តរជាតិ ដើម្បីត្រួតពិនិត្យរាល់ទិដ្ឋភាពនៃការអនុវត្តដំណោះស្រាយនយោ

បាយ ។ នៅក្នុងរយៈពេលឆ្លងកាត់ ឬ អន្តរកាល ក្រុមប្រទេសអាស៊ានស្នើឲ្យបង្កើតរដ្ឋាភិបាលផ្សះផ្សាជាតិបណ្តោះអាសន្នមួយ[204] ដែលស្ថិតនៅក្រោមការដឹកនាំរបស់សម្តេច សីហនុ ។ រដ្ឋាភិបាលបណ្តោះអាសន្ននេះ នឹងធ្វើជារដ្ឋបាលបណ្តោះអាសន្នជំនួសឲ្យរដ្ឋបាលរបស់រដ្ឋាភិបាលចម្រុះត្រីភាគីផង និង រដ្ឋបាលនៃរដ្ឋាភិបាល ហ៊ុន សែន នៅភ្នំពេញផង ។ ក្នុងរដ្ឋាភិបាលនេះ សមាសភាពចូលរួមមានចំនួនស្មើគ្នានៃភាគីនីមួយៗក្នុងរដ្ឋាភិបាលត្រីភាគី និង ភាគី ហេង សំរិន/ហ៊ុន សែន ។

តាមសំណើនេះ អាស៊ានបានទទួលយករដ្ឋាភិបាលភ្នំពេញថាជាភាគីមួយស្រេចទៅហើយ ក្នុងការចរចាស្វែងរកសន្តិភាពសម្រាប់កម្ពុជា ។ គួរឲ្យកត់សម្គាល់ដែរថា ក្រុមប្រទេសអាស៊ានមិនបាននិយាយឲ្យចំថារដ្ឋាភិបាលបណ្តោះអាសន្ននេះជារដ្ឋាភិបាលចតុភាគីទេ តែថាជារដ្ឋាភិបាលជាតិបណ្តោះអាសន្ន ។ បានន័យថាបើសិនជាមានការព្រមព្រៀងគ្នារវាងភាគីខ្មែរ រដ្ឋាភិបាលនេះមិនបាច់មានខ្មែរក្រហមក៏បានដែរ ។

នៅពេលដែលក្រុមប្រទេសអាស៊ាន ស្នើឲ្យមានការពង្រឹងឯកភាព សាមគ្គីភាពក្នុងជួររដ្ឋាភិបាលចម្រុះត្រីភាគីនោះ រដ្ឋាភិបាលនេះត្រូវបានទទួលរងនូវការបែកបាក់យ៉ាងខ្លាំង ទាំងដោយសារការដណ្តើមឧត្តមភាពខាងផ្នែកយោធាពីសំណាក់ខ្មែរក្រហមលើដៃគូពីរទៀតរបស់ខ្លួនផង ទាំងការបែកបាក់ផ្ទៃក្នុងនៃរណសិរ្សមិនមែនកុម្មុយនីស្តទាំងពីរផង ។ នៅថ្ងៃទី ៦ កុម្ភៈ ១៩៨៦ លោកអនុរដ្ឋមន្ត្រីក្រសួងការបរទេសថៃ អារុណ ផានុពង្ស[205] ដោយមានលោកឯកអគ្គរាជទូតថៃឈ្មោះ ធាវ៉ាត់ អមផង បានជួបប្រជុំជាមួយតំណាងរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យដែលមានជាអាទិ៍ លោក ខៀវ សំផន លោក សុន សេន (តំណាងខ្មែរក្រហម)

[204] ឯកសារសម្ងាត់ Asean Suggested Modalities for Political Settlement of the Kampuchean Problem, February 3, 1986.

[205] ឯកសារសម្ងាត់ រ.ជ.រ.ប.ខ. Compte-rendu de la Réunion au Ministère des Affaires Étrangères, Bangkok, le 6 Février 1986.

លោក នាង ជិនហាន លោក ប៊ុន សាយ លោក សឺន ស៊ូបែរ្ត (តំណាង រ.ជ.រ.ប.ខ) និង លោក ចក់ សារិ លោក ប៉ែន ដារ៉ែត (តំណាង ហ៊ុន សុិន ប៊ុច) ដើម្បីសុំឲ្យ ភាគីខ្មែរទទួលយកបែបបទដំណោះស្រាយរបស់អាស៊ានមកពិនិត្យ និង ផ្តល់មតិ មុនអាស៊ានលើកឡើងជាស្ថាពរ ។ នៅក្នុងជំនួបនោះ មន្ត្រីការទូតជាន់ខ្ពស់ថៃ ឆាវ៉ាត់ បានសុំឲ្យទាំងរ.ជ.រ.ប.ខ. ទាំងហ៊ុន សុិន ប៊ុច ខិតខំបញ្ចប់ជម្លោះផ្ទៃក្នុងឲ្យ បានឆាប់ ព្រោះជៀសវាងកុំឲ្យមជ្ឈដ្ឋានខាងក្រៅយល់ថា ការតស៊ូរបស់យើងទាំង អស់គ្នាជាការឥតប្រយោជន៍ ។

មែនទែនកាលនោះ ខ្ញុំមិនបានយល់ដឹងឲ្យស៊ីជម្រៅ ពីជម្លោះផ្ទៃក្នុងនៅក្នុង ជួរហ៊ុន សុិន ប៊ុចទេ ខ្ញុំដឹងតែបញ្ហារវាងលោកតា សឺន សាន និង ក្រុមឧត្តមសេនីយ សក់ ស៊ុតសាខន ក្នុងជួរ រ.ជ.រ.ប.ខ.តែប៉ុណ្ណោះ ។ ក៏ប៉ុន្តែ តាមរយៈសារព័ត៌មាន ខ្ញុំអាចកាត់ស្មានថាមានការខ្វែងគំនិតគ្នារវាងព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ព្រះ រាជបុត្ររបស់សម្តេច សីហនុ ដែលជាឧត្តមមេបញ្ជាការ និង លោកឧត្តមសេនីយ ទៀប បែន ដែលជាអគ្គមេបញ្ជាការនៃកងទ័ពសីហនុនិយម (ANS) ។ ពួកយើង ដែលនៅជុំវិញលោកតា សឺន សាន បានគិតថាបញ្ហានៅក្នុង ហ៊ុន សុិន ប៊ុច ក៏មិន ខុសពីទំនាស់ផ្ទៃក្នុងរបស់រ.ជ.រ.ប.ខ.ឡើយ ។ យើងយល់ថា ក្រុមឧត្តមសេនីយថៃ មានផែនការកាត់ផ្តាច់បញ្ជាការរបស់កងទ័ពសីហនុនិយម ឲ្យមកស្ថិតនៅតែក្រោម ឧត្តមសេនីយ ទៀប បែន ដើម្បីឲ្យមេដឹកនាំយោធាថៃអាចប្រើប្រាស់កងទ័ពនេះ បានដោយស្រួល ។ ដោយសារធ្លាប់មានជម្លោះផ្ទៃក្នុងជាមួយលោកឧត្តមសេនីយ សក់ ស៊ុតសាខន ដែលប៉ុនប៉ងកាត់ផ្តាច់កងទ័ពរ.ជ.រ.ប.ខ ឲ្យផុតពីការដឹកនាំរបស់ លោកតាៗប្រធាន សឺន សាន បានផ្ញើសារទូរលេខមួយច្បាប់ចុះថ្ងៃទី ៨ កុម្ភៈ

១៩៨៦[206] ទៅថ្វាយសម្តេច សីហនុ អំពីបទពិសោធន៍មិនល្អនៅក្នុងជួរ រ.ជ.រ.ប.ខ. និង អំពីជំនឿរបស់លោកតាប្រធានថា សម្តេចអាចដោះស្រាយបញ្ហាផ្ទៃក្នុងនៃកងទ័ពសីហនុនិយមនេះបាន ។ ជាមួយនោះ លោកតា សឺន សាន ក៏សូមថ្លែងថ្វាយនូវការដឹងគុណចំពោះព្រះអង្គដែលបានគាំទ្រលោកតាដែរ នៅក្នុងជម្លោះផ្ទៃក្នុងៗជួរ រ.ជ.រ.ប.ខ. ។

នៅថ្ងៃទី ១២ កុម្ភៈ ១៩៨៦ ទំនងជាចង់ឆ្លើយតបទៅក្រុមប្រទេសអាស៊ានថា រដ្ឋាភិបាលចម្រុះត្រីភាគីមានសាមគ្គីភាពល្អរវាងគ្នា និង គ្នា លោក ខៀវ សំផន និង សុន សេន ក្នុងនាមកម្ពុជាប្រជាធិបតេយ្យ បានចេញសេចក្តីថ្លែងការណ៍មួយដើម្បីគាំទ្រសម្តេច សីហនុ និង មួយទៀត ដើម្បីគាំទ្រលោក តា សឺន សាន ដែលកំពុងប្រឈមមុខចំពោះជម្លោះផ្ទៃក្នុង ។ ទាក់ទងនឹងហ៊ុន សុិន ប៊ុច[207] ខ្មែរក្រហមប្រកាសថា នៅពេលបច្ចុប្បន្នពួកគេទទួលស្គាល់សម្តេច នរោត្តម សីហនុ ជាប្រធានកម្ពុជាប្រជាធិបតេយ្យ និង នៅពេលខាងមុខក៏ពួកគេនឹងទទួលស្គាល់សម្តេចជាប្រធាននៃកម្ពុជា ។ ម្យ៉ាងទៀត នៅក្នុងសេចក្តីថ្លែងការណ៍នោះ ខ្មែរក្រហមក៏បានបញ្ជាក់នៅចំពោះមតិជាតិ និង អន្តរជាតិថាកម្ពុជាប្រជាធិបតេយ្យ នឹងខិតខំសម្រេចឲ្យបាននូវមហាសាមគ្គីភាពជាតិ នៅក្នុងក្របខ័ណ្ឌនៃរបបមូលធននិយម និង សភានិយម ដែលផ្ទុយស្រឡះពីរបបប្រល័យពូជសាសន៍ កាលពីពេលពួកនេះកាន់អំណាចពីឆ្នាំ ១៩៧៥ ទៅ ១៩៧៩ ។

ចំពោះការគាំទ្រដល់លោកតា សឺន សាន និង រ.ជ.រ.ប.ខ.វិញ ពួកខ្មែរ

[206] Son Sann, Télégramme à Son Altesse Royale Samdech Preah Norodom Sihanouk, le 8 Février 1986.
[207] Khieu Samphan, Son Sen, Statement By The Democratic Kampuchea Party concerning its Position vis-à-vis the Present and Future Role of Samdech Norodom Sihanouk and The National United Front For an Independent Neutral Peaceful and Cooperative Cambodia (FUNCINPEC), Democratic Kampuchea, February 12, 1986.

ក្រហមតាមរយៈលោក ខៀវ សំផន និង សុន សេន បានថ្លែងយ៉ាងខ្លីថា:[208] "កាគីកម្ពុជាប្រជាធិបតេយ្យ ចាត់ទុករណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ និង ប្រធានរបស់ខ្លួន ជាកម្លាំងនយោបាយរបស់ជាតិមួយ ទាំងបច្ចុប្បន្ន ទាំងអនាគត" ។ បើប្រៀបធៀបការគាំទ្ររបស់ខ្មែរក្រហមចំពោះសម្តេច សីហនុ ការគាំទ្ររបស់ខ្មែរក្រហម ចំពោះលោកតា សឺន សាន មិនបានបញ្ចេញឲ្យបានច្បាស់លាស់ប៉ុន្មានទេ ។ ពួកគេគាំទ្រ រ.ជ.រ.ប.ខ. និង ប្រធានរបស់ខ្លួនគឺ គេមិនបានបញ្ជាក់ថានរណាជាប្រធានរ.ជ.រ.ប.ខ.ទេ នៅពេលដែលលោកឧត្តមសេនីយ សក់ ស៊ុតសាខន កំពុងទាមទារអំណាចដឹកនាំរ.ជ.រ.ប.ខ.ជំនួសលោកតា សឺន សាន ។ ពួកគេអាចគាំទ្រលោក សក់ ស៊ុតសាខន ជាប្រធានក៏បាន លោកតា សឺន សាន ជាប្រធានក៏បាន ។ ទាំងនេះ ក៏ប្រហែលជាពួកខ្មែរក្រហម មិនចង់ឲ្យមានការប៉ះទង្គិចជាមួយក្រុមឧត្តមសេនីយថៃផង ឬ ក៏ចង់បំពេញចិត្តមេទ័ពថៃផងក៏ថាបាន ។ នៅក្នុងសេចក្តីថ្លែងការណ៍របស់ខ្មែរក្រហមនោះ ពួកគេមិនបានចែងគាំទ្រលោកតា សឺន សាន ក្នុងឋានៈជារដ្ឋមន្ត្រីទី១នៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យនោះទេ ឬ សំដែងមតិចំពោះតួនាទីរបស់លោកតា សឺន សាន នាពេលអនាគតឡើយ ។

នៅបន្ទាត់ជាបន្តបន្ទាប់នេះ ខ្ញុំសូមបកមកក្រោយបន្តិចដើម្បីលើកយកបញ្ហាផ្ទៃក្នុង និង ការពាក់ព័ន្ធនយោបាយមកអធិប្បាយ ។ បញ្ហាផ្ទៃក្នុងរបស់រ.ជ.រ.ប.ខ.មានការស្មុគ្រស្មាញជាងបញ្ហានៅក្នុងជួរ ហ៊ុន សុិន ប៊ិច ដោយហេតុថានៅក្នុងជួរហ៊ុន សុិន ប៊ិច គ្មានបុគ្គលណា ឬ ក្រុមណាហ៊ានបំពាន ឬ រំលោភលើការដឹកនាំរបស់សម្តេច សីហនុ ជាដាច់ខាត ។ ផ្ទុយទៅវិញ នៅក្នុងជួររ.ជ.រ.ប.ខ. ក្រុមលោកឧត្តមសេនីយ សក់ ស៊ុតសាខន ហ៊ានចេញមុខប្រឆាំងនឹងការដឹកនាំ

[208] ខៀវ សំផន, សុន សេន, សេចក្តីថ្លែងការណ៍របស់កាគីកម្ពុជាប្រជាធិបតេយ្យចំពោះតួនាទីបច្ចុប្បន្ន និង អនាគតរបស់រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរនិងប្រធានរបស់ខ្លួន, កម្ពុជាប្រជាធិបតេយ្យថ្ងៃទី ១២ កុម្ភៈ ១៩៨៦ ។

របស់លោកតា សឺន សាន រួចទាមទារឲ្យលោកតាដើរតួនាទីត្រឹមតែប្រធានកិត្តិយសតែប៉ុណ្ណោះ ។ ប្រការដែលពិបាកដោះស្រាយនោះគឺ ទោះបីជាលោកតា សឺន សាន បានបញ្ឈប់លោកឧត្តមសេនីយ សក់ ស៊ុតសាខន ពីមុខតំណែងអគ្គមេបញ្ជាការនៃ ក.ជ.រ.ប.ខ.ក៏ដោយ ក៏ក្រុមប្រទេសអាស៊ាន ជាពិសេស ប្រទេសថៃនៅតែទទួលស្គាល់លោកឧត្តមសេនីយ សក់ ស៊ុតសាខន ថាជាមេដឹកនាំកំពូលមួយរូបនៃរ.ជ.រ.ប.ខ.ក្នុងផ្នែកយោធាដដែល ។

នៅថ្ងៃទី ១២ កុម្ភៈ ១៩៨៦ លោកតា សឺន សាន អមដោយលោក ប៊ុន សាយ លោក នាង ជិនហន និង លោក សឺន ស៊ូបែរ្ត បានជួបសន្ទនាការងារជាមួយ លោក អារុណ ផានុពង្ស អនុរដ្ឋមន្ត្រីក្រសួងការបរទេសថៃ ដើម្បីប្តូរយោបល់គ្នាលើសំណើបែបបទដំណោះស្រាយរបស់អាស៊ាន[209] ។ នៅក្នុងជំនួបនោះ ជាដំបូង លោកតា សឺន សាន បានសំដែងមតិថាវៀតណាមមិនចង់ចរចាទេ ដូច្នេះលោកតាយល់ថា មិត្តភក្តិកំពុងស្វែងរកកលយុទ្ធ ដើម្បីបង្ខំវៀតណាមឲ្យមកកាន់តុចរចា ។ បន្ទាប់មក លោកតាឆ្លៀតសុំទាមទារអំណាចយោធា ។ លោកតាប្រធាន រ.ជ.រ.ប.ខ. បានថ្លែងថារយៈពេល ១៨ ខែ ជារយៈពេលខ្លីណាស់ នៅពេលដែលពួកយើងកំពុងខាតពេលវេលាដ៏មានតម្លៃដោយសារវិបត្តិផ្ទៃក្នុង ។ លោកតា សឺន សាន បានជម្រាបដៃគូសន្ទនាថា លោកតាបើកទ្វារចំហរជានិច្ចសម្រាប់ដំណោះស្រាយផ្ទៃក្នុងណាមួយ ដោយបានទាមទារថាក្នុងហានៈជាប្រធានរ.ជ.រ.ប.ខ. លោកតាត្រូវតែមានសិទ្ធិលើកិច្ចការនយោបាយ ការទូត កិច្ចការស៊ីវិល និង ហិរញ្ញវត្ថុ ។ ម្យ៉ាងទៀតចាប់តាំងពីថ្ងៃ ១ កុម្ភៈ ១៩៨៦ រហូតមក លោកតាបានចេញសេចក្តីសម្រេចថា គណៈកម្មាធិការបណ្តោះអាសន្នដែលហៅថា កឺស៊ីស៊ីអេស របស់លោកឧត្តមសេនីយ សក់ ស៊ុតសាខន ជាអង្គការចាត់តាំងខុសច្បាប់ ។ ឆ្លើយតបទៅលោកតា សឺន សាន

[209] ឯកសារសម្ងាត់ រ.ជ.រ.ប.ខ. Meeting at the Thai Ministry of Foreign Affairs, Bangkok, February 12, 1986.

អ្នកការទូតជាន់ខ្ពស់ថៃគ្រាន់តែឆ្លើយថា ពួកគេជាមិត្តតែគេមិនអាចជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់មិត្តទេ ។ រាល់ជំនួបនៅពេលក្រោយៗទៀតជាមួយប្រទេសផ្តល់ជំនួយ លោកតា សឺន សាន តែងយកវេទិកានៃជំនួបនោះ ដើម្បីសុំឲ្យគេជួយផ្តល់អំណាចបញ្ជាលើកងកម្លាំងយោធារបស់ រ.ជ.រ.ប.ខ. មកឲ្យលោកតាវិញ មិនដែលខានឡើយ ។

នៅថ្ងៃទី ១៧ កុម្ភៈ ១៩៨៦ ក្រុមប្រទេសអាស៊ានបានជួបជាមួយតំណាងរដ្ឋាភិបាលចម្រុះត្រីភាគីម្តងទៀត ដើម្បីចង់បានប្រតិកម្មអំពីសំណើបែបបទដំណោះស្រាយកម្ពុជា[210] ។ ខាងកម្ពុជាប្រជាធិបតេយ្យមានលោក ខៀវ សំផន លោក សុន សេន ខាង ហ៊ុន ស៊ិន ប៊ិច មានព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ចំណែកឯខាង រ.ជ.រ.ប.ខ. មានលោក នាង ជិនហន លោក ប៊ុន សាយ និង លោក សឺន ស៊ូបែរ្ត ជាតំណាងចូលរួម គ្មានខាងលោក សក់ ស៊ុតសាខន ឬ តំណាងចូលរួមទេ ។ ឆ្លើយតបទៅសំណួររបស់អាស៊ាន លោក ខៀវ សំផន ឆ្លើយថាពុំទាន់អាចមានចម្លើយជាស្ថាពរទេ ដោយហេតុអវត្តមានរបស់សម្តេច សីហនុ និង លោករដ្ឋមន្ត្រីទី១ សឺន សាន ។ ក៏ប៉ុន្តែជាជំហររបស់កម្ពុជាប្រជាធិបតេយ្យ រាល់ការចរចាណាមួយ ត្រូវធ្វើឡើងរវាងអ្នកឈ្លានពាន គឺវៀតណាមផ្ទាល់ជាមួយអ្នករងគ្រោះ គឺកម្ពុជាប្រជាធិបតេយ្យ ។ ខ្មែរក្រហមចង់និយាយផ្ទាល់ជាមួយវៀតណាម ។ គេយល់ថាវិធីគាបសង្កត់វៀតណាមឲ្យចូលមកចរចា ត្រូវធ្វើតាមរយៈ ការបង្កើនសកម្មភាពយោធា ដោយសហការយ៉ាងជិតស្និទ្ធជាមួយដៃគូពីរទៀតនៅក្នុងរដ្ឋាភិបាលចម្រុះត្រីភាគី ។ ចំណែកឯខាង រ.ជ.រ.ប.ខ.វិញ បានប្រកាសចូលរួមជាមួយអាស៊ានក្នុង

[210] Khmer People's National Liberation Front, Compte-rendu de la Réunion entre les parties du CGDK et les "Senior Officials" des Pays de l'ASEAN, Hotel Ambassador, Bangkok, le 17 Février 1986.

ការស្វែងរកដំណោះស្រាយបញ្ចប់សង្គ្រាម តាមរយៈការចរចាក្នុងសន្និសីទអន្តរជាតិ ក្នុងក្របខ័ណ្ឌនៃសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ និង តាមសេចក្តីថ្លែងការណ៍របស់សន្និសីទអន្តរជាតិស្តីពីកម្ពុជា កាលពីខែ កក្កដា ១៩៨១ ។ ក៏ប៉ុន្តែ រ.ជ.រ.ប.ខ. ប្រកាន់ថា រាល់ការចរចាត្រូវជៀសវាងកុំឲ្យមានការ ទទួលស្គាល់របស់ដែលបានបង្កើតឡើង ដោយការឈ្លានពានរបស់វៀតណាម ។ និយាយរួមគោលជំហរទាំងខ្មែរក្រហម ទាំងរ.ជ.រ.ប.ខ. មិនមានការកែប្រែអ្វីឡើយ ។

នៅថ្ងៃទី ១៨ កុម្ភៈ ១៩៨៦ ក្រុមប្រទេសអាស៊ាន បានជួបជាមួយតំណាង ក្រុមចលនាតស៊ូមិនមែនកុម្មុយនីស្ត រ.ជ.រ.ប.ខ. និង ហ៊ុន សុិន ប៊ុច[211] ។ នៅក្នុង ជំនួបជាមួយក្រុមប្រទេសអាស៊ាននាពេលនោះ ទោះបីជាលោកឧត្តមសេនីយ សក់ ស៊ុតសាខន ត្រូវបានលោកតា សឺន សាន បញ្ឈប់ពីតំណែងអគ្គមេបញ្ជាការក.ជ.រ .ប.ខ.ទៅហើយយ៉ាងណាក៏ដោយ លោកឧត្តមសេនីយរូបនេះក៏ត្រូវបានអញ្ជើញឲ្យ ចូលរួមប្រជុំ និង ដើរតួនាទីជាមេដឹកនាំយោធានៃចលនាមិនមែនកុម្មុយនីស្ត រួមជា មួយព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ។ ទាំងលោកឧត្តមសេនីយ សក់ ស៊ុតសាខន ទាំងព្រះអង្គម្ចាស់ រណឫទ្ធិ សុទ្ធតែបានថ្លែងពីការរីកចំរើនរបស់កងទ័ពនីមួយៗនៅ ក្នុងផ្ទៃប្រទេស ។ លោកឧត្តមសេនីយ សក់ ស៊ុតសាខន បាននិយាយពីកិច្ចសហ ការគ្នាល្អ នៅលើសមរភូមិរវាងកងទ័ពទាំងបីនៃរដ្ឋាភិបាលចម្រុះ ចំណែកឯព្រះអង្គ ម្ចាស់ រណឫទ្ធិ មានបន្ទូលពីការជួយទំនុកបំរុង និង សហការមួយចំនួនពីកងទ័ព រដ្ឋាភិបាលភ្នំពេញ ចំពោះកងទ័ពសីហនុនិយម ។ នៅពេលនោះ អ្នកតំណាងអា ស៊ានបានណែនាំឲ្យបង្កើនការឃោសនា និង សង្កត់ធ្ងន់លើផែនការនយោបាយ និង ការទូត ។ តាមរយៈជំនួបនេះ ក្រុមអាស៊ានបានបង្ហាញឲ្យឃើញយ៉ាងច្បាស់នូវការ

[211] ឯកសារ រ.ជ.រ.ប.ខ. Compte-rendu de la réunion entre les parties nationales du CGDK et les pays de l'Asean sur la question militaire, le 18 Février 1986.

គាំទ្រចំពោះលោកឧត្តមសេនីយ សក់ ស៊ុតសាខន ទោះជាមានការមិនពេញចិត្តពីលោកតា សឺន សាន យ៉ាងណាក៏ដោយ ។

ផែនការសន្តិភាព ៨ ចំណុចរបស់ត្រីភាគី

ចាប់តាំងពីថ្ងៃទី ១៥ ដល់ ២១ មីនា ១៩៨៦ លោកតា សឺន សាន បានធ្វើដំណើរជាមួយលោក ខៀវ សំផន ពីទីក្រុងបាងកកទៅទីក្រុងប៉េកាំង ដើម្បីទៅគាល់សម្តេច សីហនុ ដើម្បីផ្លាស់ប្តូរមតិគ្នា ក្នុងការលើកឡើងនូវសំណើដំណោះស្រាយនយោបាយរបស់រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ។ នៅថ្ងៃទី ១៧ មីនា ១៩៨៦ នៅទីក្រុងប៉េកាំង អ្នកដឹកនាំរដ្ឋាភិបាលចម្រុះត្រីភាគី បានព្រមព្រៀងគ្នាស្នើចេញផែនការសន្តិភាព ៨ ចំណុច[212] ដែលយោងទៅតាមសេចក្តីសម្រេចរបស់មហាសន្និបាតនៃអង្គការសហប្រជាជាតិ និង តាមសេចក្តីថ្លែងការណ៍របស់សន្និសីទអន្តរជាតិស្តីពីកម្ពុជា ឆ្នាំ ១៩៨១ ។ ចំណុចដែលគួរកត់សម្គាល់នោះគឺ រដ្ឋាភិបាលចម្រុះត្រីភាគីមិនទាមទារឲ្យកងទ័ពវៀតណាមដកចេញទាំងអស់ ដូចពេលមុនៗទេ ។ ម្តងនេះមេដឹកនាំត្រីភាគី សុំឲ្យរដ្ឋាភិបាលក្រុងហាណូយធ្វើការចរចាផ្ទាល់ជាមួយរដ្ឋាភិបាលត្រីភាគី ដើម្បីពិភាក្សាអំពីដំណើរការនៃការដកកងទ័ពវៀតណាមជាពីរតំណាក់កាល ។ ក្រោយពីមានការព្រមព្រៀងស្តីពីការដកកងទ័ពចេញមក នឹងមានការឈប់បាញ់គ្នា ដើម្បីឲ្យវៀតណាមដកកងទ័ពតាមការព្រមព្រៀងនោះ ។ ការដកកងទ័ព និង ការឈប់បាញ់គ្នានេះ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យផ្ទាល់របស់អ្នកសង្កេតការណ៍នៃអង្គការសហប្រជាជាតិ ។ ចំណុចសំខាន់ថ្មីមួយទៀតនោះគឺ រដ្ឋាភិបាលត្រីភាគីសុខចិត្តចរចាជាមួយរដ្ឋាភិបាលក្រុងភ្នំពេញ

[212] Khieu Samphan, Samdech Norodom Sihanouk, Son Sann, Coalition Government of Democratic Kampuchea's Proposal for A Political Settlement to the Problem of Kampuchea, Beijing, March 17, 1986.

របស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលពីមុនមកគេតែងតែប្រកែកមិនព្រមចរចាជាមួយ ។ ក៏ប៉ុន្តែការចរចានេះ ត្រូវធ្វើឡើងបន្ទាប់ពីរៀតណាមដកកងទ័ពនៅតំណាក់កាលទី១ ដើម្បីរៀបបង្កើតរដ្ឋាភិបាលចម្រុះចតុភាគីរបស់ប្រទេសកម្ពុជា ដោយមានសម្តេច សីហនុ ជាប្រធាន និង លោកតា សឺន សាន ជារដ្ឋមន្ត្រីទី១ ។ រដ្ឋាភិបាលចម្រុះចតុភាគីនេះ នឹងធ្វើការបោះឆ្នោតក្រោមការត្រួតពិនិត្យរបស់ក្រុមអ្នកសង្កេតការណ៍របស់អង្គការសហប្រជាជាតិ ។ នៅក្នុងផែនការបង្កើតរដ្ឋាភិបាលមានគ្រោងតំណែងប្រធានផង និង រដ្ឋមន្ត្រីទី១ផង (ដោយសារមានប្រធានផងតួនាទីរដ្ឋមន្ត្រីទី១ មិនអាចជានាយករដ្ឋមន្ត្រីពេញសិទ្ធិដូចធម្មតាទេ) ។ ចំណុចដែលគួរឲ្យចាប់អារម្មណ៍នោះគឺ រដ្ឋាភិបាលចតុភាគីចាំបាច់ត្រូវតែមានភាគីខ្មែរក្រហម ដែលនៅក្នុងសំណើបែបបទរបស់អាស៊ានមិនបាននិយាយឲ្យចំទេ ។ ម្យ៉ាងទៀតនៅក្នុងសំណើរបស់អាស៊ាននោះ ក៏មិនបាននិយាយពីតួនាទីរបស់លោកតា សឺន សាន នៅពេលអនាគត ដែលគេគ្រាន់តែលើកថារដ្ឋាភិបាលជាតិបណ្តោះអាសន្នស្ថិតនៅក្រោមការដឹកនាំរបស់សម្តេច សីហនុ ។ សំណើសន្តិភាព ៨ ចំណុចដែលចេញនៅទីក្រុងប៉េកាំងនេះ មានបំណងបញ្ជាក់បន្ថែមអំពីការគាំទ្ររបស់ដៃគូនៅក្នុងរដ្ឋាភិបាលចម្រុះ ចំពោះតួនាទីដឹកនាំអនាគតរបស់លោកតា សឺន សាន ដែលកំពុងទទួលការខូចខាត ដោយសារការប្រឆាំងពីក្រុមឧត្តមសេនីយ សក់ ស៊ុត សាខន ។ ដូច្នេះសំណើផែនការសន្តិភាព ៨ ចំណុចរបស់រដ្ឋាភិបាលចម្រុះត្រីភាគីនេះបានបង្ហាញនូវឯកភាពរបស់ខ្លួនចំពោះមុខពិភពលោក ។

រំលឹកឡើងវិញបន្តិចអំពី ចិន និង វិបត្តិផ្ទៃក្នុង រ.ជ.រ.ប.ខ.

នៅទីក្រុងប៉េកាំង មេដឹកនាំរដ្ឋាភិបាលចម្រុះទាំងបីរូបគឺ សម្តេច សីហនុ លោកតា សឺន សាន និង លោក ខៀវ សំផន បាននាំសំណើសន្តិភាព ៨

ចំណុចនេះ ទៅដូនថ្នាក់ដឹកនាំជាន់ខ្ពស់ចិន ។ នៅក្នុងជំនួបជាមួយលោក ហ៊ូ យ៉ៅបាង (Hu Yaobang)[213] អគ្គលេខានៃគណបក្សកុម្មុយនីស្តចិន លោកអគ្គលេខាចិនរូបនេះ បានលើកសរសើរសម្តេច សីហនុ និង ដៃគូរបស់ព្រះអង្គ ដែលបានរួបរួមគ្នាសហការគ្នាយ៉ាងល្អ រហូតដល់សម្រេចចេញបាននូវសំណើសន្តិភាព ៨ ចំណុច ដែលជាសំណើប្រវត្តិសាស្ត្រអាចនាំទៅដោះស្រាយជម្លោះកម្ពុជាតាមផ្លូវនយោបាយផង និង អាចជួយឲ្យមានប្រក្រតីភាពឡើងវិញនៃស្ថានភាពនៅតំបន់អាស៊ីភាគអគ្នេយ៍នេះផង ។ ក៏ប៉ុន្តែ លោកអគ្គលេខាបានបន្ថែមថា លក្ខខណ្ឌសម្រាប់ដំណោះស្រាយនៅមិនទាន់គ្រប់គ្រាន់ទេ ព្រោះបញ្ហាកម្ពុជាជាបញ្ហាអន្តរជាតិ ។ ដល់វេនលោកតា សឺន សាន មានមតិ លោកតាមិនបានលើកយកបញ្ហាសំណើសន្តិភាព ៨ ចំណុចមកធ្វើជាប្រធានបទសំខាន់នោះទេ តែលើកយកបញ្ហាផ្ទៃក្នុងរ.ជ.រ.ប.ខ. មកលាតត្រដាងទៅវិញ ។ លោកតាថ្លែងជាអាទិថាចាប់តាំងពីខែធ្នូ ឆ្នាំមុន បន្ទាប់ពីទស្សនកិច្ចប្រកបដោយជោគជ័យនៅប្រទេសចិនជាមិត្ត លោកតាប្រធានបានជួបប្រទះនូវបញ្ហាជម្លោះផ្ទៃក្នុងៗជួររ.ជ.រ.ប.ខ. ដែលធ្វើឲ្យខាតពេលវេលា និង អស់ថាមពលជាច្រើន ។

លោក ហ៊ូ យ៉ៅបាង បានឆ្លើយតបចំពោះរឿងរ៉ាវផ្ទៃក្នុងនេះថាៈបញ្ហាផ្ទៃក្នុងជាបញ្ហាដែលពិបាកនិយាយ ឬ ដែលពិបាកធ្វើអត្ថាធិប្បាយជាទីបំផុត ។ ក៏ប៉ុន្តែអ្វីដែលសំខាន់ ដែលប្រទេសចិនអាចលើកឡើងនៅពេលនេះគឺៈ ទី១ -ចិនទទួលស្គាល់ឯកឧត្តម សឺន សាន ជាអ្នកស្នេហាជាតិ និង ជាអ្នកតស៊ូស្រឡាញ់ជាតិ ទី២ -ចិនសម្គាល់ ឯកឧត្តម សឺន សាន ជាមិត្តចាស់ និង ជាមិត្តល្អម្នាក់របស់ប្រទេសចិន ។ ចំណុចពីរនេះ ចិនមិនដែលផ្លាស់ប្តូរឡើយ ។ សម្តេច សីហនុ ក៏បញ្ជាក់ជូនមេដឹកនាំចិនថែមទៀតថា គ្មានបញ្ហាអ្វីធំដុំក្នុងជួររដ្ឋាភិបាលចម្រុះទេ មានតែបញ្ហា

[213] Notes Recueillies (Confidentielles) sur l'entretien politique entre S.E Hu Yaobang, Secrétaire Général du PCC et le Gouvernement de Coalition du Kampuchea Démocratique, Beijing, le 18 Mars 1986.

តូចតាចតែប៉ុណ្ណោះ ។ ព្រះអង្គធានាមិនឲ្យមេដឹកនាំចិនព្រួយបារម្ភអ្វីចំពោះឯកភាព និង សាមគ្គីភាពរបស់ភាគីទាំងអស់នៅក្នុងរដ្ឋាភិបាលចម្រុះខ្មែរត្រីភាគីនេះឡើយ ។

ព្រឹកស្អែកឡើង លោកតា សឺន សាន និង គណៈប្រតិភូរ.ជ.រ.ប.ខ.បានជួបជាមួយលោកអនុរដ្ឋមន្ត្រីក្រសួងការបរទេស លីវ ស៊ូគីង (Liu Shuquing) ។ នៅក្នុងជំនួបនោះ លោកតាប្រធានបានចេញតវ៉ាត្រង់ៗថា ពួកយោធាថៃកំពុងយកបញ្ហាផ្ទៃក្នុង រ.ជ.រ.ប.ខ. មកធ្វើជាលេសដើម្បីត្រួតត្រាផ្ទាល់លើកងទ័ព រ.ជ.រ.ប.ខ[214] ។ លោកតា សឺន សាន ជំរាបលោកអនុរដ្ឋមន្ត្រីចិនថាដោយសំអាងថាទម្រាំរកដំណោះស្រាយទំនាស់ផ្ទៃក្នុងបាន ក្រុមយោធាថៃបានកោះប្រជុំមេបញ្ជាការ រ.ជ.រ.ប.ខ.ចំនួន ១០ នាក់ ណែនាំអ្នកទាំង ១០ នាក់នោះឲ្យបង្កើតជាគណៈកម្មការយោធាមួយហៅថា "គណៈកម្មការមេបញ្ជាការ ១០ នាក់" (The 10 Commander-Committee" ដើម្បីដឹកនាំបញ្ជាក.ជ.រ.ប.ខក្រោមការត្រួតពិនិត្យរបស់នាយទាហានថៃម្នាក់ឈ្មោះលោកសក្តិប្រាំ វិស្ណុ ឬ វិស្ណូ[215] (Colonel Vishu) ។ លោកតាប្រធាន រ.ជ.រ.ប.ខ មានការព្រួយបារម្ភខ្លាចថា ការធ្វើរបៀបនេះអាចឲ្យយោធាថៃប្រើកងទ័ពរ.ជ.រ.ប.ខ ទៅបំពេញបេសកកម្មដទៃផ្សេង មិនត្រូវតាមគោលបំណងរបស់រដ្ឋាភិបាលចម្រុះត្រីភាគី ឬ ផ្ទុយពីស្មារតីនៃសេចក្តីថ្លែងការណ៍គូឡាឡាំពួ ។ លោកតាបន្ថែមទៀតថា មិនតែប៉ុណ្ណោះយោធាថៃឈប់បើកប្រាក់ជំនួយចិនផ្តល់ដល់ភាគីរបស់លោកតាទៀតផង ។ ជាចម្លើយតបវិញ លោកអនុរដ្ឋមន្ត្រីក្រសួងការបរទេសចិន បានសុំឲ្យលោកតា សឺន សាន ប្រញាប់ដោះស្រាយទំនាស់ផ្ទៃក្នុងឲ្យបានឆាប់រហ័ស ដោយសុំឲ្យធ្វើតាមមតិណែនាំរបស់លោក

[214] Notes d'entretien politique entre S.E. Son Sann, Premier Ministre du CGKD et S.E. Liu Shuqin, Vice Ministre A.E. de la RPC, Beijing, le 19 Mars 1986.

[215] ខ្មែរយើងខ្លះហៅ វិស្ណុ ខ្លះហៅ វិស្ណូ ។ ឈ្មោះនេះជាឈ្មោះសម្ងាត់ទេ ឈ្មោះពិតប្រាកដ គឺ ស៊ូរ៉ាយុទ្ធ ជូឡានន្ត (Surayuth Chulanond) ។ នៅឆ្នាំ ២០០៦ លោក ស៊ូរ៉ាយុទ្ធ ជូឡានន្ត បានឡើងកាន់តំណែងជានាយករដ្ឋមន្ត្រីនៃប្រទេសថៃ បន្ទាប់ពីមានរដ្ឋប្រហារយោធាទំលាក់លោក តាក់ស៊ិន ពីអំណាច ។

ឧត្តមសេនីយ ឆាវលិត ដែលបានបែងចែកការទទួលខុសត្រូវរួចស្រេចហើយគឺ លោកតា សឺន សាន ក្នុងឋានៈជានាយករដ្ឋមន្ត្រីទទួលខុសត្រូវខាងការទូត និង នយោបាយ ឯលោកឧត្តមសេនីយ សក់ ស៊ុតសាខន ទទួលខុសត្រូវជាមេបញ្ជាការ កងទ័ព ។ តាមពិតទៅ ទាំងលោកតា សឺន សាន ទាំងលោកឧត្តមសេនីយ សក់ ស៊ុតសាខន សុទ្ធតែអះអាងថាទទួលយកតាមមតិណែនាំរបស់លោក ឆាវលិត ទាំងអស់គ្នា ។ ក៏ប៉ុន្តែអ្វីដែលមិនទាន់ចុះសម្រុងគ្នានោះគឺការគ្រប់គ្រងថវិការបស់ កងទ័ព និង ការត្រួតត្រាជំរុំជនភៀសខ្លួន ។ លោកតា សឺន សាន ក្នុងឋានៈជា ប្រធានចលនាយល់ថា លោកតាត្រូវតែមានការទទួលខុសត្រូវលើការចាយវាយទាំង អស់រាប់ទាំងចំណាយយោធាផង ។ ម្យ៉ាងទៀត លោកតាប្រធាន ក៏ត្រូវការអំណាច "ត្រួតត្រា" ជំរុំភៀសខ្លួនផង ព្រោះនៅទីនោះហើយ ដែលជាប្រភពនៃការគាំ ទ្រនយោបាយសម្រាប់ការដឹកនាំរបស់លោកតា ។ ដោយមានការគាំទ្រពីជនភៀស ខ្លួននៅតាមជំរុំនេះហើយដែលលោកតា សឺន សាន អាចមានប្រសាសន៍ថាលោកតា បានទទួលការគាំទ្រពី "ប្រជារាស្ត្រខ្មែរ" ។ មែនទែនទៅ អំណាចត្រួតត្រាជំរុំនោះ មានន័យត្រឹមតែអាចទទួលការគាំទ្រខាងផ្នែកនយោបាយតែប៉ុណ្ណោះ ព្រោះថាការ គ្រប់គ្រងផ្ទាល់លើជំរុំស្ថិតនៅក្នុងដៃអាជ្ញាធរថៃ និង អង្គការសហប្រជាជាតិឯនោះ ទេ ។ ចំណែកឯលោកឧត្តមសេនីយ សក់ ស៊ុតសាខន ក៏ត្រូវការអំណាច "ត្រួតត្រា" ជំរុំជនភៀសខ្លួនដែរ ព្រោះនៅទីនោះហើយដែល លោកឧត្តមសេនីយអាចជ្រើស រើសយុទ្ធជនឲ្យចូលបំរើកងទ័ព ។ លើសពីនោះទៅទៀត ប្រធានជំរុំនីមួយៗអាច មានលទ្ធភាព ឆ្លៀតដកហូតយកជំនួយជាម្ហូបអាហារ ឬ សម្ភារៈខ្លះដែលនៅសល់ ពីការចែកចាយដល់ជនភៀសខ្លួន យកទៅបំរើសកម្មភាពនយោបាយ ឬ យោធា តាមនិន្នាការរបស់គេម្នាក់ៗ ទោះជាពួកគេស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរ ថៃ និង អង្គការសហប្រជាជាតិក៏ដោយ ។

នៅសម័យនោះ ប្រទេសចិនផ្តល់ជំនួយបីប្រភេទដល់រ.ជ.រ.ប.ខ. ក្រៅពីជំនួយផ្នែកការទូតដល់រដ្ឋាភិបាលចម្រុះទាំងមូល ។ ជំនួយទាំងនោះមាន៖ -ជំនួយយោធាគឺ អាវុធ គ្រាប់រំសេវ និង សម្ភារៈយោធា -ជំនួយសម្ភារៈ និង ជំនួយការទូត ។ ជំនួយយោធា ត្រូវបានប្រគល់ទៅយោធាថៃសិន រួចទើបយោធាថៃប្រគល់មកឲ្យ រ.ជ.រ.ប.ខ. តាមសេចក្តីសុំរបស់ភាគីនេះ ។ ជំនួយសម្ភារៈមានជាអាទិ៍ ម្ហូបកំប៉ុង ចបជីក ចបកាប់ ប្រដាប់ប្រដារការិយាល័យ និង សំលៀកបំពាក់ជាដើម ។ ជំនួយនេះ ត្រូវផ្តល់ដល់ភាគីរ.ជ.រ.ប.ខ. ដោយមានការអនុញ្ញាតពីយោធាថៃ ។ ចំណែកជំនួយការទូតគឺ ជាថវិកាសម្ងាត់ ដែលស្ថានទូតចិនបើកផ្តាល់ជូនលោកតា សឺន សាន សម្រាប់បំពេញបេសកកម្មការទូត ។ ថវិកាសម្ងាត់នេះ ចិនហាមមិនឲ្យប្រាប់អ្នកណាក្រៅពីមន្ត្រីស្ថានទូតចិននៅបាងកកទេគឺ ចិនមិនបានឲ្យថៃដឹងពីជំនួយនេះឡើយ ។ នៅឆ្នាំ ១៩៨៥-៨៦ ជំនួយសម្ភារៈចិនដល់រ.ជ.រ.ប.ខ.មានតម្លៃមួយលានយន់ ។ នៅក្នុងជំនួបជាមួយលោកអនុរដ្ឋមន្ត្រី លីវ ស៊ូគីង លោកតា សឺន សាន ស្នើសុំចិនយកជំនួយសម្ភារៈមួយលានយន់នោះមកជាថវិកា ដើម្បីជួយផ្គត់ផ្គង់ទ័ពពិសេសថ្មីមួយ ដែលលោកតាមានបំណងចង់បង្កើត និង ចង់ដាក់ឲ្យនៅក្រោមបញ្ជាលោកឧត្តមសេនីយ ថាច់ រ៉ែង ។ ក៏ប៉ុន្តែភាគីចិនមិនយល់ព្រមតាមសំណើនេះ ទំនងជាចិនមិនចង់មានបញ្ហាវែងឆ្ងាយជាមួយក្រុមយោធាថៃ ដែលបានសម្រេចមិនឲ្យលោកតា សឺន សាន រវើរវល់ក្នុងកិច្ចការយោធា ។ ដូច្នេះគំរោងបង្កើតកងទ័ពពិសេសសំរាប់លោក ថាច់ រ៉ែង ក៏ត្រូវធ្លាក់ទឹកមិនបានសម្រេចតាមបំណងលោកតាឡើយ ។ ចំណែកឯថវិកាសម្ងាត់សំរាប់ការងារទូត មានចំនួនជាសាច់ប្រាក់សុទ្ធ ២០០ ០០០ ដុល្លារក្នុងមួយឆ្នាំ ។ បើលោកតាត្រូវការពេលណា លោកតាអាចចាត់មន្ត្រីឲ្យទៅបើកផ្តាល់ពីស្ថានទូតចិននៅបាងកក បានគ្រប់ពេលវេលា ។

ជំនួយជាចំហររបស់អាមេរិកលើកដំបូង

ទំនាស់ផ្ទៃក្នុងរវាងលោកតា សឺន សាន និង ក្រុមឧត្តមសេនីយ សក់ ស៊ុតសាខន កើតឡើងនៅចំពេល ដែលសហរដ្ឋអាមេរិកកំពុងរៀបចំជួយផ្តល់ជំនួយជាចំហរលើកដំបូងដល់ចលនាមិនមែនកុម្មុយនីស្ត ចំនួនប្រហែលប្រាំលានដុល្លារ ស.រ.អា ក្នុងមួយឆ្នាំ ។ ជំនួយនោះ ជាជំនួយយោធាដែលមិនសម្លាប់មនុស្ស (Non-Lethal) បានន័យថាជំនួយយោធាដែលគ្មានអាវុធយុទ្ធភ័ណ្ឌ ឬ គ្រាប់រំសេវសម្រាប់សម្លាប់មនុស្ស ។ តាមពិតទៅ ទោះជាស.រ.អា នៅមិនទាន់អស់សុបិន្តអាក្រក់អំពីបរាជ័យរបស់ខ្លួននៅវៀតណាមនាទសវត្សរ៍ឆ្នាំ ១៩៧០ យ៉ាងណាក៏ដោយ ក៏ ស.រ.អា លបចេញយុទ្ធសាស្ត្រមួយ ដើម្បីជួយដំរុញចលនាមិនមែនកុម្មុយនីស្តឲ្យមានមុខជាចលនាគួរឲ្យទុកចិត្តបាន ដែលអាចឲ្យប្រជារាស្ត្រខ្មែរជ្រើសយកបានជាជំនួសក្រុមកុម្មុយនីស្ត ។ គំនិតសំខាន់គឺ ការបង្រួបបង្រួមចលនារបស់សម្តេចសីហនុ និង ចលនារបស់លោកតា សឺន សាន ឲ្យចូលគ្នាជាកងទ័ពអ្នកជាតិនិយមតែមួយ ក្រោមបញ្ជាការរួមតែមួយ ដែលមិនចំណុះខ្មែរក្រហម ។ ក្រុមលោកឧត្តមសេនីយ សក់ ស៊ុតសាខន ដែលហ៊ានចេញមុខប្រឆាំងលោកតា សឺន សាន ប្រហែលជាអាចយល់ជាមុននូវទំនោរនយោបាយរបស់ស.រ.អានេះ ។

បញ្ជាការរួមនៃកងទ័ពមិនមែនកុម្មុយនីស្តទាំងពីរ អាចជានិមិត្តរូបនៃការកកើតនូវកម្លាំងមួយថ្មី ដែលគ្មានទំនាក់ទំនងអ្វីជាមួយខ្មែរក្រហមឡើយ ។ អាជ្ញាធរយោធាថៃស្ថិតនៅពីក្រោយយ៉ាងរឹងមាំនៃបញ្ជាការរួមនេះ ។ ពួកឧត្តមសេនីយថៃទាំងនោះ គាំទ្រលោកឧត្តមសេនីយ សក់ ស៊ុតសាខន ជាអគ្គមេបញ្ជាការនៃកងកម្លាំងច្របាច់បញ្ចូលគ្នានេះ ដែលជួយផ្តល់ទម្ងន់ដល់លោកឧត្តមសេនីយខ្មែររូបនេះ ក្នុងការដណ្តើមអំណាចដឹកនាំពីលោកតា សឺន សាន ។ នៅពេលនោះ លោក

ឧត្តមសេនីយ សក់ ស៊ុតសាខន អះអាងថាពួកគាត់ជាអ្នកជំរុញឲ្យមានទំនាក់ទំនងជិតស្និទ្ធគ្នារវាងរ.ជ.រ.ប.ខ. និង ហ៊ុន សុន បុិច ផ្ទុយពីលោកតា សឺន សាន ដែលត្រូវបានចោទប្រកាន់ថា ជាអ្នកបង្កឧបសគ្គដល់កិច្ចសហប្រតិបត្តិការគ្នារវាងចលនាទាំងពីរនេះ ។ ក៏ប៉ុន្តែប្រសិនបើគេទុកថ្វាយសម្តេច សីហនុ ធ្វើការជ្រើសរើស តើលោក តា សឺន សាន ឬ លោកឧត្តមសេនីយ សក់ ស៊ុតសាខន ដើម្បីព្រះអង្គសហការជាមួយនោះ សម្តេចប្រាកដជាជ្រើសរើសយកលោកតា សឺន សាន មិនខានឡើយ ។ តាមគេហទំព័ររបស់ព្រះអង្គ ដែលគេប្រទះឃើញជាច្រើនឆ្នាំក្រោយមក សម្តេច សីហនុ[216] ទ្រង់មានព្រះសំណេរផ្ញើលព្រះហស្តព្រះអង្គស្តីពីទំនាស់ផ្ទៃក្នុងរ.ជ.រ.ប.ខ.នាសម័យនោះ មានន័យជាអាទិថាទំនាស់ផ្ទៃក្នុងរវាងក្រុម សឺន សាន ជាមួយក្រុម ជៀន ដែល-ហ្គាហ្វា ពាងម៉ែត - សក់ ស៊ុតសាខន តាមការពិតមិនមែនកើតឡើងដោយសារមានអ្នកគាំទ្រ ឬ មានអ្នកប្រឆាំងចំពោះកិច្ចសហការជាមួយភាគី សីហនុ នោះទេ ។ ក្រុមហ្គាហ្វា ពាងម៉ែត តាំងខ្លួនជាអ្នកចង់ឲ្យមានសហការជិតស្និទ្ធពិតប្រាកដរវាងរ.ជ.រ.ប.ខ. និង ហ៊ុន សុន បុិច ចំណែកឯក្រុម សឺន សាន ជាអ្នកប្រឆាំង ។ តាមពិត ក្រុម ហ្គាហ្វា ពាងម៉ែត ជៀន ដែល ហ៊ឹង គន្ធុន ជាក្រុមប្រឆាំង សីហនុ ខ្លាំងជាងក្រុម សឺន សាន ទៅទៀត ។ ក៏ប៉ុន្តែគេយកលេសនេះ ព្រោះវាស្រួល និង ផ្តល់ផលចំណេញដល់ក្រុមហ្គាហ្វា ព្រោះអ្នកគាំទ្ររបស់ពួកគេ ទាំងស.រ.អា ទាំងអាស៊ាន ជាពិសេស គេចង់ឲ្យមានកិច្ចសហការល្អរវាងភាគីមិនមែនកុម្មុយនីស្តទាំងពីរ ។

[216] Norodom Shanouk, Ce “rift” entre le clan de Son Sann et celui de Dien Del-Gaffar Peangmeth-Sak Sutsakhan...., a handwritten note (undated) www.norodomsihanouk.info

ខ្ញុំប្រាប់មន្ត្រីអាមេរិកថា "បើមិនជួយ ក៏យើងនៅតែតស៊ូ"

តាមព្រះសំណេររបស់ព្រះអង្គនេះ សម្តេច សីហនុ ក៏ទ្រង់យល់ថាមេក្លោងមួយនៃការបះបោរប្រឆាំងលោកតា សឺន សាន គឺ លោក ហ្គាហ្វា ៣ងម៉េត ដូចខ្ញុំធ្លាប់សសេរនៅវគ្គមុនៗរួចហើយ ។ សម្តេច សីហនុ ក៏ទ្រង់យល់ដែរថាក្រុមប្រឆាំងទាំងនោះ សុទ្ធតែជាមនុស្សនៃរបបសាធារណរដ្ឋដែលបានទម្លាក់ព្រះអង្គពីអំណាចកាលពីឆ្នាំ ១៩៧០ ។ ចំណែកឯក្រុមយោធាថៃ ក៏មានហេតុផលរបស់គេដែរក្នុងការគាំទ្រក្រុមលោកឧត្តមសេនីយ សក់ ស៊ុតសាខន ព្រោះថារាល់ជំនួយដែលត្រូវផ្តល់ដល់កងកម្លាំងថ្មីនេះ នឹងត្រូវផ្តល់តាមរយៈកងទ័ពថៃទាំងអស់ ។ ជំនួយគ្រប់បែបយ៉ាង ដែលផ្តល់ដល់កម្លាំងប្រដាប់អាវុធខ្មែរ ទាំងថ្មីទាំងចាស់ ត្រូវតែឆ្លងកាត់តាមប្រទេសថៃជាដាច់ខាត ។ គួរបញ្ជាក់ទៀតដែរថា ប្រសិនបើលោកតា សឺន សាន មានទំនាក់ទំនងល្អជាមួយសហរដ្ឋអាមេរិក នៅក្នុងកំរិតអ្នកសម្រេចគោលនយោបាយឯទីក្រុងវ៉ាស៊ិនតោន ក្រុមលោក សក់ ស៊ុតសាខន រក្សាបាននូវទំនាក់ទំនងល្អជាមួយស្ថានទូតអាមេរិកនៅបាងកក ។ នេះក៏ដោយសារការងារជាប្រចាំរបស់ហ្គាហ្វាដែរ ។ ចំណែករូបខ្ញុំ នាសម័យនោះ ខ្ញុំក៏មានទំនាក់ទំនងខ្លះៗដែរជាមួយស្ថានទូតអាមេរិកនោះ តែទំនាក់ទំនងរបស់ខ្ញុំបានត្រឹមកំរិតទាបគឺ ត្រឹមថ្នាក់លេខាទី ២ ឬ ទី ៣ ប៉ុណ្ណោះ ។ ក្នុងចំណោមក្រុមលេខានោះ មានមន្ត្រីម្នាក់ឈ្មោះ ម៉ាក់កកមិច (McCormick) ។ ជាញឹកញាប់ ខ្ញុំតែងសុំឲ្យលោក ម៉ាក់កកមិច ជួយបញ្ជូនសំណើសុំជំនួយស.រ.អា ទៅមន្ត្រីថ្នាក់លើរបស់គាត់ ។ ថ្ងៃមួយដោយធុញទ្រាន់ ចំពោះការមិនអើពើរបស់ស្ថានទូតអាមេរិកក្នុងការឆ្លើយតបមកពួកយើង ខ្ញុំក៏បានប្រាប់លោក ម៉ាក់កកមិច ថា យើងខ្ញុំត្រូវការជំនួយរបស់អស់លោក ក៏ប៉ុន្តែមានជំនួយ ឬ ឥតជំនួយ យើងខ្ញុំក៏ត្រូវតែបន្តការតស៊ូរំដោះជាតិ ព្រោះនោះជា

កាតព្វកិច្ចរបស់ពួកយើងជាខ្មែរ ។ ច្រើនខែក្រោយមក ខ្ញុំបានទទួលដំណឹងតាមមិត្តកក្តិនៅទីក្រុងវ៉ាស៊ិនតោនថា អ្វីដែលខ្ញុំនិយាយប្រាប់លោក ម៉ាក់កកមិច នៅបាងកកនោះ បានឮទៅដល់ក្រសួងការបរ ទេសអាមេរិក ។

លោកតាបានស៊ីញ៉ៅលើក្រដាស តែលុយបានទៅអ្នកផ្សេង

ដោយអន្ទះអន្ទែងចង់ដឹងថា តើជំនួយស.រ.អា ដែលនឹងត្រូវផ្តល់ដល់ក្រុមខ្មែរមិនមែនកុម្មុយនីស្តនោះនឹងត្រូវផ្តល់តាមរយៈក្រុមណា? រ.ជ.រ.ប.ខ. (ខាងលោកតា សឺន សាន) បានធ្វើអនុស្សារណៈមួយច្បាប់ទៅជូនលោក ហ្គាស្តុន សៃគួរ (Gaston Sigur)[217] ឧបការីរដ្ឋមន្ត្រី (ឋានៈស្មើអនុរដ្ឋមន្ត្រី) ក្រសួងការបរ ទេសស.រ.អា ដើម្បីជំរាបថា រ.ជ.រ.ប.ខ. បានត្រៀមខ្លួននឹងបង្ហាញជូនមន្ត្រីអាមេរិកអំពីបែបបទនៃការប្រើប្រាស់ជំនួយនេះ នៅពេលណាដែលបានទទួលដំណឹងជាផ្លូវការអំពីការផ្តល់ជំនួយអាមេរិក ។ នៅក្នុងអនុស្សារណៈនោះ ពួកយើងបានគូសបញ្ជាក់អំពីមូលហេតុដែលអាមេរិកត្រូវជួយចលនាមិនមែនកុម្មុយនីស្តគឺ៖ ១. ដើម្បីឆ្លើយតបទៅនឹងប្រតិកម្មជាអវិជ្ជមានរបស់វៀតណាម ចំពោះសំណើសន្តិភាព ៨ ចំណុចរបស់រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ២. ដើម្បីជាវង្វាន់លើកទឹកចិត្តដល់រដ្ឋាភិបាលចម្រុះ ចំពោះការរីកចំរើនខាងយោធានៅលើសមរភូមិ និង នៅលើឆាកអន្តរជាតិ ។ ក៏ប៉ុន្តែតាមពិតទៅ ប្រសិនបើមានការជ្រៀតចូលជ្រៅទៅក្នុងប្រទេសនៃកងកម្លាំងប្រដាប់អាវុធមែន កងកម្លាំងប្រដាប់អាវុធនោះភាគច្រើនជាកម្លាំងខ្មែរក្រហម ដែលខ្លាំងជាងគេ នៅពេលដែលកងទ័ពមិនមែនកុម្មុយនីស្តមិន

[217] Khmer People's National Liberation Front, Memorandum presented to His Excellency Mr. Gaston Sigur, US Assistant Secretary of State for East Asia and Pacific Affairs, March 26, 1986.

អាចចេញឆ្ងាយពីទល់ដែនទេនោះ ។ នៅក្នុងអនុស្សារណៈនោះដែរ រ.ជ.រ.ប.ខ.បានសង្កត់ធ្ងន់ថា ពួកយើងត្រូវតែប្រើយុទ្ធសាស្ត្រសង្គ្រាមទ័ពព្រៃ ។ ជាសេចក្តីសន្និដ្ឋានពួកយើងអះអាងថាប្រសិនបើកងកម្លាំងមិនមែនកុម្មុយនីស្តនៅតែខ្សោយ ខ្មែរក្រហមនឹងទទួលជ័យជំនះនៅក្នុងសង្គ្រាម ហើយក្រុមមិនមែនកុម្មុយនីស្តនឹងត្រូវរលាយបាត់ស្រមោលពីឆាកនយោបាយនៅកម្ពុជាមិនខានឡើយ ។ ទាំងនេះជាហេតុផលដែលរ.ជ.រ.ប.ខ. បង្ហាញដល់ក្រសួងការបរទេសអាមេរិក ដើម្បីទាក់ទាញឲ្យស.រ.អាផ្តល់ជំនួយយោធាដល់កងកម្លាំងនៃចលនាតស៊ូមិនមែនកុម្មុយនីស្ត ។

នៅទីបំផុត អាមេរិកក៏ផ្តល់ជំនួយយោធា ដែលមិនមែនសម្រាប់សម្លាប់មនុស្ស (Non-Lethal) នេះមែន ។ នៅពេលនោះ អ្នកតំណាងលោកតា សឺន សាន ត្រូវអាជ្ញាធរថៃហៅឲ្យទៅចុះហត្ថលេខាលើឯកសារទទួលទាំងឡាយ ។ ក៏ប៉ុន្តែ ពួកយើងបានត្រឹមតែចុះហត្ថលេខាទទួលលើក្រដាសតែប៉ុណ្ណោះ ឯថវិកាជាសាច់ប្រាក់ត្រូវធ្លាក់ទៅក្រុមផ្សេងទៅវិញ ។ មែនទែន ការបើកយកប្រាក់ត្រូវសម្រេចដោយក្រុមការងារ តាមមតិណែនាំរបស់លោកឧត្តមសេនីយ ធាវលិត ។ ដូច្នេះអ្នកទទួលជំនួយពិតប្រាកដគឺ មួយផ្នែកធំបានទៅក្រុមយោធារបស់រ.ជ.រ.ប.ខ. ដែលមានលោកឧត្តមសេនីយ សក់ ស៊ុតសាខន ជាមេដឹកនាំ និង មួយផ្នែកទៀតបានទៅខាង ហ៊ុន សុិន ប៊ិច តំណាងដោយព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ដែលជាព្រះរាជបុត្រ និង ជាព្រះរាជតំណាងសម្តេច សីហនុ ។ បើនិយាយឲ្យចំទៅជំនួយអាមេរិក ដែលគេហៅថាជំនួយសូឡានោះមិនដែលបានធ្លាក់ ដល់ដៃក្រុមលោកតា សឺន សាន សោះឡើយ ។ នៅឆ្នាំ ១៩៨៨ លោកតា សឺន សាន[218] បានផ្ញើលិខិតមួយច្បាប់ជូនលោក សូឡា ដើម្បីតវ៉ាថាមិនដែលបានឃើញស្រមោលជំនួយនោះម្តងណាឡើយ ។ លោកតាសរសេរថាការប្រើប្រាស់ជំនួយយោធាគ្មាន

[218] Son Sann, [Letter] to the Honourable Stephen J. Solarz, Chairman Sub-Committee on Asia Pacific Affairs, Congress of the United States, June 22, 1988.

គណនេយ្យភាពសម្រាប់ខ្ញុំ និង មិនបានឲ្យខ្ញុំដឹងឮអ្វីទាំងអស់ ។ រាល់ៗឆ្នាំ គេឲ្យខ្ញុំចុះហត្ថលេខាទទួលលើឯកសារ ដើម្បីគេយកទៅបើកប្រាក់ ។ តាមពិតទៅ ដោយសារតែយើងទទួលថវិកាផ្ទាល់ពីក្រុមយោធាថៃ យើងក៏មិនអាចដឹងឲ្យច្បាស់លាស់ថា ថវិកាប៉ុន្មានជាថវិការបស់ ស.រ.អា តើអាមេរិកឲ្យមកក្រុមយើងប៉ុន្មាន? ឲ្យទៅខាងក្រុមលោក សក់ ស៊ុតសាខន ប៉ុន្មាន និង តើក្រុមឧត្តមសេនីយថៃកាត់យកប៉ុន្មាន?នៅក្នុងលិខិតចុះថ្ងៃទី ២២ មិថុនា ១៩៨៨ នោះ លោកតា សឺន សាន ក៏តវ៉ាដែរថា នៅពេលដែលទាំងប្រធាន ទាំងបុគ្គលិករ.ជ.រ.ប.ខ. ធ្វើការអត់យកប្រាក់ខែ និង នៅពេលដែលទាហានធម្មតា ទទួលការឧបត្ថម្ភតិចជាង ៥ ដុល្លារក្នុងមួយថ្ងៃ នាយទាហានជាន់ខ្ពស់រាប់ទាំងការិយាល័យអគ្គមេបញ្ជាការ ក.ជ.រ.ប.ខ. ក្រោមការដឹកនាំរបស់លោកឧត្តមសេនីយ សក់ ស៊ុតសាខន ផង នាំគ្នាបែងចែកប្រាក់ឧបត្ថម្ភប្រចាំខែក្នុងម្នាក់ៗពី ៨០០ ទៅ ៦០០០ ដុល្លារ ។

តាមការយល់ដឹងរបស់ពួកយើងៗទទួលពីទាហានថៃក្នុងមួយខែៗ នូវប្រាក់សុទ្ធចំនួនមួយលានបាត ឬ បួនម៉ឺនដុល្លារ ។ បន្ទាប់មក គេកាត់នៅត្រឹមប្រាំបីសែនបាត ឬ បីម៉ឺនពីរពាន់ដុល្លារនៅឆ្នាំ ១៩៨៥ ។ នៅឆ្នាំ ១៩៨៨ គេបន្តយមកប្រាំសែនបាត ឬ ពីរម៉ឺនប្រាំពាន់ដុល្លារ រួចនៅទីបញ្ចប់ គេកាត់មកត្រឹមបួនសែនបួនម៉ឺនប្រាំបួនពាន់បាត ឬ មួយម៉ឺនប្រាំពីរពាន់ប្រាំបួនរយហុកសិបដុល្លារ ។ ពួកថៃនិយាយថាប្រាក់ដែលគេកាត់ពីក្រុម សឺន សាន គេយកទៅប្រគល់ឲ្យក្រុម សក់ ស៊ុតសាខន ។ អ្នកវិភាគព័ត៌មានបានប៉ាន់ប្រមាណថាជំនួយរបស់ ស.រ.អា សម្រាប់ចលនាមិនមែនកុម្មុយនីស្តមានប្រហែលពី ១២ ទៅ ១៨ លានដុល្លារក្នុងមួយឆ្នាំ ។

តាំងពីច្រើនឆ្នាំមកហើយ ដែលទីក្រុងវ៉ាស៊ិនតោនខិតខំរិះរកវិធីផ្តល់ជំនួយដល់ក្រុមអ្នកតស៊ូខ្មែរមិនមែនកុម្មុយនីស្ត ព្រោះសមាជិកសភា និង សមាជិកព្រឹទ្ធសភាអាមេរិកមួយចំនួន ជាពិសេសលោក សូឡា យល់ឃើញថាជំនួយនេះ អាច

ជួយជាការគាបសង្កត់បន្ថែមទៀតដល់វៀតណាម ឲ្យដកកងទ័ពចេញពីកម្ពុជា ។ ក៏ប៉ុន្តែ អ្នកនយោបាយអាមេរិកទាំងនោះ ក៏មិនចង់ឃើញការដកកងទ័ពវៀតណាមចេញទៅដោយត្រូវបានជំនួសវិញ ដោយការរំលែត្រឡប់មកកាន់អំណាចវិញនៃរបបប្រល័យពូជសាសន៍ ប៉ុល ពត ទេ ។ សមាជិកនៃព្រឹទ្ធសភាអាមេរិកមួយចំនួនយល់ថាការទុកឲ្យរដ្ឋាភិបាលក្រុងភ្នំពេញ ហេង សំរិន-ហ៊ុន សែន កាន់អំណាចនៅភ្នំពេញ គ្រាន់បើជាងការរំលែត្រឡប់មកកាន់អំណាចរបស់បនប្រល័យពូជសាសន៍ ប៉ុល ពត ។ ដូច្នេះចាប់តាំងពីឆ្នាំ ១៩៨៦ មក ក៏កាន់តែមានអ្នកនយោបាយអាមេរិកច្រើនឡើងៗ ស្នើឲ្យរដ្ឋាភិបាលអាមេរិកចាប់ផ្តើមគិតគូរធ្វើឲ្យមានភាពប្រសើរឡើងនូវទំនាក់ទំនងជាមួយប្រទេសវៀតណាម ។ និន្នាការរបស់អាមេរិកបែបនេះធ្វើឲ្យក្រុមខ្មែរមិនមែនកុម្មុយនីស្ត មានការបារម្ភកាន់តែខ្លាំងចំពោះការប្រែប្រួលគោលជំហរអាមេរិកក្នុងទំនាក់ទំនងជាមួយវៀតណាម ។

អាមេរិកចង់ឲ្យមានទំនាក់ទំនងជាមួយវៀតណាម

នៅឆ្នាំ ១៩៨៧ មានការប៉ុនប៉ងធ្វើវិសោធនកម្មច្បាប់ស្តីពីទំនាក់ទំនងអាមេរិក-វៀតណាម ស្នើឡើងដោយអ្នកតំណាងរាស្ត្រឈ្មោះ ពីទែរ កូសម៉ាយែរ (Peter Kostmayer) ដែលគេហៅថាវិសោធនកម្មកូសម៉ាយែរ ។ ជាទូទៅ អ្នកនយោបាយក្រុងវ៉ាស៊ិនតោនខ្លះ ចាប់ផ្តើមគិតគូរកែលំអទំនាក់ទំនងសហរដ្ឋអាមេរិក-វៀតណាម ជាពិសេសគំនិតចេញពីមជ្ឈដ្ឋានសភាតំណាងរាស្ត្រ និង ព្រឹទ្ធសភា ក្នុងការបើកការិយាល័យបច្ចេកទេស និង ការផ្លាស់ប្តូរទំនាក់ទំនងទ្វេភាគី អាមេរិក-វៀតណាម ។ គំនិតបែបនេះ ធ្វើឲ្យពួកយើងនៅក្នុងជួរ.ជ.រ.ប.ខ. មានការបារម្ភខ្លាចអាមេរិកផ្លាស់ប្តូរគោលនយោបាយរបស់ខ្លួនចំពោះបញ្ហាកម្ពុជា ព្រោះថាសហរដ្ឋអាមេរិកធ្លាប់អះអាងថាដរាបណាវៀតណាមមិនដកកងទ័ពចេញពីកម្ពុជាទេ អាមេរិកមិនកែសំរួល

ឲ្យមានប្រក្រតីភាពឡើងវិញ ក្នុងទំនាក់ទំនងជាមួយវៀតណាមឡើយ ។ នៅថ្ងៃទី ១ ឧសភា ១៩៨៧ លោកតា សឺន សាន ផ្ញើលិខិតពីរច្បាប់ មួយច្បាប់ទៅជូនលោក ប្រធានាធិបតី រ៉ូណាល់ រីហ្គាន (Ronald Reagan)[219] និង មួយច្បាប់ទៀតទៅជូន លោក ស្តេហ្វាន់ សូឡា[220] ដើម្បីសំដែងនូវការព្រួយបារម្ភរបស់ក្រុមយើង ។ លោកតា សឺន សាន សរសេរថា សញ្ញាតូចតាចណាមួយ ចំពោះវៀតណាមអំពី បំណងកែលំអទំនាក់ទំនងជាមួយសហរដ្ឋអាមេរិក-វៀតណាម អាចចាត់ទុកជា ជំហានដ៏សំខាន់ ព្រោះវៀតណាមអាចយល់ថា ក្រុងវ៉ាស៊ិនតោនមិនរឹងត្អឹងពេកទេគឺ មិនទាមទារឲ្យវៀតណាមដកទ័ពចេញពីកម្ពុជាទៀតឡើយ ។ លោកតា សឺន សាន បានស្នើសុំឲ្យលោកប្រធានាធិបតីអាមេរិក រ៉ូណាល់ រីហ្គាន និង លោកតំណាងរាស្ត្រ សូឡា ប្រឆាំងនឹងគំនិតកែលំអទំនាក់ទំនងជាមួយវៀតណាម ក្នុងពេលដែល វៀតណាម កំពុងតែដាក់កងទ័ពឲ្យកាន់កាប់ទឹកដីកម្ពុជា ។

ចំពោះការព្រួយបារម្ភនេះលោក ហ្វ្រែង កាលលូស៊ី (Frank Carlucci) ទីប្រឹក្សាសន្តិសុខនៅសេតវិមាន[221] បានឆ្លើយក្នុងនាមលោកប្រធានាធិបតី រ៉ូណាល់ រីហ្គាន់ មានន័យជាអាទិថា ស.រ.អានៅតែចាប់អារម្មណ៍ចំពោះសោកនាដកម្មនៅ កម្ពុជា និង ថាសហរដ្ឋអាមេរិកនឹងធ្វើប្រក្រតីភាពនៃទំនាក់ទំនងជាមួយវៀតណាម តែក្នុងបរិបទនៃដំណោះស្រាយមួយនៃបញ្ហាកម្ពុជា ដែលគេអាចទទួលបាន និង ដែលក្នុងនោះរួមមានទាំងការដកកងទ័ពវៀតណាមផង ។ លោក កាលូស៊ី ជានា ចំពោះ រ.ជ.រ.ប.ខ. ថា ស.រ.អា មិនផ្លាស់ប្តូរគោលជំហរនយោបាយដ៏សំខាន់នេះទេ ទាក់ទងនិងបញ្ហាកម្ពុជា ។ លោក កាលូស៊ី បានបន្ថែមទៀតថារដ្ឋាភិបាលលោក ប្រធានាធិបតី រីហ្គាន់ នឹងប្រឆាំងការបញ្ជូនសញ្ញាណាមួយដល់ប្រទេសវៀតណាម

[219] Son Sann, [Letter] to His Excellency President Ronald Reagan, The White House, May 1, 1987.
[220] Son Sann, [Letter] to The Honourable Stephen J. Solarz, May 1, 1987.
[221] Frank C. Carlluci, [Letter] to Mr. Son Sann, President, Khmer People's National Liberation Front, June 15, 1987.

ដែលអាចនាំឲ្យមានការយល់ច្រឡំថាស.រ.អា លែងទាមទារឲ្យមានការដកកងទ័ពវៀតណាមពីកម្ពុជាទៀតទេ ។ ចំណែកឯលោកតំណាងរាស្ត្រ សូឡា ក៏បានឆ្លើយតបថាលោក ក៏មិនផ្លាស់ប្តូរជំហរនយោបាយរបស់លោកដែរទេ[222] ។ លោកនៅតែមានជំនឿថា ការដកកងទ័ពវៀតណាមពីកម្ពុជា នៅតែជាលក្ខខណ្ឌមុនដំបូងបង្អស់ (pre-condition) ក្នុងការធ្វើឲ្យមានប្រក្រតីភាពឡើងវិញនៅក្នុងទំនាក់ទំនងរវាងទីក្រុងវ៉ាស៊ិនតោន និង ក្រុងហាណូយ ។ លោក សូឡា ជានាថានឹងខឹតខំបន្តឲ្យ ស.រ.អា ផ្តល់ជំនួយដល់ចលនាមិនមែនកុម្មុយនីស្តតទៅទៀត ។ ក៏ប៉ុន្តែ លោក សូឡា ក៏សារភាពថា លោកមិនបិទទ្វារជិតទាំងអស់ក្នុងទំនាក់ទំនងជាមួយប្រទេសវៀតណាមនោះទេ ព្រោះថាស្ទើរតែគ្រប់ប្រទេសទាំងអស់នៃសមាគមអាស៊ានសុទ្ធតែមានស្ថានទូតប្រចាំនៅទីក្រុងហាណូយ ។ លោក សូឡា គាំទ្រទំនាក់ទំនងជាមួយវៀតណាមឲ្យមានត្រឹមកំរិត "ប្រជាជន" និង "ប្រជាជន" (People to People) ដូចជាការផ្លាស់ប្តូរទេស្សនកិច្ចផ្នែកវប្បធម៌ ឬ ផ្នែកស្រាវជ្រាវវិទ្យាសាស្ត្រទៅវិញទៅមកដែលលោក សូឡា ចាត់ទុកថាអាចជាច្រកទ្វារសម្រាប់និយាយគ្នា (a channel of communication) ។ តាមរយៈឥរិយាបថនេះ គេអាចមើលឃើញថា ស.រ.អា ក៏កំពុងគិតគូរដល់ដំណើរការប្រក្រតីភាពនៃទំនាក់ទំនងជាមួយប្រទេសវៀតណាម និង ដល់ការទប់ស្កាត់របបខ្មែរក្រហម មិនឲ្យវិលមកកាន់អំណាចវិញផងដែរ ។

[222] Stephen J. Solarz, [Letter] to Hon. Son Sann, President, Khmer People's National Liberation, Washington DC, June 3, 1987.

នៅឡាហ៊ាន ហ៊ុន សែន - គាត ឈន់ លបទាក់ទងគ្នា

គួររំលឹកដែរថា បញ្ហាកម្ពុជាក៏មានផលប៉ះពាល់ដល់សមាជិកភាពរបស់ប្រទេសនេះនៅក្នុងចលនាមិនចូលបក្សសម្ព័ន្ធដែរ ។ ចលនាមិនចូលបក្សសម្ព័ន្ធបានត្រូវបង្កើតឡើងនៅដើមទសវត្សរ៍ឆ្នាំ ១៩៦០ ដែលនៅពេលនោះមានស្ថាបនិកសំខាន់ៗដូចជាលោកសេនាប្រមុខ ទីតូ នៃប្រទេសយូហ្គោស្លាវី លោកប្រធានាធិបតី ស៊ូកាណូ នៃប្រទេសឥណ្ឌូណេស៊ី លោកប្រធានាធិបតី ណាស់ស្សែរ នៃប្រទេសអេហ្ស៊ីប លោកនាយករដ្ឋមន្ត្រី នេហរូ នៃប្រទេសឥណ្ឌា និង លោកប្រធានាធិបតី ណាក្រូម៉ាស នៃប្រទេសហ្គាណា ។ តាមពិតទៅ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ នោះ ប្រទេសកម្ពុជាយើងក្រោមព្រះរាជកិច្ចដឹកនាំរបស់សម្តេច សីហនុ ជាព្រះប្រមុខរដ្ឋក៏បានដើរតួនាទីដ៏សកម្មនៅក្នុងចលនានោះរហូតដល់ឆ្នាំ ១៩៧០ គឺរហូតដល់ពេលប្រទេសយើងធ្លាក់ចូលក្នុងភ្នក់ភ្លើងសង្គ្រាម ។

ចលនាមិនចូលបក្សសម្ព័ន្ធ ប្រមូលផ្តុំប្រទេសមួយចំនួន ដែលសំដែងគោលជំហរនយោបាយមិនចូល ទាំងខាងប្លុកកុម្មុយនីស្តក្រោមការដឹកនាំរបស់សហភាពសូវៀត និង ទាំងខាងប្លុកលោកសេរីដែលមានសហរដ្ឋអាមេរិកជាមេក្លោង ។ គួរកត់សំគាល់ដែរថា ប្រទេសកុម្មុយនីស្តមួយចំនួនដូចជា ចិន វៀតណាម យូហ្គោស្លាវី និង គុយបាជាដើម ក៏ជាសមាជិកសំខាន់នៃចលនានេះដែរ[223] ។ នៅឆ្នាំ ១៩៧៩ ប្រទេសកម្ពុជាបានបញ្ជូនគណៈប្រតិភូពីរទៅចូលរួមសិន្និសីទកំពូលលើកទី ៦ នៃចលនាមិនចូលបក្សសម្ព័ន្ធ នៅទីក្រុងឡាហ៊ាននៃប្រទេសគុយបាគឺគណៈប្រតិភូមួយដឹកនាំដោយលោកប្រធាន ហេង សំរិន នៃរដ្ឋាភិបាលក្រុងភ្នំពេញ ដែលមាន

[223] គោលបំណងនៃប្រទេសសមាជិកមួយចំនួនធំនៃចលនាមិនចូលបក្សសម្ព័ន្ធគឺ មិនចូលរួមមិនកាន់ជើង ឬ គាំទ្រភាគីណាមួយក្នុងការប្រណាំងប្រជែងខាងសព្វាវុធរវាង ស.រ.អា និង សហភាពសូវៀត ។

លោករដ្ឋមន្ត្រីក្រសួងការបរទេស ហ៊ុន សែន អមដំណើរផង និង គណៈប្រតិភូមួយទៀតជាគណៈប្រតិភូខ្មែរក្រហមដឹកនាំដោយលោក ខៀវ សំផន ដោយមានលោក គាត ឈន់ ជាសមាជិកគណៈប្រតិភូមួយរូបដែរ ។ គណៈប្រតិភូទាំងពីរមិនត្រូវបានអនុញ្ញាតឲ្យចូលរួមប្រជុំទេ ដោយហេតុថាអង្គសន្និសីទ បានសម្រេចទុកអាសនៈកម្ពុជាឲ្យនៅទំនេររហូតដល់មានដំណោះស្រាយជាស្ថាពរលើជម្លោះកម្ពុជា ។ តែទោះជាមិនបានចូលប្រជុំយ៉ាងណាក៏ដោយ ក៏ពេលនោះជាឱកាសឲ្យលោករដ្ឋមន្ត្រីក្រសួងការបរទេស ហ៊ុន សែន ធ្លៀតទាក់ទងជាសម្ងាត់ជាមួយលោក គាត ឈន់ ផងដែរ[224] ។ ប្រទេសកម្ពុជាយើងបានវិលទៅអង្គុយលើអាសនៈ ក្នុងចលនាមិនចូលបក្សសម្ព័ន្ធវិញ បន្ទាប់ពីមានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស នាឆ្នាំ ១៩៩១[225] ។ នៅក្នុងរយៈពេលដែលពុំទាន់មានដំណោះស្រាយបញ្ហាកម្ពុជា ចលនាមិនចូលបក្សសម្ព័ន្ធនាសម័យប្រប្រជុំកំពូលលើកទី ៦ នៅទីក្រុងឡាហាវ៉ានៃប្រទេសគុយបា និង នាសម័យប្រជុំកំពូលលើកទី ៧ នៅទីក្រុងញូវដែលីនៃប្រទេសឥណ្ឌា បានសម្រេចរក្សាទុកអាសនៈកម្ពុជាឲ្យនៅទំនេរ និង បានអំពាវនាវឲ្យមានការដកកងទ័ពបរទេសចេញពីតំបន់អាស៊ីភាគអគ្នេយ៍ និង ឲ្យបន្តរកដំណោះស្រាយនយោបាយតាមរយៈការចរចា ។ ចលនានេះបានបញ្ចូលបញ្ហាកម្ពុជាទៅក្នុងបញ្ហាតំបន់អាស៊ីភាគអគ្នេយ៍ និង ផ្តល់ការយល់ព្រមដល់ការប្រឹងប្រែងទាំងអស់ សំដៅទៅកសាងឲ្យបានឆាប់រហ័សនូវតំបន់មួយដែលមានសន្តិភាព សេរីភាព និង អព្យា

[224] ក្នុងបទសម្ភាសន៍របស់សម្តេចតេជោ ហ៊ុន សែន ជាមួយក្រុមស្រាវជ្រាវប្រវត្តិសាស្ត្រដឹកនាំដោយ ឯ.ឧ. អៀង មូលី និង ស៊ន សំណាង កាលពីថ្ងៃ ១៦ មីនា ២០១០ សម្តេចតេជោបានឲ្យដឹងថាលោកបាបញ្ជូនលិខិតសម្ងាត់ជូនលោក គាត ឈន់ ។

[225] គណៈប្រតិភូកម្ពុជាដឹកនាំដោយសម្តេច សីហនុ ក្នុងឋានៈជាព្រះប្រធានក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជា (អេស អិន ស៊ី) បានទៅចូលរួមសន្និសីទកំពូលលើកទី១០ នៃចលនាមិនចូលបក្សសម្ព័ន្ធនេះ នៅទីក្រុងហ្សាការតា ប្រទេសឥណ្ឌូណេស៊ី ពីថ្ងៃទី ១-៦ ខែកញ្ញា ១៩៩២ ។ រូបខ្ញុំ (អៀង មូលី) ក៏បានចូលរួមជាសមាជិកនៃគណៈប្រតិភូកម្ពុជានេះដែរ ។

ក្រឹតភាព ។

នៅក្នុងលិខិតចុះថ្ងៃទី ២៦ មីនា ១៩៨៦ ទៅជូនអស់លោករដ្ឋមន្ត្រីក្រសួងការបរទេសនៃប្រទេសសមាជិកចលនាមិនចូលបក្សសម្ព័ន្ធ លោក ង្វៀង កូថាច់ រដ្ឋមន្ត្រីក្រសួងការបរទេសវៀតណាម បានស្នើឲ្យចលនានេះបន្តទុកអាសនៈកម្ពុជានៅទំនេរតទៅទៀត សម្រាប់សម័យប្រជុំកំពូលលើកទី ៨ នាខែ កញ្ញា ១៩៨៦ នៅទីក្រុងហារ៉ារ៉ (Harare) នៃប្រទេស ស៊ីមបាវ៉ (Zimbawe) ដោយសំអាងថាដើម្បីជៀសវាងការខ្វែងមតិគ្នានៅក្នុងចលនានេះ ។ លោក ង្វៀង កូថាច់ ក៏បានស្នើឲ្យសន្និសីទលើកទី ៨ បន្តប្រកាន់គោលជំហរដដែលដូចសម័យប្រជុំកំពូលមុនៗដែរ ចំពោះបញ្ហាកម្ពុជា និង តំបន់អាស៊ីភាគអគ្នេយ៍[226]។ នៅក្នុងលិខិតដដែលនោះ ប្រមុខការទូតវៀតណាម បានឲ្យដឹងថាក្រុមប្រទេសឥណ្ឌូចិនដែលមានប្រទេសវៀតណាមជាតំណាង និង ក្រុមប្រទេសអាស៊ានដែលមានប្រទេសឥណ្ឌូណេស៊ីជាតំណាង បានចាប់ផ្តើមចរចាគ្នារួចទៅហើយ រីឯការចរចាទ្វេភាគីក៏បានចាប់ផ្តើមដែរ រវាងវៀតណាមជាមួយម៉ាឡេស៊ី និង រវាងម៉ាឡេស៊ីជាមួយលាវ ។ តាមរយៈសកម្មភាពនេះ វៀតណាមព្យាយាមធ្វើឲ្យមានការចរចាគ្នាក្នុងលំដាប់តំបន់ ដែលក្នុងនោះការទាមទារណាមួយឲ្យដកកងទ័ពវៀតណាមពីកម្ពុជា ក៏ត្រូវភ្ជាប់ជាមួយការដកកងទ័ពបរទេសទាំងអស់ពីប្រទេសដ៏ទៃនៅក្នុងតំបន់អាស៊ីភាគអគ្នេយ៍ ដូចជាដកកងទ័ពអាមេរិកចេញពីប្រទេសហ្វីលីពីនដែរ ដើម្បីធ្វើតំបន់នេះឲ្យទៅជាតំបន់សន្តិភាព សេរីភាព និង អព្យាក្រឹត ។ ជាមួយនិងគោលជំហរជាសាធារណៈនេះ ដែលវៀតណាមបានភ្ជាប់បញ្ហាកម្ពុជាទៅនិងបញ្ហាតំបន់ និង បានព្យាយាមគេចចេញពីការចោទប្រកាន់ថាជាអ្នកឈ្លានពានកម្ពុជា មេដឹកនាំវៀតណាមក៏បានខឹតខំជំរុញឲ្យមានការជួបចរចាគ្នារវាងភាគីខ្មែរគឺ រដ្ឋាភិបាលចម្រុះត្រីភាគី និង រដ្ឋាភិបាលក្រុង

[226] Nguyen Co Thach, Vietnamese Foreign Minister, Letter to Foreign Ministers of Non-Aligned Countries, Hanoi, March 26, 1986.

ភ្នំពេញជាមុនសិន ។

វៀតណាមស្នើសម្តេចរៀបចំឲ្យមានការចរចាជាពីរដំណាក់កាល

នៅវេលាម៉ោង ១០ កន្លះយប់ទី ២៤ តុលា ១៩៨៦ សម្តេច សីហនុ បានកោះហៅអស់លោកឯកអគ្គរដ្ឋទូតនៃរដ្ឋាភិបាលត្រីភាគីគឺ លោក អ៊ុម ស៊ីម តំណាង រ.ជ.រ.ប.ខ. អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរីរ័ត្ន តំណាងហ៊ុន សុិន ប៊ិច លោក ជួន ប្រសិទ្ធិ តំណាងខ្មែរក្រហមប្រចាំនៅអង្គការសហប្រជាជាតិឲ្យទៅចូលគាល់ព្រះអង្គនៅថ្ងៃបន្ទាប់វេលាម៉ោង ១២ កន្លះ នៅសណ្ឋាគារ ហេមស្លី នៅទីក្រុងញ៉ីវយ៉ក ដើម្បីចូលរួមប្រជុំការងារ និង នាំព័ត៌មានទៅជូនថ្នាក់ដឹកនាំនៃភាគីរៀងៗខ្លួនៗ ។ ដោយមានវត្តមានលោក ខែក ស៊ីសូដា នៅអមព្រះអង្គផង សម្តេច សីហនុ ជំរាបអស់លោកទូតទាំងនោះថាកាលពីថ្ងៃទី ២៤ តុលា វេលា ម៉ោង ១១ កន្លះព្រឹក ព្រះអង្គបានប្រទានសវនាការឲ្យលោកឯកអគ្គរដ្ឋទូតអូទ្រីស កាល ហ្វីសស្ឆ័រ (Karl Fishcer) ចូលគាល់ដើម្បីពិភាក្សាការងារ ។ ក្នុងសវនាការនោះ លោកទូតអូទ្រីសបានទូលព្រះអង្គថា ប្រទេសវៀតណាមបានស្នើតាមរយៈប្រទេសអូទ្រីស សូមឲ្យមានការចរចាជាពីរដំណាក់កាលគឺ៖ ដំណាក់កាលទី១ហៅថាដំណាក់កាលជាតិដែលសុំឲ្យសម្តេច រួមជាមួយអ្នកតំណាងរ.ជ.រ.ប.ខ.មួយរូប និង អ្នកតំណាងខ្មែរក្រហមមួយរូបលើកលែងតែ ប៉ុល ពត ចេញ ជួបចរចាជាមួយ លោក ហេង សំរិន និង លោក ហ៊ុន សែន នៅទីក្រុងវីយែន ប្រទេសអូទ្រីស ។ ដំណាក់កាលទី២ ហៅថាដំណាក់កាល អន្តរជាតិ ដែលប្រទេសវៀតណាម ព្រមជាមួយមហាអំណាចឯទៀតនឹងចូលរួមប្រជុំជាមួយភាគីខ្មែរ ប្រសិនបើដំណាក់កាលទី១បានទទួលជោគជ័យ ដើម្បីធានាលើការព្រមព្រៀងរវាងភាគីខ្មែរទាំង

នោះ[227] ។ ចំពោះសំណើរបស់វៀតណាមនេះ សម្តេចបានមានព្រះបន្ទូលជំរាបលោកទូតអូទ្រីសថា ដោយព្រះអង្គស្គាល់ច្បាស់នូវគោលជំហររបស់ដៃគូរបស់ព្រះអង្គក្នុងជួររដ្ឋាភិបាលចម្រុះត្រីភាគី ជំនួបរវាងភាគីខ្មែរនៅទីក្រុងវីយែននោះមិនអាចធ្វើបានទេ ព្រោះខាងត្រីភាគីប្រកាន់យកការចរចាផ្ទាល់ជាមួយវៀតណាម ដោយគេសំអាងថា សង្គ្រាមបច្ចុប្បន្នជាសង្គ្រាមរវាងវៀតណាមដែលជាអ្នកឈ្លាន ពាន និង កម្ពុជាប្រជាធិបតេយ្យដែលជាអ្នករងគ្រោះ មិនមែនជាសង្គ្រាមស៊ីវិលរវាងខ្មែរ និង ខ្មែរនោះទេ ។ ក៏ប៉ុន្តែ ប្រសិនបើវៀតណាមសុខចិត្តចូលមកចរចាជាមួយរដ្ឋាភិបាលត្រីភាគី ភាគីខ្មែរម្ខាងទៀតនៅភ្នំពេញអាចចូលរួមក្នុងសមាសភាពនៃគណៈប្រតិភូរបស់វៀតណាម ។ សម្តេចជំរាបអស់លោកទូតខ្មែរត្រីភាគីថា នេះគ្រាន់តែជាការយល់ឃើញផ្ទាល់របស់ព្រះអង្គតែប៉ុណ្ណោះ ព្រោះព្រះអង្គជឿថា នៅពេលនេះ វៀតណាមមិនអាចទទួលយកតាមគោលជំហរត្រីភាគីបានឡើយ ទោះជាវៀតណាមកំពុងជួបបញ្ហាជាច្រើន និង កំពុងរកវិធីដោះស្រាយយ៉ាងណាក៏ដោយ ។ មុននិងបិទអង្គប្រជុំ សម្តេច សីហនុ បានស្នើឲ្យកងកម្លាំងត្រីភាគីបង្កើនសកម្មភាពយោធា ដើម្បីបង្ខំឲ្យវៀតណាមចូលមករកតុចរចា ។

នៅចំពោះមុខនៃការផ្តួចផ្តើមគំនឹតការទូតជាបន្តបន្ទាប់ ពីសំណាក់ប្រទេសវៀតណាម និង ក្រុមប្រទេសឥណ្ឌូចិន ខ្មែរក្រហមដែលមានចិន និង ក្រុមយោធាថៃនៅពីក្រោយ បានខឹតខំបង្ហាញរូបភាពនៃឯកភាពស្អឹតរមួតរវាងកងកម្លាំងត្រីភាគី ដោយជំរុញឲ្យមានការរួមប្រជុំអគ្គមេបញ្ជាការកងទ័ពនៃភាគីទាំងបី ។ នៅថ្ងៃទី ១៨ វិច្ឆិកា ១៩៨៦ ក្នុងហាន:ជាព្រះរាជតំណាងសម្តេច សីហនុ និង ជាអគ្គមេបញ្ជាការនៃកងទ័ពសីហនុនិយម ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ បានធ្វើជាអធិបតីនៃអង្គប្រជុំមួយដែលមានលោក សុន សេន ខាងខ្មែរក្រហម និង លោក សក់ ស៊ុតសាខន

[227] Um Sim, Propositions Vietnamiennes Pour Une Négociation En Deux Phases, Une Note Sur la Réunion de Travail, à l'hotel Helmsley, New York, le 24 octobre 1986.

ខាងក.ជ.រ.ប.ខ. ចូលរួម ហើយបានចេញសេចក្តីប្រកាសមួយ មានចំណុចជាអាទិ៖[228]-សំដែងការរីករាយចំពោះជ័យជំនះយោធាក្នុងរដូវវស្សាទី ៨ កន្លងទៅ -រីករាយ ចំពោះកិច្ចសហការកាន់តែល្អរវាងកងទ័ពទាំងបី -ឯកភាពសកម្មភាពយោធានៅរដូវប្រាំងទី ៩ -ខឹតខំពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការ និង សាមគ្គីភាពរវាងកងកម្លាំងទាំងបីភាគី ។ ចំណុចសំខាន់នៃអង្គប្រជុំនេះ ក្រៅពីបង្ហាញរូបភាពស្តីពីឯកភាព សាមគ្គីភាព និង កិច្ចសហប្រតិបត្តិការល្អនៃកម្លាំងត្រីភាគី វត្តមានរបស់លោក សក់ ស៊ុតសាខន ដែលកំពុងដណ្តើមតួនាទីដឹកនាំពីលោកតា សឺន សាន ជាសញ្ញាឲ្យដឹងថា ក្រុមយោធាថៃ និង ប្រទេសគាំទ្រ.ជ.រ.ប.ខ. នៅតែទទួលស្គាល់លោកឧត្តមសេនីយរូបនេះជាអគ្គមេបញ្ជាការក.ជ.រ.ប.ខ. ទោះជាលោកតា សឺន សាន សប្បាយចិត្ត ឬ មិនសប្បាយចិត្តក៏ដោយ ។ តាមពិតដូចខ្ញុំបានសរសេរនៅវគ្គមុនរួចហើយ នៅចុងឆ្នាំ ១៩៨៦ ក្រុមយោធាថៃបង្ខំឲ្យលោកតា សឺន សានធ្វើការជោនាឡើងវិញជាមួយលោក សក់ ស៊ុតសាខន ។ ដូច្នេះហើយទើបនៅថ្ងៃទី ១១ មករា ១៩៨៧ លោកតា សឺន សាន បានចេញក្រឹត្យតែងតាំងលោកឧត្តមសេនីយ សក់ ស៊ុតសាខន ជាអគ្គមេបញ្ជាការក.ជ.រ.ប.ខ. ទោះជាលោកតាប្រធានចង់ដាក់លក្ខខណ្ឌយ៉ាងណាក៏ដោយ ។ តាមពិតទៅ លោក ឆាវលិត បានដាក់កំហឹតឲ្យភាគីលោកតា សឺន សាន និង ឧត្តមសេនីយ សក់ ស៊ុតសាខន បញ្ចប់ជម្លោះផ្ទៃក្នុងឲ្យបានជាស្ថាពរនៅដំណាច់ឆ្នាំ ១៩៨៦ នោះ[229]។ ក្នុងលិខិតចុះថ្ងៃទី ១៨ ធ្នូ ១៩៨៦ ផ្ញើជូនលោកតាប្រធានរ.ជ.រ.ប.ខ. លោក សក់ ស៊ុតសាខន បានបញ្ជាក់ថាអ្នកនាំពាក្យរបស់លោក ឆាវលិត បានព្រមានថាបើក្នុងពីរអាទិត្យទៀត មិនមានការស្រុះស្រួលគ្នាទេនោះ រ.ជ.រ.ប.ខ.នឹងត្រូវរិនាសសាបសូន្យមិន

[228] នរោត្តម រណឫទ្ធិ-សុន សេន-សក់ ស៊ុតសាខន, សេចក្តីប្រកាសព័ត៌មាន, ថ្ងៃទី ១៨ វិច្ឆិកា ១៩៨៦ ។

[229] សក់ ស៊ុតសាខន, [លិខិត] ជូនឯកឧត្តម សឺន សាន ប្រធានរ.ជ.រ.ប.ខ, ថ្ងៃទី ១៨ ធ្នូ ១៩៨៦ ។

ខានឡើយ ។

សេអូសេស្គូ ទូលសម្តេចឲ្យខំរកដំណោះស្រាយនយោបាយ

នៅដើមឆ្នាំ ១៩៨៧ សម្តេច សីហនុ យាងទៅប្រទេសរូម៉ានីម្តងទៀត ។ នៅក្នុងជំនួបជាមួយលោកប្រធានាធិបតី សេអូសេស្គូ (Ceausescu) នៅថ្ងៃទី ១២ មករា ១៩៨៧ ក្នុងរយៈពេល ២ ម៉ោង នៅទីក្រុងប៊ុយការ៉េស សម្តេច សីហនុ និង លោកប្រធានាធិបតី បានផ្លាស់ប្តូរមតិគ្នាលើបញ្ហាកម្ពុជា ។ សម្តេចព្រះប្រធាននៃកម្ពុជាប្រជាធិបតេយ្យ បានរៀបរាប់សភាពការណ៍នៅលើសមរភូមិថាមានភាពអនុគ្រោះនៅគ្រប់ចំណុចដល់ចលនាតស៊ូ ក៏ប៉ុន្តែលោកប្រធានាធិបតីឆ្លើយតបវិញថា នៅលើឆាកអន្តរជាតិ សភាពការណ៍អនុគ្រោះដល់ការស្វែងរកដំណោះស្រាយនយោបាយ ដោយសន្តិវិធី និង ប្រកបដោយសមធម៌ ។ លោក សេអូសេស្គូ ទូលសម្តេចថា ប្រទេសវៀតណាមបានស្នើយកទីក្រុងប៊ុយការ៉េសជាទីកន្លែងជួបពិភាក្សាគ្នារវាង សីហនុ និង ហេង សំរិន ។ សម្តេច សីហនុ ឆ្លើយថាជំនួបបែបនេះមិនអាចធ្វើបានឡើយ ដោយហេតុថាដៃគូរបស់ព្រះអង្គក្នុងត្រីភាគីគឺ ខ្មែរក្រហម និង លោកតា សឺន សាន នឹងធ្វើការជំទាស់[230] ។ លោកប្រធានាធិបតីទូលសម្តេចទៀតថា ប្រទេសវៀតណាម នឹងមិនទទួលយកឡើយនូវការចោទប្រកាន់ថាជាអ្នកឈ្លានពានកម្ពុជា ។ លោកថ្វាយយោបល់ថាជាការសមហេតុសមផលណាស់ដែលត្រីភាគីត្រូវបង្កើតរដ្ឋាភិបាលចតុភាគីជាមួយភាគី ហេង សំរិន ដើម្បីធ្វើជារដ្ឋាភិបាលផ្សះផ្សាជាតិមួយ ។ លោក សេអូសេស្គូ ទូលទៀតថាគឺរដ្ឋាភិបាលផ្សះផ្សាជាតិនេះហើយ ដែលជាអ្នកស្នើសុំឲ្យប្រទេសវៀតណាមដកកងទ័ពរបស់គេចេញពី

[230] Norodom Sihanouk, mon compte-rendu succinct de mon entretien politique, d'une durée de 2 heures, avec Son Excellence Monsieur le Président Nicolae Ceausescu de la République Socialiste de Roumanie, Bucarest, Lundi 12 Janvier 1987.

កម្ពុជាជាពីរដំណាក់កាល ដូចសំណើរបស់រដ្ឋាភិបាលចម្រុះត្រីភាគីធ្លាប់បានស្នើយ៉ាងនោះដែរ ។ ប្រទេសវៀតណាមប្រាកដជានឹងដកកងទ័ពតាមសំណើមិនខានឡើយ ។

ទោះជាភ្លាមៗនោះ សម្តេច សីហនុ មិនទាន់ទទួលយកបាននូវសំណើជួបផ្ទាល់ជាមួយភាគីភ្នំពេញយ៉ាងណាក៏ដោយ ក៏ព្រឹត្តិការណ៍ជាបន្តបន្ទាប់បានបញ្ជាក់ថាព្រះអង្គមិនបានបោះចោលទាំងស្រុងនូវគំនិតជួបចរចានេះទេ ។ ម្យ៉ាងទៀតគួរកត់សំគាល់ផងដែរថា សំណើរបស់លោកប្រធានាធិបតីរូម៉ានីនេះ បានធ្វើឲ្យខ្មែរក្រហមចាប់អារម្មណ៍យ៉ាងខ្លាំង ។ នៅថ្ងៃទី ១៨ មករា ១៩៨៧ លោក ខៀវ សំផន បានសរសេរសំបុត្រមួយច្បាប់ថ្វាយសម្តេច សីហនុ ក្នុងន័យចង់ចូលគាល់ដើម្បីពិភាក្សាអំពីសំណើរបស់លោក សេអូសេស្គូ ឬ ដើម្បីស្នើព្រះរាជយោបល់ថាតើគួរទៅជួបលោកប្រធានាធិបតីរូម៉ានីនេះ នៅទីក្រុងប៊ុយការ៉េស្តដែរឬទេ? នៅថ្ងៃទី ២៥ មករា ១៩៨៧ សម្តេច សីហនុ បានផ្ញើសារទូរលេខតបវិញ ដោយបានណែនាំទាំងលោក ខៀវ សំផន ទាំងលោកតា សឺន សាន ថាមិនចំបាច់ទៅរូម៉ានី ឬ មកគាល់ព្រះអង្គទេ ព្រោះថាព្រះអង្គបានដោះស្រាយជាមួយលោកប្រធានាធិបតីសេអូសេស្គូ រួចស្រេចបាច់អស់ហើយ តាមសំណូមពររបស់កម្ពុជាប្រជាធិបតេយ្យគឺគ្មានការចរចាផ្ទាល់ណាមួយ រវាងរដ្ឋាភិបាលចម្រុះត្រីភាគីជាមួយភាគីក្រុងភ្នំពេញឡើយ[231]។ នៅក្នុងសារទូរលេខនោះ សម្តេច សីហនុ ហាក់ដូចជាចង់ផ្ញើផ្ទាល់ឲ្យដៃគូពីរនាក់ទៀតរបស់ព្រះអង្គថា បើនៅតែប្រកាន់គោលជំហរឹងត្អឹងទៀតនោះ មិនចាំបាច់ខាតពេលវេលាខ្វាយខ្វល់អំពីដំណោះស្រាយរូម៉ានីនេះទេ ដោយព្រះអង្គទ្រង់ជ្រាបច្បាស់ថា ក្រុងហាណូយប្រាកដជាមិនព្រមអង្គុយចរចាផ្ទាល់ជាមួយរដ្ឋាភិបាលចម្រុះត្រីភាគី ដែលមានខ្មែរក្រហមជាធ្មឹងខ្នងនោះឡើយ ។

[231] Norodom Sihanouk, Télégramme A Son Excellence Khieu Samphan, Vice Président du Kampuchea Démocratique, c/o S.E. Ambassadeur Chan Youran, Pekin, 25 janvier 1987.

ចំណែកខាង រ.ជ.រ.ប.ខ.វិញបន្ទាប់ពីបានបញ្ចប់ដំណោះផ្ទៃក្នុងរួចមក រ.ជ.រ.ប.ខ.ជាពិសេសលោកតា សឺន សាន បានផ្តើមគំនឹតនយោបាយថ្មីមួយក្លាមគឺ គំនឹតបង្កើតតំបន់អង្គរជាតំបន់វប្បធម៌អន្តរជាតិគ្មានកងកំលាំងប្រដាប់អាវុធ ។ ក៏ប៉ុន្តែគួរបញ្ជាក់ថា ការជានាគ្នារវាងលោកតា សឺន សាន និង លោកឧត្តមសេនីយ សក់ ស៊ុតសាខន នាពេលនោះ គ្រាន់តែជាការជានាតាមរូបភាពក្រៅតែប៉ុណ្ណោះ មិនមែនជាការស្រុះស្រួលគ្នាពិតប្រាកដឡើយ ព្រោះភាគីនីមួយៗនៅតែបន្តរក្សាគោលដំហរដើមរបស់គេរៀងៗខ្លួនដដែល ។ លោកឧត្តមសេនីយ សក់ ស៊ុតសាខន នៅតែបន្តចាត់ចែងការងារខាងផ្នែកកងទ័ពតែម្នាក់ឯង ដោយមិនបានពិគ្រោះ ឬ ទទួលការព្រមព្រៀងជាមុនពីលោកតាប្រធាន ដូចមានចែងក្នុងឧបសម្ព័ន្ធនៃក្រឹត្យតែងតាំងអគ្គមេបញ្ជាការនោះឡើយ ។ ភស្តុតាងនៃចំណាត់ការជាអត្តនោម័តរបស់លោកឧត្តមសេនីយ សក់ ស៊ុតសាខន ក្លាមៗនោះគឺ ការបំពាក់ឋានន្តរសក្តិថ្នាក់ឧត្តមសេនីយ ជាពិសេសដល់នាយទាហានក.ជ.រ.ប.ខ. ដែលនាំឲ្យមានការដាស់តឿនក្រើនរំលឹកពីលោកតា សឺន សាន ផង[232] ។

លោកតាចង់សុំឲ្យតំបន់អង្គរអព្យាក្រឹត

ដោយសំអាងទៅដល់ការប្រកាស អំពាវនាវរបស់លោកអតីតរដ្ឋមន្ត្រីក្រសួងការបរទេសនៃប្រទេសអូទ្រីស វីល្លីបាល ប៉ា កាលពីឆ្នាំ ១៩៨៤ ក្នុងឋានៈជាប្រធានសន្និសីទអន្តរជាតិស្តីពីកម្ពុជា ឬ អាយ ស៊ី ខេ លោកតា សឺន សាន បានចេញផ្សាយនូវអនុស្សារណៈមួយស្តីអំពីតំបន់វប្បធម៌អង្គរ ជាតំបន់គ្មានកំលាំងប្រដាប់អាវុធ ជាតំបន់អព្យាក្រឹត្យ ដើម្បីឲ្យអ្នកជំនាញការអន្តរជាតិមកជួយជួសជុល

[232] សឺន សាន ប្រធានរ.ជ.រ.ប.ខ. ផ្ញើជូនលោកឧត្តមសេនីយ សក់ ស៊ុតសាខន ថ្ងៃទី ២២ កុម្ភៈ ១៩៨៧ ។

កែលំអប្រាសាទអង្គរវត្ត និង ប្រាសាទអង្គរធំ[233] ។ ចំណុចសំខាន់នៃគំនិតនោះគឺ អង្គការយូណេស្កូ ជាអ្នកផ្តើមគំនិតស្នើឲ្យមានតំបន់វប្បធម៌អន្តរជាតិ ដោយមានការ យល់ព្រមពីប្រទេសសមាជិក ជាពិសេសប្រទេសនៅអឺរ៉ុប រួមទាំងប្រទេសរូម៉ានី និង យូហ្គោស្លាវីផង ។ ចំណែកឯប្រទេសឥណ្ឌាដែលមានអ្នកជំនាញការនៅហ្នឹងកន្លែង ស្រាប់ ក៏អាចជួយធ្វើឲ្យសម្រេចឡើងនូវគំនិតផ្តួចផ្តើមនេះ ។ អនុស្សារណៈនោះ បញ្ជាក់ថា ក្រោយពេលដែលគំនិតនេះបានត្រូវទទួលយកទាំងអស់គ្នា ហើយតំបន់ វប្បធម៌អង្គរត្រូវធ្វើអន្តរជាតូបនីយកម្ម ដោយអង្គការយូណេស្កូជាអ្នកធានាឧបត្ថម្ភ គ្រប់យ៉ាង ។ ក្នុងន័យនេះ ទាំងព្រលានយន្តហោះ ទាំងទីក្រុងសៀមរាប ត្រូវបើកឲ្យ អ្នកជំនាញការអន្តរជាតិចេញចូលដោយសេរី ព្រមទាំងត្រូវអនុញ្ញាតឲ្យមានការនាំ ចូលនូវសំភារៈ និង ស្បៀងទាំងឡាយមកក្នុងតំបន់វប្បធម៌ដែលអាចនឹងបើកឲ្យអ្នក ទេសចរណ៍មកពីគ្រប់ភាគីចូលមកទស្សនាផង ។ ក៏ប៉ុន្តែអនុស្សារណៈនេះ ក៏បាន ដាក់លក្ខខណ្ឌថា រាល់ការចរចាបង្កើតតំបន់វប្បធម៌នេះ មិនត្រូវនាំឲ្យមានការទទួល ស្គាល់រដ្ឋាភិបាលក្រុងភ្នំពេញ មុនពេលដែលមានការផ្សះផ្សាជាតិនោះឡើយ ។ ការ លើកឡើងនូវគំនិតផ្តួចផ្តើមនេះ សំអាងថាបេតិកភណ្ឌវប្បធម៌អង្គរ ដែលត្រូវបាន ខូចខាតតាំងពីឆ្នាំ ១៩៧១ មកនោះ ត្រូវការជួសជុលឲ្យបានឆាប់រហ័ស និង មិន ត្រូវស្ថិតនៅក្រោមការត្រួតត្រារបស់ភាគីមានជម្លោះណាមួយឡើយ ។ បើនិយាយ ឲ្យស្រួលស្តាប់តំបន់អង្គរ-សៀមរាប អាចត្រូវបានរំដោះចេញពីការកាន់កាប់របស់ រដ្ឋាភិបាលភ្នំពេញ តាមរយៈអន្តរជាតូបនីយកម្មនៃតំបន់នេះ ។ ក្នុងលិខិតផ្ញើថ្វាយ សម្តេច សីហនុ និង ជូនលោក ខៀវ សំផន លោក តា សឺន សាន បានរំលឹកថា ថ្នាក់ដឹកនាំរដ្ឋាភិបាលចម្រុះធ្លាប់គាំទ្រឲ្យលោកតាក្នុងឋានៈជារដ្ឋមន្ត្រីទី១ សរសេរ លិខិតគាំទ្រលោក វីល្លីបាល ប៉ា ដែលប្រកាសសុំ ឲ្យបង្កើតតំបន់វប្បធម៌នេះកាលពី

[233] The Office of the Prime Minister of the Coalition Government of Democratic Kampuchea, Memorandum on the conception of an Angkor cultural zone from all the presence of the armed forces, February 26, 1987.

ឆ្នាំ ១៩៨៤ ។ ក៏ប៉ុន្តែ លោក ខៀវ សំផន ហាក់ដូចជាមានក្តីបារម្ភយ៉ាងខ្លាំងចំពោះ គំនិតផ្តួចផ្តើមនេះ ។ នៅក្នុងចម្លើយផ្ញើជូនលោកតា សឺន សាន លោក ខៀវ សំផន បានលើកឡើងថា រដ្ឋាភិបាលចម្រុះធ្លាប់ បានពិភាក្សាបញ្ហានេះ នៅក្រោមព្រះអធិបតីភាពសម្តេច សីហនុ ហើយទាំងអស់គ្នាយល់ឃើញថា គ្រប់ជំហាននៃការគិតគូរ ត្រូវមានការប្រយ័ត្នប្រយែងខ្ពស់បំផុតគឺ មិនត្រូវនាំទៅឲ្យមានការទទួលស្គាល់របបក្រុងភ្នំពេញដោយអន្តរជាតិសោះឡើយ[234] ។ លោក ខៀវ សំផន សុំឲ្យផ្តល់ព័ត៌មានច្បាស់លាស់ថែមទៀត ដើម្បីពិចារណា ជាពិសេសខ្មែរក្រហមចង់ដឹងថា តើមានប្រទេសជាមិត្តណាខ្លះដែលលោកតា សឺន សាន អះអាងថាបានគ្រាំទ្រគំនិតនេះ? តាមពិតទៅ ខ្មែរក្រហមក៏មានបំណងដណ្តើមកាន់កាប់តំបន់នេះដែរ ដូច្នេះខ្មែរក្រហមគ្មានផលប្រយោជន៍អ្វី ក្នុងការប្រកាសតំបន់វប្បធម៌អន្តរជាតិនេះឡើយ ។ ចំណែកឯក្រុមលោកតា សឺន សាន គ្រាន់តែនឹកគិតថា សហគមន៍អន្តរជាតិប្រាកដជាអាចធ្វើការគាបសង្កត់ប្រទេសវៀតណាម និង រដ្ឋាភិបាលក្រុងភ្នំពេញ ដើម្បីយកតំបន់អង្គរ-សៀមរាប ជាតំបន់អន្តរជាតិដែលមិនត្រូវស្ថិតនៅក្រោមអំណាចភាគីណាមួយឡើយ ព្រោះថាប្រាសាទអង្គរ មានតម្លៃវប្បធម៌ធំធេងមហាសាល មិនអាចមានការប្រឆាំងជំទាស់ក្នុងការជួសជុលកែលំអឡើយ ។ បើពិនិត្យលើអនុស្សារណៈនោះ គេមិនទាន់ឃើញចំណុចលំអិត ដែលអាចយកមកអនុវត្តបានឡើយ ។ ដូច្នេះទើបនៅថ្ងៃទី ១៥ មិថុនា ១៩៨៧ ពីទីក្រុងប៉ារីស ប្រទេសបារាំង លោកតា សឺន សាន បានចេញសេចក្តីថ្លែងការណ៍ បញ្ជាក់អំពីតំបន់វប្បធម៌នោះដូចតទៅ៖[235] ១- កងទ័ពបរទេស និង កម្លាំងប្រដាប់អាវុធដែលពាក់ព័ន្ធក្នុងជម្លោះ ត្រូវដកចេញក្នុងរង្វង់ ៥០ គ.ម ពីតំបន់សៀមរាប-អង្គរ ២-

[234] Khieu Samphan, Vice-Président du Kampuchea Démocratique chargé des Affaires Etrangères, à S.E. M. Son Sann, Premier Ministre du Gouvernement de Coalition du Kampuhea Démocratique, le 24 avril 1987.

[235] Son Sann, Déclaration de Son Excellence Son Sann, Premier Ministre du Gouvernement de Coalition de Kampuchea Démocratique(GCKD) Président de Front National de Libération du Peuple Khmers (FNLPK), Paris, le 15 Juin 1987.

អនុញ្ញាតឲ្យតំណាងភាគីទាំងអស់មកជួបជុំគ្នាដោយសេរី ដើម្បីពិភាក្សាអំពីនីតិវិធីបច្ចេកទេសស្តីអំពីការជួសជុលកែលំអប្រាសាទអង្គរ ដោយមិននាំឲ្យទទួលស្គាល់តាមផ្លូវច្បាប់ (នូវរបបគ្រប់គ្រងទីក្រុងភ្នំពេញ) នោះឡើយ ដើម្បីនាំមកនូវជំនួយអន្តរជាតិដូចជាជំនួយពីអង្គការយូណេស្កូជាដើម ៣- អនុញ្ញាតឲ្យអ្នកបច្ចេកទេសខ្មែរ រួមជាមួយអ្នកបច្ចេកទេសអន្តរជាតិនៃអង្គការយូណេស្កូ ចេញចូលតំបន់នេះដោយមានការធានាសន្តិសុខអំពីអន្តរជាតិ ។

នៅថ្ងៃទី ៤ កក្កដា ១៩៨៧ លោក អាម៉ាឌូ ម៉ាតា ម៉ាក់បូវ (Amadou-Mahtar M'Bow) អគ្គនាយកអង្គការយូណេស្កូ បានផ្ញើលិខិតឆ្លើយតបចំពោះសំណើរបស់លោកតា សឺន សាន ថា[236] អង្គការយូណេស្កូបានយកចិត្តទុកដាក់ក្នុងបញ្ហាអភិរក្ស និង ការពារប្រាសាទអង្គរវត្ត ហើយលោកអគ្គនាយកក៏ធ្លាប់លើកយកបញ្ហានេះមកជជែកជាច្រើនដង នាសម័យប្រជុំរបស់ក្រុមប្រឹក្សាប្រតិបត្តិនៃអង្គការយូណេស្កូនេះដែរ ។ លោកអគ្គនាយកសន្យាថានឹងធ្វើគ្រប់យ៉ាងក្នុងអំណាចរបស់អង្គការយូណេស្កូ ដើម្បីឲ្យសំរេចគោលដៅនេះ ។ បន្ទាប់មក សំណើរបស់លោកតា សឺន សាន ក៏ស្ងាត់បាត់ឈឹងរហូតមក ។ គំនិតផ្តួចផ្តើមនយោបាយយកតំបន់អង្គរ-សៀមរាប ជាតំបន់វប្បធម៌អន្តរជាតិ ជាតំបន់អព្យាក្រឹត្យគ្មានកងទ័ព ឬ គ្មានកងប្រដាប់អាវុធនេះ មិនបានឈានទៅទទួលផ្លែផ្កាឡើយ ដោយខ្វះការគាំទ្រពីគ្រប់ភាគីដែលពាក់ព័ន្ធនៅក្នុងជម្លោះ ។ ភាគីភ្នំពេញដែលកំពុងស្វែងរកការទទួលស្គាល់ពីអន្តរជាតិ ប្រាកដជាមិនអាចទទួលយកគំនិតនេះទេ ព្រោះថ្នាក់ដឹកនាំទីក្រុងភ្នំពេញក៏អាចមើលឃើញនូវតម្លៃដ៏ធំធេងរបស់ប្រាសាទអង្គរ ហើយក៏អាចយកបញ្ហាពាក់ព័ន្ធតំបន់ប្រាសាទទាំងនេះ មកធ្វើជាកម្មវត្ថុមួយនៃការតស៊ូស្វែងរកការទទួលស្គាល់អន្តរជាតិបានដែរ ។ ដូច្នេះចំណុចដែលចង់គេចចេញពីការទទួលស្គាល់រដ្ឋាភិបាល

[236] Amadou-Mahtar M'Bow, Le Directeur général, UNESCO, (à) S. Exc. Monsieur Son Sann, Premier Ministre du Kampuchea Démocratique, Paris, le 4 juillet 1987.

ក្រុងភ្នំពេញ ជាចំណុចដែលនាំឲ្យបរាជ័យ ។ ក៏ប៉ុន្តែ ចំពោះលោកតា សឺន សាន យ៉ាងហោចណាស់ ក៏លោកតាចង់ឲ្យអន្តរជាតិមើលឃើញថា លោកតាជាអ្នកយកចិត្តទុកដាក់ក្នុងការថែរក្សាការពារប្រាសាទអង្គរជាងអ្នកដឹកនាំឯទៀត ។ ម្យ៉ាងទៀត លោកតាក៏ចង់បង្ហាញថា រ.ជ.រ.ប.ខ.ក៏ចង់ឲ្យមានការជួបចរចាគ្នារវាងភាគីខ្មែរដែរ ទោះជាគំនិតផ្តួចផ្តើមរបស់លោកតានោះ មិនមានលក្ខណៈប្រាកដនិយមក៏ដោយ ។

ខ្ញុំទៅឃោសនាជាថ្មីនៅអឺរ៉ុប

សូមបញ្ជាក់ថា ក្នុងខែ កុម្ភៈ និង មីនា ១៩៨៧ នោះ រូបខ្ញុំបានត្រូវចាត់ឲ្យទៅបំពេញបេសកកម្មនៅទ្វីបអឺរ៉ុប ដើម្បីឃោសនារកការគាំទ្រពីសំណាក់ជនភៀសខ្លួនខ្មែរចំពោះរ.ជ.រ.ប.ខ. ជាពិសេសចំពោះលោកតា សឺន សាន ក្រោយពេលដែលមានការផ្សព្វផ្សាយថាជំលោះផ្ទៃក្នុងត្រូវបានបញ្ចប់ ។ បេសកកម្មរបស់ខ្ញុំនាពេលនោះមានគោលដៅពង្រឹងការគាំទ្ររបស់សមាជិកសមាជិការ.ជ.រ.ប.ខ. នៅប្រទេសបារាំង បែលហ្សិក ស្វីស និង អាឡឺម៉ង់ ។ ប្រធានបទសំខាន់គឺ ផ្តោតលើគុណសម្បត្តិដឹកនាំរបស់លោកតា សឺន សាន និង បញ្ជាក់ពីលក្ខខណ្ឌអត្តនោម័តរបស់លោកតា សឺន សាន ក្នុងការតែងតាំងលោកឧត្តមសេនីយ សក់ ស៊ុតសាខន ជាអគ្គមេបញ្ជាការក.ជ.រ.ប.ខ.ឡើងវិញ ។ តាមពិតទៅ សង្គ្រាមពាក្យសំដីរវាងក្រុមទាំងពីរនៅតែបន្តជានិច្ច ។ សកម្មភាពរបស់ខ្ញុំ គ្រាន់តែជាការឆ្លើយតបទៅនិងសកម្មភាពឃោសនារបស់ក្រុមលោក សក់ ស៊ុតសាខន ដែលមានលោក យ៉ែម ស៉ារុង លោកវេជ្ជបណ្ឌិត ឃូ គិមយាន និង លោក សំ សុខ ជាដើមជាសកម្មជន ។ សកម្មភាពឃោសនារបស់ខ្ញុំ បានធ្វើឲ្យការគាំទ្ររបស់ជនភៀសខ្លួន សមាជិក សមាជិការបស់រ.ជ.រ.ប.ខ. មានសន្ទុះ និង ភាពសកម្មឡើងវិញយ៉ាងខ្លាំងក្លា នាំឲ្យលោក

ប៉ុង គិមគន ប្រធានការិយាល័យផ្សាយព័ត៌មានរ.ជ.រ.ប.ខ.ប្រចាំទីក្រុងប៉ារីស មានមោទនភាពខ្ពស់ ។ នៅថ្ងៃទី ១៦ មីនា ១៩៨៧ លោក ប៉ុង គិមគន បានផ្ញើលិខិតមួយច្បាប់ជាភាសាបារាំងជូនលោកតាប្រធាន ដើម្បីរាយការណ៍លំអិតអំពីលទ្ធផលជាវិជ្ជមាននៃបេសកកម្មរបស់ខ្ញុំនោះ[237] ។

ពួកយើងមិនដឹងថាសម្តេចយាងទៅព្យុងយ៉ាង ដើម្បីធ្វើអ្វីទេ ?

នៅថ្ងៃទី ១៦ មេសា ១៩៨៧ លោកប្រធានាធិបតី លី សៀននៀន និងលោកនាយករដ្ឋមន្ត្រី ហ្សាវ ហ្ស៊ីយ៉ាង នៃប្រទេសចិនបានផ្ញើសារអបអរសាទរចំពោះខួបកំណើតលើកទី១២ នៃកម្ពុជាប្រជាធិបតេយ្យថ្វាយសម្តេច សីហនុ ក្នុងឋានៈព្រះអង្គជាប្រធានកម្ពុជាប្រជាធិបតេយ្យ ដោយបញ្ជាក់សាជាថ្មីថារដ្ឋាភិបាល និងប្រជាជនចិន នឹងបន្តផ្តល់ការគាំទ្រយ៉ាងរឹងមាំ ដល់ប្រជាជនកម្ពុជាក្នុងបុព្វហេតុដ៏ពិសិដ្ឋនៃការតស៊ូប្រឆាំងអំពើរំលោភឈ្លានពានរបស់វៀតណាម ដើម្បីការពារមាតុភូមិ[238]។ នៅថ្ងៃដដែលនោះ សម្តេច សីហនុ បានឆ្លើយតបវិញ ពីទីក្រុងព្យុងយ៉ាង ជាទីដែលព្រះអង្គគង់នៅ ដោយមានព្រះបន្ទូលជាអាទិ៍ថា ប្រទេសចិន និង កម្ពុជា ជាបងប្អូន ដែលកំពុងសាមគ្គីគ្នា និង នឹងបន្តសាមគ្គីគ្នាតទៅមុខជាយូរអង្វែង និងជាយុទ្ធមិត្តដែលមិនអាចបំបែកចេញពីគ្នាបានឡើយ[239] ។

សូមបញ្ជាក់ថានៅឯទីក្រុងបាងកក ពួកយើងមិនបានដឹងថា សម្តេចយាង

[237] Pong Kim Koan, le Chef du Bureau d' Information du FNLPK, à Son Excellence le Président du FNLPK et Premier Ministre du GCKD, Paris, le 16 mars 1987.

[238] Li Xiannian, Président de la République Polpulaire de Chine, Zao Ziyang, Premier Ministre du Conseil d'Etat de la République Populaire de Chine, à Samdech Norodom Sihanouk, Président du Kampuchea Démocratique, Son Excellence Son Sann, Premier Ministre du Gouvernement de Coalition du Kampuchea Démocratique, Son Excellence Khieu Samphan, Vice-President du Kampuchea Démocratique, Beijing, le 16 avril 1987.

[239] Norodom Sihanouk, Président du Kampuchea Democratique, à Son Excellence Monsieur LI XIANNIAN, Président de la République Populaire de Chine, Son Excellence Monsieur Zao Ziyang, Premier Ministre du Conseil d' Etat de la République Populaire de Chine, Pyong Yang, le 16 Avril 1987.

ទៅទីក្រុងព្យុងយ៉ាងតាំងពីពេលណាទេ ។ ជាទម្លាប់របស់ព្រះអង្គដែលធ្លាប់ប្រកាន់ក្នុងកាលកន្លងមក ប្រសិនបើសម្តេច សីហនុ មានបំណងធ្វើសកម្មភាពនយោបាយអ្វីមួយ ដែលអាចឲ្យថ្នាក់ដឹកនាំចិនមិនពេញចិត្ត ព្រះអង្គតែងយាងចេញពីប្រទេសនេះទៅគង់នៅប្រទេសជប៉ុន ជាពិសេស នៅប្រទេសកូរ៉េខាងជើង ដែលព្រះអង្គមានមិត្តជិតស្និទ្ធម្នាក់គឺ លោកប្រធាន គិម អ៊ីល ស៊ុង ជាអ្នកគាំទ្រយ៉ាងពេញទំហឹង ។ មុននឹងយាងចេញពីទីក្រុងប៉េកាំង សម្តេច សីហនុ បានផ្ញើសារទូរលេខមួយច្បាប់ជូនលោកតា សឺន សាន ដើម្បីសុំបញ្ជីឈ្មោះសមាជិកគណៈប្រតិភូរ.ជ.រ.ប.ខ. ដែលត្រូវចូលរួមក្នុងប្រតិភូផ្លូវការនៃរដ្ឋាភិបាលចម្រុះត្រីភាគី សម្រាប់ទស្សនកិច្ចនៅប្រទេសចិន នាខែ សីហា ១៩៨៧ ខាងមុខ ។ នៅក្នុងសារទូរលេខនោះ សម្តេច សីហនុ បានស្នើឲ្យបញ្ចូលឈ្មោះសមាជិកខ្លះមកពីខាងភាគីលោកឧត្តមសេនីយ សក់ ស៊ុតសាខន កុំដាក់តែខាងលោកតា សឺន សាន ក្នុងបញ្ជីគណៈប្រតិភូនោះ ដើម្បីជា "ឧត្តមប្រយោជន៍នៃចលនាតស៊ូជាតិ"[240]។ ហេតុដូច្នោះហើយទើបលោកតា សឺន សាន បានបញ្ចូលឈ្មោះលោកឧត្តមសេនីយ សក់ ស៊ុតសាខន ជាសមាជិកទី៤ នៃគណៈប្រតិភូរ.ជ.រ.ប.ខ. បន្ទាប់ពីឈ្មោះលោកតា សឺន សាន លោក អ៊ឹម ឈូដេត និង លោក ប៊ុន សាយ សម្រាប់ទស្សនកិច្ចរបស់ថ្នាក់ដឹកនាំរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ នៅប្រទេសចិនក្នុងខែ សីហា ១៩៨៧[241] ។

[240] Norodom Sihanouk, Président du Kampuchea Démocratique, A S.E. Son Sann, Premier Ministre du CGDK, Beijing 11 Mars 1987.
[241] Son Sann, Prime Minister, Coalition Government Democratic Kampuchea, A Son Altesse Royale Samdech Preah Norodom Sihanouk, Président du Kampuchea Démocratique, le 27 avril 1987.

ព្រះអង្គផ្អាកធ្វើប្រធានត្រីភាគី ព្រោះខ្មែរក្រហមរំលោភ

គួររំលឹកថា នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ នាទសវត្សរ៍ឆ្នាំ ១៩៨០ នោះ ខ្មែរក្រហមបានបង្កការរំលោភតាមផ្លូវអាវុធ ទៅលើដៃគូមិនមែនកុម្មុយនីស្តរបស់ខ្លួនជាញឹកញាប់ តាមផែនការដណ្តើមឧត្តមភាពនៅលើសមរភូមិរបស់ពួកគេ ។ ការរំលោភទាំងនោះរួមមានឃាតកម្មទៅលើយុទ្ធជននៃក.ជ.រ.ប.ខ.ផងដែរ ដូចជាក្នុងករណីឃាតកម្មលើរូបប្រធានកងអនុសេនាតូចក.ជ.រ.ប.ខ. ឈ្មោះ ព្រំ ចំរើន នៅស្រុកពួក ខេត្តសៀមរាប នៅថ្ងៃទី ១២ កុម្ភៈ ១៩៨៧ ដែលនាំឲ្យមានការតវ៉ាជាលាយលក្ខណ៍អក្សរពីភាគីយើង ។ នៅក្នុងលិខិតតវ៉ា លោកតា សឺន សាន ក្នុងនាមជារដ្ឋមន្ត្រីទី១ នៃរដ្ឋាភិបាលចម្រុះ និង ជាប្រធានរ.ជ.រ.ប.ខ.បានព្រមានលោក ខៀវ សំផន ថាសកម្មភាពបែបនេះជាអំពើប្រព្រឹត្តិឡើងដោយចេតនា និងគិតទុកជាមុន ព្រមទាំងសុំឲ្យខ្មែរក្រហមបញ្ចប់យ៉ាងឆាប់ ដើម្បីរក្សាយុទ្ធសាមគ្គីភាពក្នុងផ្នែកងកម្លាំងរដ្ឋាភិបាលចម្រុះ[242] ។ ក្រៅពីការរំលោភតាមផ្លូវអាវុធ ពួកខ្មែរក្រហម នៅឆ្លៀតឱកាសកេងយកចំណេញក្នុងការចូលរួមសន្និសីទ ឬ ប្រជុំអន្តរជាតិតែម្នាក់ឯង ដោយលាក់មិនឲ្យដៃគូពីរទៀតដឹង តាមរយៈការក្តោបក្តាប់កិច្ចការបរទេសដែលមានលោក ខៀវ សំផន ជាអ្នកទទួលខុសត្រូវក្នុងជួររដ្ឋាភិបាលចម្រុះ ។

នៅក្នុងលិខិតតវ៉ាលោករដ្ឋមន្ត្រីទី១ សឺន សាន សូមឲ្យខ្មែរក្រហមជួយពង្រឹងស្មារតីសហប្រតិការក្នុងរង្វង់រដ្ឋាភិបាលត្រីភាគី ឲ្យបានរឹងប៉ឹងឡើងវិញឲ្យសមស្របតាមគោលការណ៍រួមរបស់រដ្ឋាភិបាលនេះ[243] ។ ម្យ៉ាងទៀត ការរំលោភរបស់ពួកខ្មែរក្រហម ក៏កើតមានទៅលើកងកម្លាំងរបស់សម្តេច សីហនុ ដែរ មិនមែន

[242] សឺន សាន ប្រធានរ.ជ.រ.ប.ខ និង ជារដ្ឋមន្ត្រីទី១ នៃរដ្ឋាភិបាលចំរុះកម្ពុជាប្រជាធិបតេយ្យ ជូនឯកឧត្តម ខៀវ សំផន អនុប្រធានកម្ពុជាប្រជាធិបតេយ្យទទួលបន្ទុកកិច្ចការបរទេស, ថ្ងៃទី ១៦ ខែមិនា ១៩៨៧ ។

[243] សឺន សាន រដ្ឋមន្ត្រីទី១នៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ជូនឯកឧត្តម ខៀវ សំផន អនុប្រធាន ។

កើតមានតែចំពោះយុទ្ធជនរ.ជ.រ.ប.ខ.នោះឡើយ ។ ការរំលោភបំពានរបស់ខ្មែរក្រហមនេះ ក៏បានក្លាយជាមូលហេតុគ្រប់គ្រាន់សម្រាប់សម្តេច សីហនុ យកមកអាង ដើម្បីដកថយចេញពីខ្មែរក្រហម និង រកវិធីជួបចរចាផ្ទាល់ជាមួយភាគីក្រុងភ្នំពេញ ។ នៅថ្ងៃទី ៧ ឧសភា ១៩៨៧ ពីទីក្រុងព្យុងយ៉ាង សម្តេច សីហនុ ចេញសេចក្តីប្រកាស តាមបណ្តាញទីភ្នាក់ងារព័ត៌មានអន្តរជាតិថា ព្រះអង្គបានសំរេចព្រះទ័យ ព្យួរភារកិច្ចរបស់ព្រះអង្គជាប្រធានកម្ពុជាប្រជាធិបតេយ្យចាប់ពីថ្ងៃទី ៧ ឧសភា ១៩៨៧ រហូតដល់ថ្ងៃទី ៧ ឧសភា ១៩៨៨ ដោយសំអាងថាពួកខ្មែរក្រហមបានវាយប្រហារទៅលើកងទ័ពរបស់ព្រះអង្គ[244] ។ បន្ទាប់មកទៀត សម្តេចបានគំរាមថានឹងបន្តផ្អាកការងារជាប្រធាននេះតទៅទៀត ក្នុងរយៈពេល ១២ ខែ ម្តងរហូតដល់ពួកខ្មែរក្រហមផ្លាស់ប្តូរនយោបាយរបស់ខ្លួន ឈប់វាយប្រហារមកលើកម្លាំងគាំទ្រព្រះអង្គ និង បញ្ឈប់រាល់អំពើរំលោភសិទ្ធិមនុស្សទាំងអស់នៅក្នុងដំរុំដែនកៀសខ្លួនដែលពួកនេះត្រួតត្រា ។

ក្រុមរ.ជ.រ.ប.ខ.យើងនៅឯទីក្រុងបាងកក ដែលបានទទួលដំណឹងស្តីពីការសម្រេចព្រះទ័យរបស់សម្តេច សីហនុ តែតាមបណ្តាញសារព័ត៌មានអន្តរជាតិនោះ មានការភ្ញាក់ផ្អើល និង មានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះស្ថិរភាពនៃរដ្ឋាភិបាលចម្រុះ ។ នៅក្នុងសារផ្ញើថ្វាយព្រះអង្គ លោកតា សឺន សាន ទូលសម្តេច សីហនុ ថាលោកតានៅសង្ឃឹមថា ព័ត៌មាននោះមិនពិត និង បញ្ជាក់ជាថ្មីថា រ.ជ.រ.ប.ខ. នៅតែគាំទ្រព្រះអង្គយ៉ាងពេញទំហឹង ក្នុងព្រះឋានៈជាប្រធានកម្ពុជាប្រជាធិបតេយ្យ ដែលជាតួនាទីមានលក្ខណៈស្លាប់រស់សម្រាប់បុព្វហេតុនៃការតស៊ូរំដោះជាតិ[245]។

ជាមួយនោះ មេដឹកនាំ រ.ជ.រ.ប.ខ. ក្នុងឋានៈជារដ្ឋមន្ត្រីទី១ នៃរដ្ឋាភិបាល

កម្ពុជាប្រជាធិបតេយ្យ ទទួលបន្ទុកកិច្ចការបរទេស, ថ្ងៃទី ៧ ឧសភា ១៩៨៧ ។

[244] បានន័យថា ក្នុងរយៈពេល១២ខែនេះ ព្រះអង្គឈប់ប្រតិបត្តតួនាទីផ្លូវការជាប្រធានកម្ពុជាប្រជាធិបតេយ្យ ។

[245] Son Sann, A Son Altesse Royale Samdech Preah Norodom Sihanouk, Président du Kampuchea Démocratique, Pyong Yang, le 14 Mai 1987.

ចម្រុះ ក៏បានផ្ញើលិខិតមួយច្បាប់ទៀតទៅលោក ខៀវ សំផន ដើម្បីឲ្យខ្មែរក្រហមបញ្ចប់វិបត្តិនេះឲ្យបានឆាប់រហ័ស និង ឲ្យអង្វរករសម្តេច សីហនុ សុំកុំឲ្យព្រះអង្គសំរេចព្រះទ័យបែបនេះ ដែលអាចមានផលវិបាកដល់រដ្ឋាភិបាលចម្រុះ ជាពិសេសចំពោះសហប្រតិបត្តិការរវាងកងទ័ពទាំងបីនៃចលនាតស៊ូ ។ ជាមួយនោះ លោកតា សឺន សាន ក៏បានរំលឹកឡើងវិញថា ការប៉ះទង្គិចខាងផ្លូវអាវុធកើតមាន ទាំងចំពោះកងទ័ពសីហនុនិយម ទាំងចំពោះកងទ័ព រ.ជ.រ.ប.ខ. ជាពិសេស លោកតារំលឹកអំពីឃាតកម្មដែលរ.ជ.រ.ប.ខ.បានធ្វើការតវ៉ាទៅលោក ខៀវ សំផន តាមលិខិត ចុះថ្ងៃទី ១៩ មីនា ១៩៨៧ ដែលលោក ខៀវ សំផន បានសន្យាថានឹងធ្វើការស៊ើបអង្កេតតាមសំបុត្រចុះថ្ងៃទី ២១ មីនា ១៩៨៧ ក៏ប៉ុន្តែ រួចមកក៏នៅស្ងាត់ឈឹងរហូត[246] ។

ខ្មែរក្រហមភ័យខ្លាចបាត់អាសនៈ

គួររំលឹកថា នៅឯទីក្រុងវ៉ាស៊ិនតោនឯនោះ ចលនាទាមទារឲ្យមានការកាត់ទោសពួក ប៉ុល ពត អំពីបទប្រល័យពូជសាសន៍ ក៏កាន់តែទទួលបាននូវការគាំទ្រពីមជ្ឈដ្ឋានអ្នកនយោបាយអាមេរិក ជាពិសេសក្នុងចំណោមសមាជិកសភាដែលកាន់តែធ្វើឲ្យក្រុមប្រទេសអាស៊ានព្រួយបារម្ភថែមទៀត ។ ពួកខ្មែរក្រហម មានការខ្វាយខ្វល់ជាខ្លាំងចំពោះឥរិយាបថរបស់សម្តេច សីហនុ នេះ ។ ពួកគេក៏សុំចូលគាល់ព្រះអង្គនៅទីកន្លែង និង ពេលវេលាណាក៏ដោយឲ្យតែព្រះអង្គអនុគ្រោះ ។ តាមសារព័ត៌មានចេញផ្សាយនៅទីក្រុងបាងកក លោក ខៀវ សំផន និង សុន សេន បានផ្ញើសារថ្វាយសម្តេច សុំឲ្យព្រះអង្គពិចារណាឡើងវិញ អំពីការសំរេចផ្អាកការងាររបស់ព្រះអង្គជាប្រធានកម្ពុជាប្រជាធិបតេយ្យនេះ ព្រោះថាខ្មែរក្រហមភ័យខ្លាចបាត់បង់អា

[246] សឺន សាន រដ្ឋមន្ត្រីទី១ ជូនចំពោះឯកឧត្តម ខៀវ សំផន, អនុប្រធានកម្ពុជាប្រជាធិបតេយ្យ ទទួលបន្ទុកកិច្ចការបរទេស, ថ្ងៃទី ១៤ ឧសភា ១៩៨៧ ។

សន:របស់រដ្ឋាភិបាលចម្រុះនៅអង្គការសហប្រជាជាតិ ។ ពួកគេសន្យាថាសុខចិត្ត ធ្វើការទូទាត់ជាថវិកាសងជម្ងឺចិត្តដល់គ្រួសារយុទ្ធជនរបស់សម្តេច ដែលបានបាត់បង់ជីវិត[247] ។ ជាមួយនោះ លោក ខៀវ សំផន ក៏ព្រលយពាក្យឲ្យដឹងថា គាត់មិនជឿថាសម្តេច សីហនុ សម្រេចដកថយនេះ ដោយសារសកម្មភាពអមិត្តរបស់ខ្មែរក្រហមនោះទេ ។ គំនឹតបែបនេះ ក៏ស្របតាមការវិភាគរបស់អ្នកសង្កេតការណ៍មួយចំនួន ដែលបកស្រាយថា ការសម្រេចព្រះទ័យរបស់សម្តេចគឺ ជាកលល្បិច ឬ យុទ្ធវិធីនយោបាយ ដើម្បីបង្ហាញនូវភាពទន់ភ្លន់ និង សេរីភាពរបស់ព្រះអង្គក្នុងការស្វែងរកលទ្ធភាពជួបចរចាផ្ទាល់ជាមួយក្រុងហាណូយ ឬ ក្រុងភ្នំពេញ[248]។ អ្នកការទូតមួយចំនួននៅទីក្រុងបាងកក បានបង្ហើបឲ្យកាសែតបាងកកប៉ុស្តចេញផ្សាយថ្ងៃទី ៥ មិថុនា ១៩៨៧ ថាកាលពីពីរសប្តាហ៍មុនវៀតណាមសុខចិត្តទទួលជួបចរចាជាមួយសម្តេច សីហនុ នាពេលមួយ នៅពេលព្រះអង្គយាងទៅដល់ប្រទេសបារាំង[249] ។ ក៏ប៉ុន្តែ នៅក្នុងទូរលេខផ្ញើទៅព្រះរាជបុត្រព្រះអង្គគឺ ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ នៅទីក្រុងបាងកក សម្តេច សីហនុ ចោទថាមានតែក្រុមអ្នកបន្ទាបបន្ថោកព្រះអង្គទេ (détracteurs) ដែលអាចប្រឌិតរឿងថា ព្រះអង្គរិះគន់ខ្មែរក្រហមគ្រាន់តែជាលេសដើម្បីទៅចរចាផ្ទាល់ជាមួយវៀតណាម និង ជាមួយរដ្ឋាភិបាល ហេង សំរិន-ហ៊ុន សែន ។ សម្តេចបញ្ជាក់ទៀតថា ព្រះអង្គគ្មានទំនាក់ទំនងអ្វីទាំងអស់ជាមួយក្រុងហាណូយ ក្រុងភ្នំពេញ ឬ ក្រុងមូស្គូ ហើយព្រះអង្គក៏គ្មានបំណងបង្កើតទំនាក់ទំនងជាមួយក្រុងទាំងនោះទេ ។ ក៏ប៉ុន្តែ ព្រះអង្គមិនទាត់ចោលទាំងស្រុងនូវជំនួបណាមួយនាពេលខាងមុខឡើយ ដោយសម្តេច សីហនុ ថ្លែងថា "ប្រសិនបើនៅថ្ងៃណាមួយនាពេលខាងមុខខាងភាគីម្ខាងទៀត សុំមកគាល់ខ្ញុំៗនឹងមិនភ្លេចជំរាបសាជា

[247] The Nation, Khmer Rouge Appeal to Sihanouk, June 1, 1987, p. 5.
[248] Nayan Chanda, The Prince Makes Waves, Far Eastern Economic Review, Vol. 136, No 25, June 18, 1987, p. 48.
[249] Bangkok Post, Sihanouk denies he'll talk with Phnom Penh, June 5, 1987.

រណជនឲ្យបានជ្រាបឡើយ" ។ ចំពោះការសុំចូលគាល់ពីសំណាក់លោក ខៀវ សំផន នោះ ព្រះអង្គបដិសេធមិនឲ្យចូលគាល់ព្រះអង្គទេ ដោយសំអាងថាព្រះអង្គ កំពុងមានវិបត្តិខាងសតិអារម្មណ៍(វិបត្តិខាងផ្លូវចិត្ត) ដែលកាន់តែធ្ងន់ធ្ងរឡើងពី ១ ថ្ងៃ ទៅ ១ ថ្ងៃ ។

ជាការពិតណាស់ សម្តេច សីហនុ ប្រាកដជាមិនអាចធ្វើទំនាក់ទំនងផ្ទាល់ ណាមួយជាមួយរដ្ឋាភិបាលក្រុងភ្នំពេញបានឡើយ ប្រសិនបើព្រះអង្គនៅតែបំពេញ ការកិច្ចផ្លូវការជាប្រធានកម្ពុជាប្រជាធិបតេយ្យ ព្រោះថាទាំងចិនទាំងខ្មែរក្រហម និង ប្រទេសខ្លះនៃក្រុមអាស៊ានផង សុទ្ធតែប្រកាន់គោលជំហរឲ្យមានការជួបចរចា ជាមួយវៀតណាមស្តីពីការដកកងទ័ពវៀតណាមជាមុនសិន មុននឹងនិយាយជាមួយ អ្នកដឹកនាំក្រុងភ្នំពេញ ។ ចំពោះសម្តេច សីហនុ ការដកថយពីកម្ពុជាប្រជាធិបតេយ្យ និង ក្នុងព្រះឋានៈជាអតីតព្រះមហាក្សត្រ បានផ្តល់សេរីភាពដើម្បីឈានទៅបំរើ នយោបាយផ្ទាល់របស់ព្រះអង្គ ។

លោកតា សឺន សាន ទៅស្នាបស្នង់នៅរូម៉ានី

នៅពេលជាមួយនោះ លោកតា សឺន សាន ក៏បានដឹកនាំគណៈប្រតិភូ រ.ជ.រ.ប.ខ. មួយទៅធ្វើទស្សនកិច្ចនៅប្រទេសរូម៉ានី ពីថ្ងៃទី ១៧ ទៅ ១៩ មិថុនា ១៩៨៧ ទោះបីជាសម្តេច សីហនុ បានទូន្មានរួចហើយថា មិនចាំបាច់ទៅជួបលោក ប្រធានាធិបតី សេអូសេស្គូ នោះទេ ដូចខ្ញុំបានរៀបរាប់ពីខាងលើរួចហើយ ។ ក៏ប៉ុន្តែ អ្នកដឹកនាំរ.ជ.រ.ប.ខ.សំអាងថា ទស្សនកិច្ចនោះមានគោលដៅទៅថ្លែងអំណរគុណ ដោយផ្ទាល់មាត់ចំពោះលោកប្រធានាធិបតី សេអូសេស្គូ ដែលបានខំប្រឹងប្រែងរក ដំណោះស្រាយបញ្ហាកម្ពុជា និង ជាមួយនោះ ក៏សុំឲ្យប្រទេសរូម៉ានីជួយរកមធ្យោ

បាយគ្រប់យ៉ាង ដើម្បីបញ្ចប់ទុក្ខវេទនារបស់ប្រជារាស្ត្រខ្មែរ[250] ។ បេសកកម្មរបស់គណៈប្រតិភូយើងនាពេលនោះគ្រាន់បានតែត្រឹមផ្លាស់ប្តូរមតិគ្នាតែប៉ុណ្ណោះ ព្រោះថាលោកតា សឺន សាន ដើរតួនាទីជារដ្ឋមន្ត្រីទី១នៃរដ្ឋាភិបាលចម្រុះត្រីភាគី ដែលមានគោលជំហរនយោបាយទាមទារឲ្យមានការចរចាជាមួយវៀតណាម ស្តីពីការដកកងទ័ពពីកម្ពុជាជាមុនៗនឹងចរចាជាមួយរដ្ឋាភិបាលក្រុងភ្នំពេញ នៅពេលដែលមេដឹកនាំរូម៉ានីណែនាំឲ្យមានការផ្សះផ្សាជានាគ្នាជាមួយក្រុងភ្នំពេញសិននោះ ។ បេសកកម្មនៅប្រទេសរូម៉ានីនោះ ក៏ជាឱកាសមួយសម្រាប់រូបខ្ញុំបានចូលរួមជាសមាជិកប្រតិភូ ។ ប្រទេសរូម៉ានីជាប្រទេសកុម្មុយនីស្តដំបូងគេដែលខ្ញុំបានទៅដល់ ។ ក្រៅពីការងារនយោបាយដូចខ្ញុំបានលើកឡើងខាងលើ ខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះកិច្ចការពិធីការ ។ មន្ត្រីពិធីការរូម៉ានីប្រកាន់ភាពហ្មត់ចត់ណាស់ទាំងពេលវេលាទាំងទីកន្លែង ត្រង់ណាត្រូវឈរត្រង់ណាត្រូវអង្គុយ ខាងមុខខាងក្រោយ ពេលលើកម្ហូបអាហារតើពេលណាដែលគេត្រូវដាក់ជូនភ្ញៀវឲ្យបានព្រមៗគ្នាជាដើម ឧទាហរណ៍ នៅពេលនាយករដ្ឋមន្ត្រីគេមកដល់ តើប្រធានគណៈប្រតិភូយើងត្រូវដើរទៅមុខប៉ុន្មានជំហាន នាយករដ្ឋមន្ត្រីគេឈានមកប៉ុន្មានជំហាន មុននឹងចាប់ដៃគ្នា។

នៅក្នុងគណៈប្រតិភូ រូបខ្ញុំត្រូវបានផ្តល់ឋានៈស្មើរដ្ឋមន្ត្រី ។ មនុស្សជំនិតរបស់លោកតា សឺន សាន ម្នាក់ដែលមានអាយុច្រើនជាងខ្ញុំ បានប្រាប់មន្ត្រីពិធីការរូម៉ានីថាគាត់ មានឋានៈស្មើទេសរដ្ឋមន្ត្រី ។ តាមប្រព័ន្ធបារាំង ទេសរដ្ឋមន្ត្រី (Ministre d'Etat) មានឋានៈខ្ពស់ជាងរដ្ឋមន្ត្រី ។ ពាក្យនេះគេបកប្រែជាភាសាអង់គ្លេសថា Senior Minister ។ ក៏ប៉ុន្តែបើគេបកប្រែពីភាសាបារាំង Ministre d'Etat ជាភាសាអង់គ្លេស តាមពាក្យមួយម៉ាត់ៗគេអាចបកថា Ministre ជា Minister រីឯ Etat ជា State ដូច្នេះ Ministre d'Etat បកប្រែជា State Minister

[250] Coalition Government of Democratic Kampuchea, Office of the Prime Minister, Communiqué de Presse, Bucarest le 17 Juin 1987.

ដែលតាមប្រព័ន្ធសហព័ន្ធ (Federal) មានឋានៈទាបជាងរដ្ឋមន្ត្រីទៅវិញ ។ មន្ត្រីពិធីការរូម៉ានី ប្រហែលជាគិតថាមនុស្សជំនិតរបស់លោកតា សឺន សាន នោះមានឋានៈត្រឹម State Minister តែប៉ុណ្ណោះ ទើបគេចាត់កន្លែងឲ្យគាត់អង្គុយបន្ទាប់ពីខ្ញុំ ធ្វើឲ្យគាត់មានការអាក់អន់ចិត្តជាខ្លាំង ។

គំរោងជួបចរចាគ្នា តាមរូបភាពទីទៃៗ

គួររំលឹកថាតាំងពីឆ្នាំ ១៩៨៥ រៀងមក ទោះជាមានការប្រើកម្លាំងយោធាវាយប្រហារគ្នាទៅវិញទៅមកយ៉ាងខ្លាំងក្លាយ៉ាងណាក៏ដោយ ក៏គំនឹតផ្តួចផ្តើមឲ្យមានការជួបចរចាគ្នារវាងគូបដិបក្ខកើតមានជាហូរហែដែរ ក្រោមរូបមន្តផ្សេងៗដូចជាចរចាជាក្រុមៗក្បែរៗគ្នា (Proximity talks) និង ជួបគ្នាក្នុងពេលជប់លៀងកេសដ្ឋៈកុកតែ (Cocktail Party) ។ នៅថ្ងៃទី ៧ ឧសភា ១៩៨៧ លោកតា សឺន សាន ក្នុងឋានៈជារដ្ឋមន្ត្រីទី១ នៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ បានចេញសេចក្តីប្រកាសមួយ អបអរសាទរចំពោះការផ្តួចផ្តើមគំនឹតរបស់លោករដ្ឋមន្ត្រីការបរទេសឥណ្ឌូណេស៊ី ម៉ុកតា កាស៊ុម៉ាដម៉ាថា (Mochtar Kasumaadmaja) ដែលស្នើរៀបចំជប់លៀងកេសដ្ឋៈកុកតែមួយ នៅទីក្រុងហ្សាកាតា ។ តាមវិធីនេះគូបដិបក្ខអាចជួបគ្នាបាន ព្រោះនេះគ្រាន់តែជាការជួបគ្នាក្រៅផ្លូវការតែប៉ុណ្ណោះ ។ បើមិនធ្វើតាមវិធីនេះទេ គូបដិបក្ខមិនងាយជួបនិយាយគ្នាបានឡើយ ដោយហេតុថាភាគីនីមួយៗមានគោលជំហរនយោបាយខុសគ្នាខ្លាំងពេក ។ នៅក្នុងសេចក្តីប្រកាសនោះ លោកតា សឺន សាន ថ្លែងថាយើងខ្ញុំរីករាយណាស់ ប្រសិនបើវៀតណាមទទួលយល់ព្រមចូលរួមដែរ ក្នុងន័យដែលលោកតាចង់បញ្ជាក់បន្ថែមថាជម្លោះនាពេលនោះជាជម្លោះរវាងកម្ពុជា និង វៀតណាម មិនមែនជាសង្គ្រាមស៊ីវិល

រវាងខ្មែរ និង ខ្មែរនោះទេ[251] ដែលជាគោលដំហរផ្ទុយទាំងស្រុងពីគោលដំហរវៀតណាម ។ ទោះជាគំនឹតជប់លៀងកុកតែនេះ បានទទួលការគាំទ្រពីប្រទេសមួយចំនួនក៏ដោយ ក៏នៅទីបំផុតត្រូវទទួលបរាជ័យ ។ ដូច្នេះ ន.ជ.ន.ប.ខ. និង លោកតា សឺន សាន គ្រាន់តែបង្ហាញរូបភាពខាងក្រៅថា មិនមែនមានតែសម្តេច សីហនុ ទេ ដែលចេះស្វែងរកដំណោះស្រាយជម្លោះតាមការចរចា លោកតាក៏ខំដែរ ។ តែលោកតាមិនហ៊ានឈានទៅរកការចរចាផ្ទាល់ជាមួយភាគីភ្នំពេញដូចសម្តេច សីហនុ នោះឡើយ ។

ដូចបានបញ្ជាក់រួចហើយក្នុងវគ្គមុនៗ ភាគីក្រុងភ្នំពេញប្រាកដជាទទួលផលប្រយោជន៍ច្រើនក្នុងការជួបចរចាផ្ទាល់ជាមួយសម្តេច សីហនុ ដូច្នេះអ្នកដឹកនាំខ្មែរនៅភ្នំពេញ ជាពិសេសលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ត្រូវតែបន្តបេសកកម្មនេះឲ្យបានសម្រេច ។ ផលប្រយោជន៍សំខាន់ជាងគេនោះគឺ ការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត ឲ្យបានជាស្ថាពរ ។ ចំណែកសម្តេច សីហនុ ពិតជាទតឃើញឧបសគ្គធំៗក្នុងការស្វែងរកដំណោះស្រាយនយោបាយ ដើម្បីបញ្ចប់សង្គ្រាមនៅកម្ពុជា ក៏ប៉ុន្តែព្រះអង្គក៏ពិតជាបានប្តេជ្ញាថាដំណោះស្រាយបែបណាក៏ដោយ ក៏ត្រូវតែសាកល្បង ។ ម្យ៉ាងទៀតសម្តេច សីហនុ ក៏បានវាយតម្លៃច្បាស់អំពីធាតុពិតរបស់របបខ្មែរក្រហម ដែលព្រះអង្គអាចយល់ថាត្រូវតែរកវិធីគេចចេញពីពួកនេះ ។ ជាការពិតណាស់ ព្រះអង្គអាចផ្លាស់ប្តូរសម្ព័ន្ធភាពបាន ឲ្យតែអាចកសាងសន្តិភាព និងរំដោះកម្ពុជាពីខ្មែរក្រហមបាន ។ គំនឹតគេចចេញពីខ្មែរក្រហមរបស់ព្រះអង្គនេះ ក៏ស៊ីសង្វាក់គ្នាជាមួយនយោបាយផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត របស់អ្នកដឹកនាំក្រុងភ្នំពេញ ដែលជាកត្តានាំឲ្យមានការស្វែងរកការជួបចរចាគ្នាដោយផ្ទាល់ក្នុងឋានៈជាខ្មែរដូចគ្នា ។

[251] Statement of H. E. Son Sann, Prime Minister of the Coalition Government of Democratic Kampuchea, May 8, 1987.

មិត្តភាពរវាងលោក យ៉ាស្សែរ អារ៉ាហ្វាត់ និង សម្តេច សីហនុ

នៅទីក្រុងព្យុងយ៉ាង ឆ្ងាយពីភ្នែករបស់ចិន សម្តេច សីហនុ ប្រាកដជាមានភាពងាយស្រួលក្នុងការបំពេញការងារទូតមួយចំនួន ទៅតាមគោលជំហរនយោបាយផ្ទាល់របស់ព្រះអង្គ ។ ម្យ៉ាងទៀត នៅទីក្រុងព្យុងយ៉ាង សម្តេច សីហនុ ក៏មានអ្នកការទូតដៃលព្រះអង្គអាចទុកព្រះទ័យ អាចធ្វើជាអ្នកនាំពាក្យ ឬ មេអណ្តើករវាងព្រះអង្គ និង ភាគីម្ខាងទៀតបានដោយប្រសិទ្ធភាព ។ អ្នកនាំពាក្យ ឬ មេអណ្តើកនោះគឺ លោកឯកអគ្គរដ្ឋទូតនៃអង្គការរំដោះប៉ាឡេស្ទីន ប្រចាំប្រទេសកូរ៉េខាងជើង ឈ្មោះ សាហ្វារីនី (Sapharini)[252] ។ ដោយសារនយោបាយគាំទ្រការតស៊ូប្រយុទ្ធរបស់ប្រជាជនប៉ាឡេស្ទីន តាំងពីសម័យដៃលព្រះអង្គកាន់អំណាចជំនាន់សង្គមរាស្ត្រនិយមរៀងមក សម្តេច សីហនុ បានក្លាយជាមហាមិត្តម្នាក់របស់សពលោកប្រធាន យ៉ាស្សែរ អារ៉ាហ្វាត់ (Yasser Arafat) នៃអង្គការរំដោះប៉ាឡេស្ទីន ។ រូបខ្ញុំ (អៀង មូលី) ដៃលមានកព្វសំណាងបានចូលរួមក្នុងគណៈប្រតិភូជាន់ខ្ពស់របស់កម្ពុជា នៅសន្និសីទកំពូលនៃចលនាប្រទេសមិនចូលបក្សសម្ព័ន្ធនៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូណេស៊ី នៅឆ្នាំ ១៩៩២ ដឹកនាំដោយសម្តេច សីហនុ ព្រះប្រធានក្រុមប្រឹក្សាជាតិជាន់ខ្ពស់ អេស អិន ស៊ី បានឃើញផ្ទាល់ភ្នែកនូវមិត្តភាពដ៏ធំធេងរវាងរដ្ឋបុរសទាំងពីរ ។ នាពេលឈប់សម្រាកមួយ ចន្លោះអង្គប្រជុំនៃសន្និសីទ ក្នុងសាលដ៏ធំ ខ្ញុំឃើញលោកប្រធាន យ៉ាស្សែរ អារ៉ាហ្វាត់ ក្នុងឯកសណ្ឋានប៉ារ៉ា កាំភ្លើងខ្លីនៅនិងចង្កេះ ពាក់មួកជាមួយក្រមាដៃលជានិមិត្តសញ្ញាអារ៉ាប់របស់គាត់ ដើរកាត់ហ្វូងប្រមុខរដ្ឋ និង ប្រមុខរដ្ឋាភិបាល តម្រង់មកអាសនៈកម្ពុជា ដើម្បីមកឱបរឹតបើប

[252] ហ៊ុន សែន, ១០ ឆ្នាំនៃដំណើរកម្ពុជា ១៩៧៩-១៩៨៩, ទំព័រ ១៦៨, គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ, ពោធិពុម្ព ណុប បូផាន់ ភ្នំពេញ ១៩៨៨ ។

សម្តេច សីហនុ យ៉ាងស្និទ្ធស្នាលបំផុត ។ យ៉ាងនេះហើយ ទើបនៅទីក្រុងព្យុងយ៉ាង មានលេចឮដំណឹងថាសម្តេច សីហនុ បានត្រៀមជួបជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅខែ មិថុនា ១៩៨៧ ក៏ប៉ុន្តែ បន្ទាប់ពីមានជំនួបរវាងលោកនាយករដ្ឋ មន្ត្រីស្តីទីនៃប្រទេសចិន ជាមួយអ្នកម្នាង ម៉ូនិច គំរោងនោះត្រូវបានបោះបង់ចោល ទៅវិញ ។

ខ្មែរក្រហមរិះគន់សម្តេចថាធ្លាក់ក្នុងអន្ទាក់របស់វៀតណាម

កាលសម័យនោះ ពួកយើងនៅឯទីក្រុងបាងកក ពុំបានដឹងពីគំរោងជួបចរចាគ្នានោះទេ ។ ពួកយើងទទួលបានព័ត៌មាននេះ នៅពេលក្រោយៗទៀតតែប៉ុណ្ណោះ តាមរយៈបណ្តាញទីភ្នាក់ងារអន្តរជាតិ ។ ម្យ៉ាងទៀត ពួកយើងក៏ពុំមានឯកសារផ្លូវការពាក់ព័ន្ធនិងគំរោងជំនួបនេះដែរទេ ។ គួរបញ្ជាក់ថា នៅឯទីក្រុងប៉េកាំងឯនោះវិញ ទូតរបស់ខ្មែរក្រហមបានធ្វើសកម្មភាពលាងខ្លួន កែខ្លួន តាមស្ថានទូតនានា ដើម្បីឲ្យមជ្ឈដ្ឋានទូតយល់ថាការសម្រេចព្រះទ័យរបស់សម្តេច សីហនុ ផ្អាកការងារជាប្រធានកម្ពុជាប្រជាធិបតេយ្យនោះ មិនមែនដោយសារអំពើខុសឆ្គងរបស់ពួកខ្មែរក្រហមនោះទេ តែគឺជាការគិតគូរកវិធីថ្មីផ្ទាល់របស់ព្រះអង្គឯណោះទេដែលខ្មែរក្រហមចោទថាព្រះអង្គកំពុងធ្លាក់ក្នុងអន្ទាក់របស់វៀតណាម (Accuser d'être tombé dans le piège des Vietnamiens) ។ សកម្មភាពការទូតរបស់ខ្មែរក្រហមនេះ បានធ្វើឲ្យអ្នកម្នាង ម៉ូនិច ព្រះជាយាសម្តេច សីហនុ មានការមិនពេញចិត្តជាខ្លាំង ព្រមទាំងបានព្រមានថា នឹងកាត់បន្ថយទំនាក់ទំនងជាមួយពួកនេះ មិនឲ្យដូចពីមុនទៀតទេនាពេលអនាគត[253] ។

ចំពោះសម្តេច សីហនុ វិញព្រះអង្គនៅតែបន្តបង្ហាញឲ្យឃើញរូបភាពថាព្រះ

[253] Monique Sihanouk, Chang Sou On, 22 Juillet 1987.

អង្គគង់នៅឆ្ងាយគឺ មិនសកម្មខ្លាំងក្លាទៀតទេ ជាមួយពួកខ្មែរក្រហម ក៏ប៉ុន្តែព្រះអង្គ ក៏គិតគូរ មិនធ្វើអ្វីឲ្យចិនអាក់អន់ចិត្តពេកដែរ ។ ពីទីក្រុងព្យុងយ៉ាង ព្រះអង្គណែនាំ ឲ្យលោក ចាន់ យូរ៉ាន់ ឯកអគ្គរដ្ឋទូតខ្មែរក្រហម ប្រចាំទីក្រុងប៉េកាំងអនុវត្តតាម នៅពេលព្រះអង្គយាងត្រឡប់ទៅប្រទេសចិនវិញនៅខែ សីហា ខាងមុខ ដើម្បីដឹក នាំគណៈប្រតិភូជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ ធ្វើទស្សនកិច្ចផ្លូវការនៅប្រទេសចិន ដូចតទៅ៖ -មិនផ្តល់កិច្ចសម្ភាសន៍ដល់អ្នកកាសែត វិទ្យុ ឬ ទូរទស្សន៍ណាមួយ ឡើយ -សុំការអនុញ្ញាតពីថ្នាក់ដឹកនាំចិន ដើម្បីកុំឲ្យព្រះអង្គផ្តល់កិច្ចសម្ភាសន៍ដល់ អ្នកកាសែត វិទ្យុ ឬ ទូរទស្សន៍រាប់ទាំងកាសែត វិទ្យុ និង ទូរទស្សន៍ចិន ក្នុងនោះមាន ទីភ្នាក់ងារសីនហួរផង -សម្តេចមិនធ្វើជាអធិបតីនៃអង្គប្រជុំគណៈរដ្ឋមន្ត្រីត្រីភាគី ឡើយ -នៅក្នុងឱកាសនៃការគង់ប្រថាប់នៅទីក្រុងប៉េកាំង សម្តេចអាចប្រទានសវ នាការជាលក្ខណៈឯកជន និង ដោយគ្មានវត្តមានអ្នកកាសែត វិទ្យុ ឬទូរទស្សន៍ណា ទាំងអស់ ចំពោះ ឯ. ឧ. ខៀវ សំផន និង សវនាការមួយទៀតជូន ចំពោះ ឯ. ឧ. សឺន សាន ប្រសិនបើអស់លោកណាមួយចង់សន្ទនានយោបាយជាមួយព្រះអង្គ - នៅទីបញ្ចប់នៃទស្សនកិច្ចរបស់គណៈប្រតិភូ សម្តេចមិនចូលរួមក្នុងសន្និសីទសារ ព័ត៌មានទេ តែព្រះអង្គអាចអានអត្ថបទនៃសេចក្តីថ្លែងការណ៍រួមរបស់សមាសភាព ត្រីភាគី អត្ថបទដែលលោក ខៀវ សំផន និង ភាគីខ្មែរក្រហមជាអ្នកតាក់តែងជា ភាសាខ្មែរ និង ដោយទទួលបានការឯកភាពពីលោកតា សឺន សាន[254]។

[254] Norodom Sihanouk, Note pour S.E. Chan Youran, Ambassadeur du Kampuchea Démocratique en R. P. de Chine, Pyongyang, le 11 Juillet 1987.

ចិនថា មិនទាន់ដល់ពេលចរចាទេ

នៅថ្ងៃទី ១៤ កក្កដា ១៩៨៧ សម្តេច សីហនុ ជួបជាមួយអ្នកការទូតអូទ្រីស ដែលបានមកគាល់ព្រះអង្គនៅទីក្រុងព្យុងយ៉ាង ដើម្បីទូលថារដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម បានសុំឲ្យរដ្ឋាភិបាលអូទ្រីសជួយធ្វើអន្តរាគមន៍ចំពោះព្រះអង្គ ក្នុងបំណងឲ្យមានការជួបគ្នានៃភាគីខ្មែរទាំង ៤ គឺ៖ ហ៊ុន សិន ប៊ិច រ.ជ.រ.ប.ខ កម្ពុជាប្រជាធិបតេយ្យ ឬ ខ្មែរក្រហម និង សាធារណរដ្ឋប្រជាមានិតកម្ពុជា នៅទីក្រុងវីយែននៃប្រទេសអូទ្រីស តាមរូបមន្តជប់លៀងកេសជ្ជៈកុកតែ ។ ចំពោះសំណើនេះ សម្តេច សីហនុ ឆ្លើយថាការជួបប្រជុំបែបនេះ មិនអាចធ្វើបានទេ ព្រោះពួកខ្មែរក្រហមប្រាកដជានឹងដំទាស់មិនខានឡើយ ។ ដូច្នេះ អ្នកចូលរួមប្រជុំនឹងមានតែពីរភាគីទេគឺ៖ ហ៊ុនសិនប៊ិច និង សាធារណរដ្ឋប្រជាមានិតកម្ពុជា ដោយសម្តេចចាត់ទុកថា រ.ជ.ប.ខ និង ខ្មែរក្រហមនឹងប្រកាន់យកគោលនយោបាយតែមួយគឺគ្មានការចរចាផ្ទាល់ជាមួយភាគីភ្នំពេញ បើគ្មានការចរចាជាមួយវៀតណាមជាមុនទេនោះ ។ តាមពិតទៅសម្តេច សីហនុ ជ្រាបច្បាស់ណាស់ថាលោកតា សឺន សាន មិនហ៊ានធ្វើអ្វីឲ្យចិនខឹងសម្បារនោះឡើយ ។ ក្នុងករណីដែលមានភាគីចូលរួមតែពីរបែបនេះ សម្តេច សីហនុ ណែនាំអ្នកការទូតអូទ្រីសនោះឲ្យរៀបចំជាសិក្ខាសាលាអន្តរជាតិវិញ តែព្រះអង្គបញ្ជាក់ថាបើសិក្ខាសាលានេះមិនបានរៀបចំឡើងដោយរដ្ឋាភិបាលអូទ្រីសទេ ព្រះអង្គក៏មិនចូលរួមដែរ ។ សម្តេចបានបញ្ជាក់ថារូបមន្តសិក្ខាសាលាមានភាពទន់ភ្លន់ ជាងរូបមន្តជប់លៀងកេសជ្ជៈកុកតែ ព្រោះថាបើមានភាគីណាមិនចូលរួម ក៏មិនបង្កើតឧបសគ្គធ្វើឲ្យរាំងស្ទះដល់ការរួមប្រជុំសិក្ខាសាលាដែរ ។ ម្យ៉ាងទៀត ប្រសិនបើនៅក្នុងសិក្ខាសាលាមានតំណាងប្រទេសជាច្រើនចូលរួមដូចជាប្រទេសបារាំង រូម៉ានី ស៊ុយអែដ ឥណ្ឌូណេស៊ី ម៉ាឡេស៊ី

អូទ្រីសជាដើម អ្វីដែលសិក្ខាសាលាស្នើសុំដល់ភាគីពាក់ព័ន្ធក្នុងជំលោះ អាចជាការគាបសង្កត់ខាងផ្លូវចិត្ត (ឬ ផ្នែកសីលធម៌) (pression morale) មួយដ៏ធំទៅលើភាគីពាក់ព័ន្ធទាំងនោះ ឲ្យបន្ធោបន្ធន់ឥរិយាបថរបស់ខ្លួនឈានទៅរកការសំរុះសំរួលគ្នា[255] ដែលគេកំពុងត្រូវការជាចាំបាច់បំផុតនាពេលនោះ ។

បើមើលតាមសកម្មភាពការទូតនៅត្រីមាសទី ៣ នៃឆ្នាំ ១៩៨៧ នោះ គំនឹតផ្តួចផ្តើមឲ្យមានការជួបចរចាគ្នា ហាក់ដូចជាឈានទៅមុខជានិច្ច ។ ក៏ប៉ុន្តែប្រទេសមហាអំណាចដែលមានតួនាទីសំខាន់ ក្នុងបញ្ហាកម្ពុជាយល់ឃើញថាពេលវេលានៅមិនទាន់មកដល់នៅឡើយទេ ។ នៅខែ សីហា ១៩៨៧ លោករដ្ឋមន្ត្រីការបរទេសថៃ សិទ្ធិ សារ៉ែតសីលា បានថ្លែងជាសាធារណៈថាលោកបានជួបមេដឹកនាំចិននៅឯប្រទេសចិន ហើយថានៅក្នុងជំនួបជាមួយលោក តេង ស៊ាវពីង នោះ មេដឹកនាំចិនរូបនេះបានណែនាំប្រទេសអាស៊ានថា វៀតណាមមិនទាន់កែប្រែគោលជំហរនៅឡើយទេ ដូច្នេះសកម្មភាពអ្វីដែលប្រញាប់ប្រញាល់ពេក អាចនាំឲ្យបញ្ហាកាន់តែស្មុគស្មាញសាំញ៉ាំថែមទៀត[256] ។ តាមបណ្តាញព័ត៌មានអន្តរជាតិ លោក សិទ្ធិ សារ៉ែតសីលា ចោទប្រកាន់វៀតណាមថា ជាអ្នកបំផ្លាញរូបមន្តដប់លៀងកុកតៃរបស់អាស៊ានដែលគេថាបានព្រមព្រៀងគ្នាជាគោលការណ៍រួចហើយ ។ ក៏ប៉ុន្តែវៀតណាមបានបរិហារថាសំណើរបស់អាស៊ាននាពេលនោះ មានគោលដៅបង្ហាញរូបភាពឲ្យឃើញថាក្រុងហាណូយជាអ្នកឈ្លានពានកម្ពុជា[257] ។ ទាំងនេះហើយដែលធ្វើឲ្យកិច្ចការទូតនៅពេលនោះ មិនបានសម្រេចជោគជ័យ ។

ជាមួយគ្នានោះលោក សិទ្ធិ សារ៉ែតសីលា បានថ្លែងថានៅក្នុងជំនួបជាមួយសម្តេច សីហនុ នៅទីក្រុងព្យុងយ៉ាង លោកបានទទួលដំណឹងដ៏រីករាយថា សម្តេច

[255] Norodom Sihanouk, Compte-rendu succinct de mon entretien politique avec Monsieur Wolfgang A. Entmayr, de la Représentation de l'Autriche en la R.P.D. de Coré, Palais Chhang Sou On, Mardi 14 Juillet 1987.
[256] Bangkok Post, Asean Told Not to Rush Peace Bid, August 26, 1987.
[257] The Nation, Phnom Penh Echoes Hanoi, Quoted Kuala Lumpur Times, August 26, 1987

នឹងយាងទៅទីក្រុងញីវយ៉ក នៅខែ កញ្ញា ទោះជាព្រះអង្គមិនដឹកនាំគណៈប្រតិភូកម្ពុជាប្រជាធិបតេយ្យ នៅឯអង្គការសហប្រជាជាតិក៏ដោយ ព្រោះថាកិត្តិនាមរបស់ព្រះអង្គមានតម្លៃណាស់សម្រាប់បុព្វហេតុនៃរដ្ឋាភិបាលចម្រុះត្រីភាគី ។ នៅពេលព្រះអង្គយាងទៅដល់ក្រុងប៉េកាំង នៅចុងខែ សីហា សម្តេច សីហនុ មានបន្ទូលថា ព្រះអង្គអាចឆ្លើយ "ទេ" បានចំពោះអ្វីៗដែលលោកខៀវ សំផន និង លោកតា សឺន សាន ស្នើឡើង តែព្រះអង្គមិនអាចប្រកែកបានទេ ចំពោះប្រទេសចិនដែលជាមហាមិត្តរបស់ព្រះអង្គ[258]។ តាមពិតទៅ ប្រទេសគាំទ្ររដ្ឋាភិបាលចម្រុះត្រីភាគី ជាពិសេស ក្រុមប្រទេសអាស៊ាន ដែលមានប្រទេសថៃជាអ្នកនាំមុខ ព្រមទាំងប្រទេសចិនផង មានការព្រួយបារម្ភចំពោះការគាំទ្រអាសនៈកម្ពុជាប្រជាធិបតេយ្យ ដែលអាចធ្លាក់ចុះ បើគ្មានវត្តមានរបស់សម្តេច សីហនុ ទេនោះ ។ ដូច្នេះដំណឹងដែលថា សម្តេច យាងទៅទីក្រុងញីវយ៉កពិតជាដំណឹងល្អ ចំពោះលោក សិទ្ធី សាវ៉ែតសីលា និង មិត្តភក្តិមែន ។

នៅខែ កញ្ញា ១៩៨៧ សម្តេចយាងទៅទីក្រុងញីវយ៉កដូចបានគ្រោងទុក តែព្រះអង្គមិនដឹកនាំគណៈប្រតិភូកម្ពុជាប្រជាធិបតេយ្យ ចូលរួមមហាសន្និបាតនៃអង្គការសហប្រជាជាតិដូចឆ្នាំមុនៗទេ ។ នៅឆ្នាំ ១៩៨៧ នោះ រដ្ឋាភិបាលចម្រុះត្រីភាគី រៀបចំសុន្ទរកថារបស់សម្តេច ក្នុងឋានៈព្រះអង្គជាប្រធានកម្ពុជាប្រជាធិបតេយ្យ ដោយមានលោករដ្ឋមន្ត្រីទី១ សឺន សាន ជាអ្នកអានជំនួស នៅក្នុងអង្គប្រជុំនៃអង្គការសហប្រជាជាតិ ។ ជាមួយនិងដំណើរយាងទៅទីក្រុងញីវយ៉កក៏មានការផ្សព្វផ្សាយនៅទីក្រុងបាងកកថា សម្តេចនឹងមិនជួបចរចាជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ទេ ។ ក៏ប៉ុន្តែ បើគេពិនិត្យអត្ថបទកាសែតដែលផ្សាយដំណឹងនោះឲ្យច្បាស់ ក្រៅពីចំណងជើងធំៗនៅទំព័រទីមួយ គេអាចយល់បានថាសម្តេច សីហនុ

[258] The Nation, Sihanouk Arrives for China, August 30, 1987.

មិនបដិសេធទាំងស្រុងទេនូវលទ្ធភាពនៃការជួបគ្នា ព្រោះព្រះអង្គថ្លែងថាព្រះអង្គមិនជួបទេ លើកលែងតែក្នុងករណីមានការស្នើសុំពីមេដឹកនាំខ្មែរនៅក្រុងភ្នំពេញ[259] ។

បង្ហាញរូបភាពថាសាមគ្គី នៅពេលដែលបែកបាក់

គួបផ្សំជាមួយយុទ្ធនាការផ្នែកការទូតនៅអង្គការសហប្រជាជាតិ តំណាងកងទ័ពត្រីភាគីបានបង្កើនកិច្ចប្រតិបត្តិការទំនាក់ទំនងសាធារណៈ ដោយរៀបចំអង្គប្រជុំមួយនៅទីក្រុងបាងកក ដើម្បីគាំទ្រជំហររបស់រដ្ឋាភិបាលចម្រុះក្រោមការដឹកនាំរបស់សម្តេច សីហនុ ។ អង្គប្រជុំត្រីភាគីនោះ មានគោលដៅបង្ហាញរូបភាពថា កងទ័ពនៃចលនាទាំងបីនៅតែបន្តរួបរួម និង សហការគ្នាល្អតទៅទៀត[260]។ ចូលរួមជាតំណាងខ្មែរក្រហមមានលោក សុន សេន ឯលោក ទួន ចាយ ជាតំណាងព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ អគ្គបញ្ជាការកងទ័ពជាតិសីហនុនិយម ។ ខាង រ.ជ.រ.ប.ខ. គ្មានទាហានចូលរួមទេ មានតែរូបខ្ញុំ (អៀង មូលី) និង លោក សឺន ស៊ូបែរ្ត ជាតំណាងកងទ័ព ។ តាមពិត តាមគំរោងឯកសារ គេត្រៀមឈ្មោះលោក សក់ ស៊ុតសាខន ជាអ្នកចុះហត្ថលេខាលើសេចក្តីប្រកាសព័ត៌មាន ។ គួររំលឹកឡើងវិញថា ទោះបីជាមានការផ្សះផ្សាគ្នា និង ទោះបីជាលោកឧត្តមសេនីយ សក់ ស៊ុតសាខន ត្រូវបានតែងតាំងជាផ្លូវការជាអគ្គមេបញ្ជាការនៃកងទ័ពយ៉ាងណាក៏ដោយ ក៏រវាងលោកតា សឺន សាន និង ក្រុមយោធារបស់លោក សក់ ស៊ុតសាខន គ្មានការសំរុះសំរួលគ្នាដែរ ។ លោក សក់ ស៊ុតសាខន ក្នុងហានៈជាអគ្គមេបញ្ជាការក.ជ.រ.ប.ខ. មិនបានពិគ្រោះជាមួយលោកតា សឺន សាន ទេ ចំពោះកិច្ចការធំៗមួយចំនួនដូចជាការតែងតាំងលោក ជៀន ដែល និង លោក ប៉ុក សំអាន ជាអគ្គមេបញ្ជា

[259] The Nation, Sihanouk Assures Bangkok: He Won't Meet Hun Sen, September 1, 1987.
[260] សុន សេន, អៀង មូលី, សឺន ស៊ូបែរ្ត, ឧត្តមសេនីយត្រី ទួន ចាយ, សេចក្តីប្រកាសព័ត៌មាន, ថ្ងៃទី ២៧ សីហា ១៩៨៧ ។

ការរង និង ជានាយអគ្គសេនាធិការដោដើម ដូចមានក្នុងលក្ខខណ្ឌដែលលោកតា សឺន សាន បានដាក់ចេញមុននឹងធ្វើការតែងតាំងលោក សក់ ស៊ុតសាខន នោះ ។ លោកតា សឺន សាន ធ្លាប់បានលើកយកករណីគ្មានការពិគ្រោះគ្នាក្នុងការតែងតាំងលោក ជៀន ដែល និង លោក ប៉ុក សំអាន នេះ ទៅជំរាបលោកឧត្តមសេនីយ សុជិន្តា ក្រាប្រយង្គ ក្នុងជំនួបមួយកាលពីថ្ងៃទី ២៨ មេសា ១៩៨៧[261] ។ តាំងពីពេលនោះមក លោកតា សឺន សាន និង លោក សក់ ស៊ុតសាខន បំពេញការកិច្ចដោយឡែកពីគ្នាគឺ ខាងនយោបាយម្ខាង និង ខាងយោធាម្ខាង ដោយគ្មានសហការគ្នាយ៉ាងជិតស្និទ្ធឡើយ។ ការបាក់បែកនេះចេះតែបន្តរហូតដល់មានការបង្កើតគណបក្សនយោបាយពីរផ្សេងគ្នាសម្រាប់ការបោះឆ្នោតសកលឆ្នាំ ១៩៩៣ ។

ទីបំផុតសម្តេចឪសុំឲ្យតាៗជួយឲ្យមានការជួបគ្នា

បន្ទាប់ពីការប៉ុនប៉ងជួបគ្នានៅទីក្រុងព្យុងយ៉ាង មិនបានសម្រេចនោះមក សម្តេច សីហនុ បានសរសេរសំបុត្រមួយច្បាប់នៅថ្ងៃទី ១៨ កក្កដា ១៩៨៧ ទៅជូនឥស្សរជនខ្មែរ នៅប្រទេសបារាំងគឺ៖ ឯ. ឧ. ញឹក ដូឡុង ចៅសែនកុសល ឈុំ ហ៊ុយ កន្ទិល ឈាន វ៉ែម នង គិមនី ជុន អ៊ុក និង ឯ. ឧ. ឌួង សំអុល ដើម្បីជួយរៀបចំឲ្យមានការជួបគ្នារវាងភាគីខ្មែរ ដែលមានជម្លោះជាមួយគ្នា[262] ។ មកដល់ចំណុចនេះ ខ្ញុំនឹកដល់កាលសម័យសង្គមរាស្ត្រនិយមក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ កាលព្រះអង្គក្តាប់អំណាចយ៉ាងណែននោះ សម្តេច សីហនុ តែងលើកហេតុផលថាដោយសារមានសំណើពីបាតុកម្ម ឬ សមាជជាតិ ទើបព្រះអង្គសម្រេចធ្វើសកម្មភាព

[261] សេចក្តីបកប្រែសង្ខេបនៃពាក្យសន្ទនារវាង ឯ.ឧ.ប្រធាន ជាមួយ ឧ. សុជិន្តា ក្រាប្រយង្គ កាលពីថ្ងៃទី ២៨ មេសា ១៩៨៧ ។

[262] ហ៊ុន សែន, ១០ ឆ្នាំនៃដំណើរកម្ពុជា ១៩៧៩-១៩៨៩, op. cit, ទំព័រ ១៧១ ។

នយោបាយអ្វីមួយ ។ ដូច្នេះលើកនេះ ព្រះអង្គយោងទៅលើអន្តរាគមន៍របស់ឥស្សរជនទាំង ៧ នាក់ ជាហេតុផលបន្ថែម ដើម្បីឈានទៅជួបចរចាជាមួយមេដឹកនាំក្រុងភ្នំពេញ ។ ក្នុងចំណោមឥស្សរជនទាំង ៧ រូប មួយចំនួនគឺ លោកតា ហ៊ុយ កន្ទុល ឈាន វ៉ែម នង គិមនី និង ជុន អ៊ុក សុទ្ធតែជាសមាជិកក្រុមប្រឹក្សាព្រឹទ្ធាចារ្យ (Conseil des Sages) របស់រ.ជ.រ.ប.ខ. ដែលធ្លាប់ប្រកាសជាសាធារណៈដកសេចក្តីទុកចិត្តពីលោកតាប្រធានរ.ជ.រ.ប.ខ.ម្តងរួចហើយ កាលពីឆ្នាំ ១៩៨៥ ។ វរជនចាស់ទុំទាំងនោះ ប្រហែលជាយល់ឃើញថា គោលដំហរទន់ភ្លន់របស់សម្តេច សីហនុ អាចមានប្រសិទ្ធភាពជាងគោលជំហរលោកតា សឺន សាន ។ ចាប់តាំងពីចុងឆ្នាំ ១៩៨៥ រហូតមក លោកតា ហ៊ុយ កន្ទុល និង ជុន អ៊ុក ក៏បានចូលរួមយ៉ាងសកម្មជាមួយលោកឧត្តមសនីយ សក់ ស៊ុតសាខន ដើម្បីប្រឆាំងនិងការដឹកនាំរបស់លោកតា សឺន សាន ក្នុងជួររ.ជ.រ.ប.ខ. ។ នៅថ្ងៃ ទី ៤ កញ្ញា ១៩៨៧ ឥស្សរជនទាំង ៧ នាក់សរសេរសំបុត្រជូនរដ្ឋាភិបាលក្រុងភ្នំពេញ ដោយអំពាវនាវឲ្យមានការជួបគ្នា[263] ។ ទាក់ទងនិងជំនួប ហ៊ុន សែន - សីហនុ នេះ មេដឹកនាំក្រុងភ្នំពេញបានផ្ញើលិខិតទៅថ្វាយសម្តេច នៅឯទីក្រុងប៉ារីសតាំងពីមុនពេលព្រះអង្គយាងចេញពីទីក្រុងព្យុងយ៉ាងឯនោះ តែលិខិតនោះមិនបានទៅដល់សម្តេចទេ នេះបើតាមការអះអាងរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ។ លោកបានបកស្រាយថា "ពួកអ្នកហៃហម និង កងរក្សាព្រះអង្គ" គេបង្កើតលក្ខខណ្ឌច្រើនបែបច្រើនយ៉ាងរហូតហ៊ានសម្រេចនូវកិច្ចការជំនួសសម្តេច ។ យ៉ាងនេះហើយ ដើម្បីធានាឲ្យមានការទាក់ទងផ្ទាល់ជាមួយសម្តេច សីហនុ ថ្នាក់ដឹកនាំក្រុងភ្នំពេញបានសម្រេចវាយទូរលេខថ្វាយព្រះអង្គតាមរយៈព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ព្រះរាជបុត្រ និងជាតំណាងរបស់ព្រះអង្គប្រចាំនៅទីក្រុងបាងកក ។ ព្រះអង្គម្ចាស់ រណឫទ្ធិ បាននាំ

[263] ហ៊ុន សែន, ១០ ឆ្នាំនៃដំណើរកម្ពុជា ១៩៧៩-១៩៨៩, op. cit. ទំព័រ ១៧២ ។

យកសារទូលេខទៅថ្វាយសម្តេច សីហនុ ផ្ទាល់នៅប្រទេសបារាំងដែលភ្លាមៗនោះ ព្រះអង្គបានឆ្លើយតបទៅទីក្រុងភ្នំពេញវិញ ដោយថ្លែងអំណរគុណផង និង យល់ព្រមជួបគ្នាផង ។ សម្តេចទុកលទ្ធភាពឲ្យភាគីភ្នំពេញជាអ្នករើសរើសថ្ងៃខែជួបគ្នា[264] ឯទីកន្លែងព្រះអង្គបានជ្រើសយកប្រទេសបារាំង ដោយបានទទួលការលើកទឹកចិត្តពីរដ្ឋាភិបាលបារាំងរួចហើយ ។ ចំពោះមេដឹកនាំក្រុងភ្នំពេញ ការដែលសម្តេចសុខចិត្តជួបចរចាគ្នានៅប្រទេសបារាំងលើកនេះ អាចចាត់ទុកជាឱកាសមាស ដែលមិនត្រូវឲ្យបាត់បង់បានឡើយ ។ ក្រុងភ្នំពេញជ្រើសយកថ្ងៃទី ២ ធ្នូ ១៩៨៧ សម្រាប់ការចរចាគ្នា ។ ការជ្រើសយកថ្ងៃទី ២ ធ្នូ នេះមិនមែនជ្រើសយកដោយចៃដន្យនោះទេ តែក៏ជាការគិតគូរឲ្យចំអត្ថន័យប្រវត្តិសាស្ត្រនៃការផ្តួលរំលំ ប៉ុល ពត ព្រោះថាថ្ងៃទី ២ ធ្នូ ១៩៨៧ ជាខួបឆ្នាំទី ៩ នៃកំណើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៧៨ នៅក្នុងស្រុកស្នួល ខេត្តក្រចេះ ដើម្បីប្រមូលកម្លាំងវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ ។

ផែនការជំនួប សីហនុ - ហ៊ុន សែន នៅប្រទេសបារាំង មិនបានធ្វើឲ្យក្រុម រ.ជ.រ.ប.ខ.ចាប់អារម្មណ៍ប៉ុន្មានទេ ព្រោះយល់ថាបើគ្មានការគាំទ្រពីចិន និង អាស៊ានទេ ជំនួបនោះប្រាកដជានឹងទទួលបរាជ័យមិនខានឡើយ ។ ផ្ទុយទៅវិញ មនុស្សជិតស្និទ្ធជាមួយសម្តេច សីហនុ សំដែងសុទិដ្ឋិនិយម និង អំណរសោទរចំពោះគំរោងជំនួបនេះ ។ លោកតា ញឹក ជូឡុង ក្នុងលិខិតថ្វាយព្រះពរព្រះអង្គនាឱកាសចំរើនព្រះជន្មគំរប់ ៦៥ ព្រះវស្សា បានសរសេរជាភាសាបារាំងក្នុងន័យជាអាទិថា អ្វីដែលសម្តេចបានធ្វើកន្លងមកបានទទួលលទ្ធផលជាផ្លែផ្កា គួរជាទីកក់ក្តៅ ។ លិខិតនោះ នៅទីបញ្ចប់បានសរសេរថាខ្មែរទាំងអស់ទាំងក្នុង ទាំងក្រៅ ផ្តោត

[264] ហ៊ុន សែន, ១០ ឆ្នាំនៃដំណើរកម្ពុជា ១៩៧៩-១៩៨៩, op. cit, ទំព័រ ១៧៣ ។

សេចក្តីសង្ឃឹមតែមួយគត់ និង ចុងក្រោយបំផុតទៅលើអង្គសម្តេចឪ ព្រះបិតាឯករាជ្យខ្មែរ[265] ។ ចំណែកព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិបានសរសេរលិខិតថ្វាយព្រះពរមួយច្បាប់ទៀតជាភាសាបារាំង ដែលខ្ញុំសុំដកស្រង់អត្ថន័យជាភាសាខ្មែរនូវវគ្គមួយនេះដូចតទៅ៖ "ខួបលើកទី៦៥ នៃព្រះរាជពិធីចំរើនព្រះជន្មវស្សាព្រះវរបិតានេះ ជាផ្លូវបត់ដ៏សំខាន់ក្រៃលែង (le grand tournant) នៃបញ្ហាកម្ពុជា ហើយទាំងនេះ ក៏ដោយសារការប្រឹងប្រែងដ៏ត្រឹមត្រូវ និង ឥតឈប់ឈររបស់ព្រះវរបិតា ដើម្បីរកដំណោះស្រាយមួយ ដែលនឹងប្រកបដោយកិត្តិយស ព្រមទាំងត្រឹមត្រូវបំផុតសម្រាប់ប្រទេសដ៏កំសត់របស់យើង[266]" ។ សុទិដ្ឋិនិយមនេះក៏ស៊ីសង្វាក់ជាមួយគោលនយោបាយរបស់រដ្ឋាភិបាលក្រុងភ្នំពេញ ដែលប្តេជ្ញាទាក់ទាញសម្តេច សីហនុ ឲ្យចេញពីសម័ន្ធភាពជាមួយខ្មែរក្រហម ឲ្យបានជោគជ័យតាមយុទ្ធសាស្ត្រផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត ទោះជាត្រូវថ្វាយតំណែងកំពូលណាមួយដូចជា ប្រមុខរដ្ឋជាដើមចំពោះព្រះអង្គ ។

ជំនួប សីហនុ - ហ៊ុន សែន នៅ ហ្សែរ អង់តាកជឺន័រ

តាមឯកសារទទួលបាន យើងអាចវិភាគបានថា សម្តេច សីហនុ ប្រើព្រះហានៈរបស់ព្រះអង្គជាអតីតព្រះមហាក្សត្រ ដើម្បីជួបជាមួយរាស្ត្រម្នាក់របស់ព្រះអង្គ ចំណែកឯក្រុងភ្នំពេញយល់ថាជំនួប សីហនុ - ហ៊ុន សែន ជាជំនួបរវាងគូបដិបក្ខ ដែលនឹងជួបពិភាក្សាគ្នាដោយស្មើភាព ដើម្បីស្វែងរកដំណោះស្រាយបញ្ចប់ជម្លោះនៅកម្ពុជា[267] ។ ទោះជាមានការយល់ឃើញខុសគ្នា អំពីទម្រង់នៃការជួបគ្នាយ៉ាង

[265] Nhiek Tioulong, [A] Son Altesse Royale Samdech Norodom Sihanouk du Cambodge, Sucy-en-Brie, le 27 Octobre 1987.
[266] Norodom Ranariddh, [lettre] datée à Bangkok, le 23 octobre 1987.
[267] ហ៊ុន សែន, ១០ ឆ្នាំនៃដំណើរកម្ពុជា ១៩៧៩-១៩៨៩, op. cit, ទំព័រ ១៧៤-១៧៥ ។

ណាក៏ដោយ ក៏នៅទីបំផុត ជំនួបបានត្រូវរៀបចំឡើងនៅ ហ្វែរ អង់តាកដឺន័រ (Fère-en-Tardenois) នៅប្រទេសបារាំង នៅថ្ងៃទី ២ ធ្នូ ១៩៨៧ ប្រាកដមែន ។ សម្តេច សីហនុ បានសន្យាថា ព្រះអង្គមិនលាក់បាំងអ្វីទាំងអស់ រាល់ការពិភាក្សាដែលព្រះអង្គធ្វើជាមួយមេដឹកនាំក្រុងភ្នំពេញ ដោយព្រះអង្គនឹងផ្តល់ដល់ពួកយើងក្នុងជួរ.ជ.រ.ប.ខ.នូវខ្សែអាត់ថតសម្លេង(កាសែតថតចម្លង)នៃអង្គប្រជុំទាំងអស់ ។ ដូច្នេះរូបខ្ញុំដែលកំពុងស្នាក់នៅឯទីក្រុងបាងកក ក៏ត្រៀមរង់ចាំស្តាប់ខ្សែអាត់ថតសម្លេងនោះយ៉ាងយកចិត្តទុកដាក់ ។ ប៉ុន្មានថ្ងៃក្រោយមក ខ្ញុំក៏បានទទួលខ្សែអាត់ដូចសន្យា តាមរយៈក្រុមការងារវិទ្យុសម្លេងខ្មែរហៅ វី អូ ខេ ។ ខ្ញុំចំណាយពេលជាច្រើនម៉ោងដើម្បីស្តាប់ការពិភាក្សាទាំងអស់ ដែលថតក្នុងខ្សែអាត់រាប់សិបកាសែត ។ សូមបញ្ជាក់ថានៅថ្ងៃចុងក្រោយនៃការពិភាក្សាគឺ ថ្ងៃទី ៤ ធ្នូ ភាគីទាំងពីរ មានការចេញផ្សាយនូវសេចក្តីថ្លែងការណ៍រួមមួយមាន ៤ ចំណុចគឺ៖ ១-បញ្ហាកម្ពុជាទាមទារឲ្យមានដំណោះស្រាយនយោបាយមួយ មិនមែនដោយកម្លាំងយោធាទេ ២-បញ្ហាកម្ពុជា ត្រូវដោះស្រាយដោយជនកម្ពុជាខ្លួនឯងតាមរយៈការចរចា ៣-នាំមកវិញនូវសន្តិភាព ការកសាងប្រទេសឡើងវិញ និង ការបង្កើតប្រព័ន្ធនយោបាយឯករាជ្យ ប្រជាធិបតេយ្យ អធិបតេយ្យ អព្យាក្រឹត មិនចូលបក្សសម័ន្ធ ៤-ការជួបគ្នាលើកក្រោយនឹងប្រព្រឹត្តទៅនៅខែ មករា ១៩៨៨ [268]។ ទាំងនេះអាចរាប់បានជាចំណុចវិជ្ជមាននៃជំនួប ។ ចំពោះសម្តេច សីហនុ ព្រះអង្គបានផ្សព្វផ្សាយឲ្យសាធារណៈជនជ្រាបនូវខ្លឹមសារនៃជំនួប សីហនុ - ហ៊ុន សែន នោះមានដាអាទិ៍ថា៖ ជំនួបរវាងព្រះអង្គជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នោះ ជាការចរចាពិតប្រាកដ ដើម្បីសាកល្បងដោះស្រាយបញ្ហាកម្ពុជា ។

[268] ឯក សំអុល, ជំនួយស្មារតីស្តីពីដំណើរការចរចា ដើម្បីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជា, ថ្ងៃទី ២ ធ្នូ ២០០៩ ។

ជំនួបនេះបានទទួលការអបអរសាទរពីជនរួមជាតិខ្មែរ ទាំងក្នុង ទាំងក្រៅ ភាគច្រើនយ៉ាងធំធេង និង ទទួលបានការពេញចិត្តពីសហគមន៍អន្តរជាតិ លើក លែងតែក្រុមស្រឡាញ់សង្គ្រាមខ្មែរក្រហម និង ពួកប្រជាភិថុតិខ្មែរខៀវ (ត្រង់នេះ ព្រះអង្គសំដៅទៅរកពួកយើងរ.ជ.រ.ប.ខ. ឬ ពួកលោកតា សឺន សាន) និង រដ្ឋាភិបាលបរទេសខ្លះ ដែលគេមានផលប្រយោជន៍ក្នុងការបន្តជម្លោះនៅកម្ពុជា ។ ចំពោះសម្តេច សីហនុ ព្រះអង្គទទួលយកការជួបជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ថាដូចជាការជួបជាមួយអ្នកតំណាងក្រុងហាណូយ ឬ ក្រុងមូស្គូ យ៉ាងដូច្នោះដែរ ។ ក៏ប៉ុន្តែសម្តេចសំដែងការអាក់អន់ព្រះទ័យចំពោះក្រុងហាណូយដែលមិនព្រមចាត់បេសកជន ឲ្យមកចរចាផ្ទាល់ជាមួយព្រះអង្គអំពីបញ្ហាកម្ពុជា - វៀតណាមទោះបីជានៅក្នុងរង្វង់ចលនាតស៊ូខ្មែរ ព្រះអង្គជាមេដឹកនាំតែមួយគត់ ដែលជៀសវាងមិននិយាយតែពីសតែពាសដូចលោកតា សឺន សាន និង អ្នកឯទៀត ដែលថា "វៀតណាមឈ្លានពានកម្ពុជា" ហើយម្យ៉ាងទៀតមានតែសម្តេចមួយអង្គគត់ ដែលមិនបានទាមទារឲ្យមានតែការចរចាផ្ទាល់ជាដាច់ខាត រវាងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ជាមួយរដ្ឋាភិបាលចម្រុះត្រីភាគីយ៉ាងណាក៏ដោយ[269] ។

គួររំលឹកថា សម្តេច សីហនុ បានហៅលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ថា កញ្ជ្រោងស្វាវជាភាសាបារាំងថា (jeune renard) នៅក្នុងកំណត់ជូនអ្នកកាសែតនាឱកាសសិក្ខាសាលាទូទាំងពិភពលោករបស់ ហ៊ុន សុិន ប៊ិច នៅថ្ងៃទី ២០ ធ្នូ ១៩៨៧ នៅប្រទេសបារាំង ។ សម្តេច សីហនុ ក៏លើកឡើងនូវចំណុចមួយចំនួនដែលព្រះអង្គចង់បានជាចម្លើយជាក់លាក់ពីមេដឹកនាំក្រុងភ្នំពេញ នៅពេលជួបគ្នាម្តងទៀត នៅខែ មករា ១៩៨៨ ដូចតទៅ៖ ក្នុងករណីដែលមានការបង្កើតរដ្ឋាភិបាលផ្សះផ្សារួបរួមជាតិចតុភាគី តើលោក ហ៊ុន សែន យល់ព្រមដាក់រដ្ឋាភិបាលផ្សះ

[269] Norodom Sihanouk, Note pour la Presse, Roissy-en-France, le 20 Décembre 1987.

ផ្សារួបរួមជាតិចតុកាគីខាងលើ ឲ្យស្ថិតនៅក្រោមអំណាចច្បាប់នៃរដ្ឋកម្ពុជាថ្មីមួយ ដែលមិនមែនសាធារណរដ្ឋប្រជាមានិតកម្ពុជានៃរបបក្រុងភ្នំពេញ និង មិនមែនកម្ពុជាប្រជាធិបតេយ្យរបស់ខ្មែរក្រហមគឺ ព្រះអង្គចង់បានរបបថ្មីមួយទៀត[270] ។ ជាការពិតណាស់ចំពោះសម្តេច សីហនុ ដែលធ្លាប់ទាមទារឯករាជ្យពីបារាំងក្នុងទសវត្សរ៍ឆ្នាំ ១៩៥០ ព្រះអង្គប្រាកដជាមានការលំបាកក្នុងការធ្វើមាតុភូមិនិវត្តន៍ចូលប្រទេសវិញ នៅចំពោះមុខវត្តមាននៃកងទ័ពវៀតណាមនៅកម្ពុជា ទោះបីជាកងទ័ពនេះបានជួយរំដោះកម្ពុជាពី ប៉ុល ពត យ៉ាងណាក៏ដោយ ។ ម្យ៉ាងទៀតសម្តេច សីហនុ ក៏ប្រាកដជាពិបាកដកព្រះអង្គពីកម្ពុជាប្រជាធិបតេយ្យ ដែលកំពុងទទួលបាននូវការទទួលស្គាល់ពីអង្គការសហប្រជាជាតិ ប្រសិនបើគ្មានរូបមន្តផ្លូវច្បាប់ថ្មីដែលអាចទទួលយកបានដូចជាយ៉ាងហោចណាស់ ឈ្មោះប្រទេស ទង់ជាតិ ភ្លេងជាតិជាដើម ។

នៅក្នុងកំណត់ជូនអ្នកកាសែត នាឱកាសសិក្ខាសាលា ហ៊ុន សុិន ប៊ុច នោះសម្តេច សីហនុ បានសរសេរថា នៅពេលជួបគ្នាម្តងទៀតនៅខែ មករា ១៩៨៨ ប្រសិនបើលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន មិនឆ្លើយឲ្យបានច្បាស់លាស់នូវចំណុចសំណួរខាងលើទេ ព្រះជាយាព្រះអង្គគឺ អ្នកម្នាង ម៉ូនិច អនុប្រធានទី២ នៃហ៊ុន សុិន ប៊ុច នឹងប្រឆាំងមិនព្រមឲ្យព្រះអង្គចុះព្រះហស្តលេខាលើសេចក្តីប្រកាសរួមជាមួយមេដឹកនាំក្រុងភ្នំពេញដូចមុនទៀតឡើយ រីឯជំនួប សីហនុ - ហ៊ុន សែន លើកទី៣ ដែលគ្រោងនឹងធ្វើនៅទីក្រុងព្យុងយ៉ាង ប្រទេសកូរ៉េខាងជើងនាខែ មេសា ១៩៨៨ ក៏នឹងត្រូវលើកសិន[271] ។

[270] ដូចយោងខាងលើ ។

[271] ដូចយោងខាងលើ ។

សម្តេចសុំឲ្យប្តូរឈ្មោះ ភ្លេងជាតិ និង ទង់ជាតិនៃប្រទេសខ្មែរ

ដើម្បីត្រៀមជួបជាមួយមេដឹកនាំក្រុងភ្នំពេញ សម្តេច សីហនុ បានចេញសេចក្តីប្រកាសមួយ ជាពិសេសសំដៅទៅរដ្ឋាភិបាលចម្រុះត្រីភាគី និង ប្រទេសគាំទ្រ ព្រមទាំងមិត្តភក្តិនៃរដ្ឋាភិបាលនេះថា ការឈប់សម្រាកអវត្តមានរបស់ព្រះអង្គពីតំណែងប្រធានកម្ពុជាប្រជាធិបតេយ្យ មិនកំណត់ត្រឹមថ្ងៃទី ៧ ឧសភា ១៩៨៨ នោះទេ ក៏ប៉ុន្តែនឹងបន្តរហូតដោយគ្មានកំណត់ដរាបណាខ្មែរក្រហម (ភាគីកម្ពុជាប្រជាធិបតេយ្យ និង ខ្មែរខៀវ (រ.ជ.រ.ប.ខ.) ដៃគូទាំងពីររបស់ព្រះអង្គក្នុងរដ្ឋាភិបាលចម្រុះត្រីភាគី - មិនព្រមផ្លាស់ប្តូរឈ្មោះ រដ្ឋ ភ្លេងជាតិ និង ទង់ជាតិខ្មែរ និងដរាបណាក្រុមទាំងនោះគឺ ខ្មែរក្រហម និង ខ្មែរខៀវនៅតែរំលោភសិទ្ធិមនុស្សទៅលើប្រជាពលរដ្ឋតទៅទៀត ។ ត្រង់នេះសម្តេច សីហនុ ចុចចំចំណុចខ្សោយរបស់ខ្មែរក្រហមគឺ ការរំលោភសិទ្ធិមនុស្ស ។ ចំណែកឯចំពោះរ.ជ.រ.ប.ខ.វិញ សម្តេចវាយប្រហារពីរយ៉ាង៖ ទី១. ព្រះអង្គប្រើពាក្យខ្មែរខៀវដែលព្រះអង្គធ្លាប់តែប្រើចំពោះខ្មែរនិយមលោក សឺង ង៉ុកថាញ់ ស្តាំនិយមសាធារណរដ្ឋក្បត់ជាតិ បន្ថែមលើពាក្យប្រជាកិច្ចុត- ទី២. ព្រះអង្គចោទថារំលោភសិទ្ធិមនុស្សដូចខ្មែរក្រហមដែរ ។ គួរកត់សំគាល់ថានាសម័យនោះអង្គការក្រៅរដ្ឋាភិបាលមួយចំនួន បានចោទប្រកាន់មេដឹកនាំជំរុំនងចាន់ និង វិទ្ធិសែនរបស់រ.ជ.រ.ប.ខ.ថា បានរំលោភសិទ្ធិមនុស្ស ក៏ប៉ុន្តែក៏ពុំមានន័យថាជំរុំជនភៀសខ្លួនខ្មែរឯទៀត បានរួចខ្លួនផុតពីការចោទប្រកាន់អំពីបទរំលោភសិទ្ធិមនុស្សនោះឡើយ រួមទាំងជំរុំរបស់ខ្មែរក្រហម និង ជំរុំដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នកសីហនុនិយមផង ។ សម្តេច សីហនុ ក៏ធ្លាប់តវ៉ាដែរ ទៅសភាអឺរ៉ុប ដែលបានចោទប្រកាន់ក្រុមចលនាតស៊ូទាំងអស់រួមទាំងចលនារបស់ព្រះអង្គផងនោះថា មានការរំលោភសិទ្ធិមនុស្ស ដែលនាំឲ្យសម្តេចឆ្លើយបកទៅវិញថាជា

ការចោទប្រកាន់អយុត្តិធម៌ ព្រមទាំងសុំឲ្យសភាអឺរ៉ុបបញ្ជូនបេសកជន មកស៊ើបអង្កេតនៅជំរុំសាយប៊ី និង មូលដ្ឋានភ្នំស្រួចទៀតផង[272] ។

តាមពិតទៅ នៅតាមជំរុំជនភៀសខ្លួន មេដឹកនាំនយោបាយដែលមិនបានរស់នៅផ្ទាល់ក្នុងជំរុំ មិនអាចធានានូវសុក្រិតភាពនៃការគ្រប់គ្រងជំរុំបានទេ ព្រោះអំណាចពិតប្រាកដស្ថិតនៅក្នុងកណ្តាប់ដៃនៃក្រុមនាយទាហានថៃដែលត្រួតត្រាលើមេជំរុំខ្មែរទៀតផងឯនោះទេ ។ មេដឹកនាំនយោបាយមានច្រើនតែត្រឹមឥទ្ធិពលខាងផ្លូវចិត្ត ឬ ខាងផ្លូវសីលធម៌តែប៉ុណ្ណោះ ។ ដូច្នេះ ការវាយប្រហាររបស់ព្រះអង្គមកលើ រ.ជ.រ.ប.ខ. គ្រាន់តែជាការគាបសង្កត់ផ្នែកនយោបាយ ដែលសម្តេច សីហនុ មានការប៉ិនប្រសព្វក្នុងការយកមកប្រើប្រាស់ ប្រឆាំងគូប្រកួតប្រជែងរបស់ព្រះអង្គតែប៉ុណ្ណោះ ។

ជាមួយនឹងការប្រកាស បន្តផ្អាកការងារជាប្រធានកម្ពុជាប្រជាធិបតេយ្យ សម្តេច សីហនុ ក៏បានផ្សព្វផ្សាយនូវលក្ខខណ្ឌមួយទៀត ឲ្យដៃគូទាំងពីរនោះទទួលយកគឺ ការផ្លាស់ប្តូរ ឈ្មោះ ភ្លេងជាតិ និង ទង់ជាតិនៃប្រទេសកម្ពុជា ដោយព្រះអង្គឲ្យជ្រើសយកឈ្មោះ កម្ពុជាជាភាសាខ្មែរ Cambodge ជាភាសាបារាំង និង Cambodia ជាភាសាអង់គ្លេស ចំណែកទង់ជាតិឲ្យយកទង់ជាតិសម័យមុនសង្គ្រាម គឺ ទង់ពណ៌ខៀវ ក្រហម មានរូបប្រាសាទអង្គរវត្តកំពូលបីពណ៌សនៅចំកណ្តាល ឯភ្លេងជាតិ ឲ្យយកបទនគររាជ ដែលកម្ពុជាធ្លាប់ប្រើចាប់ពីទសវត្សរ៍ឆ្នាំ ១៩៤០ ១៩៥០ ១៩៦០ ត្រង់វគ្គទី២ឆ្ពើមពីប្រាសាទសីលាកំបាំងកណ្តាលព្រៃតទៅ[273]...។

[272] Norodom Sihanouk, Télégramme, Au Parlement Européen, Strasbourg, France ផ្សាយក្នុង www.norodomsihanouk.info le 2 Septembre 2004.
[273] Norodom Sihanouk, Déclaration de Norodom Sihanouk du Cambodge, Paris, le 10 Décembre 1987.

លោកតាមិនចូលរួមប្រជុំ តែលបសុំជួប ហ៊ុន សែន ស្ងាត់ៗ

ដើម្បីចង់បញ្ជាក់ថា រ.ជ.រ.ប.ខ មិនមែនជាឧបសគ្គ ឬ ប្រឆាំងចំពោះជំនួប សីហនុ-ហ៊ុន សែន នាខែ ធ្នូនោះ រ.ជ.រ.ប.ខ.បានចេញសេចក្តីប្រកាសព័ត៌មានមួយ ដើម្បីបំភ្លឺអត្ថបទរបស់ទីភ្នាក់ងារសារព័ត៌មានបារាំង ចេញផ្សាយតាមសារព័ត៌មាន បាងកកប៉ុស្ត (Bangkok Post) នៅថ្ងៃទី ៩ ធ្នូ ១៩៨៧ ។ សេចក្តីប្រកាសមាន ន័យជាអាទិថាៈ សម្តេច សីហនុ និង លោករដ្ឋមន្ត្រីទី១ សឺន សាន ធ្លាប់ជួប ពិភាក្សាគ្នាជាច្រើនដងមកហើយ អំពីគំរោងជំនួបសម្តេច សីហនុ-ហ៊ុន សែន ទាំង នៅទីក្រុងប៉ារីស ទាំងនៅទីក្រុងញីវយ៉ក ក្នុងរាល់មហាសន្និបាតអង្គការសហប្រជា ជាតិ - លោករដ្ឋមន្ត្រីទី១ សឺន សាន បានទូលសម្តេចថា គាំទ្ររាល់វិធានការណា ដែលមានគោលដៅបញ្ចប់ទុក្ខវេទនារបស់ប្រជាពលរដ្ឋខ្មែរ ដូច្នេះសំដែងស្វាគមន៍ ចំពោះការផ្តួចផ្តើមគំនិតរបស់ព្រះអង្គនាពេលនេះ និង នៅពេលខាងមុខ[274] ។ សេចក្តីប្រកាសព័ត៌មានបន្តទៀតថាៈ លោករដ្ឋមន្ត្រីទី១ សឺន សាន មិនដែល ប្រកែកថា មិនចូលរួមក្នុងការផ្តួចផ្តើមគំនិតរកសន្តិភាព ដែលនាំឲ្យមានការដកកង ទ័ពវៀតណាមចេញពីកម្ពុជា និង ឲ្យមានការបោះឆ្នោតទូទៅ និង ដោយសេរី ឆ្ពោះ ទៅរកការផ្សះផ្សាជាតិនោះទេ ។ សេចក្តីប្រកាសព័ត៌មានបានចែងថា តាមទម្លាប់ រៀងមក លោករដ្ឋមន្ត្រីទី១ សឺន សាន នឹងធ្វើការពិគ្រោះជាមួយប្រជាពលរដ្ឋដែល ស្ថិតនៅក្រោមការទទួលខុសត្រូវរបស់រ.ជ.រ.ប.ខ.គឺជនភៀសខ្លួនខ្មែរនៅក្នុងជំរុំ និង ជាមួយក្របខ័ណ្ឌរ.ជ.រ.ប.ខ. ឬ កម្មាភិបាល (បើនិយាយតាមភាសាអ្នកនៅក្នុង ស្រុកនាសម័យនោះ) ។ ក៏ប៉ុន្តែ ចំពោះការចូលរួមក្នុងជំនួប សីហនុ-ហ៊ុន សែន លើកទី ២ នៅខែ មករា ជាបន្ទាប់នោះ សេចក្តីប្រកាសព័ត៌មានមិនបានចែងឲ្យ

[274] Office of the Prime Minister, Coalition Government of Democratic Kampuchea, Press Communique, December 9, 1987.

ច្បាស់ថា ប្រាកដជានឹងចូលរួមទេ ព្រោះសំអាងទៅលើការកិច្ចជាច្រើនដែលលោក រដ្ឋមន្ត្រីទី១ កំពុងជាប់ដៃបំពេញ ដែលមិនអនុញ្ញាតឲ្យសន្យាទទួលយកការកិច្ចថ្មី ទៀតនៅឡើយ[275] ។ ជំហររបស់លោកតា សឺន សាន នៅពេលនោះហាក់ដូច ជានៅពាំត្រណោតណាស់ ព្រោះម្យ៉ាង មិនហ៊ានធ្វើសកម្មភាពអ្វីឲ្យឃ្លាតចេញពី គោលជំហរចិន និង ប្រទេសអាស៊ានខ្លះ ដែលមានប្រទេសថៃជាអ្នកនាំមុខ ។ គោលជំហរនោះ ទាមទារឲ្យមានការដកកងទ័ពវៀតណាម ឬ ឲ្យចរចាជាមួយ វៀតណាមជាមុន និង ម្យ៉ាងទៀត ក៏មិនចង់ឃើញសម្តេច សីហនុ នាំមុខជានិច្ចក្នុង ការផ្តួចផ្តើមគំនិតចរចា ជាមួយក្រុងភ្នំពេញ ឬ ស្វែងរកសន្តិភាព ។ នៅក្នុងសេចក្តី ថ្លែងការណ៍មួយចុះថ្ងៃទី ២១ ធ្នូ ១៩៨៧ លោកតា សឺន សាន ថ្លែងថានឹងចូលរួម ប្រជុំជាមួយភាគីខ្មែរ (ជំនួប សីហនុ-ហ៊ុន សែន) ក្នុងឋានៈឯកជន មិនមែនក្នុង ឋានៈជារដ្ឋមន្ត្រីទី១នៃរដ្ឋាភិបាលចម្រុះទេ ប្រសិនបើវៀតណាមចូលរួមដែរ ។ សេចក្តីថ្លែងការណ៍បញ្ជាក់ថា ប្រសិនបើមានហេតុផលណាមួយ មិនអាចឲ្យវៀត ណាមចូលរួមប្រជុំជាមួយភាគីខ្មែរភ្លាមៗទេនោះ លោករដ្ឋមន្ត្រីទី១ សឺន សាន សុំឲ្យវៀតណាមចេញសេចក្តីថ្លែងការណ៍ជាឧឡារិកមួយ (តាមរយៈលិខិតផ្ញើជូន លោកអគ្គលេខាអង្គការសហប្រជាជាតិ ជាពិសេសជូនទៅប្រទេសមហាអំណាច ទាំង៥ ដែលជាសមាជិកអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាសន្តិសុខឲ្យបានមុនពេលភាគីខ្មែរ ប្រជុំ ដោយសន្យាថានឹងដកកងទ័ពរបស់ខ្លួនទាំងអស់ពីកម្ពុជាយ៉ាងឆាប់ជាទីបំផុត បន្ទាប់ពីការប្រជុំខ្មែរចតុភាគី[276]។ បើនិយាយឲ្យខ្លី លោកតា សឺន សាន ចង់ចូលរួម ប្រជុំជាមួយសម្តេច សីហនុ ដែរ ប្រសិនបើវៀតណាមសន្យាដកកងទ័ពចេញពី

[275] ដូចយោងខាងលើ ។

[276] Son Sann, Statement of H E Son Sann Prime Minister of the Coalition Government of Democratic Kampuchea and President of the Khmer People's National Liberation Front, December 21, 1987.

កម្ពុជា ជាលាយលក្ខណ៍អក្សរនៅចំពោះមុខអង្គការសហប្រជាជាតិ ជាពិសេស ចំពោះមុខប្រទេសមហាយក្សទាំង៥នៃក្រុមប្រឹក្សាសន្តិសុខ ។

ចំពោះការដកកងទ័ពវៀតណាមនេះ រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជានៅក្រុងភ្នំពេញបានឲ្យដឹងថា វៀតណាមបានដកកងទ័ព ចំនួន ២០ ០០០ នាក់រួចហើយ កាលពីខែ វិច្ឆិកា ១៩៨៧ កន្លងទៅ ហើយនឹងបន្តដកតទៅទៀត ក៏ប៉ុន្តែចំណុចសំខាន់នោះគឺ ក្រុងភ្នំពេញបានចងភ្ជាប់ការបញ្ឈប់ជំនួយយោធាដល់គ្រប់ភាគីក្នុងដំណោះ ជាមួយនិងការដកកងទ័ពវៀតណាមទាំងអស់ពីកម្ពុជា ដូចមានចែងក្នុងសេចក្តីអំពាវនាវកាលពីថ្ងៃទី ៨ តុលា ១៩៨៧ មាន ៥ ចំណុច[277] ។ យ៉ាងណាក៏ដោយ ទោះជាតាមរូបភាពក្រៅ លោកតា សឺន សាន បានបង្ហាញគោលជំហរតឹងតែងក្នុងការចរចាមិនខុសពីគោលជំហរខ្មែរក្រហមទេនោះ ក៏លោកតាលបចាត់ឲ្យមនុស្សជំនិតរបស់គាត់គឺ លោកឧត្តមសេនីយ ថាច់ រ៉ែង ទាក់ទងជាសម្ងាត់ជាមួយក្រុងភ្នំពេញដែរ ដោយពុំបានឲ្យពួកយើងដែលកំពុងស្នាក់នៅទីក្រុងបាងកកបានដឹងសោះឡើយ ។ ក្នុងឯកសារដែលលោកតាចុះហត្ថលេខាដើម្បីឲ្យលោក ថាច់ រ៉ែង ប្រើជារបៀបសារតាំង ហើយដែលពួកយើងរកឃើញច្រើនឆ្នាំក្រោយមកទៀតនោះ លោកតា សឺន សាន បានចេញសេចក្តីសម្រេចលេខពិសេសមួយ ចុះថ្ងៃទី ២៣ ធ្នូ ១៩៨៧ ចាត់តាំងលោកឧត្តមសេនីយ ថាច់ រ៉ែង ជាអ្នកតំណាងផ្ទាល់របស់ប្រធានរ.ជ.រ.ប.ខ. ដើម្បីស្វែងរកដំណោះស្រាយ ទាក់ទងការដកកងទ័ពវៀតណាម និង ការផ្សះផ្សាជាតិ[278]។ ខ្ញុំយល់ថា ចំណាត់ការដ៏សម្ងាត់របស់លោកតាប្រធាន រ.ជ.រ.ប.ខ.នេះ ប្រហែលជាធ្វើតាមមតិរបស់លោក ថាច់ រ៉ែង ខ្លួនឯងតែម្តង ព្រោះលោក ថាច់ រ៉ែង មានទំនាក់ទំនងជាមួយក្រុមស៊ើបការសម្ងាត់របស់បារាំង ដែល

[277] ឯក សំអុល, ជំនួយស្មារតីស្តីពីដំណើរការចរចា ដើម្បីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជា, op. cit ។

[278] Son Sann, Front National de Libération du Peuple Khmer, Décision No 87/SPECIAL/FNL, le 23 Décembre 1987.

អាចផ្តល់គំនិត ឲ្យរ.ជ.រ.ប.ខ.ទាក់ទងផ្ទាល់ជាមួយក្រុងភ្នំពេញ ដើម្បីចរចាគ្នា ។ ក៏ប៉ុន្តែបេសកកម្មរបស់លោក ថាច់ រ៉េង នោះមិនបានទទួលជោគជ័យទេដោយសារលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន មិនព្រមទទួលឲ្យជួប ។ តាមជំនួយស្មារតីផ្ញើជូនលោកតា សឺន សាន លោកឧត្តមសេនីយ ថាច់ រ៉េង បង្ហាញហេតុផលថាបានជាលោក ហ៊ុន សែន មិនឲ្យជួបនោះ ព្រោះលោក ហ៊ុន សែន បានទទួលសំបុត្រមួយច្បាប់ពីអ្នកប្រឆាំងលោកតា សឺន សាន ម្នាក់នៅប្រទេសបារាំង ដែលជាក្រុមលោក សក់ ស៊ុតសាខន ។ សំបុត្រនោះរាយការណ៍យ៉ាងអាក្រក់អំពី រ.ជ.រ.ប.ខ. និង ជាពិសេស អំពីតួបុគ្គលរបស់ ឯ.ឧ. សឺន សាន ដែលនាំឲ្យលោក ហ៊ុន សែន សម្រេចមិនទទួលជួបជាមួយអ្នកតំណាងរបស់ប្រធាន រ.ជ.រ.ប.ខ. ។ បើតាមជំនួយស្មារតីនោះ លោក ថាច់ រ៉េង រាយការណ៍ថា លោក ហ៊ុន សែន ប្តេជ្ញាថានឹងធ្វើអ្វីៗទាំងអស់ដើម្បីទាក់ទាញសម្តេច សីហនុ ឲ្យមកសហការជាមួយក្រុងភ្នំពេញ ហើយថា លោក ហ៊ុន សែន នៅពេលនោះបដិសេធ ឯ.ឧ. សឺន សាន ចោល តែក៏បានឲ្យដឹងថា បើលោក សឺន សាន ចង់មកចូលរួម ឲ្យចូលទៅរួមប្រជុំក្នុងជំនួប សីហនុ-ហ៊ុន សែន លើកទី២ នៅពេលជាបន្តបន្ទាប់នោះទៅ ។ ជំនួយស្មារតីបានរាយការណ៍ទៀតថា នៅក្នុងប្រទេសមានការទាមទារតាមរយៈខិត្តបណ្ណជាច្រើនឲ្យសម្តេច សីហនុ យាងចូលកម្ពុជាឲ្យបានឆាប់ ហើយថាឯក្នុងប្រទេសនោះ គេមិនឮសម្លេងរបស់រ.ជ.រ.ប.ខ.ទាល់តែសោះ ។ នៅទីបញ្ចប់ លោក ថាច់ រ៉េង មានមតិថាត្រូវតែបន្តការតស៊ូតទៅទៀត ក៏ប៉ុន្តែបញ្ហានៅត្រង់ថាតើប្រទេសអាស៊ាន ចិន និងសហរដ្ឋអាមេរិកផ្តល់លទ្ធភាពជូនលោកប្រធានរ.ជ.រ.ប.ខ.ត្រឹមកំរិតណា[279]?

គួររំលឹកថា បន្ទាប់បានជួបចរចាជាមួយសម្តេច សីហនុ ពីថ្ងៃទី ២ ទៅ ៤ ធ្នូ ១៩៨៧ រួចមក លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានសរសេរសំបុត្រមួយច្បាប់ទៅ

[279] Thach Reng, Memorandum, (date illisible) Février 1988 ?

ជូនឥស្សរជន ៧ រូប ដែលបានជួយផ្តើមគំនិតជួយឲ្យមានការជួបគ្នាគឺ៖ ឯ. ឧ. ញឹក ជូឡុង ចៅសែនកុសល ឈុំ ហ៊ុយ កន្ទុល ឈាន វ៉ែម នង គិមនី ជុន អ៊ុក និង ឯ. ឧ. ឌួង សំអុល ដើម្បីថ្លែងអំណរគុណផង និង ដើម្បីអំពាវនាវឲ្យឥស្សរជនចាស់ទុំទាំងនោះ ជួយបន្តប្រឹងប្រែងខឹតខំអញ្ជើញភាគីឯទៀតមានលោកតា សឺន សាន និង លោក ខៀវ សំផន ឲ្យមកចូលរួមប្រជុំនៅលើកក្រោយៗទៀត[280]។ ដូចនេះ ជាដំបូងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន មានបំណងចង់ឲ្យមានការជួបចរចាជាមួយភាគីខ្មែរទាំងអស់ ក៏ប៉ុន្តែលោកក៏ត្រូវមានការប្រុយត្ន័ប្រយែងកុំឲ្យមានការបកស្រាយបន្តយសារសំខាន់នៃជំនួប សីហនុ - ហ៊ុន សែន ដែលទើបសម្រេចរួចរាងហើយនោះ ។ គេអាចវិភាគបានថាការដែលលោក ហ៊ុន សែន សម្រេចមិនទទួលជួបអ្នកតំណាងប្រធានរ.ជ.រ.ប.ខ.មានហេតុផលពីរយ៉ាង៖ ម្យ៉ាង បើទទួលឲ្យជួបហាក់ដូចជាទុកឲ្យលោកតា សឺន សាន កេងចំណេញខ្លាំងពេក ព្រោះលោកតា និង រ.ជ.រ.ប.ខ.តែងតែ និង នៅតែចាត់ទុករបបភ្នំពេញជារបបខុសច្បាប់ ជាកញ្ជះយួន ឬ អាយ៉ងយួន ។ កេងយកចំណេញ នៅត្រង់លោកតាអាចជួបផង និង អាចជេរផង ។ ដូច្នេះមិនត្រូវលបជួបជាសំងាត់ទេ ។ ម្យ៉ាងទៀត បើជួបលោកតា សឺន សាន សម្តេច សីហនុ អាចយល់ថាតួអង្គរបស់ព្រះអង្គមិនមានប្រយោជន៍អ្វីប៉ុន្មានឡើយ សម្រាប់ក្រុងភ្នំពេញ ។ នៅលើចំណុចនេះ សម្តេច សីហនុ បានលើកឡើងកាលពីថ្ងៃទី ១១ ធ្នូ ១៩៨៧ ក្នុងជំនួបជាមួយបណ្តាទូតនៃក្រុមប្រទេសអាស៊ាន នៅហ្វែរ អង់តាកដឺន័រ (Fères-en-Tardenois) ប្រទេសបារាំងថា ហ៊ុន សែន ត្រូវការ សឺន សាន និង ខៀវ សំផនជាងត្រូវការ សីហនុ[281] ។

[280] ហ៊ុន សែន, ១០ ឆ្នាំនៃដំណើរកម្ពុជា ១៩៧៩-១៩៨៩, op. cit.ទំព័រ ១៨០ ។

[281] ដូចយោងខាងលើ ។

លោកតា សឺន សាន និង មនុស្សស្និទ្ធរបស់លោកតា បានលាក់បាំងការប៉ុនប៉ងទាក់ទងជាសម្ងាត់ជាមួយមេដឹកនាំក្រុងភ្នំពេញយ៉ាងជិតបំផុត ។ ពួកយើងក្មេងៗដែលពេលនោះកំពុងស្នាក់នៅឯទីក្រុងបាងកក ជឿប្រាកដក្នុងចិត្តថាគ្មានការប៉ុនប៉ងទាក់ទងជាសម្ងាត់ណាមួយឡើយ ។ ពួកយើងជឿថាលោកតា សឺន សាន មិនមែនជាមនុស្សនិយាយផ្សេងធ្វើផ្សេងនោះទេ ។ ម្យ៉ាងទៀត ពួកយើងក៏មិនបានដឹងថាលោកតា សឺន សាន បានចេញសេចក្តីសម្រេចតែងតាំងលោក ថាច់ រ៉េង តាមផ្លូវការជាតំណាង ឲ្យទៅទាក់ទងជាសម្ងាត់ជាមួយមេដឹកនាំក្រុងភ្នំពេញសោះទេ ។ ការសម្ងាត់របស់លោកតា សឺន សាន បានត្រូវបែកធ្លាយនៅពេលសម្តេច សីហនុ ជួបចរចាជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន លើកទី ២ នៅ សាំង ហ្សែកម៉ាំង អង់ឡេយ (Saint-Germain-en-Laye) នៅថ្ងៃទី ២០ និង ២១ មករា ១៩៨៨ ព្រោះនៅពេលនោះ លោក ហ៊ុន សែន បានទូលសម្តេចអំពីការប៉ុនប៉ងទាក់ទងជាសម្ងាត់របស់លោកតា សឺន សាន តាមរយៈលោក ថាច់ រ៉េង ។ សម្តេច សីហនុ បានផ្សព្វផ្សាយព័ត៌មាននេះយ៉ាងទូលំទូលាយ នៅពេលព្រះអង្គរាយការណ៍អំពីជំនួបលើកទី២ ជាមួយលោក ហ៊ុន សែន នៅក្នុងរបាយការណ៍របស់ព្រះអង្គត្រង់ទំព័រទី៧ ភាគទី២ ។

គួរបញ្ជាក់ថា នៅថ្ងៃទី ១៩ មករា ១៩៨៨ គឺ មុនជំនួប សីហនុ-ហ៊ុន សែន លើកទី២ មួយថ្ងៃ លោកតា សឺន សាន បានចូលគាល់សម្តេច សីហនុ ដើម្បីបញ្ជាក់គោលជំហរដដែលៗសាជាថ្មីថាលោកតានឹងចូលរួមប្រជុំជាមួយ ប្រសិនបើមានអ្នកតំណាងប្រទេសវៀតណាមមានវត្តមានចូលរួមប្រជុំ ឬ ប្រសិនបើវៀតណាមផ្ញើលិខិតទៅលោកអគ្គលេខាអង្គការសហប្រជាជាតិ ដោយសន្យាថានឹងដកកងទ័ពទាំងអស់របស់ខ្លួនចេញពីប្រទេសកម្ពុជាក្រោយអង្គប្រជុំនោះ[282] ។ សេចក្តីប្រកាសព័ត៌

[282] Office of the Prime Minister, Coalition Government of Democratic Kampuchea, Communiqué de Presse, Paris, le 19 Janvier 1988.

មានរបស់ការិយាល័យលោករដ្ឋមន្ត្រីទី១ សឺន សាន នៅទីក្រុងប៉ារីសទាក់ទងនឹងការចូលគាល់នេះ មិនបាននិយាយដល់ការប៉ុនប៉ងជួបចរចាជាមួយលោក ហ៊ុន សែន ជាសម្ងាត់នោះទេ ។ ក៏ប៉ុន្តែ នៅថ្ងៃ ទី ២៣ មករា ១៩៨៨ បន្ទាប់ពីសម្តេច សីហនុ បានផ្សព្វផ្សាយព័ត៌មានស្តីពីការប៉ុនប៉ងទាក់ទងជាសម្ងាត់របស់លោកតា សឺន សាន នោះភ្លាម ការិយាល័យរ.ជ.រ.ប.ខ.ប្រចាំនៅទីក្រុងប៉ារីសជាទីដែលលោកតា សឺន សាន កំពុងស្នាក់នៅ បានចេញសេចក្តីប្រកាសមួយទៀត បដិសេធយ៉ាងដាច់អហង្ការនូវព័ត៌មាន ដែលថាលោកតា សឺន សាន ប៉ុនប៉ងស្វែងរកការចរចាជាសម្ងាត់ជាមួយលោក ហ៊ុន សែន ដោយបកស្រាយថាជាព័ត៌មានមិនពិតប្រឌិតដោយលោក ហ៊ុន សែន តែប៉ុណ្ណោះ ។ សេចក្តីប្រកាសព័ត៌មាននោះ បន្តទៀតថា ក្នុងឋានៈជារដ្ឋមន្ត្រីទី១នៃរដ្ឋាភិបាលស្របច្បាប់ ដែលទទួលស្គាល់ដោយអង្គការសហប្រជាជាតិ ឯ. ឧ. សឺន សាន មិនដែលមានគំនិតជួបនរណាមួយនៃរបបខុសច្បាប់នៅភ្នំពេញសោះឡើយ[283] ។ ជាមួយគ្នានេះ ពួកយើងដែលនៅប្រចាំការឯទីក្រុងបាងកកក៏ជួយបន្ថែមបដិសេធព័ត៌មានស្តីពីការប៉ុនប៉ងជួបសម្ងាត់របស់លោកតា សឺន សាន ថាជាព័ត៌មានមិនពិត ព្រោះព័ត៌មាននោះត្រូវបានផ្សព្វផ្សាយតាមបណ្តាញសារព័ត៌មានអន្តរជាតិ[284] ។ ជាងនេះទៅ ទៀត រូបខ្ញុំ (អៀង មូលី) ក្នុងឋានៈជាជំនួយការ (ឧបការី) នៃប្រធានរ.ជ.រ.ប.ខ.បានផ្ញើលិខិតមួយច្បាប់ទៅបណ្ណាធិការរបស់សាព័ត៌មានបាងកកប៉ុស្ត បំភ្លឺអត្ថបទមួយ របស់លោក ហ្សាក់ បេកាអែរ (Jacques Bekaert) ដែលសរសេរថា "លោក ប្រធានរ.ជ.រ.ប.ខ. សឺន សាន បានប៉ុនប៉ងដោយខ្លួនឯង ដើម្បីជួបជាសម្ងាត់ជា មួយលោក ហ៊ុន សែន" និងថា "ការប៉ុនប៉ងនេះនាំឲ្យក្រុមប្រទេសអាស៊ានរិះគន់យ៉ាងខ្លាំង"[285] ។ នៅក្នុង

[283] Le Bureau d'Information du FNLPK à Paris, Communiqué, Paris, le 23 Janvier 1988.
[284] Khmer People's National Liberation Front, Press Release, January 26, 1988.
[285] Ieng Mouly, Letter to the Editor, Bangkok Post, Bangkok, January 29, 1988.

លិខិតរបស់ខ្ញុំៗបដិសេធព័ត៌មាននោះទាំងស្រុងថាជាព័ត៌មានគ្មានមូលដ្ឋាន ព្រោះខ្ញុំជឿច្បាស់ថាលោកតា សឺន សាន មិនមានផែនការជួប លោក ហ៊ុន សែន នោះទេ បើគ្មានវត្តមានរបស់អ្នកតំណាងវៀតណាមនៅក្នុងអង្គប្រជុំ ដូចដែលលោកតាធ្លាប់ប្រកាសញឹកញាប់មកហើយ តាមបន្ទាត់នយោបាយរបស់រដ្ឋាភិបាលត្រីភាគី ។ ម្យ៉ាងទៀតខ្ញុំសរសេរបែបនោះ ក៏ដោយសារតែខ្ញុំពុំបានដឹងពីកិច្ចការសម្ងាត់ ដែលលោកតា សឺន សាន បានចាត់ចែងនៅឯទីក្រុងប៉ារីសជា មួយលោក ថាច់ រ៉ែង និងក្រុមគ្រួសាររបស់លោកតាយ៉ាងស្ងាត់ជាទីបំផុត ។

ជំនួបលើកទី២ នៅ សាំង ហ្សែកម៉ាំង អង់ ឡេយ

នៅជំនួប សីហនុ-ហ៊ុន សែន លើកទី២ អ្វីដែលព្រះអង្គចង់បានជាចម្លើយពីលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន គឺការដកកងទ័ពវៀតណាម និង ការបង្កើតរបបរដ្ឋមួយថ្មី ដែលមិនមែនជាសាធារណរដ្ឋប្រជាមានិតកម្ពុជា និង ក៏មិនមែនជារដ្ឋកម្ពុជាប្រជាធិបតេយ្យរបស់ខ្មែរក្រហមដែរ ។ សម្តេច សីហនុ ធ្លាប់ដាក់ជាលក្ខខណ្ឌចំពោះលោក ខៀវ សំផន និង លោកតា សឺន សានឲ្យផ្លាស់ប្តូរឈ្មោះ ទង់ជាតិ និងភ្លេងជាតិរបស់ខ្មែរក្រហមចេញ ដោយឲ្យយកឈ្មោះកម្ពុជាជាភាសាខ្មែរ ឲ្យយកទង់ជាតិខ្មែរសម័យមុនសង្គ្រាមគឺទង់ ពណ៌ខៀវ ក្រហម និង រូបប្រាសាទអង្គរពណ៌ាសកំពូលបីនៅចំកណ្តាល រីឯភ្លេងជាតិឲ្យយកបទនគររាជត្រង់វគ្គទី ២ បើចង់ឲ្យព្រះអង្គបន្តសហការតទៅទៀត ។ ជាមួយនោះសម្តេច សីហនុ ក៏ចង់ឲ្យលោក ហ៊ុន សែន ទទួលយកសំណើនេះរបស់ព្រះអង្គដែរ ។ នៅត្រង់ចំណុចនេះ លោក ខៀវ សំផន ក្នុងនាមខ្មែរក្រហម បានធ្វើសំបុត្រមួយច្បាប់មកលោកតា សឺន សាន ដើម្បីកុំឲ្យបោះបង់ចោលនូវរដ្ឋកម្ពុជាប្រជាធិបតេយ្យ ដែលមានលក្ខណៈស្របច្បាប់ដោយបានការទទួលស្គាល់ពីអង្គការសហប្រជាជាតិ ។ លោក ខៀវ សំផន បាន

សរសេរថា "យើងចាំបាច់ឈរឲ្យរឹងមាំលើហានៈនៃរដ្ឋកម្ពុជាប្រជាធិបតេយ្យជារដ្ឋ ស្របច្បាប់តែមួយគត់នៃកម្ពុជា" ។ តែអ្វីដែលគួរឲ្យអស់សំណើចនោះ នៅត្រង់ មេខ្មែរក្រហមរូបនេះអះអាងថា "រដ្ឋកម្ពុជាប្រជាធិបតេយ្យប្រសូតចេញមកពីសភា ដែលជ្រើសរើសឡើងតាមការបោះឆ្នោតសកល សេរី ផ្ទាល់ និង ស្ងាត់ នាខែ កុម្ភៈ ១៩៧៦" (លោក ខៀវ សំផន មិនបានដាក់ឲ្យច្បាស់លាស់ទេថា តើខ្មែរក្រហម បោះឆ្នោតនៅថ្ងៃណានាខែ កុម្ភៈ ១៩៧៦នោះ) ។ នៅពេលនោះ ខ្មែរក្រហមនៅ ចចេសមិនទាន់ទទួលយកសំណើរបស់សម្តេច សីហនុ នៅឡើយទេ ។ ចំណែកឯ រ.ជ.រ.ប.ខ.មិនមានបញ្ហាអ្វីទេ ក្នុងការទទួលតាមសំណើរបស់ព្រះអង្គ ។ គួររំលឹកថា នៅក្នុងជំនួបលើកទី២ នៅ សាំង ហ្សែកម៉ាំង អង់ ឡេយនោះ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានទូលសួរសម្តេច សីហនុ ថាតើការបង្កើតរបបថ្មីនោះស្ថិតនៅលើមូល ដ្ឋានច្បាប់អ្វី? ព្រោះថាលោកនាយករដ្ឋមន្ត្រីជឿថាមានតែសាធារណរដ្ឋប្រជាមានិត កម្ពុជាទេ ដែលជាកម្លាំងយ៉ាងរឹងមាំដើម្បីវាយកំទេចរបបប្រល័យពូជសាសន៍ ប៉ុល ពត កុំឲ្យវិលមកកាប់សម្លាប់ប្រជាជនទៀតបាន ។ កាលពីជំនួបលើកមុន នៅខែ ធ្នូ កន្លងទៅលោក ហ៊ុន សែន ធ្លាប់ស្នើសម្តេច សីហនុ ឲ្យភាគីទាំងពីរសហការគ្នា ដើម្បីដោះស្រាយបញ្ហាកម្ពុជាគឺ សម្តេចវិលត្រឡប់មកដឹកនាំសាធារណរដ្ឋប្រជាមា និតកម្ពុជា ចំណែកឯកម្លាំងរបស់ព្រះអង្គ នឹងមានតួនាទីដ៏សំខាន់ក្នុងការកសាង ប្រទេស[286] ។ តាមពិតទៅ មេដឹកនាំក្រុងភ្នំពេញមានយុទ្ធសាស្ត្រ និង យុទ្ធវិធី ច្បាស់លាស់ក្នុងការចរចាគឺៈ ១-រក្សាឲ្យបាននូវសមិទ្ធផលសង្គម ដែលកើតចេញពី ថ្ងៃ ៧ មករា ១៩៧៩ និង ២-វាយកំទេចឲ្យអស់នូវរបបប្រល័យពូជសាសន៍ ទាំងកម្លាំងយោធា ទាំងអង្គការចាត់តាំងនយោបាយ ។ នៅជំនួបលើកទី ២ នាខែ មករា ១៩៨៨ នេះដែរ លោក ហ៊ុន សែន ក៏បានស្នង់ស្ទាបមតិសម្តេច សីហនុ

[286] កែវ បាភ្នំ, សម្តេច ហ៊ុន សែន និង ពាក្យសន្យាជាប្រវត្តិសាស្ត្រ, ឯកសារជំនួយស្មារតី op. cit. ទំព័រ ៧៧ ។

ថាតើព្រះអង្គយល់យ៉ាងណា ប្រសិនបើមានជំនួប ហ៊ុន សែន-សឺន សាន ដោយសារតែលោកតា សឺន សាន បានសុំជួបជាសម្ងាត់? តាមការវាយតម្លៃរបស់មេដឹកនាំក្រុងភ្នំពេញ សម្តេចមិនចង់ទុកឲ្យលោកតា សឺន សាន ចូលរួមក្នុងការចរចា ហ៊ុន សែន - សីហនុ ទេគឺ ព្រះអង្គមិនចង់ឲ្យភាគី សឺន សាន ជួបភាគីភ្នំពេញ ទេ[287] ។ គួររំលឹកថា នៅពេលដែលសម្តេច សីហនុ ផ្សព្វផ្សាយដំណឹងអំពីលោកតា សឺន សាន ចង់ជួបជាសម្ងាត់ជាមួយភាគីភ្នំពេញនោះ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ក៏បានឲ្យអ្នកកាសែតដឹងពីលិខិតសិទ្ធិប្រទានដែលលោកតា សឺន សាន ផ្តល់ឲ្យលោកឧត្តមសេនីយ ថាច់ រ៉ែង ទាក់ទងជាមួយភាគីភ្នំពេញ ។ លោក ហ៊ុន សែន ធ្វើយ៉ាងនេះ ដើម្បីទប់ទល់ជាមួយលោកតា សឺន សាន ផង និង ដើម្បីជាជំនួយគាំទ្រសម្តេច សីហនុ ផង ។ សកម្មភាពនយោបាយរបស់លោក ហ៊ុន សែន បែបនេះ បានជានាំចំពោះសម្តេច សីហនុ នូវសារៈសំខាន់នៃសហការរវាងភាគីទាំងពីរ ដែលត្រូវតែដើរទៅមុខជានិច្ច ទោះបីជាភាគីពីរទៀតមិនចូលរួមក៏ដោយ ។ ម្យ៉ាងទៀត ការលាតត្រដាងការសម្ងាត់ស្តីពីសំណើសុំជួបពីសំណាក់លោកតា សឺន សាន ជាការបញ្ជាក់ថ្វាយសម្តេច សីហនុ ថាទោះបីជាដៃគូរបស់ព្រះអង្គក្នុងជួររដ្ឋាភិបាលចម្រុះប្រកាស មិនជួបចរចាជាមួយក្រុងភ្នំពេញយ៉ាងណាក៏ដោយ ក៏គង់មានអ្នកខ្លះមកលបសុំជួបដោយស្ងាត់ៗដែរ ។

នៅថ្ងៃទី ២០ កុម្ភៈ ១៩៨៨ ពីទីក្រុងប៉េកាំង សម្តេច សីហនុ ផ្ញើសារជូនជនរួមជាតីខ្មែរ ដែលអានដោយព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ជាព្រះរាជបុត្រ និងជាតំណាងព្រះអង្គប្រចាំនៅទីក្រុងបាងកក ដើម្បីពន្យល់ពីដំណើរការនៃការចរចាកន្លងមកជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ។ សម្តេច សីហនុ ទាញហេតុផលថា ដោយសារលោក ហ៊ុន សែន មិនព្រមរំលាយរបបសាធារណរដ្ឋប្រជាមានិត

[287] កែវ បាភ្នំ, មានយោងដូចខាងលើ ទំព័រ ១០៨ ។

កម្ពុជា ជាមួយនិងការបដិសេធមិនព្រមរំលាយរបបកម្ពុជាប្រជាធិបតេយ្យ ព្រះអង្គ មិនទាន់អាចយាងចូលមកក្នុងប្រទេសបាននៅឡើយទេ ។ នៅក្នុងសាររបស់ព្រះ អង្គនោះ សម្តេច សីហនុ វាយប្រហារភាគីឯទៀតថាមិនបានគិតពីផលប្រយោជន៍ ជាតិ គិតតែប្រយោជន៍រៀងៗខ្លួន ដោយហៅឈ្មោះភាគីទាំងនោះជាភាគីខ្មែរវៀត មិញ ខ្មែរក្រហម និង ខ្មែរខៀវ (ខ្មែរខៀវគឺពួក សឺន សាន - សក់ ស៊ុតសាខន សាធារណរដ្ឋនិយម) ។ ក៏ប៉ុន្តែលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានធ្វើសេចក្តី សន្និដ្ឋានបែបសុទិដ្ឋិនិយមលើជំនួប សីហនុ - ហ៊ុន សែន លើកទី២ នៅប្រទេស បារាំងថា ការចរចាលើកទី ២ នេះ ពិតមែនតែបានបញ្ចប់ដោយគ្មានចេញសេចក្តី ប្រកាសរួម ប៉ុន្តែភាគីទាំងពីរសុទ្ធតែចាត់ទុកថាជាជំហានរីកចំរើនមួយថ្មីទៀតក្នុង ការឆ្ពោះទៅរកការដោះស្រាយពិតប្រាកដនូវបញ្ហាកម្ពុជា ។ មិនតែប៉ុណ្ណោះ ភាគី ទាំងពីរបានព្រមព្រៀងថានឹងជួបគ្នាជាបន្តបន្ទាប់ទៀត ។

ខ្ញុំសូមស្លេះទុកមួយអន្លើសិន នូវដំណើរបត់បែនទៅរកសន្តិភាពនៅ កម្ពុជា ត្រឹមភាគទីមួយនេះ ក៏ប៉ុន្តែនឹងបន្តនៅភាគទីពីរក្នុងសៀវភៅមួយទៀត ។ នៅក្នុង ដំណើរសន្តិភាពនេះ ជំនួប សីហនុ-ហ៊ុន សែន ជាចំណុចគន្លឹះមួយនៃដំណោះ ស្រាយបញ្ហាកម្ពុជា នៅពេលដែលបញ្ហានេះត្រូវបានបំបែកជាពីរទិដ្ឋភាពគឺ ទិដ្ឋ ភាពជាតិ និង ទិដ្ឋភាពអន្តរជាតិ ។ នៅក្នុងទិដ្ឋភាពជាតិ លោកនាយករដ្ឋមន្ត្រីហ៊ុន សែន សង្កត់ធ្ងន់លើការផ្សះផ្សាបង្រួបបង្រួមជាតិ ដោយមានមូលដ្ឋានលើការវាយ ផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត រួមទាំងកម្លាំងយោធា និង អង្គការចាត់ តាំងនយោបាយផង ។ ភាគីណាដែលប្រឆាំងនិងគោលការណ៍បែបនេះ ប្រាកដ ជានឹងត្រូវទទួលការចោទប្រកាន់ពីសំណាក់ប្រជាជនកម្ពុជាថា ចូលដៃជាមួយ ប៉ុល ពត មិនខានឡើយ ។ ជំនួប សីហនុ-ហ៊ុន សែន បានទម្លុះភាពទាល់ច្រកមួយ ព្រោះនោះជាការចាប់ផ្តើមនៃការផ្សះផ្សាជាតិ ដែលជាកត្តាចម្បងបំផុតនៃការ

កសាងសន្តិភាព និង ការរស់រានមានជីវិតរបស់កម្ពុជាយើង ។ ការដែលសម្តេច សីហនុ ជួបចរចាជាមួយមេដឹកនាំក្រុងភ្នំពេញ ក៏បានន័យថាព្រះអង្គទទួលស្គាល់ សមិទ្ធផលសង្គម ដែលកើតឡើងដោយសារថ្ងៃទី ៧ មករា ១៩៧៩ រួចទៅហើយ ។ ជំនួបនេះ ក៏បង្ហាញឲ្យឃើញថាខ្មែរខ្លួនឯង ក៏ខំស្វែងរកដំណោះស្រាយ បញ្ហារបស់ខ្មែរដែរ ទោះជាបញ្ហានោះរបូតផុតពីដៃខ្មែរយ៉ាងណាក៏ដោយ ។ ទាំងនេះក៏ជាសម្ពាធនយោបាយទៅលើតួអង្គទាំងអស់នៅក្នុងជម្លោះកម្ពុជា ឲ្យសិក្សាឡើងវិញនូវយុទ្ធសាស្ត្ររៀងៗខ្លួន ។ ជំនួប សីហនុ-ហ៊ុន សែន មិនអាចកើតមានបានឡើយ ប្រសិនបើគ្មានសេចក្តីប្តេជ្ញាចិត្តយ៉ាងដាច់ខាតពីតួអង្គដ៏សំខាន់ ២ អង្គ នៃប្រវត្តិសាស្ត្រសម័យទំនើបរបស់កម្ពុជា ។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ក្នុងភាពអង់អាច បានដឹកនាំការប្រយុទ្ធយ៉ាងមុតស្រួច តម្រង់ទៅគោលដៅមួយដោយគ្មានងាករេគឺ ការផ្តួលរំលំរបបប្រល័យពូជសាសន៍ឲ្យបានជោគជ័យ ទោះជាត្រូវធ្វើពលីកម្មអ្វីក៏ដោយ ។ សម្តេចព្រះ នរោត្តម សីហនុ ដែលរាល់សកម្មភាពរបស់ព្រះអង្គ សុទ្ធតែត្រូវបានផ្សារភ្ជាប់ជាមួយនឹងព្រឹត្តិការណ៍របស់ប្រជាជាតិខ្មែរទាំងអស់នោះ បានប្តេជ្ញាថាអ្វីៗអាចធ្វើបានទាំងអស់ ឲ្យតែអាចបញ្ចប់ទុក្ខវេទនារបស់កូនចៅ ប្រជារាស្ត្ររបស់ព្រះអង្គបាន ទោះជាត្រូវប្រឈមជាមួយឧបសគ្គអ្វីក៏ដោយ ។

សេចក្តីសន្និដ្ឋាន

នៅក្នុងប្រទេសនីមួយៗ វាសនារបស់ពលរដ្ឋ តែងត្រូវបានផ្សារភ្ជាប់ទៅនឹងវាសនារបស់ជាតិ ឯវាសនាជាតិក៏អាស្រ័យលើគុណភាព ឬ ទេពកោសល្យដឹកនាំរបស់អ្នកដឹកនាំ និង របៀបរបបគ្រប់គ្រងនៃប្រទេសជាតិនោះ ។ ប្រទេសកម្ពុជាយើងពីឆ្នាំ ១៩៦០ ទៅ ១៩៧០ ស្ថិតនៅក្នុងបរិបទភូមិសាស្ត្រនយោបាយមួយដែលមហាអំណាចប្រើកម្លាំងរៀងៗខ្លួន ដើម្បីដណ្តើមឥទ្ធិពលលើប្រទេសតូចតាច ។ ប្លុកម្ខាងធ្វើសង្គ្រាមក្នុងនាមមនោគមវិជ្ជាកុម្មុយនីស្ត ដើម្បីរំដោះមនុស្សជាតិចេញពីអាណានិគមនិយម មូលធននិយម ក្នុងន័យកសាងសង្គមអន្តរជាតិមួយដែលជឿនលឿន ស្អាតស្អំ និង ស្មើភាពគ្នា ។ ប្លុកមួយទៀត ធ្វើសង្គ្រាម ដើម្បីការពារសិទ្ធិ សេរីភាព និង សេចក្តីថ្លៃថ្នូររបស់មនុស្ស ។ កម្ពុជាយើង នាសម័យនោះជ្រើសយកផ្លូវកណ្តាល ដោយប្រកាន់យកមាគ៌ានៃអព្យាក្រឹតភាព ដែលជាធម្មតាមិនត្រូវមានការលំអៀងទៅខាងប្លុកណាមួយឡើយ ។ បន្ថែមលើនោះ ទ្រឹស្តីព្រះពុទ្ធសាសនាក៏ត្រូវបានយកមកបូកផ្សំ បង្កើតមនោគមវិជ្ជាជាតិមួយ ដែលមានឈ្មោះថា "សង្គមនិយមព្រះពុទ្ធសាសនា" ។ នយោបាយអព្យាក្រឹត្យនោះ បាននាំមកនូវសន្តិភាពក្នុងមួយរយៈពេល ក៏ប៉ុន្តែនៅទីបំផុតក៏មិនអាចបញ្ចៀសភ្លើងសង្គ្រាមមិនឲ្យឆាបឆេះកម្ពុជាបានឡើយ ។ អស់ជិតបីទសវត្សរ៍ ប្រទេសយើងក៏ទទួលរងនូវមហាវិនាសកម្ម ដែលនាំឲ្យខ្មែររាប់លាននាក់បានបាត់បង់ជីវិត ។

មនុស្សដែលបានឆ្លងកាត់សង្គ្រាម ដែលនៅសេសសល់ពីសង្គ្រាម ភាគច្រើនប្រាកដជាអាចវាយតម្លៃបានថា តើសន្តិភាពមានន័យពិតៗយ៉ាងណា? និងមានតម្លៃកម្រិតណា? ជាពិសេស សន្តិភាពក្នុងសេរីភាព ។ គេពិតជាទទួលស្គាល់ថាសន្តិភាពដែលនាំមកនូវសេរីភាព និង សេចក្តីថ្លៃថ្នូររបស់មនុស្សមានតម្លៃមហា

សាលដែលគ្មាននរណាអាចកាត់ថ្លៃបានឡើយ ។ គឺសន្តិភាពក្នុងសេរីភាពនេះ ហើយ ដែលខ្មែរយើងម្នាក់ៗប៉ងប្រាថ្នាចង់បាន ។

ក្នុងចំណោមអ្នករស់រានមានជីវិត រួចផុតពីសម័យសង្គ្រាម អ្នកខ្លះប្រើបញ្ញា ឬ ការឈ្លាសវៃ ចេះរៀនសូត្រពីពេលវេលា ទឹកដីទីកន្លែង ដើម្បីរស់ ។ អ្នកខ្លះទៀត រស់បាន ដោយពឹងផ្អែកលើទេវតា ជឿលើព្រេងសំណាងពីជាតិមុន បណ្តោយជីវិត តាមព្រហ្មលិខិត គឺស្រេចលើអ្វីៗដែលទេវតាចារទុកទាំងអស់ ។ អ្នកទាំងនោះសុទ្ធ តែបានទទួលនូវបទពិសោធន៍រៀងៗខ្លួន ដែលគួរតែបន្សល់ទុកឲ្យអនុជនជាន់ ក្រោយបានយល់ដឹង ។

អ្វីដែលយើងអាចយល់ដឹងបាន តាមរយៈព្រឹត្តិការណ៍នយោបាយកន្លងមក នោះគឺ៖

-អព្យាក្រឹតភាពនៃកម្ពុជាពីឆ្នាំ ១៩៥៧ ទៅ ១៩៧០ អាចទទួលជោគជ័យ បញ្ចៀសសង្គ្រាមបាន ប្រសិនបើកម្ពុជាមានឯកភាព និង សាមគ្គីភាពពិតប្រាកដ និង ប្រសិនបើប្រទេសជិតខាងស្ថិតនៅក្នុងសន្តិភាពដូចយើងដែរ ។ ម្យ៉ាង នៅក្នុង ផ្នែកនយោបាយផ្ទៃក្នុង យើងពុំមានឯកភាព និង សាមគ្គីភាពពិតប្រាកដឡើយ ។ តាមពិត ចលនាសង្គមរាស្ត្រនិយមមានគោលដៅបង្រួបបង្រួមជាតិ ក៏ប៉ុន្តែ អ្នក នយោបាយខ្មែរត្រូវបានបែងចែកជា៖ ខ្មែរក្រហម ខ្មែរខៀវ និង ខ្មែរស៊ីជម្ពូជាដើម ។ ម្យ៉ាងទៀត ទោះជាយើងប្រកាសថាយើងប្រកាន់នយោបាយអព្យាក្រឹត្យឥតលំអៀង យ៉ាងណាក៏ដោយ ក៏សហរដ្ឋអាមេរិក នៅតែចោទប្រកាន់ និង រករឿងប្រទេស កម្ពុជាថាជាជម្រករបស់កងទ័ពវៀតកុង ដែលកំពុងតែធ្វើសង្គ្រាមរំដោះជាតិ ប្រឆាំង អាមេរិកនៅប្រទេសវៀតណាមនាសម័យនោះ ។ ដូច្នេះ សង្គ្រាមនៅវៀតណាម ក៏រីករាលដាលមកដល់កម្ពុជា ។

-ប្រទេសចិនដើរតួនាទីដ៏សំខាន់នៅក្នុងសង្គ្រាមឥណ្ឌូចិន និង ជាប់ជំពាក់

យ៉ាងខ្លាំង នៅក្នុងជម្លោះកម្ពុជា ។ ប្រទេសចិនបានផ្តល់ការគាំទ្រឥតសំចៃដល់សម្តេចព្រះ នរោត្តម សីហនុ នៅគ្រប់កាលៈទេសៈទាំងអស់ ដែលគ្មានប្រទេសមហាអំណាចណាធ្វើដូចឡើយ ។ ក៏ប៉ុន្តែជាមួយនោះ ប្រទេសចិនក៏ជាសម្ព័ន្ធមិត្រយ៉ាងជិតស្និទ្ធបំផុតនៃរបបកម្ពុជាប្រជាធិបតេយ្យរបស់ ប៉ុល ពត ។ ទាំងអស់នោះក៏ដើម្បីផលប្រយោជន៍របស់ចិន ក្នុងការទប់ស្កាត់ឥទ្ធិពលរបស់មហាអំណាចឯទៀតនៅក្នុងតំបន់ដែរ ។

-ក្នុងមួយព្រះជន្មរបស់ព្រះអង្គ សម្តេចព្រះ នរោត្តម សីហនុ បានដើរតួនាទីជាប្រវត្តិសាស្ត្រ និង បានផ្សារភ្ជាប់វាសនាផ្ទាល់របស់ព្រះអង្គ ទៅនឹងវាសនារបស់ប្រជាជាតិខ្មែរទាំងមូល ។ កាលណាគេនិយាយអំពីប្រទេសកម្ពុជាក្រោយសង្គ្រាមលោកលើកទី២ គេមិនអាចបំភ្លេច មិននិយាយបានឡើយ អំពីសម្តេចព្រះ នរោត្តម សីហនុ ។ ព្រះអង្គ ឡើងគ្រងរាជសម្បត្តិក្នុងយុវវ័យ នៅក្នុងសម័យអាណាព្យាបាលបារាំង ។ បន្ទាប់មក ព្រះអង្គដឹកនាំព្រះរាជបូជនីយកិច្ចទាមទារ និង ទទួលបាននូវឯករាជ្យពីបារាំង ។ ព្រះអង្គផ្ទេររាជសម្បត្តិទៅព្រះវររាជបិតា ដែលគេមិនដែលឃើញសោះនៅក្នុងលោក ដើម្បីយាងចូលប្រឡូកក្នុងឆាកនយោបាយ ។ នៅក្នុងសម័យសាធារណរដ្ឋខ្មែរ ព្រះអង្គទទួលរងនូវការប្រមាថ និង បន្ទាបបន្ថោកជាអតិបរមា ។ ព្រះអង្គបានគង់នៅក្នុងរបប ប៉ុល ពត ដែលកាប់សម្លាប់ព្រះញាតិវង្សរបស់ព្រះអង្គ ព្រមទាំងបានវាយប្រហាររបបគ្រប់គ្រងរដ្ឋសម័យសង្គមរាស្ត្រនិយមថាជារបបសក្តិភូមិ ។ ដោយសារការវាយផ្តួលរំលំរបប ប៉ុល ពត ដោយកងទ័ពវៀតណាម និង កងទ័ពនៃរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ព្រះអង្គក៏នៅគង់ព្រះជន្មដែលក្រោយមកនាំឲ្យព្រះអង្គ អាចរំដោះព្រះកាយពីការឃុំគ្រងរបស់ខ្មែរក្រហមទៀតផង ។ ព្រះអង្គមានទេពកោសល្យក្នុងការថែរក្សានូវសេចក្តីស្រឡាញ់ និងស្វាមីភក្តិពីប្រជារាស្ត្រតូចតាច អ្នកស្រែចំការខ្មែរចំពោះព្រះអង្គជានិច្ច ។ ព្រះ

ករុណាព្រះមហាវីរក្សត្រ សម្តេចតារបស់យើងបានបង្ហាញពីសមត្ថភាពខ្ពស់ក្នុងការ ការពារអាយុជីវិតនយោបាយរបស់ព្រះអង្គបាន គ្រប់កាលសម័យ ទោះជាត្រូវជួបនូវ មហាឧបសគ្គបែបណាក៏ដោយ ។ ព្រះអង្គអាចរក្សាព្រះជន្ម និង អាចចេញមកដើរ តួនាទីដឹកនាំនយោបាយនៅកម្ពុជាជាថ្មីទៀតបាន រហូតសម្រេចនូវកិច្ចព្រមព្រៀង សន្តិភាពមួយ ដែលគ្មានអ្នកនយោបាយខ្មែរណាធ្វើដូចបានឡើយ ។

-របបសាធារណរដ្ឋរបស់លោក លន់ នល់ ដែលកើតចេញពីព្រឹត្តិការណ៍ ១៨ មីនា ១៩៧០ បានយកសន្ទុះទឹកចិត្តជាតិនិយមប្រឆាំងវៀតណាមរបស់ខ្មែរ ជាពិសេស ខ្មែរអ្នកនៅទីក្រុង និង បញ្ញវន្តមួយចំនួន ដើម្បីទាញយកលក្ខណៈស្រប ច្បាប់ និង ការគាំទ្រពីប្រជាពលរដ្ឋខ្មែរ ។ ក៏ប៉ុន្តែ អសមត្ថភាពក្នុងការដឹកនាំ និង អំពើពុករលួយដែលស៊ីរូងសង្គមជាតិទាំងមូលនៅសម័យសាធារណរដ្ឋ បានធ្វើឲ្យ របបនេះធ្លាក់ខ្លួនទន់ខ្សោយជាទីបំផុត ដែលត្រូវពឹងផ្អែកទាំងស្រុងតែទៅលើជំនួយ របស់អាមេរិកតែប៉ុណ្ណោះ ។ របបបែបនេះ មិនអាចរស់រានមានជីវិតបានឡើយ បើទោះជាទទួលជំនួយទំហំធំកម្រិតណាក៏ដោយ ។

-របបខ្មែរក្រហម ប៉ុល ពត បានឆ្លៀតយកចំណេញពីការទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ចេញពីអំណាចរបស់ក្រុមលោក លន់ នល់ នៅឆ្នាំ ១៩៧០ ដើម្បីយកព្រះនាមព្រះអង្គមកប្រើ ក្នុងការបង្កើតកម្លាំងរណសិរ្សរួបរួមជាតិមួយ ឆ្ពោះទៅដណ្តើមអំណាច ។ ខាងផ្នែកកងទ័ព ជាដំបូង ពួក ប៉ុល ពត ឆ្លៀតប្រើកង ទ័ពវៀតណាមកុម្មុយនីស្ត ជាកម្លាំងស្រួច ក្នុងការវាយកំទេចកងទ័ពសាធារណរដ្ឋ ខ្មែរ បន្ទាប់មក ពួកគេក៏ច្បាំងជាមួយកងទ័ពវៀតណាមវិញម្តង ។ ប៉ុល ពត បានយកការភូតភរកុហកបោកប្រាស់ ការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ និង ការកាប់ សម្លាប់មនុស្សដោយឥតរើសមុខ និង ដោយគ្មានការជំនុំជំរះ ជាមធ្យោបាយក្នុងការ ក្តោបក្តាប់អំណាចរបស់ខ្លួន ។ របៀបគ្រប់គ្រងបែបនេះ ក៏ក្លាយទៅជាអំពើប្រល័យ

ពូជសាសន៍ និង បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិមួយ ដែលគ្មាននរណាអាចលើកលែងទោសឲ្យបានឡើយ ។ ចលនាតស៊ូរើបំរះប្រឆាំង ប៉ុល ពត ក៏លេចចេញឡើងតាមរូបភាពផ្សេងៗ ជាចលនាផ្ទៃក្នុងក៏មាន ជាចលនាតស៊ូនៅតាមទល់ដែន ខ្មែរ-ថៃ ក៏មាន ។ ប៉ុន្តែ ដោយសារការរៀបចំរបស់ ប៉ុល ពត ឲ្យមហាជនរស់នៅជាសមូហភាពតាមរបៀបបាយរួម ធ្វើការរួម ការផ្តត់ផ្តង់កស្តុការដល់រាល់ចលនាតស៊ូរើបំរះផ្ទៃក្នុង ពិតជាមានការលំបាកខ្លាំងណាស់ ។ ដូច្នេះ បើគ្មានអន្តរាគមន៍ពីកម្លាំងខាងក្រៅឲ្យទាន់ពេលវេលាទេ ការផ្តួលរំលំរបប ប៉ុល ពត នឹងត្រូវប្រើពេលវេលាយូរដែលអាចឲ្យក្រុម ប៉ុល ពត អាចបន្តកាប់សម្លាប់ខ្មែរច្រើនហ្មឺន ច្រើនសែននាក់ទៀត ទោះជាពួកនេះត្រូវប្រជាពលរដ្ឋទូទាំងប្រទេស ស្អប់ខ្ពើមជាទីបំផុតយ៉ាងណាក៏ដោយ ។ ដោយសារគ្មានការគាំទ្រពីប្រជាពលរដ្ឋ របប ប៉ុល ពត រស់បានតែ ៣ ឆ្នាំ ៨ ខែ ២០ ថ្ងៃប៉ុណ្ណោះគឺ មានអាយុខ្លីជាងរបបសាធារណរដ្ឋ លន់ នល់ ទៅទៀត ។

-កងទ័ពវៀតណាម ដែលធ្លាប់កៀកស្មាប្រយុទ្ធរួមគ្នាជាមួយខ្មែរក្រហម នៅគ្រាដំបូង ក្នុងសង្គ្រាមប្រឆាំងរបបលោក លន់ នល់ នៅទីបំផុត ក៏បានត្រឡប់មកជួយវាយផ្តួលរំលំរបប ប៉ុល ពត វិញ ដោយទទួលជោគជ័យ នៅថ្ងៃទី ៧ មករា ១៩៧៩ ។ ក៏ប៉ុន្តែ វត្តមាននៃកងទ័ពវៀតណាមនៅកម្ពុជា ក៏ត្រូវទទួលការចោទប្រកាន់ថា ជាអំពើឈ្លានពានកម្ពុជាហើយចំណុចនេះ ក៏ក្លាយជាហេតុផលនៃការកកើតចលនាអ្នកជាតិនិយមប្រឆាំងវៀតណាម ពីសំណាក់ជនជាតិខ្មែរមួយចំនួនជាពិសេស ពីជនជាតិខ្មែរនៅក្រៅប្រទេស ។ ទាំងនេះ ក៏ដោយសារប្រជាពលរដ្ឋខ្មែរជាទូទៅ តែងតែមើលឃើញនៅក្នុងប្រវត្តិសាស្ត្ររបស់ខ្លួនថា រាល់អន្តរាគមន៍របស់កងទ័ពនៃប្រទេសជិតខាងនៅកម្ពុជា ជាអំពើឈ្លានពានដើម្បីត្របាក់លេបយកទឹកដីកម្ពុជា ។ ជាមួយនោះ ពួកខ្មែរក្រហមក៏ឆ្លៀតកេងយកចំណេញពីសន្ទុះទឹកចិត្ត

ជាតិនិយមនេះ ហើយទទួលបានការចូលរួមបង្កើតរណសិរ្សប្រឆាំងវៀតណាមមួយ ក្នុងរូបភាពជារដ្ឋាភិបាលចម្រុះត្រីភាគី ពីសម្តេចព្រះ នរោត្តម សីហនុ និង លោកអតីតរដ្ឋមន្ត្រីទី១ សឺន សាន ។ ក៏ប៉ុន្តែមហាសោកនាដកម្មដែលប្រជាពលរដ្ឋ ខ្មែរទទួលរងក្នុងរបបប្រល័យពូជសាសន៍ បាននាំឲ្យមានការផ្តន្ទាទោសរបបខ្មែរ ក្រហមកាន់តែខ្លាំងឡើង និង កាន់តែមានលក្ខណៈសកលឡើង ។ និន្នាការនេះ ក៏ សមស្របជាមួយគោលនយោបាយវាយកំទេចខ្មែរក្រហមប្រល័យពូជសាសន៍ ទាំង អង្គការចាត់តាំងនយោបាយ ទាំងអង្គការចាត់តាំងយោធា ដឹកនាំដោយលោក នាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលប្រកាន់យកយ៉ាងខ្ជាប់ខ្ជួន និង នាំមុខអនុវត្តបាន ដោយប្រសិទ្ធភាព ។

-នៅក្នុងសម័យកាលប្រទេសជាតិធ្លាក់ក្នុងក្តីមហន្តរាយ ក៏លេចចេញនូវអ្នក ដឹកនាំខ្មែរវ័យក្មេងមួយរូប ដែលមានជាតិកំណើតចេញពីត្រកូលកសិករខ្មែរសុទ្ធ សាធ និង ដែលបានប្តេជ្ញាចិត្តវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ឲ្យបានសម្រេច ដើម្បីរំដោះប្រជាពលរដ្ឋខ្មែរចេញពីទាសភាព ទោះជាត្រូវស្វែងរកជំនួយពីកងទ័ព បរទេសឲ្យមកជួយក៏ដោយ ។ លោកនាយករដ្ឋមន្ត្រីវ័យក្មេង ហ៊ុន សែន បានប្រើ យុទ្ធសាស្ត្រផ្តួលរំលំរបបប្រល័យពូជសាសន៍ប្រកបដោយជោគជ័យ ដើម្បីវាយបក ទៅគ្រប់ការឡោមព័ទ្ធសេដ្ឋកិច្ច និង នយោបាយ រហូតបានក្លាយជាដៃគូមិនអាចខ្វះ បានមួយ នៅវាល់ការចរចាស្វែងរកសន្តិភាពនៅកម្ពុជា ។ ឈានចេញពីការប្រមាថ មើលងាយរបស់ក្រុមបដិបក្ខថាជាអាយ៉ងរបស់វៀតណាម លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានឡើងអង្គុយស្មើមុខនៅតុចរចាជាមួយសម្តេចព្រះ នរោត្តម សីហនុ ។ ជំនួប សីហនុ - ហ៊ុន សែន លើកទីមួយ នៅ ហ្សឺរ អង់តាក ដឺន័រ បាន ទំលាយភាពទាល់ច្រក និង បើកទ្វារឲ្យ ខ្មែរ និង ខ្មែរ អាចនិយាយគ្នាដោយផ្ទាល់

បាន ។ នេះជាដំហានមួយដ៏សំខាន់ ឆ្ពោះទៅរកដំណោះស្រាយសន្តិភាពសម្រាប់ប្រជាជនខ្មែរ និង សម្រាប់ប្រទេសកម្ពុជា ។

-តាមចរន្តនៃប្រវត្តិសាស្ត្រ ជីវិតរបស់ខ្ញុំក៏ប្រព្រឹត្តទៅ ដូចប្រជាពលរដ្ឋខ្មែរឯទៀតដែរ ដោយទទួលផលល្អនៃសន្តិភាព និង ទទួលផលប៉ះពាល់អាក្រក់នៃសង្គ្រាម ។ មួយរយៈ ខ្ញុំបានក្លាយជាជនភៀសខ្លួន ឃ្លាតឆ្ងាយពីស្រុកទេស រស់នៅម្នាក់ឯង ក្នុងសង្គមនៃប្រទេសសេរីមួយ ដែលអាចជួយមនុស្សឧស្សាហ៍ព្យាយាមដែលចេះខំប្រឹងប្រែងក្នុងជីវិតឲ្យទទួលជោគជ័យបាន ។ ក៏ប៉ុន្តែក្នុងហានៈជាខ្មែរគ្មាននរណាអាចផ្តាច់ខ្លួន មិនឈឺឆ្អាល មិនញាប់ញ័រ ឬ មិនសោកសង្រេងចំពោះទុក្ខវេទនា ចំពោះការឈឺចាប់របស់ប្រជាពលរដ្ឋខ្មែរនៅក្នុងប្រទេសខ្មែរនោះឡើយ ។ ជីវិតនយោបាយរបស់ខ្ញុំ ហាក់ដូចជាចាប់ផ្តើមឡើង ដោយការផ្សងព្រេង ក៏ប៉ុន្តែខ្សែបន្ទាត់នៃជីវិតនយោបាយនេះ ប្រាកដជាដើរតាមគន្លងនៃសេចក្តីស្នេហាជាតិ ស្រឡាញ់ទឹកដីភូមិស្រុក និង ជនរួមជាតិខ្មែរពិតៗ ។ រាល់ជោគជ័យ សុទ្ធតែបានមកដោយការប្រឹងប្រែង ប្រើអស់កម្លាំងកាយចិត្ត មិនមែនបានមកដោយស្រួលៗនោះឡើយ ។

ឯកសារគន្ថនិទ្ទេសភាសាខ្មែរ

កែវ បាក្នំ

-សម្តេច ហ៊ុន សែន និង ពាក្យសន្យាជាប្រវត្តិសាស្ត្រ, ឯកសារជំនួយស្មារតី ភ្នំពេញ ២០១០ ។

ក្រុមស្រាវជ្រាវ ឆយ យីហ៊ាង, ប្រែង ពិសិដ្ឋ, លេង ណៃគីម, ម៊ិល វ៉ាសនា, កិន ណារ៉ុង, ម៉ម សារិត, ជា មុនីឫទ្ធិ, គិន ភា

-សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន, នាយករដ្ឋមន្ត្រី ប្រសូតពីត្រកូលកសិករ, រោងពុម្ពពន្លឺពេជ្រ, ភ្នំពេញ ២០០៧ ។

ខៀវ សំផន, សុន សេន

-សេចក្តីថ្លែងការណ៍របស់ភាគីកម្ពុជាប្រជាធិបតេយ្យ ចំពោះតួនាទីបច្ចុប្បន្ន និង អនាគតរបស់រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ និង ប្រធានរបស់ខ្លួន, កម្ពុជា ប្រជាធិបតេយ្យ, ថ្ងៃទី ១២ កុម្ភៈ ១៩៨៦ ។

ចាយ ធុល, ឈាន វ៉ែម, ហ៊ុយ គន្ធុល, លិម គ្រី, នង គិមនី, ជុន អ៊ុក, ស៊ឹម វ៉ា ឯកសារគ្នាចំណងជើង, ប៉ារីស, ១៥ មិថុនា ១៩៨៥ ។

ទ្រឿង មាលី

-អគ្គលេខាធិការ ស.ខ.ប (ទូលថ្វាយសម្តេច នរោត្តម សីហនុ), ប៉ារីស, ថ្ងៃទី០៨ សីហា ១៩៧៩ ។

ជៀន ដៃល

-សំបុត្រផ្ញាល់ដៃជូនលោកប្រធាន, បន្ទាយអំពិល, ថ្ងៃទី ១៧ តុលា ១៩៨២ ។

-សំបុត្រផ្ញាល់ដៃជូនលោកប្រធាន, បន្ទាយអំពិល, ថ្ងៃទី ១៩ តុលា ១៩៨២ ។

នេត គុណ និង សាយ បូរី

-សេចក្តីកត់ហេតុនៃការិយាល័យរៀបចំបោះឆ្នោតជ្រើសរើសគណកម្មការនាយក សម្រាប់ឆ្នាំ ១៩៧៩-៨០ ថ្ងៃទី ៨ មេសា ១៩៧៩ ។

នរោត្តម រណឫទ្ធិ, សុន សេន, សក់ ស៊ុតសាខន

-សេចក្តីប្រកាសព័ត៌មាន, ថ្ងៃទី ១៨ វិច្ឆិកា ១៩៨៦ ។

សក់ ស៊ុតសាខន (ឧត្តមសេនីយ)

-សេចក្តីសម្រេច, គណកម្មាធិការបណ្តោះអាសន្ននៃអគ្គសេនាធិការ នៃកងទ័ពជាតិរំដោះប្រជាពលរដ្ឋខ្មែរ, អំពិល, ថ្ងៃទី ៨ វិច្ឆិកា ១៩៨២ ។

-លិខិតសម្ងាត់ផ្ញាល់ខ្លួនផ្ញើជូនឯកឧត្តម សឺន សាន ប្រធានរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ ថ្ងៃទី ៥ ធ្នូ ១៩៨៥ ។

-លិខិតជូនឯកឧត្តម សឺន សាន ប្រធាន រ.ជ.រ.ប.ខ., ថ្ងៃទី ១៨ ធ្នូ ១៩៨៦ ។

ស៊ិន សំណាង

-អនុសញ្ញាពាណិជ្ជកម្ម និង សាសនា ថ្ងៃទី ១៨ តុលា ១៨៥៦ នៅក្នុង ទស្សនាវដ្តីរាជបណ្ឌិតសភាកម្ពុជា លេខ១ ត្រីមាសទី១, ភ្នំពេញ, ២០០២ ។

សឺន សាន

-ប្រសាសន៍ថ្លែងក្នុងឱកាសមហាសន្និបាតនៃប្រជាពលរដ្ឋខ្មែរ នៅសហរដ្ឋអាមេរិក, ព្រឹត្តិបត្រ រ.ជ.រ.ប.ខ. ខែ កក្កដា ១៩៨១ ។

-សេចក្តីប្រកាសចំពោះមុខសារព័ត៌មាននានា, ព្រឹត្តិបត្រ រ.ជ.រ.ប.ខ ខែ កញ្ញា ១៩៨១ ។

-សេចក្តីអំពាវនាវរបស់លោកប្រធានរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ អគ្គមេបញ្ជាការនៃកងទ័ពជាតិរំដោះប្រជាពលរដ្ឋខ្មែរ, អំពិល, ថ្ងៃទី ១៨ ខែ តុលា ១៩៨២ ។

-លិខិតប្រធាន រ.ជ.រ.ប.ខ. ផ្ញើជូនលោកឧត្តមសេនីយ សក់ ស៊ុតសាខន, ថ្ងៃទី ២២ កុម្ភៈ ១៩៨៧ ។

-លិខិតប្រធាន រ.ជ.រ.ប.ខ. និង ជារដ្ឋមន្ត្រីទី១ នៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ជូនឯកឧត្តម ខៀវ សំផន អនុប្រធានកម្ពុជាប្រជាធិបតេយ្យ ទទួលបន្ទុកកិច្ចការបរទេស, ថ្ងៃទី ១៦ មីនា ១៩៨៧ ។

-សេចក្តីបកប្រែសង្ខេបពាក្យសន្ទនារវាង ឯ.ឧ. ប្រធាន ជាមួយ ឧ. សុជិន្តា ក្រាប្រយង្គ កាលពីថ្ងៃទី ២៨ មេសា ១៩៨៧ ។

-លិខិតរដ្ឋមន្ត្រីទី១ នៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ជូនឯកឧត្តម ខៀវ សំផន អនុប្រធានកម្ពុជាប្រជាធិបតេយ្យទទួលបន្ទុកកិច្ចការបរទេស, ថ្ងៃទី ៧ ឧសភា ១៩៨៧ ។

-លិខិតរដ្ឋន្ត្រីទី១ ជូនចំពោះឯកឧត្តម ខៀវ សំផន អនុប្រធានកម្ពុជាប្រជាធិបតេយ្យទទួលបន្ទុកកិច្ចការបរទេស, ថ្ងៃទី ១៤ ឧសភា ១៩៨៧ ។

សុន សេន, អៀង មូលី, សឺន ស៊ូប៊ែរ្ត, ឧត្តមសេនីយត្រី ទួន ចាយ

-សេចក្តីប្រកាសព័ត៌មាន, ថ្ងៃទី ២៧ សីហា ១៩៨៧ ។

ហ៊ុន សែន (សម្តេចតេជោ)

-១០ ឆ្នាំនៃដំណើរកម្ពុជា ១៩៧៩-១៩៨៩, គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ, រោងពុម្ព ណុប បូផាន់, ភ្នំពេញ, ១៩៨៨ ។

-បទសម្ភាសន៍សម្តេចតេជោ ផ្តល់ជូនក្រុមស្រាវជ្រាវប្រវត្តិសាស្ត្រដឹកនាំដោយឯ.ឧ. អៀង មូលី និង ស៊ន សំណាង កាលពីថ្ងៃទី ១៦ មីនា ២០១០ ។

អ៊ិន តាំ

-ឆ្នាំខួបទី៥ នៃរដ្ឋាភិបាលចម្រុះត្រីភាគី និង សម្លេងភ្នំពេញ, ទស្សនាវដ្តី នគរខ្មែរ ឆ្នាំទី៩ លេខ ៩៨ មិថុនា ១៩៨៦ ។

អេង-សុត

-ឯកសារមហាបុរសខ្មែរ - ផែនដីព្រះអង្គឌួង - ភ្នំពេញ ១៩៦៩ ។

ឯក សំអុល

-ជំនួយស្មារតីពីដំណើរការចរចាដើម្បីដំណោះស្រាយនយោបាយរួមនៃជម្លោះកម្ពុជា, ថ្ងៃទី ២ ធ្នូ ២០០៩ ។

ឱក សិរីសោភក្តិ

-លិខិតជូនលោកប្រធានរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ, សមរភូមិមុខ, ក្រៃតេយ៍ ថ្ងៃទី ១ មេសា ឆ្នាំ ១៩៨២ ។

អៀង មូលី

-អត្ថបទសរសេរដៃគ្មានចុះថ្ងៃខែ ។

ក្រុមឯកសារគន្ថនិទ្ទេសតាសាបរទេស

Asean

-Asean Suggested Modalities for Political Settlement of the Kampuchean Problem, February 3, 1986. (Secret Document).

Asiaweek

-Where Does It Leave Sihanouk, April 21, 1978.

Bangkok Post

-New Khmer Rouge govt announced by Alan Dawson, Lineup, Bangkok Post, December 28, 1979.
-Jacques Bakaert, KPNLF Split by Rebel Faction, December 19, 1985.
-Sihanouk denies he'll talk with Phnom Penh, June 5, 1987.
-Asean Told Not To Rush Peace Bid, August 26, 1987.

Boun Say

-Note à S.E le Président du FNLPK, Document Secret, 21 June 1986.

Carlucci Frank C.

-Letter to Mr. Son Sann, President, Khmer People's National Liberation Front, The White House, Washington, June 15, 1987.

CGDK

-Memorandum, Meeting of H.E Son Sann with H.E. ACM Siddhi Savetsila, Minister of Foreign Affairs of the Royal Thai Government, August 15, 1985.
-Compte-rendu de la Réunion entre les Parties du GCKD et les "Senior Officials" des Pays de l'ASEAN, Hotel Ambassador, Bangkok, le 17 Février 1986.

-Compte-rendu de la Réunion entre les Parties Nationales du GCKD et les Pays de l'ASEAN sur la Question Militaire, le 18 Février 1986.

-Coalition Government of Democratic Kampuchea's Proposal for A Political Settlement to the Problem of Kampuchea, Beijing, March 17, 1986.
-Notes (recueillies) sur l'entretien politique entre S.E. Hu Yaobang, Secrétaire Général du PCC et le Gouvernement de Coalition du Kampuchea Démocratique, Mardi 18 Mars 1986.
-Notes d'entretien politique entre S.E. Son Sann, Premier Ministre du GCKD et S.E. Liu Shuqin, Vice-Ministre des A. E. de la RPC, Beijing, 19 Mars 1986.
-Office of the Prime Minister, Memorandum on the Conception of An Angkor Cultural Zone Free from All Presence of the Armed Forces, February 26, 1987.
-Office of the Prime Minister, Statement of H.E. Son Sann, Prime Minister of the Coalition Government of Democratic Kampuchea, May 8, 1987.
-Office of the Prime Minister, Communiqué de Presse, Bucarest, le 17 Juin 1987.
-Office of the Prime Minister, Press Communique, December 9, 1987.
-Office of the Prime Minister, Communiqué de Presse, 19 janvier 1988.

Democratic Kampuchea

-Translation of the official Record of the Sixth Ad-Hoc Committee meeting held on October 4, 1981 under the Presidency of Mrs. Ieng Thirith of Democratic Kampuchea.
-Memorandum by the Democratic Kampuchea Party Concerning the Declaration of the Formation of the Coalition Government of Democratic Kampuchea, May 7, 1982.

Deng Xiaoping

-Letter to Lee Kuan Yew dated May 28, 1981 with attachment: Three Points of Principle Concerning the Kampuchean Questions Set Forth by Vice-Chairman Deng Xiaoping during his Talks with Prime Minister Lee Kuan Yew on 11 November 1980.

Douzième Conférence

-Des Ministres des Affaires Etrangères du Cambodge, du Laos et du Vietnam tenue à Vientiane, Laos, du 23 au 24 Janvier 1986. (Points à retenir).

Far Eastern Economic Review

-Norman Peagam, Political Stability at Stake, Questions After the Massacre, February 11, 1976.
-Nayan Chanda, the Barbarous Raid Mystery, March 12, 1976.
-A Correspondent, Waging War on the Land, March 26, 1976.
-Richard Nations, Busload of Trouble, March 10, 1978.
-Nayan Chanda, Vietnam Prepares for a Long War, April 21, 1987.
-Nayan Chanda, the Prince Makes Waves, Vol 136, No 25, June 18, 1987.

FNLPK

-Communiqué de Presse, le 16 October 1982.
-Compte-rendu de la Réunion au Ministère des Affaires Etrangères, Bangkok, le 6 Février 1986.
-Le Bureau d'Information à Paris, Communiqué, Paris, le 23 Janvier 1988.

Hall, D.G. E

-A History of South-East Asia, Third Edition, London, 1968.

Huy Kanthoul

-Verbal Notes of KPNLF Provisional Central Committee addressed to Diplomatic Missions in Bangkok, December 17, 1985.

Dien Del (General)

-Message, A Son Excellence Son Sann, le 22 Décembre 1985.

Ieng Mouly

-Compte-rendu de l'Entretien du Président du FNLPK avec l'Ambassadeur des Etats Unis, Paris, le 19 Mars 1982.
-Memo à Son Excellence le Président, Memo 82/01 IM, 12 Juin 1982.
-Lettre à Tep Darong datée du 23-6-82.
-A Son Excellence le Président du Front National de Libération du Peuple Khmer et Premier Ministre du Gouvernement de Coalition du Kampuchea Démocratique, Paris, le 12 Mars 1984.
-Letter to the Editor, Bangkok Post, January 29, 1988.

Khieu Samphan

-Lettre adressée à S. E. M. Son Sann, Premier Ministre du Gouvernement de Coalition du Kampuchea Démocratique, le 24 Avril 1987.

Khieu Samphan, Son Sen

-Statement by the Democratic Kampuchea Party Concerning its Position vis-à-vis the Present and Future Role of Samdech Norodom Sihanouk and the United Front for an Independent Neutral Peaceful and Cooperative Cambodia (FUNCINPEC), Democratic Kampuchea, February 12, 1986.

Khin Sok

Le Cambodge entre le Siam et le Vietnam (de 1775 à 1860), Ecole Française d'Extrême-Orient, Paris, 1991.

KPNLF

-Proclamation of the Khmer People's National Liberation Front, Khmer Territory, October 9, 1979.

-Confidential Note on the Formation of the Coalition Government of Democratic Kampuchea, November 1981.
-Press Release, Khmer Territory, December 17 , 1982.
-Military Situation at Banteay Ampil, January, 1985.
-Minutes of the Meeting at the Thai Ministry of Foreign Affairs, February 12, 1986.
-Memorandum Presented to His Excellency Mr. Gaston Sigur, US Assistant Secretary of State for East Asia and Pacific Affairs, March 26,1986.
-Press Communiqré, January 18, 1987.
-Press Release, January 26, 1988.

Li Xiannian,

Président de la République Populaire de Chine, Zao Ziyang, Premier Ministre du Conseil d'Etat de la République Populaire de Chine, à Samdech Norodom Sihanouk, Président du Kampuchea Démocratique,
Son Excellence Son Sann, Premier Ministre du Gouvernement de Coalition du Kampuchea Démocratique,
Son Excellence Khieu Samphan,
Vice-Président du Kampuchea Démocratique, Beijing,
le 16 Avril 1987.

M'Bow, Amadou-Mahtar

-Lettre à S. Exc. Monsieur Son Sann, Premier Ministre du Gouvernement de Coalition du Kampuchea Démocratique, Paris, le 4 Juillet 1987.

Ministère de l'Information

-Documents, Cabinets Ministériels Khmers, du 18 mars 1945 au 18 mars 1970, Phnom Penh, 1970.

Nations (The)

-Khmer Rouge Appeal to Sihanouk, June 1, 1987.
-Phnom Penh Echoes Hanoi, Quoted Kuala Lumpur Times, August 26, 1987.

-Sihanouk Arrives for China, August 30, 1987.
-Sihanouk Assures Bangkok: He Won't Meet Hun Sen, September 1, 1987.

Nations Unies
-Rapport de la Conférence Internationale sur le Kampuchea, New York, 1981.

Nguyen Co Thach
-Letter to Foreign Ministers of Non-Aligned Countries, Hanoi, March 26, 1986.

Nhiek Tioulong
-Lettre à Son Altesse Royale Samdech Norodom Sihanouk du Cambodge, Sucy-en-Brie, le 27 Octobre 1987.

Norodom Monique Sihanouk
-Lettre datée à Chang Sou On, 22 Juillet 1987.

Norodom Ranariddh
-Lettre datée à Bangkok, le 23 Octobre 1987.

Norodom Sihanouk
-La CIA contre le Cambodge, Francois Maspéro, Paris, 1973.
-Message du Prince à Tous Ses Compotriotes, Pyong-Yang, le 12 juillet 1979.
-(Deuxième Message du Prince), A Tous Ses Compatriotes A l`Etranger, Pyong-Yang, le 12 Juillet 1979.
-(Troisième Message du Prince), A Tous Ses Compatriotes A l`Etranger, Pyong-Yang, le 12 Juillet 1979.
-(Huitième Message du Prince), A Ses Compatriotes A l`Etranger, Pyong-Yang, Juillet 1979?

-(Neuvième Message du Prince), A Ses Compatriotes A l`Etranger, Pyong-Yang, le 21 Juillet 1979.
-Télégramme du Samdech Sihanouk en date du 20 Mai 1980 à Son Excellence In Tam, BMD No 4, Juillet 1980.
-Resumé des Paroles du Président Nicolae Ceausescu de Roumanie avec Norodom Sihanouk et Khieu Samphan,
A Bucarest, en Août 1982.
-Norodom Sihanouk's Replies to SonSannian Accusations and Questions in Minneapolis, November 10, 1984.
-Memorandom, New York, November 15, 1984.
-Prisonnier des Khmers Rouges, Cameron, 1986.
-Ce « Rift » entre le Clan de Son Sann et celui de Dien Del-Gaffar Peang Meth-Sak Sutsakhan.....a handwritten note (undated) published on www.norodomsihanouk.info
-Mon Compte-Rendu Succinct de mon Entretien Politique, d'une durée de 2 heures, avec Son Excellence Monsieur le Président Nicolae Ceausescu de la République de Roumanie, Bucarest, Lundi 12 Janvier 1987.
-Télégramme A Son Excellence Khieu Samphan,Vice-Président du Kampuchea Démocratique, c/o S.E. Ambassadeur Chan Youran, Pekin, 25 Janvier 1987.
-Lettre du Président du Kampuchea Démocratique à Son Excellence Son Sann, Premier Ministre du CGDK, Beijing 11 Mars 1987.
-Lettre du Président du Kampuchea Démocratique à Son Excellence Monsieur LI XIANNIAN, Président de la République Populaire de Chine, Son Excellence Monsieur Zao Ziyang, Premier Ministre du Conseil d'Etat de la République Populaire de Chine, Pyongyang, le 16 Avril 1987.
-Note pour S.E. Chan Youran, Ambassadeur du Kampuchea Démocratique en R. P. de Chine, Pyongyang, le 11 Juillet 1987.
-Compte-rendu de mon entretien politique avec Monsieur Wolfgang A. Entmayr, de la Représentation de l'Autriche
en la R.P.D. de Corée, Palais Chang Sou On, Mardi 14 Juillet 1987.
-Déclaration de Norodom Sihanouk du Cambodge, Paris, le 10 Decembre 1987.
-Note pour la Presse, Roissy-en-France le 20 Decembre 1987.

-A Sad Deterioration of my Relationship with the People's Republic of China, the Cup to the Dreg, a handwritten manuscript published on www.norodomsihanouk.info, May 4, 2004.
-The Birth of FUNCINPEC, -The First Summit of the Three Khmer Anti-Vietnamese Colonialist Leaders and the " Dragon Lady", the Cup to the Dreg, a handwritten manuscript published on www.norodomsihanouk.info, May 10, 2004.
-The Leading Role of the People's Republic of China and Asean in the Process of Building Up Democratic Kampuchea's CGDK, the Cup to the Dreg, a handwritten manuscript published on www.norodomsihanouk.info, May 11, 2004.
-Following the Historical Inter-Cambodian Summit of Singapore, Sihanouk's Enemies Lay into Him Tooth and Nail, the Cup to the Dreg, a handwritten manuscript published on www.norodomsihanouk.info, May 13, 2004.
-To Eliminate Me to Son Sann's Advantage Would Only Help the Viets..., Editorial, BMD November-December 1981, a handwritten manuscript published on www.norodomsihanouk.info, May 14, 2004.
-Telegramme au Parlement Europeen, Strasbourg France, published on www.norodomsihanouk.info le 2 Septembre 2004.
-Shadow over Angkor, Memoirs of His Majestythe King of Cambodia, translated by Ambassador Julio A. Jeldres, Monument Books, 2005.

Norodom Sihanouk (Samdech), Son Sann (HE), Khieu Samphan (HE),

-Joint Statement, Singapore 2-4 September 1981.
-Declaration of the Formation of the Coalition Government of Democratic Kampuchea.

Pong Kim Koan

-Procès-verbal de la réunion de travail, Paris, le 6 September 1985.
-Le Chef du Bureau d'Information du FNLPK, à Son Excellence le Président du FNLPK et Premier Ministre du GCKD, Paris, le 16 Mars 1987.

Sak Sutsakhan (General)

-Memorandum pour la Haute Information de Monsieur le Président du FNLPK et Commandant-en-Chef des FANLPK, le 21 Février 1981.
-Compte-rendu de la Réunion avec le Général Chao le 10 Septembre 1982.
-Message A Son Excellence Son Sann, le 22 Décembre 1985.
-Khmer People's National Liberation Armed Forces, Special Order of the Day, 20 December 1985.

Stephen J. Solarz

-Letter to Hon. Son Sann, President, Khmer People's National Liberation Front, Washington DC, June 3, 1987.

Son Sann

-Télégramme 00740 à SAR Norodom Sihanouk, c/o Ministère des Affaires Etrangères, RP de Chine, le 8 Janvier 1979.
-Front National de Libération du Peuple Khmer, Décision No. 79/01/FNL, Territoire Khmer, le 09 Octobre 1979.
-Front National de Libération du Peuple Khmer, Décision No. 79/02/FNL, Territoire Khmer, le 09 Octobre 1979.
-Front National de Libération du Peuple Khmer, Décision No. 79/03/FNL, Territoire Khmer, le 09 Octobre 1979.
-President of the Khmer Pedople's National Liberation Front, Speech, Khmer Territory, October 9, 1979.
-Front National du Libération du Peuple Khmer, Décision No 79/04/FNL, Territoire Khmer, le 15 October 1979.
-Front National de Libération du Peuple Khmer, Décision No 79/05/FNL, Territoire Khmer, le 15 October 1979.
-Front National de Libération du Peuple Khmer, Décision No 79/06/FNL, Territoire Khmer, le 15 October 1979.
-Front National de Liberation du Peuple Khmer, Décision No 79/07/FNL, Territoire Khmer, le 15 October 1979.
-President of the Khmer People's National Liberation Front, Press Conference, Khmer Territory, November 23, 1979.

-President of the Khmer People's National Liberation Front, Speech, at the Closing Ceremony of the Political, Warfare Training and the Graduation of the 1st Group of Special Forces, Khmer Territory, January 5, 1980, KPNLF Bulletin No. 2, February 1980.
-Front National de Libération du Peuple Khmer, Décision No. 80/03/FNL, Territoire Khmer, le 11 mars 1980.
-Speech delivered at the Opening Session of the Congress, KPNLF Bulletin, Special Issue no. 4, April 1980.
-Observations of Mr. Son Sann on the Draft Proposal Entitled « Declaration on the Formation of the Coalition Government » as Provided by Major General Chaovalit, May 27, 1982.
-Memorandum Presented by Mr. Son Sann To Major General Chaovalit Yongchaiyuth, the Royal Thai Armed Forces, June 1, 1982.
-Memorandum Presented by Mr. Son Sann To Major General Chaovalit Yongchaiyuth, the Royal Thai Armed Forces, June 2, 1982.
-Memorandum Presented by Mr. Son Sann To Major General Chaovalit Yongchaiyuth, June 3, 1982.
-Son Sann To Dear General Chavalit, June 2, 1982. (A kind of Memo).
-Décision du Président du Comité Exécutif, no 82/07/FNL, Territoire Khmer, le 11 Juin 1982.
-Télégramme à Son Altesse Royale Samdech Preah Norodom Sihanouk, Président du Kampuchea Démocratique, c/o Ministère Affaires Etrangères, Beijing, 8 Février 1986.
-Khmer People's National Liberation Front, Décret No 86/03/FNL, Fait le 15 Février 1986.
-Khmer People's National Liberation Front, Décret No 86/04/FNL, Fait le 15 Février 1986.
-Khmer People's National Liberation Front, Décret No 86/06/FNL, Fait le 16 Février 1986.
-Khmer People's National Liberation Front, Decret No 87/01/FNL, (Unofficial Translation), January 11, 1987.
-Lettre à Son Altesse Royale Samdech Preah Norodom Sihanouk, Président du Kampuchea Démocratique, Pyong Yang,

le 14 Mai 1987.
-Lettre à Son Altesse Royale Samdech Preah Norodom Sihanouk, Président du Kampuchea Démocratique, Beijing, le 27 Avril 1987.
-Letter to The Honourable Stephen J. Solarz, Washington DC, May 1, 1987.

-Letter to His Excellency President Ronald Reagan, the White House, Washington DC, May 1, 1987.
-Déclaration de Son Excellence Son Sann, Premier Ministre du Gouvernement de Coalition du Kampuchea Démocratique (GCKD), Président du Front National de Libération du Peuple Khmer (FNLPK), Paris le 15 Juin 1987.
-Statement of H.E. Son Sann, Prime Minister of the Coalition Government of Democratic Kampuchea and President of the Khmer People's National Liberation Front, December 21, 1987.
-Décision du Président du Front National de Libération du Peuple Khmer, No 87/Special/FNL, le 23 Décembre 1987.
-Khmer People's National Liberation Front, Décision No 88-01/FNL, Fait le 31 janvier 1988.
-Letter to The Honourable Stephen J. SOLARZ, Chairman, Sub-Committee on Asian and Pacific Affairs, Congress of the United States House of Representatives, Washington DC, June 22, 1988.
-Spech delivered at the International Confenence on Human Rights: Cambodia, Survery and Prospects, Strasbourg, France, December 12-14, 1988.
-The Memoirs of Son Sann, Cambodia, Daily Press, 2011.

Sorn Samnang

-L'Evolution de la Société Cambodgienne entre les Deux Guerres Mondiales (1919-1939), Thèse pour le Doctorat d'Histoire, Université Paris VII, Paris, Octobre 1995.

Thach Reng

-To General Chavalit Yongchaiyuth, (A kind of Memo) Bangkok, 28 December 1982.

-Compte-rendu pour l'Information du Président du FNLPK, Situation Militaire, le 25 Janvier 1983.
-Memorandum (date illisible) Fevrier 1988 ?

Thomas Roland

-L'évolution économique du Cambodge (1900-1940), Thèse de Doctorat, Université de Paris 7, 1978.

Um Sim

-Propositions Vietnamiennes Pour Une Négotiation en Deux Phases, une note sur la réunion de travail, à l'hotel Helmsley, New York, le 24 Octobre 1986.

Teap Ben, Dien Del

-PERMICO, Press Release, Free Combodia, August 22, 1985.

ឯកសារឧបសម្ព័ន្ធ

សេចក្តីថ្លែងការណ៍រួមបង្កើតរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ

JOINT STATEMENT

His Royal Highness Samdech Norodom Sihanouk, His Excellency Mr Son Sann and His Excellency Mr Khieu Samphan met in Singapore from 2-4 September 1981, and agreed to:

1 Express the desire to form a coalition government of Democratic Kampuchea with a view to continuing the struggle in all forms for the liberation of Cambodia from the Vietnamese aggressors;

2 Set up an ad hoc committee to study the principles and the forms enabling the achievement of the above coalition government and objective;

3 Express their full support for the Declaration and Resolution of the International Conference on Kampuchea and other relevant United Nations General Assembly resolutions on Cambodia;

4 Appeal to all peace-loving nations of the world to render their full support to the Declaration and Resolution of the International Conference on Kampuchea and other relevant United Nations General Assembly resolutions on Cambodia.

It is agreed that all anti-Vietnamese forces avoid any clashes among themselves.

The three parties agreed that they would refrain from bringing to the public their differences during the whole period of the agreement.

NORODOM SIHANOUK SON SANN KHIEU SAMPHAN

លិខិតបញ្ជាក់របស់លោក សឺន សាន ជូនឧត្តមសេនីយ ឆាវលិត
អំពីការចូលរួមបង្កើតរដ្ឋាភិបាលចម្រុះត្រីភាគី

Dear General Chavalit

I hereby declare my acceptance in toto of this Declaration of the Formation of the Coalition Government of Democratic Kampuchea, and I shall be ready to meet with ~~the leaders of~~ H.R.H. Samdech Norodom Sihanouk and H.E. Khieu Samphan in order to sign the aforesaid Declaration.

June 2nd 1982

Son Sann

សេចក្តីប្រកាសបង្កើតរដ្ឋាភិបាលចម្រុះត្រីភាគី

COALITION GOVERNMENT
OF DEMOCRATIC KAMPUCHEA
-oOo-

CABINET OF
THE PRIME MINISTER

Information & Press

No. 01/82/CG

DOCUMENT

DECLARATION
OF
THE FORMATION OF THE
COALITION GOVERNMENT
OF
DEMOCRATIC KAMPUCHEA

His Royal Highness Samdech Norodom Sihanouk, His Excellency Mr. Son Sann and His Excellency Mr. Khieu Samphan, in pursuance of their Joint Statement made in Singapore on 4 September 1981, have agreed to form a Coalition Government of Democratic Kampuchea.

Purpose

The purpose of the Coalition Government of Democratic Kampuchea is:

1. To mobilise all efforts in the common struggle to liberate Kampuchea from the Vietnamese aggressors with the view to restoring the Motherland as a sovereign and independent country.

2. To bring about the implementation of the Declaration of the International Conference on Kampuchea and other relevant United Nations General Assembly Resolutions.

Operating Principles

1. The Coalition Government of Democratic Kampuchea is under the legitimacy and framework of the State of Democratic Kampuchea which is a Member State of the United Nations; to this end, the Coalition Government of Democratic Kampuchea will strive to defend the Democratic Kampuchea seat in the United Nations.

/....

2. Each participating party in the Coalition Government of Democratic Kampuchea shall retain its own organisation, political identity and freedom of action, including the right to receive and dispose of international aids specifically granted it; the Coalition Government of Democratic Kampuchea shall have no right to take any decision infringing or restricting this autonomy.

3. The workings of the Coalition Government of Democratic Kampuchea shall be guided by the principles of tripartism, equality and non-preponderance.

4. The operation of the Coalition Government of Democratic Kampuchea shall be governed by the principle of consensus applicable to matters of importance and relating to:

4.1 The settlement of the Kampuchean problem.

4.2 International treaties or agreements.

4.3 The appointment of important delegations such as those in charge of discussing the settlement of the problem of Kampuchea.

4.4 The eventual modification of the structure or composition of the Coalition Government of Democratic Kampuchea.

4.5 The appointment of ambassadors or representatives of Democratic Kampuchea to different countries or international organisations.

To ensure the order and the efficiency of the Democratic Kampuchea diplomatic affairs, no question of change of ambassadors or representatives of Democratic Kampuchea currently in office should be raised in the period of six months following the formation of the Coalition Government of Democratic Kampuchea.

5. Any decision or activity of any party in violation of the above provisions is null and void.

/....

Composition and Operation of the Coalition Government of Democratic Kampuchea

The Coalition Government of Democratic Kampuchea will be administered by a Council of Ministers. In accordance with the principles of tripartism, equality and non-preponderance, the Council will comprise an Inner Cabinet and a number of Coordination Committees.

1. The Inner Cabinet consists of:

1.1 President of Democratic Kampuchea:
Samdech Norodom Sihanouk

1.2 Vice President of Democratic Kampuchea
in charge of Foreign Affairs:
H.E. Mr. Khieu Samphan

1.3 Prime Minister: H.E. Mr. Son Sann

2. Coordination Committees are established in the following areas:

2.1 Finance and Economy

2.2 Defence

2.3 Culture and Education

2.4 Health and Social Affairs

Each Coordination Committee will be chaired by three appointees of ministerial rank representing the three participating parties. These ministerial posts in the Coordination Committees, however, do not constitute any part of the Inner Cabinet, and are subordinated to it.

The Council of Ministers of the Coalition Government of Democratic Kampuchea will convene regular meetings inside

/....

Kampuchea. Extraordinary meetings can also be convened when urgent problems present themselves. Meetings are convened by the President, Vice President, or Prime Minister of the Coalition Government of Democratic Kampuchea, and presided over in the same order of precedence by the three members of the Inner Cabinet.

The Inner Cabinet Council of Ministers will be entrusted with the responsibility of preserving the existence of the Coalition Government of Democratic Kampuchea, which includes the discussion and settlement of differences arising over the interpretation and/or implementation of the Operating Principles governing the Coalition Government of Democratic Kampuchea. In the event of failure, the Presidents of the three participating parties will be requested to meet to work out a solution.

In accordance with the above-mentioned Operating Principles, each of the three participating parties reserves the right to its freedom of action so as to ensure its own continuity, in the event that an impasse has developed which renders the Coalition Government of Democratic Kampuchea inoperative. In this case the current State of Democratic Kampuchea led by H.E. Mr. Khieu Samphan will have the right to resume its activities as the sole legal and legitimate State of Democratic Kampuchea and as a Member State of the United Nations in order to ensure the continuity of the State of Democratic Kampuchea.

In testimony whereof, H.R.H. Samdech Norodom Sihanouk, H.E. Mr. Son Sann, and H.E. Mr. Khieu Samphan have affixed their signatures at the end of this Declaration formalising the formation of the Coalition Government of Democratic Kampuchea.

Done in Kuala Lumpur this 22nd day of June, 1982.

[signed]	[signed]	[signed]
Samdech Norodom Sihanouk	H.E. Mr. Son Sann	H.E. Mr. Khieu Samphan

ជីវប្រវត្តិសង្ខេបរបស់អ្នកនិពន្ធ

លោក **អៀង មូលី** កើតនៅថ្ងៃទី០២ ខែ វិច្ឆិកា ឆ្នាំ ១៩៥០ នៅភូមិស្នាយពល ឃុំកោ ស្រុកពារាំង ខេត្តព្រៃវែង ។ លោកបានធ្វើការសិក្សានៅមហាវិទ្យាល័យពាណិជ្ជសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និង នៅវិទ្យាស្ថានជាតិបច្ចេកទេសសេដ្ឋកិច្ច និង គណនេយ្យ (Institut National des Techniques Economiques et Comptables) នៃមន្ទីរអភិរក្សជាតិមុខរបរ (Conservatoire National des Arts et Métiers) នៅទីក្រុងប៉ារីស នៃប្រទេសបារាំង។

-ចាប់ពីឆ្នាំ ១៩៧៤ រហូតដល់ឆ្នាំ ១៩៨២ លោកបានបំពេញការងារជាប្រធានផ្នែកគណនេយ្យនៃក្រុមហ៊ុនបារាំង និង អាមេរិក នៅទីក្រុងប៉ារីស ។

-នៅឆ្នាំ ១៩៨២ លោកបានចេញពីប្រទេសបារាំង មកចូលធ្វើការតស៊ូនៅក្នុងជួរចលនា រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ (រ.ជ.រ.ប.ខ) ។

-នៅឆ្នាំ ១៩៨៨ បានទទួលតំណែងជាអគ្គលេខាធិការនៃចលនាអ្នកជាតិនិយម រ.ជ.រ.ប.ខ. នេះ ។

-នៅឆ្នាំ ១៩៩០ លោកត្រូវបានជ្រើសតាំងជាសមាជិកក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជា អេស អិន ស៊ី (SNC) ហើយក៏បានចូលរួមចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសនៅឆ្នាំ ១៩៩១ ។

នៅក្នុងការបោះឆ្នោតឆ្នាំ ១៩៩៣ លោក **អៀង មូលី** បានជាប់ឆ្នោតជាអ្នកតំណាងរាស្ត្រមណ្ឌលខេត្តព្រៃវែង និង ជារដ្ឋមន្ត្រីក្រសួងព័ត៌មាន បន្ថែមលើតួនាទីអ្នកតំណាងរាស្ត្រ ។ ក្នុងឋានៈនេះ លោកជាស្ថាបត្យករមួយរូបក្នុងការគាក់តឹងច្បាប់សារព័ត៌មានរបស់ប្រទេសកម្ពុជា ។

លោកបានបំពេញតួនាទីជាប្រធានក្រុមប្រឹក្សាកិបាលមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា (CMAC) ចាប់តាំងពីឆ្នាំ ១៩៩៣ មកដល់ចុងឆ្នាំ ២០០៨ ។

បច្ចុប្បន្ន លោកមានតួនាទីជាទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការពិសេស និង ជាអនុប្រធានទី១ នៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ ។

នៅឆ្នាំ ១៩៩៧ លោក **អៀង មូលី** បានទទួលសញ្ញាប័ត្រថ្នាក់បណ្ឌិតកិត្តិយស ខាងផ្នែកអក្សរសាស្ត្រ មនុស្សជាតិ (Doctor of Humane Letters, Honoris Causa) ពីសាកលវិទ្យាល័យ Armstrong រដ្ឋកាលីហ្វ័រនី សហរដ្ឋអាមេរិក ។

នៅឆ្នាំ ២០០១ និង ឆ្នាំ ២០០៣ លោក **អៀង មូលី** បានចូលរួមកម្មវិធីសម្រាប់អ្នកគ្រប់គ្រង (Executive Programs) របស់សាលាផ្នែកគ្រប់គ្រងរដ្ឋ ចន អេហ្វ កេណឺឌី (John F. Kennedy School of Government) នៃសាកលវិទ្យាល័យហាវើដ (Harvard University) ក្រោមប្រធានបទ «អ្នកដឹកនាំនៃសតវត្សទី ២១» (Leadership for the 21st Century) និង «គ្រប់គ្រងជាយុទ្ធសាស្ត្រនៃភ្នាក់ងារអនុវត្តច្បាប់» (Strategic Management for Regulatory Enforcement Agency) ។ ចាប់តាំងពីឆ្នាំ ២០០៥ រៀងរហូតមក លោកជាសមាជិកនៃក្រុម «ចក្ខុវិស័យអាស៊ីសម្រាប់សតវត្ស ២១» (Asia Vision 21) នៃសាកលវិទ្យាល័យហាវើដ(Harvard University) សហរដ្ឋអាមេរិក ។

លោក **អៀង មូលី** ធ្លាប់បានសរសេរអត្ថបទស្តីពីរបបប្រជាធិបតេយ្យ និង សិទ្ធិមនុស្សសម្រាប់ការផ្សាយនៃពុទ្ធិកសមា គមខ្មែរនៅជាយដែនក្នុងទសវត្សឆ្នាំ ១៩៨០ និង អត្ថបទភាសាអង់គ្លេសក្នុងទស្សនាវដ្តីនៃសកម្មភាពកំចាត់មីន "Mine Action Journal" នៃសាកលវិទ្យាល័យ ជេម ម៉ាឌីសុន (James Madison University) សហរដ្ឋអាមេរិក ។

លោកទទួលមេដាយថ្នាក់ មហាសេរីឧ្ឍន៍នៃព្រះរាជាណាចក្រកម្ពុជា និង មេដាយថ្នាក់ ធិបឌិន្ទ ដឺឡាឡេស៊ីយ៉ុងដូនើរ (Commandeur de la Légion d'Honneur) នៃសាធារណរដ្ឋបារាំង ។

លោក **អៀង មូលី** រៀបការជាមួយលោកស្រី **អៀង សេដ្ឋាមូលី** ហើយមានបុត្រា ១ នាក់ និង បុត្រី ១ នាក់ ៕

មតិអ្នកអានមិនទាន់ចប់

"រឿងដំណាល រឿងទាក់ទងនឹងប្រវត្តិសាស្ត្រមានច្រើន ក៏ប៉ុន្តែមានតិចណាស់រឿងដំណាល និង ប្រវត្តិដែលនិយាយអំពីមនុស្ស និង អំពីសង្គម ដែលគេរស់នៅ និង ធ្លងកាត់ដោយលំបាក ។ លំអានទាំងឡាយនៃអតីតកាលមានសារៈសំខាន់ខ្លាំងណាស់ចំពោះយុវជនជំនាន់ក្រោយ ដូចដែលលោកបានគូសបញ្ជាក់ក្នុងសៀវភៅរបស់លោកយ៉ាងដូច្នោះ ។"

Seun Nmott, ប្រទេសបារាំង

"ខ្ញុំបាទសូមថ្លែងនូវអំណរគុណដ៏ជ្រាលជ្រៅ ចំពោះអំណោយដ៏ថ្លៃថ្លារបស់ឯកឧត្តមជាសៀវភៅដែលតំណាងនូវបញ្ញាញាណ និង បទពិសោធន៍ពេញមួយជីវិតរបស់ឯកឧត្តមដល់រូបខ្ញុំបាទ ។ ថ្វីត្បិតតែខ្ញុំបាទមិនទាន់បានអាន គឺត្រឹមតែអាននូវមាតិការឿងតែប៉ុណ្ណោះ ក៏សៀវភៅនេះបានទាក់ទាញភ្នែកអ្នកអានរួចទៅហើយ ដើម្បីនឹងបន្តទៅទំព័រជាបន្ទាប់ ។

សៀវភៅនេះថ្លៃណាស់ ពីព្រោះយើងមិនអាចកាត់ថ្លៃបានទេនូវអ្វីដែលជាបញ្ញាញាណ និង បទពិសោធន៍ !

សៀវភៅនេះថ្លា ពីព្រោះវាបង្ហាញពីការពិត ដែលខ្ញុំគិតថា អ្នកនិពន្ធនឹងមិនបានប្រយោជន៍អ្វីទេពីការលាក់កំបាំង ។ ដូច្នេះ ការពិតគឺជារបស់ថ្លា ។

ខ្ញុំបាទសូមជូនពរចំពោះឯកឧត្តម សូមមានសុខភាពល្អ និង សង្ឃឹមថា កូនខ្មែរនឹងបានអានសៀវភៅប្រភេទនេះជាបន្តបន្ទាប់នៅពេលអនាគតជាមិនខាន ។"

ពីខ្ញុំបាទដោយសេចក្តីគោរព និង អរគុណ
ហេង មណីចិន្តា, បាត់ដំបង

មតិអ្នកបានអានចប់

"សៀវភៅរបស់លោកដែលមិនអាចកាត់ថ្លៃបាន និង គ្មានអ្វីប្រដូចបាន ធ្វើឲ្យខ្ញុំចាប់អារម្មណ៍យ៉ាងខ្លាំង ដោយសារសៀវភៅនេះងាយអាន ប្រាកដនិយម ត្រង់ៗ គ្មានការលាក់លៀម សម្បូរដោយព័ត៌មានច្រើន និង ធ្វើឲ្យមានការជេក់ចិត្តអានជាដើម ។ សៀវភៅនេះបានសរសេរដោយផ្អែកលើចំណុចល្អៗ ប្រកបដោយបទពណ៌នាគួរឲ្យជឿទុកចិត្តរាប់មិនអស់ និង លំអដោយពាក្យពេចន៍កំប្លុកកំប្លែង ។ សៀវភៅនេះ ដែលមានលក្ខណៈលើសពីសៀវភៅស្វ័យជីវប្រវត្តិ គឺជាសៀវភៅរឿង និង ជាសៀវភៅប្រវត្តិសាស្ត្រ ។"

អ៊ូ រ៉ាហាវ៉ុជ, ប្រទេសអូស្ត្រាលី